សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

# កម្រងច្បាប់
# និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងដីធ្លី

**(Compilation of Laws and Legal Regulations Relating to Land)**

ចងក្រងឡើងវិញដោយ ហាប់ ផល្លី

កម្រងឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងដីធ្លីនេះ
ត្រូវបានដកស្រង់ចេញពីរាជកិច្ច និងពីក្រសួង ស្ថាប័នពាក់ព័ន្ធ។
កញ្ញាឃឹម ម៉ារំណែត លោកសូ ហឿន លោកឈាន បូណា និង
លោកភូ ភក្តីបានជួយផ្តល់ឯកសារពាក់ព័ន្ធមួយចំនួន។

ចងក្រង និងវាយឡើងវិញដោយបណ្ឌិត ហាប់ ផល្លី

**©2010 ហាប់ ផល្លី**

រក្សាសិទ្ធិគ្រប់បែបយ៉ាង។ គ្មានផ្នែកណាមួយនៃឯកសារនេះត្រូវបានផលិតឡើងវិញចេញពីសៀវភៅនេះផ្ទាល់ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ពីម្ចាស់កម្មសិទ្ធិ ទោះតាមរូបភាពណា ឬមធ្យោបាយណាក៏ដោយ។

មានតម្កល់ទុកនៅបណ្ណាល័យរបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
រាជធានីភ្នំពេញ

បោះពុម្ពនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

សូមគោរពជូនស្នាដៃនេះ ចំពោះ

លោកឪពុក ហាប់ ច្រាន និងអ្នកម្តាយ លាង គីមហៀង

អ្នកម្តាយចិញ្ចឹម លាង គីមអ៊ី

លោកឪពុកក្មេក យក់ ខួន និងអ្នកម្តាយក្មេក កែ ស្រ៊ិន

សូមថ្លែងអំណរគុណ

ចំពោះសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ  និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

ក្នុងការជួយជ្រោមជ្រែងឱ្យឯកសារនេះ  កើតជារូបរាងឡើងៗ

# អារម្ភកថា

ដោយយល់ឃើញថា ការចងក្រងឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងដីធ្លី មានសារៈសំខាន់ដល់ការសិក្សាស្រាវជ្រាវផ្នែកនេះ និងជួយសម្រួលដល់ការស្វែងយល់របស់អ្នកច្បាប់ ខ្ញុំបាទបានរៀបចំប្រមូលចងក្រងឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលខ្ញុំបាទមាន តាំងពីឆ្នាំ១៩៨៥ រហូតដល់បច្ចុប្បន្ននេះ ។

រាល់អក្ខរាវិរុទ្ធនៅក្នុងឯកសារចងក្រងនេះ ត្រូវបានសរសេរដោយផ្អែកជាចម្បងទៅតាមវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត ដែលបានបោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ នៅឆ្នាំ១៩៦៧។ រាល់ការកែប្រែដែលមានបំណងឱ្យមានភាពដូចគ្នានៅក្នុងឯកសារនេះ មិនមានផលប៉ះពាល់ដល់អត្ថន័យដើមទេ។ ខ្ញុំបាទបានដាក់បន្ថែមលេខសម្គាល់ជាលេខឡាតាំងដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវពិតប្រាកដ ទៅលើផ្នែកខ្លះនៃឯកសារនេះដែលឯកសារផ្លូវការដើមរបស់វាត្រូវបានសរសេរឡើងដោយមានការខ្វះចន្លោះ។ លេខសម្គាល់នេះនឹងត្រូវបានសរសេរនៅផ្នែកខាងក្រោមនៃទំព័រនោះស្រាប់។ ចំណែកលេខសម្គាល់របស់ឯកសារផ្លូវការដើមត្រូវបានសរសេរជាលេខខ្មែរ ដោយបញ្ជាក់នៅផ្នែកខាងក្រោមនៃទំព័រដដែលនោះ។

កំហុសអចេតនាអាចនឹងកើតមាន ទាំងកំហុសផ្នែកអក្ខរាវិរុទ្ធ និងកំហុសផ្នែកបច្ចេកទេស។ ហេតុដូច្នេះហើយ សូមមិត្តអ្នកអានទាំងអស់មេត្តាអធ្យាស្រ័យផង។ ជាមួយគ្នានេះដែរ ខ្ញុំបាទសូមស្វាគមន៍រាល់សំណូមពរ និងមតិយោបល់របស់មិត្តអ្នកអានទាំងអស់ ដើម្បីឱ្យឯកសារនេះកាន់តែមានលក្ខណៈល្អប្រសើរ និងងាយស្រួលប្រើប្រាស់។

សូមអរគុណទុកជាមុននូវកិច្ចសហប្រតិបត្តិការរបស់លោកអ្នក។

ហាប់ ផល្លី

# មាតិកា


## 1985

1 អនុក្រឹត្យស្តីពីការគ្រប់គ្រងប្រើប្រាស់ដីធ្លីកសិកម្ម, លេខ០៦អនក្រ, ០៦ ឧសភា ១៩៨៥ (Sub-decree on the Management of the Use of Agricultural Land, No.06ANK, May 06, 1985) **1**

## 1987

2 សេចក្តីណែនាំស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ, សេចក្តីណែនាំ២២៤៦ឧសក/មក/បស, ២៤ សីហា ១៩៨៧ (Instruction on the Management of State Property, No.2246OSK/MK/BS, August 24, 1987) **8**

## 1989

3 សេចក្តីសម្រេចចិត្តស្តីពីគោលនយោបាយចំពោះកសិកររបស់បក្សប្រជាជនបដិវត្តកម្ពុជានៅមហាសន្និបាតកម្មាភិបាលទូទាំងប្រទេសលើកទី II ខែមេសា ឆ្នាំ១៩៨៩ (Decision on Policy for Farmers of Cambodian Revolutionary People's Party at the Second General Assembly for Nationwide Comrade in April 1989) **13**

4 សេចក្តីសម្រេចចិត្តស្តីពីគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លីរបស់បក្សប្រជាជនបដិវត្តកម្ពុជានៅមហាសន្និបាតកម្មាភិបាលទូទាំងប្រទេសលើកទី II ខែមេសា ឆ្នាំ១៩៨៩ (Decision on Policy for Land Management and Use of Cambodian Revolutionary People's Party at the Second General Assembly for Nationwide Comrade in April 1989) **18**

5 សេចក្តីប្រកាសស្តីពីគោលនយោបាយប្រកបរបរផលិតកម្ម អាជីវកម្ម កសិកម្មតាមរបៀបវេរប្រវាស់ដៃរបស់បក្សប្រជាជនបដិវត្តកម្ពុជានៅមហាសន្និបាតកម្មាភិបាលទូទាំងប្រទេសលើកទី II ខែមេសា ឆ្នាំ១៩៨៩ (Proclamation on Policy for Production, Exploitation, Agriculture via Share Turn of Cambodian Revolutionary People's Party at the Second General Assembly for Nationwide Comrade in April 1989) **22**

6 អនុក្រឹត្យស្តីពីការផ្តល់កម្មសិទ្ធិលើផ្ទះជូនដល់ពលរដ្ឋកម្ពុជា, លេខ២៥អនក្រ, ២២ មេសា ១៩៨៩ (Sub-decree on Granting House Ownership to the Cambodian Citizens, No.25ANK, April 22, 1989) **24**

7 សេចក្តីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី, សេចក្តីណែនាំអនុវត្ត០៣សណន, ០៣ មិថុនា ១៩៨៩ (Instruction on the Implementation of Land Use and Management Policy, No.03SNN, June 03, 1989) **28**

8 សារាចរស្ដីពីការអនុវត្តអនុក្រឹត្យស្ដីពីការផ្ដល់កម្មសិទ្ធិលើផ្ទះជូនពលរដ្ឋកម្ពុជានៅរដ្ឋធានីភ្នំពេញ, សារាចរ០៥សរច, ០៥ មិថុនា ១៩៨៩ (Circular on the Implementation of Sub-decree on Granting House Ownership to Cambodian Citizens Living in Phnom Penh, Circular No.05SRC, June 05, 1989) **33**

9 ប្រកាសស្ដីពីការប្រើប្រាស់ឯកសារពាក់ព័ន្ធនឹងដីធ្លី, ប្រកាស២៧៤៦ប្រក/កសក, ០២ សីហា ១៩៨៩ (Proclamation on the Use of Land-Related Documents, No.2746PK/KSK, August 02, 1989) **38**

10 ប្រកាសរួមស្ដីពីការកំណត់ប្រាក់ចំណូលពីការចេញឯកសារពាក់ព័ន្ធនឹងដីធ្លី, លេខ០០៦០ប្រក/កសក-០០១កហវ, ០៧ សីហា ១៩៨៩ (Joint Proclamation on the Determination of Revenue from Documents Relating to Land, No.0060PK/KSK-001KHV, August 02, 1989) **40**

11 លិខិតរបស់ក្រសួងកសិកម្មស្ដីពីការប្រើប្រាស់ឯកសារពាក់ព័ន្ធនឹងដីធ្លី, លេខ៣៨៥៦កសក/ម/របៈ ៣០ តុលា ១៩៨៩ (Letter of Ministry of Agriculture on the Use of Documents Relating to Land, No.3856KSK/M/RB, October 30, 1989) **43**

12 ប្រកាសស្ដីពីការតែងតាំង និងសកម្មភាពនាយកដ្ឋានសុរិយោដី, ប្រកាស១១១ប្រក/កសក, ៣១ តុលា ១៩៨៩ (Proclamation on the Appointment and Activity of the Department of Cadastre, No.111PK/KSK, October 31, 1989) **45**

**1990**

13 លិខិតរបស់ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រីស្ដីពីករណីសំណើសុំអនុញ្ញាតពន្យារពេលទទួលពាក្យស្នើសុំកាន់កាប់ដីធ្លី, លេខ៩៤សជណ/កស, ១៧ មករា ១៩៩០ (Letter of the Office of the Council of Ministers on the Request to Delay the Acceptance of Land Applications, No.94SCN/KS, January 17, 1990) **49**

14 សារាចរស្ដីពីការគ្រប់គ្រងគេហដ្ឋាន ដីធ្លីដែលជួលឱ្យអង្គការអន្តរជាតិ ក្រុមហ៊ុន ឬជនបរទេស, សារាចរ០១សរ, ១៨ មករា ១៩៩០ (Circular on the Management of Residences and Land Leased to International Organizations, or Foreign Companies or Foreigners, No.01SR, January 18, 1990) **50**

15 លិខិតរបស់ក្រសួងកសិកម្មស្ដីពីការពន្យារពេលទទួលពាក្យស្នើសុំកាន់កាប់ដីធ្លី, លេខ៤៨៥កសក/ម/រប, ២៩ មករា ១៩៩០ (Letter of Ministry of Agriculture on the Delay of Acceptance of Land Applications, No.485KSK/ M/RB, January 29, 1990) **52**

16 សារាចរណែនាំស្ដីពីគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី, សារាចរណែនាំ១៣១កសក/សរណន, ១០ មេសា ១៩៩០ (Instructive Circular on the Policy of Land Administration and Use, No.131KSK/SRNN, April 10, 1990) **53**

17 សេចក្ដីជូនដំណឹងស្ដីពីការទទួលពាក្យស្នើសុំកាន់កាប់ដីធ្លី និងវិធានការអនុវត្តបន្ត, លេខ៣៤៥១កសក/សជណ, ២១ កក្កដា ១៩៩០ (Notification on the Acceptance of Land Applications and Subsequent Measures, No.3451KSK/SCN, July 21, 1990) **56**

18 ប្រកាសរួមស្ដីពីការកំណត់ប្រាក់ចំណូលពីការចេញឯកសារពាក់ព័ន្ធនឹងដីធ្លី, លេខ៣៥៤ប្រក/កសក-០១២កហវ, ១៨ តុលា ១៩៩០ (Joint Proclamation on the Determination of Revenue from Documents Relating to Land, No.354PK/KSK-012KHV, October 18, 1990) **59**

19 សេចក្ដីណែនាំរួមបន្ថែមលើការអនុវត្តប្រកាសរួមលេខ០០៦០ប្រក/កសក-០០១កហវ និងលេខ៣៥៤ប្រក/កសក-០១២កហវ, លេខ៣៥៥កសក/សណន-០០៧កហវ, ១៨ តុលា ១៩៩០ (Joint Instruction in Addition to the Implementation of Joint Circular No. 0060PK/KSK-001KHV and No.354PK/KSK-012KHV, No.355KSN/SNN-007KHV, October 18, 1990) **61**

20 សេចក្ដីណែនាំស្ដីពីការកែសម្រួលសេចក្ដីណែនាំលេខ០៣សណន ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី, លេខ០៣សណន, ០៨ ធ្នូ ១៩៩០ (Instruction on the Amendment of Instruction No.03SNN dated June 03, 1989 of the Council of Ministers, No.03SNN, December 08, 1990) **63**


**1991**


21 សារាចរស្ដីពីការផ្ដល់កម្មសិទ្ធិ និងលក់ផ្ទះសំបែងជូនពលរដ្ឋក្នុងរដ្ឋធានីភ្នំពេញ, សារាចរ០២សរ, ០៧ កុម្ភៈ ១៩៩១ (Circular on Ownership Grants and Sale of House to People Living in Phnom Penh, No.02SR, February 07, 1991) **65**

22 ច្បាប់ស្ដីពីការបង្កើតពន្ធប្រថាប់ត្រា, លេខ២១ក្រ, ១៥ កុម្ភៈ ១៩៩១ (Law on the Establishment of the Stamp Duties, No.21K, February 15, 1991) **67**

23 លិខិតរបស់ខុទ្ទកាល័យមជ្ឈិមបក្សស្ដីពីករណីលុបវិភាគទានស្នេហាជាតិដោយឱ្យបង្កើតពន្ធដីជំនួសវិញ, លេខ០៥៧ដ/ខបប, ២៣ កុម្ភៈ ១៩៩១ (Letter of Office of Party Center on Abolishing National Contribution by Creating Land Taxation Instead, No.057D /KhBB, February 23, 1991) **69**

24 សេចក្ដីណែនាំស្ដីពីការចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងការកសាងឯកសារពាក់ព័ន្ធ, លេខ១១៦សដ/សណន, ១១ មេសា ១៩៩១ (Instruction on the Issuance of Titles of Land Possession and Establishment of Related Documents, No.116SD /SNN, April 11, 1991) **70**

25 អនុក្រឹត្យស្ដីពីការប្រមូលពន្ធប្រថាប់ត្រា, លេខ២០អនក្រ, ២១ កញ្ញា ១៩៩១ (Sub-decree on the Collection of the Stamp duties, No.20ANK, September 21, 1991) **74**

26 សេចក្តីជូនដំណឹងរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីស្តីពីការបើកយុទ្ធនាការផ្តល់សិទ្ធិលើដីលំនៅឋាន និងអគារគ្រប់ប្រភេទ, លេខ១៥៤សជណ, ២៦ តុលា ១៩៩១ (Notification from the Council of Ministers on the Mission to Provide Residential Land and All Types of Buildings, No.154SCN, October 26, 1991) **81**

**1992**

27 ប្រកាសស្តីពីការណែនាំអនុវត្តអនុក្រឹត្យស្តីពីការប្រមូលពន្ធប្រថាប់ត្រា, លេខ០០៧ប្រក/កហវ, ០២ មករា ១៩៩២ (Proclamation on the Implementation Instruction of Sub-decree on the Collection of the Stamp Duties, No.007PK/KHV, January 02, 1992) **83**

28 លិខិតរបស់ក្រសួងកសិកម្មស្តីពីសំណើសុំកាត់បន្ថយបែបបទខ្លះនៃការចុះបញ្ជីកាដំហាន I សុរិយោដី, លេខ៥០៤កសក, ០៨ កុម្ភៈ ១៩៩២ (Letter of Ministry of Agriculture on the Request to Reduce Some Forms of Registration Step 1 Cadastre, No.504KSK, February 08, 1992) **86**

29 លិខិតរបស់នាយកដ្ឋានសុរិយោដីស្តីពីសេចក្តីណែនាំរបៀបរបបចុះលេខាចារឹក, លេខ០៨៣សដ, ១៧ មីនា ១៩៩២ (Letter of the Department of Cadastre on the Registration Method, No.083SD, March 17, 1992) **87**

30 សេចក្តីណែនាំស្តីពីការកំណត់ប្រភេទទ្រព្យក្នុងការកសាងឯកសារផ្សេងៗពាក់ព័ន្ធនឹងអចលនវត្ថុ, លេខ០៨៤សដ/សណន, ១៧ មីនា ១៩៩២ (Instruction on the Determination of Property Types for Establishing Documents Relating to Immovable Property, No.084SD/SNN, March 17, 1992) **88**

31 សារទូរលេខរបស់ក្រសួងកសិកម្មស្តីពីការជំរុញការងារអង្កេតវាស់វែង និងផ្តល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លី, លេខ១១៣១កសក/ម/សរ, ២៦ មីនា ១៩៩២ (Telegram of Ministry of Agriculture on the Push of Survey and the Grant of Land Possession Titles, No.1131KSK/M/SR, March 26 1992) **91**

32 ប្រកាសស្តីពីការអនុញ្ញាតឱ្យជំនាញសុរិយោដីប្រើប្រាស់លិខិតសញ្ញាពាក់ព័ន្ធនឹងការផ្ទេរអចលនវត្ថុ, ប្រកាស២៩៦ប្រក/កសក/មរស, ០៩ មិថុនា ១៩៩២ (Proclamation on the Authorization to Use Conventional Act Relating to the Transfer of Property, No.296PK/KSK/MRS, June 09, 1992) **92**

33 សេចក្តីណែនាំស្តីពីចលនានៃលិខិតសញ្ញាក្នុងការផ្ទេរអចលនវត្ថុ, លេខ១៧០សដ/សណន, ០៧ កក្កដា ១៩៩២ (Instruction on Movement of Conventional Act in Regard to Immovable Transfer, No170SD/SNN, July 07, 1992) **93**

34 ច្បាប់ភូមិបាល, លេខ១០០ក្រ, ១៣ តុលា ១៩៩២ (Land Law, No.100K, October 13, 1992) **98**

35 សារាចរណែនាំស្តីពីវិធានការចំពោះសកម្មភាពរំលោភយកដីសាធារណៈ, លេខ០៣សរណន, ១៤ ធ្នូ ១៩៩២ (Instructive Circular on the Measure toward the Public Land Grabbing Activities, No.03SRNN, December 14, 1992) **156**

**1993**

36 សេចក្តីសម្រេចស្តីពីការកំណត់សមត្ថកិច្ចលើបច្ចេកទេសវាស់វែង, លេខ០០៤សសរ/កសក, ០៦ មករា ១៩៩៣ (Decision on the Determination of the Competence of Survey Technique, No.004SSR/KSK, January 06, 1993) **159**

37 ច្បាប់ស្តីពីការបែងចែកទ្រព្យសម្បត្តិ, លេខ០៩ក្រ, ០៨ កុម្ភៈ ១៩៩៣ (Law on the Division of Property, No.09 K, February 08, 1993) **161**

38 សារាចរស្តីពីកម្មសិទ្ធិស្របច្បាប់របស់ប្រជាពលរដ្ឋបច្ចុប្បន្ន និងកម្មសិទ្ធិសាធារណៈ, សារាចរ ០១សរ, ០៣ កក្កដា ១៩៩៣ (Circular on the Current Legal Public and Private Ownership, No.01SR, July 03, 1993) **162**

39 លិខិតរបស់នាយកដ្ឋានសុរិយោដីអំពីសភាពការណ៍ស្តីពីបញ្ហាដីធ្លី, លេខ១៦៦សដ, ១៦ សីហា ១៩៩៣ (Letter of the Department of Cadastre about the Situation on Land Issues, No.166SD, August 16, 1993) **163**

40 ព្រះរាជក្រឹត្យស្តីពីការបង្កើតតំបន់ការពារធម្មជាតិ, ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ (Royal Decree on the Creation of Natural Protected Areas, dated November 01, 1993) **164**

**1994**

41 លិខិតរបស់ក្រសួងយុត្តិធម៌ស្តីពីការដោះស្រាយវិវាទរដ្ឋបាល, លេខ២៤៧សច/តុលាការ/៩៤, ០១ កុម្ភៈ ១៩៩៤ (Letter of Ministry of Justice on Administrative Dispute Resolutions, No.247SC/Court/94, February 01, 1994) **167**

42 លិខិតរបស់នាយកដ្ឋានសុរិយោដីអំពីការណែនាំស្តីពីការបញ្ជាក់បន្ទុកពាក់ព័ន្ធនឹងការបញ្ចាំអចលនវត្ថុ និងការធ្វើលេខាចារឹក, លេខ១៦២សដ/សណន, ០២ សីហា ១៩៩៤ (Letter of the Department of Cadastre about Instruction on Certification of Encumbrance Relating to Antichresis and Registration, No.162SK/SNN, August 02, 1994) **169**

43 ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់, លេខ០៤នស៩៤, ១០ សីហា ១៩៩៤ (Law on Land Management, Urban Planning and Construction, No.04NS94, August 10, 1994) **171**

44 លិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីករណីសុំពិនិត្យ និងកែសម្រួលឯកសារពាក់ព័ន្ធនឹងដីធ្លី, លេខ១៦២៣សជណ/កស, ០៧ កញ្ញា ១៩៩៤ (Letter of the Council of Ministers on the Request of the Examination and Revision of the Documents Relating to Land, No.1623SCN/KS, September 07, 1994) **178**

45 បែបបទនៃការបំពេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ "ប័ណ្ណថ្មី" ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩៤ (The Form for Filling Titles of Immovable Property "New Titles" dated September 07, 1994) **180**

46 អនុក្រឹត្យស្តីពីការផ្តល់សិទ្ធិចុះហត្ថលេខាលើប្លង់ដីកម្មសិទ្ធិ ការផ្ទេរកម្មសិទ្ធិ និងអាជ្ញាប័ណ្ណសាងសង់អគារក្នុងរាជធានីភ្នំពេញ, លេខ៥៧អនក្រ, ២៩ កញ្ញា ១៩៩៤ (Sub-decree on the Delegation of the Authority to Sign on Land Ownership, Transfer of Land Ownership, and Building Construction in Phnom Penh, No.57ANK, September 29, 1994) **186**

47 អនុក្រឹត្យស្តីពីការផ្ទេរនាយកដ្ឋានសុរិយោដីនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឋិតនៅក្រោមការគ្រប់គ្រងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី, លេខ៥៨អនក្រ, ០៣ តុលា ១៩៩៤ (Sub-decree on the Transfer of the Department of Cadastre of the Ministry of Agriculture, Forestry and Fisheries to be under the Supervision of the Office of the Council of Ministers, No.58ANK, October 03, 1994) **188**

**1995**

48 សារាចរស្តីពីការធ្វើកម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ (ដីធ្លី និងអគារ), លេខ០០៣សរ/សហវ/ទរ, ១៤ មករា ១៩៩៥ (Circular on the Identification of Ownership over State Property (Land and Buildings), No.003SR/SHV/TR, January 14, 1995) **190**

49 លិខិតរបស់នាយកដ្ឋានសុរិយោដីអំពីសេចក្តីណែនាំស្តីពីការអនុវត្តតាមស្មារតីអង្គប្រជុំបូកសរុបការងារសុរិយោដីទូទាំងប្រទេស, លេខ០០៤សដ, ១២ មករា ១៩៩៥ (Letter of the Department of Cadastre about the Instruction on the Implementation of the Spirit of the Meeting Concluding Nationwide Cadastral Work, No.004, January 21, 1995) **192**

50 លិខិតរបស់នាយកដ្ឋានសុរិយោដីអំពីការផ្តល់របាយការណ៍ស្តីពីការជម្រះបញ្ជីឯកសារចាស់, លេខ០៣២សដ, ២១ កុម្ភៈ ១៩៩៥ (Letter of the Department of Cadastre about the Submission of the Report on the Satisfaction of Old Documents, No.032SD, February 21, 1995) **194**

51 សេចក្តីជូនដំណឹងស្តីពីបទប្បញ្ញត្តិទាំងឡាយស្តីពីពន្ធ និងអាករដែលប្រមូលដោយអង្គការពន្ធ, លេខ០០៥សជណ/សហវ/ពដ, ២៥ កុម្ភៈ ១៩៩៥ (Notification on the Provisions on Taxes and Imposts Collected by Taxation Units, No.005SCN/SHV/BD, February 25, 1995) **196**

52 សារាចរអន្តរក្រសួងស្តីពីសមត្ថកិច្ច និងទំនាក់ទំនងការងាររវាងអភិបាលខេត្ត-ក្រុង ជាមួយប្រធានតុលាការ និងព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង, លេខ២០៤សរ/៩៥, ០២ មីនា

១៩៩៥ (Joint Circular on Competency and Work Relations between Provincial/ Municipal Governors with Court Chiefs and Provincial/Municipal Prosecutors, No.204SR/95, March 02, 1995) **202**

53 លិខិតរបស់នាយកដ្ឋានសុរិយោដីអំពីការកំណត់អក្សរសម្គាល់លេខប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុតាមបណ្តាខេត្ត-ក្រុង, លេខ០៥៣សដ, ១១ មេសា ១៩៩៥ (Letter of the Department of Cadastre on the Determination of Letters Identifying the Number of a Title of Immovable Property in Provinces-Municipalities, No.053SD, April 11, 1995) **205**

54 លិខិតរបស់នាយកដ្ឋានសុរិយោដីអំពីករណីយឺតយ៉ាវក្នុងការផ្តល់របាយការណ៍ស្តីពីការជម្រះបញ្ជីឯកសារចាស់, លេខ០៥៧សដ, ២៤ មេសា ១៩៩៥ (Letter of the Department of Cadastre about the Slowness in Submitting the Report on the Satisfaction of Old Documents, No.057SD, April 24, 1995) **207**

55 លិខិតរបស់សម្តេចនាយករដ្ឋមន្ត្រីទី១ផ្ញើជូនសម្តេចនាយករដ្ឋមន្ត្រីទី២ស្នើឱ្យការសុំកាន់កាប់ដីធ្លីឆ្លងកាត់ទីស្តីការគណៈរដ្ឋមន្ត្រី, លេខ៩១៨ខុទ្ទ/៩៤, ១៦ មិថុនា ១៩៩៥ (Letter of the First Prime Minister to the Second Prime Minister Requested that the Applications of Land Possession should be Passed to the Office of Council of Ministers, No.918KhT/94, June 16, 1995) **208**

56 លិខិតរបស់សម្តេចនាយករដ្ឋមន្ត្រីទី២ ផ្ញើតបសម្តេចនាយករដ្ឋមន្ត្រីទី១អំពីការយល់ព្រមលិខិតលេខ៩១៨ខុទ្ទ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៥, លេខ៩៧ខ/២-៩៥, ២២ មិថុនា ១៩៩៥ (Letter of the Second Prime Minister to the First Prime Minister on Agreeing with Letter No.918KhT dated June 16, 1995, No.97Kh/2-95, June 22, 1995) **209**

57 អនុក្រឹត្យស្តីពីការប្រកាសទ្រព្យសម្បត្តិរដ្ឋ, លេខ៥៣អនក្រ/បក/២៧ មិថុនា ១៩៩៥ (Sub-decree on the Declaration of State Property, No.53ANK/BK/June 27, 1995) **210**

58 លិខិតរបស់គណៈរដ្ឋមន្ត្រីស្តីពីករណីបញ្ហាទំនាស់កម្មសិទ្ធិដីធ្លីរវាងអាជ្ញាធរ និងប្រជារាស្ត្រ, លេខ១០៥២សជណ/សរ, ០៥ កក្កដា ១៩៩៥ (Letter of the Council of Ministers on the Land Conflict Issues between Authorities and People, No.1052SCN/SR, July 05, 1995) **212**

59 អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មការវាយតម្លៃដីធ្លីមិនបានប្រើប្រាស់, លេខ៥៨អនក្រ, ២៥ កក្កដា ១៩៩៥ (Sub-decree on the Establishment of Unused Land Evaluation Committee, No.58ANK, July 25, 1995) **213**

60 លិខិតរបស់ក្រសួងយុត្តិធម៌អំពីការអនុវត្តអនុក្រឹត្យលេខ២៥អនក្រ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៨៩ ស្តីពីការផ្តល់កម្មសិទ្ធិលើផ្ទះជូនពលរដ្ឋកម្ពុជា, លេខ៧៣៣សរច/វវ/៩៥, ២៥ កក្កដា

១៩៩៥ (Letter of Ministry of Justice about the Implementation of Sub-decree No.25ANK dated April 22, 1989 on Granting House Ownership to the Cambodian Citizens, No.733SRC/RV/95, July 25, 1995) **215**

61 លិខិតរបស់ក្រសួងបរិស្ថានស្តីពីបញ្ហាកម្មសិទ្ធិដីធ្លីក្នុងតំបន់ការពារធម្មជាតិ, លេខ១៧១៩បស្ថ, ១៤ កញ្ញា ១៩៩៥ (Letter of Ministry of Environment on Land Ownership Issues in Natural Protected Areas, No.1719BSt, September 14, 1995) **217**

62 លិខិតរបស់ប្រធាននាយកដ្ឋានសុរិយោដីស្តីពីការកាន់កាប់សៀវភៅចុះបញ្ជីអចលនវត្ថុ, លេខ ១៧៨សដ, ២២ វិច្ឆិកា ១៩៩៥ (Letter of the Department of Cadastre on the Management of Immovable Register, No.178SD, November 22, 1995) **218**

## 1996

63 សារាចរស្តីពីការរៀបចំធ្វើគម្រោងប្លង់គោលនៅតាមខេត្ត-ក្រុង ទូទាំងព្រះរាជាណាចក្រកម្ពុជា, សារាចរលេខ០២សរ, ១៥ មករា ១៩៩៦ (Circular on the Preparation of Master Plan in the Provinces and Municipalities Throughout the Kingdom of Cambodia, Circular No.02SR, January 15, 1996) **220**

64 លិខិតរបស់ប្រធាននាយកដ្ឋានសុរិយោដីផ្ញើជូនគ្រប់ការិយាល័យសុរិយោដីខេត្ត-ក្រុងស្តីពីការគ្រប់គ្រងឯកសារសុរិយោដី, លេខ០៥០សដ, ២១ មីនា ១៩៩៦ (Letter of Chief of the Department of Cadastre to all Provincial-municipal Cadastral Offices on the Management of Cadastral Documents, No.050SD, March 21, 1996) **223**

65 ប្រកាសស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់, លេខ២២៤ប្រក/សហវ/ពដ, ០៥ កក្កដា ១៩៩៦ (Proclamation on the Collection of Tax on Unused Land, No.224/PK/SHV/BD, July 05, 1996) **225**

66 លិខិតរបស់នាយកដ្ឋានសុរិយោដីស្តីពីការទទួលខុសត្រូវលើលិខិតសញ្ញាផ្ទេរសិទ្ធិរបស់ប្រធានការិយាល័យសុរិយោដីខេត្តក្រុង និងប្រធានការិយាល័យភូមិបាលស្រុក-ខណ្ឌ, លេខ១២៧សដ, ៣១ កក្កដា ១៩៩៦ (Letter of the Department of Cadastre on the Accountability of the Chief of Provincial-Municipal Cadastral Office and the Chief of District Land Bureau toward Conventional Act in Regard to Ownership Transfer, No.127SD, July 31, 1996) **229**

67 លិខិតរបស់ក្រសួងសាធារណការ និងដឹកជញ្ជូនស្តីពីការសុំកំណត់ដីបម្រុងផ្លូវគ្រប់ប្រភេទទូទាំងព្រះរាជាណាចក្រកម្ពុជា, លេខ២០២១សក/៤, ០៧ សីហា ១៩៩៦ (Letter of Ministry of Public Affairs and Transportation on the Request to Determine the Reserved Land

for all Types of Roads Throughout the Kingdom of Cambodia, No.2021SK/4, August 07, 1996) **231**

68 លិខិតរបស់ក្រសួងបរិស្ថានស្តីពីករណីកំណត់ដីបម្រុងឧទ្យានជាតិ ដីបម្រុងផ្លូវគ្រប់ប្រភេទដីបម្រុងរុក្ខា-នេសាទទូទាំងព្រះរាជាណាចក្រកម្ពុជា, លេខ១៤៩៤បស្ត, ១២ កញ្ញា ១៩៩៦ (Letter of Ministry of Environment on the Determination of Reserved Land for National Parks, Reserved Land for All Types of Roads, Reserved Land for Forestry-Fishery Throughout the Kingdom of Cambodia, No.1494BSt, September 12, 1996) **232**

69 ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ, នស/រកម/១២៩៦/៣៦, ២៤ ធ្នូ ១៩៩៦ (Law on the Environmental Protection and Natural Resource Management, NS/RKM/1296/36, December 24, 1996) **236**

## 1997

70 លិខិតរបស់នាយកដ្ឋានសុរិយោដីស្តីពីការទទួលខុសត្រូវក្នុងការពិនិត្យឯកសារសុរិយោដី, លេខ១៤៦សជ, ១៣ ឧសភា ១៩៩៧ (Letter of the Department of Cadastre on the Accountability toward the Examination of Cadastral Documents, No.146SD, May 13, 1997) **245**

71 លិខិតរបស់នាយកដ្ឋានសុរិយោដីស្តីពីករណីបដិសេធប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ, លេខ១៥៧សជ, ១២ មិថុនា ១៩៩៧ (Letter of the Department of Cadastre on the Refusal of Titles of Land Possession or Titles of Immovable Property, No.157SD, June 12,1997) **247**

72 លិខិតរបស់នាយកដ្ឋានសុរិយោដីស្តីពីការបាត់បង់ និងខូចខាតឯកសារជំនាញ និងសម្ភារៈប្រើប្រាស់ផ្សេងៗ, លេខ១៩២សជ, ១៩ សីហា ១៩៩៧ (Letter of the Department of Cadastre on the Loss and Damage of Technical Documents and Other Materials, No.192SD, August 19, 1997) **250**

73 អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់, លេខ៨៧អនក្រ/បក, ១៨ ធ្នូ ១៩៩៧ (Sub-decree on the Organization and Functioning of the National Commission for Land Management, Urban Planning, and Construction, No.87ANK/BK, December 18, 1997) **251**

74 អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់, លេខ៨៦អនក្រ/បក, ១៩ ធ្នូ ១៩៩៧ (Sub-decree on Construction Permit, No.86ANK/BK, December 19, 1997) **258**

75 បទបញ្ជាស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ, បទបញ្ជា៣០បប, ២៥ ធ្នូ ១៩៩៧ (Order on the Management of Sate Property, No.30BB, December 25, 1997) **284**

76 សេចក្តីណែនាំបន្ថែមអំពីកិច្ចការជំនាញ, លេខ២៥៩សជ, ៣០ ធ្នូ ១៩៩៧ (Additional Instruction on Technical Affairs, No.259SD, December 30, 1997) **291**

**1998**

77 សេចក្តីសម្រេចស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់, លេខ០០៤សសរ/សហវ/ពដ, ២៤ សីហា ១៩៩៨ (Decision on the Collection of Unused Land Taxes, No.004SSR /SHV/BD, August 24, 1998) **302**

**1999**

78 ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/០៧, ១១ មករា ១៩៩៩ (Royal Decree NS/RKT/0199, 07/January 11, 1999)- ការកំណត់ និងគ្រប់គ្រងព្រៃតំបន់ដីជម្រាល (Determination and Management of Forest in Land Slope Areas) **304**

79 សេចក្តីប្រកាសស្តីពីវិធានការគ្រប់គ្រង និងលុបបំបាត់ភាពអានាធិបតេយ្យក្នុងវិស័យព្រៃឈើ, លេខ ០១ប្រក, ២៥ មករា ១៩៩៩ (Proclamation on the Management and Elimination of Anarchy in Forest Sector, No.01PK, January 25, 1999) **306**

80 សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការដោះស្រាយបាតុភាពដីធ្លី នៅតាមបណ្តាខេត្ត-ក្រុងទូទាំងប្រទេស, លេខ៤៧សសរ, ១០ មិថុនា ១៩៩៩ (Decision on the Establishment of Land Dispute Resolution Commissions in Provinces/Municipalities Throughout the Country, No.47SSR, June 10, 1999) **311**

81 ច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, នស/រកម/០៦៩៩/០៩, ២៣ មិថុនា ១៩៩៩ (Law on the Establishment of the Ministry of Land Management, Urban Planning and Construction, NS/RKM /0699/09, June 23, 1999) **314**

82 អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ៦២អនក្រ/បក, ២០ កក្កដា ១៩៩៩ (Sub-decree on the Organization and Functioning of the Ministry of Land Management, Urban Planning and Construction, No.62ANK/BK, July 20, 1999) **316**

83 ប្រកាសស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង និងតួនាទី ភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ, លេខ៧៦ប្រក, ០២ កញ្ញា ១៩៩៩ (Proclamation on the Function, Duty and Structure of Provincial /Municipal Office of Land Management, Urban Planning, Construction and Cadastre; and Function, Duty of Subordinate Offices, No.76PK, September 02, 1999) **340**

84 សេចក្តីប្រកាសស្តីពីវិធានការលុបបំបាត់ភាពអានាធិបតេយ្យក្នុងបញ្ហាទន្ទ្រានកាន់កាប់ដីធ្លី, លេខ ០៦ប្រក, ២៧ កញ្ញា ១៩៩៩(Proclamation on the Measure of Elimination of Anarchy in Land Grabbing Issues, No.06PK, September 27, 1999) **350**

85 សារាចរណែនាំស្តីពីការអនុវត្តពន្ធលើដីធ្លីមិនបានប្រើប្រាស់, សារាចរ០១៧សរន/សហវ/ពដ, ០១ ធ្នូ ១៩៩៩ (Instructive Circular on the Tax Implementation on Unused Land, No.017SRN/SHV/BD, December 01, 1999) **354**


**2000**

86 អនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃសម្បទាន, លេខ០៥អនក្រ/បក, ០៧ កុម្ភៈ ២០០០ (Sub-decree on Forest Concessions Management, No.05ANK/BK, February 07, 2000) **362**

87 សេចក្តីសម្រេចស្តីពីការបង្កើតក្រុមជំនួយការផ្ទាល់ប្រធានគណៈកម្មការដោះស្រាយបាតុភាពបញ្ហាដីធ្លីនៅតាមបណ្តាខេត្ត-ក្រុងទូទាំងប្រទេស, លេខ២២ដនសគ,ដីធ្លី, ០៧ មីនា ២០០០ (Decision on the Establishment of Nationwide Group of Personal Assistants to the Chairman of Land Dispute Settlement Committee, No.22DNSK/Land, March 07, 2000) **379**

88 អនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, លេខ១១អនក្រ/បក, ២២ មីនា ២០០០ (Sub-decree on the Procedure of Establishing Cadastral Index Maps and Land Registers, No.11 ANK/BK, March 22, 2000) **381**

89 លិខិតរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានកម្មវត្ថុស្តីពីការអនុវត្តគោលការណ៍ដីចំណីផ្លូវជាតិ ផ្លូវខេត្ត ផ្លូវឃុំ ផ្លូវរថភ្លើងនៅទូទាំងព្រះរាជាណាចក្រកម្ពុជា, លេខ៩៦១សហវ, ០៦ មេសា ២០០០ (Letter of Senior Minister, Minister of Economy and Finance on the Subject of the Implementation of Principles of Reserved Land for National, Provincial, Communal Roads; Railways throughout the Kingdom of Cambodia, No.961SHV, April 06, 2000) **389**

90 សេចក្តីណែនាំស្តីពីការអនុវត្តលក្ខណការណ៍រដ្ឋបាលលើការងារសុរិយោដីនៃមន្ទីរដនសសខេត្ត-ក្រុង, លេខ៤២៧ដនស/រប, ០៨ មេសា ២០០០ (Instruction on the Implementation of the Administrative Principle of Cadastral Work at the Provincial Department of Land Management, Urban Planning, Construction and Cadastre, No.427DNS/RB, April 08, 2000) **391**

91 លិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីការកំណត់ថ្លៃឈ្នួលដីសម្បទាន, លេខ៨០៣សជណ, ៣១ ឧសភា ២០០០ (Letter of Council of Ministers about the Determination of Land Concession Fee, No.803SCN, May 31, 2000) **393**

92 សារាចរណែនាំអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី (ការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ), លេខ០០៣ដនស/សដ, ២០ កក្កដា ២០០០ (Instructive Circular Relating to the Implementation of the Procedure of Establishing Cadastral Index Map and Land Register (Systematic Registration), No.003DNS/SD, July 20, 2000) **395**

93 អនុក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី, លេខ៨៨អនក្រ/បក, ០១ ធ្នូ ២០០០ (Sub-decree on the Establishment of the Council of Land Policy, No.88ANK/BK, December 01, 2000) **404**

94 អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី, លេខ៩៦អនក្រ/បក, ១៣ ធ្នូ ២០០០ (Sub-decree on the Organization and Functioning of Secretariat General of the Council of Land Policy, No.96ANK/BK, December 13, 2000) **409**

**2001**

95 ច្បាប់ភូមិបាល, នស/រកម/០៨០១/១៤, ៣០ សីហា ២០០១ (Land Law, NS/RKM/0801/14, August 30, 2001) **415**

96 សេចក្តីជូនដំណឹងស្តីពីការបញ្ចប់ការចូលកាន់កាប់ភោគៈលើអចលនវត្ថុ, លេខ៤៣សជណ/កបច, ០៦ កញ្ញា ២០០១ (Notification on the Cessation of Acquisitive Possession on Immovable Property, No.43SCN/KBC, September 06, 2001) **487**

97 សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការកំណត់ដីភូមិ និងដីកសិកម្មដែលប្រជាពលរដ្ឋកំពុងធ្វើអាជីវកម្មក្នុងដែនព្រៃសម្បទាន, លេខ៤៣៨សសរ/កសក, ១៨ តុលា ២០០១ (Decision on Creating the Committee to Determine Residential and Agricultural Land within Forest Concession, No.438SSR/KSK, October 18, 2001) **488**

98 សេចក្តីប្រកាសស្តីពីការផ្អាកសកម្មភាពអាជីវកម្មព្រៃគុបសម្រាប់ក្រុមហ៊ុនព្រៃសម្បទាន, ប្រកាស ៥៧២១កសក, ១៣ ធ្នូ ២០០១ (Proclamation on the Suspension of Forest Exploitation Activities for Forest Concession Companies, No.5721KSK, December 13, 2001) **490**

**2002**

99 ប្រកាសអន្តរក្រសួងស្តីពីការកំណត់ចំណូលពីសោហ៊ុយសេវាសុរិយោដី, លេខ៣៧៧សហវ, ២៨ ឧសភា ២០០២ (Inter-ministerial Proclamation on the Determination of the Revenue from the Cadastral Service Fee, No.377SHV, May 28, 2002) **492**

100 អនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, លេខ៤៦អនក្រ/បក, ៣១ ឧសភា ២០០២ (Sub-decree on the Procedure of Establishing Cadastral Index Maps and Land Registers, No.46ANK/BK, May 31, 2002) **497**

101 អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី, លេខ៤៧អនក្រ/បក, ៣១ ឧសភា ២០០២ (Sub-decree on the Organization and Functioning of the Cadastral Commission, No.47ANK/BK, May 31, 2002) **505**

102 អនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, លេខ៤៨អនក្រ/បក, ៣១ ឧសភា ២០០២ (Sub-decree on Sporadic Registration, No.48ANK/BK, May 31, 2002) **517**

103 លិខិតរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីសំណើកែលំអនីតិវិធីនៃការគ្រប់គ្រង និងប្រើប្រាស់ថវិការដ្ឋ ចំណូលពុំមែនសារពើភ័ណ្ឌ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង, លេខ៣៣៤០សហវ, ១១ កក្កដា ២០០២ (Letter of Ministry of Economy and Finance about the Request to Improve the Procedure of the Management and Use of State Budget, Income other than Inventory and the Management of State Property at the Provincial Department of Land Management, Urban Planning, Construction and Cadastre, No.3340SHV, July 11, 2002) **526**

104 លិខិតរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្តីពីការកែលំអនីតិវិធីនៃការគ្រប់គ្រង និងប្រើប្រាស់ថវិកាចំណូលពុំមែនការសារពើភ័ណ្ឌ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង, លេខ៥៨៤ដនស/ផសហ, ២៤ កក្កដា ២០០២ (Letter of the Ministry of Land Management, Urban Planning and Construction about the Improvement of the Management and Use of Budget and Income other than Inventory and the Management of State Property at the Provincial Department, Urban Planning, Construction and Cadastre, No.584 DNS/PSH, July 24, 2002) **529**

105 សារាចរណែនាំអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី (ការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ), លេខ០០១ដនស/សជ, ១៩ សីហា ២០០២ (Instructive Circular Relating to the Implementation of the Procedure of Establishing Cadastral Index Map and Land Register (Systematic Registration), No.001DNS/SD, August 19, 2002) **530**

106 ប្រកាសស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី, លេខ១១២ដនស/ប្រក, ២១ សីហា ២០០២ (Proclamation on the Guideline and Procedures of the Cadastral Commission, No.112DNS/PK, August 21, 2002) **540**

107 ច្បាប់ស្តីពីព្រៃឈើ, នស/រកម/០៨០២/០១៦, ៣១ សីហា ២០០២ (The Forestry Law, NS/RKM/0802/016, August 31, 2002) **565**

## 2003

108 អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច, លេខ១៩អនក្រ/បក, ១៩ មីនា ២០០៣ (Sub-decree on the Social Land Concession, No.19ANK/BK, March 19, 2003) **619**

109 ប្រកាសស្តីពីការបំពេញបន្ថែមការណែនាំអនុវត្តប្រមូលពន្ធប្រថាប់ត្រា, លេខ៦០៦សហវ/ពដ, ២៧ សីហា ២០០៣ (Proclamation on the Supplementation of Implementation Instruction of the Stamp Duty Collection, No.606SHV/PD, August 27, 2003) **638**

110 ប្រកាសស្តីពីគោលការណ៍ណែនាំអនុវត្តអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច, លេខ២០០ដនស/ប្រក, ១៩ វិច្ឆិកា ២០០៣ (Proclamation on the Instructive Principle of Implementing the Sub-decree on Social Land Concessions, No.200DNS/PK, November 19, 2003) **640**

111 ប្រកាសអន្តរក្រសួងស្តីពីការកំណត់ភារកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងរឿងវិវាទដីធ្លី, លេខ០២ ប្រកន/០៣, ២៦ វិច្ឆិកា ២០០៣ (Inter-ministerial Proclamation on the Determination of Competence of the Court and Cadastral Commission Regarding Land Disputes, No.02PKN/03, November 26, 2003) **655**


## 2004


112 សេចក្តីណែនាំស្តីពីការប្រើប្រាស់ផ្លូវថ្នល់, លេខ០១៥ផថ, ២០ មករា ២០០៤ (Instruction on the Use of Right-of-Way, No.015PTh, January 20, 2004) **657**

113 លិខិតរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីករណីសំណើសុំអនុញ្ញាតជាគោលការណ៍លើតម្លៃសេវាចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធសម្រាប់គម្រោង LMAP នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ០៥៩សហវ/ទរ, ១២ មករា ២០០៤ (Letter of the Ministry of Economy and Finance on the Request of Principle Permit on Service Fee of Systematic Land Registration for LMAP Project of the Ministry of Land Management, Urban Planning and Construction, No.059SHV/TR, January 12, 2004) **661**

114 សារាចរណែនាំអនុវត្តនីតិវិធីនៃការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ, លេខ០១ដនស/សដ, ១៩ មីនា ២០០៤ (Instructive Circular on Implementation of Procedure of Sporadic Land Registration, No.01DNS/SD, March 19, 2004) **662**

115 សេចក្តីណែនាំស្តីពីការចុះបញ្ជីដីបន្ត, លេខ០២ដនស/សដ, ២៨ ឧសភា ២០០៤ (Instruction on the Subsequent Land Registration, No.02DNS/SD, May 28, 2004) **675**

116 បទបញ្ជាស្តីពីការទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការកាប់រាន ការដុត ការឈូសឆាយ និងការហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើ, លេខ០១បប, ០៩ មិថុនា ២០០៤ (Order on the Prevention, Squelching, and Elimination of Clearing, Burning, Raking Over, and Enclosing Forest Land for Occupation, No.01BB, June 09, 2004) **683**

117 លិខិតរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការបញ្ឈប់ចេញបង្កាន់ដៃទទួលពាក្យស្នើសុំកាន់កាប់ដីធ្លី, លេខ៦២១ដនស/សដ, ១៦ មិថុនា ២០០៤ (Letter of the Ministry of Land Management, Urban Planning and Construction about the Stop of Issuing Land Application Receipts, No.621DNS/SD, June 16, 2004) **687**

118 សេចក្តីណែនាំអនុវត្តបទបញ្ជាស្តីពីការទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការកាប់រាន ដុតឈូសឆាយ និងហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើ, លេខ៦២៣ដនស/សដ, ១៦ មិថុនា ២០០៤ (Implementation Instruction on the Prevention, Squelching, and Elimination of Clearing, Burning, Raking Over, and Enclosing Forest Land for Occupation, No.623DNS/SD, June 16, 2004) **688**

119 ប្រកាសស្តីពីវិធានការជំរុញ និងប្រមូលបំណុល ចំណូលថ្លៃឈ្នួលរោងចក្រ សហគ្រាស និងអចលនវត្ថុរបស់រដ្ឋ, លេខ៣១៥សហវ/ប្រក, ២៣ កញ្ញា ២០០៤ (Proclamation on the Measure of Enforcing and Collecting Debt, Rent Income from Factories, Enterprises, and State Immovable Property, No.315SHV/PK, September 23, 2004) **689**

120 អនុក្រឹត្យស្តីពីការកែសម្រួលមាត្រា៤នៃអនុក្រឹត្យលេខ៨៨អនក្រ/បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី, លេខ៦៨អនក្រ/បក, ១៨ តុលា ២០០៤ (Sub-decree on Revising Article 4 of Sub-decree on No. 88ANK/ BK dated December 01, 2000 on the Establishment of the Council of Land Policy, No.68ANK/BK, October 18, 2004) **692**

121 ប្រកាសស្តីពីបែបបទនៃការដោះដូរអចលនទ្រព្យរបស់រដ្ឋនៅតាមបណ្តាក្រសួង ស្ថាប័ន និងខេត្ត-ក្រុង, លេខ៣៨៦សហវ/ទរ, ២០ តុលា ២០០៤ (Proclamation on Procedure of the Exchange of State Immovable Property at Ministries, Institutions, and Provinces/Municipalities, No.386SHV/TR, October 20, 2004) **695**

122 ប្រកាសអន្តរក្រសួងស្តីពីការកែសម្រួលប្រកាសអន្តរក្រសួងលេខ៣៧៧សហវ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០២ ស្តីពីការកំណត់ចំណូលពីសោហ៊ុយសេវាសុរិយោដី, លេខ៣៩៦សហវ/ប្រក, ២៨ តុលា ២០០៤ (Inter-ministerial Proclamation on the Amendment of Inter-ministerial Proclamation No.377SHV dated May 28, 2002 on the Determination of the Revenue from the Cadastral Service Fee, No.396SHV/PK, October 28, 2004) **697**

## 2005

123 លិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីករណីរបាយការណ៍ស្តីពីការប្រមូលពន្ធប្រថាប់ត្រាលើការផ្ទេរអចលនវត្ថុ, លេខ២២៩សជណ, ០៩ កុម្ភៈ ២០០៥ (Letter of the Council of

Ministers about the Report on the Collection of Stamp duties on the Transfer of Immovable Property, No.225SCN, February 09, 2005) **701**

124 លិខិតរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្តីពីការទទួលខុសត្រូវលើលិខិតសញ្ញាផ្ទេរសិទ្ធិ, លេខ១៧៩ដនស/សដ, ១០ កុម្ភៈ ២០០៥ (Letter of the Ministry of Land Management, Urban Planning and Construction about the Responsibility on Conventional Act of Transfer, No.179DNS/SD, February 10, 2005) **703**

125 បទបញ្ជាស្តីពីការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ, លេខ០២បប, ១៣ មិថុនា ២០០៥ (Order on Strengthening the Management of State Property, No.02BB, June 13, 2005) **705**

126 សារាចរណែនាំស្តីពីការផ្តល់សម្បទានដីសេដ្ឋកិច្ចសម្រាប់គម្រោងវិនិយោគនៅក្នុងក្របខ័ណ្ឌនៃការអនុវត្តបទបញ្ជាលេខ០២បប ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ, លេខ០៥សរណន, ០១ កក្កដា ២០០៥ (Instructive Circular on Providing Economic Land Concession for Investment Plan with regard to the Implementation of Order No.02BB dated June 13, 2005 on Strengthening the Management of State Property, No.05SRNN, July 01, 2005) **708**

127 លិខិតរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្តីពីការផ្តល់ព័ត៌មាន និងឯកសារដីធ្លីដែលពាក់ព័ន្ធនឹងដីព្រៃ, លេខ១០២៩ដនស/សដ, ១៣ កក្កដា ២០០៥ (Letter of the Ministry of Land Management, Urban Planning and Construction about Providing Information and Land Documents Relating to Forest Land, No.1029DNS/SD, July 13, 2005) **710**

128 ប្រកាសអន្តរក្រសួងស្តីពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ-សង្កាត់ ក្នុងការចុះបញ្ជីដីធ្លី, លេខ២១៥ប្រក/ដនស/មផ, ០៩ កញ្ញា ២០០៥ (Inter-ministerial Proclamation on the Function and Responsibility of Communal Administration in Land Registration, No.215PK/DNS/MC, September 09, 2005) **712**

129 សេចក្តីណែនាំស្តីពីនីតិវិធីសវនាការនៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ, លេខ១៤៥៥ដនស/គសជ, ២៣ កញ្ញា ២០០៥ (Instruction on the Hearing Procedures of the National Cadatral Commission, No.1455DNS/KSC, September 23, 2005) **719**

130 សារាចរណែនាំស្តីពីការចុះបញ្ជីអគារ និងក្បាលដីសហកម្មសិទ្ធិ, លេខ០១ដនស/អកគដ/សរណន, ២១ កញ្ញា ២០០៥ (Instructive Circular on the Registration of Buildings and Parcels of Co-ownership Land, No.01DNS/AKKD/ SRNN, September 21, 2005) **732**

131 អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ, លេខ១១៨អនក្រ/បក, ០៧ តុលា ២០០៥ (Sub-decree on the State Land Management, No.118ANK/BK, October 07, 2005) **736**

132 អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច, លេខ១៤៦អនក្រ/បក, ២៧ ធ្នូ ២០០៥ (Sub-decree on the Economic Land Concession, No.146ANK/BK, December 27, 2005) **756**

## 2006

133 ប្រកាសអន្តរក្រសួងស្តីពីសោហ៊ុយលើសេវាសំណង់, លេខ០៣៣សហវ/ប្រក, ១២ មករា ២០០៦ (Inter-ministerial Proclamation on the Construction Service Fee, No.033 SHV/PK, January 12, 2006) **776**

134 សេចក្តីសម្រេចស្តីពីការកំណត់បរិបទនៃការពិនិត្យ និងសម្រេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់, លេខ០៥សសរ, ០៦ កុម្ភៈ ២០០៦ (Decision on the Determination of the Context of the Control and Decision on Construction Permit Applications, No.05SSR, February 06, 2006) **786**

135 សេចក្តីជូនដំណឹងស្តីពីការបង់សេវានៃការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ, លេខ០១សជណ, ១៦ កុម្ភៈ ២០០៦ (Notification on the Service Payment of Systematic Land Registration, No.01SCN, February 16, 2006) **790**

136 ព្រះរាជក្រឹត្យស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី, នស/រកត/០២០៦/០៩៧, ២៦ កុម្ភៈ ២០០៦ (Royal Decree on the Establishment of the National Authority for Land Dispute Resolutions, NS/RKT/ 0206/097, February 26, 2006) **792**

137 លិខិតរបស់ក្រសួងយុត្តិធម៌ស្តីពីការអនុវត្តសាលក្រម ឬសាលដីកាស្ថាពរពាក់ព័ន្ធនឹងការផ្ទេរអចលនវត្ថុ, លេខ៣៣០/កយ/រប/០៦, ០៣ មីនា ២០០៦ (Letter of the Ministry of Justice about the Implementation of Final Judgments Relating to the Transfer of Immovable Property, No.330/KY/RB/06, March 03, 2006) **796**

138 ប្រកាសស្តីពីការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ, លេខ៤២ដនស/បក, ១០ មីនា ២០០៦ (Proclamation on Identifying, Mapping, and Classifying State Land, No.42DNS/BK, March 10, 2006) **798**

139 អនុក្រឹត្យស្តីពីការកែប្រែមាត្រា៥ និងមាត្រា២៨ នៃអនុក្រឹត្យលេខ៤៧អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី, លេខ៣៤អនក្រ/បក, ២០ មេសា ២០០៦ (Sub-decree on the Modification of Articles 5 and 28 of Sub-decree No.47ANK/BK dated May 31, 2002 on the Organization and Functioning of Cadastral Commission, No.34ANK/BK, April 20, 2006) **818**

140 លិខិតរបស់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រស្តីអំពីបញ្ហាទាក់ទងនឹងការផ្ទេរដី-ផ្ទះ ក្នុងតំបន់ដែលបានធ្វើការវិនិច្ឆ័យរួចហើយ, លេខ៦៨អសដភ, ២៤ មេសា ២០០៦ (Letter of the General Department of Cadastre and Geography about Issues Relating to the Transfer of Land and Houses in Adjudicated Areas, No.68ASDP, April 24, 2006) **821**

141 សេចក្ដីណែនាំរួមស្ដីពីការអនុវត្តអនុក្រឹត្យលេខ៣៤អនក្រ/បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៦, លេខ០៥សណន, ២៧ មេសា ២០០៦ (Joint Instruction on the Implementation of Sub-decree No.34ANK/BK dated April 20, 2006, No.05SNN, April 27, 2006) **823**

142 សារាចរណែនាំស្ដីពីគោលការណ៍ និងនីតិវិធីចុះបញ្ជីដីបំពេញបន្ថែម, លេខ០៦សណន, ០៥ ឧសភា ២០០៦ (Instructive Circular on the Principles and Procedures of Complementary Land Registration, No.06SNN, May 05, 2006) **825**

143 បទបញ្ជាស្ដីពីការទប់ស្កាត់ការកាប់រានដីព្រៃឈើគ្រប់ប្រភេទរបស់រដ្ឋយកធ្វើជាកម្មសិទ្ធិ, លេខ ០១បប/១០ ឧសភា ២០០៦ (Order on the Prevention of Clearing State Forest Land for Ownership, No.01BB/May 10, 2006) **827**

144 សេចក្ដីណែនាំស្ដីអំពីវិធានការធានាសុវត្ថិភាពនៃឯកសារសុរិយោដី និងទិន្នន័យគោលនៃការចុះបញ្ជីដីធ្លីជា Digital, លេខ៩៥អសដក, ២៣ ឧសភា ២០០៦ (Instruction on the Safety Measure of Cadastral Documents and Principle Data of Digital Land Registration, No.95ASDP, May 23, 2006) **829**

145 សេចក្ដីណែនាំស្ដីពីការប្រើប្រាស់ត្រាមោឃភាពប័ណ្ណចាស់ក្នុងតំបន់វិនិច្ឆ័យ, លេខ១២៩សណន/សដក, ២៧ មិថុនា ២០០៦ (Instruction on the Use of Stamp to Abrogate Old Titles in Adjudicated Areas, No.129SNN/SDP, June 27, 2006) **834**

146 សេចក្ដីជូនដំណឹងស្ដីពីការផ្អាកជាបណ្ដោះអាសន្ននូវការចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលើដីព្រៃឈើគ្រប់ប្រភេទ, លេខ០៩សជណ/សជ, ០៤ កក្កដា ២០០៦ (Notification on the Temporary Postponement of Issuing Owner Certificates for Immovable Property or Title of Immovable Property of All Types of Forest Land, No.09SCN/SD, July 04, 2006) **836**

147 លិខិតរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្ដីពីករណីសុំគោលការណ៍ពង្រឹងការងារគ្រប់គ្រងដីធ្លី, លេខ៦៥៣ជនស/សជ, ០៦ កក្កដា ២០០៦ (Letter of the Ministry of Land Management, Urban Planning and Construction about the Request of Principles to Strengthen Land Management Issues, No.653DNS/SD, July 06, 2006) **837**

148 អនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី, លេខ៦៥អនក្រ/បក, ១៤ កក្កដា ២០០៦ (Sub-decree on the Organization and Functioning of the General Secretariat of the National Authority for Land Dispute Resolutions, No.65ANK/BK, July 14, 2006) **838**

149 សេចក្ដីណែនាំស្ដីពីការកសាងឯកសារចុះបញ្ជីដីធ្លី, លេខ១១សណន, ២១ កក្កដា ២០០៦ (Instruction on the Preparation of Land Registration Documents, No.11SNN, July 21, 2006) **847**

150 ព្រះរាជក្រឹត្យស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ, លេខ នស/រកត/០៨០៦/៣៣៩, ០៣ សីហា ២០០៦ (Royal Decree on Principles and Provisions of Transferring Public Property of the State and Public Entities No.NS/RKT/0806/339, August 03, 2006) **851**

151 ប្រកាសស្តីពីការគ្រប់គ្រង និងការទប់ស្កាត់បទល្មើសលើធនធានធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិ, លេខ២៥៨ប្រក/បស្ថ/កអធ, ២៥ សីហា ២០០៦ (Proclamation on the Management and Prevention of Crime over Natural Resources in Natural Protected Areas, No.258PK/BSt/KAF, August 25, 2006) **854**

152 លិខិតរបស់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រស្តីពីការអនុវត្តសាលក្រម ឬសាលដីកាស្ថាពរពាក់ព័ន្ធនឹងការផ្ទេរអចលនវត្ថុ, លេខ១៨៧អសដភ, ២៨ សីហា ២០០៦ (Letter of General Department and Geography on the Implementation of Final Judgments Relating to the Transfer of Immovable Property, No.187ASDP, August 28, 2006) **862**

153 សេចក្តីសម្រេចស្តីពីការកំណត់ក្រមសីលធម៌សម្រាប់មន្ត្រីអនុវត្តគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី, លេខ៤៣សសរ, ២៣ តុលា ២០០៦ (Decision on the Determination of Ethics for Staff to Implement Land Management and Administration Project, No.43SSR, October 23, 2006) **864**

154 សេចក្តីសម្រេចស្តីពីការបង្កើតប្រព័ន្ធទទួលពាក្យបណ្តឹងសម្រាប់គម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី, លេខ៤២សសរ, ២៣ តុលា ២០០៦ (Decision on the Establishment of Claim Reception System for Land Management and Administration Project, No.42SSR, October 2006) **869**

155 អនុក្រឹត្យស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ, លេខ១២៩អនក្រ/បក, ២៧ វិច្ឆិកា ២០០៦ (Sub-decree on the Rules and Procedures of Transferring Public Property of the State and Public Entities, No.129ANK/BK, November 27, 2006) **873**

156 លិខិតរបស់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ជម្រាបមកប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីគ្រប់ខេត្ត-ក្រុង ដែលទទួលបានប្រតិភូកម្មហត្ថលេខាអំពីការបញ្ជូនតារាងសម្រង់អចលនវត្ថុ និងតារាងផ្លាស់ប្តូរអចលនវត្ថុ, លេខ២៦៥អសដភ, ២៨ វិច្ឆិកា ២០០៦ (Letter of General Department and Geography Informing Chief of Provincial Department, Urban Planning, Construction and Cadastre already Received Signature Delegation on the Submission of Cadastral Survey and Immovable Transfer Table, No.265ASDP, November 28, 2006) **889**

157 លិខិតរបស់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រស្តីពីការអនុវត្តនីតិវិធីចុះបញ្ជីដី-ការផ្ទេរសិទ្ធិ និងការចុះបន្ទុកលើដី-ផ្ទះ ក្នុងតំបន់ដែលកំពុងធ្វើការវិនិច្ឆ័យ និងតំបន់ដែលបានធ្វើការវិនិច្ឆ័យរួចហើយ, លេខ២៧៣អសដភ, ០៦ ធ្នូ ២០០៦ (Letter of General Department of Cadastre and Geography on the Implementation of Land Registration Procedure, Transfer of Right, and Registration of Land-House Encumbrances in Areas under and after Adjudication, No.273ASDP, December 06, 2006) **891**

158 សេចក្តីណែនាំស្តីពីគោលការណ៍ នីតិវិធី និងរូបមន្តលេខាចារឹកទាក់ទងនឹងទ្រព្យសហភោគី ឬកម្មសិទ្ធិករអវិភាគ, លេខ២៧៤អសដភ, ០៦ ធ្នូ ២០០៦ (Instruction on the Principle, Procedure and Formula of Inscription Relating to a Co-owner or an Owner of Indivisible Ownership, No.274ASDP, December 06, 2006) **893**

159 សេចក្តីសម្រេចស្តីពីការផ្តល់សេវាសុរិយោដី, លេខ៥១សសរ, ២១ ធ្នូ ២០០៦ (Decision on Providing Cadastral Services, No.51SSR, December 21, 2006) **896**

160 សេចក្តីសម្រេចស្តីពីការបញ្ចូលឯកសារលក្ខណវិនិច្ឆ័យក្នុងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ជាឧបសម្ព័ន្ធរបស់ប្រកាសលេខ៤២ដនស/បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៦ ស្តីពីការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ, លេខ៥២សសរ, ២៥ ធ្នូ ២០០៦ (Decision of the Inclusion of the Adjudicative Documents into Classification of State Land as an Index of Proclamation No.42DNS/BK dated March 10, 2006 on Identifying, Mapping, and Classifying State Land, No.52SSR, December 25, 2006) **900**

161 ប្រកាសរួមស្តីពីយន្តការផ្តល់សេវាផ្សព្វផ្សាយកសិកម្មដល់កសិករសម្បទានដីសង្គមកិច្ច, លេខ៥០៧ប្រក/កសក, ២៦ ធ្នូ ២០០៦ (Joint Proclamation on Mechanism to Provide Agricultural Dissemination Services for Social Land Concession Peasants, No.507PK/KSK, December 26, 2006) **929**

## 2007

162 លិខិតរបស់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រស្តីពីករណីលក់ផ្ទះ ដី ឬអចលនវត្ថុក្នុងតំបន់ដែលបានធ្វើការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធរួច តែម្ចាស់ផ្ទះអាក់ខានពុំបានចូលរួមផ្តល់ព័ត៌មាន, លេខ០៤អសដភ, ០៣ មករា ២០០៧ (Letter of the General Department of Cadastre and Geography on the Sale of Land, Houses and Immovable Property in Areas already Systematically Registered but House Owners Failed to Provide Information, No.04ASDP, January 03, 2007) **932**

163 សេចក្តីណែនាំស្តីពីវិធានការទប់ស្កាត់ការកាប់រានដីព្រៃឈើ និងការចេញលិខិតបញ្ជាក់ការទិញលក់ដីក្នុងតំបន់ការពារធម្មជាតិ, លេខ០០១សណន, ០៩ មករា ២០០៧ (Instruction on the

Prevention Measure of Clearing Forest Land and Land Sale Certification in Natural Protected Areas, No.001SNN, January 09, 2007) **933**

164 សារាចរស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់, លេខ០២សរ, ២៦ កុម្ភៈ ២០០៧ (Circular on the Illegal Occupation of State Land, No.02SR, February 26, 2007) **936**

165 សេចក្តីណែនាំអនុវត្តសារាចររាជរដ្ឋាភិបាលលេខ០២សរ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់ក្រោមដែនសមត្ថកិច្ចរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, លេខ២៩៤៣កសក, ០៥ មិថុនា ២០០៧ (Instruction on the Implementation of Governmental Circular No.02 on the Illegal Occupation of State Land Under the Capacity of Ministry of Agriculture, Forestry, and Fisheries, No.2943KSK, June 05, 2007) **946**

166 សេចក្តីជូនដំណឹងស្តីពីការគ្រប់គ្រងប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់, លេខ០១០/សហវ/ប្រក/ពដ, ០៦ មិថុនា ២០០៧ (Notification on the Management of the Collection of Tax on Unused Land, No.010SHV/PK/BD, June 06, 2007) **951**

167 សារាចរណែនាំស្តីពីចំណាត់ការ និងនីតិវិធីនៃការដោះស្រាយរឿងក្តីដែលមានពាក់ព័ន្ធនឹងដីរដ្ឋ, លេខ០១កយ/សរណន/០៧, ០៣ កក្កដា ២០០៧ (Instructive Circular on the Measurement and Procedure of Conflict Resolutions Related to State Land, No.01KY/SRNN/07, July 03, 2007) **953**

168 ប្រកាសស្តីពីលក្ខណវិនិច្ឆ័យខាងហិរញ្ញវត្ថុរបស់អ្នកសុំដីសម្បទានសង្គមកិច្ច, លេខ២៦៣សអយ, ០៣ កក្កដា ២០០៧ (Proclamation on Financial Criteria of Social Concession Land Applicants, No.263 SAY, July 03, 2007) **956**

169 ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីឯកជនរបស់រដ្ឋ, លេខ៩៥ប្រក/ជនស/មផ, ២៥ កក្កដា ២០០៧ (Inter-ministerial Proclamation on the Procedure on Managing of the Use of Private State Land, No.95PK/DNS/MP, July 25, 2007) **960**

170 អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មការកំណត់ផ្ទៃទីតាំងបឹងបួក្នុងព្រះរាជាណាចក្រកម្ពុជា, លេខ១០១អនក្រ/បក, ១៥ សីហា ២០០៧ (Sub-decree on the Establishment of the Committee for Determining of the Areas of Lake Location in the Kingdom of Cambodia, No.101 ANK/BK, August 15, 2007) **970**

171 អនុក្រឹត្យស្តីពីការដាក់បញ្ចាំ ការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬសិទ្ធិលើសម្បទានដីសេដ្ឋកិច្ច, លេខ១១៤អនក្រ/បក, ២៩ សីហា ២០០៧ (Sub-decree on the Paw and Transfer of Right to Long Lease or Right to Economic Land Concession, No.114ANK/BK, August 29, 2007) **973**

172 សេចក្តីណែនាំស្តីពីវិធីកែតម្រូវឯកសារផ្លូវការ និង Digital (សម្រាប់នីតិវិធីចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ), លេខ២៧៣/អសដក, ៣០ តុលា ២០០៧ (Instruction on Method of Revising Official and Digital Documents (For Systematic Land Registration Procedures), No.273/ASDP, October 30, 2007) **983**

173 សារាចរណែនាំស្តីពីការអនុវត្តផែនការបែងចែកសម្បទានដីសង្គមកិច្ច, លេខ០៦សរណន, ០៨ វិច្ឆិកា ២០០៧ (Instructive Circular on the Implementation of the Social Land Concession Distribution Plan, No.06SRNN, November 8, 2007) **986**

## 2008

174 អនុក្រឹត្យស្តីពីវិធាននៃការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ការដាំដើមឈើ, លេខ២៦អនក្រ/បក, ២៥ មីនា ២០០៨ (Sub-decree on the Rule of Providing Right of Use over State Forest for Planting Trees, No.26 ANK/BK, March 25, 2008) **988**

175 លិខិតរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់អំពីគោលការណ៍ណែនាំស្តីពីការចុះបញ្ជីដីសម្បទានសេដ្ឋកិច្ច, លេខ០១ដនស/សណន/អសដក, ០២ កញ្ញា ២០០៨ (Letter of the Ministry of Land Management, Urban Planning and Construction about Instructive Principle on the Registration of Economic Concession Land, No.01DNS/SNN/ASDP, September 2, 2008) **998**

176 អនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច, លេខ១៣១អនក្រ/បក, ១៥ កញ្ញា ២០០៨ (Sub-decree on the Amendment of the Sub-decree on Economic Land Concession, No.131ANK/BK, September 15, 2008) **1001**

177 ព្រះរាជក្រឹត្យស្តីពីវិសោធនកម្មមាត្រា១នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី, នស/រកត/១០០៨/១១០៦, ០៩ តុលា ២០០៨ (Royal Decree on the Amendment of Article 1 of Royal Decree No.NS/RKT/0106/097 dated February 26, 2006 on the Establishment of the National Authority for Land Dispute Resolutions, No.SN/RKT/1008/1106, October 09, 2008) **1004**

## 2009

178 អនុក្រឹត្យស្តីពីការកែសម្រួលមាត្រា៤ថ្មីនៃអនុក្រឹត្យលេខ៦៨អនក្រ/បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៤ ស្តីពីការកែប្រែមាត្រា៤នៃអនុក្រឹត្យលេខ៨៨អនក្រ/បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី, លេខ៣៥អនក្រ/បក, ០៦ កុម្ភៈ ២០០៩ (Sub-decree on Revising Article 4 New of Sub-decree No.68ANK /BK

dated October 18, 2004 on Revising Article 4 of Sub-decree No. 88ANK/BK dated December 01, 2000 on the Establishment of the Council of Land Policy, No.35ANK/BK, February 06, 2009) **1007**

179 អនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់, លេខ៧២អនក្រ/បក, ០៥ ឧសភា ២០០៩ (Sub-decree on the Commune Land Use Planning Procecdure, No.72ANK/BK, May 5, 2009) **1010**

180 លិខិតរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់អំពីការណែនាំស្តីពីការចុះបញ្ជីដីរដ្ឋដែលជាកម្មវត្ថុនៃសម្បទានដីសេដ្ឋកិច្ច ឬជួលរយៈពេលវែង និងការចុះបញ្ជីសិទ្ធិលើសម្បទានដីសេដ្ឋកិច្ច ឬសិទ្ធិជួលរយៈពេលវែង, លេខ០៦ដនស/អសដ/សណន, ០៨ មិថុនា ២០០៩ (Letter of the Ministry of Land Management, Urban Planning, and Construction about the Instruction on the Registration of of State Land Subject to Economic Land Concessions or Long Term Leases and the Registration of Rights over Economic Land Concessions or Rights over Long Term Leases, No.06DNS/ASD/SNN, June 8, 2009) **1024**

181 អនុក្រឹត្យស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច, លេខ៨៣អនក្រ/បក, ០៩ មិថុនា ២០០៩ (Sub-decree on the Procedure of Land Registration of Indigenous People Land, No.83ANK/BK, June 09, 2009) **1027**

182 អនុក្រឹត្យស្តីពីការបន្ថែមសមាជិកគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ, លេខ៨៩អនក្រ/បក, ២២ មិថុនា ២០០៩ (Sub-decree on the Addition of the Memebers of National Social Land Concession Committee, No.89ANK/BK, June 22, 2009) **1039**

183 សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលស្តីពីគោលនយោបាយដីធ្លី, លេខ២៧សជណ/អគ, ០១ កក្កដា ២០០៩ (Government Statement on Land Policy, No.27SCN/AK, July 01, 2009) **1041**

184 អនុក្រឹត្យស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ, លេខ១២៦អនក្រ/បក, ១២ សីហា ២០០៩ (Sub-decree on the Management and Use of Coownership Buildings, No.126ANK/BK, August 12, 2009) **1049**

185 លិខិតរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់អំពីគោលការណ៍ណែនាំស្តីពីការចុះបញ្ជីដីដែលតុលាការបដិសេធវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់-កាប់អចលនវត្ថុ, លេខ១២ដនស/សដ, ១៥ កញ្ញា ២០០៩ (Letter of the Ministry of Land Management, Urban Planning and Construction about the Instructive Principle on the Registration of Land which Court Denies the Owner Certificate for

Immovable Property and Certificate of Immovable Property, No.12DNS/SD, September 15, 2009) **1073**

186 លិខិតរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់អំពីគោលការណ៍ណែនាំស្ដីពីការចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ចំពោះក្បាលដីឋិតក្នុងតំបន់វិនិច្ឆ័យសម្រាប់ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ដែលម្ចាស់មិនបានផ្ដល់ព័ត៌មានអំពីការផ្លាស់ប្ដូរមុនពេលបិទផ្សាយទិន្នន័យជាសាធារណៈ, លេខ១៨ដនស/ណន, ១៧ វិច្ឆិកា ២០០៩ (Letter of the Ministry of Land Management, Urban Planning and Construction about the Instructive Principle on Issuing the Owner Certificate for Immovable Property in terms of Land Parcels in Adjudication Areas for Systematic Land Registration which the Owner Failed to Provide Information about Changes before Public Announcement, No.18DNS/NN, November 17, 2009) **1075**

## 2010

187 ច្បាប់អស្សាមិករណ៍, លេខ នស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០ (Expropriation Law, No.NS/RKM/0210/003, February 26, 2010) **1079**

188 ច្បាប់ស្ដីពីការផ្ដល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស, លេខ នស/រកម/០៥១០/០០៦, ២៤ ឧសភា ២០១០ (Law on Granting Ownersihp over Private Part of Ownership Buildings for Foreigners, No.NS/RKM/0510/ 006, May 24, 2010) **1094**

189 សារាចរស្ដីពីការដោះស្រាយសំណង់បណ្ដោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់តាមរាជធានី ទីក្រុង និងទីប្រជុំជន, លេខ០៣សរ, ៣១ ឧសភា ២០១០ (Circular on Squatter Settlement on State Land Illegally Grabbed in the Capital, Cities and Towns, No.03SR, May 31, 2010) **1102**

190 ប្រកាសស្ដីពីការប្រមូលពន្ធលើអចលនទ្រព្យ, លេខ៤៩៣សហវ/ប្រក, ១៩ កក្កដា ២០១០ (Proclamation on the Collection of Tax on Immovable Property, No.493SHV/PK, July 19, 2010) **1109**

*វាយឡើងវិញ*

រដ្ឋកម្ពុជា

ក្រុមប្រឹក្សារដ្ឋមន្ត្រី ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

លេខ០៦អនក្រ

# អនុក្រឹត្យ
# ស្តីពីការគ្រប់គ្រងប្រើប្រាស់ដីធ្លីកសិកម្ម

## ក្រុមប្រឹក្សារដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា
- បានឃើញច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ០៣ក្រ ចុះថ្ងៃទី១០ កុម្ភៈ ១៩៨២
- បានឃើញក្រឹត្យច្បាប់លេខ០៧ក្រច ចុះថ្ងៃទី១៣ កក្កដា ១៩៨៣ ស្តីពីសមត្ថកិច្ច និងនីតិវិធីនៃការធ្វើច្បាប់ និងបទបញ្ជា
- បានឃើញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា លេខ២៣៦/៨០/សរ ចុះថ្ងៃទី៣០ សីហា ១៩៨០ ស្តីអំពីការពង្រីកសេដ្ឋកិច្ចគ្រួសារ
- តាមសំណើរបស់ក្រសួងកសិកម្ម

## សម្រេច

## ជំពូកទី១ បទប្បញ្ញត្តិទូទៅ

### មាត្រា១

ដីធ្លីកសិកម្មមានដីស្រែ វាលរាប ដីស្រែខ្ពង់រាប ដីទួល ដីព្រៃដែលមានការអនុញ្ញាត ដីចម្ការ ដីតាមមាត់ទន្លេ ដីកោះ វាលស្មៅធម្មជាតិ ទោះជាកំពុងដាំដុះ ឬទុកចោលទំនេរ និងបឹងស្រះ ត្រពាំង ទំនប់ទឹកដែលឋិតនៅក្រៅដែននេសាទ ត្រូវគ្រប់គ្រងឱ្យបានម៉ត់ចត់ និងប្រើប្រាស់ឱ្យបានសមស្រប។

រដ្ឋអំណាចគ្រប់ថ្នាក់ មានភារកិច្ចគ្រប់គ្រង និងប្រើប្រាស់ដីធ្លីទូទៅតាមព្រំប្រទល់ភូមិសាស្ត្ររដ្ឋបាលរបស់ខ្លួន។ ចំពោះតំបន់ណាដែលមិនទាន់បានកំណត់ព្រំប្រទល់ច្បាស់លាស់ ត្រូវរដ្ឋអំណាចមូលដ្ឋានតំបន់នោះ ស្នើឡើងថ្នាក់លើដែលមានសមត្ថកិច្ចដើម្បីពិនិត្យ និងសម្រេច។

ហាមឃាត់ការទិញ លក់ បញ្ចាំ ប្រវាស់ ជួលដី និង/ឬជួលពលករធ្វើដី ទោះជាក្រោមរូបភាពណាក៏ដោយ។

ហាមផ្តាច់ការកាប់គាស់ រាន ឬឆ្ការព្រៃដោយគ្មានការអនុញ្ញាតយកទៅធ្វើស្រែចម្ការ ឬធ្វើអាជីវកម្ម ឬរ៉ែនៅក្នុងដី និងនៅកន្លែងដែលមានបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រជាតិ។

**មាត្រា២**

ក្រុមសាមគ្គីបង្កបង្កើនផល កសិដ្ឋានរដ្ឋ ស្ថានីយ៍ពិសោធន៍កសិកម្ម រុក្ខដ្ឋាន សាលាបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម និងផ្នែកនានា មានអាទិភាពក្នុងការប្រើប្រាស់ដីធ្លីដែលចែងក្នុងមាត្រា១ ដើម្បីផលិតតាមផែនការកំណត់របស់រដ្ឋ។

ដីសម្រាប់កសិកម្មមួយចំណែក ត្រូវបានប្រគល់ឱ្យគ្រួសារកសិករ កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ ដែលរស់នៅក្នុងមូលដ្ឋានផ្ទាល់ដើម្បីធ្វើសេដ្ឋកិច្ចគ្រួសារ និងសម្រាប់ធ្វើលំនៅឋានតាមការកំណត់របស់រដ្ឋ។

## ជំពូកទី២ ការប្រើប្រាស់ និងគ្រប់គ្រងដីធ្លី

**មាត្រា៣**

ក្រុមសាមគ្គីបង្កបង្កើនផល មានសិទ្ធិប្រើប្រាស់ដីកសិកម្មដូចតទៅ៖

-ដីដែលរដ្ឋអំណាចបដិវត្តបានប្រគល់ឱ្យក្រោយថ្ងៃរំដោះ៧ មករា ១៩៧៩

-ដីដែលរដ្ឋអំណាចបដិវត្តបានអនុញ្ញាតឱ្យស្តារឡើងវិញ និងគាស់រានបន្ថែម

-ដីដែលរដ្ឋអំណាចបដិវត្តបានប្រគល់ឱ្យប្រើប្រាស់ជាបណ្តោះអាសន្ន

ចំនួនផ្ទៃដីដែលប្រគល់ឱ្យក្រុមសាមគ្គីបង្កបង្កើនផល ត្រូវគិតទៅតាមមធ្យមភាគនៃចំនួនប្រជាជនទូទៅនៅក្នុងឃុំ-សង្កាត់ រួមទាំងអ្នកចូលបម្រើកងទ័ព នគរបាល កម្មាភិបាល កម្មករ បុគ្គលិករដ្ឋ និងជនពលីដើម្បីបដិវត្តដែលមានឈ្មោះក្នុងបញ្ជីជំរឿនគ្រួសារនៅមូលដ្ឋាន។

**មាត្រា៤**

កសិដ្ឋានរដ្ឋ មជ្ឈមណ្ឌលកសិកម្ម សាលាបណ្ដុះបណ្ដាលបច្ចេកទេសកសិកម្ម មានសិទ្ធិប្រើប្រាស់ដីកសិកម្មដូចតទៅៈ

-ដីដែលជាអតីតកសិដ្ឋានរដ្ឋ ស្ថានីយ៍ពិសោធន៍កសិកម្ម សាលាបណ្ដុះបណ្ដាលបច្ចេកទេសកសិកម្មដែលរដ្ឋឱ្យស្ថាបនា និងជួសជុលឡើងវិញ និងដីដែលរដ្ឋប្រគល់ឱ្យដើម្បីពង្រីក និងស្ថាបនាបន្ថែម ។

-ដីដែលរដ្ឋបានអនុញ្ញាតឱ្យស្ដារឡើងវិញ ឬគាស់រានបន្ថែម ។

-ដីដែលរដ្ឋអំណាចមូលដ្ឋានបានប្រគល់ឱ្យប្រើប្រាស់ជាបណ្ដោះអាសន្ន ។

មូលដ្ឋាននៅក្រោមឱវាទផ្នែកផ្សេងៗ ដែលសុំដីសម្រាប់ផលិតកម្ម ក៏ត្រូវបានប្រគល់ដីសម្រាប់ប្រើប្រាស់ដែរ ។

ចំនួនផ្ទៃដីដែលប្រគល់ឱ្យមូលដ្ឋាននានាខាងលើ ត្រូវផ្អែកទៅតាមលទ្ធភាពនៃកម្លាំងពលកម្ម និងសំណូមពរនៃការអភិវឌ្ឍរបស់ផ្នែកដែលបានបញ្ចូលក្នុងផែនការរដ្ឋ ។

**មាត្រា៥**

គ្រួសារនានាមានលទ្ធភាពប្រើប្រាស់ប្រភេទដីកសិកម្មដូចតទៅៈ

-ដីសម្រាប់លំនៅឋាន និងដីសម្រាប់ធ្វើសេដ្ឋកិច្ចគ្រួសារ "គិតទាំងចម្ការគ្រួសារ" ដែលរដ្ឋអំណាចបានប្រគល់ឱ្យប្រើប្រាស់តាមការកំណត់ និងតាមគោលនយោបាយរបស់រដ្ឋ ។

-ដីបោះបង់ចោលទំនេរដែលរដ្ឋអំណាចបានអនុញ្ញាតឱ្យស្ដារឡើងវិញ ឬគាស់រានបន្ថែម ។

-ដីដែលក្រុមសាមគ្គីបង្កបង្កើនផលបានប្រគល់ឱ្យប្រើប្រាស់បណ្ដោះអាសន្ន ។

ចំពោះគ្រួសារដែលឈប់បង្កបង្កើនផល ឬផ្លាស់លំនៅឋានទៅស្នាក់នៅមូលដ្ឋានផ្សេងៗទៀត ដោយមានមូលហេតុត្រឹមត្រូវ និងដោយរដ្ឋអំណាចមូលដ្ឋានអនុញ្ញាតយល់ព្រម គ្រួសារនោះត្រូវប្រគល់ដីដែលខ្លួនប្រើប្រាស់ឱ្យរដ្ឋអំណាចឃុំ-សង្កាត់វិញ ដើម្បីប្រគល់ឱ្យក្រុមសាមគ្គីបង្កបង្កើនផលប្រើប្រាស់ ។ រដ្ឋអំណាចមូលដ្ឋាននោះត្រូវជួយសម្រុះសម្រួលសមស្របចំពោះផលដំណាំ និងសំណង់របស់គ្រួសារនោះ ។

ចំពោះដីដែលម្ចាស់មិនប្រើប្រាស់ រដ្ឋអំណាចមូលដ្ឋានមានភារកិច្ចគ្រប់គ្រង និងប្រគល់ជាបណ្ដោះអាសន្នឱ្យក្រុមសាមគ្គីបង្កបង្កើនផល ឬឱ្យគ្រួសារណាមួយសម្រាប់បង្កបង្កើនផល ។

ចំពោះគ្រួសារកម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍ ហើយមានលទ្ធភាពបង្កបង្កើនផលកសិកម្ម ត្រូវរដ្ឋអំណាចមូលដ្ឋានប្រគល់ដីឱ្យមួយចំនួនដើម្បីប្រើប្រាស់។

ចំពោះជនរត់ចោលជួរខ្មាំង ហើយត្រលប់មកជួបជុំជាមួយគ្រួសារវិញ បើចង់ចូលរួមបង្កបង្កើនផលកសិកម្ម ក៏មានសិទ្ធិប្រើប្រាស់ដីធ្លីដូចកសិករដទៃទៀតដែរ។

**មាត្រា៦**

ដីសម្រាប់បង្កបង្កើនផលដើម្បីទ្រទ្រង់បេឡារបស់រដ្ឋអំណាច និងអង្គការមហាជន នៅឃុំ ភូមិ ដើម្បីប្រគល់ឱ្យអង្គភាពចាត់តាំងរដ្ឋអំណាច អង្គការមហាជន ឈ្លប នគរបាល នៅឃុំ ភូមិ បង្កបង្កើនផលយកកម្រៃសម្រាប់ប្រើប្រាស់ក្នុងការងាររួម។

-ឃុំនីមួយៗអាចរក្សាទុកដីស្រែចម្ការមួយចំនួនមិនលើសពី៦ហិកតា នៅកន្លែងណាដែលមានដីទូលាយ ហើយមានមនុស្សតិច។ នៅកន្លែងណាដែលមានផ្ទៃដីតិច ហើយមានមនុស្សច្រើន នោះអាចរក្សាទុកដីស្រែចម្ការចំនួន៣ហិកតា។

-ភូមិនីមួយៗអាចរក្សាទុកដីស្រែចម្ការប្រមាណពី១ ទៅ២ហិកតា នៅកន្លែងណាដែលមានដីទូលាយ ហើយមានមនុស្សតិច។ នៅកន្លែងណាដែលមានផ្ទៃដីតិច ហើយមានមនុស្សច្រើន នោះ អាចរក្សាទុកដីចំនួន១ហិកតា។

គណៈកម្មាធិការប្រជាជនបដិវត្តស្រុក មានសមត្ថកិច្ចពិនិត្យ និងសម្រេចលើចំនួនផ្ទៃដីខាងលើ ស្របតាមសភាពការណ៍ជាក់ស្តែងនៅតំបន់នីមួយៗ។

ក្នុងករណីចង់យកចំនួនដីលើសពីការកំណត់ខាងលើ ត្រូវគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុងពិនិត្យ និងសម្រេច។

**មាត្រា៧ អំពីដីសម្រាប់សាលារៀន**

ដើម្បីបង្កលក្ខណៈឱ្យសិស្សានុសិស្សចូលរួមពលកម្មដោយផ្ទាល់ ក្រៅពីដីសង់អគារ និងទីធ្លា ត្រូវរក្សាទុកដីមួយចំនួនសម្រាប់សួនច្បារ យោលទៅតាមផ្ទៃដីតំបន់នីមួយៗ និងលទ្ធភាពពលកម្មរបស់សិស្ស។

**មាត្រា៨ អំពីដីវត្តអារាម**

ដីដែលឋិតនៅក្នុងបរិវេណវត្តអារាម ត្រូវទុកឱ្យវត្តអារាមប្រើប្រាស់។

**មាត្រា៩ អំពីបឹង ស្រះ ថ្លុក ត្រពាំងដែលឋិតនៅក្រៅដែននេសាទ**

ចំពោះបឹង ស្រះ ថ្លុក ត្រពាំង ដែលឋិតនៅក្នុងភូមិ ឃុំណា ត្រូវភូមិ ឃុំនោះ គ្រប់គ្រង និងប្រើប្រាស់រួមដោយផ្តល់អាទិភាពដល់ប្រជាជនក្នុងការយកទឹកស្រោចដំណាំ និងចិញ្ចឹមត្រី តែប្រសិនបើស្រះ ថ្លុក ត្រពាំងនោះតូចតាចដែលបម្រើសេដ្ឋកិច្ចគ្រួសារ ត្រូវទុកឱ្យគ្រួសារនោះប្រើប្រាស់។

ចំពោះបឹងធំៗដែលឋិតនៅក្រៅដែននេសាទ "ហើយមានការពាក់ព័ន្ធដល់ឃុំជាច្រើននៅក្នុងស្រុកតែមួយនោះ ត្រូវស្រុកគ្រប់គ្រង និងប្រើប្រាស់ ប្រសិនបើពាក់ព័ន្ធដល់ស្រុកច្រើន ត្រូវខេត្តគ្រប់គ្រង និងប្រើប្រាស់"។

ការប្រើប្រាស់បឹងធំៗនេះ ត្រូវផ្អែកទៅលើទម្លាប់របស់មូលដ្ឋានដែលបម្រើផលប្រយោជន៍រួមរបស់ប្រជាពលករ។

**មាត្រា១០ អំពីវាលស្មៅធម្មជាតិ**

វាលស្មៅធម្មជាតិដែលឋិតនៅក្នុងមូលដ្ឋានណា ត្រូវរដ្ឋអំណាចមូលដ្ឋាននោះគ្រប់គ្រងសម្រាប់សត្វ។

**មាត្រា១១ អំពីដីនៅទំនេរមិនទាន់បង្កបង្កើនផល**

ដីកសិកម្មចោលទំនេរ និងដីមិនទាន់កាប់ឆ្ការឋិតនៅមូលដ្ឋានណា ត្រូវមូលដ្ឋាននោះមានផែនការប្រើប្រាស់ និងគ្រប់គ្រងឱ្យបានសមស្រប មិនត្រូវទុកឱ្យនៅទំនេរ ឬធ្វើជាកម្មសិទ្ធិរបស់បុគ្គលណាមួយឡើយ។

រដ្ឋត្រូវជួយឧបត្ថម្ភដល់ក្រុមសាមគ្គីបង្កបង្កើនផល កសិដ្ឋានរដ្ឋ ស្ថាប័ននានាប្រជាជននៅទីក្រុង ទីរួមខេត្ត ក្នុងការស្តារដីចោលទំនេរ និងរានដីថ្មី។

ដើម្បីពង្រីកផលិតកម្មកសិកម្ម អ្នកដែលបានសុំស្តារដី ឬរានដីថែម គឺគ្មានបង់ប្រាក់អ្វីទាំងអស់។ ការអនុញ្ញាតឱ្យខ្ចីដីសម្រាប់បង្កបង្កើនផល លើផ្ទៃដីដែលមិនទាន់ដាំដុះដូចខាងលើត្រូវមានរយៈពេលកំណត់ពី៣ ទៅ៥ឆ្នាំ យោលទៅលើកម្លាំងពលកម្ម សម្ភារៈដែលចំណាយទៅលើការងារនោះ។ ត្រូវបានលើកលែងវិភាគទានស្នេហាជាតិក្នុងរយៈពេល២ឆ្នាំ ចំពោះដីដែលបានស្តារឡើងវិញ និង៥ឆ្នាំ ចំពោះដីទើបបានរានថ្មី។

**មាត្រា១២ អំពីដីស្ថាបនាសំណង់**

ការផ្តល់ដីសម្រាប់ស្ថាបនាសំណង់នានា ត្រូវសម្រេចដោយក្រុមប្រឹក្សារដ្ឋមន្ត្រី ឬគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង ដោយផ្អែកលើគម្រោងប្លង់នៃសំណង់ដែលស្ថាប័នមានសមត្ថកិច្ចបានសម្រេច។

ការផ្តល់ដីសម្រាប់ស្ថាបនាសំណង់នៅក្នុងភូមិ ឃុំ-សង្កាត់ ត្រូវគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង សម្រេចតាមសំណើរបស់គណៈកម្មាធិការប្រជាជនបដិវត្តស្រុក-ខណ្ឌ ទីរួមខេត្ត ឃុំ-សង្កាត់។

ការយកដីសម្រាប់ស្ថាបនាសំណង់ ត្រូវជូនដំណឹងទៅអ្នកកាន់កាប់ដីនោះ មួយរដូវបង្កបង្កើនផលជាមុន ម្ចាស់សំណង់ថ្មីនេះត្រូវសហការជាមួយរដ្ឋអំណាចមូលដ្ឋានក្នុងការសម្របសម្រួលចំពោះការបង់ខាតរបស់អ្នកកាន់កាប់នោះ។

**មាត្រា១៣ អំពីសិទ្ធិផ្តល់ដីសម្រាប់សំណង់**

-គណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង មានសមត្ថកិច្ចផ្តល់ដីពី៥ហិកតាចុះមក។

-ការផ្តល់ដីពី៥ហិកតាឡើងទៅ ជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។

**មាត្រា១៤ អំពីការខ្ចីដីសម្រាប់បង្កបង្កើនផល**

-ចំពោះមូលដ្ឋានណាដែលមានដីធ្លីច្រើន រួមទាំងដីសំណង់ចាស់បោះបង់ចោល ហើយពុំទាន់មានលទ្ធភាពធ្វើអស់ផ្ទៃដី ត្រូវឱ្យមូលដ្ឋានផ្សេងៗទៀតខ្វះដី ខ្ចីដីដើម្បីបង្កបង្កើនផល។

-ក្រុមសាមគ្គីបង្កបង្កើនផលដែលធ្វើមិនអស់ផ្ទៃដី ត្រូវឱ្យគ្រួសារសមាជិកក្រុម ឬក្រុមផ្សេងៗទៀត ខ្ចីដីដែលសល់ដើម្បីបង្កបង្កើនផល។ ក្រោយពេលប្រមូលផលរួចហើយ ត្រូវសងដីនោះឱ្យក្រុមសាមគ្គីវិញ។

## ជំពូកទី៣ ទោសប្បញ្ញត្តិ

**មាត្រា១៥**

ជនណាទិញ លក់ បញ្ចាំ ប្រវាស់ ជួលដី និង/ឬជួលពលករធ្វើដីបឹង ទោះក្រោមរូបភាពណាក៏ដោយត្រូវផ្តន្ទាទោសតាមច្បាប់រដ្ឋបាល។

**មាត្រា១៦**

*វាយឡើងវិញ*

ជនណាកាប់គាស់ រាន ឬឆ្ការព្រៃ ដោយគ្មានការអនុញ្ញាតយកទៅធ្វើស្រែចម្ការ ឬធ្វើអាជីវកម្មផលរ៉ែនៅក្នុងដី និងនៅកន្លែងដែលមានបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ ត្រូវទទួលទោសតាមច្បាប់ជាធរមាន។

## ជំពូកទី៤ បទប្បញ្ញត្តិជាអវសាន

**មាត្រា១៧**

ក្រសួងកសិកម្ម គណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន។

**មាត្រា១៨**

អនុក្រឹត្យនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃដែលប្រកាសផ្សាយជាសាធារណៈ។

<u>កន្លែងទទួល</u>

-ខុទ្ទកាល័យមជ្ឈិមបក្ស ដើម្បីជ្រាបជាព័តិមាន
-ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ
-ឯកសារ

ភ្នំពេញ ថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៨៥

**ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី**

**ប្រធាន**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

<u>ចម្លងជូន</u>

-គ្រប់គណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង
"ដើម្បីអនុវត្ត"
-ឯកសារ

លេខ៧៧ចល

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៨៥

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី**

**អនុរដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ប៊្យាស់ លាស់**

*វាយឡើងវិញ*

**សេចក្តីណែនាំ/២២៤៦ ឧសក/មក/បស/ថ្ងៃទី២៤ សីហា ១៩៨៧**

## សេចក្តីណែនាំស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

ក្នុងរបបបដិវត្តយើង សម្ព័ន្ធ រោងចក្រ ក្រុមហ៊ុន និងមធ្យោបាយដឹកជញ្ជូនទុព្វសម្ភារៈបរិក្ខារព្រមទាំងវត្ថុធាតុដើម ដែលឋិតនៅក្នុងមូលដ្ឋាន ផលិតកម្មទាំងនោះគឺជាទ្រព្យសម្បត្តិរបស់ប្រជាជនដែលមានរដ្ឋគ្រប់គ្រងតាមរយៈកម្មាភិបាល តាំងពីជួរថ្នាក់ដឹកនាំក្រសួង រហូតដល់កម្មាភិបាលគ្រប់ជាន់ថ្នាក់ក្នុងអង្គភាពផលិតកម្មនីមួយៗ។ ទ្រព្យសម្បត្តិដូចលើកឡើងនេះគឺជាមូលដ្ឋានសម្ភារៈមួយផ្នែកដ៏មានតម្លៃ និងជាប្រភពនៃកម្លាំងសេដ្ឋកិច្ច ដើម្បីរួមចំណែកធានាកិច្ចការពារ និងកសាងមាតុភូមិឆ្លងកាត់អន្តរកាល ជាជំហានៗឡើងលទ្ធិសង្គមនិយម និងលើកស្ទួយជីវភាពរបស់ប្រជាជនឱ្យបានកាន់តែល្អប្រសើរឡើងថែមទៀត។

ដោយយល់ជ្រួតជ្រាបច្បាស់ពីបញ្ហានេះ ក្រសួង និងអង្គភាពចំណុះទាំងអស់បានឯកភាពគ្នាលើទស្សនៈចាត់តាំង និងសកម្មភាពក្នុងការដាក់វិធានការការពារ ថែរក្សា ទ្រព្យសម្បត្តិរដ្ឋចេញសារាចរ និងសេចក្តីកំណត់ណែនាំជាបន្តបន្ទាប់ សកម្មរួមចំណែកបង្កើតអង្គការត្រួតពិនិត្យរបស់ប្រជាជនតាមមូលដ្ឋានបានមួយចំនួន ព្យាយាមជំរុញការងារ អង្កេតសម្ភារៈបរិក្ខារទំនិញ វត្ថុធាតុដើមតាមដំណាក់កាលនីមួយៗបានម៉ត់ចត់ល្អ និងបង្កើតចំនួនយុទ្ធនាការចុះត្រួតពិនិត្យផ្ទាល់ដល់ទីកន្លែងទទួលបានលទ្ធផលល្អគួរជាទីពេញចិត្ត និងកាត់បន្ថយបាននូវការអន្តរាយ ការបាត់បង់ ការខ្ជះខ្ជាយទ្រព្យសម្បត្តិរដ្ឋ។

ប៉ុន្តែទន្ទឹមនឹងនេះ ក៏នៅមានចំណុចខ្វះខាតជាអត្តនោម័តកម្មាភិបាលគ្រប់គ្រងអង្គភាព ការិយាល័យ ផ្នែក និងក្រុមផលិតកម្មមួយចំនួនដូចជា៖

១-ការថមថយគុណភាពខាងផ្នែកសីលធម៌រស់នៅបដិវត្ត បណ្តាលឱ្យបាត់បង់កិត្យានុភាពដឹកនាំ គ្រប់គ្រងរបស់ខ្លួន ញ៉ាំងឱ្យបុគ្គលិកកម្មករមានការស្រកស្រុតថាមពលក្នុងពលកម្ម ហើយបែរជាមានជំងឺប្រៀបធៀបចាប់ប្រព្រឹត្តនូវបាតុភាពអសកម្ម ប៉ះពាល់ទ្រព្យសម្បត្តិរដ្ឋតាមគំរូអាក្រក់នេះទៅវិញ។

២-ការធ្លាក់ចុះនូវស្មារតីទទួលខុសត្រូវ និងសម្បជញ្ញៈការងារដោយធូររលុង បណ្តែតបណ្តោយឱ្យខូចខាតគ្រឿងចក្រ គ្រឿងម៉ាស៊ីន បាត់បង់វត្ថុធាតុដើម និងសម្ភារៈផ្សេងៗជាបន្តបន្ទាប់។

៣-អគ្គនាយកមិនកសាងតម្លៃដើមឱ្យបានត្រឹមត្រូវ មានការបំប៉ោងតម្លៃវត្ថុធាតុដើមទិញចូល ឬបន្ទាប់តម្លៃលក់ផលិតផលសម្រេច ដោយមិនបញ្ចូលមុខចំណាយផលិតឱ្យបានគ្រប់គ្រាន់ដើម្បីកេងយកប្រាក់លំអៀង។

៤-ការឃុបឃិត ឬធ្វេសប្រហែសមិនព្រមចុះធ្វើការត្រួតពិនិត្យបណ្តាលឱ្យបណ្តាផ្នែកផលិតកម្ម ចំណុះ ល្មើសសន្ទស្សន៍គុណភាព ដោយលួចកែប្រែបច្ចេកវិជ្ជាដើម្បីបង្កើនចំនួនផលិតផលសម្រេចឱ្យលើសបរិមាណដែលបានកំណត់ សម្រាប់ចែកចាយធ្វើប្រជាភិថុតដល់បុគ្គលក្រុម និងអង្គភាពរបស់ខ្លួន។

៥-ភាពស្លាប់ក្រឡានៃរូបភាព និងវិធីសាស្ត្រគ្រប់គ្រង ដែលជាបច្ច័យអាក្រក់នៃការខ្វះសមត្ថភាពលើគ្រប់វិស័យរបស់ខ្លួន។

អាស្រ័យហេតុនេះ ក្នុងគោលបំណងរាំងខ្ទប់នូវបាតុភាពបាត់បង់ទ្រព្យសម្បត្តិរដ្ឋ ដែលបណ្តាលមកពីមូលហេតុដូចបានលើកខាងលើ ហើយដែលទាមទារចាំបាច់ត្រូវតែកែលំអជាបន្ទាន់ដើម្បីបង្កើនប្រសិទ្ធភាពគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋឱ្យបានគង់វង់នោះ ក្រសួងមានវិធានការមួយចំនួនដូចតទៅ ដើម្បីបំពេញបន្ថែមទៅលើសារាចរ និងសេចក្តីកំណត់ណែនាំមុនៗ ស្តីពីបញ្ហានេះដល់អង្គភាពចំណុះដើម្បីទុកជាទិសសម្រាប់អនុវត្តៈ

**ក.វិធានការអប់រំ**

បណ្តាសមមិត្តទទួលខុសត្រូវ សាខាបក្ស ក្រុមស្នូល សម្ព័ន្ធយុវជន និងសហជីពក្នុងអង្គភាពនីមួយៗ ត្រូវមានវិធានការអប់រំសមាជិករបស់ខ្លួនគ្រប់រូប ឱ្យមានការភ្ញាក់រឭកដោយខ្លួនឯងក្នុងការអនុវត្ត ដោយម្ចាស់ការច្នៃប្រឌិត និងមានលទ្ធផលល្អ នូវភារកិច្ចការពារទ្រព្យសម្បត្តិរដ្ឋ។

អប់រំបំពាក់បំប៉នចំណេះដឹងខាងនយោបាយ វប្បធម៌ បច្ចេកទេស ទស្សនៈ គោលជំហរ អាកប្បកិរិយា សីលធម៌របស់វណ្ណៈកម្មករ ដើម្បីធ្វើឱ្យគេក្លាយទៅជាមនុស្សថ្មីសង្គមនិយម សំដៅបង្កើនសមត្ថភាព និងលើកកម្ពស់មនសិការធ្វើម្ចាស់សមូហភាពរបស់គេ ធ្វើឱ្យគេក្លាយជាកម្លាំង

ចលករសំខាន់បំពេញបានយ៉ាងល្អបំផុត នូវគ្រប់ភារកិច្ចដែលថ្នាក់លើប្រគល់ជូន ជាពិសេសមានភារកិច្ចការពារទ្រព្យសម្បត្តិរដ្ឋ។

ទទួលបាននូវការអប់រំ និងយល់ដឹងខាងលើនេះ ទើបមហាជន ពលករយើងចេះគោរពស្រឡាញ់ពលកម្ម មានគុណធម៌បដិវត្ត មានស្មារតីសន្សំសំចៃ មិនខ្ជះខ្ជាយសម្ភារៈ វត្ថុធាតុដើម និងផលិតផលសម្រេច ឧស្សាហ៍ព្យាយាម ស្អាតស្អំ សកម្មការពារទ្រព្យសម្បត្តិរដ្ឋ ពង្រីកសិទ្ធិធ្វើម្ចាស់សមូហភាពរបស់គេប្រឆាំងទប់ទល់នឹងសតិអារម្មណ៍សួនតួនិយម គិតតែផលប្រយោជន៍ផ្ទាល់ខ្លួន។ ត្រូវអប់រំឱ្យចេះគួបផ្សំបានត្រឹមត្រូវនូវផលប្រយោជន៍៣ គឺផលប្រយោជន៍របស់គេជាពលករម្នាក់ៗ ផលប្រយោជន៍សមូហភាព អង្គភាព និងផលប្រយោជន៍របស់ប្រជាជនទាំងមូល ហើយផ្ដើមចេញពីនេះ គេនឹងយល់ច្បាស់ថាការប្រើប្រាស់ខ្ជះខ្ជាយទ្រព្យសម្បត្តិរដ្ឋ លួចទ្រព្យសម្បត្តិរដ្ឋធ្វើជាទ្រព្យផ្ទាល់ខ្លួនរបស់គ្រួសារ គឺក្បត់ប្រជាជន និងមានទោសចំពោះប្រជាជន។

**ខ.វិធានការបច្ចេកទេស**

ថ្នាក់គ្រប់គ្រង សម្ព័ន្ធ ក្រុមហ៊ុន រោងចក្រ ត្រូវម្ចាស់ការបង្កើតឱ្យបាននូវបទបញ្ជាគ្រប់គ្រងថែទាំប្រើប្រាស់គ្រឿងចក្រ គ្រឿងម៉ាស៊ីន សម្ភារៈបរិក្ខារវត្ថុធាតុដើម ដោយអនុវត្តរបៀបរបបកត់ត្រាឱ្យបានត្រឹមត្រូវ និងប្រគល់សិទ្ធិទទួលខុសត្រូវតាមផ្នែក តាមថ្នាក់ និងបុគ្គលឱ្យបានច្បាស់លាស់ ដោយចងក្រងជាខ្សែរយៈទទួលខុសត្រូវតាមរូបភាពចុះកិច្ចសន្យាដែលជាការមួយចាំបាច់បំផុត ដើម្បីបង្ខំឱ្យបណ្ដាផ្នែកផលិតកម្ម បណ្ដាថ្នាក់ បុគ្គលចូលរួមចំណែកទទួលខុសត្រូវចៀសវាងកុំឱ្យមានទស្សនៈពឹងផ្អែក និងឆ្លើយដាក់គ្នា។

ខាងក្រោមនេះគឺជាការបញ្ជាក់មួយចំនួន ដើម្បីងាយស្រួលក្នុងការអនុវត្តជាក់ស្ដែង៖

ផ្នែកឃ្លាំងវត្ថុធាតុដើម ត្រូវវិធានាតាមកិច្ចសន្យាផ្ដល់វត្ថុធាតុដើមឱ្យផ្នែករៀបចំ ឬលាយផ្សំតាមបរិមាណ និងគុណភាពដែលបានកំណត់។ ក្នុងករណីនេះ អង្គភាពនីមួយៗត្រូវទិញចូលនូវឧបករណ៍វិទ្យាសាស្ត្រ និងរង្វាស់រង្វាល់គ្រប់ប្រភេទដើម្បីវាស់ស្ទង់គុណភាព និងបរិមាណវត្ថុធាតុដើមឱ្យបានត្រឹមត្រូវ ដែលក្នុងពេលបច្ចុប្បន្នអង្គភាពរបស់ខ្លួនពុំទាន់មានគ្រប់គ្រាន់។

-ផ្នែករៀបចំ ឬលាយផ្សំត្រូវវិធានាផ្ដល់តាមកិច្ចសន្យាឱ្យផ្នែកផលិតនូវផលិតផលពាក់កណ្ដាលសម្រេចតាមបរិមាណ និងគុណភាពដែលបានកំណត់ក្នុងបទដ្ឋាន និងក្នុងសន្ទស្សន៍គុណភាព។

-ផ្នែកបង្កើយត្រូវធានាផ្តល់តាមកិច្ចសន្យាឱ្យផ្នែកឃ្លាំងផលិតផលសម្រេចនូវផលិតផលសម្រេចតាមបរិមាណ និងគុណភាពដែលបានកំណត់ក្នុងបទដ្ឋាន និងក្នុងសន្ទស្សន៍គុណភាព។

-ក្នុងន័យចៀសវាងការបាត់បង់ពេលវេលា កិច្ចសន្យានេះត្រូវធ្វើរួមគ្នាតែមួយ និងអូសរ៉ូណេអូឱ្យហើយ ជូនដល់បណ្តាផ្នែកផលិតកម្មពាក់ព័ន្ធដើម្បីបំពេញបន្ថែម និងចុះហត្ថលេខាតែប៉ុណ្ណោះ។

**គ. វិធានការសេដ្ឋកិច្ច**

ស្មារតីភ្ញាក់រឭករបស់កម្មាភិបាល បុគ្គលិក កម្មករអាចស្ថិតស្ថេរបាន ក៏អាស្រ័យដោយគំនាស់សេដ្ឋកិច្ចដែលជាកត្តាគន្លឹះ និងមានឋាមពលដ៏ស័ក្តិសិទ្ធិក្នុងការលើកកម្ពស់ស្មារតី ការពារទ្រព្យសម្បត្តិរដ្ឋ និងជំរុញល្បឿនអភិវឌ្ឍរបស់ប្រទេសជាតិ។ វិធានការសេដ្ឋកិច្ចមានឥទ្ធិពលលើគ្រប់វិស័យជីវភាពសង្គមដែលទាមទារត្រូវតែសកម្ម ឈឺឆ្អាលដោះស្រាយនូវរាល់បញ្ហាដែលពាក់ព័ន្ធនឹងពលកម្ម ព្រមទាំងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលករ។

ចំពោះមុខ ត្រូវជំនះឱ្យបាននូវរាល់ការលំបាកដើម្បីដោះស្រាយហូបបាយមួយពេល នៅពាក់កណ្តាលវេនផលិតកម្ម។ យកចិត្តទុកដាក់កសាងលំដាប់ថ្នាក់បច្ចេកទេស បទដ្ឋានពលកម្មឱ្យបានឆាប់រហ័ស ដើម្បីកែលំអការផ្តល់ប្រាក់បៀវត្ស និងប្រាក់កម្រៃជូនពលករឱ្យបានសមស្រប។ យកចិត្តទុកដាក់ជំរុញ អនុវត្ត សម្រេច និងលើកផែនការដើម្បីឱ្យពលករអាចទទួលបានប្រាក់រង្វាន់ថែមទៀត។

**ឃ. វិធានការរដ្ឋបាល**

ក្នុងករណីដែលមានការបាត់បង់ ឬខូចខាតវត្ថុធាតុដើមត្រូវរកឱ្យឃើញជាបន្ទាន់នូវជនប្រព្រឹត្តបទល្មើសហើយវិនិច្ឆ័យឱ្យបានតឹងរ៉ឹង និងប្រកបដោយយុត្តិធម៌។

ចំពោះការប៉ះពាល់ទ្រព្យសម្បត្តិរដ្ឋ ជនប្រព្រឹត្តបទល្មើសត្រូវទទួលវិន័យតាមកម្រិតបទល្មើសដូចតទៅ៖

-ត្រូវធ្វើការក្រើនរំឭក ស្តីបន្ទោស និងចាប់បង្ខំជនប្រព្រឹត្តបទល្មើសឱ្យសារភាពកំហុសព្រមទាំងចុះខសន្យាប្តេជ្ញាកែប្រែ។

-ត្រូវធ្វើការព្រមាន និងចាប់បង្ខំឱ្យសារភាពកំហុស ព្រមទាំងចុះខសន្យាប្តេជ្ញាកែប្រែ។

-ត្រូវប្រគល់ខ្លួនឱ្យផ្នែករដ្ឋបាល អង្គភាពដើម្បីសួរចម្លើយ និងធ្វើកំណត់ហេតុជូនក្រុមប្រឹក្សាវិន័យរបស់អង្គភាពនោះ ដើម្បីវិនិច្ឆ័យ និងផ្ដើមមតិអំពីវិធានការដោះស្រាយ ស្នើឡើងក្រុមប្រឹក្សាវិន័យក្រសួង។

ចំពោះជនណាដែលរំលោភលើមុខងារ សិទ្ធិអំណាចរបស់ខ្លួនដើម្បីប៉ះពាល់ ឬប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ ក្នុងគោលដៅទាញយកកម្រៃផ្ទាល់ខ្លួន និងមានឧបាយកលពិសពុល បំផ្លិចបំផ្លាញយ៉ាងគ្រោះថ្នាក់បណ្ដាលឱ្យមានការអន្តរាយខាងសម្ភារៈ និងផលវិបាកធ្ងន់ធ្ងរ និងត្រូវឃាត់ខ្លួនបញ្ជូនទៅស្ថាប័នមានសមត្ថកិច្ចដើម្បីវិនិច្ឆ័យទោសតាមច្បាប់ជាធរមាន។

ទន្ទឹមនេះដែរ ក្រសួងមានសំណូមពរដល់បណ្ដាកម្មាភិបាលទទួលខុសត្រូវគ្រប់ជាន់ថ្នាក់ក្នុងអង្គភាពនីមួយៗ ត្រូវមានការមធ្យ័តចំពោះខ្លួន ត្រូវរាំងខ្ទប់ដោយខ្លួនឯងនូវជំងឺនាម៉ឺននិយម និងបុគ្គលនិយម ហើយធ្វើជាគំរូល្អដល់មហាជនពលករ គឺមានន័យថា បើមានបុណ្យសក្ដិ និងសិទ្ធិអំណាចត្រូវបង្ការជំងឺអាងបុណ្យសក្ដិ និងសិទ្ធិអំណាច បើមានតួនាទីគ្រប់គ្រងអង្គភាពសេដ្ឋកិច្ចដែលមានទំនិញ និងប្រាក់កាសច្រើនគឺត្រូវបង្ការជំងឺលួចកឹបកេងទ្រព្យសម្បត្តិរដ្ឋ។

ដើម្បីធានាការអនុវត្តឱ្យបានខ្លាំងក្លាជាប់ជានិច្ច នូវវិធានការទាំងបួនខាងលើដែលពាក់ព័ន្ធនិងកិច្ចការការពារទ្រព្យសម្បត្តិរដ្ឋ ក្រសួងនឹងកំណត់ចាត់តាំងក្រុមប្រតិបត្តិការពិសេសចំនួន២ក្រុមក្នុងចំណោមកម្មាភិបាលនៃនាយកដ្ឋានសេនាធិការមួយចំនួន ដើម្បីសហការស្និតល្មួតជាមួយក្រុមប្រតិបត្តិការបទដ្ឋាននៃសាមីអង្គភាព សំដៅចុះស្រាវជ្រាវ និងកែសម្រួលនូវការខុសឆ្គងរបស់បណ្ដាអង្គភាពចំណុះ។

ក្នុងគោលដៅបង្កលក្ខណៈងាយស្រួល ដើម្បីអនុវត្តសេចក្ដីណែនាំរបស់ក្រសួងនេះ សម្ព័ន្ធក្រុមហ៊ុន រោងចក្រទាំងអស់ត្រូវមានវិធានការរៀបចំកម្មាភិបាលគ្រប់គ្រងឡើងវិញ ដើម្បីធានាគុណភាព និងសមត្ថភាព។

ក្រោយពីបានទទួលសេចក្ដីណែនាំនេះ គ្រប់អង្គភាពចំណុះត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងស៊ីជម្រៅទៅក្នុងជួរមហាជនពលករជាបន្ទាន់ ហើយចាត់តាំងអនុវត្តឱ្យបានម៉ត់ចត់ត្រឹមត្រូវរួចរាយការណ៍អំពីលទ្ធផលដែលទទួលបាន និងការលំបាកក្នុងការអនុវត្ត ដោយបញ្ចូលទៅក្នុងរបាយការណ៍ប្រឡងប្រណាំង ហើយផ្ញើឡើងក្រសួងតាមកាលបរិច្ឆេទកំណត់។

**បក្សប្រជាជនបដិវត្តកម្ពុជា**

## សេចក្តីសម្រេចចិត្តស្តីពីគោលនយោបាយចំពោះកសិករ

### I-សភាពការណ៍រួមរបស់កសិករកម្ពុជា

ប្រវត្តិសាស្ត្រកន្លងមកបានបញ្ជាក់ឱ្យយើងឃើញច្បាស់ថា វណ្ណៈកសិករកម្ពុជាមានតួនាទីដ៏ធំធេងក្នុងបុព្វហេតុកសាង និងការពារមាតុភូមិ។ កសិករយើងដែលមានចំនួនភាគច្រើនដាច់ខាត "ជាង៨០ភាគរយ" នៃប្រជាជនក្នុងសង្គមកម្ពុជាទាំងមូលធ្លាប់មានការតស៊ូអំណត់ និងឧស្សាហ៍ព្យាយាម ស្រឡាញ់ពលកម្ម ថ្នៃប្រឌិតក្នុងពលកម្ម ផលិតកម្ម ដោយផ្សារភ្ជាប់ខ្លួននឹងខឿនផលិតកម្មតូចតាចនៃកសិកម្មប្រទេសយើង។

ក្រោមរបបជិះជាន់សង្កត់សង្កិនរបស់ពួកសក្តិភូមិ ពួកអាណានិគមនិយម ពួកចក្រពត្តិនិយម និងបរិវារ កសិករយើងបានរួមតស៊ូប្រយុទ្ធប្រឆាំងនឹងអំពើត្រួតត្រាជិះជាន់សង្កត់សង្កិន អំពើបង្ក្រាបរារាំងបង្ខាំងទុកឱ្យរស់នៅក្នុងជីវភាពលំបាកតោកយ៉ាក និងគ្មានសិទ្ធិសេរីភាព។ ជាងនេះទៅទៀតក្រោមការដឹកនាំរបស់បក្សប្រជាជនបដិវត្តកម្ពុជា កសិករយើងបានក្រោកតស៊ូប្រឆាំងនឹងរបបប្រល័យពូជសាសន៍ប៉ុលពត អៀង សារី ខៀវ សំផន ដែលបានធ្វើឱ្យសង្គមកម្ពុជាទាំងមូលក្រឡាប់ចាក់ខឿនសេដ្ឋកិច្ចសង្គមខ្ទេចខ្ទាំដល់ឫសគល់។

ក្រោយថ្ងៃរំដោះ៧ មករា ១៩៧៩ ក្រោមការដឹកនាំរបស់បក្សប្រជាជនបដិវត្តកម្ពុជា កសិករយើងក៏ដូចប្រជាជនទូទាំងប្រទេសមានសេចក្តីសោមនស្សរីករាយឥតឧបមា ដោយប្រជាជាតិបានទទួលឯករាជ្យ និងមានសេរីភាពពិតប្រាកដ ហើយខិតខំពុះពារឧបសគ្គគ្រប់បែបយ៉ាងដើម្បីស្តារ និងកសាងប្រទេសជាតិឱ្យចាកផុតពីគ្រោះទុរ្ភិក្ស និងធ្វើឱ្យជីវភាពរស់នៅមានស្ថិរភាពជាបណ្តើរៗឡើងវិញ។ ប៉ុន្តែ ដោយយើងមានមូលដ្ឋានសម្ភារៈបច្ចេកទេសតិចតួចស្តួចស្តើង ទ្រង់ទ្រាយផលិតកម្មតូច ការងារគ្រប់គ្រងនៅសាមញ្ញ ហើយកម្រិតយល់ដឹងអំពីបច្ចេកទេសរបស់កសិករយើងនៅទាប...។ល។ កសិករយើងនៅជួបប្រទះនឹងការលំបាកច្រើនក្នុងជីវភាពរស់នៅ ក៏ដូចជាក្នុងផលិតកម្មដែរ។

ដើម្បីឆ្លើយតបតាមបំណងប្រាថ្នារបស់កសិករ និងធ្វើឱ្យខឿនសេដ្ឋកិច្ចជាតិមានការរីកចម្រើនរឹងមាំងឆាប់រហ័សនោះ បក្សប្រជាជនបដិវត្តកម្ពុជាបានចាត់ទុកវិស័យកសិកម្មជាប្រៀបខ្លាំងនៃខឿនសេដ្ឋកិច្ចជាតិ និងបានកំណត់គោលនយោបាយសំខាន់ៗចំពោះកសិករដែលមានគោលបំណង និងសំណូមពរដូចខាងក្រោមសំដៅ៖

១-ការពារសិទ្ធិ និងផលប្រយោជន៍របស់កសិករដើម្បីពង្រីកសម្ព័ន្ធភាពជាយុទ្ធសាស្ត្ររបស់កសិករ កម្មករ និងបញ្ញវន្ត។

២-ប្រើប្រាស់ឱ្យអស់លទ្ធភាពកម្លាំងពលកម្ម ប្រភពទុន ទ្រព្យសម្បត្តិ ទេពកោសល្យរបស់កសិករដើម្បីលើកកម្ពស់ជីវភាពរស់នៅ និងរួមចំណែកធ្វើឱ្យជនបទមានការអភិវឌ្ឍជាជំហានសមស្របតាមការរីកចម្រើនរបស់បដិវត្តកម្ពុជា។

៣-ប្រើប្រាស់ និងពង្រីកឱ្យអស់នូវលទ្ធភាពដីធ្លី មធ្យោបាយ និងឧបករណ៍ផលិតកម្មដែលកសិករមាននាបច្ចុប្បន្ន និងទៅអនាគត។ បង្កលក្ខណៈឱ្យកសិករបានធ្វើម្ចាស់ពិតប្រាកដលើមធ្យោបាយ ឧបករណ៍ ការផលិត និងភោគផល។

៤-បង្កលក្ខណៈឱ្យពលករមួយចំនួនដែលប្រកបរបរអាជីវកម្ម ផលិតកម្មមិនច្បាស់លាស់ស្ម័គ្រចិត្តទៅបង្កបង្កើនផលកសិកម្ម។

**II-គោលនយោបាយរបស់បក្ស និងរដ្ឋចំពោះកសិករ និងកាតព្វកិច្ចរបស់កសិករចំពោះបក្ស និងរដ្ឋ**

**ក-គោលនយោបាយរបស់បក្ស និងរដ្ឋចំពោះកសិករ**

ដើម្បីលើកទឹកចិត្តកសិករអនុវត្តផលិតកម្ម អាជីវកម្មរីកចម្រើន រួមចំណែកក្នុងបុព្វហេតុការពារ និងកសាងមាតុភូមិ បក្ស និងរដ្ឋត្រូវយកចិត្តទុកដាក់ចំពោះកសិករ។

**១-អំពីអង្គការចាត់តាំង**

កសិករត្រូវមានអង្គការចាត់តាំងរបស់ខ្លួនមួយគឺសមាគមកសិករ ដែលជាអង្គការមួយតំណាងស្របច្បាប់សម្រាប់ចូលរួមមតិពិគ្រោះ ពិភាក្សា ការពារសិទ្ធិ និងផលប្រយោជន៍របស់កសិករលើរាល់សកម្មភាពការងារសង្គម។

**២-អំពីមធ្យោបាយ និងឧបករណ៍ផលិតកម្ម**

រដ្ឋត្រូវ៖

-ឱ្យកសិករមានសិទ្ធិកាន់កាប់ដីតាមច្បាប់ដែលរដ្ឋបានកំណត់។

-លើកទឹកចិត្តឱ្យកសិករប្រើប្រាស់ធនធានសម្ភារៈបរិក្ខារក្នុងស្រុក។ លើកទឹកចិត្តឱ្យក្រុមហ៊ុនពាណិជ្ជកម្មរដ្ឋ ឬឯកជននាំចូលបន្ថែមនូវមធ្យោបាយ និងសម្ភារៈកសិកម្មដែលមិនអាចផលិតក្នុងស្រុកបានដោយបន្ធូរបន្ថយពន្ធ ដើម្បីលក់ ឬជួលជូនកសិករ។

-វិនិយោគទុនសម្រាប់សំណង់ធារាសាស្ត្រធំ មធ្យោបាយ និងបើកទូលាយបណ្តាញគមនាគមដឹកជញ្ជូន។

-ខិតខំពង្រីកបន្ថែមនូវមូលដ្ឋានសម្ភារៈ បច្ចេកទេស វិទ្យាសាស្ត្រ សិក្សា និងកំណត់តំបន់ផលិតកម្ម កសិកម្ម និងណែនាំកសិករអនុវត្តវិទ្យាសាស្ត្រ បច្ចេកទេសទំនើបក្នុងផលិតកម្ម សំដៅនាំមកនូវប្រសិទ្ធភាពខ្ពស់។ លើកទឹកចិត្តការស្រាវជ្រាវឃើញបច្ចេកវិទ្យាថ្មី ពូជថ្មីដែលបម្រើផ្នែកកសិកម្ម។

-អនុញ្ញាត និងបង្កលក្ខណៈងាយស្រួលឱ្យកសិករខ្ចីទុនពីធនាគារសម្រាប់ផលិតកម្មអាជីវកម្ម។

**៣-អំពីថ្លៃ និងចរាចរកសិផល**

រដ្ឋត្រូវមានគោលនយោបាយថ្លៃឱ្យបានសមស្របទៅតាមតំបន់នីមួយៗ ដោយចាត់ទុកថានោះគឺជាគំនាស់សេដ្ឋកិច្ចមួយយ៉ាងសំខាន់ សំដៅលើកទឹកចិត្តប្រជាកសិករឱ្យខិតខំផលិត។ កសិករមានសិទ្ធិធ្វើចរាចរកសិផលដែលខ្លួនផលិតបាន និងលក់លើទីផ្សារ។

**៤-អំពីជីវភាពរស់នៅ**

រដ្ឋត្រូវ៖

-យកចិត្តទុកដាក់កែលំអជីវភាពរស់នៅរបស់កសិករជាបណ្តើរៗទាំងស្មារតី និងសម្ភារៈលើមូលដ្ឋាន ជំរុញការបង្កបង្កើនផល។

-យកចិត្តទុកដាក់ណែនាំ និងបង្កលក្ខណៈងាយស្រួលឱ្យកសិករបន្តប្រពៃណីជួយទំនុកបម្រុងគ្នាទៅវិញទៅមកតាមរបៀបវេរប្រវាស់ដៃ និងតាមទម្លាប់ផ្សេងៗទៀតរបស់ប្រជាជន។

-ចាត់តាំងការរៀនសូត្រនយោបាយ អប់រំសតិអារម្មណ៍ និងផ្សព្វផ្សាយសភាពការណ៍ថ្មី វិទ្យាសាស្ត្រ បច្ចេកទេសទំនើបជូនកសិករ។

-បើកទូលាយឱ្យកសិករចូលរួមប្រាស្រ័យក្នុងការកសាងកម្លាំងពិតបដិវត្ត និងចូលរួមមានមតិពិភាក្សាលើរាល់សកម្មភាពការងារកសិកម្ម និងសង្គមតាមរយៈអង្គការតំណាងរបស់ខ្លួន គឺសមាគមកសិករ។

-បើកទូលាយផ្នែកវប្បធម៌ សិល្បៈមហាជន ជំនឿសាសនាដែលមានចរិតស្នេហាជាតិ និងចម្រើនជឿនលឿន។

-យកចិត្តទុកដាក់ណែនាំកសិករឱ្យយល់ដឹងពីក្បួនអនាម័យ ការការពារ និងលើកកម្ពស់សុខភាព។ នៅតំបន់ដែលខ្វះទឹក ចាំបាច់ត្រូវជួយដោះស្រាយឱ្យកសិករមានទឹកប្រើប្រាស់ ដោយជីកអណ្តូង និងស្រះជាដើម រៀបចំគិលានដ្ឋាន កសាងមន្ទីរពេទ្យ និងបង្កើតបន្ថែមសាលារៀនចំណេះទូទៅ សាលាបច្ចេកទេសគ្រប់ផ្នែកនៅតាមមូលដ្ឋានដើម្បីឱ្យកសិករ និងកូនចៅគេបានទទួលការពិនិត្យព្យាបាលសុខភាព ក្រេបជញ្ជក់ចំណេះដឹង។ ក្នុងការសាងសង់ត្រូវបំផុសកសិករឱ្យជួយរួមចំណែក។ រដ្ឋត្រូវខិតខំធានាជូរកម្មាភិបាល សុខាភិបាល អប់រំ និងបច្ចេកទេស។

-ដោះស្រាយឱ្យបានសមស្របរចនាសម្ព័ន្ធចាត់តាំងផលិតកម្ម កែច្នៃ និងបែងចែកប្រើប្រាស់កសិផល។

-យកចិត្តទុកដាក់សម្រួលដល់កសិករឱ្យរៀបចំភូមិ ឬឃុំ លំនៅឋានបានសមស្របទៅតាមលក្ខណសម្បត្តិ និងលទ្ធភាពដីធ្លីនៃតំបន់នីមួយៗ។

-បើកទូលាយផែនការស្តារ និងពង្រីកគមនាគមន៍ដឹកជញ្ជូន។

-បើកទូលាយមុខរបរជំនាញសិប្បកម្មមូលដ្ឋាន កែច្នៃកសិផល និងមុខរបរផ្សេងទៀតតាមលទ្ធភាពរបស់តំបន់នីមួយៗ ក្នុងគោលបំណងដោះស្រាយឱ្យកសិករមានការងារធ្វើជាប្រចាំ។

-ជារួមរដ្ឋត្រូវធានាសិទ្ធិរស់នៅ និងប្រកបមុខរបររបស់កសិករតាមច្បាប់របស់រដ្ឋ។

**ខ-កាតព្វកិច្ចរបស់កសិករចំពោះបក្ស និងរដ្ឋ**

កសិករត្រូវ៖

-មានកាតព្វកិច្ចចូលរួមចំណែកគ្រប់សកម្មភាពបដិវត្ត។

-មានកាតព្វកិច្ចចូលរួមបង្កបង្កើនផល។

-មានកាតព្វកិច្ចបង់ពន្ធតាមច្បាប់របស់រដ្ឋ។

-រិះរកគ្រប់វិធីសាស្ត្រថែបំប៉នដីស្រែចម្ការ ដើម្បីប្រកបអាជីវកម្មឱ្យបានទិន្នផលខ្ពស់ផង និងឱ្យអស់ផ្ទៃដីដែលរដ្ឋបានប្រគល់ឱ្យគ្រប់គ្រងផង។

-មានស្មារតីថែរក្សារការពារឱ្យបានល្អនូវកេរតំណែលប្រវត្តិសាស្ត្រដែលមានក្នុងមូលដ្ឋាន។

III-**ការចាត់អនុវត្ត**

សេចក្ដីសម្រេចចិត្តនេះត្រូវផ្សព្វផ្សាយឱ្យបានស៊ីជម្រៅក្នុងបក្ស រដ្ឋ និងប្រជាជនដើម្បីកម្មាភិបាល បក្ខជន ប្រជាជនយល់ច្បាស់ និងអនុវត្តបានត្រឹមត្រូវ។

ក្រុមប្រឹក្សារដ្ឋមន្ត្រីត្រូវចេញគោលការណ៍ជាក់ស្ដែងដើម្បីឱ្យគ្រប់ផ្នែក គ្រប់ថ្នាក់ និងប្រជាជនអនុវត្តបានល្អនូវសេចក្ដីសម្រេចចិត្តនេះ។

សេចក្ដីសម្រេចចិត្តនេះជំនួសសេចក្ដីសម្រេចចិត្តសន្និបាតកម្មាភិបាលទូទាំងប្រទេសលើកទី I ស្ដីពីគោលនយោបាយចំពោះកសិករ។

**សន្និបាតកម្មាភិបាលទូទាំងប្រទេសលើកទី II**

ខែមេសា ឆ្នាំ១៩៨៩

**បក្សប្រជាជនបដិវត្តកម្ពុជា**

## សេចក្តីសម្រេចចិត្តស្តីពីគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី

### I-គោលបំណង និងសំណូមពរ

-ដើម្បីជំរុញឱ្យមានប្រសិទ្ធភាពខ្ពស់នូវការកែលំអដីធ្លី ការដាំដុះ ការធ្វើប្រពលវប្បកម្ម ការបង្កើនរដូវ ការចិញ្ចឹមសត្វ រុក្ខវប្បកម្ម វារីវប្បកម្ម ការការពារបរិស្ថានត្រូវធ្វើការកែលំអនូវការគ្រប់គ្រង ប្រើប្រាស់ដីធ្លីសមស្របនឹងសភាពការណ៍រីកចម្រើនរបស់បដិវត្តកម្ពុជា។

-នៅពេលណាដែលផលប្រយោជន៍របស់កសិករត្រូវបានធានា នៅពេលនោះទើបកសិករបញ្ចេញអស់កម្លាំងកាយចិត្តរបស់ខ្លួនធ្វើពលកម្ម ផលិតកម្ម ច្នៃប្រឌិតបង្កើននូវទ្រព្យសម្បត្តិ សម្ភារៈ ដើម្បីលើកស្ទួយជីវភាពខ្លួន និងសេដ្ឋកិច្ចជាតិ។

រដ្ឋត្រូវ៖

-បង្កគ្រប់លក្ខណៈដើម្បីឱ្យប្រជាជនមានលទ្ធភាពធ្វើផលិតកម្មដោយមានអារម្មណ៍នឹងនរក្នុងការគ្រប់គ្រង និងប្រើប្រាស់ដីធ្លីមានភាពម្ចាស់ការច្នៃប្រឌិតបង្កើនគុណភាពដីកាន់តែប្រសើរ និងទាញយកអត្ថប្រយោជន៍ដីដែលបានកាន់កាប់ពីមួយឆ្នាំទៅមួយឆ្នាំ ឱ្យបានកាន់តែខ្ពស់ជាលំដាប់។

-ធ្វើឱ្យកម្មាភិបាលគ្រប់ផ្នែក គ្រប់ថ្នាក់ និងប្រជាជនឃើញគុណប្រយោជន៍ដីក្នុងការស្តារពង្រីកកសិកម្ម និងផ្នែកសេដ្ឋកិច្ចផ្សេងទៀត។

-ធ្វើឱ្យប្រជាជនគ្រប់រូបស្គាល់កាតព្វកិច្ចរបស់ខ្លួនចំពោះរដ្ឋ និងយល់អំពីការសាមគ្គីជួយទំនុកបម្រុងគ្នាក្នុងការគ្រប់គ្រង និងប្រើប្រាស់ដីធ្លីសម្រាប់បង្កបង្កើនផលតាមគោលការណ៍កំណត់។

### II-គោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី

ដីធ្លីនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាជាកម្មសិទ្ធិរបស់រដ្ឋ។ រដ្ឋមានវិធានការកែលំអការគ្រប់គ្រង និងប្រើប្រាស់ដីធ្លីឱ្យមានប្រសិទ្ធភាព។

រដ្ឋត្រូវមានស្ថាប័នទទួលបន្ទុកការងារភូមិសាស្ត្ររដ្ឋបាល និងសុរិយោដី។

ជីវត្តអារាម ទីស្មសាន សាលារៀន មន្ទីរពេទ្យ ស្ថានីយពិសោធន៍ កសិដ្ឋានចាស់ៗ រោងចក្រ សហគ្រាស និងអតីតសំណង់ដែលមានមកហើយ ត្រូវទុកអាទិភាពរក្សាព្រំចាស់។

បឹងបួ ថ្លុក ត្រពាំង អូរ ព្រែក ស្ទឹង ទន្លេដែលឋិតក្រៅដែននេសាទកំណត់ដោយក្រសួងកសិកម្ម ដីទួលសាធារណៈ វាលស្មៅធម្មជាតិ ត្រូវប្រើប្រាស់ផ្អែកទៅតាមទម្លាប់របស់មូលដ្ឋាន។

បេតិកភណ្ឌវប្បធម៌ ប្រវត្តិសាស្ត្រជាតិ រ៉ែដែលមាននៅក្នុងដី នៅលើដី និងនៅបាតសមុទ្រ និងក្រោមសមុទ្រជាសម្បត្តិរបស់រដ្ឋ។

**១-អំពីការកំណត់បែងចែក**

ដីធ្លីទាំងអស់ត្រូវបានកំណត់បែងចែកជា៤ប្រភេទគឺៈ

**ក-ដីសម្រាប់សង់លំនៅឋាន**

គ្រួសារប្រជាជននីមួយៗត្រូវបានបែងចែកដីជូនមួយកន្លែងទំហំមិនលើសពី២.០០០ម$^{២}$ សម្រាប់សង់លំនៅឋានសមស្របតាមលក្ខណៈភូមិសាស្ត្រ និងលទ្ធភាពនៃមូលដ្ឋាននីមួយៗ។

គ្រួសារប្រជាជននៅតាមទីប្រជុំជន ទីរួមស្រុក-ខណ្ឌ ខេត្ត-ក្រុងអាចមានដីមួយឡូត៍ទំហំសមស្របតាមលទ្ធភាពជាក់ស្តែងសម្រាប់សាងសង់លំនៅឋាន។

ចំពោះជនភៀសខ្លួនកម្ពុជា ជនរួមជាតិកម្ពុជានៅបរទេសដែលបានវិលត្រលប់មកមាតុភូមិវិញ និងជនទាំងឡាយដែលបានបោះបង់ចោលជួរខ្មាំងវិលត្រលប់មកជាមួយប្រជាជន និងបដិវត្តិវិញនឹងត្រូវបានបែងចែកដីសម្រាប់សង់លំនៅឋានដូចខាងលើដែរ។

**ខ-ដីស្រែ និងចម្ការសម្រាប់ផលិតកម្ម-អាជីវកម្ម**

គ្រួសារកសិករដែលបានតស៊ូធ្វើស្រែចម្ការយ៉ាងតិច១ឆ្នាំជាប់រហូតមកទល់ថ្ងៃកំណត់នេះត្រូវបានបែងចែកដីស្រែចម្ការដែលមានស្រាប់តាមលទ្ធភាពនៃមូលដ្ឋាន វៀរលែងតែដីកសិដ្ឋានកៅស៊ូរដ្ឋដែលឱ្យប្រជាកសិករធ្វើអាជីវកម្មបណ្តោះអាសន្ន។

ចំពោះជនភៀសខ្លួនកម្ពុជា ជនរួមជាតិកម្ពុជានៅបរទេសដែលបានវិលត្រលប់មកមាតុភូមិវិញ និងជនទាំងឡាយដែលបានបោះបង់ចោលជួលខ្មាំងវិលត្រលប់មកជាមួយប្រជាជន និងបដិវត្តិវិញនឹងត្រូវបានបែងចែកដីស្រែចម្ការសល់ទំនេរ ឬដីសម្រាប់រានថ្មីស្របតាមលទ្ធភាពនៃមូលដ្ឋាននីមួយៗ។

ក្រៅពីដីស្រែចម្ការ ស្ថាប័នមានសមត្ថកិច្ចត្រូវបែងចែកដីសម្រាប់ដាំឈើតាមលក្ខណៈភូមិសាស្ត្រនៃមូលដ្ឋាននីមួយៗឱ្យគ្រួសារកសិករសម្រាប់ដាំដុះ និងទទួលផល ហើយត្រូវកំណត់ប្រភេទឈើដែលត្រូវដាំឱ្យបានច្បាស់លាស់។

**គ-ដីបម្រុងវត្តា និងនេសាទ**

ដីប្រភេទនេះត្រូវបានកំណត់ឱ្យបានច្បាស់លាស់បំផុត នូវព្រំប្រទល់ជាក់ស្តែងដែលមានផែនទីកំណត់ដោយស្ថាប័នមានសមត្ថកិច្ចថ្នាក់លើ ។

**ឃ-ដីបម្រុងរបស់រដ្ឋ**

ក្រៅពីដីទាំងបីប្រភេទខាងលើនេះជាដីបម្រុងរបស់រដ្ឋ ។ មូលដ្ឋាននីមួយៗត្រូវមានដីត្រៀមសម្រាប់ធ្វើលំនៅឋាន សំណង់ផ្សេងៗ សួនសាធារណៈ និងផ្លូវថ្នល់នាពេលអនាគត ។

**២-អំពីរូបភាពនៃការគ្រប់គ្រង និងប្រើប្រាស់ដីធ្លី**

សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីរួមមាន៖

ក-កម្មសិទ្ធិ៖ រដ្ឋផ្តល់ជូនដល់គ្រួសារនីមួយៗដែលបានបំពេញបែបបទតាមគោលការណ៍កំណត់របស់រដ្ឋនូវសិទ្ធិកម្មសិទ្ធិលើដីសម្រាប់សង់លំនៅឋាន ។

ខ-ភោគៈ៖ ក្រោយពីបានទទួលដីស្រែចម្ការហើយ គ្រួសារកសិករដែលបំពេញបែបបទតាមគោលការណ៍កំណត់ ដោយប្រើប្រាស់ទាញយកអត្ថប្រយោជន៍ឱ្យអស់ផ្ទៃដីក្នុងរយៈពេលមួយឆ្នាំហើយនោះ ទើបត្រូវបានផ្តល់ឱ្យសិទ្ធិភោគៈលើដីនោះ ។

គ-សម្បទាន៖ ចំពោះដីដែលលើសពីសិទ្ធិទាំងពីរខាងលើ រដ្ឋអាចប្រគល់ជាដីសម្បទានថែមទៀតដោយកំណត់រយៈពេលច្បាស់លាស់យោលទៅតាមមុខដំណាំ ។

សិទ្ធិកាន់កាប់ ប្រើប្រាស់ដីធ្លី "កម្មសិទ្ធិ ភោគៈ និងសម្បទាន" នឹងត្រូវកំណត់ដោយច្បាប់មួយដោយឡែក ។

**៣-អំពីកាតព្វកិច្ចរបស់ "កម្មសិទ្ធិករ ភោគី និងសម្បទានិក"**

ជារៀងរាល់ឆ្នាំ សាមីអ្នកប្រើប្រាស់ដីធ្លីត្រូវមានកាតព្វកិច្ចដូចតទៅ៖

-ទាញយកអត្ថប្រយោជន៍ពីដីឱ្យអស់ពីលទ្ធភាពដោយប្រើប្រាស់គ្រប់មធ្យោបាយ ។

-ធានាប្រើប្រាស់ ថែរក្សាដីធ្លីឱ្យមានការគង់វង្ស និងមានការរីកចម្រើន ។

-បង់ពន្ធ ឬបង់ឈ្នួលដីជូនរដ្ឋឱ្យបានទៀងទាត់បំផុតតាមអត្រា និងកាលកំណត់របស់រដ្ឋ ។

-ហាមឃាត់ការចាប់ដីទំនេរគ្រប់ប្រភេទ បង់ពន្ធទុកសម្រាប់លក់ និងជួលឱ្យអ្នកដទៃ ។

-គោរពតាមរាល់គោលការណ៍របស់រដ្ឋអំពីការគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ។

-ក្នុងករណីពិសេសដែលរដ្ឋត្រូវការដីដើម្បីសង់ ឬពង្រីកតំបន់សេដ្ឋកិច្ចសំខាន់ៗ ប្រជាជនជាម្ចាស់កម្មសិទ្ធិ ភោគី ឬសម្បទានិកនូវដីតំបន់នេះត្រូវបង្គ្រប់លក្ខណសម្បត្តិ បំពេញតាមសំណូមរបស់រដ្ឋ ដោយរដ្ឋគិតគូរគោលនយោបាយឱ្យបានសមស្រប និងឈរលើផលប្រយោជន៍ជាចម្បង។

-មិនឱ្យកេណ្ឌពលករធ្វើដីបម្រើផលប្រយោជន៍ឯកជន ប៉ុន្តែមានសិទ្ធិជួលពលកម្មមួយចំនួនទៀតបាននៅក្នុងពេលដែលផលិតកម្មមានភាពតឹងតែងតាមរដូវកាល និងមានសិទ្ធិជួលអ្នកណែនាំបង្ហាញខាងបច្ចេកទេសទៀតដែរ។

-មិនឱ្យមានសិទ្ធិជាឯកជនក្នុងដែនបម្រុងរុក្ខា នេសាទ អាងតម្កល់ទឹកស្រោចស្រព បរិវេណរ៉ែ មណ្ឌលបេតិកភណ្ឌវប្បធម៌ ប្រវត្តិសាស្ត្រជាតិ វត្តអារាម ទីស្មសាន សួន និងទួលសាធារណៈ ដីសម្រាប់ថ្នល់ សំណង់ផ្សេងៗ បឹង អូរ ព្រែក ស្ទឹង ទន្លេ សមុទ្រ។

**III- បង្កើនការដឹកនាំរបស់បក្សចំពោះការគ្រប់គ្រង និងប្រើប្រាស់ដីធ្លី**

-បក្សមានសំណូមពរដល់បក្ខជន និងកម្មាភិបាលគ្រប់ផ្នែក គ្រប់ថ្នាក់ឱ្យបានគ្រប់គ្នា និងផ្សព្វផ្សាយបានទូលំទូលាយក្នុងប្រជាជន មហាជន ដើម្បីបង្កើនការគ្រប់គ្រង និងប្រើប្រាស់ដី ជំរុញការបង្កបង្កើនផល កសាងកម្លាំងពិតបដិវត្តឱ្យបានរឹងមាំ កសាងជនបទថ្មី លើកកម្ពស់ការភ្ញាក់រឭករបស់មហាជន សំដៅវាយកម្ទេចរាល់ល្បិចកលបំផ្លិចបំផ្លាញរបស់កម្លាំងចំពោះបដិវត្តនៃប្រទេសយើង។

-រដ្ឋត្រូវចេញច្បាប់ និងបទកំណត់ច្បាស់ ធានាលក្ខណៈនៃសិទ្ធិកាន់កាប់ ប្រើប្រាស់ដីធ្លីឱ្យមានប្រសិទ្ធភាព សំដៅធ្វើឱ្យប្រជាជនមានអារម្មណ៍នឹងនរ រីករាយក្នុងផលិតកម្ម អាជីវកម្មសមស្របតាមទិសឈានឡើងបដិវត្តកម្ពុជា។

-ក្រុមប្រឹក្សារដ្ឋមន្ត្រីត្រូវធ្វើការណែនាំលំអិតស្តីពីការគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ឬចេញគោលការណ៍ជាក់ស្តែងដើម្បីឱ្យគ្រប់ផ្នែក គ្រប់ថ្នាក់ អង្គភាពបង្កបង្កើនផល និងប្រជាជនអនុវត្តបានល្អនូវសេចក្តីសម្រេចចិត្តរបស់សន្និបាតនេះ។

សេចក្តីសម្រេចចិត្តនេះ ជំនួសសេចក្តីសម្រេចចិត្តនៃសន្និបាតគណៈកម្មាធិការមជ្ឈិមបក្សលើកទី៩ អាណត្តិទី IV ស្តីពីការគ្រប់គ្រងដីធ្លីធ្វើកសិកម្ម។

**សន្និបាតកម្មាភិបាលទូទាំងប្រទេសលើកទី II**

ខែមេសា ឆ្នាំ១៩៨៩

**បក្សប្រជាជនបដិវត្តកម្ពុជា**

## សេចក្តីប្រកាស
## ស្តីពីគោលនយោបាយប្រកបរបរផលិតកម្ម អាជីវកម្ម កសិកម្ម
## តាមរបៀបវេរប្រវាស់ដៃ

ផ្អែកតាមស្មារតីនៃសេចក្តីសម្រេចចិត្តស្តីពីគោលនយោបាយចំពោះកសិករ គោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លីដែលសន្និបាតកម្មាភិបាលទូទាំងប្រទេសលើកទី II បានកំណត់។

ដើម្បីឱ្យកសិករជាអ្នកធ្វើម្ចាស់ពិតប្រាកដលើដីធ្លី លើការងារផលិតកម្ម អាជីវកម្ម មធ្យោបាយឧបករណ៍ពលកម្ម និងលើផលិតផលពលកម្ម ហើយមានការនឹងនរចិត្តក្នុងការរស់នៅប្រកបរបរចិញ្ចឹមជីវិត ពង្រឹងផលិតកម្ម កែលំអជីវភាពរស់នៅ និងអភិវឌ្ឍជនបទឱ្យរីកចម្រើនឆាប់រហ័ស។

បក្ស និងរដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាប្រកាសឱ្យកសិកររស់នៅប្រកបរបរចិញ្ចឹមជីវិតតាមរបៀបវេរប្រវាស់ដៃ ឬទៅតាមទម្លាប់ផ្សេងទៀតលើមូលដ្ឋាននៃការស្រុះស្រួលគ្នា សមស្របតាមប្រពៃណីទំនៀមទម្លាប់ល្អរបស់កសិករដែលធ្លាប់មានជាយូរលង់ណាស់មកហើយ។ បក្ស និងរដ្ឋលើកទឹកចិត្តការអនុវត្តប្រពលវប្បកម្ម និងការបញ្ចូលមធ្យោបាយ ឧបករណ៍ផលិតកម្ម វិទ្យាសាស្ត្រ បច្ចេកទេសទៅក្នុងវិស័យកសិកម្ម សំដៅលើកកម្ពស់ទិន្នផលពលកម្មឱ្យកើនឡើងជានិច្ច រួមចំណែកពង្រីកពង្រឹងខឿនសេដ្ឋកិច្ចសង្គមកិច្ចជាតិឱ្យកាន់តែមានស្ថិរភាព និងរឹងមាំ។

ស្ថាប័នបក្ស រដ្ឋអំណាច និងអង្គការមហាជននៅមូលដ្ឋានមានភារៈបំផុស អប់រំ លើកទឹកចិត្តប្រជាកសិករឱ្យយកចិត្តទុកដាក់ ជួយឧបត្ថម្ភទំនុកបម្រុងគ្រួសារយុទ្ធជននៅសមរភូមិមុខ គ្រួសារយុទ្ធជនពលី ពិការ និងគ្រួសារមានសគុណចំពោះបដិវត្ត ជនឥតទីពំនាក់អាស្រ័យទៅតាមប្រពៃណីដែលធ្លាប់មានស្រាប់របស់ប្រជាជន សំដៅធ្វើឱ្យគ្រប់គ្រួសារនៅជនបទបានរស់នៅ និងរីកចម្រើនឡើងដោយសុខដុមរមនា។

*វាយឡើងវិញ*

សេចក្តីប្រកាសនេះជំនួសសេចក្តីសម្រេចចិត្តរបស់សន្និបាតគណៈកម្មាធិការមជ្ឈិមបក្សលើកទី៧ អាណត្តិទី IV ស្តីពីសភាពការណ៍ និងភារកិច្ចពង្រឹងក្រុមសាមគ្គីបង្កបង្កើនផល។ ឯក្រុមសាមគ្គីបង្កបង្កើនផលដែលបានចាត់តាំងរួចមក ហើយត្រូវប្រែក្លាយជារូបភាពចាត់តាំងក្រុមប្រជាជន ដើម្បីគ្រប់គ្រងរដ្ឋបាល ជីវភាពនយោបាយ សតិអារម្មណ៍ និងអនុវត្តភារកិច្ចវាយខ្មាំង ការពារមូលដ្ឋាន។

**សន្និបាតកម្មាភិបាលទូទាំងប្រទេសលើកទី II**

ខែមេសា ឆ្នាំ១៩៨៩

រដ្ឋកម្ពុជា

ក្រុមប្រឹក្សារដ្ឋមន្ត្រី ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

លេខ២៥អនក្រ

ភ្នំពេញ ថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៨៩

## អនុក្រឹត្យ
## ស្តីពីការផ្តល់កម្មសិទ្ធិលើផ្ទះជូនពលរដ្ឋកម្ពុជា

## ក្រុមប្រឹក្សារដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា
- បានឃើញច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ០៣ក្រ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២
- បានឃើញក្រឹត្យច្បាប់លេខ០៧ក្រច ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៨២ ស្តីពីសមត្ថកិច្ច និងនីតិវិធីនៃការធ្វើច្បាប់ និងបទបញ្ជា
- បានឃើញអនុក្រឹត្យលេខ០១អនក្រ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៨១ ស្តីពីរបៀបរៀបរយសាធារណៈក្នុងរដ្ឋធានី
- បានឃើញអនុក្រឹត្យលេខ០៣អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៨២ ស្តីពីតម្លៃឈ្នួលផ្ទះក្នុងទីក្រុងភ្នំពេញ

## សម្រេច

### មាត្រា១

ដីសង់លំនៅឋាន និងអគារធំ តូច ផ្ទះជាភូមិគ្រឹះ ផ្ទះដាច់ដោយឡែកឯទៀត ឬផ្ទះល្វែងទាំងអស់ក្នុងទូទាំងសាធារណរដ្ឋប្រជាមានិតកម្ពុជា ជាទ្រព្យសម្បត្តិរួមរបស់ប្រជាជនដែលរដ្ឋគ្រប់គ្រងតាមច្បាប់ជាធរមាន។

គ្មានជនណាមួយអាចទាមទារសិទ្ធិលើកម្មសិទ្ធិចាស់មុនឆ្នាំ១៩៧៩ លើដីសង់លំនៅឋាន ឬលើផ្ទះប្រភេទណាមួយបានឡើយ។

មាត្រា២

ចាប់ពីថ្ងៃនេះតទៅ រដ្ឋបែងចែកកម្មសិទ្ធិដាច់ឱ្យគ្រួសារជាពលរដ្ឋកម្ពុជា លើលំនៅឋានដែលគ្រួសាររបស់ខ្លួនកំពុងរស់នៅក្នុងឃុំ-សង្កាត់ទូទាំងប្រទេស ហើយដែលរដ្ឋអំណាចឃុំ-សង្កាត់នោះទទួលស្គាល់។ គ្រួសារពលរដ្ឋកម្ពុជាដែលរស់នៅលើលំនៅឋានណាដែលជាផ្ទះភូមិគ្រឹះ ផ្ទះដាច់ដោយឡែកឯទៀត ឬផ្ទះល្វែងត្រូវបានទទួលកម្មសិទ្ធិកាន់កាប់ ប្រើប្រាស់លំនៅឋាននោះ ដែលសន្មតហៅថាផ្ទះសម្រាប់រស់នៅតរៀងទៅ។

កម្មសិទ្ធិលើផ្ទះនេះ អាចបន្តមតិកទៅកូន-ចៅកាន់កាប់ ប្រើប្រាស់ដោយគ្មានកំណត់ពេល ឬប្រគល់ជាអំណោយឱ្យទៅបងប្អូនញាតិមិត្ត ឬលក់ឱ្យទៅអ្នកដទៃណាមួយទៀតកាន់កាប់ប្រើប្រាស់បាន លើកលែងតែការប្រើប្រាស់ដោយអ្នកទាំងនោះបម្រើគោលដៅ និងផលប្រយោជន៍ដែលផ្ទុយនឹងច្បាប់កំណត់។ រដ្ឋហាមឃាត់ការលក់ផ្ទះ និងដីសង់លំនៅឋានទៅឱ្យជនបរទេស។

មាត្រា៣

ម្ចាស់លំនៅឋានដូចបានកំណត់ខាងលើនេះ ត្រូវបង់ថ្លៃឈ្នួលដីប្រចាំឆ្នាំលើដីឡូតិ៍ ដែលលំនៅឋាននោះឋិតនៅលើ។

បើលំនៅឋាននោះជាផ្ទះល្វែងក្នុងអគាររួមមួយ ឬជាភាគមួយនៃផ្ទះទាំងមូល ម្ចាស់ផ្ទះល្វែង ឬម្ចាស់ភាគនីមួយៗ ត្រូវរួមវិភាគទានបង់ថ្លៃឈ្នួលដីដែលអគាររួម ឬផ្ទះទាំងមូលឋិតនៅលើ តាមសមាមាត្រនៃផ្ទៃក្រឡាសំណង់ដែលកាន់កាប់រៀងៗខ្លួន។

ប្រាក់ឈ្នួលដីប្រចាំឆ្នាំនេះ មិនអាចឱ្យលើសពីប្រាំភាគរយនៃប្រាក់បំណាច់សុទ្ធ របស់កម្មាភិបាល បុគ្គលិក កម្មករ និងកងកម្លាំងប្រដាប់អាវុធ។

មាត្រា៤

មេក្រុមគ្រួសារដែលកំពុងរស់នៅលើលំនៅឋាន ដែលឋិតនៅក្រោមការគ្រប់គ្រងរបស់ឃុំ-សង្កាត់ណា ត្រូវធ្វើលិខិតសុំកាន់កាប់កម្មសិទ្ធិលើលំនៅឋានដែលខ្លួនរស់នៅតាមរយៈរដ្ឋអំណាចឃុំ-សង្កាត់នោះ។

កម្មាភិបាល បុគ្គលិក កម្មករ កងកម្លាំងប្រដាប់អាវុធ ត្រូវធ្វើលិខិតសុំតាមរយៈក្រសួង មន្ទីរ ឬអង្គភាពរបស់ខ្លួន ដែលត្រូវបញ្ជូនលិខិតនោះទៅគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុងចាត់ការតាមសមត្ថកិច្ច។

គណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង ជាអង្គការមានសមត្ថកិច្ចចេញវិញ្ញាបនបត្រជូនពលរដ្ឋសម្រាប់ប្រើប្រាស់ជាផ្លូវការ។

**មាត្រា៥**

ក្រៅពីកម្មាភិបាល បុគ្គលិក កម្មករ កងកម្លាំងប្រដាប់អាវុធ ប្រជាជនដែលកំពុងរស់នៅលើលំនៅឋាន ឬដីសង់លំនៅឋានណាមួយ ត្រូវសុំទិញលំនៅឋាន ឬដីសង់លំនៅឋាននោះផ្តាច់ពីរដ្ឋទុកជាកម្មសិទ្ធិផ្ទាល់របស់ខ្លួន លើកលែងតែប្រជាជនដែលបានចេញថវិកាសង់លំនៅឋាននោះដោយខ្លួនឯង។

លំនៅឋានសង់ដោយខ្លួនឯងត្រូវទុកជាកម្មសិទ្ធិផ្ទាល់របស់សាមីជន ដែលបានសាងសង់។ ក្នុងករណីពិសេសគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុងត្រូវកំណត់គោលនយោបាយជាក់ស្តែង។ ថ្លៃលំនៅឋានត្រូវកំណត់តាមផ្ទៃក្រឡាកាន់កាប់តាមប្រភេទ និងស្ថានភាពផ្ទះ និងតាមគោលដៅប្រើប្រាស់។ ក្រុមប្រឹក្សារដ្ឋមន្ត្រីប្រគល់ជូនគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុងកំណត់ថ្លៃខាងលើនេះតាមសភាពការណ៍ជាក់ស្តែងនៃខេត្ត-ក្រុងនីមួយៗ។

**មាត្រា៦**

ក្រុមគ្រួសារណា ឬជនទាំងឡាយណាដែលកំពុងរស់នៅ ឬប្រកបអាជីវកម្មក្នុងអគារសាធារណៈគ្មានសិទ្ធិទទួលកម្មសិទ្ធិលើផ្នែកណាមួយ ឬលើអគារសាធារណៈនោះឡើយ។

អគារសាធារណៈទាំងឡាយត្រូវប្រគល់ជូនរដ្ឋមន្ត្រីប្រើប្រាស់ជាចាំបាច់ សម្រាប់ផលប្រយោជន៍សាធារណៈ។

**មាត្រា៧**

ការលក់ដូរផ្ទះ ឬការធ្វើអំណោយផ្ទះ ត្រូវធ្វើដោយកិច្ចសន្យាដែលអ្នកទិញ ឬអ្នកទទួលអំណោយត្រូវយកទៅចុះបញ្ជីប្រថាប់ត្រា ហើយបង់ថ្លៃប្រថាប់ត្រាចំនួនដប់ភាគរយនៃតម្លៃផ្ទះតាមប្រភេទផ្ទះ សម្រាប់នៅ សម្រាប់ធ្វើអាជីវកម្ម សេវាកម្ម សិប្បកម្ម ឬឧស្សាហកម្ម។

**មាត្រា៨**

ផ្ទះដែលយកទៅបម្រើទិសដៅធ្វើអាជីវកម្ម សេវាកម្ម សិប្បកម្ម ឬឧស្សាហកម្មត្រូវបង់ពន្ធជូនរដ្ឋ។ អាត្រាពន្ធនេះត្រូវកំណត់ដោយក្រុមប្រឹក្សារដ្ឋមន្ត្រី តាមផ្ទៃក្រឡាបម្រើអាជីវកម្មផលិតកម្ម។

*វាយឡើងវិញ*

មាត្រា៩

ម្ចាស់ផ្ទះទាំងឡាយមានកាតព្វកិច្ចថែទាំ សំអាតជួសជុលផ្ទះឱ្យបានល្អ គង់វង្សជានិច្ច ហើយត្រូវរក្សាអនាម័យខ្ពស់មិនត្រូវឱ្យលេចឡើងនូវក្លិន ឬសូរសំឡេងដែលប៉ះពាល់ដល់សុខុមាលភាព និងភាពស្ងប់ស្ងៀមនៅជុំវិញខ្លួនឡើយ។

មាត្រា១០

សំណង់បន្ថែម ឬសំណង់ថ្មី ត្រូវមានការអនុញ្ញាតពីគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុងជាមុនសិន។

មាត្រា១១

គណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង ត្រូវទទួលខុសត្រូវចំពោះការគ្រប់គ្រងផ្ទះសំណង់គ្រប់ប្រភេទ និងការត្រួតពិនិត្យការចុះបញ្ជី ការបែងចែកកម្មសិទ្ធិលើផ្ទះ ការប្រើប្រាស់ផ្ទះ ការទារឈ្នួលដី ទារពន្ធ និងទទួលខុសត្រូវចំពោះការថែទាំផ្លូវសាធារណៈ ធំ តូច លូបង្ហូរទឹកអនាម័យនៅទីសាធារណៈ និងភាពស្ងប់ស្ងៀមនៅក្នុងរង្វង់ភូមិសាស្ត្រនៃការគ្រប់គ្រងរបស់ខ្លួន។

មាត្រា១២

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជាមោឃៈ។

មាត្រា១៣:

ខុទ្ទកាល័យប្រឹក្សារដ្ឋមន្ត្រីគ្រប់ក្រសួង មន្ទីរ និងគណៈកម្មាធិការប្រជាជនបដិវត្តខេត្តក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ។

មាត្រា១៤

អនុក្រឹត្យនេះមានអានុភាពគតិយុត្ត ចាប់តាំងពីថ្ងៃប្រកាសផ្សាយជាសាធារណៈ។

ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី

ប្រធាន

ហត្ថលេខា និងត្រា

ហ៊ុន សែន

**រដ្ឋកម្ពុជា**

**ក្រុមប្រឹក្សារដ្ឋមន្ត្រី** **ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល**

លេខ០៣សណន

ភ្នំពេញ ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៨៩

**សេចក្តីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី**

អនុលោមតាមសេចក្តីសម្រេចចិត្តរបស់សន្និបាតកម្មាភិបាលទូទាំងប្រទេសលើកទីពីរ នាខែមេសា ឆ្នាំ១៩៨៩ ស្តីអំពីគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ក្រុមប្រឹក្សារដ្ឋមន្ត្រីធ្វើការណែនាំដូចតទៅ៖

-ដីធ្លីនៃរដ្ឋកម្ពុជាជាសម្បត្តិរបស់រដ្ឋ។

-ពលរដ្ឋកម្ពុជាមានសិទ្ធិពេញទីក្នុងការកាន់កាប់ប្រើប្រាស់ដីធ្លី និងមានសិទ្ធិតំណមតិកលើដីធ្លីដែលរដ្ឋប្រគល់ឱ្យសម្រាប់រស់នៅ និងធ្វើអាជីវកម្ម។

-គ្មានជនណាមួយអាចទាមទារសិទ្ធិលើកម្មសិទ្ធិចាស់មុនឆ្នាំ១៩៧៩ លើដីធ្លី។

-រដ្ឋមិនសើរើ និងបែងចែកជាថ្មីលើដីដែលបានកាន់កាប់រួចហើយចាប់ពីថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ មកទល់ថ្ងៃចេញសេចក្តីណែនាំអនុវត្តនេះរហូតដល់មានច្បាប់ភូមិបាល។

**I_អំពីការកំណត់ បែងចែក និងរូបភាពនៃការគ្រប់គ្រង និងប្រើប្រាស់ដីធ្លី**

**ក_ដីសម្រាប់សង់លំនៅឋាន**

នឹងប្រគល់ជូនជាកម្មសិទ្ធិចំពោះដីសម្រាប់សង់លំនៅឋាន ដែលត្រូវសម្រេចចេញដោយប្រធានគណៈកម្មាធិការប្រជាជនខេត្ត-ក្រុង។

ចំពោះដីបែងចែកថ្មី ដីប្រភេទនេះត្រូវកំណត់មិនឱ្យលើសពី២.០០០ម$^{២}$ សម្រាប់មួយគ្រួសារ។ ប៉ុន្តែក្នុងករណីបើគ្រួសារប្រជាជនណាមួយដែលពីមុនមានដីសម្រាប់សង់លំនៅឋានលើសពី២.០០០ម$^{២}$ នោះចំណែកដែលលើសត្រូវចាត់ចូលជាដីភោគៈវិញ។ ក្នុងការបែងចែក មូលដ្ឋាននីមួយៗ ត្រូវរៀបចំឱ្យមានប្លង់ទូទៅជាបណ្តោះអាសន្នមួយ ដែលក្នុងនោះមានឡូត៍នីមួយៗ ផ្លូវ និងដីត្រៀមបម្រុងរបស់មូលដ្ឋានសម្រាប់ពង្រីកទៅអនាគត។

**ខ.ដីស្រែចម្ការសម្រាប់ផលិតកម្មអាជីវកម្ម**

-ផ្តល់ជូនជាភោគៈ លើផ្ទៃដីស្រែ ឬចម្ការ។ ដីភោគៈគឺជាដីដែលរដ្ឋប្រគល់សិទ្ធិផ្តាច់មុខជូនដល់គ្រួសារកសិករកាន់កាប់ប្រើប្រាស់ក្នុងពេលធ្វើផលិតកម្ម-អាជីវកម្ម និងបន្តមតិក។ ដីភោគៈខុសគ្នានឹងដីកម្មសិទ្ធិត្រង់៖

+ដីភោគៈអាចថេរភាពក្នុងដំណាក់កាលដែលកំពុងប្រើប្រាស់ ពេលឈប់ប្រើប្រាស់គឺលែងជាភោគៈ។

+ដីកម្មសិទ្ធិថេរភាពគ្មានកំណត់ពេល ទោះបីមិនប្រើប្រាស់ ឬមិនធ្វើអាជីវកម្មក៏ដោយក៏នៅជាកម្មសិទ្ធិដដែល លើកលែងតែច្បាប់ពិសេស។

ដីភោគៈមិនកំណត់រយៈពេលប្រើប្រាស់ទេ។ ផ្ទៃដីជាភោគៈត្រូវកំណត់មិនឱ្យលើសពី៥ហ.តយោលទៅតាមលទ្ធភាពដីរបស់មូលដ្ឋាន និងលទ្ធភាពរបស់គ្រួសារនីមួយៗ។ ដីភោគៈនេះត្រូវបានផ្តល់ជូនតែចំពោះគ្រួសារណាដែលបានតស៊ូធ្វើស្រែចម្ការ យ៉ាងតិចមួយឆ្នាំមុនថ្ងៃកំណត់នេះ។ ដីភោគៈបានត្រូវប្រធានគណៈកម្មាធិការប្រជាជនស្រុកចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ឱ្យ។

ចំពោះដីសម្រាប់បង្កបង្កើនផលដើម្បីទ្រទ្រង់បេឡារបស់រដ្ឋអំណាច និងអង្គការមហាជន ឃុំ ភូមិ ត្រូវរក្សាទុកជាដីបម្រុងរបស់មូលដ្ឋាន តាមការកំណត់ដូចខាងក្រោម៖

-ឃុំនីមួយៗអាចរក្សាទុកដីស្រែចម្ការមួយចំនួនមិនលើសពី៦ហិកតា នៅកន្លែងណាដែលមានដីទូលាយ ហើយមានមនុស្សតិច។ នៅកន្លែងណាដែលមានផ្ទៃដីតិច ហើយមានមនុស្សច្រើននោះ អាចរក្សាទុកដីស្រែចម្ការចំនួន៣ហិកតា។

-ភូមិនីមួយៗអាចរក្សាទុកដីស្រែចម្ការប្រមាណពី១ហិកតា ទៅ២ហិកតានៅកន្លែងណាដែលមានដីទូលាយហើយមានមនុស្សតិច។ នៅកន្លែងណាដែលមានផ្ទៃដីតិច ហើយមានមនុស្សច្រើននោះអាចរក្សាទុកដីចំនួន១ហិកតា។

ក្នុងករណីដែលពីមុនមកភូមិ ឃុំ បានរក្សាដីទុកលើសពីការកំណត់នេះ ភាគដែលលើសត្រូវបែងចែកជូនប្រជាជន។

ចំពោះដីដែលបានគាស់រានរួចហើយ និងដីបម្រុងរានថ្មីត្រូវតែមានសេចក្តីកំណត់ពីក្រសួងកសិកម្មជាមុន មុននឹងសម្រេចចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ទោះជាភោគៈ ឬសម្បទានក្តី ដើម្បីចៀសវាងកុំឱ្យប៉ះពាល់ដីក្នុងដែនរុក្ខា និងនេសាទ។

ចំពោះជនភៀសខ្លួនកម្ពុជា ជនរួមជាតិកម្ពុជានៅបរទេសដែលបានវិលត្រលប់មកមាតុភូមិវិញ និងជនទាំងឡាយដែលបានបោះបង់ចោលជួរខ្មាំង វិលត្រលប់មកជាមួយប្រជាជន និងបដិវត្តវិញ នឹងត្រូវបែងចែកដីសង់លំនៅឋាន ដីស្រែចម្ការសល់ទំនេរ ឬដីសម្រាប់រានថ្មីសមស្របតាមលទ្ធភាពនៃមូលដ្ឋាននីមួយៗ។

ផ្តល់ជូនជាសម្បទានចំពោះដីដែលមានទំហំលើសពី៥ហិកតាឡើងទៅ។ សម្បទានគឺជាសិទ្ធិកាន់កាប់ជាដំណាក់កាលដែលរដ្ឋបើកឱ្យលើផ្ទៃដីធំ សម្រាប់ដាំដុះដំណាំសំខាន់ៗបម្រើឱ្យសេដ្ឋកិច្ចជាតិ។ ដីសម្បទានត្រូវបានកំណត់រយៈពេលប្រើប្រាស់ច្បាស់លាស់ យោលទៅតាមអាយុកាលនៃដំណាំនីមួយៗ។ ផុតអាណត្តិអាយុកាលដំណាំទី១ អាចផ្តល់ជូនសិទ្ធិជាលើកទី២ និងបន្តបន្ទាប់។ ការផ្តល់ដីជាសម្បទានត្រូវយោលទៅតាមលទ្ធភាពរបស់មូលដ្ឋាន និងលទ្ធភាពរបស់គ្រួសារនីមួយៗ។ រដ្ឋមន្ត្រីក្រសួងកសិកម្ម ជាអ្នកចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីសម្បទាន។ គ្រួសារប្រជាជននីមួយៗមានសិទ្ធិកាន់កាប់ប្រើប្រាស់ដីទាំងបីប្រភេទខាងលើ ហើយក្នុងដំណាក់កាលបច្ចុប្បន្នដែលមិនទាន់មានច្បាប់ភូមិបាល រដ្ឋចេញជាប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីជាជំនួសសិន។

**II.-អំពីកម្មវិធីការងារ**

មេក្រុមគ្រួសារដែលបានកាន់កាប់ដី ត្រូវប្រញាប់ធ្វើពាក្យស្នើសុំកាន់កាប់មកគណៈកម្មាធិការប្រជាជនស្រុក តាមរយៈឃុំ ភូមិដែលកំពុងរស់នៅ តាមគំរូបែបបទដែលក្រសួងកសិកម្មបានបោះពុម្ពចែកជូន។

ប្រកាសបើកថ្ងៃទទួលពាក្យស្នើសុំកាន់កាប់ដីទូទាំងប្រទេស ចាប់ពីថ្ងៃចេញសេចក្តីណែនាំអនុវត្តនេះដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៨៩។ ផុតកំណត់នេះ រដ្ឋចាត់ទុកថាជាដីទំនេរគ្មានម្ចាស់កាន់កាប់។

**III.-អំពីការចាត់តាំងអនុវត្ត**

-ក្រសួងកសិកម្មត្រូវរួសរាន់បង្កើតនាយកដ្ឋានសុរិយោដី និងភូមិបាលដើម្បីដឹកនាំ គ្រប់គ្រង និងប្រើប្រាស់ដីធ្លីទូទាំងប្រទេស។ ចំពោះមុខគណៈកម្មាធិការប្រជាជនគ្រប់ជាន់ថ្នាក់មិនត្រូវជ្រើសរើសក្របខ័ណ្ឌថ្មី ឬបង្កើតផ្នែកសុរិយោដីតាមមូលដ្ឋានទេ គប្បីប្រើប្រាស់ក្របខ័ណ្ឌរបស់ផ្នែកក្សេត្រសាស្ត្រការិយាល័យកសិកម្មស្រុក និងកសិកម្មឃុំ ក្នុងការចុះធ្វើអង្កេតវាស់វែងជាក់ស្តែង និងចុះបញ្ជិកាផ្សេងៗអំពីការគ្រប់គ្រង និងប្រើប្រាស់ដីធ្លី។

-ក្រសួងកសិកម្ម ត្រូវបោះពុម្ពប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី សៀវភៅចុះបញ្ជីអចលនវត្ថុ សៀវភៅទទួលពាក្យស្នើសុំបង្កាន់ដៃ និងឯកសារផ្សេងៗលក់ចែកជូនខេត្ត-ក្រុងឱ្យបានគ្រប់គ្រាន់ទាន់ពេលវេលា។ ទន្ទឹមនឹងនេះត្រូវសហការឱ្យបានជិតស្និទ្ធតាមបណ្តាខេត្ត-ក្រុង ព្រមទាំងធ្វើផែនការណែនាំលំអិត អំពីបែបបទសំណុំលិខិតស្នើរបៀបរបបតម្កល់ឯកសារ និងការចុះបញ្ជីក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ ឬក៏ចាត់កម្មាភិបាលជំនាញចុះជួយផ្ទាល់។

-ក្រសួងផែនការ ក្រសួងហិរញ្ញវត្ថុ និងក្រសួងពាក់ព័ន្ធ ត្រូវត្រៀមលក្ខណៈសម្រួលគ្រប់បែបយ៉ាង ដើម្បីដំណើរការអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពល្អតទៅ។

-គណៈកម្មាធិការប្រជាជនខេត្តត្រូវចាត់តាំងគណៈកម្មការមូលដ្ឋានដែលមាន៖

+គណៈកម្មការកណ្តាល "ថ្នាក់ស្រុក"

| | |
|---|---|
| -ប្រធានគណៈកម្មាធិការប្រជាជនស្រុក | ប្រធាន |
| -ប្រធានការិយាល័យកសិកម្មស្រុក | អនុប្រធាន |
| -ប្រធានគណៈកម្មាធិការប្រជាជនគ្រប់ឃុំ | សមាជិក |

គណៈកម្មការនេះមានភារកិច្ចពិនិត្យទទួលពាក្យស្នើសុំកាន់កាប់ដី ប្រមូលផ្តុំការងារគ្រប់ឃុំជុំវិញ និងតាមដានការចុះវាស់វែងជាក់ស្តែង និងធ្វើមូលវិចារណ៍សម្រេចលើពាក្យស្នើ។

+អនុគណៈកម្មការអង្កេតវាស់វែងចុះអនុវត្តផ្ទាល់តាមឃុំនីមួយៗ

| | |
|---|---|
| -ប្រធានកសិកម្មឃុំ | ប្រធាន |
| -ប្រធានភូមិគ្រប់ភូមិ | អនុប្រធាន |

អនុគណៈកម្មការនេះមានភារកិច្ចចុះធ្វើអង្កេតវាស់វែងជាក់ស្តែង និងលើកសំណើជូនគណៈកម្មការកណ្តាលពិនិត្យ និងសម្រេច បន្ទាប់ពីបិទសម័យទទួលពាក្យស្នើ។

ទន្ទឹមនឹងនេះ ខេត្តត្រូវធ្វើការផ្សព្វផ្សាយសេចក្តីសម្រេចចិត្តស្តីពីគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី និងសេចក្តីណែនាំអនុវត្តនេះឱ្យបានទូលំទូលាយក្នុងជួរកម្មាភិបាល និងប្រជាជនដើម្បីឱ្យជ្រួតជ្រាប ងាយស្រួលក្នុងកិច្ចដំណើរការអនុវត្ត។ ក្នុងករណីជួបការលំបាកស្មុគស្មាញអំពីការអនុវត្តនេះ ត្រូវរាយការណ៍មកក្រសួងកសិកម្មដើម្បីមានវិធានការកែលំអ និងដោះស្រាយ។

*វាយឡើងវិញ*

មូលដ្ឋាននីមួយៗត្រូវយកចិត្តទុកដាក់ថែរក្សាព្រំចាស់របស់ដីវត្តអារាម ទីស្នសាន សាលារៀន មន្ទីរពេទ្យ ស្ថានីយ៍ពិសោធន៍ កសិដ្ឋាន រោងចក្រ សហគ្រាស ប្រព័ន្ធសំណង់ធារាសាស្ត្រ និងបណ្ដាសំណង់ផ្សេងៗទៀតដែលមានពីមុនមក។ ករណីចាំបាច់ក្នុងផលិតកម្ម អាជីវកម្មដីទាំងនោះ អាចផ្ដល់ជូនប្រជាជនខ្ចីដោយមានកិច្ចសន្យាខ្ចីច្បាស់លាស់ សម្រេចដោយប្រធានគណៈកម្មាធិការប្រជាជនស្រុក។ កិច្ចសន្យាត្រូវមានបញ្ជាក់អំពីរយៈពេលខ្ចី "មិនឱ្យលើសពីបីឆ្នាំ" និងសន្យាមិនទាមទារអ្វីពេលផុតអាណត្តិខ្ចី ហើយដែលរដ្ឋត្រូវការ។ ពេលផុតអាណត្តិ ហើយដែលរដ្ឋមិនទាន់ត្រូវការទេនោះ សាមីអ្នកខ្ចីអាចស្នើខ្ចីបន្ត ដោយមានកិច្ចសន្យាខ្ចីថ្មីទៀត។

**IV.អំពីកាតព្វកិច្ចរបស់អ្នកកាន់កាប់ប្រើប្រាស់ដីធ្លី**

សាមីអ្នកកាន់កាប់ប្រើប្រាស់ដីធ្លីគ្រប់រូបភាព ត្រូវអនុវត្តឱ្យបានដាច់ខាតកាតព្វកិច្ចដែលមានចែងក្នុងសេចក្ដីសម្រេចចិត្តស្ដីពីគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី។ រដ្ឋនឹងមានវិធានការដកហូតសិទ្ធិក្នុងករណីមិនអនុវត្តតាមរាល់កាតព្វកិច្ចខាងលើ។

**ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី**

**ប្រធាន**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

*កន្លែងទទួល*

-ខុទ្ទកាល័យមជ្ឈិមបក្ស

-ខុទ្ទកាល័យរដ្ឋសភា

-ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ

*"ដើម្បីជ្រាបជាព័ត៌មាន"*

-ក្រសួងកសិកម្ម

*"ដើម្បីអនុវត្ត"*

-ឯកសារ

រដ្ឋកម្ពុជា

ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

គណៈកម្មាធិការប្រជាជនរដ្ឋធានីភ្នំពេញ

លេខ០៥សរច ភ្នំពេញ ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៨៩

## សារាចរ

## ការអនុវត្តអនុក្រឹត្យស្ដីពីការផ្ដល់កម្មសិទ្ធិលើផ្ទះជូនពលរដ្ឋកម្ពុជានៅរដ្ឋធានីភ្នំពេញ

ក្រុមប្រឹក្សារដ្ឋមន្ត្រីបានចេញអនុក្រឹត្យលេខ២៥អនក្រ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៨៩ ក្នុងគោលបំណងរៀបចំឱ្យមានកម្មសិទ្ធិត្រឹមត្រូវលើផ្ទះសំបែងជូនពលរដ្ឋកម្ពុជា។ ដើម្បីអនុវត្តអនុក្រឹត្យនេះឱ្យបានចំទិសដៅ និងប្រកបដោយលទ្ធផលល្អ គណៈកម្មាធិការប្រជាជនរដ្ឋធានីភ្នំពេញសូមធ្វើការណែនាំដូចតទៅ៖

១-ផ្ទះសំបែង ដីធ្លីក្នុងរដ្ឋធានីភ្នំពេញ ទោះបីរាល់ស្ថាប័នរដ្ឋ អង្គការសមូហភាពដែលកំពុងកាន់កាប់ប្រើប្រាស់មិនចំពោះស្ថាប័នមជ្ឈិម ឬក្រុង ឯកជនត្រូវចាត់ទុកជាទ្រព្យសម្បត្តិរួមរបស់ប្រជាជន ហើយត្រូវបានគណៈកម្មាធិការប្រជាជនរដ្ឋធានីភ្នំពេញគ្រប់គ្រង បែងចែកតាមគោលការណ៍របស់រដ្ឋដែលបានកំណត់។

២-គណៈកម្មាធិការប្រជាជនរដ្ឋធានីភ្នំពេញ ប្រគល់ភារកិច្ចឱ្យមន្ទីររៀបចំក្រុង និងសំណង់គ្រប់គ្រង ចុះបញ្ជី តាមដាន ត្រួតពិនិត្យផ្ទះសំបែង ដីធ្លី ដោះស្រាយបាតុភាពទំនាស់គ្រប់គ្រងក្នុងការបែងចែក កម្មសិទ្ធិលើផ្ទះគ្រប់ប្រភេទ របៀបរបបប្រើប្រាស់ផ្ទះ អនុវត្តការងារទារឈ្នួលផ្ទះ និងដី បង់ពន្ធផ្ទះ និងដីតាមឆ្នាំនៃប្រភេទផ្ទះនីមួយៗដែលស្នាក់នៅ-អាជីវកម្ម-សិប្បកម្ម-សេវាកម្ម-ឧស្សាហកម្មតូច ។ល។

៣-កម្មាភិបាល បុគ្គលិក កម្មករ កងកម្លាំងប្រដាប់អាវុធ ដែលបម្រើការងារក្នុងក្របខ័ណ្ឌរបស់រដ្ឋជាមេគ្រួសារ និងប្រជាជនជាមេគ្រួសារបច្ចុប្បន្នកំពុងកាន់កាប់ផ្ទះសំបែងរបស់រដ្ឋ ហើយដើម្បីឱ្យបានស្របច្បាប់ទទួលផ្ទះជាកម្មសិទ្ធិ និងដីធ្លី ដើម្បីកាន់កាប់ ប្រើប្រាស់ទៅតាមអនុក្រឹត្យលេខ២៥អនក្រ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៨៩ នោះបានត្រូវមានវិញ្ញាបនបត្រកាន់កាប់ផ្ទះ និងដីដែលគណៈកម្មាធិការប្រជាជនរដ្ឋធានីភ្នំពេញចេញឱ្យ។

៤-ការដាក់ពាក្យស្នើសុំកម្មសិទ្ធិផ្ទះសំបែង និងដីធ្លី ដើម្បីកាន់កាប់ប្រើប្រាស់ ត្រូវអនុវត្តដូចខាងក្រោមនេះ៖

-ចំពោះកម្មាភិបាល បុគ្គលិក កម្មករ កងកម្លាំងប្រដាប់អាវុធ ជាមេគ្រួសារត្រូវដាក់ពាក្យស្នើសុំតាមរយៈក្រសួង មន្ទីរ អង្គភាពរបស់ខ្លួន ដោយមានវិញ្ញាបនបត្រ រដ្ឋបាលបញ្ជាក់កាំប្រាក់ច្បាស់លាស់ និងមានលិខិតបញ្ជាក់ទីលំនៅពីរដ្ឋអំណាចមូលដ្ឋាន បញ្ជូនមកមន្ទីររៀបចំក្រុង និងសំណង់ដើម្បីពិនិត្យ ។

-ចំពោះប្រជាជនជាមេគ្រួសារ ត្រូវដាក់ពាក្យស្នើសុំតាមរយៈគណៈកម្មាធិការប្រជាជនសង្កាត់ ឃុំ ខណ្ឌ ស្រុកបញ្ជូនមកមន្ទីររៀបចំក្រុង និងសំណង់ដើម្បីពិនិត្យ ។

-ចំពោះពលរដ្ឋណាបានសាងសង់ផ្ទះដោយចេញថវិកាដោយខ្លួនឯង ដើម្បីឱ្យបានស្របច្បាប់ទទួលផ្ទះជាកម្មសិទ្ធិ និងដីធ្លី ដើម្បីកាន់កាប់ប្រើប្រាស់នោះ ត្រូវធ្វើពាក្យស្នើសុំដូចមានចែងក្នុងចំណុចទីពីរខាងលើនេះដែរ ។

-ពលរដ្ឋក្នុងរដ្ឋធានីត្រូវទៅទំនាក់ទំនងទៅសហគ្រាសគ្រប់គ្រងអចលនវត្ថុ និងបណ្ដាសាខាប្រចាំខណ្ឌ ស្រុករបស់សហគ្រាសគ្រប់គ្រងអចលនវត្ថុនៃមន្ទីររៀបចំក្រុង និងសំណង់ ដើម្បីទិញលិខិតស្នើសុំក្នុងការបំពេញទម្រង់បែបបទ ។

-ចំពោះសំណង់ទាំងឡាយណា ដែលសាងសង់ធ្វើឱ្យខូចខាតសណ្ដាប់ធ្នាប់របៀបរៀបរយសាធារណៈ អាជ្ញាធិបតេយ្យ គណៈកម្មាធិការប្រជាជនរដ្ឋធានីភ្នំពេញពិនិត្យ និងចេញវិញ្ញាបនបត្រជូនកម្មសិទ្ធិផ្ទះសំបែង និងដីធ្លីដើម្បីកាន់កាប់ប្រើប្រាស់នោះបាន នៅពេលណាម្ចាស់សំណង់គោរពតាមគោលការណ៍ណែនាំរបស់មន្ទីររៀបចំក្រុង និងសំណង់ ដែលគណៈកម្មាធិការប្រជាជនរដ្ឋធានីភ្នំពេញបានកំណត់ ។

៥-ពលរដ្ឋគ្រប់រូបក្រោយពីបានទទួលផ្ទះជាកម្មសិទ្ធិ និងដីធ្លីនៅរដ្ឋធានីភ្នំពេញ ដើម្បីកាន់កាប់រួចមក ត្រូវមានកាតព្វកិច្ចពេញលេញបង់ពន្ធជូនរដ្ឋ ថែទាំ សំអាត ជួសជុលជាអចិន្ត្រៃយ៍តាមគោលការណ៍របស់រដ្ឋ ដែលបានកំណត់សំដៅឱ្យផ្ទះសំបែងក្នុងរដ្ឋធានីភ្នំពេញ រក្សាបាននូវសោភ័ណភាព សណ្ដាប់ធ្នាប់ របៀបរៀបរយ រក្សានូវអនាម័យបានល្អ ចៀសវាងធ្វើឱ្យខូចមហន្តរាយដល់ផ្ទះសំបែង ដូចជាឆាប់ស្រុតទ្រុឌទ្រោម បាក់បែក ឬក៏យកផ្ទះសំបែងនោះទៅផលិតអ្វីផ្សេងៗដែលប៉ះពាល់ដល់សុខុមាលភាពអ្នកជិតខាង ឬក៏ធ្វើអ្វីដែលមានស្នូរសំឡេងខ្លាំងរញ្ជួយដល់គ្រឹះសំណង់នៃផ្ទះនោះ ត្រូវបានហាមឃាត់ដាច់ខាត ។

៦-រាល់រចនាសម្ព័ន្ធគ្រប់ប្រភេទ ថ្នាក់ផ្ទះដែលមានផ្ទៃក្រឡាសម្រាប់បម្រើ ផលប្រយោជន៍សាធារណៈ និងរាល់ប្រព័ន្ធប្រឡាយទឹក ផ្លូវសាធារណៈធំតូច លូបង្ហូរទឹក ដែលកំពុងប្រើប្រាស់

សម្រាប់បម្រើផលប្រយោជន៍សាធារណៈមិនត្រូវហួងហែង ឬរំលោភយកជាកម្មសិទ្ធិរបស់ខ្លួន ឬអង្គភាពណាមួយឡើយ គឺត្រូវទុកបម្រើផលប្រយោជន៍រួមដដែល។

៧-ក្រោយពីបានទទួលផ្ទះជាកម្មសិទ្ធិ និងដីធ្លីដើម្បីកាន់កាប់ប្រើប្រាស់រួចមក ត្រូវធ្វើរបងផ្ទះទៅតាមលក្ខណៈបច្ចេកទេសដោយមិនត្រូវធ្វើរបងខ្ពស់ពេក ឬបាំងបិទដោយស័ង្កសីខ្ពស់ហួស ដែលនាំឱ្យខូចសោភ័ណភាពផ្ទះ បាត់សោភ័ណភាពរបស់ទីក្រុង លើកលែងតែករណីផ្ទះដែលមានលក្ខណសម្បត្តិពិសេសខ្លះដែលគណៈកម្មាធិការប្រជាជនរដ្ឋធានីភ្នំពេញកំណត់សម្រេចជូន។

៨-ពលរដ្ឋក្នុងរដ្ឋធានីភ្នំពេញដែលបានទទួលផ្ទះជាកម្មសិទ្ធិ និងដីធ្លីដើម្បីកាន់កាប់ ប្រើប្រាស់ ហើយមានសិទ្ធិយកទៅបម្រើការស្នាក់នៅ ក្នុងករណីយកទៅបម្រើអាជីវកម្ម សិប្បកម្ម សេវាកម្ម ឬផ្លាស់ប្តូរគោលដៅប្រើប្រាស់ ត្រូវមានការអនុញ្ញាតពីគណៈកម្មាធិការប្រជាជនរដ្ឋធានីភ្នំពេញ។ ក្នុងករណីអនុវត្តខុសនឹងច្បាប់របស់រដ្ឋត្រូវផាកពិន័យ ឬបញ្ជូនទៅតុលាការវិនិច្ឆ័យទោសតាមច្បាប់។

៩-ការផ្ទេរផ្ទះសំបែង អំណោយបន្តកេរ្តិ៍មតិកអាចប្រព្រឹត្តទៅលុះត្រាតែផ្ទះនោះជាកម្មសិទ្ធិ ហើយត្រូវបានការឯកភាពពីមន្ទីររៀបចំក្រុង និងសំណង់ និងត្រូវបានគណៈកម្មាធិការប្រជាជនរដ្ឋធានីភ្នំពេញចេញវិញ្ញាបនបត្រកាន់កាប់ផ្ទះជូន។

១០-ចំពោះប្រជាជនបច្ចុប្បន្នកំពុងស្នាក់នៅធ្វើអាជីវកម្ម សិប្បកម្ម សេវាកម្ម ឧស្សាហកម្ម ត្រូវទិញផ្ទះពីរដ្ឋផ្តាច់មុខទុកជាកម្មសិទ្ធិរបស់ខ្លួនតាមតម្លៃដែលរដ្ឋបានកំណត់។

១១-ពលរដ្ឋគ្រប់រូបក្រោយពីបានទទួលផ្ទះជាកម្មសិទ្ធិ និងដីធ្លី ដើម្បីកាន់កាប់ប្រើប្រាស់រួចមក ហើយមានបំណងចង់លក់ ដូរ ផ្ទេរ អំណោយដោយមិនគិតទាំងផ្ទះដែលសាងសង់ដោយថវិកាខ្លួនឯង គូភាគីទាំងសងខាងត្រូវបង់ថ្លៃ "ប្រថាប់ត្រា" ចំនួន១០ភាគរយនៃតម្លៃផ្ទះ ដោយគិតតម្លៃតាមប្រភេទផ្ទះស្នាក់នៅអាជីវកម្ម សិប្បកម្ម សេវាកម្ម ឧស្សាហកម្ម។

១២-ចំពោះពលរដ្ឋដែលមានផ្ទះសម្រាប់ស្នាក់នៅ ឬដីសម្រាប់សង់លំនៅឋាន ត្រូវបានហាមឃាត់ដាច់ខាត មិនត្រូវលក់ ឬដោះដូរដោយរូបភាពណាក៏ដោយទៅឱ្យជនបរទេស តែបើមានក្នុងលក្ខណៈនោះ ឬដោះដូរត្រូវដកហូតទុកជាសម្បត្តិរដ្ឋ។

១៣-គ្រប់ស្ថាប័នរដ្ឋ ក្រុមហ៊ុនសមូហភាព សេដ្ឋកិច្ចរដ្ឋចម្រុះឯកជន ឬឯកជនដែលបានយកផ្ទះ និងដីធ្លីរបស់ខ្លួនរកស៊ីបម្រើគោលដៅអាជីវកម្ម សិប្បកម្ម សេវាកម្ម ឧស្សាហកម្មតូចត្រូវបង់អត្រាពន្ធផ្ទះ និងដីប្រចាំខែនីមួយៗដែលរដ្ឋបានកំណត់។

១៤-គ្រប់ប្រភេទថ្នាក់ផ្ទះក្នុងរដ្ឋធានីភ្នំពេញ ត្រូវបានគណៈកម្មាធិការប្រជាជនរដ្ឋធានីភ្នំពេញប្រគល់ឱ្យមន្ទីររៀបចំក្រុង និងសំណង់ដើម្បីវាយតម្លៃតាមសភាពការណ៍ជាក់ស្តែងទៅ

តាមប្រភេទផ្ទះនីមួយៗ ដោយគិតតាមអាយុរបស់ផ្ទះ គុណភាពផ្ទះខ្ពស់ ឬទាបគិតទៅតាមតំបន់ទីប្រជុំជនច្រើន ឆ្ងាយទីប្រជុំជន រួចបញ្ជូនមកគណៈកម្មាធិការប្រជាជនរដ្ឋធានីភ្នំពេញដើម្បីពិនិត្យសម្រេចលក់ជូនពលរដ្ឋដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់រស់នៅក្នុងរដ្ឋធានីភ្នំពេញ។

១៥-ដីសង់លំនៅឋាន និងគ្រប់គ្រងប្រភេទថ្នាក់ផ្ទះដោយគិតទាំងរោងចក្រ សហគ្រាស សណ្ឋាគារ រោងភាពយន្ត ធនាគារ ស្ថានីយប្រេងឥន្ធនៈ ។ល។ និង ។ល។ ដែលជារបស់ឯកជនមុនឆ្នាំ១៩៧៩មិនអាចចាត់ទុកជាកម្មសិទ្ធិ ឬទាមទារកម្មសិទ្ធិចាស់របស់ខ្លួនវិញបានឡើយ ត្រូវទុកជាសម្បត្តិរួមរបស់ប្រជាជន ហើយឋិតនៅក្រោមការគ្រប់គ្រង បែងចែករបស់គណៈកម្មាធិការប្រជាជនរដ្ឋធានីភ្នំពេញ។

១៦-ដីសង់លំនៅឋាននៅក្រុងភ្នំពេញ ដែលមានប្លង់បច្ចេកទេស មានប្លង់ក្បាលដីដែលមានបែងចែកជាឡូត៍ ព្រមទាំងបានរៀបចំការងារអភិវឌ្ឍន៍រួចស្រេចហើយនោះ ត្រូវហាមឃាត់មិនឱ្យយកទៅពុះបែងចែកជាឡូត៍តូចៗទៀតទេ ដែលធ្វើឱ្យប៉ះពាល់ដល់ប្រព័ន្ធសេវាកម្មផ្សេងៗ។ល។ រដ្ឋមិនអនុញ្ញាតឱ្យពលរដ្ឋណាសាងសង់លើដីបម្រើផលប្រយោជន៍សាធារណៈ អគារសាធារណៈ វប្បធម៌សាធារណៈ តំបន់គោលដៅអភិវឌ្ឍន៍ទីក្រុងឡើយ និងហាមឃាត់ដាច់ខាតមិនឱ្យយកដីធ្លីជីកស្រះចិញ្ចឹមត្រីដែលនាំឱ្យខូចខាត បាត់បង់ដីធ្លីសម្រាប់សាងសង់លំនៅឋាន។

១៧-រាល់សំណង់សាងសង់ដីក្នុងទីក្រុងភ្នំពេញមិនគិតថាស្ថាប័នមជ្ឈិម ឬក្រុងមុននឹងធ្វើការសាងសង់ត្រូវមានប្លង់ និងមានការអនុញ្ញាតច្បាប់កាន់កាប់ដីជាមុនសិន។ ក្រោយពីបានទទួលវិញ្ញាបនបត្រកាន់កាប់ដី ពីគណៈកម្មាធិការប្រជាជនរដ្ឋធានីភ្នំពេញហើយ បើសាមីអង្គភាពទុកដីនោះចោលទំនេរក្នុងកំលុងពី៦ខែ ទៅ១ឆ្នាំ គណៈកម្មាធិការប្រជាជនរដ្ឋធានីភ្នំពេញត្រូវដកហូតដីនោះមកវិញដើម្បីទុកឱ្យស្ថាប័នផ្សេងៗទៀតដែលចាំបាច់ចំពោះមុខ។ ចំពោះពលរដ្ឋណាប្រើប្រាស់ដីនោះខុសទិសដៅតាមល័ក្ខខ័ណ្ឌតម្រូវពុំបានបង់ពន្ធដីជូនរដ្ឋ ឬទុកដីនោះទំនេរដោយគ្មានប្រើប្រាស់អ្វីក្នុងរយៈពេល៦ខែ ទៅ១ឆ្នាំ គិតតាំងពីពេលបានទទួលច្បាប់អនុញ្ញាតឱ្យកាន់កាប់នោះ ត្រូវបានគណៈកម្មាធិការប្រជាជនរដ្ឋធានីភ្នំពេញព្រមានណែនាំអប់រំ ឬផាកពិន័យ។

បើដីនោះមានទំហំលើសពី៥ហិកតា ឡើងជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីជាអ្នកសម្រេច។ បើទំហំពី៥ហិកតាចុះក្រោមជាសមត្ថកិច្ចរបស់គណៈកម្មាធិការប្រជាជនរដ្ឋធានីភ្នំពេញជាអ្នកសម្រេច។ ចំពោះសំណង់បន្ថែម ឬសំណង់ថ្មីត្រូវមានប្លង់ឯកភាពពីមន្ទីររៀបចំក្រុង និងសំណង់ ដើម្បីដាក់ជូនគណៈកម្មាធិការប្រជាជនរដ្ឋធានីភ្នំពេញសម្រេច បើក្នុងករណីជួសជុលតូច ឬមធ្យមដែលមិនធ្វើឱ្យខូចខាតទ្រង់លក្ខណៈសំណៅដើមនៃផ្ទះ គឺប្រគល់ឱ្យមន្ទីររៀបចំក្រុង និងសំណង់ពិនិត្យ និងសម្រេច។

*វាយឡើងវិញ*

១៨-ផ្ទះគ្រប់ប្រភេទដែលក្រុមជាងកំពុងធ្វើការជួសជុលគ្មានប្លង់ ខុសប្លង់ ខុសរចនាសម្ព័ន្ធ ឬធ្វើឱ្យខូចស្ថាបត្យកម្មនៃផ្ទះ និងដោយគ្មានការអនុញ្ញាតពីគណៈកម្មាធិការប្រជាជនរដ្ឋធានីភ្នំពេញ នោះ មន្ទីររៀបចំក្រុង និងសំណង់សហការជាមួយរដ្ឋអំណាចមូលដ្ឋាន ឃាត់ទុកជាបណ្តោះអាសន្ន នូវសម្ភារៈ ឧបករណ៍សាងសង់ចំពោះម្ចាស់ផ្ទះ និងក្រុមជាងត្រូវព្រមាន ឬពិន័យជាប្រាក់ពី ៥.០០០រ០០ ទៅ៥០.០០០រ០០ ឬបញ្ជូនទៅតុលាការវិនិច្ឆ័យទោសតាមច្បាប់។

១៩-រាល់ការពាក់ព័ន្ធគោលការណ៍របស់មន្ទីររៀបចំក្រុង និងសំណង់ និងករណីផ្សេងៗ ទៀតត្រូវដោះស្រាយឱ្យហើយស្រេចជាមុនសិន ទើបគណៈកម្មាធិការប្រជាជនរដ្ឋធានីភ្នំពេញចេញ វិញ្ញាបនបត្រជូនបាន។ ចំពោះផ្ទះ ឬដីធ្លីណាដែលកំពុងមានទំនាស់នោះ គណៈកម្មាធិការប្រជាជន រដ្ឋធានីភ្នំពេញនឹងពិនិត្យចេញវិញ្ញាបនបត្រកាន់កាប់ផ្ទះ ឬដីធ្លីឱ្យបាននៅពេលណាដែលអង្គការ សមត្ថកិច្ចដោះស្រាយទំនាស់រួច។ ចំពោះផ្ទះបាក់បែក ទ្រុឌទ្រោមគណៈកម្មាធិការប្រជាជនរដ្ឋធានី ភ្នំពេញពុំចេញវិញ្ញាបនបត្រជូនបានទេ។

២០-ពលរដ្ឋគ្រប់រូបមិនគោរពតាមខ្លឹមសារខាងលើនៃសារាចរនេះ ត្រូវទទួលខុសត្រូវ ចំពោះមុខច្បាប់ជាធរមាន។

២១-ក្នុងជំហានដកពិសោធន៍ដំបូងដើម្បីអនុវត្តអនុក្រឹត្យលេខ២៥អនក្រ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៨៩នេះ គណៈកម្មាធិការប្រជាជនរដ្ឋធានីភ្នំពេញជ្រើសរើសយកសង្កាត់ និងឃុំ ណាមួយក្នុងខណ្ឌ ស្រុកនីមួយៗ ដើម្បីធ្វើជាគំរូឈានទៅអនុវត្តទូទាំងរដ្ឋធានីភ្នំពេញ។ គណៈកម្មា ធិការប្រជាជនរដ្ឋធានីភ្នំពេញមានសេចក្តីសង្ឃឹម និងជឿជាក់ថា ផ្អែកលើសារាចរនេះ បណ្តាស្ថាប័ន ទាំងមជ្ឈិម និងក្រុងឋិតក្នុងភូមិសាស្ត្ររដ្ឋធានីភ្នំពេញត្រូវចាត់តាំងការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ជាបន្ទាន់ដល់កម្មាភិបាល កម្មករ និងប្រជាជនដែលឋិតក្នុងក្របខ័ណ្ឌរបស់ខ្លួន គ្រប់គ្រងធ្វើយ៉ាង ណាឱ្យបានយល់ច្បាស់លាស់ ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

**ជ.គណៈកម្មាធិការប្រជាជនរដ្ឋធានីភ្នំពេញ**

**ប្រធាន**

**ហត្ថលេខា និងត្រា**

**ថោង ខុន**

*កន្លែងទទួល*

-ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី *"ដើម្បីជ្រាបជាសេចក្តីរាយការណ៍"*

-គ្រប់ក្រសួង មន្ទីរ

-គ្រប់មន្ទីរ អង្គភាព ខណ្ឌ ស្រុកជុំវិញក្រុង *"ដើម្បីជួយសហការក្នុងការអនុវត្ត"*

-កាលប្បវត្តិ-ឯកសារ

រដ្ឋកម្ពុជា
ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

ក្រសួងកសិកម្ម
លេខ២៧៤៦ប្រក/កសក

ភ្នំពេញ ថ្ងៃទី០២ ខែសីហា ឆ្នាំ១៩៨៩

## ប្រកាស
## ស្តីពីការប្រើប្រាស់ឯកសារពាក់ព័ន្ធនឹងដីធ្លី

## រដ្ឋមន្ត្រីក្រសួងកសិកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា
- បានឃើញច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ០៣ក្រ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២
- បានឃើញក្រឹត្យច្បាប់លេខ០៧ក្រច ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៨២ ស្តីពីសមត្ថកិច្ច និងនីតិវិធីនៃការធ្វើច្បាប់ និងបទបញ្ជា
- បានឃើញអនុក្រឹត្យលេខ១៨អនក្រ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៨៤ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម
- បានឃើញសេចក្តីណែនាំអនុវត្តនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ០៣សណន ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី
- បានឃើញការចាំបាច់របស់ក្រសួងកសិកម្ម

## សម្រេច

**មាត្រា១**

ប្រកាសឱ្យប្រើជាផ្លូវការទូទាំងប្រទេសនូវ៖

-ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី

*វាយឡើងវិញ*

-បង្កាន់ដៃទទួលពាក្យស្នើសុំកាន់កាប់

-សៀវភៅទទួលពាក្យស្នើសុំកាន់កាប់

-សៀវភៅចុះបញ្ជីអចលនវត្ថុ

-ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ដែលក្រសួងកសិកម្មបានបោះពុម្ពលក់ចែកជូនតាមគំរូភ្ជាប់មកជាមួយនេះ ។

**មាត្រា២**

គណៈកម្មាធិការប្រជាជនគ្រប់ខេត្ត-ក្រុង ត្រូវចាត់តំណាងមកទាក់ទងនៅនាយកដ្ឋានសុរិយោដី ក្រសួងកសិកម្ម អំពីចំនួនសេចក្តីត្រូវការឯកសារខាងលើ ចាប់ពីថ្ងៃបានទទួលសេចក្តីប្រកាសនេះតទៅ ។

**មាត្រា៣**

មន្ទីរ នាយកដ្ឋានសុរិយោដី នាយកដ្ឋានផែនការ-ស្ថិតិ នាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ មន្ទីរកសិកម្មខេត្ត-ក្រុង ត្រូវទទួលបន្ទុករៀងៗខ្លួនអនុវត្តប្រកាសនេះ ។

**មាត្រា៤**

ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈ ។

| | | |
|---|---|---|
| *កន្លែងទទួល* | *លេខ៤៥សរ/សណ* | **រដ្ឋមន្ត្រីក្រសួងកសិកម្ម** |
| -ខុទ្ទកាល័យមជ្ឈិមបក្ស | បានឃើញ និងយល់ព្រម | **ហត្ថលេខា និងត្រា** |
| -ខុទ្ទកាល័យរដ្ឋសភា | ភ្នំពេញ ថ្ងៃទី០២ ខែសីហា ឆ្នាំ១៩៨៩ | **សាយ ឈុំ** |
| -ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ | **ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី** | |
| -គ្រប់ក្រសួង មន្ទីរជុំវិញមជ្ឈិម | **អនុប្រធាន** | |
| -គណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង | **ហត្ថលេខា និងត្រា** | |
| *"ដើម្បីជាព័ត៌មាន"* | **ជា សុទ្ធ** | |
| -ដូចក្នុងមាត្រា៣ | | |
| *"ដើម្បីអនុវត្ត"* | | |
| -កាលប្បវត្តិ-ឯកសារ | | |

**រដ្ឋកម្ពុជា**

ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

ក្រសួងកសិកម្ម-ក្រសួងហិរញ្ញវត្ថុ

លេខ០០៦០ប្រក/កសក-០០១កហវ

## ប្រកាសរួម
## ស្តីពីការកំណត់ប្រាក់ចំណូលពីការចេញឯកសារពាក់ព័ន្ធនឹងដីធ្លី

## រដ្ឋមន្ត្រីក្រសួងកសិកម្ម និងក្រសួងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា។
- បានឃើញច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ០៣ក្រ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២។
- បានឃើញក្រឹត្យ-ច្បាប់លេខ០៧ក្រច ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៨២ ស្តីពីសមត្ថកិច្ចនិងនីតិវិធីនៃការធ្វើច្បាប់ និងបទបញ្ជា។
- បានឃើញសេចក្តីសម្រេចលេខ០៦ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៧៩ របស់ក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា ស្តីពីការបង្កើតក្រសួងហិរញ្ញវត្ថុ។
- បានឃើញអនុក្រឹត្យលេខ១៨អនក្រ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៨៤ ស្តីពីតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម។
- បានឃើញសេចក្តីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ០៣សណន ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។

### សម្រេច

**មាត្រា១**

អនុញ្ញាតឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់តាមគំរូភ្ជាប់មកជាមួយនេះ នូវខ្ទង់ចំណូលដូចខាងក្រោម៖

-ប្រាក់ចំណូលពីការធ្វើអង្កេត វាស់វែងដែលមានទឹកប្រាក់ប្រាំរៀល "៥រ០០" សម្រាប់ដីមួយកន្លែង។

-ប្រាក់ចំណូលពីការកត់ត្រា និងកសាងឯកសារដែលមានទឹកប្រាក់ប្រាំរៀល "៥៖០០" សម្រាប់ដីមួយកន្លែង ។

-ប្រាក់ចំណូលពីការចុះបញ្ជិកាដែលមានទឹកប្រាក់សែសិបរៀល "៤០៖០០" សម្រាប់ដីមួយកន្លែង ។

**មាត្រា២**

បង្កាន់ដៃបង់ប្រាក់ទាំងបីប្រភេទខាងលើ ចែកជាបីច្បាប់ដូចជា៖

-១ច្បាប់ "សន្លឹកចុង" ជូនម្ចាស់ពាក្យស្នើ បន្ទាប់ពីបង់ប្រាក់រួច ។

-១ច្បាប់ "សន្លឹកកណ្តាល" ខ្ទាស់ជាប់នឹងពាក្យស្នើ ។

-១ច្បាប់ "សន្លឹកគល់" ទុកឯកសារក្បាលបញ្ជីសម្រាប់សរុបបង់ចូលធនាគារ ។

**មាត្រា៣**

ប្រាក់ចំណូលពីការធ្វើអង្កេត វាស់វែង និងប្រាក់ចំណូលពីការកត់ត្រា និងកសាងឯកសារត្រូវបង់ចូលថវិកាខេត្ត ។

ប្រាក់ចំណូលពីការចុះបញ្ជិកាត្រូវបង់ចូលថវិការដ្ឋ ។

**មាត្រា៤**

ប្រធានការិយាល័យស្រុក-ខណ្ឌ ជាអ្នកទទួលខុសត្រូវចេញបង្កាន់ដៃខាងលើដោយមានការឯកភាពពីប្រធានគណៈកម្មាធិការប្រជាជនស្រុក-ខណ្ឌ ហើយត្រូវបញ្ឈប់ក្បាលបង្កាន់ដៃដល់ថ្ងៃទី១០ និង២៥ រៀងរាល់ខែ រួចសរុបធ្វើការបង់ប្រាក់នៅធនាគារស្រុក-ខណ្ឌ ឬខេត្ត-ក្រុងដោយបែងចែកឱ្យតាមខ្ទង់ចំណូលឱ្យបានច្បាស់លាស់ ។

ប្រាក់ចំណូលទាំងនេះត្រូវកាត់ទុក២ភាគរយ សម្រាប់ផ្តល់ជូនការិយាល័យកសិកម្មស្រុកខណ្ឌ ជាប្រាក់បំណាច់ទទួលខុសត្រូវ ធានាការបាត់បង់ និងទុកដាក់ ។

**មាត្រា៥**

ការចំណាយដែលបានមកពីខ្ទង់ចំណូលនៃការធ្វើអង្កេតវាស់វែង ត្រូវសម្រេចដោយគណៈកម្មាធិការប្រជាជនខេត្ត យោលទៅតាមសភាពការណ៍ជាក់ស្តែង ក្នុងការចុះធ្វើអង្កេតវាស់វែង និងការផ្ទៀងផ្ទាត់ ពិនិត្យពិច័យស្ថានភាពដែលមានគម្រោងផែនការចំណាយថ្នាក់ស្រុក-ខណ្ឌ ។

ការចំណាយដែលបានមកពីខ្ទង់ចំណូលនៃការកត់ត្រា និងកសាងឯកសារត្រូវសម្រេចដោយប្រធានគណៈកម្មាធិការប្រជាជនខេត្ត យោលទៅតាមសភាពការណ៍ជាក់ស្តែងក្នុងការកត់ត្រាចុះបញ្ជី និងកសាងឯកសារ ដោយមានសំណើពីការិយាល័យកសិកម្មស្រុក-ខណ្ឌ ។

*វាយឡើងវិញ*

ការចំណាយដែលបានមកពីខ្ទង់ចំណូលនៃការចុះបញ្ជិកា ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ។

**មាត្រា៦**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**មាត្រា៧**

ប្រធានមន្ទីរ ប្រធានអង្គភាពពាក់ព័ន្ធរបស់ក្រសួងកសិកម្ម និងរបស់ក្រសួងហិរញ្ញវត្ថុ ប្រធានមន្ទីរកសិកម្ម និងប្រធានមន្ទីរហិរញ្ញវត្ថុគ្រប់ខេត្ត-ក្រុង ត្រូវទទួលបន្ទុករៀងៗខ្លួនអនុវត្តប្រកាសនេះ។

**មាត្រា៨**

ប្រកាសនេះមានអានុភាពគតិយុត្តចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈ។

*លេខ៤៨៨សរ/សណ* — ភ្នំពេញ ថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៨៩

| | | |
|---|---|---|
| បានឃើញ និងយល់ព្រម | **រដ្ឋមន្ត្រីក្រសួងកសិកម្ម** | **រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ** |
| ភ្នំពេញ ថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៨៩ | **ហត្ថលេខា និងត្រា** | **ហត្ថលេខា និងត្រា** |
| **ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី** | **សាយ ឈុំ** | **ឆាយ ថន** |
| **ហត្ថលេខា និងត្រា** | | |
| **ជា សុទ្ធ** | | |

*កន្លែងទទួល*

-ខុទ្ទកាល័យមជ្ឈិមបក្ស

-ខុទ្ទកាល័យរដ្ឋសភា

-ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ

-គ្រប់ក្រសួងមន្ទីរជុំវិញមជ្ឈិម

គណៈកម្មាធិការប្រជាជនខេត្ត-ក្រុង

*"ដើម្បីជូនជ្រាប"*

-ដូចក្នុងមាត្រា៧ *"ដើម្បីអនុវត្ត"*

- កាលប្បវត្តិ-ឯកសារ

*វាយឡើងវិញ*

រដ្ឋកម្ពុជា

ក្រសួងកសិកម្ម ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

លេខ៣៨៥៦កសក/ម/រប

ភ្នំពេញ ថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៨៩

រដ្ឋមន្ត្រីក្រសួងកសិកម្ម

ជម្រាបមក

សមមិត្តប្រធានគណៈកម្មាធិការប្រជាជនគ្រប់ខេត្ត-ក្រុង

កម្មវត្ថុ ការប្រើប្រាស់ឯកសារពាក់ព័ន្ធនឹងដីធ្លី

យោង -ប្រកាសលេខ២៧៤៦ប្រក/កសក ចុះថ្ងៃទី០២-០៨-៨៩ របស់ក្រសួងកសិកម្មស្តីពីការប្រើប្រាស់ឯកសារពាក់ព័ន្ធនឹងដីធ្លី។

-ស្មារតីវគ្គបំប៉ននកសាងឯកសារដីធ្លី ពីថ្ងៃទី០៣-១០-៨៩ ដល់០៥-១០-៨៩ របស់នាយកដ្ឋានសុរិយោដី។

ន័យដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបសមមិត្តប្រធានជ្រាបថា ក្នុងការអនុវត្តសេចក្តីណែនាំអនុវត្តលេខ០៣សណន ចុះថ្ងៃទី០៣-០៦-៨៩ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីពិសេសជំហានដំបូងក្នុងការដាក់ពាក្យ និងទទួលពាក្យស្នើសុំកាន់កាប់ដី អាចនឹងមានការរាំងស្ទះបញ្ជូនពាក្យពីភូមិ ឃុំ រហូតដល់ស្រុក ចំពោះដីដែលប្រជាជនភូមិ ឃុំ ស្រុកក្រៅមកធ្វើ។

ក្នុងន័យនេះ ក្រសួងកសិកម្មសូមធ្វើការណែនាំដូចតទៅ៖

ភូមិ ឃុំ ស្រុកមួយមានសល់ដីស្រែ-ចម្ការ ហើយបានត្រូវប្រជាជនភូមិ ឃុំ ស្រុកមួយទៀតមកធ្វើជារហូតដល់ថ្ងៃចេញសេចក្តីសម្រេចនេះ។ ក្នុងការដាក់ពាក្យស្នើសុំកាន់កាប់ដីភូមិ ឃុំ ស្រុកដែលមានដីត្រូវសម្រួលបញ្ជូនពាក្យ និងទទួលពាក្យរបស់ប្រជាជនដែលធ្លាប់កាន់កាប់នោះមិនត្រូវធ្វើឱ្យរាំងស្ទះដំណើរនេះឡើយ។

អាស្រ័យហេតុនេះ សូមសមមិត្តប្រធានមានវិធានការផ្សព្វផ្សាយដល់គ្រប់ភូមិ ដើម្បីអនុវត្តជំហានដំបូងឱ្យមានប្រសិទ្ធភាពតាមសំណូមពរ។

*វាយឡើងវិញ*

សូមសមមិត្តប្រធានទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ។

ជូនពរ សុខភាពល្អ និងជ័យជំនះគ្រប់ភារកិច្ចបដិវត្ត។

**អនុរដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ឈា សុង**

*កន្លែងទទួល*

-ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"

-នាយកដ្ឋានសុរិយោដី

"ដើម្បីមុខការ"

-ឯកសារ

រដ្ឋកម្ពុជា

ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

ក្រសួងកសិកម្ម

លេខ១១១ប្រក/កសក ភ្នំពេញ ថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៨៩

## ប្រកាស

## ស្តីពីការតែងតាំង និងសកម្មភាពនាយកដ្ឋានសុរិយោដី

### រដ្ឋមន្ត្រីក្រសួងកសិកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា
- បានឃើញច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ០៣ក្រ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២
- បានឃើញអនុក្រឹត្យលេខ១៨អនក្រ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៨៤ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម
- បានឃើញអនុក្រឹត្យលេខ៣១អនក្រ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ១៩៨៩ ស្តីពីការផ្ទេរនាយកដ្ឋានគ្រប់គ្រងគោលនយោបាយសេដ្ឋកិច្ចកសិកម្មឱ្យទៅជានាយកដ្ឋានសុរិយោដី
- បានឃើញការចាំបាច់របស់ក្រសួងកសិកម្ម

### សម្រេច

មាត្រា១

នាយកដ្ឋានសុរិយោដី ជាអង្គភាពមួយនៅក្នុងបន្ទុកក្រសួងកសិកម្ម មានទីតាំងនៅក្រុងភ្នំពេញ មានតួនាទីជាសេនាធិការជំនួយឱ្យក្រសួងកសិកម្ម លើការងារគ្រប់គ្រង និងប្រើប្រាស់ដីធ្លីទូទាំងប្រទេស។

មាត្រា២

នាយកដ្ឋានសុរិយោដីមានប្រព័ន្ធគ្រប់គ្រងឯកភាពទូទាំងប្រទេស មានសិទ្ធិដឹកនាំ និងត្រួតពិនិត្យលើរាល់អង្គការចាត់តាំងសុរិយោដីពីមជ្ឈិមដល់មូលដ្ឋាន ។

**មាត្រា៣**

នាយកដ្ឋានសុរិយោដីមានភារកិច្ចជាក់ស្តែងដូចខាងក្រោម៖

១-សិក្សាស្រាវជ្រាវរាល់គោលការណ៍ គោលនយោបាយរបស់បក្ស និងរដ្ឋដើម្បីកសាងគម្រោងលិខិតបទដ្ឋានទាំងឡាយដែលពាក់ព័ន្ធនឹងការគ្រប់គ្រង និងប្រើប្រាស់ដីធ្លីជូនថ្នាក់លើពិនិត្យ និងសម្រេច ព្រមទាំងចាត់តាំងអនុវត្តឱ្យបានល្អ និងមានប្រសិទ្ធភាព ។

២-កសាងទិសដៅផែនការ ដើម្បីបម្រើការងារដែលជាកម្មវត្ថុ និងមុខសញ្ញានៃតួនាទីភារកិច្ចរបស់នាយកដ្ឋានសុរិយោដី ។

៣-កសាងបណ្តាឯកសារដែលពាក់ព័ន្ធនឹងការគ្រប់គ្រងប្រើប្រាស់ដីធ្លី ។ ពិនិត្យ និងសម្រេចលើរាល់បណ្តាឯកសារស្នើសុំកាន់កាប់ដីធ្លីក្នុងក្របខ័ណ្ឌ និងសិទ្ធិអំណាចរបស់ខ្លួន ។

៤-ធ្វើការងារអភិរក្សសុរិយោដី និងអធិការកិច្ចនៅក្នុងតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់នាយកដ្ឋានសុរិយោដី ។

៥-អប់រំនយោបាយ សតិអារម្មណ៍ បំពាក់បំប៉ន បណ្តុះបណ្តាលបច្ចេកទេសដល់កម្មាភិបាល បុគ្គលិក កម្មករ ។

៦-លើកគម្រោងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសលើវិស័យវិទ្យាសាស្ត្រ បច្ចេកទេស ។

៧-សហការជាមួយបណ្តាអង្គភាពនៅក្នុងបន្ទុកក្រសួងកសិកម្ម និងបណ្តាក្រសួងផ្សេងៗទៀតដែលមានពាក់ព័ន្ធក្នុងភារកិច្ចគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ។

**មាត្រា៤**

អំពីរចនាសម្ព័ន្ធចាត់តាំងរបស់នាយកដ្ឋានសុរិយោដី

ក-ក្បាលម៉ាស៊ីនដឹកនាំ

នាយកដ្ឋានសុរិយោដី ដឹកនាំដោយប្រធាន១រូប និងបណ្តាអនុប្រធានមួយចំនួនជំនួយការគឺ៖ ប្រធាននាយកដ្ឋានសុរិយោដីទទួលបន្ទុកដឹកនាំរួម ទទួលបន្ទុកផ្ទាល់ ដោយឡែកការងារមួយចំនួន ទទួលខុសត្រូវលើរាល់សភាពការណ៍នៃការងារក្នុងនាយកដ្ឋានសុរិយោដីចំពោះមុខរដ្ឋ

មន្ត្រីក្រសួងកសិកម្ម។ ប្រធាននាយកដ្ឋានសុរិយោដីអនុវត្តសិទ្ធិដឹកនាំ តាមរបបប្រធានដែលបានកំណត់លើមូលដ្ឋាននេះ ត្រូវពង្រឹងពង្រីកឱ្យបានល្អរបបមូលភាពដឹកនាំ ជាក់ស្តែងប្រធាននាយកដ្ឋានសុរិយោដីមានភារកិច្ចចាត់ចែងការងារនយោបាយ សង្គមកិច្ច សេដ្ឋកិច្ច បច្ចេកទេស ចាត់តាំងក្បាលម៉ាស៊ីន បណ្តាផ្នែកនៅចំណុះការិយាល័យ និងចេញសេចក្តីសម្រេច ក្នុងសិទ្ធិអំណាចជាប្រធាននាយកដ្ឋានសុរិយោដី ដោយឡែកចំពោះការងារ កម្មាភិបាល ត្រូវឋិតនៅក្នុងមូលភាពថ្នាក់ដឹកនាំនាយកដ្ឋានពិនិត្យ និងសម្រេចដោយមានការចូលរួមមតិពីអង្គការចាត់តាំងបក្ស និងអង្គការចាត់តាំងអង្គការមហាជននៅក្នុងមូលដ្ឋាន។

បណ្តាអនុប្រធាននាយកដ្ឋានជាជំនួយការឱ្យប្រធាននាយកដ្ឋាន ត្រូវបានប្រធានបែងចែកប្រគល់ការងារមួយចំនួនឱ្យទទួលបន្ទុក ត្រូវរាយការណ៍ និងទទួលការណែនាំពីប្រធាន ហើយនិងទទួលខុសត្រូវចំពោះមុខប្រធាន លើរាល់សភាពការណ៍ក្នុងការងារ ដែលបានបែងចែកប្រគល់ឱ្យទទួលបន្ទុក ទន្ទឹមនេះក៏រួមជាមួយប្រធាន ទទួលខុសត្រូវលើរាល់សភាពការណ៍នៃការងារ ក្នុងនាយកដ្ឋានចំពោះមុខរដ្ឋមន្ត្រីក្រសួងកសិកម្ម។

ខ-ក្បាលម៉ាស៊ីនចាត់តាំង

បណ្តាការិយាល័យសេនាធិការជំនួយការផ្ទាល់របស់នាយកដ្ឋានសុរិយោដីមាន៥គឺ៖

១-ការិយាល័យរដ្ឋបាល និងចាត់តាំង

២-ការិយាល័យផែនការ និងគណនេយ្យ

៣-ការិយាល័យកិច្ចការថ្មី

៤-ការិយាល័យអភិរក្សសុរិយោដី

៥-ការិយាល័យអធិការកិច្ចភូមិបាល។

តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់បណ្តាការិយាល័យនៅចំណុះនាយកដ្ឋានសុរិយោដី ត្រូវសម្រេចដោយប្រធាននាយកដ្ឋានសុរិយោដី ដោយឡែកប្រធាន អនុប្រធានការិយាល័យត្រូវសម្រេចតែងតាំង ឬបញ្ជប់ដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម។

នាយកដ្ឋានសុរិយោដីមានបណ្តាញអង្គការចាត់តាំងសុរិយោដី ធ្វើសកម្មភាពនៅតាមមូលដ្ឋានខេត្ត-ក្រុង ស្រុក-ខណ្ឌ ជាជំនួយការដល់នាយកដ្ឋានសុរិយោដីគឺ៖

-នៅខេត្ត-ក្រុងមានការិយាល័យសុរិយោដីខេត្ត-ក្រុង មានថ្នាក់ស្មើការិយាល័យនៅចំណុះនាយកដ្ឋាននៃក្រសួងមន្ទីរជុំវិញមជ្ឈិម ដែលសម្រេចចាត់តាំងបង្កើត ឬរំសាយចោលដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម។ ការិយាល័យសុរិយោដីខេត្ត-ក្រុងដឹកនាំដោយប្រធាន១រូប និងបណ្ដាអនុប្រធានមួយចំនួនជំនួយការដែលសម្រេចតែងតាំង ឬបញ្ឈប់ដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម ដោយមានការស្ទាបស្ទង់យោបល់ពីមូលដ្ឋាន។

-នៅស្រុក-ខណ្ឌមានការិយាល័យភូមិបាលស្រុក-ខណ្ឌ មានថ្នាក់ស្មើការិយាល័យ ហើយនៅចំណុះគណៈកម្មាធិការប្រជាជនស្រុក-ខណ្ឌដែលសម្រេចចាត់តាំង ឬរំសាយចោលដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម។ ការិយាល័យភូមិបាលស្រុក-ខណ្ឌដឹកនាំដោយប្រធាន១រូប និងបណ្ដាអនុប្រធានមួយចំនួនជំនួយការដែលសម្រេចតែងតាំង ឬបញ្ឈប់ដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម ដោយមានការស្ទាបស្ទង់យោបល់ពីមូលដ្ឋាន។

**មាត្រា៥**

តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ការិយាល័យសុរិយោដីខេត្ត-ក្រុង និងការិយាល័យភូមិបាលស្រុក-ខណ្ឌ អាស្រ័យដោយប្រធាននាយកដ្ឋានសុរិយោដីពិនិត្យ សម្រេចដោយមានមតិឯកភាពពីក្រសួងកសិកម្ម។

**មាត្រា៦**

អង្គការចាត់តាំងសុរិយោដីនៅមូលដ្ឋាន ត្រូវឋិតនៅក្រោមការដឹកនាំផ្នែករដ្ឋបាល និងនយោបាយ សតិអារម្មណ៍របស់មូលដ្ឋាន។

**មាត្រា៧**

ក្របខ័ណ្ឌរបស់អង្គការចាត់តាំងសុរិយោដីទាំងអស់ ជាក្របខ័ណ្ឌរបស់នាយកដ្ឋានសុរិយោដីដែលត្រូវបានក្រសួងកសិកម្មសម្រេចកំណត់បែងចែកប្រគល់ឱ្យរាល់អង្គការចាត់តាំងទាំងនោះ យកទៅប្រើប្រាស់ដោយយោងតាមសំណើរបស់ប្រធាននាយកដ្ឋានសុរិយោដី។

**មាត្រា៨**

គណៈកម្មាធិការប្រជាជនខេត្ត-ក្រុង មន្ទីរនាយកដ្ឋានចាត់តាំង និងកម្មាភិបាលនាយកដ្ឋានសុរិយោដីគ្រប់អង្គភាពក្នុងបន្ទុកក្រសួងកសិកម្ម មានភារកិច្ចអនុវត្តប្រកាសនេះចាប់ពីថ្ងៃដែលបានចុះហត្ថលេខាតទៅ។

**រដ្ឋកម្ពុជា**

**ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល**

**ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី**

លេខ៩៤សជណ/កស

ភ្នំពេញ ថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៩០

**រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី**

**ជម្រាបមក**

**សមមិត្តរដ្ឋមន្ត្រីក្រសួងកសិកម្ម**

កម្មវត្ថុ ករណីសំណើសុំអនុញ្ញាតពន្យារពេលទទួលពាក្យស្នើសុំកាន់កាប់ដីធ្លីរហូតដល់ថ្ងៃទី៣០-០៦-១៩៩០ របស់ក្រសួងកសិកម្ម។

យោង -លិខិតលេខ១៣៦កសក ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ១៩៩០ របស់ក្រសួងកសិកម្ម។

-ចំណារសមមិត្តអនុប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩០។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបសមមិត្តរដ្ឋមន្ត្រីជ្រាបថា៖ ក្រុមប្រឹក្សារដ្ឋមន្ត្រីបានឯកភាពឱ្យក្រសួងកសិកម្មពន្យារពេលទទួលពាក្យស្នើសុំកាន់កាប់ដីធ្លី រហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩០ តាមសំណើហើយ។

អាស្រ័យហេតុនេះ ស្នើសមមិត្តរដ្ឋមន្ត្រីជ្រាប និងចាត់ចែងអនុវត្តតាមន័យដូចបានជម្រាបជូនខាងលើ។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី**

**អនុរដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ប៊ុន អ៊ុយ**

កន្លែងទទួល

-ក្រសួងផែនការ

"ដើម្បីជ្រាបជាព័ត៌មាន"

-នាយកដ្ឋានសរុប

- ឯកសារ

រដ្ឋកម្ពុជា
ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

ក្រុមប្រឹក្សារដ្ឋមន្ត្រី
លេខ០១សរ ភ្នំពេញ ថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៩០

## សារាចរស្តីពី
## ការគ្រប់គ្រងគេហដ្ឋាន ដីធ្លីដែលជួលឱ្យអង្គការអន្តរជាតិ ក្រុមហ៊ុន ឬជនបរទេស

ក្នុងទិសពង្រីកកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ ជាមួយបណ្តាប្រទេសសង្គមនិយម ជាបងប្អូន និងអង្គការអន្តរជាតិនានា ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ចឱ្យមានប្រសិទ្ធភាព និងបង្កលក្ខណសម្បត្តិឱ្យក្រុមហ៊ុន ឬភ្ញៀវបរទេសចូលមកធ្វើអាជីវកម្ម ផលិតកម្មដើម្បីរួមចំណែកស្តារសេដ្ឋកិច្ច សង្គមកិច្ចរបស់ប្រទេសជាតិ បញ្ហាដោះស្រាយគេហដ្ឋាន ដីធ្លីសម្រាប់បណ្តាអង្គការអន្តរជាតិ ក្រុមហ៊ុន ឬភ្ញៀវបរទេសនៅទីក្រុងភ្នំពេញ និងតាមទីរួមខេត្តនានា គឺជាការចាំបាច់សំខាន់មួយផ្នែកដែរ។

ផ្អែកតាមសភាពការណ៍នេះ ក្រុមប្រឹក្សារដ្ឋមន្ត្រីកំណត់នូវវិធានការចាំបាច់ចំពោះមុខដូចខាងក្រោមនេះ៖

១-ជនបរទេសដែលបានទទួលការអនុញ្ញាតឱ្យស្នាក់នៅក្នុងរដ្ឋកម្ពុជា មានសិទ្ធិជួលគេហដ្ឋាន ដីធ្លីបាន។

២-ក្រសួងការបរទេស ក្រសួងមហាផ្ទៃ និងគណៈកម្មាធិការប្រជាជនខេត្ត-ក្រុងត្រូវរួមគ្នាទទួលខុសត្រូវក្នុងការរៀបចំគេហដ្ឋាន ដីធ្លីដល់បណ្តាអង្គការអន្តរជាតិ ក្រុមហ៊ុន ឬភ្ញៀវបរទេសដែលធ្វើសកម្មភាពនៅតាមខេត្ត-ក្រុងនីមួយៗ ដោយត្រូវយកចិត្តទុកដាក់សំខាន់បំផុតដល់បញ្ហាថែរក្សា ការពារសន្តិសុខជូនភ្ញៀវឱ្យបានល្អ។

៣-អនុញ្ញាតឱ្យពលរដ្ឋកម្ពុជាអាចជួលគេហដ្ឋាន ដីធ្លីជាកម្មសិទ្ធិរបស់ខ្លួនដល់អង្គការអន្តរជាតិ ក្រុមហ៊ុន ឬភ្ញៀវបរទេសណាដែលមានការអនុញ្ញាតឱ្យស្នាក់អាស្រ័យនៅ និងធ្វើបេសកកម្មនៅក្នុងរដ្ឋកម្ពុជាពីក្រសួងការបរទេស។ ការជួលគេហដ្ឋាន ដីធ្លីនេះ ត្រូវមានការអនុញ្ញាតពីគណៈកម្មាធិការប្រជាជនខេត្ត-ក្រុង ដោយមានយោបល់ឯកភាពពីក្រសួងមហាផ្ទៃ និងក្រសួងការបរទេស។

ពលរដ្ឋកម្ពុជាដែលមានគេហដ្ឋាន ដីធ្លីជាកម្មសិទ្ធិ ហើយមានបំណងចង់ជួលឱ្យជនបរទេស ចាំបាច់ត្រូវមកចុះឈ្មោះផ្តល់ព័ត៌មានដល់គណៈកម្មាធិការប្រជាជនខេត្ត-ក្រុង។

៤-ក្នុងការកំណត់ថ្លៃឈ្នួលគេហដ្ឋាន ដីធ្លីជាមូលដ្ឋានសម្រាប់ជនបរទេស គណៈកម្មាធិការប្រជាជនខេត្ត-ក្រុង រៀបចំបទដ្ឋានមួយនៅតាមភូមិសាស្ត្រ និងប្រភេទគេហដ្ឋាន ដីធ្លីនីមួយៗ។ ផ្អែកតាមថ្លៃឈ្នួលជាមូលដ្ឋាននេះ ម្ចាស់គេហដ្ឋាន ដីធ្លីនឹងពិភាក្សាលំអិតជាក់ស្តែងថែមទៀតឱ្យឯកភាពជាមួយអ្នកទទួលជួល។

៥-ម្ចាស់កម្មសិទ្ធិគេហដ្ឋាន ដីធ្លីដែលជួលឱ្យជនបរទេសត្រូវមានកាតព្វកិច្ចដូចតទៅ៖

-ចូលរួមក្នុងចលនាការពារសន្តិសុខ សណ្តាប់ធ្នាប់សង្គម។

-ត្រូវបង់ពន្ធប៉ាតង់ និងពន្ធអាជីវកម្មចំពោះចំណូលដែលបានមកពីការជួលគេហដ្ឋាន ដីធ្លីតាមបណ្តាក្រឹត្យ-ច្បាប់ដែលមានចែង។

-ត្រូវបើកគណនីជាប្រាក់រៀលនៅធនាគារ ហើយត្រូវផ្ទេរថ្លៃឈ្នួលគេហដ្ឋាន ដីធ្លីពីរូបិយប័ណ្ណបរទេសមកជាប្រាក់រៀលតាមអត្រាប្តូរប្រាក់ ដែលប្រកាសផ្សាយដោយធនាគារជាតិកម្ពុជាបញ្ចូលទៅក្នុងគណនីខាងលើ។

-កិច្ចសន្យាជាលាយលក្ខណ៍អក្សរជួលគេហដ្ឋាន ដីធ្លីឱ្យជនបរទេសត្រូវបានការឯកភាពពីគណៈកម្មាធិការប្រជាជនខេត្ត-ក្រុង។

៦-អ្នកជួលគេហដ្ឋាន ដីធ្លី មានកាតព្វកិច្ចគោរពតាមកិច្ចសន្យាដែលបានឯកភាពចុះហត្ថលេខាជាមួយម្ចាស់គេហដ្ឋាន ដីធ្លី។

គ្រប់ក្រសួង ស្ថាប័ន គណៈកម្មាធិការប្រជាជនខេត្ត-ក្រុងផ្អែកលើខ្លឹមសារនៃសារាចរ នេះត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងចាត់តាំងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

*វាយឡើងវិញ*

**រដ្ឋកម្ពុជា**

**ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល**

ក្រសួងកសិកម្ម

លេខ៤៨៥កសក/ម/រប

ភ្នំពេញ ថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩០

**រដ្ឋមន្ត្រីក្រសួងកសិកម្ម**

**សូមជម្រាបមក**

**សមមិត្តប្រធានគណៈកម្មាធិការប្រជាជនគ្រប់ខេត្ត-ក្រុង**

<u>កម្មវត្ថុ</u> ការពន្យារពេលទទួលពាក្យស្នើសុំកាន់កាប់ដីធ្លី រហូតដល់ថ្ងៃទី៣០-០៦-៩០។

<u>យោង</u> -សារទូរលេខរបស់ក្រសួងកសិកម្មលេខ១៣៥កសក/ម/រប ចុះថ្ងៃទី០៩-០១-៩០ ស្ដីពីការពន្យារពេលទទួលពាក្យស្នើសុំកាន់កាប់ដីធ្លី។

-លិខិតរបស់ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រីលេខ៩៤សជណ/កស ចុះថ្ងៃទី១៧ មករា ១៩៩០ "ជូនភ្ជាប់"។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបសមមិត្តប្រធានជ្រាបថា៖ ក្រុមប្រឹក្សារដ្ឋមន្ត្រីបានឯកភាពឱ្យក្រសួងកសិកម្មពន្យារពេលទទួលពាក្យស្នើសុំកាន់កាប់ដីធ្លី រហូតដល់ថ្ងៃទី៣០ មិថុនា ឆ្នាំ១៩៩០។

អាស្រ័យហេតុនេះ សូមសមមិត្តប្រធានចាត់ការទទួលពាក្យស្នើសុំកាន់កាប់ដីធ្លីបន្តរហូតដល់ថ្ងៃកំណត់ដូចបានជម្រាបជូនខាងលើ។

**ជ.រដ្ឋមន្ត្រីក្រសួងកសិកម្ម**

**អនុរដ្ឋមន្ត្រីទី១**

**ហត្ថលេខា និងត្រា**

**ឈា សុង**

*<u>ចម្លងជូន</u>*

-ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី

*"ដើម្បីជូនជ្រាប"*

-នាយកដ្ឋានសុរិយោដី

*"ដើម្បីអនុវត្ត"*

- ឯកសារ-កាលប្បវត្តិ

**រដ្ឋកម្ពុជា**

**ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល**

**ក្រសួងកសិកម្ម**

លេខ១៣១កសក/សរណន ភ្នំពេញ ថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៩០

**សារាចរណែនាំ**

**ស្តីពីគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី**

យោងស្មារតីសេចក្តីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ០៣ សណន ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី និងលិខិតលេខ៤៨៥កសក/មរប ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩០ របស់ក្រសួងកសិកម្មស្តីពីការពន្យារពេលសម័យទទួលពាក្យស្នើសុំកាន់កាប់ដីធ្លី ក្រសួងកសិកម្មសង្កេតឃើញថា ខេត្ត-ក្រុងមួយចំនួនបានខិតខំយកចិត្តទុកដាក់ជំរុញការអនុវត្តបានល្អបង្គួរ ដោយរៀបចំបណ្តាញទទួលពាក្យពីប្រជាជនគ្រប់គ្រងចំណូលពីការដាក់ពាក្យ និងបណ្តាវិធានការជាក់ស្តែងផ្សេងៗទៀត មានការបើកវគ្គផ្សព្វផ្សាយ ការបញ្ចុះកម្មាភិបាលចុះជួយ ការត្រួតពិនិត្យ។ល។ ទន្ទឹមនោះ ក៏មានខេត្ត-ក្រុងខ្លះមិនទាន់អនុវត្តបានល្អ និងសមស្របនៅឡើយ។

អាស្រ័យហេតុនេះ ក្រសួងកសិកម្មសូមធ្វើការណែនាំលំអិត ដល់គណៈកម្មាធិការប្រជាជនគ្រប់ខេត្ត-ក្រុងដូចតទៅ៖

**១.ការអនុវត្តជំហានទី១**

ជំហាននេះគឺសម័យទទួលពាក្យស្នើសុំកាន់កាប់ដីធ្លី ដែលត្រូវបិទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩០។ ដូច្នេះបណ្តាខេត្ត-ក្រុងត្រូវខិតខំយ៉ាងណាអនុវត្តឱ្យបានសម្រេច ក្នុងរយៈពេលនេះដោយមិនអនុញ្ញាតឱ្យពន្យារពេលទទួលពាក្យជាលើកទី២ទៀតទេ។

ក្នុងការទទួលពាក្យ មូលដ្ឋានស្រុក-ខណ្ឌជួបការលំបាកអំពីបញ្ហាចុះហត្ថលេខា លើបង្កាន់ដៃបង់ប្រាក់គ្រប់ប្រភេទ។ ក្រសួងកសិកម្មសូមជម្រាបថា ក្នុងការចុះហត្ថលេខានេះមិនមែនសំដៅ

តែប្រធានគណៈកម្មាធិការប្រជាជនស្រុកតែម្នាក់ទេ គឺបណ្ដាសមមិត្ត ក្នុងជួរគណៈកម្មាធិការប្រជាជនស្រុក-ខណ្ឌ "ប្រធាន អនុប្រធាន សមាជិកអចិន្ត្រៃយ៍" អាចចុះហត្ថលេខាបាន។ តែបញ្ហាដែលត្រូវចៀសវាង គឺមិនអនុញ្ញាតឱ្យឆ្លាក់ត្រាហត្ថលេខាបោះលើបង្កាន់ដៃ ឬអូសស្ដង់ស៊ីលហត្ថលេខាផ្ដិតលើបង្កាន់ដៃទេ។

ទន្ទឹមនឹងនោះសូមគណៈកម្មាធិការប្រជាជនខេត្ត-ក្រុង ស្រុក-ខណ្ឌ ជំរុញការទូទាត់ឯកសារ និងការបង់ប្រាក់នៅធនាគារ បណ្ដាចំណូលពីការចេញបង្កាន់ដៃ "ក,ខ,គ" ដែលមានចែងក្នុងប្រកាសរួមរបស់ក្រសួងកសិកម្ម និងហិរញ្ញវត្ថុលេខ០០៦០ប្រក/កសក ០០១កហវ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៨៩ ស្រាប់ "តារាងភ្ជាប់"។

**២.ការអនុវត្តជំហានទី២**

ជំហាននេះគឺសម័យធ្វើអង្កេតវាស់វែង និងចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លី ធ្វើជូនប្រជាជនដែលត្រូវចាប់ដំណើរការបន្ទាប់ពីបិទសម័យទទួលពាក្យ។

ក្នុងការត្រៀមអនុវត្តជំហាននេះ ក្រសួងកសិកម្មបើកវគ្គវិក្រឹត្យការជំនាញសុរិយោដី និងច្បាប់ រយៈពេល៣៩ថ្ងៃ "ពីថ្ងៃ១៩ កុម្ភៈ ដល់២៤ មីនា ឆ្នាំ១៩៩០" ជូនកម្មាភិបាលខេត្ត-ក្រុងទាំង២១រួចហើយ។ ដូច្នេះគ្រប់ខេត្ត-ក្រុងត្រូវចាត់រៀបចំបើកវគ្គវិក្រឹត្យការ បន្តជូនដល់កម្មាភិបាលគ្រប់ស្រុក-ខណ្ឌ ឃុំ-សង្កាត់ ដើម្បីមានការយល់ដឹងងាយស្រួលអនុវត្តជំហានទី២នេះ។

ម្យ៉ាងទៀត ដើម្បីមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការសរុបរាយការណ៍ជូនក្រុមប្រឹក្សារដ្ឋមន្ត្រីក្រសួងកសិកម្ម សូមឱ្យបណ្ដាខេត្ត-ក្រុងធ្វើរបាយការណ៍អំពីសភាពការណ៍អនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លីតាមចំណុចដូចខាងក្រោម៖

-ការទទួលពាក្យសរុបក្នុងខេត្ត-ក្រុង............ ត្រូវជា.................. កន្លែង

-ការចេញបង្កាន់ដៃបង់ប្រាក់ "ក"................ បង្កាន់ដៃត្រូវជា....... រៀល

-ការចេញបង្កាន់ដៃបង់ប្រាក់ "ខ"................ បង្កាន់ដៃត្រូវជា....... រៀល

-ការចេញបង្កាន់ដៃបង់ប្រាក់ "គ"................ បង្កាន់ដៃត្រូវជា....... រៀល

-ការទូទាត់ថ្លៃពាក្យស្មើ............................. រៀលត្រូវជា............ ភាគរយ

-ការវាយតម្លៃ

*វាយឡើងវិញ*

-ការលំបាក និងការងាយស្រួល

-សំណូមពរ

-សន្និដ្ឋាន

របាយការណ៍នេះស្នើផ្ញើមកដល់ក្រសួងកសិកម្មមុនថ្ងៃ១០ ខែមិថុនា ឆ្នាំ១៩៩០។

ក្រសួងកសិកម្មមានសង្ឃឹមយ៉ាងមាំថា សមមិត្តប្រធានគណៈកម្មាធិការប្រជាជនខេត្ត ក្រុង នឹងខិតខំជំរុញអនុវត្តឱ្យបានសម្រេច តាមស្មារតីសេចក្តីសម្រេចចិត្តរបស់សន្និបាតកម្មាភិបាលទូទាំងប្រទេសលើកទី II ស្តីពីគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លីជាពុំខាន។

**ជ.រដ្ឋមន្ត្រីក្រសួងកសិកម្ម**

**អនុរដ្ឋមន្ត្រីទី១**

**ហត្ថលេខា និងត្រា**

**ឈា សុង**

*ចម្លងជូន*

-ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី

*"ដើម្បីជូនជ្រាប"*

-គ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម

*"ដើម្បីជាព័ត៌មាន"*

-នាយកដ្ឋានសុរិយោដី

*"ដើម្បីមុខការ"*

- ឯកសារ

រដ្ឋកម្ពុជា

ក្រសួងកសិកម្ម ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

លេខ៣៤៩១កសក/សជណ

ភ្នំពេញ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៩០

## សេចក្តីជូនដំណឹង
## ស្តីពីការទទួលពាក្យស្នើសុំកាន់កាប់ដីធ្លី និងវិធានការអនុវត្តបន្ត

យោងតាមស្មារតីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រងប្រើប្រាស់ដីធ្លីលេខ០៣សណន ចុះថ្ងៃទី០៣-០៦-៨៩ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី និងលិខិតលេខ៤៨៥កសក/ម/របចុះថ្ងៃទី២៩-០១-៩០ របស់ក្រសួងកសិកម្មស្តីពីការពន្យារពេលសម័យទទួលពាក្យស្នើសុំកាន់កាប់ដីធ្លី រហូតដល់ថ្ងៃទី៣០-០៦-៩០ កន្លងមកនេះ ក្រសួងកសិកម្មពិនិត្យឃើញថា គ្រប់ខេត្ត-ក្រុងទាំងអស់មិនអាចអនុវត្តបាន១០០ភាគរយតាមកាលកំណត់ឡើយ។ ទន្ទឹមនេះ ខេត្តមួយចំនួនមិនបានធ្វើរបាយការណ៍តែម្តង។

ចំពោះមុខសភាពការណ៍នេះ ក្រុមប្រឹក្សារដ្ឋមន្ត្រីនាសម័យប្រជុំថ្ងៃទី៥-៦-៧ កក្កដា ១៩៩០ បានសម្រេចអនុញ្ញាតឱ្យទទួលពាក្យស្នើសុំកាន់កាប់ដីពីប្រជាជនដែលមិនទាន់បានដាក់ជាបន្តទៅទៀត។

ដើម្បីអនុវត្តបន្តឱ្យបានល្អ និងមានប្រសិទ្ធភាពតាមសេចក្តីណែនាំរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រសួងកសិកម្មសូមធ្វើការណែនាំបន្ថែមដល់គណៈកម្មាធិការប្រជាជនគ្រប់ខេត្ត-ក្រុងនូវចំណុចមួយចំនួនដូចតទៅ៖

**១_ការអនុវត្តជំហានទី១**

-ទទួលពាក្យស្នើសុំកាន់កាប់ដីធ្លីពីប្រជាជនដែលមិនទាន់បានជាបន្តទៅទៀត។

-ក្នុងអំឡុងខែកក្កដា ជំរុញគ្រប់ស្រុកជម្រះបញ្ជិកាក្នុងការចេញបង្កាន់ដៃបង់ប្រាក់ បង្កាន់ដៃទទួលពាក្យឱ្យអស់តាមចំនួនពាក្យដែលបានទទួល។

-ជំរុញកម្មាភិបាលទទួលបន្ទុកសុរិយោដីគ្រប់គ្រងចំណូលតាមប្រភេទ បង់ចូលធនាគារ និងរាយការណ៍តាមក្រសួងកសិកម្ម ។

-គណៈកម្មាធិការប្រជាជនគ្រប់ស្រុក-ខណ្ឌត្រូវចេញប្រកាស អញ្ជើញសាមីអ្នកស្នើសុំកាន់កាប់ដីធ្លីតាមចំនួនជាក់ស្តែង ឱ្យជួបជុំតាមកាលកំណត់របស់គណៈកម្មាធិការកណ្តាល ដើម្បីចាប់ផ្តើមបើកអង្កេតវាស់វែងតាមភូមិ ឃុំ ។

-មានវិធានការទប់ស្កាត់យ៉ាងម៉ឺងម៉ាត់ ចំពោះបាតុភាពឆ្លៀតឱកាសជីវិតយកប្រាក់ពីប្រជាជន-បំប៉ោងថ្លៃឯកសារលើសពីការកំណត់របស់រដ្ឋ ។ល ។

-ទប់ស្កាត់កុំឱ្យមានការដកហូត ឬសើរើបែងចែកដីដែលប្រជាជនបានកាន់កាប់ ហើយមុនថ្ងៃចេញសេចក្តីសម្រេចចិត្តរបស់សន្និបាតកម្មាភិបាលទូទាំងប្រទេសលើកទី II ទោះជាដីនេះប្រជាជនមិនទាន់បានដាក់ពាក្យនៅឡើយក៏ដោយ ។

-ដោយឡែក រដ្ឋធានីភ្នំពេញ "ខណ្ឌទាំង៤" នឹងត្រូវធ្វើការប្រកាសទទួលពាក្យស្នើសុំកាន់កាប់ដីធ្លី "រយៈ២ខែ" ក្រោយពេលការិយាល័យសុរិយោដីក្រុងដំណើរការ ។

-ចាត់ចុះធ្វើអធិការកិច្ច ដើម្បីត្រួតពិនិត្យការងារ និងប្រមូលចំណូលបង់ចូលថវិការដ្ឋ ។

**២-ការអនុវត្តជំហានទី២**

-ខេត្ត-ក្រុងដែលមិនទាន់បានបើកវគ្គវិក្រឹត្យការជំនាញសុរិយោដី និងច្បាប់ ត្រូវជំរុញការបើកវគ្គជូនដល់កម្មាភិបាលគ្រប់ស្រុក-ខណ្ឌ ឃុំ-សង្កាត់ ដើម្បីងាយស្រួលដល់ការអនុវត្តជំហានទី២ គឺអង្កេត វាស់វែង និងចេញប័ណ្ណ ។

-អនុវត្តការងារធ្វើអង្កេត វាស់វែង និងប្រគល់ប័ណ្ណសម្គាល់សិទ្ធិ ។

-ទំនាក់ទំនងទទួលយកឯកសារ សម្រាប់ធ្វើកំណត់ហេតុអង្កេតពីក្រសួងកសិកម្ម "នាយកដ្ឋានសុរិយោដី"

-ចំពោះដីទំនាស់ យើងមិនទាន់ចេញប័ណ្ណជូនទេ រង់ចាំការសម្រុះសម្រួល ក្នុងករណីដែលអាចសម្រុះសម្រួលបាន ឬការសម្រេចពីស្ថាប័នមានសមត្ថកិច្ច ក្នុងករណីទំនាស់ធ្ងន់ធ្ងរ ។

ម្យ៉ាងទៀត ចំពោះខេត្ត-ក្រុងដែលមិនទាន់បានធ្វើសំណើចាត់តាំងកម្មាភិបាលដឹកនាំការិយាល័យសុរិយោដីខេត្ត-ក្រុង និងការិយាល័យភូមិបាលស្រុក-ខណ្ឌ ស្នើសហការជាមួយគណៈ

*វាយឡើងវិញ*

កម្មាធិការបក្សពិនិត្យ និងធ្វើការវាយតម្លៃលើកសំណើមកក្រសួងកសិកម្ម ដើម្បីក្រសួងកសិកម្មមានលទ្ធភាពចាត់ការបន្ត។

ក្រសួងកសិកម្មមានសង្ឃឹមថា សមមិត្តប្រធានគណៈកម្មាធិការប្រជាជនគ្រប់ខេត្ត-ក្រុងនឹងខិតខំជំរុញអនុវត្តបានជោគជ័យ តាមស្មារតីនៃសេចក្តីសម្រេចចិត្តរបស់សន្និបាតកម្មាភិបាលទូទាំងប្រទេសលើកទី II ស្តីពីគោលនយោបាយគ្រប់គ្រង ប្រើប្រាស់ដីធ្លីជាពុំខាន។

**រដ្ឋមន្ត្រីក្រសួងកសិកម្ម**

**ហត្ថលេខា និងត្រា**

**សាយ ឈុំ**

*ចម្លងជូន*

-ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី

*"ដើម្បីជូនជ្រាប"*

-គ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម

-គ្រប់មន្ទីរកសិកម្មខេត្ត-ក្រុង

*"ដើម្បីជាព័ត៌មាន"*

-នាយកដ្ឋានសុរិយោដី

*"ដើម្បីមុខការ"*

-ឯកសារ-កាលប្បវត្តិ

រដ្ឋកម្ពុជា

ក្រសួងកសិកម្ម-ក្រសួងហិរញ្ញវត្ថុ ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

លេខ៣៥៤ប្រក/កសក-០១២កហវ

## ប្រកាសរួមស្តីពីការកំណត់ប្រាក់ចំណូលពីការចេញឯកសារពាក់ព័ន្ធនឹងដីធ្លី

### រដ្ឋមន្ត្រីក្រសួងកសិកម្ម
### និងរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា
- បានឃើញច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ០៣ក្រ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២
- បានឃើញក្រឹត្យ-ច្បាប់លេខ០៧ក្រច ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៨២ ស្តីពីសមត្ថកិច្ច និងនីតិវិធីនៃការធ្វើច្បាប់ និងបទបញ្ជា។
- បានឃើញសេចក្តីសម្រេចលេខ០៦ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៨៤ របស់ក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា ស្តីពីការបង្កើតក្រសួងហិរញ្ញវត្ថុ។
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៨៤ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម
- បានឃើញសេចក្តីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ០៣សណន ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។

### សម្រេច

**មាត្រា១**

មាត្រា៥ និងមាត្រា៧ នៃប្រកាសរួមលេខ០០៦០ប្រក/កសក ០០១កហវ ចុះថ្ងៃទី០៧ សីហា ឆ្នាំ១៩៨៩ ត្រូវបានកែប្រែដូចខាងក្រោម៖

*មាត្រា៥ថ្មី* ការចំណាយដែលបានមកពីខ្ទង់ចំណូលនៃការធ្វើអង្កេតវាស់វែង និងចំណូលពីការកត់ត្រា និងកសាងឯកសារ ត្រូវសម្រេចដោយប្រធានគណៈកម្មាធិការប្រជាជនខេត្ត-ក្រុង យោលទៅតាមសភាពការណ៍ជាក់ស្តែង ក្នុងការធ្វើអង្កេត វាស់វែង ការកត់ត្រាចុះបញ្ជី និងការកសាងឯកសារ ដោយមានគម្រោងចំណាយពីការិយាល័យសុរិយោដីខេត្ត-ក្រុង។

*វាយឡើងវិញ*

ការចំណាយដែលបានមកពីខ្ទង់ចំណូលនៃការចុះបញ្ជិកា ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ។

*មាត្រា៧ថ្មី* ប្រធានមន្ទីរ ប្រធានអង្គការពាក់ព័ន្ធរបស់ក្រសួងកសិកម្ម និងរបស់ក្រសួងហិរញ្ញវត្ថុ ប្រធានការិយាល័យសុរិយោដី និងប្រធានមន្ទីរហិរញ្ញវត្ថុគ្រប់ខេត្ត-ក្រុង ត្រូវទទួលបន្ទុករៀងៗខ្លួនអនុវត្តប្រកាសនេះ។

**មាត្រា២**

មាត្រា១, ២, ៣, ៤ និង៦ នៃប្រកាសរួមលេខ០០៦០ប្រក/កសក ០០១កហវ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៨៩ ត្រូវរក្សាទុកដដែល។

**មាត្រា៣**

ប្រកាសនេះមានអានុភាពគតិយុត្តចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈ។

*លេខ៤៩សរ/សណ*　　　　　　　　　　ភ្នំពេញ ថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៩០

| បានឃើញ និងយល់ព្រម | **រដ្ឋមន្ត្រីក្រសួងកសិកម្ម** | **រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ** |
|---|---|---|
| ភ្នំពេញ ថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩០ | **អនុរដ្ឋមន្ត្រីទី១** | **ហត្ថលេខា និងត្រា** |
| **ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី** | **ហត្ថលេខា និងត្រា** | |
| **អនុប្រធាន** | **ឈា សុង** | **ឆាយ ថន** |
| **ហត្ថលេខា និងត្រា** | | |
| **ជា សុទ្ធ** | | |

*កន្លែងទទួល*
- -ខុទ្ទកាល័យមជ្ឈិមបក្ស
- -ខុទ្ទកាល័យរដ្ឋសភា
- -ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ
- -គ្រប់ក្រសួងមន្ទីរជុំវិញមជ្ឈិម

គណៈកម្មាធិការប្រជាជនខេត្ត-ក្រុង

*"ដើម្បីជូនជ្រាប"*

-ដូចក្នុងមាត្រា៧ "ដើម្បីអនុវត្ត"

- កាលប្បវត្តិ-ឯកសារ

រដ្ឋកម្ពុជា

ក្រសួងកសិកម្ម-ក្រសួងហិរញ្ញវត្ថុ ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

លេខ៣៥៥ប្រក/កសក-០០៧កហវ

## សេចក្តីណែនាំរួមបន្ថែមលើការអនុវត្តប្រកាសរួមលេខ០០៦០ប្រក/កសក.០០១កហវ និងលេខ៣៥៤ប្រក/កសក.០១២កហវ

យោងស្មារតីនៃប្រកាសរួមលេខ០០៦០ប្រក/កសក-០០១កហវ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៨៩ របស់ក្រសួងកសិកម្ម និងក្រសួងហិរញ្ញវត្ថុស្តីពីការកំណត់ប្រាក់ចំណូលពីការចេញឯកសារពាក់ព័ន្ធនឹងដីធ្លី ក្រសួងទាំងពីរសង្កេតឃើញថាខេត្ត-ក្រុង ស្រុក-ខណ្ឌមួយចំនួនបានខិតខំបានយកចិត្តទុកដាក់ជំរុញការអនុវត្តបានល្អបង្គួរ ដោយមានបញ្ជីទូទាត់ឯកសារ និងបង់ប្រាក់ចូលធនាគារបានទាន់ពេលវេលា បង្ការាំងស្កាត់បាននូវរាល់បាតុភាពបាត់បង់ ខូចខាតជាយថាហេតុ ឬប្រើប្រាស់ចាយវាយខុសមុខសញ្ញា ក៏ប៉ុន្តែនៅមានខេត្ត-ក្រុង ខណ្ឌ-ស្រុកខ្លះមិនទាន់អនុវត្តបានល្អ និងសមស្របនៅឡើយ។

### ១.អំពីចំណូលថវិកា

-នៅថ្នាក់ស្រុក-ខណ្ឌ ចំពោះប្រាក់ចំណូលដែលទទួលបានពីការចេញបង្កាន់ដៃទាំងបីប្រភេទដូចដែលប្រកាសរួមបានកំណត់ គណៈកម្មាធិការប្រជាជនស្រុក-ខណ្ឌត្រូវជំរុញកម្មាភិបាលដែលទទួលបន្ទុកការងារនេះ ឱ្យយកមកបង់ចូលធនាគារស្រុក-ខណ្ឌជាបន្ទាន់ដោយកាត់ចេញនូវប្រាក់រង្វាន់ពីរភាគរយលើចំណូលសរុប។ ប្រាក់រង្វាន់ពីរភាគរយនេះ ត្រូវបានទៅការិយាល័យកសិកម្មស្រុក-ខណ្ឌចាត់ជាប្រាក់បំណាច់ទទួលខុសត្រូវ ធានាការបាត់បង់ និងទុកដាក់។

-នៅថ្នាក់ខេត្ត-ក្រុង ការិយាល័យសុរិយោដីខេត្ត-ក្រុងត្រូវបើកគណនីរបស់ខ្លួនដាច់ដោយឡែកពីមន្ទីរកសិកម្ម។ គណៈកម្មាធិការប្រជាជនខេត្ត-ក្រុងមានភារកិច្ចតាមដាន និងណែនាំការិយាល័យសុរិយោដីខេត្ត-ក្រុង ដែលជាម្ចាស់គណនីក្តាប់ជាប់ជាប្រចាំនូវចំណូលដែលត្រូវបង់ឱ្យថវិកាខេត្ត-ក្រុង និងថវិកាមជ្ឈិម។ ចំពោះចំណូលដែលបង់ឱ្យថវិកាខេត្តបានមកពីការចេញបង្កាន់ដៃ "ក" និង "គ" នោះត្រូវរក្សាទុកក្នុងគណនីសុរិយោដីខេត្ត-ក្រុង។ ដោយឡែក ចំណូលដែលបង់

ឱ្យថវិកាមជ្ឈិមបានមកពីការចេញបង្កាន់ដៃ "ខ" ការិយាល័យសុរិយោដីខេត្ត-ក្រុងត្រូវតែរួសរាន់បង្វែរមកគណនីរបស់នាយកដ្ឋានសុរិយោដី "គណនីលេខ០៤.២៥៩.០១ នៃធនាគារខណ្ឌចំការមន" ជាបន្ទាន់ គឺមិនមែនបង្វែរទៅថវិកាមជ្ឈិម "ក្រសួងហិរញ្ញវត្ថុ" តែម្តងនោះទេ និងមិនត្រូវបង្អែរបង្អង់យកទៅចំណាយឱ្យខ្ទង់ណាមួយបណ្តោះអាសន្នបានឡើយ ។

**២-អំពីចំណាយ**

រាល់ចំណាយដែលប្រើប្រាស់ពីប្រាក់ចំណូលបានមកពីការធ្វើអង្កេត វាស់វែង និងប្រាក់ចំណូលពីការកត់ត្រា និងកសាងឯកសារបង្កាន់ដៃ "ក" និង "គ" គណៈកម្មាធិការប្រជាជនខេត្តមានសិទ្ធិសម្រេចឱ្យការិយាល័យសុរិយោដីខេត្តចាយវាយក្នុងរង្វង់នៃប្រភេទការងារដែលបានកំណត់ក្នុងប្រកាសរួមដោយមានគម្រោងចំណាយច្បាស់លាស់ ។

រាល់ចំណាយដែលប្រើប្រាស់ប្រាក់ចំណូលពីការចុះបញ្ជិកា "បង្កាន់ដៃខ" ដែលត្រូវបង់ចូលថវិកាមជ្ឈិមនោះ គឺក្រសួងហិរញ្ញវត្ថុជាអ្នកសម្រេច ។

ក្រសួងកសិកម្ម និងក្រសួងហិរញ្ញវត្ថុមានសង្ឃឹមយ៉ាងមាំថា សមមិត្តប្រធានគណៈកម្មាធិការប្រជាជនខេត្ត-ក្រុង មន្ទីរហិរញ្ញវត្ថុខេត្ត-ក្រុង ធនាគារខេត្ត-ក្រុង និងគណៈកម្មាធិការប្រជាជនស្រុក-ខណ្ឌ ព្រមទាំងធនាគារស្រុក-ខណ្ឌ នឹងខិតខំអស់លទ្ធភាពគ្រប់គ្រងចំណូលថវិកាជំពូកខាងលើបានសម្រេចតាមសេចក្តីណែនាំនេះ ដើម្បីឈានជាបណ្តើរៗទៅសម្រេចជោគជ័យជាស្ថាពរក្នុងការអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លីនៅពេលដ៏ខ្លីខាងមុខ ។

ភ្នំពេញ ថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៩០

**រដ្ឋមន្ត្រីក្រសួងកសិកម្ម**
**អនុរដ្ឋមន្ត្រីទី១**
**ហត្ថលេខា និងត្រា**
**ឈា សុង**

**រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ**
**ហត្ថលេខា និងត្រា**
**ឆាយ ថន**

*<u>ចម្លងជូន</u>*

ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី
*"ដើម្បីជូនជ្រាប"*
-នាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ ក្រសួងកសិកម្ម
-នាយកដ្ឋានសុរិយោដី ក្រសួងកសិកម្ម
-នាយកដ្ឋានហិរញ្ញកិច្ចស្ថាបនាសេដ្ឋកិច្ច ក្រសួងហិរញ្ញវត្ថុ
*"ដើម្បីមុខការ"*
-ឯកសារ

រដ្ឋកម្ពុជា

ក្រុមប្រឹក្សារដ្ឋមន្ត្រី ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

លេខ០៣សណន

ភ្នំពេញ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៩០

## សេចក្ដីណែនាំ
## ស្ដីពីការកែសម្រួលសេចក្ដីណែនាំលេខ០៣សណន
## ចុះថ្ងៃទី០៣ មិថុនា ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុលោមតាមស្មារតីនៃសម័យប្រជុំពេញអង្គរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នាថ្ងៃទី៥-៦-៧ ខែកក្កដា ១៩៩០ ស្ដីពីការអនុញ្ញាតឱ្យបន្តទទួលពាក្យសុំកាន់កាប់ដីរបស់ប្រជាកសិករ និងរួសរាន់វាស់វែងប្រគល់លិខិតកាន់កាប់ជូនប្រជាជន ការអនុវត្តជំហានទី១ យើងសម្រេចទទួលពាក្យស្នើសុំកាន់កាប់ដីធ្លីទូទាំងប្រទេសបាន៣.៧០០.០០០ប្លង់ដី គឺប្រមាណ៧០ភាគរយប៉ុណ្ណោះ។

ដើម្បីអនុវត្តបន្ត និងជំរុញអនុវត្តជំហានទី២ គឺការធ្វើអង្កេតវាស់វែង ផ្ដល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លីជូនប្រជាជនទាន់ពេលវេលា និងស្របតាមលក្ខណៈបច្ចេកទេសសុរិយោដី ក្រុមប្រឹក្សារដ្ឋមន្ត្រីធ្វើការណែនាំ និងកែសម្រួលសមាសភាពគណៈកម្មការកណ្ដាល "ថ្នាក់ស្រុក" និងអនុគណៈកម្មការអង្កេតវាស់វែងតាមឃុំនីមួយៗ ដែលមានចែងនៅក្នុងសេចក្ដីណែនាំលេខ០៣សណន ចុះថ្ងៃទី០៣-០៦-៨៩ដូចតទៅ៖

គណៈកម្មាធិការប្រជាជនខេត្ត-ក្រុង ត្រូវចាត់តាំងគណៈកម្មការមូលដ្ឋានដែលមាន៖

+គណៈកម្មការកណ្ដាល "ថ្នាក់ស្រុក"

- -ប្រធានគណៈកម្មាធិការប្រជាជនស្រុក.................... ប្រធាន
- -ប្រធានការិយាល័យភូមិបាល................................ អនុប្រធាន
- -ប្រធានគណៈកម្មាធិការប្រជាជនឃុំ........................ សមាជិក

+អនុគណៈកម្មការអង្កេតវាស់វែងចុះអនុវត្តផ្ទាល់តាមឃុំ-សង្កាត់នីមួយៗ

*វាយឡើងវិញ*

-ប្រធានឃុំ-សង្កាត់............................................ ប្រធាន

-កម្មាភិបាលការិយាល័យសុរិយោដីខេត្ត-ក្រុង.......... អនុប្រធាន

-កម្មាភិបាលការិយាល័យកសិកម្មស្រុក-ខណ្ឌ........... សមាជិក

-ប្រធានភូមិសាមី............................................... -ដ-

-ចាស់ព្រឹទ្ធាចារ្យក្នុងភូមិ ១នាក់............................ -ដ-

អនុគណៈកម្មការនេះមានភារកិច្ចចុះធ្វើអង្កេតវាស់វែងជាក់ស្តែង បំពេញសំណុំលិខិត កំណត់ហេតុឱ្យបានច្បាស់លាស់ និងលើកសំណើជូនគណៈកម្មការកណ្តាលពិនិត្យ និងសម្រេច ។

ក្រសួងកសិកម្ម និងគណៈកម្មាធិការប្រជាជនគ្រប់ខេត្ត-ក្រុង ត្រូវសហការរៀបចំ ឱ្យបានជាបន្ទាន់ នូវក្បាលម៉ាស៊ីនដឹកនាំការិយាល័យសុរិយោដីខេត្ត-ក្រុង និងការិយាល័យភូមិបាល ស្រុក-ខណ្ឌ ។

ទទឹមនេះ ត្រូវសហការជំរុញអនុវត្តជំហាន២ គឺការអង្កេតវាស់វែង ចុះបញ្ជី និងចេញ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លីទាន់សភាពការណ៍ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

**ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី**

**អនុប្រធាន**

**ហត្ថលេខា និងត្រា**

**ជា សុទ្ធ**

*កន្លែងទទួល*

-ខុទ្ទកាល័យមជ្ឈិមបក្ស

-ខុទ្ទកាល័យរដ្ឋសភា

-ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ

*"ដើម្បីជ្រាបជាព័ត៌មាន"*

-ក្រសួងកសិកម្ម

-គណៈកម្មាធិការប្រជាជនខេត្ត-ក្រុង *"ដើម្បីអនុវត្ត"*

-កាលប្បវត្តិ-ឯកសារ

រដ្ឋកម្ពុជា

ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

គណៈកម្មាធិការប្រជាជនរដ្ឋធានីភ្នំពេញ

លេខ០២សរ ភ្នំពេញ ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ១៩៩១

សារាចរ

ស្តីពីការផ្តល់កម្មសិទ្ធិ និងលក់ផ្ទះសំបែងជូនពលរដ្ឋក្នុងរដ្ឋធានីភ្នំពេញ

ដើម្បីអនុវត្តស្មារតីអនុក្រឹត្យលេខ២៥អនក្រ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីឱ្យមានប្រសិទ្ធភាព គណៈកម្មាធិការប្រជាជនរដ្ឋធានីភ្នំពេញបានរៀបចំបើកយុទ្ធនាការមួយ ដើម្បីជំរុញការផ្តល់កម្មសិទ្ធិ និងលក់ផ្ទះសំបែងជូនពលរដ្ឋក្នុងរដ្ឋធានីភ្នំពេញ។

ដើម្បីអនុវត្តការងារនេះឱ្យបានទទួលលទ្ធផលល្អប្រសើរ និងទាន់ពេលវេលា គណៈកម្មាធិការប្រជាជនរដ្ឋធានីភ្នំពេញ សូមធ្វើការណែនាំដូចខាងក្រោម៖

១-គ្រប់គ្រួសារទាំងអស់ដែលមានទីលំនៅក្នុងរដ្ឋធានីភ្នំពេញ ហើយដែលពុំទាន់មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ត្រូវមកទិញ និងការដាក់ពាក្យសុំកម្មសិទ្ធិ នៅតាមសង្កាត់ឃុំដែលខ្លួនកំពុងរស់នៅឱ្យបានទាន់ពេលវេលា ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

២-ការប្រកាសលក់ផ្ទះសំបែងជូនពលរដ្ឋ ត្រូវចាត់ដំណើរការនៅដើមខែកុម្ភៈ ឆ្នាំ១៩៩១។ ចំពោះប្រភេទផ្ទះអឺ០ និងអឺ០ហ្សិត រដ្ឋកំណត់ប្រកាសលក់ជូនប្រជាជនក្នុងរយៈពេលមួយខែ ចាប់ពីដើមខែរហូតដល់ដំណាច់ខែកុម្ភៈ ឆ្នាំ១៩៩១។

៣-រដ្ឋផ្តល់កម្មសិទ្ធិជូនចំពោះតែគ្រួសារដែលមានមេគ្រួសារជាកម្មាភិបាល បុគ្គលិកកម្មករក្របខ័ណ្ឌរដ្ឋ យុទ្ធជន និងប្រជាជនក្រីក្រ ហើយត្រូវអនុវត្តដូចក្នុងចំណុចទីមួយ។

៤-ចំពោះគ្រួសារប្រជាជនដែលពុំមានចែងក្នុងចំណុចទី៣ ត្រូវដាក់ពាក្យសុំទិញ និងតម្លៃតាមការកំណត់របស់រដ្ឋឱ្យបានទាន់ពេលវេលា។ ករណីដែលមានការគេចវេស មិនព្រមបង់ថវិកា

ជូនរដ្ឋក្នុងរយៈពេលមួយខែ ក្រោយពីជូនដំណឹងស្តីពីការលក់លំនៅឋាន រដ្ឋនឹងធ្វើការដកហូតដើម្បីលក់ឱ្យអ្នកដទៃទៀត។

៥-ក្រោយពេលដែលរដ្ឋចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ផ្តល់ជូនរួចហើយ ក្នុងករណីមានការលក់ដូរ ឬផ្ទេរឱ្យអ្នកដទៃទៀត ម្ចាស់កម្មសិទ្ធិថ្មីត្រូវបង់ថវិកាចំនួន១០ភាគរយលើតម្លៃលំនៅឋានជាក់ស្តែងជូនរដ្ឋ ជាតម្លៃប្រថាប់ត្រាកាត់ឈ្មោះ។

៦-គណៈកម្មាធិការប្រជាជនរដ្ឋធានីនឹងរៀបចំគណៈកម្មការមួយ ដើម្បីចុះធ្វើការបែងចែកប្រភេទ និងតម្លៃលំនៅឋានដែលត្រូវលក់ជូនប្រជាជន។

គណៈកម្មាធិការប្រជាជនរដ្ឋធានីភ្នំពេញសង្ឃឹម និងជឿជាក់លើស្មារតីយកចិត្តទុកដាក់របស់គ្រប់សណ្តាប់បណ្តាផ្នែកមូលដ្ឋាន និងប្រជាជនក្នុងរដ្ឋធានីភ្នំពេញទាំងមូល ការអនុវត្តខ្លឹមសារសារាចរនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

*វាយឡើងវិញ*

រដ្ឋកម្ពុជា

ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

**ក្រុមប្រឹក្សារដ្ឋ**

លេខ២១ក្រ

## ក្រឹត្យ

## ក្រុមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំរដ្ឋសភា និងក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ០៤ក្រ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២

## សម្រេច

ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតពន្ធប្រថាប់ត្រា ដែលរដ្ឋសភានៃរដ្ឋកម្ពុជាបានអនុម័តនៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៩១នាសម័យប្រជុំសាមញ្ញលើកទី២០ នីតិកាលទី១។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩១

**ជ.ក្រុមប្រឹក្សារដ្ឋ**

**ប្រធាន**

**ហត្ថលេខា និងត្រា**

**ហេង សំរិន**

*កន្លែងទទួល*

-ខុទ្ទកាល័យមជ្ឈិមបក្ស

-ខុទ្ទកាល័យរដ្ឋសភា

-ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី

-គ្រប់ទីស្តីការរដ្ឋមន្ត្រី និងស្ថាប័នថ្នាក់ប្រហាក់ប្រហែល

-គ្រប់គណៈកម្មាធិការប្រជាជនខេត្ត-ក្រុង

-រដ្ឋកិច្ច

-កាលប្បវត្តិ-ឯកសារ

**រដ្ឋកម្ពុជា**
**ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល**
**ច្បាប់**
**ស្តីពីការបង្កើតពន្ធប្រថាប់ត្រា**

**មាត្រា១**

ត្រូវបានបង្កើតពន្ធប្រថាប់ត្រា។

**មាត្រា២**

ពន្ធប្រថាប់ត្រាត្រូវបានអនុវត្តលើការផ្ទេរកម្មសិទ្ធិតាមរូបភាពលក់ទិញ៖

| | |
|---|---|
| -ផ្ទះ និងដីសង់លំនៅឋាន | ៦ភាគរយ |
| -រថយន្តគ្រប់ប្រភេទ | ៤ភាគរយ |
| -ម៉ូតូគ្រប់ប្រភេទ | ២ភាគរយ |
| -ទូក កាណូត កប៉ាល់ សាឡង់ | ២ភាគរយ |

**មាត្រា៣**

ចំណូលដែលបានមកពីពន្ធប្រថាប់ត្រា ត្រូវបង់ចូលថវិការដ្ឋ។

**មាត្រា៤**

តំណាង ឬភ្នាក់ងារអាជ្ញាធរណាដែលបង្ខំទារ ឬទទួលយកប្រាក់ពន្ធប្រថាប់ត្រាដែលគ្មានចែងក្នុងច្បាប់ ឬដែលលើសពីការកំណត់ក្នុងច្បាប់ត្រូវផ្តន្ទាទោស៖

១-ដាក់ពន្ធនាគារពី១ឆ្នាំ ដល់៥ឆ្នាំ បើកម្រៃដែលបានមកពីអំពើល្មើស មានចំនួនតិចជាង ១០.០០០៛ "មួយម៉ឺនរៀល"។

២-ដាក់ពន្ធនាគារពី៥ឆ្នាំដល់១០ឆ្នាំ បើកម្រៃដែលបានមកពីអំពើល្មើស មានចំនួន ១០.០០០៛ "មួយម៉ឺនរៀល" ដល់១០០.០០០ "មួយសែនរៀល"

៣-ដាក់ពន្ធនាគារពី១០ឆ្នាំ ឡើងទៅរហូតដល់អស់មួយជីវិត បើកម្រៃដែលបានមកពីអំពើល្មើសមានចំនួនលើសពី១០០.០០០៛ "មួយសែនរៀល" ឡើងទៅ។

**មាត្រា៥**

បែបបទនៃការប្រថាប់ត្រា និងបែបបទនៃការប្រមូលពន្ធប្រថាប់ត្រាត្រូវកំណត់ដោយអនុក្រឹត្យ។

ច្បាប់នេះ រដ្ឋសភានៃរដ្ឋកម្ពុជាបានអនុម័តនៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៩១ នាសម័យប្រជុំលើកទី២០ នីតិកាលទី១។

ភ្នំពេញ ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ១៩៩១

**ជ.រដ្ឋសភា**
**ប្រធាន**
**ហត្ថលេខា និងត្រា**
**ជា ស៊ីម**

*វាយឡើងវិញ*

បក្សប្រជាជនបដិវត្តកម្ពុជា

គណៈកម្មាធិការមជ្ឈិម

**ខុទ្ទកាល័យមជ្ឈិមបក្ស**

លេខ០៥៧ជ/ខបប

ភ្នំពេញ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៩១

**គោរពជូន**

**រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី**

*កម្មវត្ថុ* ករណីលុបបរិភាគទានស្នេហាជាតិ ដោយឱ្យបង្កើតពន្ធដីជំនួសវិញ

*យោង* ស្មារតីសម្រេចរបស់អង្គប្រជុំការិយាល័យនយោបាយមជ្ឈិមបក្ស ថ្ងៃទី១៦ ខែមករា ឆ្នាំ ១៩៩១។

តាមកម្មវត្ថុ និងយោងខាងលើ ខុទ្ទកាល័យមជ្ឈិមបក្សសូមជម្រាបជូនថា ការិយាល័យនយោបាយមជ្ឈិមបក្សសម្រេចជាគោលការណ៍ឱ្យលុបពាក្យបរិភាគទានស្នេហាជាតិ ដោយត្រូវបង្កើតច្បាប់ពន្ធដារជំនួសវិញ។

ដូចស្មារតីជម្រាបជូនខាងលើ ស្នើសមមិត្តរាយការណ៍ជូនក្រុមប្រឹក្សារដ្ឋមន្ត្រី ដើម្បីមានវិធានការចាត់ចែងអនុវត្តឱ្យបានសមស្រប និងទទួលលទ្ធផលល្អ។

គោរពជូនសុខភាពល្អ និងជ័យជំនះ។

*កន្លែងទទួល*

-ក្រសួងយុត្តិធម៌ "ដើម្បីជូនជ្រាប"

-ក្រសួងកសិកម្ម "និងសហការអនុវត្ត"

-ឯកសារ

**ជ.ប្រធានខុទ្ទកាល័យមជ្ឈិមបក្ស**

**អនុប្រធានទី១**

**ហត្ថលេខា និងត្រា**

**អ៊ឹម ឈុនលឹម**

**រដ្ឋកម្ពុជា**

**ក្រសួងកសិកម្ម** **ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល**

**នាយកដ្ឋានសុរិយោដី**

លេខ១១៦សដ/សណន ភ្នំពេញ ថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៩១

**សេចក្ដីណែនាំ**

**ស្ដីពីការចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងការកសាងឯកសារពាក់ព័ន្ធ**

ដើម្បីអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លីនាជំហាន II មានប្រសិទ្ធភាពធានាបានទាំងលក្ខណការណ៍បច្ចេកទេស ទាំងគោលការណ៍ច្បាប់ នាយកដ្ឋានសុរិយោដីសូមធ្វើការណែនាំអំពីការចេញប័ណ្ណសម្គាល់សិទ្ធិ និងការកសាងឯកសារមូលដ្ឋានដល់គ្រប់ការិយាល័យសុរិយោដីខេត្ត-ក្រុង និងការិយាល័យភូមិបាលស្រុក-ខណ្ឌដូចតទៅ៖

**I-អំពីការចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី**

**១.គោលការណ៍រួម**

ការចេញប័ណ្ណសម្គាល់សិទ្ធិត្រូវផ្អែកលើកំណត់ហេតុអង្កេតដែលបានសម្រេចហើយ៖

-ចំពោះដីស្រែ និងចម្ការ កំណត់ហេតុអង្កេតនេះត្រូវសម្រេចដោយសមមិត្តប្រធានគណៈកម្មាធិការប្រជាជនស្រុក។

-ចំពោះដីសង់លំនៅឋាន កំណត់ហេតុអង្កេតនេះត្រូវសម្រេចដោយសមមិត្តប្រធានគណៈកម្មាធិការប្រជាជនខេត្ត-ក្រុង។

ក្នុងករណីដីគាស់-ដីរានថ្មី ការសម្រេចអាស្រ័យដោយសមមិត្តរដ្ឋមន្ត្រីក្រសួងកសិកម្ម។

**២.វិធីសាស្ត្រនៃការចេញប័ណ្ណ**

បន្ទាប់ពីបានសម្រេចលើកំណត់ហេតុអង្កេតតាមគោលការណ៍ខាងលើរួចហើយ សំណុំលិខិតកំណត់ហេតុអង្កេតនេះត្រូវបង្វិលមកការិយាល័យភូមិបាលស្រុក-ខណ្ឌសាមី ដែលត្រូវសរសេរប័ណ្ណសម្គាល់សិទ្ធិនេះគឺប្រធានការិយាល័យភូមិបាល និងប្រធានគណៈកម្មាធិការប្រជាជនស្រុក

ខណ្ឌ ជាអ្នកចុះហត្ថលេខាទាំងដីសង់លំនៅឋាន ទាំងដីស្រែ ឬចម្ការ ដោយត្រូវសរសេរទឹកខ្មៅក្រហមលើទំព័រដើមខាងឆ្វេង ផ្នែកខាងលើ "យោងកំណត់ហេតុអង្កេតចុះថ្ងៃ..................សម្រេចដោយសមមិត្តប្រធានគណៈកម្មាធិការប្រជាជន.........................." ។

**២.១-អំពីរបៀបសរសេរលើប័ណ្ណ**

ត្រូវសរសេរជាទឹកពណ៌ខ្មៅ ឬវាយអង្គុលីលេខច្បាស់ ស្អាតដោយមិនអនុញ្ញាតកោសលុបដាច់ខាត ។

**២.២-អំពីរបៀបចុះលេខលើប័ណ្ណ**

-លេខប័ណ្ណត្រូវស្របជាមួយលេខក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ ។

-ប្រធានការិយាល័យសុរិយោដីខេត្ត-ក្រុងត្រូវកំណត់អក្សរអាទិសង្កេត “initiale” ជាអក្សរឡាតាំង ជូនដល់ការិយាល័យភូមិបាលគ្រប់ស្រុក ដោយមានសៀវភៅបង្កាន់ដៃសម្រេច “Quittancier” ច្បាស់លាស់ ។ ឧទាហរណ៍ ខេត្តកណ្តាលមាន១១ស្រុក យើងដាក់សម្រាប់ស្រុកទីរួមខេត្ត A ស្រុកកៀនស្វាយ B ស្រុកលើកដែក C ...រហូតដល់គ្រប់ស្រុក ។

នៅតាមស្រុកក៏ដូចគ្នាដែរគឺយើងកំណត់តាមឃុំ លុះត្រាតែគ្រប់ឃុំ ដូចនៅស្រុកកៀនស្វាយ ឃុំយកបាត្រ $B_1$ ឃុំកំពង់ស្វាយ $B_2$ ឃុំគគីរធំ $B_3$ ... ។

ដូច្នេះលេខចុះក្នុងសៀវភៅមានជាអាទិ៍ $B_3$ - 001 និងបន្តបន្ទាប់... ។ នោះយើងនឹងអាចដឹងថាលេខនេះនៅក្នុងឃុំគគីរធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

**២.៣-អំពីការកសាងសំណុំឯកសារពាក់ព័ន្ធ**

ដើម្បីចូលរួមចំណែកទទួលខុសត្រូវក្នុងការពិនិត្យ មុននឹងចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីជូនប្រជាជន បន្ទាប់ពីស្រុក-ខណ្ឌបានចុះហត្ថលេខាហើយ ការិយាល័យភូមិបាលត្រូវផ្ញើប័ណ្ណភ្ជាប់ពាក្យស្នើ និងកំណត់ហេតុអង្កេតមកការិយាល័យសុរិយោដីខេត្ត-ក្រុង ដើម្បីជួយពិនិត្យលើលក្ខណការណ៍-គោលការណ៍ និងបោះត្រាការិយាល័យសុរិយោដីខេត្ត-ក្រុង ខាងខ្នងប័ណ្ណត្រង់កន្លែង "ប្រធាននាយកដ្ឋានសុរិយោដី" ដោយចុះហត្ថលេខាបំព្រួញ “Parapher” នៅចុងផង ។

ដោយឡែក លើទំព័រដើមកំណត់ហេតុអង្កេតផ្នែកខាងលើ "ខាងស្តាំ" ការិយាល័យសុរិយោដីខេត្ត-ក្រុងត្រូវចុះលេខប័ណ្ណ និងថ្ងៃ ខែ ឆ្នាំ ចេញប័ណ្ណជាទឹកខ្មៅពណ៌ "ក្រហម" ។

សំណុំលិខិតនេះ "រួមមានប័ណ្ណសម្គាល់សិទ្ធិ ភ្ជាប់កំណត់ហេតុអង្កេត និងពាក្យស្នើ" ត្រូវត្រលប់ទៅការិយាល័យភូមិបាលវិញ ដើម្បីចែកប័ណ្ណជូនប្រជាជន ម្ចាស់កាន់កាប់បន្ទាប់ពីបានចុះចូលក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុតាមឃុំនីមួយៗដែលដីនោះឋិតនៅរួច។ ទន្ទឹមនេះ ការិយាល័យភូមិបាលត្រូវយកចិត្តទុកដាក់ខ្ពស់បំផុតលើការរៀបចំ និងតម្កល់ទុកពាក្យស្នើ និងកំណត់ហេតុអង្កេតតាមលេខរៀង និងតាមឃុំ។ ចៀសវាងដាច់ខាត ការបាត់បង់ ព្រោះនេះជាសក្ខីប័ត្រដើមសំខាន់ណាស់ទៅអនាគត។

## II-អំពីសៀវភៅចុះបញ្ជីអចលនវត្ថុ

សៀវភៅចុះបញ្ជីអចលនវត្ថុមានសារៈសំខាន់បំផុតមិនអាចខ្វះបាន ក្នុងវិស័យគ្រប់គ្រងអចលនវត្ថុ។ ឯកសារនេះត្រូវរក្សាទុកដាក់ឱ្យបានត្រឹមត្រូវ និងយូរអង្វែង។ ប្រធានការិយាល័យភូមិបាលស្រុក-ខណ្ឌ និងប្រធានការិយាល័យសុរិយោដីខេត្ត-ក្រុងត្រូវទទួលខុសត្រូវចំពោះមុខក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុនេះ។

### ១-អំពីការកសាងសៀវភៅចុះបញ្ជីអចលនវត្ថុ

សៀវភៅចុះបញ្ជីអចលនវត្ថុ កសាងឡើងនៅតាមស្រុក-ខណ្ឌ ដោយការិយាល័យភូមិបាលស្រុក-ខណ្ឌ។ សៀវភៅនេះ ចុះបញ្ជីអចលនវត្ថុ និងម្ចាស់កាន់កាប់តាមឃុំនីមួយៗដាច់ពីគ្នា។ ការចុះបញ្ជីក្នុងសៀវភៅនេះ ទាមទារមានមនសិការប្រុងប្រយ័ត្ន អក្សរស្អាត ហើយច្បាស់ មិនកោសលុប ក្នុងករណីបើសរសេរខុសត្រូវកែជាទឹកខ្មៅក្រហម យល់ព្រមដោយប្រធានការិយាល័យសុរិយោដីខេត្ត-ក្រុង មិនអនុញ្ញាតឱ្យហែកសន្លឹកសៀវភៅនេះទេ។ សៀវភៅចុះបញ្ជីអចលនវត្ថុនីមួយៗ ត្រូវមានលេខដែលកំណត់ឱ្យក្នុងសៀវភៅបង្កាន់ដៃសម្រេច "Quittancier" របស់ការិយាល័យសុរិយោដីខេត្ត-ក្រុង។ ទូទាំងខេត្ត-ក្រុង លេខក្បាលសៀវភៅចុះបញ្ជីអចលនវត្ថុមិនត្រូវឱ្យជាន់គ្នាទេ។

### ២-អំពីការថែរក្សាសៀវភៅចុះបញ្ជីអចលនវត្ថុ

ប្រធានការិយាល័យភូមិបាលស្រុក-ខណ្ឌត្រូវទទួលខុសត្រូវ ក្នុងការថែរក្សាសៀវភៅចុះបញ្ជីអចលនវត្ថុ ដោយរៀបចំទុកដាក់ឱ្យមានសណ្តាប់ធ្នាប់ក្នុងបន្ទប់ ឬទូចាក់សោមាំទាំ។ មិនអនុញ្ញាតឱ្យអ្នកគ្មានភារកិច្ចបើកមើល ឬសរសេរអ្វីបន្ថែមដាច់ខាត។

*វាយឡើងវិញ*

**៣-អំពីការចុះចរន្តការក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ**

គឺជាការងារប្រចាំថ្ងៃដែលការិយាល័យភូមិបាលត្រូវយកចិត្តទុកដាក់ចុះក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ ឱ្យបានទៀងទាត់បំផុត ចៀសវាងដាច់ខាតការចេញប័ណ្ណសម្គាល់សិទ្ធិជូនប្រជាជនមុនចុះបញ្ជីនេះ។

ម្យ៉ាងទៀត ដើម្បីធានាការអន្តរាយសៀវភៅចុះបញ្ជីអចលនវត្ថុ ដោយគ្រោះប្រធានសក្តិណាមួយជាយថាហេតុ រៀងរាល់កន្លះខែម្តង ការិយាល័យភូមិបាលត្រូវផ្ញើតារាងសម្រង់បញ្ជីអចលនវត្ថុទៅការិយាល័យសុរិយោដីខេត្ត-ក្រុង ដើម្បីការិយាល័យសុរិយោដីចុះចរន្តការបន្តកសាងបានសៀវភៅចុះបញ្ជីអចលនវត្ថុមួយទៀត ដូចគ្នានឹងសៀវភៅដែលតម្កល់ទុកនៅស្រុកខណ្ឌ តាមតារាងសម្រង់បញ្ជីអចលនវត្ថុដែលនាយកដ្ឋានសុរិយោដីនឹងសិក្សាបោះពុម្ពចែកជូន។

**៤-អំពីការធ្វើលេខាចារឹកក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ**

បច្ចុប្បន្ន នាយកដ្ឋានសុរិយោដីកំពុងធ្វើការសិក្សាស្រាវជ្រាវបណ្តាលិខិតសញ្ញាពាក់ព័ន្ធនឹងការផ្ទេរសិទ្ធិផ្សេងៗលើអចលនវត្ថុ ដើម្បីសិក្សាគោលការណ៍ធ្វើលេខាចារឹកឱ្យឯកភាពទូទាំងប្រទេស ក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ។

នាយកដ្ឋានសុរិយោដី មានសង្ឃឹមយ៉ាងមុតមាំថា បណ្តាសមមិត្តថ្នាក់ដឹកនាំការិយាល័យសុរិយោដីខេត្ត-ក្រុង និងការិយាល័យភូមិបាលស្រុក-ខណ្ឌ អនុវត្តនូវសេចក្តីណែនាំខាងលើនេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់ បម្រើបានតាមសំណូមពររបស់បក្ស-រដ្ឋ និងប្រជាជន សមស្របតាមពាក្យស្លោក អ្វីៗទាំងអស់ដើម្បីបង្កើនជំនឿរបស់ប្រជាជនលើរបបថ្មី។

**ប្រធាននាយកដ្ឋានសុរិយោដី**

**ហត្ថលេខា**

**លឹម គានហោ**

*<u>ចម្លងជូន</u>*

-ក្រសួងកសិកម្ម

-គណៈកម្មាធិការប្រជាជនគ្រប់ខេត្ត-ក្រុង

*"ដើម្បីជូនជ្រាប"*

-គ្រប់ការិយាល័យក្រោមឱវាទនាយកដ្ឋានសុរិយោដី

*"ដើម្បីមុខការ"*

រដ្ឋកម្ពុជា

ក្រុមប្រឹក្សារដ្ឋមន្ត្រី ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

លេខ២០អនក្រ

ភ្នំពេញ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩១

## អនុក្រឹត្យ

## ស្តីពីការប្រមូលពន្ធប្រថាប់ត្រា

## ក្រុមប្រឹក្សារដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា
- បានឃើញច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ០៣ក្រ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២
- បានឃើញច្បាប់ស្តីពីការបង្កើតពន្ធប្រថាប់ត្រា ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ២១ក្រ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ១៩៩១
- បានឃើញសេចក្តីសម្រេចលេខ០៦ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៧៩ របស់ក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជាស្តីពីការបង្កើតក្រសួងហិរញ្ញវត្ថុ
- បានឃើញច្បាប់ស្តីពីការកែប្រែការចាត់តាំងតួនាទី និងភារកិច្ចរបស់ក្រសួងហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ៤៧ក្រ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩
- បានឃើញក្រឹត្យច្បាប់លេខ០៧ក្រច ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៨២ ស្តីពីសមត្ថកិច្ច និងនីតិវិធីនៃការធ្វើច្បាប់ និងបទបញ្ជា
- បានឃើញអនុក្រឹត្យលេខ២៤អនក្រ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៩០ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងហិរញ្ញវត្ថុ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១ បទប្បញ្ញត្តិទូទៅ

មាត្រា១

គ្រប់ករណីផ្ទេរសិទ្ធិ ឬកម្មសិទ្ធិផ្ទះ គឺដីសង់លំនៅឋាន រថយន្តគ្រប់ប្រភេទម៉ូតូគ្រប់ប្រភេទ ទូក កាណូត កប៉ាល់ សាឡាង់ តាមរូបភាពទិញលក់ ដោយទូទាត់ជាសាច់ប្រាក់ ជាវត្ថុ និងជាចំណែកភាគហ៊ុន ត្រូវមានកិច្ចសន្យាជាលាយលក្ខណ៍អក្សរ និងត្រូវបង់ពន្ធប្រថាប់ត្រាតាមការកំណត់ក្នុងច្បាប់ស្តីពីការបង្កើតពន្ធប្រថាប់ត្រាក្នុងរយៈពេល៣០ថ្ងៃយ៉ាងយូរគិតពីថ្ងៃ ខែដែលបានកត់ត្រាចុះក្នុងកិច្ចសន្យា។

មាត្រា២

ត្រូវហាមឃាត់ការផ្តល់សិទ្ធិ ឬកម្មសិទ្ធិផ្ទះ ដី ដីសង់លំនៅឋាន រថយន្តគ្រប់ប្រភេទ ម៉ូតូគ្រប់ប្រភេទ ទូក កាណូត កប៉ាល់ សាឡាង់ដែលបានមកដោយសារការទិញលក់ ហើយដែលមិនទាន់បានបង់ពន្ធប្រថាប់ត្រា។

មាត្រា៣

ត្រូវហាមឃាត់ការគេចវេសមិនបង់ពន្ធ ការបន្លំពន្ធប្រថាប់ត្រា ការធ្វើឱ្យរាំងស្ទះ ឬការប្រឆាំងនឹងការត្រួតពិនិត្យការប្រមូលពន្ធប្រថាប់ត្រារបស់អង្គការមានសមត្ថកិច្ច។

## ជំពូកទី២ បែបបទនៃការប្រមូលពន្ធប្រថាប់ត្រា

មាត្រា៤

ពន្ធប្រថាប់ត្រាផ្ទេរសិទ្ធិ ឬកម្មសិទ្ធិតាមរូបភាពទិញលក់ផ្ទះ ដី ដីសង់លំនៅឋាន រថយន្តគ្រប់ប្រភេទ ម៉ូតូគ្រប់ប្រភេទ ទូក កាណូត កប៉ាល់ សាឡាង់ ត្រូវប្រមូលពីអ្នកដែលបានទទួលសិទ្ធិ ឬកម្មសិទ្ធិតាមអត្រាកំណត់ក្នុងមាត្រា២ នៃច្បាប់ស្តីពីការបង្កើតពន្ធប្រថាប់ត្រា ដោយគិតតាមតម្លៃលើទីផ្សារនាពេលផ្ទេរសិទ្ធិ ឬកម្មសិទ្ធិ។

ក្រសួងហិរញ្ញវត្ថុអាចកំណត់តម្លៃមួយហៅថា ថ្លៃគិតពន្ធប្រថាប់ត្រាផ្ទេរសិទ្ធិ ឬកម្មសិទ្ធិសម្រាប់រយៈកាលនីមួយៗ។

មាត្រា៥

ការផ្ទេរសិទ្ធិ ឬកម្មសទ្ធិតាមរូបភាពទិញលក់ ដោយដោះដូរគ្នារវាងផ្ទះ ដី ដីសង់លំនៅឋាន រថយន្តគ្រប់ប្រភេទ ម៉ូតូគ្រប់ប្រភេទ ទូក កាណូត កប៉ាល់ សាឡាង់ ពន្ធប្រថាប់ត្រាត្រូវប្រមូលពីអ្នកដែលបានទទួលសិទ្ធិ ឬកម្មសិទ្ធិ។

**មាត្រា៦**

ការយកផ្ទះ ដីសង់លំនៅឋាន រថយន្តគ្រប់ប្រភេទ ម៉ូតូគ្រប់ប្រភេទ ទូក កាណូត កប៉ាល់ សាឡាង់ចូលជាភាគហ៊ុនក្នុងក្រុមហ៊ុននានា គឺជាការផ្ទេរកម្មសិទ្ធិពីរូបវន្តបុគ្គល ទៅនីតិបុគ្គលតាមរូបភាពទិញលក់ ដោយទូទាត់ជាចំណែកភាគហ៊ុន ពន្ធប្រថាប់ត្រាត្រូវប្រមូលលើក្រុមហ៊ុន។

**មាត្រា៧**

ពន្ធប្រថាប់ត្រា ត្រូវបានលើកលែងចំពោះ៖

ក-ការទទួលសិទ្ធិ ឬកម្មសិទ្ធិដោយដោះដូរតាមសំណូមពររបស់អង្គការរដ្ឋ និងអង្គការសង្គម។

ខ-ការទទួលសិទ្ធិ ឬកម្មសិទ្ធិរបស់ស្ថាប័នរដ្ឋតាមរូបភាពទិញលក់ ដោយថវិកាដែលរដ្ឋបើកផ្ដល់ ឬដោះដូរជាមួយទ្រព្យសម្បត្តិដែលបានកត់ត្រាចុះក្នុងបញ្ជីសារពើភ័ណ្ឌរបស់ស្ថាប័ននោះ។

គ-ការទិញរថយន្តគ្រប់ប្រភេទ ម៉ូតូគ្រប់ប្រភេទ ទូក កាណូត កប៉ាល់ សាឡាង់ធ្វើជាទំនិញដើម្បីលក់វិញរបស់អាជីវកម្មដ្ឋាននានាដែលបានបង់ពន្ធប៉ាតង់ និងបង់ពន្ធអាជីវកម្មត្រឹមត្រូវ។

**ជំពូកទី៣ ភារកិច្ចរបស់អ្នកទទួលសិទ្ធិ និងម្ចាស់កម្មសិទ្ធិ**

**មាត្រា៨**

អ្នកទទួលសិទ្ធិ ឬម្ចាស់កម្មសិទ្ធិផ្ទះ ដី ដីសង់លំនៅឋាន រថយន្តគ្រប់ប្រភេទ ម៉ូតូគ្រប់ប្រភេទ ទូក កាណូត កប៉ាល់ សាឡាង់ដែលបានមកតាមរូបភាពទិញលក់ ត្រូវមានភារកិច្ចដូចខាងក្រោម៖

១-ត្រូវធ្វើកិច្ចសន្យាទិញលក់ជាលាយលក្ខណ៍អក្សរ។

២-បំពេញសំណុំលិខិតឱ្យបានត្រឹមត្រូវ និងគ្រប់គ្រាន់តាមការកំណត់របស់អង្គការមានសមត្ថកិច្ចក្នុងការផ្ដល់សិទ្ធិ ឬកម្មសិទ្ធិ។

៣-បង់ពន្ធប្រថាប់ត្រាឱ្យបានទាន់ពេលត្រឹមត្រូវ និងគ្រប់គ្រាន់តាមច្បាប់កំណត់ និងត្រូវរក្សាទុកបង្កាន់ដៃទទួលប្រាក់ពន្ធប្រថាប់ត្រាភ្ជាប់ជាមួយលិខិតផ្ដល់សិទ្ធិ ឬកម្មសិទ្ធិរបស់អង្គការមានសមត្ថកិច្ច។

**ជំពូកទី៤ អង្គការមានសមត្ថកិច្ចប្រថាប់ត្រា និងប្រមូលពន្ធប្រថាប់ត្រា**

**មាត្រា៩**

កិច្ចការប្រថាប់ត្រា និងការប្រមូលពន្ធប្រថាប់ត្រា គឺជាសមត្ថកិច្ចរបស់អង្គការពន្ធក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់របស់ក្រសួងហិរញ្ញវត្ថុ។

**មាត្រា១០**

សិទ្ធិ និងភារកិច្ចរបស់កម្មាភិបាល បុគ្គលិកពន្ធទទួលបន្ទុកប្រថាប់ត្រា និងប្រមូលពន្ធប្រថាប់ត្រា៖

ក-ក្នុងពេលបំពេញភារកិច្ច កម្មាភិបាល បុគ្គលិកពន្ធត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសម្គាល់ មានលិខិតសម្គាល់ខ្លួនភ្ជាប់ជាមួយ។

-អនុវត្តឱ្យត្រឹមត្រូវតាមការកំណត់របស់រដ្ឋស្តីពីការប្រមូលប្រាក់ បង់ប្រាក់ចូល ថវិកាការត្រួតពិនិត្យ ការគ្រប់គ្រង និងប្រើប្រាស់ឯកសារបោះពុម្ពដើម្បីប្រមូលពន្ធ។

-កត់ត្រាចូលក្នុងបញ្ជីសៀវភៅប្រថាប់ត្រាដែលមានចុះលេខ ចុះហត្ថលេខា បោះត្រាដោយនាយកដ្ឋានពន្ធដារ។ បញ្ជីនេះត្រូវកត់ត្រាតាមលំដាប់លំដោយនៃពេលវេលាមិនត្រូវទុកឱ្យសល់បន្ទាត់ ឬចុះរំលងបន្ទាត់ និងត្រូវចុះតាមលេខរៀង។ នៅលើកិច្ចសន្យាទិញលក់ ដោះដូរត្រូវកត់ត្រាលេខរៀងដែលបានចុះក្នុងបញ្ជីប្រថាប់ត្រា ដើម្បីជាសញ្ញាសម្គាល់។ បញ្ជីប្រថាប់ត្រានេះត្រូវរក្សាទុកឱ្យគង់វង្ស សម្រាប់ធ្វើជាឯកសារមូលដ្ឋាន ហើយត្រូវបានចុះសេចក្តីបញ្ជាក់បញ្ឈប់នៅពេលដាច់ឆ្នាំពីអង្គការពន្ធថ្នាក់លើ។

ខ-ក្នុងការបំពេញភារកិច្ច កម្មាភិបាល បុគ្គលិក ដែលទទួលកិច្ចការប្រថាប់ត្រា មានសិទ្ធិដូចតទៅ៖

-ណែនាំអ្នកទទួលសិទ្ធិ ឬកម្មសិទ្ធិឱ្យបំពេញសំណុំលិខិតបែបបទឱ្យបានគ្រប់គ្រាន់ តាមគំរូកំណត់។

-ពិនិត្យ និងទាមទារឱ្យអ្នកដែលទទួលសិទ្ធិ ឬកម្មសិទ្ធិបង្ហាញឯកសារដែលទាក់ទងដល់ការបង់ពន្ធប្រថាប់ត្រា។

-មិនទទួលលិខិតស្នើសុំប្រថាប់ត្រា ដែលគ្មានសំណុំលិខិតគ្រប់គ្រាន់តាមការកំណត់។

**មាត្រា១១**

សមត្ថកិច្ចដោះស្រាយអំពីបញ្ហាពន្ធប្រថាប់ត្រា ពិន័យ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ។

សេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ គឺជាសេចក្តីសម្រេចចុងក្រោយ ។

**មាត្រា១២**

កម្មាភិបាល បុគ្គលិកពន្ធដែលសម្រេចភារកិច្ចបានស្នាដៃល្អនឹងត្រូវបានទទួលរង្វាន់តាមរបបកំណត់របស់ក្រសួងហិរញ្ញវត្ថុ។

រដ្ឋអំណាចមូលដ្ឋានដែលមានស្នាដៃជួយអង្គការពន្ធក្នុងការអនុវត្តអនុក្រឹត្យនេះ ត្រូវបានទទួលរង្វាន់តាមការកំណត់របស់ក្រសួងហិរញ្ញវត្ថុ។

**ជំពូកទី៥ ទោសប្បញ្ញត្តិ**

**មាត្រា១៣**

អ្នកទទួលសិទ្ធិ ឬកម្មសិទ្ធិតាមរូបភាពទិញលក់ផ្ទះ ដី ដីសង់លំនៅឋាន រថយន្តគ្រប់ប្រភេទ ម៉ូតូគ្រប់ប្រភេទ ទូក កាណូត កប៉ាល់ សាឡាង់ ដែលមិនបានឆ្លើយប្រកាស និងបង់ពន្ធប្រថាប់ត្រាឱ្យបានទាន់ពេលតាមការកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវទទួលពិន័យជាប្រាក់ស្មើ១%ក្នុងមួយថ្ងៃ លើចំនួនប្រាក់ពន្ធប្រថាប់ត្រាដែលត្រូវបង់។ ក្រៅពីការបង់ប្រាក់ពិន័យដែលយឺតយ៉ាវនេះ នៅត្រូវបង់ប្រាក់ពន្ធប្រថាប់ត្រាឱ្យគ្រប់ចំនួនតាមការកំណត់ថែមទៀត។

**មាត្រា១៤**

ជនណាដែលគេចវេស ឬបន្លំពន្ធប្រថាប់ត្រាត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយដង ដល់បីដងលើប្រាក់ពន្ធដែលគេចវេស ឬបន្លំ។ ក្រៅពីបង់ប្រាក់ពិន័យ ជនល្មើសត្រូវបង់ឱ្យគ្រប់ចំនួននូវប្រាក់ពន្ធប្រថាប់ត្រាដែលខ្លួនបានគេចវេស ឬបន្លំនោះថែមទៀត។ អ្នករួមផ្សំគំនិតក្នុងការគេចវេស ឬបន្លំពន្ធប្រថាប់ត្រា ត្រូវទទួលការពិន័យដូចអ្នកអនុវត្តផ្ទាល់ដែរ។

ករណីមិនរាងចាលត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**មាត្រា១៥**

ក្នុងករណីដែលមានការតវ៉ាអំពីចំនួនប្រាក់ពន្ធ និងប្រាក់ពិន័យអ្នកទទួលសិទ្ធិ ឬកម្មសិទ្ធិផ្ទះ ដី ដីសង់លំនៅឋាន រថយន្តគ្រប់ប្រភេទ ម៉ូតូគ្រប់ប្រភេទ ទូក កាណូត កប៉ាល់ សាឡាង់តាម

ការទិញលក់ត្រូវបង់ឱ្យគ្រប់ចំនួននូវប្រាក់ពន្ធប្រថាប់ត្រា និងប្រាក់ពិន័យតាមការកំណត់។ បើមិនព្រមបង់ពន្ធប្រថាប់ត្រា និងពិន័យត្រូវបញ្ជូនសំណុំរឿងទៅតុលាការខេត្ត-ក្រុងដើម្បីជំនុំជម្រះ។

**មាត្រា១៦**

កម្មាភិបាល បុគ្គលិកមានសមត្ថកិច្ចផ្តល់សិទ្ធិ ឬកម្មសិទ្ធិទាំងឡាយណាដែលបានផ្តល់សិទ្ធិ ឬកម្មសិទ្ធិផ្ទះ ដី ដីសង់លំនៅឋាន រថយន្តគ្រប់ប្រភេទ ម៉ូតូគ្រប់ប្រភេទ ទូក កាណូត កប៉ាល់ សាឡង់ ដោយការទិញលក់ ហើយដែលមិនទាន់បានបង់ពន្ធប្រថាប់ត្រា ត្រូវចេញសងថ្លៃពន្ធប្រថាប់ត្រាឱ្យបានគ្រប់ចំនួន និងត្រូវទទួលការពិន័យជាប្រាក់ដល់បីដង នៃប្រាក់ពន្ធប្រថាប់ត្រាដែលត្រូវបង់។ ក្នុងករណីធ្ងន់ធ្ងរត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**មាត្រា១៧**

តំណាង ឬភ្នាក់ងារអាជ្ញាធរដែលគ្មានសមត្ថកិច្ចអំពីបញ្ហាពន្ធប្រថាប់ត្រា ហើយលើកលែងបន្ថយពន្ធប្រថាប់ត្រា ផ្អាក ពន្យារពេល ឬហាមឃាត់ការប្រមូលពន្ធប្រថាប់ត្រា និងការពិន័យត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន និងត្រូវចេញសងប្រាក់ពន្ធប្រថាប់ត្រា និងប្រាក់ពិន័យដែលខូចខាតដោយសារការលើកលែងបន្ថយ ផ្អាក ពន្យារពេល ឬហាមឃាត់នោះថែមទៀត។

ក្នុងករណីធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**មាត្រា១៨**

តំណាង ឬភ្នាក់ងារជាអាជ្ញាធរណាដែលបង្ខំទារ ឬទទួលយកប្រាក់ពន្ធប្រថាប់ត្រា ដែលគ្មានចែងក្នុងច្បាប់ ឬដែលលើសពីការកំណត់ក្នុងច្បាប់ ត្រូវផ្តន្ទាទោសតាមមាត្រា៤នៃច្បាប់ស្តីពីការបង្កើតពន្ធប្រថាប់ត្រា។

**មាត្រា១៩**

ជនណាធ្វើឱ្យរាំងស្ទះ ឬប្រឆាំងនឹងការត្រួតពិនិត្យ និងការប្រមូលពន្ធប្រថាប់ត្រា ឬប្រមូលប្រាក់ពិន័យអំពីពន្ធប្រថាប់ត្រា ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

## ជំពូកទី៦ បទប្បញ្ញត្តិជាអវសាន

**មាត្រា២០**

រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុមានភារកិច្ចចេញប្រកាសណែនាំអនុវត្តអនុក្រឹត្យនេះ។

*វាយឡើងវិញ*

**មាត្រា២១**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា២២**

រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ រដ្ឋមន្ត្រីនៃក្រសួងដែលមានការពាក់ព័ន្ធ និងគណៈកម្មាធិការប្រជាជនខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង។ខ្លួន។

**មាត្រា២៣**

អនុក្រឹត្យនេះមានអានុភាពគតិយុត្តចាប់ពីថ្ងៃដែលប្រកាសផ្សាយជាសាធារណៈ។

**ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី**

**អនុប្រធាន**

**ហត្ថលេខា និងត្រា**

**ជា សុទ្ធ**

*កន្លែងទទួល*

-ខុទ្ទកាល័យមជ្ឈិមបក្ស

-ខុទ្ទកាល័យរដ្ឋសភា

-ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ

*"ដើម្បីជ្រាបជាព័ត៌មាន"*

-ដូចមាត្រា២២ "ដើម្បីអនុវត្ត"

-កាលប្បវត្តិ-ឯកសារ

រដ្ឋកម្ពុជា

ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

ក្រុមប្រឹក្សារដ្ឋមន្ត្រី

លេខ១៥៤សជណ                                        ភ្នំពេញ ថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩១

## សេចក្តីជូនដំណឹងរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុវត្តទៅតាមសេចក្តីសម្រេចចិត្តស្តីពីគោលនយោបាយ និងប្រើប្រាស់ដីធ្លីដែលសន្និបាតកម្មាភិបាលទូទាំងប្រទេសលើកទី២ បានដាក់ចេញសេចក្តីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លីរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីលេខ០៣សណន ចុះថ្ងៃទី០៣-០៦-១៩៨៩ និងបណ្តាលិខិតបទដ្ឋានផ្សេងៗទៀត ក្រុមប្រឹក្សារដ្ឋមន្ត្រីធ្វើការកត់សម្គាល់ឃើញថា ល្បឿន និងសន្ទុះការងារក្នុងការផ្តល់សិទ្ធិលើដីលំនៅឋាន និងអគារគ្រប់ប្រភេទនៅមានកម្រិតទាបដែលពុំទាន់អាចឆ្លើយតបនឹងសំណូមពរ បំណងប្រាថ្នារបស់រដ្ឋ និងប្រជាជននៅឡើយ ពិសេសក្នុងទីប្រជុំជន ទាំងក្រុង ទាំងជនបទ។

អាស្រ័យហេតុនេះ ដើម្បីឱ្យការងារខាងលើបានបម្រើពិតប្រាកដដល់វិស័យនយោបាយនៃប្រទេសជាតិ ក្រុមប្រឹក្សារដ្ឋមន្ត្រីកំណត់ដូចខាងក្រោម៖

-ក្រសួងកសិកម្មត្រូវបើកយុទ្ធនាការជាបន្ទាន់ក្នុងការផ្តល់សិទ្ធិលើដីលំនៅឋាន និងអគារគ្រប់ប្រភេទក្នុងក្របខ័ណ្ឌក្នុងទូទាំងប្រទេស ពិសេសរដ្ឋធានីភ្នំពេញ ធ្វើយ៉ាងណាឱ្យបានចប់សព្វគ្រប់នៅដំណាច់ឆ្នាំ១៩៩១នេះ។

-រដ្ឋអំណាចមូលដ្ឋានគ្រប់ជាន់ថ្នាក់ ត្រូវសហការ និងបង្កលក្ខណៈងាយស្រួលដល់អង្គភាពជំនាញសុរិយោដីដែលបោះទីតាំងនៅកន្លែងនោះ ដើម្បីធ្វើសកម្មភាពឱ្យបានល្អប្រសើរ។

-ស្ថាប័ននានាដែលមានការពាក់ព័ន្ធត្រូវជួយឧបត្ថម្ភដល់កិច្ចយុទ្ធនាការនេះ ដើម្បីធានាបាន ទាំងបរិមាណ ទាំងគុណភាព។

*វាយឡើងវិញ*

ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុប្រធាន

ហត្ថលេខា និងត្រា

ជា សុទ្ធ

*កន្លែងទទួល*

-ខុទ្ទកាល័យគណៈកម្មាធិការកណ្តាល នៃគណបក្សប្រជាជនកម្ពុជា

-ខុទ្ទកាល័យរដ្ឋសភា

-ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ

-ក្រសួងកសិកម្ម

*"ដើម្បីជូនជ្រាប"*

-គណៈកម្មាធិការប្រជាជនគ្រប់ខេត្ត-ក្រុង

*"ដើម្បីអនុវត្ត"*

-គ្រប់ក្រសួង និងស្ថាប័ន

*"ដើម្បីជ្រាប និងសហការអនុវត្ត"*

-ឯកសារ-កាលប្បវត្តិ

**រដ្ឋកម្ពុជា**

**ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ អព្យាក្រឹត វឌ្ឍនភាពសង្គម**

**ក្រសួងហិរញ្ញវត្ថុ**

លេខ០០៧ប្រក/កហវ ភ្នំពេញ ថ្ងៃទី០២ ខែមករា ឆ្នាំ១៩៩២

**ប្រកាស**

**ស្តីពីការណែនាំអនុវត្តអនុក្រឹត្យស្តីពីការប្រមូលពន្ធប្រថាប់ត្រា**

យោងតាមមាត្រា២០នៃអនុក្រឹត្យលេខ២០អនក្រ ចុះថ្ងៃទី២១ កញ្ញា ឆ្នាំ១៩៩១ ស្តីពីការប្រមូលពន្ធប្រថាប់ត្រា ក្រសួងហិរញ្ញវត្ថុសូមប្រកាសនូវសេចក្តីណែនាំអនុវត្តអនុក្រឹត្យនេះដូចមានខ្លឹមសារខាងក្រោម៖

**I.មុខសញ្ញាត្រូវប្រមូលពន្ធ និងត្រូវលើកលែងពន្ធប្រថាប់ត្រា**

ពន្ធប្រថាប់ត្រាត្រូវប្រមូលលើគ្រប់ករណីផ្ទេរសិទ្ធិ ឬកម្មសិទ្ធផ្ទះ ដី ដីសង់លំនៅឋាន រថយន្តគ្រប់ប្រភេទ ម៉ូតូគ្រប់ប្រភេទ ទូក កាណូត កប៉ាល់ សាឡាង់ តាមរូបភាពទិញ លក់ ដោយទូទាត់ជាសាច់ប្រាក់ ជាចំណែកភាគហ៊ុន និងដោះដូរជាវត្ថុទោះជារវាងបុគ្គល និងបុគ្គល និងសមូហភាព បុគ្គល និងអង្គការរដ្ឋ ឬរវាងសមូហភាព និងសមូហភាព និងអង្គការរដ្ឋ និងអង្គការរដ្ឋ។

ពន្ធប្រថាប់ត្រាត្រូវបានលើកលែងចំពោះករណីដូចខាងក្រោម៖

-ការទទួលសិទ្ធិ ឬកម្មសិទ្ធិដោយដោះដូរតាមសំណូមពររបស់អង្គការរដ្ឋ និងអង្គការសង្គម។

-ការទទួលសិទ្ធិ ឬកម្មសិទ្ធិរបស់ស្ថាប័នរដ្ឋតាមរូបភាពទិញ លក់ ដោយថវិកាដែលរដ្ឋបើកផ្តល់ ឬដោះដូរជាមួយទ្រព្យសម្បត្តិដែលមានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌរបស់ស្ថាប័ននោះ។

-ការទិញរថយន្តគ្រប់ប្រភេទ ម៉ូតូគ្រប់ប្រភេទ ទូក កាណូត កប៉ាល់ សាឡាង់ ធ្វើជាទំនិញដើម្បីលក់វិញរបស់អាជីវកម្មដ្ឋាននានាដែលបានបង់ពន្ធប៉ាតង់ និងបង់ពន្ធអាជីវកម្មត្រឹមត្រូវ។

**II.បែបបទប្រមូលពន្ធប្រថាប់ត្រា និងប្រថាប់ត្រា**

គ្រប់ករណីផ្ទេរសិទ្ធិ ឬកម្មសិទ្ធិផ្ទះ ដី ដីសង់លំនៅឋាន រថយន្តគ្រប់ប្រភេទ ម៉ូតូគ្រប់ប្រភេទ ទូក កាណូត កប៉ាល់ តាមរូបភាពទិញ លក់ ត្រូវមានកិច្ចសន្យាជាលាយលក្ខណ៍អក្សរ និង

បំពេញសំណុំលិខិតឱ្យបានគ្រប់គ្រាន់ តាមគំរូកំណត់អង្គការពន្ធ ដើម្បីស្នើសុំប្រថាប់ត្រាចុះបញ្ជី ហើយ និងបង់ពន្ធប្រថាប់ត្រា។

**១-អត្រាពន្ធ និងថ្លៃគិតពន្ធ**

ពន្ធប្រថាប់ត្រាអនុវត្តលើគ្រប់ករណីផ្ទេរសិទ្ធិ ឬកម្មសិទ្ធិតាមរូបភាពទិញ លក់ តាមអត្រាពន្ធ៖

-៦% ចំពោះផ្ទះ ដី និងដីសង់លំនៅឋាន

-៤% ចំពោះរថយន្តគ្រប់ប្រភេទ

-២% ចំពោះម៉ូតូគ្រប់ប្រភេទ

-២% ចំពោះទូក កាណូត កប៉ាល់ សាឡង់

លើតម្លៃទ្រព្យសម្បត្តិទាំងនោះ គិតតាមថ្លៃលើទីផ្សារ នាពេលផ្ទេរសិទ្ធិ ឬកម្មសិទ្ធិ។

ប៉ុន្តែ ចំពោះមុខនេះ ក្រសួងហិរញ្ញវត្ថុកំណត់ថ្លៃមួយសម្រាប់ធ្វើជាមូលដ្ឋានគិតពន្ធ "ថ្លៃគិតពន្ធប្រថាប់ត្រា"។ ការផ្ទេរកម្មសិទ្ធិរថយន្តគ្រប់ប្រភេទ ម៉ូតូគ្រប់ប្រភេទ ទូក កាណូត កប៉ាល់ សាឡង់ នៅក្នុងទូទាំងប្រទេស និងការផ្ទេរសិទ្ធិ ឬកម្មសិទ្ធិផ្ទះ ដី ដីសង់លំនៅឋាន នៅរដ្ឋធានីភ្នំពេញត្រូវអនុវត្តតាមថ្លៃកំណត់ដូចមានរាយក្នុងតារាងភ្ជាប់ជាឧបសម្ព័ន្ធជាមួយនឹងសេចក្ដីប្រកាសនេះ។ ដោយឡែក ចំពោះថ្លៃគិតពន្ធប្រថាប់ត្រាលើការផ្ទេរសិទ្ធិ ឬកម្មសិទ្ធិផ្ទះ ដីសង់លំនៅឋាន នៅតាមបណ្ដាខេត្ត-ក្រុងផ្សេងៗទៀតនោះ សាខាពន្ធដារខេត្ត-ក្រុង ត្រូវពិភាក្សាជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីកំណត់ ហើយដាក់ជូនក្រសួងហិរញ្ញវត្ថុពិនិត្យ និងសម្រេចមុននឹងអនុវត្ត។

ក្នុងករណីថ្លៃនៅលើទីផ្សារមានការប្រែប្រួល ក្រសួងហិរញ្ញវត្ថុនឹងពិនិត្យ កែសម្រួលថ្លៃគិតពន្ធប្រថាប់ត្រាដែលបានកំណត់នេះឱ្យបានសមស្រប។

**២-របៀបរបបប្រមូលពន្ធប្រថាប់ត្រា និងប្រថាប់ត្រា**

ពន្ធប្រថាប់ត្រាត្រូវប្រមូលក្នុងរយៈពេល៣០ថ្ងៃយ៉ាងយូរ គិតពីថ្ងៃដែលបានកត់ត្រាចុះក្នុងកិច្ចសន្យា។

ក្រោយពេលទទួលសំណុំលិខិត និងពិនិត្យឃើញថាមានគ្រប់គ្រាន់ហើយ ភ្នាក់ងារពន្ធដែលមានសមត្ថកិច្ចត្រូវចុះពិនិត្យជាក់ស្ដែង នូវស្ថានភាពទ្រព្យសម្បត្តិដែលត្រូវផ្ទេរ គិតពន្ធប្រមូលពន្ធប្រថាប់ត្រា ផ្ដល់បង្កាន់ដៃទទួលប្រាក់ពន្ធឱ្យអ្នកទទួលសិទ្ធិ ឬម្ចាស់កម្មសិទ្ធិ សម្រាប់ភ្ជាប់ជាមួយ

*វាយឡើងវិញ*

សំណុំលិខិតសុំផ្ទេរសិទ្ធិ ឬកម្មសិទ្ធិប្រថាប់ត្រាលើកិច្ចសន្យាទិញ លក់ និងកត់ត្រាចុះក្នុងបញ្ជីប្រថាប់ត្រា។

បញ្ជីប្រថាប់ត្រាមានពីរប្រភេទគឺ៖

-បញ្ជីប្រថាប់ត្រា ចំពោះករណីផ្ទេរសិទ្ធិ ឬកម្មសិទ្ធិផ្ទះ ដី ដីសង់លំនៅឋាន

-បញ្ជីប្រថាប់ត្រា ចំពោះករណីផ្ទេរសិទ្ធិ រថយន្ត ម៉ូតូ ទូក កាណូត កប៉ាល់ សាឡង់។

**III.ការចាត់តាំងអនុវត្ត**

កិច្ចការប្រថាប់ត្រា និងបង់ពន្ធប្រថាប់ត្រាចំពោះ៖

-ការផ្ទេរសិទ្ធិ ឬកម្មសិទ្ធិផ្ទះ ដី ដីសង់លំនៅឋាន ត្រូវអនុវត្តនៅផ្នែក ឬក្រុមប្រថាប់ត្រានៃអង្គភាពពន្ធក្នុងភូមិសាស្ត្រដែលផ្ទះ ដី ដីសង់លំនៅឋាននោះតាំងនៅ។

-ការផ្ទេរកម្មសិទ្ធិរថយន្ត ម៉ូតូ ទូក កាណូត កប៉ាល់ សាឡង់ត្រូវអនុវត្តនៅផ្នែក ឬក្រុមប្រថាប់ត្រានៃអង្គការពន្ធក្នុងមូលដ្ឋាននៃភាគីណាមួយនៃភាគីអ្នកទិញ អ្នកលក់។

**IV.កិច្ចការដកប្រាក់ទុកជូនជារង្វាន់**

ក្រសួងហិរញ្ញវត្ថុអនុញ្ញាតឱ្យដកប្រាក់ទុកជូនរង្វាន់ដូចតទៅ៖

-ចំពោះពន្ធប្រថាប់ត្រាលើផ្ទះ ដី ដីសង់លំនៅឋានអនុញ្ញាតឱ្យដក២ភាគរយ ១ភាគរយទុកជូនផ្នែកសុរិយោដី ១ភាគរយទុកជូនរដ្ឋអំណាចដែលផ្ទះ ដី ដីសង់លំនៅឋានទាំងនោះតាំងនៅ។

-ចំពោះពន្ធប្រថាប់ត្រាលើរថយន្តគ្រប់ប្រភេទ ម៉ូតូគ្រប់ប្រភេទ ទូក កាណូត កប៉ាល់ សាឡង់ គឺអនុញ្ញាតឱ្យដក១ភាគរយទុកផ្នែកគមនាគមន៍។

ប្រកាសណែនាំនេះមានប្រសិទ្ធភាពក្រោយរយៈពេល៧ថ្ងៃ បន្ទាប់ពីថ្ងៃដែលបានចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ**
**ហត្ថលេខា និងត្រា**
**ឆាយ ថន**

*ចម្លងជូន*
-ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី
-គ្រប់ក្រសួង មន្ទីរជុំវិញមជ្ឈិម
-គ្រប់ខេត្ត-ក្រុង
-គ្រប់សាខាពន្ធដារខេត្ត-ក្រុង
-ឯកសារ-កាលប្បវត្តិ

*វាយឡើងវិញ*

រដ្ឋកម្ពុជា

ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

ក្រសួងកសិកម្ម

លេខ៥០៤កសក ភ្នំពេញ ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩២

**រដ្ឋមន្ត្រីក្រសួងកសិកម្ម**

**សូមជម្រាបមក**

**លោកប្រធានគណៈកម្មាធិការប្រជាជនគ្រប់ខេត្ត-ក្រុង**

កម្មវត្ថុ៖ សំណើសុំកាត់បន្ថយបែបបទខ្លះនៃការចុះបញ្ជិកាជំហាន I សុរិយោដី។

សេចក្តីដូចមានក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូនលោកប្រធាន មេត្តាជ្រាបថា ផ្អែកតាមសំណូមពររបស់អង្គសិក្ខាសាលាសុរិយោដី ពីថ្ងៃទី២៥ ដល់២៨ ធ្នូ ១៩៩១ កន្លងទៅ និងពិនិត្យលើលក្ខណៈជាក់ស្តែងក្នុងការអនុវត្ត នៅមូលដ្ឋានផ្ទាល់ ឃើញថាក្នុងការបំពេញបែបបទចុះបញ្ជិកាជំហាន I កន្លងទៅនេះមានការលំបាក និងយឺតយ៉ាវដោយសារតម្រូវឱ្យចុះហត្ថលេខាលើបង្កាន់ដៃទាំងបី គឺ ក ខ និង គ។ ដូចនេះ ដើម្បីកាត់បន្ថយបែបបទឱ្យកាន់តែខ្លីងាយស្រួលក្នុងការអនុវត្ត និងរក្សាបានខ្លឹមសារដើមផងនោះ ខ្ញុំសូមជម្រាបជូនលោកប្រធានជ្រាប និងជួយមានវិធានការផ្សព្វផ្សាយដល់គ្រប់មូលដ្ឋានថាក្រសួងកសិកម្មអនុញ្ញាតឱ្យចុះហត្ថលេខាតែលើបង្កាន់ដៃ ខ ដោយសរសេរបន្ថែមនូវចំនួនទឹកប្រាក់ សរុបទាំងអស់ឱ្យបានច្បាស់លាស់ ហើយបែកបង្កាន់ដៃ ក និង គ កិបភ្ជាប់ជាមួយបង្កាន់ដៃ ខ នោះទុកជាឯកសារ។

អាស្រ័យសេចក្តីដូចបានជម្រាបជូនខាងលើ សូមលោកប្រធានគណៈកម្មាធិការប្រជាជនគ្រប់ខេត្ត-ក្រុង មេត្តាជ្រាប និងចាត់វិធានការផ្សព្វផ្សាយអនុវត្តឱ្យមានប្រសិទ្ធភាពតាមការគួរ។

**ជ.រដ្ឋមន្ត្រី**

**អនុរដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**សំរិត ប៊ិច**

*ចម្លងជូន*

-នាយកដ្ឋានសុរិយោដី

*"ដើម្បីមុខការ"*

-ឯកសារ-កាលប្បវត្តិ

**រដ្ឋកម្ពុជា**

**ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល**

**ក្រសួងកសិកម្ម**

**នាយកដ្ឋានសុរិយោដី**

លេខ០៨៣សជ ភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៩២

**ប្រធាននាយកដ្ឋានសុរិយោដី**

**ជម្រាបមក**

**លោកប្រធានការិយាល័យសុរិយោដីខេត្ត-ក្រុង**

កម្មវត្ថុ៖ សេចក្តីណែនាំអំពីរបៀបរបបចុះលេខាចារឹកលើបណ្ណលិខិតសញ្ញាផ្សេងៗដែលពាក់ព័ន្ធដល់ការគ្រប់គ្រងអចលនវត្ថុ។

ន័យដូចមានក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូនលោកប្រធានថា ដើម្បីតាក់តែង និងចុះលេខាចារឹកនៅលើបណ្ណលិខិតសញ្ញាផ្សេងៗដែលពាក់ព័ន្ធនឹងការគ្រប់គ្រងអចលនវត្ថុ ឱ្យបានត្រឹមត្រូវ និងគតិយុត្តក្នុងក្របខ័ណ្ឌទូទាំងប្រទេសនោះ នាយកដ្ឋានសូមធ្វើការណែនាំ និងកំណត់ជូនមានគំរូជូនភ្ជាប់មកជាមួយនេះស្រាប់។

អាស្រ័យហេតុនេះ សូមលោកប្រធានជ្រាប និងចាត់ការអនុវត្តជាបន្ទាន់ដោយធានាបាននូវប្រសិទ្ធភាពខ្ពស់។

**ប្រធាន**

**នាយកដ្ឋានសុរិយោដី**

**ហត្ថលេខា និងត្រា**

**លឹម គានហោ**

ចម្លងជូន
- ក្រសួងកសិកម្ម
  "ដើម្បីជូនជ្រាប"
- ការិយាល័យអភិរក្សសុរិយោដី
- ការិយាល័យអធិការកិច្ចភូមិបាល
  "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ

*វាយឡើងវិញ*

**រដ្ឋកម្ពុជា**
**ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល**

**ក្រសួងកសិកម្ម**
**នាយកដ្ឋានសុរិយោដី**
លេខ០៨៤សជ ភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៩២

**សេចក្ដីណែនាំ**
**ស្ដីពីការកំណត់ប្រភេទទ្រព្យក្នុងការកសាងឯកសារផ្សេងៗពាក់ព័ន្ធនឹងអចលនវត្ថុ**

ដើម្បីអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លីឱ្យមានប្រសិទ្ធភាព ធានាបាននូវលក្ខណៈបច្ចេកទេស និងគោលការណ៍នៃច្បាប់ នាយកដ្ឋានសុរិយោដី សូមធ្វើការណែនាំអំពីការកំណត់បែងចែកប្រភេទទ្រព្យដូចតទៅ៖

**កំណត់ទ្រព្យសម្បត្តិ**

**I.-ទ្រព្យឯកជន**

**១.-*ទ្រព្យសម្បត្តិនីតិជនលីវ*** -ឈ្មោះ សុខ សៅ ...............(លីវ)

**២.-*ទ្រព្យសម្បត្តិខាងប្ដី*** (P.M)

| | |
|---|---|
| ក-ប្ដីប្រពន្ធកំពុងរស់នៅជាមួយគ្នា | -ឈ្មោះ សុខ សៅ (ជាប្ដីនាង រស់ សំ) |
| ខ-ប្ដីប្រពន្ធរស់នៅ តែលែងគ្នា | -ឈ្មោះ សុខ សៅ (លែងលះពីនាង រស់ សំ) តាមសាលក្រមលេខ...........ចុះថ្ងៃទី........... |
| | -ឈ្មោះ សុខ សៅ លែងលះពីនាង រស់ សំ (មានប្រពន្ធក្រោយឈ្មោះនាង ជា សុនី) |
| គ-ប្ដីនៅរស់ ប្រពន្ធស្លាប់ | -ឈ្មោះ សុខ សៅ (ជាប្ដីនាង រស់ សំ ស្លាប់) |
| | -ឈ្មោះ សុខ សៅ ពោះម៉ាយពីខ្មោចនាង រស់ សំ (មានប្រពន្ធក្រោយឈ្មោះនាង ជា សុនី) |
| ឃ-ប្ដីស្លាប់ ប្រពន្ធនៅរស់ | -មតិកខ្មោច សុខ សៅ (ជាប្ដីនាង រស់ សំ មេម៉ាយ) |
| | -មតិកខ្មោច សុខ សៅ ជាប្ដីនាង រស់ សំ (មានប្ដីក្រោយឈ្មោះ......................) |

| | |
|---|---|
| ង-ប្ដីស្លាប់ ប្រពន្ធស្លាប់ | -មតិកខ្មោច សុខ សៅ ជាប្ដីខ្មោចនាង រស់ សំ |

**៣.ទ្រព្យសម្បត្តិខាងប្រពន្ធ** (PF)

| | |
|---|---|
| ក-ប្ដីប្រពន្ធកំពុងរស់នៅជាមួយគ្នា | -នាង រស់ សំ ( ជាប្រពន្ធឈ្មោះ សុខ សៅ) |
| ខ-ប្ដីប្រពន្ធនៅរស់ តែលែងគ្នា | -នាង រស់ សំ ( លែងលះពីឈ្មោះ សុខ សៅ) |
| | ( តាមសាលក្រមលេខ............ចុះថ្ងៃទី...........) |
| | -នាង រស់ សំ លែងលះពីឈ្មោះ សុខ សៅ |
| | ( មានប្ដីក្រោយឈ្មោះ........................) |
| គ-ប្រពន្ធនៅរស់ ប្ដីស្លាប់ | -នាង រស់ សំ "ជាប្រពន្ធឈ្មោះ សុខ សៅ ស្លាប់" |
| | -នាង រស់ សំ មេម៉ាយពីខ្មោច សុខ សៅ |
| | ( មានប្ដីក្រោយឈ្មោះ.........................) |
| ឃ-ប្រពន្ធស្លាប់ ប្ដីរស់ | -មតិកនាង រស់ សំ ជាប្រពន្ធឈ្មោះ សុខ សៅ |
| | -មតិកនាង រស់ សំ "ជាប្រពន្ធឈ្មោះ សុខ សៅ" |
| | ( មានប្រពន្ធក្រោយឈ្មោះ.....................) |
| ង-ប្រពន្ធស្លាប់ ប្ដីរស់ | -មតិកខ្មោច នាង រស់ "ជាប្រពន្ធខ្មោច សុខ សៅ" |

**៤.ទ្រព្យសម្បត្តិរួមប្ដី ប្រពន្ធ** (BC)

| | |
|---|---|
| ក-ប្ដីប្រពន្ធ រស់នៅជាមួយគ្នា | -ឈ្មោះ សុខ សៅ និងនាង រស់ សំ "ប្ដីប្រពន្ធ" |
| ខ-ប្ដីប្រពន្ធនៅរស់ តែលែងគ្នា | -ឈ្មោះ សុខ សៅ និងនាង រស់ សំ |
| | "លែងលះតាមសាលក្រមលេខ.......ចុះថ្ងៃទី......." |
| គ-ប្ដីរស់ ប្រពន្ធស្លាប់ | -ឈ្មោះ សុខ សៅ និងនាង រស់ សំ "ស្លាប់" |
| | -ឈ្មោះ សុខ សៅ និងនាង រស់ សំ "ស្លាប់" |
| | ( មានប្រពន្ធក្រោយឈ្មោះ.......................) |
| ឃ-ប្ដីស្លាប់ ប្រពន្ធរស់ | -ឈ្មោះ សុខ សៅ ស្លាប់ "និងនាង រស់ សំ មេម៉ាយ" |
| | -ឈ្មោះ សុខ សោ ស្លាប់ និងនាង រស់ សំ មេម៉ាយ |
| | ( មានប្ដីក្រោយឈ្មោះ............................) |

ង-ប្តីស្លាប់ ប្រពន្ធស្លាប់ -មតិកខ្មោច សុខ សៅ និងខ្មោចនាង រស់ សំ "ប្តីប្រពន្ធ"

**៥-ទ្រព្យសម្បត្តិឯកជននៃសមូហភាព**

-ឯកជន (Bien des Collectivités Privées)

-ទ្រព្យសម្បត្តិក្រុមហ៊ុន -ឈ្មោះក្រុមហ៊ុនឡតដ្ឋជ្រោយអំពិល "នីតិបុគ្គលឈរឈ្មោះតំណាងឱ្យក្រុមហ៊ុន"

**II-ទ្រព្យសម្បត្តិនៃសមូហភាពរដ្ឋ** (Bien des Collectivités de l'Etat)

១-ទ្រព្យសម្បត្តិឯកជននៃសមូហភាពរដ្ឋ (Bien Privé des Collectivités de l'Etat)

-ដីបេឡាភូមិ បេឡាឃុំ

-ទ្រព្យសម្បត្តិឯកជនរបស់ភូមិ -ឈ្មោះគណៈកម្មាធិការភូមិ យកបាត

-ទ្រព្យសម្បត្តិឯកជនរបស់ឃុំ -ឈ្មោះគណៈកម្មាធិការឃុំ ក្បាលកោះ

-នីតិបុគ្គល

២-ទ្រព្យសម្បត្តិសាធារណៈនៃសមូហភាពរដ្ឋ (Bien Public des Collectivités de l'Etat)

-បឹង ទន្លេ វត្ត សាលារៀន ទីស្នសាន អគារសាធារណៈ ផ្លូវ ដីបម្រុង សួន វាលយន្តហោះ.......... ។ល។

-ទ្រព្យសម្បត្តិមន្ទីរស្រុក ឃុំ ភូមិ -ឈ្មោះមន្ទីរស្រុក កៀនស្វាយ

-ឈ្មោះសាលា ជំពូវ័ន្ត

-ឈ្មោះវត្ត ចំប៉ា

-នីតិបុគ្គល

**ប្រធាន**
**នាយកដ្ឋានសុរិយោដី**
**ហត្ថលេខា និងត្រា**
**លឹម គានហោ**

<u>ចម្លងជូន</u>

-ក្រសួងកសិកម្ម

"ដើម្បីជូនជ្រាប"

-ការិយាល័យអភិរក្សសុរិយោដី

-ការិយាល័យអធិការកិច្ចភូមិបាល

"ដើម្បីមុខការ"

-ឯកសារ-កាលប្បវត្តិ

**រដ្ឋកម្ពុជា**

**ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល**

**ក្រសួងកសិកម្ម**

លេខ១១៣១កសក/ម/សរ ភ្នំពេញ ថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៩២

## សារទូរលេខ

<u>អ្នកផ្ញើ</u>៖ រដ្ឋមន្ត្រីក្រសួងកសិកម្ម

<u>អ្នកទទួល</u>៖ គណៈកម្មាធិការប្រជាជនគ្រប់ខេត្ត-ក្រុង

<u>ខ្លឹមសារ</u>៖ កន្លងមកនេះ ក្រសួងកសិកម្មពិនិត្យឃើញថា ខេត្ត-ក្រុងមួយចំនួនបានយកចិត្តទុកដាក់ជំរុញយ៉ាងសកម្មនូវការងារជំហាន I និងជំហាន II សុរិយោដី។ តែទន្ទឹមនឹងនេះ ក៏ពិនិត្យឃើញថា ខេត្ត-ក្រុងខ្លះមិនទាន់បានយកអស់លទ្ធភាពជំរុញការងារនេះនៅឡើយ។ ដូច្នេះដើម្បីជំរុញការងារអង្កេតវាស់វែង និងផ្តល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លី ផ្ទះសំបែងឱ្យខ្លាំងក្លា ជាយុទ្ធនាការឯកភាពទូទាំងប្រទេសនោះ សូមលោកប្រធានជួយមានវិធានការគ្រប់លទ្ធភាព ទាំងមធ្យោបាយ សម្ភារៈ និងកម្លាំងពលកម្ម ដើម្បីឱ្យការងារនេះប្រព្រឹត្តទៅមានប្រសិទ្ធភាពខ្ពស់។

**រដ្ឋមន្ត្រីក្រសួងកសិកម្ម**

**អនុរដ្ឋមន្ត្រីទី១**

**ហត្ថលេខា និងត្រា**

**ឈា សុង**

<u>ចម្លងជូន</u>

-ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"

-នាយកដ្ឋានសុរិយោដី

"ដើម្បីមុខការ"

រដ្ឋកម្ពុជា
ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

ក្រសួងកសិកម្ម
លេខ២៩៦ប្រក/កសក

ភ្នំពេញ ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ១៩៩២

## ប្រកាសស្តីពីការអនុញ្ញាតឱ្យជំនាញសុរិយោដី ប្រើប្រាស់លិខិតសញ្ញាពាក់ព័ន្ធនឹងការផ្ទេរអចលនវត្ថុ

### រដ្ឋមន្ត្រីក្រសួងកសិកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា
- បានឃើញច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ០៣ក្រ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២
- បានឃើញក្រឹត្យច្បាប់លេខ០៧ក្រច ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៨២ ស្តីពីសមត្ថកិច្ច និងនីតិវិធីនៃការធ្វើច្បាប់ និងបទបញ្ជា
- បានឃើញអនុក្រឹត្យលេខ១៨អនក្រ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៨៤ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម
- តាមសំណើរបស់នាយកដ្ឋានសុរិយោដី

### សម្រេច

**មាត្រា១**

អនុញ្ញាតឱ្យជំនាញសុរិយោដី ប្រើប្រាស់ជាផ្លូវការក្នុងទូទាំងប្រទេសនូវលិខិតសញ្ញាពាក់ព័ន្ធនឹងការផ្ទេរអចលនវត្ថុមាន៖

-លិខិតលក់ផ្តាច់

-លិខិតអំណោយផ្តាច់

-លិខិតចែកដីក្នុងចំណែកដោយព្រមព្រៀងគ្នា ដែលក្រសួងកសិកម្មបានបោះពុម្ព និងលក់ចែកជូនដូចមានឯកសារឧបសម្ព័ន្ធភ្ជាប់ជាមួយ ។

**មាត្រា២**

ជំនាញសុរិយោដីត្រូវមានភារកិច្ចអនុវត្តតាមគំរូលិខិត ដូចមានចែងក្នុងមាត្រា១ខាងលើនេះ ។

**មាត្រា៣**

ប្រកាសនេះមានអានុភាពគតិយុត្តចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈ ។

រដ្ឋមន្ត្រីក្រសួងកសិកម្ម
ហត្ថលេខា និងត្រា
ងួន ញ៉ិល

*វាយឡើងវិញ*

**រដ្ឋកម្ពុជា**
**ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល**

**ក្រសួងកសិកម្ម**
លេខ១៧០សជ/សណន                                        ភ្នំពេញ ថ្ងៃទី៧ ខែ៧ ឆ្នាំ១៩៩២

**សេចក្តីណែនាំ**
**ស្តីពីចលនានៃលិខិតសញ្ញាក្នុងការផ្ទេរអចលនវត្ថុ**

ដើម្បីអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លីឱ្យមានប្រសិទ្ធភាព ធានាបាននូវលក្ខណៈបច្ចេកទេស និងគោលការណ៍នៃច្បាប់ នាយកដ្ឋានសុរិយោដីសូមធ្វើការណែនាំស្តីអំពីចលនានៃលិខិតសញ្ញាក្នុងការផ្ទេរសិទ្ធិអចលនវត្ថុដូចតទៅ៖

**I.លក់ផ្តាច់ អំណោយផ្តាច់**

**ក.លក់ ឬអំណោយទាំងមូល**

ក្រោយពីគូភាគីទាំងសងខាង "អ្នកលក់ និងអ្នកទិញ" ឬ "អ្នកធ្វើអំណោយ និងអ្នកទទួល" បានឯកភាពគ្នាហើយ គូភាគីត្រូវនាំគ្នាទៅការិយាល័យភូមិបាលស្រុក-ខណ្ឌដែលគ្រប់គ្រងអចលនវត្ថុនោះ ដោយមានសាក្សីពីរនាក់ទៅជាមួយផង ដើម្បីធ្វើលិខិតសញ្ញាលក់ ឬអំណោយទៅតាមសំណូមពររបស់ខ្លួន។

**ការងាររបស់ការិយាល័យភូមិបាល "លើកទី១"**

នៅពេលដែលគូភាគីបានទៅទំនាក់ទំនងជាមួយប្រធានការិយាល័យភូមិបាល ឬភ្នាក់ងារភូមិបាលស្រុក-ខណ្ឌ ដើម្បីធ្វើលិខិតសញ្ញា ប្រធានការិយាល័យភូមិបាល ឬភ្នាក់ងារភូមិបាលស្រុកខណ្ឌត្រូវ៖

១-ពិនិត្យ ផ្ទៀងផ្ទាត់នូវរាល់បណ្តាលិខិតស្នាមទាំងអស់ឱ្យបានសព្វគ្រប់ ត្រឹមត្រូវច្បាស់លាស់ជាមុនសិនដូចជា៖

-ពិនិត្យប័ណ្ណសម្គាល់សិទ្ធិ ផ្ទៀងផ្ទាត់ជាមួយសៀវភៅចុះបញ្ជីអចលនវត្ថុ តើដូចគ្នាឬទេ? ប្រភេទទ្រព្យ............តើមានបន្ទុកអ្វីខ្លះ?

-ពិនិត្យអត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួនរបស់អ្នកទិញ ឬអ្នកទទួលអំណោយ តើជាជនពេញវ័យមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការទិញ ឬទទួលអំណោយដែរឬទេ?

-ត្រូវសួរបញ្ជាក់សាក្សីទាំងពីរនាក់ និងប្រាប់ហេតុផលដល់សាក្សីឱ្យបានច្បាស់លាស់ផង។ ក្នុងករណីអ្នកលក់ អ្នកទិញ អ្នកធ្វើអំណោយ អ្នកទទួលអំណោយគ្មានអត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួនដាច់ខាតត្រូវធ្វើលិខិតរដ្ឋបាលបញ្ជាក់ពីមេឃុំ ឬប្រធានសង្កាត់ឱ្យបានច្បាស់លាស់ត្រឹមត្រូវ។

២-ការិយាល័យភូមិបាលស្រុក-ខណ្ឌត្រូវចុះពិនិត្យ អង្កេតមើលអចលនវត្ថុ ពិនិត្យព្រំប្រទល់ តើមានការផ្លាស់ប្តូរឬទេ? មានទំនាស់ដែរឬទេ? ព្រមទាំងពិនិត្យទំហំផង។

៣-បើពិនិត្យទៅឃើញថា រាល់បណ្តាចំណុចខាងលើមានគ្រប់គ្រាន់ហើយ ការិយាល័យភូមិបាលស្រុក-ខណ្ឌអាចតែងលិខិតផ្លាស់ប្តូរទៅតាមបទដ្ឋាន និងតាមសំណូមពរជូនភាគីទាំងសងខាងបាន។ លិខិតសញ្ញាត្រូវធ្វើជាពីរច្បាប់ សរសេរដោយដៃទាំងពីរច្បាប់ មិនឱ្យកោសលប់ ឬសរសេរជាន់លើគ្នា រូបមន្តឱ្យបានត្រឹមត្រូវ វាយតម្លៃដីឱ្យបានសមស្រប ប្រាក់ថ្លៃប្រថាប់ត្រាគិតឱ្យបានត្រឹមត្រូវតាមអត្រាកំណត់។

ក្នុងករណីមានការខុសឆ្គងពុំសមស្រប មិនគ្រប់លក្ខណៈ ត្រូវកែតម្រូវដោយទឹកខ្មៅក្រហម ព្រមទាំងចុះហត្ថលេខា ឬផ្តិតមេដៃគូភាគី និងចុះហត្ថលេខាអ្នកតែងផង។

ក្រោយតែងលិខិតសញ្ញាចប់ ការិយាល័យភូមិបាលស្រុក-ខណ្ឌ ត្រូវប្រគល់លិខិតសញ្ញាទាំងពីរច្បាប់ និងប័ណ្ណសម្គាល់សិទ្ធិឱ្យទៅគូភាគីយកទៅទីស្នាក់ការឃុំ-សង្កាត់ ឬស្រុក-ខណ្ឌដោយនាំទាំងសាក្សីពីរនាក់ទៅជាមួយផង ដើម្បីឱ្យប្រធានឃុំ-សង្កាត់ ឬស្រុក-ខណ្ឌបញ្ជាក់ ចុះហត្ថលេខា និងបោះត្រាទទួលស្គាល់មេដៃស្តាំគូភាគីទាំងសងខាង និងសាក្សីទាំងពីរនាក់នៅចំពោះមុខ។

៤-ក្រោយពីបញ្ជាក់ឃុំ-សង្កាត់ ស្រុក-ខណ្ឌរួចហើយ ការិយាល័យភូមិបាលត្រូវចុះក្នុងសៀវភៅបញ្ជាក់លិខិត។

៥-ចុះក្នុងសៀវភៅកត់ត្រាលិខិត រួចប្រគល់លិខិតសញ្ញានេះឱ្យគូភាគីយកទៅប្រថាប់ត្រា (បង់លុយ)។

៦-ក្រោយពីប្រថាប់ត្រារួច ការិយាល័យភូមិបាលស្រុក-ខណ្ឌត្រូវ៖

-ផ្ញើដីកាអម

-ចុះក្នុងសៀវភៅសំណៅចេញដំណើរលិខិត (Régistre de depart) រួចបញ្ជូនលិខិតសញ្ញាទាំងពីរច្បាប់ និងប័ណ្ណសម្គាល់សិទ្ធិទៅការិយាល័យសុរិយោដីខេត្ត-ក្រុង តាមរយៈសៀវភៅបញ្ជូនលិខិត (Carnet de Transmission) ។

<u>ការងាររបស់ការិយាល័យសុរិយោដីខេត្ត-ក្រុង៖</u>

ប្រធានការិយាល័យត្រូវបញ្ជូនលិខិតសញ្ញា និងប័ណ្ណសម្គាល់សិទ្ធិទៅផ្នែកអភិរក្ស ។

<u>ផ្នែកអភិរក្សត្រូវ៖</u> ពីមុន Chef Bureau de Conservation

-ចុះក្នុងសៀវភៅចលនាលិខិត (Mouvement des actes) ឬហៅថា Contrôle des actes រួចប្រគល់ឱ្យក្រុមផ្សេងទៀតផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវ លើការតែងលិខិតសញ្ញាទាំងពីរច្បាប់ លើប័ណ្ណសម្គាល់សិទ្ធិ និងលើលិខិតរណបផ្សេងទៀត បើសិនជាមាន។ បើពិនិត្យទៅឃើញថាមានការខ្វះខាតដោយប្រការណាមួយ ប្រធានផ្នែកអភិរក្ស ត្រូវធ្វើដីកាអមបញ្ជូនលិខិតនោះត្រលប់ទៅការិយាល័យភូមិបាលស្រុក-ខណ្ឌ ដើម្បីធ្វើការកែតម្រូវ ឬបំពេញបន្ថែមទៅតាមលក្ខណៈដែលបានពិនិត្យឃើញ។ បើពិនិត្យទៅឃើញថា ត្រឹមត្រូវសព្វគ្រប់ហើយ ភ្នាក់ងារពិនិត្យផ្ទៀងផ្ទាត់ត្រូវចុះហត្ថលេខាទទួលខុសត្រូវ ព្រមទាំងដាក់ឈ្មោះ ចុះថ្ងៃ ខែ ឆ្នាំ ពិនិត្យនៅក្នុងលិខិតសញ្ញាទាំងពីរច្បាប់ រួចធ្វើលេខាចារឹក។

**<u>ការធ្វើលេខាចារឹកមាន៖</u>**

១-កសាងប័ណ្ណសម្គាល់សិទ្ធិថ្មី

២-ចុះក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ "ធ្វើចរន្តការ" រួចឱ្យប្រធានផ្នែកអភិរក្សចុះលេខាចារឹក។

៣-ដកលិខិតសញ្ញាមួយច្បាប់ និងប័ណ្ណសម្គាល់សិទ្ធិចាស់ "ឈ្មោះអ្នកលក់ អ្នកឱ្យ" ព្រមទាំងលិខិតរណបផ្សេងៗ "បើមាន" ទុកជាឯកសារនៅផ្នែកអភិរក្សសុរិយោដីខេត្ត-ក្រុង និងចុះលេខឯកសារលើលិខិតសញ្ញាផង។

៤-លិខិតសញ្ញាមួយច្បាប់ទៀត និងប័ណ្ណសម្គាល់សិទ្ធិថ្មីដែលបានធ្វើលេខាចារឹករួចហើយ ការិយាល័យសុរិយោដីខេត្ត-ក្រុង ត្រូវធ្វើដីកាអមផ្ញើទៅការិយាល័យភូមិបាលស្រុក-ខណ្ឌវិញ។

ប័ណ្ណសម្គាល់សិទ្ធិថ្មីនេះមានចុះហត្ថលេខា តែប្រធានការិយាល័យសុរិយោដីខេត្ត-ក្រុងទេ ពុំចាំបាច់មានហត្ថលេខារបស់ភូមិបាល និងប្រធានស្រុកឡើយ។

<u>**ការងាររបស់ការិយាល័យភូមិបាល "លើកទី២"**</u>

ការិយាល័យភូមិបាលស្រុក-ខណ្ឌត្រូវ៖

១-ចុះក្នុងសៀវភៅកត់ត្រាលិខិត

២-ចុះចរន្តការនៅក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ

៣-ចុះចរន្តការក្នុងប័ណ្ណឯកតភូតពន្ធដី ឬកសាងប័ណ្ណឯកសារពន្ធដីថ្មី

៤-ចុះក្នុងសៀវភៅប្រគល់លិខិតដើម្បីប្រគល់លិខិតសញ្ញាលក់ផ្តាច់ ឬអំណោយផ្តាច់នោះឱ្យទៅអ្នកទិញ ឬអ្នកទទួលអំណោយ ព្រមទាំងប័ណ្ណសម្គាល់សិទ្ធិថ្មីផង។

<u>**បញ្ជាក់**</u>

នៅពេលប្រគល់លិខិតសញ្ញា និងប័ណ្ណសម្គាល់សិទ្ធិ ប្រធានការិយាល័យភូមិបាលត្រូវឱ្យអ្នកទិញ ឬអ្នកទទួលអំណោយផ្តិតមេដៃ និងចុះឈ្មោះអ្នកទទួលក្នុងសៀវភៅប្រគល់លិខិតផង។

**ខ.លក់ ឬអំណោយដោយបំបែកក្បាលដី**

ចលនាលិខិតដូច លក់ ឱ្យ ទាំងមូលដែរ ប៉ុន្តែដំបូងបង្អស់ មុននឹងតាក់តែងលិខិត ការិយាល័យភូមិបាលស្រុក-ខណ្ឌ ត្រូវបំពេញបន្ថែមនូវការងារដូចខាងក្រោម៖

១-វាស់បំបែកក្បាលដីលក់ ឬអំណោយតាមសំណូមពររបស់អ្នកលក់ ឬអ្នកធ្វើអំណោយ។

២-ធ្វើសលាកប័ត្រវាស់បំបែកក្បាលដីដល់ទីកន្លែង ដោយមានគំនូរ និងមានការទទួលខុសត្រូវពីភ្នាក់ងារភូមិបាល។

៣-ក្នុងសលាកប័ត្រនេះ ត្រូវបានគូភាគីផ្តិតមេដៃទទួលស្គាល់ និងយល់ព្រម ហើយត្រូវមានអ្នកជិតខាងចំនួនពីរនាក់បានដឹងឮ និងផ្តិតមេដៃជាមួយផង។

៤-ពេលបានទទួលសលាកប័ត្រវាស់បំបែកក្បាលដីនោះមកហើយ ទើបអាចតាក់តែងលិខិតសញ្ញាបាន។ ឯសលាកប័ត្រនេះត្រូវបិទភ្ជាប់នឹងទំព័រទី២នៃលិខិតសញ្ញា ហើយបោះត្រាចំកណ្តាលត្រង់កន្លែងបិទតភ្ជាប់នោះ។

<u>**ការិយាល័យសុរិយោដីខេត្ត-ក្រុង**</u>

ការិយាល័យសុរិយោដីខេត្ត៖

១-ត្រូវផ្ទៀងផ្ទាត់លិខិតសញ្ញាទាំងពីរច្បាប់ ប័ណ្ណសម្គាល់សិទ្ធិ និងសលាកប័ត្រវាស់បំបែកក្បាលដី។

២-ធ្វើលេខាចារឹកក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ និងប័ណ្ណសម្គាល់សិទ្ធិ។

៣-កសាងប័ណ្ណសម្គាល់សិទ្ធិដីដែលបំបែកលក់ ឬឱ្យទៅតាមចំណែកដីដែលលក់ ឬឱ្យនោះ។

៤-ដកទុកលិខិតសញ្ញាលក់មួយច្បាប់ និងលិខិតរណបផ្សេងៗសម្រាប់ឯកសារ និងឱ្យលេខលើលិខិតសញ្ញាផង។

៥-ធ្វើដីកាអមផ្ញើមកការិយាល័យភូមិបាលស្រុក-ខណ្ឌវិញ នូវលិខិតលក់មួយច្បាប់ ប័ណ្ណសម្គាល់សិទ្ធិដើម និងប័ណ្ណសម្គាល់សិទ្ធិថ្មី។

ការិយាល័យភូមិបាលស្រុក៖

ត្រូវចុះបញ្ជីដូចការលក់ដីទាំងមូលដែរ តែលើកនេះត្រូវ៖

-ប្រគល់លិខិតលក់ (ឬអំណោយផ្ដាច់) និងប័ណ្ណសម្គាល់សិទ្ធិថ្មីឱ្យទៅអ្នកទិញ ឬអ្នកទទួលអំណោយ។

-ឯប័ណ្ណសម្គាល់សិទ្ធិដើមត្រូវប្រគល់ឱ្យអ្នកលក់ ឬអ្នកធ្វើអំណោយវិញ។

**II.លិខិតចែកដោយព្រមព្រៀង**

ចលនាលិខិតនេះដូចគ្នានឹងលិខិតលក់ ឬអំណោយដែរ ប៉ុន្តែមុននឹងតាក់តែងលិខិតសញ្ញា អ្នកទទួលមតិកត្រូវមានសំបុត្រតំណវង្សត្រកូល និងបដិញ្ញាណសម្គាល់អ្នកត្រូវទទួលមតិកគ្រប់កូនទាំងអស់។

**ប្រធាននាយកដ្ឋានសុរិយោដី**
**ហត្ថលេខា និងត្រា**
**លឹម គានហោ**

<u>*ចម្លងជូន*</u>
-ក្រសួងកសិកម្ម
"ដើម្បីជូនជ្រាប"
-ការិយាល័យអភិរក្សសុរិយោដី
-ការិយាល័យអធិការកិច្ចភូមិបាល
"ដើម្បីមុខការ"
-ឯកសារ-កាលប្បវត្តិ

**រដ្ឋកម្ពុជា**

**ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល**

**ក្រុមប្រឹក្សារដ្ឋ**

លេខ១០០ក្រ

**ក្រឹត្យ**

**ក្រុមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំរដ្ឋសភា និងក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ០៤ក្រ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២

**សម្រេច**

ប្រកាសឱ្យប្រើច្បាប់ភូមិបាលដែលរដ្ឋសភានៃរដ្ឋកម្ពុជាបានអនុម័តនៅថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩២ នាសម័យប្រជុំលើកទី២៣ នីតិកាលទី១។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩២

**ជ.ក្រុមប្រឹក្សារដ្ឋ**

**ប្រធាន**

**ហត្ថលេខា និងត្រា**

**ហេង សំរិន**

រដ្ឋកម្ពុជា

រដ្ឋសភា ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

# ច្បាប់ភូមិបាល

## បទប្បញ្ញត្តិទូទៅ

### មាត្រា១

ដីធ្លីនៃរដ្ឋកម្ពុជាជាសម្បត្តិរបស់រដ្ឋ ហើយត្រូវបានរដ្ឋគ្រប់គ្រងដោយឯកភាពទូទាំងប្រទេស។ រដ្ឋមិនទទួលស្គាល់ដាច់ខាតរបបកម្មសិទ្ធិចាស់លើដីធ្លីមុនឆ្នាំ១៩៧៩។ កម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀតលើដីធ្លីត្រូវឋិតនៅក្រោមអំណាចនៃច្បាប់នេះ។

### មាត្រា២

ពលរដ្ឋកម្ពុជាមានសិទ្ធិពេញទី ក្នុងការកាន់កាប់ប្រើប្រាស់ដីធ្លី និងមានសិទ្ធិតំណមតិកលើដីធ្លីដែលរដ្ឋប្រគល់ឱ្យសម្រាប់រស់នៅ និងធ្វើអាជីវកម្ម។

### មាត្រា៣

រដ្ឋធានាឱ្យអ្នកប្រើប្រាស់ដីធ្លីនូវសិទ្ធិកាន់កាប់ ប្រើប្រាស់ និងទទួលផលស្របច្បាប់អំពីដីធ្លី។ ការប៉ះពាល់ដល់កម្មសិទ្ធិឯកជននៃពលរដ្ឋ ត្រូវហាមឃាត់មិនឱ្យមាន វៀរលែងតែប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើក្នុងករណីដែលមានចែងក្នុងច្បាប់។ ក្នុងន័យនេះម្ចាស់កម្មសិទ្ធិមានសិទ្ធិទទួលបំណាច់ជាមុនដោយត្រឹមត្រូវ និងសមរម្យ។

### មាត្រា៤

រ៉ែ បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រជាតិដែលមាននៅក្នុងដី នៅលើដី នៅបាតសមុទ្រ និងនៅក្រោមបាតសមុទ្រជាសម្បត្តិរបស់រដ្ឋ។

### មាត្រា៥

មិនឱ្យមានសិទ្ធិជាឯកជន ក្នុងដែនបម្រុងរុក្ខា នេសាទ អាងតម្កល់ទឹកស្រោចស្រព បរិវេណមណ្ឌលរ៉ែ មណ្ឌលបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រជាតិ វត្តអារ៉ាម ទីស្មសាន សាលារៀន សួន និងទួលសាធារណៈ អតីតសំណង់រដ្ឋ ដីបម្រុង និងដីចំណើសម្រាប់ផ្តល់ ដីបម្រុង និងដីសម្រាប់ផ្លូវដែក ទន្លេ សមុទ្រ។

## មាតិកាទី១ កម្មសិទ្ធិលើអចលនវត្ថុ
## ជំពូកទី១ អំពីអចលនវត្ថុ "អចលនទ្រព្យ"
## ផ្នែកទី១ អំពីប្រភេទនៃអចលនទ្រព្យ

**មាត្រា៦**

អចលនវត្ថុគឺវត្ថុដែលមានស្ថានភាពជាប់នឹងកន្លែងតែមួយ មិនកម្រើកពីកំណើតក្តី ពីភ័ព្វវាសនានៃវត្ថុនោះក្តី។ វត្ថុទាំងឡាយខ្លះដែលដឹកនាំបានតាមកំណើតរបស់វា តែច្បាប់រាប់បញ្ចូលជាអចលនវត្ថុ ដែលហៅថាអចលនវត្ថុតាមសន្មតរបស់ច្បាប់។

សិទ្ធិប្រត្យក្សទាំងឡាយលើអចលនវត្ថុ ក៏ទុកជាអចលនវត្ថុដែរ។

**មាត្រា៧**

អចលនវត្ថុពីកំណើតគឺដីធ្លី សំណង់គ្រប់ប្រភេទ ដែលសង់លើគ្រឹះ ឬសង់ដោយបាយអរ និងឥដ្ឋ សំណង់ទាំងឡាយ បើរុះរើទៅនឹងនាំឱ្យខូចខាតអស់តម្លៃច្រើន។

**មាត្រា៨**

អចលនវត្ថុពីភ័ព្វវាសនានោះ គឺវត្ថុទាំងពួងទោះបីពីកំណើតមកដឹកនាំបានក៏ដោយ ក៏ត្រូវទុកជាអចលនវត្ថុដែរ ព្រោះវាជាបរិវារនៃអចលនវត្ថុ វាត្រូវតែនៅជាប់នឹងអចលនវត្ថុ ជួនកាលព្រោះវានោះជារបស់ដែលកើតអំពីអចលនវត្ថុ ដូចជាផលានុផលនៃរុក្ខជាតិគ្រប់យ៉ាង ដែលមិនទាន់ច្រូតកាត់ចាកដើម ឬមិនទាន់ដាច់ចេញអំពីដី ឬដើមឈើដែលកំពុងទ្រទ្រង់នូវផ្លែ ជួនកាលពីព្រោះវានោះជារបស់ចាំបាច់ ឬមានប្រយោជន៍ក្នុងអាជីវកម្មខាងកសិកម្ម ខាងឧស្សាហកម្ម ខាងពាណិជ្ជកម្មនៃមូលនិធិ ដូចជាសត្វចិញ្ចឹមយកធារ ចិញ្ចឹមសម្រាប់លក់ សម្រាប់អូស សម្រាប់ដឹកនាំ សម្រាប់ប្រណាំង សម្រាប់ភ្ជួររាស់ យន្តឧបករណ៍ឧបភោគភណ្ឌ ប្រដាប់ប្រដា និងសម្ភារៈទាំងឡាយ ជី ពូជ និងកូនឈើ ជួនកាលពីព្រោះវានោះជារបស់ដែលគេផ្សំចូលគ្នានឹងអចលនវត្ថុពីកំណើត ដោយប្រការថាបើគេនឹងបំបែកវាចេញពីអចលនវត្ថុឱ្យជាវត្ថុដឹកនាំបាន លុះណាតែគេធ្វើឱ្យវាខូចរបៀបដែលបានរៀបចំ ហើយខូចប្រយោជន៍ ខូចសេចក្តីស្រួល និងខូចលំអនៃអចលនវត្ថុនោះជួយទ្រទ្រង់មក ដូចយ៉ាងទបង្ហូរទឹក កញ្ចក់ធំ បដិមាករ និងគោមព្យួរ ឬភ្ជាប់នឹងជញ្ជាំងពិដានក្តារជាដើម។

**មាត្រា៩**

អចលនវត្ថុតាមសន្មតរបស់ច្បាប់ នោះគឺវត្ថុដែលច្បាប់តម្កល់ឱ្យនៅក្នុងរបៀបជាអចលនវត្ថុពីកំណើត ថ្វីបើវាជាវត្ថុដឹកនាំបាន។

អចលនវត្ថុទាំងឡាយនោះគឺទូកដែលមានចំណុះ៣០តោនឡើងទៅ ផ្ទះផែដែលមានចំណុះដូចគ្នានឹងសិទ្ធិប្រត្យក្សលើអចលនវត្ថុ។

**មាត្រា១០**

ទ្រព្យជាអចលនវត្ថុ និងសិទ្ធិប្រត្យក្សលើអចលនវត្ថុនោះ ជួនកាលអាចជារបស់ឯកជននៃជនតែម្នាក់ ឬច្រើននាក់ ដែលមានចំណែករៀង១ខ្លួនលើទ្រព្យតែមួយនោះ ឬលើសិទ្ធិតែមួយដែលនឹងញែកឱ្យបែកគ្នាមិនបានក៏មាន ជួនកាលជារបស់សមូហភាពនៃប្រជាជនមួយក្រុម ឬជារបស់ប្រជាជនទាំងអស់ក៏មាន។

ទ្រព្យប្រភេទទីមួយ "គឺទ្រព្យឯកជន" ត្រូវទុកជាកម្មសិទ្ធិឯកជនផ្ទាល់ខ្លួនម្នាក់១ ទ្រព្យប្រភេទទីពីរ "គឺទ្រព្យសមូហភាព" ត្រូវទុកជាសម្បត្តិសាធារណៈ និងជាសម្បត្តិឯកជននៃសមូហភាព។

ក្នុងករណីទាំងឡាយនេះ ឯកជនក្តី សមូហភាពក្តីត្រូវតែមានសិទ្ធិលើអចលនវត្ថុ ដូចមានរាយខាងក្រោមនេះ ឯសិទ្ធិក្រៅពីនោះច្បាប់មិនទទួលស្គាល់សោះទេ៖

១-កម្មសិទ្ធិ

២-ភោគៈ

៣-ការអនុញ្ញាតឱ្យដាំដំណាំ

៤-សម្បទាន

៥-ផលុបភោគ

៦-សិទ្ធិប្រើប្រាស់ និងអាស្រ័យនៅ

៧-សេវភាព

៨-ការបញ្ចាំអចលនវត្ថុ

៩-អ៊ីប៉ូតែក

សិទ្ធិស្តីពីការអនុញ្ញាតឱ្យដាំដំណាំ និងសិទ្ធិសម្បទាន នឹងកំណត់ក្នុងច្បាប់ដោយឡែក។

**មាត្រា១១**

ផលុបភោគ សិទ្ធិប្រើប្រាស់ និងអាស្រ័យនៅ សេវភាពទាំងអស់នោះជាប្រការធ្វើឱ្យសៅហ្មងដល់សិទ្ធិរបស់កម្មសិទ្ធិករ ឱ្យខានអាស្រ័យផ្តាច់មុខតែម្នាក់ឯងនូវកម្មសិទ្ធិរបស់ខ្លួនដោយខ្លួនព្រមព្រៀងដោយចេតនាផង ឬដោយច្បាប់បង្ខំមកផង។ សិទ្ធិទាំង៣ខាងលើនេះមានសំដែងក្នុងមាតិកាទី៣ ស្តីពីអវយវភេទនៃកម្មសិទ្ធិ ដែលមិនមែនជាប្រាតិភោគប្រត្យក្សទេ។

ការបញ្ចាំអចលនវត្ថុ ចាត់ទុកជាប្រាតិភោគប្រត្យក្ស សម្រាប់ការពារសេចក្តីប្តេជ្ញា ដែលកម្មសិទ្ធិករបានដាក់អចលនវត្ថុជាគ្រឿងធានានោះ កុំឱ្យគេចកែទៅណាបាន គឺត្រូវតែប្រតិបត្តិតាមកាតព្វកិច្ចរបស់ខ្លួន ដើម្បីជាប្រយោជន៏ដល់អ្នកទទួលបញ្ចាំ។

## ផ្នែកទី២ អំពីទំនាក់ទំនងរវាងអចលនវត្ថុជាមួយម្ចាស់អចលនវត្ថុ

### មាត្រា១២

ម្ចាស់អចលនវត្ថុដែលច្បាប់ទទួលស្គាល់ មានសិទ្ធិទទួលផលគ្រប់បែបយ៉ាងអំពីអចលនវត្ថុនោះមានផលធម្មជាតិ និងផលស៊ីវិល ។

ផលធម្មជាតិគឺផលិតផលដែលកើតអំពីដីធ្លី ឬសត្វស្រុក សិទ្ធិវន្តត្រូវទទួលផលនោះតាមរូបកំណើតរបស់វា ។

ផលស៊ីវិលគឺផលទុន ធនលាភ និងការប្រាក់សិទ្ធិវន្ត ត្រូវទទួលលផ្នលនោះដោយយកជាប្រាក់ ។

### មាត្រា១៣

សាមញ្ញជនទាំងឡាយអាចចាត់ចែងនូវទ្រព្យ និងសិទ្ធិទាំងឡាយដែលខ្លួនមានក្នុងឋានៈខ្លួនជាឯកជនបានដោយសេរី ដោយគ្រាន់តែថាមុននឹងធ្វើកិច្ចការទាំងឡាយ សាមញ្ញជនត្រូវតែគោរពតាមបទប្បញ្ញត្តិនៃច្បាប់ជាធម្មានុរូបផងតែប៉ុណ្ណោះ ។

### មាត្រា១៤

ដើម្បីគ្រប់គ្រងសម្បត្តិរបស់ខ្លួន សមូហភាពដែលមានសម្បត្តិត្រូវទុកដូចជាបុគ្គលម្នាក់ដែរហៅថានីតិបុគ្គល ដែលត្រូវមានបុគ្គលភាពមួយដែរ តែដាច់ដោយឡែកផ្សេងពីបុគ្គលភាពនៃសមាជិកម្នាក់ៗរបស់ខ្លួន ហើយដែលត្រូវជាតំណាងសមាជិកនោះ ក្នុងការអាស្រ័យនូវសិទ្ធិទាំងឡាយរបស់ខ្លួនផង ។

ដើម្បីគ្រប់គ្រង និងចាត់ចែងសម្បត្តិខ្លួននោះ ទោះជាសម្បត្តិសាធារណៈក្តី ជាសម្បត្តិឯកជនក្តី សមូហភាពត្រូវប្រតិបត្តិតាមច្បាប់ដោយឡែក ។

### មាត្រា១៥

ទ្រព្យទាំងឡាយណាដែលផលប្រយោជន៍សង្គមតម្រូវថា ត្រូវតែរក្សាទុកតាមរូបកំណើតរបស់វា ដើម្បីជាគុណប្រយោជន៍ដល់សាធារណជនទាំងមូល ទ្រព្យសម្បត្តិទាំងឡាយនោះ ត្រូវទុកជាសម្បត្តិសាធារណៈនៃសមូហភាពរដ្ឋ។ ទ្រព្យទាំងនោះ បើនៅតែមានលក្ខណៈដូចពោលខាងលើ អ្នកណាលក់ដូរ ចាយវាយទៅណាមិនបានជាដាច់ខាត ។

**មាត្រា១៦**

ទ្រព្យណាដែលមិនមានប្រយោជន៍ទូទៅដូចពោលមកនោះទេ ហើយដែលអ្នកទាំងពួង ក៏អាចមានគ្រប់គ្នាបានដែរ ទ្រព្យនោះត្រូវទុកជាសម្បត្តិឯកជននៃសមូហភាព។

**មាត្រា១៧**

ទ្រព្យទាំងឡាយនៃសម្បត្តិសាធារណៈ នៅពេលដែលវាលែងមានប្រយោជន៍សង្គម ហើយ វាក៏ត្រលប់ទៅជាសម្បត្តិឯកជនវិញតាមរយៈច្បាប់ដាំដំណាំ ឬសម្បទាន ហើយវាលែងនៅជាសម្បត្តិ ដែលគេលក់ដូរមិនបានទៀតនោះឡើយ។

**មាត្រា១៨**

ទ្រព្យដែលទំនេរ និងឥតម្ចាស់ ទ្រព្យនៃជនដែលស្លាប់ឥតទាយាទ មតិកដែលគេបោះបង់ ចោលត្រូវបានមកជាសម្បត្តិឯកជននៃរដ្ឋ។

អចលនវត្ថុឥតចុះបញ្ជី ទោះបីបង្កបង្កើនផលក្តី ឥតបង្កបង្កើនផលក្តី ក្នុងកំណត់៥ឆ្នាំ ត្រូវ ចាត់ទុកជាសម្បត្តិឯកជននៃរដ្ឋ។

អចលនវត្ថុចុះបញ្ជីដែលម្ចាស់អចលនវត្ថុមិនបានបង់ពន្ធ ឬអាករ ឬឈ្នួល តាមកាល និង អត្រាកំណត់របស់រដ្ឋ ក្នុងរយៈ៥ឆ្នាំជាប់ៗគ្នា និងទ្រព្យដែលអ្នកទាំងពួងប្ដឹងថាលែងយក ក៏ត្រូវបាន មកជាសម្បត្តិឯកជននៃរដ្ឋដែរ។

## ជំពូកទី២ អំពីកម្មសិទ្ធិ

**មាត្រា១៩**

កម្មសិទ្ធិគឺជាសិទ្ធិដែលច្បាប់បើកឱ្យអាស្រ័យ ឱ្យចាត់ចែងនូវទ្រព្យណាមួយយ៉ាងផ្ដាច់ការ និងផ្ដាច់មុខតែម្នាក់ឯង កុំឱ្យតែយកវត្ថុនោះទៅប្រើប្រាស់ដោយបទឯណាដែលខុសនឹងច្បាប់បាន ហាមហើយ។

នឹងអាចទៅជាដីកម្មសិទ្ធិ គឺចំពោះតែដីសម្រាប់សង់លំនៅឋាន។ ចំពោះដីសម្រាប់សង់ លំនៅឋានក្នុងទីប្រជុំជន និងទីក្រុងត្រូវកំណត់ក្នុងច្បាប់មួយដោយឡែក។

**មាត្រា២០**

គ្មានជនណាមួយត្រូវគេបង្ខំឱ្យផ្ទេរនូវទ្រព្យជាកម្មសិទ្ធិរបស់ខ្លួនបានឡើយ។ ប្រសិនបើ ការបង្ខំនោះ មិនមែនជាការចាំបាច់យកមកធ្វើជាសាធារណប្រយោជន៍ទេ ហើយនិងមិនបានបង់ សំណួកចិត្តជាមុនដោយត្រឹមត្រូវ និងសមរម្យទេ។

**មាត្រា២១**

អ្នកមានកម្មសិទ្ធិនៃទ្រព្យអ្វីមួយ រមែងមានសិទ្ធិត្រូវបានអ្វីៗទាំងអស់ដែលកើតពីទ្រព្យនោះ និងអ្វីៗទាំងអស់ដែលដុះជាបរិវារនៃទ្រព្យនោះ ពីកំណើតក្តី ពីសិប្បនិមិត្តក្តី សិទ្ធិនេះហៅថាសិទ្ធិដំណុះ ។

## ផ្នែកទី១ អំពីសិទ្ធិដំណុះដែលកើតអំពីវត្ថុ

**មាត្រា២២**

ផលធម្មជាតិដែលកើតអំពីដី ផលស៊ីវិល ធារដែលកើតអំពីសត្វ ត្រូវបានទៅកម្មសិទ្ធិករដោយអំណាចនៃសិទ្ធិដំណុះនេះ ។

**មាត្រា២៣**

ផលដែលកើតអំពីវត្ថុនឹងបានទៅកម្មសិទ្ធិករ លុះណាតែជននេះបានសងថ្លៃការងារ ថ្លៃពូជដែលតតិយជនបានធ្វើមកនោះ ។

## ផ្នែកទី២ អំពីសិទ្ធិដំណុះលើអ្វីដែលជាប់ និងដែលផ្សំគ្នានឹងវត្ថុ

**មាត្រា២៤**

អ្វីៗដែលដុះជាប់ និងដែលផ្សំគ្នានឹងវត្ថុណាត្រូវបានទៅកម្មសិទ្ធិករនៃវត្ថុនោះ ។

**មាត្រា២៥**

កម្មសិទ្ធិនៃដី គឺជាកម្មសិទ្ធិទាំងខាងលើ និងទាំងខាងក្រោមដី ។ កម្មសិទ្ធិករអាចដាំដំណាំនិងសង់សំណង់នៅលើដីតាមអធ្យាស្រ័យនៃខ្លួនបាន វៀរតែកាលណាដែលមានច្បាប់ និងបទបញ្ជាទាំងឡាយហាមឃាត់ ។

កម្មសិទ្ធិករអាចសង់សំណង់ក្រោមដី និងជីករូងរករបស់អ្វីដែលកើតក្នុងដីតាមសេចក្តីប្រាថ្នានៃខ្លួនបាន វៀរតែកាលណាដែលមានច្បាប់ និងបទបញ្ជាបានហាមឃាត់ហើយ ។

**មាត្រា២៦**

សំណងដំណាំ និងការទាំងឡាយដែលធ្វើលើដី ឬក្នុងដីបើគ្មានសម្គាល់អ្វីថាជារបស់អ្នកដទៃទេ ត្រូវសន្មតថាជាកម្មសិទ្ធិករធ្វើដោយធនធានរបស់ខ្លួន ។

**មាត្រា២៧**

កម្មសិទ្ធិករនៃដីដែលបានធ្វើសំណង់ និងការរៀបធ្វើដោយសម្ភារៈដែលមិនមែនជារបស់ខ្លួន ត្រូវចេញថ្លៃសម្ភារៈទាំងនោះឱ្យម្ចាស់គេវិញ។ កម្មសិទ្ធិករ អាចត្រូវទណ្ឌកម្មឱ្យសងជំងឺចិត្តគេផង ក៏បាន បើគប្បីឱ្យសងតែម្ចាស់សម្ភារៈមិនមានសិទ្ធិនឹងអូសយករបស់ទាំងនោះវិញឡើយ។

**មាត្រា២៨**

បើដំណាំ សំណង់ និងការរៀបទាំងពួង គឺតតិយជនបានសង់ បានធ្វើដោយសម្ភារៈរបស់ខ្លួន ហើយកម្មសិទ្ធិករត្រូវមានសិទ្ធិនឹងទុករបស់ទាំងនោះ ឬនឹងឱ្យតតិយជននោះរុះរើនាំយកចេញបាន។ បើកម្មសិទ្ធិករឱ្យយកដំណាំ និងសំណង់ទាំងនោះចេញ អ្នកដែលបានដាំបានសង់នោះត្រូវនាំយកចេញដោយខ្លួនបង់ខាតសោហ៊ុយ និងទារជំងឺចិត្តអ្វីមិនបានឡើយ។ តតិយជននោះអាចនឹងត្រូវទណ្ឌកម្មឱ្យចេញសោហ៊ុយជំងឺចិត្តទៀតក៏បាន ប្រសិនបើកិច្ចការនោះបានបណ្តាលឱ្យមានព្យសនកម្មដល់កម្មសិទ្ធិករនៃដី។

បើកម្មសិទ្ធិករចូលចិត្តទុកដំណាំ និងការរៀបទាំងឡាយ នោះជននេះត្រូវចេញថ្លៃសម្ភារៈ និងថ្លៃពលកម្មឱ្យគេដោយមិនគិតថាដីនោះអាចនឹងបានតម្លៃកើនឡើងទៀតតិច ឬច្រើនយ៉ាងណាឡើយ។

ប៉ុន្តែ បើដំណាំ សំណង់ និងការរៀបទាំងឡាយដែលតតិយជនធ្វើនោះ ត្រូវតុលាការបានដកហូតហើយ តែមិនដាក់ទណ្ឌកម្មឱ្យតតិយជនសងផលមកម្ចាស់ដីវិញទេព្រោះតតិយជនធ្វើដោយចេតនាសុចរិតនោះ កម្មសិទ្ធិករមិនអាចនឹងឱ្យគាស់ដំណាំ ឬរើសំណង់នោះចេញបានប៉ុន្តែ កម្មសិទ្ធិករអាចនឹងជ្រើសរើសដោយចេញថ្លៃសម្ភារៈ និងថ្លៃពលកម្មបាន ឬដោយសងប្រាក់ស្មើនឹងតម្លៃដែលដីនោះត្រូវកើនតម្លៃទៀតក៏បាន។

**មាត្រា២៩**

ដីដែលដុះនៅទីមាត់ទន្លេ មាត់ស្ទឹងបន្តិចម្តងៗមើលដឹងហៅថាល្បប់។ ល្បប់ត្រូវបានជាប្រយោជន៍នៃកម្មសិទ្ធិករដែលមានដីនៅមាត់ទឹកដែលនាវា ឬក្បូនចេញចូលបានបណ្តែតបាន ឬមិនបាន តែបើចេញចូលបានបណ្តែតបាន កម្មសិទ្ធិករត្រូវទុកផ្លូវមាត់ទឹក ឬផ្លូវសម្រាប់ទាញពួរនាវា ឱ្យស្របតាមបទបញ្ជាទាំងឡាយ។

**មាត្រា៣០**

ល្បប់ដែលដុះដោយទឹកហូរដាច់ដីពីច្រាំងម្ខាងបន្តិចម្តងៗ មើលមិនដឹងទៅដុះឯច្រាំងម្ខាង ត្រូវបានទៅកម្មសិទ្ធិករនៃច្រាំងដែលដុះ។ ឯកម្មសិទ្ធិករនៃច្រាំងដែលខាតដីដែលទឹកនាំទៅនោះនឹងមកទាមទារយកដីនោះមិនបានទេ។

បទប្បញ្ញត្តិនេះមិនតម្រូវឱ្យអនុវត្តលើល្បប់ក្នុងសមុទ្រ ដែលប្រែប្រួលដោយទឹកសមុទ្រនោះឡើយ។

**មាត្រា៣១**

ប្រសិនបើទន្លេ ឬស្ទឹង ព្រែក ដែលនាវាចេញចូលបានក្តី មិនបានក្តី មានជំនន់ភ្លាមៗនាំឱ្យបាក់ដីមាត់ទឹកមួយកន្លែងធំចំណាំបាន ហើយនាំទៅភ្ជាប់នឹងដីខាងក្រោមខ្សែទឹក ឬនឹងត្រើយម្ខាង កម្មសិទ្ធិករដែលបានបាត់ដីនោះនឹងទារយកដីខ្លួនវិញបាន តែត្រូវឱ្យប្តឹងទារក្នុងឆ្នាំនោះ បើរំលងមួយឆ្នាំទៅ បណ្តឹងទាមទារនោះមិនត្រូវទទួលឡើយ លើកលែងតែកម្មសិទ្ធិករនៃដីដែលមានល្បប់ដុះនោះមិនទាន់បានកាន់កាប់នៅឡើយ។

**មាត្រា៣២**

កោះធំ កោះតូច ទាំងឡាយដីដែលដុះក្នុងផ្ទៃទន្លេ ឬស្ទឹងព្រែកដែលជាទីអាចដើរអាចបណ្តែតនាវា ក្បូនបានត្រូវបានមករដ្ឋតាមបទបញ្ជាដែលមានជាធរមាន។

**មាត្រា៣៣**

កោះធំ កោះតូចទាំងឡាយ និងដីដែលដុះក្នុងស្ទឹង ព្រែកមិនជាទីដើរ បណ្តែតនូវក្បូនទេ ត្រូវបានទៅកម្មសិទ្ធិករដែលមានដីនៅនឹងមាត់ស្ទឹង មាត់ព្រែក ខាងកោះដុះនោះ បើកោះមិនដុះជ្រុលទៅម្ខាងទេនោះ ត្រូវបានទៅកម្មសិទ្ធិករដែលមានដីនៅត្រើយទាំងពីរខាង យកតាមបន្ទាត់ដែលគេសន្មតថាពុះពាក់កណ្តាលស្ទឹងជាប្រមាណ។

**មាត្រា៣៤**

ប្រសិនបើស្ទឹង ឬទន្លេណាមួយបែកដៃថ្មីកាត់ និងឱបដីជារបស់កម្មសិទ្ធិករណាម្នាក់ដែលនៅមាត់ទឹកឱ្យទៅជាកោះ កម្មសិទ្ធិករនោះ នៅតែមានកម្មសិទ្ធិលើដីដែលដាច់នោះដដែលទោះបីកោះដែលដុះថ្មីនោះ នៅក្នុងទន្លេ ស្ទឹងជាទីដែលនាវាដើរបាន ក្បូនបណ្តែតបានក្តី។

**មាត្រា៣៥**

ប្រសិនបើទន្លេ ស្ទឹង ឬព្រែកណាមួយជាទីដែលនាវាដើរបាន ក្បួនបណ្តែតបាន ហើយបែកមានផ្លូវថ្មីចោលផ្លូវចាស់ទៅកម្មសិទ្ធិករនៅមាត់ទឹកទាំងឡាយនោះ អាចនឹងយកផ្លូវចាស់ដែលគោកនោះបាន ម្នាក់ៗត្រូវបានតាមសិទ្ធិរបស់ខ្លួនរហូតដល់បន្ទាត់ដែលប្រមាណថាពុះពាក់កណ្តាលស្ទឹងនោះ។ ថ្លៃដីនៃផ្លូវចាស់ នោះត្រូវតុលាការខេត្ត-ក្រុងទីនោះ តាំងអាជ្ញាកណ្តាលឱ្យទៅពិនិត្យកាត់ថ្លៃតាមសេចក្តីសុំពីរដ្ឋអំណាចខេត្ត ឬពីភាគីនានាដែលមានប្រយោជន៍នឹងទីនោះ។

បើកម្មសិទ្ធិករនៅមាត់ទឹកនោះ មិនចង់បានដីនោះតាមថ្លៃដែលអាជ្ញាកណ្តាលកាត់ទេ រដ្ឋអំណាចត្រូវឡាយឡុងផ្លូវចាស់នោះឱ្យសាធារណជន។ ថ្លៃដែលបានមកអំពីលក់ដីនោះត្រូវយកទៅចែកឱ្យកម្មសិទ្ធិករដែលមានដីដាច់ទៅនោះ តាមសមាមាត្រនៃដីដែលខូចខាតរៀងខ្លួនម្នាក់ៗ។

## ជំពូកទី៣ អំពីកម្មសិទ្ធិរួមគ្នា ឬសហកម្មសិទ្ធិ

### មាត្រា៣៦

សហកម្មសិទ្ធិករទាំងឡាយ អាចនឹងប្រើប្រាស់ជាមួយគ្នានូវសិទ្ធិជាកម្មសិទ្ធិករលើទ្រព្យណាមួយបាន គឺម្នាក់ៗបានមួយចំណែកគិតតាមចំនួន តែមិនគិតតាមសម្ភារៈទេ យ៉ាងនេះអ្នកទាំងនោះ ឈ្មោះថាមានភាពនៃអវិភាគកម្ម "គឺភាពចែកគ្នាមិនដាច់"។

### មាត្រា៣៧

ចំណែកនីមួយៗត្រូវសន្មតថាស្មើគ្នា។ សហកម្មសិទ្ធិករម្នាក់ៗមានសិទ្ធិ និងបន្ទុកជាកម្មសិទ្ធិករ ដោយសារចំណែកខ្លួន ដែលអាចនឹងលក់ដូរ ឬបញ្ចាំបាន ហើយម្ចាស់បំណុល ក៏អាចប្តឹងឱ្យរឹបអូសចំណែកនោះបាន ដើម្បីសងបំណុលខ្លួន។

### មាត្រា៣៨

សហកម្មសិទ្ធិករគ្រប់គ្រងនូវរបស់នោះជាមួយគ្នា លើកលែងតែកាលណាមានសេចក្តីព្រមព្រៀងគ្នាផ្សេងពីនេះទៅវិញ។ ប្រសិនបើមតិភាគច្រើន មិនបានសម្រេចផ្សេងពីនេះទេ សហកម្មសិទ្ធិករម្នាក់ៗ ក្នុងបណ្តាសហកម្មសិទ្ធិករទាំងឡាយនោះត្រូវមាននាទី និងធ្វើនូវកិច្ចការគ្រប់គ្រងធម្មតា ដូចជាជួសជុល ថែទាំ និងដាំដំណាំជាដើម។ ការទាំងឡាយណាដែលសំខាន់ជាងនេះទៅទៀតដូចជាផ្លាស់ដំណាំ និងជួសជុលធំជាដើម សហកម្មសិទ្ធិករអាចនឹងសម្រេចបាន លុះណាតែភាគច្រើននៃសហកម្មសិទ្ធិករ តំណាងនៃចំណែករៀងៗខ្លួន បូករួមមកបានជាងពាក់កណ្តាលភាគនៃរបស់ទាំងនោះព្រមព្រៀងផង។

**មាត្រា៣៩**

សហកម្មសិទ្ធិករម្នាក់ៗអាចរំពៃមើលថែទាំប្រយោជន៍រួមបាន។ ម្នាក់ៗត្រូវអាស្រ័យ និងប្រើប្រាស់នូវរបស់នោះត្រឹមព្រំដែន ដែលស្របនឹងសិទ្ធិនៃអ្នកឯទៀត។

ទោះនឹងលក់ដូរ និងបង្កបង្កើតនូវសិទ្ធិប្រត្យក្ស ឬផ្លាស់ប្តូរមុខការដែលត្រូវប្រើប្រាស់របស់នោះយ៉ាងណាៗ សហកម្មសិទ្ធិករទាំងអស់ត្រូវព្រមព្រៀងធ្វើទាំងអស់គ្នាទើបបាន លើកលែងតែករណីដែលអ្នកទាំងអស់បានព្រមព្រៀងគ្នាជាឯកច្ឆ័ន្ទ តាំងវិធានផ្សេងពីរឿងនេះទៅវិញ។

**មាត្រា៤០**

សោហ៊ុយបង់ខាតក្នុងការគ្រប់គ្រងពន្ធដារ និងបន្ទុកឯទៀតដែលកើតអំពីសហកម្មសិទ្ធិករ ឬដែលដាក់បន្ទុកលើរបស់នោះ ត្រូវសហកម្មសិទ្ធិករចេញតាមសមាមាត្រនៃចំណែករៀងៗខ្លួន វៀរតែមានសេចក្តីសម្រេចផ្សេងៗដែលផ្ទុយនឹងបញ្ញត្តិនេះ។

បើនរណាមួយបានបង់លើសហួសពីចំណែកខ្លួន អ្នកនោះត្រូវទារពីអ្នកឯទៀត តាមសមាមាត្រដូចគ្នា។

**មាត្រា៤១**

កម្មសិទ្ធិករម្នាក់ៗមានសិទ្ធិនឹងបង្ខំឱ្យបែងចែកបាន បើគ្មានកិច្ចសន្យាថាត្រូវតែនៅក្នុងអវិភាគកម្មទេ ឬបើវត្ថុនោះមិនបម្រុងទុកដើម្បីគោលបំណងណាមួយជានិរន្តរ៍ទេ។

**មាត្រា៤២**

ជនណាក៏ដោយមិនអាចនឹងបង្ខំឱ្យនរណានៅមួយក្នុង "អវិភាគកម្ម" បានទេ ហើយសហកម្មសិទ្ធិករម្នាក់ៗ អាចនាំអាទិ៍ឱ្យបែងចែកគ្នាបានជាដរាប។

សហកម្មសិទ្ធិករអាចនឹងទប់ចំណែកទាំងអស់ឱ្យនៅក្នុងអវិភាគកម្ម ក្នុងមួយកាលបានតែមិនឱ្យហួសពី៥ឆ្នាំ ល្ពឹកណាតែធ្វើកិច្ចសន្យាជាថ្មីទៀតទើបបាន។

**មាត្រា៤៣**

សហកម្មសិទ្ធិករត្រូវអស់មានទៀតហើយ កាលបើវត្ថុនោះត្រូវបែកគ្នាតាមរូបដើម លក់តាមស្ម័គ្រចិត្តទាំងអស់គ្នា ឬលក់ឡាយឡុង ហើយចែកថ្លៃគ្នា ឬមួយក៏អ្នកណាម្នាក់ ឬច្រើននាក់ទទួលយកនូវចំណែកអ្នកឯទៀតលើខ្លួននោះ។

បើសហកម្មសិទ្ធិករមិនព្រមព្រៀងគ្នាអំពីរបៀបចែកនោះទេ អ្នកទាំងនោះត្រូវប្ដឹងឱ្យតុលាការបង្គាប់ឱ្យចែកវត្ថុគ្នាតាមរូបដើមរបស់វា បើវត្ថុនោះមិនអាចចែកគ្នាបានទេ ព្រោះវានាំឱ្យខូចតម្លៃច្រើនត្រូវតែឱ្យតុលាការបង្គាប់ឱ្យឡាយឡុងក៏បាន លក់ឱ្យសហកម្មសិទ្ធិករផងគ្នាក៏បាន។

**មាត្រា៤៤**

ជាពិសេស ភាពអវិភាគកម្មដែលត្រូវនៅអស់កាលជានិច្ច និងមិនអស់ទៅដោយសារការបែងចែកនោះ គឺវត្ថុដូចខាងក្រោម៖

១-ដី និងសំណង់ទាំងឡាយ ដែលឧទ្ទិសចំពោះសព

២-ភាគដី ដែលជាដីបម្រើទ្រព្យទាំងឡាយ ដូចជាផ្លូវថ្នល់ ផ្លូវទឹកជាដើម ។ល។

**ជំពូកទី៤ អំពីអឲ្យសិទ្ធិភាព "របស់កណ្ដាល"**

**មាត្រា៤៥**

សព្ទថា "អវិភាគកម្ម" នេះ បើនិយាយអំពីកំពែង ឬជញ្ជាំងហៅថាអឲ្យសិទ្ធិភាព។

**ផ្នែកទី១ អំពីជញ្ជាំងអឲ្យសិទ្ធិ**

**មាត្រា៤៦**

ការជួសជុល និងការធ្វើជញ្ជាំងអឲ្យសិទ្ធិណាមួយឡើងវិញជាភារៈនៃអ្នកទាំងឡាយដែលមានសិទ្ធិលើរបស់នោះ តាមសមាមាត្រនៃសិទ្ធិរបស់ខ្លួនម្នាក់ៗ។

សហកម្មសិទ្ធិការទាំងពួង ការបោះបង់អឲ្យសិទ្ធិរបស់ខ្លួន ហើយអាចលែងជួយជួសជុល ឬធ្វើឡើងវិញនូវជញ្ជាំងនោះបាន ឱ្យតែជញ្ជាំងអឲ្យសិទ្ធិនោះលែងទ្រទ្រង់នូវផ្ទះរបស់ខ្លួនហើយ។

**មាត្រា៤៧**

សហកម្មសិទ្ធិករម្នាក់ៗ មិនអាចចោះជញ្ជាំងអឲ្យសិទ្ធិ ឬធ្វើអ្វីផ្ទប់ផ្អែកនឹងជញ្ជាំងនោះដោយម្ចាស់ម្ខាងមិនព្រមបានទេ ឬថាបើម្ចាស់ម្ខាងរឹងតែមិនព្រម ហើយខ្លួនក៏មិនបានប្ដឹងសុំឱ្យអ្នកជំនាញដែលជាអាជ្ញាកណ្ដាលទៅពិនិត្យសម្រេចចាត់ការជាចាំបាច់សិន ដើម្បីកុំឱ្យការរបស់ខ្លួនបង្ខូចសិទ្ធិរបស់គេនោះក៏មិនបានដែរ។

**មាត្រា៤៨**

កម្មសិទ្ធិករទាំងពួងដែលតជញ្ជាំងណាមួយ អាចធ្វើជញ្ជាំងនោះឱ្យជាអឲ្យសិទ្ធិទាំងអស់ ឬខ្លះ ដោយចេញឱ្យទៅកម្មសិទ្ធិករនៃជញ្ជាំងនោះនូវថ្លៃពាក់កណ្ដាល ឬថ្លៃភាគជញ្ជាំងដែលខ្លួនចង់ឱ្យទៅជារបស់អឲ្យសិទ្ធិ និងថ្លៃដីដែលសង់ជញ្ជាំងនោះផង។

*វាយឡើងវិញ*

មាត្រា៤៩

សហកម្មសិទ្ធិករអាចសង់ភ្ជាប់នឹងជញ្ជាំងអឡ្ឌសិទ្ធិបានហើយដាក់ធ្នឹម រត រនូត ឱ្យជិតពេញកម្រាស់ជញ្ជាំង ដោយទុកឱ្យសល់តែ៥សង់ទីម៉ែត្របាន តែការនេះមិនត្រូវធ្វើឱ្យខូចដល់សិទ្ធិនៃអ្នកម្ខាងឡើយ ប្រសិនបើអ្នកម្ខាងនោះអាចសង់ពីម្ខាង ត្រង់កន្លែងជាមួយគ្នានោះវិញដែរ អ្នកម្ខាងនោះនឹងបង្គាប់ឱ្យដាក់ធ្នឹម រត រនូត នោះបន្ថយមកត្រឹមពាក់កណ្តាលជញ្ជាំងនោះវិញក៏បាន ។

មាត្រា៥០

សហកម្មសិទ្ធិករណាមួយអាចនឹងលើកជញ្ជាំងអឡ្ឌសិទ្ធិឱ្យខ្ពស់ឡើងទៀតបាន តែអ្នកនោះត្រូវចេញថ្លៃការ្យ និងសោហ៊ុយ ថ្លៃធ្វើនិងថ្លៃថែទាំជញ្ជាំងដែលហួសកំណត់ដើមនោះតែម្នាក់ឯងមួយទៀតត្រូវចេញសំណូកចិត្តនៃបន្ទុកដោយហេតុមកពីមានសំណង់ខ្ពស់ហួសទៅលើនោះ និងឱ្យសមតាមតម្លៃផង ។

មាត្រា៥១

បើជញ្ជាំងអឡ្ឌសិទ្ធិមិនមាំ មិនអាចទ្រទ្រង់ទម្ងន់នៃកម្ពស់ទៅលើនោះបានទេ អ្នកដែលចង់ធ្វើឱ្យខ្ពស់ឡើងទៅលើទៀតនោះ ត្រូវរុះរើធ្វើជាថ្មីទាំងអស់ឡើងវិញ ។ ការខាតបង់ទាំងប៉ុន្មានត្រូវនៅលើខ្លួន ។ ឯកម្រាស់ជញ្ជាំងដែលត្រូវធ្វើលើសពីកម្រាស់ដើម ត្រូវសង់ដាក់លើខាងដីខ្លួន ។

មាត្រា៥២

អ្នកម្ខាងដែលមិនបានជួយសង់ឱ្យខ្ពស់ឡើងទេនោះ បើត្រូវការនឹងយកសំណង់នោះទុកជារបស់អឡ្ឌសិទ្ធិនៃខ្លួនដែរ ត្រូវចេញថ្លៃសំណង់ពាក់កណ្តាល និងថ្លៃដីដែលចូលទៅក្នុងកម្រាស់ជញ្ជាំងលើសពីកម្រាស់ដើមនោះ ឱ្យគេទៀតទើបបាន ។

## ផ្នែកទី២ អំពីស្នាមភ្លោះ របង ភ្លឺអឡ្ឌសិទ្ធិ

មាត្រា៥៣

កំពែងអឡ្ឌសិទ្ធិ ទោះជាស្នាមភ្លោះក្តី ទោះជារបងក្តី ទោះជាភ្លឺក្តី ត្រូវម្ចាស់កំពែងរួមនោះចេញសោហ៊ុយថែទាំរួមគ្នា តែបើសហកម្មសិទ្ធិករណាម្នាក់មិនចង់ចេញសោហ៊ុយថែទាំនោះទេ សហកម្មសិទ្ធិករនោះអាចមិនចេញបាន ដោយលះបង់អឡ្ឌសិទ្ធិរបស់ខ្លួនចោលតែប៉ុណ្ណោះ ។

ប៉ុន្តែស្នាមភ្លោះនោះ ឬភ្លឺនោះជាដីសម្រាប់បង្ហូរទឹកធម្មតាទៅហើយ សហកម្មសិទ្ធិករនឹងលះបង់អឡ្ឌសិទ្ធិរបស់ខ្លួនមិនបានឡើយ ។

*វាយឡើងវិញ*

**មាត្រា៥៤**

កម្មសិទ្ធិករដែលមានដីជាប់នឹងស្នាមភ្លោះ របង ឬភ្លឺណាមួយ ដែលមិនជារបស់អឌ្ឍសិទ្ធិទេ នឹងបង្ខំម្ចាស់ស្នាមភ្លោះ ម្ចាស់របង ម្ចាស់ភ្លឺនោះ ឱ្យព្រមដាក់នូវស្នាមភ្លោះ របង ឬភ្លឺនោះ ជារបស់អឌ្ឍសិទ្ធិឱ្យខ្លួនពុំបានឡើយ ។

**មាត្រា៥៥**

សហកម្មសិទ្ធិករម្នាក់ក្នុងបណ្តាសហកម្មសិទ្ធិករទាំងឡាយ អាចនឹងរុះរើរបងត្រឹមព្រំដីខ្លួនចេញបាន តែត្រូវធ្វើជញ្ជាំងត្រង់ព្រំដីខ្លួននោះឡើងវិញ ។

បើស្នាមភ្លោះ ឬភ្លឺអឌ្ឍសិទ្ធិនោះគ្រាន់តែដាក់កំពែងទេ សហកម្មសិទ្ធិករនោះអាចធ្វើដូចគ្នាខាងលើនេះបានដែរ ។

## ជំពូកទី៥ អំពីទ្រព្យវត្ត

**មាត្រា៥៦**

ទ្រព្យវត្តជាទ្រព្យរបស់ពុទ្ធមាមកៈ ចំណុះជើងវត្តទាំងអស់គ្នា។ ទ្រព្យនេះនឹងលក់ដូរចាយវាយយ៉ាងណាពុំបានឡើយ ហើយមិនអាចកំណត់អាយុកាលផង ។

**មាត្រា៥៧**

ទ្រព្យវត្តនឹងជួល ឬប្រវាស់បាន តែផលទុនដែលបានមកពីជួល ឬប្រវាស់នេះត្រូវទុកសម្រាប់តែកិច្ចការក្នុងសាសនាប៉ុណ្ណោះ ។

**មាត្រា៥៨**

ការគ្រប់គ្រងនូវទ្រព្យវត្តជាភារៈរបស់សហគមន៍ពុទ្ធមាមកៈទាំងអស់គ្នា។ អ្នកទាំងនោះអាចចាត់អាចារ្យ ឬតំណាងម្នាក់ឱ្យមានសិទ្ធិក្តីក្តាំដល់តុលាការបាន នៅវេលាណាដែលមានរឿងក្តីពីទ្រព្យនោះ ។

## ជំពូកទី៦ អំពីលទ្ធកម្មនូវកម្មសិទ្ធិ និងអំពីការផ្ទេរនូវកម្មសិទ្ធិអចលនវត្ថុ

**មាត្រា៥៩**

ជនម្នាក់ៗអាចបានកម្មសិទ្ធិ ហើយអាចផ្ទេរកម្មសិទ្ធិឱ្យជនម្នាក់ទៀត តាមសន្តតិកម្ម និងតាមកិច្ចសន្យាបាន។ ម្យ៉ាងទៀតគេអាចធ្វើភោគៈឱ្យទៅជាកម្មសិទ្ធិបានតាមការប្តូររូបភាពប្រើប្រាស់ដី ហើយដែលបានចុះក្នុងសៀវភៅចុះកម្មសិទ្ធិអចលនវត្ថុរួចហើយ ។

*វាយឡើងវិញ*

មាត្រា៦០

ក្នុងរឿងអចលនវត្ថុ លិខិតដែលផ្ទេរកម្មសិទ្ធិ ឬភោគៈ និងសិទ្ធិប្រត្យក្សនឹងទុកជាត្រឹមត្រូវចំពោះតតិយជនបាន លុះណាតែលិខិតនោះមានរូបមន្តយថាភូត និងមានចុះបញ្ជីអចលនវត្ថុទៀតផង។

**មាតិកាទី២ អំពីភោគៈ**

មាត្រា៦១

ដែលហៅថាភោគៈ នោះគឺជាសភាពការណ៍មួយដែលមានន័យថា កិរិយាកាន់កាប់នូវវត្ថុអ្វីមួយយ៉ាងផ្ដាច់មុខតែឯង និងបំពេញចំពោះវត្ថុនោះនូវកិច្ចការទាំងឡាយដូចដែលកម្មសិទ្ធិករបានបំពេញហើយដែរ។

មាត្រា៦២

នាកាលភោគីបានកាន់កាប់នូវភោគៈនោះ ដោយឥតប្រើវិហិង្សាទេ ព្យាយាមកាន់កាប់ដោយសុចរិត ឱ្យដឹងឮដល់សាធារណជន ឥតអាក់ខាន និងឥតព្រលាំទេ ភោគៈនោះនឹងញ៉ាំងភោគីឱ្យមានអានុភាពចំពោះច្បាប់បាន។

មាត្រា៦៣

ភោគៈដែលគេបានមកដោយវិហិង្សា មិនទុកជាភោគៈត្រឹមត្រូវតាមច្បាប់ឡើយ។ ក៏ប៉ុន្តែ បើកាលណាគេប្រើវិហិង្សា ក្នុងពេលមានតតិយជនឥតសិទ្ធិសោះមកដណ្ដើមនោះ វិហិង្សានេះគ្មានឥទ្ធិពលអ្វីទៅលើភោគៈ ដែលគេបានដោយសន្តិភាពតាំងពីដើមមកនោះទេ។

មាត្រា៦៤

ភោគីត្រូវកាន់កាប់ដោយសុចរិត គឺថាភោគីមិនដឹងថាតតិយជនណាមានសិទ្ធិលើវត្ថុដែលខ្លួនកំពុងកាន់កាប់នោះសោះ។

មាត្រា៦៥

ភោគីត្រូវកាន់កាប់វត្ថុនោះជាសាធារណៈគឺថាភោគីនោះកាន់កាប់ឥតលាក់បិទបាំងទេ អ្នកទាំងពួងដែលត្រូវចង់តវ៉ាអំពីសិទ្ធិរបស់ខ្លួនលើវត្ថុនោះនឹងបានដឹង ឮ ឃើញមិនខាន។

មាត្រា៦៦

ចំពោះរឿងអចលនវត្ថុ សេចក្ដីដែលទុកជាប្រកាសឱ្យអ្នកផងទាំងពួងដឹងឮនោះគឺ៖

-ភោគីបានប្ដឹងសុំកាន់កាប់ដល់ប្រធានឃុំ-សង្កាត់ ជាចៅនាទីនៃអចលនវត្ថុនោះ

-ភោគីបានបង់ពន្ធដីជាទៀងទាត់។

**មាត្រា៦៧**

បណ្ដឹងនោះត្រូវប្រាប់នូវទំហំដី ប្រភេទដី និងព្រំប្រទល់ដី។ ប្រធានឃុំ-សង្កាត់ ត្រូវចម្លងសេចក្ដីនោះទាំងអស់ចុះក្នុងសៀវភៅសម្រាប់កត់លិខិតបញ្ជាក់ ហើយចុះហត្ថលេខាផង បើដីនោះមានគេចុះក្នុងបញ្ជីអចលនវត្ថុរួចហើយ ភោគីមិនអាចប្ដឹងដូចនោះបានឡើយ។

**មាត្រា៦៨**

ភោគីត្រូវកាន់កាប់ថែរក្សាភោគៈជានិរន្តរ៍ គឺថាត្រូវធ្វើនូវកិច្ចការទាំងពួងតាមធម្មតាជាប្រក្រតី កុំបីបោះបង់ចោលឱ្យមានចន្លោះ កាលដែលមិនគួរចោលឡើយ ហើយដែលផ្ទុយនឹងដំណើរការនៃវត្ថុនោះទៅវិញផង។

**មាត្រា៦៩**

ការទុកអចលនវត្ថុឱ្យនៅទំនេរខ្លះនឹងទុកជាបានកាន់កាប់ ឬមិនជាប់នោះ ស្រេចលើយោបល់តុលាការ។ តុលាការត្រូវសង្កេតតាមប្រភេទនៃវត្ថុ បើឃើញយ៉ាងណា ត្រូវអធិប្បាយហេតុយ៉ាងនោះក្នុងសាលក្រម។

**មាត្រា៧០**

ការដែលទុកដីរេចរិលឱ្យមានជីជាតិនោះ នឹងទុកជាបោះបង់ចោលពុំទាន់បាន។ កិរិយាកាន់កាប់នូវភោគៈ តាមកាលសម័យដ៏គប្បីដូច្នេះ ក៏ឈ្មោះថាបានកាន់កាប់ជានិច្ចហើយ។

**មាត្រា៧១**

ភោគីត្រូវកុំកាន់កាប់ភោគៈដោយព្រលាំ គឺថាភោគីទោះកាន់កាប់ដោយខ្លួនឯងក្ដី ទោះឱ្យអ្នកដទៃធ្វើឱ្យក្ដី ត្រូវកាន់កាប់ឱ្យឃើញថា ការនោះប្រាកដជាធ្វើដើម្បីខ្លួន ក្នុងគោលដៅខ្លួនជាភោគីយ៉ាងផ្ដាច់មុខកុំឱ្យឃើញថា ការដែលធ្វើនោះគឺធ្វើដោយសារសិទ្ធិណាមួយផ្សេងទៀតវិញ។

**មាត្រា៧២**

ភោគៈក្នុងដៃអ្នកណា អ្នកនោះត្រូវសន្មតថាជាភោគីដោយធម្មានុរូប ឈ្មោះណាប្រកាន់ជាសិទ្ធិនៃភោគីនោះដោយប្រការយ៉ាងណា១ ឈ្មោះនោះត្រូវរកស្មេរនៃសិទ្ធិរបស់ខ្លួនមកជាបន្ទាល់។

**មាត្រា៧៣**

ភោគីអាចនឹងផ្ទេរនូវសិទ្ធិរបស់ខ្លួនខ្លះ ឬទាំងអស់ឱ្យទៅអ្នកដទៃតាមសន្តតិកម្មមានបណ្តាំបាន ឬតាមកិច្ចសន្យាក៏បាន។ លិខិតផ្ទេរនូវភោគៈនោះ ត្រូវធ្វើតាមរូបមន្តយថាភូត។

**មាត្រា៧៤**

ក្នុងរឿងអចលនវត្ថុ បើភោគីណាមានដីមួយកន្លែងដោយសន្តិភាព ដោយសុចរិត មានផ្សាយជាសាធារណៈ ឥតព្រលាំក្នុងកំលុង៥ឆ្នាំជាប់ៗគ្នា ហើយដីនោះជាដីទំនេរគ្មានក្នុងបញ្ជិកាអ៊ីម៉ាទ្រីគុឡាស្យុងថាជារបស់អ្នកឯណាទេ ភោគីនោះត្រូវឡើងជាកម្មសិទ្ធិករនៃដីនោះដោយធម្មានុរូប។

**មាត្រា៧៥**

សិទ្ធិនៃភោគៈអចលនវត្ថុ នឹងឡើងទៅជាសិទ្ធិកម្មសិទ្ធិក្រោយពេលដែលអចលនវត្ថុនោះបានចុះបញ្ជិកាកម្មសិទ្ធិរួចហើយ។

**មាត្រា៧៦**

ដីទាំងឡាយដែលភោគីបានបោះបង់ចោលក្នុងរវាង៣ឆ្នាំជាប់ៗគ្នា ត្រូវធ្លាក់ទៅជាសម្បត្តិឯកជននៃរដ្ឋ។

## មាតិកាទី៣ អំពីអវយវភេទនៃកម្មសិទ្ធិ

**មាត្រា៧៧**

វត្ថុណាជាកម្មសិទ្ធិនៃជនម្នាក់ ហើយបានទៅជនម្នាក់ទៀតអាស្រ័យផលវត្ថុនោះ ឈ្មោះថាមានអវយវភេទ។

សិទ្ធិដែលនៅសល់អវយវភេទនោះ ហើយដែលបានមកកម្មសិទ្ធិករហៅថាអសារកម្មសិទ្ធិ។

### ជំពូកទី១ អំពីផលុបភោគ

**មាត្រា៧៨**

ផលុបភោគ គឺការអាស្រ័យនូវផលនៃអចលនវត្ថុណាមួយដែលជាកម្មសិទ្ធិនៃអ្នកដទៃមានកំណត់កាលដែលមិនអាចលើសពីអាយុនៃអ្នកបានសិទ្ធិអាស្រ័យផលនោះឡើយ។

**មាត្រា៧៩**

ផលុភោគកើតមកអំពីច្បាប់ក៏មាន កើតមកអំពីការព្រមព្រៀងក៏មាន។ ផលុបភោគនេះ អាចកើតឡើងឥតកំណត់កាលក៏បាន ឬមានកំណត់ថារហូតដល់ថ្ងៃណាដែលបានសម្រេចនូវល័ក្ខខ័ណ្ឌណាមួយក៏បាន។

កិច្ចសន្យាអំពីផលុបភោគនឹងយកជាទីអាងបាន លុះត្បិតតែរវាងភាគីផងគ្នាក៏ដោយ ក៏ត្រូវធ្វើជាលិខិតតាមរូបមន្តយថាភូតដែរ។ លិខិតនេះនឹងយកជាទីអាងចំពោះតតិយជនបាន តែក្រោយពេលដែលលិខិតនេះ បានចុះក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ ឬសៀវភៅចុះភោគៈអចលនវត្ថុរួចហើយ។ នេះចំពោះតែកិច្ចសន្យាដែលទាក់ទងនឹងអចលនវត្ថុជាកម្មសិទ្ធិ។

## ផ្នែកទី១ អំពីសិទ្ធិផលុបភោគី

### មាត្រា៨០

ផលុបភោគីមានសិទ្ធិអាស្រ័យនូវផលានុផលទាំងពួង ទោះជាផលធម្មជាតិក្តី ទោះជាផលស៊ីវិលក្តី ដែលកើតអំពីអចលនវត្ថុដែលខ្លួនបានផលុបភោគនោះ។

### មាត្រា៨១

ផលានុផលធម្មជាតិណាកើតនៅលើដីក្នុងវេលាដែលបើកឱ្យស៊ីផល ផលានុផលនោះត្រូវបានទៅផលុបភោគី។ ផលានុផលធម្មជាតិណាកើតឡើងក្នុងវេលាដែលត្រូវអស់សិទ្ធិស៊ីផល ផលានុផលនោះត្រូវបានទៅអសារកម្មសិទ្ធិករនៃដី។ ឯការភ្ជួររាស់សាបព្រោះស្ទូងដាំនោះ បើបានជាធ្វើហើយ មិនត្រូវឱ្យគិតយកថ្លៃអំពីគ្នាទេ។ ប៉ុន្តែបើមានអ្នកណាជួល ឬប្រវាស់ធ្វើ ក៏មិនបានត្រូវឱ្យអ្នកនេះ ខូចប្រយោជន៍ដែលត្រូវបានក្នុងវេលាដាក់ឱ្យស៊ីផលក្តី ក្នុងវេលាអស់សិទ្ធិស៊ីផលក្តី។

### មាត្រា៨២

ឯផលស៊ីវិលត្រូវបានទៅផលុបភោគី តាមសមាមាត្រនៃរយៈវេលាផលុបភោគី។

### មាត្រា៨៣

ផលុបភោគីនឹងអាស្រ័យនូវផលនៃអចលនវត្ថុនោះដោយខ្លួនឯង ឬនឹងជួលឱ្យទៅអ្នកដទៃ ឬផ្ទេរនូវសិទ្ធិនោះឱ្យទៅអ្នកដទៃដោយយកថ្លៃ ឬឥតយកថ្លៃបាន។

បើជួល ឬប្រវាស់កិច្ចសន្យាមិនត្រូវកំណត់ឱ្យហួសពីពាន្ឆ្នាំ។ បើចង់ជួល ឬប្រវាស់បន្តកិច្ចសន្យាថ្មីនេះ ត្រូវធ្វើមុនមួយឆ្នាំនៃថ្ងៃអស់សិទ្ធិ។

### មាត្រា៨៤

ផលុបភោគីត្រូវបានអាស្រ័យផលដីដែលចម្រើនដោយល្បប់ មកលើដីដែលខ្លួនបានផលុបភោគនោះដែរ។

**មាត្រា៨៥**

ផលុបភោគីប្រើប្រាស់នូវសេវភាពទាំងឡាយ និងជាទូទៅនូវសិទ្ធិទាំងឡាយដែលកម្មសិទ្ធិករអាចប្រើប្រាស់បាន ហើយផលុបភោគីប្រើប្រាស់នូវសិទ្ធិទាំងនោះ បានដូចកម្មសិទ្ធិករដែរ ។

**មាត្រា៨៦**

ផលុបភោគី ត្រូវបានសិលាជាតិក្នុងបរិវេណដីដែលខ្លួនត្រូវបានផលុបភោគនោះ ដូចជាកម្មសិទ្ធិករដែរ ។

**មាត្រា៨៧**

អសារកម្មសិទ្ធិករមិនអាចធ្វើអ្វីឱ្យខូចខាតសិទ្ធិនៃផលុបភោគីបានឡើយ ។ ខាងផលុបភោគីវិញ លុះដល់វេលាអស់សិទ្ធិស៊ីផលហើយ ក៏មិនអាចទាមទារសំណូកចិត្តអ្វី ព្រោះថាខ្លួនបានតុបតែងអចលនវត្ថុដែលជាក់ជាផលុបភោគរបស់ខ្លួននោះដែរ ទោះបីអចលនវត្ថុនោះបានកើនតម្លៃដោយសារស្នាដៃរបស់ខ្លួនក៏ដោយ ។

ក៏ប៉ុន្តែ បើសិនផលុបភោគីបានសង់គេហដ្ឋាននៅទីនោះ ខ្លួន ឬទាយាទខ្លួនអាចនឹងសុំឱ្យគេប្រតិបត្តិតាមបទប្បញ្ញត្តិនៃមាត្រា២៨បាន ។

បើបានតាក់តែងផ្ទះសំបែងដែលមាននៅទីនោះដោយកញ្ចក់ឆ្លុះ កញ្ចក់រូប និងគ្រឿងតែងឯទៀតក្តី ផលុបភោគី ឬទាយាទរបស់ខ្លួន អាចនឹងរើយកវិញបាន តែត្រូវរៀបចំទីនោះឱ្យដូចប្រក្រតីដើមវិញ ។

## ផ្នែកទី២ អំពីកាតព្វកិច្ចនៃផលុបភោគី

**មាត្រា៨៨**

ផលុបភោគី ត្រូវទទួលនូវអចលនវត្ថុតាមសភាពដែលមានក្នុងពេលនោះ ក៏ប៉ុន្តែមុននឹងចាប់ផ្តើមប្រើប្រាស់ត្រូវមានការត្រួតពិនិត្យពីប្រធានឃុំ-សង្កាត់ នូវស្ថានភាពខាងសម្ភារៈនៃទីកន្លែងនោះសិន ចំពោះមុខអសារកម្មសិទ្ធិករ ។

**មាត្រា៨៩**

មួយទៀតមុននឹងចាប់ផ្តើមប្រើប្រាស់ ផលុបភោគីត្រូវតែរកអ្នកធានាអំពីកិច្ចការដែលខ្លួនប្រើប្រាស់នោះ គឺត្រូវប្រើប្រាស់ដូចខ្លួនជាមេគ្រួសារដ៏ប្រពៃ បានន័យថាផលុបភោគីត្រូវស៊ីផល

ឱ្យល្អបីដូចខ្លួនឯងនោះជាកម្មសិទ្ធិករ ហើយយកចិត្តទុកដាក់នឹងផលប្រយោជន៍នៃកម្មសិទ្ធិករផង។

ឪពុក និងម្តាយដែលជាផលុបភោគីនៃទ្រព្យរបស់កូនដែលជាអនីតិជននោះ មិនបាច់ឱ្យមានអ្នកធានាឡើយ សហព័ន្ធនៅរស់ដែលជាផលុបភោគីនៃទ្រព្យរបស់ខ្មោចប្តី ឬប្រពន្ធខ្លួន ក៏មិនបាច់ឱ្យមានអ្នកធានាដែរ។

**មាត្រា៩០**

បើផលុបភោគគ្មានអ្នកធានាទេ អចលនវត្ថុនោះត្រូវយកទៅដាក់ជាឈ្នួល ឬត្រូវដាក់ក្នុងវិសុណ្ឋាប័នឈ្នួលដី និងឈ្នួលផ្ទះ ឬផលដែលវិសុណ្ឋាបនិកបានទទួលមកនោះត្រូវកាត់សោហ៊ុយគ្រប់យ៉ាងឱ្យជ្រះស្រឡះទៅ ហើយប្រគល់តែផលដែលសល់នោះទៅឱ្យផលុបភោគី។

**មាត្រា៩១**

ទោះបីឃើតយូរក្រេរកអ្នកធានាបានក្តី ផលុបភោគីមិនត្រូវខានបាននូវផលដែលខ្លួនមានសិទ្ធិត្រូវបាននោះឡើយ ផលទាំងឡាយនោះត្រូវបានទៅផលុបភោគី តាំងពីថ្ងៃដែលចាប់បើកផលុបភោគនោះមក។

**មាត្រា៩២**

ផលុបភោគី ត្រូវទទួលបន្ទុកជួសជុលតែលើការថែទាំប៉ុណ្ណោះ ឯការជួសជុលធំៗទាំងឡាយ ជាភារៈលើអសារកម្មសិទ្ធិករ។ ប៉ុន្តែបើការខូចខាតនេះបណ្តាលមកពីផលុបភោគីមិនបានជួសជុលថែទាំ តាំងពីថ្ងៃដែលបើកផលុបភោគនោះទេ នោះផលុបភោគីត្រូវទទួលជួសជុលលើខ្លួនឯងទាំងអស់។

**មាត្រា៩៣**

ការជួសជុលធំៗទាំងឡាយនោះ គឺជួសជុលជញ្ជាំងធំៗ និងគ្រឿងដំបូលលើផ្លាស់ថ្មីម ផ្លាស់រត និងប្រក់ទាំងមូល ការជួសជុលទំនប់ជញ្ជាំងទប់ និងរបងកំពែងទាំងមូល។ ការជួសជុលក្រៅពីនេះ ទុកជាការជួសជុលថែទាំ។

**មាត្រា៩៤**

ក្នុងសភាពខូចខាតព្រោះចាស់ទ្រុឌទ្រោម ឬត្រូវអន្តរាយដោយគ្រោះប្រធានសក្តិ អសារកម្មសិទ្ធិករក្តី ផលុបភោគីក្តី មិនត្រូវគេបង្ខំឱ្យសង់ឡើងវិញឡើយ។

ប៉ុន្តែបើអសារកម្មសិទ្ធិករ ឬផលុបភោគីបានយកអចលនវត្ថុនោះ ទៅចុះកិច្ចសន្យាធានារ៉ាប់រង ហើយអសារកម្មសិទ្ធិករ ឬផលុបភោគីអាចសុំយកថ្លៃធានារ៉ាប់រងដែលបានមកនោះទៅធ្វើ ឬជួសជុលឡើងវិញបាន។

**មាត្រា៩៥**

ក្នុងវេលាដែលខ្លួនកំពុងអាស្រ័យផល ផលុបភោគីត្រូវទទួលបន្ទុកប្រចាំឆ្នាំ ដែលជាប់លើអចលនវត្ថុទាំងអស់ដូចជាពន្ធដារ ពន្ធអាករទាំងឡាយ និងសោហ៊ុយធានារ៉ាប់រង ដែលទំនៀមធ្លាប់ដាក់លើផលនៃអចលនវត្ថុនោះ។

មួយទៀត ផលុបភោគីត្រូវទទួលធ្វើឱ្យបានសម្រេច និងទទួលស្គាល់ជាថ្មីឱ្យទាន់ពេលនូវកិច្ចសន្យាធានារ៉ាប់រងនៃអចលនវត្ថុដែលនៅក្នុងផលុបភោគរបស់ខ្លួន គឺកិច្ចសន្យាដែលមានហើយក្នុងវេលាដែលបើកផលុបភោគនោះក្តី កិច្ចសន្យាដែលអសារកម្មសិទ្ធិករនឹងតម្រូវឱ្យធ្វើនាពេលខាងក្រោយក្តី។

**មាត្រា៩៦**

ចំពោះបន្ទុកទាំងឡាយដែលអាចផ្ទុកលើកម្មសិទ្ធិ ក្នុងរយៈវេលានៃផលុបភោគី និងអសារកម្មសិទ្ធិករត្រូវជួយបង់គ្នាដូចខាងក្រោម៖

អសារកម្មសិទ្ធិករត្រូវទទួលបន្ទុកទាំងនោះ ហើយផលុបភោគីត្រូវគិតការប្រាក់ឱ្យអសារកម្មសិទ្ធិករវិញ។

ផលុបភោគីនឹងចេញប្រាក់បង់មុន ហើយដល់ពេលវេលាដែលខ្លួនលែងអាស្រ័យផលនោះ ទៅសឹមទារយកប្រាក់ដើមមកវិញក៏បាន។

**មាត្រា៩៧**

បើមានកើតក្តីអំពីដំណើរប្រើប្រាស់នូវអចលនវត្ថុទាំងឡាយ ដែលដាក់ជាផលុបភោគខ្លួននោះ ផលុបភោគីត្រូវទទួលចេញតែខ្ចាត់ក្តី និងក្រយាពិន័យទេ ប្រសិនបើមាន។

**មាត្រា៩៨**

ប្រសិនបើក្នុងរយៈវេលានៃផលុបភោគនោះ មានតតិយជនណាមកព្យាបាទសិទ្ធិនៃអសារកម្មសិទ្ធិករ ផលុបភោគីត្រូវមកប្រាប់អសារកម្មសិទ្ធិករ បើពុំបានប្រាប់ទេ ហើយការនោះនឹងបណ្តាល

ឱ្យមានព្យសនកម្មដល់អសារកម្មសិទ្ធិករ ផលុបភោគីត្រូវទទួលខុសត្រូវលើខ្លួន ដូចក្នុងករណីដែលខ្លួនធ្វើឱ្យខូចនូវវត្ថុគេ ហើយត្រូវទទួលសងគេវិញ។

## ផ្នែកទី៣ ផលុបភោគត្រូវចប់ត្រឹមណា

**មាត្រា៩៩**

ផលុបភោគត្រូវចប់៖

១-ត្រឹមផលុបភោគីស្លាប់

២-ត្រឹមដល់កំណត់កាល ឬត្រឹមល័ក្ខខ័ណ្ឌដែលបានកំណត់ទុក ជាពេលត្រូវចប់នោះបានសម្រេច

៣-ត្រឹមផលុបភោគី លែងស៊ីផលតទៅទៀត

៤-ត្រឹមអចលនវត្ថុដែលត្រូវដាក់ជាផលុបភោគនោះអន្តរាយអស់។

**មាត្រា១០០**

មួយទៀត កាលណាអសារកម្មសិទ្ធិករប្តឹងពីផលុបភោគីថា ប្រើប្រាស់អចលនវត្ថុនោះដោយរំលោភមានធ្វើឱ្យខូចអចលនវត្ថុ ឬបណ្តោយឱ្យអចលនវត្ថុខូច ពុំថែទាំជាដើម នោះតុលាការនឹងកាត់រំលោះសិទ្ធិលែងឱ្យអាស្រ័យផលតទៅទៀតបាន។

ក្នុងករណីនេះ ម្ចាស់បំណុលនៃផលុបភោគីមានសិទ្ធិនឹងធ្វើអន្តរាគមន៍ក្នុងការណ៍នេះបាន ម្ចាស់បំណុលអាចសុំជួសជុលការខូចខាតនោះហើយនិងសុំធានាទៅអនាគតបាន។

ដោយយោលទៅតាមគរុភាពនៃកាលៈទេសៈ ចៅក្រមអាចកាត់សេចក្តីឱ្យផ្តាច់ផលុបភោគជាដាច់ខាតក៏បាន ឬនិងបញ្ជាឱ្យប្រគល់នូវអចលនវត្ថុទៅអសារកម្មសិទ្ធិករវិញ តែឱ្យម្ចាស់របស់នេះចេញប្រាក់ប៉ុន្មាន១ក្នុង១ឆ្នាំ ទៅឱ្យផលុបភោគី ឬទៅឱ្យសិទ្ធិវន្តរបស់ផលុបភោគីនោះដរាបដល់កំណត់វេលាដែលត្រូវចប់ផលុបភោគនោះក៏បាន។

**មាត្រា១០១**

ការដែលអសារកម្មសិទ្ធិករ លក់នូវអចលនវត្ថុដែលដាក់ជាផលុបភោគនោះមិននាំឱ្យផ្លាស់ប្តូរនូវស្ថានភាពនៃផលុបភោគឡើយ។ ផលុបភោគីនៅតែមានសិទ្ធិអាស្រ័យផលអចលនវត្ថុនេះតទៅទៀត លើកលែងតែផលុបភោគីនោះប្រកែកយ៉ាងច្បាស់ថាលែងអាស្រ័យផលុបភោគទៀតហើយ។

*វាយឡើងវិញ*

**មាត្រា១០២**

បើផលុបភោគីប្រកែកលែងអាស្រ័យផលហើយ ដោយក្លែងចង់ឱ្យខូចសិទ្ធិនៃម្ចាស់បំណុលខ្លួន ម្ចាស់បំណុលអាចនឹងប្ដឹងឱ្យបដិសេធពាក្យប្រកែកនេះបាន លើកលែងតែក្នុងរឿងដែលផលុបភោគនោះជាមតិក។

**មាត្រា១០៣**

បើអចលនវត្ថុត្រូវអន្តរាយទាំងអស់ ទើបផលុបភោគីត្រូវផុតអំណាចអាស្រ័យផល។ តែបើគ្រាន់តែខូចភាគខ្លះទេនោះ ផលុបភោគីត្រូវមានសិទ្ធិអាស្រ័យផលត្រង់ភាគដែលនៅល្អ។

**មាត្រា១០៤**

បើបានដាក់តែត្រឹមអគារមួយជាផលុបភោគទេ ហើយអគារនោះអន្តរាយអស់ទៅ ផលុបភោគី មិនត្រូវនៅមានសិទ្ធិអាស្រ័យផលលើដី លើគ្រឿងសំណង់នោះឡើយ។

បើបានដាក់សម្បត្តិទាំងពួងមានអគារដែលអន្តរាយនោះជាផលុបភោគដែរ បទប្បញ្ញត្តិចុងបំផុតនៃមាត្រា៩៤នៃច្បាប់នេះតម្រូវឱ្យអនុវត្តក្នុងករណីទាំងពីរនេះ លើកលែងតែមានហេតុយ៉ាងណាផ្សេងទៀត។

**មាត្រា១០៥**

ភោគៈអាចអនុវត្តបទប្បញ្ញត្តិនៃផលុបភោគនេះបានតែក្នុងក្របខ័ណ្ឌនៃសិទ្ធិរបស់ភោគៈប៉ុណ្ណោះ។

## ជំពូកទី២ អំពីសិទ្ធិប្រើប្រាស់ និងអាស្រ័យនៅ

**មាត្រា១០៦**

សិទ្ធិប្រើប្រាស់ អនុញ្ញាតឱ្យអត្ថគាហក ហូតយកពីអចលនវត្ថុណាមួយនូវផលទាំងឡាយតាមសមគួរដល់សេចក្ដីត្រូវការរបស់ខ្លួន និងគ្រួសារខ្លួន។

ដែលហៅថាសិទ្ធិអាស្រ័យនៅ គឺជាសិទ្ធិដែលអនុញ្ញាតឱ្យអត្ថគាហកបានកាន់កាប់កន្លែងក្នុងផ្ទះមួយគួរសមជាទីជ្រកនៅរបស់ខ្លួន និងគ្រួសារខ្លួន។

សិទ្ធិទាំងពីរ គឺសិទ្ធិប្រើប្រាស់ និងសិទ្ធិអាស្រ័យនៅបានអនុញ្ញាតឱ្យអត្ថគាហកយ៉ាងនេះហើយទោះបីថ្ងៃក្រោយមកអត្ថគាហកនោះមានប្ដី ប្រពន្ធក្ដី ឬមានកូនក្ដី ក៏សិទ្ធិនេះនៅតែមានដល់អត្ថគាហកដដែល។

**មាត្រា១០៧**

ផលុបភោគបានកើតឡើង និងបានរលត់ទៅវិញដោយរបៀបយ៉ាងណា សិទ្ធិប្រើប្រាស់ និងអាស្រ័យនៅកើតឡើង និងរលត់ទៅវិញដោយរបៀបយ៉ាងនោះដែរ ។ សិទ្ធិទាំងឡាយរបស់អ្នកប្រើប្រាស់ ត្រូវតែសម្រេចគ្នាឱ្យដាច់ស្រេច ហើយចុះជាខសន្យាក្នុងសំបុត្របញ្ជាក់ឱ្យសព្វគ្រប់ ឬបើគ្មានសំបុត្របញ្ជាក់ទេ ត្រូវគោរពតាមបទប្បញ្ញត្តិ ដូចមានខាងក្រោមនេះ ។

**មាត្រា១០៨**

អត្តគាហកទាំងឡាយដែលបានសិទ្ធិប្រើប្រាស់ និងអាស្រ័យនៅនោះ ត្រូវទទួលគោរពកាតព្វកិច្ចទាំងឡាយដែលមានចែងក្នុងមាត្រា៨៨, ៨៩, ៩១, ៩៥, ៩៧ និង៩៨នៃច្បាប់នេះ ។

**មាត្រា១០៩**

អត្តគាហកទាំងឡាយនោះមិនអាចផ្ទេរ ជួល នូវសិទ្ធិខ្លួនឱ្យអ្នកដទៃបានឡើយ ។

**មាត្រា១១០**

បើអ្នកប្រើប្រាស់អោបក្រសោបយកផលដីទាំងអស់ ឬក៏យកផ្ទះទាំងមូលនៅតែម្នាក់ឯង អ្នកនេះត្រូវទទួលចេញសោហ៊ុយដាំ សោហ៊ុយជួសជុលថែទាំ និងទទួលបង់ពន្ធដារទាំងពួង និងសោហ៊ុយធានារ៉ាប់រងដូចផលុបភោគី ។

បើអ្នកនោះយកផលតែមួយភាគ ឬយកកន្លែងតែមួយភាគក្នុងផ្ទះនោះទេ អ្នកនោះត្រូវជួយចេញបន្ទុកខាងលើ តាមសមាមាត្រនៃចំណែកដែលខ្លួនប្រើប្រាស់ និងអាស្រ័យ ។

## ជំពូកទី៣ អំពីសេវភាព

**មាត្រា១១១**

ដែលហៅថាសេវភាពនៃដី គឺបន្ទុកដែលតម្រូវទៅលើអចលនវត្ថុមួយហៅថាដីបម្រើ ឬដីក្រោមដើម្បីឱ្យអចលនវត្ថុមួយទៀតហៅថាដីប្រើ ឬដីលើជារបស់កម្មសិទ្ធិករម្នាក់ទៀតប្រើប្រាស់ ។

**មាត្រា១១២**

សេវភាពមានច្រើនបែប គឺសេវភាពកើតមកពីធម្មជាតិ សេវភាពកើតមកពីច្បាប់ និងសេវភាពកើតមកពីកិច្ចសន្យាតាមដំណើរ ដែលសេវភាពនោះលេចមកពីស្ថានភាពនៃទីកន្លែង ឬលេចចេញមកពីច្បាប់បង្កើត ឬលេចចេញមកពីកម្មសិទ្ធិករទាំងឡាយបានព្រមព្រៀងគ្នាចុះកិច្ចសន្យា ។

## ផ្នែកទី១ អំពីសេវភាពកើតពីធម្មជាតិ

**មាត្រា១១៣**

ដីក្រោមត្រូវទទួលទឹកដែលហូរតាមធម្មជាតិពីដីខ្ពស់មក។ កម្មសិទ្ធិករនៃដីក្រោមមិនអាចលើកថ្នល់ ភ្លឺ ធ្វើទំនប់ ឬធ្វើការអ្វីៗឯទៀត ទប់ឃាត់ឃាំងទឹកនេះមិនឱ្យហូរបានឡើយ។

**មាត្រា១១៤**

កម្មសិទ្ធិករនៃដីខាងលើ មានសិទ្ធិនឹងទុកទឹកភ្លៀង និងទឹកហូរកាត់ដីខ្លួន ប្រើប្រាស់បានកុំឱ្យតែល្មើសនឹងបញ្ញត្តិខាងលើ។

**មាត្រា១១៥**

កម្មសិទ្ធិករទាំងឡាយដែលមានដីនៅប្រឡទីដែលទឹកហូរ ត្រូវបណ្ដោយទឹកនោះឱ្យហូរទៅលើដីជិតខាងទាំងអស់។ ឯម្ចាស់ដីដែលជិតៗទាំងឡាយនោះសោតទៀត ក៏ត្រូវតែបណ្ដោយទឹកឱ្យហូរដូចគ្នាទៅកាន់ដីម្ខាងៗទៅទៀត តាមសេចក្ដីដែលត្រូវការរាល់គ្នាក្នុងកសិកម្ម។

## ផ្នែកទី២ អំពីសេវភាព កើតពីច្បាប់

**មាត្រា១១៦**

សេវភាពកើតពីច្បាប់មានពីរយ៉ាងគឺ សេវភាពដែលមានកម្មវត្ថុបម្រើប្រយោជន៍សាធារណៈ និងសេវភាពបម្រើប្រយោជន៍ឯកជន។

**មាត្រា១១៧**

សេវភាពកើតពីច្បាប់ដែលបម្រើប្រយោជន៍សាធារណៈនោះកើតមកពីច្បាប់ ឬបទប្បញ្ញត្តិជាពិសេសដែលកម្មសិទ្ធិករនៃដីត្រូវតែគោរពតាម។

**មាត្រា១១៨**

សេវភាពកើតពីច្បាប់ដែលបម្រើប្រយោជន៍ឯកជន គឺជាបទប្បញ្ញត្តិរបស់ច្បាប់ដែលកំណត់ព្រំដែនឱ្យកម្មសិទ្ធិករម្នាក់ៗ អាចធ្វើនូវអ្វីផ្សេងៗលើដីរបស់ខ្លួនបាន ដើម្បីកុំឱ្យប៉ះពាល់ដល់សិទ្ធិនៃកម្មសិទ្ធិករជិតខាង។

**មាត្រា១១៩**

កម្មសិទ្ធិករទាំងឡាយណាធ្វើនូវការទាំងឡាយណា ដែលនាំឱ្យសៅហ្មងដល់ដីជិតខាង ដូចជាខួងដី ជីកស្នង់ដី ជីករូងដី គរទុកក្នុងដីរបស់ខ្លួននូវវត្ថុប្រកបដោយគ្រោះថ្នាក់ នូវវត្ថុស្អុយ

មានជាតិកាចនាំឱ្យខូចសុខភាពគេ កម្មសិទ្ធិករទាំងពួងនោះត្រូវប្រតិបត្តិតាមបទប្បញ្ញត្តិនៃច្បាប់ដោយឡែកដែលកំណត់ចម្ងាយឱ្យប្រយ័ត្នក្តីដែលកំណត់ការឱ្យធ្វើសម្រាប់ទប់ជ្រែងក្តី។

**មាត្រា១២០**

កម្មសិទ្ធិករម្នាក់ៗ មិនអាចនឹងធ្វើប្រហោងទ្វារ បង្អួច កើយ ឬយ៉ងទៀតៗ បែបៗគ្នាត្រង់ចំទៅលើដីអ្នកជិតខាងចម្ងាយតិចជាង២ម៉ែត្របានទេ។

**មាត្រា១២១**

កម្មសិទ្ធិករម្នាក់ៗមិនអាចដាំឈើធំ តូច មានកម្ពស់លើសពីពីរម៉ែត្រ នៅប្របព្រំដីអ្នកជិតខាងដែលមានចម្ងាយតិចជាងពីរម៉ែត្របានទេ ថាបើមានអ្នកជិតខាងគេប្រាប់ឱ្យយកចេញ ត្រូវយកចេញភ្លាម។

**មាត្រា១២២**

កម្មសិទ្ធិករដែលមានដីក្នុងទីបិទមុខឥតច្រកនឹងដើរចេញ ចូល ទៅកាន់ផ្លូវសាធារណៈបាន ឬច្រកនោះតូចពេកមិនគួរនឹងធ្វើកសិកម្ម ឬឧស្សាហកម្មទេ អាចនឹងសុំបើកផ្លូវលើដីអ្នកជិតខាងបាន តែអ្នកនោះត្រូវចេញសោហ៊ុយឱ្យគេតាមសមាមាត្រនៃការខូចខាត ដែលបណ្តាលមកពីការបើកផ្លូវនោះ។

**មាត្រា១២៣**

ផ្លូវនោះត្រូវបើកឱ្យទៀងទាត់ ដោយយកតែកន្លែងណាដែលត្រង់ពីដីបិទមុខនោះ ទៅផ្លូវសាធារណៈជាងកន្លែងឯទៀត។

ប៉ុន្តែការបើកផ្លូវនេះត្រូវកំណត់ត្រង់កន្លែងណា ដែលមិនសូវខូចខាតដល់ម្ចាស់ដី ដែលឱ្យបើកផ្លូវនោះច្រើនពេកផង។

**មាត្រា១២៤**

បើដីណាមួយបិទមុខដោយហេតុមកពីបែងចែកដី ដើម្បីលក់ដូរចែកគ្នា ឬដោយចុះកិច្ចសន្យាប្រការឯណាទៀត ផ្លូវដែលអាចសុំបើកនោះ ត្រូវបើកតែលើដីដែលសល់ពីការបែងចែកនោះ ឬលើដីដទៃទៀត ដែលកម្មវត្ថុនៃកិច្ចសន្យាបាន។

ប៉ុន្តែបើផ្លូវដែលបើកលើដីទាំងនោះនៅតែមិនគ្រប់គ្រាន់ទេ មាត្រា១២២ នៅតែគួរយកមកអនុវត្តបានទៀត។

**មាត្រា១២៥**

កម្មសិទ្ធិករទាំងពួងណាត្រូវការយកទឹក ដែលខ្លួនមានសិទ្ធិប្រើប្រាស់បានមកដាក់លើដីខ្លួន កម្មសិទ្ធិករនោះ អាចនឹងសុំបើកទីនោះ តាមដីដែលនៅខណ្ឌដីខ្លួនបាន តែកម្មសិទ្ធិករនោះត្រូវចេញសោហ៊ុយឱ្យម្ចាស់នោះ។

**មាត្រា១២៦**

កម្មសិទ្ធិករដដែលនោះអាចនឹងសុំបញ្ចេញទឹកដែលខ្លួនបង្ហូរមកស្រោចដីខ្លួននោះ តាមទីទាបទាំងឡាយបាន តែកម្មសិទ្ធិករនោះត្រូវចេញសោហ៊ុយឱ្យគេជាដរាប។

**មាត្រា១២៧**

កម្មសិទ្ធិករណាមានដីលិចទឹកខ្លះ ឬទាំងអស់ ត្រូវការបង្ហូរទឹកតាមប្រឡាយ ឬតាមបំពង់រូម ឬដោយប្រការឯណាដើម្បីបញ្ចេញទឹកអាក្រក់ចេញពីដីខ្លួន តាមដីជាតំណោងពីដីខ្លួនមក កម្មសិទ្ធិករនោះអាចធ្វើបានដូចគ្នានឹងខាងលើនេះដែរ។

**មាត្រា១២៨**

កម្មសិទ្ធិករណាមានដីជាប់នឹងមាត់ទឹកត្រើយខាងអាយ ហើយចង់យកទឹកស្រោចដីខ្លួន កម្មសិទ្ធិករនោះអាចនឹងសង់សិល្បការ្យដែលជាចាំបាច់ក្នុងការបង្ហូរទឹកសង្កត់លើដីត្រើយខាងនាយបាន តែត្រូវចេញសោហ៊ុយឱ្យគេជាដរាប។

**មាត្រា១២៩**

កម្មសិទ្ធិករជាម្ចាស់ដីដែលព្រមឱ្យសង់ឱ្យធ្វើការ្យអ្វី លើដីខ្លួននោះអាចនឹងសុំប្រើទំនប់នោះជាមួយផងបាន។ ប៉ុន្តែកម្មសិទ្ធិករនោះត្រូវចេញសោហ៊ុយធ្វើ និងសោហ៊ុយថែទាំពាក់កណ្តាលម្នាក់ស្មើគ្នា។ បើដូច្នេះ កម្មសិទ្ធិករនេះមិនត្រូវទារសោហ៊ុយថ្លៃដីឡើយ បើបានជាទារទៅហើយ ត្រូវតែបង្វិលឱ្យគេវិញ។

## ផ្នែកទី៣ អំពីសេវភាពដែលមនុស្សបង្កើត

**មាត្រា១៣០**

ច្បាប់អនុញ្ញាតឱ្យកម្មសិទ្ធិករទាំងឡាយបង្កើតនូវសេវភាពទាំងឡាយណា ដែលខ្លួនយល់ឃើញថាគួរធ្វើលើដីរបស់ខ្លួនជាគុណប្រយោជន៍ដល់កម្មសិទ្ធិករទាំងឡាយឯទៀតបាន ឱ្យតែសេវភាព

ទាំងឡាយនោះ ពិតជាមានប្រយោជន៍តាមសេចក្តីត្រូវការប្រើប្រាស់នៃដីប្រើ ហើយមួយទៀត កុំឱ្យមានអ្វីជាទីទាស់ដល់សេចក្តីរៀបរយជាសាធារណជនផង ។

ការប្រើប្រាស់ និងទំហំនៃសេវភាព ដែលកើតឡើងដោយរបៀបយ៉ាងនេះ ត្រូវតែធ្វើជាប័ណ្ណដើម្បីទុកជាភស្តុតាងនៃការបង្កើតសេវភាពនោះ បើឥតមានប័ណ្ណទេត្រូវព្រមព្រៀងតាមបែបបទដូចមានខាងក្រោមនេះ ។

**មាត្រា១៣១**

សេវភាពទាំងឡាយដែលកើតឡើងមកពីមនុស្សធ្វើ នឹងត្រូវទុកជាកើតដោយត្រឹមត្រូវតាមច្បាប់បាន លុះណាតែភាគីបានធ្វើសំបុត្រមានបញ្ជាក់ ហើយយកទៅចុះក្នុងបញ្ជិកាកម្មសិទ្ធិដីទៀត ទើបតតិយជនតវ៉ាមិនបាន ។

កាលបើការទាក់ទងពីដីបម្រើ ទៅដីប្រើបានកើតឡើងហើយរវាងកម្មសិទ្ធិករនៃដីទាំងពីរយ៉ាងនេះក៏ដោយ បើកម្មសិទ្ធិករណាលក់ដូរដីរបស់ខ្លួនឱ្យទៅតតិយជនណាម្នាក់ ហើយមិនបានចុះសេចក្តីឱ្យប្រាកដក្នុងសំបុត្រលក់នោះថា សេវភាពនោះត្រូវនៅជាប្រក្រតីដដែល ការទាក់ទងនោះក៏ត្រូវលែងមានតទៅទៀតដែរ ។

**មាត្រា១៣២**

អ្នកណាមួយបង្កើតសេវភាពមួយហើយ អ្នកនោះត្រូវគេសន្មតថា ខ្លួនព្រមបើកឱ្យគេធ្វើអ្វីៗតាមចិត្ត ដែលជាការចាំបាច់ក្នុងការប្រើនូវសេវភាពនោះ ។

សេវភាពបើកឱ្យយកទឹកអំពីម៉ាស៊ីនទឹកណាមួយ នឹងបណ្តាលឱ្យអ្នកយកទឹកនោះ មានសិទ្ធិដើរកាត់ដីដែលមានម៉ាស៊ីនទឹកនោះបាន ។

**មាត្រា១៣៣**

កម្មសិទ្ធិករនៃដីប្រើមានសិទ្ធិនឹងធ្វើនូវការរៀទាំងពួងដែលចាំបាច់លើដីបម្រើ ដើម្បីប្រើប្រាស់ និងថែរក្សានូវសេវភាពដែលគេព្រមឱ្យខ្លួនប្រើ ។

**មាត្រា១៣៤**

ការរៀទាំងឡាយដែលត្រូវធ្វើជាចាំបាច់ដើម្បីប្រើប្រាស់ និងថែរក្សានូវសេវភាពនោះ ត្រូវជាភារៈនៃម្ចាស់ដីប្រើជាអ្នកចេញសោហ៊ុយ វៀរលែងតែបានព្រមព្រៀងគ្នាយ៉ាងណាផ្សេងទៅវិញ ទើបត្រូវប្រតិបត្តិតាមសេចក្តីព្រមព្រៀងនោះបាន ។

*វាយឡើងវិញ*

**មាត្រា១៣៥**

ក្នុងករណីដែលម្ចាស់ដីបម្រើត្រូវចេញសោហ៊ុយវិញ អ្នកនេះអាចលះបង់ដីរបស់ខ្លួនត្រង់ដែលទៅក្នុងសេវភាពនោះឱ្យទៅកម្មសិទ្ធិករនៃដីប្រើបាន ដើម្បីឱ្យផុតពីចេញសោហ៊ុយ ។

**មាត្រា១៣៦**

ប្រសិនបើដីប្រើទើបនឹងត្រូវបែងជាច្រើនភាគ សេវភាពនោះក៏ត្រូវនៅបម្រើដីប្រើតាមភាគដីនីមួយៗតទៅទៀត កុំឱ្យតែដីបម្រើនោះមានល័ក្ខខ័ណ្ឌរឹតតែធ្ងន់ឡើងទៀត។ ឧទាហរណ៍បើសេវភាពនោះគឺជាផ្លូវដើរ កម្មសិទ្ធិករនៃភាគដីផ្សេងៗទាំងឡាយ ត្រូវដើរតែតាមផ្លូវមួយត្រង់កន្លែងដដែលដែលមានពីដើមមក ។

**មាត្រា១៣៧**

កម្មសិទ្ធិករនៃដីបម្រើមិនអាចធ្វើនូវកិច្ចការឯណា ដែលជាទីនាំឱ្យការប្រើប្រាស់នូវសេវភាពនោះមានការចង្អៀតចង្អល់ ឬឱ្យទៅជាការមិនស្រួលប្រើបានទេ ។

ដូច្នេះកម្មសិទ្ធិករនៃដីបម្រើ មិនអាចផ្លាស់ប្តូរសេវភាពនៃកន្លែង ឬលើកយកសេវភាពនោះឱ្យទៅនៅកន្លែងផ្សេងប្រើប្រាស់ខុសពីកន្លែងដើមបានទេ ។

ប៉ុន្តែបើទុកស្ថានភាពដើមទៅ នឹងនាំឱ្យសេវភាពនោះអាចបង់ប្រាក់របស់កម្មសិទ្ធិករនៃដីបម្រើច្រើនគឺមិនឱ្យម្ចាស់ដីចំណេញជួសជុលទៅលើដីនោះទេ អ្នកនេះអាចសុំដាក់សេវភាពជំនួសវិញនៅទីឯទៀតបាន ដែលស្រួលដូចគ្នាជាសេវភាពជំនួសវិញបាន កម្មសិទ្ធិករនៃដីប្រើនឹងប្រកែកពុំបានឡើយ ។

**មាត្រា១៣៨**

ឯខាងកម្មសិទ្ធិករនៃដីប្រើវិញក៏ដូច្នោះដែរ អ្នកនេះនឹងប្រើប្រាស់នូវសេវភាពតែក្នុងព្រំដែនមានកំណត់ទុកក្នុងប័ណ្ណ ដោយមិនអាចផ្លាស់ប្តូរអ្វីនៅលើដីបម្រើ ឬនៅលើដីប្រើឱ្យរឹតតែធ្ងន់ លើស្ថានភាពមុននោះបានទេ ។

## ផ្នែកទី៤ សេវភាពរលត់ទៅដោយរបៀបណា

**មាត្រា១៣៩**

សេវភាពត្រូវរលត់៖

១-ដោយហេតុរលត់សិទ្ធិ ដែលបង្កើតសេវភាពនោះ

២-ដោយហេតុដីប្រើ និងដីបម្រើទាំងពីរនេះ បានធ្លាក់ទៅលើដៃនៃម្ចាស់តែម្នាក់

៣-ដោយហេតុដីដែលមានសេវភាពនោះវិនាសអស់ហើយ ។

**មាត្រា១៤០**

ភោគៈក៏អាចអនុវត្តតាមបទប្បញ្ញត្តិទាំងឡាយនៃសេវភាពនេះដែរ ។

## មាតិកាទី៤ អំពីប្រាតិភោគអចលនវត្ថុ

**មាត្រា១៤១**

ម្ចាស់បំណុលទាំងឡាយមានសិទ្ធិលើអចលនវត្ថុ ដែលកូនបំណុលបានដាក់ធានាប្រាក់ដែលបានខ្ចី តាមប្រាតិភោគប្រត្យក្សពីរៈ

-ការបញ្ចាំអចលនវត្ថុ

-អ៊ីប៉ូតែក

## ជំពូកទី១ អំពីការបញ្ចាំអចលនវត្ថុ

**មាត្រា១៤២**

ការបញ្ចាំគឺជាកិច្ចសន្យាដែលកូនបំណុលខ្លួនឯងក្តី តតិយជនណាម្នាក់ក្តីដាក់ទ្រព្យអ្វីមួយនៅដៃម្ចាស់បំណុល សម្រាប់រ៉ាប់រងសងបំណុលណាមួយ ដោយឱ្យម្ចាស់បំណុលនេះមានសិទ្ធិយកថ្លៃ នៃទ្រព្យដែលបញ្ចាំនោះជាសំណងប្រាក់ខ្លួនមុនម្ចាស់បំណុលឯទៀត ។

**មាត្រា១៤៣**

ការបញ្ចាំអចលនវត្ថុត្រូវតែមានកិច្ចសន្យាតាមរូបមន្តនៃលិខិតបញ្ជាក់ទើបបាន ។

**មាត្រា១៤៤**

តាមគោលការណ៍ កិច្ចសន្យានេះត្រូវបញ្ជាក់ដោយប្រធានគណៈកម្មាធិការប្រជាជនឃុំ ឬសង្កាត់ជាចៅនាទីនៃអចលនវត្ថុនោះ ។

បើអចលនវត្ថុច្រើនធានាតែបំណុលមួយ កិច្ចសន្យានោះត្រូវបញ្ជាក់ដោយប្រធានគណៈកម្មាធិការប្រជាជនឃុំ ឬសង្កាត់ ជាចៅនាទីនៃអចលនវត្ថុទាំងឡាយនោះឋិតនៅ ។ កិច្ចសន្យានេះ ត្រូវបញ្ជាក់ដោយប្រធានគណៈកម្មាធិការប្រជាជនស្រុក ឬខណ្ឌ ជាចៅនាទីនៃអចលនវត្ថុនោះផង ។

**មាត្រា១៤៥**

កិច្ចសន្យាបញ្ចាំអចលនវត្ថុ ត្រូវយកទៅប្រថាប់ត្រាភ្ជាម នៅការិយាល័យភូមិបាលសាមី បន្ទាប់ពីបានបញ្ជាក់រដ្ឋអំណាចរួចហើយត្រូវបញ្ជូនទៅចុះលេខាចារឹក និងតម្កល់ទុកនៅប័ណ្ណសារដ្ឋាន នៃការិយាល័យសុរិយោដីមួយច្បាប់។

**មាត្រា១៤៦**

ការបញ្ចាំអចលនវត្ថុនឹងត្រូវទុកជាការប្ដេជ្ញាត្រឹមត្រូវតាមច្បាប់ ហើយតតិយជនមិន អាចមកតវ៉ាបាននោះ គឺលុះណាតែលិខិតជាទីប្ដេជ្ញានោះ បានចុះក្នុងសៀវភៅចុះកម្មសិទ្ធិអចលនវត្ថុ ដូចដែលមានបញ្ញត្តក្នុងមាត្រា១៤៥ខាងលើនេះ ដែលត្រូវធ្វើឱ្យស្របតាមស្ថានភាពនៃអចលនវត្ថុ បញ្ចាំនោះផង។

ការមិនបានធ្វើប្រកាសនេះ នឹងបណ្ដាលឱ្យម្ចាស់បំណុលផ្លាស់សិទ្ធិចាកប្រាតិភោគប្រត្យក្ស អស់ ហើយបន្សល់ទុកឱ្យអ្នកនោះត្រឹមតែសិទ្ធិប្ដឹងឱ្យសងប្រាក់ដែលខ្ចីទៅតែប៉ុណ្ណោះ។ សិទ្ធិប្ដឹង នេះក៏ដូចជាសិទ្ធិដែលបើកឱ្យប្ដឹងទារប្រាក់ចងការដែរគឺសុទ្ធតែជាសិទ្ធិមានអាជ្ញាយុកាល។ អាជ្ញា យុកាលនេះមានកំណត់៥ឆ្នាំ។

**មាត្រា១៤៧**

អចលនវត្ថុតែមួយអាចបញ្ចាំបានតែនឹងម្ចាស់បំណុលម្នាក់ ឬច្រើននាក់ដែលសាមគ្គីគ្នា។

**មាត្រា១៤៨**

អចលនវត្ថុដែលដាក់បញ្ចាំនឹងប្រគល់ឱ្យម្ចាស់បំណុលក៏បាន មិនប្រគល់ឱ្យក៏បាន មិនបង្ខំ ទេ។ គេអាចបញ្ចាំដោយប្រគល់តែប័ណ្ណនៃអចលនវត្ថុនោះប៉ុណ្ណោះក៏បាន។

**មាត្រា១៤៩**

ដូច្នេះបើប្រគល់ ឬមិនប្រគល់នូវអចលនវត្ថុដល់ម្ចាស់បំណុលទេ និទ្ទេសនៃការនោះត្រូវ ចុះឱ្យច្បាស់ក្នុងកិច្ចសន្យាបញ្ចាំនោះ។

បើមុនដំបូងប្រគល់ ហើយក្រោយមកមិនប្រគល់វិញ ឬមុនមិនប្រគល់ ហើយក្រោយ មកប្រគល់វិញ និទ្ទេសនៃការផ្លាស់ប្ដូរនេះត្រូវកត់លើខ្នងនៃកិច្ចសន្យានោះដែរ។

**មាត្រា១៥០**

បើបានប្រគល់អចលនវត្ថុឱ្យដោយជាក់លាក់ ម្ចាស់បំណុលត្រូវតែប្រគល់ទ្រព្យបញ្ចាំនោះឱ្យទៅកូនបំណុលវិញជាក់ជាកំហិតក្នុងពេលដែលជននោះបានសងបំណុលអស់ហើយ ។

ក្នុងរយៈពេល១០ឆ្នាំរាប់ពីថ្ងៃធ្វើកិច្ចសន្យាមក បើកិច្ចសន្យានោះមិនបានកំណត់ថ្ងៃសងទេ និងរាប់ពីថ្ងៃដែលដល់កំណត់ឱ្យសងបើកិច្ចសន្យានោះមានកំណត់ថ្ងៃឱ្យសង ប្រសិនបើម្ចាស់បំណុលមិនបានប្តឹងដល់តុលាការ ទារបំណុលនោះទេ ម្ចាស់បំណុលត្រូវថ្លស់សិទ្ធិទទេ គឺប្តឹងលែងបានតទៅទៀត ។

ការថ្លស់សិទ្ធិនេះ មិនត្រឹមតែតម្រូវឱ្យម្ចាស់បំណុលប្រគល់អចលនវត្ថុឱ្យកូនបំណុលវិញប៉ុណ្ណោះទេ គឺតម្រូវឱ្យកូនបំណុលបានរួចពីការសងបំណុលទៀតផង ។

**មាត្រា១៥១**

ប្រសិនបើអចលនវត្ថុបញ្ចាំនៅនឹងដៃកូនបំណុល ព្រោះកាលបញ្ចាំនោះមិនបានប្រគល់ដីឱ្យម្ចាស់បំណុលទេ កូនបំណុលត្រូវតែសងប្រាក់ម្ចាស់បំណុលទាំងដើម ទាំងការ ដូចដែលមានចែងក្នុងកិច្ចសន្យា ទើបអាចលោះដោះខ្លួនឱ្យរួចពីបំណុលបាន ។

ក្នុងករណីដែលបញ្ចាំគ្មានប្រគល់អចលនវត្ថុនេះ ម្ចាស់បំណុលត្រូវតែប្តឹងតុលាការ ក្នុងរយៈពេលដូចមានចែងក្នុងមាត្រា១៥០ខាងលើនេះដើម្បីទារប្រាក់បំណុលនោះ បើមិនប្តឹងទេ ម្ចាស់បំណុលនេះនឹងត្រូវថ្លស់សិទ្ធិដូចគ្នា ។

កាលបើរយៈពេលទាំងនោះកន្លងផុតទៅ បន្ទុកដែលផ្ទុកលើអចលនវត្ថុរបស់កូនបំណុលក៏ត្រូវលុបចោលតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រាខាងលើដែរ ។

**មាត្រា១៥២**

ទោះជាយ៉ាងណាក៏ដោយ ក៏ម្ចាស់បំណុលមិនត្រូវឡើងជាកម្មសិទ្ធិករនៃអចលនវត្ថុបញ្ចាំនោះពេញច្បាប់ឡើយ ។

ខសន្យាណាដែលផ្ទុយនឹងបទប្បញ្ញត្តិនេះត្រូវទុកជាមោឃៈ និងអសារឥតការ ។

**មាត្រា១៥៣**

កិច្ចសន្យានៃការបញ្ចាំ គ្រាន់តែបើកឱ្យម្ចាស់បំណុលមានសិទ្ធិត្រឹមតែប្តឹងឱ្យដកសិទ្ធិនៃអចលនវត្ថុនោះ យកមកសងខ្លួនដែលជាអ្នកមានឯកសិទ្ធិ និងបុរិមាមុនម្ចាស់បំណុលដទៃទៀតតែប៉ុណ្ណោះ ។

ប្រសិនបើក្នុងរយៈពេលដែលអចលនវត្ថុនោះនៅជាប់ក្នុងកិច្ចសន្យាបញ្ចាំ ហើយអ្នកទទួលបញ្ចាំ ទិញអចលនវត្ថុដែលនៅនឹងដៃខ្លួន ឬមិននៅនឹងដៃខ្លួនទេ កិច្ចសន្យាលក់នោះត្រូវតែធ្វើតាមរូបមន្ត ដូចមានចែងក្នុងមាត្រា១៤៤នៃច្បាប់នេះទើបបាន។

**មាត្រា១៥៤**

អ្នកទទួលបញ្ចាំត្រូវប្រើប្រាស់នូវអចលនវត្ថុនោះ ដោយយកចិត្តទុកដាក់ដូចគ្នានឹងផលុបភោគដែរ។ ម្ចាស់បំណុលត្រូវថែទាំ និងរក្សានូវអចលនវត្ថុនោះឱ្យគង់ល្អ បើវត្ថុនោះខូចខាត ព្រោះអំពើរបស់ខ្លួន ឬក៏ព្រោះកំហុសរបស់ខ្លួន ខ្លួននឹងត្រូវមានទោសឱ្យសងតម្លៃដែលខូចខាតនោះដោយកាត់ប្រាក់ក្នុងបំណុលខ្លួនបាន។

**មាត្រា១៥៥**

នៅពេលដែលផុតកិច្ចសន្យាដោយសារកូនបំណុលសងប្រាក់អស់ហើយ ឬក៏ដោយសារខ័យសក្តិក្តី អ្នកទទួលបញ្ចាំត្រូវតែបង្វិលទៅឱ្យកូនបំណុលវិញនូវអចលនវត្ថុ ឬតម្លៃអចលនវត្ថុនោះ ប្រសិនបើវាអន្តរាយព្រោះកំហុសរបស់ខ្លួន។

**មាត្រា១៥៦**

បើរយៈពេលនៃកិច្ចសន្យានោះត្រូវផុតកំណត់ ហើយកូនបំណុលមកសុំលោះវត្ថុគេវិញ តែអ្នកទទួលបញ្ចាំមិនព្រមឱ្យលោះ អ្នកនោះត្រូវជំពាក់ផល និងផលទុននៃកូនបំណុលវិញ តាំងពីថ្ងៃដែលគេសុំលោះមក។

**មាត្រា១៥៧**

ក៏ប៉ុន្តែបើកិច្ចសន្យានោះមិនបានចែងឱ្យច្បាស់លាស់ពីថ្ងៃកំណត់សងទេ ម្ចាស់បំណុលនៅតែមានសិទ្ធិយកផល និងផលចម្រូតដែលជាប់នៅដើមក្តី និងដែលបានបេះប្រលេះ ច្រូតកាត់ទុកដាក់ហើយក្តី ដែលជាផលកើតមកពីការយកចិត្តទុកដាក់របស់ខ្លួនពីការងាររបស់ខ្លួន និងពីទុនរបស់ខ្លួន។

**មាត្រា១៥៨**

ការប្រាក់ត្រូវលែងមាន តាំងពីកូនបំណុលសុំសងប្រាក់វិញ។ ការស្នើសុំសងនេះ ត្រូវប្រាប់ឱ្យច្បាស់ថាសុំសងប៉ុន្មាន ហើយការស្នើនេះត្រូវកត់ក្នុងលិខិតមួយដែលប្រធានឃុំ-សង្កាត់ ត្រូវចុះហត្ថលេខាខ្លួនជាមួយនិងកូនបំណុល និងសាក្សីពីរនាក់ផង។

បើកូនបំណុលចង់សងនៅពាក់កណ្ដាលឆ្នាំមុនរដូវចម្រូត កូនបំណុលនេះត្រូវសងការប្រាក់ក្នុងឆ្នាំនោះ ហើយការនោះត្រូវយកតាមអត្រាកំណត់គឺ ២០ភាគរយក្នុងមួយឆ្នាំ។

**មាត្រា១៥៩**

ការបង់ពន្ធដារត្រូវបង់ទុកជាបន្ទុកលើកូនបំណុល ប្រសិនបើកិច្ចសន្យានោះមិនបានប្ដេជ្ញាថា ដូចម្ដេចទេ។

**មាត្រា១៦០**

កាលបើកូនបំណុលសងបំណុលដែលបញ្ចាំអចលនវត្ថុ ហើយម្ចាស់បំណុលមិនអាចនឹងឃាត់អចលនវត្ថុនោះទុកតទៅទៀតដោយអាងហេតុថា កូនបំណុលនៅជំពាក់បំណុលមួយទៀតបានឡើយ ទោះបំណុលក្រោយនោះដល់កំណត់ត្រូវទារក្ដី ប្រសិនបើគ្មានកិច្ចសន្យាបញ្ចាំមួយជាថ្មីទៀតនិយាយថា បញ្ចាំដីដដែលនេះ និងមិនបានធ្វើតាមរូបមន្តនៃកិច្ចសន្យាមុនទេ។

**មាត្រា១៦១**

កូនបំណុលអាចយកសិទ្ធិខាងលើនេះទៅប្រើប្រាស់លើទាយាទ ឬលើសិទ្ធិវន្តនៃម្ចាស់បំណុលបាន។

**មាត្រា១៦២**

សិទ្ធិខាងលើនេះក៏ជារបស់ទាយាទនៃកូនបំណុល ឬសិទ្ធិវន្តនៃកូនបំណុល ព្រមទាំងសមាជិកនៃគ្រួសារដែលអាចស្រដីថា ខ្លួនជាសហកម្មសិទ្ធិករនៃវត្ថុបញ្ចាំនោះដែរ។

**ជំពូកទី២ អំពីអ៊ីប៉ូតែក**

**មាត្រា១៦៣**

អ៊ីប៉ូតែកជាប្រាតិភោគប្រត្យក្ស ដែលបើកឱ្យម្ចាស់បំណុលប្ដឹងនៅវេលាដែលដល់កំណត់សង ហើយសុំឱ្យលក់អចលនវត្ថុនោះ ទោះនៅលើដៃនរណាក្ដី ដើម្បីយកប្រាក់សងខ្លួនជាអ្នកមានឯកសិទ្ធិ និងបុរិមាជាងម្ចាស់បំណុលឯទៀត ដោយគ្មានដកអចលនវត្ថុនោះពីកម្មសិទ្ធិករទេ។

**មាត្រា១៦៤**

មានតែអចលនវត្ថុដែលមានប័ណ្ណសម្គាល់សិទ្ធិទេ ទើបអាចដាក់អ៊ីប៉ូតែកបាន។

**មាត្រា១៦៥**

ដូចគ្នានឹងការបញ្ចាំអចលនវត្ថុដែរ ម្ចាស់បំណុលមិនត្រូវឡើងជាកម្មសិទ្ធិករនៃអចលនវត្ថុដែលដាក់អ៊ីប៉ូតែកនោះពេញច្បាប់ឡើយ ។

**មាត្រា១៦៦**

កិច្ចសន្យាដាក់អ៊ីប៉ូតែកត្រូវធ្វើនៅសាការី បើមិនដូច្នោះទេត្រូវទុកជាមោឃៈជាដាច់ខាត ។

**មាត្រា១៦៧**

កិច្ចសន្យាត្រូវបញ្ជាក់ពីទីតាំង និងទំហំដី បន្ទុកផ្សេងៗលើដី និងអំពីតម្លៃសរុបនៃអចលនវត្ថុដែលត្រូវដាក់អ៊ីប៉ូតែក ។

**មាត្រា១៦៨**

គេអាចដាក់អ៊ីប៉ូតែកច្រើនដងបន្តបន្ទាប់គ្នាលើអចលនវត្ថុតែមួយ ក្នុងរយៈពេលតែមួយ ឱ្យម្ចាស់បំណុលច្រើននាក់ ។ ម្ចាស់បំណុលម្នាក់ៗ មានសិទ្ធិតាមលំដាប់បុរិមានៃការប្រថាប់ត្រា ។

**អំពីសិទ្ធិម្ចាស់បំណុលអ៊ីប៉ូតែក**

**មាត្រា១៦៩**

ម្ចាស់បំណុលអ៊ីប៉ូតែកទាំងឡាយ មានសិទ្ធិសុំប្តឹងឱ្យលក់អចលនវត្ថុដែលដាក់អ៊ីប៉ូតែក បើដល់ថ្ងៃកំណត់ឱ្យសងហើយកូនបំណុលមិនសង ដោយមិនគិតពីលំដាប់ថ្នាក់ម្ចាស់បំណុលអ៊ីប៉ូតែកឡើយ ។

**មាតិកា៥ អំពីសន្តតិកម្ម**

**មាត្រា១៧០**

សន្តតិកម្មគឺការផ្ទេរនូវបេតិកភណ្ឌនៃបុគ្គលណាម្នាក់ដែលស្លាប់ឱ្យទៅជនម្នាក់ទៀត ឬច្រើននាក់ដែលហៅថាទាយាទ ឬសន្តតិជន ។

សន្តតិកម្មត្រូវផ្ទេរតាមច្បាប់ ឬតាមឆន្ទៈរបស់ខ្មោច ។

សន្តតិកម្មដែលផ្ទេរតាមច្បាប់ ហៅថាសន្តតិកម្មឥតបណ្តាំ សន្តតិកម្មដែលផ្ទេរតាមឆន្ទៈរបស់ខ្មោច ហៅថាសន្តតិកម្មមានបណ្តាំ ។

**មាត្រា១៧១**

សន្តតិកម្មត្រូវចាប់ចែកក្រោយថ្ងៃដែលខ្មោចនោះស្លាប់ និងនៅទីដែលជាលំនៅក្រោយបង្អស់របស់ខ្មោច ។

**មាត្រា១៧២**

ជនដែលអាចទទួលសន្តតិកម្មបាននោះ គឺមនុស្សដែលមានជីវិតរស់នៅមានសមត្ថភាព និង មិនទាន់កាត់កាល់ថាជាអភ័ព្វបុគ្គលទេ។

ទារកដែលនៅក្នុងគភ៌នៅឡើយ បើកើតមករវាង៣០០ថ្ងៃ គិតតាំងពីថ្ងៃដែលខ្មោចនោះស្លាប់មក ហើយរស់អាចទទួលនូវសន្តតិកម្មបាន។

**មាត្រា១៧៣**

ទណ្ឌិតដែលមានទោសឧក្រិដ្ឋអស់មួយជីវិត ត្រូវទុកជាជនគ្មានសមត្ថភាពនឹងទទួលបានឡើយ។ ឯទណ្ឌិតនេះ បើបានទទួលនូវការលើកទោស ឬការប្តូរទោសណាមួយហើយនិងមានសមត្ថភាពឡើងវិញ។

សន្តតិកម្មឥតបណ្តាំណា ដែលត្រូវបានទៅទណ្ឌិតដែលមានទោសឧក្រិដ្ឋអស់មួយជីវិត សន្តតិកម្មនោះ ត្រូវធ្លាក់ទៅបច្ចាញាតិនៃជននោះទទួលជួស។

**មាត្រា១៧៤**

តុលាការអាចកាត់សេចក្តីទុកជនទាំងឡាយដូចខាងក្រោមនេះ ជាអភ័ព្វបុគ្គលដែលមិនគប្បីឱ្យទទួលនូវសន្តតិកម្ម "មតិក" ឡើយ

១-ជនដែលបានព្យាបាទដល់ជីវិតនៃខ្មោចកាលនៅរស់ ទោះធ្វើជាមេគេក្តី ជាសហការីក្តី ឬគ្រាន់តែសមគំនិតក្តី។

២-ជនដែលមានអាយុច្រើនជាង១៦ឆ្នាំ បានស្គាល់ឃាតករជនដែលសម្លាប់ខ្មោច ហើយព្រងើយកន្តើយពុំប្តឹងតុលាការ។

៣-ជនដែលប្តឹងបង្កាច់ទោសពីខ្មោច ឱ្យខ្មោចត្រូវឧក្រិដ្ឋទោស ឬទោសគុកជាមជ្ឈិម។

៤-ជនដែលអាចមកបាន ហើយមិនមកថែទាំ ឬឧបត្ថម្ភ នៅវេលាដែលខ្មោចនោះមានជំងឺឈឺលើកក្រោយបំផុតដែលខ្លួនបានដឹងដែរ។

៥-ជនដែលនៅជិតកន្លែងដែលខ្មោចនោះស្លាប់ អាចមកបាន ហើយមិនមកជួយលើកខ្មោច ស្រោចឆ្អឹងដោយឥតហេតុគប្បីឱ្យខាន។

៦-មនុស្សដែលខ្មោចបានបណ្តេញឱ្យចេញពីផ្ទះ ព្រោះអកតញ្ញូតា ព្រោះមិនមានសេចក្តីគោរព ព្រោះទុរាចារ ឬព្រោះហេតុដទៃទៀត ហើយមិនបានមកសុំខមាទោសមុនពេលដែលស្លាប់។

តុលាការនឹងកាត់សេចក្ដីឱ្យកាត់កាល់យ៉ាងនេះបាន លុះណាតែជនណាម្នាក់ដែលមានប្រយោជន៍ក្នុងរឿងនេះបានប្ដឹងផង។

**មាត្រា១៧៥**

ជនអភ័ព្វនេះត្រូវសន្មតថាមិនបានទទួលនូវសន្តតិកម្មសោះ។

សន្តតិកម្មដែលត្រូវបានមកជននោះ ត្រូវធ្លាក់ទៅលើជនទាំងឡាយដែលត្រូវបានសន្តតិកម្មនោះទាំងអស់ ប្រសិនបើជនអភ័ព្វនោះមិនបានរស់នៅក្នុងវេលាដែលខ្មោចធ្វើមរណកាលទេ ក៏ប៉ុន្តែកូនមានខាន់ស្លា ដែលកើតអំពីជនអភ័ព្វនោះរវាង៣០០ថ្ងៃ ក្រោយថ្ងៃស្លាប់នៃជនអភ័ព្វនោះ ហើយរស់ ត្រូវស៊ីមតិកឪពុកវាបាន។

សន្តតិកម្មដែលត្រូវកាត់កាល់ ត្រូវបង្វិលចំណែកសន្តតិកម្មដែលខ្លួនបានទទួលរួចហើយព្រមទាំងផល និងផលទុនដែលខ្លួនបានហូតយកតាំងពីថ្ងៃដែលចែកសន្តតិកម្មនោះមកវិញ។

**មាត្រា១៧៦**

ជនអភ័ព្វអាចនឹងកាន់កាប់ ថែរក្សានូវសន្តតិកម្មដែលបានទៅកូនខ្លួនដែលនៅក្នុងអនីតិភាពបាន។

## មាតិកាទី៦ អំពីកិច្ចសន្យា

## ជំពូកទី១ អំពីការលក់អចលនវត្ថុ

**មាត្រា១៧៧**

ការលក់អចលនវត្ថុជាកិច្ចសន្យាដែលជនម្នាក់ហៅថា អ្នកលក់ត្រូវផ្ទេរនូវសិទ្ធិនៃអចលនវត្ថុនោះ ឬកម្មសិទ្ធិណាមួយជារបស់ខ្លួនឱ្យទៅជនម្នាក់ទៀត ហៅថាអ្នកទិញដែលជាអ្នកត្រូវចេញថ្លៃជាប្រាក់តាមតម្លៃនៃវត្ថុនោះ ឬសិទ្ធិនោះឱ្យអ្នកលក់។

**មាត្រា១៧៨**

កម្មសិទ្ធិករទាំងពួងអាចលក់អចលនវត្ថុ ឬសិទ្ធិទាំងឡាយលើអចលនវត្ថុដែលជាកម្មសិទ្ធិផ្ទាល់របស់ខ្លួនបាន វៀរតែក្នុងករណីដែលមានច្បាប់ ឬបទបញ្ញាណាហាមឃាត់តែប៉ុណ្ណោះ។

**មាត្រា១៧៩**

កិច្ចសន្យានៃការលក់អចលនវត្ថុត្រូវតែធ្វើជាលិខិតតាមរូបមន្តលិខិតយថាភូតទើបបាន។

**មាត្រា១៨០**

ត្រូវទុកជាមោឃៈ៖

-ការលក់អចលនវត្ថុមិនមែនជារបស់ខ្លួន

-ការលក់អចលនវត្ថុពីប្ដី ឱ្យទៅប្រពន្ធ ឬពីប្រពន្ធឱ្យទៅប្ដី

-ការលក់អចលនវត្ថុអវិភាគ "ដែលបំបែកគ្នាមិនបាន" ដោយសហកម្មសិទ្ធិករម្នាក់ ដោយគ្មានបានទទួលការព្រមព្រៀងពីសហកម្មសិទ្ធិករឯទៀត ។

**មាត្រា១៨១**

គេអាចលក់អចលនវត្ថុដែលនឹងមាននាអនាគតបាន វៀរលែងតែមតិកដែលមានម្ចាស់នៅរស់នៅឡើយ ទោះបីម្ចាស់មតិកនោះយល់ព្រមផងក៏ដោយ ។

**មាត្រា១៨២**

ការផ្ទេរនូវកម្មសិទ្ធិរបស់អ្នកលក់ឱ្យទៅអ្នកទិញ ទុកជាត្រឹមត្រូវគិតតាំងពីថ្ងៃដែលសំបុត្រលក់នោះមានសេចក្ដីបញ្ជាក់មានប្រថាប់ត្រា និងមានចុះក្នុងបញ្ជិកាកម្មសិទ្ធិផងទៀត ។

**មាត្រា១៨៣**

បើអ្នកលក់ លក់អចលនវត្ថុថោកជាងពាក់កណ្ដាលថ្លៃដែលត្រូវលក់ក្នុងពេលនោះ ខ្លួនអាចនឹងសុំកតិកាភេទនៃការលក់បាន គឺថាតុលាការនាកាលបានទទួលពាក្យពីអ្នកលក់ ឬពីទាយាទឬសិទ្ធិវន្តនៃអ្នកលក់ហើយ ត្រូវកាត់សេចក្ដីឱ្យការលក់នោះជាមោឃៈភ្លាម ទោះបីក្នុងកិច្ចសន្យាលក់នោះ អ្នកលក់បានដាក់សេចក្ដីច្បាស់លាស់ថា ខ្លួនមិនប្ដឹងសុំកតិកាភេទទេ ប្រសិនបើអាចប្ដឹងបានក៏ដោយ ឬបានថែងច្បាស់ថា ខ្លួនធ្វើអំណោយដល់អ្នកទិញនូវថ្លៃលើសពីនេះទៅទៀតយ៉ាងនេះក៏ដោយ ។

**មាត្រា១៨៤**

បើការលក់នេះរំលងបីឆ្នាំហើយ គិតចាប់ពីថ្ងៃដែលលក់មក តុលាកាមិនគប្បីទទួលពាក្យសុំកតិកាភេទនោះឡើយ ។ អ្នកប្ដឹងនោះទោះស្រីមានប្ដីក្ដី អ្នកភៀសខ្លួនក្ដី អ្នកមានគំហាត់ក្ដី អនីតិជន ដែលនីតិជនណាម្នាក់យកអចលនវត្ថុទៅលក់ក្ដី ត្រូវគិតរយៈវេលាពាឆ្នាំដូចគ្នាទាំងអស់ ។

**មាត្រា១៨៥**

ប្រសិនបើតុលាការទុកបណ្ដឹងសុំកតិកាភេទជាត្រឹមត្រូវហើយ អ្នកទិញអាចរើសយកចំណុចណាមួយ បណ្ដាចំណុចទាំងពីរនេះ គឺប្រគល់អចលនវត្ថុឱ្យម្ចាស់វា ហើយយកថ្លៃដែលបានបង់ហើយមកវិញក៏បាន ឬទុកអចលនវត្ថុនោះ ហើយថែមប្រាក់ទៀតឱ្យគ្រប់តាមថ្លៃដែលអ្នកជំនាញបានកំណត់មកក៏បាន ។

តតិយជនដែលបានទិញតពីអ្នកទិញផ្ទាល់ក៏មានសិទ្ធិនេះដូចគ្នា លើកមួយតែអ្នកទិញផ្ទាល់រ៉ាប់ថា នឹងតវ៉ានឹងអ្នកលក់ជួស ។

**មាត្រា១៨៦**

បើអ្នកទិញពេញចិត្តនឹងទុកអចលនវត្ថុជាង ហើយថែមថ្លៃឱ្យទៀតដូចមានចែងក្នុងមាត្រាមុន ខ្លួនត្រូវចេញការប្រាក់នៃថ្លៃដែលឱ្យខ្វះនោះ តាំងពីថ្ងៃដែលអ្នកលក់ប្ដឹងមក ។

បើអ្នកទិញមិនដែលបានទទួលផលពីអចលនវត្ថុសោះទេ អ្នកនេះត្រូវបានការនៃប្រាក់ថ្លៃទិញ ដែលខ្លួនបានបង់ហើយ ដោយគិតពីត្រឹមថ្ងៃគេប្ដឹងមក ឬគិតតាំងពីថ្ងៃទិញមក ។

**មាត្រា១៨៧**

ការលក់ឯណាដែលអាជ្ញាធរខាងតុលាការជាអ្នកលក់ ដូចជាអចលនវត្ថុដែលគេទិញបានពីការលក់ឡាយឡុង ជាឧទាហរណ៍ ជនណានឹងប្ដឹងសុំកតិកាភេទក៏មិនបានដែរ ។

**មាត្រា១៨៨**

សោហ៊ុយអំពីការធ្វើលិខិតលក់ និងសោហ៊ុយប្រថាប់ត្រាផ្សេងៗជាបន្ទុករបស់អ្នកទិញ ។

## ជំពូកទី២ អំពីការដូរ

**មាត្រា១៨៩**

ការដូរជាកិច្ចសន្យាដែលភាគីទាំងឡាយព្រមព្រៀងនឹងឱ្យវត្ថុគ្នាទៅវិញទៅមក ។

**មាត្រា១៩០**

ការដូរនេះ ត្រូវប្រព្រឹត្តទៅតាមច្បាប់ និងតាមរូបមន្តនៃការលក់ដែរ ។

**មាត្រា១៩១**

បើដូរវត្ថុដែលមិនមែនជាកម្មសិទ្ធិរបស់ខ្លួន ការដូរនេះត្រូវទុកជាមោឃៈ ។ ត្រូវទុកជាមោឃៈដែរ៖

-ការដូរអចលនវត្ថុអវិភាគ ដែលគ្មានការព្រមព្រៀងពីសហកម្មសិទ្ធិករដទៃទៀត ។

-ការដូរអចលនវត្ថុជាមតិក ដែលមានម្ចាស់នៅរស់នៅឡើយ ទោះបីម្ចាស់មតិកនោះយល់ព្រមផងក៏ដោយ ។

**មាត្រា១៩២**

ការដូរដែលចាញ់បញ្ឆោតគេ អាចនឹងប្តឹងសុំឱ្យសងវត្ថុដែលខ្លួនបានប្រគល់ឱ្យនោះវិញក៏បាន ឬឱ្យសងជំងឺចិត្តក៏បាន ។

**ជំពូកទី៣ អំពីការឱ្យ ឬប្រទានកម្ម**

**មាត្រា១៩៣**

ការឱ្យគឺជាកិច្ចសន្យាដែលជនម្នាក់ហៅថាអ្នកឱ្យ ឬទាយកឱ្យនូវអចលនវត្ថុណាមួយដាច់ឥតរើរុះ ទៅជនម្នាក់ទៀត ហៅថាអ្នកទទួល ឬបដិគាហកដែលព្រមយកអចលនវត្ថុនោះ ។

**មាត្រា១៩៤**

កាលបើប្រទានកម្មប្តេជ្ញាថាឱ្យបេតិកភណ្ឌសាកល ឬឱ្យតែអចលនវត្ថុណាមួយ ប្រទានកម្មនោះ ត្រូវឱ្យដោយសំបុត្របញ្ជាក់នៅមុខអ្នកទទួលដែលព្រមទទួលផង ។

ប្រទានកម្មដែលឱ្យអចលនវត្ថុ កាលបើបានប្រថាប់ត្រា និងបានចុះបញ្ជិកាកម្មសិទ្ធិរួចហើយ ទើបទុកជាស្រេច តតិយជននឹងតវ៉ាមិនបានឡើយ ។

**មាត្រា១៩៥**

ប្រទានកម្មដែលធ្វើឱ្យហេតុមរណៈ ហៅថាអច្ច័យទាន ។

**មាត្រា១៩៦**

នាកាលអ្នកទទួលប្រទានកម្ម មានសមត្ថភាពអាចនឹងចុះកិច្ចសន្យាបានហើយ អ្នកនេះអាចប្រកែកមិនព្រមយកសប្បុរិសទាននេះបានជាដរាប ។

ម្ចាស់បំណុលនៃជននេះមិនអាចធ្វើអន្តរាគមន៍ ដើម្បីបង្ខំជននេះឱ្យទទួលប្រទានកម្មបានឡើយ ។

**មាត្រា១៩៧**

ប្រទានកម្មនូវវត្ថុដែលអ្នកឱ្យនឹងមានក្នុងអនាគតនោះមិនបានទេ ប្រទានកម្មដែលធ្វើដើម្បីឱ្យអ្នកទទួលនោះព្រមសងបំណុលខ្លួន ដែលនឹងមានក្នុងអនាគតក៏មិនបានដែរ និងប្រទានកម្មដែលបើកឱ្យអ្នកឱ្យមានសិទ្ធិយកទ្រព្យដែលបានឱ្យ ហើយទៅចាត់ចែងតាមចិត្តខ្លួនក៏មិនបានដែរ ។

**មាត្រា១៩៨**

អ្នកឱ្យអាចសំចៃទុក ដើម្បីខ្លួនទទួលផលុបភោគសិទ្ធិប្រើប្រាស់ និងអាស្រ័យនៅនៃអចលនវត្ថុសិនក៏បានដែរ ។

**មាត្រា១៩៩**

ប្រទានកម្មឯណាដែលអ្នកទទួលបានព្រមទទួលហើយ ប្រទានកម្មនោះត្រូវទុកជាស្រេចឥតវិវ៉ុះដោយប្រការឯណាឡើយ វៀរលែងតែករណីដូចខាងក្រោម ។

**មាត្រា២០០**

អ្នកឱ្យ ឬសិទ្ធិវន្តរបស់អ្នកឱ្យអាចនឹងប្ដឹងសុំឱ្យបដិសេធវិញបានដោយមានហេតុដូចតទៅ៖

១-បើអ្នកទទួលមិនបានបំពេញនូវភារៈ ដែលខ្លួនមានកាតព្វកិច្ចត្រូវបំពេញ

២-បើអ្នកទទួលប្រព្រឹត្តនូវអំពើអកតញ្ញូ ឬធ្វើខ្លួនឱ្យជាអភ័ព្វជនបុគ្គលគ្រប់ល័ក្ខខ័ណ្ឌ ដូចមានចែងហើយក្នុងមាតិកានៃសន្តតិកម្ម ។

៣-បើអ្នកទទួលមិនចិញ្ចឹមអ្នកឱ្យក្នុងពេលដែលទ័លក្រ ។

**មាត្រា២០១**

ការសុំបដិសេធប្រទានកម្មនោះជាភារៈរបស់អ្នកឱ្យ ឬរបស់សិទ្ធិវន្តនៃអ្នកឱ្យ ។

**មាត្រា២០២**

ការបដិសេធនោះ បណ្ដាលឱ្យរលាយកម្មសិទ្ធិនៃអ្នកទទួល ការនោះមានអានុភាពជាល័ក្ខខ័ណ្ឌរំលាយទ្រព្យដែលបានឱ្យ ហើយនោះត្រូវបានទៅអ្នកឱ្យវិញ ដោយលែងឱ្យអ្នកទទួលមានបំណុល និងបន្ទុកទាំងពួងដែលបានធ្លាក់លើអ្នកនេះ ពីថ្ងៃមុនមក ។

**មាតិកាទី៧ អំពីកិច្ចការអភិរក្សសិទ្ធិនៃអចលនវត្ថុ**

**មាត្រា២០៣**

រាល់លិខិតសញ្ញាពាក់ព័ន្ធនឹងអចលនវត្ថុ ត្រូវប្រថាប់ត្រានៅការិយាល័យភូមិបាល ឬការិយាល័យសុរិយោដីដែលគ្រប់គ្រងអចលនវត្ថុនោះ ក្នុងរយៈពេលសាមសិបថ្ងៃ ចាប់ពីថ្ងៃបញ្ចាក់មក ពុំនោះទេលិខិតសញ្ញានេះត្រូវទុកជាមោឃៈ និងជាអសារឥតការ ។

ការិយាល័យភូមិបាល ឬការិយាល័យសុរិយោដីនឹងចុះបញ្ជីបាន លុះណាតែលិខិតសញ្ញានោះ មានគ្រប់លក្ខណៈតាមច្បាប់ ។

**មាត្រា២០៤**

ជនគ្រប់រូបអាចទំនាក់ទំនងសួរព័ត៌មានអំពីប្រាតិភោគអចលនវត្ថុ ឬបន្ទុកលើអចលនវត្ថុ នៅការិយាល័យភូមិបាល ឬនៅការិយាល័យសុរិយោដី ឬនៅនាយកដ្ឋានសុរិយោដីបានគ្រប់ពេលវេលាក្នុងសៀវភៅចុះកម្មសិទ្ធិអចលនវត្ថុ ឬសៀវភៅចុះភោគៈអចលនវត្ថុ។

ចំពោះការស្នើសុំសេចក្ដីដកស្រង់ និងចម្លងប័ណ្ណ ត្រូវធ្វើនៅការិយាល័យសុរិយោដី ឬនាយកដ្ឋានសុរិយោដី។

**មាត្រា២០៥**

កម្មសិទ្ធិអចលនវត្ថុត្រូវចុះក្នុងសៀវភៅចុះកម្មសិទ្ធិអចលនវត្ថុ។

សៀវភៅចុះកម្មសិទ្ធិអចលនវត្ថុត្រូវធ្វើជាពីរច្បាប់ដូចគ្នា ដោយមួយច្បាប់តម្កល់ទុកនៅការិយាល័យសុរិយោដីខេត្ត-ក្រុង និងមួយច្បាប់ទៀតតម្កល់ទុកនៅនាយកដ្ឋានសុរិយោដី។

**មាត្រា២០៦**

សៀវភៅចុះកម្មសិទ្ធិអចលនវត្ថុ ត្រូវចុះចរន្តការរាល់ការផ្ទេរនិទ្ទេសបន្ទុកលើអចលនវត្ថុ ការបំបែកក្បាលដី ឬការបញ្ចូលក្បាលដី។

**មាត្រា២០៧**

ភោគៈអចលនវត្ថុត្រូវចុះក្នុងសៀវភៅចុះភោគៈអចលនវត្ថុ។ សៀវភៅនេះត្រូវធ្វើជាពីរច្បាប់ដូចគ្នា ដោយមួយច្បាប់តម្កល់នៅការិយាល័យភូមិបាល និងមួយច្បាប់ទៀតនៅការិយាល័យសុរិយោដីខេត្ត-ក្រុង។

**មាត្រា២០៨**

សៀវភៅចុះភោគៈអចលនវត្ថុត្រូវចុះចរន្តការ ចំពោះតែការផ្ទេរអចលនវត្ថុ ការបំបែកក្បាលដី ដែលជាលទ្ធផលនៃសន្តតិកម្មតែប៉ុណ្ណោះ។

**មាត្រា២០៩**

សៀវភៅចុះកម្មសិទ្ធិអចលនវត្ថុ ត្រូវធ្វើតាមឃុំនីមួយៗនៃដីកម្មសិទ្ធិ ក្នុងរង្វង់ព្រំប្រទល់ភូមិសាស្ត្ររដ្ឋបាលឃុំ ដោយបញ្ជាក់ឱ្យច្បាស់នូវឈ្មោះកម្មសិទ្ធិករម្នាក់ៗ។

**មាត្រា២១០**

សៀវភៅចុះកម្មសិទ្ធិអចលនវត្ថុត្រូវចុះ៖

១-ពិពណ៌នាអំពីក្បាលដី

២-អត្រានុកូលដ្ឋានកម្មសិទ្ធិករ

៣-ការផ្លាស់ប្តូរ

៤-សេចក្តីយល់ឃើញផ្សេងៗ

**មាត្រា២១១**

សៀវភៅចុះភោគៈអចលនវត្ថុត្រូវធ្វើតាមឃុំនូវដីភោគៈ ក្នុងរង្វង់ព្រំប្រទល់ភូមិសាស្ត្ររដ្ឋបាលឃុំ ដោយបញ្ជាក់ឱ្យច្បាស់នូវឈ្មោះភោគីម្នាក់ៗ។

**មាត្រា២១២**

សៀវភៅចុះភោគៈអចលនវត្ថុត្រូវចុះ៖

១-លេខរៀងក្នុងសៀវភៅ

២-ក្រឡាផ្ទៃ

៣-ឈ្មោះអ្នកជាប់ព្រំប្រទល់ដី តាមលំដាប់ទិស

៤-ប្រភេទប្រើប្រាស់ដី ដោយបញ្ជាក់អំពីដំណាំ

៥-អត្តសញ្ញាណប័ណ្ណរបស់ភោគី

៦-ការផ្លាស់ប្តូរប្រភពនៃការកាន់កាប់ដី ការបំបែកក្បាលដី ការបញ្ចូលក្បាលដីតាមសន្តតិកម្ម ដោយមានយោងលិខិតជាសំអាង។

**មាត្រា២១៣**

ការចុះចរន្តការក្នុងសៀវភៅចុះកម្មសិទ្ធិអចលនវត្ថុនៅនាយកដ្ឋានសុរិយោដី ត្រូវធ្វើឱ្យបានស្របគ្នាតាមតារាងផ្ទេរ ដែលការិយាល័យសុរិយោដីបញ្ជូនមក។

ការចុះចរន្តការក្នុងសៀវភៅចុះភោគៈអចលនវត្ថុនៅការិយាល័យសុរិយោដី ត្រូវធ្វើឱ្យបានស្របគ្នាតាមការផ្ទេរដែលការិយាល័យភូមិបាលបញ្ជូនមក។

**មាត្រា២១៤**

ក្នុងការដំណើរការដំបូងដែលរដ្ឋយើងមិនទាន់មានប្លង់ក្បាលដី និងឧបករណ៍បច្ចេកទេស រដ្ឋអនុញ្ញាតឱ្យនាយកដ្ឋានសុរិយោដីប្រើប្រាស់សៀវភៅចុះបញ្ជីអចលនវត្ថុដែលបោះពុម្ពហើយ ជា

ជំនួសសៀវភៅចុះកម្មសិទ្ធិអចលនវត្ថុ និងសៀវភៅចុះភោគៈអចលនវត្ថុសិន តែត្រូវចុះដាច់ដោយឡែកពីគ្នា ចំពោះដីកម្មសិទ្ធិ និងដីភោគៈតាមឃុំនីមួយៗ។

**មាត្រា២១៥**

ដែលហៅថាក្បាលដីគឺជាផ្ទៃដីមួយជាក់លាក់ ឋិតនៅក្នុងឃុំតែមួយមិនពុះបំបែកដោយព្រំជាប់មិនដាច់ជារបស់ជនម្នាក់ ឬក្នុងករណីអវិភាគកម្មជារបស់ជនច្រើននាក់ ហើយប្រើប្រាស់ក្នុងរូបភាពតែមួយ។

**មាត្រា២១៦**

ចាត់ទុកជាព្រំជាប់មិនដាច់ដែលនាំឱ្យបំបែកក្បាលដីជាច្រើនក្បាលដីគឺរបង ផ្លូវ ប្រឡាយ និងផ្លូវទឹកដែលមានទទឹងយ៉ាងតិចពីរម៉ែត្រ។

**មាត្រា២១៧**

ផ្លូវថ្នល់ ផ្លូវលំ ថ្នល់ជាតិ ទីតាំងសាធារណៈ ទន្លេ ដៃទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយដែលបណ្តែតក្បូនបាន ឬមិនបាន ប្រឡាយបង្ហូរទឹកចេញចូល មិនអាចចាត់ជាក្បាលដីបានឡើយ គឺត្រូវចាត់ចូលជាសម្បត្តិសាធារណៈទាំងអស់។

## មាតិកាទី៨ អំពីទោសប្បញ្ញត្តិ

**មាត្រា២១៨**

អ្នកអភិរក្សសុរិយោដីមិនត្រូវប្រកែកមិនទទួលពាក្យ ឬចាត់ការយឺត ឬជំទាស់មិនព្រមចុះហត្ថលេខាចារឹកចេញប័ណ្ណសម្គាល់សិទ្ធិ ចម្លងប័ណ្ណសម្គាល់សិទ្ធិ ចំពោះសំណុំពាក្យស្នើទាំងឡាយដែលត្រឹមត្រូវគ្រប់គ្រាន់តាមលក្ខណៈច្បាប់ ត្រូវទទួលទោសរដ្ឋបាល ដោយមិនគិតដល់ព្យសនកម្មដែលបណ្តាលមកពីអំពើរបស់ខ្លួន។

**មាត្រា២១៩**

អ្នកអភិរក្សសុរិយោដីណាដែលធ្វេសប្រហែស ភ្លេចចុះហត្ថលេខាចារឹក ឬលេខាចារឹកខុស ភ្លេចចុះនិទ្ទេសក្នុងសៀវភៅកម្មសិទ្ធិអចលនវត្ថុ ក្នុងសៀវភៅចុះភោគៈអចលនវត្ថុ និងក្នុងប័ណ្ណសម្គាល់សិទ្ធិនូវប្រាតិភោគ ឬបន្ទុកផ្សេងៗនៃអចលនវត្ថុនោះ ត្រូវទទួលទោសរដ្ឋបាល ដោយមិនគិតដល់ព្យសនកម្មដែលបណ្តាលមកពីអំពើរបស់ខ្លួន។

**មាត្រា២២០**

នៅពេលអាជ្ញាធរមានសមត្ថកិច្ចពិនិត្យឃើញថា ព្យសនកម្មនេះពិតជាបណ្តាលមកពីកំហុសរបស់អ្នកអភិរក្ស អ្នកនេះត្រូវចេញតម្លៃខូចខាត និងជំងឺចិត្តដល់សិទ្ធិវន្ត។

**មាត្រា២២១**

ជនណាបានលួចលក់ ឬលួចបញ្ចាំអចលនវត្ថុដោយប្រាប់ថាជាអចលនវត្ថុរបស់ខ្លួននូវអចលនវត្ថុដែលខ្លួនបានដឹងថាមិនមែនជារបស់ខ្លួន ឬដោយប្រាប់ថាអចលនវត្ថុនោះនៅទំនេរ ឥតមានអ្នកណាជាម្ចាស់ទេ ប៉ុន្តែតាមសេចក្តីពិតខ្លួនបានដឹងថាអចលនវត្ថុនោះបានលក់ ឬបញ្ចាំនឹងគេរួចទៅហើយ ជននោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ឆ្នាំ ដល់៥ឆ្នាំ ដោយមិនគិតដល់ព្យសនកម្មដែលបណ្តាលមកពីអំពើរបស់ខ្លួន។

**មាត្រា២២២**

ត្រូវមានទោសដូចមាត្រា២២១ដែរ៖

១-ជនដែលប្រកាសចុះក្នុងសៀវភៅចុះភោគៈអចលនវត្ថុ ឬសៀវភៅចុះកម្មសិទ្ធិអចលនវត្ថុ ក្នុងនាមផ្ទាល់របស់ខ្លួនលើអចលនវត្ថុដែលខ្លួនដឹងថាមិនមែនជារបស់ខ្លួន។

២-ជនដែលប្រកាសចុះបញ្ជីនូវប្រាតិភោគប្រត្យក្សលើប័ណ្ណសម្គាល់សិទ្ធិ ដែលខ្លួនដឹងថាមិនមែនជារបស់ខ្លួន និងជនដែលយល់ព្រមចុះបញ្ជី ដោយដឹងជាមុននូវសភាពការណ៍ខាងលើ។

៣-ជនដែលនៅពេលកសាងប័ណ្ណសម្គាល់សិទ្ធិ ពុំបានប្រកាសឱ្យចុះនូវប្រាតិភោគ និងបន្ទុកនៃអចលនវត្ថុរបស់ខ្លួនដោយចេតនា។

៤-ជនណាក៏ដោយដែលបានភូតកុហក ចុះកិច្ចសន្យាជាមួយតតិយជនលើអចលនវត្ថុ។

**មាត្រា២២៣**

ភ្នាក់ងារមានសមត្ថកិច្ចដែលបានចូលរួមគំនិតក្នុងការតាក់តែងលិខិត លួចអចលនវត្ថុដូចមានចែងក្នុងមាត្រា២២១ និង២២២នៃច្បាប់នេះ ត្រូវចាត់ទុកជាអ្នកសមគំនិត។

អ្នកសមគំនិតត្រូវផ្តន្ទាទោសដូចគ្នានឹងអ្នកផ្តើមគំនិតដែរ។

**មាត្រា២២៤**

ជនណាដែលបានកាន់កាប់ដីគ្រប់ប្រភេទ ហើយមិនបានមកប្រកាសចុះបញ្ជីអចលនវត្ថុក្នុងរយៈពេល៣ខែ ត្រូវពិន័យឱ្យបង់ពន្ធអាករ និងបន្ទុកផ្សេងៗលើអចលនវត្ថុនោះ គិតចាប់ពីថ្ងៃ

ដែលច្បាប់ភូមិបាលនេះចូលជាធរមាន។ បើនៅតែមិនព្រមមកប្រកាសក្នុងរយៈពេល៥ឆ្នាំក្រោយមកទៀត ដីនេះនឹងត្រូវធ្លាក់មកជាសម្បត្តិឯកជននៃរដ្ឋ។

**មាត្រា២២៥**

ជនណាដែលធ្វើឱ្យរាំងស្ទះនូវការប្រកាសដីធ្លី ត្រូវផ្តន្ទាទោសរដ្ឋបាល បើមិនរាងចាលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ខែ ដល់១ឆ្នាំ។

**មាត្រា២២៦**

ជនណាជំទាស់ ឬធ្វើឱ្យរាំងស្ទះនូវកិច្ចការវាស់វែងលើផ្ទៃដី ការដាំបង្គោលស៊ីម៉ងត៍ដៅចំណុច ការតាំងទីផ្លាកសុរិយោដី ទោះជាបណ្តោះអាសន្នក្តី ឬស្ថាពរក្តីត្រូវព្រមាន។ បើមិនរាងចាលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ខែ ដល់១ឆ្នាំ។

**មាត្រា២២៧**

ជនណាលើកចេញ ឬរំកិលបង្គោលស៊ីម៉ងត៍ដៅចំណុច និងទីតាំងផ្លាកសញ្ញាសុរិយោដីនឹងត្រូវព្រមាន។ បើមិនរាងចាល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ខែ ដល់១ឆ្នាំ ដោយមិនគិតដល់ការខូចខាតដែលបណ្តាលមកពីអំពើរបស់ខ្លួន។

ច្បាប់នេះ រដ្ឋសភានៃរដ្ឋកម្ពុជាបានអនុម័តនៅថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩២
នាសម័យប្រជុំសាមញ្ញលើកទី២៣ នីតិកាលទី១។

ភ្នំពេញ ថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩២

**ជ.រដ្ឋសភា**

**ប្រធាន**

**ហត្ថលេខា និងត្រា**

**ជា ស៊ីម**

# សទ្ទានុក្រម
LEXIQUE

## ក . ខ . គ

<u>កតិកាភេទ</u> (Rescision) កិរិយាបដិសេធកិច្ចសន្យាណាមួយដោយមកពីកិច្ចសន្យានោះមានវិការៈដល់ឫសគល់នៃការព្រមព្រៀង។ ក្នុងទីនេះ កតិកាភេទ បានន័យថា បដិសេធនៃកិច្ចសន្យាលក់ចោល ដោយមកពីលក់វត្ថុណាមួយថោកជាងពាក់កណ្តាលថ្លៃមែនទែន។

<u>ការជម្រះមតិក</u> (Liquidation des successions) កិរិយាធ្វើបញ្ជីទ្រព្យសម្បត្តិរបស់ខ្មោច ឱ្យដឹងថានៅសល់ប៉ុន្មាន បាត់ប៉ុន្មាន ដើម្បីនឹងចែកគ្នារវាងទាយាទ និងទាយាទ។

<u>កាត់កាល់</u> (Exhereder)) បដិសេធជនណាម្នាក់ ឬច្រើននាក់មិនឱ្យមានសិទ្ធិទទួលមតិកនៃខ្មោច។

<u>កាយវិកលកម្ម</u> (Mutillation) ការធ្វើឱ្យបាត់បង់ ឬពិការនូវអវយវៈណាមួយនៃកាយ។

<u>ការទូទាត់</u> (Compensation) ការយកចំណេញមកបំពេញការខាត។ ក្នុងច្បាប់ ជនពីរនាក់មានជំពាក់កាតព្វកិច្ចគ្នាទៅវិញទៅមក ហើយកាត់កងគ្នាមិនឱ្យជំពាក់គ្នាទៅវិញទៅមក។ ឧ. ឈ្មោះ "ក" ជំពាក់តុងទីនឈ្មោះ "ខ" ពីរម៉ឺនរៀល ក៏ប៉ុន្តែឈ្មោះ "ខ" ត្រូវនៅជំពាក់ការសង់ផ្ទះឱ្យឈ្មោះ "ក" ដែរ។ លុះអ្នកទាំងពីរនាក់នេះគិតឃើញថា បំណុលខ្លួនល្មមកាត់កងគ្នាបាន ក៏សុខចិត្តព្រមទូទាត់គ្នា មិនឱ្យជំពាក់គ្នាទៅវិញទៅមក។

<u>ការ្យ</u> (Ouvrage) ផលអ្វីទាំងពួងដែលកើតមកពីស្នាដៃជាង ឬពីស្នាដៃសិល្បករ។ ឧ. តុ ទូ ជាការ្យរបស់ជាង ឯប្រលោមលោកជាការ្យរបស់អ្នកនិពន្ធ។

<u>កើយ</u> (Balcon) រានហាលតូចគ្មានសសរទ្រពីក្រោមទេ តែមានបង្កាន់ដៃព័ទ្ធជុំវិញ។

<u>កោសលវិច័យ</u> (Expertise) សេចក្តីរាយការណ៍របស់អ្នកជំនាញការ ដែលតុលាការ ឬចៅក្រមចាត់ឱ្យធ្វើ។

<u>កម្សាប់ព្រលឹង</u> (Indemniser) ឱ្យសំណូកចិត្ត ឬសងសោហ៊ុយដែលខូចខាត។

<u>កំដឹង ឬកូនបំណុល</u> (Débiteur) ជនអ្នកជំពាក់ប្រាក់ ឬជំពាក់កាតព្វកិច្ចគេ។ បុរាណច្រើនប្រើពាក្យកំដឹងនេះ ជាមួយនឹងពាក្យកំដរ។ ឧ. អ្នកឯងជាកំដឹង ឬជាកំដរគេ។

<u>កំណត់ដៃ</u> (Extrait) សេចក្តីស្រង់ ឬលិខិតដែលចម្លងយកតែសេចក្តីសំខាន់ពីអត្ថបទ ឬពីលិខិតណាមួយ។ ឧ. កំណត់ដៃបញ្ជីជាតិ។

កំពែង (Cloture) គូ ស្នាមភ្លោះ របង ភ្លឺស្រែ . . . ។

ក្រាន (Foyer) សម័យបុរាណកន្លែងដែលគេដុតភ្លើងសម្រាប់អាំង ឬសម្រាប់ចំអិនអាហារនៃគ្រួសារ សម័យឥឡូវនេះ កន្លែងជាទីនៅនៃគ្រួសារ ។

ខ័យសក្តិ (Forclusion) ការអស់ទៅនៃសិទ្ធិប្តឹងផ្តល់ដល់តុលាការ ដោយហេតុថា រយៈវេលាដែលច្បាប់ឱ្យអំណាចប្តឹងបាននោះកន្លងផុតអស់ទៅ ។

ខ្ទាត់ (Frais de justice) ប្រាក់ប្រដាប់ក្តី

គណនី (Comptes) ការវាយតម្លៃនៃចំនួនអ្វីមួយ ។ បញ្ជីដែលកត់បំណុល ឬដែលកត់សំណង ។

គំហាត់ "ជន" (Interdit) កិរិយាឃាត់មិនឱ្យធ្វើអ្វីមួយ ។ ជនគំហាត់ គឺជនមានសតិប្រាជ្ញាទន់ខ្សោយល្ងីល្ងើ ឬមានទោសខាងអាជ្ញាដែលច្បាប់អាជ្ញា ឬច្បាប់ស៊ីវិលឃាត់មិនឱ្យមានសេរីភាពក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិខ្លួន ។

### ច . ឆ . ជ

ចាត់តាំង (Désigner) ជ្រើសរើសជនណាម្នាក់ ហើយបញ្ជាឱ្យកាន់កាប់មុខការ ឬមុខងារណាមួយ ។

ឆន្ទានុសិទ្ធិ (Pouvoir discrétionnaire) អំណាចដែលប្រគល់ដល់ចៅក្រម ឱ្យរើសយកមធ្យោបាយណាមួយតាមចិត្តខ្លួន មកដោះស្រាយបញ្ហាណាមួយ ។

ជនតា (Génération) ពួកជនដែលកើតមួយជំនាន់ៗ ។

ជីវព្រឹត្តិ (Subsistance) អាហារ ម្ហូបចំណី សម្លៀកបំពាក់

### ដ

ដំណុះ "សិទ្ធិ" (Droit d'accession) អ្វីៗដែលដុះ ដែលកើតពីវត្ថុអ្វីមួយ ។ សិទ្ធិដំណុះ សិទ្ធិលើអ្វីៗទាំងពួងដែលដុះ ឬដែលកើតអំពីវត្ថុ ឬអំពីសត្វដែលជាទ្រព្យរបស់ខ្លួន ។ ឧ. ម្ចាស់មេគោត្រូវបានកូនគោដែលកើតអំពីមេគោខ្លួន ។ សិទ្ធិរបស់ម្ចាស់ដី ម្ចាស់គោនោះហៅថា "សិទ្ធិដំណុះ" . . . ។

### ត . ថ . ទ . ធ . ន

តក្កកម្ម (Invention) កិរិយាបង្កើតវត្ថុមួយថ្មីមុនអ្នកទាំងពួង ។ អ្នកដែលបង្កើតម៉ាស៊ីនដេរមុនគេឈ្មោះ ធីម៉ុន្នីអេ ដូច្នេះម៉ាស៊ីនដេរជា តក្កកម្មរបស់ធីម៉ុន្នីអេ ។

តតិយជន (Tiers, Tierce) ជនទីបី ឬភាគីទីបីក្នុងរឿង ។ អ្នកដទៃ ឬអ្នកក្រៅ ។ ឧ. អ្នកលក់ និងអ្នកទិញជាភាគីទី១ និងទី២ ក្នុងការលក់នេះដែរ ហៅថាតតិយជន ។

<u>តាវកាលិក</u> (Prestation) វត្ថុជាទីតាំងនៃកាតព្វកិច្ចណាមួយ។ ឧ. ស្រូវដែលជនម្នាក់ខ្ចីពីជនម្នាក់ទៀត ហៅថាតាវកាលិកនៃការខ្ចី។

<u>តិថិ</u> (Quantum) ចំនួនថ្ងៃ ខែ ឬឆ្នាំដែលវិលមកជួបគ្នាវិញ។ ឧ. ពីថ្ងៃទី៧រោច ខែចែត្រ មកដល់ថ្ងៃ៧រោជ ខែពិសាខ ហៅថាតិថិ។

<u>តែងតាំង</u> (Nommer) ឱ្យមុខការ ឱ្យគុណភាព។ ឧ. ឈ្មោះ "ក" បានតែងតាំងឈ្មោះ "ខ" ជាទាយាទរបស់ខ្លួន។

<u>ថ្លស់សញ្ជាតិ</u> (Dechéance de la nationalité) លែងឱ្យបានសញ្ជាតិដែលបានហើយតទៅទៀត ដកហូតយកសញ្ជាតិមកវិញ។

<u>ទណ្ឌិត</u> (Condamné) ជនដែលតុលាការបានដាក់ទណ្ឌកម្មរួចហើយ។ ជនដែលកំពុងរងទណ្ឌកម្មរបស់តុលាការ។

<u>ទាយាទ</u> (Héritier) អ្នកដែលច្បាប់តម្រូវឱ្យទទួលមតិកពីជនណាម្នាក់។ ឧ. កូនជាទាយាទរបស់ឪពុក ម្ដាយ ជីដូន ជីតា ជាទាយាទរបស់ចៅដែលឥតមានបច្ឆាញាតិជាតំណវង្ស។

<u>ទាសភាព</u> (Esclavage) ភាពជាខ្ញុំបម្រើគេ។

<u>ទាស់មុខស្នេន៍</u> (Inceste) យកញាតឯកដែលច្បាប់ហាមមកធ្វើជាប្ដី ឬជាប្រពន្ធ។ ឧ. មា យកក្មួយធ្វើជាប្រពន្ធ ហៅថា ទាស់មុខស្នេន៍។

<u>ទិដ្ឋាការ</u> (Visa) ហត្ថលេខា ត្រាដែលបានចុះ បានបោះលើលិខិតណាមួយដើម្បីឱ្យលិខិតនោះមានតម្លៃពេញលក្ខណៈច្បាប់ ឬដើម្បីបញ្ជាក់ថា ម្ចាស់លិខិតនោះបានបង់ពន្ធរួចហើយ។

<u>ទុរាចារ</u> (Indonduite) ការប្រព្រឹត្តតែអំពើអាក្រក់ អបាយមុខ។

<u>ធនលាភ</u> (Rente) ផលដែលផ្ដល់មកឱ្យរាល់ឆ្នាំ ដូចជាការប្រាក់ ឈ្នួលដី ឈ្នួលផ្ទះជាដើម។

<u>ធម្មានុរូប</u> (Légitime) ដែលមានគុណភាពជាអ្វីមួយតាមច្បាប់។ ចៅហ្វាយស្រុក ជាអាជ្ញាធរធម្មានុរូប។ កូនដែលកើតពីឪពុកម្ដាយមានខាន់ស្លា ហៅថាកូនធម្មានុរូប ឬកូនមានខាន់ស្លា។

<u>ធម្មានុរូបកម្ម</u> (Légitimation) ការធ្វើជនគ្មានគុណភាពតាមច្បាប់ ឱ្យជាជនមានគុណភាពបរិបូណ៌តាមច្បាប់។ ការធ្វើកូនឥតខាន់ស្លាឱ្យជាកូនមានខាន់ស្លា ហៅថាធម្មានុរូបកម្ម។

<u>នវកម្ម</u> (Novation) ការបង្កើតកាតព្វកិច្ចមួយថ្មី ដើម្បីយកទៅជំនួសកាតព្វកិច្ចចាស់។ ឧ. ការយកស្រែស្លែងទៅដាក់បញ្ចាំជំនួសស្រែទួល ដែលបញ្ចាំបីថ្ងៃមុន ហៅថានវកម្ម។

<u>និទ្ទេស</u> (Mention) សេចក្តីដែលចុះដោយសង្ខេបនៅលើរឹមទំព័រ ឬនៅខាងចុងទំព័រនៃលិខិតណាមួយ ។

<u>និរាករ</u> (Abroger) លប់ចោល លែងឱ្យប្រើច្បាប់នោះតទៅទៀត ។

<u>នីតិបុគ្គល</u> (Personne morale) ក្រុមនៃមនុស្សដែលច្បាប់ទទួលស្គាល់ថា ជាបុគ្គលដែរ តែដទៃអំពីសមាជិកនៃខ្លួន ។ ឧ. ពុទ្ធិកសមាគមជានីតិបុគ្គល ក្រុមហ៊ុនធ្វើស្ករ ក៏ជានីតិបុគ្គលដែរ ។

<u>នីតិភាព</u> (Majorité) អាយុដែលច្បាប់បើកឱ្យមានសិទ្ធិពេញលេញបរិបូណ៌ ។ ឧ. នៅប្រទេសកម្ពុជាអាយុដែលត្រូវទុកជាអនីតិភាពគឺ២១ឆ្នាំ ។

<u>នីតិវិធី</u> (Procédure) វិធីដែលតុលាការប្រើប្រាស់ដើម្បីចាត់ចែងរឿងក្តីតាំងពីដើមរហូតដល់ចប់ ។

<u>នីតិសម្បទា</u> (Habilité) សមត្ថភាពដែលច្បាប់បើកឱ្យជនម្នាក់ៗ មានយ៉ាងគ្រប់គ្រាន់ ដើម្បីនឹងធ្វើកិច្ចការអ្វីមួយ ។ ឧ. ស្នងការប៉ូលីស មាននីតិសម្បទានឹងធ្វើកំណត់ហេតុ អំពីបទល្មើសជាលហុកេតមានក្នុងតំបន់របស់ខ្លួន ។ ឧ. ជនអភ័ព្វមិនមាននីតិសម្បទានឹងទទួលមតិកពីឪពុកម្តាយឡើយ ។

**ប . ផ . ព . ភ . ម**

<u>បច្ឆាញាតិ ឬបច្ឆាជន</u> (Descendants) ជន ឬពួកជនដែលកើតក្រោយ ជនមួយពួកទៀត ឧ. កូនបច្ឆាជនរបស់ឪពុកម្តាយ ។

<u>បញ្ជិកាអ៊ីម៉ាទ្រីគុឡាយស្យុង</u> (Régistre immatriculation) សៀវភៅបញ្ជីរបស់ក្រសួងសុរិ-យោដីសម្រាប់កត់ត្រាដីកម្មសិទ្ធិ ។

<u>ប័ណ្ណ</u> (Titre) លិខិតដែលមានរូបមន្តយថាភូត "ដែលមានរូបភាព និងទម្រង់ត្រឹមត្រូវតាមច្បាប់" សម្រាប់បញ្ជាក់អំពីសិទ្ធិណាមួយ ។ ឧទាហរណ៍ដែលអ្នកផងទាំងពួងហៅថា សន្លឹកផែនទី នោះជាប័ណ្ណកម្មសិទ្ធិ ។

<u>ប័ណ្ណសារដ្ឋាន</u> (Archive) ទីសម្រាប់តម្កល់លិខិតផ្សេងៗ ដែលមានសារៈសំខាន់ដូចបញ្ជីអត្រានុ-កូលដ្ឋានជាដើម ។

<u>បន្ទុក, ភារៈ ឬធុរៈ</u> (Charges) មុខការ, មុខងារ, អាណត្តិ, ប្រតិកម្មដែលជនណាម្នាក់ធ្វើ ឬបំពេញ ។

<u>បរិវត្ត "រូបមន្ត"</u> (Formule exécutoire) រូបមន្តដែលមានសេចក្តីថាឱ្យយកទៅសម្រេចបាន ។

បាលិត (Pupille) កូនកំព្រាជាអនីតិជនដែលឋិតនៅក្រោមអាណាព្យាបាលនៃជនណាម្នាក់។

បិតុភាព (Paternité) ក្រសែញាតិដែលទាក់ទងពីឪពុកម្ដាយទៅកូន។

បុត្តភាព (Filiation) ក្រសែញាតិដែលទាក់ទងពីឪពុកម្ដាយទៅកូនបង្កើតរបស់ខ្លួន។

បុព្វញាតិ (Ascendants) ពួកជនដែលកើតមុនជនមួយពួកទៀត។ ឧ. ឪពុក ម្ដាយ ជីដូន ជីតា . . . ។ល។ . . . ជាបុព្វញាតិរបស់កូនចៅ . . . ។

បុរិមា (Préférence) សេចក្ដីរាប់អាន ជននេះច្រើនជាងជននោះ។ សិទ្ធិដែលបើកឱ្យជនណាម្នាក់បានអ្វីមួយមុនជនឯទៀត។

បេតិកភណ្ឌ (Patrimoine) ទ្រព្យដែលជនម្នាក់ៗបាន និងបំណុលដែលជនម្នាក់ៗជំពាក់គេ។ ទាំងទ្រព្យ ទាំងបំណុលរបស់ជនម្នាក់ៗហៅថាបេតិកភណ្ឌ។

ប្រកាសនៈ (Publicité) កិរិយាប្រកាសឱ្យសាធារណជនបានដឹង ឬដោយវាចារ ឬដោយលិខិតជាលាយលក្ខណ៍អក្សរ។

ប្រតិសកម្ម (Rétroactivité) ការដែលមានអានុភាពបកទៅអតីតកាលវិញ។

ប្រធាន (Principal) ដែលធំ ដែលសំខាន់ជាងគេ ដែលជាមេលើគេ។

ប្រវត្តិកាល (Période) រដូវ ពេលវេលាដែលប្រព្រឹត្តទៅក្នុងមួយរយៈ។ ពាក្យសាមញ្ញច្រើននិយាយថា "សម័យ"។ សម័យដែលខ្មែររីកចម្រើនរុងរឿង ឬប្រវត្តិកាលនៃខ្មែររុងរឿង។

ប្រាតិភោគប្រត្យក្ស (Sureté) ការយកទ្រព្យទៅធានាបំណុល។ ពាក្យបុរាណថា កំជាប់ដោយវត្ថុ។ ឧ. ការបញ្ចាំស្រែជាប្រាតិភោគប្រត្យក្សអចលនវត្ថុ។ ការបញ្ចាំខ្សែមាស ជាប្រាតិភោគប្រត្យក្សចលនវត្ថុ។

ផលចម្រូត (Récolte) ផលដែលច្រូត បេះ ប្រលេះ ដកពីដើមមក។

ផលទុន (Revenu) ផល ឬចំណេញដែលកើតមកពីប្រាក់ទុន ឬពីផលមូលនិធិដែលគេយកទៅប្រកបមុខរបរណាមួយ។

ផលធម្មជាតិ (Fruit naturel) ផលិតផលដែលកើតអំពីដីធ្លី ឬកូនសត្វស្រុកដែលកើតពីមេបាវាមក។

ផលស៊ីវិល (Fruit civil) ប្រាក់ដែលបានមកពីវត្ថុ ឬពីប្រាក់ ដូចជាការប្រាក់ ឬឈ្នួលផ្ទះជាដើម។

ផលុបភោគ (Usufruit) សិទ្ធិបរិភោគ និងប្រើប្រាស់ផល និងផលទុនដែលកើតមកពីទ្រព្យជាកម្មសិទ្ធិអ្នកដទៃ។ ឧ. ឈ្មោះ "ក" បានឱ្យស្រែមួយកន្លែងជាកម្មសិទ្ធិរបស់ខ្លួនទៅឈ្មោះ "ខ" ធ្វើយកផលចិញ្ចឹមជីវិតអស់មួយជីវិតក្ដី អស់កាលមានកំណត់ក្ដី ឥតយកឈ្នួលទេ ប៉ុន្តែដីនោះនៅជាដីរបស់ឈ្មោះ "ក" ដដែល។ សិទ្ធិដែល "ក" បើកឱ្យ "ខ" បរិភោគផលដីរបស់ខ្លួននោះហៅថាផលុបភោគ។ "ខ" គឺជាផលុបភោគី ហើយ "ក" ជាអសារកម្មសិទ្ធិករ។

ផលុបភោគី (Usufruitier) អ្នកបាននូវផលុបភោគ អ្នកស៊ីផល។

ព្យសនកម្ម (Préjudice) ការខូចខាត ឬសេចក្ដីវិនាសអន្តរាយដល់រូបកាយក្ដី ដល់សម្ភារៈក្ដី ដល់ទឹកចិត្តក្ដី ដែលបណ្ដាលមកពីអំពើនៃអ្នកដទៃ។

ព្យាកុលភាព (Confusion) ភាពច្រឡំច្របូកច្របល់គ្នា។ ក្នុងទីនេះ ព្យាកុលភាពបានន័យថា មនុស្សម្នាក់ជាកូនបំណុលផង ជាម្ចាស់បំណុលផងនៃជនតែម្នាក់។

ព្រឹត្តិការណ៍ (Evènement) អ្វីៗដែលកើតមានឡើង ឬដែលប្រព្រឹត្តទៅ។ ឧ. សង្គ្រាមរវាងអារ៉ាប់និងអ៊ីស្រាអែលនាបច្ចុប្បន្នគឺជាព្រឹត្តិការណ៍មួយគួរឱ្យចង់ដឹង។

ភាគី (Partie) គូក្ដី គូសញ្ញា ជនម្ខាងៗនៃកិច្ចសន្យា។

ភោគៈ (Possession) សិទ្ធិដែលជនម្នាក់ៗមានលើទ្រព្យណាមួយជាបណ្ដោះអាសន្ន មិនទាន់ស៊ីបជារបស់ខ្លួន។ "ភោគៈ" ជាពាក្យផ្ទុយនឹងកម្មសិទ្ធិដែលជាសិទ្ធិពេញបរិបូណ៌របស់ជនម្នាក់លើទ្រព្យណាមួយ។ ឧ. ដីផែនទីជាកម្មសិទ្ធិ ឯដីគ្មានផែនទីគឺជាដីដែលមានតែចុងសន្លឹក ជាដីភោគៈ។

មជ្ឈមណ្ឌល (Centre) ទីធ្លាកណ្ដាល។ ទីកន្លែងដែលជាប្រធាននៃកិច្ចការទាំងពួង។

មធ្យោបាយ (Moeyn) អ្វីដែលជាគ្រឿងសម្រាប់យកទៅស្រាយកិច្ចការ ឬបញ្ហាណាមួយ។

មាតិកភណ្ឌ (Matrimonial) អ្វីៗ ឬទ្រព្យដែលទាក់ទងក្នុងពេលអាពាហ៍ពិពាហ៍។

មូលសាស្ត្រ ឬគោលច្បាប់ (Principe) គំនិតដើមដែលគួរសន្និដ្ឋានថា ជាមូលដ្ឋាននៃច្បាប់។

## យ . រ . ល . វ

យ៉ (Saillie) ចំណែកផ្ទះដែលចេញពីជញ្ជាំងទៅខាងមុខ។

រដ្ឋវាសី (Minorité ethnique) រាស្ត្រភាគតិចដែលមានអម្បូរខុសពីរាស្ត្រភាគច្រើនក្នុងរដ្ឋ ឬក្នុងប្រទេសណាមួយ។ ឧ. ខ្មែរឥស្លាមជារដ្ឋវាសីនៃប្រទេសកម្ពុជា។

រូបមន្ត (Formalité) ការងារដែលត្រូវបំពេញឱ្យមានរូបតាមច្បាប់របស់តុលាការ ។

រូបវន្តបុគ្គល (Personne physique) បុគ្គលដែលមានរូបមែនៗគឺមនុស្សមែនៗ ផ្ទុយនឹងនីតិបុគ្គលដែលជាមនុស្សដោយសន្មតតាមរបៀបច្បាប់ ។

លោកចរិយាធម៌ (Bonnes moeurs) កិរិយាប្រព្រឹត្ត ឬទម្លាប់របស់មនុស្សម្នាក់ៗនៅតាមទំនៀមឬច្បាប់របស់ប្រទេសមួយៗ ។

លោហិត "ញាតិ" (Lien de parenté) ញាតិដែលជាប់ពីកំណើតមក ដូចជាឪពុក និងកូនជាដើម ។ ពាក្យនេះផ្ទុយនឹងញាតិពន្ធ ដែលជាញាតិសាច់ថ្លៃ ។

ល័ក្ខខ័ណ្ឌ (Conditions) តុលភាពដែលត្រូវមាន ឬខដែលត្រូវបំពេញឱ្យគ្រប់ចំនួន ដើម្បីឱ្យបានសម្រេចបំណងណាមួយ ។ ឧ. មនុស្សប្រុស ស្រីដែលចង់ការគ្នាជាប្តី ប្រពន្ធត្រូវមានល័ក្ខខ័ណ្ឌច្រើនយ៉ាង ដូចមានសំដែងក្នុងមាត្រា១១៤ ដល់១៤៧នៃក្រមរដ្ឋប្បវេណី ។

លក្ខណៈ (Caractère) ភិនភាគ ឬកពារ កិរិយា បែបបទ ។

លទ្ធកម្ម (Acquisition) ការបានឡើងជាភោគី ឬជាកម្មសិទ្ធិករនៃវត្ថុណាមួយ ដោយការងាររបស់ខ្លួនក្តី ដោយទិញក្តី ដោយដូរក្តី ដោយសន្តតិកម្មក្តី ។

លិខិតបញ្ជាក់ (Acte certifié) លិខិតដែលមេឃុំ ឬចៅហ្វាយស្រុក បានសូត្រខ្លាំងៗ ច្បាស់ៗ ឱ្យគូភាគីស្តាប់ ហើយចុះហត្ថលេខាខ្លួន ជាមួយនឹងគូភាគីលើលិខិតនោះ ។

លិខិតយថាភូត (Acte authentique) លិខិតធ្វើតាមរូបមន្តនៃច្បាប់ ដូចជាលិខិតបញ្ជាក់ជាដើម ។

វិធវភាព (Viduite) ភាពទំនេរ ភាពមេម៉ាយ

វិធាន (Règle) មូលសាស្ត្រ ច្បាប់ បន្ទាត់ ។

វិធានការ (Mesure) មធ្យោបាយ សេចក្តីប្រយ័ត្ន ស្មៀត ។

វិនិច្ឆ័យ (Justiciable) អ្នកដែលមានសិទ្ធិឱ្យតុលាការជំនុំជម្រះឱ្យ ។

វិភេទ (Altération) ការកែប្រែសារជាតិនៃវត្ថុណាមួយ ឱ្យខុសចាកន័យ តម្លៃ ទិសដៅដើមរបស់វា ដើម្បីឱ្យមានព្យសនកម្មណាមួយ ។

វិសាលភាពនៃអាណត្តិ (Etendue du mandat) វិសាលភាព ភាពទូលំទូលាយ ។ វិសាលភាពនៃអាណត្តិ អំណាចនៃអាណត្តិ ។

វិហិង្សា (Violence) សេចក្តីឃោរឃៅ ។

## ស . ហ

សញ្ជាតូបនីយកម្ម (Naturalisation) ការធ្វើឱ្យជនបរទេសបាននូវសញ្ជាតិនៃប្រទេស ដែលជននោះនៅ ។ ការសុំចូលជាតិ ។

សតិសានុញ្ញាត (Homologation) សេចក្តីយល់ព្រមរបស់អាជ្ញាធររដ្ឋបាល ឬអាជ្ញាធរតុលាការចំពោះលិខិតណាមួយដែលត្រូវធ្វើតាមច្បាប់ ។

សន្តតិកម្ម (Succession) ការបញ្ជូនតាមច្បាប់នូវទ្រព្យរបស់អ្នកស្លាប់ឱ្យទៅអ្នករស់ ។ មតិក ឬទ្រព្យរបស់ខ្មោចដែលត្រូវបានទៅទាយាទ ។

សមគ្គសង្វាស (Union) ការរួមរស់នៅរបស់ប្តីប្រពន្ធ ។

សមត្ថកិច្ច (Compétence) សិទ្ធិរបស់តុលាការដែលមាន ដើម្បីជំនុំជម្រះរឿងក្តីណាមួយ ។

សម្បត្តិសាធារណៈនៃសមូហភាពរាជការ (Domaine pulic des collectivités administratives) ទ្រព្យដែលត្រូវរក្សាឱ្យគង់រូប តាមធម្មជាតិរបស់វា ដើម្បីទុកឱ្យអ្នករួមសង្គម ប្រើប្រាស់ជាអង្វែងទៅ ដូចជាស្ពាន ថ្នល់ . . .។ល។ ទ្រព្យទាំងអស់នេះ គង់នៅជាសាធារណប្រយោជន៍ ដរាបណាអ្នកផងនឹងលក់ នឹងដូរមិនបានជាដាច់ខាតដរាបនោះ ។

សម្បត្តិឯកជននៃសមូហភាព (Domaine privé des collectivités) ទ្រព្យរបស់សង្គមណាមួយដែលមិនសម្រាប់ឱ្យជនក្នុងសង្គមនោះ ប្រើប្រាស់ជាសាធារណៈទូទៅទេ ជាសម្បត្តិដែលសង្គមអាចលក់ ដូរ ជួល ពាត់ ឱ្យទៅអ្នកដទៃយកទៅឱ្យធ្វើជាទ្រព្យរបស់ខ្លួនបាន ។ ដូចជាដីក្រុងភ្នំពេញ ដែលជនជាតិខ្មែរម្នាក់ៗអាចជួល ឬទិញពីរាជការក្រុង មកសង់ផ្ទះបាន ។

សម្បទាន (Concession) ទ្រព្យដែលគេទិញ ឬសុំដាច់ពីរដ្ឋមកធ្វើជាទ្រព្យរបស់គេ ។

សមាមាត្រ (Proportion) ការ ឬរបស់អ្វីមួយដែលសម ដែលល្មមនឹងការ ឬរបស់មួយទៀត ។ ឧ. ទណ្ឌកម្មដែលតុលាការបានផ្តន្ទានេះមានសមាមាត្រនឹងអំពើដែលជននោះបានប្រព្រឹត្តហើយ គឺថាសមរម្យនឹងអំពើនោះហើយ ។

សមូហភាព (Collectivité) ជនទាំងឡាយដែលមករួមគ្នាជាក្រុម ឬជាសម្ព័ន្ធមួយ ។ មនុស្សទាំងអស់ក្នុងឃុំ ឬក្នុងស្រុក ឬក្នុងក្រុងណាមួយ ហៅថាសមូហភាព ។

*វាយឡើងវិញ*

សវនាការ (Audience) ពេល ឬកន្លែងដែលតុលាការជំនុំជម្រះក្ដី។ បុរាណពីដើមហោថា ក្រឡាក្រម។

សហកម្មសិទ្ធិ (Co-propriété) កម្មសិទ្ធិតែមួយជារបស់ជនច្រើននាក់។ ឧ. ជនច្រើននាក់រួបរួមទិញរថយន្តមួយ។ រថយន្តនោះជាសហកម្មសិទ្ធិរបស់ជនទាំងឡាយដែលទិញនោះ។

សហកម្មសិទ្ធិករ (Co-propriétaire) អ្នកដែលមានសហកម្មសិទ្ធិ។

សហគមន៍ (Communauté) អ្វីៗដែលជនទាំងឡាយយកមករួមគ្នា។ ទ្រព្យសហគមន៍ គឺទ្រព្យដែលប្ដី ប្រពន្ធរកបានជាមួយគ្នា។

សហចារី (Co-auteur) អ្នកដែលចូលរួមក្នុងការប្រព្រឹត្តនូវអំពើណាមួយជាអ្នកដៃដល់។

សហទាយាទ (Co-héritier) អ្នកដែលត្រូវចូលរួមក្នុងការចែកមតិកណាមួយ។

សហព័ទ្ធ (Conjoint) ប្ដី ឬប្រពន្ធ ឬទាំងប្ដី ទាំងប្រពន្ធ។

សាទុក្ខ "បណ្ដឹង" (Pourvoi) បណ្ដឹងដែលប្ដឹងដល់សាលាវិនិច្ឆ័យដោយមិនសុខចិត្តនឹងសាលក្រម ឬសាលដីកាណាមួយ។

សារជាតិ (Substance) សម្ភារៈគ្រប់យ៉ាង អ្វីដែលឆ្ងាញ់ពិសា ដែលមានរសជាតិ។

សាលដីកា (Arré) សេចក្ដីសម្រេចរបស់តុលាការជាន់ខ្ពស់ មានសាលាឧទ្ធរណ៍ និងសាលាវិនិច្ឆ័យជាដើម។

សិទ្ធិប្រទាន (Procuration) អំណាចដែលជនម្នាក់ឱ្យទៅជនម្នាក់ទៀត ឱ្យយកទៅប្រើប្រាស់ក្នុងនាមខ្លួន និងជំនួសខ្លួន។

សុពលភាព (Validité) គុណភាពនៃអ្វីៗដែលនៅខ្លាំង នៅមាំ នៅមានតម្លៃថាជារបស់ត្រឹមត្រូវ។

សិទ្ធិវន្ត (Ayant-droit) អ្នកមានសិទ្ធិលើវត្ថុណាមួយ។ ឧ. កាលណាអ្នកបង់ប៉ោកេ មានគ្រោះថ្នាក់ខ្លាំងដល់ស្លាប់ជាដើម សហព័ទ្ធ និងកូនទាំងឡាយដែលនៅក្នុងបន្ទុកនៃអ្នកនោះអាចទារតាវកាលិកពីក្រុមប៉ោកេ ព្រោះខ្លួនមានគុណភាពជាសិទ្ធិវន្ត។

សិលាជាតិ (Carnère) កន្លែងជាទីកើតនៃថ្ម កន្លែងដែលគេជីកយកថ្ម។

សិល្បករ (Artisan) អ្នកធ្វើការ អ្នកបង្កើតផល ដោយដៃដើម្បីជាប្រយោជន៍ខ្លួន ដោយធ្វើតែម្នាក់ឯង ឬក៏មានប្រពន្ធកូនក្នុងគ្រួសារជួយធ្វើផង។

ស្ត ឬស្តបន្ទាល់ (Preuve) អ្វីដែលជាទីតាំង ឬដែលចង្អុលបង្ហាញនូវការពិត នូវសច្ចធម៌នៃវត្ថុណាមួយ ។ ឧ. សាក្សី លិខិតឯកជន លិខិតបញ្ជាក់ទាំងអស់នេះជាស្តបន្ទាល់នៃកាតព្វកិច្ច ។

សេនាធិការក្នុងកងទ័ព (Officier de l'armée) ទាហានដែលមានបណ្ដាសក្តិធំ តាំងពីអនុសេនីយ៍ឯកឡើងទៅ ។

សេវភាព (Servitude) បន្ទុកដែលផ្ទុកលើអចលនវត្ថុម្យ៉ាងដែលហៅថា អចលនវត្ថុបម្រើ ដើម្បីជាប្រយោជន៍ដល់អចលនវត្ថុម្យ៉ាងទៀត ដែលហៅថា អចលនវត្ថុប្រើ ។ ឧ. ស្រែក្រោមមានសេវ-ភាពខាងទទួលទឹកពីស្រែលើ ។ ស្រែក្រោមហៅថា ស្រែបម្រើ ហើយស្រែលើហៅថា ស្រែប្រើ ។

សោធន (Pension) ប្រាក់ដែលគេឱ្យដល់ជនណាម្នាក់ ដើម្បីឱ្យជននោះយកទៅចាយវាយក្នុងការចិញ្ចឹមជីវិត ។

សោធនអាហារណើ (Pension alimentaire) សោធនដែលបើកឱ្យគ្រួសារមានប្រពន្ធ កូនជាដើម ដើម្បីឱ្យយកទៅចិញ្ចឹមជីវិត ។

សំណងចិត្ត (Indemnité) ប្រាក់ដែលឱ្យដើម្បីលុបលាងនូវព្យសនកម្មណាមួយ ។

ស្ថាពរ (Définitif) ដែលសម្រេចរួចស្រេចអស់ហើយ ឥតយកមកជំនុំជម្រះ ឬសម្រេចសេចក្តីទៀត ។

ស្លាកល័ក្ត (Scelle) ស្លាកធ្វើពីក្រដាស ឬធ្វើពីក្រណាត់សំពត់មានបោះត្រា ដែលចៅក្រម ឬស្នងការប៉ូលីសយកទៅបិទដោយកាកល័ក្តនៅទ្វារផ្ទះ ទ្វារទូជាដើម ដើម្បីទុកជាបម្រាមកុំឱ្យបើក ។

ហត្ថលេខី (Signataire) អ្នកចុះហត្ថលេខា អ្នកស៊ីញ៉េ ។

ហិតូបត្ថម្ភកៈ (Curateur) ជនដែលចាត់ឱ្យឃុំគ្រងទ្រព្យរបស់អនីតិជនដែលបានអត្តាធីនភាព ឬរបស់ជនល្ងីល្ងើជាដើម ។

អ

អក្ខរាវិរុទ្ធ (Orthographe) កិរិយាសរសេរនូវពាក្យនៃភាសាណាមួយឱ្យបានត្រឹមត្រូវ ។

អច្ច័យទាន (Legs) សំបុត្របណ្ដាំដែលផ្ដាំឱ្យចែកទ្រព្យមតិកណាមួយឱ្យទៅជនណាម្នាក់ ឬច្រើននាក់ ។

អឡ្ហសិទ្ធិ (Mitoyen) ដែលមានសិទ្ធិពាក់កណ្ដាលម្នាក់ដែលជារបស់ជនពីរនាក់ និងជាព្រំនៃកម្មសិទ្ធិនៃជនទាំងពីរនាក់នោះផង ។ ឧ. ជញ្ជាំងអឡ្ហសិទ្ធិគឺជាជញ្ជាំងរបស់ជនពីរនាក់ដែលមានផ្ទះជាប់គ្នា ។

អឡ្កសិទ្ធិភាព (Mitoyenneté) ភាពដែលជាអឡ្កសិទ្ធិ។ ឧ. អឡ្កសិទ្ធិភាពនៃជញ្ជាំង។

អត្តសញ្ញាណ (Identite) សញ្ញាទាំងអស់នៃជនម្នាក់ៗដែលគ្រឿងសម្គាល់កុំឱ្យភាន់ច្រឡំនឹងជនម្នាក់ទៀត។

អត្តាធីនភាព (Emancipation) ការបើកឱ្យក្មេងដែលនៅក្នុងអនីតិជននៅឡើយគ្រប់គ្រងខ្លួន និងទ្រព្យសម្បត្តិខ្លួនដោយខ្លួនឯង។

អត្ថគាហក (Benéficiare) អ្នកដែលបានចំណេញ ឬបានកម្រៃពីវត្ថុណាមួយពីគុណប្រយោជន៍អ្វីមួយ ឬពីឯកសិទ្ធិណាមួយ។

អត្ថិភាព (Existence) ភាពដែលមាន។ ឧ. អត្ថិភាពនៃព្រះអាទិទេព។ ជីវិ ឧ. អស់អត្ថិភាព អស់ជីវិត។ របៀបរស់នៅ។ ឧ. អត្ថិភាពនៃកសិករ។

អធិលាភ (La plus-value) ការកើនតម្លៃនៃទ្រព្យណាមួយ លើសពីតម្លៃមុន តាមទ្រឹស្តីខ្លះ អធិលាភគឺផលប៉ុន្មានដែលនាយទុនបោកយកពីផលិតករមកដោយទុកឱ្យផលិតករ តែប្រាក់ឈ្នួលបន្តិចបន្តួចល្មមតែរស់ប៉ុណ្ណោះ តាមទ្រឹស្តីទាយទុននិយមប្រាក់ថ្លៃផលិតផលដែលសល់ពីកាត់ប្រាក់ឈ្នួល ផលិតករមកហៅថាអធិលាភ។

អនិយ័ត (Alternative) មិនប្រាកដ។ កាតព្វកិច្ចអនិយ័ត។ ឧ. ដើម្បីឱ្យកាតព្វកិច្ចរបស់ខ្ញុំមួយរលត់ ខ្ញុំត្រូវឱ្យសេះគេប្រាំ ឬឱ្យប្រាក់គេ ១០.០០០៛។ ការសងនេះមិនប្រាកដជាសងសេះ ឬប្រាក់ទេ ស្រេចលើខ្ញុំជាកូនបំណុលរើសសងគេចុះ។ កាតព្វកិច្ចដូចបាននាំឧទាហរណ៍មកនេះហៅថាកាតព្វកិច្ចអនិយ័ត។

អនីតិភាព (Minorité) ភាពនៃបុគ្គលអ្នកមានវ័យក្មេង ដែលច្បាប់ចាត់ទុកថាជាមនុស្សមានសមត្ថភាពមិនទាន់គ្រប់គ្រាន់នឹងទទួលខុសត្រូវក្នុងអំពើ ដែលខ្លួនបានប្រព្រឹត្តនោះទេ។

អភិរក្សសុរិយោដី "របប" (Régime de conseration cadastrale)

អវត្តមាន (Absence) ការមិននៅ មិនឃើញមុខ ឬបាត់ខ្លួនពីលំនៅអស់រយៈពេលជាច្រើនឆ្នាំ។

អវយវភេទ (Démembrement) ការបាត់បែកអវយវៈ។ ក្នុងច្បាប់អវយវភេទ បានន័យថាការផ្ទេរសិទ្ធិខ្លះរបស់ខ្លួន លើកម្មសិទ្ធិណាមួយឱ្យទៅអ្នកដទៃ។

អវិភាគភាព (Indivisibilité) ភាពដែលចែកគ្នាមិនបាន។ ឧ. ផ្ទះមួយជាមតិករបស់កូនប្រាំនាក់ ពុះផ្ទះនោះចែកគ្នា ផ្ទះនោះនឹងអន្តរាយជាមិនខាន។ ដូច្នោះផ្ទះនោះជាមតិកអវិភាគ។

អសមត្ថភាព (Incapacité) ដែលគ្មានសមត្ថភាព ជនអសមត្ថភាពគឺជនដែលគ្មានសមត្ថភាពនឹងរស់នៅ ដោយឥតអាណាព្យាបាលបាននឹងគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួន ដោយខ្លួនឯងកើត ដូចជាអនីតិជនជាដើម។

អសារកម្មសិទ្ធិ (Nu-propriété) កម្មសិទ្ធិដែលឥតឱ្យផលដល់ម្ចាស់កម្មសិទ្ធិទេ ដោយហេតុថាម្ចាស់កម្មសិទ្ធិនោះឱ្យសិទ្ធិខ្លួនទៅអ្នកដទៃស៊ីផលនៃកម្មសិទ្ធិនោះទាំងអស់។

អាឃិវត្ថុ (Chose précieuse) វត្ថុដែលមានតម្លៃច្រើន។

អាជ្ញាធរ (Autorité) អ្នកទ្រទ្រង់អំណាច អ្នករដ្ឋការដែលកាន់អំណាច។

អាជ្ញាយុកាល (Prescription) មធ្យោបាយម្យ៉ាងសម្រាប់ដោះខ្លួនឱ្យរួចផុតពីកាតព្វកិច្ចណាមួយ កាលណាបើម្ចាស់កាតព្វកិច្ចនោះបណ្តែតបណ្តោយឱ្យជំពាក់យូរពេកមិនទារ។

អាហារ-សោធន (Pension-alimentaire) ប្រាក់ដែលជនម្នាក់ឱ្យទៅជនម្នាក់ទៀតដើម្បីចិញ្ចឹមជីវិត។

ឯកសិទ្ធិ (Privilege) អំណាចដែលត្រូវបានទៅជនណាម្នាក់ច្រើនជាងជនឯទៀត។

ឧបាទេសកម្ម (Subrogation) ឧបាទេស ឬផ្ទេរអំណាចខ្លួនជាម្ចាស់បំណុលឱ្យទៅជនម្នាក់ទៀតកាន់ប្រើអំណាចនោះជួសខ្លួន។

ឯកាធិភាព (Monopole) សិទ្ធិធ្វើ ឬលក់របស់អ្វីៗណាមួយដាច់មុខតែឯង អ្នកផងនឹងធ្វើ ឬលក់ផងដែរមិនបាន។

ឱកាសទាន (Exeguatur) ការឱ្យឱកាស ឬបើកដៃឱ្យធ្វើអ្វីមួយ។ បទបញ្ជា ឬសេចក្តីអនុញ្ញាតឱ្យប្រតិបត្តិកិច្ចការអ្វីមួយ។

**រដ្ឋកម្ពុជា**

**ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល**

**ក្រុមប្រឹក្សារដ្ឋមន្ត្រី**

លេខ០៣សរណន

ភ្នំពេញ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩២

## សារាចរណែនាំ

## ស្តីពី

## វិធានការចំពោះសកម្មភាពរំលោភយកដីសាធារណៈ

យោងតាមស្មារតីនៃអង្គប្រជុំកាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩២ នៅទីស្តីការរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ជាមួយលោកនាយករដ្ឋបាលស៊ីវិលនៃអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិ ក្រុមប្រឹក្សារដ្ឋមន្ត្រី សូមធ្វើការណែនាំដល់គណៈកម្មាធិការប្រជាជនគ្រប់ខេត្ត-ក្រុងដូចតទៅ៖ ក្នុងសភាពការណ៍នាពេលបច្ចុប្បន្ន ដែលរដ្ឋាភិបាលនៃរដ្ឋកម្ពុជាយើងកំពុងយកចិត្តទុកដាក់អនុវត្តកិច្ចព្រមព្រៀងទីក្រុងប៉ារីសដើម្បីនាំមកនូវការបង្រួបបង្រួមជាតិ សន្តិភាព ស្ថិរភាពជូនប្រជាជនកម្ពុជា យើងពិនិត្យឃើញថា មានបាតុភាពអសកម្មជាច្រើនបានកើតឡើងនៅក្នុងសង្គមជាតិយើង នៅទីក្រុង ក៏ដូចជានៅតាមខេត្តនានាទូទាំងប្រទេស ដូចជាចោរកម្ម ការឆក់ប្លន់ ឧក្រិដ្ឋកម្ម ហើយជាពិសេសទៅទៀតនោះ មានជនល្មើសមួយចំនួនបានរំលោភចូលទៅបោះបង្គោល ឬសង់សំណង់ក្នុងបរិវេណដីសាធារណៈ ដើម្បីបែងចែកគ្នាកាន់កាប់យកជាកម្មសិទ្ធិរបស់ខ្លួនផ្ទាល់។ បាតុភាពអសកម្មទាំងនេះបានធ្វើឱ្យសង្គមជាតិយើងមានភាពច្របូកច្របល់ ប្រជាជនយើងមានការព្រួយបារម្ភ និងភ័យខ្លាចបាត់លំនឹងក្នុងចិត្ត និងថយជំនឿលើការដឹកនាំដ៏ត្រឹមត្រូវរបស់រដ្ឋាភិបាលនៃរដ្ឋកម្ពុជាយើង មិនតែប៉ុណ្ណោះ ក៏បានបញ្ជាក់ផងដែរថា រដ្ឋអំណាចមូលដ្ឋានរបស់យើងចុះខ្សោយ ពុំមានសមត្ថភាពក្នុងការគ្រប់គ្រងរដ្ឋបាល។

ក្រុមប្រឹក្សារដ្ឋមន្ត្រីបានទទួលព័ត៌មានពិតប្រាកដថា ជនល្មើសដែលរំលោភយកដីសាធារណៈទាំងនោះ មិនមែនជាអ្នកគ្មានផ្ទះសំបែង គ្មានដីធ្លីកាន់កាប់សោះនោះទេគឺភាគច្រើនសុទ្ធសឹងជាអ្នក

ដែលមានលំនៅឋានត្រឹមត្រូវហើយដែរ ប៉ុន្តែគេប្រព្រឹត្តល្មើសដូច្នេះ ដើម្បីធ្វើជារបររកស៊ីរបស់គេ ពីព្រោះកាលណាគេកាន់កាប់បានដីកន្លែងណាមួយហើយ គេនឹងលក់ដីនោះ រួចហើយគេនឹងទៅបន្ត ប្រព្រឹត្តដដែលនៅកន្លែងផ្សេងទៀត។ យើងបានសង្កេតឃើញផងដែរថាអំពើដ៏ខ្មៅកខ្វក់ដូចខាង លើនេះហាក់បីដូចជាមានការចាត់តាំងត្រឹមត្រូវ មានមេបញ្ជាដឹកនាំ និងបំផុសឱ្យធ្វើ ពីព្រោះចលនា តែងកើតឡើងប្រហាក់ប្រហែលគ្នានៅស្ទើរគ្រប់កន្លែង វិធីវិធីដែលគេប្រព្រឹត្តនោះ ក៏មិនខុសប្លែក គ្នាប៉ុន្មានដែរ។ យើងអាចវាយតម្លៃបានថា សកម្មភាពនៃការរំលោភដីសាធារណៈនេះ គឺជាសកម្ម ភាពបម្រើខាងនយោបាយផងដែរ។

ដើម្បីប្រឆាំងចំពោះបទល្មើសដូចខាងលើនេះ ក្រុមប្រឹក្សារដ្ឋមន្ត្រីសូមស្នើគណៈកម្មា ធិការប្រជាជនខេត្ត-ក្រុងថា ជាបឋមត្រូវចាត់តាំងមន្ត្រីរដ្ឋការ ឬអ្នកមុខអ្នកការដែលប្រកបដោយ ប្រជាប្រិយភាព និងត្រូវបានប្រជាជន មហាជនស្រឡាញ់ និងគោរពរាប់អានឱ្យចុះអប់រំ និងពន្យល់ ណែនាំដល់ជនល្មើស ឱ្យគេបានជ្រួតជ្រាបអំពីផលវិបាកទាំងឡាយ ដែលអាចនឹងកើតមានឡើងពី សកម្មភាពផ្ទុយនឹងច្បាប់ដែលគេកំពុងប្រព្រឹត្ត ថានោះគឺជាអំពើមួយនាំមកនូវគ្រោះថ្នាក់ដ៏ធំធេង ចំពោះជាតិ និងប្រជាជនកម្ពុជាយើង ជាពិសេសក្នុងដំណាក់កាលបច្ចុប្បន្ននេះដែលសភាពការណ៍ នយោបាយរបស់ប្រទេសជាតិកំពុងមានភាពស្មុគស្មាញ។ ក្រោយពីបានពន្យល់ណែនាំមួយលើក ឬ ពីរលើក ហើយគេនៅតែរឹងរូស មិនស្តាប់ មិនអនុវត្តតាមការទូន្មានរបស់យើងនោះ គណៈកម្មា ធិការប្រជាជនគ្រប់ខេត្ត-ក្រុង ត្រូវអនុវត្តច្បាប់ជាធរមាន និងអនុវត្តសេចក្តីសម្រេចចិត្ត ឬសាល ក្រមតុលាការប្រសិនបើមាន។ បើគេនៅតែមិនគោរពច្បាប់ទេ នោះយើងមិនអាចសំងំស្ងៀមទុក ឱ្យគេបន្តប្រព្រឹត្តខុសឆ្គងបែបនេះតទៅទៀតបានឡើយ ដូច្នេះក្នុងករណីចាំបាច់ គណៈកម្មាធិការ ប្រជាជនខេត្ត-ក្រុងអាចបញ្ជាឱ្យប្រើកម្លាំងរដ្ឋបាល រួមមានកម្លាំងនគរបាល និងកម្លាំងប្រដាប់អាវុធ ដើម្បីបង្ខំជនល្មើសឱ្យចុះរុះរើបង្គោលដែលបានបោះនោះ ឬសំណង់ដែលគេសង់ដោយខុសច្បាប់នៅ លើដីសាធារណៈនោះ បើពុំនោះសោតទេ ក៏អាចឱ្យកម្លាំងរដ្ឋបាលរបស់យើងចុះរុះរើផ្ទាល់ក៏បានដែរ។ ប៉ុន្តែមុននឹងអនុវត្តការប្រើប្រាស់កម្លាំងដូចជម្រាបខាងលើនេះ គណៈកម្មាធិការប្រជាជនខេត្ត-ក្រុង ត្រូវជូនព័ត៌មានយ៉ាងតិច៣០ថ្ងៃឱ្យជនបង្កអនាធិបតេយ្យបានដឹងមុន និងឱ្យរុះរើដោយខ្លួនឯង។

*វាយឡើងវិញ*

ទន្ទឹមនោះ ត្រូវជូនព័ត៌មានទៅអ៊ិនតាក់ ដើម្បីឱ្យគេចុះពិនិត្យផ្ទាល់ និងសហការជាមួយយើងផង ដែរ។

ក្រុមប្រឹក្សារដ្ឋមន្ត្រីសង្ឃឹមថា អស់លោកប្រធានគណៈកម្មាធិការប្រជាជនខេត្ត-ក្រុង នឹងយកចិត្តទុកដាក់អនុវត្តតាមសារាចរណែនាំនេះ ប្រកបដោយប្រសិទ្ធភាព ហើយចៀសវាងបាននូវបាតុភាពដែលអាចនឹងកើតមានឡើងដោយថាហេតុនោះ។

**ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី**

**អនុប្រធាន**

**ហត្ថលេខា និងត្រា**

**ស ខេង**

ចម្លងជូន

-គ្រប់ក្រសួង មន្ទីរជុំវិញមជ្ឈិម

-គ្រប់ខេត្ត-ក្រុង

រដ្ឋកម្ពុជា

ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

ក្រសួងកសិកម្ម

លេខ០០៤សសរ/កសក ភ្នំពេញ ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៩៣

## សេចក្តីសម្រេច
## ស្តីពីការកំណត់សមត្ថកិច្ចលើបច្ចេកទេសវាស់វែងដី

## រដ្ឋមន្ត្រីក្រសួងកសិកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា
- បានឃើញច្បាប់ភូមិបាលដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ១០០ក្រ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩២
- បានឃើញអនុក្រឹត្យលេខ១៨អនក្រ ចុះថ្ងៃទី០២-១០-១៩៨៤ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម
- បានឃើញអនុក្រឹត្យលេខ៣១អនក្រ ចុះថ្ងៃទី១៤-០៦-១៩៨៩ ស្តីពីការផ្ទេរនាយកដ្ឋានគ្រប់គ្រងគោលនយោបាយសេដ្ឋកិច្ចកសិកម្ម ឱ្យទៅជានាយកដ្ឋានសុរិយោដី
- បានឃើញសំណើរបស់នាយកដ្ឋានសុរិយោដី

## សម្រេច

### ប្រការ១

រាល់ការងារវាស់វែងដី និងកសាងប្លង់ដីគ្រប់ប្រភេទជាសមត្ថកិច្ចរបស់សុរិយោដី។

### ប្រការ២

រាល់ការងារវាស់វែង និងកសាងប្លង់ទីតាំងរួមលើផ្ទៃដីដែលមានទំហំលើសពី៥ហិកតាឡើងទៅ ជាសមត្ថកិច្ចរបស់នាយកដ្ឋានសុរិយោដី។

*វាយឡើងវិញ*

**ប្រការ៣**

រាល់ការងារវាស់វែង និងកសាងប្លង់ទីប្រជុំជនជាសមត្ថកិច្ចរបស់នាយកដ្ឋានសុរិយោដី ។

**ប្រការ៤**

ក្នុងករណីការិយាល័យសុរិយោដីខេត្ត-ក្រុង ពុំទាន់មានលទ្ធភាពអនុវត្តតាមសមត្ថកិច្ចរបស់ខ្លួនបាន ត្រូវធ្វើសំណូមពរមកនាយកដ្ឋានសុរិយោដីដើម្បីជួយអន្តរាគមន៍ ។

**ប្រការ៥**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៦**

លោកប្រធានមន្ទីរនាយកដ្ឋានសុរិយោដី ការិយាល័យសុរិយោដីខេត្ត-ក្រុងត្រូវមានភារកិច្ចរៀង១ខ្លួន ដើម្បីអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ជ.រដ្ឋមន្ត្រីក្រសួងកសិកម្ម**
**អនុរដ្ឋមន្ត្រីទី១**
**ហត្ថលេខា និងត្រា**
**ឈា សុង**

*<u>ចម្លងជូន</u>*

-ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី

-គ្រប់ខេត្ត-ក្រុង

"ដើម្បីមុខការ"

-ដូចក្នុងប្រការ៦

"ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

រដ្ឋកម្ពុជា

ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

ក្រុមប្រឹក្សារដ្ឋ/រដ្ឋសភា

លេខ០៩ក្រ

## ច្បាប់ស្តីពីការបែងចែកទ្រព្យសម្បត្តិ

## ក្រុមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជា

មាត្រា១

ទ្រព្យសម្បត្តិជាចលនវត្ថុ និងជាអចលនវត្ថុទាំងអស់ដែលគណបក្សប្រជាជនកម្ពុជា និងរដ្ឋកម្ពុជាបានប្រើប្រាស់ និងគ្រប់គ្រងពីឆ្នាំ១៩៧៩មកដល់បច្ចុប្បន្នត្រូវបែងចែកគ្នា ចាប់ពីច្បាប់នេះចូលជាធរមាន។

មាត្រា២

ទ្រព្យសម្បត្តិជាចលនវត្ថុ និងជាអចលនវត្ថុទាំងអស់ដែលរដ្ឋាភិបាលនៃរដ្ឋកម្ពុជាបានប្រើប្រាស់ និងគ្រប់គ្រងរហូតមកដល់បច្ចុប្បន្នត្រូវចាត់ទុកជាទ្រព្យសម្បត្តិរបស់រដ្ឋ។

មាត្រា៣

ទ្រព្យសម្បត្តិជាចលនវត្ថុ និងអចលនវត្ថុទាំងអស់ដែលគណបក្សប្រជាជនកម្ពុជាបានប្រើប្រាស់ និងគ្រប់គ្រងរហូតមកដល់បច្ចុប្បន្ន ត្រូវចាត់ទុកជាទ្រព្យសម្បត្តិរបស់គណបក្សប្រជាជនកម្ពុជា។

មាត្រា៤

ទ្រព្យសម្បត្តិជាចលនវត្ថុ និងអចលនវត្ថុដែលបច្ចុប្បន្ននៅប្រើប្រាស់ និងគ្រប់គ្រងរួមគ្នា ត្រូវរដ្ឋាភិបាលនៃរដ្ឋកម្ពុជា និងគណបក្សប្រជាជនកម្ពុជាពិភាក្សាបែងចែក ដោយឯកភាពគ្នា និងតាមស្ថានការជាក់ស្តែង។

មាត្រា៥

រដ្ឋាភិបាលនៃរដ្ឋកម្ពុជា និងគណបក្សប្រជាជនកម្ពុជា ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិខាងលើនេះរៀងៗខ្លួន ចាប់តាំងពីច្បាប់នេះចូលជាធរមាន។

មាត្រា៦

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ភ្នំពេញ ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣

*វាយឡើងវិញ*

**រដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា**

លេខ០១សរ

**សារាចរស្តីពីកម្មសិទ្ធិស្របច្បាប់របស់ប្រជាពលរដ្ឋបច្ចុប្បន្ន និងកម្មសិទ្ធិសាធារណៈ**

**សហប្រធានរដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា**

សូមជម្រាបមក

អស់លោកអភិបាលខេត្ត-ក្រុងទូទាំងប្រទេសកម្ពុជា

**កម្មវត្ថុ៖** អំពីកម្មសិទ្ធិស្របច្បាប់របស់ប្រជាពលរដ្ឋបច្ចុប្បន្ន និងកម្មសិទ្ធិសាធារណៈ ។

**យោង** សេចក្តីប្រកាសរបស់រដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៩៣ និងដោយពិនិត្យឃើញនៅតាមខេត្ត-ក្រុង ស្រុក ឃុំ-សង្កាត់ជាច្រើនកើតឡើងនូវអំពើឃោរឃៅក្នុងការដណ្តើមកាន់កាប់ដីធ្លី ផ្ទះសំបែង អគារ ទីធ្លា និងសួនសាធារណៈ បណ្តាលឱ្យប្រជារាស្ត្រមានការភ័យព្រួយដល់កម្មសិទ្ធិរបស់ខ្លួន ដែលចាំបាច់ត្រូវមានការជួយដោះស្រាយជាបន្ទាន់ ។

រដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា សូមឱ្យអភិបាលខេត្ត-ក្រុងទូទាំងប្រទេស ចាត់វិធានការជាបន្ទាន់ ដើម្បីធានាការពារកម្មសិទ្ធិស្របច្បាប់បច្ចុប្បន្នរបស់ប្រជាពលរដ្ឋ ដូចជាដីធ្លី ផ្ទះសំបែង និងទ្រព្យសម្បត្តិរបស់រដ្ឋ ដូចជាអគារសាធារណៈ ទីធ្លា និងសួនសាធារណៈ ហើយបញ្ជូនជនល្មើសទៅតុលាការដើម្បីផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

ក្រោយបានទទួលសារាចរនេះ អភិបាលខេត្ត-ក្រុងទាំងអស់ត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរមកក្រសួងមហាផ្ទៃ ក្នុងរយៈពេល១ខែ បានន័យថានៅដំណាច់ខែកក្កដា ឆ្នាំ១៩៩៣ អំពីលទ្ធផលដែលសម្រេចបានក្នុងបញ្ហាទាំងអស់ខាងលើនេះ ។

ភ្នំពេញ ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ១៩៩៣

**រដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា**

**ហត្ថលេខា**

**ស្តេចក្រុមហ្លួង**

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

ចម្លងជូន

-ក្រសួងមហាផ្ទៃ និងសន្តិសុខជាតិ

"ដើម្បីសហការអនុវត្ត"

-កាលប្បវត្តិ-ឯកសារ

**កម្ពុជា**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**នាយកដ្ឋានសុរិយោដី**

លេខ១៦៦សដ ភ្នំពេញ ថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៣

**ប្រធាននាយកដ្ឋានសុរិយោដី**

**សូមជម្រាបមក**

**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

កម្មវត្ថុ៖ សភាពការណ៍ស្តីពីបញ្ហាដីធ្លី

ន័យដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមអនុញ្ញាតជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្នុងសភាពការណ៍បច្ចុប្បន្ន ការលំបាក បាតុភាព និងភាពអនាធិបតេយ្យជុំវិញបញ្ហាដីធ្លីបានកើតឡើង និងកំពុងឈានទៅរកការស្មុគស្មាញ អាស្រ័យដោយមកពីការយឺតយ៉ាវក្នុងការផ្តល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លី ពោលគឺការចុះបញ្ជីដីទាំងអស់ចូលក្នុងសៀវភៅដី "Livre foncier" ។

ក្នុងន័យនេះ ដើម្បីជំរុញដំណើរការផ្តល់ប័ណ្ណឱ្យមានសន្ទុះលឿន បន្ថយបានការលំបាក និងបាតុភាពអនាធិបតេយ្យ នាយកដ្ឋានសុរិយោដីបានចងក្រងប្រមូលផ្តុំបញ្ហាដីធ្លី "ដូចមានជូនជាប់ជាមួយនេះ" ដាក់ជូនក្រសួង និងរដ្ឋាភិបាលជាមូលដ្ឋានក្នុងការកែលំអការគ្រប់គ្រង និងប្រើប្រាស់ដីធ្លីឱ្យមានប្រសិទ្ធភាព ។

អាស្រ័យហេតុនេះ សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាពិនិត្យ និងសម្រេចតាមការគួរ ។

សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

**អនុប្រធាន**

**ហត្ថលេខា និងត្រា**

**លឹម វ៉ាន់**

*ចម្លងជូន*

-គ្រប់ការិយាល័យក្រោមឱវាទនាយកដ្ឋានសុរិយោដី

"ដើម្បីជ្រាបជាព័ត៌មាន"

-ឯកសារ-កាលប្បវត្តិ

## ព្រះរាជក្រឹត្យស្តីពីការបង្កើតតំបន់ការពារធម្មជាតិ

## ព្រះរាជក្រឹត្យ

### យើងព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣
- យោងសេចក្តីអនុម័តទុកចិត្តរបស់រដ្ឋសភាលើសមាសភាពនៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩៣
- យោងតាមការចាំបាច់

### ត្រាស់បង្គាប់

### មាត្រា១ ការទទួលខុសត្រូវលើតំបន់ការពារធម្មជាតិ

រដ្ឋលេខាធិការដ្ឋានគ្រប់គ្រងបរិស្ថាន ទទួលខុសត្រូវក្នុងការដឹកនាំគ្រប់គ្រងធ្វើផែនការ និងអភិវឌ្ឍប្រព័ន្ធតំបន់ការពារធម្មជាតិរបស់ជាតិ រួមមានការការពារបរិស្ថាន ដីព្រៃឈើ តំបន់ដីសើម និងតំបន់ឆ្នេរ។ រដ្ឋលេខាធិការដ្ឋានគ្រប់គ្រងបរិស្ថានមានសិទ្ធិអំណាចបង្កើត និងធ្វើជាប្រធានគណៈកម្មាធិការសមស្រប សម្រាប់សម្របសម្រួលអន្តរក្រសួងលើបន្ទាត់នយោបាយ និងបច្ចេកទេស។ ការគ្រប់គ្រង និងអភិបាលប្រព័ន្ធតំបន់ការពារធម្មជាតិរបស់ជាតិ ជាការទទួលខុសត្រូវរួមរបស់រដ្ឋលេខាធិការដ្ឋានគ្រប់គ្រងបរិស្ថាន ដោយសហការជាមួយស្ថាប័នមានសមត្ថកិច្ចឯទៀត។

ប្រព័ន្ធនេះរួមបញ្ចូលរាល់ប្រភេទដែនបម្រុងទុកសម្រាប់ទិសដៅគ្រប់គ្រងដូចតទៅ៖

១-ឧទ្យានធម្មជាតិ៖ ដែនធម្មជាតិ និងទស្សនីយភាពដែលត្រូវការពារ ដើម្បីបម្រើឱ្យវិទ្យាសាស្ត្រ ការអប់រំ និងការកំសាន្ត។

២-ដែនជម្រកសត្វព្រៃ៖ ដែនធម្មជាតិដែលធានានូវល័ក្ខខ័ណ្ឌធម្មជាតិចាំបាច់ ក្នុងការការពារប្រភេទសត្វព្រៃ និងរុក្ខជាតិរបស់ជាតិសំខាន់ៗ និងសហគមន៍ធម្មជាតិ ឬលក្ខណរូបសាស្ត្ររបស់បរិស្ថាន ជាទីដែលភាវៈទាំងនេះត្រូវការជាពិសេសនូវអន្តរាគមន៍ពីមនុស្សសម្រាប់ភាពស្ថិតស្ថេររបស់វា។

៣-តំបន់ការពារទេសភាព៖ តំបន់ដែលត្រូវថែទាំទេសភាពធម្មជាតិ និងពាក់កណ្តាលធម្មជាតិសំខាន់ៗ សម្រាប់រមណីយដ្ឋានដល់សាធារណជនក្នុងការសម្រាកកំសាន្ត និងធ្វើទេសចរណ៍។

៤-តំបន់ដែលទទួលរងនូវការប្រើប្រាស់ច្រើនមុខ៖ តំបន់ដែលផ្តល់នូវភាពស្ថិតស្ថេរលើប្រភពទឹក ព្រៃឈើ សត្វព្រៃ ត្រី វាលស្មៅ និងការកំសាន្តដែលតម្រូវឱ្យមានការអភិវឌ្ឍអភិរក្សធម្មជាតិ ក្នុងគោលដៅចម្បងនៃសកម្មភាពសេដ្ឋកិច្ច។

**មាត្រា២**

ការកំណត់តំបន់ការពារធម្មជាតិ ការកំណត់ប្រព័ន្ធអេកូឡូស៊ី ដី តំបន់ដីសើម និងតំបន់ឆ្នេរសមុទ្រ ត្រូវបានបញ្ជាក់នៅក្នុងផែនទីដែលភ្ជាប់ជាមួយនេះ ដើម្បីចាត់ចែង និងអភិវឌ្ឍតាមការកំណត់ដូចតទៅ៖

**១.ឧទ្យានជាតិ**

| | ផ្ទៃដី "ហ.ត" | ទីតាំង |
|---|---|---|
| ១-ខ្ពង់រាបគីរីរម្យ | ៣៥.០០០ | ខេត្តកំពង់ស្ពឺ និងកោះកុង |
| ២-ភ្នំបូកគោ | ១៤០.០០០ | ខេត្តកំពត |
| ៣-កែប | ៥.០០០ | ខេត្តកំពត |
| ៤-រាម | ១៥០.០០០ | ក្រុងព្រះសីហនុ |
| ៥-បុទុមសាគរ | ១៧១.២៥០ | ខេត្តកោះកុង |
| ៦-ភ្នំគូលែន | ៣៧.៥០០ | ខេត្តសៀមរាប |
| ៧-វីរៈជ័យ | ៣៣២.៥០០ | ខេត្តស្ទឹងត្រែង និងរតនគីរី |

**២.ដែនជម្រកសត្វព្រៃ**

| | | |
|---|---|---|
| ៨-ភ្នំឱរាល់ | ២៥៣.៧៥០ | ខេត្តកោះកុង ពោធិ៍សាត់ កំពង់ឆ្នាំង |
| ៩-ពាមក្រសោប | ២៣.៧៥០ | ខេត្តកោះកុង |
| ១០-ភ្នំសំកុស | ៣៣៣.៧៥០ | ខេត្តកោះកុង |
| ១១-រនាមដូនសំ | ១៧៨.៧៥០ | ខេត្តបាត់ដំបង |
| ១២-គូលេន-ព្រហ្មទេព | ៤០២.៥០០ | ខេត្តសៀមរាប និងព្រះវិហារ |
| ១៣-បឹងពែរ | ២៤២.៥០០ | ខេត្តកំពង់ធំ |
| ១៤-លំផាត់ | ២៥០.០០០ | ខេត្តរតនគីរី និងមណ្ឌលគីរី |
| ១៥-ភ្នំព្រេច | ២២២.៥០០ | ខេត្តមណ្ឌលគីរី និងក្រចេះ |

| | | |
|---|---|---|
| ១៦-ភ្នំណោមល្បើវ | ៤៧.៥០០ | ខេត្តមណ្ឌលគិរី |
| ១៧-ស្នួល | ៧៥.០០០ | ខេត្តក្រចេះ |
| **៣_តំបន់ការពារទេសភាព** | | |
| ១៨-អង្គរ | ១០.៨០០ | ខេត្តសៀមរាប |
| ១៩-បន្ទាយឆ្មារ | ៨១.២០០ | ខេត្តបន្ទាយមានជ័យ |
| ២០-ព្រះវិហារ | ៥.០០០ | ខេត្តព្រះវិហារ |
| **៤_តំបន់ប្រើប្រាស់ច្រើនយ៉ាង** | | |
| ២១-ដងពែង | ២៧.៧០០ | ខេត្តកោះកុង |
| ២២-សំឡូត | ៦០.០០០ | ខេត្តបាត់ដំបង |
| ២៣-ទន្លេសាប | ៣១៦.២៥០ | ខេត្តកំពង់ឆ្នាំង កំពង់ធំ សៀមរាប បាត់ដំបង និងពោធិ៍សាត់ |

**មាត្រា៣ វិសោធនកម្ម**

បណ្តាប្រព័ន្ធការពារធម្មជាតិនេះអាចនឹងកែប្រែពង្រីកបន្ថែមនៅពេលអនាគត ដោយផ្អែកលើព័ត៌មានវិទ្យាសាស្ត្រជាមូលដ្ឋានដែលទាក់ទងទៅនឹងអភិរក្សជីវសាស្ត្រ និងការរក្សាឱ្យមានភាពស្ថិតស្ថេរនៃទេសភាពនៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ អាទិភាព**

បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៥**

នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២នៃរាជរដ្ឋាភិបាលកម្ពុជា ទេសរដ្ឋមន្ត្រីទទួលបន្ទុករៀបចំដែនដី និងនគរូបនីយកម្ម រដ្ឋមន្ត្រីក្រសួងកសិកម្ម និងរដ្ឋលេខាធិការគ្រប់គ្រងបរិស្ថានទទួលបន្ទុកអនុវត្តឱ្យបានសម្រេចព្រះរាជក្រឹត្យនេះ។

**មាត្រា៦ ការអនុវត្ត**

ក្រឹត្យនេះមានអានុភាពជាតតិយុត្តទូទាំងព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

*វាយឡើងវិញ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការក្រសួងយុត្តិធម៌**

លេខ២៤៧សច/តុលាការ/៩៤ ភ្នំពេញ ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៩៩៤

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

សូមជម្រាបមក

លោកប្រធានតុលាការខេត្ត-ក្រុង

*សូមជ្រាប*។

កម្មវត្ថុ៖ អំពីការដោះស្រាយវិវាទរដ្ឋបាល។

ខ្ញុំសូមជម្រាបអស់លោកថា ចាប់តាំងពីថ្ងៃទី០៨ កុម្ភៈ ១៩៩៣ មក ច្បាប់ស្តីអំពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃសាលាជម្រះក្តីទូទាំងព្រះរាជាណាចក្រកម្ពុជា បានផ្តល់សម្ថកិច្ចជំនុំជម្រះវិវាទរដ្ឋបាលបន្ថែមទៀតជូនតុលាការខេត្ត-ក្រុង។

វិវាទរដ្ឋបាលបានន័យថាបណ្តឹងរបស់ប្រជាពលរដ្ឋដែលមិនសុខចិត្តនឹងអំពើណាមួយ ឬសេចក្តីសម្រេចណាមួយរបស់រាជការដែលគេយល់ឃើញថា ប៉ះពាល់ដល់ប្រយោជន៍របស់គេ។

ឧទាហរណ៍ រថយន្តរបស់អង្គការរដ្ឋបើកបរក្នុងពេលម៉ោងធ្វើការបានបុកប្រជាជនម្នាក់ធ្វើឱ្យមានរបួសជាទម្ងន់។ ជនរងគ្រោះ ឬតំណាងរបស់ជននោះប្តឹងមកតុលាការ។

ឧទាហរណ៍ រដ្ឋអំណាចថ្នាក់ស្រុក ឬថ្នាក់ឃុំបានយកដីដែលប្រជាជនបានកាន់កាប់យូរឆ្នាំមកហើយ ធ្វើជាដីបម្រុងទុកសម្រាប់ប្រើប្រាស់តាមផ្លូវរដ្ឋ ឬយកទៅជួល ឬលក់ឱ្យឈ្មួញ ហើយប្រជាជនមិនសុខចិត្តក៏ប្តឹងមកតុលាការ។

១-បណ្តឹងប្រភេទខាងលើនេះ ចំពោះអំពើដែលបានប្រព្រឹត្ត ឬចំពោះសេចក្តីសម្រេចដែលបានចេញក្រោយថ្ងៃទី៨ កុម្ភៈ ១៩៩៣ ត្រូវតុលាការមានសមត្ថកិច្ចដោះស្រាយ។

២-ចំពោះអំពើ ឬសេចក្តីសម្រេចដែលបានប្រព្រឹត្ត ឬបានចេញមុនថ្ងៃ ខែ ឆ្នាំខាងលើនេះ ប៉ុន្តែប្រជាពលរដ្ឋបានប្តឹងជាបន្តបន្ទាប់រហូតមកដល់សព្វថ្ងៃនេះ នោះក៏ត្រូវតុលាការមានសមត្ថកិច្ចដោះស្រាយ ។

៣-ខ្ញុំសូមបញ្ជាក់ថា តាំងពីឆ្នាំ១៩៩២មក ច្បាប់ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅដំបូងគេនៃតុលាការខេត្ត-ក្រុង បានផ្តល់សមត្ថកិច្ចជូនតុលាការជំនុំជម្រះរឿងព្រហ្មទណ្ឌ និងរឿងរដ្ឋប្បវេណី ។

អាស្រ័យហេតុនេះ វិវាទរដ្ឋប្បវេណីរវាងប្រជាជន និងប្រជាជនលើរឿងដី ផ្ទះជាសមត្ថកិច្ចរបស់តុលាការ ។

មានវិវាទដី ផ្ទះខ្លះ រដ្ឋអំណាចយកទៅដោះស្រាយ ។ ចំពោះវិវាទរដ្ឋប្បវេណីប្រភេទនេះ ទោះបីបានប្តឹងមកតុលាការមុនថ្ងៃទី៨ កុម្ភៈ ១៩៩៣ ឬក្រោយថ្ងៃទី៨ កុម្ភៈ ១៩៩៣ តុលាការសុទ្ធតែមានសមត្ថកិច្ចដោះស្រាយទាំងអស់ ។ ប៉ុន្តែ តុលាការមិនត្រូវបដិសេធសេចក្តីសម្រេចរបស់រដ្ឋអំណាចទេ ។ តុលាការសម្រេចតាមធម្មតា លើវិវាទទុកដូចជារដ្ឋអំណាចឥតបានពិនិត្យ និងសម្រេចអ្វីទាំងអស់ ។

**រដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ចែម ស្ងួន**

<u>ចម្លងជូន</u>

-គណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-អភិបាលខេត្ត-ក្រុង

-តុលាការកំពូល និងមហាអយ្យការ

-សាលាឧទ្ធរណ៍ និងមហាអយ្យការ

-អយ្យការខេត្ត-ក្រុង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**នាយកដ្ឋានសុរិយោដី** ភ្នំពេញ ថ្ងៃទី០២ ខែសីហា ឆ្នាំ១៩៩៤

លេខ១៦២សជសណន

**ប្រធាននាយកដ្ឋានសុរិយោដី**

**ជម្រាបមក**

**លោកប្រធានការិយាល័យសុរិយោដីគ្រប់ខេត្ត-ក្រុង**

កម្មវត្ថុ៖ ការណែនាំស្តីពីបន្ទុកពាក់ព័ន្ធនឹងការបញ្ចាំអចលនវត្ថុ និងការធ្វើលេខាចារឹក។

ន័យដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបលោកប្រធានថា កន្លងមកការិយាល័យសុរិយោដីខេត្ត-ក្រុង តែងបានទទួលពីអតិថិជននូវបណ្តឹលិខិតសញ្ញាពាក់ព័ន្ធនឹងការបញ្ចាំអចលនវត្ថុ ដើម្បីបញ្ជាក់ពីបន្ទុកនៃអចលនវត្ថុដែលដាក់បញ្ចាំ ហើយមិនបានធ្វើលេខាចារឹកលើប័ណ្ណ ក៏ដូចជាក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ។

ដើម្បីចៀសវាងបាតុភាព ឬព្យសនកម្មផ្សេងៗដែលបណ្តាលមកពីការបញ្ជាក់ ការមិនធ្វើលេខាចារឹក "យោងមាត្រា២១៩-២២០ នៃច្បាប់ភូមិបាល" នាយកដ្ឋានសូមធ្វើការណែនាំដូចខាងក្រោម៖

**១.អំពីការបញ្ជាក់**

ប្រធានការិយាល័យភូមិបាលស្រុក-ខណ្ឌ ឬប្រធានការិយាល័យសុរិយោដីខេត្ត-ក្រុង ដែលគ្រប់គ្រងអចលនវត្ថុដាក់បញ្ចាំ ត្រូវចេញលិខិតបញ្ជាក់ដោយចុះលេខក្នុងសៀវភៅសំណៅលិខិតចេញ “Registre de départ” មុននឹងប្រគល់ជូនអតិថិជន។

រូបមន្តបញ្ជាក់ និងគំរូមានចែងក្នុងឧបសម្ព័ន្ធលេខ១ ដែលនាយកដ្ឋាននឹងបោះពុម្ពចែកជូន។

**២.អំពីការធ្វើលេខាចារឹក**

នៅពេលដែលបានទទួលសំណុំឯកសារនៃលិខិតសញ្ញា និងពិនិត្យឃើញគ្រប់គ្រាន់ និង ត្រឹមត្រូវហើយ ការិយាល័យភូមិបាលត្រូវចុះក្នុងសៀវភៅកត់ត្រាលិខិត "Carnet de dépôt" ហើយស្រង់យកលេខក្នុងសៀវភៅកត់ត្រាលិខិតនេះ ចុះលើលិខិតសញ្ញាផ្នែកខាងលើ រួចបញ្ជូនមក ការិយាល័យសុរិយោដីខេត្ត-ក្រុង។

ការិយាល័យសុរិយោដីខេត្ត-ក្រុង ក្រោយពិនិត្យផ្ទៀងផ្ទាត់ឃើញថាត្រឹមត្រូវហើយត្រូវ ចុះក្នុងសៀវភៅចលនាលិខិត "Carnet de movement des actes" រួចធ្វើលេខាចារឹកលើប័ណ្ណ "ផ្នែកខាងខ្នង" និងក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ "Registre de déclaration" តាមគំរូ ក្នុងឧបសម្ព័ន្ធលេខ២ ដោយយកលេខក្នុងសៀវភៅនេះជាលេខប័ណ្ណសារដ្ឋានតាមឃុំ "Numéro archivage par khum" រួចហើយបញ្ជូនទៅការិយាល័យភូមិបាលវិញនូវប័ណ្ណ និងលិខិតសញ្ញា ដើមមួយច្បាប់ដើម្បីចុះចរន្តការ និងផ្តល់ទៅជូនអតិថិជនដោយមានផ្តិតមេដៃទទួលលិខិត ក្នុង សៀវភៅប្រគល់លិខិត "Carnet de remise des actes"។

ចំពោះការលោះវិញក៏ត្រូវធ្វើលេខាចារឹកដូចករណីបញ្ចាំដែរ "រូបមន្តឧបសម្ព័ន្ធលេខ២"។

អាស្រ័យហេតុនេះ សូមលោកប្រធានចាត់ការអនុវត្តតាមខ្លឹមសារណែនាំនេះឱ្យបានម៉ត់ ចត់ និងមានប្រសិទ្ធភាពខ្ពស់។

**ប្រធាននាយកដ្ឋានសុរិយោដី**

**អនុប្រធាន**

**ហត្ថលេខា និងត្រា**

**លឹម វ៉ាន់**

*<u>ចម្លងជូន</u>*

-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

"ដើម្បីជូនជ្រាប"

-ការិយាល័យអភិរក្សសុរិយោដី

-ការិយាល័យអធិការកិច្ច

"ដើម្បីមុខការ"

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជក្រម

លេខ០៤/នស/៩៤

## យើង

## ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣
- គណៈរដ្ឋមន្ត្រីបានយល់ព្រមផង

## ប្រកាសឱ្យប្រើ

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នាថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ដូចមានសេចក្តីតទៅនេះ៖

## ជំពូកទី១ កម្មវត្ថុ

**មាត្រា១**

ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់មានកម្មវត្ថុជំរុញឱ្យមានការរៀបចំកែលំអទីក្រុង និងតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធានាកិច្ចអភិវឌ្ឍសុខដុមនៃប្រទេសក្នុងស្មារតី៖

-គោរពប្រយោជន៍រួម និងប្រយោជន៍បុគ្គលផង គោរពសិទ្ធិឯកជនផង គោរពបទបញ្ញាច្បាប់ផង និងត្រួតពិនិត្យការសាងសង់ផង ។

-ធានាការអភិវឌ្ឍសំដៅរកលំនឹងរវាងទីក្រុង និងតំបន់ជនបទ ផ្អែកទៅលើភូមិសាស្ត្រ និងលក្ខណៈពិសេសនៃជនបទនីមួយៗ ។

-ធានាលើតម្លៃសម្បត្តិធម្មជាតិ សម្បត្តិវប្បធម៌ និងធានាការអភិវឌ្ឍវិស័យសេដ្ឋកិច្ច វិស័យទេសចរណ៍ និងរក្សាបាននូវគុណភាពបរិស្ថាន ។

មាត្រា២

ច្បាប់រៀបចំទឹកដី នគរូបនីយកម្ម និងសំណង់នេះត្រូវសំអាងទៅលើកម្មសិទ្ធិដែលអនុលោមទៅតាមច្បាប់ភូមិបាលបច្ចុប្បន្ន ក្នុងករណីដែលច្បាប់ភូមិបាលត្រូវកែប្រែ ផ្លាស់ប្ដូរ ច្បាប់ស្ដីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់នឹងត្រូវកែច្នៃឱ្យស្របទៅតាមច្បាប់ភូមិបាលនេះដែរ ។

មាត្រា៣

ដើម្បីសម្រេចនូវបំណងដែលបានចែងខាងលើនេះ ត្រូវបង្កើតឱ្យមានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ដែលមានសមាជិក និងសំណើការតែងតាំង និងរៀបចំដោយអនុក្រឹត្យ ។

ចំពោះរាជធានីភ្នំពេញ គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់សម្រាប់ក្រុងភ្នំពេញមួយត្រូវបង្កើត ។ គណៈកម្មាធិការនេះដឹកនាំដោយប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ហើយដែលមានប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងភ្នំពេញ ឬអភិបាល អភិបាលរង ព្រមទាំងអង្គភាពបច្ចេកទេសដែលមានសមត្ថកិច្ចចូលរួមជាសមាជិកផងដែរ ។ សមាសភាពច្បាស់លាស់ ព្រមទាំងដំណើរការនៃគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់សម្រាប់ក្រុងភ្នំពេញត្រូវកម្រិតដោយអនុក្រឹត្យ ។

ចំពោះខេត្ត-ក្រុងនានា ត្រូវបង្កើតអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ដែលដឹកនាំដោយអភិបាលខេត្ត-ក្រុង និងអង្គភាពបច្ចេកទេសខេត្ត-ក្រុងដែលមានសមត្ថកិច្ចចូលរួមជាសមាជិកផង។ សមាសភាពច្បាស់លាស់ ព្រមទាំងដំណើរការនៃអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ក្រោយពីមានការយល់ព្រមរបស់គណៈកម្មាធិការជាតិនេះ ។

**ជំពូកទី២ ឯកសារទាក់ទងនឹងការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់**

មាត្រា៤

ឯកសារទាំងឡាយដែលទាក់ទងនឹងការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ត្រូវរៀបចំតាមករណីនីមួយៗ ឱ្យសមស្របទៅតាមស្ថានភាព លក្ខណៈពិសេសនៃទឹកដីខេត្ត-ក្រុង តំបន់ក្នុងស្មារតីការពារដល់បេតិកភណ្ឌ ដល់បរិស្ថានការពារធនធានធម្មជាតិ ព្រមទាំងធានាដល់ការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច ។

មាត្រា៥

គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់រាជធានីភ្នំពេញ ឬអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ខេត្ត-ក្រុងនីមួយៗត្រូវគូសប្លង់គោលដើម្បីធ្វើការរៀបចំ និងអភិវឌ្ឍនៃរាជធានី ខេត្ត-ក្រុងរបស់ខ្លួន។ ប្លង់គោលនេះត្រូវមានការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ និងកំណត់ដោយអនុក្រឹត្យ ។

ដើម្បីការពារនូវបេតិកភណ្ឌ ការពារបរិស្ថាន និងដើម្បីធានាអភិវឌ្ឍសេដ្ឋកិច្ចចំពោះតំបន់ពិសេសណាមួយដែលគណៈរដ្ឋមន្ត្រីបានកំណត់ គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ មានភារៈរៀបចំប្លង់គោលសម្រាប់តំបន់ពិសេសនោះដាក់ជូនគណៈរដ្ឋមន្ត្រីអនុម័ត។

## ជំពូកទី៣ ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់

**មាត្រា៦**

ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ត្រូវរៀបចំឡើងសម្រាប់រាជធានី ខេត្ត-ក្រុង។ ប្លង់នេះត្រូវមានការគោរពពីសំណាក់ឯកជន ក៏ដូចជាអាជ្ញាធរសាធារណៈក្នុងកិច្ចការសាងសង់របស់ខ្លួន។

**មាត្រា៧**

ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ត្រូវតែបញ្ជាក់ឱ្យច្បាស់លាស់អំពីតំបន់ដែលត្រូវប្រើប្រាស់សម្រាប់ការពារជាតិ សម្រាប់កសិកម្ម សម្រាប់ពាណិជ្ជកម្ម សម្រាប់ឧស្សាហកម្ម សម្រាប់សិប្បកម្ម វប្បធម៌ ទេសចរណ៍ សាសនា ព្រមទាំងសម្រាប់សំណង់នៃរដ្ឋបាល និងបរិក្ខារសាធារណៈ ។ ប្លង់នេះកំណត់ផងដែរនូវលទ្ធភាពសម្រាប់សាងសង់។

**មាត្រា៨**

ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ត្រូវគោរពតាមប្លង់គោល ដូចមានចែងក្នុងមាត្រា៥នៃច្បាប់នេះ។

**មាត្រា៩**

ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់សម្រាប់រាជធានី និងខេត្ត-ក្រុងនីមួយៗត្រូវមានការទទួលយល់ព្រមពីគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ខេត្ត-ក្រុង រួចត្រូវមានការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ទៀត។ ប្លង់ទាំងអស់ត្រូវមានការទទួលគោរពពីឯកជន ក៏ដូចជាអាជ្ញាធរសាធារណៈទាំងពួងផង។

**មាត្រា១០**

រាជរដ្ឋាភិបាលរៀបចំបទប្បញ្ញត្តិពិសេស និងសេវាភាពនគរូបនីយកម្មដើម្បីការពារ និងលើកតម្លៃរមណីយដ្ឋាន ឬអចលនវត្ថុណាដែលនឹងផ្តល់នូវអត្ថប្រយោជន៍ខាងផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រ

វប្បធម៌ សោភ័ណភាព ឬបច្ចេកទេស។ បញ្ជីអចលនវត្ថុ រមណីយដ្ឋានទាំងនោះនឹងកំណត់ដោយអនុក្រឹត្យ។

ការរុះរើការផ្លាស់ប្តូរទ្រទ្រង់ និងការគ្រប់គ្រងអចលនវត្ថុ និងរមណីយដ្ឋានទាំងនោះត្រូវកំណត់ដោយច្បាប់ស្តីពីការការពារបេតិកភណ្ឌ។

បទប្បញ្ញត្តិពិសេស និងសេវាភាពនគរូបនីយកម្មដើម្បីការពារ និងលើកតម្លៃរមណីយដ្ឋាន ឬអចលនវត្ថុដែលផ្តល់ផលប្រយោជន៍ដល់ផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភ័ណភាព ឬបច្ចេកទេសត្រូវចារឹកក្នុងប្លង់គោលរៀបចំទឹកដី នគរូបនីយកម្ម និងអភិវឌ្ឍន៍ និងចារឹកក្នុងប្លង់ប្រើប្រាស់ដីធ្លី និងសំណង់។

រាជរដ្ឋាភិបាលកំណត់ដោយអនុក្រឹត្យនូវបញ្ជីអចលនវត្ថុ ដែលមានប្រយោជន៍ដល់ផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភ័ណភាព និងបច្ចេកទេស ដើម្បីធានាការគ្រប់គ្រងអចលនវត្ថុទាំងនេះ តាមបញ្ញត្តិច្បាប់ស្តីពីការការពារបេតិកភណ្ឌ។

## ជំពូកទី៤ ការងារ និងសំណង់

### មាត្រា១១

រាល់ការកកាយ រុករក ឬស្ទង់ដែលមានការប៉ះពាល់ដល់ខាងផ្នែកបុរាណវិទ្យាចាំបាច់ត្រូវមានការអនុញ្ញាតពីរាជរដ្ឋាភិបាល។

រាល់ការសាងសង់ ក្នុងករណីជួបប្រទះនូវវត្ថុអ្វីមួយដែលមានអត្ថប្រយោជន៍ខាងផ្នែកបុរាណវិទ្យា ឬប្រវត្តិសាស្ត្រ អ្នកទទួលខុសត្រូវការដ្ឋានត្រូវមានកាតព្វកិច្ចរាយការណ៍មកអាជ្ញាធរមានសមត្ថកិច្ចឱ្យបានជ្រាបភ្លាមៗ។ អាជ្ញាធរមានសមត្ថកិច្ចត្រូវបញ្ឈប់ ផ្អាកសំណង់ជាបន្ទាន់។

### មាត្រា១២

រាល់បុគ្គល ឬស្ថាប័នឯកជនក៏ដូចជាអាជ្ញាធរសាធារណៈ ត្រូវហាមឃាត់មិនឱ្យសាងសង់លើទីធ្លាដែលមានលក្ខណៈជាសាធារណៈដូចតទៅ៖

-ទីបម្រុងទុកទឹក និងទំនប់ទឹក

-ទីបម្រុងជីករ៉ែ និងតំបន់ព្រៃឈើ

-រមណីយដ្ឋានបុរាណវិទ្យា និងប្រវត្តិសាស្ត្រ

-សួនច្បារ ឧទ្យានសាធារណៈ និងតំបន់អភិវឌ្ឍន៍

-ដីបម្រុងទុកសម្រាប់ផ្លូវ បម្រុងសម្រាប់ចំណីផ្លូវ និងដីបម្រុងទុកសម្រាប់ផ្លូវរថភ្លើង និងអាកាសយានដ្ឋាន

-ទន្លេ សមុទ្រ ព្រែក ស្ទឹង ព្រមទាំងឆ្នេរច្រាំង

-ជាទូទៅនៅលើដីទាំងឡាយណាដែលបញ្ញត្តិច្បាប់កំណត់មិនឱ្យសង់ ។

ល័ក្ខខ័ណ្ឌនៃការគ្រប់គ្រងតំបន់ទាំងនោះ ល័ក្ខខ័ណ្ឌសំណង់ ឬតាំងទីលំនៅធុនស្រាល បណ្តោះអាសន្នអនុញ្ញាតបានដោយអនុក្រឹត្យ ។

**មាត្រា១៣**

ការងារសាងសង់ និងការតាំងទីត្រូវធ្វើឡើងដោយគោរពតាមឯកសារដែលទាក់ទងនឹងការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ គោរពតាមប្លង់គោលដែលមានចែងក្នុងមាត្រា៤ និង ៥នៃច្បាប់នេះ ។

**មាត្រា១៤**

រាល់ការសាងសង់ រាល់ការកែប្រែទិដ្ឋភាព ឬការកែប្រែការប្រើប្រាស់សំណង់ណាមួយត្រូវមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ។ ពាក្យស្នើសុំអនុញ្ញាតសាងសង់ ត្រូវមានឯកសារ និងប្លង់ចាំបាច់ ។ នីតិវិធីក្នុងការអនុវត្តមាត្រានេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា១៥**

ឯកសារ និងប្លង់ចាំបាច់សម្រាប់ភ្ជាប់ពាក្យសុំអនុញ្ញាតសាងសង់សំណង់ធំៗ ត្រូវរៀបចំឡើងដោយស្ថាបត្យករខ្មែរមានសញ្ញាប័ត្រ ឬជនណាដែលមានការទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច ។ ល័ក្ខខ័ណ្ឌដែលទាមទារអំពីសញ្ញាប័ត្រ និងទាមទារការទទួលស្គាល់ខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា១៦**

ពាក្យសុំអនុញ្ញាតសាងសង់ត្រូវយកមកដាក់សុំដោយម្ចាស់កម្មសិទ្ធិដី ឬអ្នកបានទទួលសិទ្ធិពីម្ចាស់កម្មសិទ្ធិ ។ ពាក្យសុំអនុញ្ញាតនេះត្រូវមានភ្ជាប់មកជាមួយផងនូវឯកសារបញ្ជាក់អំពីកម្មសិទ្ធិរបស់ម្ចាស់ដី ។

**មាត្រា១៧**

មិនអនុញ្ញាតឱ្យសាងសង់នូវសំណង់ណា ក្នុងលក្ខណៈដែលមិនសមស្របនឹងប្លង់គោល ឬប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ ។

មិនអនុញ្ញាតឱ្យសាងសង់ បើគម្រោងសាងសង់នោះមានការប៉ះពាល់ដល់សន្តិសុខសាធារណៈ ប៉ះពាល់ដល់បរិស្ថាន ប៉ះពាល់ដល់អនាម័យសាធារណៈ សំណង់ ឬអចលនវត្ថុដែលមានសារៈប្រយោជន៏

ដល់ផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភ័ណភាព បច្ចេកទេស ឬប៉ះពាល់ដល់តំបន់ដែលមានធនធានធម្មជាតិ។

មិនអនុញ្ញាតឱ្យសាងសង់ បើសិនជាពុំមានការរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធ បរិក្ខារសាធារណៈឱ្យបានគ្រប់គ្រាន់ និងគម្រោងសំណង់ដែលសុំ។

**មាត្រា១៨**

ក្នុងករណីពុំទាន់មានប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ អាជ្ញាធរខេត្ត-ក្រុងត្រូវបង្កើតគណៈកម្មាធិការដើម្បីពិនិត្យពាក្យសុំ និងចេញលិខិតអនុញ្ញាតសាងសង់។

**មាត្រា១៩**

ចំពោះគម្រោងសំណង់រដ្ឋបាល អង្គភាពដែលស្នើសុំសាងសង់ត្រូវមានការអនុញ្ញាតជាមុនពីអាជ្ញាធរមានសមត្ថកិច្ច។ ការអនុញ្ញាតនោះអាចផ្តល់បានតែចំពោះសំណង់ណាដែលមានលក្ខណៈចាំបាច់សម្រាប់ដំណើរការផ្នែករដ្ឋបាល។ ការអនុញ្ញាតនេះមិនអាចនាំឱ្យមានការផ្លាស់ប្តូរនូវការប្រើប្រាស់ដីធ្លីដែលបានកំណត់មកហើយ ហើយក៏មិនអាចកែប្រែនូវលក្ខណៈសាធារណៈ និងអត្ថប្រយោជន៍ទូទៅនៃតំបន់នេះឡើយ។

**មាត្រា២០**

សំណង់ទាំងឡាយណាដែលអ្នកវិនិយោគទុនឯកជន បានសាងសង់នៅលើដីរបស់រដ្ឋស្រប តាមកិច្ចសន្យាណាមួយ ត្រូវប្រគល់មកឱ្យរដ្ឋវិញពេលផុតកំណត់ចែងក្នុងកិច្ចសន្យានោះ។

**មាត្រា២១**

បើគ្មានមូលហេតុត្រឹមត្រូវដែលបានបញ្ជាក់ក្នុងច្បាប់នេះ មន្ត្រីរាជការណាដែលប្រកែកមិនព្រមទទួលពិនិត្យពាក្យសុំសាងសង់ ឬចេញលិខិតអនុញ្ញាតសាងសង់ ឬប្រឆាំងនឹងការចេញលិខិតអនុញ្ញាតសាងសង់ក្នុងរយៈពេលមួយយ៉ាងយូរ៤៥ថ្ងៃទេនោះ ត្រូវផ្តន្ទាទោសតាមបញ្ញត្តិច្បាប់។

ក៏ត្រូវផ្តន្ទាទោសផងដែរ ចំពោះភ្នាក់ងារណាដែលបានពិនិត្យគម្រោងសាងសង់ និងចេញលិខិតអនុញ្ញាតសាងសង់ដែលមិនស្របនឹងបទប្បញ្ញត្តិ។

ភ្នាក់ងារត្រួតពិនិត្យលើសំណង់ដែលពុំបានជំទាស់ ពេលដែលខ្លួនឃើញសំណង់លើការដ្ឋានណាមួយមិនគោរពតាមគម្រោងដែលអនុញ្ញាត ត្រូវផ្តន្ទាទោសតាមបញ្ញត្តិច្បាប់។

ទណ្ឌកម្មផ្នែករដ្ឋបាល ដែលត្រូវយកមកអនុវត្តចំពោះភ្នាក់ងារដែលមានកំហុសដូចបានរៀបរាប់ខាងលើនេះ ត្រូវកំណត់ដោយច្បាប់រដ្ឋបាល។

ចំណែកឯអ្នកសាងសង់ដែលមិនគោរពលិខិតអនុញ្ញាតសាងសង់ទេនោះ នឹងត្រូវទទួលបង្គាប់ឱ្យរុះរើកែសំណង់ឱ្យស្របតាមលិខិតអនុញ្ញាតសាងសង់ក្នុងរយៈពេល៣០ថ្ងៃ យ៉ាងយូរគិតចាប់ពីថ្ងៃទទួលលិខិតបញ្ជាផ្លូវការ ។

មន្ត្រីរាជការណាដែលរួមគំនិតនឹងត្រូវដាក់បទចោទប្រកាន់ចំពោះមុខតុលាការ ។ នៅពេលពិនិត្យឃើញមានសំណង់ខុសឆ្គង ការដ្ឋានត្រូវបញ្ឈប់ ហើយជាយថាហេតុ សម្ភារៈ និងឧបករណ៍សំណង់នៅទីនោះត្រូវទទួលរឹបអូសតាមបង្គាប់តុលាការ ។ ក្នុងករណីដែលអ្នកសាងសង់ទទួលរងគ្រោះដោយមិនមែនជាកំហុសរបស់ខ្លួន អ្នករងគ្រោះអាចប្រើសិទ្ធិរបស់ខ្លួនដើម្បីប្តឹងទៅតុលាការទារជំងឺចិត្ត ។

**មាត្រា២២**

ម្ចាស់សំណង់ មុនពេលវាយកម្ទេចសំណង់របស់ខ្លួនដែលមានស្រាប់ ត្រូវមានលិខិតអនុញ្ញាតរុះរើពីអាជ្ញាធរមានសមត្ថកិច្ចជាមុនសិន ។

បែបបទនៃការរុះរើវាយកម្ទេចសំណង់នឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

ការអនុញ្ញាត ឱ្យរុះរើវាយកម្ទេចសំណង់អាចត្រូវបដិសេធបាន ក្នុងលក្ខណៈដែលការរុះរើកម្ទេចសំណង់នោះមានទាក់ទិននឹងបញ្ហាសង្គមកិច្ច បច្ចេកទេស និងបេតិកភណ្ឌដែលរដ្ឋបានកត់ត្រា ។

**មាត្រា២៣**

បទប្បញ្ញត្តិទាំងឡាយណាដែលមាននៅក្នុងច្បាប់ពីមុនស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤

**ក្នុងព្រះបរមនាម និងតាមព្រះរាជបង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រីទី១** **នាយករដ្ឋមន្ត្រីទី២**

**ព្រះហស្តលេខា និង ហត្ថលេខា**

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

បានបង្គំទូលថ្វាយ និងជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី១ និងទី២

ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការវប្បធម៌

វិចិត្រសិល្បៈ រៀបចំដែនដី និងនគរូបនីយកម្ម

**ហត្ថលេខា**

**វណ្ណ ម៉ូលីវណ្ណ**

ព្រះរាជាណាចក្រកម្ពុជា

**ទីស្តីការគណៈរដ្ឋមន្ត្រី** ជាតិ សាសនា ព្រះមហាក្សត្រ

លេខ១៦២៣សជណ/កស

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩៤

**សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ជម្រាបមក**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

កម្មវត្ថុ៖ ករណីសំណើសុំពិនិត្យ និងកែសម្រួលឯកសារពាក់ព័ន្ធដីធ្លី

យោង៖ លិខិតលេខ៣២៩៧កសក/មសរ ចុះថ្ងៃទី៥-៨-៩៤ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ព្រះរាជចំណារសម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី១ ចុះថ្ងៃទី២៦-៩-១៩៩៤

-ចំណារសម្តេច នាយករដ្ឋមន្ត្រីទី២ ចុះថ្ងៃទី២៧-៩-១៩៩៤

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការរដ្ឋមន្ត្រីសូមជម្រាបឯកឧត្តមជ្រាបថា រាជរដ្ឋាភិបាលបានសម្រេចឯកភាពជាគោលការណ៍ តាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការកែសម្រួលឯកសារពាក់ព័ន្ធនឹងដីធ្លីមានដូចខាងក្រោម៖

-ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី

-សៀវភៅចុះបញ្ជីអចលនវត្ថុ

-កំណត់ហេតុអង្កេតដី

-ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ

ប៉ុន្តែពង្រីកឱ្យបានធំនូវ Colonne ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត (សូមកុំដាក់ស្រុកកំណើត)។

សូមឯកឧត្តមទទួលការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

*វាយឡើងវិញ*

ជ.សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ស៊ុំ ម៉ានិត នូវ កានុង

<u>ចម្លងជូន</u>

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងមហាផ្ទៃ

"ដើម្បីជ្រាបជាព័តិមាន"

-ខុទ្ទកាល័យសម្ដេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី១

-ខុទ្ទកាល័យសម្ដេច នាយករដ្ឋមន្ត្រីទី២

-ចំណុចកណ្ដាល

-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ទីស្តីការគណៈរដ្ឋមន្ត្រី ជាតិ សាសនា ព្រះមហាក្សត្រ

នាយកដ្ឋានសុរិយោដី

**បែបបទនៃការបំពេញ**

**ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ "ប័ណ្ណថ្មី"**

**I.** **អំពីទំព័រដើម**

ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុដែលនឹងចេញឱ្យប្រើប្រាស់ថ្មីនេះមានតម្លៃដូចគ្នានឹងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីកន្លងមក។

ប៉ែកខាងស្តាំនៃទំព័រដើមខាងលើបង្អស់គឺឈ្មោះប្រទេស

"ព្រះរាជាណាចក្រកម្ពុជា"

បន្ទាប់មកគឺបាវចនា

ជាតិ សាសនា ព្រះមហាក្សត្រ

អក្សរធំៗពីខាងក្រោមគឺឈ្មោះប័ណ្ណដាក់ថា

"ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ"

ចំពោះខ្ទង់ដែលត្រូវបំពេញខាងក្រោយលេខ គឺជាលេខប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុដែលចុះដោយនាយកដ្ឋានសុរិយោដី លេខនេះគ្មានចុះក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុទេ។

ខ្ទង់ដែលត្រូវបំពេញខាងក្រោយពាក្យ ឃុំ-សង្កាត់ ស្រុក-ខណ្ឌ ខេត្ត-ក្រុង គឺចុះពីទីកន្លែងដែលដីឋិតនៅ។

ផ្នែកខាងក្រោម មានប្រកាសជូនជាព័ត៌មានដល់សាមីជនដែលទទួលបានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុថ្មីនេះ ត្រូវចុះហត្ថលេខាយល់ព្រមពីនាយកដ្ឋានសុរិយោដី។

នៅទំព័រដដែលនេះ ចំហៀងខាងឆ្វេង ពីខាងលើដាក់ថា ឈ្មោះដី .................... "គឺជាឈ្មោះដីដែលម្ចាស់កាន់កាប់ដី" ទម្លាប់ប្រើដើម្បីងាយស្រួលក្នុងការរកទីកន្លែងដី។

*វាយឡើងវិញ*

ឧទាហរណ៍៖ ស្រែវាល, ស្រែតាគង់ ។

ឈ្មោះភូមិគឺជាភូមិដែលដីឋិតនៅ ។

**អំពីព្រំប្រទល់៖** ចំណុចនេះជាកត្តាសំខាន់សម្រាប់យើងកំណត់ទីតាំងព្រំដី ការចុះព្រំប្រទល់ដីអាស្រ័យដោយមានការឯកភាពគ្នាជាក់ស្តែងរវាងម្ចាស់ដីដែលនៅជាប់គ្នា ប្រការនេះយើងបានធ្វើចប់សព្វគ្រប់នៅក្នុងកំណត់ហេតុអង្កេតរួចហើយ ។

ជាទូទៅ ទិសធំៗមានបួន តែបើដីឋិតនៅជាប់ព្រំគ្នាពីចំហៀង ក៏ត្រូវតែចុះឈ្មោះទិសធំទាំងបួននេះដែរគឺមិនត្រូវប្រើទិសព្យសាន អាគ្នេយ៍ និរតី ឬពាយ័ព្យឡើយ ។

នៅខាងក្រោមបង្អស់ពីចំហៀងខាងឆ្វេង គឺការចុះហត្ថលេខាទទួលខុសត្រូវរបស់ប្រធានការិយាល័យភូមិបាលស្រុក-ខណ្ឌ ក្រោយពីបានសរសេរនូវខ្ទង់ដែលត្រូវចុះសព្វគ្រប់ក្នុងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុរួចហើយ ព្រមទាំងបញ្ជាក់ពីឈ្មោះស្រុក និងចុះថ្ងៃ ខែ ឆ្នាំ ចុះហត្ថលេខាផង ។

ឧទាហរណ៍៖ ត្រាំកក់នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៩៤

**II.** **<u>នៅទំព័រខាងខ្នង</u>**

១-នៅទំព័រនេះ នៅខាងឆ្វេងខាងលើបំផុត មានដាក់ លេខ........ ខាងក្រោយលេខនេះគឺជាលេខអាទិសង្កេតរបស់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ចុះដោយនាយកដ្ឋានសុរិយោដី

២-អក្ខរសញ្ញាខ្លួន " " លេខនេះឋិតនៅខាងស្តាំនៃទំព័រនេះគឺជាលេខតាងដោយអក្សរសម្រាប់សម្គាល់ម្ចាស់កាន់កាប់អចលនវត្ថុ លេខនេះត្រូវបំពេញដោយការិយាល័យភូមិបាលស្រុក-ខណ្ឌ ។ ឧទាហរណ៍៖ ជុំ កាន "លីវ" $ក_1$

សាន កប $ក_2$

នៅទំព័រខាងខ្នងនេះ ពីក្រោមលេខ និងអក្ខរសញ្ញាខ្លួនមានតារាងមួយបែងចែកជាបួនខ្ទង់ធំៗដែលមានខ្លឹមសារដូចខាងក្រោមនេះ៖

**-ខ្ទង់ធំទី១** គឺជាខ្ទង់សម្រាប់ពិពណ៌នាអំពីក្បាលដីមួយក្បាល ហើយដែលជាកម្មវត្ថុរបស់កម្មសិទ្ធិករមួយនាក់ ឬភោគីមួយនាក់ "ជារូបវន្តបុគ្គល ឬនីតិបុគ្គល ។ ខ្ទង់ធំទី១នេះចែកចេញជា ពីរខ្ទង់តូចៗទៀតគឺ៖

**-ខ្ទង់តូចទី១ក្នុងខ្ទង់ធំទី១**

ខ្ទង់នេះសម្រាប់បញ្ជាក់ពីប្រភេទដី

ឧទាហរណ៍៖ ដីស្រែ សរសេរអក្សរកាត់ "ស្រ"

ដីចម្ការ សរសេរ "ចម្ការ"

ដីលំនៅឋាន សរសេរ លំនៅឋាន ឬ "ភ"

**-ខ្ទង់តូចទី២នៃខ្ទង់ធំទី១៖** សម្រាប់បញ្ជាក់ពីទំហំដីដែលមានចែកជាបីចន្លោះតូចៗ ចន្លោះទី១គឺជាឯកតា ជាហិកតា សរសេរអក្សរកាត់ "ហ" ចន្លោះទី២ គឺអារ សរសេរកាត់ "អ" ចន្លោះទី៣ គឺសង់ទីអារ សរសេរ "ស"។

**-ខ្ទង់ធំទី២៖** ខ្ទង់នេះសម្រាប់ចុះអត្រានុកូលដ្ឋានរបស់អ្នកកាន់កាប់អចលនវត្ថុ។ ខ្ទង់នេះនិយាយដាច់ដោយឡែកតែពីមនុស្ស ពោលគឺម្ចាស់ដីដែលចែកចេញជាបួនខ្ទង់តូចៗ។

**-ខ្ទង់តូចទី១នៃខ្ទង់ធំទី២៖** ខ្ទង់នេះសម្រាប់ចុះនាមត្រកូល និងនាមខ្លួន ទាំងប្តីប្រពន្ធ ព្រមទាំងបញ្ជាក់ឱ្យបានច្បាស់លាស់ពីប្រភេទអចលនទ្រព្យដូចជា៖

**ក-ទ្រព្យខាងប្តី "** " ត្រូវសរសេរនាមត្រកូល និងនាមប្តីនៅបន្ទាត់ទី១ រួចសរសេរឈ្មោះប្រពន្ធនៅបន្ទាត់ទី២ សរសេរក្នុងវង់ក្រចក " "។

ឧទាហរណ៍ សុខ សាន្ត

"ជាប្តីនាងស៊ុម"

**ខ-ទ្រព្យខាងប្រពន្ធ "** " ត្រូវសរសេរនាមត្រកូល និងនាមខ្លួនប្រពន្ធនៅបន្ទាត់ទី១ ឯឈ្មោះប្តីជាអ្នកពាក់ព័ន្ធជាមួយ ត្រូវសរសេរក្រោមនៅបន្ទាត់ទី២ក្នុងវង់ក្រចក។

ឧទាហរណ៍ នាង ខៀវ

"ជាប្រពន្ធ ម៉ែន គីម"

**គ-ទ្រព្យសម្បត្តិរួម "ប្តី ប្រពន្ធ" "** " បើទ្រព្យសម្បត្តិនេះជាទ្រព្យសម្បត្តិរួមគ្នា ប្តីប្រពន្ធត្រូវចុះនាមត្រកូល និងនាមខ្លួនរបស់ប្តីជាមុននៅក្នុងបន្ទាត់ទី១ នៅជួរបន្ទាត់ទី២ ចំពាក់កណ្តាល នាមត្រកូល និងនាមខ្លួនរបស់ប្តីបន្ទាត់ខាងលើ ដាក់ថា និង។

បន្ទាត់ទី៣ដាក់ឈ្មោះប្រពន្ធ ទាំងនាម និងគោត្តនាម បន្ទាត់ទី៤ ដាក់ថា ប្រពន្ធ ក្នុងវង់

ក្រចក "          "។

**ឃ-ទ្រព្យលីវ** ប្រភេទទ្រព្យនេះ ទោះបីម្ចាស់ទ្រព្យជាភេទប្រុស ឬភេទស្រីក៏ដោយ សរសេរនាម និងគោត្តនាមម្ចាស់ទ្រព្យនៅជួរបន្ទាត់ទី១ ហើយបន្ទាត់ទី២ ចំពីក្រោមឈ្មោះម្ចាស់ទ្រព្យខាងលើ ត្រូវសរសេរដាក់ថា លីវ ក្នុងវង់ក្រចក "          "។

ឧទាហរណ៏៖ សេក សោម

"លីវ"

ខ្ទង់តូចទី១នៃខ្ទង់ធំទី២នេះ សរសេរបាន... មិនអនុញ្ញាតឱ្យសរសេរលើសពីនេះឡើយ ទោះបីប្រភេទទ្រព្យដទៃក្រៅពីប្រភេទ៤ខាងលើ។

**ខ្ទង់តូចទី២នៃខ្ទង់ធំទី២** ខ្ទង់នេះសម្រាប់ចុះថ្ងៃ ខែ ឆ្នាំ និងស្រុកកំណើតរបស់ម្ចាស់ដីគ្រប់ប្រភេទ។

នៅបន្ទាត់ទី១ ចំឈ្មោះម្ចាស់ដី ភ្នាក់ងារសុរិយោដីយើងត្រូវសរសេរតែឆ្នាំកំណើតតែម្តង មិនបាច់ចុះថ្ងៃ ខែ ទេ។

ឧទាហរណ៏៖ ១៩៣៨, ១៩០១

នៅបន្ទាត់ទី២ក្នុងខ្ទង់នេះ ក្រោមឆ្នាំកំណើតត្រូវសរសេរឃុំ ឬសង្កាត់ដែលម្ចាស់ដីកើត មិនបាច់ដាក់ស្រុក ឬខេត្តទេ។

**-ត្រង់ខ្ទង់ដាក់ថាសាវតារ** "ខ្ទង់ទី៣តូចនៃខ្ទង់ទី២ធំ"

-ខ្ទង់នេះត្រូវសរសេរនៅលើបន្ទាត់ទី១ ដាក់ឈ្មោះឪពុករបស់ម្ចាស់ដី សរសេរអក្សរកាត់ ឧទាហរណ៏៖ ឪ៖ ម៉ែន។ ឯបន្ទាត់ទី២ ដាក់ឈ្មោះម្តាយ ដោយសរសេរម្តាយជាអក្សរកាត់ដាក់ថា ម៖ ខៀវ។

ត្រង់ចំណុចនេះ បើឪពុក ឬម្តាយ ម្ចាស់ដីមិនស្គាល់ឈ្មោះ ភ្នាក់ងារសុរិយោដី ត្រូវសរសេរ ឪ៖ មិនស្គាល់ ឬម៖ មិនស្គាល់។

**-ខ្ទង់ទី៤តូចនៃខ្ទង់ធំទី២** ខ្ទង់នេះសម្រាប់បញ្ជាក់ពីសញ្ជាតិ ម្ចាស់អចលនវត្ថុដែលជាជនជាតិខ្មែរ មិនមែនជាជនជាតិបរទេសឡើយ ហើយត្រូវសរសេរពាក្យខ្មែរឱ្យចំបន្ទាត់ម្ចាស់អចលនវត្ថុតាមប្រភេទអចលនវត្ថុ។

ឧទាហរណ៍ទី១ សួន សេន ខ្មែរ ឧទាហរណ៍ទី២ នាង គង់ ខ្មែរ

"ជាប្ដីនាង គង់" "ជាប្រពន្ធ សួន សេន"

**-ខ្ទង់ធំទី៣៖** ខ្ទង់នេះបញ្ជាក់យ៉ាងច្បាស់លាស់ពីការទំនាក់ទំនងរវាងអចលនវត្ថុ និងម្ចាស់អចលនវត្ថុ ដោយផ្អែកលើលិខិតស្នាមផ្លូវការជាមូលដ្ឋាន។

ខ្ទង់ទី៣ធំ ចែកចេញជាពីរខ្ទង់តូចៗ ដែលមានខ្លឹមសារដូចខាងក្រោម៖

**ខ្ទង់តូចទី១នៃខ្ទង់ធំទី៣**

ខ្ទង់នេះសម្រាប់ធ្វើលេខាចារឹកនូវសិទ្ធិប្រត្យក្សនៃអចលនវត្ថុបញ្ជាក់ពីប្រវត្តិអចលនវត្ថុតាមរយៈលិខិតផ្លូវការផ្សេងៗដែលពាក់ព័ន្ធ៖

ឧទាហរណ៍៖ ពីទ្រព្យរដ្ឋមកឈ្មោះ..........................................

បានមកពីទិញ ពីការធ្វើអំណោយ...........................។

ភ្នាក់ងារសុរិយោដីត្រូវធ្វើចរន្តការ និងធ្វើលេខាចារឹកជាប្រចាំ និងជាលំដាប់លំដោយនៅក្នុងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុនេះ ដើម្បីតាមដាននូវរាល់ការវិវត្តនៃអចលនវត្ថុ។

ការធ្វើលេខាចារឹកត្រូវបញ្ជាក់ឱ្យច្បាស់ពីប្រភពនៃអចលនវត្ថុ ប្រភេទនៃអចលនទ្រព្យដោយផ្អែកលើលិខិតផ្សេងៗដូចជា លិខិតបតិដ្ឋាភាគ លិខិតផ្ទេរសិទ្ធិ លិខិតទទួលស្គាល់ លិខិតប្រកាស លិខិតកែប្រែ..................ជាដើម។

**ខ្ទង់តូចទី២នៃខ្ទង់ធំទី៣**

ខ្ទង់នេះសម្រាប់ធ្វើចរន្តការ និងធ្វើលេខាចារឹកនូវរាល់បន្ទុកលើអចលនវត្ថុក្នុងនោះមាន៖

-ការបញ្ចាំបានប្រគល់អចលនវត្ថុ ឬឥតប្រគល់អចលនវត្ថុ

-សេវភាព

-ផលុបភោគ

-វិសុណ្ឌាប័ន

-ការហាមមិនឱ្យប៉ះពាល់លើសិទ្ធិនៃអចលនវត្ថុ

-និក្ខេប ឬអ៊ីប៉ូតែក

*វាយឡើងវិញ*

ខ្ទង់នេះសម្រាប់ចុះនូវការលើកលែងវិញនូវបន្ទុកលើអចលនវត្ថុ ឬការលុបវិញ ការហាមឃាត់មិនឱ្យលក់........................។

**-ខ្ទង់ផ្សេងៗជាខ្ទង់ទី៤ធំ** ខ្ទង់នេះសម្រាប់ទុកកែតម្រូវតាមលក្ខណៈបច្ចេកទេសរបស់ការងារសុរិយោដី ក្នុងការសរសេរខុស ឬបញ្ជាក់ពីទិដ្ឋភាពជាក់ស្តែងពាក់ព័ន្ធក្នុងការបំបែកក្បាលដីលក់ឱ្យ ឬចែក.......................។

ភ្នំពេញ ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៩៤

**ជ.ប្រធាននាយកដ្ឋានសុរិយោដី**

**អនុប្រធានទទួលបន្ទុកក្តាប់រួម**

**ហត្ថលេខា និងត្រា**

**លឹម វ៉ាន់**

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ៥៧អនក្រ

## អនុក្រឹត្យ
## ស្តីពីការផ្តល់សិទ្ធិចុះហត្ថលេខាលើប្លង់ដីកម្មសិទ្ធិ ការផ្ទេរកម្មសិទ្ធិ និងអាជ្ញាប័ណ្ណសាងសង់អគារក្នុងរាជធានីភ្នំពេញ

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសេចក្តីត្រូវការចាំបាច់

### សម្រេច

**មាត្រា១**

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ប្រចាំរាជធានីភ្នំពេញជាអ្នកមានសិទ្ធិចុះហត្ថលេខាលើប្លង់ដីកម្មសិទ្ធិ ការផ្ទេរកម្មសិទ្ធិ និងអាជ្ញាប័ណ្ណសាងសង់អគារគ្រប់ផ្នែកក្នុងរាជធានីភ្នំពេញ។

**មាត្រា២**

ក្នុងករណីអវត្តមានឯកឧត្តមប្រតិភូ ត្រូវផ្ទេរសិទ្ធិជូនអភិបាលរងម្នាក់ ដើម្បីចុះហត្ថលេខាជំនួស។

**មាត្រា៣**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៤**

*វាយឡើងវិញ*

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ត្រូវទទួលអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហត្ថលេខា និងចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៩៤

| | | |
|---|---|---|
| <u>កន្លែងទទួល</u> | **នាយករដ្ឋមន្ត្រីទី១** | **នាយករដ្ឋមន្ត្រីទី២** |
| -ខុទ្ទកាល័យព្រះមហាក្សត្រ | **ព្រះហស្តលេខា** | **ហត្ថលេខា** |
| -អគ្គលេខាធិការដ្ឋានរដ្ឋសភា | **និងត្រា** | |
| -ដូចមាត្រា៤ | **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |
| -ឯកសារ-កាលប្បវត្តិ | | |

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ៥៨អនក្រ

## អនុក្រឹត្យ

## ស្តីពីការផ្ទេរនាយកដ្ឋានសុរិយោដីនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឋិតនៅក្រោមការគ្រប់គ្រងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- យោងតាមសំណូមពរចាំបាច់

## សម្រេច

### មាត្រា១

ផ្ទេរនាយកដ្ឋានសុរិយោដីនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទាំងក្របខ័ណ្ឌមន្ត្រីរាជការ រួមទាំងចលនវត្ថុ និងអចលនវត្ថុទាំងអស់ឱ្យឋិតនៅក្រោមការគ្រប់គ្រងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

### មាត្រា២

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៣**

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងរដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែតុលា ឆ្នាំ១៩៩៤

| កន្លែងទទួល | នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
|---|---|---|
| -ខុទ្ទកាល័យព្រះមហាក្សត្រ | **ព្រះហស្តលេខា** | **ហត្ថលេខា** |
| -អគ្គលេខាធិការដ្ឋានរដ្ឋសភា | **និងត្រា** | |
| -ខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១ | **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |
| -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២ | | |
| -ដូចមាត្រា៣ | | |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

លេខ០០៣សរ/សហវ/ទរ                    ភ្នំពេញ ថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៩៥

## សារាចរ

## ស្តីពីការធ្វើការធ្វើកម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ (ដីធ្លី និងអគារ)

កន្លងមកការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងខេត្ត ក្រុង ទើបតែអនុវត្តបានត្រឹមការកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌប្រចាំឆ្នាំតែប៉ុណ្ណោះ។ ទន្ទឹមនេះ គោលនយោបាយរបស់រាជរដ្ឋាភិបាលបាន និងកំពុងជំរុញយ៉ាងសកម្ម ក្នុងការពិនិត្យតាមដាន និងប្រមូលផ្តុំកត់ត្រានូវទ្រព្យសម្បត្តិរដ្ឋ ដើម្បីគ្រប់គ្រងឱ្យបានម៉ឺងម៉ាត់តាមផ្លូវច្បាប់។

ដើម្បីចៀសវាងនូវការបាត់បង់ទ្រព្យសម្បត្តិរដ្ឋជាយថាហេតុ និងក្នុងគោលបំណងបង្កលក្ខណៈងាយស្រួលឱ្យរាជរដ្ឋាភិបាលគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមធ្វើការណែនាំដល់គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងខេត្ត-ក្រុងនានាដូចតទៅ៖

១-ត្រូវចាត់តាំងធ្វើកម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ (ដីធ្លី និងអគារ) ដែលឋិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងខេត្ត-ក្រុង ទោះបីជាដីធ្លី និងអគារមួយចំនួនដែលបានជួលឱ្យឯកជន ឬក្រុមហ៊ុន (ក្នុងស្រុក និងបរទេស) ក្តី ដោយរាប់ទាំងអគារសំណង់ដែលបានជួសជុល និងសាងសង់ កំពុងដំណើរការអាជីវកម្ម សេវាកម្មផង (ផ្អែកតាមកិច្ចសន្យាជួល និងកិច្ចសន្យាវិនិយោគដែលកំពុងអនុវត្ត) នោះជាបន្ទាន់។

២-ការិយាល័យភូមិបាលខេត្ត-ក្រុងត្រូវរៀបចំធ្វើកម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ ជូនដល់បណ្តាក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងខេត្ត-ក្រុងឱ្យបានទាន់ពេលវេលា។

៣-ក្រោយពេលបានរៀបចំធ្វើកម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ (ដីធ្លី និងអគារ) រួចរាល់ហើយក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងខេត្ត-ក្រុងទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើ

*វាយឡើងវិញ*

បណ្តាឯកសារនៃកម្មសិទ្ធិទាំងនោះមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៥ជាកំណត់។

ក្រោយពេលទទួលបាននូវសារាចរនេះ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងខេត្ត ក្រុង ត្រូវមានវិធានការអនុវត្ត ការធ្វើកម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ (ដីធ្លី និងអគារ) ឱ្យមានប្រសិទ្ធភាពខ្ពស់។

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ហត្ថលេខា និងត្រា**

**គាត ឈន់**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**នាយកដ្ឋានសុរិយោដី** ភ្នំពេញ ថ្ងៃទី១២ ខែមករា ឆ្នាំ១៩៩៥

លេខ០០៤សដ

**ប្រធាននាយកដ្ឋានសុរិយោដី**

**ជម្រាបមក**

**លោកប្រធានការិយាល័យសុរិយោដីគ្រប់ខេត្ត-ក្រុង**

កម្មវត្ថុ៖ សេចក្តីណែនាំស្តីពីការអនុវត្តតាមស្មារតីអង្គប្រជុំបូកសរុបការងារសុរិយោដីទូទាំងប្រទេស។

ឯកសារភ្ជាប់៖ កំណត់ហេតុអង្គប្រជុំបូកសរុបការងារសុរិយោដីពីថ្ងៃ២៨ ដល់៣០ ធ្នូ ១៩៩៤

ន័យដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបលោកប្រធានថា ដើម្បីអនុវត្តឱ្យបានល្អប្រសើរ និងដើម្បីឱ្យបានឯកភាពគ្នាទូទាំងប្រទេស តាមស្មារតីនៃអង្គប្រជុំ នាយកដ្ឋានសូមណែនាំនូវខ្លឹមសារគោលមួយចំនួនដូចខាងក្រោម៖

១-ជំរុញជម្រះបញ្ជី "បិទបញ្ជី" ឯកសារចាស់ឱ្យចប់ត្រឹមថ្ងៃ៣១ មករា ១៩៩៥ ដោយត្រូវរាយការណ៍មកនាយកដ្ឋាននៅថ្ងៃ១៥ កុម្ភៈ ១៩៩៥ យ៉ាងយូរអំពី៖

-ចំនួនពាក្យដែលបានទទួលទូទាំងខេត្ត-ក្រុង និងលេខរៀងបញ្ឈប់បញ្ជីក្នុងសៀវភៅទទួលពាក្យ និងបង្កាន់ដៃទទួលពាក្យ។

-លេខប័ណ្ណសម្គាល់សិទ្ធិដែលបានចេញហើយ តាមឃុំនីមួយៗដោយបញ្ឈប់បញ្ជីក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ។

-កំណត់ហេតុដែលបានកសាងហើយមិនទាន់សម្រេច "នៅកន្លែងណាខ្លះ?"

-ឯកសារដែលសល់មិនទាន់ប្រើប្រាស់ដូចជាប័ណ្ណ កំណត់ហេតុអង្កេត ពាក្យស្នើ សៀវភៅចុះបញ្ជីអចលនវត្ថុ បង្កាន់ដៃទទួលពាក្យ សៀវភៅទទួលពាក្យបង្កាន់ដៃ ក ខ គ ...។

*វាយឡើងវិញ*

២-ចាប់អនុវត្តប្រើប្រាស់ឯកសារថ្មីដែលទីស្តីការគណៈរដ្ឋមន្ត្រីបានឯកភាពហើយ តាមលិខិតលេខ១៦២៣សជណ/កស ចុះថ្ងៃទី០៧ កញ្ញា ១៩៩៤ ចាប់ពីថ្ងៃ១ កុម្ភៈ ១៩៩៥ ដោយរាល់ប័ណ្ណសម្គាល់សិទ្ធិថ្មី ត្រូវចុះហត្ថលេខានាយកដ្ឋានបន្ទាប់ពីមានហត្ថលេខាបំពេញរបស់លោកប្រធានការិយាល័យសុរិយោដីខេត្ត-ក្រុង។

ចំពោះការសម្រេចហេតុអង្កេត សូមរក្សាទុកដដែល តាមខ្លឹមសារសេចក្តីណែនាំអនុវត្តលេខ០៣សណេន ចុះថ្ងៃ០៣-០៦-៨៩ រហូតដល់មានគោលការណ៍ថ្មីមកជំនួស។

៣-ធ្វើការផ្សព្វផ្សាយអំពីតម្លៃប្រើប្រាស់របស់ប័ណ្ណសម្គាល់សិទ្ធិ ទាំងថ្មី ទាំងចាស់ គឺមានតម្លៃដូចគ្នា។

៤-កម្មករអណ្តែតមិនអនុញ្ញាតឱ្យកាន់កាប់ “Tenue à jour” ឬកសាងសៀវភៅចុះបញ្ជីអចលនវត្ថុជាដាច់ខាត។

៥-ការិយាល័យសុរិយោដីខេត្ត-ក្រុង ត្រូវធ្វើតារាងលេខអាទិសង្កេត “N° initial” តាមឃុំ ស្រុក មកនាយកដ្ឋាន ដើម្បីមានមូលដ្ឋានកសាងសៀវភៅចុះបញ្ជីអចលនវត្ថុឱ្យស្របគ្នា។

នាយកដ្ឋាននឹងប្រគល់សិទ្ធិជូនដល់ការិយាល័យសុរិយោដីខេត្ត-ក្រុងណាដែលអនុវត្តបានល្អការងារសុរិយោដី ក្នុងកាលដ៏គួរខាងមុខ។

នាយកដ្ឋានសង្ឃឹមលើស្មារតីទទួលខុសត្រូវរបស់អស់លោក ក្នុងការអនុវត្តឱ្យបានសម្រេចលទ្ធផលនៃអង្គប្រជុំបូកសរុបការងារសុរិយោដីទូទាំងប្រទេស។

**ប្រធានស្តីទី**

**ហត្ថលេខា និងត្រា**

**លឹម វ៉ាន់**

ចម្លងជូន
-ទីស្តីការគណៈរដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"
-ការិយាល័យអភិរក្សសុរិយោដី
-ការិយាល័យអធិការកិច្ច
"ដើម្បីមុខការ"
-ឯកសារ-កាលប្បវត្តិ

*វាយឡើងវិញ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**នាយកដ្ឋានសុរិយោដី**
លេខ០៣២សដ

ភ្នំពេញ ថ្ងៃទី២១ ខែ០២ ឆ្នាំ១៩៩៥

**ប្រធាននាយកដ្ឋានសុរិយោដី**
**ជម្រាបមក**
**លោកប្រធានការិយាល័យសុរិយោដីគ្រប់ខេត្ត-ក្រុង**

កម្មវត្ថុ៖ ការផ្តល់របាយការណ៍ស្តីពីការជម្រះបញ្ជីឯកសារចាស់

យោង៖ -សេចក្តីណែនាំលេខ០០៤សដ ចុះថ្ងៃទី១២-០១-៩៥

-កម្រងអត្ថបទបច្ចេកទេសសុរិយោដី II/91

ន័យដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ នាយកដ្ឋានសុរិយោដីពិនិត្យឃើញថា មានការិយាល័យសុរិយោដីជាច្រើនបាន និងកំពុងយកចិត្តទុកដាក់អនុវត្តបានល្អ។ ទន្ទឹមនេះ ក៏មានការិយាល័យសុរិយោដីមួយចំនួនខ្វះភាពម្ចាស់ការ អសកម្ម និងមានការយឺតយ៉ាវក្នុងការបិទបញ្ជីសុរិយោដី ដែលនាយកដ្ឋានបានកំណត់នៅថ្ងៃទី៣១-០១-៩៥ ហើយត្រូវបញ្ជូនមកនាយកដ្ឋានឱ្យបានមុនថ្ងៃទី១៥-០២-៩៥ជាកំហិត។ ទង្វើទាំងអស់នេះវាអាចរាំងស្ទះដល់ការផ្តល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុគំរូថ្មីជូនប្រជាពលរដ្ឋ និងជះឥទ្ធិពលមិនល្អដល់ផ្នែកជំនាញ។

ដូចនេះ ដើម្បីឱ្យការងារផ្តល់ប័ណ្ណប្រព្រឹត្តទៅបានមិនរអាក់រអួល នាយកដ្ឋានសូមណែនាំបន្ថែមនូវចំណុចគន្លឹះដូចតទៅ៖

១-ស្នើបញ្ជូនរបាយការណ៍តាមខ្លឹមសារដែលបានកំណត់ក្នុងសេចក្តីណែនាំលេខ០០៤សដ មកនាយកដ្ឋានជាបន្ទាន់។

២-ស្នើធ្វើតារាងស្រង់ឈ្មោះឃុំ ស្រុក ព្រមទាំងបញ្ជាក់លេខអាទិសង្កេតចុងក្រោយតាមឃុំនីមួយៗ។

*វាយឡើងវិញ*

-ធ្វើតារាងស្រង់ឈ្មោះ អ្នកកាន់កាប់អចលនវត្ថុតាមលំដាប់អក្សរ (TA) ។

-ក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុនីមួយៗមានរំលងលេខឬទេ? រំលងលេខនេះបានន័យថា ចុះលេខចោលដោយពុំបានធ្វើលេខាចារឹកសោះ ឬធ្វើដែរតែមិនគ្រប់គ្រាន់ក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ ហើយប្រគល់ប័ណ្ណទៅឱ្យម្ចាស់កាន់កាប់អចលនវត្ថុតែម្តង "បើមានសូមស្រង់លេខទាំងនោះក្នុងឃុំ ស្រុក ហើយបញ្ជាក់ពីមូលហេតុនៃការខ្វះចន្លោះ" ។

-សរុបឯកសារដែលមិនប្រើប្រាស់បច្ចុប្បន្ននៅឯណាខ្លះ?

-បញ្ជាក់អំពីការលំបាកដែលកំពុងជួបប្រទះនៅពេលនេះ ។

អាស្រ័យហេតុនេះ ស្នើលោកប្រធានគ្រប់ការិយាល័យ យកចិត្តទុកដាក់បំពេញការងារនេះឱ្យបានសម្រេច រួចបញ្ជូនមកនាយកដ្ឋានជាបន្ទាន់បំផុត ។ ករណីដែលមានការយឺតយ៉ាវក្នុងការបញ្ជូនរបាយការណ៍មកនាយកដ្ឋាន លោកប្រធានត្រូវទទួលខុសត្រូវចំពោះមុខនាយកដ្ឋាន ហើយនឹងមិនអនុញ្ញាតឱ្យបន្តធ្វើឯកសារថ្មីបានឡើយ ។

នាយកដ្ឋានសង្ឃឹមលើស្មារតីទទួលខុសត្រូវខ្ពស់របស់អស់លោក ។

**ជ.ប្រធាននាយកដ្ឋានសុរិយោដី**

**ប្រធានស្តីទី**

**ហត្ថលេខា និងត្រា**

**លឹម វ៉ាន់**

<u>ចម្លងជូន</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់សាលាខេត្ត-ក្រុង

-នាយកដ្ឋានបុគ្គលិក

*"ដើម្បីជូនជ្រាប"*

-ការិយាល័យអភិរក្សសុរិយោដី

-ការិយាល័យអធិការកិច្ច

*"ដើម្បីមុខការ"*

-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
លេខ០០៥សជណ/សហវ/ពដ ភ្នំពេញ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៥

## សេចក្តីជូនដំណឹង
## ស្តីពីបទប្បញ្ញត្តិទាំងឡាយស្តីពីពន្ធ និងអាករដែលប្រមូលដោយអង្គការពន្ធ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានកិត្តិយសសូមប្រកាសដំណឹងជម្រាបជូនលោក លោកស្រីជាអាជីវករ ជាអ្នកដឹកនាំ ជានិយោជិតនៃសហគ្រាសសាធារណៈ ឬឯកជនព្រមទាំងប្រជាពលរដ្ឋនៅក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ឱ្យបានជ្រាបថា បទប្បញ្ញត្តិទាំងឡាយស្តីពីពន្ធ និងអាករប្រមូលដោយអង្គការពន្ធ មានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ១៩៩៥ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ១០នស៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ មានខ្លឹមសារសំខាន់ៗដូចខាងក្រោម៖

**I-ពន្ធលើប្រាក់បៀវត្ស**

គឺជាពន្ធប្រចាំខែ កំណត់លើប្រាក់ចំណូលសរុបទោះជាមានឈ្មោះហៅថាជាអ្វីក៏ដោយហើយនិងលើអត្ថប្រយោជន៍ជាវត្ថុ ដែលបានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញសកម្មភាពបម្រើសហគ្រាសសាធារណៈ ឬឯកជន។

ការបើកបៀវត្សបង្កើតជាហេតុបណ្តាលឱ្យជាប់ពន្ធ។ ពន្ធនេះត្រូវបង់តាមរបៀបកាត់ទុកជារៀងរាល់ខែ ដោយនិយោជកមុនពេលបើកបៀវត្ស។

និយោជកត្រូវបង់ប្រាក់ពន្ធដែលខ្លួនបានកាត់ទុកនេះជូនទៅអង្គការពន្ធដារយ៉ាងយឺតបំផុតនៅថ្ងៃទី១៥ នៃខែបន្ទាប់។

បើនិយោជកនៅបរទេសគឺអ្នកតំណាងសារពើពន្ធនៅកម្ពុជាដែលនិយោជកបានចាត់តាំង នោះជាអ្នកបំពេញភារកិច្ចកាត់ទុកពន្ធលើបៀវត្ស មុននឹងបើបៀវត្សឱ្យអ្នកបម្រើការងារ និងអ្នកទទួលបំពេញភារកិច្ចបង្វែរប្រាក់ពន្ធបង់ជូនរដ្ឋ។

ប្រាក់បៀវត្សប្រចាំខែដែលត្រូវជាប់ពន្ធ ត្រូវបែងជាភាគសម្រាប់គណនាប្រាក់ពន្ធដោយគិតតាមអត្រាកំណើនពី៥% ដល់២០% លើភាគនីមួយៗនៃប្រាក់បៀវត្សត្រូវជាប់ពន្ធ។ ភាគនៃប្រាក់បៀវត្សប្រចាំខែពី១៛ ដល់៧៥០.០០០៛ មិនត្រូវជាប់ពន្ធឡើយ។

ផ្អែកតាមការបង្ហាញភស្តុតាងនៃស្ថានភាពគ្រួសារអ្នកបម្រើការងារជាសហព័ន្ធណាមួយដែលមានកូនជាអនីតិជន ឋិតនៅក្នុងបន្ទុកនាពេលដែលត្រូវបង់ពន្ធ ត្រូវបានទទួលនូវការបន្ថយមូលដ្ឋានកំណត់ពន្ធចំនួន៧៥.០០០រៀល ក្នុងកូនម្នាក់ៗ។

**II-ពន្ធលើដីមិនបានប្រើប្រាស់**

គឺជាពន្ធដែលកំណត់លើដីគ្មានសំណង់ និងដីដែលមានសំណង់បោះបង់ឋិតនៅក្នុងទីក្រុងនានា និងតំបន់ទាំងឡាយដែលកំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់។

ពន្ធនេះត្រូវគណនាដោយកម្មសិទ្ធិករ នៅលើគំរូលិខិតប្រកាសដែលអង្គការពន្ធផ្តល់ជូន និងត្រូវបង់យ៉ាងយឺតបំផុតនៅថ្ងៃទី៣០ ខែកញ្ញា នៃឆ្នាំនីមួយៗជូនទៅផ្នែកពន្ធនៅកន្លែងដែលដីធ្លីជាប់ពន្ធឋិតនៅ។

ពន្ធនេះត្រូវបង់តាមអត្រា២%លើថ្លៃគិតតាមទីផ្សារ វាយតម្លៃទៅតាមថ្លៃគិតក្នុងមួយម៉ែត្រក្រឡា កំណត់សម្រាប់ឆ្នាំនីមួយៗដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់។ ក្នុងការគិតពន្ធត្រូវបានអនុញ្ញាតឱ្យកាត់ចេញពីមូលដ្ឋានកំណត់ពន្ធចំនួន១២០០ម៉ែត្រក្រឡា សម្រាប់ដីមួយកន្លែង។

**III-ពន្ធលើប្រាក់ចំណេញ**

ពន្ធលើប្រាក់ចំណេញកំណត់លើប្រាក់ចំណេញដែលសម្រេចបានដោយរូបវន្តបុគ្គល និងនីតិបុគ្គលដែលប្រកបរបរនៅក្នុងព្រះរាជាណាចក្រកម្ពុជា នូវសកម្មភាពឧស្សាហកម្ម សិប្បកម្ម ពាណិជ្ជកម្ម សេវាកម្ម ដោយរាប់បញ្ចូលទាំងអាជីវកម្មព្រៃឈើ អណ្តូងរ៉ែ និងនេសាទផង។

**ការកំណត់ពន្ធនេះមានពីររបៀបគឺ៖**

-តាមរបៀបកំណត់លើប្រាក់ចំណេញម៉ៅការ

-ឬមួយតាមរបៀបកំណត់លើប្រាក់ចំណេញពិតប្រាកដ ដែលបានកំណត់ចេញពីបញ្ជីគណនេយ្យ ចំពោះសហគ្រាសជានីតិបុគ្គល ឬសហគ្រាសឯកត្តជនដែលសម្រេចបានផលរបរប្រចាំឆ្នាំលើសពី៥០០លានរៀល បានមកពីការលក់ដូរ ឬលើសពី២៥០លានរៀល ចំពោះសហគ្រាសដែលប្រកបរបរធ្វើសេវាកម្ម ។

សហគ្រាសដែលត្រូវជាប់ពន្ធលើប្រាក់ចំណេញពិតប្រាកដត្រូវបង់ជារៀងរាល់ខែនូវប្រាក់រំដោះពន្ធលើប្រាក់ចំណេញចំនួន២% គិតលើផលរបរដែលគ្រឹះស្ថានទាំងអស់របស់សហគ្រាសសម្រេចបានក្នុងខែ ។ ប្រាក់រំដោះនេះត្រូវបង់ជូនទៅអង្គភាពពន្ធដារយ៉ាងយឺតបំផុតនៅថ្ងៃទី១០ នៃ ខែបន្ទាប់ ។

ប្រាក់រំដោះនេះនឹងត្រូវបានដកចេញពីចំនួនប្រាក់ពន្ធដែលត្រូវបង់ សម្រាប់ឆ្នាំនីមួយៗ ដែលកំណត់លើមូលដ្ឋាននៃលទ្ធផលសារពើពន្ធគិតចេញពីបញ្ជីគណនេយ្យ ។

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំដែលត្រូវប្រកាសយ៉ាងយឺតបំផុតនៅថ្ងៃទី៣១ ខែមីនា តាមគំរូដែលអង្គការពន្ធផ្តល់ជូន ត្រូវគណនាដោយគិតតាមអត្រាសមាមាត្រ២០% សម្រាប់នីតិបុគ្គល និងតាមអត្រាកំណើនតាមថ្នាក់ពី១០% ទៅ៣០% សម្រាប់សហគ្រាសឯកត្តជន ។

ក្នុងករណីដែលប្រាក់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំមានចំនួនតិចជាងប្រាក់រំដោះដែលបានបង់ចំនួនលើសនេះ បង្កើតជាឥណទានពន្ធដែលត្រូវកាត់ចេញពីប្រាក់រំដោះដែលត្រូវបង់សម្រាប់ការិយបរិច្ឆេទបន្ទាប់ ឬសងវិញ ។

ប្រាក់រំដោះដែលបានបង់មានចំនួនស្មើ០,៥%នៃផលរបរនោះគឺជាប្រាក់ពន្ធអប្បបរិមាលើប្រាក់ចំណេញមិនត្រូវបានឱ្យផាត់ចេញពីប្រាក់រំដោះប្រចាំខែនៃការិយបរិច្ឆេទ ឬសងវិញឡើយ ។

**IV-ពន្ធលើផលរបរ**

អាករលើផលរបរត្រូវកំណត់ចំពោះរបរនៃបុគ្គលទាំងឡាយ ដែលប្រកបរបរទិញសម្រាប់លក់ទៅវិញមួយដងមួយគ្រា ឬជានិច្ចកាល ឬប្រកបវិជ្ជាជីវៈខាងពាណិជ្ជកម្ម ឧស្សាហកម្ម សិប្បកម្ម សេវាកម្ម ដោយរាប់បញ្ចូលទាំងអាជីវកម្មព្រៃឈើ អណ្តូងរ៉ែ និងនេសាទ នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

អាករលើផលរបរនេះក៏ត្រូវកំណត់ផងដែរលើកិច្ចប្រតិបត្តិការទាំងឡាយដែលសមូហភាព ឬអង្គការណាមួយធ្វើដោយខ្លួនឯង ឬប្រគល់សម្បទានឱ្យគេធ្វើជួសនូវមុខរបរដែលមានចែងខាងលើ ។

**អត្រាអាករលើផលរបររួមមាន៖**

-១%ចំពោះកិច្ចខាងឧស្សាហកម្ម សិប្បកម្ម និងអណ្តូងរ៉ែ ។

-១០%ចំពោះ

-ផលរបរបានមកពីប្រតិបត្តិការជួលធ្វើឡើងក្នុងសណ្ឋាគារ និងសេវាកម្មជាឧបសម្ព័ន្ធទាំងឡាយដែលទាក់ទងផ្ទាល់ទៅនឹងសណ្ឋាគារ ។

-ផលរបរបានមកពីការជួលបន្ទប់លំនៅបំពាក់ដោយអចលនវត្ថុធ្វើឡើងដែលមានលក្ខណៈជាវិជ្ជាជីវៈ ។

-ផលរបរសម្រេចបាននៅក្នុងគ្រឹះស្ថានម៉ាស្សា រង្គសាល និងទីលំហែកំសាន្តនានា

-ផលរបរសម្រេចបាននៅក្នុងភោជនីយដ្ឋាន និងភេសជ្ជដ្ឋាន ។

-អត្រាអាករលើផលរបរត្រូវកំណត់២% ចំពោះកិច្ចការដទៃទៀតដែលមិនឋិតក្នុងប្រភេទកិច្ចការដូចបានរៀបរាប់ខាងលើ ។

អាករស្នាក់នៅដែលកំណត់តាមអត្រា១០% លើថ្លៃឈ្នួលបន្ទប់សណ្ឋាគារ និងផ្ទះសំណាក់នោះត្រូវទុកជានិរាករណ៍ ។

**V-ពន្ធប៉ាតង់**

ជាប្រភេទពន្ធត្រូវប្រមូលក្នុង១ឆ្នាំម្តង ពីគ្រប់សហគ្រាសទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ បន្ទាប់ពីបានបង់ពន្ធរួច សហគ្រាសទាំងឡាយត្រូវបានទទួលប័ណ្ណប៉ាតង់មួយសន្លឹក និងត្រូវយកទៅព្យួរនៅក្នុងអាជីវកម្មដ្ឋានរបស់ខ្លួន សម្រាប់បង្ហាញបញ្ជាក់ថា បានបង់ពន្ធប៉ាតង់រួចហើយ ។ ពន្ធប៉ាតង់សម្រាប់ឆ្នាំនីមួយៗត្រូវគណនាទៅតាមផលរបរនៃឆ្នាំមុន (ឬប៉ាន់ស្មាន ប្រសិនបើជាអាជីវកម្មដ្ឋានថ្មី) ។

សហគ្រាសដែលមានប្រកបរបរច្រើនត្រូវបង់ពន្ធប៉ាតង់ផ្សេងៗគ្នា ទៅតាមមុខរបរនីមួយៗ ។ ផ្អែកតាមមុខរបរ និងចំនួនផលរបរប្រាក់ពន្ធប៉ាតង់ទាបបំផុតមានចំនួន១៥.000រៀល និងខ្ពស់បំផុត១.១៤០.000រៀល ។

**VI-ពន្ធប្រថាប់ត្រា**

រាល់ការផ្ទេរកម្មសិទ្ធិអចលនទ្រព្យ ឬការផ្ទេរសិទ្ធិកាន់កាប់ដីដែលគ្មានសំណង់ក្រោមរូបភាពជាការលក់ ការដោះដូរ ការទទួលអំណោយ ការដាក់ភាគទុនក្នុងក្រុមហ៊ុន និងរាល់ការផ្ទេរកម្មសិទ្ធិ មធ្យោបាយដឹកជញ្ជូន និងយានជំនិះមានរថយន្តដឹកទំនិញធុនធ្ងន់ ធុនស្រាល រថយន្តទោចក្រយានយន្ត កាណូត សាឡាង់ និងកប៉ាល់ ត្រូវជាប់ពន្ធប្រថាប់ត្រាតាមអត្រា៤% លើតម្លៃពិតប្រាកដនៃទ្រព្យសម្បត្តិនាថ្ងៃផ្ទេរកម្មិសទ្ធិ និងសិទ្ធិកាន់កាប់។

ម្យ៉ាងទៀត លិខិតស្តីពីការបង្កើតក្រុមហ៊ុន រំលាយក្រុមហ៊ុនបញ្ចូលគ្នា រំសាយក្រុមហ៊ុន និងកិច្ចសន្យាផ្គត់ផ្គង់សេវា ឬសម្ភារៈទំនិញដល់អង្គការសាធារណៈ ក៏ត្រូវបង់ពន្ធប្រថាប់ត្រាដែរ គឺត្រូវបង់ពន្ធប្រថាប់ត្រាតាមចំនួននឹង ១០០.000រៀល។

**VII-ភារកិច្ចសំខាន់ៗមួយចំនួនរបស់អ្នកជាប់ពន្ធ និងអាករ**

បន្ថែមលើភារកិច្ចដែលបានកំណត់ក្នុងច្បាប់ស្តីអំពីហិរញ្ញវត្ថុសម្រាប់ឆ្នាំ១៩៩៤ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ១៩៩៥ បានកំណត់ចំពោះសហគ្រាសដែលត្រូវបង់ពន្ធតាមរបបពិតប្រាកដពោលគឺសហគ្រាសដែលត្រូវកាន់បញ្ជីគណនេយ្យទៅតាមប្លង់គណនេយ្យទូទៅនៃរដ្ឋកម្ពុជាត្រូវមានកាតព្វកិច្ចចុះឈ្មោះនៅនាយកដ្ឋានពន្ធដារ និងត្រូវបានអង្គការពន្ធផ្តល់លេខអត្តសញ្ញាណកម្មសារពើពន្ធមួយដែលជាលេខសម្រាប់សម្គាល់សហគ្រាស ហើយដែលសហគ្រាសត្រូវចុះលេខអត្តសញ្ញាណកម្មនេះនៅលើរាល់ឯកសាររដ្ឋបាលគ្រប់ប្រភេទ ដូចជាលិខិតប្រកាសសារពើពន្ធ ប្រតិវេទន៍គយ និងលិខិតគ្រប់ប្រភេទដែលមានលក្ខណៈពាណិជ្ជកម្ម ដូចជាបញ្ជីប៉ាន់តម្លៃ វិក្កយបត្រពាក្យសុំចូលដេញថ្លៃផ្គត់ផ្គង់សេវា ឬសម្ភារៈទំនិញដល់អង្គការសាធារណៈជាដើម។

ឯចំពោះសហគ្រាសដែលជាប់ពន្ធតាមរបបម៉ៅការដែលមានផលរបរតាមបញ្ជីពន្ធក្នុងឆ្នាំ១៩៩៤ មានចំនួនលើសពី១០លានរៀល ត្រូវកាន់បញ្ជីចំណូលដែលត្រូវមានចុះលេខទំព័រ និងត្រូវមានការបញ្ជាក់ជាមុនដោយអង្គការពន្ធ។

ចំពោះសហគ្រាសដែលប្រកបរបរលក់ទំនិញក្នុងសភាពដើម ឬផលិតផលនានាត្រូវមានកាន់បន្ថែមនូវបញ្ជីទំនិញដែលមានអមដោយវិក្កយបត្រ និងសក្ខីប័ត្រផ្សេងៗសម្រាប់បញ្ជាក់។

**VIII-ទោសប្បញ្ញត្តិ និងវិធានការផ្សេងៗក្នុងការទារបំណុលពន្ធ**

*វាយឡើងវិញ*

អ្នកជាប់ពន្ធអាករដែលមិនបានដាក់លិខិតប្រកាស និងដែលមិនបានឆ្លើយតបចំពោះការរំឭករបស់អង្គការពន្ធ ត្រូវបង់ពន្ធទៅតាមការកំណត់ជាឯកតោភាគីរបស់អង្គការពន្ធ ។

ប្រសិនបើក្រោយពីបានទទួលលិខិតជូនដំណឹងទារ និងក្រោយពីបានទទួលលិខិតរំឭកឱ្យបង់ពន្ធរួចមក អ្នកជាប់ពន្ធអាករនៅតែរឹងរូសមិនព្រមបង់ពន្ធទៀត ផ្នែកទារបំណុលពន្ធនៃអង្គការពន្ធនិងអនុវត្តវិធានការតឹងទារដែលមានរូបភាពជាការរឹបអូសចលនវត្ថុ អចលនវត្ថុ បិទជាបណ្ដោះអាសន្ន ឬជាស្ថាពរនូវគ្រឹះស្ថានវិជ្ជាជីវៈ ហើយរហូតដល់ការលក់ចលនវត្ថុ ឬអចលនវត្ថុថែមទៀត ។

ម្យ៉ាងទៀត កតតិយជនកាន់កាប់ប្រាក់របស់អ្នកជំពាក់ពន្ធអាករនឹងពិន័យនៅពេលដែលមានសំណើដោយលិខិតជូនដំណឹងរបស់អង្គការពន្ធ មានភារៈត្រូវបង់ជំនួសអ្នកជំពាក់ពន្ធនូវប្រាក់ពន្ធ ប្រាក់អាករ និងប្រាក់ពិន័យដែលអ្នកជំពាក់ពន្ធត្រូវបង់ដោយប្រើប្រាស់មូលនិធិដែលខ្លួនបានកាន់កាប់នោះ ។

អ្នកជាប់ពន្ធអាករអាចប្ដឹងទៅតុលាការរដ្ឋប្បវេណីអំពីវិធានការតឹងទារនេះ ។

សេចក្ដីជូនដំណឹងដូចបានជម្រាបជូនខាងលើនេះ សូមលោក លោកស្រី ជាអាជីវករ ជាអ្នកដឹកនាំ ជានិយោជិតទាំងអស់ជ្រាប និងទទួលប្រតិបត្តិឱ្យបានត្រឹមត្រូវតាមច្បាប់ ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរង់ចាំជម្រាបជូននូវរាល់ចម្ងល់ទាំងឡាយរបស់លោក លោកស្រីដោយសេចក្ដីរីករាយ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ហត្ថលេខា និងត្រា**

**គាត ឈន់**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
ក្រសួងយុត្តិធម៌
លេខ២០៤សរ/៩៥

ភ្នំពេញ ថ្ងៃទី០២ ខែមីនា ឆ្នាំ១៩៩៥

## សារាចរអន្តរក្រសួង

### ឧបនាយករដ្ឋមន្ត្រី ជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ជម្រាបមក

-លោកអភិបាលខេត្ត-ក្រុង
-លោកប្រធានតុលាការខេត្ត-ក្រុង
-លោកព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង

*សូមទានជ្រាប ។*

កម្មវត្ថុ៖ ស្តីអំពីសមត្ថកិច្ច និងទំនាក់ទំនងការងាររវាងអភិបាលខេត្ត-ក្រុងជាមួយប្រធានតុលាការ និងព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង ។

តាមគោលការណ៍ច្បាប់ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់បែងចែកជាខេត្ត ក្រុង ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ អភិបាលខេត្ត-ក្រុងមានអំណាចជាតំណាងរាជរដ្ឋាភិបាល ក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់ពីសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងការគ្រប់គ្រងដែនដី គ្រប់គ្រងមនុស្ស ទ្រព្យសម្បត្តិសាធារណៈ ថែរក្សាសន្តិសុខសណ្តាប់ធ្នាប់សង្គម។ ជំរុញការអភិវឌ្ឍលើគ្រប់វិស័យ ដើម្បីលើកតម្កើងជីវភាពរស់នៅរបស់ប្រជារាស្ត្រ។ អភិបាលខេត្ត-ក្រុងជាតំណាងនៃផលប្រយោជន៍ជាតិ ។

ចំណែកតុលាការ និងអយ្យការអមតុលាការខេត្ត-ក្រុងជាអំណាចឯករាជ្យកំណត់ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាត្រង់មាត្រា១០៩។ អំណាចនេះ ប្រធានតុលាការ និងព្រះ

រាជអាជ្ញាអមតុលាការខេត្ត-ក្រុងប្រើតាមរយៈសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់។ គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ "មាត្រា១១១" នៃរដ្ឋធម្មនុញ្ញ។ ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងការធានាឯករាជ្យនៃតុលាការនេះ "មាត្រា១១៣"។

ចាប់តាំងពីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលជាច្បាប់កំពូលរបស់ជាតិបានចូលជាធរមានបញ្ញត្តិរហូតដល់បច្ចុប្បន្ននេះ ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញថាលោកអភិបាលខេត្ត-ក្រុង លោកប្រធានតុលាការ និងលោកព្រះរាជអាជ្ញាអមតុលាការខេត្តក្រុងនៅពុំទាន់យល់ច្បាស់អំពីការអនុវត្តនូវតួនាទីភារកិច្ចដែលជាសមត្ថកិច្ចរបស់ខ្លួន ក្នុងការទំនាក់ទំនងការងារគ្នានៅក្នុងខេត្ត-ក្រុង ឱ្យបានល្អប្រសើរនៅឡើយ។

ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌សូមធ្វើការណែនាំដូចតទៅ៖

១-អភិបាលខេត្ត-ក្រុងត្រូវទទួលខុសត្រូវ និងធានាការគ្រប់គ្រង និងដឹកនាំវិស័យការងាររដ្ឋបាល និងនយោបាយរបស់រាជរដ្ឋាភិបាល ព្រមទាំងការងារសំខាន់ៗនៅក្នុងខេត្ត-ក្រុងរបស់ខ្លួនរួមមាន៖

-ប្រមូលព័ត៌មានទូទៅជូនរាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃ

-ផ្សព្វផ្សាយ អនុវត្ត ជំរុញ និងតាមដានការអនុវត្តច្បាប់បទប្បញ្ញត្តិ និងសេចក្តីសម្រេចផ្សេងៗ

-មានអំណាចបញ្ជាលើអាជ្ញាធរនគរបាល

-មានអំណាចគ្រប់គ្រងលើមន្ត្រីរាជការតាមខ្សែបណ្តោយ និងតាមខ្សែទទឹងដែលបំពេញការងារនៅតាមមន្ទីរនានាក្នុងខេត្ត-ក្រុង ស្របតាមមាត្រា២២នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

-មានអំណាចសម្របសម្រួលជំរុញ និងត្រួតពិនិត្យលើមន្ត្រីរាជការ លើបណ្តាមន្ទីរជំនាញនានារបស់រដ្ឋ តាំងនៅក្នុងខេត្ត-ក្រុង លើកលែងតែការងារជំនាញឯកទេសរបស់តុលាការ និងអយ្យការអមតុលាការខេត្ត-ក្រុង អភិបាលខេត្ត-ក្រុងពុំមានអំណាចត្រួតពិនិត្យទេ ស្របតាមមាត្រា១នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

២-ប្រធានតុលាការ និងព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុងត្រូវធានាអំណាចឯករាជ្យក្នុងការសម្រេចដោយឆន្ទានុសិទ្ធិស្របច្បាប់របស់ខ្លួន តាងនាមប្រជារាស្ត្រខ្មែរក្នុងនាមព្រះមហា

ក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។ ដោយឡែក វិស័យការងាររដ្ឋបាល និងនយោបាយត្រូវឋិតនៅក្រោមការដឹកនាំរបស់អភិបាលខេត្ត-ក្រុង។ ដូច្នេះ របាយការណ៍ប្រចាំខែស្តីពីសកម្មភាពការងាររបស់តុលាការ និងអយ្យការអមតុលាការខេត្ត-ក្រុងដែលផ្ញើមកក្រសួងយុត្តិធម៌ជាខ្សែបណ្តោយត្រូវចម្លងជូនអភិបាលខេត្ត-ក្រុង ដើម្បីជ្រាបជាព័ត៌មាន។

អំណើះតទៅ បើមានប្រជារាស្ត្រប្តឹងអំពីវិវាទអ្វីមួយ អភិបាលខេត្ត-ក្រុងត្រូវណែនាំឱ្យប្រជារាស្ត្រនោះទៅប្តឹងនៅតុលាការខេត្ត-ក្រុង ឬបញ្ជូនពាក្យប្តឹងរបស់សាមីព្យាបាលអ្នកប្តឹងទៅតុលាការ ដោយមិនត្រូវទទួលដោះស្រាយរឿងក្តីដែលជាសមត្ថកិច្ចរបស់តុលាការ និងអយ្យការអមតុលាការខេត្ត-ក្រុងឡើយ។

បើគូក្តីមិនឯកភាពនឹងសេចក្តីសម្រេចរបស់តុលាការ នោះត្រូវប្តឹងតវ៉ាទៅសាលាឧទ្ធរណ៍ក្នុងរយៈពេលពីរខែ ពីព្រោះមានតែតុលាការថ្នាក់លើទេដែលមានសិទ្ធិត្រួតពិនិត្យសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោម។

ក្រោយទទួលបានសារាចរនេះ សូមលោកអភិបាលខេត្ត-ក្រុង លោកប្រធានតុលាការ និងលោកព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុងប្រជុំផ្សព្វផ្សាយ និងកំណត់ឱ្យបានច្បាស់លាស់អំពីខ្លឹមសារនៃសារាចរនេះ រួចធ្វើរបាយការណ៍មកក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ឱ្យបានជ្រាបអំពីលទ្ធផលនៃការប្រជុំផ្សព្វផ្សាយសារាចរនេះ។

សូមលោកអភិបាលខេត្ត-ក្រុង លោកប្រធានតុលាការខេត្ត-ក្រុង និងលោកព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុងអនុវត្តសេចក្តីណែនាំនៃសារាចរនេះ ឱ្យបានល្អប្រសើរដើម្បីការពារផលប្រយោជន៍ច្បាប់តទៅ។

**ទេសរដ្ឋមន្ត្រីក្រសួងយុត្តិធម៌**
**ហត្ថលេខា និងត្រា**
**ចែម ស្គូន**

**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ហត្ថលេខា និងត្រា**
**ស ខេង យូ ហុកគ្រី**

<u>ចម្លងជូន</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

"ដើម្បីជ្រាប"

-កាលប្បវត្តិ-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ទីស្តីការគណៈរដ្ឋមន្ត្រី　　　　　　　　　　　ជាតិ សាសនា ព្រះមហាក្សត្រ

នាយកដ្ឋានសុរិយោដី

លេខ០៥៣សដ　　　　　　　　　　　　　　ភ្នំពេញ ថ្ងៃទី១១ ខែ០៤ ឆ្នាំ១៩៩៥

**ប្រធាននាយកដ្ឋានសុរិយោដី**

**ជម្រាបមក**

**លោកប្រធានការិយាល័យសុរិយោដីគ្រប់ខេត្ត-ក្រុង**

កម្មវត្ថុ៖　ការកំណត់អក្សរសម្គាល់លេខប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុតាមបណ្តាខេត្ត-ក្រុង

ដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបលោកប្រធានថា ដើម្បីងាយស្រួលក្នុងការសម្គាល់លេខប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ នាយកដ្ឋានបានកំណត់អក្សរកាត់តាមបណ្តាខេត្ត-ក្រុងដូចតទៅ៖

| ល.រ | ឈ្មោះខេត្ត-ក្រុង | អក្សរសម្គាល់ | សេចក្តីផ្សេងៗ | ល.រ | ឈ្មោះខេត្ត-ក្រុង | អក្សរសម្គាល់ | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១ | ក្រុងភ្នំពេញ | ភ.ព | | ១២ | បន្ទាយមានជ័យ | ប.ជ | |
| ២ | - កែប | ក.ប | | ១៣ | - សៀមរាប | ស.រ | |
| ៣ | - ព្រះសីហនុ | ព.ន | | ១៤ | - ព្រះវិហារ | ព.ហ | |
| ៤ | ខេត្តកណ្តាល | ក.ណ | | ១៥ | - កំពង់ធំ | ក.ធ | |
| ៥ | - តាកែវ | ត.ក | | ១៦ | - កំពង់ចាម | ក.ច | |
| ៦ | - កំពត | ក.ព | | ១៧ | - ក្រចេះ | ក្រ.ច | |
| ៧ | - កោះកុង | ក.ក | | ១៨ | - ស្ទឹងត្រែង | ស.ត | |
| ៨ | - កំពង់ស្ពឺ | ក.ព | | ១៩ | - មណ្ឌលគិរី | ម.គ | |
| ៩ | - កំពង់ឆ្នាំង | ក.ឆ | | ២០ | - រតនគិរី | រ.ត | |
| ១០ | - ពោធិ៍សាត់ | ព.ស | | ២១ | - ស្វាយរៀង | ស.រ | |
| ១១ | - បាត់ដំបង | ប.ប | | ២២ | - ព្រៃវែង | ព.រ | |

*វាយឡើងវិញ*

អាស្រ័យហេតុនេះ សូមលោកប្រធានគ្រប់ការិយាល័យសុរិយោដីខេត្ត-ក្រុងទទួលស្គាល់និងកត់ត្រាចំណាំតាមតារាងខាងលើជាកំណត់។

**ជ.ប្រធាននាយកដ្ឋានសុរិយោដី**

**ប្រធានស្តីទី**

**ហត្ថលេខា និងត្រា**

**លឹម វ៉ាន់**

<u>ចម្លងជូន</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់អភិបាលខេត្ត-ក្រុង

*"ដើម្បីជូនជ្រាប"*

-ការិយាល័យអភិរក្សសុរិយោដី

-ការិយាល័យអធិការកិច្ច

*"ដើម្បីអនុវត្ត"*

-ឯកសារ

*វាយឡើងវិញ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**នាយកដ្ឋានសុរិយោដី**

លេខ០៩៧សជ

ភ្នំពេញ ថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៩៥

**ប្រធាននាយកដ្ឋានសុរិយោដី**

**ជម្រាបមក**

**លោកប្រធានការិយាល័យសុរិយោដីគ្រប់ខេត្ត-ក្រុង**

*កម្មវត្ថុ៖* ករណីយឺតយ៉ាវក្នុងការផ្តល់របាយការណ៍ស្តីពីការជម្រះបញ្ជីឯកសារចាស់

*យោង៖* -លិខិតលេខ០០៤សជ ចុះថ្ងៃទី១២-០១-៩៥

-លិខិតលេខ០៣២សជ ចុះថ្ងៃទី២១-០២-៩៥

ន័យដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកប្រធានថា ការមិនព្រមអនុវត្តតាមខ្លឹមសារនៃការណែនាំនេះ វាអាចរាំងស្ទះដល់ការផ្តល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុគំរូថ្មីជូនប្រជាពលរដ្ឋ ដែលជះឥទ្ធិពលមិនល្អដល់ផ្នែកជំនាញយើង។

ដូចនេះ ដើម្បីឱ្យការងារសុរិយោដីដំណើរការបានល្អ ស្នើលោកប្រធានចាត់ការជម្រះបញ្ជីឯកសារចាស់ដែលសេសសល់ ពិសេសកំណត់ហេតុដែលកកស្ទះនៅការិយាល័យសុរិយោដី មិនព្រមបញ្ចេញផ្តល់ប័ណ្ណឱ្យទៅអ្នកកាន់កាប់ដែលគេរង់ចាំជាយូរខែមកហើយនោះ ឱ្យបានចប់សព្វគ្រប់នៅថ្ងៃទី១៥-០៥-១៩៩៥ ជាកំណត់ បើពុំនោះទេ លោកប្រធានត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ "មាត្រា២១៨, ២១៩ និង ២២០ នៃច្បាប់ភូមិបាល"។

នាយកដ្ឋានសង្ឃឹមលើស្មារតីយកចិត្តទុកដាក់ទទួលខុសត្រូវខ្ពស់របស់អស់លោក។

**ជ.ប្រធាននាយកដ្ឋានសុរិយោដី**

**ប្រធានស្តីទី**

**ហត្ថលេខា និងត្រា**

**លឹម វ៉ាន់**

ចម្លងជូន

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់អភិបាលខេត្ត-ក្រុង

-នាយកដ្ឋានបុគ្គលិក

*"ដើម្បីជូនជ្រាប"*

-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ៩១៨ខុទ្ទ-៩៥ រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៥

**ជម្រាបជូនសម្តេច ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីទី២**

សម្តេចជាទីរាប់អានដ៏ខ្ពង់ខ្ពស់ !

ដោយសង្កេតឃើញថា រយៈពេលកន្លងមកមានប្រជាពលរដ្ឋជាច្រើនតែងតែធ្វើពាក្យបណ្តឹងជាបន្តបន្ទាប់មករាជរដ្ឋាភិបាល ស្នើសុំឱ្យជួយធ្វើអន្តរាគមន៍ដោះស្រាយអំពីបញ្ហាដីធ្លីដែលជាបញ្ហាមួយមានការស្មុគស្មាញយ៉ាងខ្លាំង និងមានការលំបាកក្នុងការដោះស្រាយ ។

ខ្ញុំមានកិត្តិយសសូមជូនយោបល់ចំពោះសម្តេចក្នុងដំណោះស្រាយបញ្ហានេះថា៖

ដើម្បីចៀសវាងបញ្ហាទំនាស់កម្មសិទ្ធិដីធ្លីរវាងអាជ្ញាធរ និងប្រជារាស្ត្រ ឬរវាងប្រជារាស្ត្រជាមួយអាជ្ញាធរនោះ ត្រូវអនុវត្តយ៉ាងណាឱ្យរាល់ការស្នើសុំកាន់កាប់ដីធ្លីឆ្លងកាត់ទីស្តីការគណៈរដ្ឋមន្ត្រី តាមរយៈនាយកដ្ឋានសុរិយោដី ដើម្បីពិនិត្យ និងសម្រេច ដោយពុំមែនត្រូវបញ្ចប់ត្រឹមនាយកដ្ឋានសុរិយោដីដូចដែលបានអនុវត្តកន្លងមកឡើយ ។ ទង្វើបែបនេះ ខ្ញុំយល់ថាយើងអាចនឹងដោះស្រាយបន្ថយនូវបញ្ហាបានមួយកម្រិតធំ ឆ្លងកាត់ការពិនិត្យ និងសិក្សាលំអិតពីទីស្តីការគណៈរដ្ឋមន្ត្រី ។

សូមសម្តេចទទួលនូវសេចក្តីស្រឡាញ់រាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

**ហត្ថលេខា និងត្រា**
**នរោត្តម រណឫទ្ធិ**
**នាយករដ្ឋមន្ត្រីទី១**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ៩៧២-៩៥ រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៩៥

**គោរពទូលថ្វាយ**

**សម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី១**

សម្តេចក្រុមព្រះជាទីគោរព !

ទូលបង្គំបានទទួលព្រះរាជសារលិខិតរបស់ព្រះអង្គលេខ៩១៨ខុទ្ទ-៩៥ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៥រួចហើយ ។

ទូលបង្គំសូមឯកភាព និងគាំទ្រព្រះរាជតម្រិះរបស់ព្រះអង្គទាំងស្រុង។ ទន្ទឹមនេះ សូមប្រគល់ភារកិច្ចឱ្យទីស្តីការគណៈរដ្ឋមន្ត្រីរៀបចំនីតិវិធីថ្មី ស្តីពីការស្នើសុំកាន់កាប់លើដីធ្លីតាមព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់ ។

សូមសម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី១ ទទួលនូវសេចក្តីគោរពដ៏ស្មោះស្ម័គ្របំផុតអំពីទូលបង្គំ ។

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីទី២**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ៥៣អនក្រ/បក

**អនុក្រឹត្យ**

**ស្តីពីការប្រកាសទ្រព្យសម្បត្តិរដ្ឋ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមចុះថ្ងៃទី២0 ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់

**សម្រេច**

**មាត្រា១**

យោងតាមស្មារតីមាត្រា៥៨នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា កោះគឺជាទ្រព្យសម្បត្តិរបស់រដ្ឋ។

**មាត្រា២**

ក្នុងន័យនេះ ដីដែលដុះចាស់ ឬថ្មីជាកោះនៅសមុទ្រ ទន្លេ ព្រែក ស្ទឹង បឹងបួទូទាំងព្រះរាជាណាក្រកម្ពុជា ត្រូវប្រកាសជាទ្រព្យសម្បត្តិរបស់រដ្ឋ ហើយមិនអនុញ្ញាតឱ្យឯកជន ឬសមូហភាពណាប្រកាសជាកម្មសិទ្ធិផ្ទាល់ខ្លួនឡើយ។

**មាត្រា៣**

*វាយឡើងវិញ*

សហរដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ព្រមទាំងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តឱ្យសម្រេចតាមអនុក្រឹត្យនេះរៀងៗខ្លួន ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៩៥

**នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២**

**ព្រះហស្តលេខា ហត្ថលេខា**

**និងត្រា**

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

*វាយឡើងវិញ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**

លេខ១០៥២សជណ/សរ　　　　　　　　　　　　រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៩៥

**សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ជម្រាបមក**
**លោកប្រធាននាយកដ្ឋានសុរិយោដី**

<u>កម្មវត្ថុ</u>៖ ករណីបញ្ហាទំនាស់ដីធ្លីរវាងអាជ្ញាធរ និងប្រជារាស្ត្រ ។

<u>យោង</u>៖ ព្រះរាជសារលិខិតលេខ៩១៨ខុទ្ទ-៩៥ ចុះថ្ងៃទី១៦-០៦-៩៥ របស់ខុទ្ទកាល័យសម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី១

លិខិតលេខ៩៧៦២-៩៥ ចុះថ្ងៃទី២២-០៦-៩៥ របស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបលោកប្រធានជ្រាបថា តាមមតិណែនាំរបស់សម្តេចនាយករដ្ឋមន្ត្រីទាំង២ រាល់ការស្នើសុំកាន់កាប់ដីធ្លីត្រូវឆ្លងកាត់ទីស្តីការគណៈរដ្ឋមន្ត្រី តាមរយៈនាយកដ្ឋានសុរិយោដី ដើម្បីពិនិត្យ និងសម្រេចដោយពុំមែនត្រូវបញ្ចប់ត្រឹមនាយកដ្ឋានសុរិយោដី ដូចដែលបានអនុវត្តកន្លងមកឡើយ ។

ហេតុនេះ សូមលោកប្រធានជ្រាប និងទទួលអនុវត្តតាមការណែនាំនេះ ឱ្យបានល្អប្រសើរ ។

សូមលោកប្រធានទទួលនូវការរាប់អានដ៏ស្មោះពីយើងខ្ញុំ ។

**ជ.សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**
**ហត្ថលេខា និងត្រា**
**ស៊ុំ ម៉ានិត　　　　នូវ កានុន**

<u>*ចម្លងជូន*</u>

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២

-ខុទ្ទកាល័យសម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី១

-នាយកដ្ឋានកសិកម្ម

-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ៥៨អនក្រ

# អនុក្រឹត្យ
# ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ១១នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## សម្រេច

**មាត្រា១**

បង្កើតគណៈកម្មការមួយមានឈ្មោះថា គណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| -រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអ្នកតំណាង | ជាប្រធាន |
| -ប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឬអ្នកតំណាង | ជាសមាជិក |

-ប្រធាននាយកដ្ឋានពន្ធដារ ឬអ្នកតំណាង ជាសមាជិក
-ប្រធាននាយកដ្ឋានទ្រព្យរដ្ឋ ឬអ្នកតំណាង ជាសមាជិក
-ប្រធាននាយកដ្ឋានសុរិយោដី ឬអ្នកតំណាង ជាសមាជិក

**មាត្រា២**

គណៈកម្មការនេះមានភារកិច្ចដូចខាងក្រោម៖

-បង្កើតបញ្ជីវាយឈ្មោះទីក្រុង និងតំបន់ដែលមានដីត្រូវជាប់ពន្ធ

-កំណត់ប្រចាំឆ្នាំនូវតម្លៃដីក្នុងមួយម៉ែត្រក្រឡា

-ផ្តល់មតិចំពោះរឿងវិវាទ

**មាត្រា៣**

គណៈកម្មការនេះមានសិទ្ធិចាត់តាំងអនុគណៈកម្មការនៅតាមខេត្ត-ក្រុងនីមួយៗ សម្រាប់ជំនួយការក្នុងការអនុវត្តភារកិច្ចខាងលើ។

**មាត្រា៤**

គណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់អនុវត្តភារកិច្ចរបស់ខ្លួន។

**មាត្រា៥**

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ និងអស់លោកដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រហស្តលេខា និងចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៥

**នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២**

**ព្រះហស្តលេខា ហត្ថលេខា**

**និងត្រា**

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការក្រសួងយុត្តិធម៌**

លេខ៧៣៣សរច/*វវ/៩៥*　　　　　　　　ភ្នំពេញ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៥

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ជម្រាបមក**

**លោកប្រធានតុលាការគ្រប់ខេត្ត-ក្រុង សាលាឧទ្ធរណ៍ និងតុលាការកំពូល**

សូមជ្រាប។

<u>កម្មវត្ថុ</u>៖ អំពីការអនុវត្តអនុក្រឹត្យលេខ២៥អនក្រ ចុះថ្ងៃទី២២-០៤-១៩៨៩ ស្តីពីការផ្តល់កម្មសិទ្ធិលើផ្ទះជូនពលរដ្ឋកម្ពុជា។

រយៈកាលកន្លងមក ក៏ដូចជាបច្ចុប្បន្នកាល ក្រសួងយុត្តិធម៌បានសង្កេតឃើញថា ចៅក្រមនៃតុលាការគ្រប់ជាន់ថ្នាក់ តែងមានយោបល់ខុសៗគ្នាស្តីពីការអនុវត្តអនុក្រឹត្យលេខ២៥អនក្រ ចុះថ្ងៃទី២២-០៤-១៩៨៩ ខាងលើនេះ។ ចៅក្រមខ្លះអនុវត្តអនុក្រឹត្យនេះដោយគ្មានការពិចារណានៅលើសភាពការណ៍ជាក់ស្តែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ជាការពិតហើយមាត្រា២នៃអនុក្រឹត្យលេខ២៥អនក្រ នោះចែងថា ចាប់ពីថ្ងៃនេះតទៅរដ្ឋបែងចែកកម្មសិទ្ធិដាច់ឱ្យគ្រួសារជាពលរដ្ឋកម្ពុជា លើលំនៅឋានដែលគ្រួសាររបស់ខ្លួនកំពុងរស់នៅក្នុងឃុំ-សង្កាត់ទូទាំងប្រទេស ហើយដែលរដ្ឋអំណាចឃុំ-សង្កាត់នោះទទួលស្គាល់។ គ្រួសារពលរដ្ឋកម្ពុជាដែលរស់នៅលើលំនៅឋានណាដែលជាផ្ទះភូមិគ្រឹះ ផ្ទះដាច់ដោយឡែកឯទៀត ឬផ្ទះល្វែង ត្រូវបានទទួលកម្មសិទ្ធិកាន់កាប់ប្រើប្រាស់លំនៅឋាននោះដែលសន្មតហៅថា ផ្ទះសម្រាប់រស់នៅតរៀងទៅ។ តាមសភាពការណ៍ជាក់ស្តែង នៅក្នុងអំឡុងឆ្នាំ១៩៨២ ដល់ឆ្នាំ១៩៨៩ដែលអនុក្រឹត្យលេខ២៥អនក្រ ចូលជាធរមាន មានអ្នកកាន់កាប់ផ្ទះដើមគេតាំងពីឆ្នាំ១៩៧៩-១៩៨០-១៩៨១ មកមានអ្នកមកសុំជ្រកកោនជាបណ្តោះអាសន្នជាមួយអ្នកកាន់កាប់ផ្ទះ ឬកាន់កាប់ដីភូមិ ដើម្បីរករបរចិញ្ចឹមជីវិត មានអ្នកខ្លះជួលផ្ទះមួយផ្នែក ឬបន្ទប់មួយក្នុងផ្ទះទាំងមូលដើម្បីស្នាក់នៅ។ ប័ណ្ណគ្រួសារ

ដែលអ្នកទាំងនេះលួចធ្វើដោយឡែកពីម្ចាស់ដើមនៃផ្ទះ មិនមែនជាឯកសារបញ្ជាក់កម្មសិទ្ធិទេ គ្រាន់តែជាឯកសារសម្គាល់អាសយដ្ឋានស្នាក់នៅតែប៉ុណ្ណោះ ពីព្រោះនៅពេលនោះ រដ្ឋអំណាចមូលដ្ឋានឃុំ-សង្កាត់ត្រួតពិនិត្យតាមដានខ្លាចមានពួកខ្មែរក្រហមជ្រៀតចូលមកលួចនៅក្នុងភូមិ ឃុំ។

ជនខ្លះសំអាងលើបង្កាន់ដៃនៃលិខិតដែលខ្លួនបានដាក់សុំទៅឃុំ-សង្កាត់នូវការអនុញ្ញាតកាន់កាប់ដីមួយផ្នែក ឬផ្ទះមួយផ្នែក ឬបន្ទប់មួយចំនួន។ បង្កាន់ដៃនេះមិនអាចយកមកសំអាងថាជាការអនុញ្ញាតរបស់រដ្ឋអំណាចឃុំ-សង្កាត់ឡើយ។ បង្កាន់ដៃនោះគ្រាន់តែជាលិខិតបញ្ជាក់ថា បានទទួលពាក្យសុំតែប៉ុណ្ណោះ។

ការលំបាកដែលក្រសួងយុត្តិធម៌ និងតុលាការជួបប្រទះគឺនៅកំលុងឆ្នាំ១៩៨៧ មកទល់នឹងពេលអាជ្ញាធរបណ្ដោះអាសន្ននៃអង្គការសហប្រជាជាតិ "អ៊ុនតាក់" មកដល់ព្រះរាជាណាចក្រកម្ពុជា ផ្ទះ និងដីត្រូវបានឡើងថ្លៃលើសពីដប់ដងនៃតម្លៃមុនឆ្នាំ១៩៨៧។ ម្ល៉ោះហើយ មានជនមួយចំនួនក្នុងចំណោមអ្នកសុំជ្រកកោនជាបណ្ដោះអាសន្នជាមួយគេ ឬអ្នកជួលផ្ទះគេ រកគ្រប់មធ្យោបាយដើម្បីដណ្ដើមយកកម្មសិទ្ធិមកយកចំណេញ។

សូមលោកចៅក្រមទាំងអស់យកច្បាប់ពីរគឺអនុក្រឹត្យលេខ២៥អនក្រ ចុះថ្ងៃទី២២-០៤-១៩៨៩ និងច្បាប់ភូមិបាលមកធ្វើជាមូលដ្ឋានអនុវត្ត វាយតម្លៃលើគ្រប់ចំណុចនៃពាក្យបណ្ដឹង និងសំអាងរបស់គូក្ដី ហើយសម្រេចសេចក្ដីឱ្យបានយុត្តិធម៌ជាទីបំផុត ដើម្បីឱ្យប្រជាជនមានជំនឿមកលើតុលាការ និងលើរាជរដ្ឋាភិបាលដែលកំពុងខិតខំអស់ពីលទ្ធភាព ដើម្បីស្តារ និងកសាងប្រទេសជាតិឡើងវិញ។

សូមលោកប្រធានតុលាការគ្រប់ជាន់ថ្នាក់ យកចិត្តទុកដាក់អនុវត្តតាមការណែនាំនេះឱ្យ.មានប្រសិទ្ធភាពខ្ពស់តទៅ។

**រដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ចែម ស្ងួន**

<u>ចម្លងជូន</u>

-អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

-អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

-ព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង

*"ដើម្បីជ្រាប និងអនុវត្ត"*

*វាយឡើងវិញ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈរដ្ឋមន្ត្រី

ក្រសួងបរិស្ថាន

លេខ១៧១៩បស្ថ

ភ្នំពេញ ថ្ងៃទី១៤ ខែ០៩ ឆ្នាំ១៩៩៥

**ជម្រាបមក**

**លោកប្រធាននាយកដ្ឋានសុរិយោដី**

កម្មវត្ថុ៖ បញ្ហាកម្មសិទ្ធិដីធ្លីក្នុងតំបន់ការពារធម្មជាតិ

*យោង៖* ព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីតំបន់ការពារធម្មជាតិ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបលោកប្រធានថា ដើម្បីការពារ និងអភិវឌ្ឍតំបន់ការពារធម្មជាតិទាំង២៣កន្លែង ដូចមានចែងក្នុងព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ប្រកបដោយប្រសិទ្ធភាព ក្រសួងបរិស្ថានសូមជម្រាបលោក ប្រធាននាយកដ្ឋានសុរិយោដីជ្រាបថា តំបន់ការពារធម្មជាតិរបស់ជាតិទាំង២៣កន្លែងដូចមានព្រំប្រទល់ក្នុងផែនទីជូនភ្ជាប់មកជាមួយ ត្រូវបានការពារ និងថែរក្សារជាសម្បត្តិរដ្ឋ ក្រសួងគ្រប់គ្រងបរិស្ថានមានភារកិច្ចដឹកនាំ និងគ្រប់គ្រងតំបន់ការពារទាំងនេះ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមលោកប្រធានជ្រាប និងអនុវត្តតាមព្រះរាជក្រឹត្យ ។

សូមលោកទទួលនូវការរាប់អានដ៏ស្មោះបំផុតអំពីខ្ញុំ ។

**រដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**បណ្ឌិត ម៉ុក ម៉ារ៉េត**

ចម្លងជូន

-ខុទ្ទកាល័យព្រះបរមរាជវាំង

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ឯកឧត្តមអភិបាលគ្រប់ខេត្ត-ក្រុងពាក់ព័ន្ធ

-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

**ទីស្តីការគណៈរដ្ឋមន្ត្រី** ជាតិ សាសនា ព្រះមហាក្សត្រ

**នាយកដ្ឋានសុរិយោដី**

លេខ១៧៨សជ ភ្នំពេញ ថ្ងៃទី២២ ខែ១១ ឆ្នាំ១៩៩៥

**ប្រធាននាយកដ្ឋានសុរិយោដី**

**ជម្រាបមក**

**លោកប្រធានគ្រប់ការិយាល័យសុរិយោដីខេត្ត-ក្រុង**

<u>កម្មវត្ថុ</u>៖ ការកាន់កាប់សៀវភៅចុះបញ្ជីអចលនវត្ថុ

យោងកម្មវត្ថុដូចមានចែងខាងលើ ខ្ញុំសូមជម្រាបអស់លោកថា កន្លងមក ទោះបីជាមានការណែនាំជាបន្តបន្ទាប់ ទាំងផ្ទាល់មាត់ ទាំងឯកសារសរសេរក្តី ក៏នៅតែលេចឡើងបាតុភាពខុសឆ្គង មិនឈប់ឈរ ជាហេតុធ្វើឱ្យឃ្លាតចាកពីភាពសុក្រឹត និងគតិយុត្ត។ ពេលនេះ ខ្ញុំសូមអស់លោកចាប់អារម្មណ៍ឱ្យបានស៊ីជម្រៅលើការងារគ្រប់គ្រង និងកាន់កាប់សៀវភៅចុះបញ្ជីអចលនវត្ថុនូវចំណុចដូចខាងក្រោម៖

-សៀវភៅចុះបញ្ជីអចលនវត្ថុជាឯកសារមូលដ្ឋានសំខាន់បំផុតសម្រាប់គ្រប់គ្រង និងតាមដានរាល់ការប្រែប្រួលអំពីសិទ្ធិ អំពីអ្នកកាន់កាប់ ឬភោគី អំពីទ្រង់ទ្រាយដី និងអំពីបន្ទុក...។

-សៀវភៅនេះបានបង្កើតឡើងជាបីច្បាប់សម្រាប់ដីមួយឃុំ ដែលមានខ្លឹមសារ ទំហំ ទ្រង់ទ្រាយ រូបភាព និងការចុះនិទ្ទេសផ្សេងៗដូចគ្នាទាំងស្រុង។ សៀវភៅនេះ ចេញប្រភពពីនាយកដ្ឋាន ហើយការិយាល័យសុរិយោដីខេត្ត-ក្រុង ការិយាល័យភូមិបាលស្រុក-ខណ្ឌកសាងសៀវភៅនេះដោយចម្លងចូលទាំងស្រុងនូវខ្លឹមសារនៃតារាងសម្រង់អ្នកកាន់កាប់អចលនវត្ថុ ឬតារាងផ្លាស់ប្តូរអចលនវត្ថុ ដោយពុំអាចបន្ថែមបន្ថយត្រង់ចំណុចណាតាមការយល់ឃើញបានឡើយ។

-សៀវភៅនេះមិនអាចសរសេររំលងទំព័រ រំលងខណ្ឌ ឬហែកទំព័រ ឬបន្ថែមសន្លឹក ឬក្នុងមួយខណ្ឌសរសេរទឹកពីរពណ៌ ឬសរសេរដោយមនុស្សផ្សេងៗគ្នាបានជាដាច់ខាត។

*វាយឡើងវិញ*

-សៀវភៅនេះត្រូវប្រគល់ឱ្យមន្ត្រីណាម្នាក់ក្នុងការិយាល័យកាន់កាប់ឱ្យបានម៉ត់ចត់ មិនត្រូវទុកចោលលើតុ ឬទីណាដែលមានមហាជនឆ្លងកាត់។ ត្រូវទុកដាក់ឱ្យមានរបៀប និងមានសោគត់មត់ ក្រៅពីមន្ត្រីទទួលបន្ទុក និងប្រធានការិយាល័យមិនអាចឱ្យបុគ្គលណាផ្សេងកាន់កាប់ ឬយកសៀវភៅនេះទៅបើកមើល ឬធ្វើអ្វីបានឡើយ។ ពេលមានភ្ញៀវចង់បានព័ត៌មានផ្សេងៗទាក់ទងនឹងសៀវភៅនេះ ចាំបាច់ត្រូវមានការអនុញ្ញាតពីប្រធានការិយាល័យជាមុនសិន។ អ្នកកាន់កាប់សៀវភៅអាចបើកមើល ហើយកត់ត្រាព័ត៌មានយកទៅផ្តល់ជូនភ្ញៀវ ដាច់ខាតមិនប្រគល់សៀវភៅឱ្យតតិយជនបើកមើលដោយខ្លួនឯង ឬដាច់ខាតមិនបើកសៀវភៅបង្ហាញនៅចំពោះមុខតតិយជនឡើយ។

-ប្រសិនបើមានចំណុចណាខុសឆ្គង ហើយចាំបាច់ត្រូវកែសម្រួលនោះ យើងអាចកែបានតែត្រូវធ្វើលំដាប់លំដោយពីប្រភពដើម (ពីនាយកដ្ឋាន ការិយាល័យសុរិយោដីខេត្ត-ក្រុង ការិយាល័យភូមិបាល) មក គឺមិនអាចកែពីការិយាល័យភូមិបាលមុន ឬពីការិយាល័យសុរិយោដីខេត្តមុនបានឡើយ។

អាស្រ័យហេតុដូចបានរៀបរាប់ខាងលើ ខ្ញុំសូមលោកប្រធានណែនាំបន្តដល់គ្រប់ការិយាល័យភូមិបាល និងពង្រឹងឱ្យបានម៉ឹងម៉ាត់បំផុតក្នុងការគ្រប់គ្រង និងកាន់កាប់សៀវភៅចុះបញ្ជីអចលនវត្ថុ ដើម្បីធានាឱ្យបាននូវគុណភាពនៃឯកសាររបស់យើងចំពោះមុខច្បាប់។

**ប្រធានស្តីទី**

**ហត្ថលេខា និងត្រា**

**លឹម វ៉ាន់**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ០២សរ**

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦

## សារាចរណែនាំ
## ស្តីពីការរៀបចំធ្វើគម្រោងប្លង់គោលនៅតាមខេត្ត-ក្រុង ទូទាំងព្រះរាជាណាចក្រកម្ពុជា

ចាប់តាំងពីរាជរដ្ឋាភិបាលត្រូវបានបង្កើតឡើងរហូតមកដល់បច្ចុប្បន្ន វិស័យសេដ្ឋកិច្ចសង្គម មានការរីកចម្រើនលូតលាស់គួរឱ្យមានមោទនភាព។ ដោយឡែកការស្តារ និងការកសាងលើផ្នែក ហេដ្ឋារចនាសម្ព័ន្ធ និងសំណង់ក៏កំពុងមានសន្ទុះឈានទៅមុខយ៉ាងខ្លាំងក្លា។ ប៉ុន្តែរាជរដ្ឋាភិបាលក៏បាន សង្កេតឃើញថា ការកសាងហេដ្ឋារចនាសម្ព័ន្ធថ្មី ការស្ថាបនារោងចក្រ សណ្ឋាគារ ភោជនីយដ្ឋាន ការស្ថាបនាទីផ្សារ ការធ្វើសួនច្បារ ឧទ្យានសាធារណៈ តំបន់អភិវឌ្ឍន៍ មជ្ឈមណ្ឌលទេសចរណ៍ តំបន់លំហែកំសាន្ត ជាពិសេសលំនៅឋាន ហាងលក់ដូរទំនិញរបស់ប្រជារាស្ត្របានបង្កឡើងនូវភាព មិនសមស្របតាមបច្ចេកទេសនៃការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ហើយសំណង់ភាគ ច្រើនបាន និងកំពុងសាងសង់ឡើងដោយអនាធិបតេយ្យ ធ្វើឱ្យខូចសោភ័ណភាពដល់ទីប្រជុំជន ទីរួមស្រុក ទីរួមខេត្ត និងទីក្រុង។

ដើម្បីដោះស្រាយបញ្ហាដែលមានលក្ខណៈចាំបាច់ និងបន្ទាន់ចំពោះអនាគតរបស់ជាតិមាតុ ភូមិអង្គរដ៏បវរនៃយើង រាជរដ្ឋាភិបាលសូមធ្វើការណែនាំចំពោះក្រសួង ស្ថាប័ន និងគ្រប់ខេត្ត-ក្រុង ឱ្យអនុវត្តនូវវិធានការសំខាន់ៗដូចខាងក្រោម៖

អនុលោមតាមច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់នៅជំពូកទី២ មាត្រា៥ ដែលបានចែងថា "គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់រាជធានីភ្នំពេញ ឬអនុ គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ខេត្ត-ក្រុងនីមួយៗត្រូវគូសប្លង់គោលដើម្បី

ធ្វើការរៀបចំ និងអភិវឌ្ឍនៃរាជធានី ខេត្ត-ក្រុងរបស់ខ្លួន។ ប្លង់គោលនេះត្រូវមានការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ និងកំណត់ដោយអនុក្រឹត្យ។

ដើម្បីការពារនូវបេតិកភណ្ឌ ការពារបរិស្ថាន និងដើម្បីធានាអភិវឌ្ឍន៍សេដ្ឋកិច្ច ចំពោះតំបន់ពិសេសណាមួយដែលគណៈរដ្ឋមន្ត្រីបានកំណត់ គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់មានការរៀបចំប្លង់គោលសម្រាប់តំបន់ពិសេសនោះដាក់ជូនគណៈរដ្ឋមន្ត្រីអនុម័ត។"

១-ដើម្បីប្រតិបត្តិច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៩៤ ឱ្យមានប្រសិទ្ធភាព រាជរដ្ឋាភិបាលសូមប្រគល់ភារកិច្ចជូនក្រសួងមហាផ្ទៃ ណែនាំដល់សាលាក្រុងភ្នំពេញ និងសាលាខេត្ត-ក្រុងទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវសហការជំរុញផ្នែកជំនាញនៃគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់រាជធានីភ្នំពេញ និងអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ខេត្ត-ក្រុង ឱ្យដំណើរការជាបន្ទាន់នូវការគូសប្លង់គោល ដើម្បីធ្វើការរៀបចំ និងអភិវឌ្ឍនៃរាជធានី ខេត្ត-ក្រុងរបស់ខ្លួនដែលក្នុងនោះ ត្រូវកំណត់អំពីហេដ្ឋារចនាសម្ព័ន្ធ បណ្តាញផ្លូវគមនាគមន៍ ទីតាំងផ្សារ តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម តំបន់សណ្ឋាគារ មណ្ឌលទេសចរណ៍ តំបន់កំពង់ផែ ចំណតរថយន្ត ចំណតរថភ្លើង ចំណតអាកាសយានដ្ឋាន តំបន់សាលារៀនចំណេះទូទៅ សាលារៀនបច្ចេកទេស ទីវត្តអារ៉ាម តំបន់រដ្ឋបាលស៊ីវិល តំបន់នគរបាល តំបន់យោធា តំបន់ការពារបរិស្ថាន តំបន់សួនច្បារ ឧទ្យានសាធារណៈ កន្លែងចាក់សំរាម អាងស្តុកទឹកសំអុយ បណ្តាញលូបង្ហូរទឹក ការរៀបចំខ្សែបណ្តាញអគ្គិសនី ដីត្រៀមបម្រុងអភិវឌ្ឍ ព្រៃត្រៀមបម្រុងជម្រកសត្វព្រៃ បឹងបួសាធារណៈ ទន្លេ ព្រែក សមុទ្រ កោះ ដីលំនៅឋាន ដីធ្វើស្រែចម្ការ ច្បារដំណាំផ្សេងៗ។ល។

២-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងទេសចរណ៍ រួមជាមួយក្រសួងគ្រប់គ្រងបរិស្ថាន ត្រូវធ្វើការណែនាំជាបន្ទាន់ដល់មន្ទីរក្រោមឱវាទរបស់ខ្លួន នៅគ្រប់ខេត្ត-ក្រុងឱ្យធ្វើការសិក្សាអំពីមុខជំនាញក្នុងការកំណត់តំបន់ដីធ្លីសម្រាប់ដំណាំកសិកម្ម ដំណាំកសិ-ឧស្សាហកម្ម និងដំណាំយុទ្ធសាស្ត្រផ្សេងៗ កំណត់តំបន់ដីសម្បទាន កំណត់តំបន់ព្រៃសម្បទាន តំបន់រោងចក្រឧស្សាហកម្ម មណ្ឌលទេសចរណ៍ ព្រៃឧទ្យានជាតិ ជម្រកសត្វព្រៃ កសាងហេដ្ឋារចនាសម្ព័ន្ធ។ល។ ដើម្បីបញ្ចូលទៅ

ក្នុងគម្រោងប្លង់គោលតាមខេត្ត-ក្រុងនីមួយៗ សំដៅឈានទៅរៀបចំធ្វើប្លង់គោលនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីជាមូលដ្ឋានជូនគណៈរដ្ឋមន្ត្រីក្នុងការសម្រេចកំណត់ដីធ្លី និងតំបន់ផ្សេងៗសម្រាប់ប្រគល់ឱ្យក្រុមហ៊ុននានាធ្វើវិនិយោគ បម្រើឱ្យការអភិវឌ្ឍប្រទេសជាតិ ធានាបាននិរន្តរភាពតទៅអនាគត និងធានាបានកិច្ចការពារបរិស្ថានទៀតផង។

៣-គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ត្រូវធ្វើការណែនាំអំពីការងារបច្ចេកទេសជំនាញលើការងាររៀបចំទឹកដី ការងារនគរូបនីយកម្ម និងការងារសំណង់ទៅដល់គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់រាជធានីភ្នំពេញ និងអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ខេត្ត-ក្រុង ឱ្យធ្វើជាសេនាធិការជូនអភិបាលខេត្ត-ក្រុងក្នុងការរៀបចំធ្វើគម្រោងប្លង់គោល ដើម្បីធ្វើការរៀបចំ និងអភិវឌ្ឍក្នុងក្របខ័ណ្ឌរង្វង់ដែនដីដែលខេត្ត-ក្រុងនីមួយៗគ្រប់គ្រង។

ទទួលបានសារាចរនេះ ក្រសួងមហាផ្ទៃ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងទេសចរណ៍ ក្រសួងគ្រប់គ្រងបរិស្ថាន ក្រសួងស្ថាប័នពាក់ព័ន្ធ និងគ្រប់សាលាខេត្ត-ក្រុងត្រូវចាត់ចែង ផ្សព្វផ្សាយ និងទទួលអនុវត្តឱ្យបានលទ្ធផលល្អប្រសើរ រួចសូមផ្ញើប្លង់គោលនេះចំនួន៤ច្បាប់ មកសុំការឯកភាពពីក្រសួងមហាផ្ទៃជាមុន រួចទើបបញ្ជូនទៅគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ពិនិត្យ និងសុំការសម្រេចពីរាជរដ្ឋាភិបាល ឱ្យបានមុនដំណាច់ខែកក្កដា ឆ្នាំ១៩៩៦ជាកំហិត។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**នាយកដ្ឋានសុរិយោដី**

**លេខ០៥០សជ**

ភ្នំពេញ ថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៩៦

**ប្រធាននាយកដ្ឋានសុរិយោដី**

**ជម្រាបមក**

**គ្រប់ការិយាល័យសុរិយោដីខេត្ត-ក្រុង**

កម្មវត្ថុ ការគ្រប់គ្រងឯកសារសុរិយោដី

កន្លងមក នាយកដ្ឋានសុរិយោដីបានកត់សម្គាល់ឃើញថា គ្រប់ការិយាល័យសុរិយោដីខេត្ត-ក្រុង ក៏ដូចជាការិយាល័យភូមិបាលស្រុក-ខណ្ឌ នៅមានការធ្វេសប្រហែសក្នុងការគ្រប់គ្រងឯកសារសូរិយោដី ដូចជា៖

១-បណ្តែតបណ្តោយឱ្យជនដែលមិនមែនជាសមត្ថកិច្ច និងមិនមែនជាភ្នាក់ងាររក្សាឯកសារបើកមើល ឆែកឆេរបញ្ជីស្ទាមគ្រប់ប្រភេទរបស់ស្ថាប័នសុរិយោដី។

២-បណ្តែតបណ្តោយឱ្យភោគីសុំខ្ចីកំណត់ហេតុអង្កេតដី យកចេញក្រៅការិយាល័យដើម្បីថតចម្លង។

៣-អនុញ្ញាតឱ្យអ្នករត់ការ ឬអតិថិជនកាន់កំណត់ហេតុអង្កេតយកទៅបង់ពន្ធប្រថាប់ត្រាដោយខ្លួនឯង ។ល។ និង ។ល។

៤-ប្រគល់កំណត់ហេតុ ឬសៀវភៅចុះអចលនវត្ថុឱ្យស្ថាប័នដទៃខ្ចី។

ករណីដូចបានរៀបរាប់ខាងលើ នាយកដ្ឋានសូមជម្រាបមកគ្រប់ការិយាល័យសុរិយោដីខេត្ត-ក្រុង និងការិយាល័យភូមិបាលស្រុក-ខណ្ឌថា រាល់ឯកសារសុរិយោដី ទោះជាផ្នែករដ្ឋបាលក្តី ផ្នែកបច្ចេកទេសក្តី ចំពោះអ្នកគ្មានសមត្ថកិច្ច ត្រូវហាមឃាត់ដាច់ខាតក្នុងការបើកមើល ឆែកឆេរ ឬកាន់យកចេញទៅក្រៅការិយាល័យដើម្បីថតចម្លង ឬបង់ពន្ធប្រថាប់ត្រាដែលជាកត្តានាំឱ្យ

*វាយឡើងវិញ*

-បាត់បង់ឯកសារ ឬរហែកខូចខាត

-កែ ឬលុបថែមថយលើឯកសារ

-បង្កទំនាស់ដីធ្លីក្នុងតំបន់

-អស់ប្រសិទ្ធភាពគ្រប់គ្រងឯកសារសុរិយោដី

ដើម្បីធានាសន្តិសុខក្នុងការងារ និងតម្លៃនៃឯកសារ ស្នើលោកការិយាល័យសុរិយោដីខេត្ត-ក្រុង និងការិយាល័យភូមិបាលស្រុក-ខណ្ឌអនុវត្តឱ្យបានម៉ឺងម៉ាត់នូវប្រការដែលត្រូវចៀសវាងខាងលើ។ ក្នុងករណីផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុរណបផ្សេងទៀត បើមាន ចំពោះកំណត់ហេតុអង្កេតដីមិនអាចបញ្ជូនទៅផ្នែកពន្ធដាដាច់ខាត សូម្បីតែថតចម្លងក៏មិនបានដែរ។ លិខិតសញ្ញា (លិខិតលក់ ចែក អំណោយ) ទៀតសោត គឺយើងតាក់តែងសម្រាប់តែទុកឯកសារមួយច្បាប់ និងប្រគល់ជូនសាមីជនមួយច្បាប់ប៉ុណ្ណោះ ស្ថាប័នពន្ធមិនអាចដកយកលិខិតដើមបានទេ បើចង់បាន ស្នើយកលិខិតដើមនេះទៅថតចម្លងទុកចុះ។

អាស្រ័យហេតុនេះ ស្នើលោកប្រធានការិយាល័យសុរិយាល័យខេត្ត-ក្រុង និងការិយាល័យស្រុក-ខណ្ឌអនុវត្តឱ្យមានប្រសិទ្ធភាពតាមខ្លឹមសារខាងលើ។

**ជ.នាយកដ្ឋានសុរិយោដី**

**អនុប្រធាន**

**ហត្ថលេខា និងត្រា**

**លឹម ហោ**

***<u>ចម្លងជូន</u>***

-ទីស្តីការគណៈរដ្ឋមន្ត្រី

-អភិបាលខេត្ត-ក្រុង

*"ដើម្បីសូមជូនជ្រាប"*

-សាខាពន្ធដារខេត្ត-ក្រុង

*"ដើម្បីជ្រាប"*

-ការិយាល័យអភិរក្សសុរិយោដី

*"ដើម្បីមុខការ"*

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

លេខ២២៤ប្រក/សហវ/ពដ រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៩៦

# ប្រកាស
## ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ១១នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤

- បានឃើញច្បាប់កែតម្រូវនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥
- បានឃើញអនុក្រឹត្យលេខ៥៨អនក្រ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
- បានឃើញប្រកាសលេខ៣១៦ប្រ/សហវ/ពដ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
- បានឃើញសេចក្តីសម្រេចលេខ០១សសរ/ពដ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់តាមបណ្តាខេត្ត-ក្រុង
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើដីមិនបានប្រើប្រាស់។

**សម្រេច**

ប្រការ១

ត្រូវជាប់ពន្ធលើមិនបានប្រើប្រាស់ គឺដីទាំងឡាយណាដែលពុំមានលក្ខណៈណាមួយនៃលក្ខណៈខាងក្រោមនេះ៖

១-ដីមានសំណង់ឋិតនៅក្នុងតំបន់លំនៅឋាន ដែលកម្មសិទ្ធិករប្រើប្រាស់ជាកន្លែងស្នាក់នៅជាសំខាន់របស់ខ្លួន និងបានស្នាក់នៅកន្លែងនោះចំនួន១៨៣ថ្ងៃ ឬច្រើនជាង គិតចាប់ពីថ្ងៃទី០១ តុលានៃឆ្នាំកន្លងទៅរហូតដល់ថ្ងៃទី៣០ ខែកញ្ញានៃឆ្នាំប្រមូលពន្ធ។ បើសិនជានៅក្នុងឆ្នាំប្រមូលពន្ធកម្មសិទ្ធិករអាចបំពេញល័ក្ខខ័ណ្ឌស្នាក់នៅចំនួន១៨៣ថ្ងៃបានសម្រាប់ឆ្នាំប្រមូលពន្ធនោះ កម្មសិទ្ធិករអាចដាក់ពាក្យសុំឱ្យបង្វិលសងប្រាក់ពន្ធដែលបានបង់រួចហើយនោះវិញបាន។

កន្លែងស្នាក់នៅជាសំខាន់របស់កម្មសិទ្ធិករ គឺជាកន្លែងដែលកម្មសិទ្ធិករបានដេកនៅ ហូបចុកយ៉ាងជាក់លាក់ជាទៀងរាល់ថ្ងៃ ក្រោយពីពេលត្រលប់ពីបំពេញការងារប្រចាំថ្ងៃ។ សម្រាប់ការកំណត់ពន្ធនេះ កម្មសិទ្ធិករម្នាក់ពុំអាចមានទីកន្លែងស្នាក់នៅជាសំខាន់លើសពីមួយកន្លែងបានទេ។

២-ដីដួលដែលមានសំណង់ មានការកាន់កាប់ដែលផ្តល់លាភការប្រចាំខែលើសពី៨០% នៃចំនួនមួយភាគដប់ពីរនៃតម្លៃដីនៅក្នុងឆ្នាំប្រមូលពន្ធ គុណនឹងមេគុណដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយក្នុងនោះតម្លៃដីត្រូវបានកំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់។

៣-ដីជួលដែលមានសកម្មភាពសេដ្ឋកិច្ចស្របតាមការកំណត់តំបន់របស់រដ្ឋ ហើយដែលបានប្រាក់ចំណូលប្រចាំខែអំពីសកម្មភាពនោះ បានលើសពីចំនួន៨០%នៃចំនួនមួយភាគដប់ពីរនៃតម្លៃដីនៅក្នុងឆ្នាំប្រមូលពន្ធ គុណនឹងមេគុណដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយក្នុងនោះតម្លៃដីត្រូវបានកំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់។

៤-ដីជាកម្មសិទ្ធិរបស់រដ្ឋដែលបានផ្តល់ទៅឱ្យនីតិបុគ្គល ឬរូបវន្តបុគ្គលណាមួយ ហើយដីនោះមានលក្ខណៈណាមួយនៃចំណុចទាំង៣ខាងលើ។

៥-ដីដែលឋិតនៅក្រោមកិច្ចព្រមព្រៀងវិនិយោគ ហើយដែលសកម្មភាពមិនទាន់បានចាប់ផ្តើមដោយមានប្រធានសក្តិ ឬដោយមូលហេតុការរងគ្រោះដោយប្រការអ្វីមួយ ដូចជាអសន្តិសុខ ហើយការពន្យារពេលនោះត្រូវបានទទួលការយល់ព្រមពីស្ថាប័នជំនាញមានសមត្ថកិច្ច និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ២**

ការបង់ពន្ធនេះមិនមែនជាល័ក្ខខ័ណ្ឌបញ្ជាក់កម្មសិទ្ធិស្របច្បាប់លើដីទេ។

**ប្រការ៣**

ក្នុងការគ្រប់គ្រងប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ ពាក្យ "កម្មសិទ្ធិករ" សំដៅដល់បុគ្គលណាដែលផ្ទេកសុរិយោដី ឬអាជ្ញាធរដែនដីចាប់ពីថ្នាក់ឃុំ-សង្កាត់ឡើងទៅបានចេញឯកសារផ្លូវការទទួលស្គាល់សិទ្ធិរបស់បុគ្គលនោះ ក្នុងការប្រើប្រាស់ដីក្នុងតំបន់ណាមួយ ជាលក្ខណៈជាប់លាប់ក្តី ឬបណ្តោះអាសន្នក្តី។

កម្មសិទ្ធិករម្នាក់គឺជាក្រុមគ្រួសារមួយ "ឪពុក ម្តាយ សាមីខ្លួន ប្រពន្ធ កូនក្នុងបន្ទុក" ឬមេគ្រួសារ និងសមាជិកក្នុងបន្ទុកមានឈ្មោះក្នុងប័ណ្ណគ្រួសារដែលចេញដោយស្ថាប័នមានសមត្ថកិច្ច។

កម្មសិទ្ធិករនៃដីជាប់ពន្ធ និងអ្នកជួលដីពីរដ្ឋដូចក្នុងចំណុច៤នៃប្រការ១មានកាតព្វកិច្ច ត្រូវគណនាប្រាក់ពន្ធទៅតាមទម្រង់ប្រកាសសារពើពន្ធដែលនាយកដ្ឋានបានផ្តល់ឱ្យ ហើយត្រូវបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់យ៉ាងយឺតបំផុតត្រឹមថ្ងៃ៣០ ខែកញ្ញានៃឆ្នាំប្រមូលពន្ធនីមួយៗ ជូនដល់ផ្នែកពន្ធដារនៅតំបន់ដែលដីនោះឋិតនៅ។ សម្រាប់ដីជាប់ពន្ធនីមួយៗ ត្រូវធ្វើប្រកាសសារពើពន្ធមួយដាច់ដោយឡែក។

**ប្រការ៤**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងប្រកាសជូនដំណឹងជាសាធារណៈអំពីតម្លៃដីក្នុងមួយម៉ែត្រក្រឡាដែលកំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ ដើម្បីឱ្យអ្នកជាប់ពន្ធអាចកំណត់មូលដ្ឋានសម្រាប់គិតពន្ធរបស់ខ្លួន។ ការជូនដំណឹងជាសាធារណៈក៏ត្រូវមានចុះបញ្ជាក់ផងដែរអំពីការបែងចែកជាតំបន់ ហើយនិងការវាយតម្លៃដីក្នុងមួយម៉ែត្រក្រឡាក្នុងតំបន់នីមួយៗ។ ការជូនដំណឹងជាសាធារណៈនេះត្រូវបិទផ្សាយនៅតាមសាលាខេត្ត-ក្រុង សាខាពន្ធដារ និងការិយាល័យប្រៃសណីយ៍ ហើយត្រូវចុះផ្សាយក្នុងសារព័ត៌មាន ចេញផ្សាយក្នុងស្រុកចំនួន២យ៉ាងតិច។

**ប្រការ៥**

ការមិនបានធ្វើការប្រកាសសារពើពន្ធ ការបង់ពន្ធមិនគ្រប់ ឬការមិនបានបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ត្រូវទទួលរងការអនុវត្តនូវមាត្រា៩៨ ហើយនិងមាត្រាមានជាប់ទាក់ទងផ្សេងទៀតនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ឆ្នាំ១៩៩៨ និងទោសទណ្ឌដែលមានចែងក្នុងច្បាប់ហិរញ្ញវត្ថុជាធរមាន។

**ប្រការ៦**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ហត្ថលេខា និងត្រា**
**គាត ឈន់**

<u>ចម្លងជូន</u>

-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២
-គ្រប់ក្រសួង ស្ថាប័នកណ្តាល
-គ្រប់សាលាខេត្ត-ក្រុង
*"ដើម្បីជូនជ្រាបជាព័ត៌មាន"*
-គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
*"ដើម្បីមុខការ"*
-គណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
-អនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
-គ្រប់អង្គភាពពន្ធដារ *"ដើម្បីអនុវត្ត"*
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
នាយកដ្ឋានសុរិយោដី
លេខ១២៧សដ

ភ្នំពេញ ថ្ងៃទី៣១ ខែ០៧ ឆ្នាំ១៩៩៦

ប្រធាននាយកដ្ឋានសុរិយោដី
ជម្រាបមក
លោកប្រធានការិយាល័យសុរិយោដីគ្រប់ខេត្ត-ក្រុង

*កម្មវត្ថុ៖* ការទទួលខុសត្រូវលើលិខិតសញ្ញាផ្ទេរសិទ្ធិរបស់ប្រធានការិយាល័យសុរិយោដីខេត្ត-ក្រុង និងប្រធានការិយាល័យភូមិបាលស្រុក-ខណ្ឌ។

កន្លងមកនាយកដ្ឋានបានកត់សម្គាល់ឃើញថា រាល់លិខិតសញ្ញាផ្ទេរសិទ្ធិអ្នកកាន់កាប់អចលនវត្ថុដែលការិយាល័យភូមិបាលស្រុក-ខណ្ឌតាក់តែង និងបញ្ជូនឡើងតាមលំដាប់ថ្នាក់នោះ ពុំបានឆ្លងយោបល់ឯកភាពពីប្រធានការិយាល័យភូមិបាលស្រុក-ខណ្ឌ និងប្រធានការិយាល័យខេត្ត ក្រុងឡើយ។

ដើម្បីមានមូលដ្ឋានទទួលខុសត្រូវនៅពេលជួបប្រទះបាតុភាពផ្សេងៗ ដែលកើតឡើង នាយកដ្ឋានសូមជម្រាបជូនថា រាល់លិខិតសញ្ញាផ្ទេរសិទ្ធិអ្នកកាន់កាប់អចលនវត្ថុ ត្រូវសរសេរឈ្មោះ និងចុះហត្ថលេខាទទួលខុសត្រូវត្រង់កន្លែង "អ្នកតែងលិខិត" ដោយប្រធានការិយាល័យភូមិបាលស្រុក-ខណ្ឌ រួចបញ្ជូនឡើងតាមលំដាប់ថ្នាក់។ នៅពេលឯកសារនេះមកដល់ការិយាល័យសុរិយោដីខេត-ក្រុង ប្រធានការិយាល័យត្រូវពិនិត្យបន្ថែមទៀត។ បើពិនិត្យឃើញមាលក្ខណៈត្រឹមត្រូវ និងគ្រប់គ្រាន់ហើយ ជាពិសេសអំពីតម្លៃអចលនវត្ថុនោះ ប្រធានការិយាល័យសុរិយោដីខេត្ត-ក្រុងត្រូវចុះហត្ថលេខាបំពេញ ចុះថ្ងៃ ខែ ឆ្នាំ និងបោះត្រាលេខាចារឹកនៅពីខាងមុខតួលេខតម្លៃអចលនវត្ថុត្រង់បន្ទាត់ "តម្លៃជាប្រាក់....................."។

ម្យ៉ាងទៀត រាល់ការផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុលើអចលនវត្ថុដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់រួចហើយ នាយកដ្ឋានសូមហាមជាដាច់ខាតនូវរបៀបរបបធ្វើកាត់ ដោយគេចវេសការ

បង់ពន្ធប្រថាប់ត្រា ពោលគឺប្រមូលយកឯកសារ ព្រមទាំងប័ណ្ណចាស់កម្ទេចចោល រួចកសាងកំណត់ហេតុថ្មី ដោយដាក់ឈ្មោះអ្នកកាន់កាប់ចុងក្រោយផ្ទាល់ចូលក្នុងកំណត់ហេតុអង្កេតតែម្តង ព្រមទាំងសរសេរចុះបន្លំឆ្នាំកាន់កាប់របស់អ្នកស្នើសុំ។ អស់លោកដែលប្រព្រឹត្តអំពើឆ្នាំឆ្លងដូចបានជម្រាបជូនខាងលើត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

ដូចបានជម្រាបខាងលើនេះ ខ្ញុំសង្ឃឹមថា អស់លោកប្រធានការិយាល័យសុរិយោដីគ្រប់ខេត្ត-ក្រុងនឹងផ្សព្វផ្សាយទូលាយដល់មន្ត្រីរាជការទាំងអស់ក្រោមឱវាទ ជាពិសេសប្រធានការិយាល័យភូមិបាលស្រុក-ខណ្ឌឱ្យអនុវត្តប្រកបដោយប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ជ.ប្រធាននាយកដ្ឋានសុរិយោដី**

**ប្រធានស្តីទី**

**ហត្ថលេខា និងត្រា**

**លឹម វ៉ាន់**

<u>ចម្លងជូន</u>

-ការិយាល័យអភិរក្ស

*"ដើម្បីមុខការ"*

-ការិយាល័យអធិការកិច្ច

*"ដើម្បីជ្រាប"*

-ឯកសារ-កាលប្បវត្តិ

*វាយឡើងវិញ*

ព្រះរាជាណាចក្រកម្ពុជា

ក្រសួងសាធារណការ និងដឹកជញ្ជូន ជាតិ សាសនា ព្រះមហាក្សត្រ

លេខ២០២១សក៤

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ០៨ ឆ្នាំ១៩៩៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ជម្រាបជូន**

**ឯកឧត្តមសហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

*កម្មវត្ថុ៖* ស្តីពីការសុំកំណត់ដីបម្រុងផ្លូវគ្រប់ប្រភេទទូទាំងព្រះរាជាណាចក្រកម្ពុជា។

*យោង៖* លិខិតលេខ៨២៨អស/សជ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៩៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមជ្រាបថា ដើម្បីសម្រេចបានតាមទិសដៅរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍប្រទេសជាតិ ស្តីពីការធានាកម្មសិទ្ធិដីធ្លី និងដើម្បីជួយសម្រួលកិច្ចការដល់នាយកដ្ឋានសុរិយោដីឱ្យអនុវត្តការងារធ្វើកម្មសិទ្ធិដីធ្លីឱ្យបានល្អ ក្រសួងសាធារណការ និងដឹកជញ្ជូនបានសិក្សា និងកំណត់ដីបម្រុងផ្លូវគ្រប់ប្រភេទដូចខាងក្រោម៖

-ផ្លូវជាតិ កំណត់យក២៥ម៉ែត្រសងខាងពីអ័ក្សផ្លូវ

-ផ្លូវខេត្ត កំណត់យក១៥ម៉ែត្រសងខាងពីអ័ក្សផ្លូវ

-ផ្លូវឃុំ កំណត់យក១០ម៉ែត្រសងខាងពីអ័ក្សផ្លូវ

សូមឯកឧត្តមទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ហត្ថលេខា និងត្រា**

**អ៊ឹង គៀត**

ចម្លងជូន

-នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធ

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

គណៈរដ្ឋមន្ត្រី ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន

លេខ១៤៩៤បស្ថ ភ្នំពេញ ថ្ងៃទី១២ ខែ០៩ ឆ្នាំ១៩៩៦

**ជម្រាបជូន**

**ឯកឧត្តមសហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

<u>កម្មវត្ថុ៖</u> ករណីកំណត់ដីបម្រុងឧទ្យានជាតិ ដីបម្រុងផ្លូវគ្រប់ប្រភេទ ដីបម្រុងរុក្ខា-នេសាទទូទាំងព្រះរាជាណាចក្រកម្ពុជា

*<u>យោង៖</u>* លិខិតលេខ៨២៨សស/សដ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៩៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

តបតាមន័យដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមសហរដ្ឋមន្ត្រីជ្រាបថា តំបន់ការពារធម្មជាតិទាំង២៣កន្លែង ដូចមានចែងក្នុងព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ របស់ព្រះករុណាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងតំបន់សើម តំបន់ឆ្នេរដែលមានកូអរដោនេជូនភ្ជាប់ខាងក្រោម ជាតំបន់ដែលព្រះរាជក្រឹត្យបានកំណត់ជាតំបន់ឧទ្យានជាតិដែនជម្រកសត្វព្រៃ តំបន់ការពារទេសភាព តំបន់ប្រើប្រាស់ច្រើនយ៉ាង តំបន់ដីសើម តំបន់ឆ្នេរនៃព្រះរាជាណាចក្រកម្ពុជា។

**<u>ដីបម្រុងទុកសម្រាប់តំបន់ការពារធម្មជាតិ</u>**

| **១-ឧទ្យានជាតិ** | **ផ្ទៃដី** | **ទីតាំង** | **កូអរដោនេ/រយៈទទឹង និងរយៈបណ្តោយ** |
|---|---|---|---|
| -ព្រះសុរាម្រិត-កុសុមៈ "គិរីរម្យ" | 35,000ha | កំពង់ស្ពឺ, កោះកុង | 11$^{0}$11'-11$^{0}$25'N.103$^{0}$57'-11$^{0}$10E |
| -ព្រះមុនីវង្ស "បូកគោ" | 140,000ha | កំពត | 10$^{0}$34'-11$^{0}$10'N.103$^{0}$52'30"-11$^{0}$10'E |
| -កែប | 5,000ha | ក្រុងកែប | 10$^{0}$24'-10$^{0}$33'N.104$^{0}$21"30"-104$^{0}$23'30"E |
| -ព្រះសីហនុ "រាម" | 21,000ha | ក្រុងព្រះសីហនុ | 10$^{0}$22'-10$^{0}$36'N.103$^{0}$36'-103$^{0}$50'E |

| | | | |
|---|---|---|---|
| -បុទុមសាគរ | 171,000ha | កោះកុង | $10^0$52'-$11^0$26'N.$103^0$02'-$103^0$30'E |
| -ភ្នំគូលែន | 37,500ha | សៀមរាប | $13^0$28'-$13^0$40'30"N.$103^0$56'-$104^0$14'30"E |
| -វិរៈជ័យ | 332,500ha | ស្ទឹងត្រែង, រតនគិរី | $13^0$57'-$14^0$42'N.$106^0$25'-$107^0$34'E |

សរុប ៧៤២.000 ha

| ២-ដែនជម្រកសត្វព្រៃ | ផ្ទៃដី | ទីតាំង | កូអរដោនេ/រយៈទទឹង និងរយៈបណ្តោយ |
|---|---|---|---|
| -ភ្នំឱរ៉ាល់ | 253,750ha | កោះកុង, ពោធិ៍សាត់, កំពង់ឆ្នាំង | $11^0$33'30"-$12^0$15'N.$103^0$56'30"-$104^0$21'20"E |
| -ពាមក្រសោប | 23,750ha | កោះកុង | $11^0$25'30"-$11^0$30'N.$102^0$57'30"-$103^0$08'30"E |
| -ភ្នំសំកុស | 333,750ha | កោះកុង | $14^0$22'-$14^0$27'N.$102^0$42'-$103^0$16'E |
| -រនាមដូនសំ | 178,750ha | បាត់ដំបង | $13^0$02'-$13^0$37'N.$102^0$20'30"-$102^0$48'E |
| -ភ្នំគូលេន-ព្រហ្មទេព | 402,500ha | សៀមរាប, ព្រះវិហារ | $13^0$43'-$14^0$19'N.$104^0$02'-$105^0$01'E |
| -បឹងពែរ | 242,500ha | កំពង់ធំ | $12^0$58'30"-$13^0$25'N.$104^0$22'-$105^0$16'E |
| -លំផាត់ | 250,000ha | រតនគិរី, មណ្ឌលគិរី | $13^0$08'-$13^0$33'N.$106^0$33'-$107^0$09'E |
| -ភ្នំព្រេច | 222,500ha | មណ្ឌលគិរី, ក្រចេះ | $12^0$29'-$12^0$59'N.$106^0$31'-$107^0$09'E |
| -ភ្នំណាមលៀរ | 47,500ha | មណ្ឌលគិរី | $12^0$14'-$12^0$42'N.$107^0$22'-$107^0$36'E |
| -ស្នួល | 75,500ha | ក្រចេះ | $11^0$57'-$12^0$13'N.$106^0$27'-$106^0$54'30"E |

សរុប ២.០៣០.៥00 ha

| ៣-តំបន់ការពារទេសភាព | ផ្ទៃដី | ទីតាំង | កូអរដោនេ/រយៈទទឹង និងរយៈបណ្តោយ |
|---|---|---|---|
| -អង្គរ | 10,800ha | សៀមរាប | $13^0$23'30"-$13^0$28'N.$103^0$46'-$103^0$58'E |
| -បន្ទាយឆ្មារ | 81,200ha | បន្ទាយមានជ័យ | $13^0$56'-$14^0$22'N.$102^0$54'-$103^0$21'E |
| -ព្រះវិហារ | 5,000ha | ព្រះវិហារ | $14^0$22'-$14^0$27'N.$104^0$38'-$104^0$45'E |

សរុប ៩៧.000 ha

| ៤.តំបន់បើប្រាស់ច្រើនយ៉ាង | ផ្ទៃដី | ទីតាំង | កូអរដោនេ/រយៈទទឹង និងរយៈបណ្តោយ |
|---|---|---|---|
| -ដងពែង | 27,700ha | កោះកុង | $11^{0}$-$11^{0}13'$N.$103^{0}28'$-$103^{0}47'$E |
| -សំឡូត | 60,000ha | បាត់ដំបង | $12^{0}32'$-$12^{0}53'$N.$102^{0}30'$-$102^{0}47'$E |
| -ទន្លេសាប | 316,250ha | កំពង់ឆ្នាំង, កំពង់ធំ, សៀមរាប, បាត់ដំបង, ពោធិ៍សាត់ | $12^{0}21'$-$13^{0}28'30''$N.$103^{0}14'$-$104^{0}43'$E |

សរុប <u>៤០៣.៩៥០ ha</u>

**សរុបតំបន់ការពារធម្មជាតិទាំង២៣កន្លែង** <u>3.273.450 ha</u>

ដោយឡែក ក្រៅពីតំបន់ការពារធម្មជាតិខាងលើ នាពេលថ្មីៗនេះ ឆ្លងតាមការសិក្សា និងការធ្វើអត្តសញ្ញាណកម្មតំបន់ដីសើម នៅទូទាំងព្រះរាជាណាចក្រកម្ពុជារវាងក្រសួងបរិស្ថាន និងអង្គការដីសើមអន្តរជាតិប្រចាំអាស៊ីប៉ាស៊ីភិច (WI-AP) បានលើកគម្រោងស្នើបន្ថែមតំបន់ដីសើមសំខាន់ៗចំនួន២៨កន្លែង ដែលក្នុងនោះមាន១២កន្លែង ឋិតនៅក្នុងតំបន់ការពារធម្មជាតិ និង ១៦កន្លែងទៀតមានដូចខាងក្រោម៖

| ៥.តំបន់ឆ្នេរ "ទឹកប្រៃ" | ផ្ទៃដី | ទីតាំង | កូអរដោនេ/រយៈទទឹង និងរយៈបណ្តោយ |
|---|---|---|---|
| -កំពង់ត្រាច | 17,500ha | កំពត | $10^{0}24'30''$-$10^{0}33'30''$N.$104^{0}24'60''$-$104^{0}36'60''$E |
| -ព្រែកកំពង់បាយ | 16,250ha | កំពត | $10^{0}30'60''$-$10^{0}33'30''$N.$104^{0}08'30''$-$104^{0}18'$E |
| -ព្រែកទឹកសាប | 21,250ha | កំពង់សោម | $10^{0}24'$-$10^{0}37'30''$N.$103^{0}40'$-$107^{0}59'$E |
| -ឆកវាលរិញ | 14,900ha | កំពង់សោម | $10^{0}35'$-$10^{0}43'10''$N.$103^{0}47'30''$-$103^{0}58'30''$E |
| -ព្រែកពីផុត | 21,250ha | កោះកុង | $11^{0}04'30''$-$11^{0}19'$N.$103^{0}18'30''$-$103^{0}36'30''$E |
| -ស្ទឹងមេទឹក | 22,500ha | កោះកុង | $11^{0}32'60''$-$11^{0}51'$N.$102^{0}51'$-$103^{0}06'00''$E |

សរុប <u>១១៣.៦៥០ ha</u>

*វាយឡើងវិញ*

| ៦.តំបន់ដីសើម "ទន្លេមេគង្គ" | ផ្ទៃដី | ទីតាំង | កូអរដោនេ/រយៈទទឹង និងរយៈបណ្តោយ |
|---|---|---|---|
| -បឹងប្រសាទទុយោ | 72,000ha | កណ្តាល | $11^{0}03'30''-11^{0}27'30''N.105^{0}00'00''-105^{0}16'30''E$ |
| -បឹងវាលសំណាប | 10,850ha | កណ្តាល | $11^{0}31'45''-13^{0}20'00''N.103^{0}34'00''-103^{0}45'E$ |
| -បឹងជ្រីង | 16,000ha | ព្រៃវែង | $11^{0}31'30''-11^{0}31'00''N.105^{0}217'-105^{0}27'30''E$ |
| -ប្រព័ន្ធទន្លេនៅខេត្តក្រចេះ | 142,250ha | ក្រចេះ | $12^{0}06'00''-13^{0}14'00''N.105^{0}42'00''-107^{0}31'00''E$ |
| -ទន្លេសេសាន | 146,250ha | រតនគីរី | $13^{0}29'-14^{0}10'N.106^{0}05'-107^{0}26'00''E$ |
| -ទន្លេសេកុង | 34,750ha | ស្ទឹងត្រែង | $13^{0}31'00''-14^{0}28'00''N.105^{0}57'00''-106^{0}45'00''E$ |
| -ទន្លេមេគង្គលើ | 48,000ha | ស្ទឹងត្រែង | $13^{0}12'00''-13^{0}56'00''N.105^{0}51'00''-106^{0}04'00''E$ |
| -ពាមពិលាង | 63,750ha | កំពង់ចាម | $12^{0}00'00''-12^{0}20'00''N.103^{0}26'00''-105^{0}42'00''E$ |
| -បឹងសៀមបួយ | 38,000ha | កំពង់ចាម | $10^{0}52'00''-12^{0}02'30''N.105^{0}00'30''-105^{0}26'00''E$ |
| -បឹងប្រាង | 12,600ha | កណ្តាល | $11^{0}31'15''-11^{0}39'00''N.105^{0}06'40''-105^{0}13'45''E$ |

សរុប ៤៥៧.៤៥០ ha

**សរុបតំបន់ឆ្នេរ និងតំបន់ដីសើមទាំង១៦កន្លែង** 571.100 ha

**ផ្ទៃដីតំបន់ការពារធម្មជាតិ តំបន់ឆ្នេរ តំបន់ដីសើម**

**នៅទូទាំងព្រះរាជាណាចក្រកម្ពុជា** 3.844.550 ha

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមសហរដ្ឋមន្ត្រី មេត្តាពិនិត្យ និងជ្រាបតាមការគួរ។

ដោយការគោរពរាប់អានដ៏ស្មោះបំផុតអំពីខ្ញុំ។

**រដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**បណ្ឌិត ម៉ុក ម៉ារ៉េត**

# ព្រះរាជក្រម

នស/រកម/១២៩៦/៣៦

## យើង

## ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស
## អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទីទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និងអំពីរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលរដ្ឋសភាអនុម័ត កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៦ នាសម័យប្រជុំលើកទី៧ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

## ជំពូកទី១ បទប្បញ្ញត្តិទូទៅ

**មាត្រា១**

ច្បាប់នេះមានគោលដៅ៖

-ការពារ លើកកម្ពស់គុណភាពបរិស្ថាន និងសុខភាពពលរដ្ឋដោយធ្វើការទប់ស្កាត់ ការកាត់បន្ថយ និងការត្រួតពិនិត្យការបំពុល

-វាយតម្លៃហេតុប៉ះពាល់បរិស្ថាន មុននឹងចេញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលចំពោះរាល់គម្រោងដែលបានស្នើឡើង

-ធានាឱ្យមានការអភិរក្ស ការអភិវឌ្ឍ ការគ្រប់គ្រង និងការប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរនូវធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា

-លើកទឹកចិត្ត និងផ្តល់លទ្ធភាពឱ្យសាធារណជន ចូលរួមក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

-បង្ក្រាបអំពើទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន។

## ជំពូកទី២ ផែនការបរិស្ថានជាតិ និងផែនការបរិស្ថានតំបន់

**មាត្រា២**

ផែនការបរិស្ថានជាតិ និងផែនការបរិស្ថានតំបន់ត្រូវសម្រេចដោយរាជរដ្ឋាភិបាល និងក្រសួងបរិស្ថានដោយសហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ។

**មាត្រា៣**

ផែនការបរិស្ថានជាតិជាផែនការសម្រាប់កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរសម្រាប់អនុវត្តទូទាំងព្រះរាជាណាចក្រកម្ពុជា។

ផែនការបរិស្ថានជាតិត្រូវ៖

-កំណត់ពីបញ្ហាបរិស្ថានសំខាន់ៗ និងបញ្ហាគ្រប់គ្រងធនធានធម្មជាតិសំខាន់ៗ ដែលពាក់ព័ន្ធនិងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម

-លើកឡើងពីវិធានការសម្រាប់ធានាការគ្រប់គ្រងបរិស្ថាន ។

**មាត្រា៤**

ផែនការបរិស្ថានតំបន់ ត្រូវអនុលោមតាមផែនការបរិស្ថានជាតិ ។ ផែនការបរិស្ថានតំបន់ត្រូវ៖

-កំណត់ពីបញ្ហាបរិស្ថានសំខាន់ៗ និងបញ្ហាគ្រប់គ្រងធនធានធម្មជាតិសំខាន់ៗ ដែលពាក់ព័ន្ធទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៃតំបន់នីមួយៗ

-លើកឡើងពីវិធានការសម្រាប់ធានាការគ្រប់គ្រងបរិស្ថាននៃតំបន់នោះ ។

**មាត្រា៥**

ផែនការបរិស្ថានជាតិ និងផែនការបរិស្ថានតំបន់ត្រូវពិនិត្យ និងកែសម្រួលយ៉ាងយូរមួយដងក្នុងរយៈពេលប្រាំឆ្នាំ ។

## ជំពូកទី៣ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**មាត្រា៦**

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវអនុវត្តលើរាល់គម្រោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈ ហើយត្រូវពិនិត្យ និងវាយតម្លៃដោយក្រសួងបរិស្ថានមុនដាក់ជូនរាជរដ្ឋាភិបាលសម្រេច ។

ការវាយតម្លៃនេះក៏ត្រូវបានអនុវត្តផងដែរចំពោះសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ ហើយដែលពុំទាន់បានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅឡើយ ។

បែបបទនៃកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងបរិស្ថាន ។

ប្រភេទ និងទំហំគម្រោង និងសកម្មភាពដែលស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការទាំងឯកជន និងសាធារណៈ ដែលត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននោះត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន ។

**មាត្រា៧**

ចំពោះរាល់ពាក្យសុំធ្វើគម្រោងវិនិយោគ និងរាល់គម្រោងដែលរដ្ឋស្នើឡើង ត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬក៏ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដូចមានចែងក្នុងមាត្រា៦នៃច្បាប់នេះ។ ក្រសួងបរិស្ថានត្រូវពិនិត្យ និងផ្តល់យោបល់លើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬការវាយតម្លៃហេតុប៉ះពាល់បរិស្ថានទៅអង្គការមានសមត្ថកិច្ច ក្នុងរយៈពេលដូចបានកំណត់ក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៤ ការគ្រប់គ្រងធនធានធម្មជាតិ

### មាត្រា៨

ធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជាដែលមានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពលប្រេងកាតនិងឧស្ម័ន ថ្មនិងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆជាតិ ធនធានជលផល ត្រូវបានអភិរក្ស អភិវឌ្ឍ និងគ្រប់គ្រងប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរ។

តំបន់ការពារធនធានធម្មជាតិមានជាអាទិ៍ ឧទ្យានជាតិ ជម្រកសត្វព្រៃ តំបន់ការពារទេសភាព តំបន់ប្រើប្រាស់ច្រើនយ៉ាងត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

### មាត្រា៩

ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធ ត្រូវធ្វើការសិក្សាស្រាវជ្រាវ វាយតម្លៃហេតុប៉ះពាល់បរិស្ថានលើធនធានធម្មជាតិ និងផ្តល់យោបល់ជូនក្រសួងពាក់ព័ន្ធ ដើម្បីធានាឱ្យធនធានធម្មជាតិដូចមានចែងក្នុងមាត្រា៨ ត្រូវបានអភិរក្ស អភិវឌ្ឍ និងគ្រប់គ្រងប្រើប្រាស់ដោយសមហេតុផលប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរ។

### មាត្រា១០

មុនពេលចេញសេចក្តីសម្រេចនានា ឬធ្វើសកម្មភាពផ្សេងៗ ទាក់ទិនដល់ការអភិរក្ស ការអភិវឌ្ឍ ឬការគ្រប់គ្រងការប្រើប្រាស់ធនធានធម្មជាតិ ក្រសួងពាក់ព័ន្ធត្រូវពិគ្រោះយោបល់ជាមួយក្រសួងបរិស្ថានអំពីនិរន្តរភាព និងភាពស្ថិតស្ថេរនៃធនធានធម្មជាតិ។

### មាត្រា១១

ក្រសួងបរិស្ថានត្រូវជូនដំណឹងជាបន្ទាន់ដល់ក្រសួងពាក់ព័ន្ធ នៅពេលណាដែលក្រសួងបរិស្ថានពិនិត្យឃើញថា ធនធានធម្មជាតិមិនមានការអភិរក្ស ការអភិវឌ្ឍ ឬការគ្រប់គ្រងការប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរទេនោះ។

## ជំពូកទី៥ កិច្ចការពារបរិស្ថាន

### មាត្រា១២

ក្រសួងបរិស្ថានត្រូវសហការជាមួយក្រសួងពាក់ព័ន្ធ ដើម្បីចងក្រងបញ្ជីសារពើភ័ណ្ឌដែលបញ្ជាក់ពី៖

-ប្រភព ប្រភេទ និងបរិមាណនៃសារធាតុបំពុល និងសំណល់ដែលបាននាំចូល និងបង្កើតឡើង ដឹកជញ្ជូន កែច្នៃឡើងវិញ បានប្រព្រឹត្តកម្ម រក្សាទុក បោះបង់ចោល ឬបញ្ចេញចោលទៅក្នុងអាកាស ទឹក ដី ឬលើដី

-ប្រភព ប្រភេទ និងបរិមាណនៃសារធាតុពុល និងសារធាតុប្រកបដោយគ្រោះថ្នាក់ដែលបាននាំចូល ផលិត ដឹកជញ្ជូន រក្សាទុក ប្រើប្រាស់ បង្កើតឡើង បានប្រព្រឹត្តកម្ម កែច្នៃឡើងវិញ បោះបង់ចោល ឬដែលបានបញ្ចេញចោលទៅក្នុងអាកាស ទឹក ឬទៅក្នុងដីឬ លើដី

-ប្រភព ប្រភេទ និងទំហំនៃការរំខានដោយសំឡេង និងរំញ័រ។

### មាត្រា១៣

ការទប់ស្កាត់ ការកាត់បន្ថយ និងការត្រួតពិនិត្យការបំពុលអាកាស ទឹក ដី ការរំខានដោយសំឡេង និងរំញ័រ ព្រមទាំងសំណល់សារធាតុពុល និងសារធាតុប្រកបដោយគ្រោះថ្នាក់ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងបរិស្ថាន។

## ជំពូកទី៦ ការត្រួតពិនិត្យ កំណត់ត្រា អធិការកិច្ច

### មាត្រា១៤

ក្រសួងបរិស្ថានត្រូវសហការជាមួយក្រសួងពាក់ព័ន្ធ ដើម្បីកំណត់ឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែងរោងចក្រ ប្រភពបំពុល តំបន់ឧស្សាហកម្ម ឬតំបន់មានសកម្មភាពអភិវឌ្ឍធនធានធម្មជាតិនានា៖

-ដំឡើង ឬប្រើប្រាស់ឧបករណ៍ត្រួតពិនិត្យ

-ផ្តល់គំរូតាង

-រៀបចំ ឬរក្សាទុក និងផ្ញើជូនពិនិត្យនូវកំណត់ត្រា និងរបាយការណ៍នានា។

**មាត្រា១៥**

ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន និងក្នុងការទទួលខុសត្រូវលើតំបន់ការពារធម្មជាតិ ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធ អាចចូលធ្វើអធិការកិច្ចក្នុងតំបន់ទីក្នុងបរិវេណអគារលើ ឬក្នុងមធ្យោបាយដឹកជញ្ជូន ឬទីកន្លែងណាមួយ។ល។ ក្នុងករណីដែលក្រសួងបរិស្ថានពិនិត្យឃើញថាប្រភពនោះធ្វើឱ្យមានការប៉ះពាល់ដល់គុណភាពបរិស្ថាន។

មន្ត្រីអធិការកិច្ចរបស់ក្រសួងបរិស្ថាន និងមន្ត្រីរបស់ក្រសួងពាក់ព័ន្ធដែលសហការជាមួយត្រូវបង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកកម្មរបស់ខ្លួននៅមុនពេលធ្វើអធិការកិច្ច។

នៅពេលធ្វើអធិការកិច្ច កាលណាពិនិត្យឃើញថាមានបទល្មើសព្រហ្មទណ្ឌកើតឡើង នោះមន្ត្រីអធិការកិច្ចត្រូវរាយការណ៍ជាបន្ទាន់ ជូនស្ថាប័នមានសមត្ថកិច្ចដើម្បីចាត់ការតាមច្បាប់។

នីតិវិធីនៃការធ្វើអធិការកិច្ច ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន។

**ជំពូកទី៧ ការចូលរួមរបស់សាធារណជន និងការស្រង់យកព័ត៌មាន**

**មាត្រា១៦**

ក្រសួងបរិស្ថានត្រូវផ្តល់ជូនតាមសំណូមពររបស់សាធារណជន នូវព័ត៌មានពីសកម្មភាពរបស់ខ្លួន និងត្រូវលើកទឹកចិត្តឱ្យមានការចូលរួមពីសាធារណជន ក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

**មាត្រា១៧**

បែបបទនៃការចូលរួមរបស់សាធារណជន និងការស្រង់យកព័ត៌មានក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងបរិស្ថាន។

**មាត្រា១៨**

ព័ត៌មានដែលទាក់ទងទៅនឹងកិច្ចការពារបរិស្ថាន ឬការគ្រប់គ្រងធនធានធម្មជាតិ ត្រូវផ្សព្វផ្សាយជូនគ្នាទៅវិញទៅមក រវាងក្រសួងបរិស្ថាន និងក្រសួងនានា។

**ជំពូកទី៨ មូលនិធិទាយជ្ជទានបរិស្ថាន**

*វាយឡើងវិញ*

**មាត្រា១៩**

ត្រូវបង្កើតគណនីពិសេសរបស់រតនាគារជាគណនីមូលនិធិទាយជ្ជទានបរិស្ថាន សម្រាប់ឱ្យក្រសួងបរិស្ថានយកទៅចាត់ចែងក្នុងកិច្ចការពារបរិស្ថាន និងការអភិរក្សធនធានធម្មជាតិក្នុងព្រះរាជាណាចក្រកម្ពុជា អនុលោមតាមច្បាប់ហិរញ្ញវត្ថុ ។

មូលនិធិទាយជ្ជទានបរិស្ថានដែលបានមកពីវិភាគទានផ្សេងៗរបស់រាជរដ្ឋាភិបាល ជំនួយរបស់អង្គការអន្តរជាតិនានា អំណោយពីអង្គការក្រៅរដ្ឋាភិបាល និងចំណូលស្របច្បាប់ផ្សេងៗ ត្រូវបញ្ចូលក្នុងថវិកាជាតិដើម្បីផ្តល់ឱ្យគណនីពិសេសខាងលើ ។

**ជំពូកទី៩ ទោសប្បញ្ញត្តិ**

**មាត្រា២០**

ចំពោះបុគ្គលណាដែលប្រព្រឹត្តល្មើសនឹងការកំណត់របស់ក្រសួងបរិស្ថាន ដូចមានចែងក្នុងមាត្រា១៨នៃច្បាប់នេះ ក្រសួងបរិស្ថានត្រូវចេញបញ្ជាជាលាយលក្ខណ៍អក្សរតម្រូវឱ្យ៖

-កែប្រែសកម្មភាពល្មើសជាបន្ទាន់ ឬក្នុងរយៈពេលណាមួយជាក់លាក់ឬ

-ផ្អាកសកម្មភាពរបស់ខ្លួនរហូតដល់បទល្មើសនោះត្រូវបានកែប្រែ ឬ

-លុបបំបាត់ការបំពុលជាបន្ទាន់ ។

**មាត្រា២១**

បុគ្គលណាមិនអនុញ្ញាត ឬរារាំងមិនឱ្យមន្ត្រីអធិការកិច្ចចូលធ្វើការត្រួតពិនិត្យ ឬធ្វើអធិការកិច្ចលើទីតាំងដូចមានចែងក្នុងវាក្យខណ្ឌទី១ មាត្រា១៥នៃច្បាប់នេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពីប្រាំសែនរៀល (៥០០.០០០រៀល) ដល់មួយលានរៀល (១.០០០.០០០រ) ។ ក្នុងករណីពុំរាងចាលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល (១.០០០.០០០រ) ដល់ប្រាំលានរៀល (៥.០០០.០០០រ) ឬផ្តន្ទាទោសដាក់ពន្ធនាគារពី១ខែ ដល់៣ខែ ឬទោសទាំងពីរនេះ ។

បុគ្គលណាប្រព្រឹត្តល្មើសនឹងមាត្រា២០នៃច្បាប់នេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពីមួយលានរៀល (១.០០០.០០០រៀល) ដល់ដប់លានរៀល (១០.០០០.០០០រៀល) ។ ក្នុងករណីពុំរាងចាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីម្ភៃមួយលានរៀល (២១.០០០.០០០រៀល) ដល់សាមសិបលានរៀល (៣០.០០០.០០០រៀល) ឬផ្តន្ទាទោសដាក់ពន្ធនាគារពី១ខែ ដល់១ឆ្នាំ ឬទោសទាំងពីរនេះ ។

**មាត្រា២២**

បើការប្រព្រឹត្តល្មើសបង្កឱ្យមានគ្រោះថ្នាក់ដល់រាងកាយ ឬជីវិតមនុស្ស ដល់ទ្រព្យសម្បត្តិឯកជន ដល់ទ្រព្យសម្បត្តិសាធារណៈ ដល់បរិស្ថាន ដល់ធនធានធម្មជាតិ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លានរៀល (១០.000.000រៀល) ដល់ហាសិបលានរៀល (៥០.000.000រៀល) ឬផ្តន្ទាទោសដាក់ពន្ធនាគារពីមួយឆ្នាំដល់ប្រាំឆ្នាំ ឬទោសទាំងពីរនេះ ។

បុគ្គលដែលប្រព្រឹត្តល្មើសត្រូវទទួលជួសជុលសងការខូចខាត និងសងជំងឺចិត្តថែមទៀត ។

**មាត្រា២៣**

ក្នុងករណីដែលការប្រព្រឹត្តល្មើសបង្កឱ្យមានគ្រោះមហន្តរាយធ្ងន់ធ្ងរ ចំពោះសង្គមជាតិ តុលាការអាចនឹងយកកាលៈទេសៈទម្ងន់ទោស ទៅប្រកបផ្សំនឹងបទល្មើសណាមួយខាងលើនេះដើម្បីផ្តន្ទាទោស ។

**មាត្រា២៤**

មន្ត្រី ឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណាដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវដាក់បទចោទប្រកាន់ចំពោះមុខតុលាការ ។

**មាត្រា២៥**

ក្រសួងបរិស្ថានត្រូវអនុវត្តទៅតាមបទប្បញ្ញត្តិនៃមាត្រា២០ខាងលើ ចំពោះបុគ្គលណាដែលប្រព្រឹត្តល្មើសនឹងអនុក្រឹត្យ និងលិខិតបទដ្ឋានផ្សេងៗដែលពាក់ព័ន្ធនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។ ក្នុងករណីរឹងទទឹង ត្រូវអនុវត្តទៅតាមបទប្បញ្ញត្តិដែលមានចែងក្នុងមាត្រា២១នៃច្បាប់នេះ ។

## ជំពូកទី១០ អន្តរប្បញ្ញត្តិ

**មាត្រា២៦**

ក្រោយពេលច្បាប់នេះចូលជាធរមានរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២00១ ចំពោះសកម្មភាពដែលកំពុងដំណើរការបច្ចុប្បន្ន រាជរដ្ឋាភិបាលអាចពន្យារពេលការប្រតិបត្តិអនុក្រឹត្យ ដែលចែងក្នុងមាត្រា១៣នៃច្បាប់នេះ តាមសំណើរបស់ក្រសួងបរិស្ថាន ។

ក្នុងការសម្រេចពន្យារពេលនេះត្រូវ៖

-ថ្លឹងថ្លែងពីប្រភេទ និងទំហំនៃគ្រោះថ្នាក់ដល់សុខភាពមនុស្ស ដល់បរិស្ថាន និងដល់ធនធានធម្មជាតិដែលអាចកើតឡើងពីការពន្យារពេលនេះ

-ពិនិត្យទៅលើលទ្ធភាព មធ្យោបាយ បច្ចេកទេស និងហិរញ្ញវត្ថុរបស់សកម្មភាពដែលកំពុងដំណើរការនេះ ។

## ជំពូកទី១១ អវសានប្បញ្ញត្តិ

**មាត្រា២៧**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានបង្គំទូលថ្វាយ និងជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី១ និងទី២

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

| **នាយករដ្ឋមន្ត្រីទី១** | **នាយករដ្ឋមន្ត្រីទី២** |
|---|---|
| **ព្រះហស្តលេខា** | **ហត្ថលេខា** |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

លេខ០១ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមករា ឆ្នាំ១៩៩៧

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ហត្ថលេខា និងត្រា**

**ស៊ិន ស៊ីវី**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

នាយកដ្ឋានសុរិយោដី

លេខ១៤៦សជ

ភ្នំពេញ ថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៩៧

ប្រធាននាយកដ្ឋានសុរិយោដី

ជម្រាបមក

លោកប្រធានមន្ទីរសុរិយោដីគ្រប់ខេត្ត-ក្រុង

*កម្មវត្ថុ៖* អំពីការទទួលខុសត្រូវក្នុងការពិនិត្យឯកសារសុរិយោដី

តបតាមកម្មវត្ថុខាងលើ នាយកដ្ឋានសុរិយោដីបានសង្កេតឃើញថា ស្ទើរគ្រប់មន្ទីរសុរិយោដីទាំងអស់ពុំទាន់មានស្មារតីទទួលខុសត្រូវ ព្រមទាំងមានភាពធូររលុងក្នុងការអនុវត្ត នូវរាល់គោលការណ៍ណែនាំរបស់នាយកដ្ឋានដែលបណ្តាលឱ្យមានការខុសឆ្គងជាញឹកញាប់នោះ គឺការពិនិត្យឯកសារអភិរក្ស។

ដូចនេះ ដើម្បីចៀសវាងនូវរាល់បណ្តាការខុសឆ្គង និងការធ្វេសប្រហែសផងទាំងឡាយ នាយកដ្ឋានសុំបញ្ជាក់បន្ថែមទៀតថា រាល់ឯកសារសុរិយោដីទាំងឡាយណាដែលត្រូវផ្ញើមកនាយកដ្ឋាន ថ្នាក់ដឹកនាំមន្ទីរត្រូវចាត់ឱ្យមន្ត្រីដែលមានភារកិច្ចពិនិត្យឯកសារយកចិត្តទុកដាក់ឱ្យបានម៉ត់ចត់ និងត្រឹមត្រូវទៅតាមគោលការណ៍ណែនាំដែលនាយកដ្ឋានបានកំណត់។ មន្ត្រីក្រៅពីប្រធានផ្នែកអភិរក្ស ឬអ្នកពិនិត្យ (vérificateur) ដែលមានការតែងតាំងរួចហើយមិនអនុញ្ញាតឱ្យបញ្ជាក់ លើឯកសារសុរិយោដីឡើយ។ ករណីមានការចាំបាច់ដោយការងារច្រើន លោកប្រធានត្រូវធ្វើសំណូមពរមកនាយកដ្ឋាន ដើម្បីតែងតាំងមន្ត្រីម្នាក់ ឬច្រើននាក់ឱ្យទទួលភារកិច្ចជាអ្នកពិនិត្យ (vérificateur) ឯកសារបាន។

អាស្រ័យហេតុនេះ ស្នើលោកប្រធានចាត់ការតាមខ្លឹមសារលិខិតនេះឱ្យមានប្រសិទ្ធភាពខ្ពស់ បើពុំនោះទេ នាយកដ្ឋាននឹងបញ្ជូនត្រលប់វិញ (rejeter) នូវរាល់ឯកសារណាដែលពិនិត្យ

*វាយឡើងវិញ*

ដោយមន្ត្រីដែលនាយកដ្ឋានពុំបានតែងតាំងឱ្យទទួលបន្ទុកពិនិត្យ ព្រមទាំងធ្វើការកត់សម្គាល់ក្នុងការអនុវត្តនេះ។

**ជ.នាយកដ្ឋានសុរិយោដី**

**អនុប្រធាន**

**ហត្ថលេខា និងត្រា**

**លឹម ហោ**

<u>កន្លែងទទួល</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់អភិបាលខេត្ត-ក្រុង

*"ដើម្បីសូមជូនជ្រាប"*

-ការិយាល័យអភិរក្ស

*"ដើម្បីមុខការ"*

-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្ដីការគណៈរដ្ឋមន្ត្រី**
**នាយកដ្ឋានសុរិយោដី**
លេខ១៥៧សជ

**ប្រធាននាយកដ្ឋានសុរិយោដី**
**សូមគោរពមក**
**ឯកឧត្ដមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

តាមរយៈ៖ ឯកឧត្ដមសហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី។

កម្មវត្ថុ៖ ករណីបដិសេធប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ។

យោង៖ -សាលក្រមលេខ២៥ "រ" ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៦ របស់តុលាការខេត្តកណ្ដាល
-ដីកាសម្រេចលេខ១៩ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ១៩៩៧ របស់តុលាការខេត្តកំពង់ចាម
-សាលក្រមលេខ០៧ ចុះថ្ងៃទី១២ មេសា ឆ្នាំ១៩៩៦ របស់តុលាការក្រុងព្រះសីហនុ

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្ដមទេសរដ្ឋមន្ត្រីមេត្តាជ្រាប ដូចតទៅ៖

រយៈកាលកន្លងមក តុលាការខេត្ត-ក្រុងជាច្រើនបានបដិសេធប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុចោល ដោយពុំមានហេតុផលត្រឹមត្រូវតាមបីករណីខាងក្រោម៖

ករណីទី១ ដីរបស់ឈ្មោះ "ក" មានប័ណ្ណត្រឹមត្រូវ តែដោយទីទ័លក្រ ឈ្មោះនេះបានខ្ចីប្រាក់ពីឈ្មោះ "ខ" យមមករកស៊ី ឬផ្គត់ផ្គង់ជីវភាព។ ក្រោមយក ជាច្រើនឆ្នាំពុំមានប្រាក់សងគេ ម្ចាស់បំណុលក៏ប្ដឹងទៅតុលាការ។ ដោយមិនមានលទ្ធភាពសងបំណុល តុលាការក៏រឹបអូសដី ហើយដាក់លក់ឡាយឡុងយកប្រាក់មកសងម្ចាស់បំណុល។ នៅពេលដែលឈ្មោះ "ខ" ឬនរណាម្នាក់ដេញថ្លៃបាន តុលាការក៏សម្រេចបដិសេធប័ណ្ណដីរបស់ "ក" ហើយបង្គាប់ឱ្យស្ថាប័នសុរិយោដីចេញប័ណ្ណថ្មីមួយទៀតឱ្យ "ខ" ឬអ្នកដេញថ្លៃបានលើដីដែលមានភិនភាគ រូបរាង ទំហំដដែលនេះ។

ករណីទី២ តាមធម្មតាមុនពេលជំនុំជម្រះក្ដី ចៅក្រមតែងតែប្រមូលគ្រប់ឯកសារដើមដែលជាកម្មវត្ថុនៃវិវាទក្នុងនោះមានប័ណ្ណសម្គាល់សិទ្ធិផងដែរ។ ផ្ទុយទៅវិញ ចៅក្រមពុំបានដកហូត

ប័ណ្ណសម្គាល់សិទ្ធិពីចុងចម្លើយ "A" ឬដកហូតពុំបាន។ ពេលជំនុំជម្រះ ដើមចោទ "B" ឈ្នះក្ដី ស្រាប់តែតុលាការចេញសាលក្រមបដិសេធប័ណ្ណដីរបស់ចុងចម្លើយ "A" ហើយបង្គាប់ឱ្យស្ថាប័នជំនាញកសាងឯកសារជាថ្មី ដើម្បីចេញប័ណ្ណសម្គាល់សិទ្ធិទៅឱ្យដើមចោទ "B" ដោយពុំបានរឹបអូសយកប័ណ្ណពីចុងចោទ "A" ប្រគល់ឱ្យដើមចោទ "B" ឬបញ្ជូនឱ្យស្ថាប័នសុរិយោដីធ្វើការផ្ទេរសិទ្ធិពី "A" ទៅ "B" តាមអំណាចសាលក្រម។

<u>ករណីទី៣</u> តុលាការជំនុំជម្រះដោយកំបាំងមុខចុងចម្លើយ ហើយត្រូវរឹបអូសអចលនវត្ថុរបស់បុគ្គល "X" ដើម្បីប្រគល់ឱ្យ "Y" ដែលត្រូវមានសិទ្ធិបន្ត ពេលនោះតុលាការបដិសេធប័ណ្ណរបស់ "X" ចោលតែម្ដង ហើយបង្គាប់ឱ្យស្ថាប័នជំនាញកសាងប័ណ្ណថ្មី លើដីនោះឱ្យទៅ "Y" វិញ។

ក្នុងករណីទាំងបីខាងលើ បើពិនិត្យអំពីលក្ខណៈគតិយុត្តរបស់ប័ណ្ណ និងឯកសារមូលដ្ឋានក្នុងការចេញប័ណ្ណឃើញថាត្រឹមត្រូវ។ ដូចនេះ តុលាការមិនគួរបដិសេធប័ណ្ណសម្គាល់សិទ្ធិចោលទេ តែត្រូវរក្សាប័ណ្ណនោះទុក ទើបស្ថាប័នសុរិយោដីអាចផ្ទេរឈ្មោះបានតាមអំណាចសាលក្រម ឬសាលដីកា។ ប្រសិនបើ តុលាការបដិសេធប័ណ្ណដែលត្រឹមត្រូវនោះ វានឹងនាំឱ្យមានភាពស្មុគស្មាញដល់ការកសាងឯកសារ និងប័ណ្ណថ្មី ព្រមទាំងការធ្វើលេខាចារឹកក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ និងឯកសារផ្សេងៗទៀត។

ខ្ញុំសូមបញ្ជាក់ថា ប័ណ្ណសម្គាល់សិទ្ធិមានចំណុចសំខាន់ៗពីរគឺ៖

-បង្ហាញ និងបញ្ជាក់អំពីបុគ្គលដែលជាម្ចាស់អចលនវត្ថុត្រូវមានសិទ្ធិ សារតារ ប្រភពនៃសិទ្ធិ។

-បង្ហាញ និងបញ្ជាក់អំពីបុគ្គលដែលជាម្ចាស់អចលនវត្ថុត្រូវមានសិទ្ធិប្រត្យក្រ ភិនភាគក្បាលដី ទំហំទ្រង់ទ្រាយ រូបរាង (មានគំនូសបង្ហាញក្នុងឯកសារ) ទីតាំងនៃដី និងប្រវត្តិនៃដី។

ពាក់ព័ន្ធនឹងវិវាទដែលកើតចេញពីការផ្លាស់ប្ដូរបុគ្គល ដែលត្រូវមានសិទ្ធិគ្រប់គ្រងកាន់កាប់ដី ហើយក្បាលដីមិនមានអ្វីប្រែប្រួលនោះ តុលាការគួររក្សាប័ណ្ណសម្គាល់សិទ្ធិក្បាលដីនោះ ទោះជាតុលាការសម្រេចប្រគល់ទៅឱ្យបុគ្គលណាថ្មីទៀតក៏ដោយចុះ គឺគ្រាន់តែបញ្ជូនសាលក្រម និងប័ណ្ណសម្គាល់សិទ្ធិទៅស្ថាប័នជំនាញសុរិយោដី ស្ថាប័នជំនាញនេះអាចធ្វើការផ្ទេរឱ្យទៅបុគ្គលដែលទទួលសិទ្ធិថ្មីបានត្រឹមត្រូវហើយ។ តែបើតុលាការបដិសេធប័ណ្ណចាស់ចោល ឬមិនដកហូតប័ណ្ណប្រគល់ឱ្យស្ថាប័នជំនាញទេ នោះជំនាញមិនអាចកសាងប័ណ្ណថ្មីឱ្យអ្នកក្រោយ (អ្នកទទួលសិទ្ធិ) បានឡើយ ព្រោះដីមួយក្បាលមិនអាចធ្វើសំណុំរឿងពីរបានទេ។

តុលាការអាចបដិសេធប័ណ្ណបាន តែក្នុងករណីក្បាលដីដែលជាកម្មវត្ថុនៃសិទ្ធិប្រត្យក្រមានការខុសឆ្គងអំពីភិនភាគ ទំហំ ទ្រង់ទ្រាយ រូបរាង ទីតាំង ឬក្បាលដីជាន់គ្នាដែលស្ថាប័នជំនាញអាចកសាងប័ណ្ណជាថ្មីឡើងវិញទៅតាមសភាពជាក់ស្តែងបាន។ ទន្ទឹមនឹងនេះ ស្ថាប័នជំនាញសុរិយោដី សូមធ្វើសំណូមពរដល់ក្រសួងយុត្តិធមិបីចំណុចថែមទៀត៖

១-រឿងក្តីដែលទាក់ទិននឹងអចលនវត្ថុ មុននឹងជំនុំជម្រះ តុលាការគួរតែស្រាវជ្រាវប្រមូលឯកសារពាក់ព័ន្ធពីសាមីភាគី (ដើមចោទ និងចុងចម្លើយ) និងស្នើឱ្យស្ថាប័នជំនាញបំភ្លឺជាមុនសិន ចៀសវាងពេលសម្រេចចេញសាលក្រមហើយ អនុវត្តមិនកើតដូចជាខុសទំហំដី ដែលជាកម្មវត្ថុបណ្តឹងដូចករណីសាលក្រមលេខ២៥ "វ" របស់តុលាការខេត្តកណ្តាលជាដើម ខុសទីតាំងក្បាលដី និងខ្វះឯកសារខ្លះដែលស្ថាប័នជំនាញមានហើយ មិនបានផ្តល់ជូនតុលាការ (ដោយតុលាការមិនបានសួររក)។

២-រាល់សាលក្រមរដ្ឋប្បវេណីដែលសម្រេចរឿងក្តីពាក់ព័ន្ធនឹងអចលនវត្ថុ និងឯកសារពាក់ព័ន្ធផ្សេងទៀត គួរតែផ្តល់ជូនស្ថាប័នជំនាញដែលមានភារកិច្ចអនុវត្តតាមផ្លូវការនូវច្បាប់ដើម។ កន្លងមក នាយកដ្ឋានពិនិត្យឃើញថាស្ថាប័នជំនាញទទួលបានតែសម្រង់ផ្ទេរសិទ្ធិឱ្យខ្លួនតែប៉ុណ្ណោះ។ ប្រការនេះអាចនឹងកើតមានការខុសឆ្គងនៅថ្ងៃណាមួយមិនខានឡើយ ដោយហេតុជួនកាលមិនច្បាស់ ជួនកាលអាចមានការជ្រៀតបន្ថែមរូបថតចម្លង. . .។ ដូចនេះ ស្ថាប័នសុរិយោដីនឹងបញ្ឈប់លែងទទួលយកឯកសាររបៀបនេះទៀតហើយ។

៣-ក្នុងករណីដែលតុលាការដកប័ណ្ណដើមពីអ្នកចាញ់ក្តីមិនបាន ដោយមូលហេតុអ្វីក៏ដោយ តុលាការគួរទុកសិទ្ធិឱ្យស្ថាប័នជំនាញអនុវត្តតាមនីតិវិធី ក្នុងការចេញប័ណ្ណទុតិយតាជំនួសប័ណ្ណដើមវិញ។

អាស្រ័យហេតុនេះ សូមឯកឧត្តមទេសរដ្ឋមន្ត្រីមេត្តាជ្រាបតាមការគួរ។

លេខ....................

ភ្នំពេញ ថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៩៧

**ជ.នាយកដ្ឋានសុរិយោដី**

**ប្រធានស្តីទី**

**ហត្ថលេខា និងត្រា**

**លឹម វ៉ាន់**

បានឃើញ និងសូមជូនមក

ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធមិ

"ដើម្បីហាម និងសុំគោលការណ៍ណែនាំតាមការគួរ"

ភ្នំពេញ ថ្ងៃទី ខែមិថុនា ឆ្នាំ១៩៩៧

**សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

ព្រះរាជាណាចក្រកម្ពុជា

**ទីស្តីការគណៈរដ្ឋមន្ត្រី** ជាតិ សាសនា ព្រះមហាក្សត្រ

**នាយកដ្ឋានសុរិយោដី**

លេខ១៩២សជ ភ្នំពេញ ថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៧

**ប្រធាននាយកដ្ឋានសុរិយោដី**

**ជម្រាបមក**

**លោកប្រធានមន្ទីរសុរិយោដីគ្រប់ខេត្ត-ក្រុង**

កម្មវត្ថុ៖ ស្តីពីការបាត់បង់ និងខូចខាតឯកសារជំនាញ និងសម្ភារៈប្រើប្រាស់ផ្សេងៗ

យោង៖ លិខិតលេខ១៤៩/៩៧សជខ/សរ ចុះថ្ងៃទី០៨-៨-១៩៩៧ របស់ខេត្តសៀមរាប

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកប្រធានថា ករណីខូចខាត និងបាត់បង់ឯកសារជំនាញ និងសម្ភារៈប្រើប្រាស់ផ្សេងៗតាមបណ្តាអង្គភាពដែលបង្កឡើងក្នុងឱកាសដែលកងកម្លាំងរាជរដ្ឋាភិបាលបង្ក្រាបកម្លាំងអនាធិបតេយ្យ និងក្រុមឧទ្ទាមខ្មែរក្រហមកាលពីថ្ងៃទី០៥ ដល់ថ្ងៃទី១៥-៧-១៩៩៧ កន្លងទៅនោះ ស្នើលោកប្រធានចាត់ឱ្យធ្វើរបាយការណ៍លំអិត និងច្បាស់លាស់ជូននាយកដ្ឋាន។ ទន្ទឹមនឹងនេះ ក៏ត្រូវចាត់មន្ត្រីឱ្យបំពេញកិច្ចការ៖

-ថតចម្លងកំណត់ហេតុអង្កេតយកមកទុកនៅសុរិយោដីខេត្តមួយច្បាប់

(PV. ចាស់ PV. ខូចខាត)

-ចម្លងសៀវភៅអចលនវត្ថុ "ទាំងគំរូចាស់ និងគំរូថ្មី"

(ឱ្យមានរក្សាទុកនៅខេត្ត និងស្រុក)

អាស្រ័យហេតុនេះ សូមលោកប្រធានចាត់ការអនុវត្តតាមខ្លឹមសារខាងលើឱ្យបានសម្រេចលទ្ធផលល្អ។

**ជ.នាយកដ្ឋានសុរិយោដី**

**ប្រធានស្តីទី**

**ហត្ថលេខា និងត្រា**

**លឹម វ៉ាន់**

*វាយឡើងវិញ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ៨៧អនក្រ/បក

**អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់

- តាមសំណើរបស់ទេសរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌ និងវិចិត្រសិល្បៈ រៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩៧

**សម្រេច**

**មាត្រា១**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិមួយឈ្មោះថា "គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ (CNATUC)។ សមាសភាពនៃគណៈកម្មាធិការជាតិ ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

គណៈកម្មាធិការជាតិនេះរួមមានសមាសភាពដូចតទៅ៖

| | |
|---|---|
| -ទេសរដ្ឋមន្ត្រី ទទួលវប្បធម៌ វិចិត្រសិល្បៈ រៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| -សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬតំណាង | អនុប្រធាន |
| -រដ្ឋមន្ត្រីសាធារណការ និងដឹកជញ្ជូន ឬតំណាង | អនុប្រធាន |
| -សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឬតំណាង | សមាជិក |
| -សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ឬតំណាង | សមាជិក |
| -រដ្ឋមន្ត្រីក្រសួងបរិស្ថាន ឬតំណាង | សមាជិក |
| -រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬតំណាង | សមាជិក |
| -រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬតំណាង | សមាជិក |
| -រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ ឬតំណាង | សមាជិក |

ប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ត្រូវអញ្ជើញរដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ ចូលរួមបំពេញបន្ថែមក្នុងគណៈកម្មាធិការជាតិ តាមករណីនីមួយៗ។

តំណាងរដ្ឋមន្ត្រី ត្រូវមានថ្នាក់យ៉ាងតិចស្មើអនុរដ្ឋលេខាធិការ។

**មាត្រា២**

ដោយឈរលើមូលដ្ឋាននៃច្បាប់ និងបទដ្ឋានជាធរមាន និងក្របខ័ណ្ឌនៃនគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ មានភារកិច្ចដូចតទៅ៖

១-ណែនាំ និងកំណត់ទិសដៅក្នុងការរៀបចំប្លង់គោលរបស់រាជធានីភ្នំពេញ និងខេត្ត ក្រុង ដើម្បីការពារធនធានធម្មជាតិនានា ដី ទឹក ខ្យល់ ព្រៃឈើ ទេសភាព និងសម្បត្តិវប្បធម៌ ឬបេតិកភណ្ឌជាតិ

២-ចងក្រងគោលនយោបាយសម្រាប់លើកកម្ពស់សម្បជញ្ញៈរបស់ប្រជារាស្ត្រ ឱ្យរួមចំណែកក្នុងការអភិវឌ្ឍវិស័យផ្សេងៗ ដូចជាសង្គមកិច្ច សេដ្ឋកិច្ច វប្បធម៌ទាំងនៅជនបទ ទាំងនៅទីក្រុង ។

៣-ណែនាំធ្វើការសិក្សា ដើម្បីបង្កើតប្លង់តាមភាគផ្នែកៗក្នុងទីរួមខេត្ត និងក្រុងនានាដោយសម្របសម្រួលទៅតាមល័ក្ខខ័ណ្ឌនៃទីកន្លែង ។

៤-តាមដាន និងពិនិត្យមើលសំណង់គ្រប់ប្រភេទដើម្បីឱ្យសមស្របជាមួយបរិស្ថានធម្មជាតិ ។

៥-គ្រោងតំបន់រក្សាទុក ដើម្បីបម្រើឱ្យសេចក្តីត្រូវការនាពេលអនាគត សម្រាប់អភិវឌ្ឍគ្រប់សកម្មភាព ដោយអនុលោមទៅតាមប្លង់គោល ។

៦-កំណត់ឱ្យការពារ និងថែរក្សាទុកឱ្យទំនេរតំបន់ជុំវិញមាត់ឆ្នេរសមុទ្រ មាត់ទន្លេ មាត់ជ្រោះ មាត់អូរ និងមាត់ព្រែក ព្រមទាំងបឹង ត្រពាំង ផ្លូវទឹក ទំនប់ អនុលោមទៅតាមការកំណត់របស់ប្លង់គោល ដើម្បីទុកឱ្យប្រជាពលរដ្ឋប្រើប្រាស់ទឹកដោយសេរី និងសម្រាប់ការធ្វើដំណើរ ។

៧-កំណត់ឱ្យការពាររមណីយដ្ឋានធម្មជាតិ តំបន់ព្រៃឈើ និងរមណីយដ្ឋាននានាដែលត្រូវបានកំណត់ដោយច្បាប់បេតិកភណ្ឌវប្បធម៌ ។

៨-កំណត់ព្រំតំបន់លំនៅឋានសម្រាប់សកម្មភាពសេដ្ឋកិច្ច វប្បធម៌ រដ្ឋបាល ទៅតាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ដោយរៀបចំបណ្តាញចែកចាយទឹក និងអគ្គិសនី ផ្លូវគមនាគមន៍ ការដឹកជញ្ជូន ព្រមជាមួយការការពារបរិស្ថាន ដោយបំបាត់ក្លិនអាក្រក់ ភាពកខ្វក់ និងការរំខានបណ្តាលមកពីស្នូរសំឡេងជាដើម ។

៩-កំណត់តំបន់ហាមឃាត់ការបោះទីតាំង និងសំណង់នៅទីកន្លែងសាធារណៈ និងទីកន្លែងជាផលប្រយោជន៍ទូទៅដូចជាសាលារៀន ទីលានកីឡា សួនច្បារ ផ្លូវថ្នល់សាធារណៈ ដីចំណីសងខាងផ្លូវសាធារណៈ បរិវេណវត្តអារាម គ្រឹះស្ថានសុខាភិបាល ដីចំណីសងខាងផ្លូវដែក បណ្តាញលូទឹក ។ល។

១០-សហការជាមួយបណ្តាក្រសួង មន្ទីរ និងអង្គភាពពាក់ព័ន្ធដើម្បីតាក់តែងគម្រោងច្បាប់ និងអត្ថបទច្បាប់ទាក់ទងនឹងក្រុងភ្នំពេញ ជនបទ និងក្រុងនានា ហើយដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងដាក់ស្នើសុំការអនុម័តពីសភាជាតិ ។

១១-ចាត់ចែងការអប់រំប្រជាពលរដ្ឋ ឱ្យម្នាក់ៗភ្ញាក់រឭកចំពោះករណីយកិច្ចរបស់ខ្លួន និងចូលរួមចំណែកក្នុងការការពារបរិស្ថាន និងការលំអទេសភាពនៅរាជធានី ក៏ដូចជានៅតាមទីប្រជុំជនក្រុង និងទីប្រជុំជនជនបទ ។

១២-សម្របសម្រួលការងារបច្ចេកទេស និងកិច្ចការផ្សេងៗទៀតដល់គណៈកម្មាធិការ និងបណ្តាអនុគណៈកម្មាធិការខេត្ត-ក្រុង តាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន តាមលទ្ធភាព និងតម្រូវការជាក់ស្តែង ។

**មាត្រា៣**

គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់មានអគ្គលេខាធិការដ្ឋានប្រតិបត្តិមួយ ជាជំនួយការ និងគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់រាជធានីភ្នំពេញ និងអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ខេត្ត-ក្រុងជាសេនាធិការ ។

គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ រាជធានីភ្នំពេញមានការិយាល័យកិច្ចការនគរូបនីយកម្មក្រុង ជាសេនាធិការ ។

អនុគណៈកម្មាធិការរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់នៅតាមបណ្តាខេត្ត-ក្រុងមានការិយាល័យកិច្ចការនគរូបនីយកម្មខេត្ត-ក្រុងជាសេនាធិការ ។

ការិយាល័យកិច្ចការនគរូបនីយកម្មឋិតនៅក្រោមការគ្រប់គ្រងផ្នែករដ្ឋបាលរបស់សាលាខេត្ត-ក្រុង និងរាជធានីភ្នំពេញ និងផ្នែកបច្ចេកទេសពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ។

គណៈកម្មាធិការ និងអនុគណៈកម្មាធិការខេត្ត-ក្រុងនេះត្រូវបានទទួលការណែនាំបច្ចេកទេសពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ និងទទួលការគ្រប់គ្រងដឹកនាំផ្ទាល់ផ្នែករដ្ឋបាលពីសាលាខេត្ត-ក្រុង ។

**មាត្រា៤**

គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់លើកសំណើតែងតាំងអ្នកជំនួយការមួយរូបជាអគ្គលេខាធិការ ។

អគ្គលេខាធិការ ត្រូវបានប្រគល់សិទ្ធិពីប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ដើម្បីប្រតិបត្តិរាល់បេសកកម្ម ដែលប្រធានប្រគល់ឱ្យទទួលបន្ទុកតាមស្មារតីនៃអនុក្រឹត្យនេះ ហើយអាចតំណាងប្រធានក្នុងក្របខ័ណ្ឌនេះ។

អគ្គលេខាធិការរៀបចំ និងចាត់ចែងសម័យប្រជុំរបស់គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ដោយទំនាក់ទំនងជាមួយបណ្ដាសមាជិកនៃគណៈកម្មាធិការជាតិ និងដោយមានការព្រមព្រៀងជាមួយប្រធានជាមុន។

**មាត្រា៥**

អគ្គលេខាធិការ មានភារកិច្ចដឹកនាំលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ និងរៀបចំជាមុខជំនាញផ្សេងៗដូចជា៖

-គ្រប់គ្រងកិច្ចការបច្ចេកទេស និងឯកសារនគរូបនីយកម្ម

-គ្រប់គ្រង និងលើកកម្មវិធីសកម្មភាព ផែនការនីតិកម្ម និងនីតិវិធី

-អធិការកិច្ច

សមាជិកលេខាធិការដ្ឋានអចិន្ត្រៃយ៍ ត្រូវបានទទួលភារកិច្ចពីអគ្គលេខាធិការ ក្រោយពីមានការយល់ព្រមពីប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៦**

គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់មានទីស្នាក់ការនៅទីស្ដីការគណៈរដ្ឋមន្ត្រី ហើយមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្ដីការគណៈរដ្ឋមន្ត្រី។

រាល់មន្ត្រីរាជការបម្រើនៅគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ត្រូវតែងតាំងដោយដាក់ឱ្យនៅក្រៅតំណែងពីក្រសួងមន្ទីរពាក់ព័ន្ធ។

ក្នុងករណីចាំបាច់ទៅតាមតម្រូវការ ការជ្រើសរើសចូលត្រូវអនុវត្តតាមសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល តាមរយៈស្ថាប័នអចិន្ត្រៃយ៍របស់រាជរដ្ឋាភិបាល។

រាល់ចំណាយសម្រាប់ដំណើរការនៃគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ រួមមានបៀវត្សរបស់បុគ្គលិក ទីស្នាក់ការ សម្ភារៈ និងមធ្យោបាយដឹកជញ្ជូន ត្រូវបានចែកក្នុងថវិការដ្ឋប្រចាំឆ្នាំរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី តាមសំណើថវិការបស់គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់។

គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់មានសិទ្ធិធ្វើសហប្រតិបត្តិការជាមួយស្ថាប័នជាតិ អន្តរជាតិ អង្គការសាធារណៈ អង្គការមូលនិធិតំបន់ ដើម្បីសុំជំនួយជាថវិកាក្នុងការធ្វើឱ្យសុក្រឹតនូវរាល់គម្រោង និងទិសដៅ ដូចបានរៀបរាប់ខាងលើ។

**មាត្រា៧**

គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់នៃក្រុងភ្នំពេញ មានប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ជាប្រធាន។

| | |
|---|---|
| -ប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| -ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ | អនុប្រធាន |
| -អភិបាលរងរាជធានីភ្នំពេញ | សមាជិក |
| -ប្រធានមន្ទីរសុរិយោដីក្រុងភ្នំពេញ | សមាជិក |
| -ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនក្រុងភ្នំពេញ | សមាជិក |
| -ប្រធានមន្ទីររៀបចំក្រុង និងសំណង់ក្រុងភ្នំពេញ | សមាជិក |
| -ប្រធានមន្ទីរនគរបាលក្រុងភ្នំពេញ | សមាជិក |
| -ប្រធានមន្ទីរបរិស្ថានក្រុងភ្នំពេញ | សមាជិក |
| -នាយកការិយាល័យកិច្ចការនគរូបនីយកម្ម | សមាជិក |

នាយកមន្ទីរដទៃទៀតនឹងត្រូវចូលរួមក្នុងសម័យប្រជុំ តាមសេចក្តីត្រូវការរបស់គណៈកម្មាធិការ។

**មាត្រា៨**

អនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ខេត្ត-ក្រុងដទៃទៀត មានអភិបាលខេត្ត-ក្រុងជាប្រធាន។

អនុគណៈកម្មាធិការនេះរួមមាន បណ្តាអង្គភាពបច្ចេកទេស ដែលត្រូវចាត់តាំងដោយអភិបាលខេត្ត-ក្រុង បន្ទាប់ពីបានទទួលការយល់ព្រមពីប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់។

**មាត្រា៩**

ក្នុងករណីមានសំណើពីអភិបាលខេត្ត-ក្រុង គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់រាជធានីភ្នំពេញ និងបណ្ដាអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ខេត្ត-ក្រុង អាចចូលរួមចំណែកអនុវត្តភារកិច្ចដែលបានកំណត់ក្នុងមាត្រា១៨ នៃច្បាប់រៀបចំទឹកដី នគរូបនីយកម្ម និងសំណង់។

**មាត្រា១០**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់រាជធានីភ្នំពេញ នឹងត្រូវកំណត់ដោយអនុក្រឹត្យ ហើយបណ្ដាអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ខេត្ត-ក្រុង នឹងត្រូវកំណត់ដោយប្រកាសរបស់គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់។

**មាត្រា១១**

បទប្បញ្ញត្តិទាំងឡាយដែលកំពុងប្រើប្រាស់បច្ចុប្បន្ន ហើយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា១២**

ទេសរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌ និងវិចិត្រសិល្បៈ រៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ អភិបាលខេត្ត-ក្រុង សមាជិកគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ និងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមតួនាទីចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩៧

**នាយករដ្ឋមន្ត្រីទី១ នាយរដ្ឋមន្ត្រីទី២**

**ហត្ថលេខា ហត្ថលេខា**

**និងត្រា**

**អ៊ឹង ហួត ហ៊ុន សែន**

<u>កន្លែងទទួល</u>

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-គ្រប់ក្រសួង ស្ថាប័នកណ្ដាល

-គ្រប់សាលាខេត្ត-ក្រុង

-ដូចមាត្រា១២

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ៨៦អនក្រ

## អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- តាមសំណើរបស់ទេសរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌ និងវិចិត្រសិល្បៈ រៀបចំដែនដី នគរូបនីយកម្ម និងសំណង់

*វាយឡើងវិញ*

- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ១៩៩៧

**សម្រេច**

**មាត្រា១**

រាល់រូបវន្តបុគ្គល ឬនីតិបុគ្គលសាធារណៈ ឬឯកជន មានសិទ្ធិសាងសង់អគារលើដីដែលជាកម្មសិទ្ធិរបស់ខ្លួន ហើយសិទ្ធិសាងសង់នេះត្រូវបានទទួលការការពារដោយអនុក្រឹត្យនេះ ។ លិខិតអនុញ្ញាតសាងសង់ ដែលត្រូវបានចេញឱ្យមុនការសាងសង់ ជាគ្រឹះនៃភាពស្របច្បាប់របស់សំណង់ ។ ឯរបៀបសុំលិខិតអនុញ្ញាតសាងសង់មានអធិប្បាយនៅក្នុងវគ្គទី១នៃអនុក្រឹត្យនេះ ។ ដើម្បីឱ្យប្រជាពលរដ្ឋ ជាពិសេសប្រជាជនក្រីក្រមានលំនៅឋានសម្រាប់រស់នៅ រាល់សំណង់តូចតាចធ្វើអំពីឈើ ឬស្លឹក រុក្ខជាតិនានាពុំទាមទារឱ្យសុំលិខិតអនុញ្ញាតសាងសង់ឡើយ ស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងមាត្រា៣នៃអនុក្រឹត្យនេះ ។

ដើម្បីធានាសុខុមាលភាពនៃសំណង់ និងសុវត្ថិភាពសាធារណៈ ព្រមទាំងដើម្បីការពារដីធ្លីសាធារណៈចាំបាច់ សម្រាប់ធានាដល់ដំណើរការរៀបចំទីក្រុង និងតំបន់កសិកម្មបានល្អប្រសើរ បទប្បញ្ញត្តិទូទៅនៃសំណង់ មានកំណត់អំពីសិទ្ធិ និងអំពីករណីយកិច្ចដល់ដំណើរការរៀបចំទីក្រុង និងតំបន់កសិកម្មបានល្អប្រសើរ បទប្បញ្ញត្តិទូទៅនៃសំណង់មានកំណត់អំពីសិទ្ធិ និងអំពីករណីយកិច្ចនៃប្រជាពលរដ្ឋ និងស្ថាប័នសាធារណៈ ក្នុងអគារសាងសង់សំណង់សាធារណៈ និងសំណង់ឯកជន ។

រាល់ការគោរពនូវបទប្បញ្ញត្តិដែលមានចែងក្នុងវគ្គទី២នៃអនុក្រឹត្យ នឹងត្រូវបានទទួលលិខិតអនុញ្ញាតសាងសង់ ។

បទប្បញ្ញត្តិទាំងនេះ ត្រូវយកមកអនុវត្តក្នុងពេលពុំទាន់មានប្លង់ប្រើប្រាស់ដីធ្លី និងប្លង់គោល អនុម័តដោយរាជរដ្ឋាភិបាល ។

បទប្បញ្ញត្តិនេះអាចនឹងបំពេញបន្ថែម ដើម្បីឱ្យស្របទៅស្ថានភាពមូលដ្ឋាន ដោយឋិតក្នុងបទប្បញ្ញត្តិសំណង់ជាក់ស្តែងក្នុងប្លង់ប្រើប្រាស់ដីធ្លីរបស់ខេត្ត-ក្រុង ។

អនុក្រឹត្យនេះមិនយកទៅអនុវត្ត លើសំណង់មានស្រាប់ដែលមានការអនុញ្ញាត ។

ចំពោះសំណង់មានស្រាប់ដែលគ្មានការអនុញ្ញាត ហើយដែលប៉ះពាល់យ៉ាងខ្លាំងក្លាដល់ប្រយោជន៍ ឬសោភ័ណភាពសាធារណៈ ការរុះរើត្រូវសម្រេចដោយរាជរដ្ឋាភិបាល ឬតំណាងដែលបានទទួលសិទ្ធិប្រទាន តាមសំណើរបស់អាជ្ញាធរមានសមត្ថកិច្ច ។

## វគ្គទី១ លិខិតអនុញ្ញាតសាងសង់ និងលិខិតអនុញ្ញាតរុះរើ

## ជំពូក១ កាតព្វកិច្ចនៃលិខិតអនុញ្ញាតសាងសង់

**មាត្រា២**

សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ជាមុន។ រាល់ការសាងសង់ក្នុងទីក្រុង និងទីប្រជុំជនត្រូវមានលិខិតអនុញ្ញាតសាងសង់ រាល់សំណង់ថ្មី សុទ្ធតែត្រូវមានលិខិតអនុញ្ញាតសាងសង់។

ការសាងសង់ឡើងវិញជាថ្មី ការពង្រីក និងការសង់បន្ថែមពីលើអគារដែលមានស្រាប់ ក៏សុទ្ធតែតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ដែរ។

ការប្តូរទ្រង់ទ្រាយអគារដែលមានស្រាប់ ត្រូវមានលិខិតអនុញ្ញាតសាងសង់ បើការងារនេះកែប្រែ៖

-ការប្រើប្រាស់របស់ផ្នែកអគារ

-ទិដ្ឋភាពនៃអគារ (Aspect des Bâtiments)

-ការធ្វើបង្គន់អនាម័យ និងការបន្តភ្ជាប់ទៅបំពង់លូ

-ការធ្វើអាងប្រព្រឹត្តកម្មទឹកកខ្វក់ តភ្ជាប់ទៅបំពង់លូ

-បង្កើនផ្ទៃក្រឡាកម្រាលសំណង់

-កន្លែងទទួលសាធារណជន (Locaux ouverts au public)

-ទម្រង់ដី (ចាក់ដីបំពេញ ជីកយកដីចេញ ប្តូរប្រភេទដីស្រែចម្ការជាដីសាងសង់) ឬប៉ះពាល់ខ្លាំងដល់ទិដ្ឋភាពទីដ្ឋានណាមួយ ដូចជាលុបបំបាត់បឹង ឬប្រឡាយបង្ហូរទឹក ឬផ្នែកណាមួយនៃប្រព័ន្ធបង្ហូរទឹកចេញ ការកាប់ដើមឈើដែលមានស្រាប់។ល។

ការសាងសង់ ឬការកែទ្រង់ទ្រាយបំបនភណ្ឌផ្សេងៗ ដែលអាចបង្កគ្រោះថ្នាក់ដោយអគ្គិភ័យ (ការដាក់ស៊ីទែន កន្លែងស្តុកប្រេងឥន្ធនៈ រោងជាងដែលមានផលិតផលគ្រឿងឆេះ កន្លែងទទួលសាធារណជន) ។ល។ ការប្តូរទ្រង់ទ្រាយអគារឧស្សាហកម្ម ឬដាក់ប៉ាណូផ្សាយពាណិជ្ជកម្ម ការដាក់អង់តែនទូរទស្សន៍ និងទូរគមនាគមន៍ ប៉ាណូស្រូបពន្លឺព្រះអាទិត្យ ក៏ដូចជារាល់គ្រឿងដទៃទៀតដែលបំពាក់ទៅនឹងអគារ ហើយឋិតនៅជិតមាត់ផ្លូវ ឬតាំងចំទិសដែលគេអាចមើលឃើញ សាលាក្រុង និងសាលាខេត្តនឹងធ្វើការណែនាំដោយឡែក។

មាត្រា៣

សំណង់ដែលពុំចំណុះក្រោមលិខិតអនុញ្ញាតសាងសង់

-សំណង់ជាលំនៅឋានប្រជាពលរដ្ឋដែលឋិតនៅទីជនបទ ឬតំបន់ឆ្ងាយពីផ្លូវជាតិ ផ្លូវដែក និងឆ្ងាយពីតំបន់រមណីយដ្ឋានទេសចរណ៍ តំបន់បេតិកភណ្ឌជាតិ តំបន់រក្សាទុកការពារដោយពុំគិតពីទំហំ ឬសម្ភារៈសំណង់ប្រើប្រាស់ឡើយ ។

-ការជួសជុល និងថែរក្សាទាំងឡាយដែលមិនផ្លាស់ប្តូរទ្រង់ទ្រាយ ឬទិដ្ឋភាពសំណង់ លើកលែងតែការជួសជុលនោះ អាចបណ្តាលឱ្យប៉ះពាល់ដល់អ្នកជិតខាង ។

-បណ្តាសំណង់ដូចខាងក្រោមនេះ ដោយគ្រាន់តែជូនដំណឹងអំពីគម្រោងសាងសង់ទៅអាជ្ញាធរមូលដ្ឋាន ដូចតទៅ៖

-ទីសក្ការៈបូជា

-សាលាសំណាក់សាធារណៈ

-បណ្តាការស្ថាបត្យកម្ម ... 

## ជំពូក២ សមត្ថកិច្ច ដែលចេញលិខិតអនុញ្ញាតសាងសង់

### មាត្រា៤ សមត្ថកិច្ចរបស់សាលាខេត្ត និងសាលាក្រុង

៤.១-ខេត្ត-ក្រុងមានសមត្ថកិច្ចក្នុងការចេញលិខិតអនុញ្ញាតសាងសង់ ក្រោមការទទួលខុសត្រូវរបស់ខ្លួន ។

៤.២-លិខិតអនុញ្ញាតសាងសង់ ត្រូវបានចុះហត្ថលេខាដោយប្រតិភូរាជរដ្ឋាភិបាលប្រចាំទីក្រុង ឬដោយអភិបាលខេត្ត-ក្រុង ឬអភិបាលរងដែលបានទទួលសិទ្ធិប្រទាន ។ រាល់ការបដិសេធមិនផ្តល់លិខិតអនុញ្ញាតសាងសង់ ត្រូវមានការបញ្ជាក់ជាលាយលក្ខណ៍អក្សរនូវមូលហេតុច្បាស់លាស់ ។

### មាត្រា៥ សមត្ថកិច្ចរបស់រាជរដ្ឋាភិបាល

៥.១-មានលិខិតអនុញ្ញាតសាងសង់មួយចំនួនជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។ រាជរដ្ឋាភិបាលមានសមត្ថកិច្ចសម្រេចផ្តល់លិខិតអនុញ្ញាតសាងសង់ ចំពោះប្រភេទសំណង់ដូចតទៅ៖

-បណ្តាអគារមានឧបនិស្ស័យខាងពាណិជ្ជកម្ម និងឧស្សាហកម្មដែលមានផ្ទៃក្រឡាកម្រាស់លើសពី៣.០០០ម៉ែត្រទ្វេគុណ ។

-រាល់សណ្ឋាគារត្រូវចាត់ទុកជាអគារមានឧបនិស្ស័យខាងពាណិជ្ជកម្ម ។

-បណ្តាអគារសម្រាប់ការបង្កបង្កើនផលកសិកម្ម សម្រាប់ធ្វើអាជីវកម្មពី៥០០ហិកតាឡើងទៅ ។

-បណ្តាអាកាសយានដ្ឋាន កំពង់ផែ ស្ថានីយអយស្ម័យយាន និងស្ថានីយរថយន្ត ។

-បណ្តាសំណង់សាធារណៈ និងឯកជនដែលមានផ្ទៃក្រឡាកម្រាលលើសពី៣.០០០ម៉ែត្រទ្វេគុណ និងផ្ទៃកពង្រីកបន្ថែមដោយគិតទាំងអគារមានស្រាប់ដែលលើសពី៣.០០០ម៉ែត្រទ្វេគុណ (វប្បធម៌ អប់រំ កីឡា រដ្ឋបាល ទេសចរណ៍ សុខាភិបាល ថាមពល ទឹក...) ។

-បណ្តាសំណង់សំខាន់ៗក្នុងទីដ្ឋានការពារ និងក្នុងក្របខ័ណ្ឌបរិស្ថាន ទេសភាព បេតិកភណ្ឌប្រវត្តិសាស្ត្រ បូរាណវត្ថុ និងវប្បធម៌ ។

-ការកែប្រែបណ្តាអគារ ជាផលប្រយោជន៍បេតិកភណ្ឌដែលបានកំណត់ទុក ។

-បណ្តាសំណង់លើទីដីក្នុងភាពមើលឃើញទៅវិញទៅមក ជាមួយប្រាង្គប្រាសាទប្រវត្តិសាស្ត្រ ។

-បណ្តាសំណង់ និងការរៀបសម្រាប់ការពារ និងអគារយោធា ។

៥.២-ក្នុងករណីនេះ លិខិតអនុញ្ញាតសាងសង់ត្រូវចុះហត្ថលេខាដោយប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់បន្ទាប់ពីបានទទួលយោបល់ឯកភាពពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ។

**មាត្រា៦ គណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់របស់សាលាខេត្ត ឬសាលាក្រុង**

៦.១-សមត្ថកិច្ចអនុលោមតាមមាត្រា១៨នៃច្បាប់រៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ គណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់មួយ ត្រូវបានបង្កើតឡើងក្នុងពេលពុំទាន់មានប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ ។ គណៈកម្មការនេះត្រូវដឹកនាំដោយប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង ឬអភិបាលខេត្ត ។

គណៈកម្មការនេះពិនិត្យរាល់សំណុំលិខិតសុំអនុញ្ញាតសាងសង់ ។

ចំពោះលិខិតអនុញ្ញាតសាងសង់ ដែលជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ក្រោយពីគណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ ពិនិត្យសំណុំលិខិតហើយ ប្រតិភូរាជរដ្ឋាភិបាលប្រចាំទីក្រុង និងអភិបាលខេត្ត-ក្រុងបញ្ជូនរបាយការណ៍ និងយោបល់ទៅគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ដើម្បីសម្រេច ។

៦.២-សមាសភាពរបស់គណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់៖

គណៈកម្មការមានសមាសភាពដូចតទៅ៖

| | |
|---|---|
| -ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង ឬអភិបាលខេត្ត | ជាប្រធាន |
| -មន្ទីរសុរិយោដី | សមាជិក |
| -មន្ទីររៀបចំក្រុង និងសំណង់ ឬការិយាល័យសំណង់ ក្នុងករណីដែលមាន | សមាជិក |
| -មន្ទីរសាធារណៈការ | សមាជិក |
| -មន្ទីរបរិស្ថាន | សមាជិក |
| -មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| -តំណាងស្ថាប័នពាក់ព័ន្ធទៅលើគម្រោងសំណង់នោះ | សមាជិក |
| -ការិយាល័យ ( មូលដ្ឋាន) កិច្ចការនគរូបនីយកម្ម | សមាជិក |

គណៈកម្មការមានសិទ្ធិកោះអញ្ជើញដើម្បីសាកសួរ ឬស្តាប់រាល់បុគ្គលដែលបានដាក់ពាក្យសុំលិខិតអនុញ្ញាតសាងសង់ និងម្ចាស់កម្មសិទ្ធិ បើម្ចាស់កម្មសិទ្ធិនោះពុំមែនជាអ្នកដាក់ពាក្យសុំ នៅពេលដែលសំណុំលិខិតអនុញ្ញាតសាងសង់នោះ បានចុះបញ្ជីជាផ្លូវការរួចហើយ ។

## ជំពូក៣ ការពិនិត្យមើលលើការចេញលិខិតអនុញ្ញាតសាងសង់

### មាត្រា៧

គ្មានលិខិតអនុញ្ញាតសាងសង់ណាមួយអាចចេញឱ្យបានទេ បើលិខិតអនុញ្ញាតសាងសង់នោះពុំគោរពតាមប្លង់គោល និងប្លង់ប្រើប្រាស់ដីធ្លី ( ក្នុងករណីដែលមានប្លង់ទាំងពីរនេះ) ឬប្រសិនបើពុំមានប្លង់ទាំងពីរនេះទេ នោះការអនុញ្ញាតត្រូវអនុវត្តតាមបទបញ្ជាទូទៅស្តីពីការប្រើប្រាស់ដីធ្លីវិញ ។

ជនទាំងឡាយដូចជានីតិបុគ្គលសាធារណៈ ឬឯកជនត្រូវគោរពវិធានការនេះជាចាំបាច់ ។

### មាត្រា៨

សំណុំលិខិតសុំលិខិតអនុញ្ញាតសាងសង់ ចំពោះក្រុងភ្នំពេញ និងទីក្រុងដទៃទៀតត្រូវដាក់នៅការិយាល័យសុំលិខិតអនុញ្ញាតសាងសង់ ( មន្ទីររៀបចំក្រុង និងសំណង់) ហើយចំពោះខេត្តត្រូវដាក់នៅសាលាស្រុក ឬសាលាខេត្ត ( មន្ទីរសំណង់) ។ បង្កាន់ដៃទទួលពាក្យសុំលិខិតអនុញ្ញាតសាងសង់មួយត្រូវបានចេញឱ្យអ្នកសុំ កាលណាសំណុំលិខិតពាក្យសុំមានគ្រប់គ្រាន់ហើយ ។

**មាត្រា៩ បណ្តាឯកសារនៃពាក្យសុំលិខិតអនុញ្ញាតសាងសង់**

ពាក្យសុំលិខិតអនុញ្ញាតសាងសង់ ត្រូវធ្វើលើគំរូលិខិតជាផ្លូវការ ហើយត្រូវមានភ្ជាប់សំណុំលិខិតដែលមានយ៉ាងតិចបំផុតនូវបណ្តាប្លង់ដូចបញ្ជាក់ខាងក្រោមនេះជា១០ច្បាប់ បត់ទំហំ (២១ × ២៩,៧ស.ម) ។

៩.១-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់អចលនវត្ថុ ឬលិខិតកាន់កាប់ដីបណ្តោះអាសន្ន។

៩.២-សលាកប័ត្រដីឡូត៍៖

ប្លង់ដីនេះធ្វើឡើងដោយភ្នាក់ងារមន្ទីរសុរិយោដី ឬដោយវេខាគណិតឯកជន។ ប្លង់នេះត្រូវចុះកាលបរិច្ឆេទ ចុះហត្ថលេខា ដោយអ្នកធ្វើ និងអនុម័តដោយមន្ទីរសុរិយោដី។

នៅលើប្លង់នេះមានបញ្ជាក់អំពី៖

-ទីតាំងនៃដីឡូត៍ដែលជាកម្មវត្ថុនៃពាក្យសុំទីតាំងនៃដីឡូត៍ដែលនៅជាប់គ្នា ផ្លូវចូលទៅដីឡូត៍នោះ ហើយនិងលក្ខណ:របស់ផ្លូវនោះ (សាធារណ: ឬឯកជន ឈ្មោះម្ចាស់កម្មសិទ្ធិ) ។

-ឈ្មោះ ឬលេខ ផ្លូវធំ និងផ្លូវតូច

-ផ្ទៃក្រឡាដីឡូត៍

-បណ្តាសំណង់ដែលមានស្រាប់នៅលើដីឡូត៍ (ទីតាំង និងកម្ពស់)

-បណ្តាសំណង់ដែលមានស្រាប់នៅលើដីឡូត៍ជាប់គ្នា ផ្ទៃបាត និងកម្ពស់របស់វា

-មាត្រដ្ឋានប្លង់រង្វាស់ជ្រុង និងមុំនីមួយៗ ការកំណត់ទិស

-ចំណុចនឹងថ្កល់សម្រាប់ជាគោលសម្គាល់កម្ពស់ ដែលបោះនៅលើដីឡូត៍

-បន្ទាត់ជួរតម្រង់ផ្លូវសាធារណ:

៩.៣-ប្លង់ទីតាំងអគារក្នុងដីឡូត៍៖

មាត្រដ្ឋាន១:២០០ (ឬ១:៥០០ ក្រោយទទួលការយល់ព្រមពីបណ្តាមន្ទីរទទួលបន្ទុកដីឡូត៍ធំៗ) ។

នៅលើប្លង់នេះមានបញ្ជាក់អំពី៖

-ការបោះទីតាំងនៃសំណង់ក្នុងដីឡូត៍ដែលជាកម្មវត្ថុនៃពាក្យសុំ ដោយមានការបញ្ជាក់អំពីចម្ងាយរវាងអគារមួយ ឬច្រើន និងព្រំប្រទល់ដីឡូត៍ ហើយនិងចម្ងាយទៅបណ្តាអគារនៅជិតខាងដែលមានស្រាប់។

-រាល់ការរៀបចំផ្នែកផ្សេងៗនៃដីទំនេរ ដោយបញ្ជាក់ប្រភេទដី និងដំណាំមានស្រាប់ និងទៅអនាគត បណ្តាកន្លែងចតរថយន្ត និងរបង (កម្ពស់ និងទីតាំង)។

-បំពង់លូក្រៅអគារ (រូបធាតុ វិជ្ជមាត្រ ចំណោត កម្រិតកម្ពស់រណ្តៅពិនិត្យ) រហូតដល់កន្លែងតភ្ជាប់ទៅបណ្តាញសាធារណៈ សម្រាប់បញ្ចេញទឹកស្អុយ និងសម្រាប់ទឹកស្អាត អាងបង្គន់អនាម័យ អណ្តូង។

-ចំណុចនឹងថ្កល់នៃកម្ពស់ដីឡូត៍ ក្រោយការងាររៀបចំហើយ។

៩.៤-ប្លង់អគារគ្រប់ជាន់៖ មាត្រដ្ឋាន១:១០០

នៅលើប្លង់នេះមានបញ្ជាក់ពី៖

-គោលដៅប្រើប្រាស់រាល់បន្ទប់ និងផ្ទៃក្រឡារបស់វា

-បណ្តាបបនភណ្ឌអនាម័យ និងកន្លែងដាក់បំពង់លូ

-ចំពោះការរៀបចំទីតាំងឧស្សាហកម្ម របៀបរៀបចំទីតាំងគ្រឿងយន្ត

៩.៥ ប្លង់ផ្នែកបណ្តោយក្រោមដីនានា និងអាងបង្គន់អនាម័យ មាត្រដ្ឋាន១:១០០

៩.៦ ប្លង់មុខភាពនៃអគារ៖ (Façades) មាត្រដ្ឋាន១:១០០

នៅលើបណ្តាប្លង់មុខភាពមានបង្ហាញអំពី៖

-កម្រិតកម្ពស់កម្រាលនីមួយៗ កម្រិតកម្ពស់ដីនៅជើងអគារ ដោយបញ្ជាក់កម្រិតកម្ពស់ដីធម្មជាតិ ដីចាក់បំពេញ ឬដីចូកចេញ។

-កម្រិតកម្ពស់ដំបូល និងព្រំដំបូល ឬកម្រិតកម្ពស់នៅពេលសង់ ហើយនៃដំបូលតែរ៉ាស់ និងក្បាំងក្បាលជញ្ជាំង។

-កម្រិតកម្ពស់សង់ហើយនៃទ្រើងផ្គារ

-រូបធាតុសម្រាប់មុខភាព (Matériaux de façade)

៩.៧-ប្លង់ពុះពីរយ៉ាងតិច៖ មាត្រដ្ឋាន១:១០០

នៅលើប្លង់ពុះមានការបង្ហាញដូចប្លង់មុខភាព ពុះមួយបង្ហាញអាងបង្គន់អនាម័យ ។

៩.៨-តារាងផ្ទៃក្រឡាមួយសម្រាប់ជាន់នីមួយៗ

៩.៩-សលាកប័ត្រគណនាផ្ទៃបាតផ្ទាល់ដី និងសន្ទស្សន៍នៃការប្រើប្រាស់ ។

ចំពោះបណ្តាការផ្លាស់ប្តូរទ្រង់ទ្រាយ ពង្រីកទំហំ ពង្រីកតឡើងលើប្លង់ត្រូវបង្ហាញរបៀបខុសពីគ្នាចំពោះ ផ្នែកមានពីមុនការរុះរើ និងសភាពគ្រោងធ្វើ ។

សាលាក្រុង និងសាលាខេត្តនីមួយៗ ត្រូវចេញសារាចរបញ្ជាក់អំពីខ្លឹមសារចាំបាច់ និងឯកសារបន្ថែមពាក់ព័ន្ធនឹងសំណុំលិខិតអនុញ្ញាតសាងសង់ ។

អាចឱ្យអ្នកសុំសាងសង់ផ្តល់បណ្តាលិខិតស្នាមបន្ថែម ដោយមូលហេតុផ្នែកធារាសាស្ត្រ ផ្នែកការពារប្រឆាំងធាតុរំខានគ្រប់ប្រភេទ ផ្នែកសណ្តាប់ធ្នាប់សាធារណៈ ការពារបេតិកភណ្ឌ និងទេសភាព ។

៩.១០-ក្រោយពីបានទទួលលិខិតអនុញ្ញាតសាងសង់ហើយ ត្រូវមានប្លង់លំអិតគ្រឿងផ្គុំសំណង់ ដែលត្រូវពិនិត្យដោយក្រសួងសាធារណការ និងដឹកជញ្ជូនមុនបើកការដ្ឋានសាងសង់ ។

**មាត្រា១០ ភាសាផ្លូវការ**

សំណុំលិខិតពាក្យសុំលិខិតអនុញ្ញាតសាងសង់ទាំងអស់ត្រូវជាភាសាខ្មែរ ។ អត្ថបទជាភាសាអង់គ្លេស ឬបារាំងអាចផ្តល់ភ្ជាប់ជាមួយនឹងលិខិតនេះ ។

**មាត្រា១១ ហត្ថលេខាលើពាក្យសុំ**

ពាក្យសុំលិខិតអនុញ្ញាតសាងសង់ និងបណ្តាប្លង់ត្រូវចុះហត្ថលេខាដោយម្ចាស់ដី និងអ្នកធ្វើគម្រោង ។

កាលណាអ្នកសុំពុំមែនជាម្ចាស់កម្មសិទ្ធិ អ្នកសុំដែលបានទទួលសិទ្ធិពីម្ចាស់កម្មសិទ្ធិ ក៏ត្រូវចុះហត្ថលេខាលើសំណុំលិខិតពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ដែរ ។

អ្នកធ្វើគម្រោងត្រូវតែជាស្ថាបត្យករខ្មែរ ឬបុគ្គលមានការរួមចំណែកជាមួយស្ថាបត្យករខ្មែរ ហើយដែលត្រូវបានទទួលស្គាល់ពីរាជរដ្ឋាភិបាល ស្នើឡើងដោយអាជ្ញាធរមានសមត្ថកិច្ច ឬដោយគណៈស្ថាបត្យករ បន្ទាប់ពីគណៈស្ថាបត្យករខ្មែរនេះត្រូវបានបង្កើតឡើង ។

ក្នុងករណីដែលសំណង់មានទំហំលើសពី៥០០ម៉ែត្រទ្វេគុណ គម្រោងអាចធ្វើបានដោយស្ថាបត្យករតែប៉ុណ្ណោះ។

**មាត្រា១២ ការផ្សព្វផ្សាយលិខិតអនុញ្ញាតសាងសង់ និងអង្កេតសាធារណៈ**

អាជ្ញាធរមានសមត្ថកិច្ចផ្សព្វផ្សាយដំណឹងដល់សាធារណជន អំពីការដាក់ពាក្យសុំដោយបិទប្រកាស ផ្សាយនៅសាលាខណ្ឌ-ស្រុក ខេត្ត និងនៅកន្លែងសាងសង់គម្រោង។

កាលបរិច្ឆេទជាផ្លូវការនៃការដាក់ពាក្យស្នើសុំ ត្រូវចារក្នុងសំណុំលិខិត ហើយជូនដំណឹងដល់អ្នកសុំ។ ម្យ៉ាងទៀតចំពោះអគារ និងបណ្តាការ្យធំៗ ឬដែលមានប្រភេទអាចធ្វើឱ្យរំខានដល់សុវត្ថិភាព សុខុមាលភាពសាធារណៈនោះ ត្រូវផ្សព្វផ្សាយដល់សាធារណជនពីការដាក់ពាក្យសុំលិខិតអនុញ្ញាតសាងសង់ដោយវិធីណាមួយផ្សេងទៀត ដែលគេយល់ឃើញថាមានប្រសិទ្ធភាពជាងដោយផ្អែកលើមធ្យោបាយ ផ្សាយព័តិមាននៅតាមមូលដ្ឋាន។

ប្រកាសមួយរបស់គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ កំណត់បញ្ជីអគារ និងការ្យដែលពាក់ព័ន្ធ។

រាល់បុគ្គលពាក់ព័ន្ធអាចសាកសួរសុំមើលសំណុំលិខិត នៅការិយាល័យសុំលិខិតអនុញ្ញាតសាងសង់ (មន្ទីររៀបចំក្រុង និងសំណង់) ចំពោះក្រុងភ្នំពេញ និងសាលាស្រុក ឬសាលាខេត្ត (មន្ទីរសំណង់) ចំពោះខេត្តក្នុងរយៈពេល២៥ថ្ងៃ និងអាចធ្វើការតវ៉ា ឬទាមទារទៅអាជ្ញាធរមានសមត្ថកិច្ច។

បណ្តឹងតវ៉ាទាំងនេះត្រូវដាក់បញ្ចូលទៅក្នុងសំណុំលិខិតពាក្យសុំ។

អាជ្ញាធរមូលដ្ឋានពិនិត្យមើលការជំទាស់ ដែលទទួលបានក្នុងពេលអង្កេត និងធ្វើរបាយការណ៍មួយជូនទៅសាលាខេត្ត សាលាក្រុងក្នុងរយៈពេល៥ថ្ងៃ។ សាលាខេត្ត សាលាក្រុង ឬគណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ (ប្រសិនបើមាន) គណៈកម្មការនេះត្រូវសម្រេចអំពីសុពលភាពនៃបណ្តឹងតវ៉ា។

**មាត្រា១៣ អង្កេតនៅតាមបណ្តាមន្ទីរមានសមត្ថកិច្ច**

គណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ (ប្រសិនបើមាន) ឬក្នុងករណីផ្សេងទៀត មន្ទីររៀបចំក្រុង និងសំណង់នៃបណ្តាខេត្ត-ក្រុងប្រមូលយោបល់ពីមន្ទីរមានសមត្ថកិច្ច ហើយធ្វើសំយោគមួយ។

យោបល់ និងសំយោគទាំងនោះជាលាយលក្ខណ៍អក្សរត្រូវដាក់ជូនអភិបាលខេត្ត ឬប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងពិនិត្យ និងសម្រេច។ បណ្ដាមន្ទីរដែលត្រូវចូលរួមពិភាក្សាជាចាំបាច់ ក្នុងពេលពុំទាន់មានគណៈកម្មការចេញលិខិតអនុញ្ញាត សាងសង់រួមមាន៖

-មន្ទីរសុរិយោដី

-មន្ទីររៀបចំក្រុង និងសំណង់

-មន្ទីរសាធារណការ

-មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ

-មន្ទីរហិរញ្ញវត្ថុ

-មន្ទីរបរិស្ថាន

-និងតំណាងស្ថាប័នពាក់ព័ន្ធ

**មាត្រា១៤ រយៈពេលពិនិត្យសំណុំលិខិត**

រយៈពេលសម្រាប់ពិនិត្យសំណុំលិខិតសុំលិខិតអនុញ្ញាតសាងសង់ ត្រូវបានកំណត់ឡើង ៤៥ថ្ងៃធ្វើការ។ រយៈពេលនេះគិតចាប់ពីថ្ងៃដែលរាល់លិខិតស្នាម ភ្ជាប់ជាមួយនឹងពាក្យសុំលិខិតអនុញ្ញាតសាងសង់បានបំពេញសព្វគ្រប់។ នៅចុងរយៈពេលកំណត់នេះ អ្នកស្នើសុំត្រូវបានទទួលដំណឹងអំពីសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរស្ដីពីការអនុញ្ញាត ឬការមិនអនុញ្ញាត ឬមួយការអនុញ្ញាតដែរ តែស្នើសុំឱ្យកែសម្រួលបន្ថែម។

ក្នុងករណីគ្មានចម្លើយណាមួយពីអាជ្ញាធរ នោះត្រូវចាត់ទុកបានចម្លើយជាវិជ្ជមាន។

កាលបរិច្ឆេទថ្ងៃទី០១នេះ ត្រូវបានកំណត់ដោយគណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ (ប្រសិនបើមាន) ឬដោយមន្ទីររៀបចំក្រុង និងសំណង់ក្នុងករណីផ្សេងទៀត។

បើអាជ្ញាធរមានសមត្ថកិច្ចបានស្នើដល់អ្នកសុំឱ្យធ្វើការកែប្រែតម្រូវ នោះរយៈពេល៤៥ថ្ងៃនៃថ្ងៃធ្វើការថ្មីមួយទៀតនឹងត្រូវគិតចាប់ពីថ្ងៃដាក់ពាក្យសុំមានការកែតម្រូវជាផ្លូវការ។

ការបដិសេធផ្ដល់លិខិតអនុញ្ញាតសាងសង់ និងការស្នើសុំឱ្យកែសម្រួល ត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកសុំ ដោយអាជ្ញាធរមានសមត្ថកិច្ច។

**ជំពូក៤ ទម្រង់បែបបទបន្ទាប់ពីបានលិខិតអនុញ្ញាតសាងសង់**

**មាត្រា១៥ ការប្រគល់លិខិតអនុញ្ញាតសាងសង់**

លិខិតអនុញ្ញាតសាងសង់ត្រូវប្រគល់ឱ្យអ្នកសុំដោយអាជ្ញាធរដែលបានអនុញ្ញាតឱ្យ ។

លិខិតអនុញ្ញាតសាងសង់មួយច្បាប់អមដោយសំណុំលិខិតគ្រប់សព្វ (ប្លង់ លិខិតស្នាម ជាឧបសម្ព័ន្ធ យោបល់ ...) ត្រូវរក្សាទុកជាឯកសារជាច់ខាតដោយសាលាខេត្ត ឬសាលាក្រុង ។

ក្នុងករណីដែលលិខិតអនុញ្ញាតសាងសង់ជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល នោះគណៈកម្មាធិការជាតិរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវរក្សាទុកជាឯកសារ១ច្បាប់ផងដែរ ។

**មាត្រា១៦ លិខិតអនុញ្ញាតសាងសង់ផុតកំណត់កាល និងការងារបោះបង់ចោល**

១៦.១-លិខិតអនុញ្ញាតសាងសង់អស់សុពលភាព បើការងារពុំដំណើរការក្នុងរយៈពេលមួយឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខា ចេញលិខិតអនុញ្ញាតសាងសង់ ។ លិខិតនេះ អាចអនុញ្ញាតពន្យារពេលបានមួយដង ។ សំណង់ដែលត្រូវចាត់ទុកថាបានចាប់ផ្តើមសាងសង់ កាលណាជើងគ្រឹះត្រូវបានធ្វើហើយ ។ ចំពោះការសាងសង់បន្ថែមជាន់ ត្រូវចាត់ទុកថាបានចាប់ផ្តើមកាលណាសសរទីមួយត្រូវបានធ្វើហើយ ។

១៦.២-កាលណាការងារសាងសង់ ត្រូវបានផ្អាកលើសពីមួយឆ្នាំ អាជ្ញាធរក្រុង ឬខេត្តអាចបង្ខំឱ្យធ្វើបញ្ចប់ ឬបង្ខំឱ្យរុះរើសំណង់ដែលបានចាប់ផ្តើម និងឱ្យរៀបចំទីកន្លែងឱ្យបានត្រឹមត្រូវដូចដើមវិញ ក្នុងរយៈពេលមួយដែលបានកំណត់ និងដោយសោហ៊ុយរបស់ម្ចាស់លិខិតអនុញ្ញាតសាងសង់ ។

**មាត្រា១៧ ការចាប់ដំណើរការការដ្ឋាន**

ការដ្ឋានពុំត្រូវចាប់ដំណើរការមុនពេលបានទទួលលិខិតអនុញ្ញាតសាងសង់ និងមុនពេលទទួលបានការអនុម័តលើប្លង់លំអិតគ្រឿងផ្គុំសំណង់ឡើយ ។

រាល់សហគ្រិនទទួលបន្ទុកស្ថាបនាសំណង់ត្រូវបញ្ជាក់ឱ្យដឹងច្បាស់ថា លិខិតអនុញ្ញាតសាងសង់ត្រូវបានអនុញ្ញាតរួចហើយ ពីព្រោះជាប់ទទួលខុសត្រូវរួមជាមួយម្ចាស់សំណង់ ។

អ្នកកាន់លិខិតអនុញ្ញាតសាងសង់ត្រូវតម្កល់ទុកនៅការដ្ឋាន នូវសេចក្តីចម្លងឯកសាររដ្ឋបាលពីការចេញលិខិតអនុញ្ញាត សាងសង់មួយច្បាប់សម្រាប់មន្ទីរក្រុង ឬខេត្តត្រួតពិនិត្យ ។ ប្លង់អនុវត្តការសាងសង់ និងប្លង់លំអិតសំណង់មួយច្បាប់ត្រូវតម្កល់ទុកជាប្រចាំនៅការដ្ឋានសម្រាប់មន្ទីរក្រុង ឬខេត្តត្រួតពិនិត្យ ។

**មាត្រា១៨ ដំណើរការទៅមុខនៃការងារ**

១៨.១-ក្រោយពីបានទទួលលិខិតអនុញ្ញាតសាងសង់ និងប្លង់លំអិតគ្រឿងផ្គុំសំណង់ហើយ ម្ចាស់សំណង់ត្រូវជូនដំណឹងទៅសាលាស្រុក-ខណ្ឌ និងចុះទិដ្ឋាការនៅមន្ទីរមានសមត្ថកិច្ច។

មុនចាប់ដំណើរការការដ្ឋាន ម្ចាស់សំណង់ត្រូវមានលិខិតអនុញ្ញាតបើកការដ្ឋានពីមន្ទីររៀបចំក្រុង និងសំណង់ ឬការិយាល័យខេត្ត-ក្រុង។

ស្ថាប័នសមត្ថកិច្ចបច្ចេកទេស ត្រូវតាមដានការអនុវត្តជាជំហាន៧ដូចតទៅ៖

-ក្រោយការបោះបង្គោលកំណត់ទីតាំងសំណង់

-ក្រោយការងារផ្នែកគ្រឹះ និងមុនការធ្វើកម្រាលក្រោមនៃជាន់ផ្ទាល់ដី

-នៅទីបញ្ចប់នៃការរៀធំៗ ( គ្រឹះ-សសរ-ជញ្ជាំង-កម្រាល...) ផ្នែកសំខាន់ៗនៃសំណង់

-នៅពេលតភ្ជាប់ទៅបណ្តាញលូទឹកស្អុយ ទឹកស្អាត និងបណ្តាញអគ្គិសនី

១៨.២-រាល់ការផ្លាស់ប្តូរម្ចាស់សំណង់ក្នុងពេលកំពុងដំណើរការសាងសង់ ត្រូវជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ច។

**មាត្រា១៩ ការរៀបចំការដ្ឋានសំណង់**

ការដាក់គរសម្ភារៈសំណង់លើផ្លូវសាធារណៈត្រូវហាមឃាត់៖

-កាលណាសំណង់ត្រូវការកន្លែងតាំងការដ្ឋានលយទៅលើផ្លូវសាធារណៈ កន្លែងលយនោះត្រូវកំណត់ត្រឹម២មទៅលើចិញ្ចើមផ្លូវ។ កន្លែងនោះត្រូវធ្វើរបងហ៊ុមព័ទ្ធ ក្នុងរយៈពេលដំណើរការរបស់ការដ្ឋាន។

-រាល់កន្លែងតាំងការដ្ឋានត្រូវរុះរើចេញក្នុងរយៈពេលមួយសប្តាហ៍ ក្រោយពេលចប់ការដ្ឋាន។

-គំនរសម្ភារៈ កាកសំណល់បានមកពីការរុះរើ ឬពីការសាងសង់ ឬការជួសជុលត្រូវយកចេញក្នុងរយៈពេលមួយសប្តាហ៍ ក្រោយពេលចប់ការងារ។

-ក្នុងករណីពុំបានរើយកសម្ភារៈកាកសំណល់ចេញពីកន្លែងតាំងការដ្ឋានទេ សាលាខណ្ឌ ឬសាលាស្រុក មានកាតព្វកិច្ចចាត់ចែងដឹកជញ្ជូនចេញដោយស្វ័យប្រវត្តិ។ ចំណាយជាបន្ទុករបស់ម្ចាស់សំណង់។

**មាត្រា២០ ការត្រួតពិនិត្យ និងការបញ្ឈប់ការងារ**

អាជ្ញាធរក្រុង ឬខេត្តអាចចូលមើល និងត្រួតពិនិត្យការដ្ឋានគ្រប់ពេលវេលា ហើយនិងពិនិត្យប្លង់ដែលបានអនុម័តរួច។ បើពិនិត្យឃើញភាពមិនត្រឹមត្រូវ អាជ្ញាធរនោះជម្រាបជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណង់ ឱ្យកែតម្រូវក្នុងរយៈពេលកំណត់មួយ។

ក្នុងករណីពុំបានអនុវត្ត ឬបានអនុវត្តពុំត្រឹមត្រូវតាមបញ្ជា ការផ្អាកការងារត្រូវចេញបញ្ជាជាបន្ទាន់ដោយអាជ្ញាធរក្រុង ឬខេត្ត។

សាលាក្រុង ឬសាលាខេត្តអាចប្ដឹងទៅតុលាការមានសមត្ថកិច្ចឱ្យចេញដីកាកិច្ចការ បញ្ជាប់ឱ្យផ្អាកការសាងសង់ ឬផ្លាស់ប្ដូរទ្រង់ទ្រាយសំណង់ដែលពុំត្រឹមត្រូវ ឬគ្មានច្បាប់នោះ។ ចំណាយជាបន្ទុករបស់ម្ចាស់សំណង់។

អនុលោមទៅតាមសភាពធ្ងន់ធ្ងរនៃការខុសឆ្គង បណ្ដាសម្ភារៈ និងទព្វសម្ភារៈរបស់ការដ្ឋានអាចត្រូវរឹបអូសតាមបង្គាប់តុលាការ។

**មាត្រា២១ វិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ**

អ្នកសុំលិខិតអនុញ្ញាតសាងសង់ ត្រូវប្រកាសប្រាប់អំពីការចប់ការងារដល់សាលាខណ្ឌ ឬសាលាស្រុក។ ពេលបញ្ចប់ការដ្ឋាន សាលាខណ្ឌ ឬសាលាស្រុកជាមួយនិងការិយាល័យសុំលិខិតអនុញ្ញាតសាងសង់ (មន្ទីររៀបចំក្រុង និងសំណង់) អាចត្រួតពិនិត្យភាពត្រឹមត្រូវស្របគ្នារវាងសំណង់ដែលធ្វើរួចហើយ និងលិខិតអនុញ្ញាតសាងសង់ដែលបានចេញឱ្យ។

ត្រូវចាត់ទុកថាពុំត្រឹមត្រូវ បើផ្ទៃបាតសំណង់ ឬផ្ទៃក្រឡាកម្រាលបានសាងសង់លើសពីកម្រិតអនុញ្ញាត។ អាចចាត់ទុកថាពុំត្រឹមត្រូវ បើទិដ្ឋភាពនៃអគារមានភាពងាយឃើញខុសគ្នាពីលិខិតអនុញ្ញាតសាងសង់ ដែលបានចេញឱ្យ។

ក្នុងករណីពុំត្រឹមត្រូវទេ អាជ្ញាធរក្រុង ឬខេត្តអាចបង្ខំម្ចាស់សំណង់ឱ្យកែតម្រូវអគារឱ្យបានត្រឹមត្រូវស្របគ្នានឹងលិខិតអនុញ្ញាតសាងសង់ដែលបានចេញឱ្យ។

ក្នុងករណីមិនគោរពតាមទេ សាលាក្រុង ឬសាលាខេត្តត្រូវប្ដឹងទៅតុលាការមានសមត្ថកិច្ចឱ្យចេញសាលក្រម ឬសាលដីកា។

វិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវមួយដែលចេញឱ្យដោយអាជ្ញាធរក្រុង ឬខេត្ត ត្រូវតែមានជាចាំបាច់ខានពុំបាន ចំពោះបណ្ដាអគារសម្រាប់ទទួលសាធារណជន សណ្ឋាគារ ការិយាល័យ

ក៏ដូចជាចំពោះបណ្តាកន្លែងធ្វើការរបស់អ្នកមានបៀវត្ស ។ វិញ្ញាបនបត្រនេះត្រូវបានទទួលមុនការបើកប្រើប្រាស់កន្លែងធ្វើការនោះ ។

វិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវមួយ ចេញឱ្យដោយអាជ្ញាធរក្រុង ឬខេត្តត្រូវតែមានជាចាំបាច់ខានពុំបាន មុនពេលបើកឱ្យប្រើប្រាស់ ចំពោះបណ្តាអគារដែលសាងសង់នៅក្នុងរមណីយដ្ឋាន និងទេសភាពធម្មជាតិ ឬក្រុងដែលមានលក្ខណៈប្រវត្តិសាស្ត្រ បុរាណសាស្ត្រ បេតិកភណ្ឌ ឬនៅកន្លែងមើលឃើញទៅវិញទៅមកជាមួយប្រាង្គប្រាសាទ ប្រវត្តិសាស្ត្រណាមួយ ។

## ជំពូក៥ លិខិតអនុញ្ញាតរុះរើ

### មាត្រា២២

រាល់ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលសិទ្ធិតំណាងក្នុងអាណត្តិដែលមានបំណងរុះរើអគារណាមួយដែលមានស្រាប់ ក្រៅពីសំណង់បណ្តោះអាសន្នមិនស្ថិតស្ថេរ ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតរុះរើ នៅការិយាល័យសុំលិខិតអនុញ្ញាតសាងសង់ ។

សំណុំពាក្យសុំលិខិតអនុញ្ញាតរុះរើត្រូវមាន៖ ប្លង់ដីឡូត៍ និងប្លង់អគារ រូបថតអគារ ឬឯកសារផ្សេងៗទៀតដែលចាំបាច់ ។

ចំពោះរាល់អគារដែលមានចុះក្នុងបញ្ជីបេតិកភណ្ឌ ពាក្យសុំអនុញ្ញាតរុះរើ ត្រូវឆ្លងតាមគណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ ហើយត្រូវបានអនុញ្ញាតដោយអភិបាលខេត្ត ឬប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង ។

លិខិតអនុញ្ញាតរុះរើត្រូវផ្សព្វផ្សាយភ្លាមជាសាធារណៈ ដោយការបិទប្រកាសនៅកន្លែងដែលអាចមើលឃើញពីផ្លូវសាធារណៈនៅកន្លែងគ្រោងធ្វើការរុះរើ ។ ការងាររុះរើពុំអាចចាប់ផ្តើមក្នុងរយៈពេលតិចជាង១៥ថ្ងៃ បន្ទាប់ពីការចេញលិខិតអនុញ្ញាតឡើយ ។

លិខិតអនុញ្ញាតរុះរើត្រូវចាត់ទុកយល់ព្រម បើពុំមានចម្លើយណាមួយក្រោយពីថ្ងៃដាក់ពាក្យសុំ៣ខែ ។ រាល់ជំទាស់ត្រូវផ្តល់ដំណឹងទៅអ្នកសុំជាលាយលក្ខណ៍អក្សរ ។

### មាត្រា២៣

បណ្តាបទបញ្ញត្តិពីសមត្ថកិច្ច និងការពិនិត្យពាក្យសុំដែលអនុវត្តចំពោះលិខិតអនុញ្ញាតសាងសង់ ត្រូវអនុវត្តបានដូចគ្នាចំពោះពាក្យលិខិតអនុញ្ញាតរុះរើ ។

### ជំពូក៦ បទល្មើស និងបណ្ដឹងតវ៉ា

**មាត្រា២៤ ករណីបទល្មើស**

រាល់សំណង់ដែលបានចាប់ផ្ដើមដំណើរមុនចេញលិខិតអនុញ្ញាតសាងសង់ ដោយអាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់ទុកជាល្មើសច្បាប់។ ការដ្ឋានត្រូវបញ្ឈប់ជាបន្ទាន់។

បណ្ដាបុគ្គលដែលបានប្រព្រឹត្តល្មើសនឹងបញ្ជារបស់រដ្ឋមន្ត្រី និងភ្នាក់ងាររបស់រាជការត្រូវជាប់ចោទហើយ ឧបករណ៍ទាំងឡាយនៅក្នុងការដ្ឋានត្រូវរឹបអូស។ ក្នុងករណីមិនរាងចាល ត្រូវពិន័យជាបទលហុ។ បើពុំព្រមបញ្ឈប់ការងារត្រូវបញ្ជូនជនល្មើសទៅតុលាការ ដែលត្រូវវិនិច្ឆ័យតាមច្បាប់ជាធរមាន។

**មាត្រា២៥ បណ្ដឹងតវ៉ា**

រាល់សេចក្ដីសម្រេចទាក់ទងនឹងពាក្យសុំលិខិតអនុញ្ញាតសាងសង់ មុនឡើងទៅតុលាការមានសមត្ថកិច្ច អាចជាកម្មវត្ថុនៃបណ្ដឹងតវ៉ាទៅអាជ្ញាធរមានសមត្ថកិច្ច ដូចបានបញ្ជាក់ក្នុងមាត្រា៤ និង៥នៃអនុក្រឹត្យនេះ ដើម្បីធ្វើការពិនិត្យលើបណ្ដឹងតវ៉ានេះ។

អាជ្ញាធរមានសមត្ថកិច្ច មាននីតិសម្បទាសម្របសម្រួលជាមួយម្ចាស់បណ្ដឹង។ ក្នុងករណីមិនបានសម្រេច អ្នកប្ដឹងអាចតវ៉ាទៅដល់ប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់បើអាជ្ញាធរមានសមត្ថកិច្ចជាអភិបាលខេត្ត ឬប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង ឬនឹងទៅដល់នាយករដ្ឋមន្ត្រី បើអាជ្ញាធរមានសមត្ថកិច្ច ជាតំណាងរាជរដ្ឋាភិបាល។

សម្រាប់កិច្ចការនេះ ត្រូវបានបង្កើតផ្នែកវិវាទមួយនៅគ្រប់សាលាខេត្ត ឬសាលាក្រុង និងក្នុងគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់។

### វគ្គទី២ បទបញ្ញាទូទៅនៃការប្រើប្រាស់ដីធ្លី

**មាត្រា២៦**

បទបញ្ញាទូទៅនៃការប្រើប្រាស់ដីធ្លីនេះ ត្រូវយកមកអនុវត្តទូទាំងព្រះរាជាណាចក្រកម្ពុជា ហើយតម្រូវឱ្យរាល់បុគ្គលសាធារណៈ និងឯកជនជារូបវន្តបុគ្គលក្ដី ឬនីតិបុគ្គលក្ដី គោរពប្រតិបត្តិតាមលិខិតអនុញ្ញាតសាងសង់ ក្នុងរយៈពេលដែលពុំទាន់មានប្លង់ប្រើប្រាស់ដីធ្លី និងប្លង់គោលនៅឡើយនោះ។

### ជំពូក១ ប្រភេទ ការកំណត់ទីតាំង និងផ្លូវពាក់ព័ន្ធចូលដល់ទីតាំងសំណង់

**មាត្រា២៧ សុវត្ថិភាព និងសុខុមាលភាពសាធារណៈ**

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ ចំពោះសំណង់ទាំងឡាយណាដែលទីតាំង ប្រភេទ ឬទំហំមានលក្ខណៈនាំឱ្យប៉ះពាល់ដល់សុខុមាលភាព ឬដល់សុវត្ថិភាពសាធារណៈនាំឱ្យរំខាន ឬបណ្តាលឱ្យមានមហន្តរាយ ។

២៧.១-ទីដីគ្រោះថ្នាក់ ( ទីដីដែលអាចមានគ្រោះថ្នាក់)

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ ចំពោះទីដីដែលអាចមានមហន្តរាយ តំបន់បាក់ស្រុតរលំ តំបន់ដីសើម ដែលត្រូវការការពារតាមមាត់ច្រាំងទន្លេ ព្រែក ស្ទឹង បឹងបួ ដែលពុំមានភាពរឹងមាំគ្រប់គ្រាន់ ហើយអាចបណ្តាលឱ្យមានគ្រោះថ្នាក់ ចំពោះសុវត្ថិភាពរបស់មនុស្ស និង សម្បត្តិទ្រព្យ លើកលែងតែភូមិដ្ឋានទាំងនោះបានអនុម័តតាមប្លង់គោល ។

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ ចំពោះដីអាចលិចទឹក កាលណាសំណង់ នោះឋិតតាមមាត់ច្រាំងទន្លេ លើព្រែក ស្ទឹង ឬបឹង បណ្តាលឱ្យថយចុះលទ្ធភាពរក្សាទឹកទុក ឬ លទ្ធភាពបង្ហូរទឹកពីទីដីនោះ និងទីដីជិតខាង និងប៉ះពាល់ដល់គុណភាពទឹក ។

២៧.២-ធាតុរំខានដោយសំឡេង

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ ឬអាចអនុញ្ញាតឱ្យតែក្នុងករណីក្រោម បញ្ញត្តិពិសេសបើសំណង់នោះ អាចត្រូវទទួលរងធាតុរំខានដោយសំឡេងខ្លាំងៗ ឬបើសំណង់នោះ អាចបង្កធាតុរំខានដោយសំឡេងខ្លាំងៗ ។

**មាត្រា២៨ ការការពាររមណីយដ្ឋាន**

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ បើសំណង់នោះមានប្រភេទ ទំហំ ឬទីតាំង អាចបណ្តាលឱ្យអន្តរាយដល់ការអភិរក្ស ឬអន្តរាយដល់ការលើកតម្លៃនៃរមណីយដ្ឋានធម្មជាតិ ឬ ក្រុង ឬកេរដំណែលប្រវត្តិសាស្ត្រ និងបូរាណវត្ថុ ឬអាចអនុញ្ញាតឱ្យតែក្នុងករណីក្រោមបញ្ញត្តិពិសេស ។

**មាត្រា២៩ បណ្តាញផ្លូវពាក់ព័ន្ធ និងចំណត**

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ ចំពោះដីដែលពុំមានផ្លូវចេញចូលដូចជា៖ ផ្លូវសាធារណៈ ផ្លូវឯកជន ច្រកផ្លូវ ឬផ្លូវឆ្លងកាត់ ដែលទទឹងត្រូវសមាមាត្រសមស្របទៅនឹងទំហំ និងការប្រើប្រាស់នៃអគារ ។

រាល់ផ្លូវ ផ្លូវឆ្លងកាត់ ច្រកផ្លូវ សម្រាប់ប្រើប្រាស់ចំពោះសំណង់មួយ ឬច្រើនពុំអាចមាន ទទឹងតិចជាង៣,៥០ម ដែលជាទំហំចាំបាច់សម្រាប់ឱ្យរថយន្តពន្លត់អគ្គីភ័យចូលបាន ។

ចំណតរថយន្ត ត្រូវមានគ្រប់គ្រាន់តាមសេចក្តីត្រូវការរបស់អគារ ហើយត្រូវឋិតនៅក្រៅពីផ្លូវសាធារណៈ។ បទដ្ឋានចំណតរថយន្តត្រូវបានកំណត់ដោយបណ្តាសាលាក្រុង និងសាលាខេត្តប៉ុន្តែពុំអាចតិចជាង៖

-ចំពោះសណ្ឋាគារ

+ចំណតរថយន្តតូច១កន្លែង សម្រាប់៥បន្ទប់

+ចំណតរថយន្តធំ១កន្លែង សម្រាប់៣០បន្ទប់

-ចំពោះការិយាល័យឯកជន និងរដ្ឋបាលសាធារណៈ

+ចំណតរថយន្ត១កន្លែង សម្រាប់ផ្ទៃក្រឡាកម្រាលសរុបទំហំ២៥០ម៉ែត្រទ្វេគុណ

-ចំពោះបណ្តាសកម្មភាពឧស្សាហកម្ម សិប្បកម្ម និងឃ្លាំងស្តុកទំនិញ ចំនួនចំណតរថយន្តត្រូវមានគ្រប់គ្រាន់សម្រាប់ការលើកដាក់ ផ្ទុក និងផ្ទេរទំនិញនៅក្រៅពីផ្លូវសាធារណៈ និងចំណតរថយន្តគ្រប់ប្រភេទ នៅក្នុងបរិវេណដីឡូតិ៍។

**មាត្រា៣០ ការបោះទីតាំងសំណង់ តាមដងផ្លូវសាធារណៈ**

៣០.១-ការបោះទីតាំងសំណង់នៅតាមដងផ្លូវជាតិ និងផ្លូវទំនប់ព័ទ្ធជុំវិញទីក្រុង អភិបាលខេត្ត ឬប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងនានា និងរាជធានីភ្នំពេញ ត្រូវកំណត់ដោយមានការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់នូវដីសាធារណៈ និងធ្លាគម្លាតនៃផ្លូវជាតិ ផ្លូវសំខាន់ៗដែលពាក់ព័ន្ធនឹងការរៀបចំទីក្រុង និងនគរូបនីយកម្ម ជាអាទិ៍ផ្លូវទំនប់។

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយនៅក្នុងតំបន់ដែលបានរៀបរាប់ខាងលើ។

៣០.២-ការបោះទីតាំងសំណង់ នៅតាមដងផ្លូវសាធារណៈក្នុងក្រុង

សំណង់ទាំងឡាយ ត្រូវបោះទីតាំងលើជួរតម្រង់ផ្លូវសាធារណៈ ឬឃ្លាតថយពីជួរតម្រង់យ៉ាងតិច៤ម។ នៅតាមច្រកផ្លូវ បណ្តាសំណង់អាចបោះទីតាំងលើជួរតម្រង់ផ្លូវច្រក។

អភិបាលខេត្ត ឬប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងនានា និងរាជធានីភ្នំពេញ កំណត់ជួរតម្រង់នៃផ្លូវសាធារណៈ និងធ្លាគម្លាតលើប្លង់មួយ ហៅថាប្លង់ជួរតម្រង់។ ប្លង់ជួរតម្រង់នេះ ត្រូវទទួលការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ចំពោះក្រុងទាំងឡាយណាដែលមានប្រជាជនលើសពី២០.០០០នាក់។ ប្លង់ទាំងនោះត្រូវផ្សព្វផ្សាយឱ្យសាធារណជនបានដឹង។

**មាត្រា៣១ ការផ្គត់ផ្គង់ទឹកស្អាត និងការបញ្ចេញចោលទឹកកខ្វក់**

៣១.១-ការផ្គត់ផ្គង់ទឹកស្អាត ត្រូវធានាឱ្យបានចំពោះរាល់សំណង់ ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់។

ក្នុងករណីដែលបណ្ដាញទឹកស្អាត ពុំផ្គត់ផ្គង់ឱ្យទៅដល់ទីដីដែលនៅលើទីដីនោះមានសំណង់មួយត្រូវបានគ្រោងទុកនោះ អ្នកស្នើសុំត្រូវបង្ហាញភស្តុតាងថា ខ្លួនអាចនឹងផ្គត់ផ្គង់ទឹកស្អាតក្នុងបរិមាណគ្រប់គ្រាន់ដល់អគាររបស់ខ្លួន និងបញ្ជាក់ថាតាមមធ្យោបាយអ្វីទោះបីតាមការបន្តភ្ជាប់ទៅនឹងបណ្ដាញទឹកស្អាតណាមួយដែលនៅជិត ឬជាអណ្ដូងទឹកដែលមានស្រាប់នៅជិតនោះ ឬដែលត្រូវជីកថ្មីក្ដី។

អ្នកស្នើសុំត្រូវបញ្ជាក់អំពីលក្ខណៈបច្ចេកទេសរបស់អណ្ដូង និងគុណភាពទឹក។ ក្នុងករណីការប្រើប្រាស់អណ្ដូងសមូហភាព សំណុំលិខិតនៃលិខិតអនុញ្ញាតសាងសង់ត្រូវមានសេចក្ដីយល់ព្រមឱ្យប្រើប្រាស់ទឹកជាលាយលក្ខណ៍អក្សរ។

៣១.២-បណ្ដាដីឡូតិ៍ ឬសំណុំលំនៅឋានត្រូវតែមានការផ្គត់ផ្គង់ដោយបណ្ដាញចែកចាយទឹកស្អាត និងមានប្រព័ន្ធលូទឹកស្អុយដែលនាំបង្ហូរចេញដល់ទីដៅតែម្ដង ដោយគ្មានកន្លែងណាមួយអាចឱ្យទឹកស្អុយដក់នៅបាន។

៣១.៣-ក្នុងករណីគ្មានប្រព័ន្ធលូទឹកស្អុយ ម្ចាស់សំណង់មានកាតព្វកិច្ចត្រូវគ្រោងសំអាត និងបញ្ចេញទឹកដែលប្រើប្រាស់ហើយទៅទីធម្មជាតិ តាមរយៈអាងបង្គន់អនាម័យ និងបណ្ដាញបំពង់មានប្រហោងរាយកប់ក្នុងដី។ បណ្ដាញនេះបែងចែកទឹកដែលចេញពីបង្គន់អនាម័យនៅក្រោមដីធ្វើឱ្យជ្រាប និងជម្រះបាន។ ម្ចាស់កម្មសិទ្ធិនៅក្នុងក្រុង ចាំបាច់ត្រូវធ្វើអាងបង្គន់អនាម័យ ហើយបន្តភ្ជាប់ទៅប្រព័ន្ធលូ។

បទដ្ឋានអាងបង្គន់អនាម័យ កំណត់ដូចតទៅ៖ ទំហំប្រើប្រាស់នៃអាងបង្គន់អនាម័យដោយគិតពីបាតអាងឡើងមកដល់បំពង់បង្ហូរចេញ៖

-ជាអប្បបរមា៣ម៉ែត្រគ្រីគុណសម្រាប់លំនៅឋានមួយ ឬ៣ម៉ែត្រគ្រីគុណក្នុងមួយជាន់នៃផ្ទះល្វែង ឬនៃភូមិគ្រឹះ ឬ៣ម៉ែត្រគ្រីគុណសម្រាប់ផ្ទៃក្រឡាកម្រាលសរុបទំហំ៨០ម៉ែត្រទ្វេគុណ។ ចំពោះសណ្ឋាគារ ២ម៉ែត្រគ្រីគុណ បូកបន្ថែម០.៥ម៉ែត្រគ្រីគុណក្នុងមួយបន្ទប់៖

-កម្ពស់អាងបង្គន់អនាម័យពុំអាចទាបជាង១.៥០ម។

-អាងបង្គន់អនាម័យត្រូវមានរន្ធបង្ហុយបន្តខ្ពស់ទៅលើ ។

-មិនត្រូវឱ្យទឹកភ្លៀងហូរចូលទៅក្នុងអាងបង្គន់អនាម័យជាដាច់ខាត ។

៣១.៤-សំណុំលិខិតសុំលិខិតអនុញ្ញាតសាងសង់ ត្រូវមានគំនូរអាងបង្គន់អនាម័យ និងប្រព័ន្ធបន្តភ្ជាប់ទៅលូបង្ហូរទឹកស្អុយ ។

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ បើពុំបង្ហាញការធានាគ្រប់គ្រាន់អំពីអនាម័យ និងសុខុមាលភាព ចំពោះសំណង់ដែលបានគ្រោង និងបណ្តាសំណង់នៅជុំវិញដែលមានស្រាប់ ។

**មាត្រា៣២ តំបន់មិនអាចសាងសង់បាន**

ខេត្ត និងក្រុងនីមួយៗ ត្រូវកំណត់ជាបន្ទាន់នូវប្លង់តំបន់មិនអាចសាងសង់បាន ។ ប្លង់នេះត្រូវមានបញ្ចូលតំបន់ការពារធម្មជាតិ តំបន់កសិកម្ម តំបន់ព្រៃឈើ និងរ៉ែដែលជាគោលដៅប្រើប្រាស់ពុំអាចផ្លាស់ប្តូរបានដោយមូលហេតុផលប្រយោជន៍សេដ្ឋកិច្ច និងបរិស្ថាន ។

ប្លង់នេះត្រូវមានបញ្ចូលរមណីយដ្ឋានធម្មជាតិ ដូចជាឆ្នេរសមុទ្រ មាត់ទន្លេ ព្រែក ស្ទឹង បឹងបួដោយមូលហេតុផលប្រយោជន៍បេតិកភណ្ឌ និងបរិស្ថាន ។

ប្លង់នេះត្រូវមានបញ្ចូលគ្រប់តំបន់អាចលិចទឹក ដែលត្រូវការពារដោយមូលហេតុជាផលប្រយោជន៍ សម្រាប់បង្ហូរទឹកភ្លៀងចេញ និងការប្រយុទ្ធប្រឆាំងនឹងទឹកជំនន់ ។

អាជ្ញាធរតាមមូលដ្ឋានត្រូវចាត់វិធានការសមស្របដើម្បីការពារ និងបង្កើនគុណសម្បត្តិតំបន់មិនអាចសាងសង់បានទាំងនោះ ។ រាល់លិខិតអនុញ្ញាតសាងសង់ មិនផ្តល់ជូនឡើយក្នុងតំបន់ទាំងនោះ ។

ក្នុងករណីមានការសាងសង់ដោយល្មើសច្បាប់ ក្នុងតំបន់ហាមឃាត់ទាំងនេះ អាជ្ញាធរដែនដីត្រូវបង្ខំឱ្យជនល្មើសរុះរើដោយខ្លួនឯង ហើយធ្វើឱ្យកន្លែងនោះមានសភាពដូចដើមវិញ ក្នុងរយៈកាលមួយកំណត់ ។

ក្នុងករណីមិនអនុវត្តតាមការកំណត់ អាជ្ញាធរដែនដីត្រូវធ្វើការផាកពិន័យ និងចាត់ឱ្យរុះរើ និងធ្វើឱ្យកន្លែងនោះមានសភាពដូចដើមវិញ ដោយចាប់បង្ខំឱ្យអ្នកល្មើសច្បាប់ ត្រូវតែចេញសោហ៊ុយចំណាយទាំងអស់នោះ ឬក្នុងករណីចាំបាច់ អាជ្ញាធរមូលដ្ឋានត្រូវប្តឹងទៅតុលាការ ដើម្បីឱ្យចេញដីកាកិច្ចការប្រញាប់បញ្ជាឱ្យរុះរើ ។

ប្លង់នេះត្រូវទទួលការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ និងត្រូវផ្សព្វផ្សាយជាសាធារណៈដល់មន្ត្រីរាជការផ្នែកអាជ្ញាធរដែនដីមូលដ្ឋាន និងមន្ត្រីជំនាញទទួលខុសត្រូវលើ "តំបន់មិនអាចសាងសង់បាន" ដែលពុំបានចាត់វិធានការចាំបាច់ ដើម្បីឱ្យមានការគោរពតំបន់ទាំងនោះទេ ត្រូវទទួលទណ្ឌកម្មរដ្ឋបាលតាមច្បាប់ជាធរមាន។

**មាត្រា៣៣ ផលប៉ះពាល់ពីសំណង់ឧស្សាហកម្ម**

សំណុំលិខិតសុំលិខិតអនុញ្ញាតសាងសង់សំណង់ឧស្សាហកម្ម ត្រូវបញ្ជាក់អំពីការបំពុលបណ្តាលមកពីសកម្មភាពឧស្សាហកម្ម និងវិធីដែលបានគ្រោងទុក ដើម្បីលុបបំបាត់ការបំពុលទាំងនោះ។

គម្រោងស្ថានីយសម្រាប់ធ្វើសំអាតតាមយថាប្រភេទ ត្រូវមានបញ្ចូលក្នុងសំណុំលិខិតសុំលិខិតអនុញ្ញាតសាងសង់។ រាល់កាកសំណល់ពីឧស្សាហកម្មត្រូវតែបានទទួលការសំអាតជាមុន ដើម្បីបង្ការកុំឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ ឬសុខភាពសាធារណៈ។ ទឹកកខ្វក់សំណល់ឧស្សាហកម្ម ពុំត្រូវឱ្យលាយឡំជាមួយទឹកភ្លៀង និងជាមួយទឹកកខ្វក់ដទៃទៀត ហើយក៏ពុំត្រូវបង្ហូរចូលត្រង់ៗ ទៅកន្លែងធម្មជាតិ ដោយពុំបានធ្វើការសំអាតជាមុនឡើយ។

ចម្ងាយអប្បបរមា ដែលត្រូវគោរពរវាងសំណង់ឧស្សាហកម្មមួយដែលមានធាតុកខ្វក់ និងលំនៅឋាននៅជិតបំផុត ត្រូវបានរដ្ឋអំណាចមូលដ្ឋានអនុវត្ត ស្របទៅតាមការណែនាំផ្ទាល់របស់រាជរដ្ឋាភិបាល។

ចំពោះឃ្លាំងស្តុកឧទង្ការ និងអាងប្រេងឥន្ធនៈទាំងឡាយត្រូវគោរពបទប្បញ្ញត្តិអន្តរជាតិអនុម័តដោយរាជរដ្ឋាភិបាល។

រាល់អំពើល្មើសនឹងបណ្តាបទប្បញ្ញត្តិខាងលើនេះ រដ្ឋអំណាចមូលដ្ឋានអាចបញ្ជាផ្អាកសកម្មភាពជាបន្ទាន់ ហើយត្រូវរាយការណ៍ជូនស្ថាប័នជំនាញ។ រដ្ឋអំណាចត្រូវជូនដំណឹងតាមផ្លូវច្បាប់ដល់ម្ចាស់សំណង់ នូវបណ្តាបទប្បញ្ញត្តិដែលត្រូវគោរពតាម។

**ជំពូក២ ការបោះទីតាំង និងទំហំសំណង់**

**មាត្រា៣៤ ការបោះទីតាំងធៀបនឹងព្រំដីឡូត៍ជិតខាង**

ធៀបនឹងព្រំដីឡូត៍ សំណង់ទាំងឡាយនឹងត្រូវសាងសង់ ឬមួយនៅជាប់នឹងព្រំ ឬមួយជាជញ្ជាំងអឌ្ឍសិទ្ធិ ឬមួយនៅចម្ងាយអប្បបរមា២មពីព្រំ។ ចន្លោះ២មនេះត្រូវទុកឱ្យនៅទំនេរពុំមានសំណង់អ្វីឡើយ។ ហាមមិនឱ្យចោះទ្វារ ឬបង្អួចនៅលើជញ្ជាំងអឌ្ឍសិទ្ធិ ឬជញ្ជាំងជាប់ព្រំ។

ចំពោះសំណង់ជាប់ព្រំ ឬសំណង់ជាជញ្ជាំងអឌ្ឍសិទ្ធិ នឹងមានកំណត់ក្នុងសេចក្តីណែនាំអនុវត្តរបស់គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ តាមសំណើរបស់ខេត្ត-ក្រុង។ ត្រូវបានចាត់ទុកថាជាបន្ទប់រស់នៅ រាល់បន្ទប់ទាំងអស់លើកលែងតែផ្ទះបាយ បន្ទប់អនាម័យ បន្ទប់សេវាផ្សេងៗ និងចន្លោះដើរក្នុងអគារ។ បទប្បញ្ញត្តិនេះត្រូវដាក់ឱ្យអនុវត្តផងដែរចំពោះសណ្ឋាគារ។ ក្នុងករណីនេះ រាល់បន្ទប់ដេក ក៏ដូចជារាល់បន្ទប់ទទួលភ្ញៀវ សុទ្ធតែត្រូវចាត់ថាជាបន្ទប់រស់នៅ។

បទប្បញ្ញត្តិនេះក៏ត្រូវដាក់ឱ្យអនុវត្តផងដែរចំពោះកន្លែងធ្វើការ។ ក្នុងករណីនេះ រាល់បន្ទប់ដែលមានមុខងារជាការិយាល័យ ឬរោងជាងប្រើប្រាស់ជាទម្លាប់ ឬជាប្រចាំថ្ងៃ ត្រូវចាត់ទុកដូចជាបន្ទប់រស់នៅដែរ លើកលែងតែបន្ទប់មិនត្រូវការជាចាំបាច់នូវពន្លឺថ្ងៃតាមមុខងារយថាប្រភេទរបស់វា ដូចជាបន្ទប់កុំព្យូទ័រ បន្ទប់ពិសោធ ស្ទូឌីយោ ភាពយន្ត។ល។

សាលាក្រុង ឬសាលាខេត្ត អាចមានសិទ្ធិឱ្យបិទរាល់ច្រកប្រហោងណា ដែលពុំគោរពតាមចម្ងាយដូចបានរៀបរាប់ខាងលើនេះ។ ចំពោះអគារមានពីមុនស្រាប់ ដែលពុំគោរពតាមបទប្បញ្ញត្តិដូចបានរៀបរាប់ខាងលើនេះទេ សាលាក្រុង ឬសាលាខេត្តអាចទាមទារឱ្យបង្កើតរបាំងការពារ កុំឱ្យមានគំហើញត្រង់ទៅលើដីឡូត៍អ្នកជិតខាង។ របាំងការពារទាំងនេះ អាចជាជញ្ជាំងមានប្រឡោះខ្យល់ ផ្ទាំងឈើ ឬអ្វីៗផ្សេងទៀតដែលពុំរាំងខ្ទប់ដំណើរខ្យល់បក់ចេញចូលក្នុងបន្ទប់រស់នៅ។

ចាត់ទុកជាបង្អួច រាល់ប្រហោងនានាដែលបណ្តាលឱ្យមានគំហើញត្រង់ ឆ្ពោះទៅលើអ្នកជិតខាង។ ក្នុងករណីណាក៏ដោយ គេអាចប្រើប្រាស់បានរាល់របាំងធ្វើពីឈើ ឬបេតុង ស្លាបព្រីលប៉ាក់ប៉ើកធ្វើពីឈើ ឬកញ្ចក់ស្រអាប់ និងស្លាបព្រីលនៅនឹងថ្កល់។

**មាត្រា៣៥ ផ្ទៃបាត**

ចំពោះផ្ទះល្វែង និងអគារលំនៅឋានសមូហភាព ផ្ទៃបាតសំណង់ធៀបទៅនឹងផ្ទៃក្រឡារបស់ដីឡូត៍ ពុំអាចលើសពី៧៥%ឡើយ។ ចំពោះផ្ទះជាលំនៅឋាន ផ្ទៃបាតសំណង់នោះពុំអាចលើសពី៥០%នៃផ្ទៃក្រឡាដីឡូត៍ឡើយ។

ផ្ទៃក្រឡាដីឡូត៍ដែលនៅសល់ពីការសាងសង់ ត្រូវរៀបចំជាសួនដោយដីជ្រាបទឹកឱ្យបានយ៉ាងតិចពាក់កណ្តាលផ្ទៃក្រឡានេះ។ ចំពោះអគារដែលមានយ៉ាងតិច១៥លំនៅ សណ្ឋាគារ អគារការិយាល័យ និងអគារឧស្សាហកម្មផ្ទៃបាតសំណង់ពុំអាចលើសពី៥០%នៃផ្ទៃក្រឡាដីឡូត៍ឡើយ។

ផ្ទៃក្រឡាដែលនៅសល់ពីសំណង់ នឹងត្រូវរៀបចំជាសួនដោយដីជ្រាបទឹកឱ្យបានយ៉ាងតិចពាក់កណ្ដាលផ្ទៃក្រឡានេះ។ សាលាក្រុង និងសាលាខេត្តត្រូវកំណត់តំបន់រៀបចំក្រុងដែលត្រូវយកបទបញ្ជាខាងលើនេះមកអនុវត្ត ហើយនិងត្រូវកំណត់បទប្បញ្ញត្តិ ពិសេសចំពោះស្ថានភាពជាក់ស្ដែង។

**មាត្រា៣៦ ប្លង់កម្ពស់**

សាលាក្រុង និងសាលាខេត្តនីមួយៗ នឹងលើកគម្រោងប្លង់កម្ពស់ក្នុងរយៈពេលមួយឆ្នាំក្រោយពីបានការអនុម័តលើអនុក្រឹត្យនេះរួច ដោយកំណត់ឱ្យតំបន់នីមួយៗនៃក្រុងនូវកម្ពស់អតិបរិមានៃសំណង់។

ប្លង់កម្ពស់នេះត្រូវគិតដល់៖

-កម្ពស់មធ្យមបច្ចុប្បន្នតាមសង្កាត់នីមួយៗ។

-លក្ខណៈសំខាន់នៃតំបន់ (ពាណិជ្ជកម្ម លំនៅឋាន ឧស្សាហកម្មនៅកណ្ដាលក្រុង ឬជាយក្រុង ដីចាក់បំពេញ ឬអត់ការប្រើប្រាស់ ទាក់ទងទៅនឹងហេដ្ឋារចនាសម្ព័ន្ធ។ល។)។

-ប្រភេទនៃសំណង់ (ផ្ទះល្វែង ភូមិគ្រឹះ គ្រឹះស្ថាន ឃ្លាំងស្តុកទំនិញ និងអគារឧស្សាហកម្ម...។ល។)។

-ប្លង់កម្ពស់នេះត្រូវបានទទួលការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ហើយផ្សព្វផ្សាយជាសាធារណៈ។

**មាត្រា៣៧ ការការពារប្រាង្គប្រាសាទ និងទេសភាព**

សាលាក្រុង និងសាលាខេត្តនីមួយៗ អាចកំណត់កម្ពស់អតិបរិមាទាបជាងកម្ពស់អតិបរមាក្នុង "ប្លង់កម្ពស់" ដើម្បីការពារបូជនីយស្ថានប្រវត្តិសាស្ត្រ រមណីយដ្ឋានធម្មជាតិ ក៏ដូចជាកន្លែងនៅជិតៗប្រាង្គប្រាសាទ ប្រវត្តិសាស្ត្រ ឬដើម្បីរក្សាទុកនូវទស្សនវិស័យនៃប្រាង្គប្រាសាទ និងទស្សនវិស័យដ៏ស្ដឹមស្ដៃ។

ការបន្ថយកម្ពស់នេះនឹងត្រូវផ្សព្វផ្សាយជាសាធារណៈ និងប្រាប់ដល់អ្នកសុំលិខិតអនុញ្ញាតសាងសង់មុនពេលដាក់សំណុំលិខិតស្នើសុំ។

**ជំពូក៣ ទិដ្ឋភាពនៃសំណង់**

**មាត្រា៣៨**

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ បើសំណង់ដែលគ្រោងនោះមានទីតាំង ស្ថាបត្យកម្ម (Architecture) ទំហំ ឬទិដ្ឋភាពក្រៅអាចនាំឱ្យប៉ះពាល់ដល់លក្ខណៈ ឬផលប្រយោជន៍ របស់ទីតាំងនៅជុំវិញ ប៉ះពាល់ដល់ទេសភាពធម្មជាតិ ឬទីក្រុងភាពស្ងប់របស់ទីសក្ការបូជា រមណីយដ្ឋាន ប្រវត្តិសាស្ត្រ ឬបូរាណសាស្ត្រ រាជវាំង និងរាជប្រាង្គប្រាសាទ។

មាត្រា៣៩

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើង បើលក្ខណៈសំណង់នោះមិនធានាសុខុមាលភាពបន្ទប់ស្នាក់នៅ ឬបន្ទប់ធ្វើការនីមួយៗត្រូវឱ្យមានខ្យល់ចេញចូល ហើយត្រូវមានបង្អួចមួយយ៉ាងតិច។ ផ្ទៃក្រឡាបញ្ចូលពន្លឺថ្ងៃសម្រាប់បន្ទប់នីមួយៗ ត្រូវមានយ៉ាងតិច១,៥០ម$^{២}$។

មាត្រា៤០

បណ្តាសំណង់ឧស្សាហកម្មអាចតម្រូវឱ្យគោរពល័ក្ខខ័ណ្ឌពិសេសចំពោះការរៀបចំ ឬការបោះទីតាំង ដើម្បីធានាការបញ្ចូលឱ្យបានល្អទៅក្នុងទេសភាព និងរមណីយដ្ឋានធម្មជាតិ ឬទីក្រុង។

មាត្រា៤១

នៅតាមឆ្នេរសមុទ្រ តាមមាត់បឹង ស្ទឹង និងទន្លេ លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ បើសំណង់នោះធ្វើឱ្យខូចនូវសោភ័ណភាពរបស់ទេសភាព និងរមណីយដ្ឋាន ដោយសារទិដ្ឋភាព ឬកម្ពស់របស់សំណង់ បើមើលពីមាត់ឆ្នេរ ពីមាត់ច្រាំង ពីសមុទ្រ ស្ទឹង ទន្លេ ឬបឹងបួ និងប៉ះពាល់ដល់គុណភាពទឹក។

**ជំពូក៤ សន្ទភាព (ដង់ស៊ីតេ)៖ កម្រិតស្របច្បាប់នៃសន្ទស្សន៍ប្រើប្រាស់**

មាត្រា៤២

ការស្ថាបនាសំណង់មួយមានសន្ទភាព លើសពីកម្រិតអតិបរមាស្របច្បាប់ តម្រូវឱ្យអ្នកទទួលលិខិតអនុញ្ញាតសាងសង់ បង់ប្រាក់ស្មើនឹងតម្លៃដែលដីដែលចាំបាច់ ដើម្បីឱ្យ "សន្ទស្សន៍ប្រើប្រាស់" សំណង់មិនលើសពីកម្រិតនេះ។

មាត្រា៤៣

"សន្ទស្សន៍ប្រើប្រាស់" ត្រូវបានកំណត់ដោយអនុបាតរវាងផ្ទៃក្រឡាកម្រាលសរុបជាផ្លូវការ (Hors oeuvre nette) នៃសំណង់នោះ និងផ្ទៃក្រឡាដីដែលសំណង់នោះនឹងត្រូវ ឬបានតាំង

នៅលើ។ កាលណាសំណង់ថ្មីមួយ បានត្រូវសាងសង់លើដីមួយកន្លែងដែលមានអគារចាស់មួយ ឬច្រើន ហើយគ្មានគម្រោងរុះរើពេលនោះទេ សន្ទភាពត្រូវគណនាដោយថែមផ្ទៃក្រឡានៃសំណង់ចាស់ ទៅលើផ្ទៃក្រឡាកម្រាលនៃសំណង់ថ្មី។

**មាត្រា៤៤**

កម្រិតអតិបរមាស្របច្បាប់នៃសន្ទស្សន៍ប្រើប្រាស់ត្រូវកំណត់ដល់ (១) សម្រាប់ទូទាំងដែនដីក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤៥**

ការផ្តល់លិខិតអនុញ្ញាតសាងសង់ នាំមកឱ្យអ្នកបានទទួលលិខិតអនុញ្ញាតសាងសង់នូវកាតព្វកិច្ចឱ្យបង់ប្រាក់នោះ។ ការបង់ប្រាក់ត្រូវធ្វើជាបីភាគស្មើគ្នា ភាគទី១នៅពេលបានទទួលលិខិតអនុញ្ញាតសាងសង់ភាគទី២នៅពេលបើកការដ្ឋាន ភាគទី៣នៅពេលបញ្ចប់សំណង់។

**មាត្រា៤៦**

តម្លៃដីសម្រាប់ការគណនាចំនួនទឹកប្រាក់ដែលត្រូវបង់ ត្រូវបានកំណត់ដោយក្រសួងហិរញ្ញវត្ថុ។

**មាត្រា៤៧**

កម្រិតស្របច្បាប់នៃ "សន្ទស្សន៍ប្រើប្រាស់" ពុំត្រូវអនុវត្តឡើយ ចំពោះសំណង់ដែលពុំត្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ ចំពោះគ្រឹះស្ថានសាធារណៈ និងចំពោះអគាររដ្ឋបាលសាធារណៈ សម្រាប់បម្រើផ្ទាល់មុខ ជាកន្លែងធ្វើការសម្រាប់ស្ថាប័នសាធារណៈ។

នាយករដ្ឋមន្ត្រី អាចសម្រេចលើកលែងការអនុវត្តកម្រិតស្របច្បាប់នៃ "សន្ទស្សន៍ប្រើប្រាស់" ចំពោះបណ្តាតំបន់រៀបចំពិសេស បន្ទាប់ពីបានយោបល់ពីគណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់។

"វាសនដ្ឋានសង្គម" ទាំងឡាយអាចទទួលនូវការលើកលែងមិនឱ្យបង់ពន្ធអាករ តាមសេចក្តីសម្រេចរបស់អភិបាលខេត្ត-ក្រុង បន្ទាប់ពីបានទទួលការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់។

**ជំពូក៥ បទបញ្ញាពិសេសសម្រាប់អនុវត្តលើភាគខ្លះនៃដែនដី**

*វាយឡើងវិញ*

**មាត្រា៤៨**

ជាការបន្ថែមដល់បទបញ្ជាទូទៅនៃការប្រើប្រាស់ដីធ្លី ការណែនាំមួយចំនួនសម្រាប់ការរៀបចំតំបន់ និងបទបញ្ជានគរូបនីយកម្មពិសេសមួយចំនួន អាចត្រូវតាក់តែងឡើងដោយអនុក្រឹត្យ ដែលអាចមានរហូតដល់ការហាមមិនឱ្យសាងសង់នៅក្នុង "តំបន់ចាប់អារម្មណ៍" ដូចជា ឆ្នេរសមុទ្រ មាត់ច្រាំងទន្លេ និងបឹងធំៗ។ រាល់ឯកសារ "នគរូបនីយកម្មមូលដ្ឋាន" និងប្លង់ខេត្តនៃតំបន់ហាមមិនឱ្យមានសំណង់ ដែលចែងក្នុងមាត្រា៣២ វគ្គទី២នៃអនុក្រឹត្យនេះត្រូវទុកជាការណែនាំទាំងនេះ និងការហាមជាយថាហេតុមិនឱ្យសាងសង់។

**មាត្រា៤៩**

បទប្បញ្ញត្តិទាំងឡាយមានពីមុនដែលផ្ទុយនឹងអនុក្រឹត្យនេះចាត់ទុកជានិរាករណ៍។

**មាត្រា៥០**

ទេសរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌ និងវិចិត្រសិល្បៈ រៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង អភិបាលខេត្ត សមាជិកគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមតួនាទីចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧

**នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២**

**ហត្ថលេខា និងត្រា**

**អ៊ឹង ហួត ហ៊ុន សែន**

<u>កន្លែងទទួល</u>

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យឯកឧត្តមនាយករដ្ឋមន្ត្រីទី១

-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រីទី២

-ដូចមាត្រា២០

-ឯកសារ-កាលប្បវត្តិ

*វាយឡើងវិញ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាល
លេខ៣០បប

## បទបញ្ជា
## ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

ចំពោះ

-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង

-ឯកឧត្តមរដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន

-ឯកឧត្តមប្រធានគ្រប់ស្ថាប័ន

-ឯកឧត្តមតំណាងប្រតិភូរាជរដ្ឋាភិបាល និងអភិបាលគ្រប់ខេត្ត-ក្រុង

-ដោយច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋកំពុងតែត្រូវបានរៀបចំ និងកែសម្រួលឡើងវិញ ដើម្បីដាក់ជូនសភាអនុម័តនាពេលខាងមុខ

-ដោយពិនិត្យឃើញមានការអនុវត្តខុសឆ្គងខ្លះក្នុងការគ្រប់គ្រង និងចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋដែលឋិតនៅក្រោមការគ្រប់គ្រងរបស់បណ្តាក្រសួង-ស្ថាប័ន និងខេត្ត-ក្រុង

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាដាក់ចេញនូវបទបញ្ជានេះ សម្រាប់អនុវត្តចំពោះមុខរហូតដល់ច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋត្រូវបានប្រកាសឱ្យប្រើជាផ្លូវការ។

១-ការប្រគល់ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ រាល់ទ្រព្យសម្បត្តិរដ្ឋទាំងឡាយដែលកំពុងឋិតនៅក្រោមការគ្រប់គ្រង ថែរក្សា និងប្រើប្រាស់របស់ក្រសួង ខេត្ត-ក្រុង សហគ្រាសសាធារណៈ ឬស្ថាប័នផ្សេងៗដែលហៅថាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ គឺជាកម្មសិទ្ធិរបស់រដ្ឋ។ រដ្ឋប្រគល់តែសិទ្ធិប្រើប្រាស់ គ្រប់គ្រង និងថែរក្សាតែប៉ុណ្ណោះ ហើយសិទ្ធិនេះអាចហូតយកវិញពេលណាក៏បាន។ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ គ្មានសិទ្ធិប្រគល់កម្មសិទ្ធិលក់ ជួល ផ្ទេរ ដោយមិនគោរពតាមបែបបទដូចមានចែងក្នុងបទបញ្ជានេះឡើយ។

២-ការធ្វើសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិរដ្ឋ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទទួលខុសត្រូវធ្វើឱ្យបានសម្រេចនូវបញ្ជីសារពើភ័ណ្ឌប្រចាំឆ្នាំនៃទ្រព្យសម្បត្តិរដ្ឋឱ្យបានត្រឹមត្រូវ ។ បញ្ជីសារពើភ័ណ្ឌនេះត្រូវមានជាអាទិ៍ ការកត់សម្គាល់ឈ្មោះអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ប្រភេទ និងលក្ខណៈសំខាន់ៗ ព្រមទាំងទីតាំងភូមិសាស្ត្រនៃទ្រព្យសម្បត្តិទាំងនោះ ។

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវសហការធ្វើឱ្យបានសម្រេចនូវបញ្ជីសារពើភ័ណ្ឌនេះ ហើយត្រូវស្រង់បញ្ជីទ្រព្យសម្បត្តិទាំងនោះ តាមគំរូដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបញ្ជូនមកឱ្យ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវផ្ញើបញ្ជីសារពើភ័ណ្ឌប្រចាំឆ្នាំរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋជូនទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីពិនិត្យ និងបញ្ជាក់ ។

៣-ការលក់ទ្រព្យសម្បត្តិរដ្ឋ

ការលក់ ជួល ដោះដូរ ត្រូវហាមជាដាច់ខាតចំពោះចលនទ្រព្យ និងអចលនទ្រព្យដែលមានលក្ខណៈជាបេតិកភណ្ឌវប្បធម៌ជាតិ ហើយដែលបានទទួលការការពារដោយព្រះរាជក្រមលេខ ០១៨៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ។

ដោយរក្សាទុកនូវបទប្បញ្ញត្តិខាងដើម ការលក់ទ្រព្យសម្បត្តិរដ្ឋនឹងអាចធ្វើបានតែល័ក្ខខ័ណ្ឌដូចមានកំណត់ខាងក្រោមនេះ៖

៣.១-ការអនុញ្ញាតឱ្យលក់

1-ការលក់អចលនទ្រព្យត្រូវអនុញ្ញាតដោយសេចក្តីសម្រេចរបស់៖

-នាយករដ្ឋមន្ត្រី តាមសំណើរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ឬទីស្តីការគណៈរដ្ឋមន្ត្រីចំពោះការលក់ទ្រព្យសម្បត្តិរដ្ឋដែលមានតម្លៃទាបជាង ឬស្មើ១.០០០លានរៀល ។

-គណៈរដ្ឋមន្ត្រី តាមសំណើរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ឬទីស្តីការគណៈរដ្ឋមន្ត្រី ចំពោះការលក់ទ្រព្យសម្បត្តិរដ្ឋដែលមានតម្លៃលើសពី ១.០០០លានរៀល ។

2-ការលក់ចលនទ្រព្យ ត្រូវបានស្នើឡើងដោយអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋនេះ ហើយអនុវត្តទៅតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៣.២-បែបបទនៃការលក់

ការលក់ទ្រព្យសម្បត្តិរដ្ឋ ត្រូវប្រព្រឹត្តទៅតាមនីតិវិធីដេញថ្លៃ ។

1-ការដេញថ្លៃនេះ អាចនឹងចាត់ចែងតាមទម្រង់៖

-ដេញថ្លៃជាលក្ខណៈអន្តរជាតិ ឬលក្ខណៈជាតិ ដោយចំហ

-ការពិគ្រោះថ្លៃជាលក្ខណៈអន្តរជាតិ ឬលក្ខណៈជាតិ

-ការដេញថ្លៃលក់ជាសាធារណៈដោយផ្ទាល់មាត់។

2-ការលក់អាចប្រព្រឹត្តតាមវិធីចរចាដោយមិនបាច់ដេញថ្លៃ ចំពោះករណីដូចតទៅ៖

-ការដេញថ្លៃជាសាធារណៈពុំបានលទ្ធផល

-ទ្រព្យនេះជាវត្ថុចាំបាច់ ដើម្បីបំពេញបេសកកម្មណាមួយជាសេវាសាធារណៈ ឬដើម្បីបម្រើផលប្រយោជន៍រួម។

-ការលក់ទ្រព្យសម្បត្តិនេះជាល័ក្ខខ័ណ្ឌចាំបាច់តម្រូវឱ្យអ្នកទិញទទួលទិញយក។

-លក្ខណៈពិសេសនៃទ្រព្យសម្បត្តិនេះ តម្រូវឱ្យអ្នកទទួលទិញមានគុណសម្បត្តិសមស្របតាមលក្ខណៈពិសេសនេះ។

-ចំនួនទឹកប្រាក់នៃការលក់នេះមិនលើសពីទឹកប្រាក់ដែលបានកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

3-កសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវរៀបចំបែបបទ និងបទបញ្ជាផ្សេងៗនៃការដាក់ឱ្យអនុវត្តការដេញថ្លៃ

4-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ឬគណៈកម្មការចំពោះកិច្ចមានភារកិច្ចរួមគ្នាចាត់ចែងការដេញថ្លៃអចលនទ្រព្យនេះ។

5-អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋមានភារៈចាត់ចែងការដេញថ្លៃលក់ចលនទ្រព្យ។

6-ឯកសារនៃការដេញថ្លៃ ត្រូវរៀបចំដោយអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ហើយត្រូវបានទទួលការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការបើកលទ្ធផលដេញថ្លៃ និងការវាយតម្លៃ ត្រូវធ្វើឡើងដោយគណៈកម្មការមួយដែលតែងតាំងដោយអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋនោះ ហើយត្រូវមានតំណាងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងទីស្តីការគណៈរដ្ឋមន្ត្រីចូលរួម។

៣.៣-ទម្រង់បែបបទនៃការលក់

លិខិតលក់អចលនទ្រព្យត្រូវចុះហត្ថលេខាដោយអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងដោយរដ្ឋមន្ត្រីផ្សេងទៀតដែលមានបទប្បញ្ញត្តិ និងលិខិតបទដ្ឋានប្រគល់សិទ្ធិពីរាជរដ្ឋាភិបាលឱ្យចុះហត្ថលេខាលើលិខិតលក់នេះដែរ។ អ្នកទទួលទិញត្រូវយកលិខិតនេះទៅអង្គភាពពាក់ព័ន្ធដើម្បីធ្វើកម្មសិទ្ធិ។ សោហ៊ុយទាំងអស់ជាបន្ទុករបស់អ្នកទទួលទិញ។

លិខិតនៃការលក់ចលនទ្រព្យដែលមានក្នុងបញ្ជីអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចុះហត្ថលេខាដោយអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ និងត្រូវជូនព័ត៌មានពីការលក់នេះ ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

លិខិតណាដែលមិនឆ្លើយតបទៅនឹងនីតិវិធីដូចមានចែងខាងលើ ក្រោយបទបញ្ជានេះចូលជាធរមាន ត្រូវចាត់ទុកជាមោឃៈ។

៣.៤-ចំណូលបានមកពីការលក់

ចំណូលនៃការលក់ទ្រព្យសម្បត្តិរដ្ឋ ត្រូវចាត់ទុកជាចំណូលថវិការដ្ឋក្នុងខ្ទង់ចំណូលជាមូលធន។

ការជម្រះបញ្ជី និងការប្រមូលចំណូលបានមកពីការលក់នេះ ត្រូវអនុវត្តតាមបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ហិរញ្ញវត្ថុ និងប្រព័ន្ធថវិការបស់រដ្ឋ មានន័យថាចំណូលត្រូវបង់ចូលគណនីរបស់រតនាគារ។

៤-ឯកជនភាវូបនីយកម្ម

ការលក់ សម្បទាន ឬការជួលសហគ្រាសសាធារណៈក្នុងក្របខ័ណ្ឌឯកជនភាវូបនីយកម្ម ត្រូវប្រព្រឹត្តទៅស្របតាមបទប្បញ្ញត្តិនៃជំពូក៤នៃព្រះរាជក្រមលេខ០១១/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ស្តីពីច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ព្រមទាំងបទប្បញ្ញត្តិដទៃទៀតស្តីពីការអនុវត្តព្រះរាជក្រមនេះ។

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវតែគោរពតាមនីតិវិធីដែលកំណត់ដោយបទប្បញ្ញត្តិខាងលើ។

៥-ការប្រើប្រាស់ ការកាន់កាប់ និងការធ្វើអាជីវកម្មឯកជននៃទ្រព្យសម្បត្តិរដ្ឋ

៥.១-សម្បទានសម្រាប់សេវាសាធារណៈ ឬសម្បទានសម្រាប់សាធារណការ

សម្បទានិកសេវាសាធារណៈ ឬសម្បទានិកសាធារណការអាចទទួលសិទ្ធិប្រើប្រាស់កាន់កាប់ និងធ្វើអាជីវកម្មទ្រព្យសម្បត្តិរដ្ឋ។

សិទ្ធិនេះកើតចេញពីកិច្ចសន្យាផ្តល់សម្បទាន ឬលិខិតគតិយុត្តផ្សេងមួយដោយឡែក។ កិច្ចសន្យា ឬលិខិតគតិយុត្តនេះ ត្រូវមានការអនុម័តយល់ព្រមពីអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ និងពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ពេលចប់សម្បទាន ទ្រព្យសម្បត្តិរដ្ឋដែលពាក់ព័ន្ធត្រូវប្រគល់ត្រលប់ជូនរដ្ឋវិញ។

៥.២-ការអនុញ្ញាតឱ្យប្រើប្រាស់ ឬកាន់កាប់ជាអាជីវកម្ម ឬមិនអាជីវកម្ម អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋអាចអនុញ្ញាតឱ្យគិតកម្រៃ ឬពុំគិតកម្រៃពីតតិយជនណាដែលយកទ្រព្យសម្បត្តិ

នោះទៅធ្វើអាជីវកម្ម ឬមិនធ្វើអាជីវកម្ម ។ តែការអនុញ្ញាតទាំងនេះ ត្រូវគោរពតាមបទប្បញ្ញត្តិ ឬបទបញ្ជាទាំងឡាយពាក់ព័ន្ធនឹងកម្មវត្ថុនេះ ។

ប្រការខាងលើនេះត្រូវអនុវត្តចំពោះ៖

-សិទ្ធិប្រើប្រាស់ផ្លូវ ស្ពាន ចំណត

-អាករដែលបានមកពីអ្នកប្រកបមុខរបរ (អ្នកដឹកជញ្ជូនជាសាធារណៈ អ្នកលក់ដូរចល័ត ។ល ។)

-អនុញ្ញាតឱ្យប្រើប្រាស់លើផ្លូវសាធារណៈ និងអ្វីដែលចំណុះឱ្យផ្លូវទាំងនោះ ដែលបានយល់ព្រមឱ្យប្រើប្រាស់ជាឯកជន៖ ការសង់តូបលក់ដូរ ឬស្ថានីយសេវាកម្ម ការតាំងផ្លាកផ្សព្វផ្សាយដំណឹង ។ល ។

ការអនុញ្ញាតនេះត្រូវចែងនៅក្នុងសៀវភៅបន្ទុក និងត្រូវបង់ពន្ធអាករផង ។

ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពន្ធអាករត្រូវបានអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋប្រមូលដោយផ្ទាល់ ប្រសិនបើអាជ្ញាធរនោះមានស្វ័យភាពថវិកា ។ ក្នុងករណីផ្ទុយពីនេះ ពន្ធអាករនោះត្រូវបង់ចូលថវិការដ្ឋ ។

៥.៣-ការអនុញ្ញាតឱ្យជួល ឬសម្បទាន

ក-ការអនុញ្ញាតឱ្យជួល ឬសម្បទាន

-ការជួល ឬសម្បទាន អាជីវកម្មព្រៃឈើ រ៉ែ អាកាសយានដ្ឋាន កំពង់ផែ បណ្តាញទូរគមនាគមន៍ អយស្ម័យយាន និងសម្បទានដី ត្រូវមានគោលការណ៍ពីរ៖

+នាយករដ្ឋមន្ត្រី តាមសំណើរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ឬទីស្តីការគណៈរដ្ឋមន្ត្រី ចំពោះការជួលអចលនទ្រព្យដែលមានតម្លៃប្រចាំឆ្នាំទាបជាង ឬស្មើនឹង៣០០លានរៀល

+គណៈរដ្ឋមន្ត្រី តាមសំណើរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ឬទីស្តីការគណៈរដ្ឋមន្ត្រី ចំពោះការជួលអចលនទ្រព្យដែលមានតម្លៃប្រចាំឆ្នាំខ្ពស់ជាង៣០០លានរៀល ។

-ការជួល ឬសម្បទានផ្សេងៗទៀត ហើយជាអាទិ៍ការជួល ឬសម្បទានដែលទាក់ទងទៅនឹងអាជីវកម្មឡូត៍នេសាទ កំពង់ចម្លង ផ្សារសាធារណៈ ចំណតរថយន្ត ។ល ។ ត្រូវមានសេចក្តីសម្រេចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ប្រការទាំងឡាយដូចមានចែងខាងលើនេះ មិនមានអានុភាពលើបទប្បញ្ញត្តិនៃអនុក្រឹត្យ ឬលើសេចក្តីសម្រេចណាមួយ ដែលចែងអំពីភារកិច្ចរបស់គណៈកម្មការចំពោះកិច្ចនានា ដែលតែងតាំងដោយរាជរដ្ឋាភិបាល។ ក៏ប៉ុន្តែ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវតែចូលរួមក្នុងគ្រប់ករណីនៃការសម្រេចជួល ឬសម្បទាននេះ។

ខ-បែបបទនៃការជួល ឬសម្បទាន

សម្បទាន ឬការដាក់ឱ្យជួលទ្រព្យសម្បត្តិរដ្ឋ ត្រូវធ្វើឡើងតាមរយៈការដេញថ្លៃ។

1-ការដេញថ្លៃនេះអាចនឹងចាត់ចែងតាមទម្រង់៖

-ដេញថ្លៃជាលក្ខណៈអន្តរជាតិ ឬលក្ខណៈជាតិដោយចំហ

-ការពិគ្រោះជាលក្ខណៈអន្តរជាតិ ឬលក្ខណៈជាតិ

-ការដេញថ្លៃជាសាធារណៈដោយផ្ទាល់មាត់

2-សម្បទាន ឬការជួលអាចប្រព្រឹត្តតាមវិធីចរចាដោយមិនបាច់ដេញថ្លៃ ចំពោះករណីណាមួយដូចតទៅ៖

- ការដេញថ្លៃជាសាធារណៈពុំបានលទ្ធផល។

-ទ្រព្យនេះជាវត្ថុចាំបាច់ដើម្បីបំពេញបេសកកម្មណាមួយជាសេវាសាធារណៈ ឬដើម្បីបម្រើផលប្រយោជន៍រួម។

-ការជួលទ្រព្យសម្បត្តិនេះជាល័ក្ខខ័ណ្ឌចាំបាច់តម្រូវឱ្យអ្នកជួល ឬសម្បទានិកទទួលយក។

-លក្ខណៈពិសេសនៃទ្រព្យសម្បត្តិនេះ តម្រូវឱ្យអ្នកទទួលជួល ឬសម្បទានមានគុណសម្បត្តិសមស្របតាមនឹងលក្ខណៈពិសេសនេះ។

-ចំនួនទឹកប្រាក់កម្រៃ ឬថ្លៃឈ្នួលមិនលើសពីទឹកប្រាក់ដែលបានកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

3-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវរៀបចំបែបបទ និងបទបញ្ជាផ្សេងៗនៃការដេញថ្លៃ។

4-អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋមានភារកិច្ចចាត់ចែងការដេញថ្លៃ។ ឯកសារដេញថ្លៃត្រូវរៀបចំដោយអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ហើយត្រូវបានយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការបើកលទ្ធផលដេញថ្លៃ និងការវាយតម្លៃ ត្រូវប្រតិបត្តិដោយគណៈកម្មការមួយដែលតែងតាំង ដោយអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ហើយត្រូវមានតំណាងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងតំណាងទីស្តីការគណៈរដ្ឋមន្ត្រីចូលរួម។

គ-លិខិតនៃការជួល ឬសម្បទានលិខិតនៃការជួល ឬសម្បទានអចលនទ្រព្យរបស់រដ្ឋ ត្រូវចុះហត្ថលេខាដោយអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ និងដោយរដ្ឋមន្ត្រីផ្សេងទៀតដែលមានបទប្បញ្ញត្តិ និងលិខិតបទដ្ឋានប្រគល់សិទ្ធិពីរាជរដ្ឋាភិបាលឱ្យចុះហត្ថលេខាលើលិខិត នៃការជួល ឬសម្បទានអចលនទ្រព្យនេះដែរ ហើយត្រូវបញ្ជាក់ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

លិខិតនៃការជួល ឬសម្បទានចលនទ្រព្យរបស់រដ្ឋ ដែលមានក្នុងបញ្ជីអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចុះហត្ថលេខាដោយអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ហើយត្រូវបញ្ជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពីការជួលនេះ ដើម្បីជាព័ត៌មានសម្រាប់តាមដាន។

លិខិតណាដែលមិនឆ្លើយតបទៅនឹងបទប្បញ្ញត្តិដូចមានចែងខាងលើ ក្រោយពីបទបញ្ជានេះចូលជាធរមានត្រូវទុកជាមោឃៈ។

ឃ-ចំណូលបានមកពីការជួល ឬសម្បទាន

ប្រាក់កម្រៃ ឬប្រាក់ថ្លៃឈ្នួលបានមកពីការជួល ឬសម្បទានទ្រព្យសម្បត្តិរដ្ឋ ត្រូវចាត់ទុកជាចំណូលថវិការដ្ឋក្នុងខ្ទង់ចំណូលទ្រព្យរដ្ឋ។

ការជម្រះបញ្ជី និងការប្រមូលចំណូលបានមកពីការជួលនេះត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងច្បាប់ហិរញ្ញវត្ថុ និងប្រព័ន្ធថវិការដ្ឋ។

ប្រសិនបើអត្ថបទច្បាប់ ឬបទប្បញ្ញត្តិអនុញ្ញាតឱ្យអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋអាចនឹងប្រមូលចំណូលដោយផ្ទាល់ ក្នុងករណីផ្ទុយពីនេះ ចំណូលត្រូវបង់ចូលក្នុងថវិការដ្ឋ។

៥.៤-លំនៅឋានសម្រាប់មន្ត្រីរាជការ

មន្ត្រីរាជការក្នុងឋានៈជាអ្នកបម្រើសេវាសាធារណៈ អាចត្រូវអនុញ្ញាតឱ្យស្នាក់នៅក្នុងគេហដ្ឋាន ដែលជាទ្រព្យសម្បត្តិរដ្ឋ។

គេហដ្ឋានដែលជាទ្រព្យសម្បត្តិរដ្ឋនេះនឹងត្រូវដកហូតយកវិញ នៅពេលចប់ពីតំណែង។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវរៀបចំបែបបទ និងល័ក្ខខ័ណ្ឌនៃការអនុញ្ញាតស្នាក់នៅនេះ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**នាយកដ្ឋានសុរិយោដី**

លេខ២៥៩សដ

## សេចក្តីណែនាំបន្ថែមអំពីកិច្ចការជំនាញ

ឆ្លងតាមការងារចុះធ្វើអធិការកិច្ចដល់មូលដ្ឋាន ការទទួលពាក្យបណ្តឹងស្តីពីទំនាស់ដីធ្លី និងការកសាងឯកសារដែលបណ្តាលអង្គភាពជំនាញបញ្ជូនមក នាយកដ្ឋានបានឃើញចំណុចដែលចាំបាច់ត្រូវពង្រឹងបន្ថែមដូចតទៅ៖

**I-អំពីការងារជំនាញ**

**១-អំពីកំណត់ហេតុអង្កេត**

ក-ធម្មតាមានពីរច្បាប់ដែលចាំបាច់ត្រូវសរសេរឱ្យដូចបោះពុម្ពគឺអក្សរដៃតែមួយ ប៊ិចសរសេរពណ៌តែមួយ សរសេរពេលតែមួយ ជួរបន្ទាត់តែមួយ បើមានលុបកែ ក៏ត្រូវធ្វើឱ្យដូចគ្នា។ ប៉ុន្តែ កន្លងមកធ្វើមិនទាន់បាន សូម្បីតែឈ្មោះអ្នកកាន់កាប់ ឬឈ្មោះសហព័ទ្ធក៏មានឈ្មោះខុសគ្នា អាយុ ឬឆ្នាំកំណើតសរសេរខុសគ្នា គិតលេខរកអាយុមិនបានត្រឹមត្រូវ ឈ្មោះភូមិ ឃុំ នៃទីតាំងដីក៏នៅតែសរសេរខុស។

បញ្ហាទ្រព្យសម្បត្តិ មន្ត្រីចុះអង្កេតត្រូវសាកសួរសាមីអ្នកកាន់កាប់ឱ្យច្បាស់អំពីប្រភព នៃទ្រព្យបានមកពីណា ដោយហេតុអ្វី? ពីពេលណាមក?

អំពីសាវតារត្រូវបំពេញឱ្យគ្រប់ចំណុចទាំងប្តី ទាំងប្រពន្ធ (លើកលែងអ្នកកាន់កាប់នៅលីវ) ទោះបីជាទ្រព្យផ្ទាល់របស់ប្តី ឬរបស់ប្រពន្ធ ហើយសហព័ទ្ធម្នាក់ស្លាប់ពីពេលណាក៏ដោយ (ត្រូវសរសេរតាមចាំ) ត្រង់ចំណុចនេះអាចមានពីរករណីខុសគ្នា៖

-ប្រសិនបើសាមីអ្នកកាន់កាប់ជាម្ចាស់ទ្រព្យផ្ទាល់ ឬទាំងពីរនាក់ប្រពន្ធជាម្ចាស់ទ្រព្យរួម (ករណីទ្រព្យរួម) ហើយមានអត្តសញ្ញាណប័ណ្ណពលរដ្ឋ យើងអាចចម្លងយកតាមខ្លឹមសារក្នុងអត្ត-សញ្ញាណប័ណ្ណតែម្តង ឯសាវតារសហព័ទ្ធម្ខាងទៀតក៏ត្រូវបំពេញដែរ លើកលែងតែចំណុចណាមិនចាំ

-ប្រសិនបើសាមី អ្នកកាន់កាប់ម្នាក់ជាម្ចាស់ទ្រព្យ ឬទាំងពីរនាក់ប្តីប្រពន្ធជាម្ចាស់ទ្រព្យរួមហើយពុំមានអត្តសញ្ញាណពលរដ្ឋទេ សាវតារត្រូវបំពេញទៅតាមចម្លើយនៃអ្នកកាន់កាប់ គួបផ្សំនឹងឯកសារ លិខិតស្នាមពាក់ព័ន្ធខ្លះទៀតដែលមានដូចជា លិខិតសម្គាល់ជាមន្ត្រី តាមក្រសួងស្ថាប័ននានា សំបុត្រកំណើត លិខិតឆ្លងដែនបើមាន ឬសំណុំលិខិតដែលពាក់ព័ន្ធដល់បុគ្គលនោះ ព្រមទាំងប័ណ្ណគ្រួសារ បញ្ជីជំរឿនផ្សេងៗទៀត។

ដោយឡែក ចំពោះទីលំនៅបច្ចុប្បន្ន មិនអាចយកតាមអត្តសញ្ញាណប័ណ្ណ (លំនៅអចិន្ត្រៃយ៍) តែម្តងទេ ព្រោះវាអាចមានពីរករណីខុសគ្នា៖

i-អាចយកតាមលំនៅអចិន្ត្រៃយ៍ដែលមាននៅក្នុងអត្តសញ្ញាណប័ណ្ណបាន ប្រសិនបើក្រោយពីធ្វើអត្តសញ្ញាណប័ណ្ណរួច ប្តីប្រពន្ធទាំងពីរនាក់មិនបានផ្លាស់ប្តូរលំនៅទេ។

ii-មិនអាចយកតាមលំនៅអចិន្ត្រៃយ៍ដែលមានក្នុងអត្តសញ្ញាណប័ណ្ណបាន ប្រសិនបើក្រោយពេលធ្វើអត្តសញ្ញាណប័ណ្ណរួចមាននរណាម្នាក់ ឬទាំងពីរនាក់ប្តីប្រពន្ធបានផ្លាស់ប្តូរទីលំនៅ មានន័យថា យើងចង់បានទីលំនៅ ដែលប្តី និងប្រពន្ធកំពុងតែរួមរស់នៅជាមួយគ្នា សព្វថ្ងៃជាក់ស្តែង (ពេលធ្វើកំណត់ហេតុ) ព្រោះវាមានប្រយោជន៍ចំពោះយើង ពេលដែលចង់ឱ្យអ្នកកាន់កាប់ផ្តល់ព័ត៌មានពាក់ព័ន្ធនឹងក្បាលដីរបស់គេ ឬពេលដែលចង់ឱ្យសមត្ថកិច្ចបញ្ជាក់ពីសាវតាររបស់អ្នកកាន់កាប់ ឬពេលមានទំនាស់...។ល។ អាចមានករណីលើកលែង ឬទីលំនៅរបស់ប្តី និងប្រពន្ធអាចខុសគ្នា ប្រសិនជាមានសាលក្រមតុលាការអនុញ្ញាតឱ្យប្តីប្រពន្ធរស់នៅបែកគ្នាមួយរយៈ ឬសាលក្រមស្ថាពរសម្រេចឱ្យប្តី និងប្រពន្ធលែងលះគ្នា ឬប្រសិនបើមានសហព័ន្ធណាម្នាក់ស្លាប់ ឬបាត់ខ្លួន។

ដូចនេះ មន្ត្រីអ្នកធ្វើកំណត់ហេតុត្រូវតែសាកសួរសាមីអ្នកកាន់កាប់ដីឱ្យបានច្បាស់ មិនអាចសំអាងទៅលើអត្តសញ្ញាប័ណ្ណ ហើយស្រង់យកលំនៅអចិន្ត្រៃយ៍ក្នុងនោះតែម្តងទេ ព្រោះវាអាចខុសពីលំនៅសព្វថ្ងៃដែលប្តី និងប្រពន្ធកំពុងរួមរស់ជាមួយគ្នា។ ត្រង់ចំណុចនេះដែរ មន្ត្រីចុះអង្កេតត្រូវសួរបញ្ជាក់ដោយច្បាស់បំផុតអំពីកាលបរិច្ឆេទនៃការកាន់កាប់ដី ហើយកត់ត្រាឱ្យបានត្រឹមត្រូវ ចៀសវាងប្រៀបនឹងឆ្នាំកំណើតរបស់អ្នកកាន់កាប់ទៅ ឃើញអាយុអ្នកកាន់កាប់បានត្រឹម១០ ឬ ១១ឆ្នាំ ឬតិចជាងនេះ នោះមិនអាចមានលក្ខណៈគ្រប់គ្រាន់ក្នុងការប្រគល់សិទ្ធិឱ្យកាន់កាប់បានទេ។ ស្ត្រី ឬបុរសនៅលីវត្រូវមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ ទើបមានសិទ្ធិកាន់កាប់ដី (អចលន

វត្ថុ) បានតែចំពោះបុរស និងនារីដែលរៀបការរួច អាចអនុគ្រោះចំពោះនារីចាប់ពីអាយុ១៨ឆ្នាំឡើង និងបុរសចាប់ពីអាយុ១៧ឆ្នាំឡើងទៅ ទោះបីជាប្រភេទទ្រព្យផ្ទាល់ ឬទ្រព្យរួមប្ដី ប្រពន្ធក្ដី។ បើមានករណីពិសេសលើសពីនេះត្រូវអធិប្បាយឱ្យបានច្បាស់លាស់ថែមទៀត ដូចជាការធ្វើអត្តាធិនភាព ឬក្មេងកំព្រាជាដើម។

**ខ-អំពីការបញ្ជាក់របស់សមត្ថកិច្ច (អាជ្ញាធរ)**

ក្នុងករណីដែលអ្នកកាន់កាប់ផ្ទាល់ពុំមានអត្តសញ្ញាណប័ណ្ណពលរដ្ឋ ឬប្ដីប្រពន្ធ ទាំងពីរនាក់ពុំមានអត្តសញ្ញាណប័ណ្ណពលរដ្ឋ សាមីខ្លួនអ្នកស្នើសុំកសាងសំណុំរឿងកាន់កាប់ដីត្រូវរកសាក្សីពីរនាក់យ៉ាងតិចដែលអាយុចាប់ពី២៥ឆ្នាំឡើង ហើយដែលធ្លាប់ដឹងអំពីសាវតារខ្លួន ផ្ដិតមេដៃទទួលស្គាល់សាវតារក្នុងកំណត់ហេតុនេះថា ពិតជាត្រឹមត្រូវនៅចំពោះមុខមេឃុំ (ឬតំណាង) ដែលជាសមត្ថកិច្ចគ្រប់គ្រងពលរដ្ឋ ក្នុងរង្វង់ដែនដីរបស់គេ (បានន័យថាមេឃុំនៃកន្លែងដែលអ្នកស្នើសុំដីកំពុងរស់នៅ)។

**គ-អំពីចម្លើយអ្នកស្នើសុំ**

នាយកដ្ឋានឱ្យតាំងសំណួរបួនចំណុចជាចាំបាច់រួចមកហើយតាមការណែនាំពីមុន។ ឃ្លោងឃ្លានៅត្រង់នេះត្រូវសរសេរទៅតាមចម្លើយរបស់អ្នកស្នើសុំ (សំដីរបស់អ្នកស្នើសុំ) អ្នកធ្វើកំណត់ហេតុ មិនត្រូវស្រង់យកតែខ្លឹមសារហើយតែងឃ្លាក្នុងនាមខ្លួនឯងនោះទេ។ បួនចំណុចនៃសំណួរត្រូវតែមានចម្លើយគ្រប់ ទោះបីចម្លើយនោះអវិជ្ជមានក៏ដោយ។

**ឃ-អំពីព្រំប្រទល់ និងការវាស់វែង**

អ្នកជាប់ព្រំដីត្រូវតែផ្ដិតមេដៃ បើយល់ព្រម។ មិនអាចយកភ្លឺស្រែធំតូច ឬភ្លឺភ្លោះមកធ្វើជាព្រំបានទេ។ បើជាប់ដីអង្គភាពរដ្ឋ ឬដីសមូហភាពផ្សេងៗត្រូវមានតំណាងត្រឹមត្រូវ ផ្ដិតមេដៃទទួលស្គាល់ព្រំផង។ ការផ្ដិតមេដៃអ្នកជាប់ព្រំមិនចាំបាច់ ប្រសិនបើសាលក្រមតុលាការបានសម្រេចរួច ហើយគណៈកម្មការអនុវត្តសាលក្រមបានចុះពិនិត្យឃើញថាត្រឹមត្រូវហើយ (មានកំណត់ហេតុភ្ជាប់)។

អំពីគំនូសបង្ហាញទីតាំងត្រូវឱ្យច្បាស់ ហើយសមល្មមអាចមើលយល់ មានទិស មានគោលចារឹក (repère) មានឈ្មោះអ្នកជាប់ព្រំ។ ដីបម្រុងផ្លូវគោក ផ្លូវដែក ផ្លូវទឹក សមុទ្រត្រូវកត់

ចម្ងាយឱ្យច្បាស់លាស់។ អ្នធ្វើកំណត់ហេតុអង្កេត ឬវាស់វែងត្រូវចុះហត្ថលេខា និងចុះកាលបរិច្ឆេទត្រឹមត្រូវទៅតាមពេលវេលាដែលបានធ្វើ។

**ង-ការសន្និដ្ឋាន និងលើកយោបល់ស្នើឡើង**

អនុគណៈកម្មការត្រូវពិនិត្យពិចារណាឱ្យច្បាស់លាស់ត្រឹមត្រូវ សុចរិតអំពីស្ថានភាពនៃក្បាលដី និងការពាក់ព័ន្ធផ្សេងៗ ថាតើការលើកសំណើផ្តល់ ឬមិនផ្តល់ប័ណ្ណ វាអាចបណ្តាលឱ្យមានផលអាក្រក់ ឬល្អកើតឡើងយ៉ាងណាខ្លះ?

យោបល់សម្រេចរបស់សមត្ថកិច្ចត្រូវសរសេរឱ្យច្បាស់ ផ្តល់ប័ណ្ណឱ្យ ឬមិនផ្តល់ បើមិនផ្តល់ត្រូវបញ្ជាក់អំពីហេតុផល។ កំណត់ហេតុអង្កេតចាស់ដែលបាន ត្រូវវាយការណ៍ជាលិខិតស្នាមបញ្ជាក់អំពីមូលហេតុពិតប្រាកដ ហើយសុំគោលការណ៍ដោះស្រាយពីនាយកដ្ឋាន។

២-ហាមដាច់ខាតមិនឱ្យកែ ទោះជាតាមរបៀបណាក៏ដោយនៅលើកំណត់ហេតុអង្កេតដី ដែលសមត្ថកិច្ចសម្រេចរួចហើយ។ រាល់ចំណុចខុសឆ្គងដែលទើបរកឃើញជាក្រោយ ត្រូវតែធ្វើសលាកប័ត្រកែតម្រូវ (មានគំរូ) រួចចុះហត្ថលេខាសម្រេចដោយសមត្ថកិច្ចដែលមានសិទ្ធិ ហើយបិទភ្ជាប់ជាមួយនឹងកំណត់ហេតុចាស់ដែលមានចំណុចខុសឆ្គងនោះ។

ដោយឡែក សៀវភៅចុះបញ្ជី និងប័ណ្ណសម្គាល់សិទ្ធិ យើងផ្អែកលើសលាកប័ត្រកែតម្រូវអាចកែទៅតាមការណែនាំដែលបានអនុវត្តបន្តបន្ទាប់រួចមកហើយ។

ចំពោះឯកសារដែលយើងមិនបានកសាងដោយខ្លួនឯង (ពាក្យស្នើសុំ) ស្ថាប័នជំនាញមិនមានសិទ្ធិកែតម្រូវសោះឡើយ បើសង្ស័យអំពីសាវតារ គួរសួរបញ្ជាក់ ហើយឱ្យសាមីម្ចាស់ពាក្យកែដោយដៃគេ បើអ្នកនោះមិនចេះអក្សរ ហើយអាចសរសេរឱ្យ តែត្រូវបញ្ជាក់ថាសរសេរ ឬកែទៅតាមសំណើរបស់សាមីខ្លួន។ ក្នុងករណីនេះ ត្រូវមានសាក្សីពីរនាក់ផ្តិតមេដៃដឹងឮផង។

ក្រៅពីសាវតារ ឬឈ្មោះអ្នកកាន់កាប់មិនចាំបាច់កែឡើយ ទោះបីខុសពីកំណត់ហេតុអង្កេតក៏ដោយ។

ចំពោះក្បាលដីដែលបំបែកជាពីរ ឬជាបី . . . ក្នុងពេលតែមួយ ត្រូវធ្វើសលាកប័ត្រវាស់បំបែកតែមួយគត់។ ឧទាហរណ៍ថា ក្បាលដីលេខ C3-0132 បំបែកជាបីក្បាល ត្រូវធ្វើសលាកប័ត្រតែមួយគត់ ដោយយកក្បាលដីដើមលេខ C3-0132 បំបែកជាបីចំណែក គឺចំណែក A-B-C ដែល

មានទំហំ និងព្រំប្រទល់តាមជាក់ស្ដែងរៀងខ្លួន ពោលគឺមិនត្រូវធ្វើសលាកប័ត្រមួយបំបែកបានក្បាលដីលេខ C3-0132 បានតែចំណែក A មួយ ហើយធ្វើសលាកប័ត្រមួយទៀតបំបែកជាពីរលេខ C3-0132 ដែរ បានក្បាលដី B និង . . . នោះទេ។ ក្រៅពីនេះ គឺគ្រាន់តែតែងលិខិតលក់ ឬអំណោយ ឬចែក . . . ស្របទៅតាមសលាកប័ត្រ និងក្បាលដីនីមួយៗ ហើយមិនចាំបាច់កែនៅលើប័ណ្ណ ឬលើឯកសារពាក់ព័ន្ធដទៃទៀតឡើយ ទុកឱ្យនាយកដ្ឋានបំពេញការងារនេះជាក្រោយ។

**៣_ការងារលេខាចរិក និងចរន្តការ**

**ក_អំពីលេខាចរិក**

លេខាចរិកជាកិច្ចអចិន្ត្រៃយ៍ និងបន្តបន្ទាប់ ដាច់ខាតមិនត្រូវទុកចោលដោយមិនសរសេរចូលនូវសំណុំឯកសារដែលបានសម្រេចរួចហើយទេ។ មន្ត្រីកាន់កាប់ទទួលខុសត្រូវលើការងារនេះត្រូវតែជាមនុស្សឧស្សាហ៍ អំណត់ ព្យាយាម សុចរិត ម៉ត់ចត់ ទៀងទាត់។ ពេលកំពុងចុះបញ្ជីឈ្មោះណាមួយត្រូវតែសរសេរឱ្យចប់ដោយប្រើទឹកខ្មៅតែមួយ សរសេរពេលតែមួយ ដៃតែមួយ ហើយអក្សរច្បាស់ ចៀសវាងអក្សរមួយអាចបកស្រាយន័យបានពីរ ឬបីយ៉ាង ឬក្រវេមក្រវាមពេញសៀវភៅ កខ្វក់មើលមិនយល់។ ហាមផ្ដាច់មិនឱ្យរំលងទំព័រ ឬហែកសន្លឹកសៀវភៅជាដាច់ខាត។ ហាមមិនឱ្យប្រមូលមន្ត្រីពីផ្នែកផ្សេងមកឱ្យជួយចុះបញ្ជីជាដាច់ខាត បើពិនិត្យឃើញថា ការងារនេះចាំបាច់ត្រូវប្រើមន្ត្រីច្រើននាក់ ថ្នាក់ដឹកនាំមន្ទីរត្រូវបន្ថែមមន្ត្រីឱ្យទៅធ្វើការក្នុងផ្នែកនេះឱ្យបានគ្រប់គ្រាន់តែម្ដង។ ការប្រមូលមន្ត្រីពីផ្នែកផ្សេងមកធ្វើកិច្ចការនេះមិនអាចធានាគុណភាព និងមិនមានស្មារតីទទួលខុសត្រូវទេ។ សៀវភៅចុះបញ្ជីទាំងបីក្បាល (នាយកដ្ឋាន មន្ទីរសុរិយោដីខេត្ត-ក្រុង ការិយាល័យភូមិបាល) ត្រូវតែចុះឱ្យដូចគ្នា ស្របគ្នាទាំងខ្លឹមសារ ទាំងបែបបទ។

**ខ_អំពីចរន្តការ**

រាល់ការផ្លាស់ប្ដូរ ដាក់បន្ទុក លើកលែងបន្ទុក ឬផ្ទេរសិទ្ធិ និងរាល់ការប្រែប្រួលអំពីក្បាលដី (ទិដ្ឋភាពរូបសាស្ត្រ) ត្រូវតែមានចុះនិទ្ទេសទៅតាមគោលការណ៍ណែនាំ មិនត្រូវភ្លេចបង្អែរបង្អង់ ឬទុកចោលរង់ចាំពេលនេះ ពេលនោះ ជាហេតុនាំឱ្យមានកំហុសឆ្គងខាងបែបបទគតិយុត្ត និងភាពប្រាកដនិយម។

ប្រធានមន្ទីរសុរិយោដីខេត្ត-ក្រុងត្រូវចាត់តាំងមន្ត្រីកាន់សំណុំឯកសារដែលត្រូវបញ្ជូនមកនាយកដ្ឋានឱ្យបានច្បាស់លាស់ (គួរត្រូវជ្រើសរើសមន្ត្រីនៅមន្ទីរ) ចៀសវាងពេលយកឯកសារ

ត្រលប់ទៅវិញ បង្កឡើងនូវភាពអសកម្មអំពីការធ្វើលេខាចារឹក និងចរន្តការក្នុងសៀវភៅចុះបញ្ជី អចលនវត្ថុ និងឯកសារផ្សេងទៀត ។

**៤_អំពីការងារធិការកិច្ច**

ក្រៅពីអធិការកិច្ចដែលចុះពីនាយកដ្ឋាន ធម្មតាប្រធាន ឬអនុប្រធានមន្ទីរមានភារកិច្ច បំពេញការងារអធិការកិច្ចទៅតាមការិយាល័យភូមិបាល ដើម្បីជួយកែលំអអង្គភាពក្រោមឱវាទ ឱ្យអនុវត្តការងារបានត្រឹមត្រូវមានគុណភាព និងប្រសិទ្ធភាព រាប់ទាំងការងាររដ្ឋបាល និងទំនាក់ទំនងជាមួយប្រជាជន មហាជននៅមូលដ្ឋានផង ។

**៥_ការរៀបចំ និងការទុកដាក់សំណុំឯកសារ**

មិនមែនជាកិច្ចការធម្មតាទេ ព្រោះវាមានគោលបំណងសំខាន់ណាស់គឺត្រូវធ្វើយ៉ាងណា ឱ្យបានគង់វង្ស គត់មត់ រក្សាបានការសម្ងាត់ និងងាយរកឃើញពេលត្រូវការ ។ ហាមដាច់ខាត យកឯកសារចេញក្រៅអង្គភាព ទោះគ្រាន់តែយកទៅឱ្យតតិយជនមើល ឬថតចម្លងក៏ដោយ បើគ្មានការអនុញ្ញាតពីថ្នាក់ដឹកនាំទេ ។

នាយកដ្ឋានសុរិយោដី អភិបាលខេត្ត និងតុលាការអាចអនុញ្ញាតឱ្យពិនិត្យឯកសារដើម (កំណត់ហេតុអង្កេត) បានបើត្រូវការ ។ តែមិនយកទៅទុកនៅទីនោះទេ គឺមន្ត្រីសុរិយោដី គ្រាន់តែយកទៅឱ្យពិនិត្យ ហើយយកត្រលប់មកវិញភ្លាម ។

**៦_ការងារបិទប្រកាសមុនពេលចុះវាស់វែង**

ត្រូវតែធ្វើឱ្យបានទៅតាមគោលការណ៍ដែលបានកំណត់ ។ ចំពោះរយៈពេល មិនត្រូវបន្ថយមកខ្លីពេកទេ យ៉ាងហោចណាស់ក៏១០ថ្ងៃដែរ ។ បើតាមធម្មតា គួរកំណត់ឱ្យលើសពី១៥ថ្ងៃ ដើម្បីពិនិត្យអ្នកពាក់ព័ន្ធដែលនៅឆ្ងាយគេទទួលបានដំណឹងនេះ ។ ការចុះធ្វើអង្កេតវាស់វែងដោយមិនបានបិទប្រកាសជាមុន ជាអំពើខុសឆ្គងចំពោះមុខច្បាប់ ជាពិសេសជនដែលពាក់ព័ន្ធនឹងក្បាលដីមានសិទ្ធិប្ដឹងឱ្យបដិសេធឯកសារចោលជាអសារបង់ ហើយកសាងឯកសារថ្មីឡើងវិញបាន ប្រសិនបើកិច្ចការដែលបានធ្វើកន្លងមកមានកំហុសមិនអាចអនុគ្រោះបាន ។

ម្យ៉ាងទៀត បើយើងប្រតិបត្តិឱ្យបានត្រឹមត្រូវទៅទាមគោលការណ៍នេះ នោះយើងអាចចៀសវាងបាននូវបាតុភាពវាស់ និងកសាងឯកសារ ផ្ដល់ប័ណ្ណជាន់គ្នា (ដីមួយកន្លែងចេញប័ណ្ណពីរ)

និងអាចចៀសវាងបានអំពីបទចោទប្រកាន់ថា ស្ថាប័នជំនាញសុរិយោដីឃុបឃិតលួចវាស់ដី ឱ្យអ្នកណាម្នាក់ដោយខុសច្បាប់។

ការបិទប្រកាសត្រូវមានកំណត់ហេតុកត់ត្រាអំពីពេលវេលា ទីកន្លែងឱ្យបានច្បាស់លាស់ រួចភ្ជាប់មកជាមួយសំណុំរឿងផង។ ការប្រកាសផ្សាយអាចធ្វើបានតាមគ្រប់មធ្យោបាយ អាស្រ័យទៅលើលទ្ធភាពជាក់ស្តែងរបស់អ្នកស្នើសុំ ដូចជាតាមរយៈសារព័ត៌មាន វិទ្យុ ទូរទស្សន៍ . . . ប៉ុន្តែចំពោះរយៈពេលត្រូវតែរក្សានៅដដែលគឺមិនបន្ថយឱ្យខ្លីពេកបានទេ។

**៧.អំពីលិខិតសញ្ញា**

លិខិតលក់ផ្តាច់ អំណោយផ្តាច់ . . . នាយកដ្ឋានបានកសាងជាពីរផ្នែកដែលត្រូវហែកដាច់ចេញពីគ្នា ពេលដែលយើងបានបំពេញសេចក្តី។ ខ្លឹមសារគ្រប់គ្រាន់អស់ហើយ ក្រដាសដែលហែកចេញ (ចុងសន្លឹក Volant) ប្រើសម្រាប់ភ្ជាប់សំណុំរឿង និងប្រគល់ឱ្យសាមីជន ដោយឡែកមួយផ្នែកទៀតដែលមានខ្លឹមសារគ្រប់គ្រាន់ដែរនោះ គឺគល់បញ្ជីដែលត្រូវនៅជាប់គ្នាទាំងដុំ មិនអាចឱ្យដាច់ដោចចេញពីគ្នាបានឡើយ ហើយត្រូវរក្សាទុកជាឯកសារសម្រាប់ក្រុមអធិការកិច្ចត្រួតពិនិត្យអំពីលិខិតសញ្ញា និងចំណូលដែលបានមកពីពន្ធប្រថាប់ត្រា។

សៀវភៅ ក្រដាសពុម្ព លិខិតសញ្ញានេះមិនអាចបង្វិលចៃញគ្នាប្រើប្រាស់តាមអង្គភាពដោយឡែកពីគ្នាបានទេ ឧទាហរណ៍ សៀវភៅមួយក្បាលនៅភូមិបាលស្រុកតាខ្មៅ គឺសម្រាប់ប្រើតែស្រុកតាខ្មៅទេ មិនអាចយកទៅប្រើនៅស្រុកកណ្តាលស្ទឹងបានឡើយ។ ចំពោះលិខិតរណបគតិយុត្តដែលត្រូវភ្ជាប់មកជាមួយសំណុំរឿង (បើមាន) ត្រូវតែធានាឱ្យបានតាមគោលការណ៍កំណត់ និងគ្រប់គ្រាន់ទៅតាមប្រភេទនៃរឿង។ មិនត្រូវផ្ញើមកនាយកដ្ឋានតែលិខិតថតចម្លងដែលមិនមានសមត្ថកិច្ចណាបញ្ជាក់ថាថតចម្លងត្រឹមត្រូវនោះមកជូននាយកដ្ឋានទេ ពិសេសរឿងដែលពាក់ព័ន្ធនឹងច្បាប់ (ដូចជាសាលក្រមតុលាការជាដើម)។

**៨.អំពីការប្រើប្រាស់ឯកសារក្រដាសពុម្ព**

នាយកដ្ឋានបានរៀបចំឯកសារនេះ ទៅតាមគោលការណ៍ដែលមានការយល់ព្រមត្រឹមត្រូវពីក្រសួងមានសមត្ថកិច្ច។ អង្គភាពដែលត្រូវការប្រើប្រាស់ ត្រូវធ្វើពាក្យសុំទិញដោយមានលិខិ និងមានការយល់ព្រមពីថ្នាក់ដឹកនាំមន្ទីរត្រឹមត្រូវ អាចលើកលែងខ្លះ ប្រសិនបើមានភាពចាំបាច់ណា

មួយ ។ ចំពោះជនដែលឋិតក្រៅក្របខ័ណ្ឌមន្ត្រីសុរិយោដី មិនអាចមកទិញ ឬដឹកនាំយកក្រដាសពុម្ព ពីនាយកដ្ឋានបានទេ ទោះបីមានលិខិតពីថ្នាក់ដឹកនាំមន្ទីរតាមខេត្ត-ក្រុងក៏ដោយ ។

រាល់ការថតចម្លងក្រដាសពុម្ព ឯកសារ លិខិតសញ្ញា និងលិខិតដែលបោះពុម្ពផ្សេងៗ ទៀត យកទៅប្រើមិនអនុញ្ញាតជាដាច់ខាត ។ ជនល្មើស បើរកឃើញមានគ្រប់ភស្តុតាងត្រូវទទួល ការចោទប្រកាន់ពីបទក្លែងក្លាយលិខិតស្នាមសាធារណៈ ។

ការិយាល័យផែនការ គណនេយ្យដែលទទួលបន្ទុកគ្រប់គ្រងឯកសារជាគំរូបោះពុម្ព ឬជា សៀវភៅផ្សេងៗទៀតត្រូវធ្វើបញ្ជីរាយឈ្មោះឯកសារទាំងនោះ ជូនមន្ទីរសុរិយោដីខេត្ត-ក្រុងជ្រាប ដើម្បីធ្វើសំណើយកទៅប្រើប្រាស់ ។

**II-ការងារពាក់ព័ន្ធនឹងតុលាការ**

ជាបណ្តើរៗឯកសារសុរិយោដីកាន់តែសំខាន់ឡើងចំពោះមុខច្បាប់ ។ ព្រោះទំនាស់ដែល កើតច្រើននៅក្នុងសង្គមយើងកន្លងមកគឺចេញពីបញ្ហាសិទ្ធិលើអចលនវត្ថុ ពិសេសគឺដីស្រែ ចម្ការ ភូមិដែលជាទ្រព្យសម្បត្តិអាយុជីវិតរបស់ប្រជាពលរដ្ឋនេះឯង ។ រាល់ការរំលោភបំពាន និងភាពមិន ច្បាស់លាស់អំពីសិទ្ធិលើអចលនវត្ថុ ត្រូវបានសាមីម្ចាស់សិទ្ធិប្តូរផ្តាច់ការពារចំពោះមុខច្បាប់ ។

សន្និបាតរបស់ក្រសួងយុត្តិធម៌ក៏បានវាយតម្លៃថា ទំនាស់ដែលកើតច្រើនរយៈពេលកន្លង មក គឺភាគច្រើនចេញអំពីសិទ្ធិលើអចលនវត្ថុ ដី ផ្ទះនេះឯង ប៉ុន្តែកម្រិតនៃការយកចិត្តទុកដាក់ដោះ ស្រាយបញ្ហានេះរបស់ក្រសួងយុត្តិធម៌ពុំទាន់បានខ្ជះខ្វែងនៅឡើយ ។ កន្លងមកនាយកដ្ឋានជំនាញ (សុរិយោដី) បានធ្វើសំណូមពរតាមរយៈសន្និបាតក្រសួងយុត្តិធម៌ប្រចាំឆ្នាំ ដើម្បីពិភាក្សារកដំណោះ ស្រាយបណ្តាចំណុចអសកម្មខ្លះដូចខាងក្រោម៖

១-ទំនាក់ទំនងសហការរវាងតុលាការខេត្ត-ក្រុង និងមន្ទីរសុរិយោដី៖

គួរមានគោលការណ៍រួមដាក់ចុះអនុវត្តឱ្យឯកភាពគ្នា ។ អង្គសន្និបាតឯកភាពថានឹងអញ្ជើញ អ្នកជំនាញពិភាក្សាគ្នាកំណត់គោលការណ៍ជូនតែ២ឆ្នាំកន្លងមកហើយ ពុំទាន់មានគោលការណ៍រួម ជាលាយលក្ខណ៍អក្សរណាមួយចេញឱ្យមូលដ្ឋានអនុវត្តនៅឡើយទេ ។ ដូចនេះ ការទំនាក់ទំនង សហការគ្នារវាងតុលាការខេត្ត-ក្រុង និងស្ថាប័នជំនាញមិនទាន់ធ្វើបានល្អនៅឡើយ ។

២-អំពីការបដិសេធប័ណ្ណដែលត្រឹមត្រូវអំពីភិនភាគ និងរូបសាស្ត្រ ហើយគ្រាន់តែប្តូរសិទ្ធិពីឈ្មោះមួយទៅ (នាយកដ្ឋានបានសរសេរលិខិតមួយតាំងពីខែមិថុនា ឆ្នាំ១៩៩៧ តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី គោរពជូនក្រសួងយុត្តិធម៌ បកស្រាយបំភ្លឺអំពីបញ្ហានេះតែមិនមានចម្លើយ)។

ករណីនេះ តុលាការមិនគួរបដិសេធប័ណ្ណចោលទេ គឺគ្រាន់តែសម្រេចថាសិទ្ធិលើអចលនវត្ថុ (ដី) ទំនាស់នេះត្រូវប្រគល់ទៅឱ្យឈ្មោះណាមួយទៅ វាគ្រប់គ្រាន់ហើយងាយស្រួលក្នុងការអនុវត្តសាលក្រមនោះទៀតផង។

៣-សំណូមពរដល់តុលាការខេត្ត-ក្រុង មុនពេលដោះស្រាយរឿងវិវាទដីធ្លី គួរមានរបាយការណ៍បំភ្លឺពីស្ថាប័នជំនាញជាមុនសិន ដើម្បីកំណត់ទីតាំង និងភិនភាគក្បាលដីឱ្យបានច្បាស់លាស់។ ពេលសាលក្រមសម្រេចជាស្ថាពរហើយ យើងអាចអនុវត្តបានត្រឹមត្រូវ និងងាយស្រួល។ កន្លងមកមានសាលក្រមសម្រេច និងក្បាលដីជាក់ស្តែងខុសគ្នា។

៤-តុលាការគួរប្រគល់សាលក្រមច្បាប់ដើម ឬសាលក្រមដែលមានបញ្ជាក់ថាត្រឹមត្រូវឱ្យមន្ទីរជំនាញមួយច្បាប់ ចំពោះវិវាទរឿងអចលនវត្ថុ និងគួររៀបចំបង្កើតគណៈកម្មការអនុវត្តសាលក្រមឱ្យបានច្បាស់លាស់គ្រប់ករណី។ ក្រោយពេលទំនាក់ទំនងសុំមន្ត្រីជំនាញពីបណ្តាអង្គភាពពាក់ព័ន្ធក្នុងរឿងនេះរួចហើយ ដើម្បីឱ្យគណៈកម្មការនេះចុះទៅអនុវត្តជាក់ស្តែង លើទីតាំង និងធ្វើកំណត់ហេតុបានត្រឹមត្រូវសម្រាប់ដោះស្រាយ។

អំពីរឿងអចលនវត្ថុ ត្រូវតែមានសាលក្រមសម្រេចទើបយកមកអនុវត្តបាន។ ដីកាសម្រេច ឬលិខិតផ្សេងៗទៀតមិនអាចទទួលមកអនុវត្តបានឡើយ។ ករណីនេះ សន្និបាតក្រសួងយុត្តិធម៌កាលពីឆ្នាំ១៩៩៦ បានកំណត់រួចហើយ។

**III-ភារកិច្ចរបស់មន្ត្រីសុរិយោដីក្នុងការអនុវត្តសាលក្រមរដ្ឋប្បវេណី**

វិវាទក្នុងរឿងអចលនវត្ថុភាគច្រើន ច្រើនតែក្លាយទៅជាទំនាស់ក្តីក្តាំដល់តុលាការ។ ក្រោយពេលសាលក្រមរដ្ឋប្បវេណីរបស់តុលាការចូលជាស្ថាពរហើយ សាលក្រមនេះត្រូវតែបានអនុវត្តតាម។

មានករណីខ្លះ ភាគីចាញ់ក្តីពុំអស់ចិត្តរឿងក្តីក្តាំ ក៏ក្រាញននៀលពុំព្រមអនុវត្តសាលក្រម ពោលគឺពុំសុខចិត្តប្រគល់នូវអចលនវត្ថុ ព្រមទាំងប័ណ្ណសម្គាល់សិទ្ធិដែលជាកម្មវត្ថុនៃទំនាស់នោះឱ្យ

ទៅភាគីឈ្នះក្តី។ អ្នកខ្លះខកចិត្តយកប័ណ្ណទៅទុកចោល ឬហែកចោល តុលាការគួរមានវិធានការចំពោះរឿងនេះ។

ដូច្នេះហើយ តុលាការខេត្ត-ក្រុងត្រូវតែបង្កើតគណៈកម្មការចម្រុះមួយសម្រាប់ចុះអនុវត្តសាលក្រមដល់ទីកន្លែង។ ក្នុងគណៈកម្មការនេះគួរតែមានមន្ត្រីសុរិយោដីមួយ ឬពីរនាក់ចូលរួម។ ការអនុវត្តសាលក្រមគឺមានន័យថា ប្រតិបត្តិជាក់ស្តែងតាមខ្លឹមសារនៃសាលក្រមតុលាការ ពោលគឺរឹបអូសប្រមូលយកនូវអចលនវត្ថុដែលក្តីគ្នានោះពីភាគីចាញ់ក្តី ឱ្យទៅភាគីឈ្នះក្តីកាន់កាប់គ្រប់គ្រងជារបស់ខ្លួន។ នៅពេលនោះមន្ត្រីសុរិយោដីយើង ដែលចូលរួមក្នុងគណៈកម្មការមានភារកិច្ចដូចតទៅ៖

**ក.ចំពោះអចលនវត្ថុដែលពុំទាន់ចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់**

១-កំណត់ទីតាំងភូមិសាស្ត្រអចលនវត្ថុ និងដៅបង្គោលគ្រប់ជ្រុង (បើព្រំដីពុំទាន់មានបង្គោល ឬរបងថ្ម) យកល្អចាក់បង្គោលបេតុងតែម្តង ចៀសវាងរំកិលបានងាយស្រួល។

២-វាស់ប្រវែងជ្រុង និងគណនាផ្ទៃក្រឡា ហើយគូររូបរាងអចលនវត្ថុចូលក្នុងកំណត់ហេតុអនុវត្តសាលក្រមឱ្យបានច្បាស់លាស់ត្រឹមត្រូវ និងគ្រប់គ្រាន់។

៣-កំណត់ឈ្មោះម្ចាស់អចលនវត្ថុ និងប្រភេទទ្រព្យសម្បត្តិឱ្យច្បាស់តាមការសម្រេចរបស់តុលាការ។

៤-ឱ្យអ្នកជាប់ព្រំទាំងអស់ផ្តិតមេដៃទទួលស្គាល់ព្រំប្រទល់រៀងខ្លួន។ បើមានអ្នកជាប់ព្រំណារឹងរូស ពុំព្រមផ្តិតមេដៃ ត្រូវរាយការណ៍ជូនគណៈកម្មការអនុវត្តសាលក្រមបញ្ជាក់ និងអះអាងព្រំនៃជ្រុងនោះ។

៥-ធ្វើអត្តសញ្ញាណក្បាលដីដែលសាលក្រមសម្រេច និងក្បាលដីជាក់ស្តែង បើមានចំណុចខុសគ្នាត្រូវលើកយោបល់ឱ្យគណៈកម្មការអនុវត្តសាលក្រមសម្រេច។

**ខ.ចំពោះដីដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុរួចហើយ**

១-ធ្វើអត្តសញ្ញាណក្បាលដីក្នុងប័ណ្ណ និងក្បាលដីដែលសាលក្រមសម្រេច បើឃើញថាត្រឹមត្រូវហើយ យើងគ្រាន់តែរាយការណ៍ជូនគណៈកម្មការអនុវត្តសាលក្រមថា អាចអនុវត្តបានហើយ។

*វាយឡើងវិញ*

២-អនុវត្តដូចក្នុងចំណុច២.៣.៤នៃចំណុច "ក" ខាងលើប្រសិនបើមានចំណុចណាខុសពីឯកសារដើម (កំណត់ហេតុអង្កេត) បើមានចំណុចណា ឬតួលេខណាដែលខុសពីឯកសារចាស់ មន្ត្រីសុរិយោដីត្រូវលើកយោបល់ជូនគណៈកម្មការអនុវត្តសាលក្រមពិនិត្យ និងដោះស្រាយ។

និយាយរួមធ្វើយ៉ាងណាឱ្យភិនភាគក្បាលដី (រូបរាង ប្រវែងជ្រុង ទំហំ អ្នកជាប់ព្រំប្រទល់) ដែលសាលក្រមសម្រេចត្រូវគ្នាទាំងស្រុងទៅនឹងដីដែលមានជាក់ស្តែង ឬមាននៅក្នុងប័ណ្ណសម្គាល់សិទ្ធិ ពិសេសកំណត់ហេតុអង្កេតតែម្តង។ ដូចនេះ អាចមានករណីខ្លះ គួរតុលាការកែតម្រូវចំណុចខ្លះនៃសាលក្រម ពិសេសអំពីភិនភាគក្បាលដីនេះតែម្តង បើមិនដូច្នេះទេ ស្ថាប័នជំនាញមិនអាចអនុវត្តតាមសាលក្រមបានទេ។

នាយកដ្ឋានមានក្តីសង្ឃឹមលើស្មារតីទទួលខុសត្រូវ និងភាពឈ្លាសវៃរបស់អស់លោកថ្នាក់ដឹកនាំ និងមន្ត្រីជំនាញក្នុងការអនុវត្តតាមក្បួនខ្នាតដែលជាលាយលក្ខណ៍ និងគោលការណ៍សម្រាប់វិស័យជំនាញចំពោះមុខ។

ភ្នំពេញ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៧

**ប្រធាននាយកដ្ឋានសុរិយោដី**

**ហត្ថលេខា និងត្រា**

**លឹម វ៉ាន់**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
លេខ០០៤សសរ/សហវ/ពដ　　　　　　　　រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៩៨

# សេចក្តីសម្រេច
# ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ១១/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងច្បាប់កែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥
- បានឃើញច្បាប់ស្តីពីសារពើពន្ធដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

- បានឃើញអនុក្រឹត្យលេខ៩៨អនក្រ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
- បានឃើញប្រកាសលេខ៣១៦ប្រក/សហវ/ពដ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
- បានឃើញប្រកាសលេខ២២៤ប្រក/សហវ/ពដ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បានឃើញប្រកាសលេខ៧៤៤ប្រក/សហវ/ពដ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៩៦ ស្តីពីការកំណត់មេគុណសម្រាប់អនុវត្តក្នុងការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បានឃើញប្រកាសលេខ០២៦ប្រក/សហវ/ពដ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៩៧ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការវាយតម្លៃដីធ្លីមិនបានប្រើប្រាស់
- យោងតាមសំណើរបស់នាយកដ្ឋានពន្ធដារ
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់។

**សម្រេច**

**ប្រការ១**

ដីធ្លីមិនបានប្រើប្រាស់ឋិតនៅក្នុងខេត្ត-ក្រុងនៃព្រះរាជាណាចក្រកម្ពុជាត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់។

**ប្រការ២**

តម្លៃដីធ្លីសម្រាប់ធ្វើជាមូលដ្ឋានគិតពន្ធលើដីធ្លីមិនបានប្រើប្រាស់ ត្រូវបានកំណត់គិតជាតម្លៃក្នុងមួយម៉ែត្រក្រឡា ទៅតាមតំបន់នីមួយៗដែលកំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់។

**ប្រការ៣**

សេចក្តីសម្រេចនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ហត្ថលេខា និងត្រា**

**គាត ឈន់**

ព្រះរាជក្រឹត្យស្តីពីការកំណត់ និងការគ្រប់គ្រងព្រៃដីតំបន់ជម្រាល

នស/រកត/០១៩៩/០៧

# ព្រះរាជក្រឹត្យ

## យើងព្រះបាទសម្តេចព្រះនរោត្តម សីហនុ រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានការយល់ព្រមពីគណៈរដ្ឋមន្ត្រីនាសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៩៨

### ត្រាស់បង្គាប់

**មាត្រា១**

ត្រូវបានបង្កើតឱ្យមានការកំណត់ និងការគ្រប់គ្រងព្រៃតំបន់ដីជម្រាលនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២**

ដីជម្រាលជាជួរនៃតំបន់ដីខ្ពស់ ដែលផ្ទៃកសងខាងនៃតំបន់នោះ មានចរន្តទឹកហូរចាក់ទៅក្នុងអូរ ស្ទឹង បឹង ទន្លេ ឬសមុទ្រ។

**មាត្រា៣**

កំណត់ និងគ្រប់គ្រងព្រៃឈើតំបន់ដីជម្រាលក្នុងគោលបំណង៖

ក-ការពារការហូរច្រោះ

ខ-កាត់បន្ថយល្បឿនចរន្តទឹកក្នុងតំបន់ដីជម្រាល

គ-រក្សានិយតភាពប្រភពទឹកក្នុងដី

ឃ-ទប់ទល់ការបាត់បង់ជីជាតិរបស់ដី

ង-រក្សានូវសុក្រឹតភាពនៃប្រភព និងគុណភាពទឹក

ច-គាំពារជីវៈចម្រុះ

ឆ-ធ្វើឱ្យមានលំនឹងដល់បរិស្ថានធម្មជាតិ

មាត្រា៤

កំណត់ផ្ទៃដីព្រៃឈើតំបន់ដីជម្រាលដើម្បីគ្រប់គ្រង និងអភិវឌ្ឍត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា៥

ផ្ទៃដីព្រៃឈើក្នុងតំបន់ដីជម្រាលអាចនឹងកែប្រែពង្រីកបន្ថែម ដោយផ្អែកទៅលើព័ត៌មានវិទ្យាសាស្ត្រ និងស្ថានភាពជាក់ស្តែងនៅពេលអនាគត ។

មាត្រា៦

ការអភិវឌ្ឍ ការធ្វើអាជីវកម្មផល អនុផលព្រៃឈើគ្រប់ប្រភេទនៅតំបន់ដីជម្រាលត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា៧

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលខុសត្រូវក្នុងការដឹកនាំគ្រប់គ្រង និងធ្វើការអភិវឌ្ឍព្រៃឈើតំបន់ដីជម្រាលដូចចែងក្នុងមាត្រា២ ហើយមានសិទ្ធិធ្វើសហប្រតិបត្តិការជាមួយអន្តរក្រសួង អង្គការអន្តរជាតិ ឬអង្គការក្រៅរដ្ឋាភិបាល លើបន្ទាត់នយោបាយព្រៃឈើ និងបច្ចេកទេស ។

មាត្រា៨

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលខុសត្រូវបន្ទុកអនុវត្តឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៩

ព្រះរាជក្រឹត្យនេះចូលជាធរមានបញ្ញត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១១ ខែមករា ឆ្នាំ១៩៩៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ០១ប្រក

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៩

**សេចក្ដីប្រកាស**
**ស្ដីពីវិធានការគ្រប់គ្រង និងលុបបំបាត់**
**ភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើ**

ដោយពិនិត្យឃើញថា ទោះបីជាក្រឹត្យ-ច្បាប់លេខ៣៥ក្រច ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៨៨ ស្ដីពីការគ្រប់គ្រងវិស័យព្រៃឈើ ព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការកំណត់តំបន់ការពារធម្មជាតិ ច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលនៅជាធរមាន និងលិខិតបទដ្ឋានជាច្រើនទៀត ដែលរាជរដ្ឋាភិបាលបានដាក់ចេញជាបន្តបន្ទាប់តាមដំណាក់កាលនីមួយៗ សំដៅមានវិធានការទប់ស្កាត់បទល្មើសលើវិស័យព្រៃឈើក៏ដោយ ក៏នៅតែមានជនខិលខូចបាននិងកំពុងឆ្លៀតឱកាសបំផ្លិចបំផ្លាញធនធានព្រៃឈើ កំពុងតែគំរាមកំហែងយ៉ាងធ្ងន់ធ្ងរបំផុតគួរឱ្យព្រួយបារម្ភ ហើយបើសិនជាកម្រិតនៃការបំផ្លិចបំផ្លាញដូចបច្ចុប្បន្ននេះនៅតែបន្តទៀតនោះ ប្រទេសកម្ពុជានឹងបាត់បង់ធនធានព្រៃឈើដ៏មានតម្លៃស្ដុកស្ដម្ភនេះ ក្នុងអំឡុងពេលដ៏ខ្លីខាងមុខ។ ការបាត់បង់ព្រៃឈើនេះនឹងជះឥទ្ធិពលយ៉ាងខ្លាំងទៅលើតុល្យភាពប្រព័ន្ធអេកូឡូស៊ីកសិកម្ម និងនេសាទរបស់កម្ពុជានៅពេលអនាគត ដែលកន្លងមកធនធានព្រៃឈើធ្លាប់តែស្រូបទាញយកនូវបរិមាណភ្លៀងដ៏ច្រើន ការពារដី និងការរក្សាស្រទាប់ទឹកក្រោមដី កាត់បន្ថយបាននូវគ្រោះកាចនៃទឹកជំនន់ និងភាពរាំងស្ងួត។ ម្យ៉ាងទៀតបើគ្មានព្រៃឈើទេ វានឹងបណ្ដាលឱ្យមានការហូរច្រោះនាំដីល្បាប់ ហូរចាក់ទៅក្នុងបឹងទន្លេសាប ធ្វើឱ្យខូចនូវមជ្ឈដ្ឋានសម្រាប់ត្រីពង និងជះឥទ្ធិពលអាក្រក់ទៅលើផលិតផលស្រូវនៅក្នុងតំបន់វាលទំនាប

ផងដែរ។ ទន្ទឹមនឹងនោះ សត្វព្រៃកំពុងតែទទួលរងនូវការបំផ្លិចបំផ្លាញដែលបង្កឡើងដោយជនគ្មានវិចារណញាណ ធ្វើឱ្យសត្វព្រៃមួយចំនួនបានរលត់ពូជពីកម្ពុជា និងមួយចំនួនទៀតកំពុងតែឈានទៅរកក្តីវិនាសទាំងស្រុង។ រីឯការរំលោភបំពានរុករានទន្រ្ទានវាតយកដីព្រៃ ដីក្នុងតំបន់ការពារធម្មជាតិ ក្រោមរូបភាពតំបន់អភិវឌ្ឍន៍យោធិន និងអភិវឌ្ឍន៍កសិកម្ម និងធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ក៏ជាបញ្ហាមួយដែលត្រូវដោះស្រាយជាបន្ទាន់ និងឱ្យមានប្រសិទ្ធភាពបំផុត។ រាជរដ្ឋាភិបាលបានប្រឹងប្រែងលើកវិធានការទប់ស្កាត់បទល្មើសព្រៃឈើ ដោយបានដាក់ចេញបទបញ្ជាជាច្រើនលើក ប៉ុន្តែការអនុវត្តពុំទាន់មានប្រសិទ្ធភាពពេញលេញ និងខ្ជាប់ខ្ជួន។ ដោយរង់ចាំការអនុម័តច្បាប់ថ្មីស្តីពីការថែរក្សា និងគ្រប់គ្រងព្រៃឈើក្នុងរយៈពេលដ៏ខ្លីខាងមុខ រាជរដ្ឋាភិបាលផ្តើមចេញពីសុទ្ធរកថានាថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៨ និងសេចក្តីប្រកាសកម្មវិធីនយោបាយ នាថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ចាំបាច់ដាក់ចេញនូវវិធានការដូចតទៅ៖

១-បញ្ឈប់ជាបន្ទាន់ និងជាកំហិតការធ្វើអាជីវកម្ម ការប្រមូលទិញលក់ និងដឹកជញ្ជូនឈើអនាធិបតេយ្យគ្រប់រូបភាព និងគ្រប់ទីកន្លែងក្នុងផ្ទៃប្រទេស លើកលែងតែការធ្វើអាជីវកម្មស្របច្បាប់ក្នុងដែនព្រៃគុបសម្បទានមានច្បាប់អនុញ្ញាត ត្រូវឋិតនៅក្រោមការគ្រប់គ្រងបច្ចេកទេសយ៉ាងតឹងរឹងបំផុតពីសមត្ថកិច្ចរុក្ខាប្រមាញ់។ ដោយឡែក តម្រូវការឈើប្រើប្រាស់ក្នុងប្រទេសត្រូវទិញយកពីការធ្វើអាជីវកម្មស្របច្បាប់របស់ព្រៃសម្បទាន ក្នុងអត្រាពី១០%-២០%នៃផែនការអាជីវកម្មប្រចាំឆ្នាំ តាមរយៈនាយកដ្ឋានរុក្ខាប្រមាញ់ ក្នុងតម្លៃសមស្រប។

២-ការងារគ្រប់គ្រង និងត្រួតពិនិត្យផល អនុផលព្រៃឈើ ត្រូវឋិតនៅក្រោមសមត្ថកិច្ចរុក្ខាប្រមាញ់គ្រប់ជាន់ថ្នាក់។ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ស្ថាប័នជំនាញផ្សេងៗ និងជនមានអំណាច ត្រូវបញ្ឈប់ជាបន្ទាន់នូវការជ្រៀតជ្រែក រំលោភបំពានចូលការងារព្រៃឈើ។

៣-បញ្ចប់នូវការអនុញ្ញាតដឹកជញ្ជូនដោយរួចថ្លៃឈើឈរគ្រប់ប្រភេទ។

៤-បញ្ឈប់ជាដាច់ខាត ការចេញគោលការណ៍ថ្មីដែលអនុញ្ញាតឱ្យប្រមូលទិញឈើអនាធិបតេយ្យ។ រាល់គោលការណ៍ដែលបានអនុញ្ញាតឱ្យប្រមូលទិញ និងដឹកជញ្ជូនឈើអនាធិបតេយ្យគ្រប់ប្រភេទ ទោះពុំទាន់បានអនុវត្ត ឬអនុវត្តពុំទាន់ចប់ក្តីត្រូវទុកជាមោឃៈ។ ឈើអនាធិបតេយ្យគ្រប់ប្រភេទចេញពីព្រៃសម្បទានណាក៏ដោយ ត្រូវធ្វើការចងក្រងសំណុំរឿងតាមនីតិវិធី។

៥-ដើម្បីរក្សានិរន្តរភាពព្រៃឈើដែលជាធនធានធម្មជាតិដ៏កម្រ និងសំដៅរក្សាបរិស្ថានធម្មជាតិផងនោះ ត្រូវបញ្ឈប់ការផ្តល់ព្រៃសម្បទានថ្មីបន្ថែមទៀត។ ការបង្វែរដីព្រៃឈើរេចរិលទៅជាដីអភិវឌ្ឍន៍ដំណាំកសិកម្ម និងឧស្សាហកម្ម ត្រូវមានការសម្រេចពីរាជរដ្ឋាភិបាល តាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានរុក្ខាប្រមាញ់) ត្រូវធ្វើការកំណត់ដែនព្រៃឈើបម្រុងទុកជាបន្ទាន់ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យសម្រេច។

៦-ត្រូវធ្វើការត្រួតពិនិត្យឡើងវិញលើកិច្ចព្រមព្រៀងព្រៃសម្បទានទាំងអស់ ហើយលុបចោលកិច្ចព្រមព្រៀងទាំងឡាយណាដែលមិនបានអនុវត្ត ឬអនុវត្តមិនបានត្រឹមត្រូវតាមកិច្ចព្រមព្រៀងតាមលំដាប់លំដោយឱ្យស្របតាមនីតិវិធី។ ព្រៃសម្បទានដែលត្រូវបានដកហូត ត្រូវរក្សាទុកជាតំបន់ព្រៃការពារធម្មជាតិ និងព្រៃរៀបចំដោយពួក នឹងមិនត្រូវបានផ្តល់ឱ្យក្រុមហ៊ុនណាផ្សេងទៀតឡើយ។

៧-ចំពោះព្រៃសម្បទានដែលអនុវត្តតាមកិច្ចព្រមព្រៀង ត្រូវជំរុញឱ្យបំពាក់បន្ថែមមធ្យោបាយកែច្នៃឱ្យដល់កម្រិតតាមកិច្ចព្រមព្រៀងដើម្បីបង្កើនតម្លៃបន្ថែម និងបង្កើនការងារឱ្យពលរដ្ឋ ព្រមទាំងជំរុញក្រុមហ៊ុនប្រតិបត្តិតាមដោយម៉ឺងម៉ាត់នូវការកាប់ឈើតាមគម្រោងផែនការ និងបទដ្ឋានបច្ចេកទេស ជាពិសេសការដាំដើមឈើឡើងវិញក្នុងតំបន់ដែលបានកាប់ឈើ និងតំបន់ព្រៃរេចរិល។ ទន្ទឹមនឹងនេះ គ្រប់ក្រុមហ៊ុនព្រៃសម្បទានទាំងអស់ត្រូវទទួលខុសត្រូវលើរាល់សកម្មភាពអនាធិបតេយ្យព្រៃឈើ ដែលកើតមានឡើងនៅក្នុងតំបន់ព្រៃរបស់ខ្លួន ដោយសហការជាមួយអាជ្ញាធរដែនដី ហើយចំពោះមុខម្ចាស់ព្រៃសម្បទាននីមួយៗ ត្រូវធ្វើព្រំប្រទល់ដែនព្រៃសម្បទានរបស់ខ្លួនឱ្យបានច្បាស់លាស់ជាចាំបាច់។

៨-បន្តហាមឃាត់ដាច់ខាតការនាំចេញឈើហ៊ុបមូល និងឈើអារសុទ្ធសាធ។ រីឯផលិតផលឈើកែច្នៃដែលបានអនុញ្ញាតឱ្យនាំចេញ ត្រូវតែមានប្រភពឈើហ៊ុបមូលច្បាស់លាស់ចេញពីព្រៃគុបប្រចាំឆ្នាំនៃព្រៃសម្បទាន។

៩-បង្ក្រាបឱ្យបានដាច់ខាតរាល់ការចាប់ ការបរបាញ់ និងការដឹកជញ្ជូន ការនាំចេញសត្វព្រៃគ្រប់ប្រភេទ រាល់មូលដ្ឋានទិញលក់សត្វព្រៃគ្រប់ប្រភេទត្រូវបំបាត់ចោល។

១០-បញ្ឈប់ជាបន្ទាន់នូវការកាប់ឆ្ការរានដីព្រៃធម្មជាតិ ឬចម្ការព្រៃដាំធ្វើជាកម្មសិទ្ធិ។ រាល់ការចេញប័ណ្ណសម្គាល់សិទ្ធិដែលពាក់ព័ន្ធនឹងដីព្រៃឈើ ត្រូវហាមឃាត់ជាដាច់ខាត រហូតដល់ការកំណត់ដែនព្រៃឈើជាផ្លូវការត្រូវបានសម្រេច។

១១-ជំរុញការដាំឈើនៅតំបន់ដីព្រៃរេចរិលគ្រប់ខេត្ត-ក្រុង ទន្ទឹមនេះត្រូវរៀបចំសហគមន៍ព្រៃឈើដើម្បីដាំឈើ និងថែរក្សាព្រៃឈើឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដើម្បីផ្តល់ឈើថាមពល (អុស-ធ្យូង) ដល់ប្រជាពលរដ្ឋប្រើប្រាស់ ហើយត្រូវលើកទឹកចិត្តដល់ការមិនប្រើប្រាស់ថាមពលអុស-ធ្យូង ដោយខិតខំធ្វើការបង្វែរទិសពីតម្រូវការប្រើប្រាស់ថាមពលអុស-ធ្យូងទៅជាការប្រើប្រាស់ថាមពលផ្សេងៗជំនួសវិញ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវផ្តល់ថវិកាជាតិសម្រាប់ដាំឈើឱ្យបានទៀងទាត់តាមផែនការប្រចាំឆ្នាំ។

១២-អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ត្រូវបង្កលក្ខណៈងាយស្រួលឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ "នាយកដ្ឋានរុក្ខាប្រមាញ់" ធ្វើសកម្មភាពទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃឱ្យមានប្រសិទ្ធភាព ដូចជារោងចក្រអារឈើកែច្នៃឈើ មធ្យោបាយ សម្ភារៈ ឧបករណ៍ដែលបម្រើឱ្យសកម្មភាពអនាធិបតេយ្យ។ ក្នុងករណីមានការស្នើសុំអន្តរាគមន៍ពីអង្គភាពជំនាញ កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរដែនដីត្រូវចូលរួមសហការដោយស្មោះត្រង់ និងមានប្រសិទ្ធភាពខ្ពស់បំផុតក្នុងការបង្ក្រាបនេះ ហើយអាចប្រើប្រាស់វិធានការគ្រប់បែបយ៉ាង រួមទាំងវិធានការសឹកផងដែរ។

១៣-ត្រូវបញ្ឈប់ជាបន្ទាន់ការទាមទារយកប្រាក់កម្រៃផ្សេងៗក្រៅផ្លូវការ ពីម្ចាស់ព្រៃគុបសម្បទានស្របច្បាប់ជាដាច់ខាត។

១៤-បុគ្គល ឬអង្គភាពណាដែលបានបង្កឱ្យមានសកម្មភាពអនាធិបតេយ្យព្រៃឈើដោយផ្ទាល់ក្តី ដោយប្រយោលក្តី ឬការពារឈ្មួញទុច្ចរិត ឬនាំចេញឈើ និងសត្វព្រៃខុសច្បាប់ ត្រូវទទួលវិន័យ ឬដកហូតមុខតំណែងតាមកម្រិតដែលបានប្រព្រឹត្ត និងត្រូវទទួលទោសតាមច្បាប់ជាធរមាន។ បន្តផ្តល់កម្រៃដល់មន្ត្រីរាជការដែលមានស្នាដៃក្នុងការងារបង្ក្រាបបទល្មើសព្រៃឈើ និងជលផលតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

*វាយឡើងវិញ*

១៥-ដើម្បីមានមូលដ្ឋានខាងផ្លូវច្បាប់ក្នុងការថែរក្សា និងគ្រប់គ្រងវិស័យព្រៃឈើឱ្យមានប្រសិទ្ធភាពខ្ពស់តាមវិធានការដូចខាងលើ រាជរដ្ឋាភិបាលខិតខំរៀបចំព្រាងច្បាប់ស្តីពីការថែរក្សា និងគ្រប់គ្រងព្រៃឈើឡើងវិញជាបន្ទាន់បំផុតឱ្យសមស្របតាមពេលវេលា និងសភាពការណ៍ជាក់ស្តែងក្នុងវិស័យព្រៃឈើ ហើយស្របទៅនឹងច្បាប់អន្តរជាតិ ដើម្បីដាក់ជូនរដ្ឋសភាអនុម័តក្នុងពេលដ៏ឆាប់ខាងមុខនេះ។ ទន្ទឹមនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវព្រាងបទដ្ឋានអនុវត្តបច្ចេកទេសព្រៃឈើដើម្បីដាក់ឱ្យក្រុមហ៊ុនព្រៃសម្បទានអនុវត្តនៅក្នុងដំណើរការអាជីវកម្មរបស់ខ្លួន។

១៦-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរាយការណ៍ជូនរាជរដ្ឋាភិបាលអំពីការងារអនុវត្តបាន និងការលំបាកក្នុងការអនុវត្ត ដើម្បីរាជរដ្ឋាភិបាលមានវិធានការជាក់ស្តែង។

១៧-ក្រសួងបរិស្ថាន ត្រូវសម្រេចចាត់តាំងយន្តការសម្រាប់តាមដានលើការអនុវត្តសេចក្តីប្រកាសនេះ តាមការចាំបាច់។

ទទួលបានសេចក្តីប្រកាសនេះ គ្រប់ស្ថាប័នពាក់ព័ន្ធ អគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវខិតខំអនុវត្តនូវវិធានការខាងលើដោយស្មារតីទទួលខុសត្រូវខ្ពស់ ឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ៤៧សសរ

**សេចក្ដីសម្រេចស្ដីពីការបង្កើតគណៈកម្មការដោះស្រាយបាតុភាពបញ្ហាដីធ្លី**

**នៅតាមបណ្ដាខេត្ត-ក្រុងទូទាំងប្រទេស**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់ និងបន្ទាន់របស់រដ្ឋាភិបាល

**សម្រេច**

ប្រការ១

បង្កើតគណៈកម្មការដោះស្រាយបាតុភាពបញ្ហាដីធ្លី នៅទូទាំងប្រទេសដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១-ឯកឧត្ដម អ៊ឹម ឈុនលឹម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| ២-ឯកឧត្ដម គន់ គីម ទីប្រឹក្សាសម្ដេចនាយករដ្ឋមន្ត្រី | អនុប្រធានទី១ |
| ៣-ឯកឧត្ដម ហុង ថៃម រដ្ឋលេខាធិការក្រសួងទំនាក់ទំនង សភា ព្រឹទ្ធសភា និងអធិការកិច្ច | អនុប្រធាន |
| ៤-ឯកឧត្ដម ចាយ សាំងយុន រដ្ឋលេខាធិការក្រសួងការពារជាតិ | អនុប្រធាន |
| ៥-ឯកឧត្ដម ព្រុំ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៦-ឯកឧត្ដម ច័ន្ទ តុងអ៊ីវ រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |

៧-ឯកឧត្តម ប៊ុន អ៊ុយ អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៨-ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត- ក្រុង សមាជិក

**ប្រការ២**

គណៈកម្មការនេះមានលេខាធិការដ្ឋានមួយជាជំនួយការ ដែលមានសមាសភាពដូចខាងក្រោម៖

១-ឯកឧត្តម ប៉ុល លឹម អគ្គាធិការរងទី១រដ្ឋបាល និងនគរបាលក្រសួងមហាផ្ទៃ ប្រធាន

២-ឯកឧត្តម ជុំ កាណាល់ ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី អនុប្រធាន

៣-ឧត្តមសេនីយ៍ទោ សិរិទ្ធិ ឌី មេបញ្ជាការរងកងទ័ពជើងគោក អនុប្រធាន

៤-ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល អភិបាលរងខេត្ត-ក្រុង សមាជិក

៥-ឧត្តមសេនីយ៍ទោ ម៉ម សុផាត ប្រធានខុទ្ទកាល័យអគ្គបញ្ជាការ គ.យ.ខ.ភ.ម សមាជិក

៦-ឧត្តមសេនីយ៍ទោ កែវ តាំ ប្រធាននាយកដ្ឋានអធិការកិច្ច ក្រសួងការពារជាតិ សមាជិក

៧-លោក យ៉ា ឡេងហាក់ ជំនួយការឯកឧត្តមទេសរដ្ឋមន្ត្រី
ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៨-លោក ខឹម ជាសោភ័ណ្ឌ អគ្គនាយករងក្រសួងទំនាក់ទំនង
ជាមួយព្រឹទ្ធភា រដ្ឋសភា និងអធិការកិច្ច សមាជិក

៩-លោក កុល វិរក្ស ប្រធានអធិការកិច្ចរដ្ឋបាលក្រសួងមហាផ្ទៃ សមាជិក

១០-លោក លឹម វ៉ាន់ ប្រធាននាយកដ្ឋានសុរិយោដី ក្រសួងរៀបចំ
ដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

១១-លោក ស៊ុន សុខ ប្រធាននាយកដ្ឋានរដ្ឋបាលក្រសួងព័ត៌មាន សមាជិក

១២-លោក សួស សំអាត មន្ត្រីនៃនាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ
និងរដ្ឋប្បវេណី ក្រសួងយុត្តិធម៌ សមាជិក

១៣-លោក ហាស់ សុខ អនុប្រធាននាយកដ្ឋានក្សេត្រសាស្ត្រ
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

**ប្រការ៣**

គណៈកម្មការនេះមានភារកិច្ច៖

-ចុះស្រាវជ្រាវ និងលើកវិធានការដោះស្រាយឱ្យមានប្រសិទ្ធភាពនូវរាល់បាតុភាពដីធ្លីដែលកើតឡើងនៅតាមបណ្ដាខេត្ត-ក្រុង។

-ធ្វើរបាយការណ៍អំពីវិធានការដោះស្រាយ និងលទ្ធផលនៃការងារខាងលើជូនរាជរដ្ឋាភិបាល។

-ក្នុងករណីកើតមានបាតុកម្ម កូដកម្មពាក់ព័ន្ធនឹងបញ្ហាដីធ្លីនៅមុខព្រះបរមរាជវាំង មុខមន្ទីរព្រឹទ្ធសភា មុខមន្ទីររដ្ឋសភា មុខទីស្ដីការគណៈរដ្ឋមន្ត្រី និងនៅតាមទីធ្លាសាធារណៈខេត្ត-ក្រុងផ្សេងៗទៀត គណៈកម្មការនេះត្រូវបញ្ជូនមន្ត្រីផ្លូវការទៅជួបពិភាក្សាជាមួយតំណាងបាតុករ កូដករ ដើម្បីដោះស្រាយបញ្ហាដោយសន្តិវិធី។ ទន្ទឹមនឹងនោះ ត្រូវរាយការណ៍ជាបន្ទាន់មករាជរដ្ឋាភិបាលដើម្បីចាត់វិធានការសមស្រប។

**ប្រការ៤**

សមាជិកនៃគណៈកម្មការទាំងអស់ ត្រូវចូលរួមការប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន។ គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់សម្រាប់សម្រួលការងារ។

**ប្រការ៥**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្ដីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៦**

រដ្ឋមន្ត្រីទទួលបន្ទុកគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ អស់លោកដែលមានឈ្មោះក្នុងប្រការ១ និងប្រការ២ត្រូវទទួលអនុវត្តសេចក្ដីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

# ព្រះរាជក្រម

នស/រកម/០៦៩៩/០៩

**យើង**

**ព្រះបាទសម្តេចព្រះនរោត្តម សីហនុ រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស**
**អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់រដ្ឋធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

**ប្រកាសឱ្យប្រើ**

ច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលរដ្ឋសភាបាន អនុម័តកាលពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៩៩ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី២ និង ព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យច្បាប់នេះឱ្យទាន់តាមការកំណត់របស់មាត្រា១១៣ ថ្មីរបស់រដ្ឋធម្មនុញ្ញ និងដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថា ស្របទាំងស្រុងនឹងរដ្ឋធម្មនុញ្ញ មាន សេចក្តីទាំងស្រុងដូចតទៅ៖

មាត្រា១

ត្រូវបានបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ចំណុះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា២

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា៣

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអាចអមដោយរដ្ឋលេខាធិការ និង/ឬអនុរដ្ឋលេខាធិការតាមការចាំបាច់ ។

មាត្រា៤

ការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា៥

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

មាត្រា៦

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩

បានបង្គំទូលថ្វាយ

សូមឡាយព្រះហត្ថលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខ១២៨ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩៩

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ហត្ថលេខា និងត្រា**

**ណាឌី តាន់**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ៦២អនក្រ/បក

**អនុក្រឹត្យ**
**ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ២០អនក្រ/បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៩៩

**សម្រេច**

**ជំពូកទី១ បទប្បញ្ញត្តិទូទៅ**

**មាត្រា១**

អនុក្រឹត្យនេះកំណត់ការរៀបចំបណ្តាអង្គភាពរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងកំណត់បេសកកម្មរបស់ក្រសួង និងមុខការរបស់បណ្តាអគ្គនាយកដ្ឋាន នាយកដ្ឋាននានា និងអង្គភាពមូលដ្ឋាននៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២ បេសកកម្ម និងរចនាសម្ព័ន្ធ

**មាត្រា២**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រគល់បេសកកម្មឱ្យដឹកនាំ និងគ្រប់គ្រងការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និងភូមិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា លើកលែងតែតំបន់ណា ឬសមត្ថកិច្ចណាដែលរាជរដ្ឋាភិបាលប្រគល់ឱ្យស្ថាប័នមួយផ្សេងទៀត។

**មាត្រា៣**

ដើម្បីអនុវត្តបេសកកម្មរបស់ខ្លួន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានភារកិច្ចដូចតទៅ៖

១-ក្នុងបេសកកម្មរៀបចំដែនដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវ៖

-លើកសំណើ និងដាក់ឱ្យអនុវត្តនូវនយោបាយរៀបចំដែនដី ដែលធានាតុល្យភាពនៃកិច្ចអភិវឌ្ឍទីក្រុង និងជនបទ និងការបែងចែកផលនៃការរីកចម្រើន។

-ធ្វើការសិក្សា និងការវិភាគសម្រាប់អនាគតទាក់ទងនឹងការរៀបចំដែនដី។ លើកសំណើ និងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានចាំបាច់ទាំងឡាយ ក្នុងការអនុវត្តនយោបាយរៀបចំដែនដី។ លើកសំណើនយោបាយផែនការសកម្មភាព និងវិធានការសមស្របដែលអនុគ្រោះដល់ការអភិវឌ្ឍដែនដី។

-យកចិត្តទុកដាក់ដល់ភាពសុខដុមនៃនយោបាយអភិវឌ្ឍន៍លើវិស័យនានា និងដល់ចំណងផ្សារភ្ជាប់គ្នារវាងសកម្មភាពនៅថ្នាក់ក្រសួង និងថ្នាក់ខេត្ត-ក្រុង។ ការងាររៀបចំដែនដី ជាការងារមានចរិតអន្តរវិស័យដែលទាមទារឱ្យក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់សហការជាមួយក្រសួងពាក់ព័ន្ធ ធ្វើជាសេនាធិការក្នុងការប្រមែប្រមូលទិន្នន័យរូបវន្ត ទិន្នន័យសេដ្ឋកិច្ច ទិន្នន័យសង្គមកិច្ច ប្រជាសាស្ត្រ... ដើម្បីរៀបចំយុទ្ធសាស្ត្រកំណត់តំបន់សំខាន់ៗដូចជាតំបន់អភិវឌ្ឍន៍សេដ្ឋកិច្ច

តំបន់អភិវឌ្ឍន៍ឧស្សាហកម្ម តំបន់ទីក្រុង តំបន់ជនបទ តំបន់អភិរក្សធម្មជាតិ តំបន់ទេសចរណ៍ តំបន់ការពារបេតិកភណ្ឌ ព្រមទាំងទីតាំងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច សង្គមកិច្ច គមនាគមន៍ ទីតាំងរដ្ឋបាលសាធារណៈ និងតំបន់ឯទៀត ដែលកំណត់ដោយរាជរដ្ឋាភិបាល

-អនុវត្តនយោបាយរៀបចំដែនដី ដែលមានភាពអនុគ្រោះដល់តំបន់ជនបទ និងតំបន់អាទិភាពរបស់រាជរដ្ឋាភិបាល

-យកចិត្តទុកដាក់ចំពោះសេចក្តីសម្រេច ស្តីពីការកសាងហេដ្ឋារចនាសម្ព័ន្ធឱ្យស្របទៅតាមអាទិភាពនៃនយោបាយរៀបចំដែនដី និងនយោបាយវិសហមជ្ឈការរដ្ឋបាល

-ជំរុញនយោបាយលើកទឹកចិត្តការវិនិយោគទៅរកតំបន់ជនបទ និងតំបន់អាទិភាពរបស់រាជរដ្ឋាភិបាលដោយសហការជាមួយក្រសួងអភិវឌ្ឍន៍ជនបទ និងស្ថាប័នពាក់ព័ន្ធដទៃទៀត

-ចូលរួមអនុវត្តការងារពាក់ព័ន្ធនឹងអាងទន្លេមេគង្គស្របតាមភារកិច្ចរបស់ក្រសួង។

២-ក្នុងបេសកកម្មការងារនគរូបនីយកម្ម និងសំណង់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវ៖

-ធ្វើការស្រាវជ្រាវ និងការវិភាគសម្រាប់អនាគត និងចងក្រងស្ថិតិទាំងឡាយទាក់ទងនឹងការងារនគរូបនីយកម្ម និងសំណង់។ លើកសំណើ និងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានចាំបាច់ទាំងឡាយក្នុងការអនុវត្តនយោបាយនគរូបនីយកម្ម និងសំណង់។

-លើកសំណើនយោបាយ ផែនការសកម្មភាព និងវិធានការសម្រាប់ការដោះស្រាយសំណង់អនាធិបតេយ្យ និងការសាងសង់លំនៅឋានដោយរក្សាទេសភាពរមណីយដ្ឋាន នៅក្នុងទីក្រុង និងទីប្រជុំជន ជនបទ និងការពារបរិស្ថាន។

-កំណត់វិធានទាំងឡាយ និងរៀបចំបទបញ្ញាទាក់ទងនឹងការកាន់កាប់ដីធ្លី នគរូបនីយកម្ម សំណង់ អស្សាមិករណ៍ ការកំណត់ដីបម្រុង

-ចេញលិខិតអនុញ្ញាត និងការយល់ព្រមទាំងឡាយទាក់ទងនឹងនគរូបនីយកម្ម និងសំណង់

-ជំរុញការសាងសង់លំនៅឋាន សង្គមកិច្ច ធ្វើប្រតិបត្តិការរៀបចំទីក្រុង ធ្វើការបែងចែកដីជាឡូត៍ជាតំបន់អភិវឌ្ឍន៍

-យកចិត្តទុកដាក់ដល់ការសាងសង់ និងការថែទាំអគារសាធារណៈ

-រួមជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីការពារបេតិកភណ្ឌ និងរមណីយដ្ឋានប្រវត្តិសាស្ត្រ

-រួមជាមួយអាជ្ញាធរអប្សរាដើម្បីការពារបេតិកភណ្ឌ និងរមណីយដ្ឋានប្រវត្តិសាស្ត្រក្នុងតំបន់ ជាសមត្ថកិច្ចរបស់អាជ្ញាធរ

-រួមជាមួយក្រសួងបរិស្ថាន ដើម្បីថែរក្សាការពារបរិស្ថាន ទេសភាព រមណីយដ្ឋានធម្មជាតិ និងប្រព័ន្ធអេកូ។

៣-ក្នុងបេសកកម្មការងារសុរិយោដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានភារកិច្ចធ្វើការស្រាវជ្រាវ កសាងលិខិតបទដ្ឋានទាំងឡាយ ដែលទាក់ទងនឹងការងារគ្រប់គ្រងប្រើប្រាស់ដីធ្លី តាមប្រព័ន្ធព័ត៌មានវិទ្យា។ ធ្វើការវាស់វែងគូរប្លង់សុរិយោដី និងចេញប័ណ្ណសម្គាល់សិទ្ធិលើដីធ្លីទូទាំងព្រះរាជាណាចក្រកម្ពុជា ធ្វើការងារអភិរក្សសុរិយោដី។

៤-ក្នុងបេសកកម្មការងារភូមិសាស្ត្រ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានភារកិច្ចគ្រប់គ្រង និងផ្សព្វផ្សាយផែនទី ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ដែលផលិតផែនទីជំនាញ ដើម្បីឱ្យផែនទីទាំងអស់ប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រឯកភាពគ្នា។

៥-គ្រប់គ្រង ត្រួតពិនិត្យ កំណត់សមត្ថភាពបច្ចេកទេសវិជ្ជាជីវៈ និងចេញលិខិតអនុញ្ញាតអាជីវកម្ម ដល់រូបវន្តបុគ្គល និងនីតិបុគ្គលដែលធ្វើអាជីវកម្មទាក់ទងនឹងលំនៅឋាន ការប្រើប្រាស់ដីធ្លី ការសាងសង់ និងការសិក្សាធ្វើគម្រោងប្លង់។

៦-តម្រង់ទិសណែនាំ តាមដានត្រួតពិនិត្យរាល់កិច្ចការលើវិស័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និងភូមិសាស្ត្រ

៧-ផ្សព្វផ្សាយ អប់រំ បណ្តុះបណ្តាលច្បាប់ បទប្បញ្ញត្តិ និងបច្ចេកទេសវិជ្ជាជីវៈ ដែលទាក់ទងនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និងភូមិសាស្ត្រ។

៨-ធ្វើសហប្រតិបត្តិការជាមួយអន្តរជាតិ និងអង្គការនានា ដើម្បីដំណើរការល្អនៃវិស័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និងភូមិសាស្ត្រ។

៩-សហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការប្រមូលពន្ធពីបេតិកភណ្ឌ។

មាត្រា៤

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានរចនាសម្ព័ន្ធដូចតទៅ៖

១-ថ្នាក់កណ្តាល៖

-ខុទ្ទកាល័យរដ្ឋមន្ត្រី

-អធិការដ្ឋាន

-អគ្គនាយកដ្ឋានរដ្ឋបាលរួមមាន៖

+នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ

+នាយកដ្ឋានបុគ្គលិក

+នាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញកិច្ច

+នាយកដ្ឋាននីតិកម្ម

+នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចការវិនិយោគ និងទំនាក់ទំនងអន្តរជាតិ

-អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្មរួមមាន៖

+នាយកដ្ឋានស្រាវជ្រាវ និងបទប្បញ្ញត្តិ

+នាយកដ្ឋានរៀបចំដែនដី

+នាយកដ្ឋាននគរូបនីយកម្ម

-អគ្គនាយកដ្ឋានសំណង់រួមមាន៖

+នាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់

+នាយកដ្ឋានសិក្សាគម្រោងប្លង់

+នាយកដ្ឋានសំណង់

-អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្ររួមមាន៖

+នាយកដ្ឋានគ្រប់គ្រងដីធ្លី

+នាយកដ្ឋានអធិការកិច្ចភូមិបាល

+នាយកដ្ឋានបច្ចេកទេស

+នាយកដ្ឋានអភិរក្សសុរិយោដី

+នាយកដ្ឋានភូមិសាស្ត្រ

-មន្ទីរពិសោធ

-មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ

-គ្រឹះស្ថាន និងសហគ្រាសក្រោមឱវាទ

-អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

២-អង្គការមូលដ្ឋាន៖

-មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង

-ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលខណ្ឌ-ស្រុក

អង្គការលេខរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ។

## ជំពូកទី៣ ខុទ្ទកាល័យរដ្ឋមន្ត្រី

### មាត្រា៥

ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលកំណត់តាមបទប្បញ្ញត្តិ នៃអនុក្រឹត្យលេខ២០អនក្រ/បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ដូចមានយោងក្នុងមូលបទខាងលើ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន។

## ជំពូកទី៤ អធិការដ្ឋាន

### មាត្រា៦

អធិការដ្ឋានរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានភារកិច្ចជាសេនាធិការឱ្យក្រសួងក្នុងការងារ៖

-ធ្វើអធិការកិច្ចជាប្រចាំទៅលើគ្រប់អង្គភាពក្រោមឱវាទក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ធ្វើរបាយការណ៍ជាប្រចាំជូនរដ្ឋមន្ត្រី អំពីការប្រព្រឹត្តទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ច ហើយនិងអំពីមធ្យោបាយកែលំអការប្រព្រឹត្តទៅអង្គភាពនោះ

-ពិនិត្យ សម្រុះសម្រួល និងដោះស្រាយវិវាទរដ្ឋបាលដែលពាក់ព័ន្ធដល់សមត្ថកិច្ច និងសកម្មភាពរបស់មន្ត្រី និងភ្នាក់ងាររបស់ក្រសួង

-ប្រតិបត្តិកិច្ចការតាមការដែលរដ្ឋមន្ត្រីបានប្រគល់ជូន

-អធិការដ្ឋានដឹកនាំដោយអធិការមួយរូប និងអមដោយអធិការរង ជាជំនួយការតាមការចាំបាច់។

**ជំពូកទី៥ អគ្គនាយកដ្ឋានរដ្ឋបាល**

**មាត្រា៧**

អគ្គនាយកដ្ឋានរដ្ឋបាល មានភារកិច្ចជាសេនាធិការឱ្យក្រសួងក្នុងការងារ៖

-គ្រប់គ្រងការងារ ដូចជារដ្ឋបាល បូកសរុបរបាយការណ៍ ឯកសារ បុគ្គលិក ផែនការ ហិរញ្ញវត្ថុ សម្ភារៈបរិក្ខារ ក្របខ័ណ្ឌក្រសួង និងការងារសិក្សាស្រាវជ្រាវនីតិកម្ម

-សម្របសម្រួលរាល់សកម្មភាពរដ្ឋបាលក្នុងក្រសួង ជាមួយបណ្តាអង្គភាពមូលដ្ឋានខេត្តក្រុង និងជាមួយក្រសួង ឬស្ថាប័ននានា

-រៀបចំកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច និងវិនិយោគ ស្របតាមនយោបាយរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ដោយសហការជាមួយក្រសួង អង្គការ ស្ថាប័នជាតិ និងអន្តរជាតិ

-ធ្វើទំនាក់ទំនងជាមួយសាធារណជន និងអន្តរជាតិ

អគ្គនាយកដ្ឋានរដ្ឋបាល ដឹកនាំដោយអគ្គនាយកមួយរូប និងមានអគ្គនាយករងជាជំនួយការតាមការចាំបាច់។ អគ្គនាយកដ្ឋាននេះមាននាយកដ្ឋានចំណុះចំនួន៥គឺ៖

+នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ

+នាយកដ្ឋានបុគ្គលិក

+នាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

+នាយកដ្ឋាននីតិកម្ម

+នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចការវិនិយោគ និងទំនាក់ទំនងអន្តរជាតិ។

**មាត្រា៨**

នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅមានតួនាទី និងភារកិច្ចដូចតទៅ៖

-សម្របសម្រួលសកម្មភាពការងារគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់កណ្តាល រវាងថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋានចំណុះក្រសួង

-កសាងផែនការការងាររបស់ក្រសួង

-គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗ របស់ក្រសួង

-រៀបចំខ្លឹមសារប្រជុំ សន្និបាត សន្និសីទ សិក្ខាសាលា និងពិធីបុណ្យផ្សេងៗ

-ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាលក្នុងទីស្តីការក្រសួង

-បូកសរុប និងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់ក្រសួង

-ធ្វើទំនាក់ទំនងអន្តរក្រសួង និងសាធារណជន

-សរុបព័ត៌មានអត្ថបទសារព័ត៌មានដែលពាក់ព័ន្ធដល់ក្រសួង នាយកដ្ឋានរដ្ឋបាលដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់។

**មាត្រា៩**

នាយកដ្ឋានបុគ្គលិក មានតួនាទី និងភារកិច្ចដូចតទៅ៖

-គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈរបស់ក្រសួង ដោយធ្វើទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-រៀបចំលិខិតរដ្ឋបាល សម្រាប់គ្រប់គ្រងអាជីព

-ធ្វើកម្មវិធីអំពីតំណែងឯកទេស និងធនធានមនុស្សរបស់ក្រសួង

-វាយតម្លៃតម្រូវការក្នុងការបណ្តុះបណ្តាលបុគ្គលិក

-តាមដាន វាយតម្លៃសមត្ថភាពបច្ចេកទេសរបស់មន្ត្រីរាជការក្នុងក្រសួង

-រៀបចំការងារបៀវត្ស ពលកម្ម ប្រាក់កម្រៃ និងគ្រប់គ្រងការងារសង្គមរបស់ក្រសួង

-រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងព័ត៌មានប្រតិបត្តិ។

នាយកដ្ឋានបុគ្គលិកដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់។

**មាត្រា១០**

នាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញកិច្ចមានតួនាទី និងភារកិច្ចដូចតទៅ៖

-សហការសម្របសម្រួលជាមួយបណ្តានាយកដ្ឋាន អង្គភាព មន្ទីរចំណុះក្រសួង ដើម្បីកសាងផែនការចំណូលចំណាយថវិការបស់ក្រសួង និងមន្ទីរខេត្ត-ក្រុង

-ប្រមូលចំណូលឱ្យបានសមស្របតាមច្បាប់ហិរញ្ញវត្ថុបង់ចូលថវិការដ្ឋ

-ប្រមូលផ្តុំ និងកែតម្រូវជំពូកថវិកាហិរញ្ញវត្ថុ

-តាមដានវិវឌ្ឍកការគ្រប់គ្រងគណនីពិសេស

-ប្រមូលផ្តុំតម្រូវការ ធ្វើកម្មវិធីចំណាយគ្រប់គ្រងការរៀបចំជួសជុលសម្ភារៈ និងបរិក្ខារ របស់ក្រសួង និងខេត្ត-ក្រុង ។

-ទំនាក់ទំនងការងារជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ឬស្ថាប័ននានា ដែលពាក់ព័ន្ធនឹងធ្វើការចំណាយថវិកាបម្រើកិច្ចប្រតិបត្តិការរបស់ក្រសួង និងខេត្ត-ក្រុង

-ចូលរួមពិនិត្យគុណភាពបរិមាណរាល់មុខសម្ភារៈ ឧបករណ៍ដែលត្រូវបញ្ចូលឃ្លាំង

-គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ

-ធ្វើកម្មវិធីចំណាយលើមធ្យោបាយធ្វើដំណើរ និងដឹកជញ្ជូន

-ធ្វើកិច្ចបញ្ជាការជាប្រចាំនូវសលាកប័ត្រ និងគណនេយ្យរូបធាតុ

-ព័ត៌មានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី

-ត្រួតពិនិត្យបច្ចេកទេសនៃប្រតិបត្តិលទ្ធកម្មសាធារណៈ

-រៀបចំ និងគ្រប់គ្រងប្រព័ន្ធទិន្នន័យរបស់ក្រសួង និងកំណត់កម្មវិធីចំណាយអភិវឌ្ឍន៍ សេដ្ឋកិច្ចលើគ្រប់ផ្នែកទាំងអស់

-សិក្សា និងវាយតម្លៃលើផ្នែកហិរញ្ញវត្ថុ និងផ្នែកសេដ្ឋកិច្ចលើគម្រោងការខាងវិនិយោគ ដែលមានប្រភពចំណាយក្នុង ឬក្រៅប្រទេសក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍

-សម្របសម្រួលជំនួយពីបរទេស និងត្រួតពិនិត្យការអនុវត្ត

-ណែនាំការងារជំនាញ ផែនការដល់គ្រប់បណ្តាអង្គភាពខេត្ត-ក្រុងដែលយកថវិការបស់ ក្រសួងទៅប្រើប្រាស់តាមគោលការណ៍ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ធ្វើរបាយការណ៍បូកសរុបការងារប្រចាំឆមាស និងប្រចាំឆ្នាំ ។

នាយកដ្ឋាននេះ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការ ចាំបាច់ ។

**មាត្រា១១**

នាយកដ្ឋាននីតិកម្មមានតួនាទី និងភារកិច្ចដូចតទៅ៖

-ជាសេនាធិការរបស់ក្រសួងក្នុងកិច្ចការនីតិកម្ម

-កសាងសេចក្តីព្រាងច្បាប់ អនុក្រឹត្យ ប្រកាស សារាចរ បទបញ្ជា លិខិតបទដ្ឋាន និងឯកសារផ្សេងៗទៀតរបស់ក្រសួង

-ពិនិត្យកែសម្រួលអត្ថបទច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋានរបស់នាយកដ្ឋាន និងបណ្តាអង្គភាព មន្ទីរចំណុះឱ្យស្របតាមច្បាប់ជាធរមាន

-ផ្តល់យោបល់ផ្នែកគតិយុត្តដល់បណ្តានាយកដ្ឋាន អង្គភាព មន្ទីរចំណុះ ក្នុងការអនុវត្តសមត្ថកិច្ចរបស់ខ្លួនឱ្យសមស្រប

-ចូលរួមបណ្តុះបណ្តាលផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានស្តីពីការរៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និងភូមិសាស្ត្រ

-ពិនិត្យ និងផ្តល់យោបល់ អំពីលក្ខណៈគតិយុត្តលើសំណុំលិខិតអនុញ្ញាតកាន់កាប់ដីធ្លី សំណុំលិខិតសុំអនុញ្ញាតសាងសង់ សំណុំលិខិតធ្វើអាជីវកម្មសិក្សាគម្រោងប្លង់ សំណុំលិខិតសុំអនុញ្ញាតធ្វើ អាជីវកម្ម សាងសង់សំណុំលិខិតសុំអនុញ្ញាតបើក និងបិទការដ្ឋានសាងសង់ដែលឋិតនៅក្នុងថ្នាក់កណ្តាល

-សហការជាមួយអធិការដ្ឋានរបស់ក្រសួងក្នុងការអង្កេតនូវរាល់ការអនុវត្តច្បាប់ និងដោះស្រាយវិវាទដែលពាក់ព័ន្ធដីធ្លី និងសំណង់

-គ្រប់គ្រងបណ្ណាល័យសម្រាប់ក្រសួង។

នាយកដ្ឋាននីតិកម្មដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់។

**មាត្រា១២**

នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចការវិនិយោគ និងទំនាក់ទំនងអន្តរជាតិមានតួនាទី និងភារកិច្ចដូចតទៅ៖

-រៀបចំកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច និងវិនិយោគ ស្របតាមនយោបាយរៀបចំដែនដី និងនគរូបនីយកម្ម ដោយធ្វើទំនាក់ទំនងជាមួយបណ្តាអ្នកផ្តល់ទុនជាប្រាក់ខ្ចី ឬជាជំនួយអន្តរជាតិ អ្នកវិនិយោគទុន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងទីស្តីការគណៈរដ្ឋមន្ត្រី

-វិភាគបណ្តាគម្រោងវិនិយោគទុនអំពីគុណភាព និងចំណុចខ្វះខាត ឬភាពមិនប្រក្រតីរបស់គម្រោងក្នុងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ខេត្ត-ក្រុង

-តាមដានការអនុវត្តគម្រោងដែលបានអនុម័តហើយ

-សម្របសម្រួលជំនួយបរទេស

-ធ្វើផែនការទំនាក់ទំនងបរទេស

-ធ្វើជាសេនាធិការឱ្យក្រសួងក្នុងការធ្វើទំនាក់ទំនង សហប្រតិបត្តិការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងធ្វើសហប្រតិបត្តិការអន្តរជាតិ។

នាយកដ្ឋាននេះដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់។

## ជំពូកទី៦ អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម

### មាត្រា១៣

អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម មានភារកិច្ចជាសេនាធិការឱ្យក្រសួងក្នុងការងារៈ

-លើកសំណើ និងអនុវត្តនយោបាយយុទ្ធសាស្ត្រ រៀបចំដែនដី និងនគរូបនីយកម្ម ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម ប្រកបដោយតុល្យភាព និងចីរភាព សំដៅការពារផលប្រយោជន៍ទូទៅ និងធ្វើឱ្យមានសណ្តាប់ធ្នាប់សាធារណៈ សោភ័ណភាព ការពារបរិស្ថាន ការពារធនធានធម្មជាតិ សម្បត្តិវប្បធម៌ និងបេតិកភណ្ឌ

-ចងក្រងព័ត៌មាន ទិន្នន័យដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីធ្វើការសិក្សាវិភាគសម្រាប់អនាគតរៀបចំកសាងគោលនយោបាយ ផែនការ កម្មវិធី នីតិវិធី ច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋាន ស្តង់ដារ និងវិធានការដែលទាក់ទងនឹងការរៀបចំដែនដី និងនគរូបនីយកម្ម

-ណែនាំ តាមដាន ត្រួតពិនិត្យ និងជំរុញការអនុវត្តនយោបាយរៀបចំដែនដី និងនគរូបនីយកម្មឱ្យបានសមស្របទូទាំងប្រទេស

-ពិនិត្យគម្រោងស្នើសុំទីតាំងសាងសង់

-លើកផែនការបណ្តុះបណ្តាលជំនាញបច្ចេកទេសដល់បុគ្គលិកក្រសួង និងបណ្តាមន្ទីរខេត្ត-ក្រុង

-សហការជាមួយអង្គការអន្តរជាតិ និងអង្គការនានា។

អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្មដឹកនាំដោយអគ្គនាយកមួយរូប និងមានអគ្គនាយករងជាជំនួយការតាមចាំបាច់។

អគ្គនាយកដ្ឋាននេះមាននាយកដ្ឋានចំណុះចំនួន៣ដូចតទៅ៖

+នាយកដ្ឋានស្រាវជ្រាវ និងបទប្បញ្ញត្តិ

+នាយកដ្ឋានរៀបចំដែនដី

+នាយកដ្ឋាននគរូបនីយកម្ម

**មាត្រា១៤**

នាយកដ្ឋានស្រាវជ្រាវ និងបទប្បញ្ញត្តិមានតួនាទី និងភារកិច្ចដូចតទៅ៖

-ធ្វើទំនាក់ទំនង សហការជាមួយក្រសួង ស្ថាប័ន និងបណ្តាខេត្ត-ក្រុង ដើម្បីស្រាវជ្រាវប្រមូលព័ត៌មាន ស្ថិតិ ទិន្នន័យ សម្រាប់ជាមូលដ្ឋានក្នុងការចងក្រងច្បាប់ស្តីពីការគ្រប់គ្រង ប្រើប្រាស់ដីធ្លីអស្សាមិករណ៍ កំណត់ដីបម្រុង និងធ្វើសេចក្តីណែនាំ សារាចរ បទប្បញ្ញត្តិ លិខិតបទដ្ឋាន ដែលទាក់ទងនឹងការរៀបចំដែនដី និងនគរូបនីយកម្ម

-ត្រួតពិនិត្យផលប៉ះពាល់នយោបាយរៀបចំដែនដី និងនគរូបនីយកម្មដែលបណ្តាលមកពីគម្រោងវិនិយោគក្នុង និងក្រៅប្រទេស

-កំណត់លក្ខណវិនិច្ឆ័យទីតាំង និងប្រភេទអាជីវកម្មនៃគម្រោងអភិវឌ្ឍន៍ ដែលប្រើប្រាស់ហិរញ្ញវត្ថុជាតិ អន្តរជាតិ រដ្ឋ និងឯកជន។

នាយកដ្ឋានស្រាវជ្រាវ និងបទប្បញ្ញត្តិដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់។

**មាត្រា១៥**

នាយកដ្ឋានរៀបចំដែនដីមានតួនាទី និងភារកិច្ចដូចតទៅ៖

-រៀបចំគោលនយោបាយ ផែនការ និងយុទ្ធសាស្ត្ររៀបចំដែនដី ធានាការប្រើប្រាស់ដីធ្លីធនធានធម្មជាតិឱ្យបានសមស្រប

-ប្រកបដោយតុល្យភាព និងចីរភាព

-រៀបចំឯកសារបច្ចេកទេសសម្រាប់ការប្រជុំអន្តរក្រសួង

-ធ្វើសេនាធិការជូនក្រសួងក្នុងការកសាងនីតិវិធី សម្រាប់ធ្វើសេមាថ្នាក់ជាតិ សេមាតាមវិស័យ សេមាថ្នាក់តំបន់ និងថ្នាក់ខេត្ត-ក្រុង

-ធ្វើវិភាគសម្រាប់អនាគត និងកសាងទម្រង់គម្រោង ផែនការ កម្មវិធី ក្នុងការរៀបចំកែលំអបណ្តាញហេដ្ឋារចនាសម្ព័ន្ធកម្រិតជាតិដើម្បីអភិវឌ្ឍន៍ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការកំណត់បណ្តាញគមនាគមន៍ ប្រព័ន្ធធារាសាស្ត្រ អាងទឹក កំពង់ផែ អាកាសយានដ្ឋាន និងកំណត់ការរៀបចំដែនដី ចែកជាតំបន់សំខាន់ៗដូចជា៖ តំបន់ឧស្សាហកម្ម កសិកម្ម ពាណិជ្ជកម្ម លំនៅឋាន ទេសចរណ៍ និងតំបន់ធម្មជាតិដូចជា៖ ព្រៃ ភ្នំ បឹង ជ្រោះ ទន្លេ សមុទ្រ ឆ្នេរសមុទ្រ តំបន់រក្សាទុកជាដើម

-តាមដានការអនុវត្តការងាររបស់បណ្តាក្រសួង និងអាជ្ញាធរដែនដីខេត្ត-ក្រុង ទាក់ទងនឹងការរៀបចំដែនដីឱ្យស្របតាមអាទិភាពដែលបានកំណត់ក្នុងក្របខ័ណ្ឌនយោបាយរៀបចំដែនដី

-តាមដានកត់ត្រាជាប្រចាំរាល់ទិន្នន័យសេដ្ឋកិច្ចសង្គមលើគម្រោងផែនទីជាតិ ។

នាយកដ្ឋានរៀបចំដែនដីដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់ ។

**មាត្រា១៦**

នាយកដ្ឋាននគរូបនីយកម្មមានតួនាទី និងភារកិច្ចដូចតទៅ៖

-លើកសំណើសេចក្តីព្រាងច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋានស្តីពីនគរូបនីយកម្ម

-អនុវត្តនយោបាយនគរូបនីយកម្មដើម្បីអភិវឌ្ឍទីក្រុង តំបន់ជុំវិញទីក្រុង ទីប្រជុំជន ជនបទ និងតំបន់ផ្សេងៗទៀតដែលជះឥទ្ធិពលលើទីក្រុង ដើម្បីលើកស្ទួយសណ្តាប់ធ្នាប់សង្គម សោភ័ណភាព សុវត្ថិភាព និងសុខុមាលភាព

-សិក្សារៀបចំប្លង់មេ និងប្លង់លំអិត ដោយបែងចែកទីក្រុង និងតំបន់ជុំវិញទីក្រុង ជាតំបន់សម្រាប់ទីតាំងមជ្ឈមណ្ឌលពាណិជ្ជកម្ម សិប្បកម្ម រដ្ឋបាល ទីតាំងសម្រាប់សកម្មភាពអប់រំ លំនៅឋាន ដីបម្រុង សាលារៀន ទីលានកីឡា ចំណីសងខាង ផ្លូវសាធារណៈ ទីលំហែកាយ មន្ទីរពេទ្យ ទីសក្ការៈបូជា វត្តអារាម សួនច្បារសាធារណៈជាដើម ។

-សហការជាមួយស្ថាប័នពាក់ព័ន្ធ រៀបចំគម្រោងបណ្តាញហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ប្រព័ន្ធធ្វើដំណើរសាធារណៈ បណ្តាញលូទឹកស្អុយ បណ្តាញទឹកស្អាត អគ្គិសនី ទូរគមនាគមន៍ និង បណ្តាញផ្សេងៗទៀតសម្រាប់តម្រូវការក្នុងក្រុង

-រៀបចំកែលំអគុណភាពទីក្រុង និងតំបន់ថ្មី ក្នុងទីក្រុង

-រៀបចំគម្រោងបង្កើតទីក្រុងថ្មី និងតំបន់អភិវឌ្ឍន៍សហគមន៍ថ្មី

-តាមដានកត់ត្រា វិភាគទិន្នន័យ សេដ្ឋកិច្ច សង្គម សមត្ថភាពផ្គត់ផ្គង់ ដឹកជញ្ជូន ស្ថិតិជំរឿន ដង់ស៊ីតេ កំណើនប្រជាជន និងកត្តាផ្សេងៗទៀតដែលជះឥទ្ធិពលទៅលើការអភិវឌ្ឍទីក្រុង។

-ពិនិត្យ និងផ្តល់លិខិតអនុញ្ញាតសាងសង់

-ត្រួតពិនិត្យ និងមានវិធានការសម្រាប់អនុវត្តនយោបាយនគរូបនីយកម្មឱ្យមានប្រសិទ្ធភាព។

នាយកដ្ឋាននគរូបនីយកម្មដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់។

## ជំពូកទី៧ អគ្គនាយកដ្ឋានសំណង់

### មាត្រា១៧

អគ្គនាយកដ្ឋានសំណង់ មានភារកិច្ចជាសេនាធិការឱ្យក្រសួងក្នុងការងារ

-លើកស្ទួយខឿនស្ថាបត្យកម្មក្នុងវិស័យសំណង់ឱ្យមានលក្ខណៈជាតិ និងទំនើបទាន់សម័យ

-ស្រាវជ្រាវ រៀបចំបទប្បញ្ញត្តិ ទម្រង់បែបបទ ក្បួនខ្នាត លក្ខណវិនិច្ឆ័យបច្ចេកទេស បច្ចេកវិទ្យា បទដ្ឋានបច្ចេកទេសផ្នែកសំណង់ និងស្ថាបត្យកម្មរួមទាំងស្តង់ដារសម្ភារៈបរិក្ខារសំណង់ឱ្យបានឯកភាព

-តម្រង់ទិស ណែនាំ តាមដាន ត្រួតពិនិត្យការសាងសង់ ការជួសជុល ការថែទាំ ការរុះរើរាល់បណ្តាគម្រោងសំណង់អគាររបស់រដ្ឋ ឯកជន អង្គការនានា រួមទាំងសំណង់បេតិកភណ្ឌ និងសំណង់ផ្សេងៗទៀត។ សំណង់ផ្សេងៗទៀតនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង។

-គ្រប់គ្រង ពិនិត្យ កំណត់សមត្ថភាពបច្ចេកទេសវិជ្ជាជីវៈ និងចេញលិខិតអនុញ្ញាតអាជីវកម្មដល់រូបវន្តបុគ្គល និងនីតិបុគ្គលដែលធ្វើអាជីវកម្មទាក់ទងទៅនឹងការសាងសង់ និងការសិក្សាគម្រោងប្លង់

-ត្រួតពិនិត្យ និងដាក់ឱ្យធ្វើការពិសោធសម្ភារៈសំណង់

-កំណត់ស្តង់ដារ គុណភាព សម្ភារៈ បរិក្ខារសំណង់ ដែលនាំចូលមកពីបរទេស និងផលិតក្នុងប្រទេស

-លើកផែនការបណ្តុះបណ្តាលជំនាញបច្ចេកទេសដល់បុគ្គលិកក្រសួង និងបណ្តាមន្ទីរខេត្ត ក្រុង និងធ្វើទំនាក់ទំនង ណែនាំបច្ចេកទេសដល់បណ្តាគ្រឹះស្ថានបណ្តុះបណ្តាលមុខវិជ្ជាសំណង់ និងស្ថាបត្យកម្ម

-សម្របសម្រួលជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីត្រួតពិនិត្យបណ្តាគម្រោងវិនិយោគសំណង់

អគ្គនាយកដ្ឋានសំណង់ដឹកនាំដោយអគ្គនាយកមួយរូប និងមានអគ្គនាយករងជំនួយការតាមការចាំបាច់។ អគ្គនាយកដ្ឋានសំណង់មាននាយកដ្ឋានចំណុះចំនួន៣៖

+នាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់

+នាយកដ្ឋានសិក្សាគម្រោងប្លង់

+នាយកដ្ឋានសំណង់

**មាត្រា១៨**

នាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់មានតួនាទី និងភារកិច្ចដូចតទៅ៖

-ស្រាវជ្រាវកសាង បទប្បញ្ញត្តិ ទម្រង់បែបបទ ក្បួនខ្នាត លក្ខណវិនិច្ឆ័យបច្ចេកទេស បច្ចេកវិទ្យា បទដ្ឋានបច្ចេកទេសផ្នែកសំណង់ និងស្ថាបត្យកម្ម រួមទាំងសម្ភារៈបរិក្ខារសំណង់

-កំណត់ស្តង់ដារប្រភេទសម្ភារៈ បរិក្ខារសំណង់ និងលក្ខណវិនិច្ឆ័យបច្ចេកទេសគុណភាព ការងារសំណង់ និងចូលរួមផ្តល់យោបល់ អំពីគុណភាពសំណង់ តម្រូវការគុណភាពសម្ភារៈបរិក្ខារ គ្រឿងចក្រ សំណង់ដែលនាំចូលពីបរទេសតាមការផ្លាស់ប្តូរពាណិជ្ជកម្ម និងផលិតក្នុងស្រុក

-ចងក្រងបណ្តាបញ្ជីតម្លៃសម្ភារៈសំណង់ គ្រឿងចក្រសំណង់ និងពលកម្មដែលប្រែប្រួលតាមខេត្ត-ក្រុង និងតាមដានជាប្រចាំនូវការប្រែប្រួលថ្លៃនៅតាមទីផ្សារទាំងនោះ

-ត្រួតពិនិត្យ និងដាក់ឱ្យធ្វើការពិសោធសម្ភារៈ គ្រឿងផ្គុំសំណង់ ដី ព្រមទាំងស្រាវជ្រាវបង្កើតមុខសម្ភារៈសំណង់ថ្មីៗ ដោយប្រើប្រាស់វត្ថុធាតុដើមក្នុងប្រទេស បម្រើឱ្យលំនៅឋានរបស់ប្រជា

ពលរដ្ឋ។ ស្រាវជ្រាវជាប្រចាំសម្ភារៈផលិតចេញថ្មីៗ គ្រឿងចក្របរិក្ខារបម្រើឱ្យការងារសាងសង់ទំនើបៗលើទីផ្សារជាតិ និងអន្តរជាតិ

-សហការជាមួយនាយកដ្ឋានបុគ្គលិក និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការបណ្តុះបណ្តាលជំនាញបច្ចេកទេសដល់បុគ្គលិកក្រសួង និងបណ្តាមន្ទីរខេត្ត-ក្រុង។ ចាត់ចែងអប់រំ ផ្សព្វផ្សាយឯកសារបច្ចេកទេសសំណង់ដល់គ្រប់មជ្ឈដ្ឋាន ដើម្បីលើកស្ទួយប្រសិទ្ធភាពសេដ្ឋកិច្ច សុវត្ថិភាព និងសុខុមាលភាពសាធារណៈ ព្រមទាំងណែនាំបច្ចេកទេសដល់គ្រឹះស្ថានបណ្តុះបណ្តាលមុខវិជ្ជាសំណង់ និងស្ថាបត្យកម្ម។

នាយកដ្ឋាននេះដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់។

**មាត្រា១៩**

នាយកដ្ឋានសិក្សាគម្រោងប្លង់មានតួនាទី និងភារកិច្ចដូចតទៅ៖

-សិក្សាគម្រោងប្លង់សាងសង់ថ្មី ជួសជុល កែលំអ ពង្រីក បើកទូលាយអគាររបស់បណ្តាក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីខេត្ត-ក្រុងដែលប្រើប្រាស់ថវិការបស់ឯកជន អង្គការនានា អ្នកវិនិយោគទុនក្នុងប្រទេស ឬក្រៅប្រទេស និងអង្គការអន្តរជាតិ។

-សិក្សាស្រាវជ្រាវធ្វើគម្រោងប្លង់ដែលចែកចេញជាផ្នែកឯកសារបច្ចេកទេស ស្ថាបត្យកម្ម និងផ្នែកគំនូរប្លង់។

-សិក្សាស្រាវជ្រាវគម្រោងប្លង់ និងធ្វើបញ្ជីប៉ាន់ស្មានសម្ភារៈនៃគម្រោងសំណង់សាធារណៈ។

-ត្រួតពិនិត្យគម្រោងប្លង់ស្ថាបត្យកម្ម និងបច្ចេកទេសសំណង់អគារ

-ត្រួតពិនិត្យសៀវភៅបន្ទុកនៃការដ្ឋានសាងសង់

-ត្រួតពិនិត្យបណ្តាគម្រោងប្លង់ អ្នកវិនិយោគនានាអំពីតម្រូវការពិតនៃសម្ភារៈសំណង់នាំចូលជារូបិយប័ណ្ណ

-គ្រប់គ្រង ត្រួតពិនិត្យ និងកំណត់សមត្ថភាពបច្ចេកទេស និងចេញលិខិតអនុញ្ញាតបើកអាជីវកម្មដល់រូបវន្តបុគ្គល និងនីតិបុគ្គលដែលធ្វើអាជីវកម្មទាក់ទងនឹងការសិក្សាធ្វើគម្រោងប្លង់ និងការសាងសង់។

នាយកដ្ឋានសិក្សាគម្រោងដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់។

**មាត្រា២០**

នាយកដ្ឋានសំណង់មានតួនាទី និងភារកិច្ចដូចតទៅ៖

-ណែនាំ តាមដាន ត្រួតពិនិត្យរាល់ការងារបច្ចេកទេសក្នុងការសាងសង់ វុះរើតាមដំណាក់កាលនីមួយៗ ដើម្បីធានាសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ គុណភាពសំណង់

-ចេញលិខិតអនុញ្ញាតបើក និងបិទការដ្ឋានរបស់បណ្តាសហគ្រាស ក្រុមហ៊ុន អង្គភាពសាងសង់នានា

-ចូលរួមធ្វើកោសលវិច័យនានា ផ្តល់សំណុំឯកសារបច្ចេកទេសដល់ស្ថាប័នមានសមត្ថកិច្ចក្នុងករណីវិវាទបញ្ហាសាងសង់ រុះរើ បាក់ស្រុត និងករណីបទល្មើសផ្សេងទៀតដែលផ្ទុយនឹងបទដ្ឋានបច្ចេកទេស

-សិក្សាលើបច្ចេកទេសសាងសង់ទំនើប រឹងមាំ មានប្រសិទ្ធភាពជាសកល និងឆាប់រហ័សដែលកំពុងត្រូវប្រើប្រាស់នៅប្រទេសនានា ពិសេសបណ្តាប្រទេសអាស៊ាន

-រៀបចំបទប្បញ្ញត្តិ សេចក្តីណែនាំក្នុងការជួសជុល ថែទាំ ប្រើប្រាស់សំណង់អគារសាធារណៈ និងបេតិកភណ្ឌ

-តាក់តែងកម្មវិធី និងកសាងគម្រោងថវិកាជួសជុល ថែទាំធំៗ ព្រមទាំងធានាអំពីលក្ខណៈបច្ចេកទេសសំណង់តាមកិច្ចសន្យា

-ស្រង់ស្ថិតិ វិភាគទិន្នន័យសេដ្ឋកិច្ច តម្លៃវប្បធម៌ ក្នុងការប្រើប្រាស់អគារសាធារណៈនិងបេតិកភណ្ឌ

-ណែនាំត្រួតពិនិត្យរាល់ការងារបច្ចេកទេសក្នុងការជួសជុល កែសម្រួល ដើម្បីធានាសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ ប្រសិទ្ធភាពសេដ្ឋកិច្ច សោភ័ណភាព គុណភាពសំណង់នៃគ្រប់បណ្តាសំណង់សាធារណៈ និងគ្រប់បណ្តាសំណង់បេតិកភណ្ឌ។

នាយកដ្ឋានសំណង់ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់។

## ជំពូកទី៨ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ

**មាត្រា២១**

អគ្គនាយកដ្ឋានសុរិយោដី ភូមិសាស្ត្រមានភារកិច្ចជាសេនាធិការឱ្យក្រសួងក្នុងការងារ៖

-ជាសេនាធិការរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់លើកិច្ចការសុរិយោដី និងភូមិសាស្ត្រ

-សិក្សាស្រាវជ្រាវ កសាងគម្រោងលិខិតបទដ្ឋានទាំងឡាយដែលពាក់ព័ន្ធនឹងការងារគ្រប់គ្រង និងប្រើប្រាស់ដីធ្លី

-កសាងទិសដៅ និងផែនការ ដើម្បីបម្រើការងារលើវិស័យសុរិយោដី និងភូមិសាស្ត្រ

-ធ្វើការវាស់វែង និងគូរផែនទីសុរិយោដី

-ចេញប័ណ្ណសម្គាល់ដីធ្លីទូទាំងព្រះរាជាណាចក្រកម្ពុជា

-ធ្វើការអភិរក្សសុរិយោដី និងធ្វើអធិការកិច្ចក្នុងតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ

-កំណត់ព្រំប្រទល់ក្បាលដី

-អភិរក្សទ្រព្យសម្បត្តិរដ្ឋ

-សហការជាមួយនាយកដ្ឋានបុគ្គលិក និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការបណ្តុះបណ្តាលបច្ចេកទេស និងមុខជំនាញដល់មន្ត្រីរាជការក្រោមឱវាទ

-ធ្វើជាសេនាធិការឱ្យក្រសួង ក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ និងបណ្តាប្រទេសនានាលើផ្នែកបច្ចេកទេស វិទ្យាសាស្ត្របម្រើឱ្យវិស័យសុរិយោដី និងភូមិសាស្ត្រ

-សហការជាមួយក្រសួង និងស្ថាប័ននានា ក្នុងការគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ។

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រដឹកនាំដោយអគ្គនាយកមួយរូប និងមានអគ្គនាយករងជាជំនួយការតាមការចាំបាច់ ។

អគ្គនាយកដ្ឋាននេះមាននាយកដ្ឋានចំណុះចំនួន៥គឺ៖

+នាយកដ្ឋានគ្រប់គ្រងដីធ្លី

+នាយកដ្ឋានអធិការកិច្ចភូមិបាល

+នាយកដ្ឋានបច្ចេកទេស

+នាយកដ្ឋានអភិរក្សសុរិយោដី

+នាយកដ្ឋានភូមិសាស្ត្រ ។

**មាត្រា២២**

នាយកដ្ឋានគ្រប់គ្រងដីធ្លីមានតួនាទី និងភារកិច្ចដូចតទៅ៖

-សិក្សាស្រាវជ្រាវច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធនឹងដីធ្លី

-ចងក្រងគោលការណ៍ វិធានការ និងការណែនាំពាក់ព័ន្ធនឹងការងារសុរិយោដី

-កសាងផែនការ និងកម្មវិធីការងារសុរិយោដី

-លើកគម្រោងសហប្រតិបត្តិការ លើវិស័យបច្ចេកទេសវិទ្យាសាស្ត្រ

-កំណត់ចំណាត់ថ្នាក់ដី និងវាយតម្លៃដី

-លើកសំណើអំពីនយោបាយដីធ្លី និងបដិរូបដីធ្លី ។

នាយកដ្ឋានគ្រប់គ្រងដីធ្លីដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់ ។

**មាត្រា២៣**

នាយកដ្ឋានអធិការកិច្ចភូមិបាលមានតួនាទី និងភារកិច្ចដូចតទៅ៖

-ត្រួតពិនិត្យការអនុវត្តច្បាប់ គោលការណ៍ ការណែនាំ តាមបណ្តាអង្គភាពចំណុះអគ្គនាយកដ្ឋាន ។

-ត្រួតពិនិត្យការងារបច្ចេកទេស ក្នុងការកំណត់វិធីសាស្ត្រវាស់វែង ការគណនាការងារសុរិយោដីខេត្ត-ក្រុង និងស្រុក-ខណ្ឌ

-ត្រួតពិនិត្យការកាន់កាប់ឯកសារសុរិយោដី

-ត្រួតពិនិត្យការគ្រប់គ្រងហិរញ្ញវត្ថុ ។

នាយកដ្ឋានអធិការកិច្ចភូមិបាលដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់ ។

**មាត្រា២៤**

នាយកដ្ឋានអភិរក្សសុរិយោដីមានតួនាទី និងភារកិច្ចដូចតទៅ៖

-កាន់កាប់ និងគ្រប់គ្រងឯកសារសុរិយោដី

-ពិនិត្យ ផ្ទៀងផ្ទាត់សំណុំលិខិតសញ្ញាផ្សេងៗពាក់ព័ន្ធនឹងអចលនវត្ថុ

-ធ្វើការអភិរក្សទ្រព្យសម្បត្តិរដ្ឋ

-ចុះបញ្ជីដីធ្លី ធ្វើលេខាចារឹក និងចរន្តការ រាល់ការវិវត្តអំពីលក្ខណរូប និងគតិយុត្តរបស់អចលនវត្ថុ

-រក្សាឯកសារ និងប័ណ្ណសារដ្ឋានភូមិបាល

-ផ្តល់ព័តិមានដីធ្លី។

នាយកដ្ឋានអភិរក្សសុរិយោដីដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់។

**មាត្រា២៥**

នាយកដ្ឋានបច្ចេកទេសមានតួនាទី និងភារកិច្ចដូចតទៅ៖

-សិក្សា កំណត់វិធីសាស្ត្រវាស់វែង និងស្តង់ដារបច្ចេកទេស

-ណែនាំបច្ចេកទេសការងារសុរិយោដីខេត្ត-ក្រុង

-គ្រប់គ្រងទិន្នន័យដីធ្លីតាមប្រព័ន្ធសុរិយោដីទំនើប

-ធ្វើការវាស់វែង កំណត់ព្រំក្បាលដី និងគូរប្លង់ក្បាលដី

-បកស្រាយរូបថត ធ្វើអត្តសញ្ញាណក្បាលដី

-សិក្សា និងកំណត់នីតិវិធីនៃការកសាងប្លង់សុរិយោដី។

នាយកដ្ឋានបច្ចេកទេសដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់។

**មាត្រា២៦**

នាយកដ្ឋានភូមិសាស្ត្រមានតួនាទី និងភារកិច្ចដូចតទៅ៖

-ចាត់តាំង អនុវត្តភារកិច្ចវាស់វែង ដាំបង្គោលបណ្តាញត្រីកោណ និងគូរផែនទីគោលជាមូលដ្ឋានទូទាំងប្រទេស

-គ្រប់គ្រងផែនទីគ្រប់ប្រភេទរបស់ព្រះរាជាណាចក្រកម្ពុជា សំដៅឱ្យឯកភាពទូទាំងប្រទេស

-ចាត់តាំង ស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកទេសវាស់វែង ថតរូប គូរ និងបោះពុម្ពផ្សាយផែនទីគ្រប់ប្រភេទ

-សហការជាមួយនាយកដ្ឋានបុគ្គលិក និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការបណ្តុះបណ្តាលមន្ត្រី បុគ្គលិកផ្នែកភូមិសាស្ត្រ

-ធ្វើជាសេនាធិការឱ្យគណៈកម្មការកំណត់ព្រំដែនរាជរដ្ឋាភិបាល អំពីការងារខណ្ឌព្រំសីមា និងបោះបង្គោលព្រំដែនរដ្ឋ

-ធ្វើជាសេនាធិការឱ្យរាជរដ្ឋាភិបាលក្នុងការវាស់វែង កំណត់ និងកែតម្រូវព្រំប្រទល់រដ្ឋបាលក្នុងប្រទេស

-ជាមជ្ឈមណ្ឌលប្រមូលផ្តុំព័ត៌មានភូមិសាស្ត្រ និងធ្វើសកម្មភាពចាត់ចែងការងារខាងវិទ្យាសាស្ត្រ វាស់វែង និងផ្តល់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ

-បង្កើតប្រព័ន្ធព័ត៌មានភូមិសាស្ត្រជាតិឯកភាពគ្នាមួយសម្រាប់ព្រះរាជាណាចក្រកម្ពុជា

-កសាងផែនទី ជាពិសេសផែនទីគោល ផែនទីឋានលេខានៃព្រះរាជាណាចក្រកម្ពុជា

-គ្រប់គ្រង និងត្រួតពិនិត្យក្នុងការបោះពុម្ព ផលិតផែនទីគ្រប់ប្រភេទសម្រាប់ធ្វើអាជីវកម្ម។

នាយកដ្ឋានភូមិសាស្ត្រដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់។

## ជំពូកទី៩ មន្ទីរពិសោធ

### មាត្រា២៧

មន្ទីរពិសោធមានតួនាទី និងភារកិច្ចដូចតទៅ៖

-ត្រួតពិនិត្យ និងទទួលពិសោធន៍រាល់បណ្តាសម្ភារៈសំណង់ គ្រឿងផ្គុំសំណង់ និងភូគព្ភសាស្ត្រ ទីតាំងសាងសង់របស់ក្រសួង អតិថិជន

-ស្រាវជ្រាវបង្កើតសម្ភារៈសំណង់ដែលប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក

-ធ្វើរបាយការណ៍បច្ចេកទេសអំពីលទ្ធផលនៃការពិសោធ

-ណែនាំ និងត្រួតពិនិត្យកិច្ចការបច្ចេកទេសពិសោធន៍សំណង់ដល់មន្ទីរពិសោធនានា។

មន្ទីរពិសោធដឹកនាំដោយប្រធានមួយរូបថ្នាក់ស្មើប្រធាននាយកដ្ឋាន និងមានអនុប្រធានជាជំនួយការតាមការចាំបាច់ ។

## ជំពូកទី១០ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ

**មាត្រា២៨**

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមានភារកិច្ចជាសេនាធិការឱ្យក្រសួងក្នុងការងារ៖

-រៀបចំផែនការ និងកម្មវិធីបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ស្របតាមនយោបាយរបស់ក្រសួង

-បណ្តុះបណ្តាលមុខជំនាញបច្ចេកទេស និងបច្ចេកវិទ្យាទំនើបៗ

-បង្រៀនព័តិមានវិទ្យា

ការគ្រប់គ្រងព័តិមានតាមប្រព័ន្ធកុំព្យូទ័រទាក់ទងមុខជំនាញរបស់ក្រសួង

- ធ្វើវិក្រឹត្យការ សុក្រឹតការចំពោះមន្ត្រីរាជការរបស់ក្រសួង

-ផ្សព្វផ្សាយ អប់រំ ណែនាំអំពីនយោបាយ ច្បាប់ បទប្បញ្ញត្តិ និងបច្ចេកទេសពាក់ព័ន្ធនឹងការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និងភូមិសាស្ត្រ

-សហការជាមួយស្ថាប័នពាក់ព័ន្ធក្នុងការណែនាំ ត្រួតពិនិត្យការងារបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ នៅសាលាឯកជនពាក់ព័ន្ធនឹងការរៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និងភូមិសាស្ត្រ

-ធ្វើជាសេនាធិការឱ្យក្រសួងក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល សហគមន៍មូលដ្ឋាន និងបណ្តាប្រទេសនានា ។

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដឹកនាំដោយប្រធានមួយរូប ថ្នាក់ស្មើប្រធាននាយកដ្ឋាន និងមានអនុប្រធានជាជំនួយការតាមការចាំបាច់ ។

## ជំពូកទី១១ គ្រឹះស្ថាន និងសហគ្រាសក្រោមឱវាទ

**មាត្រា២៩**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានគ្រឹះស្ថាន និងសហគ្រាសក្រោមឱវាទដូចខាងក្រោម៖

-សហគ្រាសសំណង់ភ្នំពេញ

-សហគ្រាសគ្រឿងចក្រសំណង់ជួសជុល

-សហគ្រាសសិក្សាស្រាវជ្រាវគូរប្លង់

-សហគ្រាសសំណង់កំពង់ចាម

-សហគ្រាសសម្ភារៈដឹកជញ្ជូន

-រោងចក្រឥដ្ឋពណិ

-រោងចក្រអារឈើ

-រោងចក្រឡឥដ្ឋ

-រោងចក្រហ្វីប្រូស៊ីម៉ងត៍

សហគ្រាសទាំងនេះឋិតនៅក្នុងបញ្ជីសារពើភ័ណ្ឌរបស់ក្រសួង និងក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញកិច្ច។

**ជំពូកទី១២ អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ**

**មាត្រា៣០**

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមក្របខ័ណ្ឌនៃបទបញ្ញាកំណត់ក្នុងអនុក្រឹត្យលេខ៨១ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការ បង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកាក្នុងបណ្តាក្រសួង។

**ជំពូកទី១៣ អង្គភាពមូលដ្ឋាន**

**មាត្រា៣១**

នៅតាមខេត្ត-ក្រុងនីមួយៗមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី និងនៅតាមខណ្ឌ-ស្រុកនីមួយៗមានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ដែលទទួលបន្ទុកអនុវត្ត និងសម្របសម្រួលសកម្មភាពការងាររបស់ក្រសួង។

**ជំពូកទី១៤ អវសានប្បញ្ញត្តិ**

**មាត្រា៣២**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងនៅរដ្ឋបាលថ្នាក់កណ្តាល ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**មាត្រា៣៣**

ភារកិច្ចទាំងឡាយណាដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ស្ថាប័នដទៃ ប្រធាននៃស្ថាប័នដទៃទាំងនោះ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវសហការជាមួយគ្នា ដើម្បីបែងចែកការទទួលខុសត្រូវ និងអនុវត្តភារកិច្ចទាំងនោះតាមរយៈប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងប្រធានស្ថាប័នទាំងនោះ ។

**មាត្រា៣៤**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា៣៥**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការទាំងអស់ដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ។

**មាត្រា៣៦**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**លេខ៧៦ប្រក**

ប្រកាស

**ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង និងតួនាទី ភារកិច្ចរបស់បណ្ណាការិយាល័យក្រោមឱវាទ**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ២០អនក្រ/បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ/បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- តាមការចាំបាច់របស់ក្រសួង

**សម្រេច**

**ប្រការ១**

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុងមានតួនាទី និងភារកិច្ចដូចតទៅ៖

-អនុវត្តគោលនយោបាយ និងទិសដៅការងាររបស់ក្រសួង រួមមានការងាររៀបចំដែនដី ការងារនគរូបនីយកម្ម ការងារសំណង់ ការងារសុរិយោដី និងការងារភូមិសាស្ត្រ ដើម្បីធានានូវតុល្យភាព និងស្ថិរភាពនៃអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម សំដៅការពារផលប្រយោជន៍ និងសណ្តាប់ធ្នាប់ជាសាធារណៈ លើកកម្ពស់សោភ័ណភាពសង្គម ការពារសម្បត្តិធម្មជាតិ និងវប្បធម៌ជាតិ

-ចងក្រងឯកសារទិន្នន័យទាក់ទងការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និងភូមិសាស្ត្រ ដោយសហការជាមួយអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ

-អនុវត្តបទប្បញ្ញត្តិ លិខិតបទដ្ឋានបច្ចេកទេសនានារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ផ្តល់មតិយោបល់ និងពិនិត្យលើការស្នើសុំទីតាំងសាងសង់ ដោយផ្អែកលើលិខិតអនុញ្ញាតរបស់ក្រសួង

-សហការជាមួយអាជ្ញាធរដែនដី អង្គការជាតិ និងអង្គការអន្តរជាតិ

-ចូលរួមផ្តល់យោបល់អំពីគុណភាពសំណង់ បរិក្ខារ និងគ្រឿងចក្រ ព្រមទាំងដាក់ឱ្យពិសោធសម្ភារៈ គ្រឿងផ្គុំសំណង់ និងភូគព្ភសាស្ត្រ

-គ្រប់គ្រង តាមដាន ត្រួតពិនិត្យការសិក្សាស្រាវជ្រាវគម្រោងប្លង់ និងសំណង់បណ្តាខេត្ត-ក្រុង ស្រុក-ខណ្ឌ ឃុំ-សង្កាត់ ក្នុងសមត្ថកិច្ចរបស់ខ្លួន និងតាមការប្រគល់ភារកិច្ចពីក្រសួង

-ចេញលិខិតអនុញ្ញាតបើកផ្លាក និងបិទអាជីវកម្ម សិក្សាគម្រោងប្លង់ និងសាងសង់ដល់រូបវន្តបុគ្គល និងក្រុមជាងសំណង់ និងពិនិត្យ តាមដាន សមត្ថភាពបច្ចេកទេសអាជីវកម្ម

-លើកផែនការបណ្តុះបណ្តាលមន្ត្រីជំនាញ

-ណែនាំការងាររៀបចំការដ្ឋានសំណង់ បើក និងបិទការដ្ឋាន

-ចេញលិខិតអនុញ្ញាតសាងសង់

-តាមដានអនុវត្តបទប្បញ្ញត្តិ សេចក្ដីណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងការជួសជុល ថែទាំ ប្រើប្រាស់សំណង់អគារ សំណង់ការ្យ និងបេតិកភណ្ឌក្នុងខេត្ត-ក្រុង

-គ្រប់គ្រងដីធ្លីគ្រប់ប្រភេទ

-វាស់វែង និងគណនាឋានលេខា ស្ថានភាពដី និងក្បាលដី ក្នុងក្របខ័ណ្ឌសមត្ថកិច្ច និងភូមិសាស្ត្ររដ្ឋបាលដែលខ្លួនទទួលខុសត្រូវ

-កសាងប្លង់ដីគ្រប់ប្រភេទ៖ ប្លង់ស្ថានភាពដីទូទៅ ប្លង់សុរិយោដី ប្លង់ក្បាលដី ប្លង់ដីក្នុងទីប្រជុំជន

-ចូលរួមសិក្សា និងកសាងឯកសារពន្ធអាករដី និងលើកគម្រោងចំណូលពន្ធអាករដីប្រចាំឆ្នាំ ក្នុងទូទាំងខេត្ត-ក្រុង ក្នុងសមត្ថកិច្ចរបស់ខ្លួន។

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់។

**ប្រការ២**

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង មានការិយាល័យក្រោមឱវាទដូចតទៅ៖

១-ការិយាល័យរដ្ឋបាល

២-ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

៣-ការិយាល័យសុរិយោដី និងភូមិសាស្ត្រ

ថ្នាក់ស្រុក-ខណ្ឌមានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល។

ចំពោះខេត្ត-ក្រុងសំខាន់ៗ ដែលមានសកម្មភាពការងារច្រើន ក្រសួងអាចបង្កើតការិយាល័យបន្ថែមមួយចំនួនទៀតតាមការចាំបាច់។

**ប្រការ៣**

តួនាទី និងភារកិច្ចនៃបណ្ដាការិយាល័យរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុងមានដូចតទៅ៖

**ក-ការិយាល័យរដ្ឋបាល**

ការិយាល័យរដ្ឋបាលមានតួនាទី និងភារកិច្ចដូចតទៅ៖

-ធ្វើការងារលិខិតចេញ ចូល និងសារ វាយអង្គុលីលេខ និងកុំព្យូទ័រ

-ធ្វើការងារតម្កល់ឯកសារ និងព័ត៌មាន

-ធ្វើរបាយការណ៍ លើកទិសដៅ និងកម្មវិធីការងារ រៀបចំខ្លឹមសារសម្រាប់សន្និបាត សិក្ខាសាលា ឬការប្រជុំផ្សេងៗ

-គេហបាល រក្សាសុវត្ថិភាព សន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងអង្គភាព

-ពិធីការ និងទំនាក់ទំនងការងារសាធារណៈ

-រៀបចំបៀវត្សពលកម្ម និងគ្រប់គ្រងស្ថិតិ

-លើកសំណើដំឡើងឋានៈ និងដាក់ពិន័យ

-កសាងផែនការបណ្តុះបណ្តាលមន្ត្រី បុគ្គលិក

-កិច្ចការហិរញ្ញកិច្ចទូទៅ៖ គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យរបស់មន្ទីរ ការងារគណនេយ្យ និងគ្រប់គ្រងចំណូលចំណាយ

-កសាងផែនការចំណូលតាមច្បាប់ហិរញ្ញវត្ថុ

-គ្រប់គ្រងកិច្ចការវិនិយោគ

-ធ្វើលិខិតស្នាមរដ្ឋបាល

-ព្រាងឯកសារគតិយុត្ត

-ចូលរួមដោះស្រាយវិវាទដីធ្លី និងសំណង់

-អនុវត្តការងារអធិការកិច្ច

-ចូលរួមធ្វើការងារកោសលវិច័យជាមួយផ្នែកជំនាញឯកទេស។

ការិយាល័យនេះដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់។

**ខ-ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានតួនាទី និងភារកិច្ចដូចតទៅ៖

១-ការងាររៀបចំដែនដី និងនគរូបនីយកម្ម

-សហការជាមួយបណ្ដាអង្គភាពស្រុក-ខណ្ឌ ដើម្បីស្រាវជ្រាវប្រមូលឯកសារព័ត៌មាន និងចងក្រងទិន្នន័យប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គមដែលទាក់ទងនឹងការងាររៀបចំដែនដី និងនគរូបនីយកម្ម រួមមានចំនួនប្រជាជន ប្រភេទលំនៅឋាន ឬសំណង់ និងលក្ខណៈសេដ្ឋកិច្ចសង្គម ដូចជាជីវភាព សមត្ថភាពផ្គត់ផ្គង់ និងដឹកជញ្ជូន

-ចូលរួមកសាងប្លង់គោលស្រុក-ខណ្ឌ និងចងក្រងឯកសារផែនការជាតិ ស្ដីពីការងាររៀបចំដែនដី

-ផ្ដល់ព័ត៌មាន និងចូលរួមកំណត់បែបផែនប្រភេទដី

-ផ្សព្វផ្សាយបទប្បញ្ញត្តិ និងលិខិតបទដ្ឋានដែលទាក់ទងនឹងការងាររៀបចំដែនដី និងនគរូបនីយកម្មដល់ឃុំ ស្រុក

-តាមដានការអនុវត្តច្បាប់ បទប្បញ្ញត្តិការងាររៀបចំដែនដី និងនគរូបនីយកម្មរបស់អាជ្ញាធរមូលដ្ឋាន

-សហការជាមួយអង្គការជាតិ និងអន្តរជាតិ ក្នុងការអនុវត្តគោលនយោបាយរៀបចំដែនដី ធានាប្រើប្រាស់ដីធ្លី សម្រាប់ការអភិវឌ្ឍឱ្យមានតុល្យភាព និងស្ថិរភាពនៅក្នុងតំបន់

-កសាងទម្រង់គម្រោងការកម្មវិធី ក្នុងការរៀបចំអភិវឌ្ឍន៍ និងកែលំអបណ្ដាញហេដ្ឋារចនាសម្ព័ន្ធសម្រាប់ឃុំ-សង្កាត់ ស្រុក-ខណ្ឌ រួមមានបណ្ដាញគមនាគមន៍ ប្រព័ន្ធធារាសាស្ត្រ អាងទឹក កំពង់ផែ . . .

-រក្សាទុកឯកសាររៀបចំដែនដី

-ផ្ដល់មតិយោបល់ពាក់ព័ន្ធការស្នើសុំទីតាំងគម្រោងរបស់បណ្ដាក្រសួង និងស្ថាប័នបច្ចេកទេស ដូចជាឧស្សាហកម្ម ពាណិជ្ជកម្ម សាធារណការ កសិកម្ម ធនធានទឹក ទេសចរណ៍ វប្បធម៌ ក្រុមហ៊ុនឯកជននានា និងគម្រោងវិនិយោគអន្តរជាតិ

-រៀបចំកម្មវិធី និងសម្របសម្រួលការងារទំនាក់ទំនងរវាងឃុំ ស្រុក

-វិភាគ និងចងក្រងតារាងពាក់ព័ន្ធបច្ចេកទេសការងារនគរូបនីយកម្ម

-ពិនិត្យ និងគ្រប់គ្រងប្លង់ប្រើប្រាស់ដីធ្លី

-សិក្សាវិភាគលើកផែនការគម្រោងការអភិវឌ្ឍន៍ទីក្រុង តំបន់ជុំវិញទីក្រុង ទីប្រជុំជន និងតំបន់ជនបទ

-រៀបចំកែលំអសោភណភាព គុណភាពទីក្រុង និងតំបន់ថ្មីក្នុងទីក្រុង ស្រុក-ខណ្ឌ ទីប្រជុំជន ឬជនបទ

-សិក្សាប្លង់មេ និងគូរប្លង់លំអិត បែងចែកតំបន់អភិវឌ្ឍន៍ស្រុក-ខណ្ឌ ទីប្រជុំជន ឬជនបទ

-ពិនិត្យ តាមដានការអនុវត្តគម្រោងការ

-លើកសំណើសេចក្តីព្រាងច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋាន នគរូបនីយកម្មនៃបណ្តាសំណង់លំនៅឋានសាធារណៈ និងសង្គម

-អនុវត្តបទប្បញ្ញត្តិ លិខិតបទដ្ឋានទាក់ទងនឹងការងារហេដ្ឋារចនាសម្ព័ន្ធ រួមមានផ្លូវថ្នល់ក្នុង និងក្រៅក្រុង បណ្តាញទឹកស្អាត បណ្តាញទឹកស្អុយ បណ្តាញអគ្គិសនី ទូរគមនាគមន៍ និងសេវាសាធារណៈ ដូចជាសួនច្បារ ទីលំហែ ផ្ទាំងគំនូរផ្សាយពាណិជ្ជកម្ម ផ្លាកសញ្ញាផ្សេងៗ

-លើកគម្រោងជួសជុលបណ្តាញហេដ្ឋារចនាសម្ព័ន្ធខេត្ត-ក្រុង ស្រុក-ខណ្ឌ ឃុំ-សង្កាត់

-សិក្សាគូរប្លង់បណ្តាញគមនាគមន៍ ទឹកស្អាត លូទឹកភ្លៀង លូទឹកស្អុយ ប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធចែកចាយថាមពលអគ្គិសនី ឧស្ម័ន ទូរគមនាគមន៍ សេវាសាធារណៈ មានជាអាទិ៍ ទីលំហែកាយ សួនច្បារ ទីតាំងផ្លាកបង្គោលផ្សាយពាណិជ្ជកម្ម

- ចងក្រងឯកសារបច្ចេកទេសបណ្តាញហេដ្ឋារចនាសម្ព័ន្ធ និងប៉ាន់តម្លៃគម្រោងការ

-វាយតម្លៃការងារបច្ចេកទេស និងពិនិត្យលទ្ធភាពនៃការអនុវត្តគម្រោងក្នុងខេត្ត-ក្រុង ស្រុក-ខណ្ឌ ឃុំ-សង្កាត់

-សិក្សា និងស្រាវជ្រាវហេតុផលប៉ះពាល់របស់គម្រោងការវិនិយោគក្នុង និងក្រៅប្រទេស ទៅលើជីវភាព នយោបាយ សង្គម និងសុខុមាលភាពរបស់ប្រជាជន

-ពិនិត្យ ការបោះទីតាំងសាងសង់ និងរុះរើ ដោយផ្អែកលើលិខិតអនុញ្ញាតរបស់ក្រសួង

-រៀបចំរបាយការណ៍បូកសរុបការងាររៀបចំដែនដី និងនគរូបនីយកម្ម។

២-ការងារសំណង់

-ប្រមូលទិន្នន័យតាមខេត្ត-ក្រុង ដើម្បីចងក្រងបទប្បញ្ញត្តិពលកម្មសំណង់ សម្ភារៈបរិក្ខារ និងគ្រឿងចក្រសំណង់ និងប្រព័ន្ធវិស្វកម្ម

-ពិនិត្យ និងដាក់ឱ្យពិសោធសម្ភារៈ គ្រឿងផ្គុំសំណង់ និងភូគព្ភសាស្ត្រ

-ចូលរួមផ្តល់យោបល់អំពីគុណភាពសំណង់ បរិក្ខារ និងគ្រឿងចក្រសំណង់

-ប្រមូលចងក្រងទិន្នន័យតាមខេត្ត-ក្រុងនូវការងារឧតុនិយម ភូគព្ភសាស្ត្រ និងជលសាស្ត្រ លើកិច្ចការសំណង់

-ចងក្រងបញ្ជីតម្លៃពលកម្ម សម្ភារៈបរិក្ខារ និងគ្រឿងចក្រសំណង់ដែលប្រែប្រួលតាម ខេត្ត-ក្រុង

-វាយតម្លៃហេតុប៉ះពាល់បរិស្ថានតាមខេត្ត-ក្រុង ដើម្បីធ្វើគម្រោងសំណង់

-សិក្សាស្រាវជ្រាវគម្រោងប្លង់ និងធ្វើបញ្ជីប៉ាន់ស្មានសម្ភារៈ និងតម្លៃតាមសមត្ថកិច្ច របស់ខ្លួន

-ចេញលិខិតអនុញ្ញាតបើកអាជីវកម្ម សិក្សាគម្រោងប្លង់ និងសាងសង់ ដល់រូបវន្តបុគ្គល និងក្រុមជាងសំណង់

-ពិនិត្យ តាមដានសមត្ថភាពបច្ចេកទេសរបស់រូបវន្តបុគ្គល និងក្រុមជាងសំណង់ដែល ប្រកបអាជីវកម្ម សិក្សាគម្រោងប្លង់ និងសាងសង់

-ធ្វើកោសលវិច័យ និងដោះស្រាយវិវាទពាក់ព័ន្ធនឹងសំណង់

-ចូលរួមលើកផែនការបណ្តុះបណ្តាលជំនាញបច្ចេកទេសសំណង់

-ណែនាំការងាររៀបចំការដ្ឋាន ការការពារសុវត្ថិភាពពលកម្ម និងសណ្តាប់ធ្នាប់ សាធារណៈ

-ពិនិត្យសៀវភៅបន្ទុកនៃការដ្ឋានសាងសង់

-តាមដានអនុវត្តបទប្បញ្ញត្តិ លិខិតបទដ្ឋាន និងសេចក្តីណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងការជួសជុល ថែទាំ ប្រើប្រាស់សំណង់អគារ សំណង់ការ្យ និង បេតិកភណ្ឌក្នុងខេត្ត-ក្រុង

-តាក់តែងកម្មវិធី និងកសាងគម្រោងថវិកាជួសជុល ថែទាំអគារសាធារណៈរបស់ខេត្ត-ក្រុង

-ស្រង់ស្ថិតិ វិភាគទិន្នន័យសេដ្ឋកិច្ច តម្លៃវប្បធម៌ ក្នុងការប្រើប្រាស់អគារសាធារណៈ និងបេតិកភណ្ឌ

-ណែនាំ និងពិនិត្យសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ សោភ័ណភាព គុណភាពសំណង់ និងហេតុប៉ះពាល់ផ្សេងៗក្នុងការជួសជុល និងកែសម្រួលបណ្តាសំណង់សាធារណៈ និងបេតិកភណ្ឌ

-ចេញលិខិតអនុញ្ញាតជួសជុល និងរុះរើអគារ លំនៅឋាន និងអគារសាធារណៈ ។

-ការិយាល័យនេះដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់ ។

**គ.ការិយាល័យសុរិយោដី និងភូមិសាស្ត្រ**

ការិយាល័យសុរិយោដី មានតួនាទី និងភារកិច្ចដូចតទៅ៖

-វាស់វែង និងគណនាឋានលេខាលើដី ក្នុងក្របខ័ណ្ឌភូមិសាស្ត្ររដ្ឋបាលខេត្ត-ក្រុង

-ចូលរួមសិក្សា លើកគម្រោងកំណត់ប្លង់ទីប្រជុំជន និងពង្រីកទីប្រជុំជន

-ពិនិត្យផ្ទៀងផ្ទាត់សំណុំបែបបទ ចុះបញ្ជីជាប្រចាំ ធ្វើលេខាចារឹករាល់សំណុំលិខិតផ្លាស់ប្តូរសិទ្ធិ ប្លង់បច្ចេកទេស រក្សា និងធានាគុណភាពឯកសារ ប័ណ្ណសារដ្ឋាន ស្ថាបនាតារាងសម្គាល់ឈ្មោះអ្នកកាន់កាប់ដី តារាងឈ្មោះអ្នកកាន់កាប់ដីតាមលំដាប់អក្សរ

-ចូលរួមកសាងប្លង់ស្ថានភាពទូទៅ ទីប្រជុំជនខេត្ត-ក្រុង ស្រុក-ខណ្ឌ គ្រប់គ្រងដីទីប្រជុំជន

-ពិនិត្យ និងផ្តល់យោបល់លើឯកសារស្នើសុំកាន់កាប់ដី ក្នុងក្របខ័ណ្ឌនៃសិទ្ធិអំណាចដែលបានកំណត់

-សិក្សាអាករ និងពន្ធដី ប្រមូលផ្តុំសលាកប័ត្រឯកត្តភូតរាល់ប្រភេទដីនីមួយៗ ដើម្បីសរុបលើកគម្រោងចំណូលពន្ធអាករលើដីជូនថ្នាក់លើសម្រេច

-ប្រថាប់ត្រាផ្ទេរសិទ្ធិផ្សេងៗដែលពាក់ព័ន្ធនឹងដីធ្លី

-តាមដានត្រួតពិនិត្យ និងធ្វើរបាយការណ៍អំពីការប្រើប្រាស់ដីធ្លី

-សរុបរបាយការណ៍តាមរបបកំណត់

-ជួយមតិ យោបល់វាយតម្លៃលើរាល់បាតុភាពវិវាទដីធ្លី

-ចូលរួមការពារបន្ទាត់ព្រំដែនសីមាអន្តរជាតិ។

-ការិយាល័យនេះដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់

ប្រការ៤

-ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ មានតួនាទី និងភារកិច្ចដូចតទៅ៖

-ជាសេនាធិការឱ្យមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង ក្នុងការអនុវត្តផ្ទាល់ និងជាក់ស្តែងលើការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និងភូមិសាស្ត្រ

-ចុះពិនិត្យជាក់ស្តែងរាល់សំណើសុំសាងសង់ និងជួសជុលសំណង់ ដើម្បីធ្វើរបាយការណ៍បច្ចេកទេស

-តាមដាន ត្រួតពិនិត្យការអនុវត្តលិខិតសាងសង់ រុះរើ និងជួសជុល

-ពិនិត្យ និងធ្វើរបាយការណ៍បច្ចេកទេសលើបណ្តឹងវិវាទផ្ទះសំបែង

-ផ្សព្វផ្សាយលិខិតបទដ្ឋានពាក់ព័ន្ធនឹងការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និងភូមិសាស្ត្រ

-អង្កេត វាស់វែងដីធ្លី ប្រមូលផ្តុំចងក្រងឯកសារក្នុងក្របខ័ណ្ឌសមត្ថកិច្ចដែលបានកំណត់

-ចុះបញ្ជីអចលនវត្ថុតាមស្រុក-ខណ្ឌ ឃុំ-សង្កាត់

-ស្តាបនាសលាកប័ត្រឯកត្តភូតរាល់ប្រភេទដីនីមួយៗ លើកគម្រោងចំណូលពន្ធដីទូទាំងស្រុក-ខណ្ឌ

-អនុវត្តគម្រោងចំណូលដែលថ្នាក់លើសម្រេច ប្រថាប់ត្រា ផ្ទេរសិទ្ធិផ្សេងៗពាក់ព័ន្ធសំណង់ និងដីធ្លី

-គ្រប់គ្រងការងារលិខិតចេញចូល បញ្ជូនឯកសារ សរុបរបាយការណ៍ តាមរបបកំណត់

-ការិយាល័យនេះដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការតាមការចាំបាច់។

**ប្រការ៥**

នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល អគ្គនាយករៀបចំដែនដី និងនគរូបនីយកម្ម អគ្គនាយកសំណង់ អគ្គនាយកសុរិយោដី និងភូមិសាស្ត្រ ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង ប្រធានការិយាល័យចំណុះមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត-ក្រុង និងប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៩

**រដ្ឋមន្ត្រី**

<u>កន្លែងទទួល</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

"ដើម្បីជូនជ្រាប"

-ដូចប្រការ៥ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ០៦ប្រក

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៩៩

## សេចក្តីប្រកាសស្តីពីវិធានការលុបបំបាត់ភាពអនាធិបតេយ្យ ក្នុងបញ្ហាទន្ទ្រានកាន់កាប់ដីធ្លី

ដោយពិនិត្យឃើញថា ទោះមានគោលនយោបាយស្តីពីការគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ច្បាប់ភូមិបាលឆ្នាំ១៩៩២ និងលិខិតបទដ្ឋានជាច្រើនទៀតដែលរាជរដ្ឋាភិបាលបានដាក់ចេញជាបន្តបន្ទាប់ សំដៅពង្រឹងប្រសិទ្ធភាពគ្រប់គ្រង និងប្រើប្រាស់ដីធ្លីឱ្យបានចំទិសដៅ ក៏នៅតែមានជនខិលខូចមួយចំនួនបាន និងកំពុងឆ្លៀតឱកាសឥតឈប់ឈរបង្កនូវភាពអនាធិបតេយ្យ រានទន្ទ្រានយកដីធ្លីក្រោមរូបភាពធ្វើជាតំបន់អភិវឌ្ឍន៍ ឬធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន។ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះបាតុភាពទន្ទ្រានយកដីធ្លី ដោយសង់រោង សង់ខ្ទម សង់ផ្ទះ ឬដាំដំណាំនៅលើដីរបស់រដ្ឋ អាងទឹក តំបន់ការពារធម្មជាតិ ឧទ្យានជាតិ ដែនជម្រកសត្វព្រៃ ដែនបម្រុង ដីចំណីផ្លូវទាំងផ្លូវថ្នល់ និងផ្លូវដែក ដីរបស់ក្រុមហ៊ុនវិនិយោគ ព្រមទាំងដីរបស់ឯកជន នៅតាមទីកន្លែងជាច្រើន ជាពិសេសនៅតាមបណ្តោយផ្លូវជាតិសំខាន់ៗ និងផ្លូវរថភ្លើង។ ប្រសិនបើភាពអនាធិបតេយ្យបែបនេះនៅតែបន្តទៅទៀតនោះ វានឹងបង្កបង្កើតនូវឧបសគ្គ និងឥទ្ធិពលអាក្រក់រាំងស្ទះដល់ផែនការអភិវឌ្ឍន៍លើគ្រប់វិស័យនាពេលបច្ចុប្បន្ន ក៏ដូចជាពេលអនាគត។

ចំពោះមុខបាតុភាពនេះ រាជរដ្ឋាភិបាលចាំបាច់ដាក់ចេញនូវវិធានការបន្ទាន់ដូចតទៅ៖

១-មិនឱ្យមានសិទ្ធិជាឯកជនលើដីរបស់រដ្ឋ ជាអាទិ៍ ដីក្នុងដែនបម្រុងរុក្ខា ដែននេសាទ អាងតម្កល់ទឹកស្រោចស្រព តំបន់ការពារធម្មជាតិ ឧទ្យានជាតិ ដែនជម្រកសត្វព្រៃ ដីព្រៃលិចទឹក ដីព្រៃកោងកាង ចម្ការព្រៃដាំ ចម្ការកៅស៊ូ ស្ថានីយ៍ និងមជ្ឈមណ្ឌលបច្ចេកទេសកសិកម្ម បរិវេណមណ្ឌលរ៉ែ មណ្ឌលបេតិកភណ្ឌវប្បធម៌ វត្តអារាម សាលារៀន សួនសាធារណៈ ដីបម្រុង ដីចំណី

ផ្លូវថ្នល់ និងដីចំណីផ្លូវដែក ក៏ដូចជាដីរបស់ក្រុមហ៊ុនវិនិយោគ និងដីរបស់ឯកជនស្របច្បាប់តាមគ្រប់រូបភាព និងគ្រប់ទីកន្លែងក្នុងផ្ទៃប្រទេស និងបញ្ឈប់ជាបន្ទាន់សកម្មភាពរានទន្ទ្រានកាន់កាប់ដីតំបន់ដែលបានរៀបរាប់ខាងលើនេះ ព្រមទាំងអ្វីៗដទៃទៀត ដែលជាសម្បត្តិសាធារណៈរបស់រដ្ឋ និងសម្បត្តិឯកជនរបស់រដ្ឋ។

២-ហាមដាច់ខាតការចេញជាបន្តទៀតនូវបង្កាន់ដៃទទួលពាក្យស្នើសុំកាន់កាប់ដីធ្លី និងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លី ដែលបានមកពីការរំលោភបំពានខាងលើ ព្រមទាំងមានវិធានការយ៉ាងតឹងរ៉ឹងបំផុតតាមច្បាប់ជាធរមាន។

៣-អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវធ្វើការស្រាវជ្រាវជាបន្ទាន់ឱ្យបានម៉ត់ចត់ នូវរាល់បាតុភាពរានទន្ទ្រានកាន់កាប់ដីធ្លីគ្រប់ប្រភេទដោយល្មើសច្បាប់ ដែលកើតមាននៅក្នុងទីតាំងខេត្ត-ក្រុងរបស់ខ្លួន ហើយត្រូវមានវិធានការទប់ស្កាត់ជាបន្ទាន់ដោយផ្អែកលើគោលការណ៍ច្បាប់ជាធរមាន។

៤-បាតុភាពអនាធិបតេយ្យនេះ បើកើតឡើងនៅក្នុងទឹកដីនៃខេត្ត-ក្រុងណា គឺអាជ្ញាធរដែនដីនៃខេត្ត-ក្រុងនោះទទួលខុសត្រូវដោះស្រាយដោយស្មារតីម្ចាស់ការ។ ប្រសិនបើជួបប្រទះការលំបាកស្មុគស្មាញ អាជ្ញាធរខេត្ត-ក្រុង ត្រូវស្នើសុំអន្តរាគមន៍ជាបន្ទាន់ពីសំណាក់ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដែលមានការចាំបាច់។

៥-អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស មេបញ្ជាការគ្រប់យោធភូមិភាគ និងក្រសួង-ស្ថាប័នជំនាញពាក់ព័ន្ធ ត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាង ហើយចូលរួមសហការឱ្យបានទាន់ពេលវេលាជាមួយដែនដីអាជ្ញាធរខេត្ត-ក្រុង តាមសំណូមពរជាក់ស្តែង។

៦-បុគ្គល អង្គភាពឋិតនៅក្រោមឱវាទរបស់ក្រសួង ស្ថាប័នណា ឬប្រជាពលរដ្ឋណាដែលបានបង្កឱ្យមានសកម្មភាពអនាធិតេយ្យ លើបញ្ហារានទន្ទ្រានកាន់កាប់ដីធ្លី ដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ក្រសួង ស្ថាប័នសាមី និងអាជ្ញាធរនៅកន្លែងនោះ ត្រូវធ្វើការអប់រំណែនាំ និងជួយជំរុញអង្គភាព ឬបុគ្គលទាំងនោះឱ្យបញ្ឈប់សកម្មភាពល្មើសច្បាប់ ហើយតម្រូវឱ្យគេធ្វើការស្ម័យរុះរើសំណង់អនាធិបតេយ្យដែលបានសង់រួច តាមការកំណត់របស់អាជ្ញាធរដែនដីមូលដ្ឋាន

ដោយគ្មានល័ក្ខខ័ណ្ឌ បើមានការរឹងទទឹងមិនព្រមអនុវត្តតាមការណែនាំនេះទេ ក្រសួង ស្ថាប័នអាណាព្យាបាលសាមី និងអាជ្ញាធរមានសមត្ថកិច្ច ត្រូវដាក់វិន័យ ឬដកហូតមុខតំណែង និងទទួលទោសតាមច្បាប់ជាធរមាន តាមកម្រិតដែលបានប្រព្រឹត្ត ។

៧-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអាជ្ញាធរដែនដីខេត្ត-ក្រុងត្រូវតពិនិត្យឱ្យបានជាក់ស្តែងលើក្រុមហ៊ុនវិនិយោគដីធ្លី និងម្ចាស់ដីធ្លីទាំងឡាយមានទំហំធំ ដែលកន្លងមកបានទទួលគោលការណ៍វិនិយោគ ស្របច្បាប់ជាយូរមកហើយ ប៉ុន្តែបានទុកចោលដីទំនេរពុំទាន់បានចាប់ផ្តើមដំណើរការឱ្យស្របទៅតាមកិច្ចសន្យានោះឡើយ ។ សមត្ថកិច្ចពាក់ព័ន្ធទាំងនោះត្រូវចាត់វិធានការម៉ឺងម៉ាត់ ដើម្បីដោះស្រាយទៅតាមច្បាប់ជាធរមាន ។

៨-កំណត់ដីចំណីផ្លូវថ្នល់ និងដីចំណីផ្លូវរថភ្លើង សម្រាប់បម្រើការអភិវឌ្ឍលើវិស័យហេដ្ឋារចនាសម្ព័ន្ធដូចតទៅ៖

-ផ្លូវជាតិលេខមួយខ្ទង់ ដូចជាលេខ២, ៣, ៦, ៧ ចម្ងាយ២៥ម៉ែត្រពីសងខាងអ័ក្សផ្លូវ លើកលែងតែផ្លូវជាតិលេខ១, ៤, ៥ កំណត់ចម្ងាយ៣០ម៉ែត្រពីសងខាងអ័ក្សផ្លូវ

-ផ្លូវជាតិមានលេខពីរខ្ទង់ ដូចជាលេខ១១, ២២, ៦៤, ៧៨ ចម្ងាយ២៥ម៉ែត្រពីសងខាងអ័ក្សផ្លូវ

-ផ្លូវខេត្តចម្ងាយ២០ម៉ែត្រពីសងខាងអ័ក្សផ្លូវ

-ផ្លូវឃុំចម្ងាយ១៥ម៉ែត្រពីសងខាងអ័ក្សផ្លូវ

ការកំណត់ចំណីផ្លូវនេះ មិនយកមកអនុវត្តក្នុងទីប្រជុំជនទេ ។

-ផ្លូវរថភ្លើងចម្ងាយ២០ម៉ែត្រពីសងខាងអ័ក្សផ្លូវ ចំពោះទីក្រុង ទីរួមខេត្ត និងទីប្រជុំជន

-ផ្លូវរថភ្លើងចម្ងាយ៣០ម៉ែត្រពីសងខាងអ័ក្សផ្លូវ ចំពោះផ្លូវដែកដែលឋិតនៅក្រៅក្រុង

-ផ្លូវរថភ្លើងចម្ងាយ១០០ម៉ែត្រពីសងខាងអ័ក្សផ្លូវ ចំពោះផ្លូវដែកក្នុងតំបន់ព្រៃភ្នំដែលមានថ្មរមៀលធ្លាក់ ឬតំបន់ព្រៃខ្ពស់ ។

ចំពោះអចលនវត្ថុដទៃទៀតដែលជាសម្បត្តិសាធារណៈរបស់រដ្ឋ និងសម្បត្តិឯកជនរបស់រដ្ឋនឹងមានការកំណត់ដោយឡែក ។

*វាយឡើងវិញ*

៩-ក្រសួងមហាផ្ទៃ សហការជាមួយក្រសួងសាធារណៈការនិងដឹកជញ្ជូន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងការពារជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវកំណត់ពេលវេលាជាក់ស្តែងឱ្យបានសមស្រប ដើម្បីឱ្យអាជ្ញាធរខេត្ត-ក្រុងអនុវត្តការរុះរើសំណង់អនាធិបតេយ្យឱ្យចេញផុតពីចំណីផ្លូវ និងផ្លូវរថភ្លើង។ ចំពោះផ្លូវលំត្រូវមានការចូលរួមពីក្រសួងអភិវឌ្ឍន៍ជនបទ។

១០-ចំពោះមុខ និងជាបន្ទាន់ រាជរដ្ឋាភិបាលប្រគល់ភារកិច្ចជូនអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ចាប់ផ្តើមអនុវត្តការងាររបស់ខ្លួន នៅតាមបណ្តោយផ្លូវជាតិលេខ១ លេខ៤ និងតាមបណ្តោយផ្លូវដែក នៅរាជធានីភ្នំពេញ ហើយនិងឈានទៅអនុវត្តនៅទីកន្លែងដទៃទៀត តាមលំដាប់អាទិភាព។

១១-គណៈកម្មការដោះស្រាយបាតុភាពដីធ្លីនៅតាមខេត្ត-ក្រុងទូទាំងប្រទេស ត្រូវតាមដានការអនុវត្តរបស់អាជ្ញាធរដែនដីខេត្ត-ក្រុង ហើយត្រូវរាយការណ៍ជូនរាជរដ្ឋាភិបាលអំពីលទ្ធផលការងារដែលអនុវត្តបាន ព្រមទាំងការលំបាកស្មុគស្មាញក្នុងការអនុវត្ត ដើម្បីរាជរដ្ឋាភិបាលមានវិធានការជាក់ស្តែង។

ទទួលបានសេចក្តីប្រកាសនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ អគ្គនាយកដ្ឋាននគរបាលជាតិ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងខិតខំអនុវត្តវិធានការខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

*វាយឡើងវិញ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**លេខ០១៧សរន/សហវ/ពដ** រាជធានីភ្នំពេញ ថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៩

## សារាចរណែនាំស្តីពីការអនុវត្តពន្ធលើដីធ្លីមិនបានប្រើប្រាស់

យោងតាមបទប្បញ្ញត្តិស្តីពីសារពើពន្ធនៃច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ១១នស៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ១៩៩៤ និងច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង ដែលត្រូវបានប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨។

អនុវត្តតាមសេចក្តីសម្រេចលេខ០០៤សសរ/សហវ/ពដ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៩៨ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងអនុលោមតាមស្មារតីនៃអង្គសិក្ខាសាលាស្តីពីការ គ្រប់គ្រងប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់នាថ្ងៃទី២០ និង២១ ខែសីហា ឆ្នាំ១៩៩៩ នៅទីរួម ខេត្តសៀមរាប ដើម្បីធានាដល់ការដាក់អនុវត្តពន្ធលើដីធ្លីមិនបានប្រើប្រាស់ក្នុងក្របខ័ណ្ឌគ្រប់ខេត្ត ក្រុង ក្នុងព្រះរាជាណាចក្រកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមធ្វើការណែនាំដូចតទៅ៖

**១-អំពីអត្តសញ្ញាណកម្មនៃដីធ្លីមិនបានប្រើប្រាស់**

ដើម្បីឱ្យការគ្រប់គ្រងប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ ប្រព្រឹត្តទៅប្រកបដោយយុត្តិធម៌ សមភាព និងតម្លាភាពនោះ ចាំបាច់ត្រូវបែងចែកឱ្យបានដាច់ពីគ្នារវាងដីធ្លីមិនបានប្រើប្រាស់ដែល បុគ្គលទិញទុកសម្រាប់លក់យកតម្លៃលើស។

**ក-ដីមានសំណង់ឋិតនៅក្នុងតំបន់លំនៅឋាន**

ដីប្រភេទនេះច្រើនមាននៅទីក្រុង ទីប្រជុំជន តាមផ្លូវជាតិ តាមដងទន្លេ ឬស្ទឹង នឹង ត្រូវបានចាត់ទុកជាដីប្រើប្រាស់ដោយមិនត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ប្រសិនបើដីនោះមាន សំណង់ ហើយត្រូវបានកម្មសិទ្ធិករដីនោះប្រើប្រាស់ជាកន្លែងស្នាក់នៅជាគោលសំខាន់របស់ខ្លួន និងបាន

ស្នាក់នៅកន្លែងនោះចំនួន១៨៣ថ្ងៃ ឬច្រើនជាងគិតចាប់ពីថ្ងៃទី០១ ខែតុលានៃឆ្នាំកន្លងទៅ រហូតដល់ថ្ងៃទី៣០ ខែកញ្ញានៃឆ្នាំប្រមូលពន្ធ។ កន្លែងស្នាក់នៅ ជាគោលសំខាន់របស់កម្មសិទ្ធិករគឺជាកន្លែងដែលកម្មសិទ្ធិករបានដេកនៅ ហូបចុកយ៉ាងជាក់លាក់ជារៀងរាល់ថ្ងៃ ក្រោយពីពេលត្រលប់ពីបំពេញការងារប្រចាំថ្ងៃ។ សម្រាប់ការកំណត់ពន្ធនេះ កម្មសិទ្ធិករម្នាក់ពុំអាចមានកន្លែងស្នាក់នៅជាគោលសំខាន់លើសពីមួយកន្លែងបានទេ។

ដីមានសំណង់ឋិតនៅក្នុងតំបន់លំនៅឋានទាំងឡាយណា ពុំមានលក្ខណៈដូចបានរៀបរាប់ក្នុងចំណុច "ក" ខាងលើ ត្រូវចាត់ទុកជាដីធ្លីមិនបានប្រើប្រាស់ នឹងត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់។

**ខ-ដីជួលដែលមានសំណង់ និងមានការកាន់កាប់**

សំដៅដល់ដីដែលឋិតនៅក្នុងតំបន់លំនៅឋាន ឬឋិតនៅក្នុងតំបន់ដែលមានសកម្មភាពសេដ្ឋកិច្ច ដូចជាតំបន់ឧស្សាហកម្ម កសិកម្ម ពាណិជ្ជកម្ម ទេសចរណ៍ . . . ហើយដីនោះមានសំណង់ផ្សេងៗ ដូចជាលំនៅឋាន អគារ ឃ្លាំង . . . ដែលបានជួលទាំងដីទាំងសំណង់ ទៅឱ្យអតិថិជនដើម្បីយកឈ្នួលប្រចាំខែ ប្រចាំឆ្នាំ ឬក្រោមកិច្ចសន្យារយៈពេលវែង។ ដីប្រភេទនេះត្រូវចាត់ទុកជាដីធ្លីប្រើប្រាស់ ដែលមិនជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ លុះណាតែដីទាំងនោះផ្តល់លាភការប្រចាំខែលើសពី៨០%នៃចំនួនមួយភាគដប់ពីរនៃតម្លៃដីនៅក្នុងឆ្នាំប្រមូលពន្ធ គុណនឹងមេគុណដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយក្នុងនោះតម្លៃដីត្រូវបានកំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់។

ដីជួលដែលមានសំណង់មានការកាន់កាប់ ហើយដែលពុំមានលក្ខណៈដូចបានរៀបរាប់ក្នុងចំណុច "ខ" ត្រូវចាត់ទុកថាដីធ្លីមិនបានប្រើប្រាស់នឹងត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់។

**គ-ដីដែលមានសកម្មភាពសេដ្ឋកិច្ចស្របតាមការកំណត់តំបន់របស់រដ្ឋ**

សំដៅដល់ដីដែលកម្មសិទ្ធិករប្រើប្រាស់សម្រាប់សកម្មភាពសេដ្ឋកិច្ច ដូចជាដាំដុះ ឧស្សាហកម្ម ពាណិជ្ជកម្ម ទេសចរណ៍ ស្របតាមការកំណត់តំបន់របស់រដ្ឋ...។ ដីប្រភេទនេះត្រូវចាត់ទុកជាដីធ្លីប្រើប្រាស់មិនត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ លុះត្រាតែប្រាក់ចំណូលប្រចាំខែបានមកពីសកម្មភាពសេដ្ឋកិច្ចទាំងនោះ លើសពីចំនួន៨០%នៃចំនួនមួយភាគដប់ពីរ នៃតម្លៃដីនៅក្នុងឆ្នាំប្រមូលពន្ធ គុណនឹងមេគុណដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយ

ក្នុងនោះតម្លៃដី ត្រូវបានកំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់។ ដីដែលមានសកម្មភាពសេដ្ឋកិច្ចពុំមានលក្ខណៈដូចបានរៀបរាប់ក្នុងចំណុច "គ" ត្រូវបានចាត់ទុកជាដីធ្លីមិនបានប្រើប្រាស់នឹងត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់។

ត្រង់ចំណុច "គ" នេះត្រូវកត់សម្គាល់ និងយកចិត្តទុកដាក់លើការខុសគ្នារវាងដីដាំដុះរបស់ប្រជាពលរដ្ឋធ្វើស្រែចម្ការពិតប្រាកដ ដែលមិនត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងដីរបស់អាជីវកររកស៊ីទិញលក់ដីដោយមិនធ្វើអាជីវកម្មលើដីនោះដោយខ្លួនឯង ដែលប្រគល់ ឬប្រវាស់ឱ្យប្រជាជនធ្វើអាជីវកម្ម និងករណីដីមួយទៀតក្រោយពីការជូនដំណឹង ស្តីពីការគ្រប់គ្រងប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ អាជីវករទិញលក់ដីខ្លះបានយកដំណាំ ដូចជាចេក អំពៅ និងដំណាំហូបផ្លែផ្សេងៗទៀតមកដាំលើដីនោះបំភាន់ភ្នែក ប្រែក្លាយដីមិនបានប្រើប្រាស់ ឱ្យមើលឃើញថាជាដីប្រើប្រាស់ក្នុងគោលបំណងគេចវេសមិនព្រមបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់។ ទាក់ទិននឹងដីខាងលើ ដើម្បីកំណត់ឱ្យបានច្បាស់លាស់ថាតើដីនោះ ជាដីប្រើប្រាស់ ឬជាដីមិនបានប្រើប្រាស់ ចាំបាច់ត្រូវគិតគូររកឱ្យឃើញនូវប្រាក់ចំណូលប្រចាំខែ ដែលបានមកពីសកម្មភាពសេដ្ឋកិច្ចដូចបានរៀបរាប់ខាងលើ។

**ឃ.ដីជាកម្មសិទ្ធិរបស់រដ្ឋជួលឱ្យនីតិបុគ្គល ឬរូបវន្តបុគ្គល**

ដីប្រភេទនេះជាដីសាធារណៈ ដែលជាកម្មសិទ្ធិរបស់រដ្ឋទោះបីមាននៅក្នុងបញ្ជីសារពើភ័ណ្ឌ ឬនៅក្រៅបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋក្តី។ បើដីរបស់រដ្ឋនេះត្រូវបានជួលទៅឱ្យនីតិបុគ្គល ឬរូបវន្តបុគ្គលណាមួយ ហើយប្រាក់ឈ្នួលប្រចាំខែបានមកតិចជាង៨0%នៃចំនួនមួយភាគដប់ពីរនៃតម្លៃដីនៅក្នុងឆ្នាំប្រមូលពន្ធ គុណនឹងមេគុណដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយក្នុងនោះតម្លៃដីត្រូវបានកំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ នោះដីប្រភេទនេះត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់។

**ង.ដីដែលឋិតនៅក្រោមកិច្ចព្រមព្រៀងវិនិយោគ**

ដីប្រភេទនេះរួមមានដីឋិតនៅក្រោមកិច្ចព្រមព្រៀងវិនិយោគ និងដីសម្បទានដែលបានការអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ឱ្យធ្វើវិនិយោគលើវិស័យអ្វីមួយ ឬដីសម្បទានរយៈពេលខ្លី មធ្យម ឬវែងដែលបានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាល ឱ្យអនុវត្តនូវគម្រោងអ្វីមួយ។ ប្រសិនបើដីវិនិយោគ ដីសម្បទាននោះពុំបាន ឬពុំទាន់ដំណើរការ ដោយទឹកជំនន់ជាប្រចាំ

ដីចម្ការមីន ឬមូលហេតុអសន្តិសុខផ្សេងៗនោះ ពុំត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ទេ ប៉ុន្តែលុះណាតែការអាក់ខាន ឬការពន្យារពេលនោះមានការបញ្ជាក់ទទួលយល់ព្រមពីស្ថាប័នជំនាញមានសមត្ថកិច្ច និងពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**២_បុគ្គលដែលត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់**

បុគ្គលដែលត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ គឺជាកម្មសិទ្ធិករនៃដីធ្លីមិនបានប្រើប្រាស់។ ការបង់ពន្ធនេះមិនមែនជាល័ក្ខខ័ណ្ឌបញ្ជាក់កម្មសិទ្ធិស្របច្បាប់លើដីធ្លីទេ។ ក្នុងការគ្រប់គ្រងប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ពាក្យ "កម្មសិទ្ធិករ" សំដៅដល់នីតិបុគ្គល ឬរូបវន្តបុគ្គលណាដែលផ្ដែកស៊ិរិយោដី ឬអាជ្ញាធរដែនដីចាប់ពីថ្នាក់ឃុំ-សង្កាត់ឡើងទៅបានចេញឯកសារផ្លូវការទទួលស្គាល់សិទ្ធិរបស់បុគ្គលនោះ ក្នុងការប្រើប្រាស់ដីក្នុងតំបន់ណាមួយជាលក្ខណៈជាប់លាប់ក្ដី ឬបណ្ដោះអាសន្នក្ដី។

កម្មសិទ្ធិករម្នាក់ជារូបវន្តបុគ្គលគឺជាគ្រួសារមួយ "ឪពុក ម្ដាយ សាមីខ្លួន ប្រពន្ធ កូននៅក្នុងបន្ទុក" ឬមេគ្រួសារ និងសមាជិកក្នុងបន្ទុកមានឈ្មោះក្នុងប័ណ្ណគ្រួសារ ដែលចេញដោយស្ថាប័នមានសមត្ថកិច្ច។

**៣_មូលដ្ឋានកំណត់ពន្ធ និងអត្រាពន្ធ**

មូលដ្ឋានកំណត់ពន្ធគឺជាថ្លៃដីគិតតាមថ្លៃដីទីផ្សារ តាមទីក្រុង និងតាមតំបន់នីមួយៗ ដែលវាយតម្លៃទៅតាមតម្លៃគិតក្នុងមួយម៉ែត្រក្រឡា កំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ យ៉ាងយឺតបំផុតនៅថ្ងៃទី៣០ ខែមិថុនានៃឆ្នាំប្រមូលពន្ធ។

ក្នុងការគិតពន្ធ ត្រូវបានអនុញ្ញាតឱ្យកាត់ចេញពីមូលដ្ឋានកំណត់ពន្ធចំនួន១.២០០ម៉ែត្រក្រឡា ក្នុងដីមួយកន្លែង។

ពន្ធនេះត្រូវកំណត់តាមអត្រា២%លើមូលដ្ឋានកំណត់ពន្ធ និងត្រូវបានគណនាដូចតទៅ៖

ប្រាក់ត្រូវបង់ពន្ធ = (ផ្ទៃដីសរុប - ១.២០០ម$^{២}$) × មូលដ្ឋានកំណត់ × ២%[1]

**៤_អំពីការប្រកាសបង់ពន្ធ**

ពន្ធលើដីធ្លីមិនបានប្រើប្រាស់គឺជាប្រភេទពន្ធអនុវត្តតាមវិធីឆ្លើយប្រកាស។ កម្មសិទ្ធិករនៃដីជាប់ពន្ធមានកាតព្វកិច្ចដាក់លិខិតប្រកាសបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ដោយគណនាប្រាក់ពន្ធខ្លួនឯងទៅ

---

[1] មិនត្រូវបានអនុញ្ញាតឱ្យដក១,២០០ម$^{២}$ ចេញ តាមរយៈសេចក្ដីជូនដំណឹងស្ដីពីការគ្រប់គ្រងប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់, លេខ០១០សហវ/ប្រក/ពដ/០៦ មិថុនា ២០០៧។ សូមមើលទំព័រ 912។

តាមគំរូលិខិតប្រកាសដែលនាយកដ្ឋានពន្ធដារបានផ្តល់ជូន ហើយត្រូវបង់ពន្ធឱ្យបានចប់សព្វគ្រប់យ៉ាង យឺតបំផុតត្រឹមថ្ងៃទី៣០ ខែកញ្ញានៃឆ្នាំសារពើពន្ធនីមួយៗ ជូនទៅផ្នែកពន្ធដារនៅកន្លែងដែលដីធ្លីឋិតនៅ។

ដីមួយកន្លែងត្រូវធ្វើលិខិតឆ្លើយប្រកាស២ច្បាប់។

**៥.នីតិវិធីនៃការកំណត់ពន្ធ និងវិធានការតឹងទារបំណុលពន្ធ**

ចាប់ពីថ្ងៃទី១តុលានៃឆ្នាំប្រមូលពន្ធ ផ្នែកពន្ធដារមានសិទ្ធិត្រួតពិនិត្យលើមូលដ្ឋានកំណត់ពន្ធ និងការបង់ពន្ធរបស់កម្មសិទ្ធិករម្នាក់ៗ។ បើពិនិត្យទៅឃើញថាកម្មសិទ្ធិករណាម្នាក់មាន៖

-ការមិនបានបំពេញកាតព្វកិច្ចដាក់លិខិតប្រកាសបង់ពន្ធ

-ការបង់ពន្ធខ្វះដោយប្រកាសមិនអស់ដីដែលខ្លួនមាន

-ការបង់ពន្ធយឺតយ៉ាវមិនតាមកាលកំណត់

ពេលនោះផ្នែកនៃពន្ធដារត្រូវធ្វើ៖

ក-<u>លិខិតរំឭកប្រកាសបង់ពន្ធ</u> (គំរូទី១)

លិខិតរំឭកប្រកាសបង់ពន្ធត្រូវធ្វើដោយផ្នែកពន្ធដារ ផ្ញើជូនទៅកម្មសិទ្ធិករដែលមិនបានដាក់លិខិតប្រកាសបង់ពន្ធ ដោយទុករយៈពេល១៥ថ្ងៃសម្រាប់ការដាក់លិខិតប្រកាសបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់។

ខ-<u>ការជូនដំណឹងស្តីពីការកំណត់ពន្ធជាឯកតោភាគី</u> (គំរូទី២)

ក្នុងករណីកម្មសិទ្ធិករមិនបានបំពេញកាតព្វកិច្ចប្រកាសបង់ពន្ធតាមកាលកំណត់ ដូចបានជម្រាបជូនក្នុងលិខិតរំឭកប្រកាសបង់ពន្ធ តាមការតម្រូវនៃបទប្បញ្ញត្តិស្តីពីវិធាន និងនីតិវិធីសារពើពន្ធ ផ្អែកតាមមាត្រា១១៦នៃច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧ ផ្នែកពន្ធដារ ចាំបាច់ត្រូវធ្វើការកំណត់ពន្ធជាឯកតោភាគី។ ក្នុងករណីនេះប្រាក់ពន្ធត្រូវកំណត់នឹងត្រូវបង់ក្នុងរយៈពេល៣ថ្ងៃ ក្រោយកាលបរិច្ឆេទប្រគល់លិខិតជូនដំណឹងទារបំណុលពន្ធ។

គ. <u>ការជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញ</u> (គំរូទី៣)

ការកំណត់ពន្ធឡើងវិញ ត្រូវអនុវត្តចំពោះកម្មសិទ្ធិករដែលបានដាក់លិខិតប្រកាស ប៉ុន្តែមានលក្ខណៈមិនគ្រប់គ្រាន់ មិនត្រឹមត្រូវ ឬមានការភ្លាំងភ្លាត់ដែលនាំឱ្យប្រាក់ពន្ធបានបង់មានចំនួនតិចជាងប្រាក់ពន្ធដែលបានកំណត់ដោយបទប្បញ្ញត្តិស្តីពីសារពើពន្ធ។

កម្មសិទ្ធិករមានរយៈពេល៣០ថ្ងៃ ដើម្បីឆ្លើយតបចំពោះការកំណត់ពន្ធឡើងវិញទៅផ្នែកពន្ធដារដែលទទួលបន្ទុកធ្វើការកំណត់ពន្ធឡើងវិញនេះ។ ក្នុងរយៈពេលនេះ កម្មសិទ្ធិករអាចទទួលយក ឬជំទាស់ចំពោះការកំណត់ឡើងវិញ។ បើសិនជាពុំបានឆ្លើយតប កម្មសិទ្ធិករត្រូវចាត់ទុកថាយល់ព្រមចំពោះការកំណត់ពន្ធឡើងវិញនេះ។

ឃ-<u>លិខិតជូនដំណឹងទារបំណុលពន្ធសម្រាប់ការកំណត់ពន្ធជាឯកតោភាគី</u> (គំរូទី៤-ក)

-ក្រោយពីមានការកំណត់ពន្ធជាឯកតោភាគី ផ្នែកកំណត់ពន្ធត្រូវបញ្ជូនលទ្ធផល ដោយធ្វើជាតារាងគណនេយ្យសារពើពន្ធ និងលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធជាឯកតោភាគី ទៅឱ្យផ្នែកប្រមូលពន្ធ។ ក្រោយពីបានទទួលលិខិតទាំងនេះ ផ្នែកប្រមូលពន្ធត្រូវផ្ញើលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធជាឯកតោភាគី និងលិខិតជូនដំណឹងទារបំណុលពន្ធទៅឱ្យកម្មសិទ្ធិករ។

-លិខិតជូនដំណឹងទារបំណុលពន្ធត្រូវមានចុះបញ្ជាក់យ៉ាងច្បាស់ថា បំណុលពន្ធ និងទោសទណ្ឌជាប់ទាក់ទិនត្រូវដល់កំណត់នឹងត្រូវបង់នៅក្នុងរយៈពេល៣ថ្ងៃ ក្រោយកាលបរិច្ឆេទប្រគល់ទទួលលិខិតនេះ។

ង-<u>លិខិតជូនដំណឹងទារបំណុលពន្ធសម្រាប់ការកំណត់ពន្ធឡើងវិញ</u> (គំរូទី៤-ខ)

ក្រោយពីបានទទួលតារាងគណនេយ្យសារពើពន្ធពីផ្នែកកំណត់ពន្ធរួចហើយ ផ្នែកប្រមូលពន្ធត្រូវធ្វើលិខិតជូនដំណឹងទារបំណុល ផ្ញើទៅឱ្យកម្មសិទ្ធិករនៃដីធ្លីមិនបានប្រើប្រាស់។

-លិខិតជូនដំណឹងទារបំណុលពន្ធត្រូវមានចុះបញ្ជាក់យ៉ាងច្បាស់ថា បំណុលពន្ធ និងទោសទណ្ឌជាប់ទាក់ទិនត្រូវដល់កំណត់នឹងត្រូវបង់ក្នុងរយៈពេល៣០ថ្ងៃ ក្រោយកាលបរិច្ឆេទប្រគល់ទទួលលិខិតនេះ។

ច-<u>លិខិតជូនដំណឹងរំឭកការទារបំណុលពន្ធ</u> (គំរូទី៥)

ក្នុងករណីដែលកម្មសិទ្ធិករមិនបានបង់បំណុលពន្ធ ក្នុងរយៈពេល៣០ថ្ងៃក្រោយកាលបរិច្ឆេទប្រគល់លិខិតជូនដំណឹងទារបំណុលពន្ធ ឬក្នុងរយៈពេល៣ថ្ងៃក្រោយកាលបរិច្ឆេទប្រគល់លិខិតជូនដំណឹងទារបំណុលពន្ធសម្រាប់ការកំណត់ពន្ធជាឯកតោភាគី ផ្នែកប្រមូលពន្ធត្រូវចេញលិខិតជូនដំណឹងរំឭកការទារបំណុលពន្ធ។

ក្នុងរយៈពេល១៥ថ្ងៃក្រោយពីថ្ងៃបានទទួលលិខិតរំឭកការទារបំណុលពន្ធ កម្មសិទ្ធិករនៅមិនព្រមមកទូទាត់បំណុលពន្ធទៀតនោះ ផ្នែកពន្ធដារត្រូវអនុវត្តនូវវិធានការតឹងទារបំណុលពន្ធដែលរួមមាន៖

-ការឃាត់ទុកគណនីនៅធនាគាររបស់អ្នកជំពាក់បំណុលពន្ធ

-ការបញ្ឈប់ប្រតិបត្តិការនាំចេញ-ចូល

-ការរឹបអូស ការលក់ទ្រព្យសម្បត្តិរបស់អ្នកជំពាក់បំណុលពន្ធ

-ការទុកជាមោឃៈនូវលិខិតអនុញ្ញាត និងអាជ្ញាប័ណ្ណ

គណៈកម្មការតឹងទារបំណុលសារពើពន្ធតាមបណ្តាខេត្ត-ក្រុងនីមួយៗ មានភារកិច្ចអនុវត្តនូវការងារខាងលើនេះ។

**៦.អំពីទោសទណ្ឌ**

ការបង់ពន្ធខ្វះ ការបង់ពន្ធយឺត ឬការមិនបានដាក់លិខិតប្រកាសសារពើពន្ធត្រូវរងការដាក់ឱ្យអនុវត្តនូវមាត្រា១១៦ និងមាត្រា១១៧នៃច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧។ ទន្ទឹមនឹងនោះផ្អែកតាមមាត្រា១៣១ និងមាត្រា១៣២នៃច្បាប់ដដែលខាងលើ កម្មសិទ្ធិករត្រូវបង់ប្រាក់ពន្ធបន្ថែមស្មើនឹង១០% ២៥% ឬ៤០%នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់២%នៃចំនួនប្រាក់ពន្ធ ដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលប្រាក់ពន្ធខ្វះមិនទាន់បានបង់។

**៧.អំពីការលើកទឹកចិត្តលើការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់**

ការលើកទឹកចិត្តចំពោះការប្រមូលពន្ធជាក់ស្តែង និងមានប្រសិទ្ធភាពត្រូវបានកំណត់ដោយច្បាប់ស្តីពីសារពើពន្ធ ប្រកាសដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ត្រង់មាត្រា៩៧ ដែលបានចែងថា "ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវកសាងប្រព័ន្ធលើកទឹកចិត្តមួយសម្រាប់មន្ត្រីភ្នាក់ងាររដ្ឋបាលសារពើពន្ធ" ចំពោះមុខ ដើម្បីឱ្យការគ្រប់គ្រងប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់នាំមកនូវប្រសិទ្ធភាពខ្ពស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអនុញ្ញាតឱ្យបង្កើតបេឡាររង្វាន់មួយដែលគ្រប់គ្រង និងបែងចែកដោយសាខាពន្ធដារខេត្ត-ក្រុង។ ប្រភពចំណូលសម្រាប់បង្កើតបេឡាររង្វាន់នេះ គឺបានមកពីចំណូលអំពីពន្ធលើដីធ្លីមិនបានប្រើប្រាស់។ បុគ្គលដែលត្រូវទទួលប្រាក់រង្វាន់ គឺមន្ត្រីភ្នាក់ងាររដ្ឋបាលសារពើពន្ធ អាជ្ញាធរឃុំ អាជ្ញាធរស្រុក គណៈកម្មការ និងអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់។

អត្រាដកប្រាក់រង្វាន់ត្រូវបានកំណត់ស្មើនឹង១០% (ដប់ភាគរយ) នៃចំណូលបានមកពីពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងត្រូវបានអនុញ្ញាតឱ្យដកមុនពេលបង់ចូលទៅរតនាគារខេត្ត-ក្រុង និងដាក់បញ្ចូលក្នុងសមាមាត្របែងចែកប្រាក់រង្វាន់ត្រូវបានកំណត់ដូចតទៅ៖

១-១០% (ដប់ភាគរយ) បែងចែកដល់គណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់

២-១៥% (ដប់ប្រាំភាគរយ) បែងចែកជូននាយកដ្ឋានពន្ធដារ

៣-២០% (ម្ភៃភាគរយ) បែងចែកជូនសាខាពន្ធដារខេត្ត-ក្រុង

៤-២៥% (ម្ភៃប្រាំភាគរយ) បែងចែកដល់អនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់

៥-១៥% (ដប់ប្រាំភាគរយ) បែងចែកជូនអាជ្ញាធរស្រុក

៦-១៥% (ដប់ប្រាំភាគរយ) បែងចែកជូនអាជ្ញាធរឃុំ

ការបែងចែកប្រាក់រង្វាន់នេះអនុវត្តចំពោះតែខេត្ត-ក្រុង ស្រុក ឃុំណាដែលបានចំណូលមកអំពីពន្ធលើដីធ្លីមិនបានប្រើប្រាស់។ ប្រាក់រង្វាន់ដែលទទួលបានក្នុងខែនីមួយៗ សាខាពន្ធដារត្រូវបែងចែកតាមសមាមាត្រដូចបានកំណត់ខាងលើ និងត្រូវធ្វើរបាយការណ៍មកនាយកដ្ឋានពន្ធដាររៀងរាល់ដំណាច់ខែ។

បេឡាប្រាក់រង្វាន់ ត្រូវគ្រប់គ្រងដោយអនុវត្តកិច្ចបញ្ជិកាឱ្យបានត្រឹមត្រូវ តាមគំរូណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

សារាចរណែនាំនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ជ.ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**រដ្ឋលេខាធិការ**
**ហត្ថលេខា និងត្រា**
**គង់ វិបុល**

<u>កន្លែងទទួល</u>

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់សាលាខេត្ត-ក្រុង "ដើម្បីជូនជ្រាបជាព័ត៌មាន"
-គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
"ដើម្បីមុខការ"
-គ្រប់អង្គភាពពន្ធដារ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ០៥អនក្រ/បក

**អនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃសម្បទាន**
**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញក្រឹត្យ-ច្បាប់លេខ៣៥ក្រច ចុះថ្ងៃទី២៥ មិថុនា ១៩៨៨ ស្តីពីការគ្រប់គ្រងវិស័យព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ០៣/នស/៩៤ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៧២អនក្រ/បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- បានឃើញប្រកាសលេខ០១ប្រក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពីវិធានការគ្រប់គ្រង និងលុបបំបាត់ភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើ
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០០

## សម្រេច

## ជំពូកទី១ បទប្បញ្ញត្តិទូទៅ

**មាត្រា១**

អនុក្រឹត្យនេះកំណត់ការគ្រប់គ្រង និងការអនុវត្តទៅលើរាល់សកម្មភាពប្រមូលផលព្រៃឈើ កិច្ចព្រមព្រៀងព្រៃសម្បទានទាំងអស់ដែលបានផ្តល់ឱ្យដោយរាជរដ្ឋាភិបាលកម្ពុជា។

**មាត្រា២**

អនុក្រឹត្យនេះមានគោលបំណង៖

-រៀបចំប្រព័ន្ធផែនការអនុវត្ត និងត្រួតពិនិត្យព្រៃសម្បទានដើម្បីឈានទៅរកតុល្យភាពក្នុងការអនុវត្តបច្ចេកទេស និងគ្រប់គ្រងផលិតផលព្រៃឈើប្រកបដោយនិរន្តរភាពនៅព្រះរាជាណាចក្រកម្ពុជា

-ធានានូវការគ្រប់គ្រង កាន់កាប់ព្រៃសម្បទាន ដើម្បីឆ្លើយតបទៅនឹងផលប្រយោជន៍សាធារណៈ និងទិសដៅយូរអង្វែងក្នុងការរៀបចំធនធានចម្រុះ និងរៀបចំដំណើរការផ្តល់ព្រៃសម្បទានឱ្យមានលក្ខណៈសមស្រប និងតម្លាភាព

-ធានានូវរបៀបរបបរៀបចំគ្រប់គ្រងព្រៃសម្បទាន ដើម្បីអភិរក្ស និងការពារជីវៈចម្រុះធម្មជាតិ មុខងារប្រព័ន្ធអេកូឡូស៊ី និងសារៈសំខាន់សេវាព្រៃឈើដូចជា៖ ការអភិរក្សដី និងការគ្រប់គ្រងទីជម្រាល

-ធានាឱ្យបានពេញលេញនូវទំនាក់ទំនង កិច្ចសហប្រតិបត្តិការ ការបំពេញមុខងារ និងការទទួលខុសត្រូវរបស់ស្ថាប័នដែលមានភារកិច្ច និងកាតព្វកិច្ចក្នុងការរៀបចំ និងគ្រប់គ្រងព្រៃសម្បទានជាមួយភាគីពាក់ព័ន្ធទាំងអស់

-ធានានូវការចូលរួម ពិគ្រោះយោបល់ពីសហគមន៍មូលដ្ឋាន ជាមួយព្រៃសម្បទាន និងស្ថាប័នគ្រប់គ្រងក្នុងការអភិវឌ្ឍផែនការគ្រប់គ្រងព្រៃសម្បទាន និងការតាមដានត្រួតពិនិត្យសកម្មភាពនៃដំណើរការប្រមូលផលព្រៃឈើលើសុពលភាពនៃព្រៃសម្បទាន

-ការពារ និងរក្សាសិទ្ធិរបស់សហគមន៍មូលដ្ឋានក្នុងការប្រើប្រាស់ធនធានព្រៃឈើ ដែលកើតមាននៅក្នុងតំបន់ព្រៃសម្បទានសម្រាប់ជីវភាព សេដ្ឋកិច្ច ការចិញ្ចឹមជីវិត និងការគោរពជំនឿខាងសាសនា

-បង្កើតប្រព័ន្ធត្រួតពិនិត្យ និងការធ្វើផែនការគ្រប់គ្រងព្រៃឈើដ៏សុក្រឹតដែលនឹងផ្តល់នូវបរិបទ និងការលើកទឹកចិត្តដល់ឧស្សាហកម្មព្រៃឈើកម្ពុជា ក្នុងការអនុវត្តប្រព័ន្ធវិញ្ញាបនបត្រព្រៃឈើដែលមានការទទួលស្គាល់ពីអន្តរជាតិ។

**មាត្រា៣**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានរុក្ខាប្រមាញ់) មានតួនាទីស្នូលក្នុងការតាមដានត្រួតពិនិត្យ និងគ្រប់គ្រងលើរាល់សកម្មភាពប្រមូលផលព្រៃឈើគ្រប់ប្រភេទ ដើម្បីធានានូវនិរន្តរភាពព្រៃឈើ។

អត្ថន័យនៃពាក្យបច្ចេកទេសដែលត្រូវបានប្រើប្រាស់នៅក្នុងអនុក្រឹត្យនេះ នឹងមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ជំពូកទី២ ការស្នើសុំ និងការសម្រេចផ្តល់ព្រៃសម្បទាន

**មាត្រា៤**

៤.១-ផ្អែកលើអនុសាសន៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានរុក្ខាប្រមាញ់) និងតាមការពិគ្រោះយោបល់ជាមួយបណ្តាក្រសួងទាំងអស់ពាក់ព័ន្ធ ព្រមទាំងសហគមន៍មូលដ្ឋាន គណៈរដ្ឋមន្ត្រីអាចសម្រេចដាក់តំបន់ព្រៃផ្តល់ផលដែលនៅទំនេរឱ្យទៅជាព្រៃសម្បទានដោយដាក់ឱ្យដេញថ្លៃតាមលក្ខណៈប្រកួតប្រជែងជាសាធារណៈ។ សំណើសុំព្រៃសម្បទានត្រូវលើកឱ្យស្របទៅតាមគោលដៅនៃការអភិវឌ្ឍថ្នាក់ជាតិ និងខេត្ត ហើយស្របតាមផែនការប្រើប្រាស់ដីធ្លីរបស់មូលដ្ឋានដែលមានស្រាប់។

៤.២-អ្នកចូលរួមដេញថ្លៃនឹងត្រូវបានទទួលយល់ព្រមឱ្យចូលរួមដេញថ្លៃ ចំពោះតែក្រុមហ៊ុនពាណិជ្ជកម្មណា ដែលបានជ្រើសរើសបញ្ចូលជាស្រេចនៅក្នុងបញ្ជីឈ្មោះ "ជ្រើសរើសជាមុន" ដែលបានរៀបចំ និងរក្សាទុកដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានរុក្ខាប្រមាញ់)។ ក្រុមហ៊ុនពាណិជ្ជកម្មដែលបានជ្រើសរើសបញ្ចូលទៅក្នុងបញ្ជីឈ្មោះ "ជ្រើសរើសជាមុន" បាន លុះត្រាតែក្រុមហ៊ុននោះបានដាក់ពាក្យស្នើសុំ និងផ្តល់នូវតឹកតាងបញ្ជាក់ថា៖

ក-មានសមត្ថភាពគ្រប់យ៉ាងក្នុងការគ្រប់គ្រងព្រៃឈើ រួមមានការធ្វើផែនការ ការប្រមូលផល ការបន្តពូជឈើ ការថែរក្សាឈើឈរ ការការពារបរិស្ថាន និងទំនាក់ទំនងសហគមន៍

ខ-មានរបាយការណ៍បញ្ជាក់ថា អនុវត្តតាមបានល្អដោយគ្មានការរំលោភបច្ចេកទេសធ្ងន់ធ្ងរនៅក្នុងយុត្តាធិការនានា ដែលពួកគេធ្លាប់បានអនុវត្តនៅក្នុងដំណើរការប្រមូលផលកន្លងមក

គ-មានធនធានហិរញ្ញវត្ថុ និងបុគ្គលិកជំនាញគ្រប់គ្រាន់ ដើម្បីអនុវត្តប្រតិបត្តិការព្រៃឈើយ៉ាងមានប្រសិទ្ធភាព។

៤.៣-សំណុំឯកសារដេញថ្លៃទាំងអស់ សម្រាប់ដាក់អញ្ជើញឱ្យមានការចូលរួមដេញថ្លៃព្រៃសម្បទានត្រូវរៀបចំឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានរុក្ខាប្រមាញ់) ដែលក្នុងនោះត្រូវមាន៖

ក-កំណត់លក្ខណវិនិច្ឆ័យទាំងអស់នៃការជ្រើសរើសដោយសៀវភៅបន្ទុក សម្រាប់ការដេញថ្លៃព្រៃសម្បទាន

ខ-កំណត់បង្ហាញពីព្រំប្រទល់ព្រៃឈើជាក់ស្តែង ដែលគ្រោងដាក់ដេញថ្លៃជាព្រៃសម្បទាន

គ-កំណត់បង្ហាញពីធនធានព្រៃឈើដែលអាចប្រមូលផលបាន និងតំបន់ហាមឃាត់អាជីវកម្ម ដោយសារហេតុផលខាងបរិស្ថាន សង្គម និងវប្បធម៌ តាមរយៈការធ្វើសារពើភ័ណ្ឌបុរេសម្បទាននៃ តំបន់ព្រៃឈើ និងការអង្កេតស្វែងយល់លើរូបភាពពីផ្កាយរណប ឬរូបថតពីលើអាកាស និងការវាយតម្លៃជនបទបន្ទាន់

ឃ-អធិប្បាយពីតម្រូវការគ្រប់គ្រង និងល័ក្ខខ័ណ្ឌការងារព្រៃសម្បទានដែលរាជរដ្ឋាភិបាលតម្រូវឱ្យម្ចាស់ព្រៃសម្បទានអនុវត្ត ការធ្វើផែនការព្រៃឈើ ការការពារ និងគ្រប់គ្រងព្រៃឈើ ការអភិរក្ស និងការការពារបរិស្ថាន ការពិគ្រោះយោបល់ និងសហប្រតិបត្តិការជាមួយសហគមន៍មូលដ្ឋាន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការផ្តល់មុខរបរដល់ប្រជាជនមូលដ្ឋាន ការអភិវឌ្ឍធនធានមនុស្ស ការផ្គត់ផ្គង់សម្ភារៈ និងសេវាកម្ម ការតាមដានពិនិត្យ និងវាយតម្លៃ ការត្រួតពិនិត្យលើលិខិតអនុញ្ញាត និងបទដ្ឋានផ្សេងៗ និងការផាកពិន័យចំពោះការមិនអនុវត្តតាម និងល័ក្ខខ័ណ្ឌការងារផ្សេងទៀតក្នុងករណីចាំបាច់

ង-ភ្ជាប់មកជាមួយនូវច្បាប់ចម្លងកិច្ចព្រមព្រៀងព្រៃសម្បទានជាគំរូ (ចំណុច៥.១ខាងក្រោម)

ច-កំណត់ច្បាស់លាស់នូវលក្ខណវិនិច្ឆ័យ សម្រាប់វាយតម្លៃការដេញថ្លៃព្រៃសម្បទានដែលត្រូវសម្រេចដោយរាជរដ្ឋាភិបាលកម្ពុជា។

៤.៤-ដំណើរការនៃការដាក់ព្រៃសម្បទានឱ្យដេញថ្លៃ តាមលក្ខណៈប្រកួតប្រជែងជាសាធារណៈនៅក្នុងអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងត្រូវរួមបញ្ចូលនូវបណ្ដាចំណុចចាំបាច់មួយចំនួនដូចខាងក្រោម៖

ក-ដំណើរការប្រព្រឹត្តទៅនៃការដេញថ្លៃ ត្រូវឋិតនៅក្រោមការដឹកនាំរបស់គណៈកម្មការដេញថ្លៃមួយដែលមានសមាសភាពកំណត់ដោយប្រមុខរដ្ឋាភិបាល

ខ-ត្រូវប្រកាសជាសាធារណៈនូវពេលវេលា និងទីកន្លែងដែលត្រូវធ្វើការដេញថ្លៃយ៉ាងតិចណាស់៩០ថ្ងៃមុនពេលដេញថ្លៃ តាមវិទ្យុ ទូរទស្សន៍ និងសារព័ត៌មានជាតិណាមួយយ៉ាងតិច

គ-ត្រូវប្រកាសជាសាធារណៈពីប្រាក់កក់ ទម្រង់ការ និងមាតិកានៃឯកសារដែលត្រូវចូលរួមដេញថ្លៃដូចជា៖ ការដេញថ្លៃជាទឹកប្រាក់ និងកិច្ចសន្យា ដើម្បីបំពេញឱ្យល័ក្ខខ័ណ្ឌការងារ និងការរំពឹងទុក ដែលមានចែងក្នុងមាត្រា៤ ចំណុច៤.៣ គ និងឃ ខាងលើ

ឃ-គ្រប់អ្នកចូលរួមដេញថ្លៃ ត្រូវបង់ប្រាក់ធានាបណ្ដោះអាសន្នក្នុងគណនីថវិកាជាតិតាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានរុក្ខាប្រមាញ់) នៅពេលដាក់សំណុំលិខិតស្នើសុំចូលរួមដេញថ្លៃ។ ចំនួនប្រាក់កក់នេះត្រូវបានកំណត់ដោយគណៈកម្មការដេញថ្លៃព្រៃសម្បទាន។

ង-ប្រកាសជាសាធារណៈដូចមានចែងក្នុងចំណុច (ខ) ខាងលើ ដោយត្រូវបញ្ជាក់ពីពេលវេលា និងទីកន្លែងដែលត្រូវបើកធ្វើការដេញថ្លៃ នឹងអញ្ជើញជាផ្លូវការនូវអ្នកស្នើសុំដេញថ្លៃ និងបុគ្គលដែលមានការចាំបាច់ផ្សេងទៀត ដើម្បីចូលរួមក្នុងឱកាសបើកឱ្យដេញថ្លៃ

ច-មុននឹងបើកឱ្យដេញថ្លៃ ដោយផ្អែកលើអនុសាសន៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានរុក្ខាប្រមាញ់) គណៈរដ្ឋមន្ត្រីត្រូវកំណត់នូវតម្លៃបម្រុងសម្រាប់ផ្ដល់ឱ្យព្រៃសម្បទានជាមូលដ្ឋានសម្រាប់ការដេញថ្លៃដោយអាចប្រកាស ឬមិនប្រកាសឱ្យដឹងចំហមុន ពេលដេញថ្លៃ

ឆ-នៅពេលវេលា និងទីកន្លែងដែលបានប្រកាស ដូចមានបញ្ជាក់នៅក្នុងចំណុច (ង) ខាងលើ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបើកបង្ហាញជាសាធារណៈនូវរាល់សំបុត្រស្នើសុំដេញថ្លៃជាទឹកប្រាក់ និងផ្នែកពាក់ព័ន្ធដទៃទៀត ដូចមានចែងក្នុងសៀវភៅបន្ទុកដេញ

ថ្លៃពីបណ្តាអតិថិជន និងត្រូវប្រកាសពីចំនួនទឹកប្រាក់ដែលហ៊ានឱ្យថ្លៃ ក្នុងស្រោមសំបុត្ររបស់អតិថិជននីមួយៗ ជូនដល់គ្រប់អ្នកចូលរួមដែលមានវត្តមាននាពេលដេញថ្លៃនោះ។

ជ-បន្ទាប់ពីការដេញថ្លៃដូចមានចែងក្នុងចំណុច ឆ ខាងលើនេះរួចមក រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវធ្វើការប្រកាសឈ្មោះអ្នកដែលមានឧត្តមភាព ដែលត្រូវជ្រើសរើសជាបេក្ខជនឈ្នះក្នុងការដេញថ្លៃព្រៃសម្បទានជាលក្ខណៈបណ្តោះអាសន្ន រហូតដល់មានការសម្រេចជាស្ថាពរពីរដ្ឋាភិបាល

ឈ-ឯកសារដែលបានដាក់ឱ្យចូលរួមដេញថ្លៃ ដូចមានចែងក្នុងចំណុច (គ) ត្រូវរក្សាទុកដោយអនុញ្ញាតឱ្យពិនិត្យជាសាធារណៈក្នុងរយៈពេល៦សប្តាហ៍ បន្ទាប់ពីបានកំណត់អ្នកឈ្នះ ក្នុងការដេញថ្លៃ។ ក្នុងអំឡុងពេលនេះ រាល់ភាគីពាក់ព័ន្ធក្នុងការដេញថ្លៃខាងលើទាំងអស់ អាចធ្វើការប្តឹងតវ៉ាពីការសម្រេចក្នុងការសម្រេចដេញថ្លៃទៅរាជរដ្ឋាភិបាល

ញ-នៅពេលបញ្ចប់រយៈពេលកំណត់៦សប្តាហ៍ និងផ្អែកទៅលើការសម្រេចដោយរាជរដ្ឋាភិបាល បេក្ខជនឈ្នះក្នុងការដេញថ្លៃ ត្រូវបានផ្តល់ការយល់ព្រមជាស្ថាពរ

ដ-នៅពេលប្រកាសជាស្ថាពរនូវឈ្មោះអ្នកឈ្នះក្នុងការដេញថ្លៃ ប្រាក់កក់ធានាបណ្តោះអាសន្នដែលបានបង់ដូចមានចែងក្នុងចំណុច (ឃ) នឹងត្រូវបង្វែរជូនវិញចំពោះអ្នកចាញ់ក្នុងការដេញថ្លៃ

ឋ-ប្រសិនបើអ្នកឈ្នះក្នុងការដេញថ្លៃ ពុំបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងព្រៃសម្បទាន ឬមិនបានបង់ប្រាក់បន្ថែមបង្គ្រប់តាមតម្លៃដែលដេញបានក្នុងអំឡុងពេល៣០ថ្ងៃ ក្រោយពីមានការសម្រេចជាស្ថាពរដូចមានចែងក្នុងចំណុច (ញ) ខាងលើ នោះប្រាក់កក់នឹងត្រូវបានរឹបអូសជាសម្បត្តិរដ្ឋដោយស្វ័យប្រវត្តិ។

**មាត្រា៥**

៥.១-ព្រៃសម្បទានថ្មី ត្រូវឋិតនៅក្រោមអភិបាលកិច្ចនៃគំរូកិច្ចព្រមព្រៀងព្រៃសម្បទានថ្មី ដែលនឹងត្រូវរៀបចំដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានរុក្ខាប្រមាញ់)។ ចំពោះព្រៃសម្បទានដែលមានស្រាប់ នឹងឋិតនៅក្រោមអភិបាលកិច្ចនៃកិច្ចព្រមព្រៀងព្រៃសម្បទានថ្មី ដោយមានការយល់ព្រមទ្វេភាគីតាមរយៈការចរចា ឬនៅពេលផុតសុពលភាពនៃកិច្ចព្រមព្រៀងព្រៃសម្បទានដែលមានស្រាប់។

៥.២-កិច្ចព្រមព្រៀងព្រៃសម្បទាន ត្រូវបិតនៅក្នុងទម្រង់ការដែលកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងយ៉ាងហោចណាស់ត្រូវបញ្ជាក់ពីៈ

ក-កាលបរិច្ឆេទ និងរយៈពេលនៃការផ្តល់ព្រៃសម្បទាន

ខ-កំណត់ឱ្យបានច្បាស់លាស់អំពីទំហំផ្ទៃដីព្រៃឈើដែលត្រូវផ្តល់ជាព្រៃសម្បទាន

គ-កំណត់ឱ្យបានច្បាស់លាស់នូវបរិមាណ និងប្រភេទនៃផលិតផលព្រៃឈើដែលអនុញ្ញាតឱ្យប្រមូលផល

ឃ-តម្រូវការពីម្ចាស់ព្រៃសម្បទាននូវរាល់សំណុំឯកសារ ផែនការ របាយការណ៍ ការសិក្សាទិន្នន័យ និងព័តិមានដែលទាក់ទងទៅនឹងប្រសិទ្ធភាពនៃការការពារ និងគ្រប់គ្រងធនធានព្រៃឈើ

ង-កំណត់នូវល័ក្ខខ័ណ្ឌផ្សេងៗទៀត ដែលចាំបាច់ដើម្បីធានាដល់ដំណើរការគ្រប់គ្រងព្រៃសម្បទានដោយនិរន្តរភាព។

៥.៣-នៅក្នុងអំឡុងពេលនៃសុពលភាព កិច្ចព្រមព្រៀងព្រៃសម្បទានត្រូវប្រគល់សិទ្ធិផ្តាច់មុខដល់ម្ចាស់ព្រៃសម្បទានដើម្បីអនុវត្តៈ

ក-កិច្ចប្រតិបត្តិការគ្រប់គ្រង និងប្រមូលផលព្រៃឈើណាមួយនៅក្នុងតំបន់សម្បទានដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង

ខ-កិច្ចប្រតិបត្តិការដទៃទៀត និងអនុវត្តការងារដែលបានយល់ព្រមតាមការចាំបាច់សម្រាប់គាំទ្រសកម្មភាពគ្រប់គ្រង និងប្រមូលផល ដូចមានចែងនៅចំណុច (ក)។

៥.៤-ការបញ្ចប់កិច្ចព្រមព្រៀងព្រៃសម្បទាន ដោយការប្រគល់មកវិញ ការដកហូតដោយសារការអនុវត្តពុំបានត្រឹមត្រូវតាមកិច្ចព្រមព្រៀង ឬការអនុញ្ញាតឱ្យបន្តកិច្ចព្រមព្រៀង មុនពេលផុតសុពលភាព ត្រូវសម្រេចដោយរាជរដ្ឋាភិបាល។ ការលុបចោលកិច្ចព្រមព្រៀងទាំងឡាយណាដែលមិនបានអនុវត្ត ឬអនុវត្តមិនបានត្រឹមត្រូវតាមកិច្ចព្រមព្រៀង ត្រូវប្រព្រឹត្តទៅតាមលំដាប់លំដោយឱ្យស្របតាមនីតិវិធី។ ព្រៃសម្បទានដែលត្រូវបានដកហូត ឬប្រគល់មកវិញកន្លងមក ត្រូវរក្សាទុកជាតំបន់ព្រៃការពារធម្មជាតិ និងព្រៃរៀបចំដោយពួក និងមិនត្រូវបានផ្តល់ឱ្យក្រុមហ៊ុនណាផ្សេងទៀតឡើយ។

៥.៥-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានរុក្ខាប្រមាញ់) ត្រូវសហការជាមួយអាជ្ញាធរដែនដី និងម្ចាស់ព្រៃសម្បទានទាំងអស់រៀបចំបង្កើតគណៈកម្មាធិការពិគ្រោះយោបល់សហគមន៍អចិន្ត្រៃយ៍មួយ ដើម្បីធ្វើជាយន្តការសម្របសម្រួលសម្រាប់ពិភាក្សា និងផ្តល់យោបល់លើរាល់បញ្ហាដែលពាក់ព័ន្ធរវាងម្ចាស់ព្រៃសម្បទាន និងបណ្តាសហគមន៍ជិតខាង ដែលមានទីតាំងនៅក្នុង ឬជិតតំបន់ព្រៃសម្បទានក្នុងគោលបំណងការពារ និងធានានូវសិទ្ធិជាប្រពៃណីរបស់សហគមន៍មូលដ្ឋាន។ ប្រធានគណៈកម្មាធិការពិគ្រោះយោបល់ អាចជាប្រធានគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ឬប្រធានអង្គការចាត់តាំងសង្គមមួយដែលមាននៅទីនោះតាមរយៈការបោះឆ្នោត។

៥.៦-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានរុក្ខាប្រមាញ់) អាចផ្តល់អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតទៅភាគីផ្សេងទៀត ក្រៅពីម្ចាស់ព្រៃសម្បទាន ដើម្បីធ្វើការប្រមូលអនុផលព្រៃឈើផ្សេងៗទៀតនៅក្នុងតំបន់ព្រៃសម្បទាន។ ការផ្តល់នូវច្បាប់អនុញ្ញាតឱ្យប្រមូលអនុផលព្រៃឈើនេះមិនត្រូវឱ្យមានបញ្ហា ឬទំនាស់ជាមួយនឹងសិទ្ធិ និងការទទួលខុសត្រូវរបស់ម្ចាស់ព្រៃសម្បទានដែលបានរៀបចំឡើង ដោយកិច្ចព្រមព្រៀងព្រៃសម្បទានឡើយ។ លិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណប្រមូលអនុផលព្រៃឈើ មិនត្រូវផ្តល់ឱ្យលើសពីរយៈពេល១ឆ្នាំ ហើយអាចបន្តសុពលភាពបានដោយផ្អែកលើការស្នើសុំ។ អាជ្ញាប័ណ្ណទាំងនេះ ត្រូវបានផ្តល់សម្រាប់ការប្រមូលអនុផលព្រៃឈើដើម្បីលក់ ពុំមែនសម្រាប់ការប្រមូលដើម្បីចិញ្ចឹមជីវិតជាប្រពៃណី ក្នុងការប្រើប្រាស់ឯកជនដោយប្រជាជនមូលដ្ឋាននោះឡើយ។

៥.៧-ឯកសារវិនិយោគទុនព្រៃសម្បទានទាំងអស់ ត្រូវបានផ្តល់ជូនចំពោះស្ថាប័នរបស់រាជរដ្ឋាភិបាល និងភាគីដែលពាក់ព័ន្ធតាមការស្នើសុំ។

៥.៨-ចំពោះការគ្រប់គ្រងលើការធ្វើអាជីវកម្មធនធានធម្មជាតិដទៃទៀត ដែលឋិតនៅក្នុងដែនព្រៃសម្បទាន ត្រូវឋិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋ តាមច្បាប់ជាធរមាន។

## ជំពូកទី៣ ការធ្វើផែនការព្រៃសម្បទាន

### មាត្រា៦

៦.១-ការគ្រប់គ្រងព្រៃឈើប្រកបដោយប្រសិទ្ធភាព នឹងទាមទារឱ្យមានការធ្វើផែនការចាំបាច់ទៅតាមកម្រិត ទំហំ និងពេលវេលា ហេតុនេះព្រៃសម្បទានត្រូវបែងចែកសម្រាប់គោលបំណងនៃការធ្វើផែនការជាតំបន់គ្រប់គ្រងព្រៃគុបប្រចាំឆ្នាំ និងប្លុកអាជីវកម្ម។

៦.២-រាល់ការធ្វើផែនការព្រៃសម្បទាន ត្រូវកំណត់រៀបចំតាមលំដាប់ថ្នាក់ដូចខាងក្រោម៖

ក-រៀបចំមាតិកា និងភារកិច្ចការងារនៃផែនការគ្រប់គ្រង ដោយពិគ្រោះយោបល់ជាមួយគ្រប់ភាគីពាក់ព័ន្ធ ដើម្បីកំណត់ឱ្យបានច្បាស់នូវលក្ខណវិនិច្ឆ័យនៃការធ្វើផែនការគ្រប់គ្រងព្រៃឈើ សង្គម បរិស្ថាន និងហិរញ្ញវត្ថុ។

ខ-កំណត់ព្រំប្រទល់តំបន់ព្រៃឈើ ដោយឈរលើការវាយតម្លៃជនបទដោយមានការចូលរួមសារពើភ័ណ្ឌធនធានព្រៃឈើ បរិស្ថាន និងធ្វើផែនទី ដើម្បីកំណត់៖

-ផ្ទៃដីមិនធ្វើអាជីវកម្ម (ដែនបម្រុងជីវៈចម្រុះ តំបន់ទ្រនាប់ផ្លូវទឹក ផ្ទៃដីការពារទីជម្រាល តំបន់ងាយរងគ្រោះ តំបន់រេចរិលខ្លាំង តំបន់ព្រៃសហគមន៍ និងតំបន់ត្រូវធ្វើការដាំដុះព្រៃឈើឡើងវិញ)។

-ផ្ទៃដីធ្វើអាជីវកម្មសុទ្ធសាធ

គ-រៀបចំផែនការគ្រប់គ្រងព្រៃសម្បទានរយៈពេលមធ្យម សម្រាប់ព្រៃដែលអាចធ្វើអាជីវកម្មបាន ដោយសារការធ្វើសារពើភ័ណ្ឌ "កម្រិតគ្រប់គ្រង" ដោយបញ្ជាក់ពី៖

-ប្រព័ន្ធរុក្ខវប្បកម្មសមស្រប និងបច្ចេកទេសប្រមូលផលសម្រាប់ប្រភេទព្រៃ និងស្ថានភាពភូមិសាស្ត្រខុសគ្នា ដោយផ្អែកលើការវាយតម្លៃលំអិតអំពីរបបប៉ះពាល់ធម្មជាតិ

-ទិន្នផលជានិរន្តរ៍សម្រាប់រយៈពេលវែង និងមធ្យមដែលកំណត់ចេញពីព័ត៌មានស្តីពីទិន្នផល និងអត្រាដំណុះ រួមជាមួយនឹងអត្រាដកហូត ដែលធានាសមាសភាព រចនាសម្ព័ន្ធ និងមុខងារអេកូឡូស៊ីរបស់ព្រៃឈើ

-ការគ្រប់គ្រង "ការជះឥទ្ធិពល" ទៅលើសង្គម និងបរិស្ថានរួមនឹងកម្មវិធីតាមដានត្រួតពិនិត្យ

-កម្មវិធីចូលរួមពិគ្រោះយោបល់ និងកិច្ចព្រមព្រៀងជាមួយសហគមន៍មូលដ្ឋាន

-ប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ឃ-រៀបចំផែនការប្រតិបត្តិការប្រចាំឆ្នាំក្នុងកម្រិតព្រៃគុប និងប្លុក ដោយអនុលោមទៅតាមក្រុមបច្ចេកទេសអនុវត្ត ដោយកំណត់បញ្ជាក់អំពី៖

-វិធីសាស្ត្រ និងគ្រឿងចក្រសម្ភារៈសម្រាប់អាជីវកម្ម

-មាឌឈើដែលត្រូវដកហូត

-ទម្រង់នៃការដៅឈើ និងអូសទាញ

-ទីតាំង និងគម្រោងផ្លូវចូលទៅកាន់ព្រៃឈើ

-សកម្មភាពថែទាំឈើឈរ កូនឈើបន្តពូជ និងការដាំដុះដើមឈើឡើងវិញ

-ការការពារធនធានវប្បធម៌ និងបរិស្ថានលើកន្លែងកំណត់ជាក់លាក់

-ការពិគ្រោះយោបល់ជាមួយសហគមន៍ប្រចាំឆ្នាំ ។

**មាត្រា៧**

៧.១-ការធ្វើផែនការគ្រប់គ្រងព្រៃសម្បទានគ្រប់លំដាប់ថ្នាក់ទាំងអស់ ត្រូវដំណើរការ និងប្រព្រឹត្តទៅតាមបែបបទបច្ចេកទេសនៃការធ្វើផែនការ ដែលមានចែងនៅក្នុងក្រុមបច្ចេកទេសអនុវត្តសម្រាប់រៀបចំគ្រប់គ្រងព្រៃឈើ ។ រាល់ផែនការគ្រប់គ្រងព្រៃឈើគ្រប់លំដាប់ថ្នាក់ទាំងអស់ នឹងមិនត្រូវបានផ្តល់ការយល់ព្រមឡើយ ប្រសិនបើផែនការទាំងនោះមិនគោរពទៅតាមគំនិត និងមិនស្របទៅតាមគោលបំណង និងគោលការណ៍នៃក្រុមបច្ចេកទេសអនុវត្តសម្រាប់រៀបចំគ្រប់គ្រងព្រៃឈើ ។

៧.២-ក្រុមបច្ចេកទេសអនុវត្តសម្រាប់រៀបចំគ្រប់គ្រងព្រៃឈើ នឹងផ្តល់នូវទិសដៅសម្រាប់ធ្វើផែនការគ្រប់គ្រងព្រៃសម្បទាន ដូចមានចែងនៅក្នុងមាត្រា៦ខាងលើ រួមមាន៖

ក-គោលការណ៍ណែនាំសម្រាប់ធ្វើប្រព័ន្ធផែនការរៀបចំគ្រប់គ្រងព្រៃសម្បទាន

ខ-គោលការណ៍ណែនាំសម្រាប់ធ្វើសារពើភ័ណ្ឌនៅក្នុងវដ្តរៀបចំគ្រប់គ្រងព្រៃឈើ

គ-គោលការណ៍ណែនាំសម្រាប់ការអភិរក្សជីវៈចម្រុះក្នុងដែនព្រៃឈើរៀបចំដោយពួក

ឃ-គោលការណ៍ណែនាំសម្រាប់សង្គមព្រៃឈើក្នុងតំបន់ព្រៃសម្បទាន

ង-គោលការណ៍ណែនាំសម្រាប់ការគ្រប់គ្រងទប់ស្កាត់ការលួចឈើ

ច-ក្រុមបច្ចេកទេសអនុវត្តសម្រាប់ប្រមូលផលព្រៃឈើ

ឆ-គោលការណ៍ណែនាំសម្រាប់ការងារវិស្វកម្មព្រៃឈើ

ជ-គោលការណ៍ណែនាំសម្រាប់រៀបចំតំបន់ពិសេស

ឈ-គោលការណ៍ណែនាំសម្រាប់វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយសហការជាមួយក្រសួងបរិស្ថាន។

៧.៣-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានរុក្ខាប្រមាញ់) ត្រូវរៀបចំគោលការណ៍ណែនាំ និងក្រុមបច្ចេកទេសអនុវត្តសម្រាប់រៀបចំគ្រប់គ្រងព្រៃឈើចាំបាច់ផ្សេងទៀត ដូចជាការជ្រើសរើសប្រព័ន្ធរុក្ខវប្បកម្មព្រៃឈើ ការថែរក្សា និងការបន្តពូជឈើ ការរៀបចំគ្រប់គ្រងជម្រកសត្វព្រៃ ការការពារផ្លូវទឹក និងការតាមដានត្រួតពិនិត្យព្រៃឈើ។

**មាត្រា៨**

ផ្អែកលើគោលការណ៍ឯកភាពរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទលើផែនការទាំងនោះ នាយកដ្ឋានរុក្ខាប្រមាញ់ ត្រូវផ្ដល់នូវលិខិតអនុញ្ញាតប្រមូលផលព្រៃឈើ និងសៀវភៅបន្ទុកដែលជាល័ក្ខខ័ណ្ឌបន្ថែមទៅឱ្យម្ចាស់ព្រៃសម្បទាន ដើម្បីចូលទៅធ្វើការប្រមូលផលព្រៃឈើនៅក្នុងព្រៃគុបប្រចាំឆ្នាំ។ ផែនការទាំងនេះ គឺជាទម្រង់ការសំខាន់ចាំបាច់នៃល័ក្ខខ័ណ្ឌអនុញ្ញាត និងជាមូលដ្ឋានសម្រាប់វាយតម្លៃការអនុវត្តតាមបទបញ្ជាព្រៃឈើ។

**ជំពូកទី៤ ការត្រួតពិនិត្យតាមដាន និងការអនុវត្តបទប្បញ្ញត្តិ**

**មាត្រា៩**

៩.១-ការត្រួតពិនិត្យតាមដានការប្រមូលផលព្រៃឈើ ត្រូវធ្វើឡើងជា២ប្រភេទ៖ ការត្រួតពិនិត្យតាមដានល័ក្ខខ័ណ្ឌព្រៃឈើ និងការត្រួតពិនិត្យតាមដានការអនុវត្តច្បាប់ព្រៃឈើ។

-ការត្រួតពិនិត្យតាមដានល័ក្ខខ័ណ្ឌព្រៃឈើ ធ្វើឡើងដើម្បីអង្កេតការផ្លាស់ប្តូរប្រព័ន្ធអេកូឡូស៊ីព្រៃឈើ ចំពោះការប្រើប្រាស់ដី ការប្រមូលផលព្រៃឈើ ឬដំណើរការនៃការងាររុក្ខវប្បកម្ម

-ការត្រួតពិនិត្យតាមដានការអនុវត្តច្បាប់ព្រៃឈើ រៀបចំឡើងដើម្បីវាយតម្លៃការអនុវត្តច្បាប់ ដូចមានចែងក្នុងផែនការដែលបានទទួលការយល់ព្រម និងបណ្ដាល័ក្ខខ័ណ្ឌដែលមានចែងក្នុងសៀវភៅបន្ទុក និងលិខិតអនុញ្ញាតឱ្យប្រមូលផលព្រៃឈើ។

៩.២-កម្មវិធីការត្រួតពិនិត្យតាមដានល័ក្ខខ័ណ្ឌព្រៃឈើ ត្រូវដាក់បញ្ចូលនៅក្នុងផែនការគ្រប់គ្រងព្រៃឈើ ដែលនឹងត្រូវទទួលខុសត្រូវដោយម្ចាស់ព្រៃសម្បទាន។ ការត្រួតពិនិត្យតាមដាននេះរួមមាន៖

ក-ត្រួតពិនិត្យមើលល័ក្ខខ័ណ្ឌនៃការប្រើប្រាស់ដីធ្លី

ខ-ត្រួតពិនិត្យមើលដំណុះកូនឈើ និងក្រោយពេលប្រមូលផលព្រៃឈើ និងល័ក្ខខ័ណ្ឌឈើឈរ

គ-ការត្រួតពិនិត្យតាមដានមើលប្រភេទសត្វព្រៃដែលមានស្រាប់

ឃ-ការត្រួតពិនិត្យតាមដានមើលរុក្ខជាតិក្នុងព្រៃមុន និងក្រោយពេលប្រមូលផលព្រៃឈើ

ង-ធ្វើការអង្កេតឡើងវិញឱ្យបានទូលំទូលាយ នូវលក្ខណៈជីវៈចម្រុះក្នុងតំបន់ព្រៃសម្បទានសម្រាប់ថេរវេលាពី៥ ទៅ១០ឆ្នាំ។ ប្រភេទនៃការការត្រួតពិនិត្យតាមដាននេះ តម្រូវឱ្យមានស្តង់ដារត្រួតពិនិត្យខ្ពស់ទាំងផ្នែកវិទ្យាសាស្ត្រ និងស្ថិតិ ហើយអាចយកទៅអនុវត្តបាន ជាមួយនឹងជំនួយការបច្ចេកទេសនៃអង្គការអន្តរជាតិតាមការចាំបាច់។

៩.៣-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានរុក្ខាប្រមាញ់) ត្រូវរៀបចំក្រុមត្រួតពិនិត្យតាមដានមើលការអនុវត្តរាល់បទប្បញ្ញត្តិប្រមូលផលព្រៃឈើ សម្រាប់ព្រៃសម្បទាននីមួយៗ ដោយកំណត់តួនាទី និងភារកិច្ចឱ្យបានច្បាស់លាស់។

ក្រុមនេះនឹងត្រូវធ្វើអធិការកិច្ចព្រំប្រទល់ព្រៃសម្បទាន និងត្រួតពិនិត្យមើលដំណើរការនៃការប្រមូលផលព្រៃឈើក្នុងព្រៃគុបប្រចាំឆ្នាំ និងប្លុក ហើយត្រូវពិនិត្យមើលនូវរាល់សកម្មភាពបទល្មើស ដែលកើតមាននៅក្នុងតំបន់ព្រៃសម្បទាន ដើម្បីចាត់វិធានការតាមច្បាប់។ រាល់ការធ្វើអធិការកិច្ចត្រូវប្រើប្រាស់នូវឯកសារបទដ្ឋាននៃទម្រង់របាយការណ៍ត្រួតពិនិត្យ ដូចមានចែងក្នុងជំពូក១៤នៃក្រុមបច្ចេកទេសអនុវត្តប្រមូលផលព្រៃឈើ។ ក្រុមការងារនេះនឹងត្រូវធ្វើការវាយតម្លៃពីការបំពេញការងារនៅក្នុងប្លុក និងលើកជាអនុសាសន៍ទៅនាយកដ្ឋានរុក្ខាប្រមាញ់ស្តីពីការបិទប្លុកមុននឹងយល់ព្រមឱ្យបើកប្លុកថ្មីទៀត។ នាយកដ្ឋានរុក្ខាប្រមាញ់ ត្រូវរៀបចំរបាយការណ៍ត្រួតពិនិត្យតាមដានការអនុវត្តបទប្បញ្ញត្តិប្រចាំឆ្នាំ សម្រាប់ព្រៃសម្បទាននីមួយៗ ហើយបញ្ជូនរបាយការណ៍ទាំងនេះទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីធ្វើការផ្សព្វផ្សាយ និងស្វែងរកមតិកែលំអដ៏ទូលំទូលាយពីសាធារណមតិ។

៩.៤-ម្ចាស់ព្រៃសម្បទានទាំងអស់ អាចបង្កើតជាកម្មវិធីត្រួតពិនិត្យតាមដានរបស់ខ្លួនសម្រាប់ត្រួតពិនិត្យការងារផ្ទៃក្នុង ឬសម្រាប់ធានាការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាពខ្ពស់។

៩.៥-នៅរៀងរាល់៥ឆ្នាំម្តងនៃការអនុវត្តផែនការគ្រប់គ្រងព្រៃសម្បទាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានរុក្ខាប្រមាញ់) ត្រូវពិគ្រោះយោបល់ជាមួយម្ចាស់ព្រៃសម្បទាន និងគណៈកម្មាធិការពិគ្រោះយោបល់សហគមន៍ដើម្បី៖

១-ត្រួតពិនិត្យឡើងវិញលើរបាយការណ៍ដែលបានអនុវត្ត

២-វាយតម្លៃលើប្រសិទ្ធភាពនៃលិខិតបទដ្ឋាន ក្រុមបច្ចេកទេសអនុវត្តសម្រាប់រៀបចំគ្រប់គ្រងព្រៃឈើ និងគោលការណ៍ណែនាំ ព្រមទាំងបទប្បញ្ញត្តិគ្រប់គ្រងព្រៃឈើដទៃទៀត។

៣-កំណត់ពីការកែលំអបន្ថែមលើផែនការគ្រប់គ្រងព្រៃសម្បទានដែលចាំបាច់ ដើម្បីជំរុញការអនុវត្តទូទៅឱ្យបានល្អប្រសើរ។

## ជំពូកទី៥ ទោសប្បញ្ញត្តិ

**មាត្រា១០**

១០.១-ក្នុងករណីមិនបានអនុវត្តតាមកាតព្វកិច្ចទាំងឡាយ ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងព្រៃសម្បទាន ឬផែនការរៀបចំគ្រប់គ្រងព្រៃឈើ នាយកដ្ឋានរុក្ខាប្រមាញ់នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការខកខានមិនបានបំពេញកាតព្វកិច្ចនេះទៅសាមីក្រុមហ៊ុនព្រៃសម្បទាន។ ប្រសិនបើមានការខូចខាតកើតឡើងដោយសារការមិនបានបំពេញកាតព្វកិច្ចនេះ សាមីក្រុមហ៊ុនព្រៃសម្បទាននឹងត្រូវបានផ្តល់រយៈពេល៩០ថ្ងៃ ដើម្បីជួសជុលការខូចខាតទាំងនោះ។ ប្រសិនបើសាមីក្រុមហ៊ុនព្រៃសម្បទាននោះ ខកខានមិនបានជួសជុលការខូចខាតនោះទេ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវធ្វើការវាយតម្លៃអំពីការខូចខាតដែលកើតមាន។

១០.២-ដោយមិនគិតពីអានុភាពនៃច្បាប់ និងបទប្បញ្ញត្តិជាធរមានដទៃទៀត ក្នុងករណីមានការបំពានលើបទប្បញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងព្រៃសម្បទាន ឬផែនការរៀបចំគ្រប់គ្រងព្រៃឈើ រាជរដ្ឋាភិបាលអាចតម្រូវឱ្យសាមីក្រុមហ៊ុនព្រៃសម្បទានបង់សំណងនៃការខូចខាត ទៅតាមលទ្ធផលនៃការវាយតម្លៃរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

១០.៣-ក្នុងករណីមានការរំលោភបំពានម្តងហើយម្តងទៀត ទៅលើបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងព្រៃសម្បទាន និងផែនការរៀបចំគ្រប់គ្រងព្រៃឈើ ហើយបើការរំលោភបំពាននេះ

បិតនៅគ្មានការជួសជុលក្នុងរយៈពេល៩០ថ្ងៃ រាជរដ្ឋាភិបាលមានភារកិច្ចប្រកាសព្យួរ ឬបញ្ឈប់ការធ្វើអាជីវកម្មព្រៃសម្បទាននោះ។

១០.៤-សាមីក្រុមហ៊ុនព្រៃសម្បទាន នឹងត្រូវបានតម្រូវឱ្យលះបង់ចោលនូវការទាមទារសិទ្ធិ ឬភោគៈលើឈើ ឬធនធានធម្មជាតិដទៃទៀត ដែលទទួលបានក្នុងរយៈពេលនៃការបំពានលើកិច្ចព្រមព្រៀងព្រៃសម្បទាន និងផែនការរៀបចំគ្រប់គ្រងព្រៃឈើ។

## ជំពូកទី៦ អវសានប្បញ្ញត្តិ

**មាត្រា១១**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១២**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្ត-ក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន។

**មាត្រា១៣**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០០

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រីសុំចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ហត្ថលេខា និងត្រា**

**ឈា សុខ**

## ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ០៥អនក្រ/បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០០
## និយមន័យនៃពាក្យបច្ចេកទេស

-<u>បរិមាណឈើអនុញ្ញាតឱ្យកាប់ប្រចាំឆ្នាំ</u> មានន័យថាជាបរិមាណដែលអាចប្រមូលផលបានក្នុងឆ្នាំនីមួយៗ ពីតំបន់ព្រៃសម្បទានណាមួយ ដោយរក្សាបាននូវប្រព័ន្ធអេកូឡូស៊ី និងមិនត្រូវធ្វើការប្រមូលផលឱ្យហួសពីលទ្ធភាពព្រៃឈើផ្តល់ឱ្យ។ បរិមាណឈើដែលអនុញ្ញាតឱ្យកាប់ប្រចាំឆ្នាំអាចប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ ប៉ុន្តែត្រូវឱ្យមានតុល្យភាពនូវកម្រិតនិរន្តរភាពលើសពីរយៈពេល១០ឆ្នាំ។

-<u>ផែនការប្រមូលផលប្រចាំឆ្នាំ</u> មានន័យថាជាឯកសារដែលកំណត់នូវបទប្បញ្ញត្តិនៅក្នុងក្របខ័ណ្ឌព្រៃគុបប្រចាំឆ្នាំសម្រាប់ការអភិវឌ្ឍ ការប្រមូលផលព្រៃឈើ ការបន្តពូជឡើងវិញ សកម្មភាពអនុវត្តរុក្ខវប្បកម្មនៅក្នុងបែបបទមួយដែលឆ្លើយតបទៅនឹងផែនការគ្រប់គ្រងព្រៃឈើ។

-<u>ជីវៈចម្រុះ</u> មានន័យថាជាភាពចម្រុះគ្នានៃរុក្ខជាតិ សត្វ និងភាវរស់ផ្សេងៗ ទៅតាមទម្រង់ និងរចនាសម្ព័ន្ធគ្រប់លំដាប់ថ្នាក់របស់វា រួមមានហ្សែន ហ្សែននេទិច ពូក ប្រភេទ ប្រព័ន្ធអេកូឡូស៊ី និងដំណើរការវិវត្ត និងមុខងារដែលជាប់ទាក់ទងជាមួយនឹងជីវៈចម្រុះ។

-<u>ប្លុក</u> មានន័យថាជាឯកតាគ្រប់គ្រងដ៏តូចបំផុត ហើយមានមុខងារជាឯកតាមួយសម្រាប់ត្រួតពិនិត្យលើកិច្ចដំណើរការអាជីវកម្មប្រមូលផលព្រៃឈើ។

-<u>សៀវភៅបន្ទុក</u> មានន័យថាជាលិខិតកំណត់គោលការណ៍ និងល័ក្ខខ័ណ្ឌបច្ចេកទេសដែលត្រូវអនុវត្តក្នុងការធ្វើអាជីវកម្មព្រៃឈើ និងរបបទទួលខុសត្រូវរបស់អ្នកទទួលព្រៃគុប សំដៅធានាតុល្យភាពរវាងការធ្វើអាជីវកម្ម ការបន្តពូជ ការការពារព្រៃ និងការសន្សំសំចៃឈើ។

-<u>ក្រុមបច្ចេកទេសអនុវត្តគ្រប់គ្រងព្រៃឈើ</u> មានន័យថាជាកម្រងបទបញ្ជាបច្ចេកទេសសម្រាប់ការគ្រប់គ្រងព្រៃឈើ ក្នុងគោលបំណងណែនាំធ្វើផែនការគ្រប់គ្រង និងការអនុវត្តនៅគ្រប់លំដាប់ថ្នាក់។

-<u>ព្រៃគុប</u> មានន័យថាជាមូលដ្ឋាននៃតំបន់ព្រៃឈើនីមួយៗ ដែលបានបង្កើតឡើងដោយមានការកំណត់ភូមិសាស្ត្រច្បាស់លាស់ ផែនការប្រមូលផលព្រៃឈើប្រចាំឆ្នាំ និងប្រើប្រាស់ជាមូលដ្ឋានសម្រាប់ធ្វើការកត់ត្រាជាប្រចាំលើកិច្ចដំណើរការព្រៃឈើទាំងអស់។

វាយឡើងវិញ

-ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានន័យថាគ្រប់សកម្មភាពដែលធ្វើឡើង ដើម្បីកំណត់ហេតុប៉ះពាល់ទៅលើធនធានធម្មជាតិ ធនធានអេកូឡូស៊ី សុខភាពសាធារណៈ និងសុខុមាលភាពសង្គម ។

-ព្រៃឈើ មានន័យថាជាប្រព័ន្ធមជ្ឈដ្ឋានធម្មជាតិចម្រុះ ដី ទឹក រុក្ខជាតិ មីក្រូសរីរាង្គ... ដែលនៅលើផ្ទៃដីត្រូវបានគ្របដណ្តប់ដោយគម្របរុក្ខជាតិឈើ ឬឫស្សីលើសពី១០ភាគរយ និងមានផ្ទៃដីលើសពី០,៥ហិកតាឡើងទៅដែលរួមមានសារព័ន្ធ ព្រៃគម្របជិតដែលមានរុក្ខជាតិឈើច្រើនស្រទាប់ខុសគ្នានឹងរុក្ខជាតិស្រទាប់ក្រោម គ្របដណ្តប់ភាគច្រើនលើផ្ទៃដី ឬសារព័ន្ធព្រៃចំហដែលមានគម្របរុក្ខជាតិជាប់ៗគ្នា ក្នុងនោះរុក្ខជាតិឈើគ្របដណ្តប់លើសពី១០ភាគរយ ។ ដំណុះព្រៃធម្មជាតិក្មេង និងព្រៃដាំសម្រាប់គោលបំណងព្រៃឈើ ដែលមានដង់ស៊ីតេគម្របស្លឹកមិនទាន់ដល់១០ភាគរយនៅឡើយ ឬផ្ទៃដីអតីតព្រៃឈើដែលរេចរិលដោយសារឥទ្ធិពលរបស់មនុស្ស ឬមូលហេតុធម្មជាតិ ប៉ុន្តែសង្ឃឹមថាអាចជួសជុលកែលំអឡើងវិញបាន ក៏ត្រូវចាត់ថ្នាក់ជាព្រៃឈើដែរ ។

-កិច្ចព្រមព្រៀងព្រៃសម្បទាន មានន័យថាជាកិច្ចព្រមព្រៀង ឬកិច្ចសន្យារវាងរដ្ឋាភិបាលកម្ពុជា និងបុគ្គល១នាក់ ឬក្រុមហ៊ុនពាណិជ្ជកម្មដែលទទួលសិទ្ធិកាន់កាប់តំបន់ព្រៃឈើ ដើម្បីធ្វើអាជីវកម្មប្រមូលផលព្រៃឈើ ទៅតាមល័ក្ខខ័ណ្ឌនៃបទប្បញ្ញត្តិដែលរៀបចំឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ។

-ផែនការគ្រប់គ្រងព្រៃឈើ មានន័យថាជាឯកសារមួយដែលឆ្លើយតបទៅនឹងគោលនយោបាយព្រៃឈើជាតិ និងធនធានធម្មជាតិដាក់បញ្ចូលទៅក្នុងការរៀបចំកម្មវិធីសម្របសម្រួលសម្រាប់គ្រប់គ្រងព្រៃសម្បទានទាំងមូល ដូចជាការកំណត់តំបន់ព្រៃឈើ និងបទបញ្ជាប្រមូលផលព្រៃឈើ និងសកម្មភាពខាងបរិស្ថានសង្គម ក្នុងរយៈពេលកំណត់មួយ (១៥ឆ្នាំ) តាមរយៈការប្រើប្រាស់បទប្បញ្ញត្តិ ដែលមានគោលដៅទូលំទូលាយប្រកបដោយសកម្មភាពគ្រប់គ្រង តាមដាន និងត្រួតពិនិត្យច្បាស់លាស់ ។

-ផលិតផលព្រៃឈើ រួមមាន៖

ក-ឈើមូល ឈើកែច្នៃ ធ្យូង អុស សំបកឈើ និងផលិតផលដែលទាញចេញពីសំបកឈើ

ខ-ដើរឈើគ្រប់ប្រភេទ ឫស ស្លឹកផ្កា ផ្លែ គ្រាប់ ផ្សិត វល្លិ ផ្តៅ ឫស្សីគ្រប់ប្រភេទ រុក្ខជាតិផលិតជាផលិតផលឱសថ គ្រឿងសំអិតសំអាង គ្រឿងទេស ចំណើសត្វ ផលិតផលវប្បធម៌ សម្រាប់ពិធីបុណ្យ សម្ភារៈសំណង់ និងស្បូវដែលទាញយកពីព្រៃឈើ ព្រៃគុម្ពោត និងរុក្ខជាតិផ្សេងៗទៀតងាប់ ឬនៅរស់។

គ-ផលិតផលព្រៃឈើផ្សេងៗទៀត និងផលប្រមាញ់គ្រប់ប្រភេទ ដែលគ្មានចែងនៅក្នុងអនុក្រឹត្យនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអាចធ្វើការប្រកាសជាផលិតផលព្រៃឈើបាន។

-<u>គោលការណ៍ណែនាំ</u> មានន័យថាជាកម្រងបទប្បញ្ញត្តិធ្វើផែនការ និងប្រតិបត្តិការប្រមូលផលព្រៃឈើដែលមិនមានការចាំបាច់គ្រប់ពេលវេលា ប៉ុន្តែវាអាចក្លាយទៅជាល័ក្ខខ័ណ្ឌនៃការអនុវត្ត ដែលមានចែងនៅក្នុងផែនការ លិខិតអនុញ្ញាត និងកិច្ចសន្យា (ដូចគ្នានឹងក្រុមបច្ចេកទេសអនុវត្តគ្រប់គ្រងព្រៃឈើ)

-<u>ព្រៃឈើអចិន្ត្រៃយ៍</u> មានន័យថា ជាតំបន់ដីដែលមានកំណត់ទីតាំងភូមិសាស្ត្រច្បាស់លាស់ និងស្របច្បាប់នៃគ្រប់ប្រភេទកម្មសិទ្ធិដែលរួមមានព្រៃ និងព្រៃផ្តល់ផលដែលឋិតនៅក្រោមការគ្រប់គ្រងដោយរដ្ឋ ម្ចាស់ព្រៃសម្បទាន សហគមន៍មូលដ្ឋាន និងអ្នកប្រើប្រាស់ព្រៃឈើផ្សេងៗទៀត សម្រាប់រយៈពេលវែងក្នុងការទាញយកផលព្រៃឈើដោយនិរន្តរភាព និងថែទាំនូវសមាសភាព និងរចនាសម្ព័ន្ធព្រៃ ព្រមទាំងតួនាទីបរិស្ថាន។

-<u>ធនធានធម្មជាតិ</u> មានន័យថាជាភោគផលដែលកើតមានឡើងដោយធម្មជាតិនៅក្នុងជម្រៅដី ឬនៅលើផ្ទៃដីនៃតំបន់ព្រៃសម្បទាន ដូចជាកំណប់រ៉ែ លោហធាតុ ឧស្ម័ន ប្រេងកាត ត្បូង ថ្ម ដីខ្សាច់ ទឹក... ។ល។ ត្រូវឋិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋតាមច្បាប់ជាធរមានផ្សេងៗទៀត។

-<u>ថ្លៃបម្រុង</u> មានន័យថាតម្លៃអប្បបរិមាដែលរាជរដ្ឋាភិបាលកម្ពុជានឹងយល់ព្រមនៅក្នុងដំណើរការដេញថ្លៃ សម្រាប់ផ្តល់ព្រៃសម្បទានណាមួយ។ តម្លៃបម្រុងអាចត្រូវបាន ឬមិនត្រូវបានប្រកាសជាចំហ មុនពេលចាប់ផ្តើមដំណើរការដេញថ្លៃ។

-<u>គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ</u> មានន័យថាជាអង្គការជ្រើសតាំងនៅថ្នាក់ភូមិដែលបង្កើតឡើងដោយអនុក្រឹត្យឋិតនៅក្រោមច្បាប់អភិវឌ្ឍន៍ជនបទ ដើម្បីផ្តល់ជាយោបល់ទៅរាជរដ្ឋាភិបាលស្តីពីតម្រូវការអភិវឌ្ឍមូលដ្ឋាន និងការផ្តួចផ្តើមគំនិត។

-<u>តំបន់</u> មានន័យថាជាអនុផ្នែកនៃព្រៃសម្បទានដែលមានលក្ខណៈអេកូឡូស៊ីជីវរូបសាស្ត្រ ឬតម្លៃនៃធនធាន ដែលតម្រូវឱ្យមានរបបគ្រប់គ្រងដោយឡែកពីតំបន់ដែលជាប់ៗគ្នា។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ២២ដនសគ/ជីធ្លី

**សេចក្ដីសម្រេច**

**ស្ដីពីការបង្កើតក្រុមជំនួយការផ្ទាល់ប្រធានគណៈកម្មការ**

**ដោះស្រាយបាតុភាពបញ្ហាដីធ្លីនៅតាមបណ្ដាខេត្ត-ក្រុងទូទាំងប្រទេស**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញសេចក្ដីសម្រេចលេខ៤៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- តាមការចាំបាច់របស់ក្រសួង

**សម្រេច**

**ប្រការ១**

បង្កើតក្រុមជំនួយការផ្ទាល់ប្រធានគណៈកម្មការដោះស្រាយបាតុភាពបញ្ហាដីធ្លី នៅតាមបណ្ដាខេត្ត-ក្រុង ទូទាំងប្រទេសដែលមានរាយឈ្មោះដូចខាងក្រោម៖

១-ឯកឧត្តម សេក សេដ្ឋា អគ្គនាយកនៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ប្រធាន

២-លោក ប៉ាល់ ប្រិច មន្ត្រីនៃអធិការដ្ឋានក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

៣-លោក សួន ស៊ីផាត ប្រធាននាយកដ្ឋានអធិការកិច្ចភូមិបាល

នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ សមាជិក

៤-លោក ភិន ហម មន្ត្រីនៃខុទ្ទកាល័យរដ្ឋមន្ត្រី សមាជិកអចិន្ត្រៃយ៍

៥- លោក សូ សីហា មន្ត្រីនៃអធិការដ្ឋានក្រសួងរៀបចំដែនដី

នគរូបនីយកម្ម និងសំណង់ លេខាធិការ

**ប្រការ២**

ក្រុមជំនួយការនេះមានភារកិច្ចជាជំនួយការជូនឯកឧត្តមរដ្ឋមន្ត្រី ក្នុងការសិក្សាស្រាវជ្រាវលើកវិធានការដោះស្រាយ ធ្វើរបាយការណ៍អំពីវិធានការ និងលទ្ធផលនៃការដោះស្រាយ ព្រមទាំងរៀបចំឯកសារផ្សេងៗដែលពាក់ព័ន្ធដល់ការងារដោះស្រាយបាតុភាពបញ្ហាដី នៅតាមបណ្ដាខេត្ត-ក្រុងទូទាំងប្រទេស។

**ប្រការ៣**

អស់លោកដែលមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តសេចក្ដីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ១១អនក្រ/បក

# អនុក្រឹត្យ

## ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញក្រឹត្យច្បាប់ ១០០ក្រ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩២ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ០៤នស/រកម ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរៀបចំក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ២០អនក្រ/បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ/បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០០

## សម្រេច

## ជំពូកទី១ បទប្បញ្ញត្តិទូទៅ

### មាត្រា១

អនុក្រឹត្យនេះកំណត់នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លីតាមរយៈការវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធ នៅក្នុងតំបន់ដែលបានប្រកាសថាជាទីតាំងធ្វើការវិនិច្ឆ័យដូចមានក្នុងមាត្រា២នៃអនុក្រឹត្យនេះ ។

### មាត្រា២

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវកំណត់ និងណែនាំបច្ចេកទេសជំនាញ និងទម្រង់បែបបទនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លីដល់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង ។

អភិបាលខេត្ត-ក្រុង ត្រូវចេញសេចក្តីប្រកាសកំណត់តំបន់ និងព្រំប្រទល់នៃទីតាំងនៃការវិនិច្ឆ័យតាមរបៀបបង្ហាញលើផែនទី ឬតាមរបៀបពិពណ៌នា ឬតាមរបៀបទាំងពីរ ។

## ជំពូកទី២ សមត្ថកិច្ច និងភារកិច្ច

### មាត្រា៣

នៅពេលដែលតំបន់ត្រូវធ្វើការវិនិច្ឆ័យបានប្រកាសហើយ អភិបាលខេត្ត-ក្រុងនៃតំបន់ធ្វើការវិនិច្ឆ័យត្រូវតែងតាំងគណៈកម្មការរដ្ឋបាល សម្រាប់តំបន់ដែលត្រូវការវិនិច្ឆ័យនោះ ។

សមាសភាពនៃគណៈកម្មការរដ្ឋបាលនោះមាន៖

| | |
|---|---|
| -តំណាងអភិបាលខេត្ត | ជាប្រធាន |
| -មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ជាមន្ត្រីសុរិយោដី | ជាសមាជិក |
| -អភិបាលស្រុក-ខណ្ឌ ឬតំណាង | ជាសមាជិក |
| -មេឃុំ ចៅសង្កាត់ ឬតំណាង | ជាសមាជិក |
| -មេភូមិ ឬតំណាង | ជាសមាជិក |
| -ចាស់ព្រឹទ្ធាចារ្យក្នុងទីតាំងធ្វើការវិនិច្ឆ័យ២រូប | ជាសមាជិក |

ភារកិច្ចរបស់គណៈកម្មការរដ្ឋបាលមាន៖

-បិទផ្សាយជាសាធារណៈនូវប្លង់បញ្ជីសុរិយោដី ជាអាទិ៍ ប្លង់សុរិយោដី និងបញ្ជីឈ្មោះអ្នកកាន់កាប់ដី

-ទទួលរាល់បណ្តឹងតវ៉ា ធ្វើការស្រាវជ្រាវ និងដោះស្រាយតាមការព្រមព្រៀង

-ធ្វើសេចក្តីសន្និដ្ឋានផ្តល់យោបល់លើឯកសារនៃការវិនិច្ឆ័យ

-លើកសំណើផ្តល់សិទ្ធិលើដីជូនអ្នកកាន់កាប់ជូនកម្មសិទ្ធិករ ឬរក្សាទុកជាទ្រព្យសម្បត្តិរដ្ឋ។

**មាត្រា៤**

នៅពេលដែលតំបន់ធ្វើការវិនិច្ឆ័យត្រូវបានកំណត់ហើយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចាត់តាំងមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ព្រមទាំងមន្ត្រីចាំបាច់មួយចំនួនទៀត រួមមានមន្ត្រីកំណត់ព្រំដី មន្ត្រីវិនិច្ឆ័យ និងមន្ត្រីវាស់វែង ដែលត្រូវបំពេញភារកិច្ចក្នុងតំបន់ធ្វើការវិនិច្ឆ័យ។

មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ដែលបានទទួលសេចក្តីណែនាំពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវទទួលខុសត្រូវចំពោះការវិនិច្ឆ័យដែលបានកំណត់ក្នុងអនុក្រឹត្យនេះ។ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យមានសិទ្ធិដឹកនាំចេញសេចក្តីណែចាំបាច់ ដល់មន្ត្រីជំនាញដែលបានតែងតាំងក្នុងវាក្យខណ្ឌទី១ មាត្រា៤នៃអនុក្រឹត្យនេះ។

មន្ត្រីកំណត់ព្រំដីមានសិទ្ធិចូលក្នុងបរិវេណអចលនវត្ថុណាមួយ នៅក្នុងតំបន់ធ្វើការវិនិច្ឆ័យ ដើម្បីកំណត់ព្រំ និងវាស់វែងហើយអាចអញ្ជើញជនដែលពាក់ព័ន្ធឱ្យផ្តល់នូវចម្លើយដោយផ្ទាល់មាត់ ឯកសារ ឬភស្តុតាងផ្សេងៗ ទាក់ទងទៅនឹងព្រំនៃក្បាលដីណាមួយ។ មន្ត្រីកំណត់ព្រំដីអាចអនុវត្តការងារតាមសិទ្ធិអំណាចផ្សេងទៀតដែលផ្តល់ដល់មន្ត្រីវាស់វែងសុរិយោដី ដូចដែលមានចែងក្នុងច្បាប់ភូមិបាលក្នុងកិច្ចការវាស់វែងដីធ្លី។

មន្ត្រីវិនិច្ឆ័យមានសិទ្ធិសាកសួរយកព័ត៌មានចាំបាច់សម្រាប់អនុវត្តការងារវិនិច្ឆ័យ អាចអញ្ជើញជនដែលពាក់ព័ន្ធឱ្យផ្តល់នូវចម្លើយដោយផ្ទាល់មាត់ ឯកសារ ឬភស្តុតាងផ្សេងៗទាក់ទងទៅនឹងការវិនិច្ឆ័យ។

ជនគ្រប់រូបមានសិទ្ធិចូលរួមពិនិត្យ និងផ្តល់យោបល់ ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ និងមានសិទ្ធិសុំឱ្យមន្ត្រីជំនាញពន្យល់បំភ្លឺអំពីខ្លឹមសារនៃទិន្នន័យដែលពាក់ព័ន្ធនឹងតំបន់ធ្វើការវិនិច្ឆ័យ ។

**មាត្រា៦**

អភិបាលខេត្ត-ក្រុង ត្រូវធ្វើលិខិតផ្លូវការដែលពិពណ៌នា និងអនុញ្ញាតឱ្យអនុវត្តនីតិវិធីវិនិច្ឆ័យ ដែលមានលក្ខណៈជាប្រព័ន្ធទៅអាជ្ញាធរមូលដ្ឋាននៃតំបន់ធ្វើការវិនិច្ឆ័យ យ៉ាងហោចណាស់ ១៥ថ្ងៃ មុនកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ធ្វើការវិនិច្ឆ័យ ។

អភិបាលខេត្ត-ក្រុង ត្រូវជូនដំណឹងជាសាធារណៈអំពីពេលវេលា និងទីកន្លែងនៃកិច្ចប្រជុំផ្សព្វផ្សាយ ។ សេចក្តីជូនដំណឹងត្រូវបិទឱ្យសាធារណជនដឹងយ៉ាងហោច៧ថ្ងៃ មុនបើកកិច្ចប្រជុំផ្សព្វផ្សាយក្នុងកន្លែងដែលងាយឃើញនៅក្នុងភូមិ ឬនៅទីតាំងធ្វើការវិនិច្ឆ័យផ្ទាល់ ។ សេចក្តីប្រកាសត្រូវតែផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាពក្នុងទីតាំងធ្វើការវិនិច្ឆ័យដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន ។

កិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ធ្វើការវិនិច្ឆ័យ ដែលមានលក្ខណៈជាប្រព័ន្ធត្រូវរៀបចំធ្វើនៅក្នុងទីតាំងធ្វើការវិនិច្ឆ័យ ។ ក្នុងកិច្ចប្រជុំនោះ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ឬតំណាងគណៈកម្មការរដ្ឋបាលត្រូវពន្យល់ពីដំណើរការនៃការវិនិច្ឆ័យបំភ្លឺពីបញ្ញាច្បាប់ និងឆ្លើយរាល់សំណួរទាក់ទងនឹងការវិនិច្ឆ័យដែលបានលើកឡើង ។

កិច្ចប្រជុំបន្ថែមសម្រាប់ថ្នាក់ភូមិនឹងត្រូវបានរៀបចំ ប្រសិនបើមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ឬអាជ្ញាធរមូលដ្ឋានចាត់ទុកជាការចាំបាច់ ។

**មាត្រា៧**

មន្ត្រីកំណត់ព្រំដីត្រូវជូនដំណឹងដល់ថ្នាក់ដឹកនាំមូលដ្ឋាន អំពីការកំណត់ព្រំដីក្នុងតំបន់ធ្វើការវិនិច្ឆ័យ ពេលវេលា និងទីកន្លែងដែលនឹងចាប់ផ្តើមធ្វើការវិនិច្ឆ័យឱ្យបានមុន៧ថ្ងៃយ៉ាងតិច ។ សេចក្តីជូនដំណឹងតម្រូវឱ្យជនដែលពាក់ព័ន្ធមកចង្អុលបង្ហាញព្រំប្រទល់នៃអចលនវត្ថុរបស់ខ្លួន តាមរបៀបដែលបានបញ្ជាក់ក្នុងសេចក្តីប្រកាសជូនដំណឹង ។

បន្ទាប់មក មន្ត្រីកំណត់ព្រំដីដែលបានទទួលការណែនាំពីអ្នកគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ត្រូវកំណត់ព្រំប្រទល់អចលនវត្ថុទាំងអស់ដែលបង្កើតបានជាក្បាលដីក្នុងប្លង់សុរិយោដី។ ក្នុងរយៈពេលធ្វើការកំណត់ព្រំប្រទល់ក្បាលដី មន្ត្រីកំណត់ព្រំដីត្រូវគោរពគោលការណ៍ដូចខាងក្រោម៖

ក-បើកម្មសិទ្ធិករ ឬម្ចាស់នៃក្បាលដី និងម្ចាស់នៃក្បាលដីដែលជាប់ព្រំមានវត្តមាន ហើយព្រមព្រៀងលើព្រំប្រទល់ នោះព្រំប្រទល់ នឹងត្រូវបានកំណត់យោងតាមការព្រមព្រៀង។

ខ-បើការព្រមព្រៀងដែលរៀបរាប់ក្នុងចំណុច (ក) នៃមាត្រានេះមិនអាចធ្វើទៅបាន ឬមានកម្មសិទ្ធិករ ឬម្ចាស់នៃក្បាលដី និងម្ចាស់នៃក្បាលដីដែលនៅជាប់ព្រំណាមួយអវត្តមាន នោះព្រំប្រទល់ត្រូវកំណត់នៅលើដីតាមឯកសារដែលមាន និងភស្តុតាងជាលក្ខណរូប ជាលាយលក្ខណ៍អក្សរ ឬចម្លើយផ្ទាល់មាត់ទាក់ទងនឹងព្រំដី។

គ-ចំពោះក្បាលដីដែលមានព្រំប្រទល់ជាប់នឹងដីសាធារណៈ និងក្បាលដីដែលប្រើប្រាស់ជាសាធារណៈ ព្រំប្រទល់ក្បាលដីត្រូវកំណត់ដោយអនុលោមទៅតាមចំណុច (ក) ឬ (ខ) នៃវាក្យខណ្ឌទី២ មាត្រា៧នៃអនុក្រឹត្យនេះ។

**មាត្រា៨**

មន្ត្រីវាស់វែងដែលបានទទួលការណែនាំពីមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ត្រូវអនុវត្តការងារវាស់វែងដែលជាតម្រូវការក្នុងការប្រតិបត្តិនីតិវិធីវិនិច្ឆ័យ និងរៀបចំប្លង់សុរិយោដី។

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង ត្រូវណែនាំលំអិតអំពីទម្រង់បែបបទ និងខ្លឹមសារនៃប្លង់សុរិយោដី។

## ជំពូកទី៣ នីតិវិធីនៃការវិនិច្ឆ័យ

**មាត្រា៩**

មន្ត្រីវិនិច្ឆ័យដែលបានទទួលការណែនាំពីមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ត្រូវអង្កេតរាល់ឯកសារ ភស្តុតាង និងព័ត៌មានផ្សេងៗជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ទាក់ទងទៅនឹងសិទ្ធិលើក្បាលដីនីមួយៗក្នុងតំបន់វិនិច្ឆ័យ ហើយកត់ត្រាសិទ្ធិទាំងនេះចូលក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី។

**មាត្រា១០**

ការរៀបចំឯកសារនៃការវិនិច្ឆ័យមានន័យដូចខាងក្រោម៖

១-ឯកសារនៃការវិនិច្ឆ័យត្រូវមាន៖

-ប្លង់សុរិយោដី

-បញ្ជីឈ្មោះម្ចាស់ដី

-ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ។

ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីនីមួយៗ ត្រូវបង្ហាញ៖

ក-អត្តសញ្ញាណក្បាលដី

ខ-អត្តសញ្ញាណម្ចាស់ដី

គ-កាលបរិច្ឆេទនៃការវិនិច្ឆ័យ

២-ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ត្រូវផ្តិតមេដៃយល់ព្រមទាំងអ្នកជាប់ព្រំ ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីវិនិច្ឆ័យ ។

៣-នៅពេលដែលឯកសារនៃការវិនិច្ឆ័យត្រូវបានបំពេញចប់សព្វគ្រប់ហើយ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យត្រូវចុះហត្ថលេខាលើឯកសារទាំងនេះ ។

**មាត្រា១១**

ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យដែលរួមមានប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដីត្រូវមានរយៈវេលា៣០ថ្ងៃនៅកន្លែងដែលងាយមើលឃើញ សម្រាប់ការអង្កេតជាសាធារណៈនៅក្នុងតំបន់ធ្វើការវិនិច្ឆ័យ ។

អាជ្ញាធរខេត្ត-ក្រុងត្រូវផ្សព្វផ្សាយដំណឹងអំពីការផ្សាយជាសាធារណៈ នូវឯកសារនៃការវិនិច្ឆ័យតាមសំណើរបស់គណៈកម្មការរដ្ឋបាល ។ ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យអាចកែតម្រូវការខុសឆ្គង ឬការភ្លេចភ្លាំងណាដែលមិនជះឥទ្ធិពលដល់ផលប្រយោជន៍ត្រឹមត្រូវស្របច្បាប់នៃជនណាមួយ ។ ការកែតម្រូវផ្សេងៗក្នុងឯកសារនៃការវិនិច្ឆ័យអាចធ្វើបាន ដរាបណាមានការយល់ព្រមពីជនពាក់ព័ន្ធដែលទទួលឥទ្ធិពលពីការកែតម្រូវនោះ ។

**មាត្រា១២**

ក្នុងអំឡុងពេលនៃការបិទផ្សាយជាសាធារណៈ ជនណាដែលមានឈ្មោះក្នុងបញ្ជី ឬអ្នកដែលមានផលប្រយោជន៍លើក្បាលដីណាមួយដែលបានចាត់ទុកថា ឯកសារនៃការវិនិច្ឆ័យមិនជាក់លាក់ ឬមិនពេញលេញអាចផ្តល់ដំណឹងដល់គណៈកម្មការរដ្ឋបាលនូវការជំទាស់របស់ខ្លួន។

ក្រោយពីផ្តល់នូវការកត់សម្គាល់ដ៏សមហេតុផល ដល់ជនគ្រប់រូបដែលពាក់ព័ន្ធនឹងការជំទាស់ និងបន្ទាប់ពីពិគ្រោះជាមួយអ្នកដែលធ្វើការជំទាស់ គណៈកម្មការរដ្ឋបាលត្រូវព្យាយាមដោះស្រាយតាមការព្រមព្រៀង។

ការជំទាស់ ឬវិវាទណាមួយដែលមិនអាចដោះស្រាយបានត្រូវបញ្ជូនទៅតុលាការ។ ក្នុងករណីនេះ គណៈកម្មការរដ្ឋបាលត្រូវអនុវត្តតាមសេចក្តីសម្រេចចុងក្រោយរបស់តុលាការ។

**មាត្រា១៣**

ក្រោយពីផុតកំណត់រយៈពេលនៃការបិទផ្សាយជាសាធារណៈ នូវឯកសារនៃការវិនិច្ឆ័យ និងបញ្ចប់ការដោះស្រាយទំនាស់តាមនីតិវិធី ដូចមានចែងក្នុងមាត្រា១២នៃអនុក្រឹត្យនេះ គណៈកម្មការរដ្ឋបាលត្រូវផ្តល់ការយល់ព្រមលើឯកសារនៃការវិនិច្ឆ័យចំពោះក្បាលដីទាំងឡាយណា ដែលមិនមានទំនាស់។

បន្ទាប់ពីការយល់ព្រម គណៈកម្មការរដ្ឋបាលត្រូវបញ្ជូនឯកសារនៃការវិនិច្ឆ័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ដើម្បីពិនិត្យលើលក្ខណៈបច្ចេកទេស និងចុះហត្ថលេខា ហើយបញ្ជូនទៅអភិបាលខេត្ត-ក្រុងចុះហត្ថលេខា។

**មាត្រា១៤**

ក្រោយពីអភិបាលខេត្ត-ក្រុង និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ចុះហត្ថលេខាហើយ ឯកសារនៃការវិនិច្ឆ័យត្រូវបានបញ្ចប់ជាស្ថាពរចំពោះក្បាលដីដែលមិនមានទំនាស់។ ចំពោះឯកសារនៃការវិនិច្ឆ័យដែលនៅពាក់ព័ន្ធនឹងវិវាទ នឹងត្រូវបញ្ចប់ជាស្ថាពរនៅពេលមានសេចក្តីសម្រេចពីតុលាការដូចដែលបានចែងក្នុងមាត្រា១២នៃអនុក្រឹត្យនេះ។

នៅពេលដែលឯកសារនៃការវិនិច្ឆ័យត្រូវបានបញ្ចប់ជាស្ថាពរ យោងតាមវាក្យខណ្ឌទី១នៃមាត្រានេះ ឯកសារនៃការវិនិច្ឆ័យព្រមទាំងឯកសារទាំងអស់ដែលទទួលបានក្នុងអំឡុងពេលនៃ

ការវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធត្រូវបញ្ជូនទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង តាមលំដាប់ថ្នាក់ដើម្បីចុះបញ្ជី។

ក្រោយពេលក្បាលដីដែលមានក្នុងឯកសារនៃការវិនិច្ឆ័យត្រូវបានចុះបញ្ជីហើយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលើគ្រប់ក្បាលដីក្នុងតំបន់ធ្វើការវិនិច្ឆ័យនេះ។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់អាចប្រគល់សិទ្ធិឱ្យខេត្ត-ក្រុងណាដែលមានគ្រប់លក្ខណសម្បត្តិដើម្បីចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុនេះ នៅក្នុងតំបន់ធ្វើការវិនិច្ឆ័យនៃខេត្ត-ក្រុងរបស់ខ្លួន។

## ជំពូកទី៤ អវសានប្បញ្ញត្តិ

**មាត្រា១៥**

អនុក្រឹត្យនេះមានអានុភាពលើតំបន់ដែលបានដំណើរការធ្វើការវិនិច្ឆ័យ មានលក្ខណៈជាប្រព័ន្ធកន្លងមក។

**មាត្រា១៦**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១៧**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអភិបាលខេត្ត-ក្រុងទាំងអស់ដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០០០

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

**បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ហត្ថលេខា**

**អ៊ឹម ឈុនលឹម**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
លេខ៩៦១សហវ

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០០

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ជម្រាបជូន**
**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ**
**ឯកឧត្តមអភិបាលខេត្ត-ក្រុងទូទាំងព្រះរាជាណាចក្រកម្ពុជា**

កម្មវត្ថុ ស្តីពីការអនុវត្តគោលការណ៍ដីចំណីផ្លូវជាតិ ផ្លូវខេត្ត ផ្លូវឃុំ ផ្លូវរថភ្លើងនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

យោង ប្រកាសលេខ០៦ប្រក របស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៩៩។

សេចក្តីដូចបានជម្រាបជូនតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា តាមរយៈបទពិសោធន៍ពីការដោះស្រាយផលប៉ះពាល់ដល់សំណង់ផ្ទះសំបែងដីធ្លីប្រជារាស្ត្រនៅតាមដងផ្លូវជាតិកន្លងមក ក្រុមការងាររបស់គណៈកម្មការអន្តរក្រសួងបានជួបប្រទះនូវបញ្ហាស្មុគស្មាញជាច្រើន ដែលក្នុងនោះមានជនមួយចំនួនបានឆ្លៀតឱកាសបង្កនូវភាពអនាធិបតេយ្យទន្ទ្រានដីធ្លីដែលជាដីចំណីផ្លូវធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន និងធ្វើការលក់ និងទិញដូរបន្តឥតឈប់ឈរ។ ក្នុងនោះក៏មានប្រជាជនមួយចំនួនបានធ្វើការសាងសង់រោងលក់ដូរធ្វើអាជីវកម្ម សង់ខ្ទម សង់លំនៅឋាន និងដាំដំណាំនៅលើដីចំណីផ្ទាល់ផងដែរ។ យោងប្រកាសលេខ០៦ប្រក របស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៩៩ បានកំណត់ដីចំណីផ្លូវថ្នល់ និងចំណីផ្លូវរថភ្លើងសម្រាប់បម្រើការអភិវឌ្ឍលើវិស័យហេដ្ឋារចនាសម្ព័ន្ធខាងក្រោម៖

-ផ្លូវជាតិមានលេខមួយខ្ទង់ ដូចជាលេខ២, ៣, ៦, ៧ ចម្ងាយ២៥ម៉ែត្រពីសងខាងអ័ក្សផ្លូវ លើកលែងតែផ្លូវជាតិលេខ១, ៤, ៥ ចម្ងាយ៣០ម៉ែត្រពីសងខាងអ័ក្សផ្លូវ។

-ផ្លូវជាតិមានលេខពីរខ្ទង់ ដូចជាលេខ១១, ២២, ៦៤, ៧៨ ចម្ងាយ២៥ម៉ែត្រពីសងខាងអ័ក្សផ្លូវ ។

-ផ្លូវខេត្ត ចម្ងាយ២០ម៉ែត្រពីសងខាងអ័ក្សផ្លូវ

-ផ្លូវឃុំ ចម្ងាយ១៥ម៉ែត្រពីសងខាងអ័ក្សផ្លូវ

-ផ្លូវរថភ្លើង ចម្ងាយ២០ម៉ែត្រពីសងខាងអ័ក្សផ្លូវ ចំពោះទីក្រុង ទីរួមខេត្ត និងទីប្រជុំជន

-ផ្លូវរថភ្លើង ចម្ងាយ៣០ម៉ែត្រពីសងខាងអ័ក្សផ្លូវ ចំពោះផ្លូវដែលដែលឋិតនៅក្រៅក្រុង

-ផ្លូវរថភ្លើង ចម្ងាយ១០០ម៉ែត្រពីសងខាងអ័ក្សផ្លូវ ចំពោះផ្លូវដែកក្នុងតំបន់ព្រៃភ្នំដែលមានថ្មរមៀលធ្លាក់ ឬតំបន់ព្រៃខ្ពស់ ។

ដើម្បីអនុវត្តប្រកាសលេខ០៦ប្រក ឱ្យមានប្រសិទ្ធភាពខ្ពស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមជម្រាបថារាជរដ្ឋាភិបាលនឹងពុំចំណាយថវិកាជាតិធ្វើការទូទាត់នូវអ្វី ដែលឋិតនៅលើដីចំណីផ្លូវ និងផ្លូវដែកឡើយ ។

ទទួលបានសេចក្តីជូនដំណឹងនេះ អាជ្ញាធរដែនដីគ្រប់ខេត្ត-ក្រុង មេត្តាផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងខិតខំអនុវត្តផែនការខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ខ្ញុំសូមឯកឧត្តមមេត្តាជ្រាបជាព័ត៌មានតាមការគួរ ។

សូមឯកឧត្តមមេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

*ចម្លងជូន*

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសាធារណការ និងដឹកជញ្ជូន

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ៨៤២៧ដនស/រប

## សេចក្តីណែនាំ
## ស្តីពីការអនុវត្តលក្ខណការណ៍រដ្ឋបាល
## លើការងារសុរិយោដីនៃមន្ទីរ ដ.ន.ស.ស ខេត្ត-ក្រុង

រយៈកាលកន្លងមក ក្រសួងបានកត់សម្គាល់ឃើញថា ក្នុងការតាក់តែង និងកសាងឯកសារសុរិយោដី ដើម្បីផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុក៏ដូចជាការស្នើសុំចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់តាមកំណត់ហេតុអង្កេតដី ឬឯកសារគតិយុត្តផ្សេងៗ គ្រប់ខេត្ត-ក្រុងបានអនុវត្តល្អបង្គួរលើវិស័យរដ្ឋបាល បច្ចេកទេស និងគតិយុត្ត។

ទន្ទឹមនឹងនេះ ក៏នៅមានខ្វះចន្លោះខ្លះដូចជា ការគួបផ្សំឯកសាររណប ការពិនិត្យខ្លឹមសារបច្ចេកទេស អក្ខរាវិរុទ្ធ បរវេណីខ្លឹមសារ ការអនុវត្តសាលក្រម ឬសាលដីកាតុលាការ ។ល។

ដើម្បីពង្រឹងនូវវិស័យបច្ចេកទេសតាមបែបរដ្ឋបាល លើការងារទាំងឡាយដូចបានរៀបរាប់មកនេះឱ្យមានភាពសុក្រឹត និងតម្លាភាពថែមទៀត និងដើម្បីយកស្មារតីទទួលខុសត្រូវលើភារកិច្ច ចំពោះមុខរបស់មន្ត្រីថ្នាក់ដឹកនាំគ្រប់ខេត្ត-ក្រុង សំដៅចៀសវាងនូវទំនាស់ ហើយរក្សាបាននូវសាមគ្គីផ្ទៃក្នុង ក្រសួងធ្វើការណែនាំតាមគោលការណ៍ខ្លះដូចខាងក្រោម៖

១-ប្រធានការិយាល័យសុរិយោដី និងភូមិសាស្ត្រនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង ស្រុក-ខណ្ឌ ចងក្រងឡើងថា "បានពិនិត្យត្រឹមត្រូវ" ហើយចុះហត្ថលេខាខាងចុងឃ្លានេះដោយមានចុះថ្ងៃ ខែ ឆ្នាំ ច្បាស់លាស់មុននឹងដាក់ជូនអនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ទទួលបន្ទុកកិច្ចការសុរិយោដីពិនិត្យបន្ត។

២-ក្នុងការអនុវត្តការងារ បើពិនិត្យឃើញឯកសារពុំទាន់មានលក្ខណៈគ្រប់គ្រាន់ទេ ត្រូវបញ្ជូនឱ្យការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌធ្វើការពិនិត្យ

និងអង្កេតឡើងវិញ។ ក្នុងករណីពិនិត្យឃើញថា ឯកសារមានភាពមិនប្រក្រតី ឬមានការលំបាកស្មុគស្មាញ ត្រូវប្រជុំអ្នកបច្ចេកទេសពាក់ព័ន្ធ ដើម្បីផ្លាស់ប្តូរយោបល់គ្នាដោះស្រាយ។ បើដោះស្រាយមិនរួច ត្រូវសុំយោបល់បច្ចេកទេសពីថ្នាក់លើបន្តបន្ទាប់។

៣-ត្រាលេខាចារឹកដែលបោះនៅលើឯកសារទាំងអស់ត្រូវបានប្រគល់សិទ្ធិឱ្យអនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីទទួលបន្ទុកកិច្ចការសុរិយោដី ដោយត្រូវចុះហត្ថលេខាបំព្រួញដោយមានចុះថ្ងៃ ខែ ឆ្នាំ។

៤-រាល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ប្រធាន និងអនុប្រធានមន្ទីរទទួលបន្ទុកការងារសុរិយោដី ត្រូវចុះហត្ថលេខាបំព្រួញមុននឹងបញ្ជូនមកអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រពិនិត្យ និងសម្រេច។

៥-ដីកាបញ្ជូនសំណុំឯកសារសុរិយោដី ត្រូវចុះហត្ថលេខាដោយប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង ក្រោយពេលដែលអនុប្រធានមន្ទីរទទួលបន្ទុកការងារសុរិយោដីបានចុះហត្ថលេខាបំព្រួញហើយ។

៦-ចំពោះចរន្តការងារនៅតាមការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌក៏ត្រូវអនុវត្តតាមបែបបទបច្ចេកទេសរដ្ឋបាលដូចនៅមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និងសុរិយោដីខេត្ត-ក្រុងដែរ។

ទទួលបានសេចក្តីណែនាំនេះ គ្រប់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង ត្រូវចាត់តាំងអនុវត្តឱ្យបានល្អប្រសើរ និងមានប្រសិទ្ធភាពខ្ពស់ ដោយចាត់តាំងណែនាំផ្សព្វផ្សាយដល់គ្រប់ការិយាល័យចំណុះមន្ទីរ និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលស្រុក-ខណ្ឌ ព្រមទាំងមន្ត្រីអ្នកឯកទេសចំណុះមន្ទីរនូវស្មារតីខាងលើ។

ភ្នំពេញ ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០០

**ទេសរដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**អ៊ឹម ឈុនលឹម**

<u>ចម្លងជូន</u>

-គ្រប់អភិបាលខេត្ត-ក្រុង

"ដើម្បីជូនជ្រាប"

-គ្រប់អង្គភាពចំណុះក្រសួង ដ.ន.ស "ដើម្បីមុខការ"

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ៨០៣សជណ** ភ្នំពេញ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០០

**សូមជម្រាបជូន**

**-ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**-ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

កម្មវត្ថុ៖ ការកំណត់ថ្លៃឈ្នួលដីសម្បទាន។

យោង៖ -លិខិតរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាលេខ១៣៦១/០០/កអក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០០

-ចំណារសម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០០។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីមានកិត្តិយសសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា ដើម្បីជំរុញ និងទាក់ទាញវិនិយោគលើវិស័យកសិកម្មដែលជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ រាជរដ្ឋាភិបាលបានកំណត់យកថ្លៃឈ្នួលដីសម្បទានដូចខាងក្រោម៖

**ក-ការកំណត់ថ្លៃឈ្នួលដីសម្បទាន**

ការកំណត់ថ្លៃឈ្នួលដីសម្បទានត្រូវគិតទៅតាមប្រភេទដី តំបន់ និងភូមិសាស្ត្រទីតាំងជាក់ស្តែងពោលគឺ៖

-ដីប្រភេទលេខ៤ (ដីរេចរិល ដីខ្សោះជីជាតិ)៖ ថ្លៃឈ្នួល០ (សូន្យ) ដុល្លារអាមេរិក ក្នុង១ហិកតា ក្នុងមួយឆ្នាំ

-ដីប្រភេទលេខ៣៖ ថ្លៃឈ្នួល៤-២ដុល្លារអាមេរិក ក្នុង១ហិកតា ក្នុង១ឆ្នាំ

-ដីប្រភេទលេខ២៖ ថ្លៃឈ្នួល៦-៣ដុល្លារអាមេរិក ក្នុង១ហិកតា ក្នុង១ឆ្នាំ

-ដីប្រភេទលេខ១៖ ថ្លៃឈ្នួល១០-៥ដុល្លារអាមេរិក ក្នុង១ហិកតា ក្នុង១ឆ្នាំ

**ខ.ការកំណត់ពេលវេលាដែលត្រូវចាប់ផ្ដើមយកថ្លៃឈ្នួលដីសម្បទាន ត្រូវផ្អែកលើប្រភេទដំណាំ**

-ដំណាំរដូវ និងដំណាំប្រចាំឆ្នាំ៖ ការយកថ្លៃឈ្នួលដីត្រូវចាប់ផ្ដើមនៅឆ្នាំទី២នៃឆ្នាំទទួលផល

-ដំណាំយូរឆ្នាំ និងដំណាំអចិន្ត្រៃយ៍៖ ការយកថ្លៃឈ្នួលដីត្រូវចាប់ផ្ដើមនៅឆ្នាំទី៣ ឬឆ្នាំទី៤នៃឆ្នាំទទួលផល។

**គ.សមត្ថកិច្ចដែលត្រូវចុះទៅកំណត់ និងប្រមូលថ្លៃឈ្នួលដីសម្បទាន**

មន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអ្នកចុះទៅធ្វើការវាយតម្លៃ និងកំណត់ថ្លៃឈ្នួលដី។ ចំពោះប្រាក់ឈ្នួលដី ក្រុមហ៊ុនត្រូវបង់ចូលក្នុងគណនីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅ៖

-រតនាគារជាតិ សម្រាប់រូបិយវត្ថុជាតិ

-ធនាគារជាតិ សម្រាប់រូបិយប័ណ្ណបរទេស។

អាស្រ័យហេតុនេះ សូមឯកឧត្តមមេត្តាជ្រាប និងសហការចាត់ចែងអនុវត្តតាមខ្លឹមសារណែនាំខាងលើនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការ គណៈរដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ស៊ុំ ម៉ានិត**

<u>ចម្លងជូន</u>

-ក្រសួងមហាផ្ទៃ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី

-គ្រប់សាលាខេត្ត-ក្រុង

- កាលប្បវត្តិ-ឯកសារ

*វាយឡើងវិញ*

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**លេខ០០៣ជនស/សជ/ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០០**

## សារាចរណែនាំ

## អនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី

## (ការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ)

អនុលោមតាមអនុក្រឹត្យលេខ១១អនក្រ/បក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០០ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមធ្វើការណែនាំដូចតទៅ៖

**ដំណាក់កាលទី១ អំពីការរៀបចំ**

១-បន្ទាប់ពីបានពិភាក្សាឯកភាពជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អំពីការជ្រើសរើសទីតាំងរួចមក អភិបាលខេត្ត-ក្រុងត្រូវចេញសេចក្តីប្រកាសកំណត់តំបន់ និងព្រំប្រទល់នៃទីតាំងធ្វើការវិនិច្ឆ័យ តាមរបៀបបង្ហាញលើផែនទី ឬតាមរបៀបពិពណ៌នា ឬតាមរបៀបទាំងពីរ ។

២-នៅពេលដែលតំបន់ធ្វើការវិនិច្ឆ័យត្រូវបានកំណត់ហើយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចាត់តាំងមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ និងមន្ត្រីចាំបាច់មួយចំនួនទៀត រួមមានមន្ត្រីកំណត់ព្រំដី មន្ត្រីវាស់វែង និងមន្ត្រីវិនិច្ឆ័យ ឱ្យទៅបំពេញភារកិច្ចនៅក្នុងតំបន់វិនិច្ឆ័យនោះ ។

៣-យោងតាមចំណាត់តាំងខាងលើ អភិបាលខេត្ត-ក្រុងត្រូវបង្កើតគណៈកម្មការរដ្ឋបាល សម្រាប់តំបន់ដែលត្រូវធ្វើការវិនិច្ឆ័យដែលមានសមាសភាពដូចតទៅ៖

| | |
|---|---|
| -តំណាងអភិបាលខេត្ត-ក្រុង | ប្រធាន |
| -មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ (មន្ត្រីវាស់វែង) | សមាជិក |
| -អភិបាលស្រុក-ខណ្ឌ ឬតំណាង | សមាជិក |
| -ប្រធានឃុំ សង្កាត់ ឬតំណាង | សមាជិក |
| -ប្រធានភូមិ ឬតំណាង | សមាជិក |
| -ចាស់ព្រឹទ្ធាចារ្យនៃតំបន់វិនិច្ឆ័យចំនួន២រូប | សមាជិក |

៤-គណៈកម្មការរដ្ឋបាលត្រូវរៀបចំប្រជុំណែនាំសមាជិករបស់ខ្លួន ឱ្យយល់អំពីកិច្ចដំណើរការនៃការវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធ កំណត់បែងចែកភារកិច្ចដល់សមាជិកម្នាក់ៗ រៀបចំផែនការសម្រាប់អនុវត្ត និងលើកសំណើទៅអភិបាលខេត្ត-ក្រុង អំពីកាលបរិច្ឆេទ និងទីកន្លែងដែលត្រូវបើកកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ និងព្រំប្រទល់នៃទីតាំងធ្វើការវិនិច្ឆ័យ និងការចុះបំពេញការងារវាលរបស់មន្ត្រីជំនាញ។

៥-អភិបាលខេត្ត-ក្រុងត្រូវធ្វើលិខិតផ្លូវការដែលពិពណ៌នា និងអនុញ្ញាតឱ្យអនុវត្តនីតិវិធីនៃការវិនិច្ឆ័យមានលក្ខណៈជាប្រព័ន្ធ ទៅអាជ្ញាធរមូលដ្ឋាននៃតំបន់ធ្វើការវិនិច្ឆ័យ យ៉ាងហោចណាស់ ១៥ថ្ងៃ មុនកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ និងព្រំប្រទល់នៃទីតាំងធ្វើការវិនិច្ឆ័យ។

៦-អភិបាលខេត្ត-ក្រុងត្រូវជូនដំណឹងជាសាធារណៈអំពីកាលបរិច្ឆេទ និងទីកន្លែងប្រជុំ។ សេចក្តីជូនដំណឹងត្រូវបិទផ្សាយ និងអាចផ្សព្វផ្សាយតាមឧបគ្រួសនសព្ទជូនសាធារណជនជ្រាប យ៉ាងហោចណាស់៧ថ្ងៃ មុនកិច្ចប្រជុំផ្សព្វផ្សាយនៅទីកន្លែងដែលងាយឃើញក្នុងភូមិ ឬនៅទីតាំងធ្វើការវិនិច្ឆ័យផ្ទាល់។ ការផ្សព្វផ្សាយសេចក្តីជូនដំណឹងនេះ មានគោលបំណងឱ្យកម្មសិទ្ធិករ ឬអ្នកកាន់កាប់ដី ព្រមទាំងជនដែលមានការពាក់ព័ន្ធនឹងក្បាលដីក្នុងតំបន់ធ្វើការវិនិច្ឆ័យ បានយល់ជ្រួតជ្រាបពីសារៈសំខាន់នៃកិច្ចប្រតិបត្តិការរបស់មន្ត្រីជំនាញ ដើម្បីមកចូលរួមផ្តល់ព័ត៌មាន ឯកសារ និងភស្តុតាងសំខាន់ៗទាក់ទងនឹងអត្តសញ្ញាណនៃក្បាលដី អត្តសញ្ញាណនៃម្ចាស់ដី ធ្វើឱ្យទិន្នន័យដែលប្រមូលបានមានភាពពិតប្រាកដ និងសុក្រឹត។

កិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ និងព្រំប្រទល់ទីតាំងធ្វើការវិនិច្ឆ័យ ត្រូវប្រព្រឹត្តទៅនៅក្នុងទីកន្លែងណាមួយ ក្នុងតំបន់ធ្វើការវិនិច្ឆ័យដែលមានជាអាទិ៍ ទីវត្តអារាម ទីសាធារណៈ សាលារៀន សាលាឃុំ-សង្កាត់ សាលាស្រុក-ខណ្ឌ ដោយយោងតាមស្ថានភាពជាក់ស្តែងនៃទីតាំងវិនិច្ឆ័យនីមួយៗ។ ក្នុងឱកាសប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ធ្វើការវិនិច្ឆ័យ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ឬតំណាងគណៈកម្មការរដ្ឋបាលត្រូវពន្យល់អំពីដំណើរការនៃការវិនិច្ឆ័យ ភាពចាំបាច់ និងឱកាសដែលត្រូវចូលរួមរបស់ប្រជាពលរដ្ឋជាម្ចាស់សិទ្ធិ បំភ្លឺអំពីសិទ្ធិស្របច្បាប់លើអចលនវត្ថុ និងកាតព្វកិច្ចដែលត្រូវបំពេញ ព្រមទាំងឆ្លើយនូវរាល់សំណួរ ឬចម្ងល់ ដែលបានលើកឡើងក្នុងអង្គប្រជុំ។

**ដំណាក់កាលទី២ អំពីប្រតិបត្តិការបច្ចេកទេស**

**១-ការងារវាល**

ក្រោមការដឹកនាំ និងត្រួតពិនិត្យរបស់មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ការងារវាល ត្រូវបានអនុវត្តដោយមន្ត្រីកំណត់ព្រំដី មន្ត្រីវាស់វែង និងមន្ត្រីវិនិច្ឆ័យ ដោយមានការសហការ និងការជួយជ្រោមជ្រែងពីមន្ត្រីនៅមូលដ្ឋាន (មេភូមិ មេឃុំ ឬចៅសង្កាត់)។

១.១-អំពីសិទ្ធិ និងភារកិច្ចរបស់មន្ត្រីជំនាញ ក្នុងពេលអនុវត្តការងារវាល

១.១.១-មន្ត្រីកំណត់ព្រំដី

-ត្រូវជូនដំណឹងទៅឃុំ-សង្កាត់ជ្រាបមុន៧ថ្ងៃយ៉ាងតិចអំពីកាលបរិច្ឆេទ និងទីកន្លែងដែលត្រូវចាប់ផ្តើមអនុវត្តការងារកំណត់ព្រំដី។ ទទួលបានសេចក្តីជូនដំណឹងនេះ មេឃុំ ចៅសង្កាត់ត្រូវជូនដំណឹងបន្តដល់សាមីអ្នកកាន់កាប់ដី និងជនពាក់ព័ន្ធដើម្បីមកចូលរួមចង្អុលបង្ហាញព្រំដីរបស់ខ្លួន។

-មានសិទ្ធិចូលក្នុងបរិវេណអចលនវត្ថុ (ក្នុងតំបន់វិនិច្ឆ័យ) ដើម្បីកំណត់ព្រំដី និងវាស់វែង ហើយអាចអញ្ជើញជនពាក់ព័ន្ធឱ្យផ្តល់ចម្លើយផ្ទាល់មាត់ ឯកសារ ឬបង្ហាញភស្តុតាងផ្សេងៗទាក់ទងនឹងព្រំដីដែលកំពុងធ្វើការកំណត់។

-មន្ត្រីទទួលបន្ទុកកំណត់ព្រំដី ត្រូវគោរពគោលការណ៍ដូចខាងក្រោម៖

ក-បើកម្មសិទ្ធិករ ឬម្ចាស់នៃក្បាលដីជាប់ព្រំ មានវត្តមានហើយបានព្រមព្រៀងគ្នាលើព្រំប្រទល់ នោះព្រំក្បាលដីនឹងត្រូវបានកំណត់ដោយយោងតាមការព្រមព្រៀង។

ខ-បើការព្រមព្រៀងដែលរៀបរាប់ក្នុងចំណុច (ក) ខាងលើ មិនអាចធ្វើទៅបាន ឬមានកម្មសិទ្ធិករ ឬម្ចាស់នៃក្បាលដី និងម្ចាស់នៃក្បាលដីដែលនៅជាប់ព្រំណាមួយអវត្តមាន នោះព្រំប្រទល់ត្រូវកំណត់នៅលើដីតាមឯកសារដែលមាន និងភស្តុតាងជាលក្ខណរូប ជាលាយលក្ខណ៍អក្សរ ឬចម្លើយផ្ទាល់មាត់ទាក់ទងនឹងព្រំដី។

គ-បើក្បាលដីមានព្រំជាប់នឹងដីសាធារណៈ ឬក្បាលដី ដែលប្រើប្រាស់ជាសាធារណៈ ព្រំប្រទល់ក្បាលដី ត្រូវបានកំណត់ដោយអនុលោមទៅតាមចំណុច (ក) ឬចំណុច (ខ) ខាងលើ។

ឃ-វិវាទអំពីព្រំដីដែលទទួលបាននៅពេលកំណត់ព្រំដី ហើយមិនអាចសម្រុះសម្រួលបាន ត្រូវបញ្ជូនទៅគណៈកម្មការរដ្ឋបាល ធ្វើការសម្រុះសម្រួល និងដោះស្រាយនៅពេលបិទផ្សាយជាសាធារណៈ នូវឯកសារនៃការវិនិច្ឆ័យ។

១.១.២-មន្ត្រីវាស់វែង

បន្ទាប់ពីបានកំណត់ព្រំដីរួច មន្ត្រីវាស់វែងត្រូវអនុវត្តការងារវាស់វែងដែលជាតម្រូវការក្នុងការកសាងប្លង់សុរិយោដី និងការអនុវត្តនីតិវិធីនៃការវិនិច្ឆ័យ ។

១.១.៣-មន្ត្រីវិនិច្ឆ័យ

-មានសិទ្ធិសាកសួរយកព័ត៌មានចាំបាច់សម្រាប់អនុវត្តការងារវិនិច្ឆ័យ ។ មន្ត្រីវិនិច្ឆ័យអាចអញ្ជើញជនពាក់ព័ន្ធឱ្យផ្តល់ចម្លើយដោយផ្ទាល់មាត់ ឯកសារ ឬភស្តុតាងផ្សេងៗ ដែលទាក់ទងនឹងការវិនិច្ឆ័យ ។

-ប្រមូលរាល់ឯកសារ ភស្តុតាង និងព័ត៌មានផ្សេងៗទាក់ទងនឹងសិទ្ធិលើក្បាលដីនីមួយៗក្នុងតំបន់ធ្វើការវិនិច្ឆ័យ ហើយកត់ត្រាសិទ្ធិទាំងនោះ ចូលក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី រួចឱ្យអ្នកកាន់កាប់ដី ផ្តិតមេដៃ ហើយមន្ត្រីនោះត្រូវចុះហត្ថលេខា និងឈ្មោះទទួលខុសត្រូវលើឯកសារនោះផងដែរ ។

-ករណីមានវិវាទកើតឡើង ទាក់ទងនឹងព្រំប្រទល់ក្តី ទាក់ទងនឹងសិទ្ធិលើក្បាលដីក្តី មន្ត្រីវិនិច្ឆ័យត្រូវកត់ត្រាក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីថាជាដីមានទំនាស់ ។

១.២-អំពីសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកកាន់កាប់ ឬអ្នកតំណាងស្របច្បាប់

អ្នកកាន់កាប់ដី ឬអ្នកតំណាងស្របច្បាប់របស់ជននេះមានកាតព្វកិច្ចចូលរួម និងសហការក្នុងការកំណត់ព្រំដី វាស់វែង និងវិនិច្ឆ័យតាមរយៈការផ្តល់នូវព័ត៌មានពិត ដោយផ្ទាល់មាត់ ជាលាយលក្ខណ៍អក្សរ ឬភស្តុតាងផ្សេងៗ ទាក់ទងនឹងក្បាលដីរបស់ខ្លួន ឬក្បាលដីដែលខ្លួនឈរឈ្មោះជាតំណាង ឬក្បាលដីអ្នកជាប់ព្រំ ដល់មន្ត្រីជំនាញ ។

ក្នុងរយៈពេលប្រតិបត្តិការរបស់មន្ត្រីជំនាញ អ្នកកាន់កាប់ដី ឬអ្នកតំណាងស្របច្បាប់នៃជននេះ ឬជនពាក់ព័ន្ធមានសិទ្ធិជំទាស់ ឬតវ៉ា ប្រសិនបើខ្លួនយល់ថា ទិន្នន័យដែលមន្ត្រីជំនាញបានកត់ត្រាចូលក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យមិនត្រឹមត្រូវ ឬខុសពីចម្លើយរបស់ខ្លួន ។

១.៣-អំពីភារកិច្ចរបស់អាជ្ញាធរដែនដី

ក-អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវបង្កលក្ខណសម្បត្តិងាយស្រួល សហការឱ្យបានល្អ និងផ្តល់សុវត្ថិភាពដល់កិច្ចប្រតិបត្តិការទាំងឡាយ មានប្រតិបត្តិការបច្ចេកទេស រដ្ឋបាលគតិយុត្ត

ដើម្បីធ្វើឱ្យសម្រេចនូវការអនុវត្តនីតិវិធីនៃការវិនិច្ឆ័យដែលប្រព្រឹត្តទៅ នៅក្នុងដែនដីដែលខ្លួនទទួលខុសត្រូវ ។

ខ-ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈ នូវឯកសារនៃការវិនិច្ឆ័យដែលមានប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដីក្នុងឃុំ-សង្កាត់ណាមួយ មេឃុំ ចៅសង្កាត់ ឬតំណាងស្របច្បាប់របស់ខ្លួន ត្រូវមានវត្តមានតាមកាលកំណត់ និងតាមតម្រូវការជាក់ស្តែងនៃការងារ ។

**២-ការងារនៅការិយាល័យ**

ទិន្នន័យដែលប្រមូលបានពីការងារវាលត្រូវបញ្ចូលក្នុងកុំព្យូទ័រ ដើម្បីកសាងប្លង់សុរិយោដី បញ្ជីឈ្មោះម្ចាស់ដី និងសៀវភៅគោលបញ្ជីដីធ្លី ។

**ដំណាក់កាលទី៣ អំពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ**

អភិបាលខេត្ត-ក្រុងត្រូវធ្វើសេចក្តីជូនដំណឹងស្តីពីការបិទផ្សាយជាសាធារណៈ នូវប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដី តាមសំណើរបស់គណៈកម្មការរដ្ឋបាល ។ ការជូនដំណឹងអាចធ្វើតាមគ្រប់មធ្យោបាយ ដូចជាតាមរយៈការប្រជុំ វិទ្យុ ទូរទស្សន៍ សារព័ត៌មាន រូបភាពបិទផ្សាយ ឬតាមឧគ្ឃោសនសព្ទ . . . ។ល ។

ការបិទផ្សាយជាសាធារណៈមានរយៈពេល៣០ថ្ងៃ ហើយត្រូវធ្វើនៅកន្លែងដែលងាយមើលឃើញក្នុងទីតាំងនៃតំបន់ធ្វើការវិនិច្ឆ័យ ដូចជាទីវត្តអារាម ទីសាធារណៈ សាលារៀន សាលាឃុំសង្កាត់ សាលាស្រុក . . . ។

ក្នុងអំឡុងពេលនៃការបិទផ្សាយ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យត្រូវណែនាំមន្ត្រីដែលទទួលខុសត្រូវការងារជំនាញនីមួយៗ ឱ្យប្រចាំការនៅកន្លែងបិទផ្សាយរៀងរាល់ថ្ងៃ ទាំងថ្ងៃឈប់សម្រាក ទាំងថ្ងៃបុណ្យផ្សេង ៗ ដើម្បីរង់ចាំពន្យល់ ឬបំភ្លឺ អំពីខ្លឹមសារនៃទិន្នន័យបកស្រាយ ចម្ងល់ផ្សេងៗដែលទាក់ទងទៅនឹងឯកសារដែលបានបិទផ្សាយ ។ ទន្ទឹមនឹងនេះ គណៈកម្មការរដ្ឋបាលក៏ត្រូវចាត់តាំងមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ និងមន្ត្រីនៅមូលដ្ឋានចាំបាច់ ជាអាទិ៍ មេឃុំ ចៅសង្កាត់ ឬតំណាងផ្លូវច្បាប់របស់ជននេះ ឱ្យមកប្រចាំការរង់ចាំទទួលបណ្តឹងជំទាស់ ឬបណ្តឹងតវ៉ា ធ្វើការស្រាវជ្រាវ និងដោះស្រាយបញ្ហាតាមគោលការណ៍កំណត់ ។

សាមីអ្នកកាន់កាប់ដី ឬតំណាងស្របច្បាប់របស់ជននេះ ដែលមិនទាន់យល់ស្របតាមការសម្រេចបណ្តោះអាសន្នរបស់មន្ត្រីជំនាញនៅពេលប្រតិបត្តិការកំណត់ព្រំដី ឬវិនិច្ឆ័យមានសិទ្ធិប្តឹងជំទាស់ ឬប្តឹងតវ៉ាទៅគណៈកម្មការរដ្ឋបាលនៅពេលបិទផ្សាយជាសាធារណៈ នូវឯកសារនៃការវិនិច្ឆ័យ ដើម្បីឱ្យគណៈកម្មការនេះលើកយកមកដោះស្រាយឡើងវិញ។ ករណីមិនអាចដោះស្រាយបាន គណៈកម្មការរដ្ឋបាលត្រូវបញ្ជូនសំណុំរឿងវិវាទនោះទៅគណៈកម្មការសុរិយោដី ធ្វើការដោះស្រាយបន្ត។ បណ្តឹងនីមួយៗ ត្រូវបានកត់ត្រាដាច់ដោយឡែកពីគ្នា ហើយត្រូវមានបញ្ជាក់ច្បាស់លាស់អំពីកម្មវត្ថុនៃបណ្តឹង ឈ្មោះ និងស្នាមមេដៃម្ចាស់បណ្តឹង ឈ្មោះ និងហត្ថលេខាមន្ត្រីទទួលកត់ត្រា និងមានការបញ្ជាក់ដឹងឮពីមេឃុំ ចៅសង្កាត់ ឬតំណាងស្របតាមច្បាប់របស់ជននេះ។

ករណីមិនមានការជំទាស់ ឬតវ៉ា ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈ ទិន្នន័យដែលបានកត់ត្រាក្នុងឯកសារបិទផ្សាយនោះ ត្រូវបានចាត់ទុកជាទិន្នន័យសុក្រឹត ដែលអាចកំណត់យកជាផ្លូវការតាមច្បាប់បាន លើកលែងចំពោះតែករណីដែលសាមីអ្នកកាន់កាប់ដី ឬអចលនវត្ថុមានឯកសារសំអាងច្បាស់លាស់ ហើយបានបង្ហាញអំពីមូលហេតុដែលមិនបានមកធ្វើការជំទាស់ ឬតវ៉ាក្នុងរយៈពេលបិទផ្សាយនោះ សាមីជនអាចដាក់ពាក្យបណ្តឹងទៅគណៈកម្មការសុរិយោដី ដើម្បីដោះស្រាយតាមនីតិវិធីដែលបានកំណត់។

មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ មានសិទ្ធិកែតម្រូវចំពោះតែការខុសឆ្គង ឬការភ្លេចភ្លាំងណាដែលមិនជះឥទ្ធិពលដល់ផលប្រយោជន៍អ្នកដទៃ។ ចំពោះការកែតម្រូវណាដែលនាំឱ្យជះឥទ្ធិពលដល់ផលប្រយោជន៍អ្នកដទៃអាចធ្វើការកែតម្រូវបាន លុះត្រាតែមានការយល់ព្រមពីជនដែលមានផលប្រយោជន៍ពាក់ព័ន្ធនោះ។

**ដំណាក់កាលទី៤ អំពីការសម្រេចលើឯកសារ**

១-ក្រោយពីផុតរយៈពេលនៃការបិទផ្សាយជាសាធារណៈ នូវឯកសារនៃការវិនិច្ឆ័យ គណៈកម្មការរដ្ឋបាល ត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការវិនិច្ឆ័យតាមខ្លឹមសារខាងក្រោម៖

ក-លទ្ធផលដែលសម្រេចបាន

-ចំនួនក្បាលដីសរុបដែលបានធ្វើការវិនិច្ឆ័យ

-ចំនួនក្បាលដីដែលមិនត្រូវបានចេញប័ណ្ណជូន ដោយការកាន់កាប់ដីរដ្ឋចាប់ផ្ដើមក្រោយច្បាប់ភូមិបាលចូលជាធរមាន

-ចំនួនក្បាលដីដែលមានលក្ខណៈត្រឹមត្រូវ និងគ្មានវិវាទ

-ចំនួនក្បាលដីដែលមានវិវាទ

-ចំនួនក្បាលដីមានវិវាទដែលគណៈកម្មការរដ្ឋបាល បានដោះស្រាយរួចតាមការព្រមព្រៀង

-ចំនួនក្បាលដីដែលមានវិវាទ ហើយបានបញ្ជូនទៅគណៈកម្មការសុរិយោដី

-ចំនួនក្បាលដីដែលកំពុងមានបណ្ដឹងទៅតុលាការ

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រត្រូវរៀបចំនូវគំរូរបាយការណ៍ស្ដីពីលទ្ធផលនៃការវិនិច្ឆ័យ ។

ខ-ធ្វើការវាយតម្លៃ លើកសំណើផ្ដល់សិទ្ធិលើដី ឬអចលនវត្ថុ តាមប្រភេទកម្មសិទ្ធិ ភោគៈសម្បទាន ឬរក្សាទុកជាដីរដ្ឋជូនកម្មសិទ្ធិករ ភោគី ឬអ្នកកាន់កាប់ ដោយយោងទៅតាមច្បាប់បទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត និងឯកសារ ឬភស្ដុតាងដែលប្រមូលបាន ។

២-ក្រោយពីប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដី ត្រូវបានកែតម្រូវរួចហើយ

-មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ត្រូវចុះហត្ថលេខាលើប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដី

-ប្រធានគណៈកម្មការរដ្ឋបាល ត្រូវចុះហត្ថលេខាលើប្លង់សុរិយោដី បញ្ជីឈ្មោះម្ចាស់ដី និងរបាយការណ៍ស្ដីពីលទ្ធផលនៃការវិនិច្ឆ័យ ។

-ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង ត្រូវចុះហត្ថលេខាបំពេញលើប្លង់សុរិយោដី បញ្ជីឈ្មោះម្ចាស់ដី និងរបាយការណ៍ស្ដីពីលទ្ធផលនៃការវិនិច្ឆ័យត្រង់ចំណុចហត្ថលេខាអភិបាលខេត្ត-ក្រុង ។

-អភិបាលខេត្ត-ក្រុងត្រូវចុះហត្ថលេខាលើប្លង់សុរិយោដី បញ្ជីឈ្មោះម្ចាស់ដី និងរបាយការណ៍ស្ដីពីលទ្ធផលនៃការវិនិច្ឆ័យ ។ ករណីមិនឯកភាព ត្រូវបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់ ។

-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះហត្ថលេខាសម្រេចជាផ្លូវការលើប្លង់សុរិយោដី បញ្ជីឈ្មោះម្ចាស់ដី និងរបាយការណ៍ស្ដីពីលទ្ធផលនៃការវិនិច្ឆ័យ ។ ក្រោយពីអភិបាលខេត្ត-ក្រុង និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះហត្ថលេខាសម្រេច

យល់ព្រមរួចហើយ ឯកសារនៃការវិនិច្ឆ័យត្រូវបានបញ្ចប់ជាស្ថាពរ និងត្រូវបានចាត់ទុកជាឯកសារផ្លូវការតាមច្បាប់ ចំពោះក្បាលដីណាដែលមិនទាក់ទងនិងវិវាទ។

ចំពោះក្បាលដីដែលមានវិវាទ ហើយមិនទាន់ដោះស្រាយចប់ជាស្ថាពរអាចត្រូវបានបន្តការដោះស្រាយនៅគណៈកម្មការសុរិយោដី ឬនៅតុលាការ។

**ដំណាក់កាលទី៥ អំពីការចេញប័ណ្ណ**

នៅពេលដែលនីតិវិធីនៃការវិនិច្ឆ័យត្រូវបានបញ្ចប់ជាស្ថាពរ ឯកសារនៃការវិនិច្ឆ័យ និងឯកសាររណបពាក់ព័ន្ធទាំងអស់ ត្រូវបានបញ្ជូលទៅរដ្ឋបាលសុរិយោដី ដើម្បីចុះបញ្ជី ចេញប័ណ្ណ និងគ្រប់គ្រង៖

-ថ្នាក់កណ្តាល ( អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ) ចំពោះឯកសារទាក់ទងនឹងខេត្ត-ក្រុងណាដែលមិនទាន់ទទួលបានប្រតិភូកម្ម

-ថ្នាក់ខេត្ត-ក្រុង (មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី) ចំពោះឯកសារដែលទាក់ទងនឹងខេត្ត-ក្រុងណាដែលបានទទួលប្រតិភូកម្មរួចហើយ។

គោលការណ៏នៃការចេញប័ណ្ណ៖

១-ចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ (ប័ណ្ណកម្មសិទ្ធិ) ចំពោះក្បាលដី ឬអចលនវត្ថុណាដែលបានកាន់កាប់ដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី៥ឆ្នាំយ៉ាងតិច គិតមកដល់កាលបរិច្ឆេទនៃការប្រកាសឱ្យប្រើច្បាប់ភូមិបាល (មាត្រា៣០វាក្យខណ្ឌទី១ នៃច្បាប់ភូមិបាល)។

២-ចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ (ប័ណ្ណភោគៈ) ចំពោះក្បាលដី ឬអចលនវត្ថុណាដែលកាន់កាប់ដោយសន្តិវិធី និងមិនមានការជំទាស់ ហើយមានរយៈពេលតិចជាង៥ឆ្នាំ មុនច្បាប់ភូមិបាលចូលជាធរមាន។ ប័ណ្ណប្រភេទនេះ អាចប្តូរយកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុនៅពេលដែលរយៈពេលនៃការកាន់កាប់ដី ឬអចលនវត្ថុនោះបានគ្រប់៥ឆ្នាំ ឬលើស។

៣-អាចចេញប័ណ្ណជូនបានចំពោះតែក្បាលដី ឬអចលនវត្ថុណាដែលគ្មានពាក់ព័ន្ធនឹងវិវាទ។

៤-ការប្រគល់ប័ណ្ណត្រូវមានសៀវភៅសម្រាប់កត់ឈ្មោះ និងចុះហត្ថលេខាមន្ត្រីអ្នកប្រគល់ និងកត់ឈ្មោះ រួចផ្តិតមេដៃអ្នកទទួលទុកជាភស្តុតាង។ ការប្រគល់ប័ណ្ណត្រូវប្រព្រឹត្តទៅនៅអង្គភាព

ស៊ុរិយោដីដែលមានសមត្ថកិច្ច។ មន្ត្រីសុរិយោដីមិនត្រូវបានអនុញ្ញាតឱ្យប្រគល់ប័ណ្ណ ជូនបុគ្គលក្រៅពីម្ចាស់សិទ្ធិពិតប្រាកដឡើយ លើកលែង៖

-ករណីម្ចាស់សិទ្ធិទទួលមរណៈភាព ឬអវត្តមាន ឬត្រូវបាត់ខ្លួន ឬបាត់បង់សមត្ថភាព ដែលច្បាប់ទទួលស្គាល់ ពេលនោះអ្នកតំណាងស្របច្បាប់មានសិទ្ធិទទួលជំនួស

-ករណីពិសេស និងចាំបាច់ ម្ចាស់សិទ្ធិអាចដាក់ពាក្យសុំប័ណ្ណបាន តែត្រូវបញ្ជាក់ច្បាស់ពីហេតុដែលមិនអាចមកទទួលប័ណ្ណនៅការិយាល័យ ទើបអនុញ្ញាតឱ្យប្រគល់ប័ណ្ណនៅគេហដ្ឋានរបស់កម្មសិទ្ធិករ ឬភោគី ដោយមន្ត្រីសុរិយោដីយ៉ាងតិច២នាក់។

៥-នៅពេលទទួលប័ណ្ណថ្មី ម្ចាស់ដី ឬអចលនវត្ថុ ត្រូវប្រគល់ប័ណ្ណចាស់ទាក់ទងនឹងសិទ្ធិលើដី ឬអចលនវត្ថុនោះ ជូនមន្ត្រីសុរិយោដី ប្រសិនបើមាន។

៦-ចំពោះនីតិបុគ្គល ប័ណ្ណត្រូវចុះឈ្មោះអង្គភាព (នីតិបុគ្គលសាធារណៈ មានជាអាទិ៍ សាលារៀន សាលាឃុំ . . . នីតិបុគ្គលឯកជន មានជាអាទិ៍ សមាគម ក្រុមហ៊ុន) មិនត្រូវចុះឈ្មោះរូបវន្តបុគ្គលជាដាច់ខាត។ ចំពោះដី ឬអចលនវត្ថុរបស់សមូហភាព ដូចជាវត្ត ឬសហគមន៍ជនជាតិដើមភាគតិច នៅក្នុងប័ណ្ណក៏ត្រូវចុះឈ្មោះវត្ត ឬសហគមន៍ . . . ដែរ គឺមិនត្រូវចុះឈ្មោះរូបវន្តបុគ្គលជាតំណាងឡើយ។ ទាក់ទងដល់ការប្រើសិទ្ធិ និងការបំពេញកាតព្វកិច្ចផ្សេងៗ ក្នុងការអនុវត្តនីតិវិធីនៃការវិនិច្ឆ័យ នីតិបុគ្គលនានា ក៏ដូចជាសមូហភាពទាំងអស់នោះ ត្រូវជ្រើសរើសតំណាងស្របច្បាប់រៀងខ្លួនតាមវិធីផ្សេងៗ គ្នាដូចជានីតិបុគ្គលសាធារណៈ មានលិខិតតែងតាំង នីតិបុគ្គលឯកជនមានការជ្រើសតាំងបណ្ណាធិការក្រុមហ៊ុន ឬប្រធានសមាគម វត្ត មានប្រធានគណៈកម្មការវត្ត សហគមន៍ជនជាតិដើមភាគតិច មានប្រធានសហគមន៍ . . .។ល។ តំណាងស្របច្បាប់ទាំងនេះមានសិទ្ធិ និងកាតព្វកិច្ចទាក់ទងនឹងអចលនវត្ថុ ដូចម្ចាស់សិទ្ធិ ជារូបវន្តបុគ្គលដែរ។ ឯប័ណ្ណដី ឬអចលនវត្ថុរបស់នីតិបុគ្គលសាធារណៈ និងឯកជន ត្រូវប្រគល់ឱ្យតំណាងស្របច្បាប់នៃនីតិបុគ្គលនីមួយៗ ជាអ្នកទទួលយក និងរក្សាទុក។ ចំពោះប័ណ្ណដី ឬអចលនវត្ថុរបស់សមូហភាព ត្រូវប្រគល់ជូនតំណាងស្របច្បាប់ ឬប្រធានសហគមន៍ទទួលយក និងរក្សាទុក។

សារាចរនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ៨៨អនក្រ/បក

**អនុក្រឹត្យ**

**ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១០០/២១៣ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០០ ស្តីពីការបញ្ចូលសមាសភាពឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- តាមសំណើរបស់ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ

**សម្រេច**

**ជំពូកទី១ បទប្បញ្ញត្តិទូទៅ**

មាត្រា១

ត្រូវបានបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី សម្រាប់ជំនួយការក្នុងប្រតិបត្តិការសកម្មភាពរបស់ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋក្នុងវិស័យដីធ្លី។ ក្រុមប្រឹក្សាគោលនយោបាយដីធ្លីមានទីតាំងឋិតនៅទីស្តីការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ជំពូកទី២ បេសកកម្ម និងសមាសភាព**

**មាត្រា២**

ក្រុមប្រឹក្សាគោលនយោបាយដីធ្លីមានបេសកកម្មផ្តួចផ្តើមជំរុញដាក់ឱ្យដំណើរការ និងតាមដានការអនុវត្តគោលនយោបាយ និងកម្មវិធីការងារដីធ្លី ស្របតាមការតម្រង់ទិសរបស់ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ។

**មាត្រា៣**

ក្រុមប្រឹក្សាគោលនយោបាយដីធ្លីមានមុខងារ និងភារកិច្ចដូចតទៅ៖

១-ផ្តួចផ្តើម និងលើកសំណើជូនឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ នូវគម្រោងផែនការកម្មវិធីការងារ និងយុទ្ធសាស្ត្រសម្រាប់ធ្វើឱ្យសម្រេចគោលដៅទាំងឡាយនៃការរៀបចំការគ្រប់គ្រង និងការបែងចែកដីធ្លី។

២-អនុវត្តសេចក្តីណែនាំដែលទទួលបានពីឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ក្នុងការដាក់ឱ្យដំណើរការយុទ្ធសាស្ត្រ និងកម្មវិធីការងារដីធ្លី។

៣-ចេញសេចក្តីសម្រេច និងសេចក្តីណែនាំដល់ក្រសួង ស្ថាប័ន ខេត្ត-ក្រុងក្នុងការដាក់ឱ្យដំណើរការកម្មវិធីការងារក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន។

៤-សម្របសម្រួលសកម្មភាពនានារបស់ក្រសួង ស្ថាប័នទាំងឡាយដែលទាក់ទងទៅនឹងកម្មវិធីការងារដីធ្លី។

៥-លើកសំណើគោលនយោបាយដីធ្លី ជូនឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ដើម្បីសុំការសម្រេច។

៦-លើកសំណើជូនឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ នូវគម្រោងច្បាប់ លិខិតបទដ្ឋាន និងវិធានការទាំងឡាយដែលទាក់ទងនឹងកិច្ចដំណើរការការងារដីធ្លី។

៧-សម្របសម្រួលមធ្យោបាយរបស់រដ្ឋ និងជំនួយអន្តរជាតិសម្រាប់ប្រើប្រាស់ក្នុងការងារដីធ្លី។

៨-ដឹកនាំ និងគ្រប់គ្រងការងារបណ្តុះបណ្តាល និងផ្សព្វផ្សាយដល់ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋទូទៅ ជាពិសេសអំពីការងារដីធ្លី។

៩-ធ្វើរបាយការណ៍ជាប្រចាំជូនឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋអំពីលទ្ធផលនៃការងារដីធ្លី។

**មាត្រា៤**

ក្រុមប្រឹក្សាកំណែទម្រង់ដីធ្លី មានសមាសភាពដូចតទៅ៖[2]

-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធាន

-រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុប្រធាន

-រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ អនុប្រធាន

-រដ្ឋលេខាធិការនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាសមាជិកអចិន្ត្រៃយ៍ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី

-រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ ជាសមាជិក

-រដ្ឋលេខាធិការនៃក្រសួងការពារជាតិ ជាសមាជិក

-រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក

-រដ្ឋលេខាធិការនៃក្រសួងបរិស្ថាន ជាសមាជិក

-រដ្ឋលេខាធិការនៃក្រសួងធនធានទឹក និងឧតុនិយម ជាសមាជិក

-រដ្ឋលេខាធិការនៃក្រសួងព័ត៌មាន ជាសមាជិក

-រដ្ឋលេខាធិការនៃក្រសួងទេសចរណ៍ ជាសមាជិក

-រដ្ឋលេខាធិការនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាសមាជិក

-រដ្ឋលេខាធិការនៃក្រសួងសាធារណការ និងដឹកជញ្ជូន ជាសមាជិក

-រដ្ឋលេខាធិការនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជាសមាជិក

-រដ្ឋលេខាធិការនៃក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ជាសមាជិក

-រដ្ឋលេខាធិការនៃក្រសួងផែនការ ជាសមាជិក

-អនុរដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

-អគ្គលេខាធិការនៃគណៈកម្មការវិនិយោគកម្ពុជា ជាសមាជិក

**មាត្រា៥**

ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានភារកិច្ចដូចតទៅ៖

-ទទួលខុសត្រូវ បំពេញមុខការទាំងឡាយរបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដូចមានចែងក្នុងមាត្រាខាងលើ និងយកចិត្តទុកដាក់ធ្វើឱ្យដំណើរការការងារដីធ្លីប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព

---

[2] សមាសភាពនេះត្រូវបានកែសម្រួលដោយអនុក្រឹត្យលេខ៦៨អនក្រ/បក/១៨ តុលា ២០០៤ និងកែសម្រួលចុងក្រោយដោយអនុក្រឹត្យលេខ៣៩អនក្រ/បក/០៦ កុម្ភៈ ២០០៩។ សូមមើលទំព័រ 654 និង 966។

-អញ្ជើញសមាជិកចូលរួមប្រជុំ កំណត់របៀបវារៈនៃការប្រជុំនានារបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី

-ដឹកនាំការពិភាក្សា និងចេញសេចក្ដីសម្រេចនានា

-អាចអញ្ជើញសមាជិករាជរដ្ឋាភិបាល ឬឥស្សរជនដែលមានសមត្ថភាពជំនាញមកចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី

-មានសិទ្ធិចុះហត្ថលេខាទ្វេភាគី និងពហុភាគីគ្រប់កិច្ចព្រមព្រៀងផ្ដល់ហិរញ្ញប្បទាន និងគ្រប់កិច្ចសន្យា ឬអត្ថបទគតិយុត្តដែលទាក់ទងទៅនឹងការងារដីធ្លី

-មានសិទ្ធិអំណាចគ្រប់គ្រាន់ក្នុងការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។

**មាត្រា៦**

ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានសិទ្ធិលើកសំណើតែងតាំងតាមករណីចាំបាច់ អ្នកជំនាញការជាតិ និងអន្តរជាតិ ហើយនិងឥស្សរជន ឬមន្ត្រីរាជការជាន់ខ្ពស់ដែលមានជំនាញក្នុងវិស័យនីតិកម្ម រដ្ឋបាលបច្ចេកទេសជាទីប្រឹក្សាបច្ចេកទេស ដើម្បីសិក្សាវិភាគធ្វើទស្សនទាន ឬផែនការកម្មលើការងារដីធ្លី និងលើកសំណើជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លីនូវគម្រោងការងារដីធ្លីដែលត្រូវដាក់ឱ្យអនុវត្ត ។

**ជំពូកទី៣ អគ្គលេខាធិការដ្ឋាន**

**មាត្រា៧**

ក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានអគ្គលេខាធិការដ្ឋានមួយជាអង្គភាពប្រតិបត្តិដែលត្រូវបានដឹកនាំ និងគ្រប់គ្រងដោយអគ្គលេខាធិការមួយរូប ។

អគ្គលេខាធិការមានអគ្គលេខាធិការរង និងទីប្រឹក្សាជាជំនួយការ ។ អគ្គលេខាធិការរង និងទីប្រឹក្សាត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់អគ្គលេខាធិការ ដោយមានមតិយល់ព្រមពីប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។

**មាត្រា៨**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លីត្រូវកំណត់ដោយអនុក្រឹត្យមួយដោយឡែក ។

មាត្រា៩

ក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដើម្បីបំពេញការងាររបស់ខ្លួន។

**ជំពូកទី៤ ប្រភពធនធាន**

មាត្រា១០

ក្រុមប្រឹក្សាគោលនយោបាយដីធ្លីមានខ្ទង់ថវិកាដោយឡែក ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មាត្រា១១

ធនធាន និងថវិការបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ត្រូវបានផ្គត់ផ្គង់ដោយៈ

-វិភាគទាននៃថវិកាជាតិ

-ហិរញ្ញប្បទានបានមកពីប្រទេស ឬអង្គការផ្តល់ជំនួយអន្តរជាតិ។

មាត្រា១២

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា១៣

ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ស្ថាប័ន និងសមាជិកទាំងអស់នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ត្រូវទទួលបន្ទុករៀងៗខ្លួនអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

**បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី**

**ជ.ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ**

**សមាជិកអចិន្ត្រៃយ៍**

**ហត្ថលេខា**

**សុខ អាន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ៩៦អនក្រ/បក

## អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ
## របស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១០០/២១៣ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០០ ស្តីពីការបញ្ចូលសមាសភាពឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ៨៨អនក្រ/បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី

### សម្រេច

### ជំពូកទី១ បទប្បញ្ញត្តិទូទៅ

មាត្រា១

អនុក្រឹត្យនេះកំណត់បេសកកម្ម មុខងារ ភារកិច្ច និងការរៀបចំអង្គភាពនានារបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។

## ជំពូកទី២ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា២**

ក្រុមប្រឹក្សាគោលនយោបាយដីធ្លីមានអគ្គលេខាធិការដ្ឋានមួយ ជាអង្គភាពប្រតិបត្តិដែលត្រូវដឹកនាំ និងគ្រប់គ្រងដោយអគ្គលេខាធិការមួយរូប ។

**មាត្រា៣**

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានបេសកកម្មដាក់ឱ្យដំណើរការកម្មវិធីការងារដីធ្លី តាមការណែនាំ និងការចង្អុលទិសរបស់ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។ ក្នុងបេសកកម្មនេះ អគ្គលេខាធិការដ្ឋានមានភារកិច្ចជាអាទិ៍៖

១-រៀបចំគោលនយោបាយដីធ្លីទូលំទូលាយ ។

២-ធ្វើវិភាគនយោបាយ និងទំនាក់ទំនងពិគ្រោះយោបល់ដើម្បីរកការឯកភាព និងការគាំទ្រពីគ្រប់មជ្ឈដ្ឋានប្រជាពលរដ្ឋលើគោលនយោបាយដីធ្លី ។

៣-លើកសំណើគោលនយោបាយដីធ្លី ទស្សនទាន ផែនការកម្ម ជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លីដើម្បីពិនិត្យ និងសម្រេច ។

៤-លើកគម្រោងការងារដីធ្លីគ្រប់ផ្នែក ជាពិសេសផ្នែកគ្រប់គ្រងដីធ្លី រៀបចំដែនដី និងបែងចែកដីធ្លី ដាក់ឱ្យដំណើរការអនុវត្ត ធ្វើការសម្របសម្រួល និងវាយតម្លៃការងារ ។

៥-យកចិត្តទុកដាក់លើការអនុវត្តគោលនយោបាយប្រើប្រាស់ដីឱ្យបានសមស្រប និងមានសមធម៌ ។

៦-ជំរុញការចុះបញ្ជីដីធ្លីជាប្រព័ន្ធទូទាំងប្រទេស ។

៧-ជំរុញការគ្រប់គ្រងផ្នែករដ្ឋបាលសុរិយោដី លើអចលនវត្ថុជាទ្រព្យសម្បត្តិរបស់រដ្ឋឱ្យមានប្រសិទ្ធភាព ។

៨-សិក្សា រៀបចំគោលនយោបាយពន្ធដារលើដីធ្លី ដើម្បីជំរុញឱ្យមានការអភិវឌ្ឍ និងសណ្តាប់ធ្នាប់ ។

៩-ធ្វើការទំនាក់ទំនងដើម្បីជំរុញឱ្យមានទំនើបកម្មឧបករណ៍ និងធនធានមនុស្ស ប្រកបដោយឯកទេសគ្រប់គ្រាន់ដើម្បីបំពេញការងារ ។

១០-ជំរុញការកសាងច្បាប់ បទប្បញ្ញត្តិ បទបញ្ជា បទដ្ឋានឱ្យបានគ្រប់គ្រាន់ ដើម្បីដំណើរការការងារដីធ្លី ។

១១-លើកវិធានការជាយុទ្ធសាស្ត្រ ដើម្បីទប់ស្កាត់ និងកាត់បន្ថយទំនាស់ដីធ្លី ។

១២-លើកផែនការបណ្តុះបណ្តាល និងផ្សព្វផ្សាយដល់ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋទូទៅ ជាពិសេសអំពីការងារដីធ្លី ។

១៣-ជំរុញតាមដាន វាយតម្លៃលើគម្រោងការងារដែលបានអនុវត្ត ព្រមទាំងធ្វើរបាយការណ៍ទៀងទាត់ ជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លីអំពីលទ្ធផលការងារ ។

**មាត្រា៤**

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ត្រូវធ្វើការប្រជុំការងារយ៉ាងតិចមួយដងក្នុងមួយខែ តាមការអញ្ជើញ និងការណែនាំរបស់អគ្គលេខាធិការ ។

**មាត្រា៥**

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដើម្បីបំពេញការងាររបស់ខ្លួន ។

**មាត្រា៦**

អគ្គលេខាធិការមានសិទ្ធិលើកសំណើជូនប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដើម្បីពិនិត្យ និងសម្រេចលើសេចក្តីសម្រេចប្រកាសតែងតាំង ឬដកចេញពីតំណែងនូវមន្ត្រីបុគ្គលិករបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។

**មាត្រា៧**

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានរចនាសម្ព័ន្ធដូចតទៅ៖

១-ក្រុមការងារនយោបាយ និងគតិយុត្ត

២-ក្រុមការងារបច្ចេកទេស

៣-ក្រុមការងារពង្រឹងស្ថាប័ន

៤-ក្រុមការងាររដ្ឋបាល

ក្រុមការងារនីមួយៗត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការតាមការចាំបាច់។

**មាត្រា៨**

ការបែងចែកលំអិតនៃភារកិច្ចរបស់បុគ្គលិក និងមន្ត្រីរាជការដែលបម្រើការងារ នៅក្នុងអគ្គលេខាធិការដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី។

**មាត្រា៩**

ក្រុមការងារនយោបាយ និងគតិយុត្តមានភារកិច្ច៖

-រៀបចំគោលនយោបាយដីធ្លីទូលំទូលាយ

-ធ្វើវិភាគនយោបាយ និងទំនាក់ទំនងពិគ្រោះយោបល់ដើម្បីរកការឯកភាព និងការគាំទ្រពីគ្រប់មជ្ឈដ្ឋានប្រជាពលរដ្ឋ ដែលពាក់ព័ន្ធនឹងបញ្ហាដីធ្លីលើគោលនយោបាយដីធ្លី

-លើកសំណើគោលនយោបាយកំណែទម្រង់ដីធ្លី ទស្សនទាន ផែនការកម្ម ជូនក្រុមប្រឹក្សាកំណែទម្រង់ដីធ្លីដើម្បីពិនិត្យ និងសម្រេច

-យកចិត្តទុកដាក់លើការអនុវត្តគោលនយោបាយប្រើប្រាស់ដីធ្លីឱ្យបានសមស្រប និងមានសមធម៌

-សិក្សា រៀបចំគោលនយោបាយពន្ធដារលើដីធ្លី ដើម្បីជំរុញឱ្យមានការអភិវឌ្ឍ និងសណ្តាប់ធ្នាប់

-ជំរុញការកសាងច្បាប់ បទប្បញ្ញត្តិ បទបញ្ជា បទដ្ឋានឱ្យបានគ្រប់គ្រាន់ដើម្បីដំណើរការការងារដីធ្លី

-លើកវិធានការជាយុទ្ធសាស្ត្រ ដើម្បីទប់ស្កាត់ និងកាត់បន្ថយទំនាស់ដីធ្លី។

**មាត្រា១០**

ក្រុមការងារបច្ចេកទេសមានភារកិច្ច៖

-លើកគម្រោងការងារដីធ្លីនៅគ្រប់ផ្នែក ជាពិសេសផ្នែកគ្រប់គ្រងដីធ្លី រៀបចំដែនដី និងបែងចែកដីធ្លី ដាក់ឱ្យដំណើរការអនុវត្ត ធ្វើការសម្របសម្រួល និងវាយតម្លៃការងារ។

-ជំរុញការចុះបញ្ជីដីធ្លីជាប្រព័ន្ធទូទាំងប្រទេស

-ជំរុញការគ្រប់គ្រងផ្នែករដ្ឋបាលសុរិយោដីលើអចលនវត្ថុជាទ្រព្យសម្បត្តិរបស់រដ្ឋឱ្យមានប្រសិទ្ធភាព។

**មាត្រា១១**

ក្រុមការងារពង្រឹងស្ថាប័នមានភារកិច្ចៈ

-ធ្វើទំនាក់ទំនងដើម្បីជំរុញឱ្យមានទំនើបកម្មឧបករណ៍ និងធនធានមនុស្សប្រកបដោយឯកទេសគ្រប់គ្រាន់ដើម្បីបំពេញការងារ

-លើកផែនការបណ្តុះបណ្តាល និងផ្សព្វផ្សាយដល់ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋទូទៅជាពិសេសអំពីការងារដីធ្លី

-ពង្រឹងគណៈកម្មការដោះស្រាយបាតុភាពបញ្ហាទំនាស់ដីធ្លី។

**មាត្រា១២**

ក្រុមការងាររដ្ឋបាលមានភារកិច្ចៈ

-គ្រប់គ្រងការងាររដ្ឋបាលរបស់អគ្គលេខាធិការដ្ឋាន

-កសាងគម្រោងថវិកាប្រចាំឆ្នាំ និងគ្រប់គ្រងការអនុវត្តថវិកា

-គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ

-រៀបចំ និងសម្រួលកិច្ចប្រជុំ និងការពិភាក្សារបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី

-ធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់អគ្គលេខាធិការដ្ឋាន

-តាមដានវាយតម្លៃគម្រោងការដីធ្លីដែលបានអនុវត្ត ព្រមទាំងធ្វើរបាយការណ៍ទៀងទាត់ជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លីអំពីលទ្ធផលការងារនេះ។

**មាត្រា១៣**

អគ្គលេខាធិការដ្ឋានប្រើប្រាស់បុគ្គលិកនៃមុខងារសាធារណៈ ឬអាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ល័ក្ខខ័ណ្ឌនៃលាភការរបស់ភ្នាក់ងារជាប់កិច្ចសន្យា និងប្រាក់បំណាច់ ពិសេសសម្រាប់បើកជូនភ្នាក់ងារមុខងារសាធារណៈ ត្រូវកំណត់ដោយប្រកាសរបស់ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី តាមសំណើរបស់អគ្គលេខាធិការ។

*វាយឡើងវិញ*

**មាត្រា១៤**

សមាជិក និងបុគ្គលិកទាំងអស់របស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី អាចទទួលបាននូវប្រាក់បំណាច់ផ្សេងៗដែលបានផ្តល់មកពីប្រទេស ឬអង្គការផ្តល់ជំនួយអន្តរជាតិនានា។

## ជំពូកទី៣ អវសានប្បញ្ញត្តិ

**មាត្រា១៥**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ចាប់ពីក្រោមថ្នាក់ប្រធាននាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តាមសំណូមពររបស់អគ្គលេខាធិការនៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី។

**មាត្រា១៦**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១៧**

ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន និងសមាជិកទាំងអស់របស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានភារកិច្ចអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០០

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

**បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី**

**ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី**

**ហត្ថលេខា**

**អ៊ឹម ឈុនលឹម**

# ព្រះរាជក្រម

នស/រកម/០៨០១/១៤

**យើង**

**ព្រះបាទសម្តេចព្រះនរោត្តម សីហនុ រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស**
**អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ប្រកាសឱ្យប្រើ**

ច្បាប់ភូមិបាល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០១ នាសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០១ នាសម័យប្រជុំពេញអង្គលើកទី៥ នីតិកាលទី១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

# ច្បាប់ភូមិបាល

**បទប្បញ្ញត្តិទូទៅ**

**មាត្រា១**

ច្បាប់នេះមានគោលដៅកំណត់អំពីរបបកម្មសិទ្ធិលើអចលនវត្ថុទាំងឡាយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធានាការពារសិទ្ធិនៃកម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុ ស្របតាមបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២**

ចាត់ទុកជាអចលនវត្ថុ តាមន័យនៃច្បាប់នេះមានអចលនវត្ថុពីកំណើត អចលនវត្ថុពីភ័ព្វវាសនា និងអចលនវត្ថុតាមការកំណត់របស់ច្បាប់។

អចលនវត្ថុពីកំណើតមានដីធម្មជាតិ ដូចជាដីព្រៃឈើ ដីកាប់រាន ដីដាំដុះ ដីទុកទំនេរ ឬមិនអាចដាំដុះ ដីលិចទឹកដោយទឹកនៅនឹងឬទឹកហូរ និងសំណង់ឬការរៀបចំទាំងឡាយដែលឋិតនៅជាប់មួយកន្លែងកើតឡើងដោយអំពើរបស់មនុស្ស ហើយមិនអាចរំកិល ឬផ្លាស់ប្តូរកន្លែងបាន។

អចលនវត្ថុពីភ័ព្វវាសនា មានវត្ថុដែលជាប់នឹងដី ឬបញ្ចូលជាមួយសំណង់ទាំងឡាយដែលមិនអាចបំបែកចេញបាន ដោយមិនធ្វើឱ្យមានការខូចខាត ឬមិនដូរសភាពដើម ដូចជាដើមឈើឧបករណ៍តែងលំអរជាដើម។

អចលនវត្ថុតាមការកំណត់របស់ច្បាប់ មានសិទ្ធិភណ្ឌិកទាំងឡាយលើអចលនវត្ថុ និងចលនវត្ថុទាំងឡាយដែលបានកំណត់ដោយច្បាប់ជាអចលនវត្ថុ។

**មាត្រា៣**

ជនគ្រប់រូបត្រូវគោរពទ្រព្យសម្បត្តិរបស់រដ្ឋ និងកម្មសិទ្ធិឯកជនស្របច្បាប់លើអចលនវត្ថុ។

ការគ្រប់គ្រងផ្នែករដ្ឋបាលសុរិយោដីលើអចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ និងការចេញប័ណ្ណកម្មសិទ្ធិលើអចលនវត្ថុទូទាំងព្រះរាជាណាចក្រកម្ពុជា ជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

បទបញ្ជា និងនីតិវិធីនៃការគ្រប់គ្រងអចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ នឹងត្រូវកំណត់ដោយអនុក្រឹត្យ។

**មាតិកាទី១ អំពីកម្មសិទ្ធិឯកជន និងកម្មសិទ្ធិសាធារណៈ**

**ជំពូកទី១ អំពីគោលការណ៍នៃកម្មសិទ្ធិ**

**មាត្រា៤**

សិទ្ធិនៃកម្មសិទ្ធិដែលចែងក្នុងមាត្រា៤៤ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ អនុវត្តទៅលើអចលនវត្ថុទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា តាមល័ក្ខខ័ណ្ឌដែលបានកំណត់ដោយច្បាប់នេះ។

**មាត្រា៥**

គ្មានបុគ្គលណាមួយត្រូវបានគេដកហូតកម្មសិទ្ធិរបស់ខ្លួនបានទេ ប្រសិនបើការដកហូតនេះមិនមែនដើម្បីប្រយោជន៍សាធារណៈ។ ការដកហូតត្រូវធ្វើឡើងតាមទម្រង់ និងនីតិវិធី បញ្ញត្តដោយច្បាប់ និងបទបញ្ជា បន្ទាប់ពីបានផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌។

**មាត្រា៦**

មានតែភោគៈត្រឹមត្រូវតាមច្បាប់ប៉ុណ្ណោះដែលអាចនាំឱ្យបានកម្មសិទ្ធិ។

រដ្ឋក៏អាចផ្តល់កម្មសិទ្ធិនៃទ្រព្យជាអចលនវត្ថុដែលជារបស់រដ្ឋ ក្នុងព្រំដែនជាក់លាក់ដែលបានកំណត់ដោយច្បាប់នេះដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរ។

រាល់ការផ្ទេរ ឬផ្លាស់ប្តូរសិទ្ធិនៃកម្មសិទ្ធិត្រូវធ្វើឡើងតាមវិធាននៃនីតិរូបនៃការលក់ ការបន្តមតិក ការដូរ ឬប្រទានកម្ម ឬតាមសេចក្តីសម្រេចរបស់តុលាការ។

**មាត្រា៧**

របបកម្មសិទ្ធិលើអចលនវត្ថុមុនឆ្នាំ១៩៧៩ មិនត្រូវបានទទួលស្គាល់។

**មាត្រា៨**

មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីនៃព្រះរាជាណាចក្រកម្ពុជា។

អ្នកមានឧបនិស្ស័យជាកម្មសិទ្ធិករលើដីនៅកម្ពុជា គឺពលរដ្ឋខ្មែរទាំងអស់ សមូហភាពដែនដីសាធារណៈ គ្រឹះស្ថានសាធារណៈ សហគមន៍ ឬសមាគមកម្ពុជាដែលបានទទួលស្គាល់ដោយច្បាប់ថាជានីតិបុគ្គល។

ជនបរទេសដែលបានក្លែងបន្លំប័ណ្ណសញ្ជាតិ ដើម្បីក្លាយជាកម្មសិទ្ធិករលើដីនៅកម្ពុជា នឹងត្រូវផ្តន្ទាទោស ដូចមានចែងក្នុងមាត្រា២៥១នៃច្បាប់នេះ។ ទ្រព្យដែលបានមកក្នុងល័ក្ខខ័ណ្ឌនេះ ត្រូវរឹបអូសយកទុកជាសម្បត្តិរដ្ឋ ដោយរដ្ឋមិនចេញសំណងឱ្យឡើយ។

មាត្រា៩

ក្រុមហ៊ុនដែលបានចុះបញ្ជីនៅកម្ពុជា ហើយដែលមានភាគហ៊ុនចាប់ពី៥១%ឡើងទៅ កាន់កាប់ដោយរូបវន្តបុគ្គលមានសញ្ជាតិខ្មែរ ឬនីតិបុគ្គលនៃច្បាប់កម្ពុជា អាចជាកម្មសិទ្ធិករនៃទ្រព្យជាដីបាន។ មានតែចំនួនភាគរយនៃប្រាក់ហ៊ុនដែលមានចែងក្នុងលក្ខន្តិកៈក្រុមហ៊ុនប៉ុណ្ណោះទេ ដែលទទួលយកជាការបាន។ រាល់ការព្រមព្រៀងដែលចុះហត្ថលេខាជាលក្ខណៈឯកជន រវាងអ្នកចូលហ៊ុនទាំងឡាយដែលមានន័យផ្ទុយពីនេះត្រូវទុកជាមោឃៈ និងគ្មានអានុភាព។

ប្រសិនបើចំនួនភាគរយដែលមានចែងក្នុងលក្ខន្តិកៈបានប្រែប្រួល បណ្តាលឱ្យក្រុមហ៊ុនលែងមានសញ្ជាតិជាខ្មែរ ក្រុមហ៊ុនមានកាតព្វកិច្ចធ្វើការផ្លាស់ប្តូរលក្ខន្តិកៈឱ្យបានសមស្របតាមស្ថានភាពជាក់ស្តែង ហើយត្រូវផ្តល់ព័ត៌មានទៅស្ថាប័នមានសមត្ថកិច្ចអំពីការប្រែប្រួលនេះ ដោយអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ជាធរមាន។

មាត្រា១០

កម្មសិទ្ធិរបស់បុគ្គលតែម្នាក់ ទោះជារូបវន្តបុគ្គលក្តី ឬនីតិបុគ្គលក្តី គឺជាកម្មសិទ្ធិឯកត្តជន។

កម្មសិទ្ធិរបស់បុគ្គលមួយក្រុមដែលមានបុព្វសិទ្ធិរៀងៗខ្លួន តាមរយៈច្បាប់ដែលមានបញ្ញត្តអំពីកម្មសិទ្ធិនេះគឺជាកម្មសិទ្ធិសមូហភាព។

កម្មសិទ្ធិរបស់បុគ្គលច្រើននាក់ ដែលអនុវត្តសិទ្ធិរបស់ខ្លួនដោយសាមគ្គីគ្នា ទៅលើទ្រព្យទាំងមូលគឺកម្មសិទ្ធិអវិភាគ។

កម្មសិទ្ធិរបស់បុគ្គលច្រើននាក់ដែលអនុវត្តនូវសិទ្ធិឯកជនផ្តាច់មុខលើភាគខ្លះនៃទ្រព្យ ហើយភាគដទៃទៀតហៅថាភាគរួម ត្រូវដាក់នៅក្រោមបទបញ្ជានីត្យានុកូល ឬតាមការព្រមព្រៀងគឺសហកម្មសិទ្ធិ។

ប្រភេទនៃកម្មសិទ្ធិនីមួយៗត្រូវបានកំណត់ដោយបទប្បញ្ញត្តិដោយឡែករបស់កម្មសិទ្ធិទាំងនោះ។

មាត្រា១១

របបគតិយុត្តនៃកម្មសិទ្ធិលើអចលនវត្ថុ ប្រែប្រួលទៅតាមតម្រូវការរបស់សង្គមខ្មែរដូចជាដីកសិកម្ម ព្រៃឈើ ផ្លូវទឹក ត្រពាំង បឹងបួ ឬធារទឹក ត្រើយសមុទ្រ ឬច្រាំងទន្លេ អចលនវត្ថុក្នុងទីក្រុង និងដីសម្រាប់សាងសង់តំបន់អភិវឌ្ឍន៍ឧស្សាហកម្ម។

ច្បាប់ពិសេសត្រូវបំពេញបទប្បញ្ញត្តិទាំងឡាយនៃអត្ថបទច្បាប់នេះ ឬតាំងបដិប្បញ្ញត្តិ

ដើម្បីរក្សានូវការចាំបាច់ខាងសង្គមសេដ្ឋកិច្ច ការរៀបចំដែនដី និងនគរូបនីយកម្ម។

បទបញ្ញាទាំងឡាយនឹងបញ្ជាក់លំអិត នូវរបបផ្សេងៗនៃកម្មសិទ្ធិដោយគោរពតាមបទប្បញ្ញត្តិនៃច្បាប់។

## ជំពូកទី២ អំពីកម្មសិទ្ធិសាធារណៈ

### មាត្រា១២

រដ្ឋជាកម្មសិទ្ធិករនៃទ្រព្យសម្បត្តិទាំងឡាយ ក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាដែលបានចែងក្នុងមាត្រា៥៨ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងទ្រព្យទិទាយាទភាពទាំងអស់ ឬទ្រព្យដែលម្ចាស់គេប្រគល់ឱ្យរដ្ឋដោយស្ម័គ្រចិត្ត ឬទ្រព្យដែលមិនមែនជាកម្មវត្ថុនៃការយកធ្វើជារបស់ឯកជន តាមច្បាប់ ឬមិនមែនជាទ្រព្យដែលកំពុងកាន់កាប់ ជារបស់ឯកជនស្របតាមបទប្បញ្ញត្តិនៃជំពូកទី៤នៃច្បាប់នេះ។

### មាត្រា១៣

ក្រៅពីរដ្ឋ សមូហភាពដែនដីសាធារណៈ គ្រឹះស្ថានសាធារណៈ និងនីតិបុគ្គលនៃនីតិសាធារណៈដែលបានទទួលស្គាល់ដោយច្បាប់ថាជានីតិបុគ្គល អាចជាកម្មសិទ្ធិករនៃទ្រព្យជាអចលនវត្ថុក្នុងល័ក្ខខ័ណ្ឌដែលបានកំណត់ក្នុងជំពូកនេះ។

### មាត្រា១៤

ទ្រព្យមួយចំនួនរបស់រដ្ឋ ឬរបស់សមូហភាពដែនដីសាធារណៈដែលត្រូវបានដាក់នៅក្រោមរបបគតិយុត្តពិសេស គឺជាទ្រព្យសម្បត្តិសាធារណៈរបស់នីតិបុគ្គលសាធារណៈ។ ទ្រព្យមួយចំនួនទៀតត្រូវគ្រប់គ្រងដូចកម្មសិទ្ធិឯកជន និងអាចជាកម្មវត្ថុនៃកិច្ចការជំនួញ គឺជាទ្រព្យសម្បត្តិឯកជនរបស់នីតិបុគ្គលសាធារណៈ។

### មាត្រា១៥

រាប់ចូលក្នុងសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ៖

-ទ្រព្យទាំងឡាយដែលបង្ហាញនូវការកើតឡើងពីធម្មជាតិដូចជាព្រៃឈើ ផ្លូវទឹកដែលនាវាឬក្បូនចេញចូលបាន បណ្តែតបាន បឹងធម្មជាតិ ច្រាំងទន្លេដែលនាវា ឬក្បូនចេញចូលបានបណ្តែតបាន និងត្រើយសមុទ្រ

-ទ្រព្យទាំងឡាយដែលជាកម្មវត្ថុនៃការរៀបចំពិសេសសម្រាប់ប្រយោជន៍ទូទៅ ដូចជា

តីរបាន កំពង់ផែ ផ្លូវដែក ស្ថានីយរថភ្លើង និងព្រលានយន្តហោះ

-ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈ តាមស្ថានភាពពីកំណើត ឬក្រោយពីបានរៀបចំ ដូចជាផ្លូវថ្នល់ ផ្លូវលំ ផ្លូវរទេះ ផ្លូវដើរ សួនច្បារ និងឧទ្យានសាធារណៈ និងដីចំណី

-ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យដំណើរការសម្រាប់សេវាសាធារណៈ ដូចជាសាលារៀន ឬអគារសិក្សាសាធារណៈ អគាររដ្ឋបាល មន្ទីរពេទ្យសាធារណៈទាំងឡាយ

-ទ្រព្យទាំងឡាយដែលបង្កើតជាដែនបម្រុងធម្មជាតិ ការពារដោយច្បាប់

-បេតិកភណ្ឌបុរាណវិទ្យា វប្បធម៌ និងប្រវត្តិសាស្ត្រ

-អចលនវត្ថុជាព្រះរាជទ្រព្យ ដែលមិនមែនជាទ្រព្យសម្បត្តិឯកជនរបស់ព្រះរាជវង្សានុវង្ស។ អចលនវត្ថុជាព្រះរាជទ្រព្យ ត្រូវបានចាត់ចែងដោយព្រះមហាក្សត្រកំពុងគ្រងរាជ្យ។

**មាត្រា១៦**

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មិនអាចលក់ដូរបានឡើយ ហើយកម្មសិទ្ធិនៃទ្រព្យទាំងនោះមិនអាចកំណត់អាជ្ញាយុកាលបានទេ។

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មិនអាចឋិតនៅក្រោមការកាន់កាប់ដោយលទ្ធកម្មពិសេសនៃជំពូកទី៤នៃច្បាប់នេះបានទេ។

ប៉ុន្តែទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ អាចជាកម្មវត្ថុនៃការអនុញ្ញាតឱ្យកាន់កាប់ ឬប្រើប្រាស់ជាបណ្ដោះអាសន្ន មិនទៀង ហើយអាចដកហូតវិញបាន បើមិនបានបំពេញកាតព្វកិច្ចបង់ពន្ធផ្សេងៗ លើកលែងតែបានអនុញ្ញាតតាមជំពូកទី៣នៃច្បាប់នេះ។ ការអនុញ្ញាតទាំងនេះ មិនអាចប្រែក្លាយទៅជាកម្មសិទ្ធិ ឬជាសិទ្ធិភណ្ឌិកជាប្រយោជន៍ដល់អ្នកកាន់កាប់ទ្រព្យទាំងនោះបានឡើយ។

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ នៅពេលបាត់បង់ផលប្រយោជន៍សាធារណៈ អាចត្រូវចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋតាមរយៈច្បាប់អនុបយោគ។

**មាត្រា១៧**

ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ អាចជាកម្មវត្ថុនៃការលក់ ការដូរ ការបែងចែក ឬការផ្ទេរសិទ្ធិតាមការកំណត់របស់ច្បាប់។

ទ្រព្យទាំងនោះអាចផ្ដល់ឱ្យតាមរយៈភតិសន្យា និងជាកម្មវត្ថុនៃកិច្ចសន្យាដែលបានធ្វើឡើងត្រឹមត្រូវតាមច្បាប់។ ល័ក្ខខ័ណ្ឌទាំងឡាយ និងនីតិវិធីនៃការលក់ និងការគ្រប់គ្រងទ្រព្យ

សម្បត្តិឯកជនរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈនឹងកំណត់ដោយអនុក្រឹត្យ ។ គ្មានការលក់ណាមួយអាចត្រូវបានសម្រេចដោយគ្មានអនុក្រឹត្យនេះឡើយ ។ ដីជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ អាចជាកម្មវត្ថុនៃសម្បទាន ក្នុងល័ក្ខខ័ណ្ឌដែលមានចែងក្នុងជំពូកទី៥នៃច្បាប់នេះ ។

គ្មានការចាប់យកដីតាមទំនើងចិត្តណាមួយអាចកើតឡើង ទៅលើទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈបានឡើយ ចាប់ពីច្បាប់នេះចូលជាធរមាន ទោះបីស្របនឹងជំពូកទី៤នៃច្បាប់នេះក៏ដោយ ។

ប៉ុន្តែដីទំនេរនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ អាចត្រូវបានបែងចែកឱ្យទៅបុគ្គលដែលត្រូវការដីក្នុងគោលដៅសង្គមកិច្ច តាមល័ក្ខខ័ណ្ឌដែលកំណត់ដោយអនុក្រឹត្យ ។

**មាត្រា១៨**

ត្រូវទុកជាមោឃៈ និងគ្មានអានុភាព ហើយមិនអាចត្រូវបានធ្វើនិយតកម្ម ទោះតាមរូបភាពណាក៏ដោយនូវ ៖

-រាល់ការចូលកាន់កាប់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ និងរាល់ការបំប្លែងការកាន់កាប់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ទៅជាសិទ្ធិកម្មសិទ្ធិ ទោះបីការកាន់កាប់ និងការបំប្លែងនេះ កើតមាននៅពេលណាក៏ដោយ ដែលមិនស្របតាមលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីដែលបានកំណត់កន្លងមក

-រាល់ការបំប្លែងទៅជាសិទ្ធិកម្មសិទ្ធិនៃដីសម្បទាន ទោះជាការបំប្លែងនោះ កើតឡើងមុនពេលច្បាប់នេះចូលជាធរមានក៏ដោយ លើកលែងតែសម្បទានដែលឆ្លើយតបនឹងប្រយោជន៍សង្គម

-រាល់សម្បទានមិនស្របនឹងបញ្ញត្តិទាំងឡាយនៃជំពូកទី៥

-រាល់ការចូលកាន់កាប់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ទោះជាតាមរូបភាពណាក៏ដោយ ដែលបានកើតឡើងក្រោយច្បាប់នេះចូលជាធរមាន ។

**មាត្រា១៩**

បុគ្គលទាំងឡាយដែលមានប័ណ្ណ ឬមានស្ថានភាពជាក់ស្តែងឋិតនៅក្រោមឥទ្ធិពលនៃមាត្រា១៨នៃច្បាប់នេះ មិនអាចទាមទារសំណងទូទាត់ ឬសោហ៊ុយសម្រាប់ការថែទាំ ឬការរៀបចំដែលបានធ្វើនៅលើអចលនវត្ថុដែលបានកាន់កាប់ដោយខុសច្បាប់បានឡើយ ។

លទ្ធកម្មណាមួយដោយខុសច្បាប់ និងដោយចេតនា ឬដោយបោកប្រាស់ លើទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈ ត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា២៥៩នៃច្បាប់នេះ។

ចំពោះការកាន់កាប់ទ្រព្យសម្បត្តិសាធារណៈដែលបណ្តាលឱ្យខូចខាត ឬធ្វើឱ្យយឺតយ៉ាវដល់ការងារដែលជាប្រយោជន៍ទូទៅ ពិសេសចំពោះការកាន់កាប់ដីចំណីផ្លូវ កម្រិតទោសនឹងត្រូវកំណត់ជាទ្វេ។

ក្នុងគ្រប់ករណី បើជនល្មើសមិនបញ្ឈប់ការកាន់កាប់របស់ខ្លួនក្នុងរយៈពេលដែលបានកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ចទេ អាជ្ញាធរអាចដំណើរការបណ្តេញជនល្មើសចេញ។

## ជំពូកទី៣ អំពីកម្មសិទ្ធិរបស់សមូហភាព

### ផ្នែកទី១ អំពីអចលនវត្ថុរបស់វត្ត

**មាត្រា២០**

អចលនវត្ថុជាដី និងជាសំណង់ដែលមាននៅក្នុង និងក្រៅបរិវេណវត្តអារាមនៃព្រះពុទ្ធសាសនា ជាបេតិកភណ្ឌប្រើប្រាស់ជានិច្ចកាលសម្រាប់ព្រះពុទ្ធសាសនា និងដាក់ឱ្យពុទ្ធសាសនិកប្រើប្រាស់ក្រោមការថែទាំរបស់គណៈកម្មការវត្ត។

**មាត្រា២១**

អចលនវត្ថុរបស់វត្ត មិនអាចលក់ដូរ ឬធ្វើអំណោយ ហើយគ្មានកំណត់អាជ្ញាយុកាលឡើយ។ អចលនវត្ថុរបស់វត្តអាចជួល ឬប្រវាស់បាន តែផលទុនដែលបានមកពីការជួល ឬប្រវាស់នេះត្រូវទុកសម្រាប់តែកិច្ចការសាសនាប៉ុណ្ណោះ។

កិច្ចការពារទ្រព្យទាំងនេះត្រូវធានាដោយគណៈកម្មការវត្ត។ នីតិវិធីនៃការជ្រើសរើសគណៈកម្មការ និងតំណាងដើម្បីការពារផលប្រយោជន៍វត្ត ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងធម្មការ និងសាសនា។

**មាត្រា២២**

ទីកន្លែងសក្ការបូជា និងទ្រព្យសម្បត្តិនៃជំនឿសាសនាដទៃទៀត មិនឋិតនៅក្រោមរបបដែលមានបញ្ញត្តក្នុងមាត្រា២០ និងមាត្រា២១នៃច្បាប់នេះឡើយ។ ទ្រព្យទាំងនោះត្រូវគ្រប់គ្រងដោយសមាគមនៃសាសនិកដែលបង្កើតឡើងទៅតាមបញ្ញត្តិនៃច្បាប់។

## ផ្នែកទី២ អំពីអចលនវត្ថុរបស់សហគមន៍ជនជាតិដើមភាគតិច

### មាត្រា២៣

សហគមន៍ជនជាតិដើមភាគតិច គឺជាក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គមវប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទម្លាប់នៃការប្រើប្រាស់ជាសមូហភាព។

ក្នុងពេលដែលរង់ចាំការកំណត់ខាងផ្លូវច្បាប់នូវលក្ខន្តិកៈរបស់សហគមន៍ ក្រុមដែលមានជាក់ស្តែងមកទល់បច្ចុប្បន្ននេះ នឹងបន្តគ្រប់គ្រងសហគមន៍ និងអចលនវត្ថុរបស់ខ្លួនតាមប្រពៃណី ហើយត្រូវអនុវត្តតាមបញ្ញត្តិនៃច្បាប់នេះ។

### មាត្រា២៤

ចាត់ទុកជាសមាជិកនៃសហគមន៍ជនជាតិដើមភាគតិច ដែលអាចទទួលគុណប្រយោជន៍ពីការធានាសិទ្ធិ និងការការពារដែលរៀបចំឡើងដោយច្បាប់នេះ រាល់បុគ្គលដែលឆ្លើយតបទៅនឹងលក្ខណវិនិច្ឆ័យនៃជាតិពន្ធុអំពីវប្បធម៌ និងសង្គមរបស់សហគមន៍ ដែលទទួលស្គាល់ដោយមតិភាគច្រើននៃសមាជិកដទៃទៀត និងដោយព្រមទទួលនូវសាមគ្គីភាព និងភាពចំណុះដែលនាំឱ្យមានការចូលក្នុងសហគមន៍។

### មាត្រា២៥

ដីសហគមន៍ជនជាតិដើមភាគតិច គឺជាដីទាំងអស់ដែលសហគមន៍បានរៀបចំនិវេសនដ្ឋាន និងប្រកបរបរកសិកម្មប្រពៃណី។

ដីសហគមន៍ជនជាតិដើមភាគតិច មិនមែនមានតែដីដែលបានដាំដុះជាក់ស្តែងនោះទេ ប៉ុន្តែមានដីបម្រុង ចាំបាច់ការដូរវេនដំណាំថែមទៀតដែលតម្រូវទៅតាមរបៀបទាញយកផលដែលធ្លាប់ធ្វើកន្លងមក ហើយត្រូវបានទទួលស្គាល់ដោយអាជ្ញាធររដ្ឋបាល។

ការវាស់វែង និងការកំណត់ព្រំប្រទល់នៃអចលនវត្ថុរបស់សហគមន៍ទាំងនោះ ត្រូវកំណត់ទៅតាមស្ថានភាពជាក់ស្តែងដូចដែលបានអះអាងដោយសហគមន៍ ដោយមានការព្រមព្រៀងពីអ្នកជិតខាង និងដែលបានកំណត់តាមនីតិវិធីក្នុងមាតិកាទី៦នៃច្បាប់នេះ និងអនុក្រឹត្យពាក់ព័ន្ធ។

**មាត្រា២៦**

កម្មសិទ្ធិនៃអចលនវត្ថុដែលបានចែងក្នុងមាត្រា២៥ ត្រូវបានផ្តល់ដោយរដ្ឋជូនសហគមន៍ជនជាតិដើមភាគតិចជាកម្មសិទ្ធិសមូហភាព។ កម្មសិទ្ធិសមូហភាពរួមមានរាល់សិទ្ធិ និងការការពារកម្មសិទ្ធិដូចកម្មសិទ្ធិឯកជនដែរ។ ប៉ុន្តែសហគមន៍នោះ គ្មានសិទ្ធិចាត់ចែងនូវចំណែកណាមួយនៃកម្មសិទ្ធិសមូហភាព ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋឱ្យទៅបុគ្គល ឬក្រុមណាមួយបានឡើយ។

ការអនុវត្តនូវសិទ្ធិជាកម្មសិទ្ធិទាក់ទងនឹងអចលនវត្ថុរបស់សហគមន៍ និងល័ក្ខខ័ណ្ឌជាក់លាក់នៃការប្រើប្រាស់ដី ត្រូវឋិតនៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរប្រពៃណី និងយន្តការនៃការធ្វើសេចក្តីសម្រេចរបស់សហគមន៍ អនុលោមតាមទំនៀមទម្លាប់របស់ពួកគេ ហើយត្រូវដាក់ឱ្យនៅក្រោមច្បាប់នៃការអនុវត្តទូទៅទាក់ទងនឹងអចលនវត្ថុ ដូចជាច្បាប់ការពារបរិស្ថានជាដើម។

បញ្ញត្តិនៃមាត្រានេះ មិនមែនជាឧបសគ្គដល់សកម្មភាពការងាររបស់រដ្ឋដែលជាតម្រូវការនៃផលប្រយោជន៍ជាតិ ឬតម្រូវការជាបន្ទាន់របស់ជាតិឡើយ។

**មាត្រា២៧**

ដើម្បីសម្រួលការវិវត្តវប្បធម៌ សេដ្ឋកិច្ច និងសង្គមនៃសមាជិកសហគមន៍ជនជាតិដើមភាគតិច និងដើម្បីអនុញ្ញាតឱ្យពួកគេបានចេញដោយសេរីពីសហគមន៍ ឬរួចចាកពីការបង្ខិតបង្ខំសិទ្ធិនៃកម្មសិទ្ធិឯកត្តជន អាចនឹងត្រូវផ្ទេរជាពិសេសឱ្យពួកគេបាន លើចំណែកសមស្របមួយនៃដីដែលប្រើដោយសហគមន៍ ប៉ុន្តែចំណែកនៃដីដែលជាកម្មវត្ថុនៃការយកធ្វើជាកម្មសិទ្ធិឯកជននោះ មិនអាចជាដីដែលចូលក្នុងនិយមន័យទូទៅនៃទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋបានទេ។

**មាត្រា២៨**

គ្មានអាជ្ញាធរណាមួយក្រៅពីសហគមន៍ អាចទទួលបានសិទ្ធិលើអចលនវត្ថុរបស់ជនជាតិដើមភាគតិចបានឡើយ។

**មាតិកាទី២ អំពីលទ្ធកម្មនៃកម្មសិទ្ធិ**

**ជំពូកទី៤ អំពីការបង្កើតឡើងវិញនូវកម្មសិទ្ធិលើអចលនវត្ថុ តាមលទ្ធកម្មពិសេសនៃភោគៈ**

**មាត្រា២៩**

ក្នុងក្របខ័ណ្ឌនៃការបង្កើតឡើងវិញនូវកម្មសិទ្ធិលើអចលនវត្ថុ នៅកម្ពុជាក្រោយសម័យមានវិបត្តិ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដោយមិនចំពោះទៅនឹងវិធានទូទៅនៃអាជ្ញាយុកាលស្តីពី

កម្មសិទ្ធិលើអចលនវត្ថុ ភោគៈនៃអចលនវត្ថុដែលត្រូវបានទទួលស្គាល់ចាប់ពីឆ្នាំ១៩៨៩ អាចបង្កើតជាពិសេសនូវសិទ្ធិភណ្ឌិកលើអចលនវត្ថុ និងនាំទៅដល់លទ្ធកម្មនៃកម្មសិទ្ធិដោយអ្នកកាន់កាប់ទ្រព្យក្នុងល័ក្ខខ័ណ្ឌដែលបានកំណត់ដោយច្បាប់នេះ ។

ការចូលកាន់កាប់ភោគៈត្រូវបញ្ចប់ នៅពេលដែលច្បាប់នេះចូលជាធរមាន ។

**មាត្រា៣០**

បុគ្គលទាំងឡាយដែលបានអាស្រ័យផលនៃភោគៈដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី៥ (ប្រាំ) ឆ្នាំយ៉ាងតិច គិតមកដល់កាលបរិច្ឆេទនៃការប្រកាសឱ្យប្រើច្បាប់នេះ លើអចលនវត្ថុដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ក្នុងការកាន់កាប់ជាឯកជន មានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរ ។

ក្នុងករណីមានការជំទាស់ដល់ការផ្តល់ប័ណ្ណកម្មសិទ្ធិស្ថាពរនេះ អ្នកតវ៉ាត្រូវយកភស្តុតាងមកបញ្ជាក់ថា ខ្លួនឯងផ្ទាល់បានបំពេញល័ក្ខខ័ណ្ឌនៃភោគៈដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី៥ (ប្រាំ) ឆ្នាំ នៅលើអចលនវត្ថុដែលមានទំនាស់ ឬយកភស្តុតាងដែលថាខ្លួនបានទិញអចលនវត្ថុនោះពីភោគីដើម ឬពីសិទ្ធិវន្តស្របច្បាប់ ឬអ្នកទទួលផ្ទេរកម្មសិទ្ធិ ឬពីសន្តតិជនរបស់ខ្លួន ។

**មាត្រា៣១**

បុគ្គលដែលបានអាស្រ័យផលនៃភោគៈកន្លងមក គិតមកដល់កាលបរិច្ឆេទដែលច្បាប់នេះចូលជាធរមាន ប្រសិនបើបានបំពេញគ្រប់គ្រាន់នូវល័ក្ខខ័ណ្ឌទាំងឡាយ ក្នុងការក្លាយទៅជាកម្មសិទ្ធិករ អាចត្រូវបានអនុញ្ញាតដោយអាជ្ញាធរមានសមត្ថកិច្ច ឱ្យបន្ថែមរយៈពេលកាន់កាប់ភោគៈរបស់ខ្លួនរហូតគ្រប់រយៈពេលស្របច្បាប់៥ (ប្រាំ) ឆ្នាំ និងបានប័ណ្ណកម្មសិទ្ធិស្ថាពរ ។ ការអនុញ្ញាតឱ្យបន្តរយៈពេល មិនអាចត្រូវបានបដិសេធដោយអាជ្ញាធរមានសមត្ថកិច្ចឡើយ ប្រសិនបើភោគៈបានមកដោយសន្តិវិធី និងមិនមានការជំទាស់ ។

អាជ្ញាធរមានសមត្ថកិច្ចដែលបដិសេធដោយរំលោភ នូវការអនុញ្ញាតឱ្យបន្តរយៈពេល ត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនចំពោះមុខច្បាប់ ។

ការទទួលស្គាល់ដោយរំលោភដោយអាជ្ញាធរមានសមត្ថកិច្ច នូវភោគៈដែលមិនបំពេញល័ក្ខខ័ណ្ឌនៃច្បាប់ ត្រូវចាត់ទុកជាមោឃៈ និងគ្មានអានុភាព ។ អាជ្ញាធរដែលបានទទួលស្គាល់ដោយរំលោភនេះ ត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនចំពោះមុខច្បាប់ ។

**មាត្រា៣២**

អចលនវត្ថុទាំងឡាយ ដែលមិនអាចក្លាយទៅជាកម្មសិទ្ធិនៃអ្នកកាន់កាប់ស្របតាមច្បាប់នេះ ក្នុងករណីភោគីបំពេញមិនបាននូវល័ក្ខខ័ណ្ឌនៃច្បាប់ដោយហេតុមកពីលក្ខណសម្បត្តិរបស់ខ្លួនជាភោគីកេងបន្លំ ឬដោយឥរិយាបទរបស់ខ្លួនជាភោគីដែលលួចលាក់នឹងច្បាប់ ឬដែលមិនចេញមុខ ឬជាភោគីដោយប្រើហិង្សា អចលនវត្ថុនោះត្រូវទុកជាសម្បត្តិរដ្ឋ ហើយមិនអាចឱ្យជនណាចូលកាន់កាប់ជាភោគីថ្មី សម្រាប់លទ្ធកម្មនៃកម្មសិទ្ធិ ក្នុងល័ក្ខខ័ណ្ឌនៃជំពូកនេះបានឡើយ ។

**មាត្រា៣៣**

ក្នុងករណីដែលមានការដកហូតអចលនវត្ថុដោយហិង្សា ឬដោយប្រើអំណាចរំលោភរបស់អាជ្ញាធរ អចលនវត្ថុនោះត្រូវបានបង្វិលមករដ្ឋវិញ ហើយមិនអាចជាកម្មវត្ថុនៃការកាន់កាប់ថ្មីបានឡើយ ប្រសិនបើគ្មានបណ្ដឹងទាមទារពីភោគីស្របច្បាប់នៃអចលនវត្ថុដែលត្រូវបានដកហូត ។ បណ្ដឹងទាមទារនេះមានរយៈពេល៣ (បី) ឆ្នាំ ចាប់ពីថ្ងៃដែលរដ្ឋប្រកាសដកហូត ។

**មាត្រា៣៤**

អ្នកកាន់កាប់ថ្មីលើអចលនវត្ថុរបស់នីតិបុគ្គលសាធារណៈ ឬរបស់បុគ្គលឯកជនដោយគ្មានប័ណ្ណ ក្រោយពីច្បាប់នេះចូលជាធរមាន ត្រូវចាត់ទុកជាអ្នកកាន់កាប់ដោយខុសច្បាប់ ហើយត្រូវទទួលទោស ដូចមានចែងក្នុងមាត្រា២៥៩នៃច្បាប់នេះ ។

**មាត្រា៣៥**

មានតែអាជ្ញាធរមានសមត្ថកិច្ចក្នុងនាមរដ្ឋ និងនីតិបុគ្គលសាធារណៈប៉ុណ្ណោះ ដែលអាចឱ្យអ្នកកាន់កាប់អចលនវត្ថុគ្មានប័ណ្ណ ឬមានប័ណ្ណមិនគ្រប់គ្រាន់ចាកចេញពីទីតាំងអចលនវត្ថុនោះ ។

សាមញ្ញជន ឬអាជ្ញាធរដែលមិនតាងនាមរដ្ឋ ឬនីតិបុគ្គលសាធារណៈ គ្មានសមត្ថកិច្ចដេញអ្នកកាន់កាប់ដោយសន្តិភាព មានប័ណ្ណត្រឹមត្រូវដោយប្រើកម្លាំងបានឡើយ ។ ការដេញអាចធ្វើបានតែតាមការបង្គាប់របស់តុលាការ យោងតាមបណ្ដឹងរបស់បុគ្គលដែលបានប្ដឹងទាមទារទ្រព្យ ។

តុលាការត្រូវពិនិត្យបញ្ជាក់រូបភាព ប្រភព កាលបរិច្ឆេទ និងល័ក្ខខ័ណ្ឌទាំងឡាយនៃប័ណ្ណដែលបានបង្ហាញ ។ តុលាការមិនអាចប្រកែកការបង្គាប់ឱ្យចាកចេញដើម្បីជាប្រយោជន៍ដល់បុគ្គលដែលបង្ហាញប័ណ្ណត្រឹមត្រូវ និងពេញលេញរបស់សុរិយោដីបានឡើយ ។

**មាត្រា៣៦**

បើវិធានការបណ្តេញចេញ បង្គាប់ដោយតុលាការ អាចបណ្តាលឱ្យមានភាពរឹករវ ឬមានផលវិបាកធ្ងន់ធ្ងរដល់សង្គម អាជ្ញាធរមានសមត្ថកិច្ចអាចសុំពន្យារការអនុវត្តជាបណ្តោះអាសន្នបាន ។

**មាត្រា៣៧**

លទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុដោយភោគៈ អាចសម្រេចបានចំពោះតែគុណប្រយោជន៍ដល់បុគ្គល ដែលបានកាន់កាប់អចលនវត្ថុស្របតាមល័ក្ខខ័ណ្ឌនៃច្បាប់នេះ ។ លទ្ធកម្មនេះ មិនអាចជាគុណប្រយោជន៍ដល់ភោគីកេងបន្លំឡើយ ។

**មាត្រា៣៨**

ដើម្បីក្លាយទៅជាកម្មសិទ្ធិលើអចលនវត្ថុបាន លុះត្រាតែភោគៈនោះត្រូវបានកាន់កាប់ដោយពិតប្រាកដ គ្មានហិង្សា ដឹងឮជាសាធារណៈ គ្មានអាក់ខាន និងដោយសុចរិត ។

ភោគីត្រូវកាន់កាប់អចលនវត្ថុដោយពិតប្រាកដ គឺថាភោគី ទោះកាន់កាប់ដោយខ្លួនឯងក្តី ឱ្យអ្នកដទៃធ្វើឱ្យក្តី ត្រូវកាន់កាប់ឱ្យឃើញថាការនោះប្រាកដជាធ្វើដើម្បីខ្លួន ក្នុងគោលដៅខ្លួនជាភោគីយ៉ាងផ្ទាល់មុខ កុំឱ្យឃើញថាការដែលធ្វើនោះ គឺធ្វើដោយសារសិទ្ធិណាមួយផ្សេងទៅវិញ ។ ប្រសិនបើភោគីពិតប្រាកដមិនចេញមុខ នៅពីក្រោយភោគីមិនពិតប្រាកដ ភោគីនោះមិនអាចទាមទារប័ណ្ណភោគៈដើម្បីធ្វើលទ្ធកម្មទៅជាកម្មសិទ្ធិបានឡើយ ។ ភោគៈនោះត្រូវបានចាត់ទុកជាមោឃៈ ។

ភោគីត្រូវកាន់កាប់អចលនវត្ថុដោយគ្មានហិង្សា គឺថាភោគៈដែលបានមកដោយហិង្សា មិនទុកជាភោគៈត្រឹមត្រូវតាមច្បាប់ឡើយ ។ ក៏ប៉ុន្តែ បើកាលណាគេប្រើហិង្សាក្នុងពេលមានតតិយជនឥតសិទ្ធិសោះមកដណ្តើម នោះហិង្សានេះគ្មានឥទ្ធិពលអ្វីទៅលើភោគៈដែលគេបានមកដោយសន្តិភាពតាំងពីដើមមកនោះទេ ។

ភោគីត្រូវកាន់កាប់អចលនវត្ថុដោយដឹងឮជាសាធារណៈ គឺថាភោគីត្រូវកាន់កាប់ដោយឥតលាក់បិទបាំង អ្នកទាំងពួងដែលចង់តវ៉ាអំពីសិទ្ធិរបស់ខ្លួនលើវត្ថុនោះនឹងបានដឹងឮឃើញមិនខាន ។

ភោគីត្រូវកាន់កាប់អចលនវត្ថុដោយគ្មានរអាក់ខាន គឺថាភោគីត្រូវធ្វើនូវកិច្ចការផងទាំងពួងតាមធម្មតា ជាប្រក្រតី ក្នុងរយៈពេលចាំបាច់នៃការទាមទារលទ្ធកម្មកម្មសិទ្ធិ ។ ការអាក់ខានក្នុងរយៈពេលខ្លី ឬបោះបង់ទុកឱ្យនៅទំនេរ ដើម្បីឱ្យមានជីជាតិឡើងវិញ មិនមែនជាឧបសគ្គដល់លទ្ធកម្មកម្មសិទ្ធិនោះទេ ។

ភោគីត្រូវកាន់កាប់អចលនវត្ថុដោយសុចរិត គឺថាភោគីមិនដឹងពីសិទ្ធិជាយថាហេតុរបស់តតិយជន លើវត្ថុដែលខ្លួនកំពុងកាន់កាប់នោះសោះ ។

**មាត្រា៣៩**

ការរង់ចាំដើម្បីឱ្យបានទៅជាកម្មសិទ្ធិពេញលេញ ភោគៈដែលស្របតាមបញ្ញត្តិនៃច្បាប់នេះបង្កើតបានជាសិទ្ធិភណ្ឌិកលើអចលនវត្ថុ។ ភោគៈនេះអាចជាកម្មវត្ថុនៃការផ្លាស់ប្តូរ ផ្ទេរសិទ្ធិ ឬជាកម្មវត្ថុនៃកិច្ចការជំនួញ។

**មាត្រា៤០**

ក្នុងការរង់ចាំការរៀបចំឡើងវិញនូវប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដី អាជ្ញាធរមានសមត្ថកិច្ចត្រូវបន្តចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ចំពោះភោគៈដែលមានកន្លងមកមុនច្បាប់នេះចូលជាធរមាន ។

ប័ណ្ណសម្គាល់សិទ្ធិនេះ ជាវត្ថុតាងនៃសិទ្ធិកាន់កាប់ ប៉ុន្តែមិនមែនជាប័ណ្ណកម្មសិទ្ធិទេ ហើយក៏មិនមែនជាលិខិតដែលតវ៉ាមិនបាននោះដែរ ។

ប័ណ្ណសម្គាល់សិទ្ធិនេះ អាចនឹងបង្កើតបានជាប័ណ្ណស្ថាពរនៃកម្មសិទ្ធិដែលមានលក្ខណៈមិនអាចតវ៉ាបាន លុះត្រាតែគ្មានការជំទាស់នៅពេលបង្កើតសៀវភៅគោលបញ្ជីដី ។

ក្នុងករណីមានការជំទាស់ទាមទារ ការកំណត់ថានរណាជាភោគីស្របច្បាប់នៃអចលនវត្ថុនោះ ត្រូវផ្អែកលើការស៊ើបអង្កេតបន្ថែមនូវរាល់ភស្តុតាងដែលពាក់ព័ន្ធទាំងអស់។ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ គឺជាភស្តុតាងមួយ ប៉ុន្តែមិនអាចកំណត់តែឯកឯងបានទេ ។

**មាត្រា៤១**

ត្រូវហាមឃាត់ការចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ដែលមិនអាចយកធ្វើជារបស់ឯកជនបាន ឬដែលមិនបានកាន់កាប់តាមល័ក្ខខ័ណ្ឌស្របច្បាប់ ។

**មាត្រា៤២**

បុគ្គលទាំងឡាយដែលមិនបានចុះបញ្ជីភោគៈស្របច្បាប់របស់ខ្លួន ដោយហេតុមិនបានដឹង ឬដោយធ្វេសប្រហែស អ្នកនោះនៅតែមានសិទ្ធិត្រូវបានការពារតាមអំណាចនៃមាត្រា២៩ មាត្រា៣០ និងមាត្រា៣១នៃច្បាប់នេះ ។

*វាយឡើងវិញ*

មាត្រា៤៣

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មិនអាចជាកម្មវត្ថុនៃលទ្ធកម្មកម្មសិទ្ធិបានឡើយ ទោះក្នុងករណីណាក៏ដោយ ។

ស្ថានភាពនៃអ្នកកាន់កាប់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនៅតែមិនទៀងទាត់ និងខុសច្បាប់ដដែល ប្រសិនជាស្ថានភាពនោះមិនកើតចេញពីការអនុញ្ញាតតាមបែបផែនដែលកំណត់ដោយច្បាប់ទេនោះ ។

បុគ្គលកាន់កាប់ខុសច្បាប់ ត្រូវបង្ខំឱ្យចាកចេញជាបន្ទាន់ ហើយត្រូវទទួលទណ្ឌកម្មដែលបានកំណត់ក្នុងមាត្រា២៥៩នៃច្បាប់នេះ ។

បុគ្គលកាន់កាប់ខុសច្បាប់ គ្មានសិទ្ធិទាមទារសំណងសម្រាប់ចំណាយលើការងារ និងការកែលំអដែលខ្លួនបានធ្វើនៅលើអចលនវត្ថុនោះឡើយ ។

មាត្រា៤៤

ប័ណ្ណ ឬឯកសារសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈ ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចឱ្យដល់បុគ្គលឯកជន ត្រូវទុកជាមោឃៈ និងគ្មានតម្លៃគតិយុត្ត ។

ភ្នាក់ងារដែលចេញប័ណ្ណ ឬឯកសារសម្គាល់សិទ្ធិកាន់កាប់នេះ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ទាំងខាងស៊ីវិល និងព្រហ្មទណ្ឌ ។

អាជ្ញាធរដែលព្រងើយកន្តើយចំពោះការរំលោភខុសច្បាប់តាមរបៀបនេះ ដែលខ្លួនបានដឹងចាត់ទុកជាអ្នករួមគំនិត ហើយត្រូវទទួលទោសដូចគ្នានឹងចារីដែរ ។

មាត្រា៤៥

ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ច មិនព្រមចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ អ្នកកាន់កាប់អចលនវត្ថុនោះ អាចធ្វើពាក្យប្តឹងទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

មាត្រា៤៦

ការចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុដោយអាជ្ញាធរមានសមត្ថកិច្ច ឱ្យបុគ្គលក្រៅពីភោគីពិតប្រាកដដែលបានកាន់កាប់អចលនវត្ថុ គឺជាបទល្មើសដែលត្រូវទទួលទោសតាមបញ្ញត្តិនៃមាត្រា២៦១នៃច្បាប់នេះ ។

មាត្រា៤៧

វិវាទរវាងភោគីចំពោះអចលនវត្ថុមួយ នឹងត្រូវដាក់ឱ្យធ្វើការស៊ើបអង្កេត និងដោះស្រាយតាមនីតិវិធីដែលបានកំណត់។ លទ្ធផលនៃការស៊ើបអង្កេត ត្រូវដាក់ជូនគណៈកម្មការសុរិយោដីដែលបង្កើតឡើងនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គណៈកម្មការនេះ ត្រូវធ្វើសេចក្តីសម្រេចលើបដិវាទកម្មនោះ។ ក្នុងករណីមិនសុខចិត្ត គូវិវាទអាចប្តឹងទៅតុលាការបាន។ ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការនេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៥ អំពីសម្បទានដី

មាត្រា៤៨

សម្បទានដី ជាសិទ្ធិស្របច្បាប់ដែលបានចែងក្នុងឯកសារគតិយុត្ត ចេញដោយអាជ្ញាធរមានសមត្ថកិច្ច តាមអំណាចឆន្ទានុសិទ្ធិឱ្យរូបវន្តបុគ្គល ឬនីតិបុគ្គល ឬក្រុមមនុស្ស ដើម្បីកាន់កាប់ដី និងប្រើប្រាស់សិទ្ធិលើដីនោះតាមការកំណត់នៃច្បាប់នេះ។

មាត្រា៤៩

សម្បទានដី ត្រូវឆ្លើយតបទៅនឹងប្រយោជន៍សង្គម ឬទៅនឹងប្រយោជន៍សេដ្ឋកិច្ច។

សម្បទានដីឆ្លើយតបទៅនឹងប្រយោជន៍សង្គម អនុញ្ញាតឱ្យអ្នកទទួលប្រយោជន៍រៀបចំដីដើម្បីសង់លំនៅឋាន ឬ/និងដាំដំណាំនៅលើដីដែលជាកម្មសិទ្ធិរបស់រដ្ឋ ដើម្បីធានាការចិញ្ចឹមជីវិត។

សម្បទានដីឆ្លើយតបទៅនឹងប្រយោជន៍សេដ្ឋកិច្ច អនុញ្ញាតឱ្យអ្នកទទួលប្រយោជន៍ កាប់ឆ្ការ ទាញយកផលដោយធ្វើអាជីវកម្មកសិឧស្សាហកម្មលើដីនៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា៥០

សម្បទានអាចមានរូបភាពផ្សេងទៀត ដូចជាការអនុញ្ញាតឱ្យប្រើប្រាស់ រៀបចំ ឬធ្វើអាជីវកម្មដីដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ ទោះជាភ្ជាប់ ឬមិនភ្ជាប់ទៅនឹងការបំពេញសេវាសាធារណៈក៏ដោយ មានជាអាទិ៍សម្បទានរ៉ែ សម្បទានកំពង់ផែ សម្បទានព្រលានយន្តហោះ សម្បទានរៀបចំតំបន់ឧស្សាហកម្ម សម្បទាននេសាទ។ សម្បទានទាំងនេះមិនឋិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់នេះទេ។

មាត្រា៥១

សម្បទានដីមិនអាចប្រគល់ឱ្យដោយឥតគិតថ្លៃទេ លើកលែងតែសម្បទានឆ្លើយតបទៅនឹងប្រយោជន៍សង្គមដែលប្រគល់ឱ្យគ្រួសារក្រីក្រសម្រាប់តាំងទីលំនៅ ឬ/និងដាំដំណាំចិញ្ចឹមជីវិត។

**មាត្រា៥២**

សម្បទានដីអាចបង្កើតបានតែសិទ្ធិក្នុងរយៈពេលមួយជាកំណត់ តាមកិច្ចសន្យាដែលបានបង្កើតសម្បទាននោះស្របតាមបញ្ញត្តិនៃច្បាប់នេះ ។

សម្បទានដីមិនអាចឈានដល់ការបង្កើតនូវសិទ្ធិជាកម្មសិទ្ធិ លើដីដែលបានផ្តល់ជាសម្បទានជាប្រយោជន៍ដល់សាមីជននោះទេ លើកលែងតែចំពោះសម្បទានដែលឆ្លើយតបទៅនឹងប្រយោជន៍សង្គម ។

**មាត្រា៥៣**

សម្បទានដីមិនអាចកើតចេញពីស្ថានភាពកាន់កាប់ដីជាក់ស្តែងបានទេ ។ សម្បទានដីត្រូវសំអាងលើលិខិតគតិយុត្តជាក់លាក់ដែលបានចេញមុនការកាន់កាប់ដីដោយអាជ្ញាធរមានសមត្ថកិច្ច គឺរដ្ឋ ឬសមូហភាពដែនដីសាធារណៈ ឬគ្រឹះស្ថានសាធារណៈដែលជាកម្មសិទ្ធិករនៃដីដែលត្រូវបានផ្តល់ជាសម្បទាន ។ សម្បទានត្រូវតែចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**មាត្រា៥៤**

សម្បទានដីត្រូវមានល័ក្ខខ័ណ្ឌ ។ សម្បទានត្រូវតែអនុលោមទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះ ដែលជាសណ្តាប់ធ្នាប់សាធារណៈ ។

លិខិតសម្បទានអាចមានខដោយឡែកផ្សេងទៀតដែលមានតម្លៃជាកិច្ចសន្យា ។

**មាត្រា៥៥**

សម្បទានដីត្រូវបានដកហូតវិញដោយសេចក្តីសម្រេចខាងរដ្ឋបាល ក្នុងករណីល័ក្ខខ័ណ្ឌច្បាប់មិនត្រូវបានគោរព ។ ករណីនេះ សម្បទានិកមានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធីដែលច្បាប់បានកំណត់ ។

សម្បទានដី អាចត្រូវបានទុកជាមោឃៈដោយតុលាការ កាលបើសម្បទានិកមិនគោរពខដោយឡែកដែលមានចែងក្នុងកិច្ចសន្យា ។

**មាត្រា៥៦**

សិទ្ធិរបស់សម្បទានិកលើដីដែលបានផ្តល់ជាសម្បទានក្នុងកំលុងពេលនៃសម្បទាន គឺជាសិទ្ធិដែលទទួលស្គាល់ដូចជាកម្មសិទ្ធិករ លើកលែងតែការផ្ទេរសិទ្ធិ ។ សម្បទានិកមានសិទ្ធិជាពិសេសក្នុងការការពារស្ថានភាពរបស់ខ្លួនដោយអាជ្ញាធរមានសមត្ថកិច្ច ។

សម្បទានិកអាចការពារដីដែលបានផ្តល់ជាសម្បទានឱ្យខ្លួនចំពោះការទន្ទ្រាន ឬការប៉ះពាល់ ទោះជាតាមរូបភាពណាក៏ដោយ ។

សម្បទានិកអាចទាញយកនូវផលិតផលពីដីរបស់ខ្លួន ធ្វើការរៀបចំដាំដុះ ស្របតាមគោលបំណងនៃសម្បទាន។ សម្បទានិកមិនអាចកែប្រែគោលបំណងនៃសម្បទាន ធ្វើឱ្យប៉ះពាល់ដល់រចនាសម្ព័ន្ធធម្មជាតិ និងធ្វើអាជីវកម្មដែលមានលក្ខណៈជាការបំផ្លាញទៅចុងបញ្ចប់នៃសម្បទានបានឡើយ។

**មាត្រា៥៧**

ការផ្ទេរដីសម្បទានមិនអាចធ្វើឡើងតាមរយៈការផ្ទេរសិទ្ធិបានឡើយ។ ការផ្ទេរដីសម្បទានអាចកើតឡើងតែតាមរយៈការបង្កើតកិច្ចសន្យាថ្មីនៃសម្បទាន ដោយអាជ្ញាធរមានសមត្ថកិច្ច ជាគុណប្រយោជន៍ដល់អ្នកទទួលសិទ្ធិសម្បទានថ្មី។

ក្នុងករណីដែលសម្បទានិកទទួលមរណភាព ទាយាទទាំងឡាយរបស់ខ្មោច ប្រសិនជាមានបំណង អាចនឹងបន្តប្រើប្រាស់សិទ្ធិទាំងនោះក្នុងរយៈពេលសម្បទានដែលនៅសល់។

**មាត្រា៥៨**

សម្បទានដីអាចធ្វើឡើងបាន តែនៅលើដីដែលជាចំណែកនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។

សម្បទានដីមិនអាចប៉ះពាល់ផ្លូវគមនាគមន៍ ដីចំណីផ្លូវ និងដីចាំបាច់សម្រាប់ថែទាំ ក៏ដូចជាផ្លូវទឹក ត្រពាំង បឹង និងដែនទឹកបម្រុងដែលមានប្រយោជន៍ដល់ការរស់នៅរបស់ប្រជាពលរដ្ឋឡើយ។

**មាត្រា៥៩**

សម្បទានដីអាចមានទំហំច្រើនបំផុតត្រឹមតែ១០.០០០ (មួយម៉ឺនហិកតា) ហិកតា។

សម្បទានដីដែលសម្រេចហើយ ហើយមានទំហំលើសពីទំហំកំណត់ខាងលើ ជាកម្មវត្ថុនៃការកាត់បន្ថយ។ ប៉ុន្តែប្រសិនបើការកាត់បន្ថយនេះ មានឥទ្ធិពលធ្វើឱ្យខូចប្រយោជន៍អាជីវកម្មដែលកំពុងមានដំណើរការ សម្បទានិកអាចនឹងទទួលបានការលើកលែងជាពិសេស។ នីតិវិធីនៃការកាត់បន្ថយ និងការលើកលែងជាពិសេស ត្រូវកំណត់ដោយអនុក្រឹត្យ។

ត្រូវបានហាមឃាត់ការចេញលិខិតសម្បទានដីច្រើនកន្លែងឱ្យបុគ្គលតែម្នាក់ ឬឱ្យនីតិបុគ្គលច្រើន តែគ្រប់គ្រងដោយរូបវន្តបុគ្គល ឬនីតិបុគ្គលដដែល១ ដែលមានទំហំសរុបធំជាងទំហំដែលបានកំណត់នៅវាក្យខណ្ឌខាងលើ។

**មាត្រា៦០**

នីតិវិធីនៃការផ្តល់សម្បទានដីសម្រាប់ការសង់លំនៅឋាន និងសម្បទានដីកសិកម្មសម្រាប់ការចិញ្ចឹមជីវិត ឬអាជីវកម្មកសិឧស្សាហកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៦១**

រយៈពេលសម្បទានដីត្រូវកំណត់៩៩ (កៅសិបប្រាំបួន) ឆ្នាំយ៉ាងច្រើន។

**មាត្រា៦២**

រាល់សម្បទានដីសម្រាប់ដំណាំឧស្សាហកម្ម ត្រូវចាប់ផ្ដើមធ្វើអាជីវកម្មក្នុងរយៈពេល ១២ (ដប់ពីរ) ខែ បន្ទាប់ពីការផ្ដល់សម្បទាន បើមិនដូច្នោះទេ នឹងត្រូវទុកជាមោឃៈ។

ការខកខានធ្វើអាជីវកម្មរយៈពេលលើសពី១២ (ដប់ពីរ) ខែ នាំឱ្យមានមោឃភាពសម្បទាន ប្រសិនបើការខកខាននោះ ពុំមានមូលហេតុត្រឹមត្រូវ។

រាល់សម្បទានដីដែលបានផ្ដល់ឱ្យមុនច្បាប់នេះចូលជាធរមាន ហើយមិនបានធ្វើអាជីវកម្មចាប់ពី១២ (ដប់ពីរ) ខែឡើងទៅគិតពីថ្ងៃដែលច្បាប់នេះចូលជាធរមាន ត្រូវទុកជាមោឃៈ ប្រសិនបើការខកខានមិនបានធ្វើអាជីវកម្មនោះ ពុំមានមូលហេតុត្រឹមត្រូវ។

រាល់ការមិនបានបំពេញកិច្ចតាមសៀវភៅបន្ទុកដោយសម្បទានិក នាំឱ្យមានការដកហូតសម្បទាន។ ក្នុងករណីនៃការដកហូតសម្បទាន ទោះជាមានមូលហេតុអ្វីក៏ដោយ សម្បទានិកគ្មានសិទ្ធិទារសំណងនៃការខូចខាតណាមួយឡើយ។

## ជំពូកទី៦ អំពីរបៀបលទ្ធកម្មនៃកម្មសិទ្ធិ

**មាត្រា៦៣**

ការផ្ទេរកម្មសិទ្ធិអចលនវត្ថុរវាងបុគ្គលឯកជនតាមរយៈការលក់ ការដូរ ការធ្វើអំណោយ ឬតាមរយៈសន្តតិកម្មត្រូវអនុវត្តតាមបញ្ញត្តិនៃច្បាប់។

### ផ្នែកទី១ អំពីលទ្ធកម្មដោយការលក់អចលនវត្ថុ

**មាត្រា៦៤**

ការលក់អចលនវត្ថុ គឺជាកិច្ចសន្យាដែលអនុញ្ញាតឱ្យផ្ទេរសិទ្ធិជាកម្មសិទ្ធិនៃអចលនវត្ថុពីអ្នកលក់ទៅឱ្យអ្នកទិញ ដោយអ្នកទិញត្រូវបង់ប្រាក់ថ្លៃអចលនវត្ថុនោះទៅឱ្យអ្នកលក់។

**មាត្រា៦៥**

ការផ្ទេរកម្មសិទ្ធិ មិនអាចជំទាស់ពីតតិយជនបាន លុះត្រាតែកិច្ចសន្យាលក់អចលនវត្ថុត្រូវបានធ្វើជាលាយលក្ខណ៍អក្សរ តាមទម្រង់លិខិតយថាភូត ធ្វើដោយអាជ្ញាធរមានសមត្ថកិច្ច ហើយត្រូវបានចុះបញ្ជីនៅអង្គភាពសុរិយោដី។

កិច្ចសន្យាលក់តែឯកឯង មិនអាចចាត់ទុកជាការផ្ទេរកម្មសិទ្ធិទ្រព្យនោះពេញលក្ខណៈច្បាប់បានឡើយ ។

**មាត្រា៦៦**

បុគ្គលដែលមានសញ្ជាតិខ្មែរ និងមានសមត្ថភាពចុះកិច្ចសន្យា អាចលក់ ឬទិញទ្រព្យជាអចលនវត្ថុបាន ។

បុគ្គលដែលមិនអាចលក់បានគឺ៖

-បុគ្គលដែលមិនមែនជាកម្មសិទ្ធិករនៃទ្រព្យដែលត្រូវលក់

-កម្មសិទ្ធិករនៃទ្រព្យអវិភាគ ដោយគ្មានការយល់ព្រមពីកម្មសិទ្ធិករអវិភាគដទៃទៀត

-បុគ្គលដែលមានអចលនវត្ថុជាកម្មវត្ថុនៃការរឹបអូស ។

បុគ្គលដែលមិនអាចទិញបានគឺ ៖

-អាណាព្យាបាលមិនអាចទិញទ្រព្យរបស់បាលិតខ្លួន

-ហិតូបត្ថម្ភកៈមិនអាចទិញទ្រព្យដែលខ្លួនគ្រប់គ្រង

-ចៅក្រម ឬភ្នាក់ងាររដ្ឋបាលមិនអាចទិញទ្រព្យដែលយុត្តាធិការរបស់ខ្លួន ឬដែលខ្លួនមានបេសកកម្មលក់

-បុគ្គលដែលមានទ្រព្យត្រូវរឹបអូសមិនអាចទិញទ្រព្យនោះវិញបានទេ ។

**មាត្រា៦៧**

ការលក់រវាងសហព័ទ្ធត្រូវទុកជាមោឃៈ ។

**មាត្រា៦៨**

អ្នកលក់ត្រូវធានាជាមួយអ្នកទិញក្នុងកិច្ចសន្យា ចំពោះអចលនវត្ថុដែលលក់នូវវាល់វិការៈ អាថិកំបាំងសំខាន់ៗ បើពុំនោះទេនាំឱ្យមានកតិកាភេទនៃការលក់ ។

**មាត្រា៦៩**

ការផ្ទេរកម្មសិទ្ធិត្រូវបានចាត់ទុកជាសម្រេច ចាប់ពីពេលដែលបានចុះបញ្ជីកិច្ចសន្យានោះនៅអង្គភាពសុរិយោដី ។ ថ្លៃលក់ត្រូវតែចុះក្នុងកិច្ចសន្យាលក់ បើមិនដូច្នោះទេ កិច្ចសន្យាលក់នោះត្រូវទុកជាមោឃៈ ។

កិច្ចសន្យាលក់អចលនវត្ថុនឹងអាចចុះបញ្ជីបាន លុះត្រាតែភាគីទាំងអស់បានបង្ហាញភស្តុតាងថា រាល់ពន្ធដារលើទ្រព្យនោះត្រូវបានបង់រួច ។

## ផ្នែកទី២ អំពីលទ្ធកម្មដោយការដូរអចលនវត្ថុ

**មាត្រា៧០**

ការដូរអចលនវត្ថុគឺជាកិច្ចសន្យាដែលភាគីទាំងសងខាង ព្រមព្រៀងឱ្យអចលនវត្ថុគ្នាទៅវិញទៅមក ។

ការដូរអចលនវត្ថុអនុញ្ញាតឱ្យផ្ទេរកម្មសិទ្ធិនៃទ្រព្យជាអចលនវត្ថុបាន ។

ការដូរនេះត្រូវមានល័ក្ខខ័ណ្ឌដូចគ្នានឹងការលក់ដែរ ។

## ផ្នែកទី៣ អំពីលទ្ធកម្មដោយសន្តតិកម្ម

**មាត្រា៧១**

អាចផ្ទេរតាមរយៈសន្តតិកម្មឥតបណ្តាំ សន្តតិកម្មមានបណ្តាំ ឬអច្ច័យទាននូវ៖

-ទ្រព្យជាអចលនវត្ថុដែលប័ណ្ណកម្មសិទ្ធិត្រូវបានរៀបចំជាស្ថាពរស្របតាមបញ្ញត្តិទាំងឡាយនៃច្បាប់នេះ

-ភោគៈទាំងឡាយស្របតាមច្បាប់ ដោយយោងទៅលើប័ណ្ណ ឬឯកសារគតិយុត្ត ឬភស្តុតាងផ្សេងៗទៀត

-រាល់អវយវភេទនៃកម្មសិទ្ធិ និងរាល់សិទ្ធិភណ្ឌិកអចលនវត្ថុ ។

**មាត្រា៧២**

ក្នុងករណីសន្តតិកម្ម ការគិតរយៈពេលចាំបាច់នៃការកាន់កាប់អចលនវត្ថុ សម្រាប់លទ្ធកម្មកម្មសិទ្ធិពេញលេញដូចដែលបានបញ្ញត្តក្នុងមាត្រា៣០ និងមាត្រា៣១នៃច្បាប់នេះ ត្រូវរាប់ចាប់ពីពេលដែលខ្មោចបានចូលកាន់កាប់ទ្រព្យនោះ ។

**មាត្រា៧៣**

ទ្រព្យជាអចលនវត្ថុដែលគ្រាន់តែកាន់កាប់ដោយជាក់ស្តែង ហើយមិនទាន់បានចុះបញ្ជី ឬបញ្ជាក់ដោយលិខិតរដ្ឋបាល ប៉ុន្តែត្រូវបានកាន់កាប់ស្របតាមល័ក្ខខ័ណ្ឌនៃច្បាប់ ក៏អាចជាកម្មវត្ថុនៃការផ្ទេរតាមសន្តតិកម្មបានដែរ ។

**មាត្រា៧៤**

ក្នុងករណីទ្រព្យកាន់កាប់គ្មានប័ណ្ណត្រូវបានផ្ទេរតាមរយៈសន្តតិកម្ម ទាយាទដែលជាអ្នកកាន់កាប់ថ្មីអាចបន្តចាត់ចែងទ្រព្យនោះ និងទទួលបាននូវកិច្ចការពារ ដោយហេតុថាស្ថានភាពរបស់ខ្លួនឆ្លើយតបទៅនឹងល័ក្ខខ័ណ្ឌនៃច្បាប់ ។

ក្នុងករណីនេះ អាជ្ញាធរមានសមត្ថកិច្ច ឬជនណាក៏ដោយ មិនអាចយកលេសពីស្ថានភាពនៃការកាន់កាប់ជាក់ស្តែងរបស់ខ្មោច ឬយកលេសពីខ្វះនូវការជម្រះមតិកត្រឹមត្រូវដើម្បីធ្វើឱ្យប៉ះពាល់សិទ្ធិនៃទាយាទ និងជាពិសេសដើម្បីបដិសេធការទទួលស្គាល់ ឬមិនបញ្ជាក់ការកាន់កាប់របស់គេបានឡើយ ។

**មាត្រា៧៥**

កាលបើអចលនវត្ថុជាមតិកប្រើប្រាស់សម្រាប់ជាលំនៅឋាននៃគ្រួសាររបស់ខ្មោច ឬដីប្រើប្រាស់សម្រាប់ការផ្គត់ផ្គង់ជីវភាពដោយផ្ទាល់ ទាយាទមិនអាចស្នើសុំបែងចែក ឬសម្រេចលក់ទ្រព្យនោះទេ លើកលែងតែមានការយល់ព្រមដោយច្បាស់ពីសហទាយាទទាំងអស់ ។ ក្នុងករណីមានការជំទាស់អំពីការបែងចែកមតិក សហទាយាទមានសិទ្ធិប្តឹងទៅតុលាការដើម្បីសុំឱ្យដោះស្រាយទំនាស់នេះ ។

ការលក់ចំណែកសិទ្ធិរបស់សហទាយាទណាម្នាក់ត្រូវទុកជាមោឃៈ ប្រសិនបើគ្មានការយល់ព្រមច្បាស់លាស់ពីសហទាយាទទាំងអស់ ។ ម្យ៉ាងទៀត ចំពោះសហទាយាទដែលបានលក់ចំណែកសិទ្ធិរបស់ខ្លួននេះ ត្រូវបាត់បង់សិទ្ធិនៃសន្តតិកម្មលើទ្រព្យដែលបានលក់ ។ សហទាយាទណាម្នាក់ដែលបានបំពានការហាមលក់មតិកនេះ ត្រូវទទួលខុសត្រូវតែម្នាក់ឯងលើអំពើរបស់ខ្លួនចំពោះអ្នកទិញ ។

**មាត្រា៧៦**

ទាយាទទាំងឡាយដែលមិនអាចបន្តនិរន្តរភាពនៃការកាន់កាប់ទ្រព្យជាមតិកបាន ដោយជាក់ស្តែង ឬដោយគតិយុត្ត ឬមិនចង់ទទួលបន្ទុកដោយខ្លួនឯង អាចធ្វើការផ្ទេរដោយប្រគល់សិទ្ធិឱ្យតតិយជនបាន ។

**មាត្រា៧៧**

បើអ្នកទទួលសម្បទានដីឆ្លើយតបទៅនឹងប្រយោជន៍សេដ្ឋកិច្ច មិនមែនជាក្រុមហ៊ុន ហើយមានប័ណ្ណអចលនវត្ថុកាន់កាប់ដោយរូបវន្តបុគ្គលម្នាក់ដែលទទួលមរណភាព សម្បទាននេះមិនអាចជាកម្មវត្ថុនៃការបែងចែក ដោយគ្មានការយល់ព្រមពីអាជ្ញាធររដ្ឋបាលដែលបានផ្តល់សម្បទានបានឡើយ ។

**មាត្រា៧៨**

ទ្រព្យទាំងឡាយដែលកម្មសិទ្ធិករស្លាប់ដោយគ្មានបន្សល់ទុកនូវទាយាទ ឬអច្ច័យលាភី ត្រូវត្រលប់មកជារបស់រដ្ឋ ហើយត្រូវបញ្ចូលក្នុងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។

**មាត្រា៧៩**

ការចាត់ចែងមតិកត្រូវឋិតនៅក្រោមវិធានទាំងឡាយនៃទម្លាប់ប្រពៃណីក្នុងរឿងនេះ ក្នុងពេលរង់ចាំការប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណីថ្មី ។

*វាយឡើងវិញ*

### ផ្នែកទី៤ អំពីលទ្ធកម្មដោយប្រទានកម្ម

**មាត្រា៨០**

ប្រទានកម្ម គឺជាកិច្ចសន្យាដែលជនម្នាក់ហៅថាអ្នកឱ្យ ឬទាយក ផ្ទេរនូវកម្មសិទ្ធិនៃទ្រព្យរបស់ខ្លួន ឱ្យទៅជនម្នាក់ទៀតហៅថាអ្នកទទួល ឬបដិគាហក ដែលព្រមទទួលយកទ្រព្យនោះ។

**មាត្រា៨១**

ប្រទានកម្មអចលនវត្ថុមិនអាចត្រូវបានជំទាស់ពីតតិយជនបាន លុះត្រាតែប្រទានកម្មនោះត្រូវបានធ្វើជាលាយលក្ខណ៍អក្សរតាមទម្រង់លិខិតយថាភូត ហើយត្រូវបានចុះបញ្ជីនៅអង្គភាពសុរិយោដី។

**មាត្រា៨២**

អចលនវត្ថុ អាចជាកម្មវត្ថុនៃប្រទានកម្មរវាងអ្នកនៅរស់ ឬប្រទានកម្មដោយហេតុមរណៈ ឬអច្ច័យទាន។ ប្រសិនបើជាប្រទានកម្មទៅវិញទៅមក ប្រតិបត្តិការនេះបង្កើតបានជាការប្តូរ។

**មាត្រា៨៣**

រដ្ឋអាចធ្វើអំណោយជាអចលនវត្ថុចំពោះតែរូបវន្តបុគ្គល ដោយហេតុផលសង្គមកិច្ច ដើម្បីឱ្យស្នាក់នៅ ឬដាំដំណាំចិញ្ចឹមជីវិត។ តម្លៃអចលនវត្ថុដែលផ្តល់ឱ្យត្រូវបានកំណត់សមស្របទៅនឹងគោលដៅណាមួយដែលចង់បាន និងមិនអនុញ្ញាតឱ្យកេងយកកម្រៃ ឬធ្វើមានបានមិនសមស្របទៅនឹងកម្រិតជីវភាពសង្គមនៃអ្នកទទួល។

ប្រទានកម្មដែលរដ្ឋបានធ្វើពីមុនមកហើយ មិនអាចសើរើបានឡើយ។

**មាត្រា៨៤**

ប្រទានកម្មទ្រព្យជាអចលនវត្ថុមិនអាចដកហូតមកវិញបានឡើយ នៅពេលដែលមានការព្រមទទួលហើយនោះ។ ប្រទានកម្មនេះអាចធ្វើការផ្ទេរសិទ្ធិកម្មសិទ្ធិបានភ្លាម។ ប៉ុន្តែទាយកអាចរក្សាទុកសម្រាប់ខ្លួននូវសិទ្ធិផលុបភោគនៃទ្រព្យ សិទ្ធិប្រើប្រាស់និងអាស្រ័យនៅនៃអចលនវត្ថុដែលត្រូវចែងក្នុងកិច្ចសន្យា និងត្រូវចុះបញ្ជីនៅអង្គភាពសុរិយោដី។

## មាតិកាទី៣ អំពីរបបកម្មសិទ្ធិឯកជន

## ជំពូកទី៧ អំពីសិទ្ធិ និងកាតព្វកិច្ចនៃកម្មសិទ្ធិករ

### ផ្នែកទី១ អំពីការអាស្រ័យផលនៃកម្មសិទ្ធិ

**មាត្រា៨៥**

កម្មសិទ្ធិករនៃទ្រព្យជាអចលនវត្ថុមានសិទ្ធិប្រើប្រាស់ អាស្រ័យផល និងចាត់ចែងទ្រព្យរបស់ខ្លួនផ្ដាច់មុខ និងទូលំទូលាយ កុំឱ្យតែយកទ្រព្យនោះទៅប្រើប្រាស់ក្នុងបទណាមួយដែលច្បាប់បានហាមឃាត់។

**មាត្រា៨៦**

កម្មសិទ្ធិករនៃទ្រព្យមិនអាចប្រើប្រាស់ទ្រព្យនោះ ក្នុងគោលដៅព្យាបាទ ឬរំខានដល់តតិយជន និងជាពិសេសដល់អ្នកជិតខាងរបស់ខ្លួនបានឡើយ។

ការប្រើប្រាស់ទ្រព្យជាធម្មតាដែលមានចរិតធម្មានុរូប មិនអាចចាត់ទុកជាការរំខាន ដែលបណ្ដាលឱ្យរាំងស្ទះដល់ការប្រើប្រាស់ទ្រព្យនោះបានឡើយ។

**មាត្រា៨៧**

កម្មសិទ្ធិករនៃដីអាចធ្វើនៅលើដី នូវរាល់ការដាំដុះ ការរៀបចំ និងការសាងសង់តាមបំណងរបស់ខ្លួន លើកលែងតែមានច្បាប់ហាមឃាត់។ ការរៀបចំ ឬការសាងសង់ទាំងនោះជាកម្មសិទ្ធិរបស់ខ្លួនទាំងអស់ស្របតាមបញ្ញត្តិនៃផ្នែកទី៣នៃជំពូកនេះ។

**មាត្រា៨៨**

កម្មសិទ្ធិករនៃទ្រព្យជាអចលនវត្ថុអាចរៀបចំ ឬកែប្រែបានដោយសេរីនូវប្រភេទ និងរចនាសម្ព័ន្ធដើមនៃទ្រព្យរបស់ខ្លួន ស្របតាមការប្រើប្រាស់ដែលខ្លួនចង់ធ្វើ តាមការកំណត់នៃច្បាប់។

**មាត្រា៨៩**

ចាត់ទុកជាការកែប្រែប្រភេទ ឬរចនាសម្ព័ន្ធដើមនៃទ្រព្យជាអចលនវត្ថុ ក្នុងន័យនៃច្បាប់នេះ មានជាអាទិ៍ការគាស់រានដី ការកាប់ព្រៃឈើ ការដាំដំណាំលើដីនោះ ការចាក់បំពេញដី ការឈូសពង្រាបភ្នំ ការជីករុករក ការជីកយកដីចេញ ការជីកអណ្ដូងរ៉ែ ឬកន្លែងយកថ្ម ការរៀបចំ ឬការធ្វើឱ្យស្ងួតដែនវារីជាតិ ការរៀបចំដីកសិកម្មទៅជាទីប្រជុំជន ការបង្កើតតំបន់ឧស្សាហកម្ម និងការបង្កើតទីតាំងរោងចក្រ។

**មាត្រា៩០**

កម្មសិទ្ធិករនៃផ្ទៃដីគឺជាកម្មសិទ្ធិករនៃផ្នែកក្រោមដី និងរាល់អ្វីៗដែលអាចទាញយកផលបាន កុំឱ្យតែផ្ទុយនឹងបញ្ញត្តិនៃមាត្រា៨៨ និងមាត្រា៨៩នៃច្បាប់នេះ។ ព្រំប្រទល់នៃផ្នែកខាងក្រោមដី ត្រូវបានកំណត់តាមបន្ទាត់ឈរនៃផ្ទៃរាបខាងលើ។

ប៉ុន្តែកម្មសិទ្ធិករមិនអាចទាមទារយកជាកម្មសិទ្ធិនូវបដិមាករ ចម្លាក់ក្រឡោត ឬបុរាណវត្ថុគ្រប់ប្រភេទដែលបានរកឃើញ។ ស្នាដៃទាំងនេះជាចំណែកនៃបេតិកភណ្ឌជាតិ ហើយត្រូវតែប្រគល់ឱ្យក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

**មាត្រា៩១**

កម្មសិទ្ធិករនៃផ្ទៃដីក៏ជាកម្មសិទ្ធិករនៃលំហអាកាស និងវត្ថុធាតុអចិន្ត្រៃយ៍ដែលឋិតនៅចំពីលើដីជាកម្មសិទ្ធិរបស់ខ្លួន លើកលែងតែបណ្ដាញខ្សែអគ្គិសនី និងទូរគមនាគមន៍ដែលត្រូវអនុវត្តតាមច្បាប់ដោយឡែក។ ជាពិសេស កម្មសិទ្ធិករអាចកាប់មែកឈើអ្នកជិតខាងដែលលយចូលមកលើកម្មសិទ្ធិរបស់ខ្លួន ឬបេះយកផលផ្លែឈើនោះបាន។

ប៉ុន្តែកម្មសិទ្ធិករមិនអាចហាមឃាត់ការហោះហើរដោយអាកាសយានគ្រប់ប្រភេទបានឡើយ។

**មាត្រា៩២**

កម្មសិទ្ធិករនៃទ្រព្យជាអចលនវត្ថុអាចបង្កើតបានជាប្រាតិភោគនៃកិច្ចសន្យា ស្របតាមបញ្ញត្តិដែលបានកំណត់ក្នុងមាតិកាទី៥នៃច្បាប់នេះ។

**មាត្រា៩៣**

កម្មសិទ្ធិករនៃទ្រព្យអាចចាត់ចែងផលិតផល និងការកើនឡើងតាមធម្មជាតិ ឬតាមសិប្បនិមិត្តដែលផ្សំគ្នា ឬដែលជាប់ជាមួយនឹងទ្រព្យនោះ តាមវិធានដែលបានកំណត់ក្នុងផ្នែកទី២ និងទី៣នៃជំពូកនេះ។

## ផ្នែកទី២ អំពីឧបាគមន៍ផលិតផល និងផលទុននៃកម្មសិទ្ធិ

**មាត្រា៩៤**

កម្មសិទ្ធិករនៃទ្រព្យជាអចលនវត្ថុ មានសិទ្ធិទទួលផលគ្រប់បែបយ៉ាងពីទ្រព្យនោះ មានផលធម្មជាតិ និងផលស៊ីវិលតាមសិទ្ធិឧបាគមន៍។

ផលធម្មជាតិគឺផលដែលកើតពីដីដោយឯកឯង ឬដោយអំពើរបស់មនុស្ស។

ផលស៊ីវិលគឺផលទុន ធនលាភ និងការប្រាក់។

**មាត្រា៩៥**

ផលដែលកើតចេញពីដំណាំលើទ្រព្យជាដី ជារបស់កម្មសិទ្ធិករនៃទ្រព្យនោះ លុះត្រាតែកម្មសិទ្ធិករនោះបានសងតម្លៃនៃការភ្ជួររាស់ ពលកម្ម និងពូជដែលបានធ្វើជាយថាហេតុដោយតតិយជន។

*វាយឡើងវិញ*

## ផ្នែកទី៣ អំពីការកើននៃកម្មសិទ្ធិ

## អនុផ្នែកទី១ អំពីការកើនដោយអំពើរបស់មនុស្ស

**មាត្រា៩៦**

សំណង់ ដំណាំ និងការងារទាំងឡាយដែលបានធ្វើនៅលើដី ឬនៅក្រោមដី ត្រូវបានចាត់ទុកថាត្រូវបានធ្វើដោយកម្មសិទ្ធិករ ដោយសោហ៊ុយផ្ទាល់ខ្លួន ហើយជារបស់កម្មសិទ្ធិករនោះ លើកលែងតែមានភស្តុតាងផ្ទុយពីនេះ។

**មាត្រា៩៧**

កម្មសិទ្ធិករនៃដីដែលបានធ្វើការសាងសង់ ដាំដុះ ឬរៀបចំដោយប្រើសម្ភារៈដែលមិនមែនជារបស់ខ្លួន ត្រូវចេញថ្លៃសម្ភារៈទាំងនោះឱ្យម្ចាស់គេវិញ។ កម្មសិទ្ធិករនោះ អាចត្រូវផ្តន្ទាទោសឱ្យសងជំងឺចិត្តផងដែរ ប្រសិនជាមាន ប៉ុន្តែម្ចាស់សម្ភារៈគ្មានសិទ្ធិដកយកសម្ភារៈនោះចេញឡើយ។

**មាត្រា៩៨**

កាលបើដំណាំ សំណង់ និងការរៀបចំទាំងឡាយត្រូវបានធ្វើឡើងដោយបំពានពីតតិយជន និងដោយសម្ភារៈរបស់ខ្លួន កម្មសិទ្ធិករនៃដីមានសិទ្ធិរក្សាទុករបស់ទាំងនោះ ឬបង្ខំឱ្យតតិយជននោះដកយកចេញបាន។

ប្រសិនជាកម្មសិទ្ធិករនៃដីសុំឱ្យដកចេញនូវដំណាំ និងសំណង់ដែលបានធ្វើដោយបំពាន សោហ៊ុយនៃការដកចេញជាបន្ទុករបស់តតិយជន ហើយគ្មានសំណងណាមួយសម្រាប់អ្នកនោះទេ។ តតិយជននោះក៏អាចត្រូវផ្តន្ទាទោសឱ្យសងជំងឺចិត្តផងដែរ ប្រសិនបើមានព្យសនកម្មជាយថាហេតុដល់កម្មសិទ្ធិករនៃដី។ ប្រសិនបើកម្មសិទ្ធិករចង់រក្សាទុកដំណាំ និងការងារទាំងនោះ កម្មសិទ្ធិករត្រូវសងថ្លៃសម្ភារៈ និងថ្លៃការងារដោយមិនគិតដល់តម្លៃលើស តិច ឬច្រើនដែលដីអាចនឹងកើនតម្លៃនោះទេ។

ចំពោះដំណាំ សំណង់ ឬការងារទាំងឡាយណាដែលបានធ្វើដោយតតិយជនដោយសុចរិតដូចមានចែងក្នុងមាត្រា៣៨នៃច្បាប់នេះ កម្មសិទ្ធិករមិនអាចសុំដកយកចេញនូវការងារ ដំណាំ ឬការរៀបចំទាំងនោះបានឡើយ។ កម្មសិទ្ធិករមានជម្រើសពីរ ឬមួយសងថ្លៃសម្ភារៈ និងថ្លៃពលកម្ម ឬមួយសងជាទឹកប្រាក់ ស្មើនឹងតម្លៃលើសដែលដីបានកើនតម្លៃក៏បាន។

## អនុផ្នែកទី២ អំពីការកើនដោយធម្មជាតិ

**មាត្រា៩៩**

ដីដុះដែលកើនឡើងជាបន្តបន្ទាប់ បន្តិចម្តងៗលើដីជាប់មាត់ទន្លេ ឬស្ទឹង ព្រែកហៅថាល្បាប់។

ល្បាប់ត្រូវបានជាប្រយោជន៍ដល់កម្មសិទ្ធិករដែលមានដីជាប់មាត់ទឹកដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបាន ឬមិនបាន។ ក្នុងករណីនាវា ឬក្បូនចេញចូលបាន បណ្តែតបាន កម្មសិទ្ធិករត្រូវទុកផ្លូវសម្រាប់ទាញពួរនាវាស្របទៅតាមបទបញ្ញាទាំងឡាយ។

**មាត្រា១០០**

ចំពោះដីដែលកើនឡើងដោយសារចរន្តទឹកហូរនាំល្បាប់បន្តិចម្តងៗ មើលមិនដឹងពីច្រាំងម្ខាង ទៅគរនៅច្រាំងម្ខាងទៀត ជាប់ជាមួយនឹងដីអ្នកផ្សេង កម្មសិទ្ធិករនៃដីដែលជាប់នឹងដីដុះនោះទទួលបានគុណប្រយោជន៍នៃល្បាប់នេះ ដោយមិនអាចឱ្យអ្នកមានដីនៅច្រាំងម្ខាងដែលបាត់ដី មកតវ៉ាយកដីដែលបាត់នោះឡើយ។

**មាត្រា១០១**

ប្រសិនជាទន្លេ ឬស្ទឹង ព្រែកដែលនាវាចេញចូលបាន ឬមិនបាន នាំយកចេញដោយកម្លាំងទឹកជំនន់ភ្លាមៗនូវចំណែកដីដ៏ធំ និងអាចស្គាល់បាន ពីច្រាំងម្ខាង ទៅភ្ជាប់នឹងដីខាងក្រោមខ្សែទឹក ឬនឹងច្រាំងម្ខាងទៀត កម្មសិទ្ធិករនៃដីដែលបាក់ចេញ អាចតវ៉ាយកជាកម្មសិទ្ធិរបស់ខ្លួនវិញបាន តែត្រូវដាក់ពាក្យប្តឹងទារក្នុងរយៈពេលយ៉ាងយូរ១ (មួយ) ឆ្នាំ គិតពីថ្ងៃកើតឡើងនូវព្រឹត្តិការណ៍នោះ បើហួសរយៈពេលនេះ បណ្តឹងទាមទារមិនត្រូវបានទទួលយកមកដោះស្រាយឡើយ លើកលែងតែកម្មសិទ្ធិករនៃដីដែលមានដីបាក់ទៅភ្ជាប់នោះ មិនទាន់បានកាន់កាប់នៅឡើយ។

**មាត្រា១០២**

កោះធំ កោះតូច និងដីដុះទាំងឡាយដែលនឹងកកើតថ្មីក្នុងផ្ទៃទន្លេ ឬស្ទឹង ព្រែកដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបានជារបស់រដ្ឋ។

**មាត្រា១០៣**

កោះធំ កោះតូច និងដីដុះទាំងឡាយដែលនឹងកកើតថ្មី ក្នុងស្ទឹង ព្រែកដែលនាវា ឬក្បូនចេញចូលមិនបាន បណ្តែតមិនបាន ត្រូវបានមកកម្មសិទ្ធិករនៃដីជាប់ច្រាំងដែលមានកោះ ឬដីដុះនោះ។ ប្រសិនបើការដុះនោះមិនបានដុះជ្រុលទៅច្រាំងម្ខាងទេនោះ ត្រូវបានទៅកម្មសិទ្ធិករដែលមានដីជាប់ច្រាំងទាំង សងខាង គិតពីបន្ទាត់ពុះពាក់កណ្តាលស្ទឹង។

**មាត្រា១០៤**

ប្រសិនបើស្ទឹង ព្រែក ឬទន្លេ បង្កើតជាផ្លូវទឹកថ្មីមួយកាត់យកដីកម្មសិទ្ធិអ្នកនៅជាប់មាត់ទឹកណាម្នាក់ ហើយបង្កើតបានជាកោះមួយ កម្មសិទ្ធិករនោះរក្សាបានសិទ្ធិជាកម្មសិទ្ធិនៃដីរបស់ខ្លួនដែលដាច់នោះដដែល ទោះបីជាកោះនោះដុះក្នុងទន្លេ ឬស្ទឹង ព្រែកដែលនាវា ឬក្បូនចេញចូលបាន បណ្ដែតបានក៏ដោយ។

**មាត្រា១០៥**

ប្រសិនជាទន្លេ ឬស្ទឹង ព្រែកណាមួយដែលនាវា ឬក្បូនចេញចូលបាន បណ្ដែតបានបង្កើតជាផ្លូវទឹកថ្មីមួយដោយបោះបង់ចោលផ្លូវទឹកចាស់ កម្មសិទ្ធិករដែលមានដីជាប់ច្រាំងនោះ អាចធ្វើលទ្ធកម្មកម្មសិទ្ធិក្នុងផ្ទៃទន្លេ ឬស្ទឹង ព្រែកចាស់ដែលគោកនោះបាន ហើយម្នាក់ៗត្រូវបានសិទ្ធិរបស់ខ្លួនរហូតដល់ខ្សែបន្ទាត់ដែលពុះពាក់កណ្ដាលទន្លេ ឬស្ទឹង ព្រែកនោះ។ ថ្លៃដីនៃផ្លូវទឹកចាស់នោះ ត្រូវបានកំណត់ដោយអ្នកជំនាញដែលតែងតាំងដោយតុលាការខេត្ត-ក្រុងទីនោះ តាមពាក្យស្នើសុំពីអាជ្ញាធរខេត្ត-ក្រុង ឬពីភាគីដែលមានប្រយោជន៍ក្នុងរឿងនេះ។

បើកម្មសិទ្ធិករនៅមាត់ទឹកនោះមិនចង់បានដីនោះតាមថ្លៃដែលអ្នកជំនាញកំណត់ទេ អាជ្ញាធរត្រូវលក់ឡាយឡុងផ្លូវទឹកចាស់នោះឱ្យសាធារណជន។ ថ្លៃដែលបានមកពីការលក់ដីនោះ ត្រូវយកទៅចែកឱ្យកម្មសិទ្ធិករដែលមានដីដាច់ទៅនោះតាមសមាមាត្រនៃដីដែលខូចខាតរៀងៗខ្លួន។

## ផ្នែកទី៤ អំពីការជួលអចលនវត្ថុ

**មាត្រា១០៦**

កម្មសិទ្ធិករនៃទ្រព្យជាអចលនវត្ថុអាចជួលទ្រព្យរបស់ខ្លួនឱ្យអ្នកដទៃបាន។ ការជួលជាកិច្ចសន្យា ដែលកម្មសិទ្ធិករនៃទ្រព្យមួយប្រគល់ទ្រព្យនោះឱ្យជនណាម្នាក់ប្រើប្រាស់ក្នុងរយៈពេលមួយ ដោយយកជាប្រាក់ឈ្នួលមកវិញយ៉ាងទៀងទាត់ តាមសមាមាត្រនៃរយៈពេលប្រើប្រាស់។ កិច្ចសន្យានៃការជួលអចលនវត្ថុហៅថាភតិសន្យា។

កិច្ចសន្យាជួលអចលនវត្ថុមានពីរយ៉ាងគឺ ការជួលរយៈពេលមិនកំណត់ និងការជួលរយៈពេលកំណត់។ ការជួលរយៈពេលកំណត់ មានការជួលរយៈពេលខ្លីអាចបន្តជាថ្មីបាន និងការជួលរយៈពេលវែង១៥ (ដប់ប្រាំ) ឆ្នាំ ឬលើស។

**មាត្រា១០៧**

កិច្ចសន្យាជួលរយៈពេលមិនកំណត់ ឬរយៈពេលខ្លី ហើយអាចជួលជាថ្មីបាន បង្កើតបានជាទំនាក់ទំនងផ្ទាល់ខ្លួនរវាងភតិសន្យាបតី និងអ្នកជួល។

ការជួលបន្តឱ្យតតិយជនអាចធ្វើទៅបាន លុះត្រាតែមានការព្រមព្រៀងដោយជាក់លាក់ ឬការអនុញ្ញាតពីកម្មសិទ្ធិករ ។

**មាត្រា១០៨**

កិច្ចសន្យាជួលរយៈពេលវែងបង្កើតបានជាសិទ្ធិភណ្ឌិកលើអចលនវត្ថុ។ សិទ្ធិនេះអាចត្រូវបានប្រគល់ឱ្យដោយមានថ្លៃ ឬផ្ទេរបន្តតាមរយៈសន្តតិកម្ម ។

ទ្រព្យដែលបានជួលរយៈពេលវែងអាចជាកម្មវត្ថុនៃការរៀបចំ និងការបំប្លែង កុំឱ្យតែការងារនោះមានអានុភាពបំផ្លាញ ឬបំប្លែងជាសារវន្តនូវសភាពដើមនៃវត្ថុនោះ លើកលែងតែមានករណីមានចែងដោយឡែកក្នុងភតិសន្យា ។

នៅពេលផុតកំណត់នៃការជួល ភតិសន្យាបតី ឬទាយាទទាំងឡាយរបស់ជននេះទទួលបានមកវិញនូវកម្មសិទ្ធិពេញលេញនៃសំណង់ ដោយគ្មានការសងសោហ៊ុយក្នុងការរៀបចំ ឬការកែលំអទាំងឡាយ ដែលបានធ្វើដោយអ្នកជួល ។ ភតិសន្យាបតី ឬទាយាទ មិនអាចបង្ខំអ្នកជួល ឱ្យប្រគល់អចលនវត្ថុ តាមស្ថានភាពដើមបានឡើយ បើសិនជាអ្នកជួលគោរពបទប្បញ្ញត្តិនៃវាក្យខណ្ឌ ២នៃមាត្រានេះ ។

**មាត្រា១០៩**

ភតិសន្យាត្រូវធ្វើឡើងតាមឆន្ទៈនៃបណ្ដាភាគី និងតាមបញ្ញត្តិនៃច្បាប់ ឬបទបញ្ជាទូទៅជាធរមាន ។

ភតិសន្យាត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ ។ ភតិសន្យាធ្វើឡើងដោយផ្ទាល់មាត់ត្រូវទុកជាបណ្ដោះអាសន្ន ហើយអាចត្រូវបានបញ្ឈប់នៅគ្រប់ពេលដោយជូនដំណឹងជាមុន ក្នុងរយៈពេលស្មើនឹងរយៈពេលបង់ប្រាក់ឈ្នួល ។

**មាត្រា១១០**

មុនការចូលអាស្រ័យផលលើអចលនវត្ថុ អ្នកជួលត្រូវតែដឹងអំពីស្ថានភាពនៃអចលនវត្ថុ និងសម្ភារៈនៅនឹងកន្លែង ដែលបានរៀបចំតាមការព្រមព្រៀងជាមួយនឹងភតិសន្យាបតី ។ ការមិនបានពិនិត្យស្ថានភាពអចលនវត្ថុ និងសម្ភារៈនៅនឹងកន្លែងនៅពេលចូលអាស្រ័យផល ត្រូវចាត់ទុកថាត្រឹមត្រូវតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងភតិសន្យា ។

ទ្រព្យដែលជួល មិនត្រូវមានវិការៈអាថ៌កំបាំងដែលធ្វើឱ្យការប្រើប្រាស់ មិនអាចប្រព្រឹត្តទៅបានតាមធម្មតាឡើយ ។

**មាត្រា១១១**

អ្នកជួលត្រូវថែទាំទ្រព្យជាធម្មតា និងត្រូវសងមកវិញក្នុងស្ថានភាពមួយស្រប តាមស្ថានភាពនៃអចលនវត្ថុ និងសម្ភារៈនៅនឹងកន្លែង នៅពេលផុតកំណត់នៃកិច្ចសន្យាជួល ដោយគិតទាំងតម្លៃនៃការខូចខាតដែលកើតពីការប្រើប្រាស់មិនធម្មតា លើកលែងករណីមានចែងដោយឡែកក្នុងភតិសន្យា ។

**មាត្រា១១២**

ភតិសន្យាបតីមិនត្រូវធ្វើសកម្មភាព ឬតិរិយាបទអ្វីដែលអាចឱ្យបង្អាក់ ឬរំខានដល់ការអាស្រ័យផលរបស់អ្នកជួលផ្ទុយពីភតិសន្យាឡើយ ។

**មាត្រា១១៣**

បែបបទនៃកិច្ចសន្យាជួលអចលនវត្ថុដើម្បីប្រើប្រាស់សម្រាប់ស្នាក់នៅ សម្រាប់ពាណិជ្ជកម្ម សម្រាប់ឧស្សាហកម្ម និងសម្រាប់កសិកម្មត្រូវកំណត់ដោយអនុក្រឹត្យ ។

## ផ្នែកទី៥ អំពីវិធានដី

**មាត្រា១១៤**

សិទ្ធិ និងកាតព្វកិច្ចនៃកម្មសិទ្ធិករត្រូវបានកម្រិតដោយវិធានដីទាំងឡាយ សំដៅធានាការពារផលប្រយោជន៍ទូទៅដែលកំណត់ដោយច្បាប់ ។

**មាត្រា១១៥**

បែបបទសំណង់ និងល័ក្ខខ័ណ្ឌទាំងឡាយនៃការរៀបចំដែនដី និងនគរូបនីយកម្ម ចំពោះកម្មសិទ្ធិករនឹងកំណត់ដោយអនុក្រឹត្យ ។

**មាត្រា១១៦**

ការប្រើប្រាស់កម្មសិទ្ធិដែលមិនស្របតាមវិធានដី តែជាប់កិច្ចសន្យាមុនការប្រកាសឱ្យប្រើច្បាប់នេះមិនអាចប៉ះពាល់បានឡើយ ។ ប៉ុន្តែការប្រើប្រាស់នោះមិនអាចពង្រីកថែម នៅក្រោយពេលប្រកាសឱ្យប្រើវិធានដីដែលបានកម្រិត ឬហាមឃាត់បានឡើយ ។

ក្នុងករណីបន្ទាន់ ឬតម្រូវការចាំបាច់នៃផលប្រយោជន៍សាធារណៈ ច្បាប់អាចបញ្ញត្តថែមទៀតនូវការអនុវត្តបន្ទាន់នៃវិធានដី កម្រិតពីការប្រើប្រាស់កម្មសិទ្ធិដែលមានលក្ខណៈជាសណ្តាប់ធ្នាប់សាធារណៈ ។

## ជំពូកទី៨ អំពីអវយវភេទនៃកម្មសិទ្ធិ

**មាត្រា១១៧**

កម្មសិទ្ធិមានអវយវភេទ កាលណាការអាស្រ័យផលបានទៅបុគ្គលក្រៅពីកម្មសិទ្ធិករនៃទ្រព្យ ។ សិទ្ធិដែលនៅសល់សម្រាប់កម្មសិទ្ធិករ ឈ្មោះថាអសារកម្មសិទ្ធិ ។

**មាត្រា១១៨**

រូបភាពនៃអវយវភេទនៃកម្មសិទ្ធិរួមមាន ៖ ផលុបភោគ សិទ្ធិប្រើប្រាស់និងអាស្រ័យនៅ និងសេវភាព ។

### ផ្នែកទី១ អំពីផលុបភោគ

**មាត្រា១១៩**

ផលុបភោគគឺការអាស្រ័យផលនៃអចលនវត្ថុដែលជាកម្មសិទ្ធិរបស់អ្នកដទៃ សម្រាប់រយៈពេលមួយ កំណត់មិនឱ្យលើសពីមួយអាយុជីវិតនៃអ្នកបានសិទ្ធិអាស្រ័យផលនោះឡើយ ។

**មាត្រា១២០**

ផលុបភោគបង្កើតឡើងដោយច្បាប់ ឬដោយការព្រមព្រៀង ។ ផលុបភោគអាចបង្កើតឡើងដោយឥតកំណត់កាលក៏បាន ឬមានកំណត់កាលក៏បាន ឬរហូតដល់បំពេញបានសម្រេចនូវល័ក្ខខ័ណ្ឌដែលបានកំណត់ក៏បាន ។

ប្រសិនបើល័ក្ខខ័ណ្ឌនៃរយៈពេលមិនបានបញ្ជាក់ ផលុបភោគត្រូវបានចាត់ទុកថាបង្កើតឡើង សម្រាប់រយៈពេលមួយអាយុជីវិតនៃអ្នកទទួលសិទ្ធិផលុបភោគ ។

កិច្ចសន្យាផលុបភោគនឹងយកជាការបាន លុះត្រាតែបានធ្វើតាមរូបមន្តយថាភូត ។ កិច្ចសន្យានេះមិនអាចជំទាស់ពីតតិយជនបាន លុះត្រាតែបានចុះបញ្ជីសុរិយោដីរួចហើយ ។

**មាត្រា១២១**

ផលុបភោគីមានសិទ្ធិអាស្រ័យផលគ្រប់ប្រភេទ ជាផលធម្មជាតិ ជាផលស៊ីវិលដែលកើតចេញពីអចលនវត្ថុដែលខ្លួនមានសិទ្ធិ ។

**មាត្រា១២២**

ផលធម្មជាតិដែលជាប់នឹងដី នៅពេលចាប់ផ្តើមផលុបភោគ ត្រូវបានទៅផលុបភោគី ។ ផលធម្មជាតិដែលមានស្ថានភាពដូចគ្នា នៅពេលចប់ផលុបភោគ ត្រូវបានទៅអសារកម្មសិទ្ធិករ

ដោយគ្មានការទូទាត់ទៅវិញទៅមកសម្រាប់ការងារភ្ជួររាស់ ឬច្រូតកាត់ ឬពូជធារអ្វីឡើយ។ ប៉ុន្តែ បើមានអ្នកជួល ឬអ្នកប្រវាស់រួចហើយ នៅពេលចាប់ផ្តើម ឬនៅពេលបញ្ចប់ផលុបភោគ អ្នកជួល ឬអ្នកប្រវាស់នេះ មិនត្រូវបាត់បង់ចំណែកដែលត្រូវបានមកខ្លួននោះទេ។

**មាត្រា១២៣**

ផលស៊ីវិលបានទៅផលុបភោគី តាមសមាមាត្រទៅនឹងរយៈពេលនៃផលុបភោគ។

**មាត្រា១២៤**

ផលុបភោគីអាចអាស្រ័យផលដោយខ្លួនឯងផ្ទាល់នូវផលុបភោគ ឬជួល ឬប្រវាស់ ឬក៏ផ្ទេរសិទ្ធិរបស់ខ្លួនដោយយកថ្លៃ ឬដោយឥតយកថ្លៃ ឱ្យទៅអ្នកដទៃបាន។

ក្នុងករណីជួល ឬប្រវាស់ កិច្ចសន្យាមិនត្រូវកំណត់ឱ្យហួសពី៣ (បី) ឆ្នាំឡើយ។ ប្រសិនបើចង់ជួល ឬប្រវាស់បន្ត កិច្ចសន្យាថ្មីត្រូវបញ្ចប់មុន១ (មួយ) ឆ្នាំនៃថ្ងៃចប់កិច្ចសន្យាផលុបភោគ។

**មាត្រា១២៥**

ផលុបភោគីអាស្រ័យផលពីការកើនដាយថាហេតុដោយល្បាប់ ទៅលើដីដែលខ្លួនមានសិទ្ធិផលុបភោគ។

**មាត្រា១២៦**

ផលុបភោគីប្រើប្រាស់នូវសេវភាពនានា និងសិទ្ធិទាំងឡាយដែលកម្មសិទ្ធិករអាចអាស្រ័យផលបាន លើកលែងតែសិទ្ធិចាត់ចែង។

**មាត្រា១២៧**

ផលុបភោគីប្រើប្រាស់សិទ្ធិតាមរបៀបដូចគ្នានឹងកម្មសិទ្ធិករ លើផលិតផលនៃកន្លែងយកថ្មដែលមានស្រាប់ នៅលើដីដែលដាក់ជាផលុបភោគ។

**មាត្រា១២៨**

ផលុបភោគីត្រូវបានទទួលថ្លៃឈ្នួលដែលត្រូវបង់ឱ្យកម្មសិទ្ធិករនៃដី ពីសម្បទានិកអណ្តូងរ៉ែក្នុងបរិវេណដីក្រោមសិទ្ធិផលុបភោគរបស់ខ្លួន។

**មាត្រា១២៩**

អសារកម្មសិទ្ធិករមិនអាចធ្វើអ្វីឱ្យរំខានដល់សិទ្ធិរបស់ផលុបភោគី ទោះតាមរូបភាពណាក៏ដោយ។

ចំណែកផលុបភោគីវិញ នៅពេលអស់សិទ្ធិអាស្រ័យផល មិនអាចទាមទារសំណងនៃការកែលំអដែលខ្លួនអះអាងថាបានធ្វើនៅលើអចលនវត្ថុជាប់ផលុបភោគបានឡើយ ទោះជាអចលនវត្ថុនោះ បានកើនតម្លៃដោយសារការរៀបចំរបស់ខ្លួនក៏ដោយ ។

ផលុបភោគី ឬទាយាទរបស់ជននេះ អាចដកយកចេញបាននូវកញ្ចក់ ផ្ទាំងគំនូរ និងគ្រឿងតុបតែងផ្សេងៗដែលខ្លួនបានដាក់តាំងនៅក្នុងអគារ ប៉ុន្តែត្រូវរៀបចំកន្លែងនោះឱ្យមានស្ថានភាពដូចដើមឡើងវិញ ។

**មាត្រា១៣០**

ផលុបភោគីត្រូវទទួលបន្ទុកតែលើការជួសជុលថែទាំប៉ុណ្ណោះ ។ ការជួសជុលធំៗជាបន្ទុករបស់អសារកម្មសិទ្ធិករ លើកលែងតែការខូចខាតណាដែលបណ្តាលមកពីការខ្វះស្មារតីថែទាំរបស់ផលុបភោគី ចាប់ពីទទួលបានផលុបភោគមក ។ ក្នុងករណីនេះ ផលុបភោគីត្រូវធ្វើដោយខ្លួនឯង ។

ការជួសជុលធំៗគឺការជួសជុលជញ្ជាំងទ្រ ក្លោងទ្វារ ការរៀបឡើងវិញនូវធ្នឹមដំបូលទាំងស្រុង ការរៀបចំឡើងវិញនូវទំនប់ទឹក ជញ្ជាំងទប់ដីឬទឹក និងរបងទាំងមូល ។

ការជួសជុលក្រៅពីនេះ ជាការជួសជុលថែទាំ ។

**មាត្រា១៣១**

ទាំងអសារកម្មសិទ្ធិករ ទាំងផលុបភោគី គ្មានកាតព្វកិច្ចសង់ឡើងវិញនូវអ្វីដែលបានទ្រុឌទ្រោម ឬអ្វីដែលបានបំផ្លាញដោយករណីប្រធានសក្តិឡើយ ។

ប៉ុន្តែបើអចលនវត្ថុដែលបានដាក់ធានារ៉ាប់រងត្រូវវិនាស បណ្តាលមកពីមហន្តរាយដោយថាហេតុអសារកម្មសិទ្ធិករ ឬផលុបភោគី អាចសុំយកថ្លៃធានារ៉ាប់រងទៅជួសជុល ឬសាងសង់ឡើងវិញបាន ។

**មាត្រា១៣២**

ផលុបភោគីត្រូវទទួលក្នុងពេលដែលខ្លួនអាស្រ័យផល នូវបន្ទុកប្រចាំឆ្នាំនៃអចលនវត្ថុដូចជាពន្ធនិងអាករ សោហ៊ុយធានារ៉ាប់រងដែលត្រូវបង់ ។

ផលុបភោគីត្រូវបន្តអនុវត្តកិច្ចសន្យាធានារ៉ាប់រង ធ្វើសាជាថ្មីឱ្យទាន់ពេលវេលា និងចុះកិច្ចសន្យាធានារ៉ាប់រងដែលមានប្រយោជន៍ដល់អចលនវត្ថុជាផលុបភោគរបស់ខ្លួន ទោះជាកិច្ចសន្យាធានារ៉ាប់រងនោះកំពុងដំណើរការ នៅពេលដែលផលុបភោគបានចាប់ផ្តើមហើយក្តី ឬជាកិច្ចសន្យាធានារ៉ាប់រងដែលតម្រូវឱ្យធ្វើនាពេលក្រោយ ដោយអសារកម្មសិទ្ធិករក្តី ។

**មាត្រា១៣៣**

ក្នុងពេលដំណើរការផលុបភោគ បើមានតតិយជនណាមកបៀតបៀនសិទ្ធិនៃអសារកម្មសិទ្ធិករ ផលុបភោគីត្រូវជូនដំណឹងទៅអសារកម្មសិទ្ធិករ បើមិនដូច្នោះទេ ផលុបភោគីនោះត្រូវទទួលខុសត្រូវលើការខូចខាត ដែលបណ្តាលមកពីរឿងនោះចំពោះអសារកម្មសិទ្ធិករ ដូចករណីដែលខ្លួនបានធ្វើឱ្យខូចខាតដោយផ្ទាល់។

**មាត្រា១៣៤**

ផលុបភោគត្រូវរលត់៖

-ដោយមរណភាពនៃផលុបភោគី

-ដោយការផុតកំណត់រយៈពេល ឬការសម្រេចបាននូវល័ក្ខខ័ណ្ឌដែលបានកំណត់

-ដោយកិច្ចព្រមលះបង់សិទ្ធិរបស់ផលុបភោគី

-ដោយអចលនវត្ថុដែលជាប់ផលុបភោគ ត្រូវអន្តរាយទាំងស្រុង

-ដោយសេចក្តីសម្រេចរបស់តុលាការស្របតាមបញ្ញត្តិនៃមាត្រា១៣៥នៃច្បាប់នេះ។

**មាត្រា១៣៥**

ការបាត់បង់សិទ្ធិរបស់ផលុបភោគី អាចនឹងត្រូវបានប្រកាសដោយតុលាការ តាមបណ្តឹងរបស់អសារកម្មសិទ្ធិករ ដោយហេតុថាផលុបភោគីបានរំលោភលើការអាស្រ័យផល ពិសេសប្រសិនបើផលុបភោគីនោះធ្វើឱ្យមានវិការភាពលើអចលនវត្ថុ ឬទុកឱ្យអចលនវត្ថុខូចខាតដោយមិនថែទាំ។

ក្នុងករណីនេះ ម្ចាស់បំណុលនៃផលុបភោគីមានសិទ្ធិប្តឹងទៅតុលាការ ដើម្បីសុំបន្តសិទ្ធិរបស់ផលុបភោគី ដោយធានាការជួសជុលនូវរាល់វិការភាពដែលមាន និងការធានាសម្រាប់អនាគត។

ដោយយោលទៅតាមកាលៈទេសៈ និងហេតុផលផ្សេងៗ តុលាការអាចប្រកាសការរលត់ដាច់ខាតនៃផលុបភោគ ឬគ្រាន់តែបង្គាប់ឱ្យប្រគល់អចលនវត្ថុឱ្យអសារកម្មសិទ្ធិករ ដោយបង់ប្រាក់ប្រចាំឆ្នាំឱ្យផលុបភោគី ឬសិទ្ធិវន្តរបស់ជននេះ នូវចំនួនប្រាក់មួយចំនួនជាកំណត់រហូតដល់បញ្ចប់ផលុបភោគ។

**មាត្រា១៣៦**

ការលក់អចលនវត្ថុដែលកំពុងជាប់ផលុបភោគដោយអសារកម្មសិទ្ធិករ មិនធ្វើឱ្យមានការផ្លាស់ប្តូរណាមួយចំពោះផលុបភោគីដែលកំពុងបន្តប្រើប្រាស់សិទ្ធិរបស់ខ្លួននោះទេ លើកលែងតែមានការលះបង់ដោយជាក់លាក់ពីផលុបភោគី។

**មាត្រា១៣៧**

ប្រសិនបើផលុបភោគមានតែលើអគារ ហើយអគារនោះត្រូវអន្តរាយដោយថាហេតុ សិទ្ធិរបស់ផលុបភោគីត្រូវរលត់ ហើយផលុបភោគីមិនអាចទាមទារសិទ្ធិផលុបភោគលើដី ឬលើសម្ភារៈសំណង់នោះទេ។

ប៉ុន្តែបើផលុបភោគមានលើដី និងលើអគារ ហើយបើអគារនោះត្រូវអន្តរាយ ផលុបភោគនៅមានលើដីដដែល ។

## ផ្នែកទី២ អំពីសិទ្ធិប្រើប្រាស់និងអាស្រ័យនៅ

**មាត្រា១៣៨**

សិទ្ធិប្រើប្រាស់គឺជាសិទ្ធិទទួលយកពីដី នូវបរិមាណផលចាំបាច់សម្រាប់សេចក្ដីត្រូវការរបស់អត្ថគាហក និងគ្រួសាររបស់ខ្លួន។

សិទ្ធិអាស្រ័យនៅ គឺជាសិទ្ធិកាន់កាប់ផ្ទះ នូវចំណែកចាំបាច់សម្រាប់រស់នៅរបស់អត្ថគាហក និងគ្រួសាររបស់ខ្លួន។

ទោះបីថ្ងៃក្រោយមក អត្ថគាហកនោះមានប្ដី ប្រពន្ធក្ដី ឬមានកូនក្ដី ក៏សិទ្ធិទាំងពីរនេះនៅតែមានដល់អត្ថគាហកដដែល ។

**មាត្រា១៣៩**

សិទ្ធិប្រើប្រាស់និងអាស្រ័យនៅកើតឡើង និងបាត់បង់ទៅវិញ តាមបែបនៃផលុបភោគដែរ ។

សិទ្ធិនៃអ្នកប្រើប្រាស់និងអ្នកអាស្រ័យនៅ កំណត់ដោយខចែងក្នុងកិច្ចសន្យាតាមរូបមន្តលិខិតយថាភូត ឬដោយបញ្ញត្តិនៃច្បាប់ដែលចែងអំពីសិទ្ធិនេះ ។

**មាត្រា១៤០**

អត្ថគាហកនៃសិទ្ធិប្រើប្រាស់ឬសិទ្ធិអាស្រ័យនៅមិនអាចផ្ទេរ ឬជួលសិទ្ធិរបស់ខ្លួនទៅអ្នកផ្សេងទៀតបានឡើយ ។

សិទ្ធិប្រើប្រាស់និងអាស្រ័យនៅ ជាសិទ្ធិផ្ទាល់ខ្លួនរបស់បុគ្គល ។ សិទ្ធិនេះបញ្ចប់នៅពេលមរណភាពនៃអត្ថគាហក ឬដោយអនុវត្តតាមល័ក្ខខ័ណ្ឌនៃកិច្ចសន្យា ។

**មាត្រា១៤១**

ប្រសិនបើអត្ថគាហកនៃសិទ្ធិប្រើប្រាស់ ប្រមូលយកផលទាំងអស់នៃដី ឬប្រសិនបើអត្ថគាហកនៃសិទ្ធិអាស្រ័យនៅ កាន់កាប់គេហដ្ឋានទាំងមូល អ្នកនោះត្រូវទទួលបន្ទុកចំណាយសោហ៊ុយក្នុងការដាំដុះ ឬការជួសជុលថែទាំ និងបង់ពន្ធអាករ និងសោហ៊ុយធានារ៉ាប់រង ដូចផលុបភោគីដែរ ។

ប្រសិនបើអត្ថគាហកយកតែចំណែកណាមួយនៃផល ឬកាន់កាប់តែមួយចំណែកនៃគេហដ្ឋាន អ្នកនោះត្រូវចូលរួមចំណាយទៅតាមសមាមាត្រដែលខ្លួនអាស្រ័យផលនោះ ។

## ផ្នែកទី៣ អំពីសេវភាព

**មាត្រា១៤២**

សេវភាពដីគឺជាបន្ទុកដែលផ្ទុកទៅលើដីមួយ ហៅដីបម្រើ ឬដីក្រោម សម្រាប់ការប្រើប្រាស់ និងប្រយោជន៍នៃដីមួយទៀត ហៅដីប្រើ ឬដីលើដែលជារបស់កម្មសិទ្ធិករផ្សេងទៀត ។

**មាត្រា១៤៣**

សេវភាពកើតពីធម្មជាតិ កើតពីច្បាប់ ឬកើតពីការព្រមព្រៀង អាស្រ័យដោយស្ថានភាពនៃទីកន្លែង ដោយការកំណត់របស់ច្បាប់ ឬដោយការព្រមព្រៀងរវាងកម្មសិទ្ធិករ ។

### អនុផ្នែកទី១ អំពីសេវភាពកើតពីធម្មជាតិ

**មាត្រា១៤៤**

ដីក្រោមត្រូវទទួលទឹកដែលហូរតាមធម្មជាតិពីដីលើ ។

កម្មសិទ្ធិករនៃដីក្រោមមិនអាចលើកទំនប់ ភ្លឺ របាំង ឬការរៀងទៃផ្សេងទៀត ទប់ការហូរនោះបានឡើយ ។

កម្មសិទ្ធិករនៃដីលើមិនអាចធ្វើអ្វី ដែលធ្វើឱ្យកាន់តែធ្ងន់ដល់សេវភាពនៃដីក្រោមបានឡើយ ។

**មាត្រា១៤៥**

កម្មសិទ្ធិករនៃដីលើមានសិទ្ធិប្រើប្រាស់ និងចាត់ចែងទឹកភ្លៀងដែលធ្លាក់មកលើដីរបស់ខ្លួន ព្រមទាំងទឹកដែលមានប្រភពផុសឡើងនៅទីនោះ លើកលែងតែក្នុងករណីដែលមានចែងក្នុងវាក្យខណ្ឌចុងក្រោយនៃមាត្រា១៤៤ ។

**មាត្រា១៤៦**

កម្មសិទ្ធិករនៃដីដែលឋិតនៅជាប់ផ្លូវទឹកហូរ ត្រូវទុកឱ្យទឹកហូរទៅលើដីជិតខាង ហើយកម្មសិទ្ធិករនៃដីជិតខាង ក៏ត្រូវមានកាតព្វកិច្ចដូចគ្នាចំពោះដីនៅឆ្ងាយ ទៅតាមតម្រូវការនៃកសិកម្ម ។

### អនុផ្នែកទី២ អំពីសេវភាពកើតពីច្បាប់

**មាត្រា១៤៧**

សេវភាពកើតពីច្បាប់មានគោលដៅប្រើប្រាស់ជាប្រយោជន៍សាធារណៈ ឬជាប្រយោជន៍ឯកជន ។

សេវភាពកើតពីច្បាប់ប្រើប្រាស់ជាប្រយោជន៍សាធារណៈ ត្រូវកំណត់ដោយច្បាប់ ឬដោយបទបញ្ជាពិសេសដែលបង្គំទៅលើកម្មសិទ្ធិករ ។

សេវភាពកើតពីច្បាប់ប្រើប្រាស់ជាប្រយោជន៍ឯកជន កំណត់ព្រំដែនដែលកម្មសិទ្ធិករអាចធ្វើសកម្មភាពមួយចំនួនក្នុងដីរបស់ខ្លួន លើកលែងតែធ្វើឱ្យប៉ះពាល់ដល់សិទ្ធិនៃកម្មសិទ្ធិករដីជិតខាង ។

**មាត្រា១៤៨**

ការកំណត់ព្រំដី និងកម្មសិទ្ធិដែលឋិតនៅតាមបណ្ដោយផ្លូវសាធារណៈ ត្រូវកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច យោងតាមសេចក្ដីត្រូវការជាក់ស្ដែងនៃផលប្រយោជន៍រួម ពិសេសតាមសេចក្ដីត្រូវការនៃការធ្វើចរាចរ ។

មុននឹងធ្វើរបង ឬកសាងអគារប្រភេទណាក៏ដោយ ដែលឋិតនៅជាប់នឹងផ្លូវសាធារណៈ កម្មសិទ្ធិករចាំបាច់ត្រូវតែត្រួតពិនិត្យមើលនូវភាពសមស្របនៃអគារនោះ ជាមួយនឹងប្លង់តម្រង់ជួរ ប្រសិនបើមាន ។ រាល់លិខិតអនុញ្ញាតសាងសង់ ត្រូវតែយកចិត្តទុកដាក់ដល់ខ្សែតម្រង់ជួរដែលមានរួចហើយ ។

អាជ្ញាធរមានសមត្ថកិច្ច អាចសម្រេចធ្វើការផ្លាស់ប្ដូរទំហំផ្លូវបាន តាមតម្រូវការចាំបាច់សម្រាប់ផលប្រយោជន៍សាធារណៈ ។ នៅពេលដែលអាជ្ញាធរធ្វើការសម្រេចពង្រីកទំហំផ្លូវ សំណង់ទាំងឡាយដែលឋិតនៅលើបន្ទាត់តម្រង់ជួរ ត្រូវបន្ថយទៅក្រោយ ។ បើជារបងធម្មតា ឬជាសំណង់ស្រាល អាជ្ញាធរតម្រូវឱ្យធ្វើការរំកិលចេញ ។ ប្រសិនបើជាអចលនវត្ថុដែលមិនអាចជាកម្មវត្ថុនៃការផ្លាស់ប្ដូរ កែសម្រួល រុះរើបាន អចលនវត្ថុនោះត្រូវឋិតក្នុងសភាពដដែលសិន រហូតដល់ពេលអាជ្ញាធរមានសមត្ថកិច្ចសម្រេច អំពីការពង្រីកដែលបានគ្រោងទុក ។ ការដកហូតកម្មសិទ្ធិមួយចំណែក ឬទាំងស្រុងអាចប្រព្រឹត្តទៅបាន ដោយអនុវត្តត្រឹមត្រូវតាមនីតិវិធីនៃច្បាប់ ។ ចំពោះដីដែលបានកាន់កាប់ស្របច្បាប់ ព្រមទាំងរបង និងសំណង់ទាំងឡាយដែលបានធ្វើឡើងត្រឹមត្រូវតាមបញ្ញត្តិនៃច្បាប់ ម្ចាស់កម្មសិទ្ធិមានសិទ្ធិទាមទារឱ្យសងការខូចខាតរបស់ខ្លួន ។

**មាត្រា១៤៩**

កម្មសិទ្ធិករដែលចង់ធ្វើនៅលើដីរបស់ខ្លួន នូវកិច្ចការដែលមានលក្ខណៈរំខានដល់ដីជិតខាង ដូចជាការខួងអណ្ដូង ការជីកស្នង់ដី ការជីករុករក ការគរទុកវត្ថុប្រកបដោយគ្រោះថ្នាក់ ដែលនាំឱ្យរំខាន ឬប៉ះពាល់ដល់សុខភាព ត្រូវអនុលោមតាមបញ្ញត្តិនៃបទបញ្ជា ពិសេសស្ដីពីការកំណត់ចម្ងាយដែលត្រូវប្រតិបត្តិ ឬស្ដីពីការងារដែលធ្វើសម្រាប់ទប់ជ្រែង ។

*វាយឡើងវិញ*

**មាត្រា១៥០**

កម្មសិទ្ធិករមិនអាចនឹងធ្វើប្រហោងទ្វារ ឬបង្អួច កើយ ឬយ៉ ត្រង់ចំគ្នាទៅវិញទៅមក ចម្ងាយតិចជាងពីរម៉ែត្រពីដីអ្នកជិតខាងបានទេ។

**មាត្រា១៥១**

កម្មសិទ្ធិករមិនអាចដាំដើមឈើធំ តូច មានកម្ពស់លើសពី២ (ពីរ) ម៉ែត្រ នៅប្របព្រំដីជាប់គ្នា ដែលមានចម្ងាយតិចជាងពីរម៉ែត្រពីព្រំដីបានទេ បើមិនដូច្នោះទេនឹងត្រូវបង្ខំឱ្យយកចេញកាលបើមានបណ្តឹងពីកម្មសិទ្ធិករដែលមានប្រយោជន៍ក្នុងរឿងនេះ។

**មាត្រា១៥២**

កម្មសិទ្ធិករដែលដីរបស់ខ្លួនត្រូវបានបិទជិត និងគ្មានច្រកចេញចូលទៅផ្លូវសាធារណៈ ឬមានច្រកមិនគ្រប់គ្រាន់សម្រាប់អាជីវកម្មកសិកម្ម ឧស្សាហកម្មនៃកម្មសិទ្ធិរបស់ខ្លួន មានសិទ្ធិស្នើសុំបើកផ្លូវឆ្លងតាមដីអ្នកជិតខាងខ្លួន ដោយត្រូវចេញសំណងតាមសមាមាត្រ ចំពោះការខូចខាតដែលបណ្តាលមកពីកិច្ចការនោះ។

**មាត្រា១៥៣**

ជាគោលការណ៍ ផ្លូវដូចមានចែងក្នុងមាត្រា១៥២ ត្រូវយកកន្លែងណាដែលមានចម្ងាយជិតជាងគេ ពីដីបិទជិតទៅផ្លូវសាធារណៈ ប៉ុន្តែត្រូវកំណត់កន្លែងណាដែលមានការខូចខាតតិចបំផុតសម្រាប់កម្មសិទ្ធិករនៃដីដែលត្រូវទទួលរង។

**មាត្រា១៥៤**

ប្រសិនបើដីបិទជិតកើតឡើងពីការបែងចែកដីតាមរយៈការលក់ ការដូរ ការចែក ឬពីកិច្ចសន្យាផ្សេងទៀត ការបើកផ្លូវឆ្លងកាត់អាចសុំតែនៅលើដីដែលនៅសល់ពីការបែងចែក។

ប៉ុន្តែបើដីដែលនៅសល់ពុំអាចបង្កើតបានជាផ្លូវគ្រប់គ្រាន់ បញ្ញត្តិនៃមាត្រា១៥២ និងមាត្រា១៥៣នៅតែអនុវត្តបានដដែល។

**មាត្រា១៥៥**

កម្មសិទ្ធិករដែលចង់ប្រើទឹកដែលខ្លួនមានសិទ្ធិដើម្បីប្រើប្រាស់ និងស្រោចស្រពដីរបស់ខ្លួនអាចទទួលបានផ្លូវនាំទឹកឆ្លងកាត់ដីដែលឋិតនៅចន្លោះកណ្តាលបាន តែត្រូវចំណាយសោហ៊ុយសងការខូចខាតឱ្យម្ចាស់ដីនោះ។

**មាត្រា១៥៦**

កម្មសិទ្ធិករអាចបញ្ចេញទឹកស្រោចស្រពរួចហើយចេញពីដីខ្លួន ឆ្លងកាត់ដីក្រោមបាន តែត្រូវចំណាយសោហ៊ុយសងការខូចខាត។

**មាត្រា១៥៧**

កម្មសិទ្ធិករនៃដីលិចទឹកទាំងស្រុង ឬមួយចំណែក អាចបង្ហូរទឹកមិនល្អចេញបាន តែត្រូវធ្វើឱ្យបានត្រឹមត្រូវតាមវិធីអនាម័យ។

**មាត្រា១៥៨**

កម្មសិទ្ធិករនៃដីជាប់មាត់ទឹក ដែលចង់ប្រើប្រាស់ទឹកដើម្បីស្រោចស្រពដីរបស់ខ្លួន អាចមានសិទ្ធិធ្វើសិល្បការចាំបាច់ ទល់ទៅលើដីដែលឋិតនៅមាត់ទឹកម្ខាងទៀត ដើម្បីរៀបចំយកទឹក តែត្រូវទទួលបន្ទុកចេញសោហ៊ុយនៃការខូចខាត។

**មាត្រា១៥៩**

កម្មសិទ្ធិករនៃដីដែលព្រមឱ្យធ្វើការអ្វីលើដីរបស់ខ្លួននោះអាចនឹងសុំប្រើទំនប់ ឬរបាំងទឹកនោះបាន ដោយត្រូវចេញសោហ៊ុយធ្វើ និងសោហ៊ុយថែទាំពាក់កណ្តាល។ កម្មសិទ្ធិករនេះមិនត្រូវទារសោហ៊ុយថ្លៃដីឡើយ បើបានទទួលហើយ ត្រូវតែបង្វិលសងគេវិញ។

**អនុផ្នែកទី៣ អំពីសេវភាពកើតពីការព្រមព្រៀង**

**មាត្រា១៦០**

ត្រូវបានអនុញ្ញាតឱ្យកម្មសិទ្ធិករបង្កើតនៅលើដីរបស់ខ្លួន នូវរាល់សេវភាពជាគុណប្រយោជន៍ដល់កម្មសិទ្ធិករនៃដីផ្សេងទៀត ឱ្យតែសេវភាពនោះមិនផ្ទុយពីសណ្តាប់ធ្នាប់សាធារណៈ។ ការប្រើប្រាស់ និងវិសាលភាពនៃសេវភាពនេះ ត្រូវកំណត់ដោយកិច្ចព្រមព្រៀងដែលបានបង្កើតសេវភាពនោះ។

**មាត្រា១៦១**

សេវភាពកើតចេញពីការព្រមព្រៀង អាចបង្កើតឡើងបានតែតាមលិខិតយថាភូតប៉ុណ្ណោះ។ សេវភាពនេះមិនអាចតតិយជនជំទាស់បានទេ ក្រោយពីការចុះលេខាចារឹកក្នុងបញ្ជីសុរិយោដី។

ទំនាក់ទំនងសេវភាពរវាងដីបម្រើ និងដីប្រើ នឹងត្រូវចប់នៅពេលដែលដីណាមួយក្នុងចំណោមដីទាំងពីរ ត្រូវបានផ្ទេរឱ្យតតិយជនណាម្នាក់ បើការរក្សាទុកសេវភាពនោះមិនបានចែងច្បាស់ក្នុងលិខិតផ្ទេរកម្មសិទ្ធិទេ។

**មាត្រា១៦២**

កម្មសិទ្ធិករដែលបានបង្កើតសេវភាពលើដីរបស់ខ្លួន ត្រូវបានចាត់ទុកថាយល់ព្រមរាល់អ្វីដែលចាំបាច់សម្រាប់សេវភាពនោះ ។ សេវភាពនៃការយកទឹកបង្កើតឡើងនៅកន្លែងប្រភពទឹក អនុញ្ញាតឱ្យអ្នកយកទឹកមានសិទ្ធិឆ្លងកាត់ដីដែលមានប្រភពទឹកនោះបាន ។

**មាត្រា១៦៣**

កម្មសិទ្ធិករនៃដីប្រើ មានសិទ្ធិធ្វើរាល់ការរៀចំាបាច់ផ្សេងៗលើដីបម្រើដើម្បីប្រើ និងរក្សាទុកសេវភាពបាន ។

**មាត្រា១៦៤**

ការរៀចំាបាច់សម្រាប់ប្រើ និងរក្សាទុកសេវភាព គឺជាសោហ៊ុយនៃកម្មសិទ្ធិករដីប្រើ លើកលែងតែមានការព្រមព្រៀងគ្នាផ្សេងពីនេះ ។

**មាត្រា១៦៥**

កម្មសិទ្ធិករនៃដីបម្រើ មិនអាចធ្វើអ្វីដែលមានបំណងបន្ថយការប្រើប្រាស់សេវភាព ឬធ្វើឱ្យសេវភាពមិនអាចប្រើបានឡើយ ។ កម្មសិទ្ធិករនៃដីបម្រើ មិនអាចប្តូរស្ថានភាពនៃការប្រើប្រាស់សេវភាពដែលបានកំណត់ពីដំបូងមកបានទេ ។ ប៉ុន្តែបើទុកសេវភាពក្នុងស្ថានភាពដើមនាំឱ្យកម្មសិទ្ធិករនៃដីបម្រើចំណាយប្រាក់លើការជួសជុលថៃទាំច្រើន កម្មសិទ្ធិករនៃដីបម្រើអាចសុំដាក់សេវភាពជំនួស នៅទីផ្សេងទៀតបានដែលស្រួលប្រើដូចគ្នា ហើយកម្មសិទ្ធិករនៃដីប្រើមិនអាចបដិសេធបានឡើយ ។

**មាត្រា១៦៦**

ចំណែកឯកម្មសិទ្ធិករនៃដីប្រើ អាចប្រើប្រាស់សេវភាពតែក្នុងព្រំដែនដែលបានកំណត់ក្នុងកិច្ចសន្យា ដោយមិនអាចធ្វើនៅលើដីបម្រើ ឬដីរបស់ខ្លួន ឱ្យមានការប្រែប្រួលណាមួយដែលអាចមានឥទ្ធិពលធ្ងន់ធ្ងរដល់ស្ថានភាពនៃដីបម្រើបានឡើយ ។

### អនុផ្នែកទី៤ អំពីការផុតរលត់នៃសេវភាព

**មាត្រា១៦៧**

សេវភាពផុតរលត់ដោយ៖

-ការបញ្ចប់កិច្ចព្រមព្រៀងដែលបង្កើតសេវភាពនេះ

-ដីប្រើ និងដីបម្រើ ធ្លាក់ក្នុងដៃកម្មសិទ្ធិករតែម្នាក់ ឬ

-មហន្តរាយទាំងស្រុងនៃដីដែលជាទីតាំងសេវភាពនេះ ។

## មាតិកាទី៤ អំពីទម្រង់នៃកម្មសិទ្ធិ

### ជំពូកទី៩ អំពីកម្មសិទ្ធិអវិភាគ

**មាត្រា១៦៨**

កម្មសិទ្ធិអវិភាគគឺជាកម្មសិទ្ធិលើទ្រព្យតែមួយដែលជារបស់បុគ្គលច្រើននាក់ ។ បុគ្គលទាំងនោះជាកម្មសិទ្ធិករអវិភាគ ។ កម្មសិទ្ធិករអវិភាគម្នាក់ៗ មានចំណែករបស់ខ្លួនក្នុងទ្រព្យនោះ ប៉ុន្តែទ្រព្យនោះមិនអាចពុះចែកគ្នាបានឡើយ ។

**មាត្រា១៦៩**

ភាគបែងនៃកម្មសិទ្ធិអវិភាគចាត់ទុកថាស្មើគ្នា ។ ក្នុងករណីដែលការបែងចែកទ្រព្យមិនស្មើគ្នា កម្មសិទ្ធិករមានសិទ្ធិ និងបន្ទុកសមាមាត្រទៅនឹងចំណែករបស់ខ្លួន ។ កម្មសិទ្ធិករម្នាក់ៗអាចលក់ចំណែក ឬចុះកិច្ចសន្យាផ្សេងៗលើចំណែករបស់ខ្លួនបាន ហើយម្ចាស់បំណុលរបស់គេម្នាក់ៗអាចរឹបអូសចំណែកនៃទ្រព្យរបស់អ្នកនោះបាន ។

**មាត្រា១៧០**

កម្មសិទ្ធិករអវិភាគគ្រប់គ្រងរួមលើកម្មសិទ្ធិអវិភាគ លើកលែងតែមានកិច្ចព្រមព្រៀងផ្ទុយពីនេះ ។ កម្មសិទ្ធិករអវិភាគម្នាក់ៗមាននាទីគ្រប់គ្រងជាធម្មតា ដូចជាការជួសជុលថែទាំ និងការដាំដុះបើកម្មសិទ្ធិករអវិភាគភាគច្រើនមិនបានចាត់ឱ្យធ្វើអ្វីផ្សេងទៀតទេ ។

កិច្ចការសំខាន់ៗដូចជាការប្ដូរដំណាំ និងការជួសជុលធំៗអាចសម្រេចបាន លុះត្រាតែភាគច្រើននៃកម្មសិទ្ធិករអវិភាគ ដែលមានចំណែករួមគ្នាលើសពីពាក់កណ្ដាលនៃទ្រព្យនោះបានយល់ព្រម ។

**មាត្រា១៧១**

កម្មសិទ្ធិករអវិភាគម្នាក់ៗ ត្រូវយកចិត្តទុកដាក់ថែទាំ និងការពារប្រយោជន៍រួម ។ កម្មសិទ្ធិករអវិភាគអាស្រ័យផលពីទ្រព្យ និងប្រើប្រាស់ទ្រព្យក្នុងព្រំដែន ដែលមិនប៉ះពាល់ដល់សិទ្ធិនៃកម្មសិទ្ធិករអវិភាគឯទៀត ។

ការព្រមព្រៀងគ្នាពីកម្មសិទ្ធិករអវិភាគទាំងអស់ ជាការចាំបាច់ សម្រាប់ការផ្ទេរសិទ្ធិ ការបង្កើតសិទ្ធិភណ្ឌិក ឬការផ្លាស់ប្ដូរគោលដៅនៃទ្រព្យ លើកលែងតែមានវិធានផ្សេងពីនេះ ។

**មាត្រា១៧២**

ចំណាយលើការគ្រប់គ្រង ការបង់ពន្ធ និងបន្ទុកផ្សេងទៀតលើទ្រព្យអវិភាគត្រូវទទួលរ៉ាប់រង ដោយកម្មសិទ្ធិករអវិភាគទាំងអស់ តាមសមាមាត្រនៃចំណែករៀងៗខ្លួន លើកលែងតែមានបញ្ញត្តិផ្ទុយពីនេះ។

**មាត្រា១៧៣**

គ្មានជនណាមួយអាចត្រូវបានបង្ខំឱ្យនៅក្នុងអវិភាគកម្មបានទេ។ កម្មសិទ្ធិករអវិភាគម្នាក់ៗ អាចទាមទារឱ្យបែងចែកទ្រព្យអវិភាគនោះបាន។

កម្មសិទ្ធិករអវិភាគទាំងឡាយអាចរក្សាទុកជាបណ្ដោះអាសន្ន នូវស្ថានភាពនៃអវិភាគកម្ម ប៉ុន្តែស្ថានភាពបែបនេះ មិនអាចចាប់បង្ខំឱ្យលើសពីរយៈពេល៥ (ប្រាំ) ឆ្នាំបានឡើយ លើកលែងតែមានកិច្ចព្រមព្រៀងថ្មី។

**មាត្រា១៧៤**

អវិភាគកម្មត្រូវចប់ដោយការបែងចែកទ្រព្យតាមរូបដើម ឬដោយការលក់ទ្រព្យហើយចែកថ្លៃគ្នា ឬដោយកម្មសិទ្ធិករអវិភាគម្នាក់ ឬច្រើននាក់ ទទួលយកចំណែករបស់អ្នកដទៃ។

ប្រសិនជាកម្មសិទ្ធិករអវិភាគ មិនយល់ព្រមតាមអំពីរបៀបនៃការចែក អ្នកទាំងនោះត្រូវប្ដឹងទៅតុលាការដែលនឹងរៀបចំចែកទ្រព្យ ឬបើទ្រព្យនោះកាលបើចែកទៅនាំឱ្យថយថ្លៃច្រើន តុលាការអាចបង្គាប់ឱ្យលក់ទ្រព្យទាំងមូលទៅឱ្យតតិយជន ឬទៅឱ្យកម្មសិទ្ធិករអវិភាគណាម្នាក់ក៏បាន។

## ជំពូកទី១០ អំពីសហកម្មសិទ្ធិ

**មាត្រា១៧៥**

សហកម្មសិទ្ធិគឺជាកម្មសិទ្ធិលើទ្រព្យជាអចលនវត្ថុរបស់បុគ្គលច្រើននាក់ បែងចែកតាមឡូត៍ដែលម្នាក់ៗបានមួយចំណែកជាឯកជន ហើយមួយចំណែកទៀតជាផ្នែកនៃទ្រព្យរួម។

**មាត្រា១៧៦**

សហកម្មសិទ្ធិករទាំងឡាយអាចរៀបចំបទបញ្ជាផ្ទៃក្នុង ដែលកំណត់របៀបគ្រប់គ្រង និងវិធាននៃការថែទាំ ព្រមទាំងកាតព្វកិច្ចរបស់សហកម្មសិទ្ធិករ ជាពិសេសចំពោះផ្នែករួម ដោយគោរពតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ។

ក្នុងករណីដែលគ្មានបទបញ្ជាផ្ទៃក្នុងនេះទេ សហកម្មសិទ្ធិត្រូវឋិតនៅក្រោមបទប្បញ្ញត្តិទាំងឡាយដែលបានកំណត់ពីមាត្រា១៧៧ ដល់មាត្រា១៨៥នៃច្បាប់នេះ។

**មាត្រា១៧៧**

សហកម្មសិទ្ធិករទាំងឡាយ មានសិទ្ធិពេញលេញលើចំណែកឯកជនរបស់ខ្លួន ដោយមិនបំពានទៅលើចំណែករួម និងមិនរំខាន ឬរាំងស្ទះដល់ការប្រើប្រាស់ចំណែករួមដោយសហកម្មសិទ្ធិករដទៃទៀត។ សហកម្មសិទ្ធិករទាំងនោះ អាចផ្ទេរសិទ្ធិដោយសេរី ជួល ឬបង្កើតផលុបភោគ រៀបចំសិទ្ធិប្រើប្រាស់និងអាស្រ័យនៅ ដាក់ហ៊ីប៉ូតែក ដាក់បញ្ចាំនូវចំណែកឯកជនរបស់ខ្លួន។ ប៉ុន្តែសហកម្មសិទ្ធិករមិនអាចបង្កើតសេវភាពលើចំណែកឯកជនរបស់ខ្លួននោះបានទេ។

**មាត្រា១៧៨**

រាល់ចំណែកនៃអគារ ឬដីសម្រាប់ការប្រើប្រាស់ផ្ដាច់មុខនៃសហកម្មសិទ្ធិករណាមួយបង្កើតបានជាចំណែកឯកជន។ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុត្រូវកំណត់អំពីប្រភេទ និងទំហំនៃចំណែកនោះ។

**មាត្រា១៧៩**

រាល់ចំណែកនៃអគារ ឬដីសម្រាប់ការប្រើប្រាស់ ឬជាប្រយោជន៍នៃសហកម្មសិទ្ធិករទាំងឡាយ ឬសហកម្មសិទ្ធិករខ្លះក្នុងចំណោមនោះបង្កើតបានជាចំណែករួម។

ទ្រព្យរួមមានជាអាទិ៍៖

-ដី ទីធ្លា ឧទ្យាននិងសួនច្បារ ផ្លូវ ច្រកចេញចូល

-ជញ្ជាំង សសរទ្រទ្រង់សំខាន់ៗនៃអគារ ឧបករណ៍រួមរាប់បញ្ចូលចំណែកនៃបណ្ដាញទឹកភ្លើង បណ្ដាញឧស្ម័នដែលអាចឆ្លងកាត់ចំណែកឯកជន

-ទូរួម បំពង់ និងក្បាលបំពង់ផ្សែង

-ទីកន្លែងនៃសេវារួម។

សិទ្ធិបន្ទាប់បន្សំខាងក្រោមនេះ ក៏ត្រូវទុកជាកម្មសិទ្ធិរួមដែរ៖

-សិទ្ធិជីករុករកវត្ថុធាតុដែលមាននៅក្នុងដី

-សិទ្ធិស្ថាបនាអគារថ្មីក្នុងទីធ្លា ឧទ្យាន ឬសួនច្បារដែលជាចំណែករួម

-សិទ្ធិជីករុករកក្នុងទីធ្លា ឧទ្យាន ឬសួនច្បារទាំងនោះ

-សិទ្ធិនៃអឡូសិទ្ធិភាពដែលជាប់ទៅនឹងចំណែករួមទាំងឡាយ

-សិទ្ធិលើកបន្តឱ្យខ្ពស់នូវអគារសម្រាប់ប្រើប្រាស់រួម ឬដែលមានកន្លែងច្រើនបង្កើត

បានជាចំណែកឯកជនផ្សេងគ្នា។ គ្មានករណីណាមួយដែលកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិជាន់លើបំផុត អាចលើកបន្តសម្រាប់តែខ្លួនឯងផ្ទាល់ ឬលក់សិទ្ធិនៃការលើកបន្តនេះឡើយ។

-បទប្បញ្ញត្តិនេះមានលក្ខណៈជាសណ្តាប់ធ្នាប់សាធារណៈ។

**មាត្រា១៨០**

សហកម្មសិទ្ធិករដែលធ្វើឱ្យប៉ះពាល់ដល់ចំណែករួមនៃអគារ ឬដី ដោយបានកែប្រែដើម្បីការប្រើប្រាស់ជាឯកជន ឬសម្រាប់លក់ នឹងត្រូវបង្ខំឱ្យរៀបចំដូចសភាពដើមវិញ។ សហកម្មសិទ្ធិករនោះត្រូវទទួលទណ្ឌកម្ម ដូចមានចែងក្នុងមាត្រា២៥៧នៃច្បាប់នេះ។

ជនក្រៅពីសហកម្មសិទ្ធិករដែលដណ្តើមយកចំណែករួម សម្រាប់ជាទីលំនៅឯកជនរបស់ខ្លួន នឹងត្រូវបង្ខំឱ្យសងកន្លែងដែលកាន់កាប់ខុសច្បាប់ ហើយត្រូវធ្វើឱ្យមានសភាពដូចដើមវិញ។

ក្នុងករណីណាក៏ដោយ អាជ្ញាធរមានសមត្ថកិច្ចមិនអាចចេញប័ណ្ណសម្គាល់សិទ្ធិឱ្យបុគ្គលនោះបានឡើយ ពុំនោះទេនឹងត្រូវចាត់ទុកជាអ្នកសមគំនិត និងត្រូវទទួលខុសត្រូវរួមជាមួយដែរ។ អាជ្ញាធរមានភារកិច្ចបង្ខំឱ្យអ្នកកាន់កាប់ដោយខុសច្បាប់រុះរើចេញ។

បញ្ញត្តិទាំងនេះ ក៏មានគោលដៅដាក់ទោសអ្នកមិនទទួលស្គាល់កម្មសិទ្ធិ និងល័ក្ខខ័ណ្ឌនៃសណ្តាប់ធ្នាប់សាធារណៈដោយផ្ទាល់ និងជាសារវ័ន្ត ហើយត្រូវអនុវត្តចំពោះការប៉ះពាល់ដែលមានកន្លងមក មុនការប្រកាសឱ្យប្រើច្បាប់នេះ។

**មាត្រា១៨១**

ចំណែករួមគឺជាកម្មសិទ្ធិអវិភាគរបស់សហកម្មសិទ្ធិករ។ សហកម្មសិទ្ធិករត្រូវធានាការថែទាំចំណែករួម។ បន្ទុកនៃការថែទាំនេះត្រូវចែកគ្នាតាមសមាមាត្រទៅនឹងតម្លៃនៃឡូតិ៍នីមួយៗ។

**មាត្រា១៨២**

ជញ្ជាំងដែលខណ្ឌចំណែកឯកជន ត្រូវចាត់ទុកជាជញ្ជាំងអឡុសិទ្ធិដូចមានចែងក្នុងជំពូកទី១១នៃច្បាប់នេះ។

**មាត្រា១៨៣**

ចំណែករួម និងសិទ្ធិបន្ទាប់បន្សំទាំងឡាយមិនអាចជាកម្មវត្ថុនៃការបែងចែក ឬបង្ខំឱ្យលក់ដាច់ដោយឡែកពីចំណែកឯកជនបានឡើយ។

*វាយឡើងវិញ*

មាត្រា១៨៤

សហកម្មសិទ្ធិករ អាចបង្កើតអង្គការគ្រប់គ្រងដែលអាចជាក្រុមប្រឹក្សាភិបាល ឬ/និង គណៈកម្មការគ្រប់គ្រង ដើម្បីទទួលបន្ទុកកិច្ចការសហកម្មសិទ្ធិ។ អង្គការគ្រប់គ្រងនេះត្រូវជ្រើសរើស ដោយមហាសន្និបាត ដែលមានការចូលរួមពីសហកម្មសិទ្ធិករទាំងអស់ ដោយគិតតាមសមាមាត្រនៃ សារៈសំខាន់នៃឡូតិ៍រៀងៗខ្លួន។ អង្គការគ្រប់គ្រង ធ្វើការសម្រេចចិត្តទាក់ទងទៅនឹងការថែទាំ សហកម្មសិទ្ធិតាមមតិភាគច្រើន។

សហកម្មសិទ្ធិករត្រូវគោរពតាមសេចក្តីសម្រេចដែលបានដាក់ចេញដោយមហាសន្និបាត ជាពិសេស ទាក់ទងទៅនឹងការថែទាំ និងការធ្វើឱ្យស្របទៅនឹងល័ក្ខខ័ណ្ឌនៃសណ្តាប់ធ្នាប់សាធារណៈនៃចំណែករួម។

សហកម្មសិទ្ធិករណាម្នាក់ ដែលមិនព្រមគោរពតាមការសម្រេចរបស់មហាសន្និបាត និង ដោះខ្លួនពីចំណែកនៃបន្ទុកដែលធ្លាក់មកលើខ្លួន អាចនឹងត្រូវបានប្តឹងទៅតុលាការ ដើម្បីបង្ខំឱ្យបង់ បន្ទុកដែលត្រូវបង់។

ក្នុងករណីគ្មានការបង្កើតអង្គការគ្រប់គ្រង ការគ្រប់គ្រងសហកម្មសិទ្ធិត្រូវរ៉ាប់រងផ្ទាល់ដោយ សហកម្មសិទ្ធិករទាំងអស់ដែលធ្វើការសម្រេចជាឯកច្ឆន្ទ។ បើសិនគ្មានការយល់ព្រមណាមួយអាចកើត ឡើងរវាងសហកម្មសិទ្ធិករទេ ដែលជាហេតុនាំឱ្យការថែទាំមិនបានល្អ ឬថយតម្លៃនៃសហកម្មសិទ្ធិ សហកម្មសិទ្ធិករទាំងអស់ ក្រោយពីមានការព្រមព្រៀងគ្នាអាចប្តឹងទៅតុលាការ ឱ្យចាត់អ្នកគ្រប់គ្រង សហកម្មសិទ្ធិម្នាក់។ ប្រាក់ឈ្នួលសម្រាប់អ្នកគ្រប់គ្រងជាបន្ទុកនៃសហកម្មសិទ្ធិករទាំងអស់។

មាត្រា១៨៥

អាជ្ញាធរមានសមត្ថកិច្ចអាចដាក់វិធានការឱ្យសហកម្មសិទ្ធិករ រ៉ាប់រងការថែទាំឱ្យល្អលើ ចំណែករួម។

សោហ៊ុយនៃការថែទាំជាបន្ទុកនៃសហកម្មសិទ្ធិករ ដោយគិតតាមសមាមាត្រទៅនឹងតម្លៃ នៃចំណែករៀងៗខ្លួន។

សហកម្មសិទ្ធិករដែលមិនព្រមចូលរួមទទួលបន្ទុកនេះ ឬមិនគោរពតាមល័ក្ខខ័ណ្ឌនៃសណ្តាប់ ធ្នាប់សាធារណៈ ត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងមាត្រា២៥៨នៃច្បាប់នេះ។

## ជំពូកទី១១ អំពីអឡុសិទ្ធិភាព

**មាត្រា១៨៦**

អឡូសិទ្ធិភាពគឺជាទម្រង់មួយនៃកម្មសិទ្ធិរួម អនុវត្តទៅលើជញ្ជាំង និងកំពែងដែលនៅត្រង់ព្រំខណ្ឌចែកកម្មសិទ្ធិពីរជាប់គ្នា។

កំពែងក្នុងន័យនៃច្បាប់នេះគឺសំដៅទៅលើស្នាមភ្លោះ របង និងភ្លឺ។

**ផ្នែកទី១ អំពីជញ្ជាំងអឡូសិទ្ធិ**

**មាត្រា១៨៧**

ការជួសជុល និងការសាងសង់ជញ្ជាំងអឡូសិទ្ធិឡើងវិញ ជាបន្ទុកនៃអ្នកដែលមានសិទ្ធិលើទ្រព្យនោះ តាមសមាមាត្រទៅនឹងសិទ្ធិនៃកម្មសិទ្ធិករម្នាក់ៗ។

រាល់កម្មសិទ្ធិករដែលពាក់ព័ន្ធអាចឱ្យរួចពីការចេញថ្លៃជួសជុល ឬសាងសង់ជញ្ជាំងអឡូសិទ្ធិឡើងវិញ ដោយលះបង់សិទ្ធិនៃអឡូសិទ្ធិរបស់ខ្លួន លើកលែងតែជញ្ជាំងអឡូសិទ្ធិទល់ទ្រអគារដែលជារបស់ខ្លួនប៉ុណ្ណោះ។

**មាត្រា១៨៨**

កម្មសិទ្ធិករណាម្នាក់នៃជញ្ជាំងអឡូសិទ្ធិ មិនអាចចោះចូលជ្រៅទៅក្នុងជញ្ជាំងអឡូសិទ្ធិ ឬធ្វើការអ្វី ដែលអាចបណ្ដាលឱ្យខូចខាតដល់ជញ្ជាំងអឡូសិទ្ធិ ដោយគ្មានការព្រមព្រៀងពីកម្មសិទ្ធិករម្ខាងទៀតឡើយ។ ក្នុងករណីគ្មានការព្រមព្រៀងគ្នា តម្រូវឱ្យមានអាជ្ញាកណ្ដាលជាអ្នកជំនាញ ដែលនឹងកំណត់មធ្យោបាយចាំបាច់ សម្រាប់ការងារថ្មី ដែលមិនរំខានដល់សិទ្ធិរបស់កម្មសិទ្ធិករណាម្នាក់។

**មាត្រា១៨៩**

កម្មសិទ្ធិករម្នាក់ៗអាចសង់ជាប់នឹងជញ្ជាំងអឡូសិទ្ធិ និងដាក់ធ្នឹមនិងរនូត ចូលក្នុងជញ្ជាំងអឡូសិទ្ធិ ដោយទុកឱ្យសល់ប្រាំសង់ទីម៉ែត្រ តែការងារនេះមិនត្រូវធ្វើឱ្យខូចដល់សិទ្ធិរបស់អ្នកម្ខាងទៀតឡើយ។ ប្រសិនបើកម្មសិទ្ធិករម្ខាងទៀតនោះមានបំណងសង់ពីម្ខាងត្រង់កន្លែងនោះមកវិញដែរ កម្មសិទ្ធិករនោះអាចមានសិទ្ធិទាមទារឱ្យបន្ថយធ្នឹម និងរនូតនោះមកត្រឹមពាក់កណ្ដាលនៃកម្រាស់ជញ្ជាំងវិញ។

**មាត្រា១៩០**

កម្មសិទ្ធិករនៃអចលនវត្ថុដែលនៅជាប់ជញ្ជាំងណាមួយរបស់កម្មសិទ្ធិករដទៃ មានសិទ្ធិធ្វើ

ជញ្ជាំងនោះ ឱ្យទៅជាជញ្ជាំងអឌ្ឍសិទ្ធិទាំងស្រុង ឬមួយចំណែក ដោយសងទៅកម្មសិទ្ធិករនៃជញ្ជាំងនោះ នូវតម្លៃពាក់កណ្ដាលនៃចំណែកដែលខ្លួនចង់ធ្វើឱ្យទៅជាអឌ្ឍសិទ្ធិ បូកនឹងពាក់កណ្ដាលតម្លៃដីដែលសង់ជញ្ជាំងពីលើនោះ។

**មាត្រា១៩១**

កម្មសិទ្ធិករម្នាក់ៗអាចសង់បន្ថជញ្ជាំងអឌ្ឍសិទ្ធិឱ្យខ្ពស់ជាងមុនបាន ប៉ុន្តែត្រូវចេញសោហ៊ុយក្នុងការសាងសង់ ការជួសជុលថែទាំជញ្ជាំងដែលខ្ពស់ហួសកំណត់ដើមនោះតែម្នាក់ឯង។ ក្រៅពីនេះកម្មសិទ្ធិករនោះ ត្រូវចេញសោហ៊ុយសម្រាប់បន្ទុកដែលកើតមកពីការលើកកម្ពស់ហួសទៅលើនោះឱ្យសមតាមតម្លៃផង។

**មាត្រា១៩២**

ប្រសិនបើជញ្ជាំងអឌ្ឍសិទ្ធិមិនមាំ មិនអាចទ្រទ្រង់កម្ពស់ដែលលើកទៅលើនោះបាន អ្នកដែលចង់លើកឱ្យខ្ពស់នោះ អាចរុះរើធ្វើជាថ្មីទាំងអស់ឡើងវិញ ដោយសោហ៊ុយផ្ទាល់ខ្លួន។ ឯកម្រាស់ជញ្ជាំងដែលត្រូវធ្វើលើសពីកម្រាស់ដើម ត្រូវសង់ដាក់ខាងលើដីរបស់ខ្លួន។

**មាត្រា១៩៣**

កម្មសិទ្ធិករម្ខាងទៀតដែលមិនបានជួយការសង់ឱ្យឡើងខ្ពស់ បើត្រូវការយកសំណង់នោះទុកជារបស់អឌ្ឍសិទ្ធិនៃខ្លួនដែរ ត្រូវចេញថ្លៃសំណង់ដែលលើកឱ្យខ្ពស់ពាក់កណ្ដាល បូកនឹងពាក់កណ្ដាលនៃថ្លៃដីដែលសង់ជញ្ជាំងលើសពីកម្រាស់ដើមនោះ។

## ផ្នែកទី២ អំពីស្នាមភ្លោះ របង ភ្លឺអឌ្ឍសិទ្ធិ

**មាត្រា១៩៤**

កំពែងអឌ្ឍសិទ្ធិដែលបានបង្កើតឡើងដោយស្នាមភ្លោះក្ដី ដោយរបងក្ដី ដោយភ្លឺក្ដី ត្រូវតែថែទាំដោយសោហ៊ុយរួម។ តែបើកម្មសិទ្ធិករណាម្នាក់ចង់ដកខ្លួនចេញពីកាតព្វកិច្ចនេះ កម្មសិទ្ធិករនោះអាចធ្វើបានដោយគ្រាន់តែលះបង់អឌ្ឍសិទ្ធិភាពរបស់ខ្លួនចោលប៉ុណ្ណោះ។

ប៉ុន្តែបើស្នាមភ្លោះ ឬភ្លឺនោះ ជាកន្លែងសម្រាប់បង្ហូរទឹកជាធម្មតា សហកម្មសិទ្ធិករមិនអាចលះបង់អឌ្ឍសិទ្ធិរបស់ខ្លួនបានឡើយ។

**មាត្រា១៩៥**

កម្មសិទ្ធិករដែលមានដីជាប់នឹងស្ពានភ្លោះ របង ឬភ្លឺណាមួយដែលមិនមែនជារបស់អឡូសិទ្ធិទេ មិនអាចតម្រូវឱ្យម្ចាស់ស្ពានភ្លោះ ម្ចាស់របង ឬម្ចាស់ភ្លឺនោះដាក់ស្ពានភ្លោះ របង ឬភ្លឺនោះជារបស់អឡូសិទ្ធិឱ្យខ្លួនបានឡើយ ។

**មាត្រា១៩៦**

កម្មសិទ្ធិករនៃរបងអឡូសិទ្ធិអាចជួសជុល កែលំអ ឬរុះរើរបងនោះ រហូតដល់ព្រំប្រទល់កម្មសិទ្ធិរបស់ខ្លួនបាន តែត្រូវធ្វើរបងត្រឹមដីរបស់ខ្លួនឡើងវិញ ។

សិទ្ធិនេះអាចប្រើបាន ក្នុងករណីបើស្ពានភ្លោះ ឬភ្លឺអឡូសិទ្ធិនោះ គ្រាន់តែប្រើប្រាស់ជារបងប៉ុណ្ណោះ ។

**មាតិកាទី៥ អំពីប្រាតិភោគអចលនវត្ថុ**

**មាត្រា១៩៧**

ទ្រព្យជាអចលនវត្ថុអាចបង្កើតជាប្រាតិភោគសម្រាប់ដាក់ធានាការសងបំណុល ដោយកម្មសិទ្ធិករនៃទ្រព្យនោះ តាមរយៈហ៊ីប៉ូតែក ឬការបញ្ចាំ ឬការដាក់ធានា ។

**ជំពូកទី១២ អំពីហ៊ីប៉ូតែក**

**មាត្រា១៩៨**

ហ៊ីប៉ូតែកគឺជាប្រាតិភោគភណ្ឌិក ដែលបើកឱ្យម្ចាស់បំណុលប្ដឹងសុំឱ្យលក់អចលនវត្ថុនោះនៅពេលដល់កំណត់សង ទោះជាអចលនវត្ថុនោះ នៅលើដៃជនណាក៏ដោយ ដើម្បីយកប្រាក់មកសងខ្លួន និងម្ចាស់បំណុលដទៃទៀត ដែលជាអ្នកមានបុព្វសិទ្ធិ និងបុរិមា ដោយមិនដកអចលនវត្ថុនោះពីកម្មសិទ្ធិករទេ ។

**មាត្រា១៩៩**

មានតែអចលនវត្ថុដែលបានចុះបញ្ជីសុរិយោដីទេ ទើបអាចជាកម្មវត្ថុនៃហ៊ីប៉ូតែកបាន ។

**មាត្រា២០០**

ម្ចាស់បំណុលមិនអាចក្លាយជាកម្មសិទ្ធិករនៃទ្រព្យដែលបានដាក់ហ៊ីប៉ូតែក ជំនួសការសងបំណុលបានឡើយ ។

**មាត្រា២០១**

កិច្ចសន្យាហ៊ីប៉ូតែក ត្រូវរៀបចំតាមរូបមន្តយថាភូត ចំពោះមុខអាជ្ញាធរមានសមត្ថកិច្ច ឬអ្នកច្បាប់ណាម្នាក់ដែលមាននីតិសម្បទាក្នុងរឿងនេះ ។ កិច្ចសន្យាត្រូវតែចុះបញ្ជីនៅអង្គភាព

សុរិយោដី។ អាជ្ញាធរមានសមត្ថកិច្ចការតាក់តែងកិច្ចសន្យាហ៊ីប៉ូតែក និងទម្រង់នៃការចុះបញ្ជី នឹងកំណត់ដោយអនុក្រឹត្យ ។

**មាត្រា២០២**

កិច្ចសន្យាហ៊ីប៉ូតែក ត្រូវសរសេរបញ្ជាក់ឱ្យច្បាស់ពីស្ថានភាព និងប្រភេទនៃទ្រព្យសេវភាព ឬបន្ទុកដែលកំណត់ដោយបទបញ្ជាទាំងឡាយ និងតម្លៃនៃទ្រព្យនោះ ។

**មាត្រា២០៣**

ហ៊ីប៉ូតែកច្រើនបន្តបន្ទាប់គ្នាអាចត្រូវបានបង្កើតនៅលើទ្រព្យតែមួយ ។ ម្ចាស់បំណុលម្នាក់ៗប្រើសិទ្ធិ តាមលំដាប់អាទិភាពនៃការចុះលេខាចារឹកហ៊ីប៉ូតែករបស់ខ្លួន ។

**មាត្រា២០៤**

ប្រសិនបើកម្មសិទ្ធិករនៃទ្រព្យដាក់ហ៊ីប៉ូតែក មិនសងបំណុលនៅពេលដល់កំណត់ត្រូវសង ម្ចាស់បំណុលម្នាក់ អាចប្តឹងសុំឱ្យលក់ទ្រព្យនោះបាន ដោយមិនគិតពីលំដាប់នៃហ៊ីប៉ូតែករបស់គេឡើយ ។ ម្ចាស់បំណុលហ៊ីប៉ូតែកនានានឹងត្រូវទទួលសំណងនៅពេលនោះដែរ តាមលំដាប់នៃហ៊ីប៉ូតែកនីមួយៗ ។

**មាត្រា២០៥**

ទ្រព្យដែលកំពុងដាក់បញ្ចាំមិនអាចដាក់ហ៊ីប៉ូតែកបានឡើយ ។

## ជំពូកទី១៣ អំពីការបញ្ចាំអចលនវត្ថុ

**មាត្រា២០៦**

ការបញ្ចាំអចលនវត្ថុគឺជាកិច្ចសន្យាដែលតាមកិច្ចសន្យានោះ កូនបំណុលប្រគល់ឱ្យម្ចាស់បំណុលរបស់ខ្លួន នូវទ្រព្យមួយដើម្បីធានាការសងបំណុល ។ ម្ចាស់បំណុលមានសិទ្ធិសុំឱ្យលក់ទ្រព្យនោះ ដើម្បីសងបំណុលតាមបុព្វសិទ្ធិ និងបុរិមា ដែលខ្លួនមានជាងម្ចាស់បំណុលឯទៀត ។

ការប្រើប្រាស់ទ្រព្យដាក់បញ្ចាំដោយម្ចាស់បំណុល អាចជំនួសការសងបំណុលនេះជាការប្រាក់តែមួយមុខ ឬជាប្រាក់ដើមនិងការប្រាក់ផងក៏បាន បើសិនមានចែងក្នុងកិច្ចសន្យាបញ្ចាំ ។

**មាត្រា២០៧**

កិច្ចសន្យាបញ្ចាំអចលនវត្ថុត្រូវធ្វើជាលាយលក្ខណ៍អក្សរ តាមរូបមន្តលិខិតយថាភូត ដោយអាជ្ញាធរមានសមត្ថកិច្ច ហើយត្រូវចុះបញ្ជីនៅអង្គភាពសុរិយោដី ។

**មាត្រា២០៨**

ការបញ្ចាំអចលនវត្ថុចាត់ទុកជាបានការ ហើយតតិយជនមិនអាចជំទាស់បាន លុះត្រាតែកិច្ចសន្យាបញ្ចាំនោះ បានធ្វើតាមបញ្ញត្តិដូចមានចែងក្នុងមាត្រា២០៧នៃច្បាប់នេះ ។

ការមិនបានចុះបញ្ជីនៅអង្គភាពសុរិយោដីនូវកិច្ចសន្យាបញ្ចាំ បណ្តាលឱ្យថ្លោះសិទ្ធិប្រាតិភោគភណ្ឌិក ហើយម្ចាស់បំណុលមានសិទ្ធិត្រឹមប្តឹងទារសំណងតាមច្បាប់ជាធរមានប៉ុណ្ណោះ ។

**មាត្រា២០៩**

ទ្រព្យជាប់កិច្ចសន្យាបញ្ចាំអចលនវត្ថុ នឹងត្រូវសងមកកូនបំណុលវិញជាចាំបាច់ ចាប់ពីពេលដែលកូនបំណុលបានសងបំណុលទាំងស្រុងរួចហើយ ។

ចំពោះកិច្ចសន្យាដែលមិនបានបញ្ជាក់ពីកាលបរិច្ឆេទផុតកំណត់សង ក្នុងរយៈពេល១០ (ដប់) ឆ្នាំគិតពីថ្ងៃដែលបានចុះកិច្ចសន្យាបញ្ចាំមក បើម្ចាស់បំណុលមិនបានដាក់ពាក្យប្តឹងទៅតុលាការដើម្បីទាមទារឱ្យសងបំណុលទេ ម្ចាស់បំណុលនោះត្រូវបាត់បង់ការធានានៃការដាក់បញ្ចាំ ។

ចំពោះកិច្ចសន្យាដែលបានបញ្ជាក់ថ្ងៃកំណត់សង ក្នុងរយៈពេល១០ (ដប់) ឆ្នាំគិតពីថ្ងៃផុតរយៈពេលសងបំណុល បើម្ចាស់បំណុលមិនបានដាក់ពាក្យប្តឹងទៅតុលាការដើម្បីទាមទារឱ្យសងបំណុលទេ ម្ចាស់បំណុលនោះត្រូវបាត់បង់ការធានានៃការដាក់បញ្ចាំ ។

ការបាត់បង់ការធានានៃការដាក់បញ្ចាំនេះ តម្រូវឱ្យម្ចាស់បំណុលប្រគល់អចលនវត្ថុ និងប័ណ្ណឱ្យកូនបំណុលវិញ តែកូនបំណុលពុំបានរួចពីការសងបំណុលឡើយ ហើយម្ចាស់បំណុលមានសិទ្ធិត្រឹមប្តឹងទារសំណង តាមច្បាប់ជាធរមានប៉ុណ្ណោះ ។

ការលើកលែងបញ្ចាំ ឬការលុបបន្ទុកបញ្ចាំ ត្រូវធ្វើលេខាចារឹកក្នុងបញ្ជីសុរិយោដី តាមការស្នើសុំរបស់កូនបំណុល ឬដោយឯកឯង ។

**មាត្រា២១០**

ក្នុងករណីណាក៏ដោយ ម្ចាស់បំណុលមិនអាចក្លាយជាកម្មសិទ្ធិករនៃទ្រព្យជាប់កិច្ចសន្យាបញ្ចាំបានឡើយ ។ ខសន្យាណាដែលផ្ទុយនឹងបទប្បញ្ញត្តិនេះត្រូវទុកជាមោឃៈ ។

**មាត្រា២១១**

កិច្ចសន្យាបញ្ចាំអចលនវត្ថុ អនុញ្ញាតឱ្យម្ចាស់បំណុលមានសិទ្ធិត្រឹមតែប្តឹងទៅតុលាការ

ឱ្យដាក់លក់អចលនវត្ថុដោយបង្ខំប៉ុណ្ណោះ ដើម្បីសងខ្លួនជាអាទិភាពដោយបុរិមា និងបុព្វសិទ្ធិ មុនម្ចាស់បំណុលដទៃទៀត ។

បើសិនជាក្នុងរយៈពេលនៃកិច្ចសន្យាបញ្ចាំ ម្ចាស់បំណុលដែលទទួលបញ្ចាំទិញអចលនវត្ថុដែលដាក់បញ្ចាំកិច្ចសន្យាទិញនេះត្រូវចុះបញ្ជីនៅអង្គភាពសុរិយោដី ពុំនោះទេនឹងត្រូវចាត់ទុកជាមោឃៈ ។

**មាត្រា២១២**

ម្ចាស់បំណុលដែលបានកាន់កាប់ទ្រព្យដាក់បញ្ចាំ អាចមានសិទ្ធិអាស្រ័យផលពីទ្រព្យនោះដូចជាផលុបភោគីដែរ លុះត្រាតែមានចែងក្នុងកិច្ចសន្យាដាក់បញ្ចាំ ។ ម្ចាស់បំណុលមានកាតព្វកិច្ចថែទាំរក្សា ទុកទ្រព្យនោះឱ្យដូចជាទ្រព្យរបស់ខ្លួន ។ បើទ្រព្យនោះខូចខាតដោយអំពើ ឬកំហុសណាមួយរបស់ខ្លួន ខ្លួនត្រូវសងតម្លៃខូចខាតនោះដោយកាត់ប្រាក់ក្នុងបំណុលបាន ។

**មាត្រា២១៣**

នៅពេលផុតរយៈពេលនៃកិច្ចសន្យាបញ្ចាំ ដោយកូនបំណុលបានសងប្រាក់អសិរិញក្តី ឬដោយផុតរយៈពេលប្តឹង ដូចមានចែងក្នុងមាត្រា២០៩ក្តី ម្ចាស់បំណុលត្រូវសងមកកូនបំណុលវិញនូវទ្រព្យ ឬតម្លៃនៃទ្រព្យ ប្រសិនបើទ្រព្យនេះត្រូវបានវិនាសដោយអំពើ ឬកំហុសណាមួយរបស់ម្ចាស់បំណុល ។

**មាត្រា២១៤**

នៅថ្ងៃចប់កិច្ចសន្យាបញ្ចាំ ហើយកូនបំណុលមកសុំលោះទ្រព្យវិញ តែម្ចាស់បំណុលមិនព្រមឱ្យលោះ ម្ចាស់បំណុលត្រូវជំពាក់កូនបំណុលវិញនូវផល ឬផលទុនដែលបានមកពីទ្រព្យដាក់បញ្ចាំ ដោយគិតចាប់តាំងពីថ្ងៃដែលកូនបំណុលសុំលោះមក ។

**មាត្រា២១៥**

បើទ្រព្យជាដី ហើយកិច្ចសន្យាបញ្ចាំមិនបានចែងឱ្យច្បាស់លាស់ពីថ្ងៃកំណត់សងទេ ម្ចាស់បំណុលនៅតែមានសិទ្ធិយកផល ឬផលទុន ដែលជាផលកើតមកពីការយកចិត្តទុកដាក់របស់ខ្លួន ពីការងាររបស់ខ្លួន និងពីទុនរបស់ខ្លួនក្នុងរដូវដែលកូនបំណុលសុំលោះ ។

ប៉ុន្តែបើទ្រព្យជាផ្ទះ ហើយកិច្ចសន្យាបញ្ចាំមិនបានចែងឱ្យច្បាស់លាស់ពីថ្ងៃកំណត់សងទេ ម្ចាស់បំណុលត្រូវប្រគល់ទ្រព្យដាក់បញ្ចាំនោះឱ្យកូនបំណុល គិតពីថ្ងៃដែលកូនបំណុលបានសងបំណុលរួច ។

**មាត្រា២១៦**

ការប្រាក់ត្រូវបានបញ្ចប់ ចាប់ពីថ្ងៃដែលកូនបំណុលបានសងបំណុលរួច មុនការបញ្ចប់កិច្ចសន្យា ។ ការស្នើសងបំណុលត្រូវបង្ហាញពីចំនួន និងត្រូវកត់ត្រាក្នុងលិខិតដែលមានចុះហត្ថលេខាដោយមេឃុំ ឬចៅសង្កាត់ជាមួយនឹងហត្ថលេខាកូនបំណុល និងសាក្សីពីរនាក់ ។

**មាត្រា២១៧**

ការបង់ពន្ធដារនៅតែជាបន្ទុកនៃកូនបំណុល លើកលែងតែមានការព្រមព្រៀងគ្នាផ្សេងពីនេះរវាងម្ចាស់បំណុល និងកូនបំណុល ។

**មាត្រា២១៨**

បើកូនបំណុលបានសងបំណុលគ្រប់ចំនួនហើយ ម្ចាស់បំណុលមិនអាចរក្សាទុកទ្រព្យដែលបានដាក់បញ្ចាំ ដោយយកលេសថាកូនបំណុលនៅជំពាក់បំណុលមួយផ្សេងទៀតបានទេ ទោះជាបំណុលក្រោយនេះដល់កំណត់ទារហើយក៏ដោយ លើកលែងតែមានកិច្ចសន្យាបញ្ចាំថ្មីមួយទៀតលើទ្រព្យដដែលនេះ ហើយបានរៀបចំតាមទម្រង់នៃច្បាប់ទៀតផង ។

កូនបំណុលអាចប្រើសិទ្ធិខាងលើនេះ លើទាយាទ ឬលើសិទ្ធិវន្តនៃម្ចាស់បំណុលបាន ។

## ជំពូកទី១៤ អំពីការដាក់ធានា

**មាត្រា២១៩**

ការដាក់ធានាគឺជាកិច្ចសន្យាមួយដែលបានសម្រេចឡើង ដើម្បីធានាការសងបំណុលដែលក្នុងនោះ កូនបំណុលប្រគល់ទៅឱ្យម្ចាស់បំណុលរបស់ខ្លួន មិនមែនជាទ្រព្យទេ តែជាប័ណ្ណកម្មសិទ្ធិនៃទ្រព្យនោះ ដែលបានចុះនិទ្ទេសក្នុងបញ្ជីសុរិយោដី ។

**មាត្រា២២០**

កិច្ចសន្យាដាក់ធានា ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ តាមរូបមន្តយថាភូត និងត្រូវចុះលេខាចារឹកក្នុងបញ្ជីសុរិយោដី ។

**មាត្រា២២១**

ក្នុងករណីណាក៏ដោយ ម្ចាស់បំណុលមិនអាចក្លាយជាកម្មសិទ្ធិករនៃទ្រព្យជាប់កិច្ចសន្យាដាក់ធានាបានឡើយ ។ ខសន្យាណាដែលផ្ទុយនឹងបទប្បញ្ញត្តិនេះត្រូវទុកជាមោឃៈ ។

កិច្ចសន្យាដាក់ធានាអនុញ្ញាតឱ្យម្ចាស់បំណុលមានសិទ្ធិត្រឹមតែប្តឹងទៅតុលាការ ឱ្យដាក់

លក់អចលនវត្ថុដោយបង្ខំប៉ុណ្ណោះ ដើម្បីសងខ្លួនជាអាទិភាពដោយបុរិមា និងបុព្វសិទ្ធិមុនម្ចាស់បំណុលដទៃទៀត។

**មាត្រា២២២**

បើកូនបំណុលបានសងបំណុល និងការប្រាក់រួចហើយតាមពេលកំណត់ ឬមុនពេលកំណត់ ម្ចាស់បំណុលត្រូវបង្វិលប័ណ្ណកម្មសិទ្ធិមកកូនបំណុលវិញ ដោយធ្វើលេខាចារឹកលើកលែងបន្ទុកក្នុងបញ្ជីសុរិយោដី។

**មាត្រា២២៣**

កូនបំណុលត្រូវរក្សាទុក គ្រប់គ្រង និងប្រើប្រាស់ទ្រព្យរបស់ខ្លួន ប៉ុន្តែមិនអាចធ្វើអ្វីដែលនាំឱ្យបន្ថយតម្លៃទ្រព្យនោះបានជាដាច់ខាត។

**មាត្រា២២៤**

សិទ្ធិវន្តនៃកូនបំណុល និងសិទ្ធិវន្តនៃម្ចាស់បំណុល មានកាតព្វកិច្ច និងសិទ្ធិដូចគ្នានឹងកូនបំណុល ឬម្ចាស់បំណុលរបស់ខ្លួនដែរ។

**មាត្រា២២៥**

ទាយាទ ឬប្រតិសិទ្ធិនៃកូនបំណុល ព្រមទាំងសមាជិកទាំងឡាយនៃគ្រួសារដែលអាចប្រកាសថាជាសហកម្មសិទ្ធិករនៃទ្រព្យដាក់ធានា មានកាតព្វកិច្ច និងសិទ្ធិ ដូចគ្នានឹងកូនបំណុលដែរ។

## មាតិកាទី៦ អំពីសុរិយោដី

## ជំពូកទី១៥ អំពីរដ្ឋបាលសុរិយោដី

**មាត្រា២២៦**

កម្មសិទ្ធិលើអចលនវត្ថុត្រូវបានធានាដោយរដ្ឋ។ តាមគោលដៅនេះ រដ្ឋបាលសុរិយោដីក្រោមការគ្រប់គ្រងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចធ្វើអត្តសញ្ញាណកម្មទ្រព្យ កសាងប្លង់សុរិយោដី ចេញប័ណ្ណកម្មសិទ្ធិ ចុះបញ្ជីដី និងផ្តល់ព័ត៌មានដល់ជនទាំងឡាយអំពីស្ថានភាពក្បាលដីទាក់ទងទៅនឹងប្រភេទ ទំហំ កម្មសិទ្ធិករ និងបន្ទុកផ្សេងៗដែលអាចមានលើក្បាលដីនោះ។

**មាត្រា២២៧**

ក្បាលដី ឬឯកតាសុរិយោដី គឺជាផ្ទៃដីមួយជាក់លាក់ ឋិតនៅក្នុងឃុំ ឬសង្កាត់តែមួយ

មិនពុះបំបែកដោយព្រំជាប់ មិនដាច់ជារបស់ជនម្នាក់ ឬច្រើននាក់ ក្នុងករណីអវិភាគកម្ម ហើយប្រើប្រាស់ក្នុងរូបភាពតែមួយ ។

ចាត់ទុកជាព្រំជាប់មិនដាច់ដែលនាំឱ្យបំបែកក្បាលដីជាច្រើនក្បាលនោះ គឺរបង ផ្លូវសាធារណៈ ប្រឡាយ និងផ្លូវទឹកដែលមានទទឹងយ៉ាងតិចពីរម៉ែត្រ ។

**មាត្រា២២៨**

ការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋបាលសុរិយោដី ត្រូវកំណត់ដោយអនុក្រឹត្យ ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា២២៩**

រដ្ឋបាលសុរិយោដីមានភារកិច្ចដូចតទៅ៖

-ធ្វើការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ តាមបញ្ញត្តិនៃអនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី

-ធ្វើការពង្រឹងការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ តាមនីតិវិធីដែលនឹងបញ្ញត្តិដោយអនុក្រឹត្យ

-អនុវត្តការអង្កេតវាស់វែងសុរិយោដីនៃក្បាលដី រួមមានការកំណត់ព្រំដី ការបំបែកក្បាលដី ការបង្រួមក្បាលដី និងការកែតម្រូវព្រំប្រទល់នៃក្បាលដី និងជាទូទៅរាល់ការប្រែប្រួលអំពីទំហំដែលបណ្តាលមកពីធម្មជាតិ ឬដោយស្ម័គ្រចិត្ត

-កសាងសៀវភៅគោលបញ្ជីដី ហើយធ្វើលេខាចារឹកឈ្មោះកម្មសិទ្ធិករ និងរាល់ទិន្នន័យដែលប្រមូលបានទាក់ទងទៅនឹងលក្ខណរូប ទំហំ និងអត្តសញ្ញាណនៃអចលនវត្ថុទាំងនោះ

-ធ្វើចរន្តការនូវរាល់ការផ្លាស់ប្តូរ ប្រែប្រួល ទាក់ទងទៅនឹងសិទ្ធិដែលកើតឡើងដោយកិច្ចសន្យាផ្ទេរ ដូចជាការលក់ ការឱ្យ ការដូរ សន្តតិកម្ម ឬពាក់ព័ន្ធនឹងការដូរប្រភេទ ឬស្ថានភាពនៃដី ដូចជាការសាងសង់ ការចាក់បំពេញដី ការជីកកកាយយកដីជាដើម

-អភិរក្សនូវរាល់ឯកសារសុរិយោដីដែលមានប្លង់សុរិយោដី បញ្ជីឈ្មោះកម្មសិទ្ធិករ សៀវភៅគោលបញ្ជីដី និងរាល់ឯកសារគតិយុត្តទាក់ទងទៅនឹងក្បាលដីនីមួយៗ

-ចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុជូនកម្មសិទ្ធិករ និងលិខិតបញ្ជាក់ផ្សេងៗ ទៀត ទាក់ទងទៅនឹងក្បាលដី

-មានកាតព្វកិច្ចប្រគល់ជូនជនដែលបានដាក់ពាក្យស្នើសុំប្លង់ថតចម្លង និងឯកសារ ព័ត៌មាន ទាក់ទងទៅនឹងទីតាំង អត្តសញ្ញាណ ព្រំដី និងសិទ្ធិដែលទាក់ទងទៅនឹងក្បាលដី

-ធ្វើលេខាចារឹកនូវរាល់ហ៊ីប៉ូតែក ការបញ្ចាំ ការដាក់ធានា ការជួលរយៈពេលវែង ឬ សេវភាពដែលបានបង្កើតឡើងលើទ្រព្យជាអចលនវត្ថុ ហើយផ្តល់ព័ត៌មានទៅគ្រប់ជនដែលសាក សួរមករដ្ឋបាលសុរិយោដី អំពីស្ថានភាពនៃកម្មសិទ្ធិដែលជាកម្មវត្ថុនៃការដាក់ហ៊ីប៉ូតែក ដាក់បញ្ចាំ ដាក់ធានា ការជួលរយៈពេលវែង ឬសេវភាពនោះ។

**មាត្រា២៣០**

សោហ៊ុយសេវាផ្សេងៗដែលទាក់ទងទៅនឹងការបំពេញភារកិច្ចខាងលើ ត្រូវកំណត់ដោយ ប្រកាសរួមរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា២៣១**

រដ្ឋបាលសុរិយោដីថ្នាក់កណ្តាល ជាអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ទទួលបន្ទុក រៀបចំ សម្របសម្រួល និងត្រួតពិនិត្យប្រតិបត្តិការទាំងឡាយនៃការវាស់វែងសុរិយោដីដែលធ្វើ ឡើងលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងរាល់ប្រតិបត្តិការកសាងប្លង់សុរិយោដី កសាងបញ្ជី ឈ្មោះកម្មសិទ្ធិករ កសាងសៀវភៅគោលបញ្ជីដី និងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ។ ក្រៅពីនេះ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ត្រូវ កំណត់វិធី និងស្តង់ដារទាក់ទងទៅនឹងឯកសារ។

**មាត្រា២៣២**

រដ្ឋបាលសុរិយោដីខេត្ត-ក្រុង ឬស្រុក-ខណ្ឌនីមួយៗ ត្រូវប្រតិបត្តិរាល់ការណែនាំពីរដ្ឋបាល សុរិយោដីថ្នាក់កណ្តាល។ រដ្ឋបាលសុរិយោដីខេត្ត-ក្រុង ឬស្រុក-ខណ្ឌ ទទួលធ្វើសម្រង់សុរិយោដី ដោយ សហការជាមួយអាជ្ញាធរមូលដ្ឋានដទៃទៀត កាន់កាប់សៀវភៅគោលបញ្ជីដី ធ្វើចរន្តការជាប្រចាំ ក្រោម ការត្រួតពិនិត្យពីរដ្ឋបាលសុរិយោដីថ្នាក់កណ្តាល រក្សាទុកឯកសារ និងផ្តល់ព័ត៌មានដល់អ្នកស្នើសុំ។

**មាត្រា២៣៣**

រដ្ឋបាលសុរិយោដីស្រុក-ខណ្ឌ ត្រូវផ្ញើច្បាប់ចម្លងនៃសម្រង់ឯកសារសុរិយោដីដល់ឃុំ ឬសង្កាត់ដែលពាក់ព័ន្ធ។ មេឃុំ ឬចៅសង្កាត់ ត្រូវអនុញ្ញាតឱ្យជនគ្រប់រូបពិគ្រោះយោបល់ ហើយត្រូវរាយការណ៍ទៅរដ្ឋបាលសុរិយោដីស្រុក-ខណ្ឌ នូវរាល់ការផ្លាស់ប្តូរដែលទាក់ទងទៅនឹងស្ថានភាពនៃកម្មសិទ្ធិ និងកម្មសិទ្ធិករក្នុងមូលដ្ឋានរបស់ខ្លួន។

## ជំពូកទី១៦ អំពីសម្រង់សុរិយោដី

**មាត្រា២៣៤**

សម្រង់សុរិយោដីត្រូវធ្វើតាមបច្ចេកទេស និងវិធីសាស្ត្រ កំណត់ដោយអនុក្រឹត្យ។

**មាត្រា២៣៥**

ក្នុងករណីចាំបាច់ រដ្ឋបាលសុរិយោដីអាចស្នើសុំទៅអាជ្ញាធរដែនដី ឬអង្គភាពយោធា ឬនគរបាលឱ្យជួយជ្រោមជ្រែង ដល់កិច្ចសហប្រតិបត្តិការធ្វើសម្រង់សុរិយោដីនៅនឹងកន្លែង។

គ្មានសមត្ថកិច្ចណាក្រៅពីរដ្ឋបាលសុរិយោដី មានសិទ្ធិកំណត់កម្មសិទ្ធិករនៃក្បាលដី ប្រភេទដី ឬទំហំដីបានឡើយ។

**មាត្រា២៣៦**

ជនទាំងឡាយ ជាពិសេសកម្មសិទ្ធិករ និងជនដែលពាក់ព័ន្ធ មានកាតព្វកិច្ចចូលរួម និងសហការក្នុងការធ្វើសម្រង់សុរិយោដី។ ជនទាំងនោះត្រូវជួយសម្រួលដល់កិច្ចប្រតិបត្តិការវាស់វែងសុរិយោដី និងធ្វើអត្តសញ្ញាណកម្មកម្មសិទ្ធិករ ហើយត្រូវរាយការណ៍អំពីការផ្លាស់ប្តូរទាំងអស់ដែលកើតមាន ទាក់ទងនឹងក្បាលដីរបស់ខ្លួន និងស្ថានភាពនៃទីតាំង និងរាល់ការផ្ទេរសិទ្ធិនៃកម្មសិទ្ធិ។

**មាត្រា២៣៧**

ក្នុងករណីមានវិវាទកម្មអំពីទំហំនៃក្បាលដី ឬឈ្មោះនៃកម្មសិទ្ធិករ កើតឡើងក្នុងពេលប្រតិបត្តិការធ្វើសម្រង់សុរិយោដី អ្នកទទួលខុសត្រូវនៃរដ្ឋបាលសុរិយោដី ត្រូវអញ្ជើញសាមីខ្លួនមកសម្រុះសម្រួល។ ចំពោះវិវាទកម្មដែលកើតឡើងក្នុងតំបន់កំពុងធ្វើការវិនិច្ឆ័យ ដែលមានលក្ខណៈជាប្រព័ន្ធ គណៈកម្មការរដ្ឋបាលមានភារៈសម្រុះសម្រួលវិវាទកម្មនេះ។ បើការព្រមព្រៀងមិនអាចប្រព្រឹត្តទៅបាន អ្នកទទួលខុសត្រូវ ត្រូវបន្តធ្វើអង្កេតវាស់វែងសុរិយោដី ហើយកសាងកំណត់ហេតុនៃវិវាទនោះ តែមិនមានសិទ្ធិអារកាត់ទេ។

កាលបើវិវាទកម្មកើតមាននៅពេលប្រគល់ប័ណ្ណ រដ្ឋបាលសុរិយោដីត្រូវប្រកាន់យកតែឈ្មោះកម្មសិទ្ធិករ ដែលបានចុះក្នុងបញ្ជីរបស់ខ្លួនប៉ុណ្ណោះ។ គ្មានករណីណាដែលរដ្ឋបាលសុរិយោដីអាចកែប្រែ ឬប្រគល់ប័ណ្ណឱ្យបុគ្គលផ្សេងទៀតបានឡើយ។

### ជំពូកទី១៧ អំពីបញ្ជី និងឯកសារសុរិយោដី

**មាត្រា២៣៨**

រដ្ឋបាលសុរិយោដី មានកាតព្វកិច្ចកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដី។

ប្លង់សុរិយោដីគ្របដណ្តប់តំបន់ដែលបានធ្វើការវិនិច្ឆ័យ ដោយមានកំណត់ព្រំប្រទល់កម្មសិទ្ធិសាធារណៈ ឬ/និងកម្មសិទ្ធិឯកជនទាំងអស់ ហើយមានបញ្ជាក់អំពីប្រភេទដីដូចជាដីដាំដុះ ដីព្រៃ ដីលិចទឹក ដីសម្រាប់សំណង់ឧស្សាហកម្មជាដើម។ ការកសាងប្លង់សុរិយោដីត្រូវអនុវត្តតាមនីតិវិធីដែលត្រូវចែងក្នុងអនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដី។ ក្បាលដីកម្មសិទ្ធិនីមួយៗត្រូវមានលេខរបស់វា។

សៀវភៅគោលបញ្ជីដី បង្ហាញចំពោះលេខក្បាលដីកម្មសិទ្ធិនីមួយៗនូវឈ្មោះកម្មសិទ្ធិករ និងមធ្យោបាយនៃការធ្វើអត្តសញ្ញាណកម្មក្បាលដី ការពិពណ៌នាអំពីកម្មសិទ្ធិ ទំហំក្បាលដី សេវភាព និងបន្ទុកផ្សេងៗលើក្បាលដី។ រាល់ការកែប្រែទិន្នន័យទាំងឡាយ ត្រូវតែបានចុះបញ្ជីនៅពេលដែលរដ្ឋបាលសុរិយោដីបានទទួលដំណឹងនេះ។ បញ្ជីនេះត្រូវបានកាន់កាប់ជា៣ (បី) ច្បាប់ ដែលមួយច្បាប់ត្រូវបានរក្សាទុកនៅរដ្ឋបាលសុរិយោដីថ្នាក់កណ្តាល និងពីរច្បាប់ទៀតរក្សាទុកនៅរដ្ឋបាលសុរិយោដីខេត្ត-ក្រុង និងស្រុក-ខណ្ឌ។

សៀវភៅគោលបញ្ជីដី បង្ហាញចំពោះលេខប័ណ្ណកម្មសិទ្ធិ នូវហ៊ីប៉ូតែក ការបញ្ចាំ ការដាក់ធានា និងការជួលរយៈពេលវែងដែលអាចដាក់បន្ទុកលើកម្មសិទ្ធិនោះ។

**មាត្រា២៣៩**

ប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដី មានតម្លៃត្រឹមត្រូវតាមច្បាប់ និងមានអានុភាពច្បាស់លាស់។ ប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដី មិនត្រូវមានការឆូតលុប ការសរសេរត្រួត ការកែ លើកលែងតែមានការបញ្ជាក់ច្បាស់លាស់។

រដ្ឋបាលសុរិយោដីគ្រប់លំដាប់ថ្នាក់ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងការកាន់កាប់នូវបញ្ជីដី និងភាពជាក់លាក់នៃប្រតិបត្តិការសម្រង់សុរិយោដី និងកិច្ចការអភិរក្សឯកសារ។

**មាត្រា២៤០**

ការសាកសួរព័ត៌មានសុរិយោដី មិនអាចត្រូវបានប្រកែកចំពោះជនដែលមានការទាក់ទងឡើយ។ ព័ត៌មានដែលបានចុះក្នុងសៀវភៅគោលបញ្ជីដី ជាកម្មវត្ថុនៃការប្រគល់ច្បាប់ចម្លងដោយត្រូវបង់ប្រាក់ដែលបានកំណត់ក្នុងមាត្រា២៣០នៃច្បាប់នេះ។

## ជំពូកទី១៨ អំពីប័ណ្ណ និងព័ត៌មានសុរិយោដី

**មាត្រា២៤១**

រដ្ឋបាលសុរិយោដីអាចចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ វិញ្ញាបនបត្របញ្ជាក់ហ៊ីប៉ូតែក សលាកប័ត្រព័ត៌មាន និងលិខិតបញ្ជាក់សុរិយោដីអំពីប្រភេទស្ថានភាពគតិយុត្ត លក្ខណរូប និងបន្ទុកនៃក្បាលដី ដោយផ្អែកលើឯកសារ និងសៀវភៅគោលបញ្ជីដី។

**មាត្រា២៤២**

វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ត្រូវចេញឱ្យចំពោះតែកម្មសិទ្ធិករ ឬអ្នកមានសិទ្ធិស្របច្បាប់លើអចលនវត្ថុនោះតែប៉ុណ្ណោះ។

**មាត្រា២៤៣**

សលាកប័ត្រព័ត៌មានសុរិយោដីអាចត្រូវបានផ្ដល់ឱ្យជនដែលបានស្នើសុំ។ ភ្នាក់ងារដែលបានផ្ដល់ព័ត៌មាននេះ ត្រូវទទួលខុសត្រូវចំពោះការផ្ដល់ព័ត៌មានមិនត្រឹមត្រូវដល់អ្នកស្នើសុំ។ ព័ត៌មានដែលផ្ដល់ឱ្យ មិននាំឱ្យជាប់ការទទួលខុសត្រូវដល់រដ្ឋបាលសុរិយោដីទេ។

**មាត្រា២៤៤**

លិខិតបញ្ជាក់សុរិយោដីគឺជាមូលដ្ឋាននៃការអះអាងជាផ្លូវការមួយនៃលិខិតគតិយុត្ត។

កម្មសិទ្ធិអចលនវត្ថុកើតឡើងដោយលិខិតលក់ ឱ្យ ដូរ ឬជម្រះមតិកដែលត្រូវបានធ្វើឡើងដោយបុគ្គលដែលមាននីតិសម្បទា ដូចមានចែងក្នុងមាត្រា៦៥នៃច្បាប់នេះ។ លិខិតទាំងនោះត្រូវតែតម្កល់ទុកនៅរដ្ឋបាលសុរិយោដី។

**មាត្រា២៤៥**

លិខិតលក់ ឱ្យ ដូរ ឬជម្រះមតិកធ្វើឡើងជាឯកជនមិនអាចចុះបញ្ជីបានឡើយ។ តតិយជនមិនអាចជំទាស់បាន លុះត្រាតែលិខិតនោះធ្វើឡើងតាមបែបបទដែលបានកំណត់ក្នុងមាត្រា២៤៤នៃច្បាប់នេះ។

*វាយឡើងវិញ*

មាត្រា២៤៦

ប្រសិនបើលិខិតលក់ ឱ្យ ដូរ ឬជម្រះមតិក បានធ្វើឡើងតាមរូបមន្តយថាភូតដោយបុគ្គលដែលមាននីតិសម្បទា ប៉ុន្តែមិនបានចុះបញ្ជីនៅសុរិយោដីទេ លិខិតនោះនៅតែតតិយជនអាចជំទាស់បាន ហើយកម្មសិទ្ធិករ និងសិទ្ធិវន្តត្រូវទទួលខុសត្រូវដោយខ្លួនឯងក្នុងការខកខានចុះបញ្ជីនេះ ។

**មាតិកាទី៧ អំពីទោសប្បញ្ញត្តិ**

**ជំពូកទី១៩ អំពីការប៉ះពាល់កម្មសិទ្ធិ**

មាត្រា២៤៧

រាល់ការប៉ះពាល់កម្មសិទ្ធិ និងសិទ្ធិស្របច្បាប់ផ្សេងទៀតលើអចលនវត្ថុ អាចជាបទល្មើសព្រហ្មទណ្ឌ អនុលោមតាមបញ្ញត្តិនៃច្បាប់នេះ ហើយការខូចខាតទាំងឡាយដែលបណ្តាលមកពីអំពើនេះ ត្រូវដោះស្រាយដោយសំណងរដ្ឋប្បវេណី ។

មាត្រា២៤៨

ត្រូវចាត់ទុកជាការប៉ះពាល់កម្មសិទ្ធិ និងសិទ្ធិស្របច្បាប់ផ្សេងៗទៀតលើអចលនវត្ថុ ជាបទល្មើសព្រហ្មទណ្ឌក្នុងន័យនៃច្បាប់នេះមាន៖

-រាល់អំពើប្រព្រឹត្តដោយជាក់ស្តែង រំលោភកាន់កាប់អចលនវត្ថុដោយចេតនា ដោយមិនទទួលស្គាល់ប័ណ្ណចេញដោយរដ្ឋបាលសុរិយោដី

-រាល់អំពើប្រព្រឹត្តដោយជាក់ស្តែង រារាំងអ្នកកាន់កាប់ដោយសន្តិភាព ឬភោគីនៃទ្រព្យមួយ នៅក្នុងតំបន់មិនទាន់មានប្លង់សុរិយោដី ដែលរបបកម្មសិទ្ធិមិនទាន់បានពង្រឹងជាស្ថាពរតាមបញ្ញត្តិនៃច្បាប់នេះ

-រាល់ការចូលកាន់កាប់មិនត្រឹមត្រូវតាមច្បាប់ ឬមិនប្រក្រតី លើអចលនវត្ថុដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដែលមិនស្របតាមមាត្រា១៧ មាត្រា១៨ និងមាត្រា១៩នៃច្បាប់នេះ

-រាល់ការបំប្លែងពីសម្បទានមកជាកម្មសិទ្ធិ លើកលែងសម្បទានឆ្លើយតបទៅនឹងប្រយោជន៍សង្គម ។

មាត្រា២៤៩

ការប៉ះពាល់កម្មសិទ្ធិក្នុងន័យនៃមាត្រាខាងលើ អាចជាទង្វើរបស់អាជ្ញាធរមានសមត្ថកិច្ច ឬជាទង្វើរបស់សាមញ្ញជន ដែលធ្វើដោយម្នាក់ឯង ឬដោយផ្សំគំនិតជាមួយភ្នាក់ងាររបស់អាជ្ញាធរ ។

**មាត្រា២៥០**

មន្ត្រី ឬអាជ្ញាធរមានសមត្ថកិច្ច ដែលបានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិស្របច្បាប់លើអចលនវត្ថុ ត្រូវទទួលទោសរដ្ឋបាល បន្ថែមលើទោសព្រហ្មទណ្ឌ និងសំណងរដ្ឋប្បវេណី។

## ផ្នែកទី១ អំពីការប៉ះពាល់កម្មសិទ្ធិសាធារណៈ ឬឯកជន ដោយសាមញ្ញជន

### អនុផ្នែកទី១ អំពីការប៉ះពាល់កម្មសិទ្ធិឯកជន

**មាត្រា២៥១**

ជនណាដែលបានក្លែងប័ណ្ណក្នុងគោលបំណងយកទៅប្រើប្រាស់ជាផ្លូវការ ទោះជាក្នុងរូបភាពអ្វីក៏ដោយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ) ឆ្នាំ ដល់៥ (ប្រាំ) ឆ្នាំ។

**មាត្រា២៥២**

ជនណាដែលបានបំភាន់មន្ត្រីសុរិយោដីក្នុងការបំពេញបេសកកម្ម ឬបំភាន់អាជ្ញាធរក្នុងការចុះបញ្ជីដី ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥០០.០០០ (ប្រាំសែន) រៀល ដល់៣.០០០.០០០ (បីលាន) រៀល ឬ/និងដាក់ពន្ធនាគារពី១ (មួយ) ខែ ដល់៦ (ប្រាំមួយ) ខែ។

**មាត្រា២៥៣**

ជនណាដែលប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ទោះជាមិនទាន់បានធ្វើប័ណ្ណ ឬកំពុងមានទំនាស់ក៏ដោយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១.៥០០.០០០ (មួយលាយប្រាំសែន) រៀល ដល់២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល ឬ/និងដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ដល់ ២ (ពីរ) ឆ្នាំ ដោយពុំទាន់គិតបញ្ចូលនូវទោសប្រព្រឹត្តអំពើហិង្សាប្រឆាំងមនុស្ស។

បន្ថែមលើទោសខាងលើ អ្នកប្រព្រឹត្តអំពើហិង្សាត្រូវទទួលខុសត្រូវចំពោះសំណងរដ្ឋប្បវេណីដល់ជនរងគ្រោះ ដែលបណ្តាលមកពីអំពើហិង្សារបស់ខ្លួន។

បើអំពើហិង្សាខាងលើត្រូវបានបញ្ជាពីជនដទៃទៀតក្រៅពីអ្នកបង្ក ហើយជននោះមិនបានចូលរួមផ្ទាល់ក្តី អ្នកបញ្ជានេះក៏ត្រូវទទួលការផ្តន្ទាទោសដូចអ្នកប្រព្រឹត្តអំពើហិង្សាផ្ទាល់ដែរ។

**មាត្រា២៥៤**

គ្មានករណីណាមួយដែលអនុញ្ញាតឱ្យប្រើប្រាស់កម្លាំងឯកជន ដើម្បីធានាចំពោះការគោរពប័ណ្ណកម្មសិទ្ធិ ឬចំពោះការប្រតិបត្តិសេចក្តីសម្រេចរបស់តុលាការ ក្នុងការបណ្តេញចេញ ឬក្នុងការ

បង្គាប់ឱ្យចាកចេញបានឡើយ។ ជនណាដែលប្រើកម្លាំងឯកជនក្នុងហេតុផលនេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៣.០០០.០០០ (បីលាន) រៀល ដល់២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល ឬ/និងផ្តន្ទាទោសដាក់ពន្ធនាគារពី៦ (ប្រាំមួយ) ខែ ដល់២ (ពីរ) ឆ្នាំ។

**មាត្រា២៥៥**

ជនណាដែលបានលួចលក់ ឬបញ្ចាំអចលនវត្ថុដែលមិនមែនជារបស់ខ្លួនត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ (ប្រាំមួយ) ខែ ដល់៣ (បី) ឆ្នាំ ដោយមិនគិតដល់ព្យសនកម្មដែលបណ្តាលមកពីអំពើរបស់ខ្លួន។

**មាត្រា២៥៦**

កម្មសិទ្ធិករណាដែលបានធ្វើការដាំដុះលើដីរបស់ខ្លួន ឬប្រគល់ដី ឬជួលដីឱ្យតតិយជនដាំដុះដោយចេតនា នូវមុខដំណាំដែលច្បាប់ ឬបទបញ្ជាហាមឃាត់ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១៥.០០០.០០០ (ដប់ប្រាំលាន) រៀល ដល់៤៥.០០០.០០០ (សែសិបប្រាំលាន) រៀល ឬ/និងផ្តន្ទាទោសដាក់ពន្ធនាគារតាមច្បាប់ជាធរមាន។

**មាត្រា២៥៧**

សហកម្មសិទ្ធិករអវិភាគដែលធ្វើឱ្យប៉ះពាល់ដល់ចំណែករួម ដូចមានចែងក្នុងមាត្រា១៨០នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១.៥០០.០០០ (មួយលានប្រាំសែន) រៀល ដល់៩.០០០.០០០ (ប្រាំបួនលាន) រៀល។ ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ទ្វេដង។

**មាត្រា២៥៨**

សហកម្មសិទ្ធិករដែលមិនព្រមចូលរួមទទួលបន្ទុកថែទាំចំណែករួមនៃសហកម្មសិទ្ធិខ្លួន ឬមិនគោរពតាមល័ក្ខខ័ណ្ឌនៃសណ្តាប់ធ្នាប់សាធារណៈ ដូចមានចែងក្នុងមាត្រា១៨៥នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥០០.០០០ (ប្រាំសែន) រៀល ដល់៣.០០០.០០០ (បីលាន) រៀល។

**អនុផ្នែកទី២ អំពីការប៉ះពាល់កម្មសិទ្ធិនៃទ្រព្យសម្បត្តិសាធារណៈ**

**មាត្រា២៥៩**

ការប៉ះពាល់កម្មសិទ្ធិនៃទ្រព្យសម្បត្តិសាធារណៈ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥.០០០.០០០ (ប្រាំលាន) រៀល ដល់៥០.០០០.០០០ (ហាសិបលាន) រៀល ឬ/និងផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ) ឆ្នាំ ដល់៥ (ប្រាំ) ឆ្នាំ។

ចារីត្រូវមានកាតព្វកិច្ចចាកចេញពីទ្រព្យសម្បត្តិសាធារណៈនោះជាបន្ទាន់។ ចារីគ្មានសិទ្ធិទារកម្រៃអំពីពលកម្ម ឬការរៀបចំដែលបានធ្វើលើទ្រព្យនោះឡើយ។

ក្នុងករណីដែលអ្នកកំពុងកាន់កាប់ទ្រព្យសម្បត្តិសាធារណៈ មុនច្បាប់នេះចូលជាធរមាន ហើយមានឯកសារសំអាង និងបញ្ជាក់ជាក់លាក់ថាខ្លួនបានទិញពីជនណាម្នាក់ អាចរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ច ដើម្បីអនុវត្តតាមវិធានច្បាប់ ចំពោះបុគ្គលដែលបានលក់ទ្រព្យសម្បត្តិសាធារណៈនេះដោយខុសច្បាប់ និងដើម្បីជាប្រយោជន៍របស់ខ្លួន ដែលបានរងគ្រោះដោយសារទង្វើនេះ។ ទោះជាយ៉ាងណាក៏ដោយ ក៏ជនរងគ្រោះនេះពុំមានសិទ្ធិកាន់កាប់បន្ត លើទ្រព្យសម្បត្តិសាធារណៈបានឡើយ។

**មាត្រា២៦០**

ជនណាដែលបានលើកចេញ ឬរំកិលចេញ ឬបំផ្លាញចោល នូវបង្គោលស៊ីម៉ងត៍ដៅចំណុចឋានលេខា និងទីតាំងផ្លាកសញ្ញាសុរិយោដី ត្រូវទទួលការព្រមានពីអាជ្ញាធរមានសមត្ថកិច្ច។ ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥០០.០០០ (ប្រាំសែន) រៀល ដល់៣.០០០.០០០ (បីលាន) រៀល ឬ/និងផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ) ខែ ដល់៦ (ប្រាំមួយ) ខែ ដោយមិនគិតដល់ព្យសនកម្មដែលបណ្តាលមកពីអំពើរបស់ខ្លួន។

**ផ្នែកទី២ អំពីការប៉ះពាល់កម្មសិទ្ធិសាធារណៈ ឬឯកជន ដោយអាជ្ញាធររដ្ឋបាល**

**មាត្រា២៦១**

មន្ត្រី ឬអាជ្ញាធរដែលបានប្រើអំណាចដោយរំលោភ ទោះមានបញ្ជាក្តី ឬគ្មានបញ្ជាក្តី ដើម្បីដកហូតអចលនវត្ថុពីអ្នកកាន់កាប់ដោយសន្តិភាព ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ពី១០.០០០.០០០ (ដប់លាន) រៀល ដល់២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល និងត្រូវទទួលទោសរដ្ឋបាលថែមទៀត។

ចាត់ទុកជាការរំលោភ មានការក្លែងបន្លំ ការកសាងប័ណ្ណដោយបំពាន ការគាបសង្កត់ ឬវិធានការសម្ភារៈដើម្បីបណ្តេញចេញ ធ្វើឡើងចំពោះអ្នកកាន់កាប់អចលនវត្ថុ។

បើការដកហូតអចលនវត្ថុបានប្រព្រឹត្តទៅដោយអំពើហិង្សា ចារីត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ (ប្រាំមួយ) ខែ ដល់២ (ពីរ) ឆ្នាំថែមទៀត។

អ្នកបញ្ជាដោយរំលោភ ត្រូវផ្តន្ទាទោសដូចគ្នានឹងអ្នកប្រព្រឹត្តផ្ទាល់ដែរ។

**មាត្រា២៦២**

អាជ្ញាធរមានសមត្ថកិច្ច ឬកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដែលបានរំលោភយកទ្រព្យជាអចលនវត្ថុក្នុងមណ្ឌលដែលខ្លួនមានភារកិច្ចការពារសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខ មកធ្វើជារបស់ខ្លួន ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ពី៣.០០០.០០០ (បីលាន) រៀល ដល់ ៣០.០០០.០០០ (សាមសិបលាន) រៀល ឬ/និងផ្តន្ទាទោសដាក់ពន្ធនាគារពី២ (ពីរ) ឆ្នាំ ដល់៥ (ប្រាំ) ឆ្នាំ និងត្រូវទទួលទោសរដ្ឋបាលថែមទៀត។

**មាត្រា២៦៣**

អាជ្ញាធរមានសមត្ថកិច្ចដែលព្រងើយកន្តើយ ឬបណ្តោយឱ្យសាមញ្ញជនប្រព្រឹត្តដោយរំលោភសិទ្ធិរបស់កម្មសិទ្ធិករ របស់ភោគី ឬរបស់អ្នកកាន់កាប់ដោយសន្តិភាព ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១.០០០.០០០ (មួយលាន) រៀល ដល់១០.០០០.០០០ (ដប់លាន) រៀល និងត្រូវទទួលទោសរដ្ឋបាលថែមទៀត។

**មាត្រា២៦៤**

ការរំលោភធ្វើឡើងដោយមន្ត្រីសុរិយោដី ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១.០០០.០០០ (មួយលាន) រៀល ដល់៥.០០០.០០០ (ប្រាំលាន) រៀល និងត្រូវទទួលទោសរដ្ឋបាលថែមទៀត។

រាប់ចូលជាការរំលោភ ការផ្តល់ទិន្នន័យជាផ្លូវការខុស ការចេញប័ណ្ណកម្មសិទ្ធិខុស ការបិទបាំងហ៊ីប៉ូតែក ឬបន្ទុកផ្សេងៗ ការបោះគោលព្រំដីខុសដោយចេតនា និងរាល់ការធ្វេសប្រហែសក្នុងការធ្វើលេខាចារឹកលើឯកសារសុរិយោដី។

**មាត្រា២៦៥**

រាល់ការប៉ះពាល់ធ្វើឡើងដោយប្រឆាំងនឹងសិទ្ធិលើដីរបស់សហគមន៍ជនជាតិដើមភាគតិចដោយអាជ្ញាធរដែលទទួលខុសត្រូវគ្រប់គ្រងតំបន់ដែលអចលនវត្ថុនោះតាំងនៅ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១.៥០០.០០០ (មួយលានប្រាំសែន) រៀល ដល់៩.០០០.០០០ (ប្រាំបួនលាន) រៀល ឬ/និងផ្តន្ទាទោសដាក់ពន្ធនាគារពី២ (ពីរ) ឆ្នាំ ដល់៥ (ប្រាំ) ឆ្នាំ និងត្រូវទទួលទោសរដ្ឋបាលថែមទៀត។

**មាត្រា២៦៦**

ការប៉ះពាល់អចលនវត្ថុរបស់វត្ត ដោយបុគ្គលដែលទទួលបន្ទុកគ្រប់គ្រង ត្រូវបង្ខំឱ្យសងទ្រព្យនោះវិញ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១.៥០០.០០០ (មួយលានប្រាំសែន) រៀល ដល់៩.០០០.០០០ (ប្រាំបួនលាន) រៀល។

*វាយឡើងវិញ*

## មាតិកាទី៨ អវសានប្បញ្ញត្តិ

**មាត្រា២៦៧**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា២៦៨**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**ហត្ថលេខា**

**អ៊ឹម ឈុនលឹម**

លេខ១៩៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ហត្ថលេខា និងត្រា**

**ណាឌី តាន់**

# សទ្ទានុក្រម
LEXIQUE

## ក . ខ . គ

កម្មសិទ្ធិ (Propriété) សិទ្ធិពេញលេញជាម្ចាស់លើទ្រព្យ ។ សិទ្ធិនេះរួមបញ្ចូលទាំងសិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យផល និងសិទ្ធិចាត់ចែងលើទ្រព្យ ។

កម្មសិទ្ធិករ (Propriétaire) ម្ចាស់កម្មសិទ្ធិលើទ្រព្យ និងមានសិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យផល និងសិទ្ធិចាត់ចែងលើទ្រព្យដែលជារបស់ខ្លួន ។

កតិកាភេទ (Rescision) កិរិយាបដិសេធកិច្ចសន្យាណាមួយ ដោយមកពីកិច្ចសន្យានោះមានវិការៈដល់ឬសគល់ នៃការព្រមព្រៀងគ្នា ។ ក្នុងទីនោះកតិកាភេទ បានន័យថាបដិសេធកិច្ចសន្យាលក់ចោល ដោយមកពីលក់អចលនវត្ថុមានវិការៈអាថិកំបាំង ។

កាតព្វកិច្ច (Obligation) ចំណងនៃសិទ្ធិដែលបង្ខំជនម្នាក់ឱ្យផ្ទេរកម្មសិទ្ធិ ឬសិទ្ធិណាមួយឱ្យបំពេញនូវកិច្ចការណាមួយ ឬឱ្យឈប់បំពេញនូវកិច្ចការណាមួយដល់ជនម្នាក់ទៀត ។

ការជម្រះមត៌ក (Règlement des successions) កិរិយាធ្វើបញ្ជីទ្រព្យសម្បត្តិរបស់ខ្មោចឱ្យដឹងថានៅសល់ប៉ុន្មាន បាត់ប៉ុន្មានដើម្បីនឹងចែកគ្នារវាងទាយាទ និងទាយាទ ។

ការ្យ (Ouvrage) ផលអ្វីទាំងពួងដែលកើតមកពីស្នាដៃជាងឬស្នាដៃសិល្បករ ។ *ឧទា.* តុ ទូ ជាការ្យរបស់ជាង ឯប្រលោមលោកជាការ្យរបស់អ្នកនិពន្ធ ។

កើយ (Balcon) រានហាលតូចគ្មានសរសរទ្រពីក្រោមទេតែមានបង្កាន់ដៃព័ទ្ធជុំវិញ ។

កូនបំណុល (Débiteur) ជនជំពាក់ប្រាក់ ឬជំពាក់កាតព្វកិច្ចគេ ។

កំពែង (Clôture) ស្នាមភ្លោះ របង ភ្លឺ ។

## ច . ឆ . ជ

ចរន្តការ (Mise à jour) ការកត់ត្រាទុកជាប្រចាំក្នុងឯកសារសុរិយោដីនូវរាល់ការប្រែប្រួល ឬការផ្លាស់ប្តូរដោយយោងតាមឯកសារគតិយុត្ត ។

ចារី (Auteur) អ្នកប្រព្រឹត្ត អ្នកដៃដល់ ។

ច្បាប់ (Loi) លិខិតបទដ្ឋានគតិយុត្តដែលអនុម័តដោយអង្គការនីតិបញ្ញត្តិ (សភា) និងចូលជាធរមានតាមរយៈព្រះរាជក្រមប្រកាសឱ្យប្រើ ។

ឆន្ទានុសិទ្ធិ (Pouvoir discrétionnaire) អំណាចដែលប្រគល់ដល់អាជ្ញាធរឱ្យរើសយកមធ្យោបាយណាមួយតាមចិត្តខ្លួនមកដោះស្រាយបញ្ហាណាមួយ ។

ជនជាតិដើមភាគតិច (Indigène) ជនជាតិខ្មែរដើម ។

## ដ . ត . ថ . ទ . ធ . ន

តតិយជន (Tiers,tierce) ជនទីបី ឬភាគីទីបីក្នុងរឿង ។ អ្នកដទៃ ឬអ្នកក្រៅ ។ *ឧទា.* អ្នកលក់ និងអ្នកទិញ ជាភាគីទី១ និងទី២ ។ អ្នកផ្សេងទៀតក្រៅពីអ្នកលក់ និងអ្នកទិញ ហៅថាតតិយជន ។

តីរឋាន (Quai) ការ្យដែលបានកសាងនៅក្នុងកំពង់ផែ ឬលើច្រាំងទន្លេ សម្រាប់នាវាចូលចតសម្រាប់អ្នកដំណើរឡើងចុះនាវា និងសម្រាប់ផ្ទុកទំនិញ និងដាក់ទំនិញចុះ ។

តែងតាំង (Nommer) ឱ្យមុខការ ឱ្យគុណភាព ផ្ដល់ឋានន្តរទី ។ *ឧទា.* ឈ្មោះ "ក" បានតែងតាំងឈ្មោះ "ខ" ជាទាយាទរបស់ខ្លួន ។

ថ្លោះសិទ្ធិ (Déchéance du droit) ប្រាស់ចាកសិទ្ធិ បាត់បង់សិទ្ធិដោយហេតុទណ្ឌកម្ម ឬដោយហេតុមិនបានបំពេញល័ក្ខខ័ណ្ឌដែលច្បាប់ ឬកិច្ចសន្យាតម្រូវឱ្យបំពេញក្នុងរយៈពេលមានកំណត់ ។

ទាយាទ (Héritier) អ្នកដែលច្បាប់តម្រូវឱ្យទទួលមតិកពីជនណាម្នាក់ ។ *ឧទា.* កូនជាទាយាទរបស់ឪពុក ម្ដាយ ចៅជាទាយាទរបស់ជីដូន ជីតា ដែលឥតមានបច្ឆាញាតិជាតំណវង្ស ។

ទ្រព្យសម្បត្តិសាធារណៈ (Domaine public) ទ្រព្យដែលត្រូវរក្សាឱ្យគង់រូបតាមធម្មជាតិរបស់វាដើម្បីទុកឱ្យអ្នករួមសង្គមប្រើប្រាស់ជាអង្វែងទៅដូចជា ស្ពាន ថ្នល់ . . .។ល ។ ទ្រព្យទាំងអស់នេះឋិតនៅជាប្រយោជន៍សាធារណៈមិនអាចលក់ ដូរ និងគ្មានកំណត់អាជ្ញាយុកាលទេ ។

ទ្រព្យសម្បត្តិឯកជន (Domaine privé) ទ្រព្យរបស់សង្គមដែលមិនសម្រាប់ឱ្យជនក្នុងសង្គមនោះប្រើប្រាស់ជាសាធារណៈទូទៅទេ ជាសម្បត្តិដែលសង្គមអាចលក់ ដូរ ជួល ធ្វើអំណោយបាន ។

ធនលាភ (Rente) ផលដែលផ្ដល់ឱ្យមករាល់ឆ្នាំ ដូចជាការប្រាក់ ឈ្នួលដី ឈ្នួលផ្ទះជាដើម ។

ធម្មានុរូប (Légitime) ដែលមានគុណភាពជាអ្វីមួយតាមច្បាប់ ។ *ឧទា.* ចៅហ្វាយស្រុកជាអាជ្ញាធរធម្មានុរូប ។ កូនដែលកើតពីឪពុក-ម្ដាយដែលមានខាន់ស្លា ហៅថាកូនធម្មានុរូប ឬកូនមានខាន់ស្លា ។

និទាយាទភាព (Déshérence) ភាពឥតអ្នកត្រូវទទួលមតិក ។

<u>និទ្ទេស</u> (Mention) សេចក្ដីដែលចុះដោយសង្ខេបនៅលើរឹមទំព័រ ឬនៅខាងចុងទំព័រនៃលិខិតណាមួយ ។

<u>និរាករណ៍</u> (Abrogation) ការលុបចោលលែងឱ្យប្រើច្បាប់នោះតទៅទៀត ។

<u>នីត្យានុកូល</u> (Légal) ដែលកើតមកពីច្បាប់ ដែលច្បាប់តាក់តែងមក ។

<u>នីតិបុគ្គល</u> (Personne morale) ក្រុមមនុស្សដែលច្បាប់ទទួលស្គាល់ថាជាបុគ្គលដែរតែដទៃពីសមាជិកនៃខ្លួន ។ *ឧទា.* ពុទ្ធិកសមាគម ជានីតិបុគ្គល ក្រុមហ៊ុនធ្វើស្ករ ក៏ជានីតិបុគ្គលដែរ ។

<u>នីតិបុគ្គលនៃនីតិសាធារណៈ</u> (Personne morale du droit public) ក្រុមរាជការសាធារណៈ ។ *ឧទា.* រដ្ឋ ខេត្ត ឃុំ ឬគ្រឹះស្ថានសាធារណៈ ដូចជាសាកលវិទ្យាល័យជាដើម ។

<u>នីតិបុគ្គលនៃនីតិឯកជន</u> (Personne morale du droit privé) សមាគម ក្រុមហ៊ុន ក្រុមមូលនិធិ ។

<u>នីតិវិធី</u> (Procédure) វិធីដែលតុលាការប្រើប្រាស់ដើម្បីចាត់ចែងរឿងក្ដីតាំងពីដើមរហូតដល់ចប់ ។

<u>នីតិសម្បទា</u> (Habilité) សមត្ថភាពដែលច្បាប់បើកឱ្យជនម្នាក់ៗមានយ៉ាងគ្រប់គ្រាន់ដើម្បីធ្វើការអ្វីមួយ ។

## ប . ផ . ព . ភ . ម

<u>បទបញ្ជា</u> (Règlement) លិខិតបទដ្ឋានដែលចេញដោយអង្គការ ឬអាជ្ញាធរមានសមត្ថកិច្ច ។

<u>បទប្បញ្ញត្តិ</u> (Disposition) សេចក្ដីបញ្ញត្តិរបស់ច្បាប់ ឬរបស់មាត្រាណាមួយនៃច្បាប់ខសំខាន់របស់លិខិតក្នុងតុលាការ ។

<u>បដិគាហក</u> (Donataire) អ្នកទទួលអំណោយ ។

<u>បដិប្បញ្ញត្តិ</u> (Dérogation) ការតាំងបញ្ញត្តិផ្ទុយ ឬមិនស្រប ។

<u>ប័ណ្ណ</u> (Titre) លិខិតដែលមានរូបមន្ដយថាភូត (ដែលមានរូបភាព និងទម្រង់ត្រឹមត្រូវតាមច្បាប់) សម្រាប់បញ្ជាក់សិទ្ធិណាមួយ ។

<u>ប្លង់សុរិយោដី ឬផែនទីសុរិយោដី ឬប្លង់ក្បាលដី</u> (Plan cadastral) ប្លង់រួមនៃដីតំបន់ណាមួយដែលមន្ត្រីជំនាញសុរិយោដីបានវាស់វែង គូរបំពេញយ៉ាងត្រឹមត្រូវ និងគ្រប់គ្រាន់តាមបទដ្ឋានបច្ចេកទេស ហើយដាក់លេខក្បាលដី ឬដីឡូត៍យ៉ាងច្បាស់លាស់ ។

<u>បន្ទុក/ភារៈ/ធុរៈ</u> (Charges) មុខការ/មុខងារ/អាណត្តិ/ប្រតិកម្មដែលជនណាម្នាក់ធ្វើ ឬបំពេញ ។

<u>បាលិត</u> (Pupille) កូនកំព្រាជាអនីតិជនដែលឋិតនៅក្រោមអាណាព្យាបាលនៃជនម្នាក់។

<u>បុព្វសិទ្ធិ</u> (Prérogative) សិទ្ធិជាពិសេសដែលឱ្យដាច់ទៅលើមុខងារ ឬទៅលើក្រុមនីមួយៗ លើសពីអ្នកដទៃ។

<u>បុរិមា</u> (Préférence) សិទ្ធិដែលបើកឱ្យជនណាម្នាក់បានអ្វីមួយមុនជនឯទៀត។

<u>បេតិកភណ្ឌ</u> (Patrimoine) ទ្រព្យដែលជនម្នាក់ៗមាន និងបំណុលដែលជនម្នាក់ៗជំពាក់គេ។ ទាំងទ្រព្យ ទាំងបំណុលរបស់ជនម្នាក់ៗហៅថា "បេតិកភណ្ឌ"។

<u>ប្រតិសិទ្ធិ</u> (Ayant cause) អ្នកទទួលសិទ្ធិបន្តពីគេដើម្បីប្រកបការរបស់ខ្លួនផង និងជំនួសគេផង

<u>ប្រធានសក្តិ</u> (Force majeure) ព្រឹត្តិការណ៍ដែលកើតឡើងដោយមិនដឹងជាមុន មិនអាចប៉ាន់ស្មានជាមុនបាននិងមិនអាចជំនះបាន។

<u>ប្រទានកម្ម</u> (Donation) ការឱ្យ-អំណោយ។

<u>ប្រាតិភោគភណ្ឌិក</u> (Sûreté réelle) ការយកទ្រព្យទៅធានាបំណុល។ *ឧទា.* ការបញ្ចាំស្រែជាប្រាតិភោគភណ្ឌិកអចលនវត្ថុ។ ការបញ្ចាំខ្សែមាសជាប្រាតិភោគភណ្ឌិកចលនវត្ថុ។ (ក្រមរដ្ឋប្បវេណីចាស់ប្រើប្រាតិភោគប្រត្យក្ស)

<u>ផលទុន</u> (Revenu) ផល ឬចំណេញដែលកើតមកពីប្រាក់ទុន ឬពីមូលនិធិដែលគេយកទៅប្រកបមុខរបរណាមួយ។

<u>ផលធម្មជាតិ</u> (Fruit naturel) ផលិតផលដែលកើតអំពីដីធ្លី ឬកូនសត្វស្រុកដែលកើតពីមេបាវា។

<u>ផលស៊ីវិល</u> (Fruit civil) ប្រាក់ដែលបានមកពីវត្ថុឬពីប្រាក់ដូចជាការប្រាក់ឬឈ្នួលផ្ទះជាដើម។

<u>ផលុបភោគ</u> (Usufruit) សិទ្ធិបរិភោគ និងប្រើប្រាស់ផល និងផលទុនដែលកើតមកពីទ្រព្យជាកម្មសិទ្ធិរបស់អ្នកដទៃ។

<u>ផលុបភោគី</u> (Usufruitier) អ្នកបាននូវផលុបភោគ អ្នកស៊ីផល។

<u>ព្យសនកម្ម</u> (Préjudice) ការខូចខាត ឬសេចក្តីវិនាសអន្តរាយដល់រូបកាយក្តី ដល់សម្ភារៈក្តី ដល់ទឹកចិត្តក្តី ដែលបណ្តាលមកពីអំពើរបស់អ្នកដទៃ។

<u>ព្រឹត្តិការណ៍</u> (Evénement) អ្វីៗដែលកើតមានឡើង ឬដែលប្រព្រឹត្តទៅ។

<u>ភតិសន្យាបតី</u> (Bailleur) ម្ចាស់អចលនវត្ថុដែលដាក់អចលនវត្ថុជួលឱ្យអ្នកដទៃ។

ភាគី (Partie) គូក្តី គូសញ្ញា ជនម្ខាង១ នៃកិច្ចសន្យា។

ភោគៈ (Possession) សិទ្ធិដែលជនម្នាក់១មានលើទ្រព្យណាមួយជាបណ្តោះអាសន្នមិនទាន់ស៊ប់ជារបស់ខ្លួនមែនទែនទេ។ "ភោគៈ" ជាពាក្យផ្ទុយនឹងកម្មសិទ្ធិដែលជាសិទ្ធិពេញបរិបូណ៌របស់ជនម្នាក់១លើទ្រព្យណាមួយ។ *ឧទា.* ដីមានប្លង់សុរិយោដី ជាដីកម្មសិទ្ធិ ឯដីមិនទាន់មានប្លង់សុរិយោដី គឺជាដីភោគៈ។

ភោគី (Possesseur) អ្នកទទួលបានភោគៈ។

មធ្យោបាយ (Moyen) អ្វីដែលជាគ្រឿងសម្រាប់យកទៅដោះស្រាយកិច្ចការ ឬបញ្ហាណាមួយ។

មាតិកា (Titre) មេសេចក្តី ដើមសេចក្តី ចំណែកធំ១នៃច្បាប់។ អត្ថបទច្បាប់ចែកចេញជាគន្ថី គន្ថីចែកចេញជាមាតិកា មាតិកាចែកចេញជាជំពូក ជំពូកនីមួយ១ចែកចេញជាផ្នែក។

## យ . រ . ល . វ

យថាហេតុ (Eventualité) ហេតុដែលពឹងផ្អែកទៅលើព្រឹត្តិការណ៍ណាមួយ គឺថាបើព្រឹត្តិការណ៍នោះកើតឡើងយ៉ាងណា ហេតុនោះ ក៏ត្រូវធ្វើយ៉ាងនោះដែរ។

យ៉ (Saillie) ចំណែកផ្ទះដែលចេញពីជញ្ជាំងទៅខាងមុខ។

រូបមន្ត (Formule) ការងារដែលត្រូវបំពេញឱ្យមានរូបតាមច្បាប់កំណត់។

រូបវន្តបុគ្គល (Personne physique) បុគ្គលដែលមានរូបមែន១ គឺមនុស្សមែន១ ផ្ទុយនឹងនីតិបុគ្គល ដែលជាមនុស្សដោយសន្មតតាមរបៀបច្បាប់។

លេខាចារឹក (Inscription) ការកត់ត្រារឿងហេតុអ្វីមួយចូលក្នុងសៀវភៅ ឬបញ្ជីតាមរូបមន្តដែលបានកំណត់ដើម្បីគ្រប់គ្រងអចលនវត្ថុ ឱ្យបានត្រឹមត្រូវតាមច្បាប់។

ល័ក្ខខ័ណ្ឌ (Condition) គុណភាពដែលត្រូវមាន ឬខដែលត្រូវបំពេញឱ្យគ្រប់ចំនួន ដើម្បីឱ្យបានសម្រេចបំណងណាមួយ។

លក្ខណៈ (Caractère) ភិនភាគ ឫកពារ កិរិយា បែបបទ។

លទ្ធកម្ម (Acquisition) ការបានឡើងជាភោគីឬជាកម្មសិទ្ធិករនៃវត្ថុណាមួយដោយការងាររបស់ខ្លួនក្តី ដោយទិញក្តី ដោយដូរក្តី ដោយសន្តិកម្មក្តី។

លិខិតយថាភូត (Acte authentique) លិខិតធ្វើតាមរូបមន្តនៃច្បាប់ ដូចជាលិខិតបញ្ជាក់ជាដើម។

វិធាន (Règle) មូលសាស្ត្រ ច្បាប់ បន្ទាត់។

<u>វិធានការ</u> (Mesure) មធ្យោបាយ សេចក្ដីប្រយ័ត្ន របៀបចាត់ចែងឡើងដើម្បីបង្ការ ឬទប់ទល់នឹងអ្វីមួយ។

<u>វិការៈអាថិកំបាំង</u> (Vice caché) គុណវិបត្តិឬការខូចខាតនៃវត្ថុអ្វីមួយដែលបានលក់ ហើយដែលគេពិនិត្យមើលលើកដំបូងទៅគ្មានឃើញថាវត្ថុនោះខូចខាតទេ ប៉ុន្តែពេលយកវត្ថុនោះទៅប្រើប្រាស់ប្រើពុំកើតឡើយ។

## ស . ឝ

<u>សន្តតិកម្ម</u> (Succession) ការផ្ទេរតាមច្បាប់នូវទ្រព្យរបស់អ្នកស្លាប់ឱ្យទៅអ្នករស់។ មតិក ឬទ្រព្យរបស់ខ្មោចដែលត្រូវបានទៅទាយាទ (អ្នកបន្តមតិក)។

<u>សៀវភៅគោលបញ្ជីដី</u> (Registre foncier) បញ្ជីគោលសម្រាប់កត់ត្រានូវខ្លឹមសារនៃទិន្នន័យដែលបង្កើតជាស្ថានភាពនៃសិទ្ធិទាក់ទងទៅនឹងទ្រព្យណាមួយ។ ទាក់ទងនឹងស្ថានភាពនេះ ជាទូទៅត្រូវបានកាន់កាប់ និងធ្វើចរន្តការតាមលំដាប់ពេលវេលា។

<u>សម្រង់សុរិយោដី</u> (Relevé cadastral) សេចក្ដីដកស្រង់នូវទិន្នន័យពាក់ព័ន្ធនឹងបច្ចេកទេស និងគតិយុត្តក្នុងវិស័យសុរិយោដី ពីស្ថានភាពជាក់ស្ដែងលើដី យកមកកសាងជាឯកសារសុរិយោដីដើម្បីធានាសិទ្ធិស្របច្បាប់របស់កម្មសិទ្ធិករ។

<u>សម្បទាន</u> (Concession) អចលនវត្ថុ (ដីធ្លី) ដែលរដ្ឋផ្ដល់ឱ្យរូបវន្តបុគ្គល ឬនីតិបុគ្គល សម្រាប់សង់លំនៅឋាន ឬ/និងបង្កបង្កើនផលដោះស្រាយជីវភាពរស់នៅក្នុងទំហំដីតូច ពិសេសសម្រាប់ប្រជាពលរដ្ឋក្រីក្រ (សម្បទានឆ្លើយតបទៅនឹងប្រយោជន៍សង្គម) ឬសម្រាប់ធ្វើការដាំដុះធ្វើអាជីវកម្មកសិឧស្សាហកម្មក្នុងទំហំដីធំទូលាយ ពិសេសសម្រាប់អ្នកវិនិយោគទុន (សម្បទានឆ្លើយតបទៅនឹងប្រយោជន៍សេដ្ឋកិច្ច) តាមរយៈកិច្ចសន្យាផ្ដល់សម្បទានដោយត្រូវបង់ប្រាក់ជូនរដ្ឋ។

<u>សម្បទានិក</u> (Concessionnaire) អ្នកទទួលបានសម្បទាន។

<u>សមាមាត្រ</u> (Proportion) ការ ឬរបស់អ្វីមួយដែលសម ដែលល្មមនឹងការ ឬនឹងរបស់មួយទៀត។ *<u>ឧទា.</u>* ទណ្ឌកម្មដែលតុលាការបានផ្ដន្ទានេះមានសមាមាត្រនឹងអំពើ ដែលជននោះបានប្រព្រឹត្តហើយគឺថាសមរម្យនឹងអំពើនោះហើយ។

<u>សមូហភាព</u> (Collectivité) ជនទាំងឡាយដែលមករួមគ្នាជាក្រុម ឬជាសម្ព័ន្ធមួយ។ មនុស្សទាំងអស់ក្នុងឃុំ ឬក្នុងស្រុក ឬក្នុងក្រុងណាមួយហៅថាសមូហភាព។

<u>សហកម្មសិទ្ធិ</u> (Co-propriété) កម្មសិទ្ធិតែមួយជារបស់ប្រជាជនច្រើននាក់។ *ឧទា.* ជនច្រើននាក់រួបរួមគ្នាទិញរថយន្តមួយ។ រថយន្តនោះជាសហកម្មសិទ្ធិរបស់ជនទាំងឡាយដែលទិញនោះ។

<u>សហកម្មសិទ្ធិករ</u> (Co-propriétaire) អ្នកដែលមានសហកម្មសិទ្ធិ។

<u>សហគមន៍</u> (Communauté) អ្វីៗដែលជនទាំងឡាយយកមករួមគ្នា។ ទ្រព្យសហគមន៍ គឺទ្រព្យដែលប្តី-ប្រពន្ធរកបានជាមួយគ្នា។

<u>សហទាយាទ</u> (Co-héritier) អ្នកដែលត្រូវចូលរួមក្នុងការចែកមតិកណាមួយ។

<u>សហព័ទ្ធ</u> (Conjoint) ប្តី ឬប្រពន្ធ ឬទាំងប្តីទាំងប្រពន្ធ។

<u>ស្ថាពរ</u> (Définitif) មាំមួន ជាប់រហូត។ *ឧទា.* សាលក្រមជាស្ថាពរគឺសាលក្រមដែលកាត់សេចក្តីជាស្រេចដាច់ខាត មិនត្រូវរុះរើទៀតទេ គឺថា គូក្តីមិនអាចប្តឹងឧទ្ធរណ៍ ប្តឹងសាទុក្ខបានឡើយ។

<u>សិទ្ធិវន្ត</u> (Ayant-droit) អ្នកមានសិទ្ធិលើវត្ថុណាមួយ។

<u>សិល្បការ្យ ឬការ្យសិល្បៈ</u> (Ouvrage d'art) សំណង់ធំៗមានសារៈសំខាន់ ធ្វើអំពីដែកឬ/និងស៊ីម៉ងត៍ ដូចជា ស្ពាន អង់តែនវិទ្យុ-ទូរទស្សន៍ ផ្លូវរូងក្នុងដី ឬភ្នំ។

<u>សេវភាព</u> (Servitude) បន្ទុកដែលផ្ទុកលើអចលនវត្ថុមួយ (ដីបម្រើ ឬដីក្រោម) ដើម្បីជាប្រយោជន៍ដល់អចលនវត្ថុមួយទៀត (ដីប្រើ ឬដីលើ) ដែលជារបស់កម្មសិទ្ធិករផ្សេងទៀត។ *ឧទា.* ស្រែក្រោមមានសេវភាពខាងទទួលទឹកពីស្រែលើ។ ស្រែក្រោមហៅថាស្រែបម្រើ ហើយស្រែលើហៅថាស្រែប្រើ។

<u>ហិតូបត្ថម្ភកៈ</u> (Curateur) ជនដែលច្បាប់ចាត់ឱ្យឃុំគ្រងទ្រព្យរបស់អនីតិជនឬទ្រព្យរបស់ជនល្ងីល្ងើជាដើម។

**អ**

<u>អច្ច័យទាន</u> (Legs) សំបុត្របណ្តាំដែលផ្តាំឱ្យចែកទ្រព្យមតិកណាមួយឱ្យទៅជនណាម្នាក់ ឬច្រើននាក់។

<u>អឌ្ឍសិទ្ធិ</u> (Mitoyen) ដែលមានសិទ្ធិពាក់កណ្តាលម្នាក់ ដែលជារបស់ជនពីរនាក់ និងជាព្រំនៃកម្មសិទ្ធិនៃជនទាំងពីរនាក់នោះផង។ *ឧទា.* ជញ្ជាំងអឌ្ឍសិទ្ធិ គឺជញ្ជាំងរបស់ជនពីរនាក់ដែលមានផ្ទះជាប់គ្នា។

អឡ្ឋសិទ្ធិភាព (Mitoyenneté) ភាពដែលជាអឡ្ឋសិទ្ធិ ។

អត្តសញ្ញាណ (Identité) សញ្ញាទាំងអស់នៃជនម្នាក់ៗដែលជាគ្រឿងសំគាល់កុំឱ្យភាន់ច្រឡំនឹងជនម្នាក់ទៀត ។

អត្តាធិនភាព (Emancipation) ការបើកឱ្យក្មេងដែលនៅក្នុងអនីតិភាពនៅឡើយគ្រប់គ្រងខ្លួននិងទ្រព្យសម្បត្តិខ្លួនដោយខ្លួនឯង ។

អត្ថគាហក (Bénéficiaire) អ្នកដែលបានចំណេញ ឬបានកំរៃពីវត្ថុណាមួយ ពីគុណប្រយោជន៍អ្វីមួយ ឬពីឯកសិទ្ធិណាមួយ ។

អនុបយោគ (Désaffectation) ការលែងប្រើតាមការចាត់ការលុបបន្ទូវគម្យស្ថាននៃអគារសាធារណៈ ។ នៅទីនេះច្បាប់អនុបយោគ ជាច្បាប់ដែលរំសាយពីប្រភេទទ្រព្យសម្បត្តិមួយទៅប្រភេទទ្រព្យសម្បត្តិមួយទៀត ដូចជារំសាយពីទ្រព្យសម្បត្តិសាធារណៈ មកជាសម្បត្តិឯកជនរបស់រដ្ឋជាដើម ។

អាណាព្យាបាល (Tuteur) បុគ្គលដែលមានភារកិច្ចតំណាងឱ្យអនីតិជន ។

អវយវភេទ (Démembrement) ការបាក់បែកអវយវៈ ។ ក្នុងច្បាប់ អវយវភេទបានន័យថា ការផ្ទេរសិទ្ធិខ្លះរបស់ខ្លួនលើកម្មសិទ្ធិណាមួយឱ្យទៅអ្នកដទៃ ។

អវិភាគកម្ម (Indivision) ភាពដែលចែកគ្នាមិនបាន ។ *ឧទា.* ផ្ទះមួយជាមតិករបស់កូន៥នាក់ ពុះផ្ទះនោះចែកគ្នា ផ្ទះនោះនឹងអន្តរាយជាមិនខាន ។ ដូច្នេះផ្ទះនេះជាមតិកអវិភាគ ។

អសារកម្មសិទ្ធិ (Nue-propriété) កម្មសិទ្ធិដែលឥតឱ្យផលដល់ម្ចាស់កម្មសិទ្ធិទេ ដោយហេតុថាម្ចាស់កម្មសិទ្ធិនោះឱ្យសិទ្ធិខ្លួនទៅ អ្នកដទៃស៊ីផលនៃកម្មសិទ្ធិនេះទាំងអស់ ។

អាជ្ញាធរ (Autorité) អ្នកទ្រទ្រង់អំណាច អ្នករាជការដែលកាន់អំណាច ។

អាជ្ញាយុកាល (Prescription) មធ្យោបាយម្យ៉ាងសម្រាប់ដោះខ្លួនឱ្យរួចផុតពីកាតព្វកិច្ចណាមួយកាលណាបើម្ចាស់កាតព្វកិច្ចនោះបណ្តែតបណ្តោយឱ្យជំពាក់យូរពេកមិនទារ ។

ឧបាគមន៍ (Accession) អំពើដែលឈានទៅដល់ការឈានទៅទទួលបាន (ក្រមរដ្ឋប្បវេណីចាស់ ប្រើ សិទ្ធិដំណុះ) ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ៤៣សជណ/កបច**

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០១

**សេចក្តីជូនដំណឹងស្តីពីការបញ្ចប់ការចូលកាន់កាប់ភោគៈលើអចលនវត្ថុ**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាសូមជូនដំណឹងដល់គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ព្រមទាំងប្រជាពលរដ្ឋទាំងអស់ឱ្យបានជ្រាបថា ច្បាប់ភូមិបាលដែលរដ្ឋសភា និងព្រឹទ្ធសភាទើបបានអនុម័តកាលពីខែកក្កដា និងសីហា ឆ្នាំ២០០១ កន្លងទៅនេះ ត្រូវបានព្រះករុណាជាម្ចាស់ជីវិតលើត្បូងឡាយព្រះហស្តលេខាប្រកាសឱ្យប្រើនាថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១រួចហើយ។ ដោយបទប្បញ្ញត្តិនៃមាត្រា២៩ វាក្យខណ្ឌទី២នៃច្បាប់នេះបានចែងច្បាស់ថា "ការចូលកាន់កាប់ភោគៈត្រូវបញ្ចប់នៅពេលដែលច្បាប់នេះចូលជាធរមាន" រាជរដ្ឋាភិបាលសូមប្រកាសថាអំណើះតទៅ រាល់ការកាន់កាប់ភោគៈលើអចលនវត្ថុត្រូវហាមឃាត់។

ដើម្បីធានាឱ្យការអនុវត្តច្បាប់ភូមិបាលនេះមានប្រសិទ្ធភាពខ្ពស់ ក៏ដូចជាការរក្សាសណ្តាប់ធ្នាប់សាធារណៈឱ្យបានរៀបរយល្អប្រសើរ រាជរដ្ឋាភិបាលសូមកំណត់នូវវិធានការដូចខាងក្រោម៖

-អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវចាត់វិធានការទប់ស្កាត់ និងហាមឃាត់មិនឱ្យមានការចូលកាន់កាប់ដីថ្មី លើអចលនវត្ថុ និងការរានដីថ្មី

-គ្រប់ក្រសួង ស្ថាប័នត្រូវចូលរួមសហការ និងបង្កលក្ខណៈដល់អាជ្ញាធរខេត្ត-ក្រុងដើម្បីអនុវត្តវិធានការបញ្ចប់ការចូលកាន់កាប់ភោគៈនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

ចំពោះភោគៈស្របច្បាប់ ដែលមានកន្លងមកមុនច្បាប់នេះចូលជាធរមាន ដោយយោងតាមមាត្រា៤០នៃច្បាប់ភូមិបាលថ្មី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបន្តចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ជូនប្រជាពលរដ្ឋបន្តទៀត ដោយធ្វើការកែសម្រួលនីតិវិធីនៃការផ្តល់ប័ណ្ណ ស្របតាមខ្លឹមសារនៃច្បាប់ភូមិបាលនេះ។

*វាយឡើងវិញ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**លេខ៤៣៨សសរ/កសក**

## សេចក្ដីសម្រេចស្ដីពីការបង្កើតគណៈកម្មការកំណត់ដីភូមិ និងដីកសិកម្ម ដែលប្រជាពលរដ្ឋកំពុងធ្វើអាជីវកម្មក្នុងដែនព្រៃសម្បទាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ/បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សម្រេច**

**ប្រការ១**

បង្កើតគណៈកម្មការមួយដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១-ឯកឧត្ដម អ៊ុក សុខុន អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាប្រធាន |
| ២-លោក ជា សំណាង អនុប្រធាននាយកដ្ឋានរុក្ខាប្រមាញ់ | អនុប្រធាន |
| ៣-លោក ចាយ សាគុណ អនុប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៤-លោក ឆេង គឹមស៊ុន ប្រធានការិយាល័យកិច្ចការព្រៃឈើ (នរប្រ) | សមាជិក |
| ៥-លោក ចាន់ សុផល អនុប្រធានវិទ្យាស្ថានសិក្សាស្រាវជ្រាវព្រៃឈើ និងសត្វព្រៃ (នរប្រ) | សមាជិក |

៦-លោក ហង្សជួន ចំរ៉ុង អនុប្រធានការិយាល័យផែនការ (នផស) សមាជិក

៧-លោក មាស មករា មន្ត្រីនាយកដ្ឋានរុក្ខាប្រមាញ់ សមាជិក

**ប្រការ២**

គណៈកម្មការនេះមានភារកិច្ចៈ

១-ធ្វើការសិក្សាស្រាវជ្រាវដីភូមិ និងដីកសិកម្មដែលប្រជាពលរដ្ឋកំពុងធ្វើអាជីវកម្មនៅគ្រប់ព្រៃសម្បទានទាំងអស់ដោយសហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត-ក្រុងសាមី។

២-ចុះវាស់វែងកំណត់ដីភូមិ និងដីកសិកម្មដែលប្រជាពលរដ្ឋកំពុងធ្វើអាជីវកម្មនៅក្នុង ដែនព្រៃសម្បទាន។

៣-រៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការកាត់ផ្ទៃដីភូមិ និងដីកសិកម្មដែលប្រជាពលរដ្ឋកំពុងធ្វើអាជីវកម្មចេញពីព្រៃសម្បទានជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ៣**

អគ្គនាយក អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានរុក្ខាប្រមាញ់ ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគ្រប់ខេត្ត-ក្រុង និងឯកឧត្តម អស់លោក ដែលមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ភ្នំពេញ ថ្ងៃទី១៨ ខែ១០ ឆ្នាំ២០០១

**រដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ច័ន្ទ សារុន**

កន្លែងទទួល

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-គ្រប់សាលាខេត្ត-ក្រុងពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

-ដូចប្រការ៣

"ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**លេខ៥៧២១កសក**

**សេចក្តីប្រកាសស្តីពីការផ្អាកសកម្មភាពអាជីវកម្មព្រៃគុបសម្រាប់ក្រុមហ៊ុនព្រៃសម្បទាន**

ក្នុងអាណត្តិទី២នៃរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ម៉ឺងម៉ាត់ និងឈ្លាសវៃបំផុតរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដំណើរការនៃការកែទម្រង់វិស័យព្រៃឈើបាន និងកំពុងទទួលនូវជោគជ័យជាបន្តបន្ទាប់ ជាពិសេសក្នុងការលុបបំបាត់អំពើអនាធិបតេយ្យព្រៃឈើគ្រប់ប្រភេទ ហើយបង្កើតបាននូវសណ្តាប់ធ្នាប់ និងប្រក្រតីភាពជាមូលដ្ឋានល័ក្ខខ័ណ្ឌគន្លឹះសម្រាប់ឈានឆ្ពោះទៅរកការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព នៅកម្ពុជានាអនាគតឆាប់ៗខាងមុខនេះ។ ទន្ទឹមនេះ ដំណើរការកែទម្រង់ការគ្រប់គ្រងព្រៃសម្បទានក៏បាន និងកំពុងអនុវត្តយ៉ាងសកម្មដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រោមជំនួយបច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ីបានដំណើរការ និងបញ្ចប់ការត្រួតពិនិត្យសើរើកិច្ចព្រមព្រៀងព្រៃសម្បទានកម្ពុជាទូទាំងប្រទេស ហើយជាលទ្ធផលគឺរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចលុបចោល និងដកហូតព្រៃសម្បទានចំនួន១៦កន្លែង មានផ្ទៃដីសរុប ២.៤៣៧.៩៧០ហិកតា ពី១២ក្រុមហ៊ុន។ រីឯក្រុមហ៊ុនព្រៃសម្បទានទាំង១៧ ដែលនៅមានសុពលភាពបានឯកភាពធ្វើការសិក្សារៀបចំផែនការគ្រប់គ្រងព្រៃសម្បទានសាជាថ្មី និងចរចាកិច្ចព្រមព្រៀងវិនិយោគទុនព្រៃសម្បទានសាជាថ្មី តាមគំរូបមាណីយ៍អន្តរជាតិនៃនិរន្តរភាពព្រៃឈើនៅត្រឹមដំណាច់ឆ្នាំ២០០១នេះ។ ប៉ុន្តែរហូតមកដល់បច្ចុប្បន្ននេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានពិនិត្យឃើញថា ពុំទានមានក្រុមហ៊ុនព្រៃសម្បទានណាមួយបានសម្រេចលទ្ធផលទាំងស្រុងតាមកម្មវិធីដែលបានឯកភាពគ្នាខាងលើនេះនៅឡើយ។

អាស្រ័យហេតុនេះ ដើម្បីសម្រេចឱ្យបាននូវគោលដៅជាចុងក្រោយក្នុងការបំពេញល័ក្ខខ័ណ្ឌគន្លឹះសម្រាប់ធានាដល់ការគ្រប់គ្រងព្រៃសម្បទានកម្ពុជាដោយនិរន្តរភាពនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រេចធ្វើសេចក្តីប្រកាសជាសាធារណៈដូចខាងក្រោមនេះ៖

១-ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០២ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានរុក្ខាប្រមាញ់) នឹងធ្វើការផ្អាកការផ្តល់លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មព្រៃគុបដល់ព្រៃសម្បទានិកទាំងអស់ រហូតដល់មានការយល់ព្រមលើផែនការគ្រប់គ្រងព្រៃឈើថ្មី ច្បាស់លាស់ស្របទៅតាមតម្រូវការនៃបទប្បញ្ញត្តិច្បាប់ និងបច្ចេកទេសសម្រាប់ដំណើរការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព។

២-រាល់ព្រៃគុបដែលបាន និងកំពុងធ្វើអាជីវកម្មក្នុងឆ្នាំ២០០១ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានរុក្ខាប្រមាញ់) នឹងធ្វើការបិទព្រៃគុប ដោយបញ្ជាឱ្យព្រៃសម្បទានិកទាំង

អស់ធ្វើការបញ្ឈប់រាល់សកម្មភាពអាជីវកម្មកាប់រំលំដើមឈើត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០១នេះ ជាកំហិត រហូតដល់តម្រូវការនៃបទប្បញ្ញត្តិច្បាប់ និងបច្ចេកទេសប្រតិបត្តិត្រូវបានបំពេញ។

៣-នាយកដ្ឋានរុក្ខាប្រមាញ់ត្រូវធ្វើសារពើភ័ណ្ឌឈើហ៊ុបស្របច្បាប់ ដែលបានមកពីការធ្វើអាជីវកម្មកាប់រំលំមុនថ្ងៃទី០១ ខែមករា ឆ្នាំ២០០២នៅក្នុងព្រៃគុប គំនរឈើ និងទីកន្លែងផ្សេងៗទៀតដែលឋិតនៅក្នុងតំបន់ព្រៃសម្បទាន ឬទីគំនរឈើផ្សេងៗទៀត ដើម្បីកំណត់ឱ្យបានច្បាស់លាស់នូវសន្និធិឈើហ៊ុបខាងលើសម្រាប់រង់ចាំព្រៃសម្បទានិកបង់ថ្លៃសួយសារ និងដឹកជញ្ជូនទៅកាន់កន្លែងកែច្នៃ ឬប្រើប្រាស់។ លទ្ធផលនៃសារពើភ័ណ្ឌឈើហ៊ុបទាំងអស់នេះអាចនឹងផ្តល់ជូនតាមការស្នើសុំ។

៤-ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០២ នាយកដ្ឋានរុក្ខាប្រមាញ់ត្រូវផ្អាកការផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនឈើហ៊ុបដល់ព្រៃសម្បទានិក រហូតដល់មានការបង់ថ្លៃសួយសារ និងវាយត្រារួច។

៥-នាយកដ្ឋានរុក្ខាប្រមាញ់ត្រូវរាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនូវលទ្ធផលការងារដែលអនុវត្តបាន និងការលំបាកក្នុងការអនុវត្តដើម្បីក្រសួងមានវិធានការជាក់ស្តែង។

សេចក្តីប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០១

**រដ្ឋមន្ត្រី**
**ហត្ថលេខា និងត្រា**
**ចំន្ទ សារុន**

<u>កន្លែងទទួល</u>

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងព័ត៌មាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងផែនការ
-ក្រសួងយុត្តិធម៌
-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-គ្រប់សាលាខេត្ត-ក្រុង
"ដើម្បីជូនជ្រាប"
-អង្គភាពក្រោមឱវាទក្រសួង
-មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត-ក្រុង
-សមាគមឧស្សាហកម្មឈើកម្ពុជា
-គ្រប់ក្រុមហ៊ុនព្រៃសម្បទាន
"ដើម្បីអនុវត្ត"

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ៣៧៧សហវ                                        រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០២

## ប្រកាសអន្តរក្រសួង[3]
## ស្តីពីការកំណត់ចំណូលពីសោហ៊ុយសេវាសុរិយោដី

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ០៤អនក្រ/បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ/បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- អនុវត្តតាមអនុក្រឹត្យលេខ៨១អនក្រ/បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណរដ្ឋបាល

---

[3] ត្រូវបានកែសម្រួលដោយប្រកាសអន្តរក្រសួងលេខ៣៩៦សហវ/បក/២៨ តុលា ២០០៤ និងត្រូវបានរៀបចំឡើង វិញដោយសេចក្តីសម្រេចចិត្តសេវាសុរិយោដីលេខ៩១សសវ/២១ ធ្នូ ២០០៦ ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ សូមមើលទំព័រ 659 និង 858 ។

- អនុវត្តតាមអនុក្រឹត្យលេខ៨២អនក្រ/បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- អនុវត្តតាមប្រកាសលេខ០០៤សហវ/មប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- អនុវត្តតាមសារាចរណែនាំលេខ០០២សហវ/ម ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩៦ ស្តីពីរដ្ឋទេយ្យចំណូល
- តាមការចាំបាច់ក្នុងការអនុវត្តច្បាប់ភូមិបាល ។

## សម្រេច

### ប្រការ១

អនុញ្ញាតឱ្យយកសោហ៊ុយសេវាសុរិយោដី លើការចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ការចេញប័ណ្ណទុតិយតា ការចេញប័ណ្ណតតិយតា ការផ្ទេរសិទ្ធិលើអចលនវត្ថុ ការចេញលិខិតបញ្ជាក់សុរិយោដី (ហ៊ីប៉ូតែក បញ្ចាំ ដាក់ធានា) ការចេញសលាកប័ត្រព័ត៌មាន ការចេញលិខិតបញ្ជាក់សុរិយោដី និងការថតចម្លងឯកសារ ព្រមទាំងការបំពេញបែបបទឯកសារផ្សេងៗទៀតដែលទាក់ទងនឹងការងារសុរិយោដី ។

### ប្រការ២

សោហ៊ុយសេវាសុរិយោដី ត្រូវបានកំណត់ដូចតទៅ៖

| ល.រ | បរិយាយ | សោហ៊ុយសេវាសុរិយោដី | | |
|---|---|---|---|---|
| | | ដីផលិតកម្ម ឬដីភោគៈ | ដីលំនៅឋាន និងដីសម្រាប់សំណង់ទូទៅ | |
| | | | ជនបទ ឬក្រៅក្រុង | ទីក្រុង ឬ ទីរួមខេត្ត |
| ១ | ការចេញប័ណ្ណ ឬប័ណ្ណទុតិយតា ឬប័ណ្ណតតិយតា "ក្នុង១ក្បាលដី" | ៥.០០០៛០០ | ១០០.០០០៛០០ | ៣៥០.០០០៛០០ |
| ២ | ការផ្ទេរអចលនវត្ថុ (ផ្ទេរដោយបំបែក ឬផ្ទេរទាំងមូល) "ក្នុង១ប័ណ្ណ" | ៥០.០០០៛០០ | ៨០.០០០៛០០ | ១០០.០០០៛០០ |
| ៣ | ការបង្រួមក្បាលដី "ក្នុង១ក្បាលដីដើម" | ១០០.០០០៛០០ | ១២០.០០០៛០០ | ១៥០.០០០៛០០ |
| ៤ | ការចេញលិខិតបញ្ជាក់ (ហ៊ីប៉ូតែក ដាក់បញ្ចាំ ដាក់ធានា) "ក្នុង១ក្បាលដី" | ១៥.០០០៛០០ | ១៨.០០០៛០០ | ២០.០០០៛០០ |
| ៥ | ការចេញសលាកប័ត្រព័ត៌មាន "ក្នុង១ក្បាលដី" | ១៥.០០០៛០០ | ១៨.០០០៛០០ | ២០.០០០៛០០ |
| ៦ | ការចេញលិខិតបញ្ជាក់សុរិយោដី "ក្នុង១ក្បាលដី" | ១៥.០០០៛០០ | ១៨.០០០៛០០ | ២០.០០០៛០០ |

*វាយឡើងវិញ*

ចំពោះការផ្ទេរសិទ្ធិលើអចលនវត្ថុ សោហ៊ុយសេវាសុរិយោដីជាបន្ទុករបស់អ្នកទទួលសិទ្ធិ។ អ្នកទទួលសិទ្ធិអចលនវត្ថុក៏ត្រូវបង់ពន្ធផ្សេងៗទៀតតាមច្បាប់សារពើពន្ធជាធរមាន។

**ប្រការ៣**

សោហ៊ុយសេវាសុរិយោដីលើការវាស់វែងដី ដោយប្រើឧបករណ៍វាស់ស្ទង់ទំនើបត្រូវបាន កំណត់ដូចខាងក្រោម៖

| ល.រ | បរិយាយ | សោហ៊ុយក្នុង១ហិកតា |
|---|---|---|
| ១ | ទំហំដីតិចជាង១០ហិកតា | ៣០.០០០៛០០ |
| ២ | ទំហំដីចាប់ពី១០ហិកតា ដល់៥០ហិកតា | ១៥.០០០៛០០ |
| ៣ | ទំហំដីចាប់ពី៥១ហិកតា ដល់៣០០ហិកតា | ១០.០០០៛០០ |
| ៤ | ទំហំដីចាប់ពី៣០១ហិកតា ដល់១.០០០ហិកតា | ៨.០០០៛០០ |
| ៥ | ទំហំដីចាប់ពី១.០០០ហិកតាឡើងទៅ | ៦.០០០៛០០ |

ចំពោះដីដែលមានទីតាំងឆ្ងាយលើសពី៥០គីឡូម៉ែត្រពីអង្គភាពសុរិយោដី ម្ចាស់ដីត្រូវទទួល បន្ទុកបន្ថែមលើ៖

១-សោហ៊ុយធ្វើដំណើរ ស្នាក់នៅ ហូបចុករបស់មន្ត្រីជំនាញ។

២-ថ្លៃបង្គោល និងការដាំបង្គោលព្រំ។

៣-ចំពោះតំបន់ព្រៃភ្នំ សោហ៊ុយសេវាសុរិយោដីត្រូវគិតបន្ថែម២០% លើសោហ៊ុយសេវា វាស់វែងសរុប។

**ប្រការ៤**

រាល់ទម្រង់បែបបទឯកសារសុរិយោដីដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តតាមនីតិវិធី សុរិយោដី។

**ប្រការ៥**

ការបង់ប្រាក់ និងការទទួលប្រាក់ចំណូលពីសោហ៊ុយសេវាសុរិយោដី ត្រូវអនុវត្តតាមរយៈ រជ្ជទេយ្យករចំណូលនៅថ្នាក់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង។

-ក្នុងករណីចាំបាច់អាចបង្កើតរជ្ជទេយ្យករចំណូលរង នៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ។

-ការបោះពុម្ព និងការបើកផ្តល់ប័ណ្ណចំណូលពីសោហ៊ុយសេវាសុរិយោដីជាបន្ទុករបស់ថវិកាដែលចាត់ចែងអនុវត្តដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៦**

ការគ្រប់គ្រងចំណូលពីសោហ៊ុយសេវាសុរិយោដី ត្រូវអនុវត្តតាមនីតិវិធីនៃកិច្ចប្រតិបត្តិការថវិកាទូទៅរបស់រដ្ឋ។

**ប្រការ៧**

ចំណូលពីសោហ៊ុយសេវាសុរិយោដី ត្រូវបានកំណត់បែងចែកដូចខាងក្រោម៖

១-៧៥%សម្រាប់បង់ចូលថវិការដ្ឋ ក្នុងនោះមាន៣៥%ដែលជាចំណែករបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់សម្រាប់ចាត់ចែងចំណាយដល់អង្គភាពជំនាញសុរិយោដីក្រោមឱវាទ។

២-១៥%សម្រាប់បម្រើឱ្យគុណប្រយោជន៍ថវិការបស់ខេត្ត-ក្រុង ក្នុងនោះមាន៥%ដែលជាចំណែករបស់ស្រុក-ខណ្ឌ។

៣-១០%សម្រាប់បម្រើឱ្យគុណប្រយោជន៍ថវិការបស់ឃុំ-សង្កាត់។

**ប្រការ៨**

ចំណូលពីសោហ៊ុយសេវាសុរិយោដីត្រូវបង់ចូលថវិការដ្ឋ និងថវិកាខេត្ត-ក្រុងនៅរតនាគារខេត្ត-ក្រុងដោយកត់ត្រានៅក្នុងជំពូក២១ ប្រការ០៣ កថាខណ្ឌ១៩។ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ត្រូវបូកសរុបធ្វើរបាយការណ៍នៃចំណូលនេះ ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្នុង១ត្រីមាសម្តង ដោយភ្ជាប់មកជាមួយនូវសលាកប័ត្របង់ប្រាក់។

**ប្រការ៩**

ផ្អែកលើការបូកសរុបសភាពការណ៍បង់ចំណូលប្រចាំត្រីមាស ដូចមានចែងក្នុងប្រការ៨ ខាងលើ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវលើកសំណើសុំចំណាយ ក្នុងរង្វង់៣៥% នៃចំណូលដែលបានបង់ចូលថវិការដ្ឋមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យសម្រេចផ្តល់ជូនតាមចំណែកដែលត្រូវបានទទួលជូនវិញ តែត្រូវភ្ជាប់មកជាមួយនូវ៖

-សលាកប័ត្របង់ប្រាក់ចំណូលពីសោហ៊ុយសេវាសុរិយោដី

*វាយឡើងវិញ*

-របាយការណ៍ចំណាយនៃចំណែក៣៥%ដែលថវិការដ្ឋបានបើកផ្តល់លើកមុន ដោយមានភ្ជាប់មកជាមួយនូវសក្ខីប័ត្រគ្រប់គ្រាន់ និងត្រឹមត្រូវ ។

នីតិវិធីនៃការបើកផ្តល់ចំណាយត្រូវធ្វើឡើងតាមរយៈអាណត្តិបើកប្រាក់ ដោយកត់ត្រានៅក្នុងជំពូក១១-០១-១៤-០២ ។

**ប្រការ១០**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ១១**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានថវិកានីយកម្ម និងហិរញ្ញកិច្ច ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ប្រធានរតនាគារជាតិ អង្គភាពពាក់ព័ន្ធទាំងអស់ដែលឋិតក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានភារកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះ ។

**ប្រការ១២**

ប្រកាសនេះមានអានុភាពគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

| ទេសរដ្ឋមន្ត្រី | រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី |
|---|---|
| រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | នគរូបនីយកម្ម និងសំណង់ |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| គាត ឈន់ | អ៊ឹម ឈុនលឹម |

<u>កន្លែងទទួល</u>

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អាជ្ញាធរសវនកម្មជាតិ

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន

-គ្រប់សាលាខេត្ត-ក្រុង

"ដើម្បីជូនជ្រាប"

-ដូចប្រការ១១ "ដើម្បីអនុវត្ត"

-ឯកសារ និងកាលប្បវត្តិ

*វាយឡើងវិញ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ៤៦អនក្រ/បក

**អនុក្រឹត្យ**

**ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៤នស/រកម ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរៀបចំក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ/បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០០

**សម្រេច**

## ជំពូកទី១ បទប្បញ្ញត្តិទូទៅ

**មាត្រា១**

អនុក្រឹត្យលេខ១១អនក្រ/បក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០០ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ត្រូវចាត់ទុកជានិរាករណ៍ ហើយត្រូវបានជំនួសដោយអនុក្រឹត្យនេះដែលកំណត់នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី តាមរយៈការវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធ នៅក្នុងតំបន់ដែលបានប្រកាសថា ជាទីតាំងធ្វើការវិនិច្ឆ័យ ដូចមានចែងក្នុងមាត្រា២នៃអនុក្រឹត្យនេះ ។

**មាត្រា២**

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវកំណត់ និងណែនាំបច្ចេកទេសជំនាញ និងទម្រង់បែបបទនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ដល់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង ។

អភិបាលខេត្ត-ក្រុងត្រូវចេញសេចក្តីប្រកាសកំណត់តំបន់ និងព្រំប្រទល់នៃទីតាំងធ្វើការវិនិច្ឆ័យតាមរបៀបបង្ហាញលើផែនទី ឬតាមរបៀបពិពណ៌នា ឬតាមរបៀបទាំងពីរ ។

## ជំពូកទី២ សមត្ថកិច្ច និងភារកិច្ច

**មាត្រា៣**

នៅពេលដែលតំបន់ត្រូវធ្វើការវិនិច្ឆ័យបានប្រកាសហើយ អភិបាលខេត្ត-ក្រុងនៃតំបន់ធ្វើការវិនិច្ឆ័យ ត្រូវតែងតាំងគណៈកម្មការរដ្ឋបាលសម្រាប់តំបន់ដែលត្រូវធ្វើការវិនិច្ឆ័យនោះ ។

សមាសភាពនៃគណៈកម្មការរដ្ឋបាលមាន៖

| | |
|---|---|
| -តំណាងអភិបាលខេត្ត | ជាប្រធាន |
| -មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ជាមន្ត្រីសុរិយោដី | ជាសមាជិក |
| -មន្ត្រីទទួលខុសត្រូវការងាររដ្ឋបាលសុរិយោដីនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង | ជាសមាជិក |
| -អភិបាលស្រុក-ខណ្ឌ ឬតំណាង | ជាសមាជិក |
| -មេឃុំ ចៅសង្កាត់ ឬតំណាង | ជាសមាជិក |
| -មេភូមិ ឬតំណាង | ជាសមាជិក |

-ចាស់ព្រឹទ្ធាចារ្យក្នុងទីតាំងធ្វើការវិនិច្ឆ័យ២រូប ជាសមាជិក

ភារកិច្ចរបស់គណៈកម្មការរដ្ឋបាលមាន៖

-បិទផ្សាយជាសាធារណៈនូវប្លង់បញ្ជីសុរិយោដី ជាអាទិ៍ ប្លង់សុរិយោដី និងបញ្ជីឈ្មោះអ្នកកាន់កាប់ដី

-ទទួលរាល់ពាក្យបណ្ដឹងតវ៉ា ធ្វើការស្រាវជ្រាវ និងដោះស្រាយតាមការព្រមព្រៀង

-ធ្វើសេចក្ដីសន្និដ្ឋាន ផ្ដល់យោបល់លើរាល់ឯកសារនៃការវិនិច្ឆ័យ

-លើកសំណើផ្ដល់សិទ្ធិលើដីជូនអ្នកកាន់កាប់ ជូនកម្មសិទ្ធិករ ឬរក្សាទុកជាទ្រព្យសម្បត្តិរដ្ឋ។

**មាត្រា៤**

នៅពេលដែលតំបន់ធ្វើការវិនិច្ឆ័យត្រូវបានកំណត់ហើយ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ត្រូវចាត់តាំងមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ព្រមទាំងមន្ត្រីចាំបាច់មួយចំនួនទៀត រួមមានមន្ត្រីកំណត់ព្រំដី មន្ត្រីវិនិច្ឆ័យ និងមន្ត្រីវាស់វែងដែលត្រូវបំពេញភារកិច្ចក្នុងតំបន់ធ្វើការវិនិច្ឆ័យ។

មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ដែលបានទទួលសេចក្ដីណែនាំពីអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រត្រូវទទួលខុសត្រូវចំពោះការវិនិច្ឆ័យដែលបានកំណត់ក្នុងអនុក្រឹត្យនេះ។ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ មានសិទ្ធិដឹកនាំចេញសេចក្ដីណែនាំចាំបាច់ដល់មន្ត្រីជំនាញដែលបានតែងតាំងក្នុងវាក្យខណ្ឌទី១ មាត្រា៤ នៃអនុក្រឹត្យនេះ។

មន្ត្រីកំណត់ព្រំដី និងមន្ត្រីវាស់វែងមានសិទ្ធិចូលក្នុងបរិវេណអចលនវត្ថុណាមួយ នៅក្នុងតំបន់ធ្វើការវិនិច្ឆ័យដើម្បីកំណត់ព្រំ និងវាស់វែង ហើយអាចអញ្ជើញជនដែលពាក់ព័ន្ធឱ្យផ្ដល់នូវចម្លើយដោយផ្ទាល់មាត់ ឯកសារ ឬភស្តុតាងផ្សេងៗទាក់ទងទៅនឹងព្រំនៃក្បាលដីណាមួយ។

មន្ត្រីវិនិច្ឆ័យ មានសិទ្ធិសាកសួរយកព័ត៌មានចាំបាច់សម្រាប់អនុវត្តការងារវិនិច្ឆ័យ អាចអញ្ជើញជនដែលពាក់ព័ន្ធឱ្យផ្ដល់នូវចម្លើយផ្ទាល់មាត់ ឯកសារ ឬភស្តុតាងផ្សេងៗទាក់ទងទៅនឹងការវិនិច្ឆ័យ។

**មាត្រា៥**

ក្នុងតំបន់ធ្វើការវិនិច្ឆ័យ ជនដែលមានការពាក់ព័ន្ធ មានកាតព្វកិច្ចចូលរួម និងសហការក្នុងការកំណត់ព្រំដី និងការវិនិច្ឆ័យ ដោយផ្ដល់នូវចម្លើយផ្ទាល់មាត់ ឯកសារ ឬភស្តុតាងផ្សេងៗដល់មន្ត្រីជំនាញ ដើម្បីអនុវត្តការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ។

ជនគ្រប់រូបមានសិទ្ធិចូលរួមពិនិត្យ និងផ្តល់យោបល់ ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ និងមានសិទ្ធិសុំឱ្យមន្ត្រីជំនាញពន្យល់បំភ្លឺអំពីខ្លឹមសារនៃទិន្នន័យដែលពាក់ព័ន្ធនឹងតំបន់ធ្វើការវិនិច្ឆ័យ ។

**មាត្រា៦**

អភិបាលខេត្ត-ក្រុងត្រូវធ្វើលិខិតផ្លូវការដែលពិពណ៌នា និងអនុញ្ញាតឱ្យអនុវត្តនីតិវិធីវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធទៅអាជ្ញាធរមូលដ្ឋាននៃតំបន់ធ្វើការវិនិច្ឆ័យ យ៉ាងហោចណាស់ ១៥ (ដប់ប្រាំ) ថ្ងៃ មុនកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ធ្វើការវិនិច្ឆ័យ ។

អភិបាលខេត្ត-ក្រុងត្រូវជូនដំណឹងជាសាធារណៈអំពីពេលវេលា និងទីកន្លែងនៃកិច្ចប្រជុំផ្សព្វផ្សាយ ។ សេចក្តីជូនដំណឹងត្រូវបិទឱ្យសាធារណជនដឹងយ៉ាងហោចណាស់៧ (ប្រាំពីរ) ថ្ងៃ មុនកិច្ចប្រជុំផ្សព្វផ្សាយក្នុងកន្លែងដែលងាយឃើញនៅក្នុងភូមិ ឬនៅទីតាំងធ្វើការវិនិច្ឆ័យផ្ទាល់ ។ សេចក្តីប្រកាសត្រូវតែផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាពក្នុងទីតាំងធ្វើការវិនិច្ឆ័យ ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន ។

កិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ធ្វើការវិនិច្ឆ័យ ដែលមានលក្ខណៈជាប្រព័ន្ធត្រូវរៀបចំធ្វើនៅក្នុងទីតាំងធ្វើការវិនិច្ឆ័យ ។ ក្នុងកិច្ចប្រជុំនោះ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ឬតំណាងគណៈកម្មការរដ្ឋបាលត្រូវពន្យល់ពីដំណើរការនៃការវិនិច្ឆ័យ បំភ្លឺពីបញ្ហាច្បាប់ និងឆ្លើយរាល់សំណួរទាក់ទងនឹងការវិនិច្ឆ័យដែលបានលើកឡើង ។

កិច្ចប្រជុំបន្ថែមសម្រាប់ថ្នាក់ភូមិនឹងត្រូវបានរៀបចំ ប្រសិនបើមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ឬអាជ្ញាធរមូលដ្ឋានចាត់ទុកជាការចាំបាច់ ។

**មាត្រា៧**

មន្ត្រីកំណត់ព្រំដី ត្រូវជូនដំណឹងដល់ថ្នាក់ដឹកនាំមូលដ្ឋានអំពីការកំណត់ព្រំដីក្នុងតំបន់ធ្វើការវិនិច្ឆ័យ ពេលវេលា និងទីកន្លែងដែលនឹងចាប់ផ្តើមធ្វើការវិនិច្ឆ័យឱ្យបានមុន៧ (ប្រាំពីរ) ថ្ងៃ យ៉ាងតិច ។ សេចក្តីជូនដំណឹងតម្រូវឱ្យជនដែលពាក់ព័ន្ធ មកចង្អុលបង្ហាញព្រំប្រទល់នៃអចលនវត្ថុរបស់ខ្លួន តាមរបៀបដែលបានបញ្ជាក់ក្នុងសេចក្តីប្រកាសជូនដំណឹង ។

បន្ទាប់មក មន្ត្រីកំណត់ព្រំដីដែលបានទទួលការណែនាំពីអ្នកគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ត្រូវកំណត់ព្រំប្រទល់អចលនវត្ថុទាំងអស់ដែលបង្កើតបានជាក្បាលដីក្នុងប្លង់សុរិយោដី។ ក្នុងរយៈពេលធ្វើការកំណត់ព្រំប្រទល់ក្បាលដី មន្ត្រីកំណត់ព្រំដីត្រូវគោរពគោលការណ៍ដូចខាងក្រោម៖

ក-បើកម្មសិទ្ធិករ ឬម្ចាស់នៃក្បាលដី និងម្ចាស់នៃក្បាលដីដែលជាប់ព្រំមានវត្តមាន ហើយព្រមព្រៀងលើព្រំប្រទល់ នោះព្រំប្រទល់នឹងត្រូវបានកំណត់យោងតាមការព្រមព្រៀង។

ខ-បើការព្រមព្រៀងដែលរៀបរាប់ក្នុងចំណុច (ក) នៃមាត្រានេះ មិនអាចធ្វើទៅបាន ឬមានកម្មសិទ្ធិករ ឬម្ចាស់នៃក្បាលដី និងម្ចាស់នៃក្បាលដីដែលនៅជាប់ព្រំណាមួយអវត្តមាន នោះព្រំប្រទល់ត្រូវកំណត់នៅលើដី តាមឯកសារដែលមាន និងភស្តុតាងជាលក្ខណរូប ជាលាយលក្ខណ៍អក្សរ ឬចម្លើយផ្ទាល់មាត់ទាក់ទងនឹងព្រំដី។

គ-ចំពោះក្បាលដីដែលមានព្រំប្រទល់ជាប់នឹងដីសាធារណៈ ឬក្បាលដីដែលប្រើប្រាស់ជាសាធារណៈ ព្រំប្រទល់ក្បាលដីត្រូវកំណត់ដោយអនុលោមទៅតាមចំណុច (ក) ឬ (ខ) នៃវាក្យខណ្ឌទី២ មាត្រា៧នៃអនុក្រឹត្យនេះ។

ឃ-វិវាទទាំងអស់អំពីព្រំប្រទល់ដែលមិនអាចដោះស្រាយបានក្នុងពេលកំណត់ព្រំដី ត្រូវបញ្ជូនទៅធ្វើការសម្រុះសម្រួល និងដោះស្រាយវិវាទក្រោមមាត្រា១២ នៃអនុក្រឹត្យនេះ។

**មាត្រា៨**

មន្ត្រីវាស់វែងដែលបានទទួលការណែនាំពីមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ត្រូវអនុវត្តការងារវាស់វែង ដែលជាតម្រូវការក្នុងការប្រតិបត្តិនីតិវិធីវិនិច្ឆ័យ និងរៀបចំប្លង់សុរិយោដី។

## ជំពូកទី៣ នីតិវិធីនៃការវិនិច្ឆ័យ

**មាត្រា៩**

មន្ត្រីវិនិច្ឆ័យដែលបានទទួលការណែនាំពីមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ត្រូវអង្កេតរាល់ឯកសារ ភស្តុតាង និងព័ត៌មានផ្សេងៗជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ទាក់ទងទៅនឹងសិទ្ធិលើក្បាលដីនីមួយៗក្នុងតំបន់ធ្វើការវិនិច្ឆ័យ ហើយកត់ត្រាសិទ្ធិទាំងនេះចូលក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី។

**មាត្រា១០**

ការរៀបចំឯកសារនៃការវិនិច្ឆ័យមានន័យដូចខាងក្រោមនេះ៖

១-ឯកសារនៃការវិនិច្ឆ័យត្រូវមាន៖

-ប្លង់សុរិយោដី

-បញ្ជីឈ្មោះម្ចាស់ដី

-ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី។

ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីនីមួយៗ ត្រូវបង្ហាញ៖

ក-អត្តសញ្ញាណក្បាលដី

ខ-អត្តសញ្ញាណម្ចាស់ដី

គ-កាលបរិច្ឆេទនៃការវិនិច្ឆ័យ

២-ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីត្រូវផ្តិតមេដៃយល់ព្រមពីម្ចាស់ដី ព្រមទាំងអ្នកជាប់ព្រំ ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីវិនិច្ឆ័យ។

៣-នៅពេលដែលឯកសារនៃការវិនិច្ឆ័យត្រូវបានបំពេញចប់សព្វគ្រប់ហើយ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យត្រូវចុះហត្ថលេខាលើឯកសារទាំងនេះ។

**មាត្រា១១**

ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យដែលរួមមានប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដីត្រូវមានរយៈវេលា៣០ (សាមសិប) ថ្ងៃ នៅកន្លែងដែលងាយមើលឃើញ សម្រាប់ការអង្កេតជាសាធារណៈនៅក្នុងតំបន់ធ្វើការវិនិច្ឆ័យ។

អាជ្ញាធរខេត្ត-ក្រុង ត្រូវផ្សាយដំណឹងអំពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ តាមសំណើរបស់គណៈកម្មការរដ្ឋបាល។

ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យអាចកែតម្រូវការខុសឆ្គង ឬការភ្លេចភ្លាំងណាដែលមិនជះឥទ្ធិពលដល់ផលប្រយោជន៍ត្រឹមត្រូវស្របច្បាប់នៃជនណាមួយ។ ការកែតម្រូវផ្សេងៗក្នុងឯកសារនៃការវិនិច្ឆ័យអាចធ្វើបាន ដរាបណាមានការយល់ព្រមពីជនពាក់ព័ន្ធដែលទទួលឥទ្ធិពលពីការកែតម្រូវនោះ។

**មាត្រា១២**

ក្នុងអំឡុងពេលនៃការបិទផ្សាយជាសាធារណៈ ជនណាដែលមានឈ្មោះក្នុងបញ្ជី ឬដែលមានផលប្រយោជន៍លើក្បាលដីណាមួយដែលបានចាត់ទុកថា ឯកសារនៃការវិនិច្ឆ័យមិនជាក់លាក់ ឬមិនពេញលេញ អាចផ្តល់ដំណឹងដល់គណៈកម្មការរដ្ឋបាលនូវការជំទាស់របស់ខ្លួន។

ក្រោយពីផ្តល់នូវការកត់សម្គាល់ដ៏សមហេតុផល ដល់ជនគ្រប់រូបដែលពាក់ព័ន្ធនឹងការជំទាស់ និងបន្ទាប់ពីពិគ្រោះជាមួយអ្នកដែលធ្វើការជំទាស់ គណៈកម្មការរដ្ឋបាលត្រូវព្យាយាមដោះស្រាយតាមការព្រមព្រៀង។

ការជំទាស់ ឬវិវាទណាមួយដែលមិនអាចដោះស្រាយបាន ត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ស្របតាមនីតិវិធីដែលនឹងកំណត់ដោយអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី។

**មាត្រា១៣**

ក្រោយពីផុតកំណត់រយៈពេលនៃការបិទផ្សាយជាសាធារណៈ នូវឯកសារនៃការវិនិច្ឆ័យ និងបញ្ចប់ការដោះស្រាយទំនាស់តាមនីតិវិធីដូចមានចែងក្នុងមាត្រា១២នៃអនុក្រឹត្យនេះ គណៈកម្មការរដ្ឋបាលត្រូវផ្តល់ការយល់ព្រមលើឯកសារនៃការវិនិច្ឆ័យ ចំពោះក្បាលដីទាំងឡាយណាដែលមិនមានទំនាស់។

បន្ទាប់ពីការយល់ព្រម គណៈកម្មការរដ្ឋបាលត្រូវបញ្ជូនឯកសារនៃការវិនិច្ឆ័យទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីដើម្បីពិនិត្យលើលក្ខណៈបច្ចេកទេស និងចុះហត្ថលេខា ហើយបញ្ជូនទៅអភិបាលខេត្ត-ក្រុងចុះហត្ថលេខា។

**មាត្រា១៤**

ក្រោយពីអភិបាលខេត្ត-ក្រុង និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ចុះហត្ថលេខាហើយ ឯកសារនៃការវិនិច្ឆ័យត្រូវបានបញ្ចប់ជាស្ថាពរ ចំពោះក្បាលដីដែលមិនមានទំនាស់។ ចំពោះឯកសារនៃការវិនិច្ឆ័យដែលនៅពាក់ព័ន្ធនឹងវិវាទ នឹងត្រូវបញ្ចប់ជាស្ថាពរនៅពេលមានការដោះស្រាយចប់សព្វគ្រប់ដោយគណៈកម្មការសុរិយោដី ឬដោយតុលាការ។

នៅពេលដែលឯកសារនៃការវិនិច្ឆ័យត្រូវបានបញ្ចប់ជាស្ថាពរ យោងតាមវាក្យខណ្ឌទី១នៃមាត្រានេះ ឯកសារនៃការវិនិច្ឆ័យ ព្រមទាំងឯកសារទាំងអស់ដែលទទួលបានក្នុងអំឡុងពេលនៃការវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធ ត្រូវបញ្ជូនទៅរដ្ឋបាលសុរិយោដីដើម្បីចុះបញ្ជី។

ក្រោយពេលក្បាលដីដែលមានក្នុងឯកសារនៃការវិនិច្ឆ័យត្រូវបានចុះបញ្ជីហើយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ លើគ្រប់ក្បាលដីក្នុងតំបន់ធ្វើការវិនិច្ឆ័យនេះ។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចប្រគល់សិទ្ធិឱ្យខេត្ត-ក្រុងណាដែលមានគ្រប់លក្ខណសម្បត្តិ ដើម្បីចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុនេះ នៅក្នុងតំបន់ធ្វើការវិនិច្ឆ័យនៃខេត្ត-ក្រុងរបស់ខ្លួន។

ការណែនាំអំពីរបៀបរបបនៃការកាន់កាប់ឯកសារសុរិយោដី និងឯកសាររណបផ្សេងៗ នឹងកំណត់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី៤ អវសានប្បញ្ញត្តិ

**មាត្រា១៥**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១៦**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ អភិបាលខេត្ត-ក្រុងទាំងអស់ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

<u>កន្លែងទទួល</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័នកណ្តាល
-គ្រប់សាលាខេត្ត-ក្រុង
-ដូចមាត្រា១៦
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ៤៧អនក្រ/បក

## អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ/បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០២

### សម្រេច

### ជំពូកទី១ បទប្បញ្ញត្តិទូទៅ

**មាត្រា១**

អនុក្រឹត្យនេះមានគោលដៅកំណត់រចនាសម្ព័ន្ធ បេសកកម្ម និងមុខងាររបស់គណៈកម្មការសុរិយោដី។

មាត្រា២

អនុក្រឹត្យនេះអនុវត្តចំពោះវិវាទ ដែលទាក់ទងនឹងអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីសុរិយោដី។ ក្នុងករណីនេះ គណៈកម្មការសុរិយោដីមានសិទ្ធិសម្រេចមុនគេក្នុងការទទួលស្គាល់ភោគីស្របច្បាប់។

## ជំពូកទី២ រចនាសម្ព័ន្ធ និងបេសកកម្ម

មាត្រា៣

គណៈកម្មការសុរិយោដីត្រូវមានបេសកកម្មដោះស្រាយវិវាទទាក់ទងនឹងអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីសុរិយោដី ដូចតទៅ៖

១-វិវាទដែលកើតមាននៅក្រៅតំបន់វិនិច្ឆ័យ

២-វិវាទដែលកើតមាននៅក្នុងតំបន់វិនិច្ឆ័យ និងដែលមិនអាចសម្រុះសម្រួលបានដោយគណៈកម្មការរដ្ឋបាល។

មាត្រា៤

គណៈកម្មការសុរិយោដីមានរចនាសម្ព័ន្ធដូចតទៅ៖

១-គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌមានអក្សរកាត់ថា គ.ស.ស.ខ មានទីតាំងនៅក្នុងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ។

២-គណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុងមានអក្សរកាត់ថា គ.ស.ខ.ក មានទីតាំងនៅក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង។

៣-គណៈកម្មការសុរិយោដីថ្នាក់ជាតិមានអក្សរកាត់ថា គ.ស.ជ មានទីតាំងនៅក្នុងទីស្តីការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង និងគណៈកម្មការសុរិយោដីថ្នាក់ជាតិមានលេខាធិការដ្ឋានជាសេនាធិការ និងជាអង្គភាពស៊ើបអង្កេត។

## ជំពូកទី៣ គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ

មាត្រា៥

គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ដឹកនាំដោយប្រធានមួយរូបដែលជាប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ ហើយត្រូវបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[4]

គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌមានមន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌជាសមាជិក។

ប្រធានគណៈកម្មការនេះត្រូវអញ្ជើញតំណាងអាជ្ញាធរដែនដីស្រុក-ខណ្ឌ ឃុំ-សង្កាត់ ភូមិ ដែលពាក់ព័ន្ធ ឬ/និងចាស់ព្រឹទ្ធាចារ្យនៅក្នុងមូលដ្ឋានឱ្យចូលរួមជាសមាជិកអាដហុក។

**មាត្រា៦**

គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌមានភារកិច្ចសម្រុះសម្រួលវិវាទ ដែលកើតមានឡើងនៅក្រៅតំបន់វិនិច្ឆ័យ។ ការសម្រុះសម្រួលវិវាទត្រូវអនុវត្តតាមទម្លាប់ប្រពៃណី និងបច្ចេកទេសសុរិយោដី។

## ជំពូកទី៤ ការសម្រុះសម្រួលនៅថ្នាក់ស្រុក-ខណ្ឌ

**មាត្រា៧**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវកំណត់ទម្រង់បែបបទនៃពាក្យបណ្ដឹង។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌត្រូវចុះបញ្ជី និងបើកសំណុំរឿងនៃរាល់វិវាទដែលបានទទួល។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌត្រូវពន្យល់អំពីនីតិវិធីដល់ភាគីវិវាទ និងសាកសួរថាតើគូវិវាទ យល់ព្រមធ្វើការដោះស្រាយសម្រុះសម្រួលតាមនីតិវិធីនេះឬទេ។

**មាត្រា៨**

គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌត្រូវស៊ើបអង្កេតលើវិវាទ។ ការស៊ើបអង្កេតរួមមានការបញ្ជាក់អំពីទីតាំងនៃក្បាលដីដែលមានវិវាទ និងភាគីពាក់ព័ន្ធ និងអំពីកម្មវត្ថុនៃវិវាទ និង

---

[4] យោងតាមអនុក្រឹត្យលេខ៣៨អនក្រ/បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៦ ស្ដីពីការកែប្រែមាត្រា៥ និងមាត្រា២៨ នៃអនុក្រឹត្យនេះ បានកំណត់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ជាអភិបាលស្រុក-ខណ្ឌ ហើយអនុប្រធាន គឺប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ រីឯសមាសភាពផ្សេងគឺនៅរក្សាដដែល។ សូមមើលទំព័រ 780។

ការប្រមូលឯកសារដែលមានចម្លើយរបស់សាក្សី និងព័ត៌មានទាក់ទងនឹងក្បាលដីមានវិវាទ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌត្រូវថតចម្លង និងបញ្ជាក់លើឯកសារចម្លងនោះ សម្រាប់ទុកជាសំណុំរឿង និងប្រគល់ច្បាប់ដើមឱ្យភាគីវិវាទ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌត្រូវកសាង និងបញ្ចូល[5] ឯកសារស៊ើបអង្កេតទៅក្នុងសំណុំរឿងវិវាទ។

**មាត្រា៩**

គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌត្រូវសម្រុះសម្រួលវិវាទក្រៅពីករណី ដែលមានចែងក្នុងមាត្រា១០នៃអនុក្រឹត្យនេះ។

ការសម្រុះសម្រួលត្រូវអនុវត្តតាមការណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា១០**

បន្ទាប់ពីការស៊ើបអង្កេត ប្រសិនបើឃើញថា វិវាទមិនអាចត្រូវបានដោះស្រាយដោយសមធម៌នៅថ្នាក់ស្រុក-ខណ្ឌ គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ត្រូវបញ្ជូនសំណុំរឿងវិវាទទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង តាមការយល់ឃើញផ្ទាល់របស់ប្រធាន ឬតាមសំណើរបស់ភាគីវិវាទទាំងសងខាង ចំពោះករណីដូចតទៅ៖

(១) -ជនម្នាក់ទាមទារដីច្រើនក្បាលដែលជាកម្មវត្ថុនៃការប្ដឹងទាមទាររបស់ភោគីតូចតាចមួយចំនួនដែរ។

(២) -ភាគីម្ខាងនៃវិវាទគឺជាអាជ្ញាធរមានឋានៈខ្ពស់។

(៣) -ករណីមានវិវាទពាក់ព័ន្ធនឹងផលប្រយោជន៍របស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ។

(៤) -វិវាទដែលពាក់ព័ន្ធនឹងដីសាធារណៈរបស់រដ្ឋ។

**មាត្រា១១**

---

[5] ឯកសារផ្លូវការត្រូវបានសរសេរ "បញ្ចូល"។

ប្រសិនបើការដោះស្រាយអាចសម្រេចបានដោយមានការព្រមព្រៀងជាឯកច្ឆន្ទពីភាគីវិវាទ គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌត្រូវធ្វើរបាយការណ៍ជូនគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង ហើយត្រូវចម្លងជូនការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌមួយច្បាប់ ដើម្បីចាប់ផ្តើមដំណើរការអនុវត្តនីតិវិធីនៃការចុះបញ្ជីក្បាលដី ដែលបានដោះស្រាយរួច។

ប្រសិនបើការដោះស្រាយមិនអាចសម្រេចបាន គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌត្រូវបញ្ជូនវិវាទ រួមជាមួយនឹងរបាយការណ៍ជាលាយលក្ខណ៍អក្សរស្តីពីការសម្រុះសម្រួលជូនគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង។

## ជំពូកទី៥ គណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង

### មាត្រា១២

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុងមានសមាសភាពដូចខាងក្រោម៖

-អភិបាល ឬអភិបាលរងខេត្ត-ក្រុង ជាប្រធាន

-ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង ជាសមាជិក

ឈ្មោះប្រធាន និងសមាជិកនៃគណៈកម្មការសុរិយោដីនេះ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រធានគណៈកម្មការសុរិយោដីខេត្ត-ក្រុង អាចអញ្ជើញតំណាងស្រុក-ខណ្ឌ ឃុំ-សង្កាត់ ឬមន្ទីរជុំវិញខេត្ត-ក្រុង ដែលពាក់ព័ន្ធឱ្យចូលរួមជាសមាជិកអាដហុក។

### មាត្រា១៣

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុងមានភារកិច្ចសម្រុះសម្រួលវិវាទដូចមានចែងក្នុងមាត្រា១០ និងមាត្រា១១ វាក្យខណ្ឌទី២នៃអនុក្រឹត្យនេះ។

សមាជិកគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង។

### មាត្រា១៤

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុងមានលេខាធិការដ្ឋានមួយ ជាសេនាធិការ និងជាអង្គភាពស៊ើបអង្កេត។

មន្ត្រីបម្រើការងារនៅលេខាធិការដ្ឋានជាមន្ត្រីមុខងារសាធារណៈ ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់តាមសំណើរបស់គណៈកម្មការសុរិយោដី។ លេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុងមានមុខងារ និងភារកិច្ចដូចតទៅ៖

-ទទួលសំណុំរឿងវិវាទពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ និងរាល់ពាក្យបណ្តឹងទាក់ទងនឹងវិវាទដីធ្លី

-ស៊ើបអង្កេតតាមការណែនាំរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង

-ធ្វើរបាយការណ៍អំពីលទ្ធផលនៃការស៊ើបអង្កេត

-រៀបចំការប្រជុំរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង

-ធ្វើកំណត់ហេតុអំពីដំណើរការសម្រុះសម្រួល និងធ្វើរបាយការណ៍អំពីលទ្ធផលនៃការសម្រុះសម្រួល

-បញ្ជូនកំណត់ហេតុ និងរបាយការណ៍ទាំងនេះ ទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ។ ក្នុងករណីការសម្រុះសម្រួលបានសម្រេច ត្រូវផ្ញើលទ្ធផលនៃការសម្រុះសម្រួលទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ

- រៀបចំ និងតម្កល់ទុកឯកសារ។

## ជំពូកទី៦ ការសម្រុះសម្រួលនៅថ្នាក់ខេត្ត-ក្រុង

### មាត្រា១៥

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុងពុំមានសិទ្ធិសម្រេចលើករណីវិវាទណាមួយទេ ប៉ុន្តែអាចបញ្ចប់វិវាទបាន ក្នុងករណីភាគីវិវាទទាំងអស់ព្រមព្រៀងគ្នាជាឯកច្ឆន្ទ។

ក្នុងករណីដែលវិវាទ ពាក់ព័ន្ធនឹងផលប្រយោជន៍របស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង សំណុំរឿងវិវាទនេះត្រូវបានបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ។

### មាត្រា១៦

ប្រសិនបើការសម្រុះសម្រួលអាចសម្រេចបាន គណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុងត្រូវផ្ញើលទ្ធផលជូនការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌដើម្បីចាប់ផ្តើមដំណើរការអនុវត្តនីតិវិធីនៃការចុះបញ្ជីក្បាលដី ដែលបានដោះស្រាយរួច។

ប្រសិនបើការដោះស្រាយមិនអាចសម្រេចបាន គណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង ត្រូវបញ្ជូនសំណុំរឿងវិវាទរួមជាមួយនឹងរបាយការណ៍ជាលាយលក្ខណ៍អក្សរ អំពីការសម្រុះសម្រួលជូនគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

## ជំពូកទី៧ គណៈកម្មការសុរិយោដីថ្នាក់ជាតិ

### មាត្រា១៧

គណៈកម្មការសុរិយោដីថ្នាក់ជាតិមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| -រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ជាប្រធាន |
| -រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ | ជាសមាជិក |
| -រដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |

ឈ្មោះប្រធាន និងសមាជិកនៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវតែងតាំងដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិអាចអញ្ជើញក្រសួង ស្ថាប័នដែលពាក់ព័ន្ធឱ្យមកចូលរួមជាសមាជិកអាដហុក ។

### មាត្រា១៨

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសមត្ថកិច្ចចេញសេចក្តីសម្រេចលើវិវាទដីភោគៈដែលគណៈកម្មការសុរិយោដីថ្នាក់ក្រោម ឬគណៈកម្មការរដ្ឋបាលពុំអាចសម្រុះសម្រួលបានដូចមានចែងក្នុងមាត្រា១៦ និងវិវាទដែលមានចែងក្នុងចំណុចទី២នៃមាត្រា៣ នៃអនុក្រឹត្យនេះ ។

សមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

### មាត្រា១៩

គណៈកម្មការសុរិយោដីថ្នាក់ជាតិមានលេខាធិការដ្ឋានមួយ ជាសេនាធិការ និងជាអង្គភាពស៊ើបអង្កេត ។

លេខាធិការដ្ឋាននេះ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់ ដែលត្រូវតែងតាំងដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

មន្ត្រីបម្រើការងារនៅលេខាធិការដ្ឋាន ជាមន្ត្រីមុខងារសាធារណៈដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់តាមសំណើរបស់គណៈកម្មការសុរិយោដី។

លេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិមានតួនាទីដូចតទៅ៖

-ទទួលសំណុំរឿងវិវាទពីគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង និងរាល់ពាក្យបណ្តឹងទាក់ទងនឹងវិវាទដីធ្លី

-ស៊ើបអង្កេតតាមការណែនាំរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ

-ធ្វើរបាយការណ៍អំពីលទ្ធផលនៃការស៊ើបអង្កេត

-រៀបចំការប្រជុំរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ

-ធ្វើកំណត់ហេតុអំពីសវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ និងធ្វើរបាយការណ៍អំពីលទ្ធផលនៃការដោះស្រាយ

-បញ្ជូនកំណត់ហេតុ និងភស្តុតាងទាំងអស់ទៅតុលាការ នៅពេលមានការប្តឹងតវ៉ាលើសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិទៅតុលាការ

-រៀបចំ និងតម្កល់ទុកឯកសារ។

## ជំពូកទី៨ ការដោះស្រាយនៅថ្នាក់ជាតិ

### មាត្រា២០

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានយុត្តាធិការពេញលេញក្នុងការធ្វើសេចក្តីសម្រេចទទួលស្គាល់ភោគី ឬកម្មសិទ្ធិករស្របច្បាប់។

ប្រសិនបើភាគីវិវាទ មិនយល់ព្រមតាមសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ភាគីវិវាទមានសិទ្ធិប្តឹងទៅតុលាការ ដូចមានចែងក្នុងមាត្រា២៣នៃអនុក្រឹត្យនេះ។

### មាត្រា២១

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវពិនិត្យឡើងវិញនូវរាល់ឯកសារទាំងអស់ដែលទាក់ទងនឹងវិវាទ ហើយប្រសិនបើយល់ឃើញថាចាំបាច់ អាចបញ្ជាឱ្យមានការស៊ើបអង្កេតបន្ថែមទៀត ពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ និងរៀបចំបើកសវនាការមុនពេលធ្វើសេចក្តីសម្រេចលើវិវាទ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវពិនិត្យដើម្បីបើកសវនាការអំពីវិវាទ តាមការស្នើសុំរបស់ភាគីណាមួយ។

ក្នុងករណីដែលគណៈកម្មការសុរិយោដីថ្នាក់ជាតិធ្វើការពិគ្រោះយោបល់ជាមួយភាគីណាមួយ នោះភាគីផ្សេងៗទៀតមានសិទ្ធិទទួលបានជូនដំណឹងជាមុន អំពីការពិគ្រោះយោបល់នេះ ដើម្បីមានវត្តមាននៅក្នុងការពិគ្រោះយោបល់ ប្រសិនបើគណៈកម្មការសុរិយោដីថ្នាក់ជាតិយល់ឃើញថាចាំបាច់ ។

**មាត្រា២២**

សេចក្តីសម្រេចត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវមានសេចក្តីសង្ខេបអំពីករណីវិវាទ និងហេតុផលលំអិតនៃការធ្វើសេចក្តីសម្រេច ។

**មាត្រា២៣**

ភាគីវិវាទមានសិទ្ធិស្នើឱ្យមានការពិនិត្យឡើងវិញផ្នែកច្បាប់ លើការសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ដោយប្តឹងទៅតុលាការក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃ ចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេច ។

ប្រសិនបើតុលាការបញ្ជូនរឿងក្តីទៅគណៈកម្មការសុរិយោដីវិញ ដោយហេតុថាគណៈកម្មការសុរិយោដីមិនបានអនុវត្តតាមនីតិវិធីសមស្រប ឬដោយមានវិវាទអំពីផលប្រយោជន៍ ឬដោយមិនបានផ្តល់ហេតុផលសមរម្យ ឬដោយអនុវត្តហួសពីសមត្ថកិច្ចរបស់ខ្លួន នោះគណៈកម្មការសុរិយោដីត្រូវចាត់វិធានការអនុវត្តតាមសំណូមពររបស់តុលាការ ។

ភាគីដែលស្នើសុំការពិនិត្យឡើងវិញផ្នែកច្បាប់ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីបណ្តឹងទៅលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ លេខាធិការដ្ឋានត្រូវធានាការពារសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដី ចំពោះតុលាការ ។

តុលាការត្រូវផ្ញើច្បាប់ចម្លងនៃសាលក្រម ឬសាលដីកាដែលបានចូលជាស្ថាពរមកគណៈកម្មការសុរិយោដីថ្នាក់ជាតិដើម្បីចាត់ចែងដំណើរការអនុវត្តនីតិវិធីនៃការចុះបញ្ជីដី ។

ប្រសិនបើគ្មានបណ្តឹងក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃ ដូចបានកំណត់នៅក្នុងមាត្រានេះ នោះសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវចាត់ទុកជាស្ថាពរ ។

## ជំពូកទី៩ ការចុះបញ្ជី

**មាត្រា២៤**

បន្ទាប់ពីសេចក្ដីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសុពលភាពអាចអនុវត្តបាន គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវផ្ញើសេចក្ដីសម្រេចនោះ ទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង ដើម្បីចាត់ចែងធ្វើការចុះបញ្ជីក្បាលដីតាមនីតិវិធីដែលបានកំណត់។

## ជំពូកទី១០ បទប្បញ្ញត្តិរដ្ឋបាល

### មាត្រា២៥

ប្រសិនបើសមាជិករបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ មានផលប្រយោជន៍នៅក្នុងវិវាទ សមាជិកនោះត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទនេះ ហើយគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុងត្រូវតែងតាំងសមាជិកថ្មីជំនួសវិញ។

ប្រសិនបើសមាជិករបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង ឬថ្នាក់ជាតិ មានផលប្រយោជន៍នៅក្នុងវិវាទ សមាជិកនោះត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទនេះ។ ប្រសិនបើចាំបាច់ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចតែងតាំងសមាជិកថ្មីជំនួសវិញ។

ក្នុងករណីដែលវិវាទពាក់ព័ន្ធនឹងផលប្រយោជន៍របស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវតែងតាំងសមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិឱ្យធ្វើជាប្រធានអាដហុកដើម្បីដោះស្រាយករណីវិវាទនេះ។

### មាត្រា២៦

ជនដែលត្រូវបានបញ្ជាក់ថាជាកម្មសិទ្ធិករ ឬភោគីស្របច្បាប់នៃក្បាលដីដែលមានវិវាទក្រោមនីតិវិធីដែលមានចែងក្នុងអនុក្រឹត្យនេះ ត្រូវបង់ថ្លៃសេវានៃការចុះបញ្ជីក្បាលដី អនុលោមតាមមាត្រា២៣០នៃច្បាប់ភូមិបាល។

### មាត្រា២៧

ភាគីវិវាទត្រូវបានជូនដំណឹងជាមុនក្នុងរយៈពេលមួយសមហេតុផល អំពីការប្រជុំដើម្បីសម្រុះសម្រួល ឬសម្រេចលើវិវាទក្រោមអនុក្រឹត្យនេះ។

ភាគីវិវាទមានសិទ្ធិចូលខ្លួនដោយខ្លួនឯង និងអាចរកជំនួយមនុស្ស ឬអង្គការណាមួយដើម្បីជួយខ្លួន ក្នុងពេលសម្រុះសម្រួលវិវាទនៅគ្រប់ថ្នាក់។

ភាគីវិវាទមានសិទ្ធិចូលខ្លួនដោយខ្លួនឯង និងអាចរកជំនួយមនុស្ស ឬអង្គការណាមួយ ដើម្បីធ្វើជាតំណាងរបស់ខ្លួនក្នុងពេលប្រជុំធ្វើសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដី។

ភាគីវិវាទមានសិទ្ធិបង្ហាញភស្តុតាងផ្ទាល់មាត់ ឬឯកសារជាក់ស្តែងដែលទាក់ទងនឹងវិវាទ ដែលត្រូវចាត់ទុកជាចំណែកមួយនៃឯកសារផ្លូវការនៃវិវាទ។

ការប្រជុំរបស់គណៈកម្មការសុរិយោដីត្រូវធ្វើឡើងជាសាធារណៈ។

គណៈកម្មការសុរិយោដីត្រូវរក្សាឯកសារផ្លូវការនៃវិវាទនីមួយៗ ដែលរួមមានឯកសារទាំងអស់ និងភស្តុតាងជាក់ស្តែងផ្ទាល់មាត់ និងលាយលក្ខណ៍អក្សរអំពីវិវាទ។ ឯកសារផ្លូវការដែលទាក់ទងនឹងវិវាទត្រូវបានបើកឱ្យភាគីពាក់ព័ន្ធពិនិត្យ។

សេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវអមដោយរបាយការណ៍ស្តីពីដំណើររឿង និងដំណើរការដោះស្រាយវិវាទ ដែលផ្អែកលើភស្តុតាងទាំងឡាយដែលអាចទុកចិត្តបាន និងត្រឹមត្រូវដែលជាផ្នែកនៃឯកសារផ្លូវការ។

ច្បាប់ចម្លងនៃសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវផ្តល់ឱ្យភាគីវិវាទនីមួយៗ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចេញប្រកាសណែនាំអនុវត្តអនុក្រឹត្យនេះ។

**មាត្រា២៨**

គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ មានសិទ្ធិប្រើប្រាស់ត្រារបស់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ។[6]

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង មានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្ត-ក្រុង។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី១១ ប្រភពធនធាន

**មាត្រា២៩**

---

[6] យោងតាមអនុក្រឹត្យលេខ៣៨អនក្រ/បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៦ ស្តីពីការកែប្រែមាត្រា៥ និងមាត្រា២៨ នៃអនុក្រឹត្យនេះ គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌមានសិទ្ធិប្រើត្រារបស់សាលាស្រុក-ខណ្ឌ។

*វាយឡើងវិញ*

គណៈកម្មការសុរិយោដីមានខ្ទង់ថវិកាដោយឡែក ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣០**

ប្រភពធនធាន និងថវិការបស់គណៈកម្មការសុរិយោដីត្រូវបានផ្តល់ដោយ៖

-ថវិកាជាតិ

-ហិរញ្ញប្បទានបានមកពីប្រទេសក្រៅ ឬអង្គការផ្តល់ជំនួយអន្តរជាតិ។

**ជំពូកទី១២ អវសានប្បញ្ញត្តិ**

**មាត្រា៣១**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៣២**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការអភិបាលខេត្ត-ក្រុងទាំងអស់ និងមន្ត្រីដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័នកណ្តាល

-គ្រប់សាលាខេត្ត-ក្រុង

-ដូចមាត្រា៣២

-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ៤៨អនក្រ/បក

## អនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ/បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០២

### សម្រេច

### ជំពូកទី១ បទប្បញ្ញត្តិទូទៅ

មាត្រា១

អនុក្រឹត្យនេះកំណត់នីតិវិធីនៃការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ នូវអចលនវត្ថុទូទាំងព្រះរាជាណាចក្រកម្ពុជា ក្នុងតំបន់ដែលមិនទាន់បានចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ។

## ជំពូកទី២ ភារកិច្ច និងកាតព្វកិច្ច

**មាត្រា២**

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានភារកិច្ចណែនាំ សម្របសម្រួល និងពិនិត្យតាមដានការអនុវត្តអនុក្រឹត្យនេះ។ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ត្រូវកំណត់ស្តង់ដារបច្ចេកទេសសម្រាប់ការកំណត់ព្រំដី ការកសាងប្លង់សុរិយោដី និងការកសាងឯកសារផ្សេងៗ ព្រមទាំងកំណត់គំរូឯកសារដែលត្រូវប្រើក្នុងនីតិវិធីដូចមានចែងក្នុងអនុក្រឹត្យនេះ។

រដ្ឋបាលសុរិយោដីស្រុក-ខណ្ឌត្រូវទទួលខុសត្រូវក្នុងការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យរាល់ក្បាលដី ដែលស្នើសុំចុះបញ្ជីក្រោមអនុក្រឹត្យនេះក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ប្រសិនបើរដ្ឋបាលសុរិយោដីស្រុក-ខណ្ឌណាមួយ មិនអាចបំពេញតាមល័ក្ខខ័ណ្ឌសម្រាប់ការចុះបញ្ជីក្រោមអនុក្រឹត្យនេះ ក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន ដោយសារតែសមត្ថភាពបច្ចេកទេស រដ្ឋបាលសុរិយោដីស្រុក-ខណ្ឌនោះអាចស្នើសុំឱ្យរដ្ឋបាលសុរិយោដីខេត្ត-ក្រុង ជួយដល់ការអនុវត្តនូវការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ។

**មាត្រា៣**

មន្ត្រីទទួលបន្ទុកការងារកំណត់ព្រំដី វាស់វែង និងវិនិច្ឆ័យ មានសិទ្ធិចូលក្នុងបរិវេណអចលនវត្ថុ នៅពេលធ្វើការអង្កេតវាស់វែង និងអាចអញ្ជើញជនពាក់ព័ន្ធឱ្យផ្តល់ព័ត៌មានផ្ទាល់មាត់ ឯកសារ ឬ/និងភស្តុតាងផ្សេងៗទាក់ទងនឹងព្រំដី ឬសិទ្ធិលើក្បាលដី។

**មាត្រា៤**

ក្នុងករណីចាំបាច់ រដ្ឋបាលសុរិយោដីអាចស្នើសុំទៅអាជ្ញាធរដែនដី ឬកងកម្លាំងប្រដាប់អាវុធឱ្យជួយជ្រោមជ្រែង ក្នុងការអនុវត្តការងារវាស់វែង។

**មាត្រា៥**

អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីដី មានកាតព្វកិច្ចចូលរួម និងសហការក្នុងការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ ដោយផ្តល់ព័ត៌មានផ្ទាល់មាត់ ឯកសារ ឬ/និងភស្តុតាង ដែលទាក់ទងនឹងការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ តាមសំណូមពររបស់មន្ត្រីទទួលបន្ទុក។

ក្នុងពេលចុះកំណត់ព្រំដី វាស់វែង និងវិនិច្ឆ័យ ក្នុងករណីអវត្តមានអ្នកដាក់ពាក្យ ឬតំណាងស្របច្បាប់ ការកំណត់ព្រំក្បាលដីត្រូវធ្វើដោយផ្អែកតាមឯកសារដែលមាន ឬ/និងភស្តុតាងដែលមានលក្ខណរូប ជាលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់ដែលទាក់ទងនឹងព្រំដី។

ជនណាដែលបានបំភាន់មន្ត្រីសុរិយោដីក្នុងការបំពេញបេសកកម្ម ឬបំភាន់អាជ្ញាធរក្នុងការចុះបញ្ជីដី ត្រូវទទួលការផ្តន្ទាទោសដូចមានចែងក្នុងមាត្រា២៥២នៃច្បាប់ភូមិបាល។

**មាត្រា៦**

ជនដែលមានការពាក់ព័ន្ធ មានកាតព្វកិច្ចចូលរួមសហការក្នុងការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ ដោយផ្តល់ព័ត៌មានផ្ទាល់មាត់ ឯកសារ ឬ/និងភស្តុតាងផ្សេងៗតាមសំណូមពររបស់មន្ត្រីទទួលបន្ទុក។

ជនគ្រប់រូបមានសិទ្ធិចូលរួមពិនិត្យ និងផ្តល់យោបល់ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ។

## ជំពូកទី៣ អំពីនីតិវិធីនៃការចុះបញ្ជីដី

**មាត្រា៧**

សាមីអ្នកកាន់កាប់ដីដែលស្នើសុំចុះបញ្ជីដី ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីដីតាមគំរូដែលបានកំណត់មករដ្ឋបាលសុរិយោដីស្រុក-ខណ្ឌ តាមរយៈមេឃុំ-ចៅសង្កាត់ដែលក្បាលដីស្នើសុំចុះបញ្ជីនោះឋិតនៅ។

ពាក្យស្នើសុំត្រូវមាន៖

-ឈ្មោះ និងស្នាមមេដៃរបស់អ្នកដាក់ពាក្យ

-ការពិពណ៌នាលំអិតអំពីក្បាលដីដែលស្នើសុំចុះបញ្ជី និងទីតាំងរបស់ក្បាលដីនោះ

-ការពិពណ៌នាអំពីសិទ្ធិលើក្បាលដីដែលស្នើសុំចុះបញ្ជី

-ឯកសារ ឬ/និងភស្តុតាងផ្សេងៗទាក់ទងនឹងក្បាលដី ឬសិទ្ធិលើក្បាលដីដែលស្នើសុំចុះបញ្ជី

**មាត្រា៨**

ពាក្យស្នើសុំត្រូវពិនិត្យដោយរដ្ឋបាលសុរិយោដីស្រុក-ខណ្ឌ ផ្អែកតាមឯកសារដែលមាន និងទិន្នន័យផ្សេងៗដែលពាក់ព័ន្ធនឹងក្បាលដីដែលស្នើសុំចុះបញ្ជី។

ក្នុងករណីពិនិត្យឃើញថា ពាក្យស្នើសុំមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប រដ្ឋបាលសុរិយោដីស្រុក-ខណ្ឌត្រូវកត់ត្រាចូលក្នុងសៀវភៅទទួលពាក្យ និងកំណត់កាលបរិច្ឆេទនៃការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ ។

ក្នុងករណីពិនិត្យឃើញថា ពាក្យស្នើសុំមានលក្ខណៈមិនសមស្រប រដ្ឋបាលសុរិយោដីស្រុកខណ្ឌត្រូវចារលើពាក្យ ដោយបញ្ជាក់ពីមូលហេតុដែលមិនអាចអនុវត្តនីតិវិធីនៃការចុះបញ្ជីបាន ។ អ្នកដាក់ពាក្យមានសិទ្ធិប្ដឹងតវ៉ាទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តក្រុង ។

ក្នុងករណីពិនិត្យឃើញថា មានវិវាទពាក់ព័ន្ធនឹងក្បាលដីដែលស្នើសុំចុះបញ្ជីនោះ រដ្ឋបាលសុរិយោដីស្រុក-ខណ្ឌត្រូវបញ្ជូនវិវាទនោះទៅធ្វើការសម្រុះសម្រួលនៅថ្នាក់ស្រុក-ខណ្ឌ តាមនីតិវិធីដែលបានកំណត់ក្នុងអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ។

**មាត្រា៩**

អភិបាលស្រុក-ខណ្ឌ ត្រូវចេញសេចក្ដីជូនដំណឹងស្ដីពីកាលបរិច្ឆេទនៃការកំណត់ព្រំដី ទៅអ្នកដាក់ពាក្យស្នើសុំ និងត្រូវបិទផ្សាយជាសាធារណៈក្នុងរយៈពេល១៤ថ្ងៃ (ដប់បួន) ថ្ងៃ យ៉ាងតិចមុនកាលបរិច្ឆេទនៃការកំណត់ព្រំដី នៅសាលាស្រុក-ខណ្ឌ សាលាឃុំ-សង្កាត់ និងនៅទីកន្លែងដែលងាយមើលឃើញក្នុងភូមិដែលក្បាលដីស្នើសុំចុះបញ្ជីនោះឋិតនៅ ។

**មាត្រា១០**

មន្ត្រីទទួលបន្ទុកកំណត់ព្រំដី និងវាស់វែង ត្រូវកំណត់ព្រំក្បាលដីដែលស្នើសុំចុះបញ្ជី តាមពេលវេលាដែលបានជូនដំណឹងដោយយោងតាមសេចក្ដីណែនាំរបស់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ និងការណែនាំរបស់រដ្ឋបាលសុរិយោដីស្រុក-ខណ្ឌ ។

នៅពេលធ្វើការកំណត់ព្រំក្បាលដី មន្ត្រីទទួលបន្ទុកត្រូវពិនិត្យឯកសារដែលមានភស្តុតាង និងព័ត៌មានជាលាយលក្ខណ៍អក្សរ និងព័ត៌មានផ្ទាល់មាត់ផ្សេងៗ ដែលទាក់ទងនឹងព្រំប្រទល់ក្បាលដីដែលស្នើសុំចុះបញ្ជី ហើយត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

ក-ក្នុងករណីអ្នកដាក់ពាក្យ និងម្ចាស់ដីជាប់ព្រំមានវត្តមាន ហើយព្រមព្រៀងគ្នាអំពីព្រំប្រទល់ និងគ្មានភស្តុតាងផ្ទុយ ការកំណត់ព្រំដីត្រូវធ្វើដោយផ្អែកតាមការព្រមព្រៀង ។

ខ-ក្នុងករណីម្ចាស់ដីជាប់ព្រំមិនមានវត្តមាន ការកំណត់ព្រំដីត្រូវធ្វើដោយផ្អែកតាមឯកសារដែលមាន និងភស្តុតាងដែលជាលក្ខណរូប ជាលាយលក្ខណ៍អក្សរ និងភស្តុតាងផ្ទាល់មាត់ដែលទាក់ទងនឹងព្រំដីនោះ ។

គ-ក្នុងករណីក្បាលដីដែលស្នើសុំចុះបញ្ជីឋិតនៅជាប់នឹងដីសាធារណៈ ឬជាប់នឹងក្បាលដីដែលប្រើប្រាស់ជាសាធារណៈ ការកំណត់ព្រំដីត្រូវធ្វើដោយយោងតាមចំណុច (ក) ឬ (ខ) ខាងលើ ។

វិវាទអំពីព្រំដីដែលមិនអាចដោះស្រាយបានក្នុងពេលកំណត់ព្រំដី ត្រូវបញ្ជូនទៅធ្វើការសម្រុះសម្រួលនៅថ្នាក់ស្រុក-ខណ្ឌតាមនីតិវិធី ដែលបានកំណត់ក្នុងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ។

ការវាស់វែងត្រូវធ្វើក្រោយពីបានកំណត់ព្រំក្បាលដីរួច ។

**មាត្រា១១**

មន្ត្រីទទួលបន្ទុកការងារវិនិច្ឆ័យ ត្រូវអង្កេតលើឯកសារដែលមានភស្តុតាង និងព័ត៌មានជាលាយលក្ខណ៍អក្សរ និងព័ត៌មានផ្ទាល់មាត់ទាក់ទងនឹងសិទ្ធិលើក្បាលដីដែលស្នើសុំចុះបញ្ជី ។

ចំពោះដីភោគៈ ការវិនិច្ឆ័យត្រូវផ្អែកលើគោលការណ៍ដូចខាងក្រោម៖

ក-ដីដែលស្នើសុំចុះបញ្ជី ត្រូវតែបានកាន់កាប់មុនថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១

ខ-ដីដែលស្នើសុំចុះបញ្ជី ត្រូវបានកាន់កាប់ដោយសន្តិវិធី និងមិនមានការជំទាស់៖

-ក្នុងករណីកាន់កាប់យ៉ាងតិចប្រាំឆ្នាំ ហើយចំណុចព្រំក្បាលដី មាននិយាមកាច្បាស់លាស់ អាចត្រូវបានស្នើផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីនោះ ។

-ក្នុងករណីកាន់កាប់យ៉ាងតិចប្រាំឆ្នាំ ប៉ុន្តែចំណុចព្រំក្បាលដីមិនទាន់មាននិយាមកាច្បាស់លាស់ អាចត្រូវបានស្នើផ្តល់សិទ្ធិជាភោគៈបន្តលើក្បាលដីនោះ ។

-ក្នុងករណីកាន់កាប់តិចជាងប្រាំឆ្នាំអាចត្រូវបានស្នើផ្តល់សិទ្ធិជាភោគៈបន្តលើក្បាលដីនោះ ។

អចលនវត្ថុរបស់រដ្ឋត្រូវបានចុះបញ្ជីជាទ្រព្យសម្បត្តិសាធារណៈ ឬជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋស្របតាមបទប្បញ្ញត្តិនៃជំពូកទី២នៃច្បាប់ភូមិបាល ។

**មាត្រា១២**

ផ្អែកតាមការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ រដ្ឋបាលសុរិយោដីស្រុក-ខណ្ឌត្រូវរៀបចំឯកសារនៃការវិនិច្ឆ័យរួមមាន៖

-ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី

-ផែនទីក្បាលដី និងគំនូសបង្ហាញទីតាំងដី

-បញ្ជីឈ្មោះម្ចាស់ក្បាលដីដែលស្នើសុំចុះបញ្ជី ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីត្រូវបង្ហាញអំពីអត្តសញ្ញាណនៃក្បាលដី កម្មសិទ្ធិករ ឬភោគី កាលបរិច្ឆេទនៃការកាន់កាប់ដី កាលបរិច្ឆេទនៃការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យរាល់សិទ្ធិ និងបន្ទុកដែលមានលើក្បាលដី ដូចមានចែងក្នុងច្បាប់ភូមិបាល។

ផែនទីក្បាលដីដែលស្នើសុំចុះបញ្ជី ត្រូវបង្ហាញអំពីអត្តសញ្ញាណនៃក្បាលដី រួមមានលេខក្បាលដី រូបរាងក្បាលដី លេខក្បាលដី ឬ/និងឈ្មោះម្ចាស់ក្បាលដីជាប់ព្រំ។

បញ្ជីឈ្មោះម្ចាស់ដីនៃក្បាលដីដែលស្នើសុំចុះបញ្ជីបង្ហាញអំពីឈ្មោះ សាវតារ ប្រភេទទ្រព្យរបស់កម្មសិទ្ធិករ ឬភោគីនៃក្បាលដី ប្រភព និងកាលបរិច្ឆេទនៃការកាន់កាប់ ទំហំ និងរូបភាពប្រើប្រាស់ដី។

**មាត្រា១៣**

បន្ទាប់ពីការពិនិត្យភាពច្បាស់លាស់ខាងបច្ចេកទេស រដ្ឋបាលសុរិយោដីស្រុក-ខណ្ឌត្រូវចុះហត្ថលេខាលើទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី។

ឯកសារនៃការវិនិច្ឆ័យដែលត្រូវផ្សព្វផ្សាយរួមមានផែនទីក្បាលដី គំនូសបង្ហាញទីតាំងដី និងបញ្ជីឈ្មោះម្ចាស់ដី។ ការផ្សព្វផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ត្រូវធ្វើឡើងក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃ នៅសាលាស្រុក-ខណ្ឌដែលមានសមត្ថកិច្ច។ សេចក្តីថតចម្លងនៃឯកសារទាំងនេះក៏ត្រូវបិទផ្សាយផងដែរ នៅទីស្នាក់ការឃុំ-សង្កាត់ដែលក្បាលដីស្នើសុំចុះបញ្ជីនោះឋិតនៅ។

អភិបាលស្រុក-ខណ្ឌត្រូវជូនដំណឹងអំពីការបិទផ្សាយជាសាធារណៈ នូវឯកសារនៃការវិនិច្ឆ័យនេះ ដល់អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីដី។ សេចក្តីជូនដំណឹងត្រូវធ្វើឡើងយ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃបើកការផ្សព្វផ្សាយជាសាធារណៈ ហើយត្រូវបិទផ្សាយនៅកន្លែងដែលងាយមើលឃើញ នៅក្នុងភូមិ នៅសាលាឃុំ-សង្កាត់ និងនៅសាលាស្រុក-ខណ្ឌ។

**មាត្រា១៤**

ក្នុងរយៈពេលនៃការផ្សព្វផ្សាយ ជនដែលមានផលប្រយោជន៍ទាក់ទងនឹងក្បាលដីស្នើសុំចុះបញ្ជី អាចជូនដំណឹងអំពីការជំទាស់របស់ខ្លួនទៅរដ្ឋបាលសុរិយោដីស្រុក-ខណ្ឌ ក្នុងករណីពិនិត្យឃើញថាឯកសារនៃការវិនិច្ឆ័យដែលបានបិទផ្សាយជាសាធារណៈមានលក្ខណៈមិនត្រឹមត្រូវ ឬមិនគ្រប់គ្រាន់។ រដ្ឋបាលសុរិយោដីស្រុក-ខណ្ឌត្រូវស៊ើបអង្កេតលើការជំទាស់នោះ ដោយផ្អែកតាមឯកសារ និងព័ត៌មានទាំងអស់ដែលប្រមូលបានក្នុងពេលអនុវត្តនីតិវិធី។

ក្នុងករណីដែលការស៊ើបអង្កេតនោះបង្ហាញថា ការជំទាស់មានលក្ខណៈសមហេតុផល រដ្ឋបាលសុរិយោដីស្រុក-ខណ្ឌអាចធ្វើការកែតម្រូវការខុសឆ្គង ឬការភ្លេចភ្លាំងដែលមិនប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់នៃជនណាមួយ។

ការកែតម្រូវផ្សេងទៀតក្នុងឯកសារនៃការវិនិច្ឆ័យ អាចធ្វើបានដរាបណាមានការយល់ព្រមពីជនពាក់ព័ន្ធដែលទទួលឥទ្ធិពលពីការកែតម្រូវនោះ។

ក្នុងករណីដែលការស៊ើបអង្កេតនោះបង្ហាញថា ការជំទាស់មានលក្ខណៈមិនសមហេតុផល ការជំទាស់ត្រូវបានដាក់ឱ្យធ្វើការសម្រុះសម្រួល និងដោះស្រាយតាមនីតិវិធីដែលមានកំណត់ក្នុងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី។

**មាត្រា១៥**

ក្រោយពីផុតកំណត់រយៈពេលនៃការបិទផ្សាយជាសាធារណៈ នូវឯកសារនៃការវិនិច្ឆ័យ និងបញ្ចប់ការដោះស្រាយទំនាស់តាមនីតិវិធីដូចមានចែងក្នុងមាត្រា១៤នៃអនុក្រឹត្យនេះ រដ្ឋបាលសុរិយោដីស្រុក-ខណ្ឌ ត្រូវបញ្ចូលក្បាលដីទៅក្នុងផែនទីមានលក្ខណៈដាច់ដោយដុំ។

ផែនទីមានលក្ខណៈដាច់ដោយដុំគឺជាប្លង់សុរិយោដីដែលបង្ហាញអំពីទីតាំង លេខ និងព្រំប្រទល់នៃក្បាលដីទាំងឡាយដែលបានចុះបញ្ជីរួច និងក្បាលដីដែលស្នើសុំចុះបញ្ជី បន្ទាប់ពីបានបិទផ្សាយជាសាធារណៈ និងបានបញ្ចប់ការសម្រុះសម្រួល និងការដោះស្រាយទំនាស់។

**មាត្រា១៦**

រដ្ឋបាលសុរិយោដីស្រុក-ខណ្ឌត្រូវផ្ញើសំណុំឯកសារទៅរដ្ឋបាលសុរិយោដីខេត្ត-ក្រុង ដូចខាងក្រោម៖

-ពាក្យស្នើសុំចុះបញ្ជីដី

-ឯកសារនៃការវិនិច្ឆ័យ

-សេចក្តីជូនដំណឹងស្តីពីកាលបរិច្ឆេទនៃការកំណត់ព្រំដី

-ការដកស្រង់ផែនទីមានលក្ខណៈដាច់ដោយដុំ

-សេចក្តីជូនដំណឹងពីការបិទផ្សាយជាសាធារណៈ

-របាយការណ៍ស្តីពីលទ្ធផលនៃការវិនិច្ឆ័យ

-ពាក្យបណ្តឹងជំទាស់តវ៉ាដែលពុំអាចដោះស្រាយបាន ប្រសិនបើមាន

-លិខិតស្នើសុំកែតម្រូវ ប្រសិនបើមាន

-កំណត់ហេតុសម្រុះសម្រួលវិវាទដែលបានដោះស្រាយរួច ប្រសិនបើមាន។

ក្នុងករណីដែលពិនិត្យឃើញថាឯកសារទាំងនោះគ្រប់គ្រាន់ និងត្រឹមត្រូវហើយ រដ្ឋបាលសុរិយោដីខេត្ត-ក្រុងត្រូវចុះហត្ថលេខា រួចបញ្ជូនទៅរដ្ឋបាលសុរិយោដីថ្នាក់កណ្តាល។

**មាត្រា១៧**

ក្បាលដីត្រូវបានចុះបញ្ជីនៅពេលដែលអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ឬរដ្ឋបាលសុរិយោដីខេត្ត-ក្រុង ដែលបានទទួលប្រតិភូកម្មពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានកត់ត្រារួចហើយក្នុងសៀវភៅគោលបញ្ជីដី។

**មាត្រា១៨**

បន្ទាប់ពីក្បាលដីត្រូវបានចុះបញ្ជីរួច រដ្ឋបាលសុរិយោដីត្រូវចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុឱ្យកម្មសិទ្ធិករនៃក្បាលដីដែលបានចុះបញ្ជី ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុឱ្យភោគីដែលបានចុះបញ្ជី។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់អាចប្រគល់សិទ្ធិឱ្យខេត្ត-ក្រុងណា ដែលមានគ្រប់លក្ខណសម្បត្តិ ដើម្បីចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ។

**មាត្រា១៩**

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រត្រូវបញ្ជូនតារាងសម្រង់អចលនវត្ថុទៅរដ្ឋបាលសុរិយោដីខេត្ត-ក្រុង ដែលមិនទាន់បានទទួលប្រតិភូកម្មពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីចុះក្នុងសៀវភៅគោលបញ្ជីដីឱ្យបានស្របគ្នា ហើយបញ្ជូនតារាងនេះបន្តទៅរដ្ឋបាលសុរិយោដីស្រុក-ខណ្ឌដើម្បីចុះក្នុងសៀវភៅគោលបញ្ជីដីឱ្យបានស្របគ្នាដែរ។

រដ្ឋបាលសុរិយោដីខេត្ត-ក្រុងដែលបានទទួលប្រតិភូកម្មពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវផ្ញើតារាងសម្រង់អចលនវត្ថុទៅរដ្ឋបាលសុរិយោដីស្រុក-ខណ្ឌ និងផ្ញើមកអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ដើម្បីចុះក្នុងសៀវភៅគោលបញ្ជីដីឱ្យបានស្របគ្នា។

ការណែនាំអំពីរបៀបរបបនៃការកាន់កាប់ឯកសារសុរិយោដី និងឯកសាររណបផ្សេងៗ ត្រូវកំណត់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២០**

សោហ៊ុយសេវាផ្សេងៗដែលទាក់ទងទៅនឹងការបំពេញភារកិច្ច ក្នុងការអនុវត្តអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរួម អនុលោមតាមមាត្រា២៣០នៃច្បាប់ភូមិបាល។

## ជំពូកទី៤ អវសានប្បញ្ញត្តិ

**មាត្រា២១**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា២២**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអភិបាលខេត្ត-ក្រុងទាំងអស់ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

<u>កន្លែងទទួល</u>

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័នកណ្តាល

-គ្រប់សាលាខេត្ត-ក្រុង

-ដូចមាត្រា២២

-ឯកសារ កាលប្បវត្តិ

*វាយឡើងវិញ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
លេខ៣៣៤០សហវ/អ រាជធានីភ្នំពេញ ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០២

គោរពជូន

ឯកឧត្តមរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី
ឯកឧត្តមអភិបាលក្រុងព្រះសីហនុ
ឯកឧត្តមអភិបាលខេត្តបន្ទាយមានជ័យ ព្រៃវែង ក្រចេះ សៀមរាប តាកែវ មណ្ឌលគីរី កោះកុង កំពង់ស្ពឺ និងកំពង់ធំ

កម្មវត្ថុ៖ សំណើកែលំអនីតិវិធីនៃការគ្រប់គ្រង និងប្រើប្រាស់ថវិការដ្ឋ ចំណូលពុំមែនសារពើពន្ធ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត-ក្រុង

យោង៖ -ព្រះរាជក្រមលេខ០១នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ១១នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៩

-ព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០១

-អនុក្រឹត្យលេខ០៤អនក្រ/បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ប្រកាសលេខ២០៩សហវ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-កំណត់ហេតុស្តីពីការធ្វើសវនកម្មនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីកោះកុង ខេត្តបន្ទាយមានជ័យ ព្រៃវែង ក្រុងព្រះសីហនុ ក្រចេះ សៀមរាប តាកែវ មណ្ឌលគីរី កំពង់ស្ពឺ និងកំពង់ធំ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានកិត្តិយសសូមជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រីជ្រាបថា ក្រោយពីបានធ្វើសវនកម្មនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តទាំង១០ ខាងលើរួចមក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្កេតឃើញថា ការគ្រប់គ្រង និងប្រើប្រាស់ថវិការដ្ឋ ចំណូលពុំមែនសារពើពន្ធ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅពុំទាន់បានល្អប្រសើរនៅឡើយ ។

ក្នុងមូលហេតុនេះ ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវ និងម៉ឺងម៉ាត់នូវច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានកិត្តិយស សូមឯកឧត្តមរដ្ឋមន្ត្រធ្វើការជំរុញមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ឱ្យអនុវត្តនូវអនុសាសន៍មួយចំនួនដូចតទៅ៖

១-ត្រូវខិតខំអនុវត្តឱ្យបានរាល់បណ្តាសំណូមពររបស់គណៈប្រតិភូអធិការកិច្ចក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលនៅសេសសល់ មិនទាន់បានអនុវត្ត

២-រជ្ជទេយ្យករ ភ្នាក់ងារបើកផ្តល់ ត្រូវកត់ត្រា តាមដានចលនាសាច់ប្រាក់ជាក់ស្តែងឱ្យបានច្បាស់លាស់ ត្រឹមត្រូវ ទៀងទាត់ និងទាន់ពេលវេលា

៣-សម្ភារៈ ប្រេងឥន្ធនៈដែលបានបែងចែកប្រើប្រាស់ត្រូវមានតារាងបែងចែក ឬមានលិខិតស្នើសុំព្រមទាំងហត្ថលេខាប្រគល់ ទទួលឱ្យបានត្រឹមត្រូវ

៤-ត្រូវរៀបចំបែបបទដកសាច់ប្រាក់ពីសាខាពន្ធដារខេត្ត និងយកទៅប្រើប្រាស់ឱ្យបានត្រឹមត្រូវតាមចំណុចទី៤នៃប្រកាសលេខ០០៧ប្រក/សហវ ចុះថ្ងៃទី០២/០១/៩២

៥-ផ្អាកការយកចំណូលពីការអង្កេតវាស់វែង ដីធ្លី ផ្ទះសំបែង ទិញ-លក់ដែលគ្មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុដែលមិនមានគោលការណ៍ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*វាយឡើងវិញ*

៦-ត្រូវកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យចលនវត្ថុ និងសម្ភារៈដែលមានទឹកប្រាក់សរុបចំនួន ១៦.៩៣១.២០០រៀល (ដប់ប្រាំមួយលានប្រាំបួនរយសាមសិបមួយពាន់ពីររយរៀលគត់) ដូចមានក្នុងតារាងឧបសម្ព័ន្ធជូនភ្ជាប់ខាងក្រោយ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមរដ្ឋមន្ត្រីជ្រាប និងមានវិធានការអនុវត្តតាមការគួរ ។

សូមឯកឧត្តមមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ហត្ថលេខា និងត្រា**

**គាត ឈន់**

<u>ចម្លងជូន</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ៥៨៤ដនស/ជសហ ភ្នំពេញ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០២

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជម្រាបជូន**

**លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីគ្រប់ខេត្ត-ក្រុង**

កម្មវត្ថុ៖ ស្តីពីការកែលំអនីតិវិធីនៃការគ្រប់គ្រង និងប្រើប្រាស់ថវិកា ចំណូលពុំមែនសារពើពន្ធ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅតាមមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីគ្រប់ខេត្ត-ក្រុង

យោង៖ លិខិតលេខ៣៣៨០សហវ/អ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

តបតាមកម្មវត្ថុ និងយោងខាងលើ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជម្រាបលោកប្រធាន ក្រោយពីបានធ្វើសវនកម្មនៅតាមមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុងមួយចំនួន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានសង្កេតឃើញថា ការគ្រប់គ្រង និងប្រើប្រាស់ថវិការដ្ឋ ចំណូលពុំមែនសារពើពន្ធ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅតាមបណ្តាមន្ទីរមួយចំនួនពុំទាន់បានល្អប្រសើរនៅឡើយ ។ ដូច្នេះ ក្រសួងឱ្យគ្រប់មន្ទីរខេត្ត-ក្រុងទាំងអស់ពិនិត្យ និងកែលំអឡើងវិញនូវរាល់ចំណុចខ្វះខាតទាំងឡាយ ដែលមានដូចក្នុងលិខិតរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុខាងលើ ហើយអនុវត្តចុះបញ្ជិកាគណនេយ្យ ហិរញ្ញវត្ថុឱ្យបានល្អប្រសើរឡើងវិញ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ក្រសួងសង្ឃឹមថាលោកប្រធានមន្ទីរគ្រប់ខេត្ត-ក្រុង នឹងអនុវត្តបានល្អតាមសេចក្តីណែនាំនេះ ។

សូមលោកប្រធានទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

**តប.រដ្ឋមន្ត្រី**
**អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល**
**ហត្ថលេខា និងត្រា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**លេខ០០១ជនស/សជ**

## សារាចរណែនាំ

## អនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី

## (ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ)

អនុលោមតាមអនុក្រឹត្យលេខ៤៦អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមធ្វើការណែនាំដូចតទៅ៖

**ដំណាក់កាលទី១ អំពីការរៀបចំ**

១-បន្ទាប់ពីបានពិភាក្សាឯកភាពជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អំពីការជ្រើសរើសទីតាំងរួចមក អភិបាលខេត្ត-ក្រុងត្រូវចេញសេចក្តីប្រកាសកំណត់តំបន់ និងព្រំប្រទល់នៃទីតាំងធ្វើការវិនិច្ឆ័យ តាមរបៀបបង្ហាញលើផែនទី ឬតាមរបៀបពិពណ៌នា ឬតាមរបៀបទាំងពីរ ។

២-នៅពេលដែលតំបន់ធ្វើការវិនិច្ឆ័យត្រូវបានកំណត់ហើយ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ត្រូវចាត់តាំងមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ និងមន្ត្រីចាំបាច់មួយចំនួនទៀត រួមមានមន្ត្រីកំណត់ព្រំដី មន្ត្រីវាស់វែង និងមន្ត្រីវិនិច្ឆ័យឱ្យទៅបំពេញភារកិច្ចនៅក្នុងតំបន់វិនិច្ឆ័យនោះ ។ ទន្ទឹមនឹងនេះ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុងពាក់ព័ន្ធនឹងតំបន់វិនិច្ឆ័យ ក៏ត្រូវចាត់តាំងមន្ត្រីម្នាក់ឱ្យទទួលខុសត្រូវការងាររដ្ឋបាលសុរិយោដីជូនអភិបាលខេត្ត-ក្រុង ដើម្បីបញ្ចូលជាសមាជិកនៃគណៈកម្មការរដ្ឋបាលផងដែរ ។

៣-យោងតាមចំណាត់តាំងខាងលើ អភិបាលខេត្ត-ក្រុងត្រូវបង្កើតគណៈកម្មការរដ្ឋបាលសម្រាប់តំបន់ដែលត្រូវធ្វើការវិនិច្ឆ័យ ទៅតាមសមាសភាពដែលបានកំណត់ក្នុងអនុក្រឹត្យ ។

៤-គណៈកម្មការរដ្ឋបាលត្រូវរៀបចំប្រជុំណែនាំសមាជិករបស់ខ្លួនឱ្យយល់ អំពីកិច្ចដំណើរការនៃការវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធ កំណត់បែងចែកភារកិច្ចដល់សមាជិកម្នាក់ៗ រៀបចំផែនការសម្រាប់អនុវត្ត និងលើកសំណើទៅអភិបាលខេត្ត-ក្រុងអំពីកាលបរិច្ឆេទ និងទីកន្លែងដែលត្រូវបើកកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ និងព្រំប្រទល់នៃទីតាំងធ្វើការវិនិច្ឆ័យ និងការចុះបំពេញការងារវាលរបស់មន្ត្រីជំនាញ។

៥-អភិបាលខេត្ត-ក្រុងត្រូវធ្វើលិខិតផ្លូវការដែលពិពណ៌នា និងអនុញ្ញាតឱ្យអនុវត្តនីតិវិធីនៃការវិនិច្ឆ័យមានលក្ខណៈជាប្រព័ន្ធ ទៅអាជ្ញាធរមូលដ្ឋាននៃតំបន់ធ្វើការវិនិច្ឆ័យ យ៉ាងហោចណាស់១៥ថ្ងៃ មុនកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ និងព្រំប្រទល់នៃទីតាំងធ្វើការវិនិច្ឆ័យ។

៦-អភិបាលខេត្ត-ក្រុងត្រូវជូនដំណឹងជាសាធារណៈអំពីកាលបរិច្ឆេទ និងទីកន្លែងប្រជុំ។ សេចក្តីជូនដំណឹងត្រូវបិទផ្សាយ និងអាចផ្សព្វផ្សាយតាមឧត្សោសនសព្ទ ជូនសាធារណជនជ្រាបយ៉ាងហោចណាស់៧ថ្ងៃ មុនកិច្ចប្រជុំផ្សព្វផ្សាយ នៅទីកន្លែងដែលងាយឃើញក្នុងភូមិ ឬនៅទីតាំងធ្វើការវិនិច្ឆ័យផ្ទាល់។ សេចក្តីជូនដំណឹងនេះមានគោលបំណងឱ្យកម្មសិទ្ធិករ ឬអ្នកកាន់កាប់ដី ព្រមទាំងជនដែលមានការពាក់ព័ន្ធនឹងក្បាលដីក្នុងតំបន់ធ្វើការវិនិច្ឆ័យ បានយល់ជ្រួតជ្រាបពីសារៈសំខាន់នៃកិច្ចប្រតិបត្តិការរបស់មន្ត្រីជំនាញ ដើម្បីមកចូលរួមផ្តល់ព័ត៌មាន ឯកសារ និងភស្តុតាងសំខាន់ៗទាក់ទងនឹងអត្តសញ្ញាណនៃក្បាលដី អត្តសញ្ញាណនៃម្ចាស់ដី ធ្វើឱ្យទិន្នន័យដែលប្រមូលបានមានភាពពិតប្រាកដ និងសុក្រឹត។

ក្នុងឱកាសប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ធ្វើការវិនិច្ឆ័យ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ឬតំណាងគណៈកម្មការរដ្ឋបាលត្រូវពន្យល់អំពីដំណើរការនៃការវិនិច្ឆ័យ ភាពចាំបាច់ និងឱកាសដែលត្រូវចូលរួមរបស់ប្រជាពលរដ្ឋជាម្ចាស់សិទ្ធិ បំភ្លឺអំពីសិទ្ធិស្របច្បាប់ លើអចលនវត្ថុ និងកាតព្វកិច្ចដែលត្រូវបំពេញ ព្រមទាំងឆ្លើយនូវរាល់សំណួរ ឬចម្ងល់ដែលបានលើកឡើងក្នុងអង្គប្រជុំ។ ផ្អែកលើសារៈសំខាន់ដូចបានបញ្ជាក់ខាងលើ សេចក្តីជូនដំណឹងត្រូវតែផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាព។ កិច្ចប្រជុំបន្ថែមសម្រាប់ថ្នាក់ភូមិនឹងត្រូវបានរៀបចំ ប្រសិនបើមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ឬអាជ្ញាធរមូលដ្ឋានចាត់ទុកជាការចាំបាច់។

កិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ និងព្រំប្រទល់ទីតាំងធ្វើការវិនិច្ឆ័យ ត្រូវប្រព្រឹត្តទៅនៅក្នុងទីកន្លែងណាមួយ ក្នុងតំបន់ធ្វើការវិនិច្ឆ័យ ដែលមានជាអាទិ៍ ទីវត្តអារាម ទីសាធារណៈ សាលារៀន សាលាឃុំ-សង្កាត់ សាលាស្រុក-ខណ្ឌ ដោយយោងតាមស្ថានភាពជាក់ស្តែងនៃទីតាំងវិនិច្ឆ័យនីមួយៗ។

**ដំណាក់កាលទី២ អំពីប្រតិបត្តិការបច្ចេកទេស**

**១.ការងារវាល**

ក្រោមការដឹកនាំ និងត្រួតពិនិត្យរបស់មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ការងារវាលត្រូវបានអនុវត្តដោយមន្ត្រីកំណត់ព្រំដី មន្ត្រីវាស់វែង និងមន្ត្រីវិនិច្ឆ័យ ដោយមានការសហការ និងការជួយជ្រោមជ្រែងពីមន្ត្រីនៅមូលដ្ឋាន (មេភូមិ មេឃុំ ឬចៅសង្កាត់ )។ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យមានភារកិច្ចត្រួតពិនិត្យលើភាពត្រឹមត្រូវលើការងារបច្ចេកទេស និងច្បាប់ក្នុងការវាស់វែង និងការបំពេញទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី និងសម្របសម្រួលការងារជាមួយអាជ្ញាធរមូលដ្ឋាន។ នៅពេលឯកសារនៃការវិនិច្ឆ័យត្រូវបំពេញចប់សព្វគ្រប់ហើយ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យត្រូវចុះហត្ថលេខាលើឯកសារទាំងនោះ។

**១.១.អំពីសិទ្ធិ និងភារកិច្ចរបស់មន្ត្រីជំនាញក្នុងពេលអនុវត្តការងារវាល**

**១.១.១.មន្ត្រីកំណត់ព្រំដី**

-ត្រូវជូនដំណឹងទៅឃុំ-សង្កាត់ជ្រាបមុន៧ថ្ងៃយ៉ាងតិច អំពីកាលបរិច្ឆេទ និងទីកន្លែងដែលត្រូវចាប់ផ្តើមអនុវត្តការងារកំណត់ព្រំដី។ ទទួលបានសេចក្តីជូនដំណឹងនេះ មេឃុំ ចៅសង្កាត់ត្រូវជូនដំណឹងបន្តដល់សាមីអ្នកកាន់កាប់ដី និងជនពាក់ព័ន្ធដើម្បីមកចូលរួមចង្អុលបង្ហាញព្រំដីរបស់ខ្លួន។

-មានសិទ្ធិចូលក្នុងបរិវេណអចលនវត្ថុ ដើម្បីកំណត់ព្រំដី និងវាស់វែង ហើយអាចអញ្ជើញជនពាក់ព័ន្ធឱ្យផ្តល់ចម្លើយផ្ទាល់មាត់ ឯកសារ ឬបង្ហាញភស្តុតាងផ្សេងៗទាក់ទងនឹងព្រំដីដែលកំពុងធ្វើការកំណត់។

-មន្ត្រីទទួលបន្ទុកកំណត់ព្រំដីត្រូវគោរពគោលការណ៍ដូចខាងក្រោម៖

ក-បើកម្មសិទ្ធិករ ឬម្ចាស់នៃក្បាលដីជាប់ព្រំ មានវត្តមានហើយបានព្រមព្រៀងគ្នាលើព្រំប្រទល់ នោះព្រំក្បាលដីនឹងត្រូវបានកំណត់ដោយយោងតាមការព្រមព្រៀង។

ខ-បើការព្រមព្រៀងដែលរៀបរាប់ក្នុងចំណុច (ក) ខាងលើ មិនអាចធ្វើទៅបាន ឬមានកម្មសិទ្ធិករ ឬម្ចាស់នៃក្បាលដី និងម្ចាស់នៃក្បាលដីដែលនៅជាប់ព្រំណាមួយអវត្តមាន នោះព្រំប្រទល់ត្រូវកំណត់នៅលើដីតាមឯកសារដែលមាន និងភស្តុតាងជាលក្ខណរូប ជាលាយលក្ខណ៍អក្សរ ឬចម្លើយផ្ទាល់មាត់ទាក់ទងនឹងព្រំដី ។

គ-បើក្បាលដីមានព្រំជាប់នឹងដីសាធារណៈ ឬក្បាលដី ដែលប្រើប្រាស់ជាសាធារណៈ ព្រំប្រទល់ក្បាលដី ត្រូវបានកំណត់ដោយអនុលោមទៅតាមចំណុច (ក) ឬចំណុច (ខ) ខាងលើ ។

ឃ-វិវាទអំពីព្រំដីដែលទទួលបាននៅពេលកំណត់ព្រំដី ហើយមិនអាចសម្រុះសម្រួលបាន ត្រូវបញ្ជូនទៅគណៈកម្មការរដ្ឋបាល ធ្វើការសម្រុះសម្រួល និងដោះស្រាយនៅពេលបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ។

**១.១.២_មន្ត្រីវាស់វែង**

បន្ទាប់ពីបានកំណត់ព្រំដីរួច មន្ត្រីវាស់វែងត្រូវអនុវត្តការងារវាស់វែង ដែលជាតម្រូវការក្នុងការកសាងប្លង់សុរិយោដី និងការអនុវត្តនីតិវិធីនៃការវិនិច្ឆ័យ ។

**១.១.៣_មន្ត្រីវិនិច្ឆ័យ**

-មានសិទ្ធិសាកសួរយកព័ត៌មានចាំបាច់សម្រាប់អនុវត្តការងារវិនិច្ឆ័យ ។ មន្ត្រីវិនិច្ឆ័យអាចអញ្ជើញជនពាក់ព័ន្ធឱ្យផ្តល់ចម្លើយ ដោយផ្ទាល់មាត់ ឯកសារ ឬភស្តុតាងផ្សេងៗ ដែលទាក់ទងនឹងការវិនិច្ឆ័យ ។

-ប្រមូលរាល់ឯកសារ ភស្តុតាង និងព័ត៌មានផ្សេងៗ ទាក់ទងនឹងសិទ្ធិលើក្បាលដីនីមួយៗ ក្នុងតំបន់ធ្វើការវិនិច្ឆ័យ ហើយកត់ត្រាសិទ្ធិទាំងនោះ ចូលក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី រួចឱ្យអ្នកកាន់កាប់ដី ផ្តិតមេដៃ ហើយមន្ត្រីនោះត្រូវចុះហត្ថលេខា និងឈ្មោះទទួលខុសត្រូវលើឯកសារនោះផងដែរ ។

-ករណីមានវិវាទកើតឡើង ទាក់ទងនឹងព្រំប្រទល់ក្តី ទាក់ទងនឹងសិទ្ធិលើក្បាលដីក្តី មន្ត្រីវិនិច្ឆ័យត្រូវកត់ត្រាក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីថាជាដីមានទំនាស់ ។

**១.២_អំពីសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកកាន់កាប់ ឬអ្នកតំណាងស្របច្បាប់**

អ្នកកាន់កាប់ដី ឬអ្នកតំណាងស្របច្បាប់របស់ជននេះមានកាតព្វកិច្ចចូលរួម និងសហការក្នុងការកំណត់ព្រំដី វាស់វែង និងវិនិច្ឆ័យ តាមរយៈការផ្តល់នូវព័ត៌មានពិត ដោយផ្ទាល់មាត់ ជាលាយលក្ខណ៍អក្សរ ឬភស្តុតាងផ្សេងៗទាក់ទងនឹងក្បាលដីរបស់ខ្លួន ឬក្បាលដីដែលខ្លួនឈរឈ្មោះជាតំណាង ឬក្បាលដីអ្នកជាប់ព្រំដល់មន្ត្រីជំនាញ។

ក្នុងរយៈពេលប្រតិបត្តិការរបស់មន្ត្រីជំនាញ អ្នកកាន់កាប់ដី ឬអ្នកតំណាងស្របច្បាប់នៃជននេះ ឬជនពាក់ព័ន្ធ មានសិទ្ធិជំទាស់ ឬតវ៉ា ប្រសិនបើខ្លួនយល់ថា ទិន្នន័យដែលមន្ត្រីជំនាញបានកត់ត្រាចូលក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យមិនត្រឹមត្រូវ ឬខុសពីចម្លើយរបស់ខ្លួន។

**១.៣-អំពីភារកិច្ចរបស់អាជ្ញាធរដែនដី**

ក-អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវបង្កលក្ខណសម្បត្តិងាយស្រួល សហការឱ្យបានល្អ និងផ្តល់សុវត្ថិភាពដល់កិច្ចប្រតិបត្តិការទាំងឡាយមានប្រតិបត្តិការបច្ចេកទេស រដ្ឋបាលគតិយុត្តដើម្បីធ្វើឱ្យសម្រេចនូវការអនុវត្តនីតិវិធីនៃការវិនិច្ឆ័យដែលប្រព្រឹត្តទៅនៅក្នុងដែនដី ដែលខ្លួនទទួលខុសត្រូវ។

ខ-ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈ នូវឯកសារនៃការវិនិច្ឆ័យដែលមានប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដីក្នុងឃុំ-សង្កាត់ណាមួយ មេឃុំ ចៅសង្កាត់ ឬតំណាងស្របច្បាប់របស់ខ្លួន ត្រូវមានវត្តមានតាមកាលកំណត់ និងតាមតម្រូវការជាក់ស្តែងនៃការងារ។

**២-ការងារនៅការិយាល័យ**

ទិន្នន័យដែលប្រមូលបានពីការងារវាលត្រូវបញ្ចូលក្នុងកុំព្យូទ័រ ដើម្បីកសាងប្លង់សុរិយោដី បញ្ជីឈ្មោះម្ចាស់ដី និងសៀវភៅគោលបញ្ជីដីធ្លី។

**ដំណាក់កាលទី៣ អំពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ**

អភិបាលខេត្ត-ក្រុងត្រូវធ្វើសេចក្តីជូនដំណឹងស្តីពីការបិទផ្សាយជាសាធារណៈ នូវប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដី តាមសំណើរបស់គណៈកម្មការរដ្ឋបាល។ ការជូនដំណឹងអាចធ្វើតាមគ្រប់មធ្យោបាយ ដូចជា តាមរយៈការប្រជុំ វិទ្យុ ទូរទស្សន៍ សារព័ត៌មាន រូបភាពបិទផ្សាយ ឬតាមឧគ្ឃោសនសព្ទ...។ល។

ការបិទផ្សាយជាសាធារណៈមានរយៈពេល៣០ថ្ងៃ ហើយត្រូវធ្វើនៅកន្លែងដែលងាយមើលឃើញ ក្នុងទីតាំងនៃតំបន់ធ្វើការវិនិច្ឆ័យ ដូចជាទីវត្តអារាម ទីសាធារណៈ សាលារៀន សាលាឃុំ-សង្កាត់ សាលាស្រុក . . .។

ក្នុងអំឡុងពេលនៃការបិទផ្សាយ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យត្រូវណែនាំមន្ត្រី ដែលទទួលខុសត្រូវការងារជំនាញនីមួយៗ ឱ្យប្រចាំការនៅកន្លែងបិទផ្សាយរៀងរាល់ថ្ងៃ ទាំងថ្ងៃឈប់សម្រាក ទាំងថ្ងៃបុណ្យផ្សេងៗ ដើម្បីរង់ចាំពន្យល់ ឬបំភ្លឺអំពីខ្លឹមសារនៃទិន្នន័យបកស្រាយ ចម្ងល់ផ្សេងៗដែលទាក់ទងទៅនឹងឯកសារដែលបានបិទផ្សាយ។ ទន្ទឹមនឹងនេះ គណៈកម្មការរដ្ឋបាលក៏ត្រូវចាត់តាំងមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ និងមន្ត្រីនៅមូលដ្ឋានចាំបាច់ ជាអាទិ៍ មេឃុំ ចៅសង្កាត់ ឬតំណាងផ្លូវច្បាប់របស់ជននេះ ឱ្យមកប្រចាំការរង់ចាំទទួលបណ្តឹងជំទាស់ ឬបណ្តឹងតវ៉ា ធ្វើការស្រាវជ្រាវ និងដោះស្រាយបញ្ហាតាមគោលការណ៍កំណត់។

សាមីអ្នកកាន់កាប់ដី ឬតំណាងស្របច្បាប់របស់ជននេះ ដែលមិនទាន់យល់ស្របតាមការសម្រេចបណ្តោះអាសន្នរបស់មន្ត្រីជំនាញនៅពេលប្រតិបត្តិការកំណត់ព្រំដី ឬវិនិច្ឆ័យមានសិទ្ធិប្តឹងជំទាស់ ឬប្តឹងតវ៉ាទៅគណៈកម្មការរដ្ឋបាលនៅពេលបិទផ្សាយជាសាធារណៈ នូវឯកសារនៃការវិនិច្ឆ័យ ដើម្បីឱ្យគណៈកម្មការនេះលើកយកមកដោះស្រាយឡើងវិញ។ ករណីមិនអាចដោះស្រាយបាន គណៈកម្មការរដ្ឋបាលត្រូវបញ្ជូនសំណុំរឿងវិវាទនោះ ទៅគណៈកម្មការសុរិយោដីធ្វើការដោះស្រាយបន្ត។ បណ្តឹងនីមួយៗត្រូវបានកត់ត្រាដាច់ដោយឡែកពីគ្នា ហើយត្រូវមានបញ្ជាក់ច្បាស់លាស់អំពីកម្មវត្ថុនៃបណ្តឹង ឈ្មោះ និងស្នាមមេដៃម្ចាស់បណ្តឹង ឈ្មោះ និងហត្ថលេខាមន្ត្រីទទួលកត់ត្រា និងមានការបញ្ជាក់ដឹងឮពីមេឃុំ ចៅសង្កាត់ ឬតំណាងស្របតាមច្បាប់របស់ជននេះ។

ករណីមិនមានការជំទាស់ ឬតវ៉ា ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈ ទិន្នន័យដែលបានកត់ត្រាក្នុងឯកសារបិទផ្សាយនោះ ត្រូវបានចាត់ទុកជាទិន្នន័យសុក្រឹត ដែលអាចកំណត់យកជាផ្លូវការតាមច្បាប់បាន លើកលែងចំពោះតែករណីដែលសាមីអ្នកកាន់កាប់ដី ឬអចលនវត្ថុមានឯកសារសំអាងច្បាស់លាស់ ហើយបានបង្ហាញអំពីមូលហេតុដែលមិនបានមកធ្វើការជំទាស់ ឬតវ៉ាក្នុងរយៈពេលបិទផ្សាយនោះ សាមីជនអាចដាក់ពាក្យបណ្តឹងទៅគណៈកម្មការសុរិយោដី ដើម្បីដោះស្រាយតាមនីតិវិធីដែលបានកំណត់។

មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យមានសិទ្ធិកែតម្រូវចំពោះតែការខុសឆ្គង ឬការភ្លេចភ្លាំងណាដែលមិនជះឥទ្ធិពលដល់ផលប្រយោជន៍អ្នកដទៃ ។

ចំពោះការកែតម្រូវណាដែលនាំឱ្យជះឥទ្ធិពលដល់ផលប្រយោជន៍អ្នកដទៃ អាចធ្វើការកែតម្រូវបានលុះត្រាតែមានការយល់ព្រមពីជនដែលមានផលប្រយោជន៍ពាក់ព័ន្ធនោះ ។

**ដំណាក់កាលទី៤ អំពីការសម្រេចលើឯកសារ**

១-ក្រោយពីផុតរយៈពេលនៃការបិទផ្សាយជាសាធារណៈ នូវឯកសារនៃការវិនិច្ឆ័យ គណៈកម្មការរដ្ឋបាល ត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការវិនិច្ឆ័យតាមខ្លឹមសារខាងក្រោម៖

ក-លទ្ធផលដែលសម្រេចបាន

-ចំនួនក្បាលដីសរុបដែលបានធ្វើការវិនិច្ឆ័យ

-ចំនួនក្បាលដីដែលមិនត្រូវបានចេញប័ណ្ណជូន ដោយការកាន់កាប់ដីរដ្ឋចាប់ផ្តើមក្រោយច្បាប់ភូមិបាលចូលជាធរមាន

-ចំនួនក្បាលដីដែលមានលក្ខណៈត្រឹមត្រូវ និងគ្មានវិវាទ

-ចំនួនក្បាលដីដែលមានវិវាទ

-ចំនួនក្បាលដីមានវិវាទ ដែលគណៈកម្មការរដ្ឋបាលបានដោះស្រាយរួចតាមការព្រមព្រៀង

-ចំនួនក្បាលដីដែលមានវិវាទ ហើយបានបញ្ជូនទៅគណៈកម្មការសុរិយោដី

-ចំនួនក្បាលដីដែលកំពុងមានបណ្តឹងទៅតុលាការ

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រត្រូវរៀបចំនូវគំរូរបាយការណ៍ស្តីពីលទ្ធផលនៃការវិនិច្ឆ័យ ។

ខ-ធ្វើការវាយតម្លៃ លើកសំណើផ្តល់សិទ្ធិលើដី ឬអចលនវត្ថុ តាមប្រភេទកម្មសិទ្ធិ ភោគៈសម្បទាន ឬរក្សាទុកជាដីរដ្ឋជូនកម្មសិទ្ធិករ ភោគី ឬអ្នកកាន់កាប់ ដោយយោងទៅតាមច្បាប់ បទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត និងឯកសារ ឬភស្តុតាងដែលប្រមូលបាន ។

២-ក្រោយពីប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដី ត្រូវបានកែតម្រូវរួចហើយ៖

-មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យត្រូវចុះហត្ថលេខាលើប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដី

-ប្រធានគណៈកម្មការរដ្ឋបាលត្រូវចុះហត្ថលេខាលើប្លង់សុរិយោដី បញ្ជីឈ្មោះម្ចាស់ដី និងរបាយការណ៍ស្តីពីលទ្ធផលនៃការវិនិច្ឆ័យ ។

-ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង ត្រូវចុះហត្ថលេខាបំពេញលើប្លង់សុរិយោដី បញ្ជីឈ្មោះម្ចាស់ដី និងរបាយការណ៍ស្តីពីលទ្ធផលនៃការវិនិច្ឆ័យ ត្រង់ចំណុចហត្ថលេខាអភិបាលខេត្ត-ក្រុង ។

-អភិបាលខេត្ត-ក្រុងត្រូវចុះហត្ថលេខាលើប្លង់សុរិយោដី បញ្ជីឈ្មោះម្ចាស់ដី និងរបាយការណ៍ស្តីពីលទ្ធផលនៃការវិនិច្ឆ័យ ។ ករណីមិនឯកភាព ត្រូវបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់ ។

-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះហត្ថលេខាសម្រេចជាផ្លូវការលើប្លង់សុរិយោដី បញ្ជីឈ្មោះម្ចាស់ដី និងរបាយការណ៍ស្តីពីលទ្ធផលនៃការវិនិច្ឆ័យ ។

ក្រោយពីអភិបាលខេត្ត-ក្រុង និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ចុះហត្ថលេខាសម្រេចយល់ព្រមរួចហើយ ឯកសារនៃការវិនិច្ឆ័យត្រូវបានបញ្ចប់ជាស្ថាពរ និងត្រូវបានចាត់ទុកជាឯកសារផ្លូវការតាមច្បាប់ ចំពោះក្បាលដីណាដែលមិនទាក់ទងនឹងវិវាទ ។

ចំពោះក្បាលដីដែលមានវិវាទ ហើយមិនទាន់ដោះស្រាយចប់ជាស្ថាពរ អាចត្រូវបានបន្តការដោះស្រាយនៅគណៈកម្មការសុរិយោដី ឬនៅតុលាការ ។

**ដំណាក់កាលទី៥ អំពីការចេញប័ណ្ណ**

នៅពេលដែលនីតិវិធីនៃការវិនិច្ឆ័យ ត្រូវបានបញ្ចប់ជាស្ថាពរ ឯកសារនៃការវិនិច្ឆ័យ និងឯកសារណាបពាក់ព័ន្ធទាំងអស់ ត្រូវបានបញ្ជូលទៅរដ្ឋបាលសុរិយោដី ដើម្បីចុះបញ្ជី ចេញប័ណ្ណ និងគ្រប់គ្រង៖

-ថ្នាក់កណ្តាល (អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ) ចំពោះឯកសារទាក់ទងនឹងខេត្ត-ក្រុងណាដែលមិនទាន់ទទួលបានប្រតិភូកម្ម

-ថ្នាក់ខេត្ត-ក្រុង (មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី) ចំពោះឯកសារដែលទាក់ទងនឹងខេត្ត-ក្រុងណាដែលបានទទួលប្រតិភូកម្មរួចហើយ ។

គោលការណ៍នៃការចេញប័ណ្ណ៖

១-ចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ( ប័ណ្ណកម្មសិទ្ធិ) ចំពោះក្បាលដី ឬអចលនវត្ថុណាដែលបានកាន់កាប់ដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី៥ឆ្នាំយ៉ាងតិច គិតមកដល់កាលបរិច្ឆេទនៃការប្រកាសឱ្យប្រើច្បាប់ភូមិបាល ( មាត្រា៣០ វាក្យខណ្ឌទី១នៃច្បាប់ភូមិបាល) ។

២-ចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ( ប័ណ្ណភោគៈ) ចំពោះក្បាលដី ឬអចលនវត្ថុណាដែលកាន់កាប់ដោយសន្តិវិធី និងមិនមានការជំទាស់ ហើយមានរយៈពេលតិចជាង៥ឆ្នាំមុនច្បាប់ភូមិបាលចូលជាធរមាន។ ប័ណ្ណប្រភេទនេះអាចប្តូរយកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុនៅពេលដែលរយៈពេលនៃការកាន់កាប់ដី ឬអចលនវត្ថុនោះបានគ្រប់៥ឆ្នាំ ឬលើស ។

៣-អាចចេញប័ណ្ណជូនបានចំពោះតែក្បាលដី ឬអចលនវត្ថុណាដែលគ្មានពាក់ព័ន្ធនឹងវិវាទ ។

៤-ការប្រគល់ប័ណ្ណត្រូវមានសៀវភៅសម្រាប់កត់ឈ្មោះ និងចុះហត្ថលេខាមន្ត្រីអ្នកប្រគល់ និងកត់ឈ្មោះ រួចផ្តិតមេដៃអ្នកទទួលទុកជាភស្តុតាង។ ការប្រគល់ប័ណ្ណត្រូវប្រព្រឹត្តទៅនៅអង្គភាពសុរិយោដីដែលមានសមត្ថកិច្ច។ មន្ត្រីសុរិយោដីមិនត្រូវបានអនុញ្ញាតឱ្យប្រគល់ប័ណ្ណជូនបុគ្គលក្រៅពីម្ចាស់សិទ្ធិពិតប្រាកដឡើយ លើកលែង៖

-ករណីម្ចាស់សិទ្ធិទទួលមរណៈភាព ឬអវត្តមាន ឬត្រូវបាត់ខ្លួន ឬបាត់បង់សមត្ថភាពដែលច្បាប់ទទួលស្គាល់ ពេលនោះអ្នកតំណាងស្របច្បាប់មានសិទ្ធិទទួលជំនួស

-ករណីពិសេស និងចាំបាច់ ម្ចាស់សិទ្ធិអាចដាក់ពាក្យសុំប័ណ្ណបាន តែត្រូវបញ្ជាក់ច្បាស់ពីហេតុដែលមិនអាចមកទទួលប័ណ្ណនៅការិយាល័យ ទើបអនុញ្ញាតឱ្យប្រគល់ប័ណ្ណនៅគេហដ្ឋានរបស់កម្មសិទ្ធិករ ឬភោគី ដោយមន្ត្រីសុរិយោដីយ៉ាងតិច២នាក់។

៥-នៅពេលទទួលប័ណ្ណថ្មី ម្ចាស់ដី ឬអចលនវត្ថុត្រូវប្រគល់ប័ណ្ណចាស់ទាក់ទងនឹងសិទ្ធិលើដី ឬអចលនវត្ថុនោះ ជូនមន្ត្រីសុរិយោដី ប្រសិនបើមាន។

៦-ចំពោះនីតិបុគ្គល ប័ណ្ណត្រូវចុះឈ្មោះអង្គភាព (នីតិបុគ្គលសាធារណៈ មានជាអាទិ៍ សាលារៀន សាលាឃុំ . . . នីតិបុគ្គលឯកជន មានជាអាទិ៍ សមាគម ក្រុមហ៊ុន) មិនត្រូវចុះឈ្មោះរូបវន្តបុគ្គលជាដាច់ខាត។ ចំពោះដី ឬអចលនវត្ថុរបស់សមូហភាព ដូចជាវត្ត ឬសហគមន៍ជនជាតិដើមភាគតិច នៅក្នុងប័ណ្ណក៏ត្រូវចុះឈ្មោះ វត្ត ឬសហគមន៍...ដែរ គឺមិនត្រូវចុះឈ្មោះរូបវន្តបុគ្គលជាតំណាងឡើយ។

*វាយឡើងវិញ*

ទាក់ទងដល់ការប្រើសិទ្ធិ និងការបំពេញកាតព្វកិច្ចផ្សេងៗ ក្នុងការអនុវត្តនីតិវិធីនៃការវិនិច្ឆ័យ នីតិបុគ្គលនានា ក៏ដូចជាសមូហភាពទាំងអស់នោះ ត្រូវជ្រើសរើសតំណាងស្របច្បាប់រៀងខ្លួន តាមវិធីផ្សេងៗគ្នា ដូចជានីតិបុគ្គលសាធារណៈ មានលិខិតតែងតាំង នីតិបុគ្គលឯកជនមានការជ្រើសតាំងបណ្ណាធិការក្រុមហ៊ុន ឬប្រធានសមាគម វត្តមានប្រធានគណៈកម្មការវត្ត សហគមន៍ជនជាតិដើមភាគតិច មានប្រធានសហគមន៍ . . .។ល។ តំណាងស្របច្បាប់ទាំងនេះមានសិទ្ធិ និងកាតព្វកិច្ចទាក់ទងនឹងអចលនវត្ថុ ដូចម្ចាស់សិទ្ធិ ជារូបវន្តបុគ្គលដែរ។

ឯប័ណ្ណដី ឬអចលនវត្ថុរបស់នីតិបុគ្គលសាធារណៈ និងឯកជន ត្រូវប្រគល់ឱ្យតំណាងស្របច្បាប់នៃនីតិបុគ្គលនីមួយៗ ជាអ្នកទទួលយក និងរក្សាទុក។ ចំពោះប័ណ្ណដី ឬអចលនវត្ថុរបស់សមូហភាព ត្រូវប្រគល់ជូនតំណាងស្របច្បាប់ ឬប្រធានសហគមន៍ទទួលយក និងរក្សាទុក។

សារាចរនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០២

**រដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**អ៊ឹម ឈុនលឹម**

កន្លែងទទួល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីសហការអនុវត្ត"

-គ្រប់ក្រសួង ស្ថាប័ន

-គ្រប់ខេត្ត-ក្រុង

"គ្រប់អគ្គនាយកដ្ឋានក្រោមឱវាទក្រសួង"

-គ្រប់មន្ទីរដនសស ខេត្ត-ក្រុង

"ដើម្បីអនុវត្ត"

-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ១១២ដនស/ប្រក

## ប្រកាសស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី

### រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ/បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៤៦អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ៤៧អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី

- បានឃើញអនុក្រឹត្យលេខ៤៨អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ
- បានឃើញប្រកាសលេខ៧៦ប្រក/ដនស ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង និងតួនាទី ភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ
- តាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**សម្រេច**

**១.និយមន័យ**

**ប្រការ១**

ប្រកាសនេះកំណត់នីតិវិធីនៃការដាក់ពាក្យប្តឹង ការសម្រុះសម្រួល និងការសម្រេចលើបញ្ហាវិវាទដីធ្លីដែលបានប្តឹងទៅគណៈកម្មការសុរិយោដីគ្រប់ថ្នាក់។

**ប្រការ២**

គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ (គសសខ) គឺជាគណៈកម្មការដែលបានបង្កើតឡើងដោយអនុលោមតាមមាត្រា៤ និងមាត្រា៩នៃអនុក្រឹត្យលេខ៤៧អនក្រ/បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង (គសខក) គឺជាគណៈកម្មការដែលបានបង្កើតឡើងដោយអនុលោមតាមមាត្រា៣ និងមាត្រា១២នៃអនុក្រឹត្យលេខ៤៧អនក្រ/បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ (គសជ) គឺជាគណៈកម្មការដែលបានបង្កើតឡើងដោយអនុលោមតាមមាត្រា៣ និងមាត្រា១៧នៃអនុក្រឹត្យលេខ៤៧អនក្រ/បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី។

"គណៈកម្មការរដ្ឋបាល" គឺជាគណៈកម្មការដែលបានបង្កើតឡើង ដើម្បីដឹកនាំការចុះបញ្ជីដីធ្លីជាប្រព័ន្ធនៅក្នុងតំបន់វិនិច្ឆ័យ។ ភារកិច្ចមួយនៃគណៈកម្មការនេះ គឺធ្វើការដោះស្រាយវិវាទដីធ្លីដែលកើតមាននៅក្នុងអំឡុងពេលនៃការចុះបញ្ជី មានលក្ខណៈជាប្រព័ន្ធស្របតាមមាត្រា៣នៃអនុក្រឹត្យលេខ៤៦អនក្រ/បក ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី។

"ដីដែលមិនទាន់បានចុះបញ្ជីសុរិយោដី" គឺជាក្បាលដីទាំងឡាយណាដែលមិនទាន់បានចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ ឬមានលក្ខណៈដាច់ដោយដុំ ស្របតាមច្បាប់ភូមិបាលឆ្នាំ២០០១។

"បុគ្គល" រួមមានរូបវន្តបុគ្គល ឬនីតិបុគ្គល។

"ដើមបណ្តឹង" គឺជាជនដែលធ្វើការប្តឹងទាមទារឱ្យមានការដោះស្រាយវិវាទដោយអនុលោមតាមប្រកាសនេះ។

"ចុងបណ្តឹង" គឺបុគ្គលដែលជំទាស់ទៅនឹងដើមបណ្តឹង។

## ២.ការចាប់ផ្តើមដំណើរការដោះស្រាយវិវាទ

### *ប្រការ៣*

បុគ្គលទាំងឡាយណាដែលទាមទារកម្មសិទ្ធិ (ឬសិទ្ធិកម្មសិទ្ធិ) ឬភោគៈ (ឬសិទ្ធិភោគៈ) លើដីមិនទាន់បានចុះបញ្ជីសុរិយោដី ហើយដីនោះមានបុគ្គលម្នាក់ ឬច្រើននាក់ផ្សេងទៀតបានទាមទារមួយផ្នែក ឬទាំងមូលដែរ អាចដាក់ពាក្យបណ្តឹងទៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌដែលដីនោះឋិតនៅ។

### *ប្រការ៤*

បុគ្គលដែលប្តឹងទាមទារធ្វើជាកម្មសិទ្ធិករ ឬភោគីនៃដីត្រូវដាក់ពាក្យបណ្តឹង លើកលែងតែក្នុងករណីដែលជននោះជាអសមត្ថជន។ ក្នុងករណីនេះ អ្នកតំណាងស្របច្បាប់របស់ជននោះអាចដាក់ពាក្យបណ្តឹងក្នុងនាមជននោះបាន។

### *ប្រការ៥*

បណ្តឹងទាមទារត្រូវធ្វើតាមទម្រង់បែបបទនៃពាក្យបណ្តឹង ដូចមាននៅក្នុងឧបសម្ព័ន្ធទី១នៃប្រកាសនេះ។ ដើមបណ្តឹងអាចទទួលយកទម្រង់បែបបទនៃពាក្យបណ្តឹងនេះពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ឬអាចធ្វើទម្រង់បែបបទនៃពាក្យបណ្តឹងរបស់ខ្លួនបាន ឱ្យតែទម្រង់បែបបទនោះមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងទម្រង់បែបបទនៃពាក្យបណ្តឹង ដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធទី១។

ពាក្យបណ្តឹងត្រូវបញ្ចូលព័ត៌មានស្តីពីដើមបណ្តឹងដូចតទៅ៖ ឈ្មោះ សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត ភេទ ឈ្មោះសហព័ទ្ធ (ប្តី-ប្រពន្ធ) កូន ឃុំ ស្រុក ខេត្ត មុខរបរ អាសយដ្ឋានបច្ចុប្បន្ន

ទីតាំងដីវិវាទ សេចក្តីពណ៌នាពីវិវាទដោយមានភាពជាក់លាក់ តាមដែលអាចធ្វើទៅបាន ឯកសារពាក់ព័ន្ធនានា ឈ្មោះ និងអាសយដ្ឋានរបស់ចុងបណ្តឹង។ ដើមបណ្តឹងត្រូវផ្តល់រាល់ព័ត៌មាន ដូចបានតម្រូវនៅក្នុងទម្រង់បែបបទបណ្តឹង ហើយត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា ឬផ្តិតមេដៃលើពាក្យបណ្តឹងនោះ។

ដើមបណ្តឹងត្រូវផ្តល់បែបបទបណ្តឹងដែលបំពេញរួច យ៉ាងហោចចំនួន០៤ច្បាប់ដែលមួយច្បាប់សម្រាប់រក្សាទុកក្នុងសំណុំឯកសាររបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ មួយច្បាប់សម្រាប់បិទផ្សាយ មួយច្បាប់សម្រាប់បញ្ជូនទៅឱ្យដើមបណ្តឹងវិញ និងមួយច្បាប់ទៀតសម្រាប់ចុងបណ្តឹង។ ក្នុងករណីមានចុងបណ្តឹងច្រើននាក់ មានឈ្មោះនៅក្នុងពាក្យបណ្តឹង នោះដើមបណ្តឹងត្រូវផ្តល់ឯកសារពាក្យបណ្តឹងមួយច្បាប់ៗ ដល់ចុងបណ្តឹងម្នាក់ៗដែលមានឈ្មោះ។

**ប្រការ៦**

នៅពេលទទួលពាក្យបណ្តឹង គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌត្រូវបើកសំណុំរឿង ហើយត្រូវកំណត់លេខ ដើម្បីជាការសម្គាល់សំណុំរឿងវិវាទតាមខេត្ត និងស្រុក ដែលដីវិវាទនោះឋិតនៅ។

មន្ត្រីទទួលពាក្យបណ្តឹងត្រូវចុះលេខសម្គាល់សំណុំរឿងវិវាទ ចុះហត្ថលេខា និងបោះត្រាផ្លូវការលើទម្រង់បែបបទ នៃពាក្យបណ្តឹងច្បាប់ដើម ហើយផ្តល់ឯកសារដែលបានចុះបញ្ជីមួយច្បាប់ទៅដើមបណ្តឹងវិញ។ ឯកសារនេះ គឺជាភស្តុតាងនៃការដាក់ពាក្យបណ្តឹងរបស់ដើមបណ្តឹង។

មន្ត្រីទទួលពាក្យបណ្តឹងត្រូវថតចម្លងឯកសារនានា ដែលបានភ្ជាប់មកជាមួយពាក្យបណ្តឹង ហើយត្រូវបញ្ចូលឯកសារថតចម្លងទាំងនេះទៅក្នុងសំណុំរឿងផ្លូវការ។ មន្ត្រីទទួលពាក្យបណ្តឹងត្រូវបង្វិលឯកសារច្បាប់ដើមទៅឱ្យដើមបណ្តឹងវិញ។

**ប្រការ៧**

ក្នុងរយៈពេលប្រាំថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យបណ្តឹង គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ត្រូវបិទផ្សាយពាក្យបណ្តឹងនោះរួមជាមួយនឹងសេចក្តីជូនដំណឹងអំពីបណ្តឹង រៀបចំឡើងដោយគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ដែលបញ្ជាក់ថា ពាក្យបណ្តឹងនោះបានចុះបញ្ជីហើយ។ សេចក្តីជូនដំណឹងពីបណ្តឹងត្រូវធ្វើឡើងតាមទម្រង់បែបបទ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ

ទី២។ សេចក្តីជូនដំណឹងនោះត្រូវអញ្ជើញបុគ្គលគ្រប់រូបដែលមានផលប្រយោជន៍នៅក្នុងជីវិវាទ ឱ្យឆ្លើយតបចំពោះពាក្យបណ្តឹងក្នុងរយៈពេល៣០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការបិទផ្សាយ សេចក្តីជូនដំណឹង និងពាក្យបណ្តឹងនោះ។

ពាក្យបណ្តឹង និងសេចក្តីជូនដំណឹងអំពីពាក្យបណ្តឹងមួយច្បាប់ត្រូវបិទផ្សាយនៅការិយាល័យ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ ហើយសាធារណជនអាចចូល មើលបានដោយសេរីក្នុងអំឡុងពេលម៉ោងធ្វើការធម្មតា។ ត្រូវអនុញ្ញាតឱ្យជនគ្រប់រូបមើលសេចក្តី ជូនដំណឹងដែលបានបិទផ្សាយនោះ ដើម្បីឱ្យដឹងថាតើខ្លួនមានផលប្រយោជន៍នៅក្នុងវិវាទនោះឬទេ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ត្រូវបិទសេចក្តីជូនដំណឹងមួយច្បាប់នៅលើទីតាំង ដីដែលមានវិវាទ។

ក្នុងរយៈពេលប្រាំថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យបណ្តឹង គណៈកម្មការសុរិ យោដីថ្នាក់ស្រុក-ខណ្ឌ ត្រូវជូនដំណឹងដល់ចុងបណ្តឹងដែលមានឈ្មោះនៅក្នុងពាក្យបណ្តឹងអំពីការ ប្តឹងទាមទារនោះ តាមរយៈការផ្តល់ដល់ចុងបណ្តឹងនូវពាក្យបណ្តឹងដែលបំពេញរួច ម្នាក់មួយច្បាប់។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ត្រូវជូនដំណឹងដល់ចុងបណ្តឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការឆ្លើយ តបចំពោះបណ្តឹងទាមទារនោះ ហើយត្រូវជូនដំណឹងដល់ចុងបណ្តឹងអំពីសិទ្ធិចូលរួមប្រជុំជាមួយគណៈ កម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ដើម្បីពិគ្រោះយោបល់អំពីបណ្តឹង។ គណៈកម្មការសុរិយោដីថ្នាក់ ស្រុក-ខណ្ឌ ត្រូវផ្តល់ឱ្យចុងបណ្តឹងនូវសេចក្តីសង្ខេបអំពីរបៀបសម្រុះសម្រួល។

**ប្រការ៨**

ចុងបណ្តឹងដែលមានឈ្មោះក្នុងពាក្យបណ្តឹងអាចឆ្លើយតបចំពោះបណ្តឹង តាមរយៈការ ដាក់សំណុំបែបបទឆ្លើយតបចំពោះបណ្តឹង ដែលមានកំណត់ក្នុងឧបសម្ព័ន្ធទី៤ ទៅគណៈកម្មការ សុរិយោដីថ្នាក់ស្រុក-ខណ្ឌ ក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីបានទទួលឯកសារចម្លងនៃពាក្យបណ្តឹង ពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ត្រូវផ្តល់ដល់ ចុងបណ្តឹងនូវឯកសារថតចម្លងមួយច្បាប់នៃពាក្យបណ្តឹង និងសេចក្តីសង្ខេបអំពីរបៀបសម្រុះសម្រួល។

រាល់បុគ្គលផ្សេងទៀតដែលមានផលប្រយោជន៍នៅក្នុងជីវិវាទនេះ ត្រូវដាក់បែបបទឆ្លើយ តបចំពោះបណ្តឹងក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីពេលដែលសេចក្តីជូនដំណឹងអំពីបណ្តឹង ត្រូវបានបិទ

ផ្សាយនៅការិយាល័យគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ និងនៅលើទីតាំងដីវិវាទដោយគិតតាមកាលបរិច្ឆេទនៃសេចក្តីជូនដំណឹងមួយណាដែលបិទក្រោយគេ។

ចុងបណ្តឹងអាចទទួលបានទម្រង់បែបបទឆ្លើយតប ចំពោះបណ្តឹងពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ឬអាចដាក់ទម្រង់បែបបទរបស់ខ្លួនផ្ទាល់បាន ឱ្យតែទម្រង់បែបបទនោះមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងទម្រង់បែបបទ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី៤។

ចុងបណ្តឹងនោះត្រូវផ្តល់ទម្រង់បែបបទឆ្លើយតបចំពោះបណ្តឹងដែលបំពេញរួច យ៉ាងហោចចំនួន០៤ច្បាប់ ដែលមួយច្បាប់សម្រាប់រក្សាទុកក្នុងសំណុំរឿងរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ មួយច្បាប់សម្រាប់បិទផ្សាយ មួយច្បាប់សម្រាប់បញ្ជូនទៅឱ្យដើមបណ្តឹងវិញ និងមួយច្បាប់ទៀតសម្រាប់ចុងបណ្តឹង។ ក្នុងករណីមានចុងបណ្តឹង ឬដើមបណ្តឹងច្រើននាក់ មានឈ្មោះនៅក្នុងពាក្យបណ្តឹង នោះចុងបណ្តឹងត្រូវផ្តល់ឯកសារចម្លងឆ្លើយតបចំពោះបណ្តឹងដល់ចុងបណ្តឹងនិង/ឬដើមបណ្តឹងដែលមានឈ្មោះម្នាក់ៗមួយច្បាប់។

ចុងបណ្តឹងត្រូវបង្ហាញឯកសារពាក់ព័ន្ធនៅពេលដាក់ពាក្យឆ្លើយតបចំពោះបណ្តឹង។ មន្ត្រីទទួលពាក្យត្រូវថតចម្លងឯកសារដែលបានដាក់ភ្ជាប់មកជាមួយនោះ រួចហើយត្រូវបង្វិលឯកសារច្បាប់ដើមទាំងនោះទៅឱ្យចុងបណ្តឹងវិញ។

ពាក្យឆ្លើយតប និងឯកសារដែលបានភ្ជាប់មកជាមួយនោះត្រូវបញ្ចូលទៅក្នុងសំណុំរឿងវិវាទផ្លូវការ។

**ប្រការ៩**

គ្មានករណីណាមួយដែលដើមបណ្តឹង ឬចុងបណ្តឹងណាម្នាក់ត្រូវបានគេសុំ ឬតម្រូវឱ្យបង់ថ្លៃដាក់ពាក្យបណ្តឹង ឬពាក្យឆ្លើយតបឡើយ។

## ៣.ការស៊ើបអង្កេត

**ប្រការ១០**

រដ្ឋបាលសុរិយោដីស្រុក-ខណ្ឌ ត្រូវចាត់មន្ត្រីសុរិយោដីចុះទៅធ្វើការស៊ើបអង្កេតបណ្តឹង។ អ្នកស៊ើបអង្កេតត្រូវចុះទៅជួបភាគីទាំងអស់កត់ត្រាសេចក្តីអះអាងរបស់ភាគី និងប្រមូលរាល់ព័ត៌មានទាក់ទងផ្សេងៗ និងភស្តុតាងផ្សេងៗទាក់ទងនឹងវិវាទនោះ រួមទាំងព័ត៌មានដែលចាំបាច់

ដើម្បីកំណត់ថា តើភាគីពាក់ព័ន្ធទាំងអស់ក្នុងវិវាទដីធ្លីនេះមានឈ្មោះនៅក្នុងសំណុំរឿងវិវាទដែលបាន ដាក់ជូនគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ហើយឬនៅ ថាជាភាគីនៃវិវាទឬអត់។ ការស៊ើប អង្កេតត្រូវចាប់ផ្តើមឱ្យបានឆាប់បំផុត តាមដែលអាចធ្វើទៅបានបន្ទាប់ពីគណៈកម្មការសុរិយោដី ថ្នាក់ស្រុក-ខណ្ឌបានទទួលពាក្យបណ្តឹង។

**ប្រការ១១**

រដ្ឋបាលសុរិយោដីស្រុក-ខណ្ឌត្រូវវាស់វែង និងកំណត់ព្រំដីដែលមានវិវាទស្របតាមនីតិ វិធីដូចមានចែងនៅក្នុងអនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ។ ប្រសិនបើរដ្ឋបាល សុរិយោដីស្រុក-ខណ្ឌ មិនអាចបំពេញការទទួលខុសត្រូវនេះបានដោយសារតែខ្លួនពុំមានសមត្ថភាព បច្ចេកទេសគ្រប់គ្រាន់ រដ្ឋបាលសុរិយោដីស្រុក-ខណ្ឌនោះអាចស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាល សុរិយោដីខេត្ត-ក្រុង។

**ប្រការ១២**

អ្នកស៊ើបអង្កេតមានសិទ្ធិជួបបុគ្គលណាម្នាក់ ឬមានសិទ្ធិមើលឯកសារដែលកំណត់ថា ចាំបាច់សម្រាប់ការស៊ើបអង្កេតឱ្យបានពេញលេញ។

បុគ្គលទាំងឡាយ រួមទាំងសាក្សីរបស់ភាគី និងសាក្សីឯទៀតត្រូវជួបជាមួយអ្នកស៊ើប អង្កេត ប្រសិនបើខ្លួនត្រូវបានស្នើសុំដោយអ្នកស៊ើបអង្កេត ហើយអ្នកស៊ើបអង្កេតត្រូវកំណត់ការ ប្រជុំតាមពេលវេលា និងទីកន្លែងដែលងាយស្រួល ចំពោះអ្នកពាក់ព័ន្ធទាំងឡាយ។

ឯកសារច្បាប់ដើមទាំងឡាយត្រូវបង្វិលទៅឱ្យអ្នកដែលផ្តល់ឯកសារនោះវិញ ហើយច្បាប់ ថតចម្លងនៃឯកសារនោះ ត្រូវរក្សាទុកនៅក្នុងកំណត់ហេតុផ្លូវការនៃវិវាទ។

**ប្រការ១៣**

ភាគីវិវាទនីមួយៗត្រូវមានវត្តមានក្នុងពេលធ្វើការស៊ើបអង្កេតដល់ទីកន្លែង និងត្រូវប៉ាន់ ស្មានសោហ៊ុយដែលទាក់ទងទៅនឹងការស៊ើបអង្កេតម្តងទៀត ក្នុងករណីដែលភាគីណាមួយអវត្តមាន។ បើអវត្តមានរបស់ភាគីមួយ បង្កឡើងដោយសារទង្វើមិនសមរម្យរបស់ភាគីឯទៀត នោះភាគីដែល មានកំហុសត្រូវចេញសោហ៊ុយសម្រាប់ថ្លៃការស៊ើបអង្កេតជាថ្មីនោះ។

**ប្រការ១៤**

ភាគីវិវាទអាចផ្តល់ភស្តុតាង និងសាក្សីបាន ហើយរាល់ភស្តុតាង និងចម្លើយរបស់សាក្សីទាំងនោះ ត្រូវក្លាយជាផ្នែកមួយនៃកំណត់ហេតុផ្លូវការនៃវិវាទ។

អ្នកស៊ើបអង្កេតត្រូវទទួលយក និងបញ្ចូលជាផ្នែកមួយនៃកំណត់ហេតុផ្លូវការនៃវិវាទ នូវរាល់ភស្តុតាងដែលត្រូវបានផ្តល់ដោយភាគី ឬដែលត្រូវបានប្រមូលក្នុងអំឡុងពេលធ្វើការស៊ើបអង្កេត។ ភស្តុតាងទាំងនោះមានជាអាទិ៍៖

-ផែនទី ឬកំណត់ហេតុអង្កេតវាស់វែង

-ឯកសារសម្គាល់ការកាន់កាប់ដី

-រូបថតរបស់ភាគីកាន់កាប់ដី

-សំបុត្រស្នាមផ្សេងៗដែលបានធ្វើដោយមានចុះអាសយដ្ឋាននៃដីនោះ សំបុត្រកំណើត ឬប័ណ្ណគ្រួសារដែលបង្ហាញពីវត្តមានយូរអង្វែងនៅលើដីនោះ ឬសៀវភៅសម្រង់ស្ថិតិរបស់ប្រធានភូមិ

-ចម្លើយរបស់អ្នកជិតខាងថា តើនរណាដែលបានរស់នៅលើដីនោះ

-បង្កាន់ដៃទទួលប្រាក់ ឬឯកសារផ្សេងៗទាក់ទងទៅនឹងការទិញដី ឬការផ្ទេរសិទ្ធិនៃដីនោះ។

**ប្រការ១៥**

អ្នកស៊ើបអង្កេតត្រូវសម្ភាសសាក្សីទាំងឡាយដែលផ្តល់ដោយភាគីវិវាទ ឬដែលអ្នកស៊ើបអង្កេតចាត់ទុកថាចាំបាច់ ដើម្បីបញ្ជាក់អង្គហេតុនៃវិវាទ។ សាក្សីនីមួយៗត្រូវធ្វើសម្បថថា នឹងនិយាយតែការពិត ហើយរាយការណ៍រាល់ព្រឹត្តិការណ៍ និងអង្គហេតុទាំងឡាយដែលសាក្សីយល់ និងជឿថាត្រឹមត្រូវ។

អ្នកស៊ើបអង្កេត ត្រូវពិនិត្យសាក្សីនីមួយៗដើម្បីកំណត់អំពីភាពគួរឱ្យជឿបាននៅក្នុងចម្លើយរបស់សាក្សី តើសាក្សីដឹងកម្រិតណា ការដឹងរបស់សាក្សីផ្អែកលើព្រឹត្តិការណ៍ទាំងឡាយ ដែលបានសង្កេតឃើញដោយខ្លួនឯងផ្ទាល់ ឬដោយគ្រាន់តែបានឮពីអ្នកណាម្នាក់ផ្សេងទៀត។ ចម្លើយសាក្សី និងការសម្ភាសសាក្សី ត្រូវទុកជាផ្នែកមួយនៃកំណត់ហេតុផ្លូវការនៃវិវាទ។

**ប្រការ១៦**

អ្នកស៊ើបអង្កេតត្រូវរៀបចំរបាយការណ៍ជាលាយលក្ខណ៍អក្សរ អំពីលទ្ធផលនៃការស៊ើបអង្កេត ដោយអនុលោមតាមទម្រង់នៃស្តង់ដារដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី៥។ លទ្ធផលទាំងនេះ

ត្រូវរួមបញ្ចូលនូវព្រំដីវិវាទ ផែនទី ឬគំនូសតាងពាក់ព័ន្ធ សេចក្តីសង្ខេបអំពីចម្លើយរបស់សាក្សី និងចម្លើយលាយលក្ខណ៍អក្សរ សេចក្តីសង្ខេបនៃរាល់ឯកសារពាក់ព័ន្ធទៅនឹងដីវិវាទដែលមានការអះអាងដោយអ្នកស៊ើបអង្កេត ឬដែលបានទទួលពីភាគីវិវាទ។

## ៤-ការកំណត់អំពីសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ក្នុងការសម្រុះសម្រួលវិវាទ

### ប្រការ១៧

បន្ទាប់ពីការស៊ើបអង្កេតត្រូវបានបញ្ចប់ គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ត្រូវកំណត់ថាតើ គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌមានសមត្ថកិច្ចធ្វើការសម្រុះសម្រួលវិវាទនោះដែរឬទេ។

វិវាទទាំងឡាយត្រូវសម្រុះសម្រួលដោយគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ លើកលែងតែប្រធាន គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ កំណត់ថាវិវាទនោះមិនឋិតនៅក្នុងសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ដោយសំអាងលើហេតុផលនានា ដូចមានចែងនៅក្នុងប្រការ១៨នៃប្រកាសនេះ ឬដោយវិវាទនោះ កើតឡើងដោយសារភាគីមួយ ឬច្រើន ប្តឹងផ្អែកលើមូលដ្ឋានមិនច្បាស់លាស់ដូចមានចែងក្នុងប្រការ១៩នៃប្រកាសនេះ។

### ប្រការ១៨

ប្រសិនបើវិវាទមិនអាចដោះស្រាយបានដោយសមធម៌នៅថ្នាក់ស្រុក-ខណ្ឌ គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ត្រូវដាក់ដាក់សំណុំរឿងវិវាទនោះដោយផ្ទាល់ជូនទៅគណៈកម្មសុរិយោដីថ្នាក់ខេត្ត-ក្រុង តាមការយល់ឃើញផ្ទាល់របស់ប្រធាន ឬតាមសំណើរបស់ភាគីវិវាទទាំងសងខាង ដូចមានចែងនៅក្នុងមាត្រា១០នៃអនុក្រឹត្យលេខ៤៧អនក្រ/បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី។

ប្រសិនបើមានភាគីតែម្ខាង ស្នើឱ្យបញ្ជូនករណីវិវាទនោះទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង វិវាទនោះត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង លើកលែងតែប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ យល់ឃើញថាសំណើនោះមិនសមហេតុផល។ ហេតុផលនៃការបដិសេធសំណើនោះរួមមាន ការកំណត់របស់ប្រធានគណៈកម្មការដែលយល់ថា សំណើនោះ

ធ្វើឡើងគ្រាន់តែដើម្បីឱ្យមានការយឺតយ៉ាវដល់ការដោះស្រាយវិវាទ ឬបង្កឱ្យមានការលំបាកដល់ភាគីម្ខាងទៀត និងអាចមានហេតុផលផ្សេងទៀត។

ប្រសិនបើប្រធានគណៈកម្មការ បដិសេធមិនបញ្ជូនវិវាទនោះដោយផ្ទាល់ទៅគណៈកម្មការសុរិយោដីខេត្ត-ក្រុង តាមសំណើរបស់ភាគីម្ខាង ប្រធានគណៈកម្មការត្រូវពន្យល់ជាលាយលក្ខណ៍អក្សរអំពីមូលហេតុនៃការបដិសេធសំណើនោះ ហើយការពន្យល់នេះត្រូវតែជាផ្នែកមួយនៃកំណត់ហេតុផ្លូវការនៃវិវាទនោះ។ ការសម្រុះសម្រួលដែលតម្រូវឱ្យមានការបញ្ជូនករណីវិវាទទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុងរួមមាន៖

-ជនម្នាក់ទាមទារដីច្រើនក្បាល ដែលជាកម្មវត្ថុនៃការប្ដឹងទាមទាររបស់ភាគីតូចតាចមួយចំនួនដែរ

-ភាគីម្ខាងនៃវិវាទគឺជាអាជ្ញាធរមានឋានៈខ្ពស់

-ករណីមានវិវាទពាក់ព័ន្ធទៅនឹងផលប្រយោជន៍របស់ប្រធានគណៈកម្មការថ្នាក់ស្រុក-ខណ្ឌ

-វិវាទពាក់ព័ន្ធនឹងដីសាធារណៈរបស់រដ្ឋ

ក្នុងករណីណាក៏ដោយ គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌមិនមានសិទ្ធិអំណាចសម្រុះសម្រួលវិវាទដែលទាក់ទងទៅនឹងដីសាធារណៈរបស់រដ្ឋឡើយ។

**ប្រការ១៩**

គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ត្រូវច្រានចោលបណ្ដឹងទាមទារណាដែលមិនត្រឹមត្រូវ ឬគ្មានមូលដ្ឋាន ឬដែលធ្វើឡើងដើម្បីយាយី ឬបំភិតបំភ័យភាគីម្ខាង។ ការច្រានចោលបណ្ដឹងមិនមែនជាប្រការគួរលើកទឹកចិត្តឱ្យធ្វើនោះទេ លើកលែងតែក្នុងករណីចាំបាច់ដើម្បីរារាំងភាពអយុត្តិធម៌តែប៉ុណ្ណោះ។

បណ្ដឹងមិនត្រឹមត្រូវគឺបណ្ដឹងដែលខ្វះមូលដ្ឋានអង្គហេតុសមហេតុផល ឬទាក់ទងទៅនឹងវិវាទដែលឋិតនៅក្រៅវង្វង់សមត្ថកិច្ចនៃច្បាប់ភូមិបាលឆ្នាំ២០០១។ ល័ក្ខខ័ណ្ឌនៃបណ្ដឹងដែលមិនមានមូលដ្ឋានអង្គហេតុគ្រប់គ្រាន់ មានជាអាទិ៍៖

-សាក្សី ឬភស្តុតាងរបស់ភាគីម្ខាងបង្ហាញថាមានលក្ខណៈក្លែងបន្លំ ឬខុស ដូចជាសាក្សីរបស់ភាគីម្ខាងដកពាក្យចម្លើយរបស់ខ្លួនវិញ ឬផ្ដល់ចម្លើយដែលប្រឆាំងដោយត្រង់ទៅនឹងការទាមទាររបស់ភាគីម្ខាង

-ការស៊ើបអង្កេត និងព័ត៌មានផ្សេងទៀតដែលភាគីស្នើឡើង មិនបង្ហាញភស្តុតាងណាមួយដែលគាំទ្រដល់ការទាមទាររបស់ភាគីដូចមានក្នុងពាក្យបណ្តឹង។

ក្នុងករណីបណ្តឹងត្រូវបានច្រានចោល ភាគីអាចប្តឹងតវ៉ាទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង។

ភាគីណាមួយដែលធ្វើការទាមទារដោយគ្មានមូលដ្ឋាន ឬមិនមានលក្ខណៈច្បាប់ត្រូវចេញសោហ៊ុយថ្លៃដំណើរការវិវាទដែលបានចំណាយមកដល់ពេលនោះ និងត្រូវទទួលទោសព្រហ្មទណ្ឌបន្ថែមទៀតដោយអនុលោមតាមច្បាប់ភូមិបាល២០០១ និងច្បាប់ផ្សេងៗទៀត។ ត្រូវរារាំងមិនឱ្យភាគីដែលដាក់ពាក្យបណ្តឹងមិនត្រឹមត្រូវប្តឹងទាមទារជាថ្មីម្តងទៀត។

ភាគីណាដែលបង្ហាញភស្តុតាងក្លែងបន្លំ ត្រូវដកចេញពីដំណើរការវិវាទ ហើយភស្តុតាងត្រូវដកចេញពីកំណត់ហេតុផ្លូវការនៃវិវាទ និងត្រូវទទួលទោសព្រហ្មទណ្ឌបន្ថែមទៀត ដូចមានចែងនៅក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ និងច្បាប់ផ្សេងៗទៀត។ ភាគីណាដែលត្រូវបានរកឃើញថា បានធ្វើការក្លែងបន្លំភស្តុតាង ឬឯកសារ អាចទទួលទោសព្រហ្មទណ្ឌ ដូចមានចែងនៅក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ និងច្បាប់ផ្សេងៗទៀត។

### ៥-ការសម្រុះសម្រួលរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ

### ប្រការ២០

បន្ទាប់ពីបញ្ចប់ការស៊ើបអង្កេតមិនតិចជាង៣០ថ្ងៃ បន្ទាប់ពីសេចក្តីជូនដំណឹងពីបណ្តឹងត្រូវបានបិទផ្សាយ ដូចមានចែងក្នុងប្រការ៧នៃប្រកាសនេះ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌត្រូវរៀបចំប្រជុំគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ដើម្បីសម្រេចលើដំណើរការសម្រុះសម្រួលវិវាទ។ កិច្ចប្រជុំត្រូវធ្វើឡើងនៅលើដីវិវាទ ឬកន្លែងដែលនៅជិតដីវិវាទតាមដែលអាចធ្វើទៅបាន។

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ត្រូវអញ្ជើញតំណាងអាជ្ញាធរដែនដីស្រុកខណ្ឌ ឃុំ-សង្កាត់ និងភូមិ និង/ឬចាស់ព្រឹទ្ធាចារ្យនៅក្នុងមូលដ្ឋាន ឱ្យចូលរួមជាសមាជិកអាដហុករបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ដើម្បីសម្រុះសម្រួលវិវាទ។ ប្រធានគណៈកម្មការសុរិយោដីស្រុក-ខណ្ឌ គប្បីយកចិត្តទុកដាក់បញ្ចូលស្ត្រីជាសមាជិកគណៈកម្មការសុរិយោដីថ្នាក់ស្រុកខណ្ឌ។

*វាយឡើងវិញ*

គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌត្រូវអញ្ជើញភាគីវិវាទមកចូលរួមការប្រជុំរដ្ឋបាល យ៉ាងហោច៥ថ្ងៃនៃថ្ងៃធ្វើការមុនថ្ងៃប្រជុំនេះ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌត្រូវផ្ដល់ដល់ភាគីទាំងអស់នូវសេចក្ដីសង្ខេបអំពីរបៀបសម្រុះសម្រួល និងត្រូវពន្យល់អំពីព័តិមាននេះដល់ភាគីទាំងអស់។

នៅពេលប្រជុំរដ្ឋបាលនេះ ភាគីត្រូវជូនដំណឹងដល់គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ អំពីការស្នើសុំរបស់ខ្លួនឱ្យបញ្ជូនសំណុំរឿងវិវាទនេះទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង ត្រូវធ្វើការជំទាស់ចំពោះវិវាទអំពីផលប្រយោជន៍នានា និងធ្វើការព្រមព្រៀងជាឯកច្ឆ័ន្ទលើសមាសភាពអ្នកសម្រុះសម្រួលដូចមានចែងក្នុងប្រការ២២នៃប្រកាសនេះ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ត្រូវដោះស្រាយរាល់វិវាទអំពីផលប្រយោជន៍ និងកំណត់អ្នកសម្រុះសម្រួលវិវាទ។ បន្ទាប់មក អ្នកសម្រុះសម្រួលត្រូវជួបជាមួយភាគីទាំងឡាយ និងកំណត់ពេលវេលាសម្រាប់ការសម្រុះសម្រួលវិវាទ។

**ប្រការ២១**

ប្រសិនបើមានសមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ មានផលប្រយោជន៍នៅក្នុងវិវាទ សមាជិករូបនោះត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទនោះ ហើយគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុងត្រូវតែងតាំងសមាជិកថ្មីជំនួសវិញ។

ប្រសិនបើមានវិវាទផលប្រយោជន៍ជាមួយប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ វិវាទនោះត្រូវដាក់ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង។

ភាគីអាចប្ដឹងជំទាស់ជាលាយលក្ខណ៍អក្សរចំពោះការចូលរួមរបស់សមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ដោយផ្អែកលើមូលដ្ឋាននៃវិវាទអំពីផលប្រយោជន៍របស់សមាជិក។ សមាជិកដទៃទៀតនៃគណៈកម្មការត្រូវសម្រេចថា តើសមាជិករូបនោះមានវិវាទអំពីផលប្រយោជន៍ដែលរារាំងមិនឱ្យសមាជិករូបនោះ ចូលរួមនៅក្នុងការដោះស្រាយវិវាទឬទេ។ វិវាទអំពីផលប្រយោជន៍ដែលចោទប្រកាន់ចំពោះប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ត្រូវដោះស្រាយតាមនីតិវិធីដូចមានកំណត់ក្នុងប្រការ១៨នៃប្រកាសនេះ។

**ប្រការ២២**

ភាគីវិវាទអាចជ្រើសរើសអ្នកសម្រុះសម្រួលក្នុងចំណោមសមាជិកអាជហុក និងសមាជិកអចិន្ត្រៃយ៍នៃគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ នៅក្នុងល័ក្ខខ័ណ្ឌតែមួយគត់គឺភាគីទាំងអស់ព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរក្នុងការប្រើអ្នកសម្រុះសម្រួលជាក់លាក់នោះ។

ក្នុងករណីភាគីវិវាទមិនអាចព្រមព្រៀងគ្នា លើសមាសភាពអ្នកសម្រុះសម្រួលជាក់លាក់ណាមួយមកពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌទេនោះ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ត្រូវចាត់តាំងអ្នកសម្រុះសម្រួលចេញពីសមាជិកអាជហុក និងសមាជិកអចិន្ត្រៃយ៍នៃគណៈកម្មការ។

ក្រុមអ្នកសម្រុះសម្រួលមានសមាជិក៣រូប ដែលមានម្នាក់ជាប្រធានត្រូវសម្រុះសម្រួលវិវាទ។

សមាជិកទាំងឡាយនៃក្រុមអ្នកសម្រុះសម្រួល យ៉ាងហោចណាស់ត្រូវមានសមាជិកម្នាក់ដែលបានទទួលការបណ្តុះណ្តាល ឬមានបទពិសោធន៍នៅក្នុងការសម្រុះសម្រួលវិវាទ និងមានសមាជិកម្នាក់ជាអ្នកដឹងអំពីស្ថានភាព និងសភាពការណ៍នៅក្នុងមូលដ្ឋាន។ ប្រសិនបើ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌកំណត់ថា គ្មានសមាជិកណាម្នាក់នៃសមាជិកក្រុមអ្នកសម្រុះសម្រួលមានបទពិសោធន៍ ឬការបណ្តុះបណ្តាលនៅក្នុងដំណើរការសម្រុះសម្រួលទេនោះ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ អាចស្នើសុំឱ្យគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង ចាត់តាំងអ្នកសម្រុះសម្រួល ដែលបានទទួលការបណ្តុះបណ្តាលឱ្យចូលរួមនៅក្នុងក្រុមអ្នកសម្រុះសម្រួល។

**ប្រការ២៣**

ភាគីវិវាទអាចជ្រើសរើសបុគ្គលម្នាក់តាមជម្រើសរបស់ខ្លួនផ្ទាល់ឱ្យជួយខ្លួននៅគ្រប់ថ្នាក់នៃដំណើរការសម្រុះសម្រួល។ បុគ្គលរូបនេះហៅថាអ្នកជំនួយការភាគី ឬអ្នកជំនួយការមិនអាចតំណាងឱ្យភាគីបានទេ ប៉ុន្តែអាចផ្តល់យោបល់ដល់ភាគីវិវាទបាន។ អ្នកជំនួយការភាគីអាចបំភ្លឺយោបល់របស់ភាគី និងអាចចូលរួមនៅក្នុងកិច្ចប្រជុំទាំងឡាយ ជាមួយអ្នកសម្រុះសម្រួល និងជាមួយភាគីបាន ប៉ុន្តែមិនអាចនិយាយជំនួសភាគីទៅកាន់អ្នកសម្រុះសម្រួល ឬភាគីផ្សេងទៀតបានទេ ឬមិនអាចធ្វើសេចក្តីសម្រេចក្នុងនាមភាគីបានឡើយ។

ប្រសិនបើអ្នកជំនួយការភាគីនោះបំពានវិធាននៃដំណើរការវិវាទ ក្រុមអ្នកសម្រុះសម្រួលត្រូវផ្តល់ការក្រើនរំឭក និងការព្រមានជាឯកជនម្តងដល់អ្នកជំនួយការនោះ។ ប្រសិនបើអ្នកជំនួយ

ការនោះបន្តបំពានទៀត ក្រុមអ្នកសម្រុះសម្រួលត្រូវហាមឃាត់អ្នកជំនួយការនោះមិនឱ្យចូលរួមនៅក្នុងដំណើរការវិវាទតទៅទៀតឡើយ។ ប្រសិនបើអ្នកជំនួយការត្រូវបានរារាំងដំណើរការសម្រុះសម្រួលត្រូវផ្អាកមួយរយៈរហូតដល់ភាគីវិវាទជ្រើសរើសអ្នកជំនួយការថ្មីបាន ឬព្រមព្រៀងបន្តដំណើរការដោយពុំចាំបាច់មានអ្នកជំនួយការ។ អ្នកសម្រុះសម្រួលត្រូវផ្តល់ឱ្យភាគីម្ខាងៗ នូវឱកាសគ្រប់គ្រាន់ដើម្បីពិគ្រោះយោបល់ ជាមួយអ្នកជំនួយការដែលត្រូវបានហាមឃាត់នៅខាងក្រៅកន្លែងធ្វើការសម្រុះសម្រួល។

## ប្រការ២៤

អ្នកសម្រុះសម្រួលត្រូវជួបជាមួយភាគីទាំងឡាយរួមគ្នា ឬដាច់ដោយឡែកពីគ្នា ប្រសិនបើមានការស្នើសុំ ដើម្បីពិភាក្សាពីបញ្ហារបស់ភាគី ពន្យល់ករណីវិវាទដល់ភាគីវិវាទដោយផ្អែកលើភស្តុតាង និងពិគ្រោះអំពីលទ្ធភាពដំណោះស្រាយនានាដែលអាចមានចំពោះវិវាទ។ ការពិគ្រោះត្រូវធ្វើឡើងដោយរក្សាការសំងាត់ក្នុងចំណោមភាគីវិវាទ អ្នកជំនួយការរបស់ភាគី និងអ្នកសម្រុះសម្រួល ហើយមិនត្រូវយកការពិគ្រោះនេះទៅធ្វើជាផ្អែកមួយនៃកំណត់ហេតុផ្លូវការនៃវិវាទឡើយ។

អ្នកសម្រុះសម្រួលអាចស្នើដំណោះស្រាយ ដោយផ្អែកលើការយល់ដឹងរបស់ខ្លួនអំពីបំណងរបស់ភាគីវិវាទ លើភស្តុតាងដែលមាន និងផ្អែកលើច្បាប់ពាក់ព័ន្ធ ប៉ុន្តែអ្នកសម្រុះសម្រួលមិនត្រូវបង្ខំឱ្យអនុវត្តតាមសំណើរបស់ខ្លួន ឬមិនត្រូវធ្វើសេចក្តីសម្រេចលើវិវាទនោះឡើយ។ មានតែភាគីវិវាទទេដែលមានសិទ្ធិសម្រេច ឬបដិសេធដំណោះស្រាយបាន។

## ប្រការ២៥

អ្នកសម្រុះសម្រួលត្រូវវិភាគភស្តុតាងដែលប្រមូលបាននៅក្នុងពេលស៊ើបអង្កេត ដើម្បីយល់ឱ្យបានពេញលេញអំពីស្ថានភាពនៃវិវាទ ប៉ុន្តែអ្នកសម្រុះសម្រួលមិនត្រូវវាយតម្លៃភស្តុតាងក្នុងសមត្ថភាពជាផ្លូវការណាមួយឡើយ។

អ្នកសម្រុះសម្រួលអាចផ្តល់យោបល់ដល់ភាគីវិវាទអំពីរបៀបបកស្រាយភស្តុតាងវិវាទ ឬតម្លៃនៃភស្តុតាងអាចត្រូវបានបកស្រាយយ៉ាងណា ប៉ុន្តែយោបល់ទាំងនោះពុំមានតម្លៃខាងផ្លូវច្បាប់ និងមិនអាចក្លាយជាលំអានសម្រាប់អនុវត្តនៅក្នុងដំណើរការសម្រុះសម្រួល ឬការវិនិច្ឆ័យណាមួយឡើយ។

*វាយឡើងវិញ*

ការវាយតម្លៃភស្តុតាងអាចបញ្ចូលជាផ្នែកមួយនៃរបាយការណ៍សម្រុះសម្រួល ដែលត្រូវបញ្ចូលទៅក្នុងកំណត់ហេតុផ្លូវការនៃវិវាទ។

**ប្រការ២៦**

ប្រសិនបើភាគីទាំងឡាយ អាចឈានដល់ការព្រមព្រៀង ក្នុងពេលសម្រុះសម្រួលដោយគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ អ្នកសម្រុះសម្រួលត្រូវបំពេញបែបបទបញ្ចប់វិវាទ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី៦ ដែលមានរៀបរាប់អំពីដំណើរការដោះស្រាយ ដោយបញ្ជាក់ច្បាស់លាស់ពីការព្រមព្រៀងដោះស្រាយនោះ។ រាល់ឯកសារ ឬផែនទីនានា ដែលអាចបំភ្លឺកិច្ចដំណោះស្រាយនោះ ត្រូវតម្កល់ជាមួយបែបបទបញ្ចប់វិវាទ។

អ្នកសម្រុះសម្រួលត្រូវអានដំណោះស្រាយព្រមព្រៀងឱ្យភាគីទាំងអស់ស្តាប់។ ភាគីវិវាទត្រូវចុះហត្ថលេខា ឬផ្តិតមេដៃលើកិច្ចព្រមព្រៀងតែក្នុងករណីដែលភាគីនោះយល់ព្រមលើរាល់ចំណុចនៃកិច្ចព្រមព្រៀង។ កិច្ចព្រមព្រៀងនឹងមានសុពលភាព ក្នុងករណីដែលភាគីវិវាទទាំងអស់បានព្រមព្រៀង និងបានចុះហត្ថលេខា ឬបានផ្តិតមេដៃ។ ភាគីវិវាទត្រូវចុះហត្ថលេខា ឬផ្តិតមេដៃលើបែបបទបញ្ចប់រឿងក្តី រួចតម្កល់បែបបទនោះនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ។ មន្ត្រីទទួលទម្រង់បែបបទបញ្ចប់រឿងក្តី ត្រូវចុះហត្ថលេខា និងបោះត្រាផ្លូវការលើទម្រង់បែបបទនេះ ហើយត្រូវផ្តល់ដល់ភាគីវិវាទនីមួយៗនូវឯកសារថតចម្លងនៃបែបបទនេះ។ ច្បាប់ថតចម្លងនៃបែបបទបញ្ចប់រឿងក្តីនេះ គឺជាភស្តុតាងនៃការដាក់តម្កល់កិច្ចដំណោះស្រាយ។

រាល់ឯកសារទាក់ទងទៅនឹងលទ្ធផលនៃការដោះស្រាយវិវាទ រួមទាំងបែបបទបញ្ចប់រឿងក្តី សេចក្តីពណ៌នានៃកិច្ចដំណោះស្រាយ និងផែនទី ឬគំនូសតាងនានាដែលអាចបំភ្លឺកិច្ចដំណោះស្រាយត្រូវបិទផ្សាយជាសាធារណៈដែលមានរយៈពេលមិនតិចជាង១៤ថ្ងៃ។ បុគ្គលណាក៏ដោយក៏អាចបញ្ចេញមតិលើឯកសារបញ្ចប់រឿងក្តីនេះ ក្នុងអំឡុងពេលប្រកាសផ្សាយជាសាធារណៈ។

ក្រុមអ្នកសម្រុះសម្រួល ត្រូវរាយការណ៍អំពីកិច្ចដំណោះស្រាយរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ និងគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង។ បន្ទាប់មក ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ ត្រូវចាប់ផ្តើមនីតិវិធីចុះបញ្ជីក្បាលដីដែលបានដោះស្រាយរួចនោះ។

**ប្រការ២៧**

ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ ត្រូវបញ្ជាក់អំពីដំណោះស្រាយជាមួយភាគីវិវាទ និងត្រូវចាប់ផ្តើមអនុវត្តនីតិវិធីចុះបញ្ជីក្បាលដីដែលបានដោះស្រាយរួចនោះ នៅពេលទទួលបានការបញ្ជាក់ថាដំណោះស្រាយបានសម្រេចដោយស្ម័គ្រចិត្ត និងថាភាគីវិវាទយល់ពីកិច្ចព្រមព្រៀង។

**ប្រការ២៨**

ប្រសិនបើភាគីមិនអាចឈានដល់ដំណោះស្រាយ ក្រុមអ្នកសម្រុះសម្រួលត្រូវរៀបចំរបាយការណ៍ស្តីពីដំណើរការសម្រុះសម្រួល អនុលោមតាមបែបបទស្តង់ដារ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី៧។ របាយការណ៍ត្រូវរួមបញ្ចូលព័ត៌មានជាមូលដ្ឋានស្តីពីភាគីវិវាទ សេចក្តីសង្ខេបជំហររបស់ភាគីវិវាទ និងសេចក្តីសង្ខេបអំពីដំណើរការសម្រុះសម្រួល។ របាយការណ៍នេះត្រូវក្លាយជាផ្នែកមួយនៃកំណត់ហេតុសាធារណៈផ្លូវការនៃវិវាទ និងត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង។

## ៦.ការសម្រុះសម្រួលរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង

**ប្រការ២៩**

ករណីសម្រុះសម្រួលជំហានដំបូង រួមមានវិវាទដែលបានបញ្ជូនទៅឱ្យគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង ដើម្បីធ្វើការសម្រុះសម្រួលដោយផ្ទាល់ ដោយអនុលោមតាមប្រការ១៨ និងប្រការ២១នៃប្រកាសនេះ។ ករណីសម្រុះសម្រួលជំហានដំបូង ត្រូវបានបញ្ជូនអមជាមួយកំណត់ហេតុផ្លូវការពេញលេញនៃវិវាទទៅឱ្យគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង។

**ប្រការ៣០**

ករណីសម្រុះសម្រួលវិវាទជំហានទី២ រួមមានវិវាទដែលដោះស្រាយមិនបានសម្រេចនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ។ ករណីសម្រុះសម្រួលជំហានទី២ ត្រូវបញ្ជូនអមជាមួយកំណត់ហេតុផ្លូវការណ៍ពេញលេញ និងរបាយការណ៍សម្រុះសម្រួលទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង។

**ប្រការ៣១**

ក្នុងរយៈពេល៦០ថ្ងៃ បន្ទាប់ពីបានទទួលបណ្ដឹងវិវាទសម្រាប់ការសម្រុះសម្រួលជំហានដំបូង ឬការសម្រុះសម្រួលជំហានទី២ គណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង ត្រូវរៀបចំកិច្ចប្រជុំរដ្ឋបាលរវាងគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង និងភាគីវិវាទ។

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង អាចអញ្ជើញតំណាងរបស់អាជ្ញាធរដែនដីស្រុក-ខណ្ឌ ឃុំ-សង្កាត់ ឬមន្ទីរជុំវិញខេត្ត-ក្រុងពាក់ព័ន្ធនានា ឱ្យចូលរួមជាសមាជិកអាដហុក ដើម្បីសម្រុះសម្រួលវិវាទ។ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង គប្បីយកចិត្តទុកដាក់បញ្ចូលស្ត្រីជាសមាជិកនៃគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង។

ក្នុងអំឡុងពេលនៃកិច្ចប្រជុំរដ្ឋបាលដំបូង ភាគីវិវាទត្រូវលើកសំណើ និងការជំទាស់ចំពោះវិវាទអំពីផលប្រយោជន៍ ប្រសិនបើមាន។ គណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង ត្រូវដោះស្រាយរាល់វិវាទអំពីផលប្រយោជន៍ និងកំណត់អ្នកសម្រុះសម្រួលសម្រាប់វិវាទនោះ។ បន្ទាប់មក អ្នកសម្រុះសម្រួលត្រូវជួបជាមួយភាគីវិវាទ និងកំណត់ពេលវេលាសម្រាប់ឱ្យភាគីបង្ហាញភស្តុតាងបន្ថែមនានា និងពេលវេលាសម្រាប់សម្រុះសម្រួលវិវាទ។

**ប្រការ៣២**

ប្រសិនបើសមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង មានផលប្រយោជន៍ក្នុងវិវាទ សមាជិករូបនោះ ត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទនោះ ហើយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់អាចតែងតាំងសមាជិកថ្មីជំនួសវិញ។

ភាគីអាចដាក់បណ្ដឹងជំទាស់ជាលាយលក្ខណ៍អក្សរចំពោះការចូលរួមរបស់សមាជិកគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុងណាម្នាក់ រួមទាំងប្រធានគណៈកម្មការ ដោយផ្អែកលើមូលដ្ឋាននៃវិវាទអំពីផលប្រយោជន៍របស់សមាជិក។ សមាជិកដទៃទៀតនៃគណៈកម្មការ ត្រូវសម្រេចថាតើសមាជិកដែលត្រូវជំទាស់អំពីវិវាទផលប្រយោជន៍នោះ ត្រូវរារាំងមិនឱ្យសាមីខ្លួនចូលរួមក្នុងការដោះស្រាយវិវាទឬទេ។

**ប្រការ៣៣**

ភាគីទាំងឡាយអាចជ្រើសរើសអ្នកសម្រុះសម្រួលក្នុងចំណោមសមាជិកអាដហុក និងសមាជិកអចិន្ត្រៃយ៍នៃគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង នៅក្នុងល័ក្ខខ័ណ្ឌតែមួយគឺភាគីវិវាទ

ទាំងអស់ព្រមព្រៀងជាលាយលក្ខណ៍អក្សរ ចំពោះការប្រើប្រាស់អ្នកសម្រុះសម្រួលនោះ។ ក្នុងករណីភាគីវិវាទទាំងអស់មិនព្រមព្រៀងលើសមាសភាពអ្នកសម្រុះសម្រួលណាមួយ ដែលមកពីគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង នោះប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង ត្រូវចាត់តាំងក្រុមអ្នកសម្រុះសម្រួលក្នុងចំណោមសមាជិកអាជប្ញាក និងសមាជិកអចិន្ត្រៃយ៍នៃគណៈកម្មការ។

ក្រុមអ្នកសម្រុះសម្រួលមានសមាជិក៣រូប ដែលមានម្នាក់ជាប្រធានត្រូវសម្រុះសម្រួលវិវាទ។ ក្រុមអ្នកសម្រុះសម្រួលយ៉ាងហោចណាស់ត្រូវរួមបញ្ចូលសមាជិកមួយរូប ជាអ្នកបានទទួលការបណ្តុះបណ្តាល ឬមានបទពិសោធន៍ក្នុងការសម្រុះសម្រួលវិវាទ និងសមាជិកមួយរូប ជាអ្នកដឹងពីស្ថានភាព និងសភាពការណ៍នៅក្នុងមូលដ្ឋាន។

**ប្រការ៣៤**

អ្នកសម្រុះសម្រួលត្រូវធ្វើការសម្រុះសម្រួលនៅលើទីតាំងដី ឬនៅជិតដីវិវាទ លើកលែងតែមានហេតុផលបញ្ជាក់ថា មានការគំរាមកំហែងដល់សន្តិសុខរបស់មន្ត្រីគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង។ ក្នុងករណីអសន្តិសុខ ដំណើរការសម្រុះសម្រួលវិវាទ ត្រូវធ្វើឡើងនៅទីកន្លែងដែលមានសន្តិសុខដែលនៅជិតដីវិវាទបំផុត។

នីតិវិធីរដ្ឋបាលសម្រាប់សម្រុះសម្រួលរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង ត្រូវដូចគ្នានឹងនីតិវិធីទាំងឡាយរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ដែលមានចែងលំអិតនៅក្នុងប្រការ២៤នៃប្រកាសនេះ។

**ប្រការ៣៥**

នីតិវិធីរដ្ឋបាលនៃដំណោះស្រាយរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង ត្រូវដូចគ្នានឹងនីតិវិធីទាំងឡាយសម្រាប់កិច្ចដំណោះស្រាយ នៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ដែលមានចែងលំអិតនៅក្នុងប្រការ២៦នៃប្រកាសនេះ។

អ្នកសម្រុះសម្រួល ត្រូវបញ្ជូនកិច្ចដំណោះស្រាយរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្តក្រុង ទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ ដើម្បីចុះបញ្ជីក្បាលដី។

**ប្រការ៣៦**

នីតិវិធីរដ្ឋបាលសម្រាប់បញ្ជាក់អំពីកិច្ចដំណោះស្រាយដែលសម្រេចបាននៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង ត្រូវដូចគ្នានឹងនីតិវិធីទាំងឡាយ នៅគណៈកម្មការសុរិយោដីថ្នាក់ស្រុកខណ្ឌ ដែលមានចែងលំអិតនៅក្នុងប្រការ២៧នៃប្រកាសនេះ ។

**ប្រការ៣៧**

នីតិវិធីរដ្ឋបាលសម្រាប់ការធ្វើរបាយការណ៍សម្រុះសម្រួលនៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង ត្រូវដូចគ្នានឹងនីតិវិធីទាំងឡាយនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ដែលមានចែងលំអិតនៅក្នុងប្រការ២៨នៃប្រកាសនេះ ។

**៧-ដំណើរការដោះស្រាយវិវាទរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ**

**ប្រការ៣៨**

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសិទ្ធិសម្រេចវិវាទទាំងឡាយដែលឋិតនៅក្រៅតំបន់វិនិច្ឆ័យ ហើយដែលមិនអាចដោះស្រាយបានដោយគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ និងគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង និងរាល់វិវាទដែលកើតមាននៅក្នុងតំបន់វិនិច្ឆ័យ ដែលមិនអាចដោះស្រាយបានដោយគណៈកម្មការរដ្ឋបាល ។

លើកលែងតែក្នុងករណីបន្ទាន់ ដូចមានពណ៌នាក្នុងប្រការ៣៩នៃប្រកាសនេះ គណៈកម្មការសុរិយោដីថ្នាក់ជាតិ មិនត្រូវពិនិត្យករណីទាំងឡាយក្នុងឋានៈជាក្រុមអ្នកសម្រុះសម្រួលជំហានដំបូងចំពោះករណីវិវាទណាមួយឡើយ ។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង ឬគណៈកម្មការរដ្ឋបាល ត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ នូវករណីវិវាទអមជាមួយកំណត់ហេតុផ្លូវការទាំងមូល និងរបាយការណ៍សម្រុះសម្រួល ដែលសង្ខេបដំណើរការវិវាទដែលបានធ្វើនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ និងគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង ឬនៅគណៈកម្មការរដ្ឋបាលតាមករណីជាក់ស្តែង ។

**ប្រការ៣៩**

ក្នុងករណីវិវាទដែលតម្រូវឱ្យមានការសម្រេច ឬដំណើរការដោះស្រាយជាបន្ទាន់ ដូចជាករណីមានការគំរាមកំហែង ឬការភ័យខ្លាចសមហេតុផលកើតឡើងពីការបង្កអគ្គិភ័យ ការប្រើកម្លាំង ឬការបំភិតបំភ័យ ភាគីវិវាទអាចស្នើទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិឱ្យចាត់វិធានការបណ្តោះ

អាសន្ន ដើម្បីការពារផលប្រយោជន៍របស់ភាគីនៅពេលដែលវិវាទកំពុងធ្វើការដោះស្រាយ។ នៅក្នុងស្ថានភាពនេះ ភាគីអាចប្ដឹងដោយផ្ទាល់ទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ឱ្យចេញសេចក្ដីសម្រេចជាបណ្ដោះអាសន្ន ដើម្បីធ្វើឱ្យស្ថានការណ៍មានស្ថិរភាពរហូតដល់មានការស៊ើបអង្កេត និងសេចក្ដីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ។ សេចក្ដីសម្រេចបណ្ដោះអាសន្នត្រូវមានខ្លឹមសារជាការរក្សាស្ថានភាពដដែល។

**ប្រការ៤០**

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវកោះប្រជុំគណៈកម្មការសុរិយោដីថ្នាក់ជាតិតាមតម្រូវការដើម្បីដោះស្រាយវិវាទ។

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិអាចអញ្ជើញតំណាងក្រសួង និងស្ថាប័នពាក់ព័ន្ធឱ្យចូលរួមជាសមាជិកអាដហុក ដើម្បីដោះស្រាយវិវាទ។ ប្រធានគប្បីយកចិត្តទុកដាក់បញ្ចូលស្ត្រីជាសមាជិកនៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ។

**ប្រការ៤១**

បន្ទាប់ពីត្រួតពិនិត្យមើលកំណត់ហេតុផ្លូវការនៃវិវាទ ឬនៅពេលផ្សេងទៀតក្នុងអំឡុងពេលធ្វើការពិនិត្យវិវាទដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិអាចសម្រេចធ្វើការសម្រុះសម្រួលវិវាទបន្ថែមទៀត។

នៅក្នុងស្ថានភាពនេះ នីតិវិធីរដ្ឋបាលដើម្បីសម្រុះសម្រួលនៅថ្នាក់ជាតិ ត្រូវអនុវត្តដូចនីតិវិធីទាំងឡាយ សម្រាប់គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ដូចមានចែងលំអិតក្នុងប្រការ២៤នៃប្រកាសនេះ។

ប្រសិនបើការសម្រុះសម្រួលមិនបានសម្រេច ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវកំណត់កាលបរិច្ឆេទសម្រាប់ការធ្វើសវនាការ ដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ។

ភាគីអាចស្នើសុំគណៈកម្មការសុរិយោដីថ្នាក់ជាតិឱ្យបញ្ជូនក្រុមអ្នកវិនិច្ឆ័យចល័តទៅកាន់ខេត្ត-ក្រុង ស្រុក-ខណ្ឌ។ ក្នុងករណីដែលគ្មានការព្រមព្រៀងគ្នារវាងភាគី ទីកន្លែងធ្វើសវនាការត្រូវឋិតនៅជិតដីវិវាទបំផុត។ នៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ គូវិវាទត្រូវកំណត់ពេលវេលាដើម្បីចុះទៅពិនិត្យមើលទីតាំងដីវិវាទ ឬព្រមព្រៀងលើកលែងការស៊ើបអង្កេតបន្ថែមទៀតបាន។

**ប្រការ៤២**

ប្រសិនបើសមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ មានផលប្រយោជន៍នៅក្នុងវិវាទ សមាជិកនោះត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទ ហើយប្រសិនបើចាំបាច់ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចតែងតាំងសមាជិកថ្មីជំនួសវិញ។

ភាគីអាចដាក់ពាក្យបណ្ដឹងជំទាស់ជាលាយលក្ខណ៍អក្សរចំពោះការចូលរួមរបស់សមាជិករួមទាំងប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដោយផ្អែកលើវិវាទអំពីផលប្រយោជន៍របស់សមាជិកនោះ។ សមាជិកដទៃទៀតនៃគណៈកម្មការត្រូវសម្រេចថា តើសមាជិកដែលត្រូវជំទាស់អំពីវិវាទអំពីផលប្រយោជន៍នោះ ត្រូវរារាំងមិនឱ្យចូលរួមក្នុងការដោះស្រាយវិវាទឬទេ។

**ប្រការ៤៣**

រាល់កិច្ចប្រជុំ ឬសវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិចាត់វិធានការផ្លូវការទាក់ទងទៅនឹងវិវាទត្រូវបើកចំហជាសាធារណៈ។

សេចក្ដីជូនដំណឹងជាមុនអំពីរាល់កិច្ចប្រជុំ ឬសវនាការ ដែលជាការចាត់វិធានការផ្លូវការត្រូវជូនដល់សាធារណជន និងប្រព័ន្ធសារព័ត៌មាន។ លេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវរក្សាទុកកំណត់ហេតុនៃដំណើរការ រឿងវិវាទទាំងអស់របស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ហើយបុគ្គលណាក៏មានសិទ្ធិមើលកំណត់ហេតុទាំងនោះ ទោះបីបុគ្គលនោះមាន ឬគ្មានផលប្រយោជន៍នៅក្នុងវិវាទនោះក្ដី។

**ប្រការ៤៤**

លើកលែងតែការប្រជុំសម្រាប់ការសម្រុះសម្រួល ដែលអាចធ្វើឡើងជាមួយភាគីវិវាទដោយឡែកពីគ្នា គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវអញ្ជើញភាគីដែលមានផលប្រយោជន៍ទាំងអស់ ឱ្យចូលរួមរាល់កិច្ចប្រជុំ និងសវនាការទាក់ទងទៅនឹងវិវាទរបស់ពួកគេ។ សេចក្ដីអញ្ជើញត្រូវបញ្ជូនទៅឱ្យភាគី យ៉ាងហោច១៥ថ្ងៃនៃថ្ងៃធ្វើការមុនពេលបើកកិច្ចប្រជុំ ឬសវនាការ។

**ប្រការ៤៥**

ភាគីអាចជ្រើសរើសបុគ្គលម្នាក់តាមជម្រើសរបស់ខ្លួនផ្ទាល់ឱ្យតំណាងខ្លួន នៅក្នុងរាល់ដំណើរការនៃរឿងវិវាទរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ។ បុគ្គលនេះហៅថា អ្នកការពារក្ដីអាចផ្ដល់ការណែនាំ ឬអាចតំណាងភាគីបាន។ អ្នកការពារក្ដី អាចបញ្ជាក់ពីចម្លើយរបស់ភាគី និងអាចចូលរួមកិច្ចប្រជុំជាមួយគណៈកម្មការសុរិយោដីថ្នាក់ជាតិ ហើយតាមការយល់ព្រមរបស់ភាគីអាចនិយាយ និងអាចធ្វើសេចក្ដីសម្រេចក្នុងនាមភាគីបាន។ ទោះបីជាយ៉ាងណាក្ដី បើគ្មានការយល់

ព្រមជាលាយលក្ខណ៍អក្សរជាក់លាក់របស់ភាគីទេនោះ អ្នកការពារក្តីមិនអាចដោះស្រាយវិវាទក្នុងនាមភាគីបានឡើយ ។

ប្រសិនបើ អ្នកការពារក្តីបំពាននីតិវិធាននៃដំណើរការរឿងវិវាទ គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវផ្តល់ការក្រើនរំឭក និងការព្រមានជាឯកជនម្តងដល់អ្នកការពារក្តី។ ប្រសិនបើអ្នកការពារក្តីនៅតែបន្តបំពានទៀត គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវហាមឃាត់អ្នកការពារក្តីនោះមិនឱ្យចូលរួមក្នុងដំណើរដោះស្រាយវិវាទទៀតឡើយ ។ ប្រសិនបើ អ្នកការពារក្តីត្រូវបានហាមឃាត់មិនឱ្យចូលរួមដំណើរការរឿងវិវាទនោះ ត្រូវផ្អាករហូតដល់ភាគីជ្រើសរើសអ្នកការពារក្តីថ្មីបាន ឬយល់ព្រមឱ្យបន្តដំណើរការដោយមិនមានអ្នកការពារក្តី។ គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវផ្តល់ឱកាសគ្រប់គ្រាន់ដល់ភាគីដើម្បីពិគ្រោះយោបល់ជាមួយអ្នកការពារក្តី ដែលត្រូវបានហាមឃាត់ឱ្យនៅក្រៅកន្លែងដោះស្រាយ ។

**ប្រការ៤៦**

គណៈកម្មការសុរិយោដីថ្នាក់ជាតិអាចធ្វើសវនាការវិវាទជាក្រុមវិនិច្ឆ័យ ឬអាចតែងតាំងសមាជិកតែម្នាក់ ឬមន្ត្រីសវនាការតែមួយរូបឱ្យធ្វើសវនាការបាន។

រាល់សវនាការ សក្ខីកម្មផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរអាចទទួលយកបាន ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មិនត្រូវបានតម្រូវឱ្យគោរពតាមវិធានភស្តុតាង ឬនីតិវិធីផ្លូវការទេ ប៉ុន្តែត្រូវធានាឱ្យភាគីទាំងអស់មានឱកាសបង្ហាញសក្ខីកម្ម និងភស្តុតាងរបស់ខ្លួនដោយយុត្តិធម៌ និងសមធម៌ ។

ភាគីនីមួយៗមានសិទ្ធិបង្ហាញសាក្សី និងបដិសេធភស្តុតាង ឬសាក្សីដែលផ្តល់ដោយភាគីផ្សេងទៀត។ បុគ្គលដែលផ្តល់សក្ខីកម្មអាចត្រូវបានតម្រូវឱ្យឆ្លើយនឹងសំណួរបញ្ជាក់អំពីសក្ខីកម្មនោះ។

**ប្រការ៤៧**

គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវស្តាប់ភស្តុតាងវិវាទ និងត្រួតពិនិត្យឯកសារផ្លូវការនៃវិវាទដែលបាន ប្រមូលនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ឬគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង ឬដោយគណៈកម្មការរដ្ឋបាល ហើយត្រូវចេញសេចក្តីសម្រេចដែលមានប្រសិទ្ធភាពអនុវត្តដោយផ្អែកលើរបាយការណ៍នេះ ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវចេញសេចក្តីសម្រេច នៅពេលធ្វើការសរុបការសន្និដ្ឋាន ការពិភាក្សារបស់ខ្លួន ហើយត្រូវធ្វើកំណត់សម្គាល់សេចក្តីសន្និដ្ឋានខាងផ្លូវច្បាប់ និងមូលដ្ឋាន

អង្គហេតុនៃសេចក្តីសម្រេចរបស់ខ្លួន។ សេចក្តីសម្រេចស្ថាពរ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងចុះហត្ថលេខាដោយប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ។

សេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវផ្ញើឱ្យភាគីទាំងឡាយ តាមរយៈសំបុត្រប្រៃសណីយ៍ និងត្រូវបើកចំហសម្រាប់ការពិនិត្យមើលជាសាធារណៈដល់បុគ្គលណាក៏ដោយទោះបីមាន ឬគ្មានផលប្រយោជន៍នៅក្នុងរឿងវិវាទនោះក្តី។

សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ត្រូវអមជាមួយសេចក្តីជូនដំណឹងដែលជំរាបភាគីវិវាទអំពីសិទ្ធិរបស់ពួកគេក្នុងការប្តឹងតវ៉ាទៅតុលាការឱ្យពិនិត្យមើលឡើងវិញផ្នែកច្បាប់ ចំពោះសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ហើយត្រូវផ្តល់ព័ត៌មានអំពីរបៀបប្តឹងទៅតុលាការផង។

## *ប្រការ៤៨*

សេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ក្លាយជាសេចក្តីសម្រេចស្ថាពរនៅនៅក្រោយរយៈពេល៣០ថ្ងៃ បន្ទាប់ពីសេចក្តីសម្រេចនោះត្រូវបានបញ្ជូន ទៅដល់ភាគីវិវាទទាំងអស់ លើកលែងតែករណីមានការប្តឹងទៅតុលាការ ឬមានការស្នើសុំឱ្យធ្វើការពិនិត្យឡើងវិញ ដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ អនុលោមតាមប្រការ៤៩នៃប្រកាសនេះ។

ប្រសិនបើគ្មានការប្តឹងតវ៉ាទៅតុលាការ ឬគ្មានការស្នើសុំឱ្យធ្វើសវនាការឡើងវិញត្រូវបានធ្វើឡើងតាមពេលវេលាត្រឹមត្រូវទេ លេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវបញ្ជូនសេចក្តីសម្រេចនោះទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ។ បន្ទាប់មក ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ ត្រូវចាប់ផ្តើមអនុវត្តនីតិវិធីចុះបញ្ជីក្បាលដីដែលត្រូវបានសម្រេចនោះ។

## *ប្រការ៤៩*

ការធ្វើសវនាការឡើងវិញពុំអាចធ្វើបានទេ លើកលែងតែមានសំឡេងយល់ព្រមពីសមាជិក៣រូបនៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ នៅពេលដែលមានភស្តុតាងថ្មីធំដុំត្រូវបានដាក់ជូនគណៈកម្មការ។

សំណើសុំធ្វើសវនាការឡើងវិញ ត្រូវដាក់ជូនជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរត្រូវបានបញ្ជូនដល់ភាគី ហើយត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនោះ ដោយត្រូវអមដោយព័ត៌មាន និងគំនូសតាងចាំបាច់នានា។

ការធ្វើសវនាការឡើងវិញ ត្រូវអនុលោមតាមសេចក្តីជូនដំណឹង និងល័ក្ខខ័ណ្ឌតម្រូវផ្នែកនីតិវិធី ដូចសវនាការដើមដែរ ។

ប្រសិនបើមានការបដិសេធចំពោះសំណើសុំឱ្យមានសវនាការឡើងវិញ គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបដិសេធនោះដល់ភាគីវិវាទ ។ នៅក្នុងករណីនេះ សេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ក្លាយជាស្ថាពរក្រោយបញ្ចប់រយៈពេល៣០ថ្ងៃ បន្ទាប់ពីសេចក្តីជូនដំណឹងពីការបដិសេធ ត្រូវបានបញ្ជូនទៅដល់ភាគីវិវាទ លើកលែងតែភាគីម្ខាងនៃគូវិវាទជូនដំណឹងអំពីការប្តឹងជំទាស់ទៅតុលាការតាមពេលវេលាត្រឹមត្រូវ ។

**ប្រការ៥០**

ភាគីណាក៏ដោយអាចប្តឹងទៅតុលាការដោយរួមគ្នា ឬជាបុគ្គលអំពីសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ បណ្តឹងជំទាស់ត្រូវដាក់ជូនទៅតុលាការក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីសេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវបានបញ្ជូនដល់ភាគីវិវាទ ។

ភាគីណាមួយដែលធ្វើបណ្តឹងទៅតុលាការ ត្រូវដាក់តម្កល់ឯកសារថតចម្លងមួយច្បាប់នៃបណ្តឹងជំទាស់នៅលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

លេខាធិការដ្ឋាន ត្រូវធ្វើសេចក្តីបញ្ជាក់ជាបន្ទាន់នូវរបាយការណ៍ផ្លូវការ ដើម្បីបញ្ជូនទៅតុលាការ ។

## ៨_បទប្បញ្ញត្តិរដ្ឋបាល

**ប្រការ៥១**

ប្រធានគណៈកម្មការសុរិយោដីគ្រប់ថ្នាក់ ត្រូវធ្វើរបាយការណ៍ប្រចាំខែស្តីពីបណ្តឹងដែលបានទទួល និងចំណាត់ការដែលបានធ្វើដោយគណៈកម្មការ ចំពោះបណ្តឹងនីមួយៗដែលគណៈកម្មការបានធ្វើ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ត្រូវផ្ញើរបាយការណ៍ប្រចាំខែទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង ។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង ត្រូវផ្ញើរបាយការណ៍ប្រចាំខែទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវផ្ញើរបាយការណ៍ប្រចាំខែទៅរាជរដ្ឋាភិបាល ។

របាយការណ៍របស់គណៈកម្មការសុរិយោដី ត្រូវបើកចំហ និងអនុញ្ញាតឱ្យសាធារណជនមើលដោយសេរី ក្នុងពេលម៉ោងធ្វើការធម្មតា ។

**ប្រការ៥២**

គណៈកម្មការសុរិយោដីគ្រប់ថ្នាក់ ត្រូវរក្សាទុកកំណត់ហេតុផ្លូវការនៃវិវាទនីមួយៗដែលបានប្ដឹងនៅគណៈកម្មការនោះ ។

កំណត់ហេតុផ្លូវការត្រូវរួមបញ្ចូលរាល់ឯកសារទាំងអស់ សេចក្ដីអះអាងភស្តុតាងផ្សេងៗ និងរបាយការណ៍ផ្សេង ៗ ដែលទាក់ទងទៅនឹងវិវាទ ។

ឯកសារផ្លូវការត្រូវបើកចំហជាសាធារណៈ និងអនុញ្ញាតឱ្យសាធារណជនចូលមើលដោយសេរី ក្នុងពេលម៉ោងធ្វើការធម្មតា ។

បុគ្គលទាំងឡាយដែលចង់ពិនិត្យមើលឯកសារ ត្រូវទៅមើលនៅការិយាល័យគណៈកម្មការសុរិយោដីនោះ និងត្រូវចុះហត្ថលេខាលើសៀវភៅភ្ញៀវ ។

នៅកន្លែងដែលមានសម្ភារៈបរិក្ខារថតចម្លង បុគ្គលទាំងឡាយអាចថតចម្លងឯកសារបាន ។

**ប្រការ៥៣**

នាយខុទ្ទកាល័យ ប្រធានគណៈកម្មការសុរិយោដីគ្រប់ថ្នាក់ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង និងប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២

**រដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**អ៊ឹម ឈុនលឹម**

<u>កន្លែងទទួល</u>

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័ន

-គ្រប់សាលាខេត្ត-ក្រុង

-ដូចប្រការ៥៣

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជក្រម

នស/រកម/០៨០២/០១៦

**យើង**

**ព្រះបាទសម្តេចព្រះនរោត្តម សីហនុ រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស**

**អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**ប្រកាសឱ្យប្រើ**

ច្បាប់ស្តីពីព្រៃឈើដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០២ នាសម័យប្រជុំពេញអង្គលើកទី៨ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០២ នាសម័យប្រជុំពេញអង្គលើកទី៧[7] នីតិកាលទី១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

---

[7] ឯកសារច្បាប់ដើមត្រូវបានសរសេរជា "...លើទី៧"។

# ច្បាប់ស្តីពីព្រៃឈើ

## ជំពូកទី១ បទប្បញ្ញត្តិទូទៅ

**មាត្រា១**

ច្បាប់នេះកំណត់អំពីក្របខ័ណ្ឌនៃការគ្រប់គ្រង ការប្រមូលផល ការប្រើប្រាស់ ការធ្វើអាជីវកម្ម ការអភិវឌ្ឍ និងការអភិរក្សព្រៃឈើនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

គោលបំណងនៃច្បាប់នេះគឺធានានូវការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថានរួមទាំងការអភិរក្សជីវៈចម្រុះ និងមតិកវប្បធម៌។

**មាត្រា២**

ច្បាប់នេះមានវិសាលភាពអនុវត្តលើរាល់ព្រៃឈើទាំងអស់ ទោះជាប្រភេទព្រៃនោះកើតឡើងដោយធម្មជាតិក្តី ឬដោយដាំក្តី។ រដ្ឋធានាសិទ្ធិប្រើប្រាស់ជាប្រពៃណីនូវផល អនុផលព្រៃឈើរបស់សមាគមមូលដ្ឋានក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ឬច្បាប់ពាក់ព័ន្ធផ្សេងទៀត។

**មាត្រា៣**

ការគ្រប់គ្រងព្រៃឈើត្រូវឋិតនៅក្រោមដែនសមត្ថកិច្ចទូទៅនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ការគ្រប់គ្រងព្រៃលិចទឹកឋិតនៅក្រោមច្បាប់មួយដោយឡែក។

រដ្ឋផ្តល់សិទ្ធិគ្រប់គ្រងតំបន់ការពារធម្មជាតិដល់ក្រសួងបរិស្ថាន ក្រោមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ព្រះរាជក្រឹត្យស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ និងលិខិតបទដ្ឋានច្បាប់ផ្សេងទៀត។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិសហការធ្វើសកម្មភាពពង្រឹងការអនុវត្តច្បាប់ ចំពោះរាល់បទល្មើសព្រៃឈើដែលកើតមាននៅក្នុងតំបន់ការពារធម្មជាតិក្រោមការសម្របសម្រួលជាមួយក្រសួងបរិស្ថានស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី១៤នៃច្បាប់នេះ។

សកម្មភាពនេះនឹងមិនធ្វើឱ្យប៉ះពាល់ដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ដូចមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឡើយ ។

**មាត្រា៤**

ក្នុងការអនុវត្តច្បាប់នេះ រាល់ការសម្រេចរបស់រាជរដ្ឋាភិបាលដែលមានសក្តានុភាពចំពោះផលប៉ះពាល់ធ្ងន់ធ្ងរទៅលើប្រជាពលរដ្ឋទូទៅ លើជីវភាពសមាគមមូលដ្ឋាន និងលើធនធានព្រៃឈើនៃព្រះរាជាណាចក្រកម្ពុជាត្រូវមានការចូលរួមជាសាធារណៈ ។

សកម្មភាពចម្បងៗ ពាក់ព័ន្ធទៅនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើដែលអាចបណ្តាលឱ្យមានផលប៉ះពាល់អាក្រក់ដល់សង្គម និងបរិស្ថានចាំបាច់ត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម ដោយផ្អែកតាមក្រុមបច្ចេកទេសគ្រប់គ្រងព្រៃឈើកម្ពុជា និងស្របតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។ ឯកសារនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម ត្រូវផ្តល់ជូនសម្រាប់ការចូលរួមផ្តល់មតិជាសាធារណៈបាន ។

រាល់ការសម្រេចចុងក្រោយលើរាល់សកម្មភាពចម្បងៗ ពាក់ព័ន្ធទៅនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ រាជរដ្ឋាភិបាលត្រូវពិចារណាលើអនុសាសន៍ចុងក្រោយនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម ។

ការសម្រេចចុងក្រោយណាមួយក្រោមមាត្រានេះ រាជរដ្ឋាភិបាលអាចធ្វើការជូនដំណឹងជាសាធារណៈ ។

**មាត្រា៥**

វាក្យសព្ទសំខាន់ៗដែលប្រើប្រាស់ និងមានអត្ថន័យសម្រាប់ច្បាប់នេះត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃច្បាប់នេះ ។

## ជំពូកទី២ រដ្ឋបាលព្រៃឈើ

**មាត្រា៦**

រដ្ឋបាលព្រៃឈើគឺជាអាជ្ញាធររដ្ឋាភិបាល ដែលចំណុះក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការគ្រប់គ្រងព្រៃឈើ និងធនធានព្រៃឈើស្របតាមគោលនយោបាយវិស័យព្រៃឈើជាតិ និងច្បាប់នេះ ។

រដ្ឋបាលព្រៃឈើមានរចនាសម្ព័ន្ធគ្រប់គ្រង ចាត់តាំងមួយឯកភាពទូទាំងប្រទេស ជាខ្សែរយៈបណ្តោយដែលបែងចែកជាថ្នាក់កណ្តាល អធិការដ្ឋាន ខណ្ឌ ផ្នែក និងសង្កាត់រដ្ឋបាលព្រៃឈើ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

រដ្ឋបាលព្រៃឈើត្រូវបំពេញភារកិច្ចរបស់ខ្លួន ស្របតាមគោលការណ៍តម្លាភាព ដោយធានានូវសិទ្ធិរបស់សាធារណជនដើម្បីចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត លើការគ្រប់គ្រងការប្រើប្រាស់ប្រកបដោយនិរន្តរភាព និងការអភិរក្សព្រៃឈើ។

**មាត្រា៧**

រដ្ឋបាលព្រៃឈើត្រូវបំពេញនូវភារកិច្ចដូចតទៅ៖

១-ធានាដល់ការគ្រប់គ្រងសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ប្រកបដោយនិរន្តរភាព ដោយដាក់បទបញ្ជាលើរាល់សកម្មភាពព្រៃឈើ។

២-សិក្សាប្រមូលទិន្នន័យលើព្រៃឈើរដ្ឋទាក់ទងនឹងកត្តាវិទ្យាសាស្ត្រ សេដ្ឋកិច្ច សង្គម និងបរិស្ថាន ដើម្បីកំណត់នូវកម្រិតផ្តល់ផលប្រកបដោយនិរន្តរភាព។

៣-វាយតម្លៃព្រំប្រទល់ ធ្វើការចាត់ថ្នាក់ និងកំណត់ដែនព្រៃឈើ ដើម្បីបង្កើតផែនទីប្រើប្រាស់ដីសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ដោយសម្របសម្រួលជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋាន។

៤-រៀបចំ និងអនុវត្តផែនការគ្រប់គ្រងព្រៃឈើជាតិនៅថ្នាក់នីមួយៗនៃរដ្ឋបាលព្រៃឈើ។

៥-បង្កើនការដាំដុះព្រៃឈើឡើងវិញនៅលើដីព្រៃរេចរិល និងដីព្រៃទំនេរ។

៦-បង្កើនការអភិវឌ្ឍកិច្ចព្រមព្រៀង និងកម្មវិធីសហគមន៍ព្រៃឈើ ដោយផ្តល់នូវជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសដល់សហគមន៍តាមការសមស្រប។

៧-អភិវឌ្ឍ និងអនុវត្តកម្មវិធីស្រាវជ្រាវ ការពារ និងថែរក្សាធនធានព្រៃឈើ និងសត្វព្រៃ។

៨-ចាត់វិធានការសមស្របដើម្បីស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបរាល់ការបំផ្លិចបំផ្លាញព្រៃឈើភ្លើងឆេះព្រៃ និងការកាប់រានព្រៃឈើ ដោយធានាការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាព។

៩-បង្កើនការអប់រំដល់ប្រជាពលរដ្ឋតាមរយៈកម្មវិធី ដែលបង្ហាញពីសារៈសំខាន់ក្នុងការគ្រប់គ្រង ការពារថែរក្សាធនធានព្រៃឈើក៏ដូចជាចាត់វិធានការស្តារប្រព័ន្ធមជ្ឈដ្ឋានធម្មជាតិ និងថែរក្សាព្រៃឈើជាតិ។

១០-បង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិ សំដៅពង្រឹងសមត្ថភាពការពារ និងអភិវឌ្ឍធនធានព្រៃឈើ។

១១-ធានាការវាយតម្លៃទាន់ពេលវេលា និងពេញលេញនូវរាល់សកម្មភាពទាក់ទងនឹងព្រៃឈើដែលមានផលប៉ះពាល់អាក្រក់ដល់សង្គម និងបរិស្ថានមុនការឯកភាពលើសកម្មភាពទាំងនេះ។

មន្ត្រីរដ្ឋបាលព្រៃឈើមានសិទ្ធិ និងភារកិច្ចដូចខាងក្រោម៖

១-ត្រួតពិនិត្យការធ្វើអាជីវកម្មប្រមូលផល អនុផលព្រៃឈើក្នុងដែនដីព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងចម្ការដាំឈើរបស់រដ្ឋ។

២-ត្រួតពិនិត្យការដឹកជញ្ជូនផល អនុផលព្រៃឈើ និងផលប្រមាញ់ តាមមធ្យោបាយដឹកជញ្ជូននានា។

៣-ត្រួតពិនិត្យកន្លែងសន្និធិផល អនុផលព្រៃឈើ ទីតាំងលក់ផល អនុផលព្រៃឈើ ឬផលប្រមាញ់។

៤-ត្រួតពិនិត្យមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើ និងឡគ្រប់ប្រភេទដែលប្រើប្រាស់ផល អនុផលព្រៃឈើជាវត្ថុធាតុដើម ឬប្រភពថាមពលអំពីឈើ។

៥-ត្រួតពិនិត្យអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងឯកសារផ្សេងទៀត ដែលតម្រូវឱ្យត្រួតពិនិត្យតាមច្បាប់នេះ។

## ជំពូកទី៣ និរន្តរភាពនៃការគ្រប់គ្រងព្រៃឈើ

### មាត្រា៨

ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ត្រូវអនុវត្តស្របតាមគោលនយោបាយវិស័យព្រៃឈើជាតិ និងច្បាប់នេះ។

ដើម្បីជំនួយឱ្យការសិក្សាស្រាវជ្រាវគោលនយោបាយវិស័យព្រៃឈើជាតិ ឱ្យមានប្រសិទ្ធភាព រាជរដ្ឋាភិបាលត្រូវបង្កើតគណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យព្រៃឈើជាតិ ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមានសមាជិកពីក្រសួងពាក់ព័ន្ធនឹងវិស័យព្រៃឈើ ។ ផ្អែកតាមអនុសាសន៍របស់គណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យព្រៃឈើជាតិ រាជរដ្ឋាភិបាលត្រូវកំណត់នូវគោលនយោបាយវិស័យព្រៃឈើជាតិ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យព្រៃឈើត្រូវកំណត់ដោយអនុក្រឹត្យ ។

គោលនយោបាយវិស័យព្រៃឈើជាតិអាចសើរើដោយរាជរដ្ឋាភិបាល ដោយផ្អែកតាមអនុសាសន៍របស់គណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យព្រៃឈើជាតិ ក្នុងល័ក្ខខ័ណ្ឌផ្លាស់ប្តូរនៃស្ថានភាពវិស័យព្រៃឈើតាមគោលការណ៍ដែលនាំមកនូវដំណោះស្រាយ ដើម្បីរក្សានិរន្តរភាពនៃការគ្រប់គ្រងព្រៃឈើ ។

**មាត្រា៩**

រដ្ឋបាលព្រៃឈើត្រូវរៀបចំផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិស្របតាមគោលនយោបាយវិស័យព្រៃឈើជាតិ ដោយមានការចូលរួមទូលំទូលាយពីគ្រប់អាជ្ញាធរពាក់ព័ន្ធ និងសហគមន៍មូលដ្ឋាន ដែលអនុលោមតាមមាត្រា៤នៃច្បាប់នេះ ។

ផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិ ត្រូវសម្រេចដោយរាជរដ្ឋាភិបាលសម្រាប់រយៈពេលវែង ដើម្បីកំណត់អាទិភាពគ្រប់គ្រងព្រៃឈើ ។

ផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិត្រូវធ្វើការពិនិត្យ និងសើរើរៀងរាល់៥ឆ្នាំម្តងដើម្បីឆ្លុះបញ្ចាំងពីល័ក្ខខ័ណ្ឌ និងកាលៈទេសៈផ្លាស់ប្តូរ ។ គណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យព្រៃឈើជាតិត្រូវផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាល លើផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិដែលបានសើរើ ។

ផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិ ត្រូវលើកឡើងនូវសមាសភាគដូចតទៅ៖

១-ពិនិត្យកត្តារូបសាស្ត្រ បរិស្ថាន និងសង្គមទាក់ទងនឹងធនធានព្រៃឈើនៅគ្រប់ថ្នាក់នៃរដ្ឋបាលព្រៃឈើ ។

២-ប៉ាន់ស្មានបរិមាណផល អនុផលព្រៃឈើគ្រប់លំដាប់ថ្នាក់ ។

៣-កំណត់ផ្ទៃដី តំបន់ត្រូវដាំឈើឡើងវិញ និងព្រៃសហគមន៍ ។

៤-ពិនិត្យកម្មវិធី និងប្រតិទិនសកម្មភាពលំអិតលើការងាររៀបចំព្រៃឈើ និងរុក្ខវប្បកម្ម ។

៥-អភិវឌ្ឍកម្មវិធីនៃការធ្វើអន្តរាគមន៍ ដល់ភាគីពាក់ព័ន្ធក្នុងការគ្រប់គ្រង និងប្រើប្រាស់ព្រៃឈើរដ្ឋ និងឯកជន ។

៦-អភិវឌ្ឍកម្មវិធីសម្រាប់អភិវឌ្ឍឧស្សាហកម្មព្រៃឈើ ទីផ្សារផល អនុផលព្រៃឈើ ។

៧-អភិវឌ្ឍកម្មវិធីស្រាវជ្រាវ ស្តីពីការអភិវឌ្ឍបច្ចេកវិជ្ជា និងវិទ្យាសាស្ត្រព្រៃឈើ ។

៨-បង្កើន និងពង្រឹងចំណេះដឹងពីព្រៃឈើដោយអញ្ជើញការចូលរួមពីសហគមន៍មូលដ្ឋានក្នុងការគ្រប់គ្រងប្រើប្រាស់ និងការពារព្រៃឈើ ។

៩-អភិវឌ្ឍធនធានមនុស្ស និងមធ្យោបាយសម្ភារៈចាំបាច់ ដើម្បីសម្រេចលើសកម្មភាពដែលបានគ្រោងនៅក្នុងកម្មវិធី ។

១០-ពង្រឹងស្ថាប័នគ្រប់គ្រងវិស័យព្រៃឈើនៅគ្រប់ថ្នាក់ កែលំអ និងពង្រឹងការអនុវត្តច្បាប់ ។

១១-ពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ជំនួយបច្ចេកទេសក្នុងតំបន់ និងក្រៅតំបន់ក្នុងកិច្ចការពារ និងអភិវឌ្ឍធនធានព្រៃឈើ ។

១២-ឧបត្ថម្ភគាំទ្ររាល់កម្មវិធីទាំងឡាយណា ដែលជំរុញឱ្យមានការអនុវត្តគោលនយោបាយវិស័យព្រៃឈើជាតិ ។

ផ្អែកតាមអនុសាសន៍របស់គណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យព្រៃឈើជាតិ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវដាក់របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តទូវគោលបំណងនៃផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិជូនរាជរដ្ឋាភិបាល ។ របាយការណ៍នេះត្រូវផ្តល់ជូនជាសាធារណៈតាមការស្នើសុំ ។

## ជំពូកទី៤ សម្បត្តិព្រៃឈើអចិន្ត្រៃយ៍

### មាត្រា១០

សម្បត្តិព្រៃឈើអចិន្ត្រៃយ៍រួមមាន៖

១-ព្រៃបម្រុងទុកអចិន្ត្រៃយ៍។

២-ព្រៃឯកជន។

ព្រៃបម្រុងទុកអចិន្ត្រៃយ៍រួមមានបីប្រភេទ៖

១-ព្រៃផ្តល់ផលត្រូវបានរក្សាទុកសម្រាប់ផលិតកម្មផល អនុផលព្រៃឈើប្រកបដោយនិរន្តរភាពដែលក្នុងនោះមុខងារការពារត្រូវចាត់ទុកជាអាទិភាពបន្ទាប់។ ព្រៃផ្តល់ផលមានជាអាទិ៍៖

-ព្រៃសម្បទាន

-ព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន

-ព្រៃឈើត្រូវស្តារឡើងវិញ

-ផ្ទៃដីព្រៃបម្រុងទុកសម្រាប់ដាំដើមឈើឡើងវិញ ឬចម្ការព្រៃឈើ

-ផ្ទៃដីព្រៃបម្រុងទុកសម្រាប់បន្តពូជព្រៃឈើ

-ផ្ទៃដីព្រៃរេចរិល

-ព្រៃសហគមន៍ក្រោមកិច្ចព្រមព្រៀង។

២-ព្រៃការពារត្រូវបានរក្សាទុកជាចម្បង ដើម្បីការពារប្រព័ន្ធមជ្ឈដ្ឋាន និងធនធានធម្មជាតិ។ ព្រៃការពារមានជាអាទិ៍៖

-ព្រៃបម្រុងទុកសម្រាប់ប្រព័ន្ធមជ្ឈដ្ឋានពិសេស

-ព្រៃសម្រាប់សិក្សាស្រាវជ្រាវ

-ព្រៃនិយតកម្មប្រភពទឹក

-ព្រៃការពារទីជម្រាល

-ព្រៃលំហែកំសាន្ត

-សួនភូតគាម

-ព្រៃជំនឿសាសនា។

ព្រៃការពារនេះអាចអនុញ្ញាតឱ្យប្រមូលផល អនុផលព្រៃឈើជាលក្ខណៈប្រពៃណីដែលមានផលប៉ះពាល់ទាបដោយសហគមន៍មូលដ្ឋាន។

៣-ផ្ទៃដីព្រៃសម្រាប់ផ្ទេរដើម្បីគោលបំណងអភិវឌ្ឍផ្សេងទៀត ជាដីទំនេរដុះរុក្ខជាតិព្រៃបន្ទាប់បន្សំដែលមិនទាន់ឋិតនៅក្នុងការប្រើប្រាស់របស់វិស័យណាមួយនៅឡើយ ត្រូវតែដាក់ឱ្យឋិត

នៅក្នុងចំណាត់ថ្នាក់នៃព្រៃបម្រុងទុកអចិន្ត្រៃយ៍រហូតដល់មានការសម្រេចឱ្យប្រើប្រាស់ និងអភិវឌ្ឍ សម្រាប់គោលបំណងផ្សេងទៀតដោយរាជរដ្ឋាភិបាល ។

ព្រៃឯកជនត្រូវថែរក្សាដោយម្ចាស់កម្មសិទ្ធិ និងមានសិទ្ធិទទួលផលប្រយោជន៍ក្នុងការ អភិវឌ្ឍ និងប្រមូលផលប្រើប្រាស់លក់ចែកចាយផលិតផលរបស់ខ្លួនដោយផ្ទាល់ ។

**មាត្រា១១**

សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ត្រូវគ្រប់គ្រង ក្នុងគោលបំណងបង្កើនជាអតិបរមានូវផលប្រ យោជន៍សង្គម សេដ្ឋកិច្ច បរិស្ថាន និងមតិកវប្បធម៌ សម្រាប់ព្រះរាជាណាចក្រកម្ពុជា និងប្រជាពល រដ្ឋកម្ពុជាស្របនឹងគោលការណ៍គ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវចាត់ថ្នាក់ចុះបញ្ជិកា និងកំណត់ព្រំប្រទល់ ព្រៃឈើទាំងអស់នៅក្នុងសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ។

ក្នុងការអនុវត្តនូវសកម្មភាពនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងធ្វើការ សម្របសម្រួលជាមួយសហគមន៍មូលដ្ឋានអាជ្ញាធរពាក់ព័ន្ធ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដើម្បីជួយដល់ដំណើរការចុះបញ្ជិកាកម្មសិទ្ធិដីសហគមន៍ជនជាតិដើមភាគតិច និងការ រៀបចំផែនទីប្រើប្រាស់ដីថ្នាក់ជាតិ ។

គ្រប់គ្រងឈើដែលបានចាត់ថ្នាក់នៅក្នុងព្រៃបម្រុងទុកអចិន្ត្រៃយ៍ត្រូវបានរៀបចំ និងគ្រប់គ្រងស្របតាមគោលបំណងនៃផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិ ។

នីតិវិធី ការបង្កើត ការចាត់ថ្នាក់ និងការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ត្រូវកំណត់ ដោយអនុក្រឹត្យ ។

**មាត្រា១២**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិអំណាចរំសាយចំណាត់ថ្នាក់ព្រៃឈើ ណាមួយពីព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។ ការសម្រេចបែបនេះត្រូវឋិតនៅក្នុងផលប្រយោជន៍សាធារណៈ និងមានសង្គតិភាពជាមួយគោលនយោបាយវិស័យព្រៃឈើជាតិ ផែនការគ្រប់គ្រងវិស័យព្រៃឈើ ជាតិ និងទិន្នន័យបច្ចេកទេសសង្គម សេដ្ឋកិច្ចដែលផ្តល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង

នេសាទ។ ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងច្បាប់នេះ ការរំសាយចំណាត់ថ្នាក់ណាមួយនៃព្រៃបម្រុងទុកអចិន្ត្រៃយ៍សម្រាប់គោលបំណងមិនមែនព្រៃឈើ ត្រូវពិចារណាលើអាទិភាពដូចខាងក្រោម៖

១-ផ្ទៃដីព្រៃសម្រាប់ផ្ទេរដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត។

២-ដីព្រៃបម្រុងទុកអចិន្ត្រៃយ៍ផ្សេងទៀត ដែលតម្រូវការបច្ចុប្បន្នខ្ពស់ជាងតម្រូវការដែលកំណត់កន្លងមក។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអាចស្នើសុំរាជរដ្ឋាភិបាលកំណត់រកផ្ទៃដីព្រៃទំនេរផ្សេងទៀត ដើម្បីជំនួយផ្ទៃដីព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដែលបានរំសាយក្នុងគោលបំណងការពារ និងដាំព្រៃឡើងវិញដើម្បីរក្សាគម្របជាអចិន្ត្រៃយ៍។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអាចស្នើសុំរាជរដ្ឋាភិបាលសម្រេចធ្វើការផ្លាស់ប្តូរចំណាត់ថ្នាក់ព្រៃណាមួយនៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ដោយផ្អែកលើទិន្នន័យសិក្សាថ្មី និងមុខងាររបស់ដីព្រៃនោះ។

រាល់ការសម្រេចរំសាយចំណាត់ថ្នាក់ព្រៃឈើដូចមានចែងក្នុងកថាខណ្ឌទី១ និងការផ្លាស់ប្តូរចំណាត់ថ្នាក់ព្រៃឈើដូចមានចែងក្នុងកថាខណ្ឌទី៣ នៃមាត្រានេះត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៥ ការគ្រប់គ្រងព្រៃសម្បទាន

### មាត្រា១៣

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាអាចផ្តល់តំបន់ព្រៃផ្តល់ផលដែលនៅទំនេរ ដោយដាក់ឱ្យដេញថ្លៃជាសាធារណៈ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រោយពីបានពិគ្រោះយោបល់ជាមួយបណ្តាក្រសួងពាក់ព័ន្ធ អាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋានរួចហើយ។

សំណុំឯកសារ និងនីតិវិធីនៃការដេញថ្លៃជាសាធារណៈចំពោះការផ្តល់ព្រៃសម្បទាន ត្រូវកំណត់ដោយអនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃសម្បទាន។

### មាត្រា១៤

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិអំណាចចុះកិច្ចព្រមព្រៀងព្រៃសម្បទានជាមួយវិនិយោគិន ឬនីតិបុគ្គលណាមួយដោយការផ្តល់សម្បទាននេះ ត្រូវមានសង្គតិភាពជាមួយ

គោលនយោបាយវិស័យព្រៃឈើជាតិ ផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិ និងបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ។

ការដេញថ្លៃជាសាធារណៈត្រូវតែអនុវត្តជាមូលដ្ឋាន នៅមុនពេលរាជរដ្ឋាភិបាលចុះកិច្ចព្រមព្រៀងព្រៃសម្បទានដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងអនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃសម្បទាន ។

គណៈកម្មការដេញថ្លៃព្រៃសម្បទានត្រូវផ្តល់នូវកាលានុវត្តភាព និងការពិចារណាជូនអ្នកដេញថ្លៃគ្រប់រូបដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងត្រូវជូនដំណឹងអំពីការដេញថ្លៃជាសាធារណៈឱ្យបានទាន់ពេលវេលា ជាពិសេសដល់ប្រជាពលរដ្ឋមូលដ្ឋានក្នុងតំបន់ដែលដាក់ជាព្រៃសម្បទាន ។

បេក្ខភាពក្រុមហ៊ុនដេញថ្លៃ ត្រូវភ្ជាប់រាល់ឯកសារដេញថ្លៃជាមួយនឹងលិខិតថ្លែងការណ៍របស់ក្រុមហ៊ុន ដែលថែងលំអិតអំពីការប្រព្រឹត្តលើកិច្ចព្រមព្រៀងព្រៃសម្បទានដែលបានអនុវត្តកន្លងមក ទោះក្នុងប្រទេសក្តី ឬក្រៅប្រទេសក្តីដោយមានភស្តុតាងធានាអះអាងផង ។

**មាត្រា១៥**

ព្រៃសម្បទានិកមានសិទ្ធិដំណើរការគ្រប់គ្រង និងប្រមូលផល អនុផលព្រៃឈើនៅក្នុងដែនព្រៃសម្បទានរបស់ខ្លួនដោយធានាថាប្រតិបត្តិការទាំងនេះនឹងមិនប៉ះពាល់ដល់៖

១-សិទ្ធិប្រើប្រាស់ជាប្រពៃណីដែលអនុវត្តនៅលើដីកម្មសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច ដែលបានចុះបញ្ជិកាដោយរដ្ឋស្របតាមច្បាប់ភូមិបាល ។

២-សិទ្ធិចេញចូល និងសិទ្ធិប្រើប្រាស់ជាប្រពៃណីអនុវត្តដោយសហគមន៍ដែលមានទីតាំងក្នុង ឬក្បែរព្រៃសម្បទាន ។

**មាត្រា១៦**

ខ្លឹមសារកិច្ចព្រមព្រៀងព្រៃសម្បទានក្នុងកម្រិតអប្បរមាត្រូវមាន៖

១-កាលបរិច្ឆេទនៃការផ្តល់ព្រៃសម្បទាន និងរយៈពេលនៃការផ្តល់ ។

២-ទីតាំងព្រៃសម្បទានដែលកំណត់បង្ហាញនូវអត្តសញ្ញាណដីកម្មសិទ្ធិសហគមន៍ជនជាតិដើមភាគតិច តំបន់ព្រៃសហគមន៍ តំបន់គ្រប់គ្រងពិសេស និងផ្ទៃដីព្រៃដែលអាចប្រមូលផលបាន ។

៣-សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរថា ព្រៃសម្បទានិកត្រូវគោរព និងមិនជ្រៀតចូលធ្វើការប្រមូលផល អនុផលព្រៃឈើក្នុងតំបន់គ្រប់គ្រងពិសេស តំបន់កម្មសិទ្ធិសហគមន៍ជនជាតិដើមភាគតិច និងព្រៃសហគមន៍ឡើយ ។

៤-ប្រភេទ និងបរិមាណផល អនុផលព្រៃឈើអនុញ្ញាតឱ្យប្រមូល និងវិធីសាស្ត្រគណនាបរិមាណដែលអាចដកហូតបាន ។

៥-ការបរិយាយពីកាតព្វកិច្ចរបស់ព្រៃសម្បទានិកក្នុងការកសាង និងការអនុវត្តគម្រោងផែនការគ្រប់គ្រងព្រៃឈើកម្រិតព្រៃសម្បទាន ព្រៃគុប និងប្លុកប្រមូលផល ។

៦-ល័ក្ខខ័ណ្ឌផ្សេងទៀតដែលកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា ឬរដ្ឋបាលព្រៃឈើ ពាក់ព័ន្ធទៅនឹងព្រៃសម្បទាន ។

**មាត្រា១៧**

កិច្ចព្រមព្រៀងព្រៃសម្បទានមិនត្រូវកំណត់ឱ្យលើសពីរយៈពេលសាមសិប (៣០) ឆ្នាំឡើយ ។

កិច្ចព្រមព្រៀងព្រៃសម្បទានអាចបញ្ឈប់ នៅពេលណាដែលរាជរដ្ឋាភិបាលបានរកឃើញថាព្រៃសម្បទានិកបានរំលោភធ្ងន់ធ្ងរលើបណ្តាល័ក្ខខ័ណ្ឌដែលតម្រូវឱ្យបញ្ឈប់ ដូចមានចែងក្នុងអនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃសម្បទាន ។

ព្រៃសម្បទានិកមានសិទ្ធិស្នើសុំការពន្យល់ពីមូលហេតុនៃការសម្រេចលុបចោលកិច្ចព្រមព្រៀងព្រៃសម្បទានមុនកាលកំណត់ដោយរាជរដ្ឋាភិបាល ។ វិធានការដោះស្រាយវិវាទ ត្រូវស្របតាមល័ក្ខខ័ណ្ឌ ដូចមានចែងក្នុងកិច្ចព្រមព្រៀងព្រៃសម្បទាន និងច្បាប់ជាធរមាន ។

ដោយផ្អែកតាមការវាយតម្លៃលើការអនុវត្តរបស់ព្រៃសម្បទានិកដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជរដ្ឋាភិបាលអាចអនុគ្រោះបន្តកិច្ចព្រមព្រៀងបាន ហើយរយៈពេលបន្តនេះមិនត្រូវលើសពីរយៈពេលកំណត់ក្នុងកិច្ចព្រមព្រៀងព្រៃសម្បទានដំបូងឡើយ ។

**មាត្រា១៨**

ការរៀបចំផែនការគ្រប់គ្រងព្រៃសម្បទានគ្រប់កម្រិត ត្រូវទទួលខុសត្រូវដោយព្រៃសម្បទានិក តាមគោលការណ៍ណែនាំដែលមានចែងក្នុងក្បួនធ្វើផែនការគ្រប់គ្រងនៃព្រៃសម្បទាន

ក្រុមបច្ចេកទេសអនុវត្តប្រមូលព្រៃឈើនៅកម្ពុជា និងប្រការទាំងឡាយដែលមានចែងក្នុងកិច្ចព្រមព្រៀងព្រៃសម្បទាន។

ព្រៃសម្បទានិកត្រូវរៀបចំផែនការគ្រប់គ្រងព្រៃសម្បទានតាមកម្រិតដូចខាងក្រោម៖

១-ផែនការគ្រប់គ្រងរយៈពេលវែងសម្រាប់ព្រៃសម្បទានទាំងមូល។

២-ផែនការប្រមូលផល អនុផលព្រៃឈើ ប្រចាំសម្រាប់កម្រិតព្រៃគុបនីមួយៗ។

៣-ផែនការគ្រប់គ្រងប្លុកប្រមូលផលសម្រាប់ការប្រមូលផលប្រចាំឆ្នាំនីមួយៗ។

ផែនការគ្រប់គ្រងព្រៃសម្បទាន និងការសើរើត្រូវកំណត់តាមវិធានខាងក្រោម៖

១-ផែនការគ្រប់គ្រងព្រៃសម្បទានត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទតាមសំណើរបស់ប្រធានរដ្ឋបាលព្រៃឈើ។ ផែនការនេះត្រូវពិនិត្យសើរើរៀងរាល់ប្រាំ (៥) ឆ្នាំម្តង។

២-ផែនការប្រមូលផលកម្រិតព្រៃគុបប្រចាំឆ្នាំ និងផែនការគ្រប់គ្រងប្លុកប្រមូលផលត្រូវសម្រេចដោយប្រធានរដ្ឋបាលព្រៃឈើ។

**មាត្រា១៩**

ព្រៃសម្បទានទាំងអស់ត្រូវតែដាក់បញ្ចូលក្នុងផែនការគ្រប់គ្រងព្រៃសម្បទាននូវការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងលិខិតបទដ្ឋាននានាស្តីពីការគ្រប់គ្រងព្រៃសម្បទាន។

ការវាយតម្លៃហេតុប៉ះពាល់សង្គមលើព្រៃសម្បទានដែលជាផ្នែកមួយនៃផែនការគ្រប់គ្រងសម្បទានត្រូវរៀបចំដោយព្រៃសម្បទានិក និងវាយតម្លៃដោយក្រសួងបរិស្ថានមុននឹងសម្រេចយល់ព្រមដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវធានាការចូលរួមផ្តល់មតិជាសាធារណៈលើផែនការគ្រប់គ្រងព្រៃសម្បទាន និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គមមុនពេលការសម្រេចចេញលិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើ។

**ជំពូកទី៦ ការគ្រប់គ្រងព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន និងព្រៃការពារ**

**មាត្រា២០**

ព្រៃផ្តល់ផលក្រៅពីព្រៃសម្បទានត្រូវបានគ្រប់គ្រងដើម្បីបម្រើជាអាទិភាពនូវសេចក្តីត្រូវការផល អនុផលព្រៃឈើប្រចាំឆ្នាំក្នុងស្រុក ។

ផល អនុផលព្រៃឈើទាំងនេះអាចធ្វើការនាំចេញបាន នៅពេលណាដែលការផ្គត់ផ្គង់លើសពីតម្រូវការប្រើប្រាស់ក្នុងស្រុក ដោយមានការសម្រេចពីរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា២១**

ប្រធានផ្នែករដ្ឋបាលព្រៃឈើមានភារកិច្ចរៀបចំ និងដាក់ស្នើផែនការគ្រប់គ្រងព្រៃផ្តល់ផល ក្រៅពីព្រៃសម្បទានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ជូនប្រធានរដ្ឋបាលព្រៃឈើពិនិត្យសម្រេច ។ ដំណើរការរៀបចំផែនការគ្រប់គ្រងព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន ត្រូវប្រព្រឹត្តទៅតាមលំនាំផែនការគ្រប់គ្រងព្រៃសម្បទាន ដូចមានចែងក្នុងមាត្រា១៨ កថាខណ្ឌទី២នៃច្បាប់នេះ ។

រូបវន្តបុគ្គល នីតិបុគ្គល ឬសហគមន៍ណាមួយអាចដាក់ពាក្យដេញថ្លៃដើម្បីទទួលបាននូវសិទ្ធិប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ នៅក្នុងដែនព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន ក្រោមនីតិវិធីនៃការដេញថ្លៃជាសាធារណៈ ។

នីតិវិធីសម្រាប់ការទទួលបានសិទ្ធិប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ នៅក្នុងដែនព្រៃផ្តល់ផលក្រៅពីព្រៃសម្បទានត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា២២**

ផ្នែកណាមួយនៃព្រៃបម្រុងទុកអចិន្ត្រៃយ៍ដែលជាតំបន់មជ្ឈដ្ឋានពិសេស ឬមានតម្លៃផ្នែកវិទ្យាសាស្ត្រ វប្បធម៌ ទេសចរណ៍ ឬជាតំបន់អភិរក្សជីវៈចម្រុះ ទឹក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវលើកសំណើជូនរាជរដ្ឋាភិបាលដើម្បីដាក់ជាព្រៃការពារ ។

រាល់ការបង្កើត ឬការរំសាយព្រៃការពារត្រូវមានរបាយការណ៍ជូនរដ្ឋសភា និងព្រឹទ្ធសភា ។

**មាត្រា២៣**

រដ្ឋបាលព្រៃឈើត្រូវរៀបចំផែនការគ្រប់គ្រងព្រៃការពារនៃព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដែលសម្រេចដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ការអនុវត្តច្បាប់ព្រៃឈើ និងគ្រប់គ្រងសកម្មភាពប្រតិបត្តិក្នុងការរៀបចំគ្រប់គ្រង ការពារគ្រប់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ជាសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើគ្រប់ថ្នាក់។

**ជំពូកទី៧ អំពីលិខិតអនុញ្ញាត និងសិទ្ធិអំណាច**

**មាត្រា២៤**

ផល អនុផលព្រៃឈើទាំងអស់ដែលឋិតនៅក្នុង និងមានប្រភពចេញពីព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវចាត់ទុកជាសម្បត្តិរដ្ឋ លើកលែងតែសិទ្ធិលើផល អនុផលព្រៃឈើដែលត្រូវបានប្រគល់ដល់រូបវន្តបុគ្គល ឬនីតិបុគ្គលត្រឹមត្រូវតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

រូបវន្តបុគ្គល នីតិបុគ្គល ឬសហគមន៍ដែលមានបំណងប្រមូលផល អនុផលព្រៃឈើសម្រាប់គោលបំណងពាណិជ្ជកម្ម ត្រូវមានលិខិតអនុញ្ញាតប្រមូលផលព្រៃឈើ។

ការប្រមូលផល អនុផលព្រៃឈើដោយសមាជិកសហគមន៍មូលដ្ឋានដែលមានបរិមាណស្មើ ឬក្រោមបរិមាណបម្រើសេចក្តីត្រូវការសម្រាប់ការរស់នៅជាប្រពៃណី ដូចមានចែងក្នុងជំពូកទី៩នៃច្បាប់នេះមិនតម្រូវឱ្យមានលិខិតអនុញ្ញាតឡើយ។

**មាត្រា២៥**

រាល់សកម្មភាពលើសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ និងផល អនុផលព្រៃឈើនៅព្រះរាជាណាចក្រកម្ពុជាតម្រូវឱ្យមានលិខិតអនុញ្ញាតសំខាន់៧ ជាអាទិ៍ដូចខាងក្រោម៖

១-លិខិតកំណត់កូតាអនុញ្ញាតឱ្យប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ។

២-លិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើ។

៣-លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ។

៤-លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើ

៥-លិខិតអនុញ្ញាតប្រើប្រាស់ព្រៃឈើ។

៦-ប្រកាសស្តីពីការបង្កើតមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើ។

៧-លិខិតអនុញ្ញាតចូលព្រៃ ដើម្បីការងាររៀបចំព្រៃគុប។

៨-លិខិតអនុញ្ញាតបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើ។

៩-លិខិតអនុញ្ញាតបង្កើតឡគ្រប់ប្រភេទ ដែលប្រើប្រាស់ផល អនុផលព្រៃឈើជាវត្ថុធាតុដើម ។

១០-លិខិតកំណត់កូតាអនុញ្ញាតឱ្យនាំចេញផល អនុផលព្រៃឈើ

១១-លិខិតអនុញ្ញាតនាំចេញ នាំចូលផល អនុផលព្រៃឈើ ។

១២-លិខិតអនុញ្ញាតផ្សេងទៀតស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

លិខិតអនុញ្ញាតដូចមានចែងខាងលើត្រូវបានផ្តល់សិទ្ធិស្នើសុំចំពោះ៖

១-ព្រៃសម្បទានិក ដែលបានទទួលការឯកភាពលើផែនការប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ ដូចតម្រូវដោយកិច្ចព្រមព្រៀងព្រៃសម្បទាន ។

២-នីតិបុគ្គលដែលបានទទួលការឯកភាពលើការប្រមូលផល ក្នុងព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន ។

៣-សហគមន៍ដែលបានទទួលសិទ្ធិធ្វើការប្រមូលផលក្នុងព្រៃសហគមន៍ លើសពីកម្រិតប្រើប្រាស់ជាប្រពៃណី ក្រោមវិធានសហគមន៍ព្រៃឈើ ។

៤-បុគ្គល ឬអតិថិជនដែលដឹកជញ្ជូនផល អនុផលព្រៃឈើចេញពីតំបន់ព្រៃប្រមូលផលឆ្ពោះទៅទិសដៅកំណត់ ។

៥-រូបវន្តបុគ្គល នីតិបុគ្គល សហគមន៍ ឬអតិថិជនទូទៅដែលអាចទទួលសិទ្ធិស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

លិខិតអនុញ្ញាតក្រោមមាត្រានេះ ត្រូវសម្គាល់ដោយ៖

១-ឈ្មោះអ្នកកាន់លិខិតអនុញ្ញាត ។

២-រយៈពេលសុពលភាពនៃលិខិតអនុញ្ញាត ។

៣-ទីតាំង និងព្រំប្រទល់ជាក់លាក់នៃតំបន់ប្រមូលផល អនុផលព្រៃឈើ ។

៤-បរិមាណផល អនុផលព្រៃឈើដែលបានអនុញ្ញាតគិតជាឯកត្តា កំណត់ដោយរដ្ឋបាលព្រៃឈើ ។

៥-ប្រភព និងទិសដៅនៃការដឹកជញ្ជូនផល អនុផលព្រៃឈើ ។

៦-ចំណុចផ្សេងទៀតអាស្រ័យតាមប្រភេទលិខិតអនុញ្ញាតដែលកំណត់ដោយរដ្ឋបាលព្រៃឈើ។

លិខិតអនុញ្ញាតក្រោមមាត្រានេះអាចពន្យារពេលបន្តប្រើប្រាស់បាន ដោយផ្អែកលើរបាយការណ៍វាយតម្លៃពីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច។

គំរូឯកសារជាលាយលក្ខណ៍អក្សរសម្រាប់លិខិតអនុញ្ញាតនីមួយៗ ត្រូវកំណត់ជាផ្លូវការដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា២៦**

ការទទួលខុសត្រូវក្នុងការចេញលិខិតអនុញ្ញាតមានដូចតទៅ៖

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិអំណាចសម្រេចលើ៖

១-លិខិតកំណត់កូតាអនុញ្ញាតឱ្យប្រមូលផល អនុផលព្រៃឈើសម្រាប់ព្រៃសម្បទាន និងព្រៃផ្ដល់ផលក្រៅពីព្រៃសម្បទាន។

២-កូតាអនុញ្ញាតឱ្យនាំចេញ និងនាំចូលផល អនុផលព្រៃឈើយោងតាមសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល។

៣-លិខិតអនុញ្ញាតឱ្យប្រើប្រាស់ព្រៃឈើដូចមានចែងក្នុងមាត្រា២៧នៃច្បាប់នេះ។

៤-ប្រកាសស្ដីពីការបង្កើតមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ និងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទធំ និងមធ្យម។

ប្រធានរដ្ឋបាលព្រៃឈើមានសិទ្ធិអំណាចផ្ដល់៖

១-លិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើសម្រាប់ព្រៃសម្បទាន និងព្រៃផ្ដល់ផលក្រៅពីព្រៃសម្បទាន។

២-លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើចេញពីព្រៃសម្បទាន និងព្រៃផ្ដល់ផលក្រៅពីព្រៃសម្បទាន។

៣-លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើសម្រាប់នាំចេញ នាំចូល។

៤-លិខិតអនុញ្ញាតចូលព្រៃដើម្បីដំណើរការរៀបចំព្រៃគុបមុនពេលចេញលិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ។

៥-លិខិតអនុញ្ញាត ឬចុះទិដ្ឋាការលើអាជ្ញាប័ណ្ណនាំចេញ នាំចូលផល អនុផលព្រៃឈើ ។

នាយខណ្ឌរដ្ឋបាលព្រៃឈើមានសិទ្ធិអំណាចផ្តល់៖

១-លិខិតកំណត់កូតាអនុញ្ញាតឱ្យប្រមូលផលអនុផលព្រៃឈើសម្រាប់សហគមន៍មូលដ្ឋាន ។

២-លិខិតអនុញ្ញាតឱ្យបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើ និងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទតូច ។

៣-លិខិតអនុញ្ញាតឱ្យបង្កើតឡគ្រប់ប្រភេទដែលប្រើប្រាស់ផល អនុផលព្រៃឈើជាវត្ថុធាតុដើមមានលក្ខណៈឧស្សាហកម្ម ឬសិប្បកម្ម ។

៤-លិខិតអនុញ្ញាតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើចេញពីព្រៃសហគមន៍ ។

នាយផ្នែករដ្ឋបាលព្រៃឈើមានសិទ្ធិអំណាចផ្តល់៖

១-លិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើលើបរិមាណលើសពីសិទ្ធិប្រើប្រាស់ជាប្រពៃណីសម្រាប់សហគមន៍មូលដ្ឋានក្នុងព្រៃសហគមន៍ ។

២-រាល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើដែលមានប្រភពចេញពីតំបន់ដែនសមត្ថកិច្ចរបស់ផ្នែករដ្ឋបាលព្រៃឈើនោះ ។

**មាត្រា២៧**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិអំណាចចេញលិខិតអនុញ្ញាតប្រើប្រាស់ព្រៃឈើដល់រូបវន្តបុគ្គល នីតិបុគ្គលសម្រាប់ដំណើរការសកម្មភាពនៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដូចខាងក្រោម៖

១-ការសិក្សាស្រាវជ្រាវបច្ចេកទេស និងវិទ្យាសាស្ត្រ ។

២-ការអប់រំ និងការបណ្តុះបណ្តាលវិស័យកសិកម្ម ។

៣-ការប្រើប្រាស់ធនធានទឹក សម្រាប់ប្រព័ន្ធស្រោចស្រព ឬគោលបំណងកសិកម្មដោយមានការឯកភាពពីក្រសួងធនធានទឹក និងឧតុនិយម ។

៤-ការបង្កើតសួនរុក្ខជាតិ ឬស្ថានីយ៍ពិសោធន៍ ។

៥-ការបង្កើតថ្នាលកូនឈើត្រូវផ្ទេរ ។

៦-ការបង្កើនតំបន់សម្រាប់សម្រាកលំហែ ទស្សនាចរកំសាន្ត ឬការថតភាពយន្តឯកសារ ។

លិខិតអនុញ្ញាតឱ្យប្រើប្រាស់ព្រៃឈើនេះមិនត្រូវយកទៅប្រើ ដើម្បីប្រមូលផល អនុផលព្រៃឈើពីតំបន់ដែលបានកំណត់សម្រាប់សកម្មភាពខាងលើឡើយ លើកលែងតែការដកហូតសម្រាប់គោលបំណងស្រាវជ្រាវវិទ្យាសាស្ត្រ ឬ វប្បកម្មដើម្បីបង្កើនគុណភាពព្រៃឈើ ។

**ជំពូកទី៨ ការហាមឃាត់ការប្រមូលផល អនុផលព្រៃឈើ និងការការពារព្រៃឈើ**

**មាត្រា២៨**

រាល់ការផ្តល់ ឬបែងចែកព្រៃបម្រុងទុកអចិន្ត្រៃយ៍សម្រាប់ការប្រមូលផល អនុផលព្រៃឈើ ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ អាចប្រព្រឹត្តទៅបានតែក្នុងករណីព្រៃបម្រុងទុកអចិន្ត្រៃយ៍នោះជាប្រភេទព្រៃផ្តល់ផល និងមានសក្តានុពលផ្តល់ផលដែលការគ្រប់គ្រង និងត្រួតពិនិត្យត្រូវតែអនុវត្តតាមក្រុមបច្ចេកទេសអនុវត្តគ្រប់គ្រងព្រៃឈើកម្ពុជា ។

គ្មានបុគ្គលណាមានសិទ្ធិផ្តល់លិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើនៅក្នុងដែនព្រៃការពារគ្រប់ប្រភេទនៃព្រៃបម្រុងទុកអចិន្ត្រៃយ៍ឡើយ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចស្នើសុំរាជរដ្ឋាភិបាលកែប្រែដែនព្រៃការពារទៅជាដែនព្រៃផ្តល់ផល នៅពេលដែលរដ្ឋបាលព្រៃឈើបានផ្តល់ទិន្នន័យសិក្សាថ្មី ចំពោះព្រៃការពារណាមួយដែលអាចមានសក្តានុពលគ្រប់គ្រាន់សម្រាប់ដកហូតបើពុំនោះទេ ការប្រមូលផល អនុផលព្រៃឈើត្រូវហាមឃាត់ ។

**មាត្រា២៩**

លើកលែងតែមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមូលហេតុជាអាទិ៍លក្ខខ័ណ្ឌអាកាសធាតុមិនអំណោយផល ឈើ ចំណីផ្លូវដែលត្រូវសាងសង់ ដោយមានការអនុញ្ញាត ឬលក្ខខ័ណ្ឌឧបទ្ទវហេតុផ្សេងទៀត ដែលស្នើឡើងដោយរដ្ឋបាលព្រៃឈើ អនុផលព្រៃឈើ ដូចខាងក្រោមក្នុងព្រៃបម្រុងទុកអចិន្ត្រៃយ៍ត្រូវបានហាមឃាត់ ។

១-ប្រភេទឈើជាប់ក្នុងលំដាប់ថ្នាក់ ដែលមិនទាន់ដល់ទំហំអប្បបរមាអនុញ្ញាតឱ្យកាប់រំលំ ។

២-ប្រភេទឈើដែលមានដោយកម្រ ។

៣-ប្រភេទឈើដែលប្រជាជនមូលដ្ឋានចោះយកជ័រតាមប្រពៃណី ។

៤-ដើមឈើផ្តល់ជ័រមានតម្លៃ ។

ផល អនុផលព្រៃឈើដែលហាមឃាត់ដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា៣០**

ហាមឃាត់ការកែច្នៃផល អនុផលព្រៃឈើ ឬការបង្កើត និងដំណើរការមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ រោងចក្រកែច្នៃឈើ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើ និងឡគ្រប់ប្រភេទនៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។

គ្រប់មូលដ្ឋានកែច្នៃផល អនុផលព្រៃឈើ និងឡគ្រប់ប្រភេទត្រូវមានទីតាំងឋិតនៅចម្ងាយប្រាំ (៥) គីឡូម៉ែត្រយ៉ាងតិច ពីដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអាចធ្វើការលើកលែងការហាមឃាត់ដែលចែងក្នុងកថាខណ្ឌទី២នៃមាត្រានេះ ក្នុងករណីដែលរដ្ឋបាលព្រៃឈើសិក្សាឃើញថា ផលប្រយោជន៍នៃការលើកលែងនេះមិនមានផលប៉ះពាល់សង្គម បរិស្ថាន ឬមានផលប៉ះពាល់កម្រិតទាប ។

**មាត្រា៣១**

ការឈូសឆាយដីព្រៃក្នុងគោលបំណងស្ថាបនាផ្លូវសាធារណៈ ក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវបានហាមឃាត់ លើកលែងតែមានការសម្រេចពីរាជរដ្ឋាភិបាលតាមសំណើរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ការឈូសឆាយដីព្រៃក្នុងគោលបំណងស្ថាបនាផ្លូវព្រៃក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវបានហាមឃាត់ លើកលែងតែមានការសម្រេចពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមសំណើរបស់ប្រធានរដ្ឋបាលព្រៃឈើ ។

រាល់គម្រោងស្ថាបនាផ្លូវសាធារណៈ ឬផ្លូវព្រៃក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ត្រូវមានការពិគ្រោះយោបល់ជាមួយអាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋាន និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម ស្របតាមមាត្រា៤នៃច្បាប់នេះ ។

ការដាក់តាំងលំនៅឋានថ្មីតាមដងផ្លូវសាធារណៈ ឬផ្លូវព្រៃក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ត្រូវបានហាមឃាត់ លើកលែងតែមានការអនុញ្ញាតពីរាជរដ្ឋាភិបាល ។

*វាយឡើងវិញ*

**មាត្រា៣២**

ព្រៃឈើត្រូវបានការពារប្រឆាំងនឹងរាល់សកម្មភាព ដែលធ្វើឱ្យខូចខាតបណ្តាលមកពី ការធ្វើអាជីវកម្មហួសហេតុ ការកាប់រានដីព្រៃដោយរំលោភ ការបំពុលមជ្ឈដ្ឋានព្រៃឈើ ភ្លើងឆេះព្រៃ ការធ្វើចម្ការពនេចរ ជំងឺ សត្វល្អិតចង្រៃ និងការនាំចូលប្រភេទរុក្ខជាតិ និងសត្វរាតត្បាត។

សកម្មភាពដែលនាំឱ្យខូតខាតដល់ព្រៃឈើដែលត្រូវបានហាមឃាត់មានដូចជា៖

១-រំកិល ដកចេញ ឬបំផ្លាញគោលសីមា ឬសញ្ញាសម្គាល់សម្រាប់កំណត់ដែនព្រៃឈើ។

២-គ្រៀវ បំពុល កាប់បំផ្លាញ ផ្តួលរំលំដើមឈើ ឬគាស់រំលើង គល់ឈើដោយគ្មានការចាំបាច់ខាងបច្ចេកទេស។

៣-ប្រើសិទ្ធិប្រមូលផល អនុផលព្រៃឈើខុសពីសិទ្ធិដែលត្រូវបានទទួលស្គាល់ ឬអនុញ្ញាត។

៤-ប្រើប្រាស់មធ្យោបាយផ្សេងៗ លែង ឬចងសត្វពាហនៈ ក្នុងកន្លែងដែលមានកូនឈើដុះថ្មីក្រោយពេលអាជីវកម្ម ឬភ្លើងព្រៃ ឬក្នុងតំបន់ព្រៃកំពុងតែដាំ ឬទើបនឹងដាំ។

៥-បង្កើតមូលដ្ឋានកែច្នៃវល្លិរមៀត ឬអនុផលព្រៃឈើផ្សេងទៀតដែលនាំមកនូវការបំពុល ឬបំផ្លាញមជ្ឈដ្ឋានព្រៃឈើ។

**មាត្រា៣៣**

រាល់សកម្មភាពកាប់រានដីព្រៃក្នុងព្រៃបម្រុងទុកអចិន្ត្រៃយ៍ត្រូវបានហាមឃាត់ លើកលែងតែករណីដែលមានចែងក្នុងមាត្រា៣១ មាត្រា៣៥ និងមាត្រា៣៧នៃច្បាប់នេះ។

**មាត្រា៣៤**

ការនាំចេញ នាំចូលគ្រាប់ពូជរុក្ខជាតិព្រៃ ឬប្រភេទរុក្ខជាតិព្រៃត្រូវឆ្លងកាត់ការសិក្សាស្រាវជ្រាវ វាយតម្លៃពីរដ្ឋបាលព្រៃឈើ និងត្រូវមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ការនាំចូលគ្រាប់ពូជរុក្ខជាតិព្រៃគ្រប់ប្រភេទ ត្រូវមានវិញ្ញាបនបត្រគ្រាប់ពូជដែលបញ្ជាក់ដោយអាជ្ញាធរវិទ្យាសាស្ត្ររបស់ប្រទេសនាំចេញ។

**មាត្រា៣៥**

បន្ថែមលើច្បាប់ដទៃទៀតដែលពាក់ព័ន្ធនឹងការយកថ្ម ដី ខ្សាច់ រ៉ែ និងធនធានធម្មជាតិដទៃទៀតដែលត្រូវអនុវត្តក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវមានការសិក្សាវាយតម្លៃជាមុនពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងទទួលការអនុញ្ញាតពីរាជរដ្ឋាបាលដោយត្រូវអនុវត្តតាមមាត្រា៤នៃច្បាប់នេះ ។

ការអនុញ្ញាតនេះត្រូវកម្រិតផងដែរនូវវិធានការការពារ និងស្តារឡើងវិញនៅទីកន្លែងគាស់កកាយយកថ្ម ដី ខ្សាច់ រ៉ែ និងធនធានធម្មជាតិដទៃទៀត ដែលអ្នកទទួលសិទ្ធិត្រូវទទួលបន្ទុកដើម្បី៖

១-ចៀសវាងបង្ក ឬធ្វើឱ្យធ្ងន់ធ្ងរដល់ការហូរចេញច្រោះបាក់ដី ឬធ្វើឱ្យខូតខាតដល់ការលូតលាស់របស់រុក្ខជាតិ ឬធ្វើឱ្យខូតខាតដល់ប្រព័ន្ធជលសាស្ត្រ និងគុណភាពទឹក ។

២-រៀបចំស្តារទីតាំងនោះឱ្យមានសភាពដូចដើមវិញ ក្រោយពេលបញ្ចប់កិច្ចការគាស់កកាយយកថ្ម ដី ខ្សាច់ រ៉ែ និងធនធានធម្មជាតិដទៃ ទៀតក្នុងរយៈពេលដែលលិខិតអនុញ្ញាតបានតំណត់ ។

**មាត្រា៣៦**

ហាមបង្កភ្លើងឆេះព្រៃក្នុងដែនសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ។ ការប្រើប្រាស់ភ្លើងអាចអនុគ្រោះ ចំពោះរដ្ឋបាលព្រៃឈើដើម្បីផលប្រយោជន៍រុក្ខវប្បកម្ម ឬអនាម័យព្រៃ ។

គោលការណ៍ណែនាំក្នុងការកំណត់តំបន់ត្រួតពិនិត្យភ្លើងឆេះព្រៃ ការការពារភ្លើងឆេះព្រៃ និងការបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងភ្លើងឆេះព្រៃសម្រាប់ជាវិធានការអនុវត្តគ្រប់តំបន់ព្រៃឈើ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ប្រជាពលរដ្ឋ កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរដែនដីគ្រប់ថ្នាក់ត្រូវមានករណីកិច្ចទទួលខុសត្រូវ ថែរក្សា ការពារព្រៃឈើ បង្ការ និងប្រយុទ្ធនឹងភ្លើងឆេះព្រៃ ។

**មាត្រា៣៧**

សហគមន៍មូលដ្ឋាន ដែលប្រកបរបរចម្ការពនេចរមានលក្ខណៈប្រពៃណី អាចអនុវត្តលើដីកម្មសិទ្ធិសហគមន៍ជនជាតិភាគតិចដែលបានចុះបញ្ជិការួចហើយជាមួយរដ្ឋ។ ផ្នែករដ្ឋបាលព្រៃឈើនៃមូលដ្ឋាននេះ ត្រូវផ្តល់ការអនុញ្ញាតការគ្រប់គ្រង និងការត្រួតពិនិត្យនៃសកម្មភាពនេះដែលជា

ផ្នែកមួយនៃផែនការគ្រប់គ្រងព្រៃសហគមន៍នោះ ។ ការអនុវត្តចម្ការពនេចរ ត្រូវហាមឃាត់ចំពោះព្រៃធម្មជាតិមិនទាន់ប៉ះពាល់ក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។

ដីព្រៃឈើដែលរៀបចំបម្រុងសម្រាប់ចម្ការពនេចរត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា៣៨**

ការអារច្រៀក និងការចាំងឈើមូលនៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវបានហាមឃាត់ ។

ការប្រើប្រាស់រណារយន្តជាមធ្យោបាយប្រមូលផលព្រៃឈើ នៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវបានហាមឃាត់ លើកលែងតែមានលិខិតអនុញ្ញាតប្រើប្រាស់ចេញដោយរដ្ឋបាលព្រៃឈើ ។

**មាត្រា៣៩**

គ្មានរូបវន្តបុគ្គលណាមួយមានសិទ្ធិផ្តល់ការអនុញ្ញាត ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ឱ្យកាប់ដើមឈើ ឬធ្វើសកម្មភាពគ្រប់យ៉ាងដើម្បីប្រមូលផល អនុផលព្រៃឈើ ឬកាន់កាប់ដីក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះឡើយ ។

**ជំពូកទី៩ សិទ្ធិប្រើប្រាស់ជាប្រពៃណី ការគ្រប់គ្រងព្រៃសហគមន៍ និងព្រៃឯកជន**

**មាត្រា៤០**

ចំពោះសហគមន៍មូលដ្ឋានរស់នៅក្នុង ឬក្បែរដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ រដ្ឋត្រូវទទួលស្គាល់ និងធានាសិទ្ធិប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍មូលដ្ឋាននោះ សម្រាប់គោលបំណងទំនៀមទម្លាប់ ជំនឿ សាសនា និងការរស់នៅដូចមានចែងក្នុងមាត្រានេះ ។

សិទ្ធិប្រើប្រាស់ជាប្រពៃណីលើផល អនុផលព្រៃឈើដោយសហគមន៍មូលដ្ឋាន មិនតម្រូវឱ្យមានលិខិតអនុញ្ញាតប្រមូលផលឡើយ ។ សិទ្ធិប្រើប្រាស់ជាព្រៃណីក្រោមមាត្រានេះរួបមាន៖

១-ការរើសប្រមូលឈើងាប់ ការបេះផ្លែឈើព្រៃ ការរុករកឃ្មុំ ការចោះយកជ័រ និងរុករកអនុផលព្រៃឈើដទៃទៀតទាំងអស់ ។

២-ការប្រើប្រាស់ឈើមកសង់លំនៅឋាន ក្រោលសត្វ របង និងសម្រាប់ធ្វើឧបករណ៍កសិកម្ម ។

៣-ការច្រូតយកស្មៅ ឬលែងសត្វពាហនៈឱ្យស៊ីស្មៅក្នុងព្រៃ។

៤-ការប្រើប្រាស់ផល អនុផលព្រៃឈើផ្សេងទៀតស្របតាមការប្រើប្រាស់ជាប្រពៃណី ជាលក្ខណៈគ្រួសារ។

៥-សិទ្ធិដោះដូរ ឬលក់អនុផលព្រៃឈើដោយពុំចាំបាច់មានលិខិតអនុញ្ញាត ប្រសិនបើការលក់ដូរនេះមិនគំរាមកំហែងដល់និរន្តរភាពព្រៃឈើ។ អតិថិជន ឬភាគីទីបីណាមួយដែលបានប្រមូលទិញអនុផលព្រៃឈើទាំងនោះពីសហគមន៍មូលដ្ឋាន ក្នុងគោលដៅពាណិជ្ជកម្មស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ អាចធ្វើការដឹកជញ្ជូនទៅកាន់បានដោយតម្រូវឱ្យមានលិខិតអនុញ្ញាតដឹកជញ្ជូន ក្រោយពេលបានបង់ថ្លៃសួយសារ និងបុព្វលាភលើអនុផលព្រៃឈើទាំងនោះរួច។

សហគមន៍មូលដ្ឋានមិនអាចផ្ទេរសិទ្ធិប្រើប្រាស់ជាប្រពៃណីឱ្យទៅភាគីទីបីបានឡើយ ទោះបីជាមានកិច្ចព្រមព្រៀងទៅវិញមកក្ដី ឬឋិតក្រោមកិច្ចសន្យាក្ដី។ សិទ្ធិប្រើប្រាស់ជាប្រពៃណីត្រូវ៖

១-ស្របតាមលំនឹងធម្មជាតិ មាននិរន្តរភាពចំពោះធនធានព្រៃឈើ និងគោរពសិទ្ធិអ្នកដទៃ។

២-ស្របតាមការអនុញ្ញាត និងការហាមឃាត់ ដែលកំណត់ដោយបទប្បញ្ញត្តិនៃច្បាប់នេះ។

**មាត្រា៤១**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិប្រគល់ផ្នែកណាមួយនៃព្រៃបម្រុងទុកអចិន្ត្រៃយ៍ឱ្យទៅសហគមន៍ដែលរស់នៅក្នុង ឬជិតតំបន់ព្រៃឈើ ក្រោមរូបភាពជាព្រៃសហគមន៍។

**មាត្រា៤២**

ខណ្ឌរដ្ឋបាលព្រៃឈើ តាមរយៈដំណើរការពិគ្រោះយោបល់ជាមួយសមត្ថកិច្ចពាក់ព័ន្ធដទៃទៀត មានភារកិច្ចសិក្សារៀបចំព្រៃបម្រុងទុកអចិន្ត្រៃយ៍ដើម្បីបង្កើតជាព្រៃសហគមន៍ ដោយកំណត់ព្រំប្រទល់ច្បាស់លាស់ និងមានទំហំសមស្របផ្អែកតាមលទ្ធភាពធនធានព្រៃឈើ និងតម្រូវការប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍។

នាយខណ្ឌរដ្ឋបាលព្រៃឈើមានសិទ្ធិសម្រេចចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ ជាមួយសហគមន៍មូលដ្ឋានណាមួយដែលរស់នៅក្នុង ឬក្បែរដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍។ កិច្ចព្រមព្រៀងនេះ ត្រូវមានសុពលភាពមិនលើសពីរយៈពេលដប់ប្រាំ (១៥) ឆ្នាំ តែអាចពន្យារបាន ដោយផ្អែកលើរបាយការណ៍ពិនិត្យ និងវាយតម្លៃឡើងវិញរបស់ថ្នាក់ផ្នែករដ្ឋបាលព្រៃឈើ។

**មាត្រា៤៣**

ព្រៃសហគមន៍ត្រូវបានគ្រប់គ្រងក្នុងលក្ខណៈសេដ្ឋកិច្ច និងដោយធានានិរន្តរភាពដោយសហគមន៍មូលដ្ឋាន ស្របតាមផែនការគ្រប់គ្រងព្រៃសហគមន៍ វិធានសហគមន៍ព្រៃឈើ និងគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ។

រដ្ឋបាលព្រៃឈើត្រូវផ្តល់ជំនួយបច្ចេកទេសតាមការស្នើសុំរបស់សហគមន៍មូលដ្ឋាន និងត្រូវតាមដានត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍។

ផែនការគ្រប់គ្រងព្រៃសហគមន៍ត្រូវរៀបចំដោយសហគមន៍មូលដ្ឋាន និងមានការយល់ព្រម ដោយថ្នាក់ខណ្ឌរដ្ឋបាលព្រៃឈើ។

ផែនការនេះនឹងត្រូវផ្ញើជូនទៅថ្នាក់កណ្តាលរដ្ឋបាលព្រៃឈើ និងត្រូវត្រួតពិនិត្យឡើងវិញជារៀងរាល់ប្រាំ (៥) ឆ្នាំម្តង ឬមុនពេលកំណត់ក្នុងករណីចាំបាច់។

ទោះបីព្រៃសហគមន៍ត្រូវបានដាំដុះ ឬដុះដោយធម្មជាតិក៏ដោយ ក៏ការគ្រប់គ្រងត្រូវអនុវត្តតាមផែនការគ្រប់គ្រងព្រៃសហគមន៍ និងក្រោមការឧបត្ថម្ភផ្នែកបច្ចេកទេស និងត្រួតពិនិត្យបច្ចេកទេសដោយរដ្ឋបាលព្រៃឈើ។

វិធានសម្រាប់ការបង្កើតការគ្រប់គ្រង និងការប្រើប្រាស់ព្រៃសហគមន៍ត្រូវកំណត់ដោយអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ។

គោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៤៤**

សហគមន៍មូលដ្ឋានដែលដំណើរការក្រោមកិច្ចព្រមព្រៀងព្រៃសហគមន៍ មានសិទ្ធិប្រមូលផល អនុផលព្រៃឈើ នៅក្នុងដែនព្រៃឈើស្របតាមផែនការគ្រប់គ្រងសហគមន៍ដែលបានកំណត់ព្រំប្រទល់ជូន ដូចមានចែងក្នុងកិច្ចព្រមព្រៀងព្រៃសហគមន៍។

សហគមន៍មូលដ្ឋាន មិនអាចយកព្រៃសហគមន៍ទៅប្រើប្រាស់ក្រោមរូបភាពព្រៃសម្បទាន ឬលក់ ដូរ ឬផ្ទេរសិទ្ធិលើព្រៃឈើនោះឱ្យភាគីទីបីបានឡើយ។

**មាត្រា៤៥**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវទទួលស្គាល់ព្រៃពាក់ព័ន្ធជំនឿសាសនារបស់សហគមន៍មូលដ្ឋានដែលរស់នៅក្នុង ឬក្បែរព្រៃនោះទុកជាព្រៃការពារសម្រាប់គោលបំណងសាសនា វប្បធម៌ ឬការអភិរក្ស។ ដើមឈើជំនឿសាសនាអាចត្រូវបានសម្គាល់ ជាពិសេស មិនអនុញ្ញាតឱ្យកាប់រំលំ និងត្រូវកំណត់ក្នុងផែនការការគ្រប់គ្រងព្រៃសហគមន៍។

**មាត្រា៤៦**

បុគ្គលដែលបានដាំដើមឈើលើដីកម្មសិទ្ធិឯកជនផ្ទាល់ ឬលើដីព្រៃរបស់រដ្ឋដែលបានប្រគល់សិទ្ធិប្រើប្រាស់ មានសិទ្ធិថែរក្សា អភិវឌ្ឍ ប្រើប្រាស់ លក់ និងចែកចាយផលិតផលរបស់ខ្លួនបាន។

វិធានស្តីពីព្រៃឯកជនត្រូវកំណត់ដោយ ប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីជំរុញលើកទឹកចិត្តដល់បុគ្គលក្នុងការដាំដុះ និងថែទាំចម្ការព្រៃឈើ។

**មាត្រា៤៧**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអាចផ្តល់ជូនបុគ្គល និងសហគមន៍ដែលអនុវត្តការគ្រប់គ្រងព្រៃឈើ ឬដាំដើមឈើដែលសម្រេចបាននូវបរិមាណ និងគុណភាពខ្ពស់នូវប្រព័ន្ធលើកទឹកចិត្តទៅតាមវិធានមានជាអាទិ៍

១-ប្រគល់លិខិតសរសើរ ប័ណ្ណសរសើរ និងប្រគល់គ្រឿងឥស្សរិយយស។

២-ផ្តល់ជំនួយអភិវឌ្ឍន៍ដោយផ្ទាល់ក្រោមកិច្ចសហប្រតិបត្តិការអន្តរជាតិ។

៣-ពន្យាររយៈពេលកិច្ចព្រមព្រៀងសម្រាប់ព្រៃសហគមន៍។

៤-ផ្សព្វផ្សាយពីសកម្មភាពមានស្នាដៃ។

## ជំពូកទី១០ ការអភិរក្សសត្វព្រៃ

### មាត្រា៤៨

ពពួកសត្វព្រៃគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជាគឺជាសម្បត្តិរបស់រដ្ឋ និងសមាសភាគនៃធនធានព្រៃឈើដែលរួមមាន៖ ពពួកថនិកសត្វ បក្សីសត្វ ឧរង្គសត្វ ថលជលិកសត្វ បាណកសត្វ និងសត្វឥតឆ្អឹងកងផ្សេងទៀត ព្រមទាំងពង កូនរបស់វា។

ពពួកសត្វព្រៃទាំងអស់នេះឋិតនៅក្រោមការគ្រប់គ្រងការសិក្សាស្រាវជ្រាវ និងការអភិរក្សដោយរដ្ឋបាលព្រៃឈើ ដោយមិនរាប់បញ្ចូលត្រី និងសត្វបង្កកំណើតក្នុងទឹក។

សំណាកសត្វព្រៃគឺជាសត្វព្រៃដែលស្លាប់ ទោះជានៅខ្លួនទាំងមូលសរីរាង្គក្នុង សរីរាង្គក្រៅ បំណែកឆ្អឹង ឬផលិតផលកែច្នៃត្រូវឋិតក្រោមសិទ្ធិគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើ។

គ្រប់ប្រភេទសត្វព្រៃទាំងអស់ត្រូវបានបែងចែកជាបីក្រុមគឺ៖

១-ក្រុមប្រភេទជិតផុតពូជ។

២-ក្រុមប្រភេទមានដោយកម្រ។

៣-ក្រុមប្រភេទមានដោយបង្គួរ។

លក្ខណវិនិច្ឆ័យសម្រាប់ចាត់ថ្នាក់ក្រុមនីមួយៗ និងបញ្ជីឈ្មោះប្រភេទសត្វក្នុងក្រុមប្រភេទជិតផុតពូជ និងប្រភេទមានដោយកម្រដែលអាចប្រែប្រួលទៅតាមតំបន់ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមសំណើរបស់រដ្ឋបាលព្រៃឈើដោយមានការពិគ្រោះយោបល់ជាមួយក្រសួងបរិស្ថាន។

### មាត្រា៤៩

ហាមឃាត់ដាច់ខាតរាល់សកម្មភាពបរបាញ់ យាយី បំផ្លិចបំផ្លាញសត្វព្រៃគ្រប់ប្រភេទដោយ៖

១-ការប្រើប្រាស់មធ្យោបាយបង្កគ្រោះថ្នាក់គ្រប់ប្រភេទ។

២-ការប្រមាញ់ក្នុងរដូវកាលហាមឃាត់។

៣-ការប្រមាញ់ក្នុងតំបន់ការពារ និងទីសាធារណៈពិសេស។

ដោយមានការឯកភាពពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋបាលព្រៃឈើមានសិទ្ធិចេញលិខិតអនុញ្ញាតចំពោះប្រភេទសត្វក្នុងក្រុម ប្រភេទជិតផុតពូជ និងក្រុមប្រភេទមានដោយកម្រសម្រាប់គោលបំណងដូចខាងក្រោម៖

១-ការសិក្សាអប់រំ ឬការស្រាវជ្រាវវិទ្យាសាស្ត្រ ។

២-ការគាំទ្រដល់កម្មវិធីនៃការចាប់បង្កាត់ពូជ ។

៣-ការផ្លាស់ប្តូរប្រភេទសត្វ អនុលោមតាមកិច្ចព្រមព្រៀងសហប្រតិបត្តិការអន្តរជាតិ ។

រាល់ការធ្វើសកម្មភាពដូចខាងក្រោម ចំពោះប្រភេទសត្វក្នុងក្រុមប្រភេទជិតផុតពូជ និងក្រុមប្រភេទមានដោយកម្រ ត្រូវហាមឃាត់៖

១-ការឃាយី ឬបំផ្លិចបំផ្លាញដល់ប្រភេទសត្វខាងលើ និងជម្រករបស់ប្រភេទសត្វទាំងនេះ ។

២-ការបរបាញ់ ទាក់ចាប់ ដាក់អង្គុប បំពុល ។

៣-ការយកធ្វើជាកម្មសិទ្ធិ សន្និធិ ឬថែរក្សាជាលក្ខណៈសួនសត្វ ឬគ្រួសារ ។

៤-ការដឹកជញ្ជូន ។

៥-ការធ្វើពាណិជ្ជកម្ម ។

៦-ការនាំចេញ នាំចូល ។

វិធាននៃការធ្វើសកម្មភាពចំពោះសត្វព្រៃគ្រប់ប្រភេទ ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ។

**មាត្រា៥០**

រាល់ការធ្វើសកម្មភាពដូចខាងក្រោម ចំពោះប្រភេទសត្វក្នុងក្រុមប្រភេទមានដោយបង្គួរ ត្រូវហាមឃាត់ លើកលែងតែមានលិខិតអនុញ្ញាតចេញដោយរដ្ឋបាលព្រៃឈើ៖

១-ការធ្វើសិន្នធិ ការថែរក្សាជាលក្ខណៈសួនសត្វ ឬគ្រួសារ ។

២-ការដឹកជញ្ជូន និងធ្វើពាណិជ្ជកម្មលើសពីបរិមាណចាំបាច់សម្រាប់ការប្រើប្រាស់ជាប្រពៃណី ។

ការនាំចេញ នាំចូលប្រភេទសត្វព្រៃក្នុងក្រុមប្រភេទមានដោយបង្គួរ ត្រូវមានលិខិតអនុញ្ញាត ចេញដោយរដ្ឋបាលព្រៃឈើដោយមានការឯកភាពពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា៥១**

រដ្ឋបាលព្រៃឈើត្រូវប្រមូលប្រាក់ចំណូលអភិរក្សសត្វព្រៃ និងប្រាក់សួយសារសត្វព្រៃដូចខាងក្រោម៖

១-ប្រាក់ចំណូលអភិរក្សសត្វព្រៃត្រូវបង់ចូលមូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិ ។

២-ប្រាក់សួយសារសត្វព្រៃត្រូវបង់ចូលថវិកាជាតិ ។

ប្រាក់ចំណូលអភិរក្សសត្វព្រៃ និងប្រាក់សួយសារសត្វព្រៃត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ជំពូកទី១១ ថ្លៃសួយសារ និងបុព្វលាភលើផល អនុផលព្រៃឈើ**

**មាត្រា៥២**

លើកលែងតែករណីដូចមានចែងក្នុងមាត្រា៥៣នៃច្បាប់នេះ រូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រមូលផល អនុផលព្រៃឈើសម្រាប់គោលដៅពាណិជ្ជកម្មលើព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវបង់ថ្លៃសួយសារ និងបុព្វលាភចូលថវិកាជាតិតាមរយៈរដ្ឋបាលព្រៃឈើ ។

រាជរដ្ឋាភិបាលត្រូវកំណត់ថ្លៃសួយសារ និងបុព្វលាភ ផ្អែកតាមសំណើរួមរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

រដ្ឋមិនតម្រូវឱ្យបង់ថ្លៃសួយសារ និងបុព្វលាភី សម្រាប់ការប្រមូលផល អនុផលព្រៃឈើលើព្រៃឯកជនឡើយ ។

គំរូកិច្ចព្រមព្រៀងព្រៃសម្បទាន ត្រូវបញ្ចូលនូវតារាងនៃថ្លៃសួយសារ និងបុព្វលាភលើផល អនុផលព្រៃឈើ ។

**មាត្រា៥៣**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអាចបន្ថយ ឬមិនយកថ្លៃសួយសារ និងបុព្វលាភលើផល អនុផលព្រៃឈើដែលប្រមូលពីព្រៃឈើរដ្ឋសម្រាប់គោលបំណងវិទ្យាសាស្ត្រ ឬដើម្បីបង្កើនការលើកទឹកចិត្តសេដ្ឋកិច្ចចំពោះការប្រើប្រាស់អស់លទ្ធភាពលើផលិតផល ។

រដ្ឋមិនយកថ្លៃសួយសារ និងបុព្វលាភពីសហគមន៍មូលដ្ឋានលើផល អនុផលព្រៃឈើដែលប្រមូលដោយសហគមន៍មូលដ្ឋានសម្រាប់សិទ្ធិប្រើប្រាស់ជាប្រពៃណី ឬប្រមូលពីព្រៃសហគមន៍ក្រោមកិច្ចព្រមព្រៀងព្រៃសហគមន៍ឡើយ ។

**មាត្រា៥៤**

រាល់ផល អនុផលព្រៃឈើត្រូវវាយតម្លៃដោយមន្ត្រីរដ្ឋបាលព្រៃឈើលើបរិមាណ និងគុណភាពនៅគំនរក្នុងព្រៃគុបប្រចាំឆ្នាំមុនពេលដឹកចេញពីព្រៃ។

គុណភាព និងបរិមាណនៃផល អនុផលព្រៃឈើដែលបានវាយតម្លៃរួចត្រូវចុះក្នុងកំណត់ហេតុបញ្ជីសៀវភៅ ក ដោយមានការឯកភាពពីប្រធានរដ្ឋបាលព្រៃឈើ។

**មាត្រា៥៥**

រាល់ផល អនុផលព្រៃឈើដែលបានចុះក្នុងកំណត់ហេតុបញ្ជីសៀវភៅ ក ត្រូវបង់ប្រាក់ថ្លៃសួយសារ និងបុព្វលាភ។

វិធាននៃការបង់ និងទទួលប្រាក់ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើ ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា៥៦**

អ្នកកាន់កាប់លិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើមិនអាចផ្ទេរ ឬលក់សិទ្ធិលើផល អនុផលព្រៃឈើទៅឱ្យបុគ្គលណាមួយផ្សេងទៀតបានឡើយ លុះត្រាតែខ្លួនបានបង់ថ្លៃសួយសារ និងបុព្វលាភលើផល អនុផលព្រៃឈើនោះរួច។

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចសម្រេចឱ្យមានការពន្យារពេលការបង់ថ្លៃសួយសារ និងបុព្វលាភលើផល អនុផលព្រៃឈើចំពោះអ្នកកាន់កាប់លិខិតអនុញ្ញាតដែលបានទទួលស្គាល់ ដោយរដ្ឋបាលព្រៃឈើថា បានអនុវត្តការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។ ការពន្យារនេះត្រូវផ្អែកតាមវិធាន និងគោលការណ៍ណែនាំស្របតាមមាត្រា៥៥ កថាខណ្ឌទី២នៃច្បាប់នេះ។

**មាត្រា៥៧**

ប្រសិនបើអ្នកកាន់កាប់លិខិតអនុញ្ញាតមិនបានបង់ថ្លៃសួយសារ និងបុព្វលាភតាមកម្មវិធីពេលវេលាកំណត់ទេនោះរដ្ឋបាលព្រៃឈើមានសិទ្ធិដកហូតយកផល អនុផលព្រៃឈើទាំងនោះដោយគ្មានល័ក្ខខ័ណ្ឌ និងឃាត់ទុកផល អនុផលព្រៃឈើទាំងនោះថែរក្សាជាកម្មសិទ្ធិរបស់រដ្ឋដដែល រហូតដល់មានដំណោះស្រាយវិវាទនេះតាមផ្លូវច្បាប់។

**មាត្រា៥៨**

មុនពេលចេញលិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើ អ្នកស្នើសុំលិខិតអនុញ្ញាត នោះត្រូវបង់ប្រាក់តម្កល់ដើម្បីធានាការបង់ថ្លៃសួយសារ និងបុព្វលាភចូលថវិកាជាតិ។ បរិមាណប្រាក់តម្កល់ត្រូវកំណត់ក្នុងកិច្ចព្រមព្រៀងព្រៃសម្បទាន ឬក្នុងលិខិតកំណត់កូតាអនុញ្ញាតឱ្យប្រមូលផលអនុផលព្រៃឈើប្រចាំឆ្នាំ។

ការប្រមូលផល អនុផលព្រៃឈើលើព្រៃសហគមន៍ ក្រោមកិច្ចព្រមព្រៀងព្រៃសហគមន៍ មិនតម្រូវឱ្យមានការបង់ប្រាក់តម្កល់នោះឡើយ។

**ជំពូកទី១២ ការដាំដើមឈើឡើងវិញ និងមូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិ**

**មាត្រា៥៩**

ប្រជាពលរដ្ឋ កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរដែនដីគ្រប់ថ្នាក់មានករណីយកិច្ចចូលរួមដាំដើមឈើ និងដាំដើមឈើឡើងវិញ។

ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការដាំដើមឈើ និងដាំដើមឈើឡើងវិញត្រូវបានលើកទឹកចិត្តដោយរាជរដ្ឋាភិបាលតាមរយៈចលនារបស់សហគមន៍ និងអង្គការសង្គមផ្សេងៗទៀត។

រដ្ឋបាលព្រៃឈើត្រូវមានវិធានការសមស្រប ក្នុងការអភិវឌ្ឍព្រៃឈើតាមរយៈការផ្សព្វផ្សាយ ការអប់រំ ការបំផុសដល់បុគ្គលសហគមន៍ និងមហាជនឱ្យដាំដើមឈើ និងការពារព្រៃឈើដោយផ្ដល់នូវជំនួយការបច្ចេកទេសចាំបាច់។

**មាត្រា៦០**

ដើម្បីជំរុញការអប់រំប្រជាពលរដ្ឋឱ្យយល់ពីសារៈសំខាន់ និងផលប្រយោជន៍នៃព្រៃឈើ ទិវាពលកម្មដាំដើមឈើជាប្រពៃណីជាតិហៅថារុក្ខទិវា ត្រូវប្រារព្ធធ្វើឡើងនៅថ្ងៃទី៩ ខែកក្កដា ជារៀងរាល់ឆ្នាំ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ឬព្រះរាជតំណាង។

ប្រជាពលរដ្ឋទាំងពីរភេទដែលជាគូស្រករថ្មី ត្រូវបានលើកទឹកចិត្តដាំដើមឈើពីរដើមក្រោមកិច្ចសម្របសម្រួល និងផ្ដល់កូនឈើដោយមន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច។

រាជរដ្ឋាភិបាលត្រូវកំណត់សួនសម្រាប់ជូនថ្នាក់ដឹកនាំជាន់ខ្ពស់ជាតិ និងអន្តរជាតិដាំដើមឈើ ដើម្បីទុកជាអនុស្សាវរីយ៍។

**មាត្រា៦១**

ការដាំដើមឈើនៅលើដីព្រៃរបស់រដ្ឋអាចធ្វើឡើងដោយរដ្ឋបាលព្រៃឈើផ្ទាល់ សហគមន៍ព្រៃឈើ ឬដោយមានការចូលរួមពីប្រជាពលរដ្ឋ តាមរយៈការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋ។ ការដាំដើមឈើនៅលើដីកម្មសិទ្ធិឯកជនអាចធ្វើឡើងបាន ដោយសិទ្ធិវន្តស្របតាមវិធានព្រៃឯកជនដូចមានចែងក្នុងមាត្រា៤៦នៃច្បាប់នេះ។

វិធាននៃការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ការដាំដើមឈើ ត្រូវកំណត់ដោយអនុក្រឹត្យ។ វិធាន និងបទបញ្ជាទាំងនេះត្រូវគិតពីសក្តានុពល ហេតុប៉ះពាល់សង្គមនៃប្រភេទឈើដែលត្រូវជ្រើសរើសសម្រាប់ការដាំនោះ។

**មាត្រា៦២**

រាជរដ្ឋាភិបាលត្រូវបង្កើតមូលនិធិមួយហៅថា មូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិ គ្រប់គ្រង ចាត់ចែង និងទទួលខុសត្រូវដោយគណៈកម្មាធិការអភិវឌ្ឍន៍ព្រៃឈើ ដែលមានរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាសហប្រធាន។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការអភិវឌ្ឍន៍ព្រៃឈើជាតិត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៦៣**

មូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិមានប្រភពចំណូលមកពី៖

១-វិភាគទានផ្សេងៗរបស់រាជរដ្ឋាភិបាល

២-បុព្វលាភលើផល អនុផលព្រៃឈើ។

៣-ប្រាក់ចំណូលអភិរក្សសត្វព្រៃ។

៤-ជំនួយរបស់អង្គការអន្តរជាតិនានា។

៥-អំណោយពីសប្បុរសជាតិ និងអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ។

៦-កម្រៃសេវាផ្សេងៗពីវិស័យព្រៃឈើ។

រាល់ចំណូលខាងលើ ត្រូវបញ្ចូលក្នុងគណនីមូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិ។

**មាត្រា៦៤**

មូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិមិនអាចត្រូវយកទៅប្រើប្រាស់សម្រាប់ការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋបាលព្រៃឈើបានឡើយ។ មូលនិធិនេះសម្រាប់ប្រើប្រាស់ចំពោះតែសកម្មភាពនេះ៖

១-ការដាំដើមឈើឡើងវិញ។

២-កិច្ចការរុក្ខវប្បកម្ម និងការស្តារព្រៃឈើឡើងវិញ។

៣-កិច្ចការពារ និងអភិរក្សព្រៃឈើ និងជីវៈចម្រុះ។

៤-ការស្រាវជ្រាវបច្ចេកទេស និងវិទ្យាសាស្ត្រព្រៃឈើ និងសត្វព្រៃ។

៥-ការផ្សព្វផ្សាយអំពីវិស័យព្រៃឈើ និងសត្វព្រៃ។

៦-ការអភិវឌ្ឍវិស័យព្រៃឈើ និងសត្វព្រៃ។

៧-ការអភិវឌ្ឍសហគមន៍ព្រៃឈើ។

៩-ការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់វិស័យព្រៃឈើ និងសត្វព្រៃ។

## ជំពូកទី១៣ វិធានការគ្រប់គ្រងសកម្មភាពព្រៃឈើ

### មាត្រា៦៥

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវបង្កើតញញួរត្រារដ្ឋបាលព្រៃឈើកម្ពុជាដើម្បី៖

១-វាយលើឈើស្របច្បាប់មុនពេលឱ្យដឹកជញ្ជូនចេញពីគំនរក្នុងព្រៃ

២-វាយលើឈើដែលជាវត្ថុតាងនៃបទល្មើសព្រៃឈើ។

ស្នាមញញួរត្រារដ្ឋបាលព្រៃឈើកម្ពុជាមានរាងមូលហើយមានអក្សរកាត់ រ. ក. និងលេខនៅពីក្រោមតួអក្សរនោះសម្រាប់សម្គាល់ញញួរត្រានីមួយៗ។

មុននឹងដាក់ឱ្យប្រើប្រាស់ញញួរត្រានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវធ្វើកំណត់ហេតុផ្តិតស្នាមញញួរត្រានេះហើយយកទៅតម្កល់ទុកជាគំរូតាងនៅក្រសួងមហាផ្ទៃ និងតុលាការខេត្ត-ក្រុង។

### មាត្រា៦៦

ញញួររដ្ឋបាលព្រៃឈើកម្ពុជាត្រូវតែបោះឱ្យបានជិតច្បាស់ដាច់ខាត ដោយមន្ត្រីរដ្ឋបាលព្រៃឈើលើរាល់ឈើហ៊ុបដូចតទៅ៖

១-ឈើហ៊ុបស្របច្បាប់ដែលត្រូវដឹកជញ្ជូនចេញពីតំនរក្នុងព្រៃរហូតដល់ទីដៅកំណត់ ត្រូវមានស្នាមញញួរត្រារដ្ឋបាលព្រៃឈើកម្ពុជា ចំនួនពីបួន (៤) ឡើងទៅនៅកន្លែងនីមួយៗ ខាងគល់ និងខាងចុងឈើហ៊ុប។

២-ឈើហ៊ុបល្មើសច្បាប់ដែលរដ្ឋបាលព្រៃឈើបានឃាត់ចាប់ ត្រូវមានស្នាមញញួរត្រាបី (៣) គឺនៅខាងគល់ កណ្ដាល ខាងចុងឈើហ៊ុប ដោយធ្វើឱ្យមានស្នាមបី (៣) រួមគ្នាបង្កើតជារាងត្រីកោណនៅកន្លែងនីមួយៗនោះ។

ចំពោះដើមឈើដែលត្រូវអនុវត្តឱ្យកាប់ក្នុងព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវមានស្នាមញញួរត្រារដ្ឋបាលព្រៃឈើកម្ពុជាចំនួន (១) ជាសម្គាល់។

ការកាន់កាប់ និងការប្រើប្រាស់ញញួរត្រារដ្ឋបាលព្រៃឈើកម្ពុជា អាចប្រព្រឹត្តទៅបានតែចំពោះមន្ត្រីរដ្ឋបាលព្រៃឈើដែលបានធ្វើសច្ចាប្រណិធាន។ វិធាននៃការគ្រប់គ្រង និងប្រើប្រាស់ញញួរត្រានោះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៦៧**

រាល់ព្រៃសម្បទានិក ឬម្ចាស់ព្រៃគុបអាចមានញញួរត្រាឯកជនសម្រាប់វាយលើផលព្រៃឈើរបស់ខ្លួនផ្ទាល់ ប៉ុន្តែស្នាមញញួរត្រាឯកជននេះត្រូវមានរាងទំហំ និងអក្សរសម្គាល់ ខុសពីស្នាមញញួរត្រារដ្ឋបាលព្រៃឈើកម្ពុជា។

មុននឹងយកទៅប្រើប្រាស់ព្រៃ សម្បទានិក ឬម្ចាស់ព្រៃគុបត្រូវបញ្ជាក់សញ្ញាសម្គាល់ និងត្រូវផ្ដិតស្នាមញញួរត្រានោះទៅសុំការអនុញ្ញាតពីប្រធានរដ្ឋបាលព្រៃឈើ និងតម្កល់ទុកជាមុននៅការិយាល័យរដ្ឋបាលព្រៃឈើសាមី។

**មាត្រា៦៨**

ទោះជាមានលិខិតអនុញ្ញាតស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះក៏ដោយ ក៏ការកាប់ដើមឈើ ការប្រមូល ឬការដឹកជញ្ជូនផល អនុផលព្រៃ ឈើក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវហាមឃាត់ចាប់ពីម៉ោងប្រាំបី (៨) យប់ ដល់ម៉ោងប្រាំ (៥) ភ្លឺ។

**មាត្រា៦៩**

ផល អនុផលព្រៃឈើគ្រប់ប្រភេទដែលចរាចរក្នុងទូទាំងប្រទេស ត្រូវមានលិខិតអនុញ្ញាតចេញដោយរដ្ឋបាលព្រៃឈើ។

ផល អនុផលព្រៃឈើគ្រប់ប្រភេទ ដែលពេលបានកាប់រំលំ ត្រូវដឹកជញ្ជូនចេញពីព្រៃឱ្យអស់មកធ្វើសន្និធិនៅគំនរអចិន្ត្រៃយ៍ក្នុងអំឡុងពេលមិនឱ្យលើសពីមួយ (១) ខែឡើយ និងត្រូវអមដោយលិខិតអនុញ្ញាតដឹកជញ្ជូនចេញដោយរដ្ឋបាលព្រៃឈើ ។

ផល អនុផលព្រៃឈើគ្រប់ប្រភេទដែលជាសន្និធិ ទោះជានៅទីណាក៏ដោយ ក៏ត្រូវអមដោយលិខិតអនុញ្ញាតដឹកជញ្ជូន ឬលិខិតអនុញ្ញាតសន្និធិចេញឱ្យដោយរដ្ឋបាលព្រៃឈើ ។

ការដឹកជញ្ជូនផល អនុផលព្រៃឈើ ឬសន្និធិខុសពីការកំណត់ក្នុងលិខិតអនុញ្ញាត ឬគ្មានលិខិតអនុញ្ញាតដឹកជញ្ជូន ឬសន្និធិត្រូវចាត់ទុកជាល្មើសច្បាប់ ។

**មាត្រា៧០**

មុនពេលបើកការដ្ឋានប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ ព្រៃសម្បទានិក ឬម្ចាស់ព្រៃគុបត្រូវយកគ្រឿងចក្រ យានយន្ត និងរណាយន្តគ្រប់ប្រភេទដែលបម្រើឱ្យការប្រមូលផល អនុផលព្រៃឈើ ទៅសុំការអនុញ្ញាតចុះបញ្ជី និងបិទស្លាកជាសម្គាល់នៅរដ្ឋបាលព្រៃឈើ ។

គ្រឿងចក្រ យានយន្ត និងរណាយន្ត គ្រប់ប្រភេទដែលបម្រើឱ្យការប្រមូលផល អនុផលព្រៃឈើដោយពុំបានចុះបញ្ជី និងបិទស្លាកជាសម្គាល់របស់រដ្ឋបាលព្រៃឈើ ហើយធ្វើចរាចរក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ត្រូវហាមឃាត់ ។

រាល់គ្រឿងចក្រ យានយន្ត និងរណាយន្តគ្រប់ប្រភេទដែលព្រៃសម្បទានិក ឬម្ចាស់ព្រៃគុបស្របច្បាប់មានបំណងធ្វើការនាំចូលដើម្បីបម្រើឱ្យការប្រមូល និងដឹកជញ្ជូនផល អនុផលព្រៃឈើ ត្រូវឆ្លងកាត់ការវាយតម្លៃភាពសមស្របពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ការប្រើប្រាស់រណាយន្តគ្រប់ប្រភេទដែលបម្រើការប្រមូលផល អនុផលព្រៃឈើ ត្រូវមានការអនុញ្ញាតពីប្រធានរដ្ឋបាលព្រៃឈើ ។

**មាត្រា៧១**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវកំណត់ដោយប្រកាសនូវចំនួនមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្មច្នៃផល អនុផលព្រៃឈើ ដើម្បីធានាបាននូវការផ្គត់ផ្គង់វត្ថុធាតុដើមជាផល អនុផលព្រៃឈើប្រកបដោយនិរន្តរភាព ។

វត្ថុធាតុដើមសម្រាប់មូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ និងសិប្បកម្មកែច្នៃអនុផលព្រៃឈើត្រូវមានប្រភពពីព្រៃសម្បទាន ព្រៃគុប ឈើរើបអូស ឬពីប្រភពស្របច្បាប់ផ្សេងទៀត ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា៧២**

ការនាំចេញផល អនុផលព្រៃឈើគ្រប់ប្រភេទទៅបរទេស ត្រូវសម្រេចតាមកម្រិតកំណត់ប្រចាំឆ្នាំដោយរាជរដ្ឋាភិបាលតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

យថាប្រភេទផល អនុផលព្រៃឈើដែលអនុញ្ញាតឱ្យនាំចេញ នាំចូលត្រូវកំណត់ដោយអនុក្រឹត្យ។

ការតម្រូវឱ្យមានអាជ្ញាប័ណ្ណនាំចេញ នាំចូលផល អនុផលព្រៃឈើត្រូវកំណត់ដោយរាជរដ្ឋាភិបាល។

**មាត្រា៧៣**

អាជ្ញាប័ណ្ណនាំចេញផល អនុផលព្រៃឈើត្រូវផ្តល់ដោយក្រសួងពាណិជ្ជកម្ម និងមានចុះទិដ្ឋាការដោយប្រធានរដ្ឋបាលព្រៃឈើជាមុន។

ការពន្យារសុពលភាពនៃអាជ្ញាប័ណ្ណនេះត្រូវផ្តល់ដោយក្រសួងពាណិជ្ជកម្ម។

រាល់ផល អនុផលព្រៃឈើនាំចេញដែលរៀបចំផ្ទុកក្នុងខុនថៃនណឺ ចាំបាច់ត្រូវមានការត្រួតពិនិត្យជាមុនដោយមន្ត្រីរដ្ឋបាលព្រៃឈើ និងបិទសំណាភ្ជិតមុនពេលអនុញ្ញាតដឹកជញ្ជូនទៅកាន់ឃ្លាំង និងទីលានបញ្ចេញទំនិញពីគយ។ គំរូសំណាបិទភ្ជិតលើខុនថៃនណឺផ្ទុកផល អនុផលព្រៃឈើនាំចេញនេះត្រូវកំណត់ដោយប្រកាសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ការនាំចេញ នាំចូលផល អនុផលការនាំចេញ នាំចូលផល អនុផលព្រៃឈើត្រូវបង់ពន្ធនាំចេញ នាំចូល និងពន្ធផ្សេងៗទៀតចូលថវិកាជាតិ។

**មាត្រា៧៤**

ឈើរសាត់តាមខ្សែទឹក កឿង ឬលិចដែលគ្មានដាក់សញ្ញា និងឈើគ្មានម្ចាស់ ត្រូវរឹបអូសជាសម្បត្តិរដ្ឋដាក់លក់ឱ្យដេញថ្លៃជាសាធារណៈ។

ក្នុងករណីមានបុគ្គលណាមួយទាមទារថា ឈើដូចមានចែងក្នុងកថាខណ្ឌទី១ជារបស់ខ្លួននោះ ត្រូវឱ្យបុគ្គលនោះបង្ហាញភស្តុតាងជាក់ស្តែង ជាអាទិ៍លិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើ លិខិតអនុញ្ញាតដឹកជញ្ជូន ឬលិខិតអនុញ្ញាតសន្ទិធិ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ចាប់ពីថ្ងៃប្រកាសជូនដំណឹងដោយរដ្ឋបាលព្រៃឈើ។

ថ្លៃលក់ឈើ ដូចមានចែងក្នុងកថាខណ្ឌទី១ មាត្រា៧៤ នៃច្បាប់នេះត្រូវបង់ចូលថវិកាជាតិ ។

ក្នុងករណីមានការបាត់បង់ឈើរសាត់តាមខ្សែទឹក កឿង ឬលិច ក៏ដូចជាការបាត់បង់ផល អនុផលព្រៃឈើផ្សេងទៀតដែលរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចបានផ្ញើឱ្យថែរក្សា បុគ្គល ឬអាជ្ញាធរដែលទទួលថែរក្សាត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ។

**មាត្រា៧៥**

បុគ្គលដែលប្រមូលដឹកជញ្ជូន កែច្នៃសន្និធិ លក់ដូរ ឬនាំចេញ នាំចូលផល អនុផលព្រៃឈើត្រូវទទួលខុសត្រូវក្នុងការបង្ហាញឯកសារដើមស្របច្បាប់នៃផល អនុផលព្រៃឈើដល់មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចត្រួតពិនិត្យ ។

## ជំពូកទី១៤ នីតិវិធីដោះស្រាយបទល្មើសព្រៃឈើ

**មាត្រា៧៦**

បទល្មើសព្រៃឈើជាបទល្មើសព្រហ្មទណ្ឌដែលមានចរិតពិសេសដូចមានចែងក្នុងច្បាប់នេះ ។

រដ្ឋបាលព្រៃឈើមានសមត្ថកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ ក្នុងការស៊ើបអង្កេតបទល្មើសព្រៃឈើ និងចងក្រងសំណុំរឿងជូនតុលាការ ។

ការស្រាវជ្រាវទប់ស្កាត់ បង្ក្រាបបទល្មើសព្រៃឈើជាសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើគ្រប់ថ្នាក់នៅក្នុងរង្វង់ដែនសមត្ថកិច្ចរៀងៗខ្លួន ។

ប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលព្រៃឈើ ដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ត្រូវអនុវត្តស្របតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា៧៧**

នៅពេលបំពេញបេសកកម្មស្រាវជ្រាវទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ មន្ត្រីរដ្ឋបាលព្រៃឈើត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសម្គាល់ ពាក់ឋានន្តរសក្តិ និងត្រូវមានលិខិតបញ្ជាបេសកកម្ម ។

មន្ត្រីរដ្ឋបាលព្រៃឈើសច្ចាប្រណិធានបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌បាន លុះត្រាតែសាមីខ្លួនបានទទួលនីតិសម្បទាពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ត្រូវធ្វើ និងចុះហត្ថលេខាលើកំណត់ហេតុបទល្មើសព្រៃឈើតាមដែនសមត្ថកិច្ចរបស់ខ្លួន។

សំលៀកបំពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ និងឋានន្តរសក្តិរបស់មន្ត្រីរដ្ឋបាលព្រៃឈើ កំណត់ដោយអនុក្រឹត្យ។

**មាត្រា៧៨**

អាជ្ញាធរដែនដីគ្រប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ អាជ្ញាធរគយ និងរដ្ឋាករ អាជ្ញាធរព្រលានយន្តហោះ និងកំពង់ផែ និងអាជ្ញាធរពាក់ព័ន្ធដទៃទៀតត្រូវបង្កភាពងាយស្រួល និងជួយផ្តល់កម្លាំងសហការក្នុងការស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ ឬថែរក្សាវត្ថុតាងបទល្មើសព្រៃឈើជាបណ្តោះអាសន្ន ក្នុងករណីមានការស្នើសុំពីមន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច។

ក្នុងករណីដែលអាជ្ញាធរទាំងឡាយបានជួបប្រទះនូវបទល្មើសព្រៃឈើជាក់ស្តែង អាជ្ញាធរទាំងនោះ៖

១-ត្រូវជូនព័ត៌មានជាបន្ទាន់ដល់មន្ត្រីរដ្ឋបាលព្រៃឈើ ឬការិយាល័យរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចដែលនៅជិតបំផុត។

២-អាចឃាត់ខ្លួនជនប្រព្រឹត្តល្មើស និងចាប់ឃាត់វត្ថុតាងបទល្មើសជាបណ្តោះអាសន្ន រួចបញ្ជូនជាបន្ទាន់ទៅមន្ត្រីរដ្ឋបាលព្រៃឈើដែលទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ ដើម្បីចាត់ការតាមនីតិវិធី។

៣-មិនត្រូវប្រមូលប្រាក់ពិន័យ ឬរឹបអូសវត្ថុតាងបទល្មើសដោយផ្ទាល់ឡើយ។

**មាត្រា៧៩**

ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌មានសិទ្ធិដូចតទៅ៖

១-អាចឱ្យបុគ្គលណាមួយឆ្លើយតបសំណួរ និងផ្តល់ព័ត៌មានដែលពាក់ព័ន្ធដល់ការប្រព្រឹត្តបទល្មើសព្រៃឈើ។

២-ចូលធ្វើការត្រួតពិនិត្យ ឬឆែកឆេរគ្រប់ទីកន្លែងរួមទាំងក្នុងព្រលានយន្តហោះ កំពង់ផែសមុទ្រ កំពង់ផែទន្លេ ផែស្ងួត ច្រកព្រំដែន ចំណតរថយន្ត ស្ថានីយ៍រថភ្លើងក្នុងករណីបទល្មើសជាក់ស្តែងដោយមានកិច្ចសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ។

៣-ដកហូតជាបណ្ដោះអាសន្ននូវអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតគ្រប់ប្រភេទដែលកំណត់ដោយច្បាប់នេះ បើសិនជាបុគ្គលទទួលអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតនោះប្រព្រឹត្តល្មើសនឹងច្បាប់នេះ ។

ក្នុងករណីបទល្មើសជាក់ស្ដែង មន្ត្រីរដ្ឋបាលរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌មានសិទ្ធិចូលឆែកនៅក្នុងទីធ្លា អគារក្នុងលំនៅឋានស្របតាមនីតិវិធីព្រហ្មទណ្ឌ ។ ការឆែកឆេរត្រូវធ្វើចំពោះមុខជនជាប់សង្ស័យ និងមានសាក្សីពីរ (២) នាក់ ដែលជាអ្នកជិតខាង ឬអ្នកម្ចាស់ផ្ទះ ។

**មាត្រា៨០**

មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ ក្នុងករណីបទល្មើសជាក់ស្ដែងត្រូវចាប់ឃាត់ជាបណ្ដោះអាសន្ន

១-រាល់ផល អនុផលព្រៃឈើ ឬផលប្រមាញ់ដែលល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

២-សត្វពាហនៈដែលបានជួបប្រទះកំពុងបំផ្លិចបំផ្លាញដំណាំឈើ ។

៣-គ្រឿងចក្រ យានយន្ត ឧបករណ៍ព្រមទាំងសត្វពាហនៈដែលបានប្រើប្រាស់ជាមធ្យោបាយសម្រាប់ប្រព្រឹត្តបទល្មើសព្រៃឈើ និងសត្វព្រៃ ។

មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវឃាត់ខ្លួនជនប្រព្រឹត្តបទល្មើសព្រៃឈើបានដល់៤៨ម៉ោងយ៉ាងយូរ ដើម្បីបំពេញសំណុំរឿងបញ្ជូនទៅតុលាការ ។

**មាត្រា៨១**

ការកសាងសំណុំរឿងនៃបទល្មើសព្រៃឈើ ត្រូវអនុវត្តច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ ។

ទម្រង់បែបបទនៃកំណត់ហេតុបទល្មើសព្រៃឈើ ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងយុត្តិធម៌ ។

**មាត្រា៨២**

វត្ថុតាងនៃបទល្មើសព្រៃឈើត្រូវបានកំណត់ដូចខាងក្រោម៖

១-ផល អនុផលព្រៃឈើ ឬផលប្រមាញ់ ដែលជាវត្ថុតាងពិតប្រាកដនៃបទល្មើស ។

២-សម្ភារៈបរិក្ខារ និងមធ្យោបាយដឹកជញ្ជូនដែលប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ។

វត្ថុតាងដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះត្រូវឃាត់ទុកជាបណ្ដោះអាសន្ន រហូតដល់សំណុំរឿងនៃបទល្មើសត្រូវបានដោះស្រាយរួចជាស្ថាពរ តាមការបង់ពិន័យអន្តរការណ៍ ឬតាមការជំនុំជម្រះរបស់តុលាការ ។

ក្នុងខណៈពេលកំពុងដឹកជញ្ជូនផល អនុផលព្រៃឈើល្មើស ឬផលប្រមាញ់ល្មើស អ្នកបើកបរមធ្យោបាយដឹកជញ្ជូនដែលគ្មានម្ចាស់នៅជាមួយត្រូវឃាត់ខ្លួនជាបណ្ដោះអាសន្ន ដើម្បីជាប្រយោជន៍នៃការស៊ើបអង្កេតរកជនល្មើស និងអ្នកផ្សំគំនិត។

ផលប្រមាញ់ស្រស់ ជាអាទិ៍សត្វរស់ និងសំណាកសត្វព្រៃដែលបានឃាត់ទុកហើយងាយខូចខាត ផ្នែករដ្ឋបាលព្រៃឈើមានសិទ្ធិលែង ឬបំផ្លាញចោល ឬរក្សាទុកជាប្រយោជន៍សាធារណៈដោយមានកំណត់ហេតុត្រឹមត្រូវ។

**មាត្រា៨៣**

មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសម្គាល់ និងពាក់ឋានន្តរសក្ដិ នៅពេលចូលរួមសវនាការរបស់តុលាការ។

**មាត្រា៨៤**

នៅរាល់ពេលសវនាការ មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ពាក់ព័ន្ធទៅក្នុងសំណុំរឿងក្តី ត្រូវមានសិទ្ធិឆ្លើយបំភ្លឺអំពីលទ្ធផលនៃការស៊ើបអង្កេតបទល្មើសព្រៃឈើនោះជូនតុលាការ។

**មាត្រា៨៥**

អាជ្ញាយុកាលនៃបណ្ដឹងបទល្មើសព្រៃឈើមានៈ

១-បទល្មើសព្រៃឈើថ្នាក់ទី១មានអាជ្ញាយុកាលដប់ប្រាំ (១៥) ឆ្នាំ គិតពីពេលប្រព្រឹត្តបទល្មើស។

២-បទល្មើសព្រៃឈើថ្នាក់ទី២មានអាជ្ញាយុកាលប្រាំ (៥) ឆ្នាំ គិតពីពេលប្រព្រឹត្តបទល្មើស។

៣-បទល្មើសព្រៃឈើថ្នាក់ទី៣មានអាជ្ញាយុកាលមួយ (១) ឆ្នាំ គិតពីពេលប្រព្រឹត្តបទល្មើស។

ការអនុវត្តអាជ្ញាយុកាលនៃបណ្ដឹងបទល្មើសព្រៃឈើត្រូវស្របតាមនីតិវិធីព្រហ្មទណ្ឌ។

**មាត្រា៨៦**

បុគ្គលដែលប្រព្រឹត្តបទល្មើសព្រៃឈើដូចមានចែងក្នុងច្បាប់នេះ ត្រូវទទួលខុសត្រូវចំពោះសកម្មភាពដែលខ្លួនបានប្រព្រឹត្ត។

បុគ្គលជាភ្នាក់ងារនៃអង្គភាពរដ្ឋ ឬឯកជនដែលប្រើប្រាស់មធ្យោបាយដើម្បីប្រព្រឹត្តបទល្មើសព្រៃឈើ ឬប្រធានអង្គភាពនោះត្រូវទទួលទោសតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

បទល្មើសព្រៃឈើដែលប្រព្រឹត្តឡើងដោយបុគ្គល ឬក្រុម ក្រោមការចាត់តាំងរបស់អង្គភាពណាមួយ ប្រធានអង្គភាពនោះត្រូវទទួលទោសតាមបទប្បញ្ញាតិនៃច្បាប់នេះ ។

**មាត្រ៨៧**

រូបវន្តបុគ្គលបរទេស ឬនីតិបុគ្គលបរទេសដែលបានប្រព្រឹត្តបទល្មើសព្រៃឈើត្រូវឋិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា៨៨**

មន្ត្រីរដ្ឋបាលព្រៃឈើដែលមានសមត្ថកិច្ចមានសិទ្ធិអំណាច ផ្អាកសកម្មភាពនៅក្នុងតំបន់ព្រៃសម្បទានទាំងមូល ឬមួយផ្នែកមួយរយៈដើម្បីចាត់ការតាមនីតិវិធីក្នុងករណីព្រៃសម្បទានិកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬល្មើសនឹងកិច្ចព្រមព្រៀងព្រៃសម្បទាន រហូតដល់ដំណោះស្រាយនៃវិវាទត្រូវបានបញ្ចប់ ។

**មាត្រា៨៩**

បុគ្គលណាដែលមិនពេញចិត្តចំពោះការសម្រេចចិត្តណាមួយ ធ្វើឡើងដោយរដ្ឋបាលព្រៃឈើស្របតាមច្បាប់នេះមានសិទ្ធិប្តឹងតវ៉ាក្នុងរយៈពេលសាមសិប (៣០) ថ្ងៃយ៉ាងយូរគិតពីថ្ងៃទទួលសេចក្តីសម្រេច នេះមកប្រធានរដ្ឋបាលព្រៃឈើ ។

ប្រធានរដ្ឋបាលព្រៃឈើត្រូវសម្រេចលើបណ្តឹងតវ៉ានោះ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃយ៉ាងយូរ ។

ក្រោយពីបានទទួលសេចក្តីសម្រេច ចុងក្រោយលើការពិនិត្យឡើងវិញដោយប្រធានរដ្ឋបាលព្រៃឈើ ក្នុងករណីមិនអាចទទួលយកបាន ជននោះអាចធ្វើបណ្តឹងតវ៉ាទៅតុលាការ ។

ការតវ៉ា ក្រោមមាត្រានេះ នឹងមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិអំណាច និងដំណើរការអនុវត្តច្បាប់របស់មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចក្រោមច្បាប់នេះឡើយ ។

## ជំពូកទី១៥ បទល្មើសព្រៃឈើ និងទោសប្បញ្ញត្តិ

**មាត្រា៩០**

ទណ្ឌកម្មក្នុងបទល្មើសព្រៃឈើមានទោសជាប់ពន្ធនាគារ រឹបអូសវត្ថុតាង ពិន័យដោយតុលាការ ពិន័យអន្តរការណ៍ ការជួសជុលការខូតខាត ការព្រមាន ការដកហូត ឬការព្យួរកិច្ចព្រមព្រៀង ឬលិខិតអនុញ្ញាត។

ការពិន័យអន្តរការណ៍លើបទល្មើសព្រៃឈើ ការជួសជុលការខូតខាត និងការព្រមានជាសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើ។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ឬជួសជុលការខូតខាត រដ្ឋបាលព្រៃឈើអាចបញ្ជូនសំណុំរឿងបទល្មើសទៅតុលាការ។

ចំពោះមន្ត្រីរាជការដែលប្រព្រឹត្តបទល្មើសព្រៃឈើ ត្រូវទទួលទោសរដ្ឋបាលបន្ថែមលើទោសទណ្ឌដែលកំណត់ក្នុងច្បាប់នេះ។

**មាត្រា៩១**

រដ្ឋបាលព្រៃឈើមានសិទ្ធិសម្រេចពីការពិន័យអន្តរការណ៍លើបទល្មើសព្រៃឈើ ដូចមានចែងក្នុងមាត្រា៩៦នៃច្បាប់នេះ។

ការពិន័យអន្តរការណ៍លើបទល្មើសព្រៃឈើ អាចធ្វើបានតែក្នុងករណីជនល្មើសសារភាពទោសកំហុស និងយល់ព្រមបង់ប្រាក់ពិន័យស្របតាមទោសប្បញ្ញត្តិនៃច្បាប់នេះ ក្នុងរយៈពេលមុនឱ្យលើសពីដប់ប្រាំ (១៥) ថ្ងៃគិតពីថ្ងៃចេញសេចក្តីសម្រេច។

បែបបទ និងសិទ្ធិសម្រេចពិន័យអន្តរការណ៍ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ក្នុងការកំណត់បរិមាណទឹកប្រាក់ពិន័យអន្តរការណ៍ ត្រូវពិចារណាលើកត្តាដូចតទៅ៖

១-ផលប្រយោជន៍សេដ្ឋកិច្ចជាក់ស្តែងពីលទ្ធផលនៃបទល្មើស។

២-ការខូតខាតដល់បរិស្ថាន។

៣-ចំនួននៃការប្រព្រឹត្តល្មើស។

៤-បរិមាណប្រាក់ពិន័យល្មើសដោយចេតនា។

៥-ការប្រព្រឹត្តល្មើសដោយចេតនា។

**មាត្រា៩២**

ប្រាក់ពិន័យអន្តរការណ៍ ប្រាក់ពិន័យតាមសាលក្រមតុលាការ ឬប្រាក់បានមកពីការលក់វត្ថុតាងត្រូវបង់ចូលថវិកាជាតិ ។

រាជរដ្ឋាភិបាលអាចសម្រេចផ្តល់រង្វាន់លើកទឹកចិត្តដល់ប្រជាពលរដ្ឋ និងមន្ត្រីដែលបានចូលរួមក្នុងករណីបង្ក្រាបបទល្មើសព្រៃឈើជាក់លាក់ណាមួយ ។

**មាត្រា៩៣**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះត្រូវទទួលទណ្ឌកម្មដូចតទៅ៖

១-ចំពោះបទល្មើសព្រៃឈើថ្នាក់ទី១ត្រូវជាប់ពន្ធនាគារពីមួយ (១) ឆ្នាំ ទៅដប់ (១០) ឆ្នាំ និងត្រូវរឹបអូសវត្ថុតាងទាំងអស់មកជាសម្បត្តិរដ្ឋ ។

២-ចំពោះបទល្មើសព្រៃឈើថ្នាក់ទី២ ត្រូវជាប់ពន្ធនាគារពីមួយ (១) ឆ្នាំ ទៅដល់ (៥) ឆ្នាំ និង/ឬត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីដប់លាន (១០.០០០.០០០) រៀល ទៅមួយរយលាន (១០០.០០០.០០០) រៀល ។ វត្ថុតាងទាំងអស់ត្រូវរឹបអូសមកជាសម្បត្តិរដ្ឋ ។

៣-ចំពោះបទល្មើសព្រៃឈើថ្នាក់ទី៣ត្រូវជាប់ពន្ធនាគារពីមួយ (១) ខែ ទៅមួយ (១) ឆ្នាំ ឬត្រូវផ្តន្ទាទោសពិន័យជាប្រាក់មួយលាន (១.០០០.០០០) រៀល ទៅដប់លាន (១០.០០០.០០០) រៀល ។ វត្ថុតាងទាំងអស់ត្រូវរឹបអូសមកជាសម្បត្តិរដ្ឋ ។

៤-ការព្រមាន ការជួសជុលការខូចខាត ការពិន័យអន្តរការណ៍ ការដកហូត ឬការព្យួរកិច្ចព្រមព្រៀង ឬលិខិតអនុញ្ញាត ។

តម្លៃទីផ្សារជាមូលដ្ឋាននៃផល អនុផលព្រៃឈើត្រូវកំណត់ដោយប្រកាសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើម្បីអនុវត្តឯកភាពទូទាំងប្រទេស ។

**មាត្រា៩៤**

បុគ្គលណាដែលបានប្រព្រឹត្តបទល្មើសព្រៃឈើ ធ្វើឱ្យប៉ះពាល់ខូចខាតដល់មជ្ឈដ្ឋានព្រៃឈើ ត្រូវចេញថ្លៃស្តារ ឬជួសជុលការខូចខាតមានល័ក្ខខ័ណ្ឌដូចដើមឡើងវិញ ។

**មាត្រា៩៥**

រដ្ឋបាលព្រៃឈើអាចចេញលិខិតព្រមាន និងតម្រូវឱ្យជួសជុលការខូចខាតចំពោះសកម្មភាពល្មើសនៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ដូចខាងក្រោម៖

១-ប្រើប្រាស់មធ្យោបាយផ្សេងៗ លែង ឬចងសត្វពាហនៈក្នុងតំបន់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ ចម្ការឈើ ឬថ្នាលកូនឈើរបស់រដ្ឋដោយបំផ្លិចបំផ្លាញឈើ ឬកូនឈើនៅទីនោះ។

២-ធ្វើឱ្យរបួស ឬធ្វើឱ្យខូចខាតដល់ដើមឈើ ឬរុក្ខជាតិផ្សេងទៀតដែលកំពុងថែរក្សា ឬដែលបានដាំ។

៣-លួច ឬធ្វើឱ្យខូចខាតរបង បង្គោល ឬស្លាកសញ្ញាក្នុងថ្នាលបណ្តុះកូនឈើ ឬក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍។

**មាត្រា៩៦**

ត្រូវទទួលពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើជាប្រាក់ចំនួនពីពីរ (២) ទៅបី (៣) ដងនៃតម្លៃវត្ថុតាងពិតប្រាកដនៃទីផ្សារ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយ ដូចខាងក្រោម៖

១-កាប់ដើមឈើដែលគ្មានស្លាកសញ្ញាសម្គាល់អនុញ្ញាតឱ្យកាប់រំលំ

២-ដឹកជញ្ជូនផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត។

៣-ធ្វើសន្និធិផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត។

៤-ដឹកជញ្ជូនផល អនុផលព្រៃឈើខុសទិសដៅ លើសបរិមាណកំណត់ក្នុងលិខិតអនុញ្ញាតដឹកជញ្ជូន។

៥-ប្រើប្រាស់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើហួសសុពលភាព។

៦-មានយថាប្រភេទផល អនុផលព្រៃឈើខុសពីការកំណត់ក្នុងលិខិតអនុញ្ញាតដឹកជញ្ជូន។

៧-ធ្វើសន្និធិផល អនុផលព្រៃឈើលើសពីលិខិតអនុញ្ញាត។

៨-នាំចេញផល អនុផលព្រៃឈើ គ្រាប់ពូជ និងប្រភេទរុក្ខជាតិព្រៃដែលលើសពីការកំណត់ក្នុងអាជ្ញាប័ណ្ណ។

៩-កាប់រំលំ អារ ច្រៀក និងចាំងឈើមូលក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ឬប្រើរណាយន្តជាមធ្យោបាយប្រមូលផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ឬគ្មានស្លាកសញ្ញា។

១០-ប្រមូលផល អនុផលព្រៃឈើក្រៅម៉ោងអនុញ្ញាត។

១១-ដឹកជញ្ជូនផល អនុផលព្រៃឈើដែលកាប់រំលំ ឬប្រមូលយកមក ដោយផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ។

១២-ផល អនុផលព្រៃឈើដែលយកមកកែច្នៃ ត្រូវបានកាប់ ឬប្រមូលដោយផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ។

១៣-ផល អនុផលព្រៃឈើគ្រប់ប្រភេទដែលលក់ដូរ ចែកចាយបានមកពីការកាប់ ឬរុករក ដឹកជញ្ជូន កែច្នៃដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ។

១៤-ផល អនុផលព្រៃឈើគ្រប់ប្រភេទដែលបានមកពីការប្រមូលផលដឹកជញ្ជូន កែច្នៃដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ។

១៥-នាំចេញផល អនុផលព្រៃឈើដែលអាជ្ញាប័ណ្ណគ្មានចុះទិដ្ឋាការដោយប្រធានរដ្ឋបាលព្រៃឈើ។

១៦-ចិញ្ចឹម បង្កាត់ពូជប្រភេទសត្វព្រៃក្នុងក្រុមជិតផុតពូជ។

១៧-យកធ្វើជាកម្មសិទ្ធិ កែច្នៃសំណាក សន្និធិ ដឹកជញ្ជូន ឬនាំចូលសត្វព្រៃរស់ និងសំណាកក្នុងក្រុមមានដោយកម្រ។

១៨-ចិញ្ចឹម បង្កាត់ពូជប្រភេទសត្វព្រៃក្នុងក្រុមមានដោយកម្រ។

១៩-ដឹកជញ្ជូន ធ្វើពាណិជ្ជកម្ម សន្និធិ កែច្នៃសំណាក ឬនាំចូលសត្វព្រៃរស់ និងសំណាកក្នុងក្រុមមានដោយបង្គួរ ដោយគ្មានលិខិតអនុញ្ញាត។

២០-បរបាញ់ក្នុងទីសាធារណៈ។

ជនណាប្រព្រឹត្តបទល្មើសដូចមានចែងក្នុងកថាខណ្ឌ១នៃមាត្រានេះ មិនរាងចាលក្នុងរយៈពេលមួយ (១) ខែ ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើជាប្រាក់ចំនួនពីពីរ (២) ទៅបួន (៤) ដង នៃតម្លៃវត្ថុតាងពិតប្រាកដនៃទីផ្សារ។

វត្ថុតាងពិតប្រាកដនៃបទល្មើសព្រៃឈើ ត្រូវរឹបអូសជាសម្បត្តិរដ្ឋស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។ វត្ថុតាងផ្សេងទៀតក្រៅពីផល អនុផលអាចប្រគល់ឱ្យសាមីជនវិញក្នុងករណីប្រព្រឹត្តល្មើសនឹងមាត្រា៩៦នៃច្បាប់នេះ។

**មាត្រា៩៧**

ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី១ដែលត្រូវជាប់ពន្ធនាគារពីប្រាំ (៥) ឆ្នាំ និងត្រូវរឹបអូសវត្ថុតាងទាំងអស់មកជាសម្បត្តិរដ្ឋ ដកហូតកិច្ចព្រមព្រៀង អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងកម្ទេចចោលវត្ថុតាងក្លែងចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម៖

១-ក្លែងញញួរត្រា ឬប្រើញញួរត្រាក្លែង ឬបំផ្លាញស្នាមញញួរត្រារដ្ឋបាលព្រៃឈើដែលវាយលើឈើហ៊ុប។

២-ក្លែងបន្លំដោយស្លៀកពាក់ឯកសណ្ឋានសម្គាល់ ឬពាក់ឋានន្តរសក្តិរបស់មន្ត្រីរដ្ឋបាលព្រៃឈើ។

៣-ក្លែងបន្លំលិខិតសាធារណៈដែលពាក់ព័ន្ធនឹងវិស័យព្រៃឈើ ឬសត្វព្រៃ។

៤-បំផ្លាញ លាក់បាំង លក់ ឬលួចវត្ថុតាងព្រៃឈើ។

៥-កម្ទេច ផ្លាស់ប្តូរ លុបបំបាត់ ឬធ្វើឱ្យខូចខាតដល់ព្រំសីមានៃតំបន់ព្រៃឈើ។

៦-កាប់រានព្រៃ ឈូសឆាយដីព្រៃ ហ៊ុំព័ទ្ធកាន់កាប់ដីព្រៃ។

៧-បង្កឱ្យភ្លើងឆេះព្រៃដោយចេតនា។

៨-គ្រៀវ បំពុល កាប់បំផ្លាញ ផ្តួលរំលំដើមឈើ ឬគាស់រំលើង ប្រមូលគល់ឈើ។

៩-បង្កើតមូលដ្ឋានកែច្នៃរលួរមៀត ឬមូលដ្ឋានសិប្បកម្មអនុផលព្រៃឈើផ្សេងទៀតដែលនាំមកនូវការបំផ្លាញព្រៃឈើ និងមជ្ឈដ្ឋានព្រៃឈើ។

១០-បរបាញ់សម្លាប់ធ្វើពាណិជ្ជកម្ម ឬនាំចេញប្រភេទសត្វក្នុងក្រុមជិតផុតពូជ។

ជនណាប្រព្រឹត្តបទល្មើសព្រៃឈើថ្នាក់ទី១មិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដងនៃបទល្មើសព្រៃឈើថ្នាក់ទី១នៃច្បាប់នេះ។

**មាត្រា៩៨**

ត្រូវផ្តន្ទាទោសក្រោមបទល្មើសថ្នាក់ទី២ដែលត្រូវជាប់ពន្ធនាគារពីមួយ (១) ឆ្នាំ ទៅប្រាំ (៥) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០) រៀល ទៅមួយរយលាន (១០០.០០០.០០០) រៀល ឬផ្តន្ទាទោសណាមួយនៃទោសទាំងពីរ វត្ថុតាងទាំងអស់ត្រូវរឹបអូសមកជាសម្បត្តិរដ្ឋ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម៖

១-មិនគោរពតាមបទបញ្ជាបច្ចេកទេសដែលបានកំណត់ក្នុងក្រុមបច្ចេកទេសអនុវត្តគ្រប់គ្រងព្រៃឈើកម្ពុជា។

២-មិនគោរពផែនការគ្រប់គ្រង និងផែនការប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ។

៣-យកលិខិតអនុញ្ញាតប្រើប្រាស់ព្រៃឈើទៅប្រមូលផល អនុផលព្រៃឈើ។

៤-ប្រើប្រាស់គ្រឿងចក្រ យានយន្តបម្រើឱ្យការប្រមូលផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ឬគ្មានស្លាកសម្គាល់។

៥-គាស់កាយយកថ្ម ដី ខ្សាច់ រ៉ែដែលមាននៅក្នុងដីនៃដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។

៦-ប្រើប្រាស់ដីព្រៃឈើលើសពីទំហំអនុញ្ញាត ឬគ្មានលិខិតអនុញ្ញាត ដើម្បីស្ថាបនាផ្លូវសាធារណៈ ផ្លូវព្រៃឈើ ឬដាក់តាំងមូលដ្ឋានសំណង់ ឬលំនៅឋានគ្រប់ប្រភេទតាមដងផ្លូវ ។

៧-បង្កើតមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទធំ និងមធ្យមដោយគ្មានប្រកាស ។

៨-បង្កើតឡគ្រប់ប្រភេទដែលប្រើប្រាស់ផល អនុផលព្រៃឈើជាវត្ថុធាតុដើមដោយគ្មានលិខិតអនុញ្ញាត ។

៩-បរបាញ់ក្នុងរដូវកាលហាមឃាត់ ឬក្នុងតំបន់ការពារ ។

១០-បរបាញ់ សម្លាប់ ធ្វើពាណិជ្ជកម្ម ឬនាំចេញប្រភេទសត្វក្នុងក្រុមមានដោយកម្រ ។

១១-បរបាញ់ សត្វព្រៃដោយប្រើមធ្យោបាយដែលបង្កគ្រោះថ្នាក់ដល់ជីវសាស្ត្រសត្វ ។

១២-យកធ្វើជាកម្មសិទ្ធិកែច្នៃសំណាក សន្និធិ ដឹកជញ្ជូន ឬនាំចូលប្រភេទសត្វរស់ និងសំណាកក្នុងក្រុមជិតផុតពូជ ។

ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី២ ដែលត្រូវជាប់ពន្ធនាគារពីមួយ (១) ឆ្នាំ ទៅប្រាំ (៥) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីដប់លាន (១០.០០០.០០០) រៀល ទៅមួយរយលាន (១០០.០០០.០០០) រៀល ។ វត្ថុតាងទាំងអស់ត្រូវរឹបអូសមកជាសម្បត្តិរដ្ឋ ចំពោះជនណា ដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម៖

១-ប្រមូលផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ។

២-ប្រមូលផល អនុផលព្រៃឈើក្រៅដែនព្រៃគុបកំណត់ក្នុងលិខិតអនុញ្ញាត ឬក្រៅភូមិសាស្ត្រដែលកំណត់ក្នុងផែនការប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ ។

៣-ផ្ទេរសិទ្ធិ ឬលក់អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ។

៤-កាប់ដើមឈើក្នុងចម្ការដាំឈើរបស់រដ្ឋ ។

៥-ប្រមូលផល អនុផលព្រៃឈើចំពោះប្រភេទឈើជាប់លំដាប់ថ្នាក់ដែលមិនទាន់ដល់ទំហំអប្បបរមាអនុញ្ញាតឱ្យកាប់រំលំប្រភេទឈើដែលមានដោយកម្រ ប្រភេទឈើដែលប្រជាជនចោះយកជ័រតាមប្រពៃណី និងប្រភេទឈើផ្តល់ជ័រមានតម្លៃ ។

៦-នាំចូលគ្រាប់ពូជរុក្ខជាតិព្រៃគ្រប់ប្រភេទ ដោយគ្មានទិដ្ឋាការពីអាជ្ញាធរវិទ្យាសាស្ត្រ របស់ប្រទេសនាំចេញ និងគ្មានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

៧-នាំចេញផល អនុផលព្រៃឈើដែលគ្មានអាជ្ញាប័ណ្ណ ។ ជនណាប្រព្រឹត្តបទល្មើសព្រៃឈើថ្នាក់ទី២មិនរាងចាល ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី១នៃច្បាប់នេះ ។

**មាត្រា៩៩**

ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី៣ដែលត្រូវជាប់ពន្ធនាគារពីមួយ (១) ខែ ទៅមួយ (១) ឆ្នាំ ឬត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលាន (១.000.000) រៀល ទៅដប់លាន (១0.000.000) រៀល វត្ថុតាងទាំងអស់ត្រូវរឹបអូសមកជាសម្បត្តិរដ្ឋ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម៖

១-ប្រើប្រាស់រណាយន្តគ្រប់ប្រភេទដែលបម្រើការប្រមូលផល អនុផលព្រៃឈើដោយគ្មានការអនុញ្ញាតពីប្រធានរដ្ឋបាលព្រៃឈើ ។

២-នាំចូលគ្រឿងចក្រ យានយន្ត និងរណាយន្តគ្រប់ប្រភេទសម្រាប់ការប្រមូលផល អនុផលព្រៃឈើដោយគ្មានការវាយតម្លៃភាពសមស្របពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

៣-នាំចេញផល អនុផលព្រៃឈើដែលគ្មានសំណាបិទភ្ជិតរបស់រដ្ឋបាលព្រៃឈើលើខុនថៃនណឺ ។

៤- យាយី ធ្វើឱ្យរបួស ប្រមូលពង កូន នៃប្រភេទសត្វក្នុងក្រុមជិតផុតពូជ ឬក្រុមមានដោយកម្រ ឬបំផ្លាញជម្រករបស់វា ។

៥-បង្កើតរោងសន្និធិ លក់ដុំ វាយនូវផល អនុផលព្រៃឈើ និងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទតូច ដោយគ្មានលិខិតអនុញ្ញាត ឬផ្ទុយពីការកំណត់ ។

៦-បង្កើតមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្មកែច្នៃផល អនុផលឈើ ឬឡគ្រប់ប្រភេទដែលប្រើប្រាស់ ឬមិនប្រើប្រាស់ផល អនុផលព្រៃឈើ ជាវត្ថុធាតុដើម ឬជាប្រភពថាមពលខុសពីទីតាំងកំណត់ដោយរដ្ឋបាលព្រៃឈើ ។

ជនណាប្រព្រឹត្តបទល្មើសបទល្មើសព្រៃឈើថ្នាក់ទី៣មិនរាងចាល ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី២នៃច្បាប់នេះ ។

*វាយឡើងវិញ*

**មាត្រា១០០**

សកម្មភាពទាំងឡាយណាដែលធ្វើឡើងដោយមន្ត្រីអាជ្ញាធរដែនដី មន្ត្រីនគរបាល មន្ត្រីនៃកងយោធពលខេមរភូមិន្ទ ឬមន្ត្រីអាជ្ញាធរផ្សេងទៀតដើម្បីធ្វើអន្តរាគមន៍ ផ្តល់ការអនុញ្ញាតដោយផ្ទាល់ ឬដោយប្រយោលជួយដល់អាជីវកម្មព្រៃឈើ និងធ្វើសកម្មភាពគ្រប់យ៉ាងផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬធ្វើការគំរាមកំហែងដល់មន្ត្រីរដ្ឋបាលព្រៃឈើ ឬរាំងស្ទះដល់ការបំពេញភារកិច្ច និងកិច្ចប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលព្រៃឈើ ត្រូវចាត់ទុកជាបទល្មើសដែលត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីមួយ (១) ឆ្នាំ ទៅប្រាំ (៥) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីដប់លាន (១០.០០០.០០០) រៀល ទៅមួយរយលាន (១០០.០០០.០០០) រៀល។

**មាត្រា១០១**

ចំពោះសកម្មភាពដូចខាងក្រោម ដែលប្រព្រឹត្តឡើងដោយមន្ត្រីរដ្ឋបាលព្រៃឈើត្រូវចាត់ទុកជាបទល្មើស និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី (១) ឆ្នាំ ទៅប្រាំ (៥) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីដប់លាន (១០.០០០.០០០) រៀល ទៅមួយរយលាន (១០០. ០០០.០០០) រៀល។

១-ផ្តល់ការអនុញ្ញាតណាមួយដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ។

២-ចូលរួមទាំងស្រុង ឬដោយផ្នែក និងដោយផ្ទាល់ក្នុងសកម្មភាពណាមួយនៃអាជីវកម្មព្រៃឈើដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ។

៣-អនុគ្រោះចំពោះបទល្មើសព្រៃឈើណាមួយ។

៤-ប្រកបរបរអាជីវកម្មណាមួយពាក់ព័ន្ធនឹងវិស័យព្រៃឈើ ទោះធ្វើជាម្ចាស់ទាំងស្រុងក្តី ជាម្ចាស់ភាគហ៊ុនក្តី ឬធ្វើជានិយោជិត ឬអ្នកធានាឱ្យអ្នកដទៃក្តីក្នុងអំឡុងពេលកំពុងកាន់តំណែង ឬក្នុងអំឡុងពេលមួយ (១) ឆ្នាំ ក្រោយពីការឈប់កាន់តំណែងដោយប្រការណាក៏ដោយ។

៥-មិនបានរាយការណ៍ ឬមិនបានដាក់ពាក្យបណ្តឹងចំពោះបទល្មើសព្រៃឈើថ្នាក់ទី១ ដែលបានកើតក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួនទាន់ពេលវេលា។

៦-ធ្វេសប្រហែសដោយចេតនាក្នុងការបំពេញភារកិច្ច ឬផ្តល់ព័ត៌មាននូវរបាយការណ៍ក្លែងបន្លំជាលាយលក្ខណ៍អក្សរដែលជាមូលហេតុបង្កឱ្យកើតមានបទល្មើសព្រៃឈើថ្នាក់ទី១។

## ជំពូកទី១៦ ការអនុវត្តសាលក្រមតុលាការ

**មាត្រា១០២**

ការអនុវត្តសាលក្រម ឬសាលដីកាស្ថាពរនៃបទល្មើសព្រៃឈើជាភារកិច្ចរបស់រដ្ឋបាលព្រៃឈើមានសមត្ថកិច្ច លើកលែងតែទោសជាប់ពន្ធនាគារ ។

**មាត្រា១០៣**

រាល់សម្រង់សាលក្រម ឬសាលដីកានៃបទល្មើសព្រៃឈើត្រូវចម្លងមួយច្បាប់ជូនរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ។

**មាត្រា១០៤**

បន្ទាប់ពីសាលក្រម ឬសាលដីកាចូលស្ថាពរ វត្ថុតាងដែលបានរឹបអូសបានត្រូវចាត់ចែងតាមនីតិវិធីដោយរដ្ឋបាលព្រៃឈើ ។

## ជំពូកទី១៧ អន្តរប្បញ្ញត្តិ

**មាត្រា១០៥**

ព្រៃសម្បទានទាំងឡាយ ទោះជាមានស្រាប់នៅមុនពេលច្បាប់នេះចូលជាធរមានក្តី ឬបានផ្តល់ឱ្យក្រោយៗមកទៀតតាមការដាក់ឱ្យដេញថ្លៃជាសាធារណៈ ដូចមានចែងក្នុងមាត្រា១៣នៃច្បាប់នេះក្តី ព្រៃសម្បទានិកត្រូវចុះកិច្ចព្រមព្រៀងព្រៃសម្បទានតាមគំរូថ្មីតែមួយជាមូលដ្ឋាន ។

**មាត្រា១០៦**

នៅទីណាដែលរដ្ឋបាលព្រៃឈើមានភស្តុតាងបញ្ជាក់ថា ការកាន់កាប់ដីព្រៃណាមួយបានមកពីការកាប់រានដីព្រៃឈើរដ្ឋដោយខុសច្បាប់មុនច្បាប់នេះចូលជាធរមាន រដ្ឋបាលព្រៃឈើមានសិទ្ធិចេញលិខិតជូនដំណឹង ក្នុងនាមរាជរដ្ឋាភិបាលជាម្ចាស់កម្មសិទ្ធិលើដីព្រៃឈើរដ្ឋ ដោយធ្វើការបណ្តេញ និងទាមទារកម្មសិទ្ធិដីព្រៃឈើរដ្ឋមកវិញដោយឥតលក្ខខ័ណ្ឌ ។

**មាត្រា១០៧**

នៅពេលច្បាប់នេះចូលជាធរមាន រោងចក្រ និងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើទាំងឡាយដែលបានបង្កើតឡើង និងកំពុងដំណើរការ ក្រោមប្រកាសអនុញ្ញាតរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលត្រូវបានផ្ទេរឱ្យឋិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

សិប្បកម្មកែច្នៃផល អនុផលព្រៃឈើទាំងនេះ ត្រូវបានអនុញ្ញាតឱ្យបន្តសកម្មភាពរហូតដល់ផុតសុពលភាពនៃប្រកាស ។

*វាយឡើងវិញ*

ចំពោះរោងចក្រកែច្នៃផល អនុផលព្រៃឈើ ត្រូវបំពេញបែបបទសុំបន្តផលិតកម្មអាជីវកម្ម ស្របតាមនីតិវិធីដូចមានចែងក្នុងច្បាប់នេះក្នុងរយៈពេលប្រាំមួយ (៦) ខែ គិតពីច្បាប់នេះចូលជាធរមាន។

**ជំពូកទី១៨ អវសានប្បញ្ញត្តិ**

**មាត្រា១០៨**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍។

**មាត្រា១០៩**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងត្រា**

**ជា ស៊ីម**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**ហត្ថលេខា**

**ច័ន្ទ សារុន**

លេខ១៨២ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០៣

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ហត្ថលេខា និងត្រា**

**ស៊ិន សីរី**

## ឧបសម្ព័ន្ធ

## សន្ទានុក្រម

<u>កិច្ចព្រមព្រៀងព្រៃសម្បទាន</u> កិច្ចសន្យារវាងរដ្ឋ និងព្រៃសម្បទានិកសម្រាប់ដំណើរការគ្រប់គ្រង និងប្រមូលផល អនុផលព្រៃឈើ ប្រកបដោយនិរន្តរភាពលើតំបន់ព្រៃឈើសម្បទានដែលរដ្ឋបាន ផ្តល់សិទ្ធិឱ្យប្រើប្រាស់ ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងបណ្តាល័ក្ខខ័ណ្ឌដែលបានព្រមព្រៀង។

<u>ដីសហគមន៍ជនជាតិដើមភាគតិច</u> ដីមានលក្ខណៈស្របច្បាប់សម្រាប់ការចុះបញ្ជិកាដោយរដ្ឋជាសម្បត្តិ របស់សហគមន៍ក្រោមច្បាប់ភូមិបាល។

<u>ថ្លៃសួយសារ</u> បរិមាណប្រាក់បង់ដោយរូបវន្តបុគ្គល នីតិបុគ្គល ឬសហគមន៍ណាមួយជូនរដ្ឋសម្រាប់ ផល អនុផលព្រៃឈើ ដែលបានធ្វើការប្រមូលផលនៅក្នុងព្រៃបម្រុងទុកអចិន្ត្រៃយ៍។

<u>ធនធានព្រៃឈើ</u> ធនធានជីវសាស្ត្រទាំងឡាយដែលកំណត់លើផ្ទៃដីព្រៃឈើមួយជាក់លាក់ រួមមាន ធនធានរុក្ខជាតិ ព្រៃឈើ និងធនធានសត្វព្រៃគ្រប់លំដាប់ថ្នាក់ និងគ្រប់ប្រភេទ រួមទាំងធនធាន ជីវសាស្ត្រផ្សេងៗទៀតដែលឋិតនៅក្នុងនោះ ក្រៅអំពីរ៉ែក្រោមដី។

<u>ប្លុកប្រមូលផល</u> ឯកតាគ្រប់គ្រងតូចបំផុតនៅក្នុងព្រៃគុបដែលមានមុខងារសម្រាប់ត្រួតពិនិត្យលើ កិច្ចដំណើរការប្រមូលផលព្រៃឈើ។

<u>បុព្វលាភ</u> ថ្លៃដែលអ្នកកាន់អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតបង់បន្ថែមលើថ្លៃសួយសារដែលជាល័ក្ខខ័ណ្ឌ មួយសម្រាប់បំពេញការងារលើផ្ទៃដីព្រៃឈើមួយជាក់លាក់។

<u>ប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ</u> សំណុំអន្តរអំពើចម្រុះនៅផ្ទៃដីមួយជាក់លាក់រវាងបណ្តាភាវៈមានជីវិត (សារព័ន្ធរុក្ខជាតិ-សត្វ មីក្រូសរីរាង្គ) ជាមួយនឹងមជ្ឈដ្ឋានគ្មានជីវិត (អាកាសធាតុ មីក្រូ អាកាសធាតុ ដី ទឹក) ដែលបង្កនូវស្ថាបនកម្មរបស់ព្រៃឈើ និងជាឯកតាបំពេញមុខងារមួយនៅលើ សំបកផែនដី។ មនុស្ស រួមជាមួយតម្រូវការផ្នែកសេដ្ឋកិច្ច ប្រពៃណី វប្បធម៌ និងបរិស្ថាន ក៏ជាផ្នែក ចម្រុះរួមមួយនៃបណ្តាប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើដែរ។

<u>ផល អនុផលព្រៃឈើ</u> ផលិតផលដែលផ្តល់ដោយព្រៃឈើរួមមានផលឈើ និងផលមិនមែនឈើ ព្រមទាំងផលិតផលកែច្នៃបន្តរបស់វា ក៏ដូចជាសេវាកម្មដែលផ្តល់ដោយព្រៃឈើ។

<u>ផ្ទៃដីព្រៃសម្រាប់ផ្ទេរដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត</u> ផ្ទៃដីទំនេរដុះរុក្ខជាតិព្រៃបន្ទាប់បន្សំ ដែលចំពោះមុខមិនទាន់ឋិតនៅក្រោមការប្រើប្រាស់ណាមួយនៅឡើយ ហើយត្រូវចាត់ក្នុងព្រៃបម្រុង ទុកអចិន្ត្រៃយ៍ជាបណ្តោះអាសន្ន។

<u>ព្រៃឈើ</u> ឯកតានៃប្រព័ន្ធមជ្ឈដ្ឋានធម្មជាតិ។ សិប្បនិមិត្តក្រោមទម្រង់ជាដីសើម ដីលិចទឹក ឬដីស្ងួត ដែលគ្របដណ្តប់ដោយរុក្ខជាតិចម្រុះ ទោះបីដុះដោយធម្មជាតិក្តី ឬដោយដាំក្តី រួមទាំងធនធានសត្វព្រៃ និងធនធានធម្មជាតិដទៃដែលឋិតនៅក្នុងនោះ ដែលមានគោលបំណងប្រើប្រាស់សំខាន់គឺជាផល អនុផលព្រៃឈើ ឬសេវាកម្មផ្តល់ដោយព្រៃឈើ។ ពុំត្រូវចាត់ទុកជាព្រៃឈើតាមន័យរបស់ច្បាប់នេះ គឺដីដែលបានកំណត់ដោយរដ្ឋជាដីកសិកម្មស្ថេរ រួមមានចម្ការដីទំនេរសម្រាប់ផលិតកម្មកសិកម្ម ក្រៅពីផលឈើ ដីក្នុងតំបន់ឧស្សាហកម្ម និងដីសម្រាប់នគរូបនីយកម្ម និងសំណង់។

<u>ព្រៃបម្រុងទុកអចិន្ត្រៃយ៍</u> ព្រៃឈើរដ្ឋគ្របដណ្តប់លើដី ដែលមិនមែនជាកម្មសិទ្ធិឯកជន និងត្រូវចាត់ថ្នាក់ជាព្រៃផ្តល់ផលព្រៃការពារ និងផ្ទៃដីព្រៃសម្រាប់ផ្ទេរដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត។

<u>ព្រៃផ្តល់ផល</u> តំបន់ព្រៃដែលមានមុខងារចម្បងសម្រាប់ផលិតកម្មផលព្រៃឈើប្រកបដោយនិរន្តរភាព ព្រៃអនុញ្ញាតឱ្យធ្វើអាជីវកម្ម ព្រៃរេចរិល តំបន់ព្រៃឈើត្រូវស្តារឡើងវិញ តំបន់បម្រុងទុកសម្រាប់បន្តពូជព្រៃឈើ ឬចម្ការព្រៃឈើ តំបន់ដាំព្រៃឈើឡើងវិញ និងតំបន់ព្រៃឈើឋិតក្រោមកិច្ចព្រមព្រៀងរវាងរដ្ឋបាលព្រៃឈើ និងសហគមន៍មូលដ្ឋាន។

<u>ព្រៃការពារ</u> តំបន់ព្រៃដែលមានមុខងារចម្បងសម្រាប់ការពារប្រព័ន្ធមជ្ឈដ្ឋានជាអាទិ៍ រក្សានិយតភាពប្រភពទឹក អភិវរក្សជីវៈចម្រុះ អភិរក្សដី ទីជម្រាល តំបន់ព្រៃរងទឹកភ្លៀង ជម្រកសត្វព្រៃមច្ឆជាតិ រាំងទឹកជំនន់ រារាំងការហូរច្រោះ រារាំងការទន្ទ្រាននៃទឹកសមុទ្រ រក្សាជីជាតិដី ឬមានតម្លៃសម្រាប់សម្បត្តិវប្បធម៌ដែលបម្រើប្រយោជន៍សាធារណៈ។ ព្រៃការពារមិនបញ្ចូលនូវតំបន់ការពារធម្មជាតិក្រោមយុត្តាធិការនៃក្រសួងបរិស្ថាន អនុលោមតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឡើយ។

<u>ព្រៃសហគមន៍</u> ព្រៃរបស់រដ្ឋដែលបានផ្តល់ជូនសហគមន៍ក្រោមកិច្ចព្រមព្រៀងរវាងនាយខណ្ឌរដ្ឋបាលព្រៃឈើ ជាមួយសហគមន៍ ឬក្រុមប្រជាពលរដ្ឋរស់នៅក្នុង ឬក្បែរព្រៃដែលពឹងផ្អែកលើព្រៃឈើសម្រាប់ការចិញ្ចឹមជីវិត និងការប្រើប្រាស់ជាប្រពៃណី ហើយដែលបានព្រមព្រៀង ធ្វើការគ្រប់គ្រងនិងប្រើប្រាស់ព្រៃឈើនោះប្រកបដោយនិរន្តរភាព។

<u>ព្រៃឯកជន</u> ចម្ការឈើដែលបានដាំ ឬដើមឈើដែលដុះដោយធម្មជាតិលើដីដែលបានចុះបញ្ជិកា និងផ្តល់ជាកម្មសិទ្ធិឯកជនក្រោមនីតិវិធី និងច្បាប់រដ្ឋ។

<u>ព្រៃសម្បទានិក</u> នីតិបុគ្គល ឬជាអង្គភាពស្របច្បាប់ជាតិ ឬបរទេសដែលត្រូវផ្តល់សិទ្ធិប្រើប្រាស់ចំពោះព្រៃសម្បទានដោយរដ្ឋ តាមរយៈដំណើរការដេញថ្លៃជាសាធារណៈស្របតាមច្បាប់នេះ។

ព្រៃគុប ផ្ទៃដីព្រៃឈើប្រភេទព្រៃផ្តល់ផលដែលកំណត់ដោយភូមិសាស្ត្រជាក់លាក់ និងបង្កើតជាមូលដ្ឋាននៃផ្ទៃដីប្រមូលព្រៃឈើប្រចាំឆ្នាំនីមួយៗ កំណត់នៅក្នុងផែនការគ្រប់គ្រងព្រៃសម្បទាន និងផែនការប្រចាំឆ្នាំ។

រដ្ឋបាលព្រៃឈើ អាជ្ញាធររដ្ឋាភិបាលគ្រប់ថ្នាក់ដែលមានសមត្ថកិច្ចគ្រប់គ្រងព្រៃឈើស្របតាមគោលនយោបាយព្រៃឈើជាតិ និងអនុវត្តតាមច្បាប់នេះ។

វិស័យព្រៃឈើ ប្រព័ន្ធនៃកិច្ចការអនុវត្តចំពោះព្រៃឈើ ផ្ទៃដីព្រៃឈើ និងអនុផលព្រៃឈើក្រោមវិធានគ្រប់គ្រងចម្រុះដែលរួមបញ្ចូលនូវគោលនយោបាយ នីតិកម្ម បច្ចេកទេសវិទ្យាសាស្ត្រ និងរដ្ឋបាលព្រៃឈើ។

សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ព្រៃឈើទូទៅនៃព្រះរាជាណាចក្រកម្ពុជាទោះជាកម្មសិទ្ធិរបស់រដ្ឋ ឬឯកជនដុះដោយធម្មជាតិ ឬដោយដាំក្តីដែលត្រូវបានកំណត់ជាពីរក្រុមៈ ព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងព្រៃឯកជន ហើយត្រូវរក្សាជាគម្របព្រៃឈើជាអចិន្ត្រៃយ៍ដើម្បីធានាដល់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព។

សហគមន៍ ក្រុមអ្នកស្រុករស់នៅក្នុងភូមិមួយ ឬច្រើននៅព្រះរាជាណាចក្រកម្ពុជាដែលមានការចាប់អារម្មណ៍លើបញ្ហាសង្គម វប្បធម៌ ប្រពៃណី និងសេដ្ឋកិច្ចក្នុងការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាពនៃតំបន់មួយដែលគាត់រស់នៅក្នុង ឬក្បែរតំបន់នោះក្នុងគោលបំណងចិញ្ចឹមជីវិត និងកែលំអជីវភាពរស់នៅ។

សហគមន៍មូលដ្ឋាន សហគមន៍ជនជាតិដើមភាគតិច ឬក្រុមអ្នកស្រុកដែលមានលំនៅដើមកំណើតក្នុងភូមិមួយ ឬច្រើនឋិតនៅក្នុង ឬក្បែរតំបន់ព្រៃឈើរដ្ឋដែលមានប្រពៃណី ទំនៀមទម្លាប់ ជំនឿសាសនា វប្បធម៌ និងរស់នៅចិញ្ចឹមជីវិតដោយពឹងអាស្រ័យទៅលើការរុករកផល អនុផលព្រៃឈើ និងប្រើប្រាស់ធនធានព្រៃឈើទាំងនោះជាមូលដ្ឋាន។

សមាគមន៍ព្រៃឈើ សហគមន៍ដែលស្ម័គ្រចិត្តចងក្រងប្រមូលផ្តុំក្រោមកិច្ចព្រមព្រៀងសហគមន៍ព្រៃឈើ ដើម្បីធ្វើសកម្មភាពអភិវឌ្ឍន៍ និងប្រើប្រាស់ធនធានព្រៃឈើប្រកបដោយនិរន្តរភាព នៅក្នុងព្រៃសហគមន៍ ដោយអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីព្រៃឈើ។

អនុផលព្រៃឈើ ផលិតផលមិនមែនជាឈើហ៊ុប ដែលទាញចេញពីព្រៃឈើ រួមមានផលិតផលនៃរុក្ខជាតិមិនមែនឈើ ផលប្រមាញ់នៃសត្វព្រៃ និងសេវាកម្មដែលផ្តល់ដោយព្រៃឈើ ហើយដែលកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ១៩អនក្រ/បក

## អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ/បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញអនុក្រឹត្យលេខ៨៨អនក្រ/បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្ដីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០៣ បានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០២

## សម្រេច

## ជំពូកទី១ បទប្បញ្ញត្តិទូទៅ

**មាត្រា១**

អនុក្រឹត្យនេះកំណត់នីតិវិធី លក្ខណវិនិច្ឆ័យ និងយន្តការសម្រាប់ធ្វើការផ្តល់សម្បទានដីសង្គមកិច្ច ដើម្បីសង់លំនៅឋាន ឬ/និងដើម្បីធ្វើកសិកម្មជាលក្ខណៈគ្រួសារ ។

**មាត្រា២**

ពាក្យទាំងឡាយខាងក្រោមនេះមានន័យដូចតទៅ៖

-សម្បទានដីសង្គមកិច្ចគឺជាយន្តការផ្ទេរដីឯកជនរបស់រដ្ឋតាមផ្លូវច្បាប់ សម្រាប់គោលបំណងសង្គមកិច្ចដល់ជនក្រីក្រដែលខ្វះខាតដីសម្រាប់សង់លំនៅឋាន ឬ/និងធ្វើកសិកម្មជាលក្ខណៈគ្រួសារ

-ដីសម្បទានសង្គមកិច្ច គឺជាដីដែលជាកម្មវត្ថុនៃសម្បទានដីសង្គមកិច្ច

-ការធ្វើកសិកម្មជាលក្ខណៈគ្រួសារ សំដៅសកម្មភាពដាំដំណាំ ឬចិញ្ចឹមសត្វជាលក្ខណៈគ្រួសារដើម្បីបំពេញសេចក្តីត្រូវការជាមូលដ្ឋាន ។

**មាត្រា៣**

ដីសម្បទានសង្គមកិច្ចអាចត្រូវផ្តល់ឱ្យសម្រាប់គោលដៅសង្គមកិច្ច ដោយអនុលោមតាមគោលដៅណាមួយ ឬគោលដៅច្រើនដូចមានខាងក្រោមនេះ៖

១-ផ្តល់ដីដល់គ្រួសារក្រីក្រដែលគ្មានទីលំនៅសម្រាប់សង់លំនៅឋាន ។

២-ផ្តល់ដីដល់គ្រួសារក្រីក្រសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ។

៣-ផ្តល់ដីដល់គ្រួសារដែលត្រូវផ្លាស់ប្តូរទីលំនៅបណ្តាលមកពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សម្រាប់ការតាំងលំនៅឋានជាថ្មី ។

៤-ផ្តល់ដីដល់គ្រួសារដែលរងគ្រោះដោយគ្រោះធម្មជាតិ ។

៥-ផ្តល់ដីដល់គ្រួសារមាតុភូមិនិវត្តន៍ ។

៦-ផ្តល់ដីដល់យោធិនរំសាយ និងគ្រួសារយុទ្ធជនពលី ពិការ ។

៧-ជួយសម្រួលដល់ការអភិវឌ្ឍសេដ្ឋកិច្ច ។

៨-ជួយសម្រួលដល់សម្បទានដីសេដ្ឋកិច្ច ដោយផ្តល់ដីឡូត៍ដល់កម្មករចម្ការធំៗសម្រាប់សង់លំនៅឋាន ឬសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ។

៩-អភិវឌ្ឍតំបន់ដែលពុំទាន់ត្រូវបានអភិវឌ្ឍសមស្រប ។

មាត្រា៤

កម្មវិធីសម្បទានដីសង្គមកិច្ចមាន៖

-កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន

-កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ។

## ជំពូកទី២ កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន

មាត្រា៥

ក្រុមប្រឹក្សាឃុំ-សង្កាត់ជាអ្នកផ្តួចផ្តើមកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ដោយរៀបចំផែនការសម្បទានដីសង្គមកិច្ច ស្របតាមល័ក្ខខ័ណ្ឌចាំបាច់នៃផែនការសម្បទានដីសង្គមកិច្ច ដូចមានចែងក្នុងជំពូកទី៤នៃអនុក្រឹត្យនេះ ។

ប្រជាពលរដ្ឋម្នាក់ ឬច្រើននាក់ ឬអង្គការដែលធ្វើការជាមួយប្រជាពលរដ្ឋ ឬតំណាងប្រជាពលរដ្ឋនៃឃុំ-សង្កាត់នោះ ក៏អាចផ្តួចផ្តើមកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋានបានដែរ ប៉ុន្តែត្រូវធ្វើតាមរយៈក្រុមប្រឹក្សាឃុំ-សង្កាត់នៃឃុំ-សង្កាត់ដែលដីសម្បទានសង្គមកិច្ចនោះឋិតនៅ ដោយរៀបចំផែនការសម្បទានដីសង្គមកិច្ច ស្របតាមល័ក្ខខ័ណ្ឌចាំបាច់នៃផែនការសម្បទានដីសង្គមកិច្ច ដូចមានចែងក្នុងជំពូកទី៤នៃអនុក្រឹត្យនេះ ។

ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវពិនិត្យផែនការសម្បទានដីសង្គមកិច្ចប្រចាំឆ្នាំដោយអនុលោមតាមនីតិវិធីនៃការរៀបចំផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ ដូចមានចែងក្នុងជំពូកទី៦នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ។

*វាយឡើងវិញ*

**មាត្រា៦**

ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវបញ្ជូនផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន តាមរយៈក្រុមការងារថ្នាក់ស្រុក-ខណ្ឌ ទៅគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង ដើម្បីសុំការសម្រេចយល់ព្រម ។

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង អាចផ្តល់ការសម្រេចយល់ព្រមលើផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ប្រសិនបើផែនការសម្បទានដីសង្គមកិច្ចនោះត្រឹមត្រូវតាមលក្ខណវិនិច្ឆ័យដែលបានកំណត់ដោយអនុក្រឹត្យនេះ និងប្រសិនបើពិនិត្យឃើញថា ដីនោះជាដីឯកជនរបស់រដ្ឋដែលនៅទំនេរ ហើយសមស្របសម្រាប់ផែនការសម្បទានដីសង្គមកិច្ច ។

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង ត្រូវជូនដំណឹងដល់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិអំពីផែនការនីមួយៗ ដែលគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុងបានផ្តល់ការសម្រេចយល់ព្រម ។ គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ អាចពិនិត្យកែសម្រួលផែនការ ឬលុបចោលសេចក្តីសម្រេចយល់ព្រមរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង ក្នុងរយៈពេលហុកសិប (៦០) ថ្ងៃ គិតពីថ្ងៃបានទទួលផែនការសម្បទានដីសង្គមកិច្ចនេះ ប្រសិនបើ៖

ក-ផែនការសម្បទានដីសង្គមកិច្ចនោះ មិនស្របនឹងអាទិភាពនៃការប្រើប្រាស់ដីថ្នាក់ជាតិ មានកំហុសបច្ចេកទេស ឬរំលោភបទប្បញ្ញត្តិទាំងឡាយនៃអនុក្រឹត្យនេះ ឬច្បាប់ផ្សេងទៀត ។

ខ-ផែនការដែលបានយល់ព្រម មិនស្របនឹងល័ក្ខខ័ណ្ឌចាំបាច់នៃកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ។

បន្ទាប់ពីបានការយល់ព្រម ក្រុមប្រឹក្សាឃុំ-សង្កាត់ដោយមានជំនួយបច្ចេកទេសពីក្រុមការងារថ្នាក់ស្រុក-ខណ្ឌជាអ្នកអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ។ ផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋានដែលបានទទួលការសម្រេចយល់ព្រមរួចហើយ ត្រូវបើកចំហជាសាធារណៈនៅសាលាឃុំ-សង្កាត់ពាក់ព័ន្ធ នៅគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង និងនៅគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ក្នុងអំឡុងពេលម៉ោងធ្វើការ ។

**ជំពូកទី៣ កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ**

មាត្រា៧

កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិអាចត្រូវបានផ្តួចផ្តើមឡើងដោយក្រសួង ស្ថាប័នពាក់ព័ន្ធមួយ ឬច្រើនក្នុងស្ថានភាពដែលកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន មិនអាចធ្វើបានពិសេសក្នុងស្ថានភាពណាមួយ ដូចខាងក្រោម៖

-កន្លែងដែលមានកម្មវិធីអភិវឌ្ឍន៍ដីនៅតំបន់ដាច់ស្រយាល ដែលពុំទាន់មានប្រជាជនមូលដ្ឋានគ្រប់គ្រាន់ ដើម្បីអភិវឌ្ឍដីនោះ

-កន្លែងដែលមានកម្មវិធីតាំងទីលំនៅថ្មីសម្រាប់គ្រួសារច្រើន ដូចជាករណីដំណោះស្រាយសំណង់បណ្តោះអាសន្ននៅតាមទីប្រជុំជន ឬគ្រួសារដែលត្រូវផ្លាស់ប្តូរទីកន្លែង

-កន្លែងដែលកម្មវិធីសម្បទានដីសង្គមកិច្ចអាចផ្សារភ្ជាប់ទៅនឹងសម្បទានដីសេដ្ឋកិច្ច ដើម្បីអភិវឌ្ឍកសិឧស្សាហកម្ម

-កន្លែងដែលមានកម្មវិធីអភិវឌ្ឍន៍ថ្មី ឬមានកម្មវិធីអភិវឌ្ឍន៍ស្រាប់ដែលត្រូវសម្របសម្រួលដោយថ្នាក់ជាតិ ដូចជាកម្មវិធីដែលគាំទ្រដោយអ្នកផ្តល់ជំនួយ ឬអ្នកវិនិយោគ

-កន្លែងដែលតម្រូវឱ្យមានសម្បទានដីសង្គមកិច្ច ដែលថ្នាក់មូលដ្ឋានមិនអាចធ្វើកម្មវិធីបាន។

ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវដាក់ផែនការសម្បទានដីសង្គមកិច្ច ដែលបានបំពេញល័ក្ខខ័ណ្ឌចាំបាច់នៃផែនការសម្បទានដីសង្គមកិច្ចដូចមានចែងក្នុងជំពូកទី៤នៃអនុក្រឹត្យនេះ ជូនគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិដើម្បីពិនិត្យ។

នៅក្នុងការផ្តួចផ្តើមផែនការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ត្រូវមានការចូលរួមយោបល់ពីគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុងដែលពាក់ព័ន្ធ ក្រុមប្រឹក្សាឃុំ-សង្កាត់ និងប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់នោះ។

មាត្រា៨

គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិអាចផ្តល់ការយល់ព្រមលើផែនការ ដែលបានស្នើឡើង ឬអាចកែសម្រួលផែនការនេះដោយពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដែលបានទទួលការសម្រេចយល់ព្រមរួចហើយត្រូវអនុវត្តដោយក្រសួង ស្ថាប័ន ឬម្ចាស់សំណើតាមការកំណត់ នៅក្នុងផែនការសម្បទានដីសង្គមកិច្ច

ថ្នាក់ជាតិ ដោយមានការសម្របសម្រួលជាមួយគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង ក្រុមប្រឹក្សាឃុំ-សង្កាត់ និងប្រជាពលរដ្ឋនៅក្នុងតំបន់ពាក់ព័ន្ធ លើកលែងតែកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិចែងផ្សេងពីនេះ។ ផែនការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិដែលបានទទួលការសម្រេចយល់ព្រមរួចហើយត្រូវបើកចំហជាសាធារណៈនៅសាលាឃុំ-សង្កាត់ពាក់ព័ន្ធ នៅគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង និងនៅគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិក្នុងអំឡុងពេលម៉ោងធ្វើការ។

## ជំពូកទី៤ ល័ក្ខខ័ណ្ឌចាំបាច់ដើម្បីធ្វើផែនការសម្បទានដីសង្គមកិច្ច

**មាត្រា៩**

ល័ក្ខខ័ណ្ឌចាំបាច់ដើម្បីធ្វើផែនការសម្បទានដីសង្គមកិច្ចរួមមាន៖

ក-ការពិពណ៌នាអំពីដី និងផែនការប្រើប្រាស់ដី ដែលត្រូវបំពេញតាមនីតិវិធីនៃការរៀបចំផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ ដូចមានចែងក្នុងជំពូកទី៦នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់។

ខ-ព័ត៌មានអំពីអត្តសញ្ញាណកម្មដី កម្មសិទ្ធិដី និងការបញ្ជាក់អំពីដីដែលនៅទំនេរ ដែលអាចប្រើប្រាស់បានសម្រាប់សម្បទានដីសង្គមកិច្ច ឬសមស្របសម្រាប់ប្រើប្រាស់ក្នុងផែនការសម្បទានដីសង្គមកិច្ច។

គ-ព័ត៌មានលំអិតអំពីការជ្រើសរើសមុខសញ្ញាអ្នកទទួលដីរួមមាន៖

-ភាពអនុគ្រោះនានាសម្រាប់ក្រុមជនងាយរងគ្រោះ ដូចមានចែងក្នុងមាត្រា១១នៃអនុក្រឹត្យនេះ

-មធ្យោបាយដែលបានប្រើសម្រាប់ធ្វើការត្រួតពិនិត្យឡើងវិញ អំពីការបំពេញលក្ខណវិនិច្ឆ័យនៃភាពអាចជ្រើសរើសបាន និងភាពអនុគ្រោះរបស់មុខសញ្ញាអ្នកទទួលដី។

ឃ-ផែនការលំអិតសម្រាប់ការបែងចែកដីដល់មុខសញ្ញាអ្នកទទួលដី រួមទាំងល័ក្ខខ័ណ្ឌពិសេសនានានៃការកាន់កាប់ និងប្រើប្រាស់ដី។

ង-ព័ត៌មានលំអិតអំពីដំណើរការដាក់ពាក្យសុំ រួមមានទីកន្លែងដាក់ពាក្យ អ្នកទទួលខុសត្រូវក្នុងការផ្សព្វផ្សាយអំពីដំណើរការដាក់ពាក្យ និងអ្នកទទួលខុសត្រូវ ក្នុងការបិទផ្សាយឈ្មោះអ្នកដាក់ពាក្យសុំ កន្លែងបិទផ្សាយសេចក្តីជូនដំណឹង ព្រមទាំងព័ត៌មានលំអិតផ្នែករដ្ឋបាលផ្សេងៗទៀត។

ច-ការវាយតម្លៃអំពីលទ្ធភាពផ្នែកហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ដើម្បីអនុវត្តផែនការនេះ ដែលរួមមាន ផ្លូវថ្នល់ ទឹក អគ្គិសនី សាលារៀន ទីផ្សារ មណ្ឌលសុខភាព ព្រមទាំងឧបករណ៍ សម្ភារៈសម្រាប់អភិវឌ្ឍដី សេវាផ្សេងទៀត ព័ត៌មានអំពីរបៀប និងពេលវេលាដែលត្រូវរៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងផ្តល់សេវាសាធារណៈទាំងនោះ ។

ឆ-ការវាយតម្លៃផលប៉ះពាល់សង្គម និងបរិស្ថាននៃកម្មវិធី និងការពិចារណាអំពីវិធានការសមស្រប ។

ជ-តម្រូវការផ្សេងទៀត ត្រូវកំណត់ដោយគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ។

**មាត្រា១០**

អ្នកសុំដីសម្បទានសង្គមកិច្ចត្រូវមានលក្ខណសម្បត្តិដូចតទៅ៖

ក-មានសញ្ជាតិខ្មែរ និងមានសមត្ថភាពតាមផ្លូវច្បាប់ដើម្បីធ្វើជាម្ចាស់ដី ។

ខ-ជាមេគ្រួសារនៃគ្រួសារដែលមានសមាជិកពីរនាក់ ឬច្រើននាក់ដែលជាប់សាច់សាលោហិតជាមួយគ្នា ឬមានចំណងអាពាហ៍ពិពាហ៍ និងរស់នៅជាមួយគ្នាក្នុងលំនៅឋានតែមួយ ។

គ-បំពេញលក្ខណវិនិច្ឆ័យខាងហិរញ្ញវត្ថុ ដែលកំណត់ដោយប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាល និងយុវនីតិសម្បទា ដោយផ្អែកលើយោបល់របស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ។ គោលការណ៍ណែនាំអំពីការវាយតម្លៃប្រាក់ចំណូលត្រូវពិចារណាដោយផ្អែកលើទំហំគ្រួសារ និងល័ក្ខខ័ណ្ឌ អាយុ និងសុខភាពនៃសមាជិកគ្រួសារ ។ គោលការណ៍ណែនាំនេះអាចប្រែប្រួលទៅតាមតំបន់ ទៅតាមពេលវេលា ស្របតាមល័ក្ខខ័ណ្ឌសេដ្ឋកិច្ច និងជីវភាពរស់នៅ ។

ឃ-មិនមែនជាកម្មសិទ្ធិករ ឬភោគីនៃដីផ្សេងទៀតដែលមានទំហំស្មើ ឬលើសពីការកំណត់ទំហំដីសម្បទានសង្គមកិច្ច ដូចមានចែងក្នុងមាត្រា១៦ និងមាត្រា១៧នៃអនុក្រឹត្យនេះ ។

ង-បានត្រៀមខ្លួនជាស្រេច មានឆន្ទៈ និងមានលទ្ធភាពចូលរួមក្នុងកម្មវិធីសម្បទានដីសង្គមកិច្ចស្របតាមផែនការសម្បទានដីសង្គមកិច្ចដែលបានយល់ព្រម ។

គ្មានជនណាម្នាក់អាចបដិសេធសិទ្ធិចូលរួមក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច របស់មេគ្រួសារជាស្ត្រី ជាជនបាត់បង់សមត្ថភាព ជាអតីតយុទ្ធជនដែលបាត់បង់សមត្ថភាព ជាយោធិនរំសាយបានឡើយ ។

**មាត្រា១១**

ក្នុងករណី អ្នកសុំដីមានចំនួនច្រើនជាងចំនួនដីសម្បទានសង្គមកិច្ច ផែនការសម្បទានដីសង្គមកិច្ចអាចបញ្ចូលលក្ខណវិនិច្ឆ័យសមហេតុផលសម្រាប់ផ្ដល់ភាពអនុគ្រោះក្នុងការជ្រើសរើសមុខសញ្ញាអ្នកទទួលដី ឬសម្រាប់ការបែងចែកដីសម្បទានសង្គមកិច្ច ដោយផ្អែកលើ៖

-គ្រួសារធំ ដែលមានសមាជិកចាប់ពីប្រាំមួយ (៦) នាក់ឡើងទៅ

-រយៈពេលដែលគ្រួសារបានរស់នៅក្នុងតំបន់ដីសម្បទានសង្គមកិច្ចនោះ

-មេគ្រួសារជាស្ត្រី ជាជនដែលបាត់បង់សមត្ថភាព ជាអតីតយុទ្ធជនដែលបាត់បង់សមត្ថភាព ជាយោធិនរំសាយ ។

**មាត្រា១២**

សេចក្ដីជូនដំណឹងនៃការដាក់ពាក្យសុំដីសម្បទានសង្គមកិច្ចត្រូវធ្វើជាចំហ និងត្រូវផ្សព្វផ្សាយនៅទីសាធារណៈមួយ ឬច្រើនកន្លែងក្នុងតំបន់ដីសម្បទាននោះ ក្នុងរយៈពេលយ៉ាងតិចសាមសិប (៣០) ថ្ងៃ មុនកាលបរិច្ឆេទនៃការទទួលពាក្យសុំ ។

ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ដីសម្បទានសង្គមកិច្ច អាចដាក់ពាក្យសុំដីសម្បទានសង្គមកិច្ចនៅសាលាឃុំ-សង្កាត់ដែលបានកំណត់ក្នុងសេចក្ដីជូនដំណឹងនោះ ដោយត្រូវបំពេញតាមគំរូពាក្យសុំ ។

គំរូពាក្យសុំត្រូវកំណត់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

អ្នកសុំដីសម្បទានសង្គមកិច្ចត្រូវបញ្ជាក់អំពីប្រភេទដីដែលស្នើសុំ ជាដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ឬជាដីសម្រាប់សង់លំនៅឋាន ឬជាដីទាំងពីរប្រភេទ ដូចមានចែងក្នុងជំពូកទី៥ នៃអនុក្រឹត្យនេះ ។

គ្រួសារណាដែលពុំត្រូវបានជ្រើសរើសជាមុខសញ្ញាអ្នកទទួលដីក្នុងផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋានអាចដាក់ពាក្យសុំទៅគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដើម្បីសុំដីសម្បទានសង្គមកិច្ចក្នុងផែនការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ។

**មាត្រា១៣**

បញ្ជីរាយនាមអ្នកសុំដីសម្បទានសង្គមកិច្ចទាំងអស់ត្រូវបិទផ្សាយជាសាធារណៈ រយៈពេលយ៉ាងតិចសាមសិប (៣០) ថ្ងៃ មុនពេលធ្វើការវាយតម្លៃ ។ កន្លែងបិទផ្សាយត្រូវបញ្ជាក់ក្នុងផែនការសម្បទានដីសង្គមកិច្ច ។

ក្រុមការងារថ្នាក់ស្រុក-ខណ្ឌដែលមានចែងក្នុងមាត្រា១៩ និងមាត្រា២៦នៃអនុក្រឹត្យនេះ ត្រូវផ្តល់ជំនួយបច្ចេកទេសក្នុងការវាយតម្លៃលើគ្រប់ពាក្យសុំ ដើម្បីកំណត់ថា អ្នកសុំដីបានបំពេញលក្ខណវិនិច្ឆ័យនៃភាពអាចជ្រើសរើសបាន ដូចបានកំណត់ក្នុងមាត្រា១០ និងមាត្រា១១ នៃអនុក្រឹត្យនេះ ។

ការសម្រេចយល់ព្រម ឬមិនយល់ព្រមលើពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ហេតុផលនៃការសម្រេចយល់ព្រម ឬមិនយល់ព្រមចំពោះអ្នកសុំដីម្នាក់ៗ និងត្រូវផ្សព្វផ្សាយជាសាធារណៈ ។

**មាត្រា១៤**

អ្នកសុំដីដែលពុំមានឈ្មោះនៅក្នុងផែនការសម្បទានដីសង្គមកិច្ច ហើយជឿជាក់ថាពាក្យសុំរបស់ខ្លួនត្រូវបានបកស្រាយមិនស្របតាមច្បាប់ភូមិបាល ឬច្បាប់ផ្សេងទៀត អាចស្នើសុំឱ្យគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង ឬគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិពិនិត្យឡើងវិញ ដោយដាក់សំណើជាលាយលក្ខណ៍អក្សរក្នុងរយៈពេលម្ភៃ (២០) ថ្ងៃ បន្ទាប់ពីសេចក្តីសម្រេចយល់ព្រម ឬជំទាស់ទៅនឹងការស្នើសុំនោះត្រូវបានបិទផ្សាយ ដូចមានចែងក្នុងមាត្រា១៣នៃអនុក្រឹត្យនេះ ។

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង ឬគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ត្រូវធ្វើការស៊ើបអង្កេតបណ្តឹង និងចាត់វិធានការសមស្រប ក្នុងរយៈពេលមិនឱ្យលើសពីសាមសិប (៣០) ថ្ងៃ បន្ទាប់ពីគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង ឬគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ បានសម្រេចយល់ព្រមលើផែនការសម្បទានដីសង្គមកិច្ចដែលពាក់ព័ន្ធ ។

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង និងគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ត្រូវរក្សាទុកបញ្ជីអ្នកសុំដីសម្បទានសង្គមកិច្ចដែលបានដាក់ពាក្យសុំ ។

បញ្ជីឈ្មោះអ្នកដាក់ពាក្យសុំដីសម្បទានសង្គមកិច្ច ត្រូវបើកចំហជាសាធារណៈក្នុងអំឡុងពេលម៉ោងធ្វើការ ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចេញសេចក្តីណែនាំស្តីពីគោលការណ៍សម្រាប់បង្កើត និងរក្សាទុកបញ្ជីឈ្មោះអ្នកសុំដី ។

## ជំពូកទី៥ ប្រភេទដីសម្បទានសង្គមកិច្ច និងល័ក្ខខ័ណ្ឌនៃការកាន់កាប់

### មាត្រា១៥

ដីសម្បទានសង្គមកិច្ចអាចត្រូវបានផ្តល់ឱ្យសម្រាប់សង់លំនៅឋាន ឬសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ឬសម្រាប់គោលដៅទាំងពីរ ។

### មាត្រា១៦

ដីសម្បទានសង្គមកិច្ច ដែលត្រូវផ្តល់ឱ្យសម្រាប់សង់លំនៅឋាន មានទំហំធំបំផុតមួយពាន់ពីររយ (១.២០០) ម៉ែត្រការ៉េ ។ ប៉ុន្តែ នៅតំបន់ជនបទដែលមានលទ្ធភាពដីទំនេរ ទំហំដីសម្បទានសង្គមកិច្ចអាចដំឡើងរហូតដល់បីពាន់ប្រាំមួយរយ (៣.៦០០) ម៉ែត្រការ៉េ ។

ក្នុងករណីសមស្រប ពិសេសនៅតំបន់ទីក្រុង សម្បទានដីសង្គមកិច្ចសម្រាប់សង់លំនៅឋានអាចផ្តល់ឱ្យតាមរូបភាពសហកម្មសិទ្ធិ ។

### មាត្រា១៧

ដីសម្បទានសង្គមកិច្ចដែលត្រូវផ្តល់ឱ្យសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ មានទំហំធំបំផុតពីរ (០២) ហិកតា ។ ប៉ុន្តែ នៅក្នុងតំបន់ខ្លះ ទំហំដីសម្បទានសង្គមកិច្ច អាចដំឡើងរហូតដល់ប្រាំ (០៥) ហិកតាអាស្រ័យទៅតាមលក្ខណៈដី សក្តានុពលដី ឬប្រភេទដំណាំ និងកម្លាំងពលកម្មរបស់គ្រួសារអ្នកសុំដី ។

### មាត្រា១៨

មុខសញ្ញាអ្នកទទួលដីត្រូវធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ជាមួយអាជ្ញាធរមានសមត្ថកិច្ចផ្តល់ដីដែលបញ្ជាក់អំពីសិទ្ធិ និងការទទួលខុសត្រូវរបស់មុខសញ្ញាអ្នកទទួលដី អនុលោមតាមកម្មវិធីសម្បទានដីសង្គមកិច្ចនេះ និងចែងពីករណីលើកលែង ដូចជាករណីប្រធានសក្តិ ឬមានជំងឺធ្ងន់ធ្ងរដែលរារាំងដល់ការបំពេញកាតព្វកិច្ចទទួលខុសត្រូវនោះ ។ ទម្រង់ និងបែបបទសម្រាប់កិច្ចសន្យាជាលាយលក្ខណ៍អក្សរនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ក្នុងករណីផែនការសម្បទានដីសង្គមកិច្ច ដែលបានសម្រេចយល់ព្រមពុំមានចែងជាពិសេសផ្សេងពីនេះ នោះវិធាននៃការកាន់កាប់ និងប្រើប្រាស់ដីក្នុងមាត្រានេះត្រូវអនុវត្តទៅលើសម្បទានដីសង្គមកិច្ចទាំងអស់ ។

ប្រសិនបើគ្មានរចនាសម្ព័ន្ធលំនៅឋានលើដីលំនៅឋាននៃសម្បទានដីសង្គមកិច្ច មុខសញ្ញាអ្នកទទួលដីត្រូវសាងសង់យ៉ាងហោចណាស់នូវចំណែកណាមួយ នៃជម្រកស្នាក់នៅជាអចិន្ត្រៃយ៍ ក្នុងរយៈពេលបី (០៣) ខែ បន្ទាប់ពីទទួលបានដី ហើយសមាជិកនៃគ្រួសារនោះត្រូវរស់នៅពិតប្រាកដ និងជាអចិន្ត្រៃយ៍លើដីនោះឱ្យបានលើសពីប្រាំមួយ (០៦) ខែ ក្នុងមួយឆ្នាំ។

មុខសញ្ញាអ្នកទទួលដីសម្បទានសង្គមកិច្ចសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ត្រូវធ្វើកសិកម្មជាក់ស្តែងលើដីនោះក្នុងរយៈពេលដប់ពីរ(១២) ខែ បន្ទាប់ពីបានទទួលដី ហើយបន្តប្រើប្រាស់ដីនេះស្របតាមល័ក្ខខ័ណ្ឌចាំបាច់នៃកម្មវិធីសម្បទាន។

បន្ទាប់ពីបានអនុវត្តត្រឹមត្រូវតាមកម្មវិធីសម្បទានដីសង្គមកិច្ចបានប្រាំ(០៥) ឆ្នាំ មុខសញ្ញាអ្នកទទួលដីមានសិទ្ធិកម្មសិទ្ធិលើដីនោះ និងអាចស្នើសុំប័ណ្ណកម្មសិទ្ធិ តាមនីតិវិធីដូចមានចែងនៅក្នុងសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ក្នុងករណីមុខសញ្ញាអ្នកទទួលដី ទទួលមរណភាពនៅក្នុងរយៈពេលកំពុងអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ទាយាទក្នុងគ្រួសារនៃមុខសញ្ញាអ្នកទទួលដីអាចបន្តអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចនេះរហូតដល់គ្រប់ប្រាំ (០៥) ឆ្នាំ ហើយមានសិទ្ធិកម្មសិទ្ធិលើដីនោះ។

មុខសញ្ញាអ្នកទទួលដីមិនអាចលក់ ដូរ ជួល ឬធ្វើអំណោយដីសម្បទានសង្គមកិច្ច ក្នុងរយៈពេលប្រាំ (០៥) ឆ្នាំដំបូងនៃការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចនេះទេ។

ប្រសិនបើមុខសញ្ញាអ្នកទទួលដីសម្បទានសង្គមកិច្ចណា ខកខានមិនបានបំពេញតាមល័ក្ខខ័ណ្ឌនៃការកាន់កាប់ និងប្រើប្រាស់ដីសម្បទាននោះ ដីនេះនឹងត្រូវវិលមកជាដីរបស់រដ្ឋវិញ ដើម្បីធ្វើការបែងចែកសាជាថ្មី។

នីតិវិធីនៃការដកហូតដីសម្បទានសង្គមកិច្ច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដោយត្រូវចែងអំពី៖

-ការជូនដំណឹងជាមុនក្នុងពេលវេលាសមស្របមួយ ដល់មុខសញ្ញាអ្នកទទួលដីដែលខកខានមិនបានបំពេញតាមល័ក្ខខ័ណ្ឌនៃការកាន់កាប់ និងប្រើប្រាស់ដីសម្បទានសង្គមកិច្ច

-ការទុកឱកាសឱ្យមុខសញ្ញាអ្នកទទួលដីឆ្លើយតប

-សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ

-គោលការណ៍ណែនាំអំពីការរើរុះ និងការកំណត់សោហ៊ុយខូចខាតសមស្រប សម្រាប់មុខសញ្ញាអ្នកទទួលដី។

## ជំពូកទី៦ ការគ្រប់គ្រងរដ្ឋបាល និងការអនុវត្ត

### មាត្រា១៩

យន្តការសម្បទានដីសង្គមកិច្ចមានបេសកកម្មផ្តួចផ្តើម និងរៀបចំកម្មវិធីសម្បទានដីសង្គមកិច្ច ធ្វើការសម្រេចលើផែនការសម្បទានដីសង្គមកិច្ច និងអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចសំដៅធ្វើការបែងចែកដីឱ្យប្រជាពលរដ្ឋដោយតម្លាភាព និងប្រសិទ្ធភាព។

យន្តការសម្បទានដីសង្គមកិច្ចមានដូចតទៅ៖

១-គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ មានអក្សរកាត់ គ.ស.ស.ជ. មានទីតាំងនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

២-គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង មានអក្សរកាត់ គ.ប.ខ. មានទីតាំងនៅសាលាខេត្ត-ក្រុង និងប្រើប្រាស់ត្រារបស់សាលាខេត្ត-ក្រុង។

៣-ក្រុមការងារថ្នាក់ស្រុក-ខណ្ឌ មានអក្សរកាត់ ក.ក.ស. មានទីតាំងនៅសាលាស្រុកខណ្ឌ និងប្រើប្រាស់ត្រារបស់សាលាស្រុក-ខណ្ឌ។

៤-ក្រុមប្រឹក្សាឃុំ-សង្កាត់។

### មាត្រា២០

គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ជាស្ថាប័នកំណត់គោលនយោបាយសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ និងឋិតនៅក្រោមការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី។

គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិមានមុខងារ និងភារកិច្ចដូចតទៅ៖

-ត្រួតពិនិត្យ តាមដានការផ្តល់សម្បទានដីសង្គមកិច្ច និងធ្វើការកែសម្រួលគោលនយោបាយ និងបទប្បញ្ញត្តិនានាប្រសិនបើចាំបាច់

-ពិនិត្យកែសម្រួល ឬលុបចោលការសម្រេចលើផែនការប្រើប្រាស់ និងបែងចែកដីនៅថ្នាក់ខេត្ត-ក្រុង ក្នុងស្ថានភាពដែល៖

វាយឡើងវិញ

+មិនស្របនឹងអាទិភាពនៃការប្រើប្រាស់ដីថ្នាក់ជាតិ

+មានកំហុសបច្ចេកទេស ឬរំលោភលើបញ្ញត្តិទាំងឡាយនៃអនុក្រឹត្យ ឬច្បាប់ផ្សេងទៀត

+ផែនការដែលបានសម្រេចយល់ព្រម មិនស្របគ្នាទៅនឹងល័ក្ខខ័ណ្ឌចាំបាច់នៃកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ

-ផ្តល់ការគាំទ្របច្ចេកទេសដល់ការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច

-ធ្វើសនិទានកម្មដីទំនេរ ជាមួយនឹងតម្រូវការដីសម្បទានសង្គមកិច្ច

- សម្របសម្រួលការអភិវឌ្ឍដីដែលគ្មានសេវា និងមិនអាចប្រើប្រាស់

-ផ្សារភ្ជាប់សម្បទានដីសង្គមកិច្ចទៅនឹងការបង្កើត ការប្រតិបត្តិ និងការកាត់បន្ថយសម្បទានដីសេដ្ឋកិច្ច

-ផ្តួចផ្តើមកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិដោយផ្ទាល់

-ត្រួតពិនិត្យការរីកចម្រើនក្នុងការអនុវត្តការប្រើប្រាស់ដីសម្បទានសង្គមកិច្ច

-សម្របសម្រួលមធ្យោបាយ និងថវិកាសម្រាប់ដំណើរការការងាររបស់យន្តការសម្បទានដីសង្គមកិច្ចគ្រប់ថ្នាក់។

**មាត្រា២១**

គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ មានសមាសភាពដូចតទៅ៖

| | |
|---|---|
| -រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ជាប្រធាន |
| -រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ជាសមាជិក |
| -រដ្ឋលេខាធិការក្រសួងការពារជាតិ | ជាសមាជិក |
| -រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| -រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| -រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិក |
| -រដ្ឋលេខាធិការក្រសួងផែនការ | ជាសមាជិក |
| -រដ្ឋលេខាធិការក្រសួងកិច្ចការនារី និងអតីតយុទ្ធជន | ជាសមាជិក |
| -រដ្ឋលេខាធិការក្រសួងបរិស្ថាន | ជាសមាជិក |

-រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម ជាសមាជិក

-រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ជាសមាជិក

-អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម ជាអគ្គលេខាធិការ ។

ប្រធានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ អាចអញ្ជើញតំណាងក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងទៀតចូលរួមជាសមាជិកតាមតម្រូវការនៃករណីនីមួយៗ ។

គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ។

ប្រធាន និងសមាជិកនៃគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ។

**មាត្រា២២**

អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដឹកនាំដោយអគ្គលេខាធិការនៃគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ។

អគ្គលេខាធិការដ្ឋាននេះមានមុខងារ និងភារកិច្ចដូចខាងក្រោម៖

-លើកគោលការណ៍ត្រួតពិនិត្យ តាមដានការផ្តល់សម្បទានដីសង្គមកិច្ច និងកែសម្រួលគោលនយោបាយ និងបទប្បញ្ញត្តិនានាជូនគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដើម្បីពិនិត្យ និងសម្រេច

-លើកគោលការណ៍លុបចោលការសម្រេច ឬកែសម្រួលផែនការប្រើប្រាស់ និងបែងចែកដីនៅថ្នាក់ខេត្ត-ក្រុងជូនគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដើម្បីពិនិត្យ និងសម្រេច

-ធ្វើជាជំនួយការបច្ចេកទេស ក្នុងការធ្វើអត្តសញ្ញាណកម្មដីសម្បទានសង្គមកិច្ច ការធ្វើសនិទានកម្មដីទំនេរ ជាមួយនឹងតម្រូវការដីសម្បទាន

-រៀបចំកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដាក់ជូនគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដើម្បីពិនិត្យ និងសម្រេច

-លើកផែនការសកម្មភាពការងាររបស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ

-អនុវត្តសេចក្តីសម្រេចរបស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ

-ជំរុញការតាមដាន វាយតម្លៃលើការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ព្រមទាំងធ្វើរបាយការណ៍ទៀងទាត់អំពីលទ្ធផលការងារជូនគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ

-រៀបចំ និងសម្រួលកិច្ចប្រជុំរបស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ

-បំពេញភារកិច្ចផ្សេងទៀត តាមការណែនាំរបស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ។

មន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋាន ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តាមសំណើរបស់អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ។

**មាត្រា២៣**

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង ជាស្ថាប័នកំណត់គោលនយោបាយសម្បទានដីសង្គមកិច្ចថ្នាក់ខេត្ត-ក្រុង ។

គណៈកម្មាធិការនេះមានមុខងារ និងភារកិច្ច៖

-ធានាឱ្យមានការអនុវត្តស្តង់ដារសម្រាប់ធ្វើចំណាត់ថ្នាក់ដី និងធ្វើផែនការប្រើប្រាស់ដី

-កំណត់អត្តសញ្ញាណកម្មដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ

-ត្រួតពិនិត្យ និងធ្វើសនិទានកម្មចំនួនដីទំនេរឱ្យស្របទៅនឹងសេចក្តីត្រូវការរបស់មុខសញ្ញាអ្នកទទួលដីនៅគ្រប់ស្រុក-ខណ្ឌនៃខេត្ត-ក្រុង

-ពិនិត្យឡើងវិញ និងវាយតម្លៃផែនការប្រើប្រាស់ដី និងផែនការសម្បទានដីសង្គមកិច្ចដែលក្រុមប្រឹក្សាឃុំ-សង្កាត់បានស្នើឡើង

-សម្រេចយល់ព្រមលើការធ្វើចំណាត់ថ្នាក់ដី ការធ្វើផែនការប្រើប្រាស់ដី និងសម្រេចលើការបែងចែកដីរដ្ឋនៅថ្នាក់ខេត្ត-ក្រុង

-ជួយក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីរៀបចំផែនការប្រើប្រាស់ដី និងធ្វើចំណាត់ថ្នាក់ដី

-សម្រេចយល់ព្រម ឬបដិសេធ ឬកែសម្រួលផែនការសម្បទានដីសង្គមកិច្ចដែលក្រុមប្រឹក្សាឃុំ-សង្កាត់បានស្នើឡើង

-បញ្ជូនផែនការសម្បទានដីសង្គមកិច្ច និងសេចក្តីសម្រេចយល់ព្រមលើផែនការសម្បទានដីសង្គមកិច្ចទៅថ្នាក់ជាតិ ដើម្បីពិនិត្យ

-សម្របសម្រួលជាមួយក្រសួងនានា ដើម្បីរៀបចំផែនការប្រើប្រាស់ដីសម្រាប់អភិវឌ្ឍ

-សហការជាមួយអាជ្ញាធរមីន ចំពោះកន្លែងដែលមានមីន ។

**មាត្រា២៤**

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុងមានសមាសភាពដូចតទៅ៖

| | |
|---|---|
| -អភិបាល ឬអភិបាលរងខេត្ត-ក្រុង | ជាប្រធាន |
| -មេបញ្ជាការផ្នែកសឹករងខេត្ត-ក្រុង | ជាសមាជិក |
| -ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី | ជាសមាជិក |
| -ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| -ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| -ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិក |
| -ប្រធានមន្ទីរផែនការ | ជាសមាជិក |
| -ប្រធានមន្ទីរកិច្ចការនារី និងអតីតយុទ្ធជន | ជាសមាជិក |
| -ប្រធានមន្ទីរបរិស្ថាន | ជាសមាជិក |
| -ប្រធានមន្ទីរធនធានទឹក និងឧតុនិយម | ជាសមាជិក |
| -ប្រធានមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា | ជាសមាជិក |

ប្រធានគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុងអាចអញ្ជើញតំណាងមន្ទីរពាក់ព័ន្ធផ្សេងទៀត ចូលរួមជាសមាជិកតាមតម្រូវការនៃករណីនីមួយៗ ។

ប្រធាន និងសមាជិកនៃគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង ត្រូវបានតែងតាំងដោយប្រធានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ។

ប្រធានគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុងត្រូវតែងតាំងមន្ត្រីម្នាក់ ឬច្រើននាក់ដោយមានការយល់ព្រមរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង ដើម្បីជួយគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុងក្នុងកិច្ចការរដ្ឋបាល ។

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុងមានអង្គភាពគាំទ្របច្ចេកទេស បីជាជំនួយការ។

**មាត្រា២៥**

អង្គភាពគាំទ្របច្ចេកទេសនៃគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង រួមមាន៖

១-អង្គភាពគាំទ្របច្ចេកទេសការងារដីធ្លី ដឹកនាំដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង។ អង្គភាពនេះមានភារកិច្ច៖

-កំណត់អត្តសញ្ញាណកម្មដី ដែលសមស្របសម្រាប់សម្បទានដីសង្គមកិច្ច

-ធានាការជ្រើសរើសដីសម្បទានបានត្រឹមត្រូវ និងមានតម្លាភាព។

២-អង្គភាពគាំទ្របច្ចេកទេសការងារជ្រើសរើសមុខសញ្ញាអ្នកទទួលដី ដឹកនាំដោយអាជ្ញាធរខេត្ត-ក្រុង។ អង្គភាពនេះមានភារកិច្ច៖

-ធានាការជ្រើសរើសមុខសញ្ញាអ្នកទទួលដីបានសមស្រប ដោយផ្អែកលើលក្ខណវិនិច្ឆ័យនៃការជ្រើសរើស

-តាមដានត្រួតពិនិត្យគម្រោងសម្បទានដីសង្គមកិច្ច និងមុខសញ្ញាអ្នកទទួលដី។

៣-អង្គភាពគាំទ្របច្ចេកទេសការងារអភិវឌ្ឍ ដឹកនាំដោយមន្ទីរអភិវឌ្ឍន៍ជនបទ។ អង្គភាពនេះមានភារកិច្ច៖

-ត្រួតពិនិត្យបញ្ហាអភិវឌ្ឍន៍ជាទូទៅ ព្រមទាំងធ្វើសនិទានកម្មចំនួនដីនឹងចំនួនអ្នកសុំដីនៅក្នុងខេត្ត-ក្រុងទាំងមូល

-ធានាហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារៈប្រើប្រាស់ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការសម្បទានដីសង្គមកិច្ច ហើយសម្ភារៈទាំងនេះត្រូវមាននៅនឹងកន្លែងតាមកាលកំណត់។

សមាសភាពនៃអង្គភាពគាំទ្របច្ចេកទេស ត្រូវបានជ្រើសរើសមន្ត្រីពីសាលាខេត្ត-ក្រុង និងពីមន្ទីរជុំវិញខេត្ត-ក្រុង ដែលជាសមាជិករបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង។

ប្រធាន និងមន្ត្រីបម្រើការក្នុងអង្គភាពគាំទ្របច្ចេកទេសត្រូវបានតែងតាំងដោយអភិបាលខេត្ត-ក្រុង។

ប្រសិនបើមានរចនាសម្ព័ន្ធស្រាប់ ដើម្បីបំពេញតាមតម្រូវការផ្អែកនេះ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុងអាចប្រើប្រាស់រចនាសម្ព័ន្ធនោះ។

**មាត្រា២៦**

ក្រុមការងារថ្នាក់ស្រុក-ខណ្ឌមានមុខងារ និងភារកិច្ចដូចតទៅ៖

-អនុវត្តការងាររបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុងនៅស្រុក-ខណ្ឌ

-ផ្តល់ជំនួយបច្ចេកទេសដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងការធ្វើអត្តសញ្ញាណកម្មដី ធ្វើចំណាត់ថ្នាក់ដី ធ្វើផែនការប្រើប្រាស់ដី ជ្រើសរើសមុខសញ្ញាអ្នកទទួលដី និងអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច

-ធានាការបែងចែកដីសម្បទានសង្គមកិច្ចថ្នាក់មូលដ្ឋានមានប្រសិទ្ធភាព និងតម្លាភាព។

**មាត្រា២៧**

សមាសភាពនៃក្រុមការងារថ្នាក់ស្រុក-ខណ្ឌមានដូចតទៅ៖

| | |
|---|---|
| -អភិបាល ឬអភិបាលរងស្រុក-ខណ្ឌ | ជាប្រធាន |
| -ប្រធានការិយាល័យស្រុក-ខណ្ឌ ដែលជាតំណាងក្រសួង ស្ថាប័ន ក្នុងសមាសភាពរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដី ថ្នាក់ខេត្ត-ក្រុងដូចមានចែងក្នុងមាត្រា២១នៃអនុក្រឹត្យនេះ | ជាសមាជិក |
| -តំណាងអាជ្ញាធរមូលដ្ឋាន | ជាសមាជិក |

ប្រធាន និងសមាជិកក្រុមការងារនេះ ត្រូវតែងតាំងដោយអភិបាលខេត្ត-ក្រុង។

**មាត្រា២៨**

ក្រុមប្រឹក្សាឃុំ-សង្កាត់មានមុខងារ និងភារកិច្ចដូចតទៅ៖

-ផ្តួចផ្តើម និងពិចារណាផែនការសម្បទានដីសង្គមកិច្ច ឱ្យស្របតាមនីតិវិធីនៃការអភិវឌ្ឍឃុំ-សង្កាត់

-អនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ដោយមានការគាំទ្របច្ចេកទេសពីក្រុមការងារថ្នាក់ស្រុក-ខណ្ឌ

-ទទួលខុសត្រូវក្នុងការជ្រើសរើសមុខសញ្ញាអ្នកទទួលដី ក្នុងចំណោមអ្នកដាក់ពាក្យសុំដី

-ទទួលខុសត្រូវក្នុងការបែងចែកដីដោយត្រឹមត្រូវ និងដោយប្រសិទ្ធភាព។

**ជំពូកទី៧ ប្រភពធនធាន**

**មាត្រា២៩**

ថវិកាសម្រាប់ដំណើរការរបស់យន្តការសម្បទានដីសង្គមកិច្ច ឋិតនៅក្នុងកញ្ចប់ថវិការបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣០**

ស្របតាមប្រព័ន្ធថវិកាឯកភាព ធនធាន និងថវិការបស់យន្តការសម្បទានដីសង្គមកិច្ចបានមកពី៖

-ថវិកាជាតិ

-ហិរញ្ញប្បទានបានមកពីក្នុង និងក្រៅប្រទេស ឬអង្គការផ្តល់ជំនួយអន្តរជាតិ។

**ជំពូកទី៨ អវសានប្បញ្ញត្តិ**

**មាត្រា៣១**

គោលការណ៍ណែនាំអនុវត្តអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣២**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៣៣**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រុមប្រឹក្សាគោលនយោបាយដីធ្លី រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអភិបាលខេត្ត-ក្រុងទាំងអស់ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

*កន្លែងទទួល*

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័នកណ្តាល

-គ្រប់សាលាខេត្ត-ក្រុង

-ដូចមាត្រា៣៣

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
លេខ៦០៦សហវ/ពដ

ប្រកាស
ស្តីពីការបំពេញបន្ថែមការណែនាំអនុវត្តប្រមូលពន្ធប្រថាប់ត្រា

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នស/៩៤ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញក្រឹត្យលេខ២១ក្រ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតពន្ធប្រថាប់ត្រា
- បានឃើញអនុក្រឹត្យលេខ២០អនក្រ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩១ ស្តីពីការប្រមូលពន្ធប្រថាប់ត្រា
- បានឃើញព្រះរាជក្រមលេខ១១នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យបើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥

- បានឃើញសារាចរលេខ០៦សរ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីវិធានការបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងការកែទម្រង់សេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ
- បានឃើញប្រកាសលេខ៥០១ប្រក/សហវ/ពដ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៥ ស្តីពីការកំណត់តម្លៃគិតពន្ធប្រថាប់ត្រា
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធប្រថាប់ត្រា

**សម្រេច**

**ប្រការ១**

ការផ្ទេរកម្មសិទ្ធិអចលនទ្រព្យ ឬផ្ទេរសិទ្ធិកាន់កាប់ដីដែលគ្មានសំណង់ ឬមធ្យោបាយដឹកជញ្ជូន ដោយអនុវត្តសាលក្រមរបស់តុលាការដែលបានសម្រេចរឹបអូសអចលនទ្រព្យ ដីដែលគ្មានសំណង់ ឬមធ្យោបាយដឹកជញ្ជូនរបស់កូនបំណុលសម្រាប់ធ្វើការទូទាត់សងបំណុលគឺមានលក្ខណៈដូចគ្នានឹងការទិញលក់ដែរ ម្ចាស់បំណុលជាអ្នកបានទទួលកម្មសិទ្ធិ បានទទួលសិទ្ធិត្រូវបង់ពន្ធប្រថាប់ត្រា។

**ប្រការ២**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៣

**ហត្ថលេខា និងត្រា**

**គាត ឈន់**

<u>ចម្លងជូន</u>

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័នកណ្តាល
-គ្រប់សាលាខេត្ត-ក្រុង
"ដើម្បីជូនជ្រាប"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
លេខ២០០ដនស/ប្រក

## ប្រកាស
## ស្តីពីគោលការណ៍ណែនាំអនុវត្តអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច

### រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ/បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៨៨អនក្រ/បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី

- បានឃើញអនុក្រឹត្យលេខ១៩អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- តាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**សម្រេច**

**១-គោលបំណង**

**ប្រការ១**

ប្រកាសនេះកំណត់គោលការណ៍ណែនាំ និងនីតិវិធីក្នុងការអនុវត្តអនុក្រឹត្យលេខ១៩អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច។

**ប្រការ២**

ដីសម្បទានសង្គមកិច្ចអាចត្រូវបានផ្តល់ឱ្យដល់រូបវន្តបុគ្គល ឬក្រុមមនុស្សដែលមានសញ្ជាតិខ្មែរ សម្រាប់គោលដៅសង្គមកិច្ច ដោយអនុលោមតាមគោលដៅណាមួយ ឬគោលដៅច្រើន ដូចមានកំណត់ក្នុងមាត្រា៣ នៃអនុក្រឹត្យលេខ១៩អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ដូចខាងក្រោម៖

១-ផ្តល់ដីដល់គ្រួសារក្រីក្រដែលគ្មានទីលំនៅ សម្រាប់សង់លំនៅឋាន។

២-ផ្តល់ដីដល់គ្រួសារក្រីក្រសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ។

៣-ផ្តល់ដីដល់គ្រួសារដែលត្រូវផ្លាស់ប្តូរទីលំនៅ បណ្តាលមកពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សម្រាប់ការតាំងលំនៅឋានជាថ្មី។

៤-ផ្តល់ដីដល់គ្រួសារដែលរងគ្រោះដោយគ្រោះធម្មជាតិ។

៥-ផ្តល់ដីដល់គ្រួសារមាតុភូមិនិវត្តន៍។

៦-ផ្តល់ដីដល់យោធិនរំសាយ និងគ្រួសារយុទ្ធជនពលី ពិការ។

៧-ជួយសម្រួលដល់ការអភិវឌ្ឍសេដ្ឋកិច្ច។

៨-ជួយសម្រួលដល់សម្បទានដីសេដ្ឋកិច្ច ដោយផ្តល់ដីឡូត៍ដល់កម្មករចម្ការធំៗ សម្រាប់សង់លំនៅឋាន ឬសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ។

៩-អភិវឌ្ឍតំបន់ដែលពុំទាន់ត្រូវបានអភិវឌ្ឍសមស្រប។

### ២_យន្តការសម្បទានដីសង្គមកិច្ច

**ប្រការ៣**

យន្តការសម្បទានដីសង្គមកិច្ចមានបេសកកម្មផ្តួចផ្តើមកម្មវិធីសម្បទានដីសង្គមកិច្ច រៀបចំផែនការសម្បទានដីសង្គមកិច្ច និងអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច សំដៅធ្វើការបែងចែកដីឱ្យប្រជាពលរដ្ឋប្រកបដោយតម្លាភាព និងប្រសិទ្ធភាព។

យន្តការសម្បទានដីសង្គមកិច្ចមានដូចតទៅ៖

-ក្រុមប្រឹក្សាឃុំ-សង្កាត់

-ក្រុមការងារថ្នាក់ស្រុក-ខណ្ឌ

-គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង

-គណៈកម្មាធិការសម្បទានដីសង្គមកិច្ច។

តួនាទី ភារកិច្ច និងសមាសភាពរបស់យន្តការសម្បទានដីសង្គមកិច្ចនីមួយៗមានកំណត់ក្នុងជំពូកទី៦នៃអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច។

### ៣_កម្មវិធីសម្បទានដីសង្គមកិច្ច

**ប្រការ៤**

កម្មវិធីសម្បទានដីសង្គមកិច្ចមានពីរថ្នាក់គឺ៖

-កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន

-កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ។

#### ក_កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន

**ប្រការ៥**

កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋានត្រូវផ្តួចផ្តើមឡើងដោយក្រុមប្រឹក្សាឃុំ-សង្កាត់ ដោយត្រូវរៀបចំផែនការសម្បទានដីសង្គមកិច្ច ស្របតាមល័ក្ខខ័ណ្ឌចាំបាច់នៃផែនការសម្បទានដីសង្គមកិច្ច។

កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ក៏អាចត្រូវបានផ្តួចផ្តើមឡើងដោយប្រជាពលរដ្ឋ ឬអង្គការដែលធ្វើការជាមួយប្រជាពលរដ្ឋ ប៉ុន្តែត្រូវធ្វើតាមរយៈក្រុមប្រឹក្សាឃុំ-សង្កាត់ដែលដី

សម្បទានសង្គកិច្ចនោះឋិតនៅ និងត្រូវរៀបចំផែនការសម្បទានដីសង្គមកិច្ច ស្របតាមល័ក្ខខ័ណ្ឌចាំបាច់នៃផែនការសម្បទានដីសង្គមកិច្ច។

**ប្រការ៦**

ផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋានត្រូវធ្វើប្រចាំឆ្នាំ ដោយអនុលោមតាមនីតិវិធីនៃការរៀបចំផែនការអភិវឌ្ឍឃុំ-សង្កាត់ ដែលបានកំណត់ក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់។

ផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋានត្រូវកំណត់ឱ្យច្បាស់នូវគោលដៅ ដូចបានកំណត់ក្នុងប្រការ២ខាងលើ កំណត់អត្តសញ្ញាណដីដែលអាចប្រើប្រាស់បានសម្រាប់សម្បទានដីសង្គមកិច្ច ឬដែលសមស្របសម្រាប់សម្បទានដីសង្គមកិច្ច ពិពណ៌នាអំពីដី និងផែនការប្រើប្រាស់ដី ពិពណ៌នាអំពីការជ្រើសរើសមុខសញ្ញាអ្នកទទួលដី ផែនការលំអិតក្នុងការបែងចែកដី រៀបរាប់អំពីដំណើរការដាក់ពាក្យ វាយតម្លៃអំពីលទ្ធភាពផ្នែកហេដ្ឋារចនាសម្ព័ន្ធចាំបាច់ វាយតម្លៃផលប៉ះពាល់សង្គម និងបរិស្ថាន និងតម្រូវការចាំបាច់ផ្សេងទៀតដែលសមស្របនឹងតំបន់ដីសម្បទានសង្គមកិច្ចនោះ។

អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ត្រូវធ្វើការណែនាំលំអិតអំពីរបៀប និងល័ក្ខខ័ណ្ឌនានា ក្នុងការកសាងផែនការសម្បទានដីសង្គមកិច្ច។

**ប្រការ៧**

ក្រុមការងារថ្នាក់ស្រុក-ខណ្ឌត្រូវផ្តល់ជំនួយបច្ចេកទេសដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងការធ្វើអត្តសញ្ញាណកម្មដី ការធ្វើចំណាត់ថ្នាក់ដី ការធ្វើផែនការប្រើប្រាស់ដី ការធ្វើផែនការ និងកំណត់លក្ខណវិនិច្ឆ័យជ្រើសរើសមុខសញ្ញាអ្នកទទួលដី និងក្នុងការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច។

**ប្រការ៨**

ផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋានត្រូវបានបញ្ជូនទៅគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង តាមរយៈក្រុមការងារថ្នាក់ស្រុក-ខណ្ឌ ដើម្បីសុំការសម្រេចយល់ព្រម។

**ប្រការ៩**

បន្ទាប់ពីបានសម្រេចយល់ព្រមហើយ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុងត្រូវជូនដំណឹងដល់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ។ គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ អាចពិនិត្យ កែសម្រួលផែនការ ឬលុបចោលសេចក្តីសម្រេចយល់ព្រមរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង ក្នុងករណីដែលផែនការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិមិនស្របនឹងល័ក្ខខ័ណ្ឌចាំបាច់នៃកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ឬមិនស្របនឹងអាទិភាពនៃការប្រើប្រាស់ដីថ្នាក់ជាតិ ឬផែនការនោះមានកំហុសបច្ចេកទេស ឬរំលោភបញ្ញត្តិទាំងឡាយនៃអនុក្រឹត្យ ឬច្បាប់ផ្សេងៗទៀត។

ការពិនិត្យ កែសម្រួលផែនការ ឬការលុបចោលសេចក្តីសម្រេចយល់ព្រមរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង ដោយគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ត្រូវធ្វើឡើងក្នុងរយៈពេល៦០ថ្ងៃ គិតពីថ្ងៃបានទទួលផែនការសម្បទានដីសង្គមកិច្ចនេះ។

## ខ.កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ

**ប្រការ១០**

កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិត្រូវបានផ្តួចផ្តើមឡើងដោយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងស្ថានភាពដែលកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋានមិនអាចធ្វើបាន ពិសេសក្នុងស្ថានភាពដូចមានកំណត់ក្នុងមាត្រា៧នៃអនុក្រឹត្យ១៩អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣នេះ ដោយត្រូវរៀបចំផែនការសម្បទានដីសង្គមកិច្ច ស្របតាមល័ក្ខខ័ណ្ឌចាំបាច់នៃផែនការសម្បទានដីសង្គមកិច្ច។

**ប្រការ១១**

ផែនការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិត្រូវបញ្ជូនទៅគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដើម្បីពិនិត្យ។

**ប្រការ១២**

គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិអាចផ្តល់ការយល់ព្រមលើផែនការ ឬកែសម្រួលផែនការដែលបានស្នើឡើង ដោយធ្វើការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

## ៤_ការអនុវត្ត

### ជំហានទី១ ការផ្សព្វផ្សាយឱ្យដឹងឮជាសាធារណៈ

**ប្រការ១៣**

ផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋានដែលបានទទួលការយល់ព្រមហើយ ត្រូវបើកចំហជាសាធារណៈនៅសាលាឃុំ-សង្កាត់ដែលដីសម្បទានសង្គមកិច្ចនោះឋិតនៅ នៅគណៈ-កម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង និងនៅគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិរាល់ពេលម៉ោងធ្វើការ ។

ដោយមានជំនួយបច្ចេកទេសពីក្រុមការងារថ្នាក់ស្រុក-ខណ្ឌ ក្រុមប្រឹក្សាឃុំ-សង្កាត់ជាអ្នកអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ដោយត្រូវផ្សព្វផ្សាយទូលំទូលាយ និងជូនដំណឹងដល់ប្រជាពលរដ្ឋ និងមុខសញ្ញាអ្នកទទួលដីអំពីកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋានអំពីគោលបំណង និងល័ក្ខខ័ណ្ឌដែលត្រូវចូលរួមក្នុងកម្មវិធីសម្បទានដីសង្គមកិច្ចនោះ ។

**ប្រការ១៤**

ផែនការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិដែលបានទទួលការសម្រេចយល់ព្រមរួចហើយ ត្រូវបើកចំហជាសាធារណៈនៅសាលាឃុំ-សង្កាត់ដែលដីសម្បទានសង្គមកិច្ចនោះឋិតនៅ នៅគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង និងនៅគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ រាល់ពេលម៉ោងធ្វើការ ។

ក្រសួង ស្ថាប័ន ឬម្ចាស់សំណើជាអ្នកអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ តាមការកំណត់នៅក្នុងផែនការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដោយមានការកំណត់ច្បាស់លាស់អំពីតួនាទីក្រសួង ស្ថាប័នពាក់ព័ន្ធ ការកំណត់អំពីការសម្របសម្រួលជាមួយគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង ក្រុមប្រឹក្សាឃុំ-សង្កាត់ និងប្រជាពលរដ្ឋនៅក្នុងតំបន់ពាក់ព័ន្ធ លើកលែងតែកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិថែងផ្សេងពីនេះ ។

### ជំហានទី២ ការជូនដំណឹងពីការដាក់ពាក្យ

**ប្រការ១៥**

ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវកំណត់កាលបរិច្ឆេទ រយៈពេល និងទីកន្លែងការទទួលសុំដីសម្បទាន។ សេចក្តីជូនដំណឹងពីការដាក់ពាក្យសុំដីសម្បទាន ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងតិច

៣០ថ្ងៃ មុនកាលបរិច្ឆេទនៃការទទួលពាក្យសុំ។ សេចក្តីជូនដំណឹងត្រូវធ្វើជាចំហ និងត្រូវបិទផ្សាយជាសាធារណៈក្នុងតំបន់ដីសម្បទាននោះ ដូចជានៅសាលាឃុំ-សង្កាត់ ទីវត្តអារាម សាលារៀន ឬទីសាធារណៈផ្សេងៗទៀត។

ក្នុងរយៈពេលជូនដំណឹងនេះ ក្រុមការងារថ្នាក់ស្រុក-ខណ្ឌត្រូវសហការជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីបើកកិច្ចប្រជុំជាមួយប្រជាពលរដ្ឋក្នុងតំបន់ដីសម្បទានសង្គមកិច្ច ផ្សព្វផ្សាយអំពីការចាប់ផ្តើមអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ពន្យល់ណែនាំអំពីដំណើរការអនុវត្ត អំពីសិទ្ធិចូលរួមរបស់ប្រជាពលរដ្ឋ អំពីល័ក្ខខ័ណ្ឌនៃការកាន់កាប់ដី និងបកស្រាយបំភ្លឺនូវរាល់សំណួរ និងចម្ងល់ដែលបានលើក។

**ប្រការ១៦**

ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ដីសម្បទានសង្គមកិច្ច និងដែលមានបំណងចូលរួមក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច ត្រូវដាក់ពាក្យសុំដីសម្បទានសង្គមកិច្ចនៅសាលាឃុំ-សង្កាត់ដែលបានកំណត់ក្នុងសេចក្តីជូនដំណឹង ដោយត្រូវបំពេញពាក្យសុំតាមគំរូក្នុងឧបសម្ព័ន្ធលេខ១នៃប្រកាសនេះ។

អ្នកសុំសម្បទានសង្គមកិច្ចត្រូវបញ្ជាក់អំពីប្រភេទដីដែលស្នើសុំ ជាដីសម្រាប់សង់លំនៅឋាន ឬជាដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ឬជាដីទាំងពីរប្រភេទ។

**ប្រការ១៧**

ការទទួលពាក្យសុំដីសម្បទានសង្គមកិច្ចមានរយៈពេល២០ថ្ងៃ។

**ប្រការ១៨**

ក្រុមការងារថ្នាក់ស្រុក-ខណ្ឌត្រូវចាត់តាំងមន្ត្រីជំនាញឱ្យចុះជួយក្នុងការងារទទួលពាក្យសុំដីសម្បទានសង្គមកិច្ច ជួយណែនាំក្នុងការបំពេញពាក្យសុំ ការទុកដាក់ឯកសារពាក្យសុំ និងការធ្វើតារាងបញ្ជីឈ្មោះអ្នកសុំដីសម្បទានសង្គមកិច្ច។

**ប្រការ១៩**

បញ្ជីឈ្មោះអ្នកសុំដីសម្បទានដីសង្គមកិច្ចទាំងអស់ ដែលបានទទួលក្នុងអំឡុងពេលទទួលពាក្យសុំដីសម្បទានសង្គមកិច្ចត្រូវបិទផ្សាយជាសាធារណៈនៅសាលាឃុំ-សង្កាត់ រយៈពេលយ៉ាងតិច៣០ថ្ងៃ មុនពេលធ្វើការវាយតម្លៃលើពាក្យសុំ។

ប្រការ២០

បញ្ជីឈ្មោះអ្នកសុំដីសម្បទានសង្គមកិច្ចត្រូវបើកចំហជាសាធារណៈ ក្នុងអំឡុងពេលម៉ោងធ្វើការ ។

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង និងគណៈកម្មការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ត្រូវរក្សាទុកបញ្ជីឈ្មោះអ្នកសុំដីសម្បទានសង្គមកិច្ចដែលបានដាក់ពាក្យសុំតាមគោលការណ៍ណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

## ជំហានទី៣ ការជ្រើសរើសមុខសញ្ញាអ្នកទទួលដី

ប្រការ២១

ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវទទួលខុសត្រូវក្នុងការជ្រើសរើសមុខសញ្ញាអ្នកទទួលដី ក្នុងចំណោមអ្នកដាក់ពាក្យស្នើសុំដីទាំងអស់ ។ ការសម្រេចយល់ព្រម ឬមិនយល់ព្រមលើពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ហេតុផលនៃការសម្រេចយល់ព្រម ឬមិនយល់ព្រមចំពោះអ្នកសុំដីម្នាក់ៗ និងត្រូវបើកចំហ និងបិទផ្សាយជាសាធារណៈ ។

ក្រុមការងារថ្នាក់ស្រុក-ខណ្ឌត្រូវផ្តល់ជំនួយបច្ចេកទេស ក្នុងការវាយតម្លៃលើគ្រប់ពាក្យសុំ ដើម្បីកំណត់ថាអ្នកសុំដីបានបំពេញលក្ខណវិនិច្ឆ័យនៃភាពអាចជ្រើសរើសបាន ឬភាពអនុគ្រោះក្នុងការជ្រើសរើសមុខសញ្ញាអ្នកទទួលដី ។

អង្គភាពគាំទ្របច្ចេកទេសការងារជ្រើសរើសមុខសញ្ញាអ្នកទទួលដី ត្រូវត្រួតពិនិត្យការជ្រើសរើសមុខសញ្ញាអ្នកទទួលដី ដោយផ្អែកលើលក្ខណវិនិច្ឆ័យនៃការជ្រើសរើសកំណត់ក្នុងផែនការសម្បទានដីសង្គមកិច្ច ។

ប្រការ២២

លក្ខណវិនិច្ឆ័យសម្រាប់ការជ្រើសរើសមុខសញ្ញាអ្នកទទួលដីមាន៖

ក-អ្នកសុំដីត្រូវមានសញ្ជាតិជាខ្មែរ និងមានសមត្ថភាពតាមផ្លូវច្បាប់ក្នុងការធ្វើជាម្ចាស់ដី

ខ-អ្នកសុំដីត្រូវតែជាមេគ្រួសារដែលមានសមាជិកពីរនាក់ ឬច្រើននាក់ដែលជាប់សាច់សាលោហិតជាមួយគ្នា ឬមានចំណងអាពាហ៍ពិពាហ៍ និងរស់នៅជាមួយគ្នាក្នុងលំនៅឋានតែមួយ

គ-អ្នកសុំដីបំពេញបានតាមលក្ខណវិនិច្ឆ័យខាងហិរញ្ញវត្ថុអំពីការវាយតម្លៃប្រាក់ចំណូល ស្របតាមល័ក្ខខ័ណ្ឌសេដ្ឋកិច្ច និងជីវភាពរស់នៅ

ឃ-អ្នកសុំដីពិតជាគ្មានដីផ្សេងទៀតដែលមានទំហំស្មើ ឬលើសពីការកំណត់ទំហំដីសម្បទានសង្គមកិច្ចដូចមានចែងក្នុងមាត្រា១៦ និងមាត្រា១៧នៃអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច

ង-អ្នកសុំដីពុំធ្លាប់បានទទួលដីសម្បទានសង្គមកិច្ច

ច-អ្នកសុំដីបានត្រៀមខ្លួនជាស្រេច មានឆន្ទៈ និងមានលទ្ធភាពចូលរួមក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច ស្របតាមផែនការសម្បទានដីសង្គមកិច្ចដែលបានយល់ព្រម ។

**ប្រការ២៣**

ក្នុងករណីអ្នកសុំដីមានចំនួនច្រើនជាងចំនួនដីសម្បទានសង្គមកិច្ច ផែនការសម្បទានដីសង្គមកិច្ចអាចបញ្ចូលលក្ខណវិនិច្ឆ័យសមហេតុផល សម្រាប់ផ្តល់ភាពអនុគ្រោះក្នុងការជ្រើសរើសមុខសញ្ញាអ្នកទទួលដី ដោយផ្អែកលើ៖

-គ្រួសារធំដែលមានសមាជិកចាប់ពី៦នាក់ឡើងទៅ

-រយៈពេលដែលគ្រួសារបានរស់នៅក្នុងតំបន់ដីសម្បទាន

-មេគ្រួសារជាស្ត្រី ជាជនបាត់បង់សមត្ថភាព ជាអតីតយុទ្ធជនដែលបាត់បង់សមត្ថភាព ជាយោធិនរំសាយ ។

**ប្រការ២៤**

រយៈពេលនៃការជ្រើសរើសមុខសញ្ញាអ្នកទទួលដី កំណត់១៥ថ្ងៃ បន្ទាប់ពីផុតរយៈពេលបិទផ្សាយជាសាធារណៈ នូវបញ្ជីឈ្មោះអ្នកសុំដីសម្បទានសង្គមកិច្ចទាំងអស់ ។

បន្ទាប់ពីការជ្រើសរើសមុខសញ្ញាអ្នកទទួលដីត្រូវបានបញ្ចប់ហើយ ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវកសាងបញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទាន និងបញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទានបម្រុង ដោយដកស្រង់យកចេញពីបញ្ជីឈ្មោះអ្នកសុំដីសម្បទានដីសង្គមកិច្ចទាំងអស់ ដែលបានទទួលក្នុងអំឡុងពេលទទួលពាក្យសុំដីសម្បទានសង្គមកិច្ច ។

បញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទាន និងបញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទានបម្រុងត្រូវបិទផ្សាយជាសាធារណៈ ក្នុងរយៈពេល២០ថ្ងៃ ដើម្បីឱ្យសាធារណជន ឬអ្នកដាក់ពាក្យសុំដីដែលពុំមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទាន ឬបញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទានបម្រុងធ្វើការជំទាស់តវ៉ា។ ផុតរយៈពេលនេះ បើគ្មានការជំទាស់តវ៉ាទេ បញ្ជីឈ្មោះដែលបានបិទផ្សាយ

ចាត់ទុកជាស្ថាពរ ហើយក្រុមប្រឹក្សាឃុំ-សង្កាត់ ដោយមានការផ្ដល់ជំនួយបច្ចេកទេសពីក្រុមការងារថ្នាក់ស្រុក-ខណ្ឌនឹងធ្វើការបែងចែកដីសម្បទានសង្គមកិច្ចនេះ ដល់អ្នកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទាន។

**ប្រការ២៥**

អ្នកសុំដីដែលពុំមានឈ្មោះនៅក្នុងបញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទាន ហើយជឿជាក់ថាពាក្យសុំរបស់ខ្លួន ត្រូវបានបកស្រាយមិនស្របតាមច្បាប់ភូមិបាល ឬច្បាប់ផ្សេងទៀត អាចស្នើសុំឱ្យគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង ឬគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ពិនិត្យឡើងវិញ ដោយដាក់សំណើជាលាយលក្ខណ៍អក្សរ ក្នុងអំឡុងពេលបិទផ្សាយជាសាធារណៈ នូវបញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទាន និងបញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទានបម្រុង។

បន្ទាប់ពីបានទទួលពាក្យស្នើសុំពិនិត្យឡើងវិញ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង ឬគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ត្រូវធ្វើការស៊ើបអង្កេតបណ្ដឹង និងចាត់វិធានការសមស្រប ក្នុងរយៈពេលមិនឱ្យលើសពី៣០ថ្ងៃ។

ពាក្យបណ្ដឹងស្នើសុំពិនិត្យឡើង និងសេចក្ដីបំភ្លឺ ឬសេចក្ដីសម្រេចរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង ឬរបស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ត្រូវបិទផ្សាយជាសាធារណៈនៅសាលាឃុំ-សង្កាត់នៃតំបន់ដីសម្បទាន ក្នុងរយៈពេលយ៉ាងតិច៧ថ្ងៃ មុនការបែងចែកដីសម្បទានសង្គមកិច្ច។

## ជំហានទី៤ ការបែងចែកដីសម្បទានសង្គមកិច្ច

**ប្រការ២៦**

បន្ទាប់ពីផុតរយៈពេលបិទផ្សាយបញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទាន ក្នុងករណីគ្មានការជំទាស់តវ៉ា ឬបន្ទាប់ពីផុតរយៈពេលបិទផ្សាយសេចក្ដីបំភ្លឺ ឬសេចក្ដីសម្រេចរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង ឬរបស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ក្នុងករណីមានការជំទាស់តវ៉ា ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវធ្វើការបែងចែកដីដល់អ្នកមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទាន។

**ប្រការ២៧**

ការបែងចែកដីសម្បទានសង្គមកិច្ច ត្រូវបានធ្វើឡើងតាមរយៈការចាប់ឆ្នោតយកលេខក្បាលដី ដែលរៀបចំឡើងដោយក្រុមប្រឹក្សាឃុំ-សង្កាត់ ដោយមានជំនួយបច្ចេកទេសពីក្រុមការងារថ្នាក់ស្រុក-ខណ្ឌ និងក្រោមការត្រួតពិនិត្យពីអង្គភាពគាំទ្របច្ចេកទេសការងារជ្រើសរើសមុខសញ្ញាអ្នកទទួលដី។

ការចាប់ឆ្នោតយកលេខក្បាលដីត្រូវបានជូនដំណឹងជាមុនយ៉ាងតិច៧ថ្ងៃ មុនកាលបរិច្ឆេទនៃការចាប់ឆ្នោត និងត្រូវធ្វើនៅទីសាធារណៈក្នុងតំបន់ដីសម្បទាន ចំពោះមុខប្រជាពលរដ្ឋ និងអ្នកត្រូវទទួលដីដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទានទាំងអស់។

**ប្រការ២៨**

មុនធ្វើការចាប់ឆ្នោតយកលេខក្បាលដី ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវធ្វើការបង្ហាញអំពីប្លង់ក្បាលដីដែលត្រូវបែងចែកក្នុងផែនការសម្បទានដីសង្គមកិច្ច ដែលបានអនុម័តយល់ព្រមហើយ អំពីលេខក្បាលដីដែលត្រូវចាប់ឆ្នោតយក និងអំពីរបៀបចាប់ឆ្នោត។

**ប្រការ២៩**

អ្នកមានសិទ្ធិក្នុងការចាប់ឆ្នោតយកលេខក្បាលដីត្រូវតែជាអ្នកមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទាន។ របៀបចាប់ឆ្នោតយកលេខក្បាលដីអាស្រ័យក្រុមប្រឹក្សាឃុំ-សង្កាត់ និងក្រុមការងារថ្នាក់ស្រុក-ខណ្ឌកំណត់តាមភាពជាក់ស្តែង។

**ប្រការ៣០**

ក្រោយពេលចាប់ឆ្នោតយកលេខក្បាលដីរួច ក្រុមប្រឹក្សាឃុំ-សង្កាត់ ដោយមានជំនួយបច្ចេកទេសពីក្រុមការងារថ្នាក់ស្រុក-ខណ្ឌ ត្រូវស្រង់ឈ្មោះ និងលេខក្បាលដីចាប់ឆ្នោតបានដោយធ្វើជាបញ្ជីឈ្មោះអ្នកទទួលដី (សម្បទានិក) និងលេខក្បាលដី។

**ប្រការ៣១**

ក្រុមប្រឹក្សាឃុំ-សង្កាត់ ឬក្រុមការងារថ្នាក់ស្រុក-ខណ្ឌ ត្រូវអញ្ជើញមុខសញ្ញាអ្នកទទួលដី ឬសម្បទានិកទាំងអស់មកប្រជុំផ្សព្វផ្សាយអំពីខ្លឹមសារនៃកិច្ចសន្យា ដែលនឹងត្រូវចុះហត្ថលេខាដោយសម្បទានិក និងក្រុមប្រឹក្សាឃុំ-សង្កាត់ ដោយសង្កត់ធ្ងន់អំពីកាតព្វកិច្ចរបស់សម្បទានិកត្រូវបំពេញក្នុងរយៈពេលសម្បទាន អំពីការទទួលបានសិទ្ធិកម្មសិទ្ធិនៅពេលល័ក្ខខ័ណ្ឌនៃការកាន់កាប់ដី

ត្រូវបានបំពេញរួច និងអំពីការដកហូតដីវិញ ប្រសិនបើសម្បទានិកមិនបំពេញបានល័ក្ខខ័ណ្ឌ និងកាតព្វកិច្ចក្នុងកិច្ចសន្យា។

បន្ទាប់ពីបានពន្យល់ផ្សព្វផ្សាយខ្លឹមសារនៃកិច្ចសន្យារួចហើយ មុខសញ្ញាអ្នកទទួលដី ឬសម្បទានិកត្រូវចុះកិច្ចសន្យាជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ តាមគំរូក្នុងឧបសម្ព័ន្ធលេខ២នៃប្រកាសនេះ។

កិច្ចសន្យាត្រូវធ្វើជា៥ច្បាប់ ដោយ៖

-ប្រគល់ឱ្យសម្បទានិក ១ច្បាប់

-តម្កល់នៅសាលាឃុំ-សង្កាត់ ១ច្បាប់

-តម្កល់នៅសាលាស្រុក-ខណ្ឌ (ក្រុមការងារថ្នាក់ស្រុក-ខណ្ឌ) ១ច្បាប់

-តម្កល់នៅសាលាខេត្ត-ក្រុង (គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង) ១ច្បាប់

-តម្កល់នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ) ១ច្បាប់។

**ប្រការ៣២**

បន្ទាប់ពីសម្បទានិក និងក្រុមប្រឹក្សាឃុំ-សង្កាត់ចុះហត្ថលេខាលើកិច្ចសន្យាហើយ កិច្ចសន្យាសម្បាទាននោះត្រូវចាត់ទុកជាផ្លូវការ ដែលភាគីហត្ថលេខីត្រូវអនុវត្តតាម។

ក្រុមប្រឹក្សាឃុំ-សង្កាត់ដោយមានជំនួយបច្ចេកទេសពីក្រុមការងារថ្នាក់ស្រុក-ខណ្ឌ និងក្រោមការណែនាំពីអង្គភាពគាំទ្របច្ចេកទេសការងារដីធ្លី ត្រូវនាំសម្បទានិកទៅបង្ហាញក្បាលដី និងប្រគល់ក្បាលដីនោះជូន។

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង ត្រូវចេញលិខិតបញ្ជាក់សម្បទានដីសង្គមកិច្ច ជូនដល់គ្រប់សម្បទានិកនៃក្បាលដីទាំងអស់។

### ជំហានទី៥ ការតាមដាន និងវាយតម្លៃការអនុវត្ត

**ប្រការ៣៣**

ក្រោយពីកិច្ចសន្យាសម្បទានដីសង្គមកិច្ចចូលជាធរមាន និងក្រោយពីបានប្រគល់ក្បាលដីរួច ក្រុមការងារស្រុក-ខណ្ឌត្រូវត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ព្រមទាំងធ្វើរបាយការណ៍ទៀងទាត់អំពីលទ្ធផលការងារ ជូនគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង។

**ប្រការ៣៤**

ចំពោះសម្បទានដីសង្គមកិច្ចសម្រាប់សង់លំនៅឋាន សម្បទានិកត្រូវសាងសង់លំនៅឋាន ឬយ៉ាងហោចណាស់ចំណែកណាមួយនៃជម្រកស្នាក់នៅ ក្នុងរយៈពេល៣ខែបន្ទាប់ពីបានទទួលដី ហើយសម្បទានិក ឬសមាជិកនៃគ្រួសារខ្លួនត្រូវរស់នៅពិតប្រាកដ និងជាអចិន្ត្រៃយ៍ទៅលើដីនោះ យ៉ាងតិច៦ខែ ក្នុង១ឆ្នាំ។

ចំពោះសម្បទានដីសង្គមកិច្ចសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ សម្បទានិកត្រូវធ្វើការដាំដុះ ឬចិញ្ចឹមសត្វជាក់ស្តែងលើដីនោះ ក្នុងរយៈពេល១២ខែ បន្ទាប់ពីបានទទួលដី និងបន្តប្រើប្រាស់ដីនោះ ស្របតាមល័ក្ខខ័ណ្ឌចាំបាច់នៃកម្មវិធីសម្បទាន។

បន្ទាប់ពីបានអនុវត្តត្រឹមត្រូវតាមកម្មវិធីសម្បទានដីសង្គមកិច្ចបាន៥ឆ្នាំ សម្បទានិកមានសិទ្ធិកម្មសិទ្ធិលើដីនោះ និងអាចស្នើសុំប័ណ្ណកម្មសិទ្ធិតាមនីតិវិធីកំណត់។

**ប្រការ៣៥**

ក្នុងរយៈពេល៥ឆ្នាំដំបូងនៃការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច សម្បទានិកមិនអាចលក់ ដូរ ជួល ឬធ្វើអំណោយដីសម្បទានសង្គមកិច្ចនេះបានឡើយ។ កិច្ចសន្យាលក់ ជួល ឬឱ្យដែលធ្វើក្នុងរយៈពេល៥ឆ្នាំដំបូងនេះត្រូវទុកជាមោឃៈ និងគ្មានអានុភាព។

ប៉ុន្តែប្រសិនបើក្នុងរយៈពេលកំពុងអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច សម្បទានិកបានទទួលមរណភាព សហព័ទ្ធដែលនៅរស់ ឬទាយាទរបស់សម្បទានិក អាចបន្តអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចនេះ រហូតដល់គ្រប់៥ឆ្នាំ ហើយមានសិទ្ធិកម្មសិទ្ធិលើដីនោះ។

**ប្រការ៣៦**

ចំពោះសម្បទានដីសង្គមកិច្ចសម្រាប់សង់លំនៅឋាន ក្នុងរយៈពេល១ខែ បន្ទាប់ពីបានទទួលដី ប្រសិនបើសម្បទានិកមិនបានធ្វើការសាងសង់លំនៅឋាន ឬចំណែកណាមួយនៃជម្រកស្នាក់

នៅទេ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង ត្រូវជូនដំណឹងដល់សម្បទានិក ឱ្យអនុវត្តល័ក្ខខ័ណ្ឌនៃការកាន់កាប់ដីតាមកិច្ចសន្យាដែលបានព្រមព្រៀងគ្នា។ សេចក្តីជូនដំណឹងជាលើកទី២ នឹងត្រូវបានធ្វើ នៅពេលសម្បទានិកមិនបានធ្វើការសាងសង់លំនៅឋាន ឬចំណែកណាមួយនៃជម្រកស្នាក់នៅ ក្នុងរយៈពេល២ខែ បន្ទាប់ពីបានទទួលដីសម្បទាន។

ចំពោះសម្បទាដីសង្គមកិច្ចសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ក្នុងរយៈពេល៦ខែ បន្ទាប់ពីបានទទួលដី ប្រសិនបើសម្បទានិកមិនបានរៀបចំដី ដើម្បីធ្វើការដាំដុះ ឬចិញ្ចឹមសត្វជាក់ស្តែងលើដីនោះទេ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុងត្រូវជូនដំណឹងដល់សម្បទានិក ឱ្យអនុវត្តល័ក្ខខ័ណ្ឌនៃការកាន់កាប់ដី តាមកិច្ចសន្យាដែលបានព្រមព្រៀងគ្នា។ សេចក្តីជូនដំណឹងជាលើកទី២នឹងត្រូវបានធ្វើ នៅពេលសម្បទានិកមិនបានរៀបចំដីដើម្បីធ្វើការដាំដុះ ឬចិញ្ចឹមសត្វជាក់ស្តែងលើដីនោះក្នុងរយៈពេល៩ខែ បន្ទាប់ពីបានទទួលដីសម្បទាន។

**ប្រការ៣៧**

ប្រសិនបើសម្បទានិកខកខានមិនបានបំពេញតាមល័ក្ខខ័ណ្ឌនៃការកាន់កាប់ និងប្រើប្រាស់ដីសម្បទាននោះ ក្រុមប្រឹក្សាឃុំ-សង្កាត់នឹងធ្វើការដកហូតសម្បទាននោះ ដើម្បីយកទៅបែងចែកដល់មុខសញ្ញាអ្នកទទួលដី ក្នុងបញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទានបម្រុង។

**ប្រការ៣៨**

ការដកហូតដីត្រូវជូនដំណឹងដល់សម្បទានិកក្នុងរយៈពេល១ខែ គិតចាប់ពីថ្ងៃប្រកាសដកហូត ដោយក្នុងសេចក្តីសម្រេចប្រកាសដកហូត ត្រូវមានបញ្ជាក់អំពីមូលហេតុ។ សម្បទានិកមានសិទ្ធិឆ្លើយតបក្នុងរយៈពេលនេះ អំពីមូលហេតុដែលខ្លួនខកខានមិនបានបំពេញតាមល័ក្ខខ័ណ្ឌនៃការកាន់កាប់ និងប្រើប្រាស់ដីសម្បទាននោះ ដោយត្រូវមានអំណះអំណាងត្រឹមត្រូវ និងច្បាស់លាស់។

សេចក្តីជូនដំណឹងពីការប្រកាសដកហូតដីសម្បទានត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវផ្សព្វផ្សាយជាសាធារណៈក្នុងរយៈពេល១ខែ គិតចាប់ពីថ្ងៃប្រកាសដកហូត។ ផុតរយៈពេលនេះ បើគ្មានបណ្តឹងឆ្លើយតបពីសម្បទានិកដែលត្រូវបានដកហូតទេ ក្រុមប្រឹក្សាឃុំ-សង្កាត់នឹងចាត់បែងចែកដីនោះ ឱ្យមុខសញ្ញាអ្នកទទួលដីក្នុងបញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទានបម្រុង តាមនីតិវិធីដូចការបែងចែកលើកដំបូង។

ក្នុងករណីមានបណ្តឹងឆ្លើយតបពីសម្បទានិក ក្រុមប្រឹក្សាឃុំ-សង្កាត់ ដោយមានជំនួយបច្ចេកទេសពីក្រុមការងារថ្នាក់ស្រុក-ខណ្ឌត្រូវធ្វើការស៊ើបអង្កេត និងលើកយោបល់ទៅគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុងដើម្បីពិនិត្យ និងសម្រេច។

**ប្រការ៣៩**

ប្រកាសនេះត្រូវអនុវត្តក្នុងតំបន់ជម្រើសមួយចំនួនដែលនឹងកំណត់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីប្រមូលនូវបទពិសោធន៍ក្នុងការអនុវត្តជំហានដំបូង ធ្វើការកែលំអ ឈានទៅអនុវត្តទូលំទូលាយទូទាំងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤០**

នាយកខុទ្ទកាល័យ ប្រធានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ អគ្គនាយកគ្រប់នាយកដ្ឋាន ប្រធានគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង ប្រធានក្រុមការងារថ្នាក់ស្រុក-ខណ្ឌ និងប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៣

**រដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**អ៊ឹម ឈុនលឹម**

<u>កន្លែងទទួល</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័ន

-គ្រប់សាលាខេត្ត-ក្រុង

-ដូចប្រការ៤០

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ០២ប្រកន/០៣ រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣

## ប្រកាសអន្តរក្រសួងស្តីពីការកំណត់ភារកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងរឿងវិវាទដីធ្លី

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ៤៧អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី
- តាមការចាំបាច់របស់ក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**សម្រេច**

ប្រការ១

វិវាទដីធ្លីទាំងឡាយត្រូវបានបែងចែកទៅតាមសមត្ថកិច្ចនីមួយៗដូចតទៅ៖

-វិវាទដីធ្លីដែលបានចុះបញ្ជីសុរិយោដីរួចហើយ គឺដីធ្លីដែលមានប័ណ្ណសម្គាល់សិទ្ធិគ្រប់ប្រភេទចេញដោយរដ្ឋបាលសុរិយោដី ត្រូវឋិតក្នុងសមត្ថកិច្ចរបស់តុលាការ។

*វាយឡើងវិញ*

-វិវាទដីធ្លីដែលមានទាន់បានចុះបញ្ជីសុរិយោដី គឺជាដីធ្លីដែលពុំទាន់មានប័ណ្ណសម្គាល់សិទ្ធិគ្រប់ប្រភេទចេញ ដោយរដ្ឋបាលសុរិយោដីត្រូវឋិតក្នុងសមត្ថកិច្ចគណៈកម្មការសុរិយោដី។

**ប្រការ២**

តុលាការគ្រប់ខេត្ត-ក្រុងត្រូវបញ្ឈប់ការទទួលបណ្តឹងវិវាទដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដីដែលជាសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ប្រការ៣**

បណ្តឹងវិវាទដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដីដែលជាសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីហើយត្រូវបានតុលាការគ្រប់ថ្នាក់ទទួល និងកំពុងចាត់ការមុនថ្ងៃចេញប្រកាសនេះ តុលាការត្រូវចាត់ការបន្តរហូតចប់សព្វគ្រប់ជាស្ថាពរ។

**ប្រការ៤**

វិវាទអំពីកិច្ចសន្យាពាក់ព័ន្ធនឹងដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដី ដូចជាវិវាទអំពីការបែងចែកមតិក និងវិវាទអំពីកិច្ចសន្យាទិញ លក់ ជួល បញ្ចាំជាដើម ជាសមត្ថកិច្ចរបស់តុលាការ។

**ប្រការ៥**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៦**

តុលាការគ្រប់ថ្នាក់ អគ្គាធិការដ្ឋាន នាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងយុត្តិធម៌ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុងក្រោមឱវាទក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មការសុរិយោដីគ្រប់ថ្នាក់មានភារកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ចុះពីថ្ងៃហត្ថលេខាតទៅ។

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**
**ហត្ថលេខា និងត្រា**
**នាវ ស៊ីថុន**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី**
**នគរូបនីយកម្ម និងសំណង់**
**ហត្ថលេខា និងត្រា**
**អ៊ឹម ឈុនលឹម**

*<u>កន្លែងទទួល</u>*
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន
-គ្រប់សាលាខេត្ត-ក្រុង
"ដើម្បីជូនជ្រាប"
-ដូចប្រការ៦ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសាធារណការ និងដឹកជញ្ជូន**
**អគ្គនាយកដ្ឋានសាធារណការ**
**នាយកដ្ឋានផ្លូវថ្នល់**
លេខ០១៥ផថ

ភ្នំពេញ ថ្ងៃទី២០ ខែ០១ ឆ្នាំ២០០៤

## សេចក្តីណែនាំស្តីពីការប្រើប្រាស់ផ្លូវថ្នល់

ដោយពិនិត្យឃើញថា ទោះបីមានគោលនយោបាយស្តីពីការគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ច្បាប់ភូមិបាលឆ្នាំ២០០១ និងសេចក្តីប្រកាសស្តីពីវិធានការលុបបំបាត់ភាពអនាធិបតេយ្យក្នុងបញ្ហាទន្ទ្រានកាន់កាប់ដីធ្លីរបស់រាជរដ្ឋាភិបាល ក៏នៅតែមានភាពខ្វះខាតសណ្តាប់ធ្នាប់ និងភាពទទួលខុសត្រូវលើបញ្ហាប្រើប្រាស់ផ្លូវថ្នល់ ឱ្យបានធានាអាយុកាលយូរអង្វែង និងមានសុវត្ថិភាពចរាចរនោះ នាយកដ្ឋានផ្លូវថ្នល់ សូមធ្វើការណែនាំដូចខាងក្រោម៖

**១-អំពីការប្រើប្រាស់ផ្លូវថ្នល់**

-សេចក្តីណែនាំនេះមានវិសាលភាពគ្របដណ្តប់លើអ្នកប្រើប្រាស់ផ្លូវថ្នល់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា

-អ្នកប្រើប្រាស់ផ្លូវសាធារណៈត្រូវគោរពឱ្យបានត្រឹមត្រូវ តាមសេចក្តីណែនាំនេះ។ សេចក្តីណែនាំនេះ កំណត់និយមន័យដូចខាងក្រោម៖

**ក-ផ្លូវជាតិ**

-ផ្លូវដែលចំណុចចាប់ផ្តើមពីទីក្រុងភ្នំពេញឆ្ពោះទៅកាន់ទីរួមខេត្ត
-ផ្លូវបំបែកចេញពីផ្លូវជាតិឆ្ពោះទៅកាន់ទីរួមខេត្ត
-ផ្លូវបំបែកចេញពីផ្លូវជាតិឆ្ពោះទៅភ្ជាប់នឹងផ្លូវជាតិ
-ផ្លូវផ្សេងៗទៀតតាមការកំណត់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

ប្រភេទផ្លូវជាតិ

ផ្លូវជាតិបែងចែកជាពីរកម្រិត

-ផ្លូវជាតិកម្រិត១ ជាផ្លូវជាតិដែលមានលេខ១ខ្ទង់
-ផ្លូវជាតិកម្រិត២ ជាផ្លូវជាតិដែលមានលេខ២ខ្ទង់

**ខ-ផ្លូវខេត្ត**

1-ផ្លូវខេត្តជាផ្លូវដែលចេញពីខេត្តឆ្ពោះទៅកាន់ទីរួមស្រុក។
2-ផ្លូវបែកចេញពីផ្លូវជាតិទៅផ្លូវខេត្ត។

3-ផ្លូវបំបែកពីផ្លូវខេត្តឆ្ពោះទៅស្រុកក្នុងករណីចំនួនចរាចរមធ្យមប្រចាំថ្ងៃ ADT ធំជាង ឬស្មើនឹង 50 ។

4-ផ្លូវបំបែកចេញពីផ្លូវខេត្តឆ្ពោះទៅផ្លូវខេត្ត ។

5-ផ្លូវជនបទ ក្នុងករណីចំនួនមធ្យោបាយចរាចរមធ្យមប្រចាំថ្ងៃធំជាង ឬស្មើ 50 (ADT) ។

6-ផ្លូវផ្សេងៗទៀត តាមការកំណត់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។

ប្រភេទលេខផ្លូវខេត្ត

ផ្លូវខេត្តមាន៣លេខ ឬ៤លេខ

**គ-ផ្លូវជនបទ**

1-ផ្លូវដែលចេញពីផ្លូវជាតិឆ្ពោះទៅឃុំ-ភូមិ

2-ផ្លូវដែលចេញពីផ្លូវខេត្តឆ្ពោះទៅឃុំ-ភូមិ

3-ផ្លូវដែលចេញពីទីរួមស្រុកទៅទីរួមស្រុក

4-ផ្លូវចេញពីទីរួមស្រុកទៅឃុំ

5-ផ្លូវចេញពីឃុំទៅឃុំ

6-ផ្លូវចេញពីឃុំទៅភូមិ

7-ផ្លូវបែកពីភូមិទៅភូមិ ។

ពាក្យថា "ផ្លូវសាធារណៈ" គឺជាផ្លូវសម្រាប់បើកឱ្យធ្វើចរាចរទូទៅជាសាធារណៈ ។

ពាក្យថា "ផ្លូវថ្នល់" ហៅកាត់ថា "ផ្លូវ" គឺជាទំហំទាំងមូលនៃទ្រូងផ្លូវ និងចិញ្ចើមផ្លូវ ។

ពាក្យថា "ទ្រូងផ្លូវ" គឺជាផ្នែកមួយនៃផ្លូវទុកសម្រាប់យានជំនិះគ្រប់ប្រភេទធ្វើចរាចរ ។

ពាក្យថា "ជាយផ្លូវ ឬចិញ្ចើមផ្លូវ" គឺជាផ្នែកសងខាងនៃទ្រូវផ្លូវ ។

ពាក្យថា "ដីចំណីផ្លូវ" គឺជាផ្ទៃដីគិតចាប់ពីអ័ក្សផ្លូវ ដែលមានចម្ងាយពីអ័ក្សផ្លូវទៅតាមប្រភេទផ្លូវ ។

+ផ្លូវជាតិមានលេខមួយខ្ទង់

-ផ្លូវជាតិលេខ ២, ៣, ៦, ៧, ៨ ដីចំណីផ្លូវមានចម្ងាយ២៥ម៉ែត្រពីសងខាងអ័ក្សផ្លូវ ។

-ផ្លូវជាតិលេខ ១, ៤, ៥ ដីចំណីផ្លូវចម្ងាយ៣០ម៉ែត្រពីសងខាងអ័ក្សផ្លូវ ។

+ផ្លូវជាតិមានលេខពីរខ្ទង់

ឧទាហរណ៍ ផ្លូវជាតិលេខ១១, ១២, ៦៤, ៧៨ ដីចំណីផ្លូវមានចម្ងាយ២៥ម៉ែត្រ ពីសងខាងអ័ក្សផ្លូវ ។

+ផ្លូវខេត្ត

-ដីចំណីផ្លូវមានចម្ងាយ២០ម៉ែត្រពីសងខាងអ័ក្សផ្លូវ ។

+ផ្លូវលំ

-ដីចំណីផ្លូវមានចម្ងាយ២០ម៉ែត្រពីសងខាងអ័ក្សផ្លូវ ។

+ផ្លូវទីរួមខេត្ត-ក្រុង ទីប្រជុំជន

-ផ្លូវមានទទឹង៩ម៉ែត្រដល់១១ម៉ែត្រ ដីចំណីផ្លូវគិតពីចិញ្ចើមប្រវែង៦ម ។

-ផ្លូវមានទទឹង១២ម៉ែត្រដល់១៨ម៉ែត្រ ដីចំណីផ្លូវគិតពីចិញ្ចើមប្រវែង៨ម ។

**២_អំពីការប្រើប្រាស់ទ្រូងផ្លូវ**

ក-យានយន្តទាំងឡាយដែលមានកង់ច្រវ៉ាក់ មិនអនុញ្ញាតឱ្យបើកបរលើទ្រូងផ្លូវឡើយ យានយន្តទាំងនោះត្រូវដឹកជញ្ជូនដោយរថយន្តសណ្តោង ។

ខ-យានយន្តទាំងឡាយណាដែលកំពុងធ្វើចរាចរ ហើយមានការខូចខាតបន្ទាន់ មិនអនុញ្ញាតឱ្យឈប់ចតនៅកណ្តាលទ្រូងផ្លូវទេ ត្រូវអូសមកជាយផ្លូវដើម្បីធ្វើការជួសជុល ជាមួយគ្នានោះ គេត្រូវដាក់សញ្ញាសម្គាល់ពេលថ្ងៃ និងដាក់ភ្លើងនៅពេលយប់ ដោយមានចម្ងាយពីយានយន្ត៣០ម៉ែត្រនៅខាងមុខយានយន្ត និងខាងក្រោយយានយន្ត ។

ការប្រើប្រាស់ជួយដោយផ្ទាល់ទៅលើផ្ទៃផ្លូវថ្នល់ត្រូវហាមឃាត់ដាច់ខាត ។ គេត្រូវប្រើកំណល់ឈើ ឬកំណល់ផ្សេងៗទៀត ដែលមានទំហំធំជាង ឬស្មើ០,០៩ម$^{២}$ ។

ក្នុងគ្រប់ករណី ការផ្ទុកឈើហ៊ុប ឬវត្ថុផ្សេងៗទៀតដែលមានបណ្តោយវែងជាងទ្រុងយានយន្តនោះមិនត្រូវលូតហួសពីគែបខាងមុខយានយន្ត និងមិនត្រូវឱ្យហួសពីគែមទ្រុងខាងក្រោយនៃយានយន្តចម្ងាយ១ម៉ែត្រ ឬធ្លាក់អូសដីឡើយ ។

ហាមដឹកដី ដីខ្សាច់ ក្រួស ថ្ម សំរាមតាមដងផ្លូវដោយគ្មានគម្របការពារ ។ ការដឹកជញ្ជូនទាំងឡាយណាដែលនាំឱ្យខូចគែមទ្រូងផ្លូវ ត្រូវសុំសេចក្តីអនុញ្ញាតពីស្ថាប័នជំនាញក្រសួងសាធារណការ និងដឹកជញ្ជូនសិន ។

ហាមឈប់ ឬចតរថយន្តដឹកជញ្ជូនបន្តកន្ទុយគ្នា ។ ក្នុងករណីចាំបាច់អាចឈប់ ឬចតបានដោយត្រូវមានចម្ងាយពីរថយន្តមួយទៅរថយន្តមួយចំនួនយ៉ាងតិច៤ម៉ែត្រ ។

ហាមផ្ទុកទំនិញនៅលើយានយន្ត មិនត្រូវឱ្យលើសទម្ងន់សរុបអតិបរមារបស់យានយន្តដែលកំណត់ដោយរោងចក្រផលិតយានយន្តឡើយ និងឱ្យស្របទៅនឹងអនុក្រឹត្យលេខ៨៣អនក្រ/បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៩។

ហាមចោះ ឬកាត់ផ្តាច់ផ្លូវថ្នល់ដើម្បីបង្កប់ប្រព័ន្ធលូ ប្រព័ន្ធខ្សែអគ្គិសនី ឬប្រព័ន្ធខ្សែទូរស័ព្ទ ប្រព័ន្ធទឹកស្អាត ។

ហាមហាលរបស់របរលើទ្រូងផ្លូវ ។

ហាមចាក់ទឹកលើទ្រូវផ្លូវ ។

ក្នុងករណីមានប្រេងឥន្ធនៈហៀរហូរលើទ្រូងផ្លូវកៅស៊ូ ត្រូវធ្វើការលាងសំអាតជាបន្ទាន់ ។

**៣_អំពីការប្រើប្រាស់ជាយផ្លូវ**

ហាមចាក់ដីលើកកម្ពស់ជាយផ្លូវ ក្នុងករណីចាំបាច់ ត្រូវពិគ្រោះជាមួយស្ថាប័នក្រសួងសាធារណការ ។ ហាមចាក់ដី សំរាមទៅក្នុងប្រឡាយ និងរណ្តៅលូបង្ហូរទឹក ។

ហាមសង់តូប តាំងទីលំនៅ ដាក់មុខទំនិញលើជាយផ្លូវ លើប្រឡាយ និងលើលូបង្ហូរទឹក។

ហាមដាំដំណាំ ដើមឈើ ឬហាលវត្ថុផ្សេងៗលើជាយផ្លូវ។

ហាមចោះ ឬកាត់ផ្តាច់ជាយផ្លូវដើម្បីកប់បំពង់លូ ប្រព័ន្ធខ្សែអគ្គិសនី ប្រព័ន្ធខ្សែទូរស័ព្ទ។ល។ ដោយគ្មានការអនុញ្ញាតពីក្រសួងសាធារណការ និងដឹកជញ្ជូន។

ហាមចងសត្វពាហនៈតាមជាយផ្លូវ។

ហាមជីកដីតាមជាយផ្លូវ។

**៤_អំពីការប្រើប្រាស់ដីចំណីផ្លូវ**

-ដីចំណីផ្លូវជាកម្មសិទ្ធិរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន

-ហាមធ្វើរបងនៅលើដីចំណីផ្លូវ

-ហាមសង់លំនៅឋានលើដីចំណីផ្លូវ

-ហាមទប់ទឹកដែលហូរចេញពីទ្រូងផ្លូវ

-ហាមជីករាំងព្រួលតាមប្រឡាយ លូ ស្ពានដែលបណ្តាលឱ្យរាំងស្ទះចរន្តទឹក។

**៥_វិធានការអនុវត្ត**

រាល់ការងារទាំងឡាយណាដែលពាក់ព័ន្ធនឹងការងារហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ទោះជាប្រើប្រាស់ប្រភពថវិកាណាក៏ដោយ ការងារបច្ចេកទេសត្រូវតែឆ្លងស្ថាប័នជំនាញ (មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង ក្រសួង) ជាដាច់ខាត ហើយស្ថាប័នជំនាញជំនួសមុខក្រសួងធ្វើការគ្រប់គ្រងឱ្យបានម៉ត់ចត់ និងមធ្យ័តបំផុត។

ក្រោយពេលទទួលបានសេចក្តីណែនាំនេះ សូមលោកប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនគ្រប់ខេត្ត-ក្រុង ចាត់វិធានការអនុវត្តឱ្យបានប្រសិទ្ធភាពខ្ពស់។ ប្រសិនបើមានភាពធ្វេសប្រហែស គ្មានភាពទទួលខុសត្រូវ នោះនាយកដ្ឋាន និងរាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងដើម្បីពិន័យ ឬបន្ទោសតាមច្បាប់វិន័យរបស់ក្រសួង។

សូមលោកប្រធានទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ។

**នាយក នាយកដ្ឋានផ្លូវថ្នល់**

**ហត្ថលេខា**

**លឹម ស៊ីដេនីន**

<u>ចម្លងជូន</u>

-ឯកឧត្តមរដ្ឋលេខាធិការ

-ឯកឧត្តមអនុរដ្ឋលេខាធិការ

-ឯកឧត្តមអគ្គនាយករងសាធារណការ

-ឯកឧត្តមអគ្គនាយករដ្ឋបាល

-ឯកឧត្តមអភិបាលខេត្ត-ក្រុង

"ដើម្បីជូនជ្រាប"

-ឯកសារ-កាលប្បវត្តិ

*វាយឡើងវិញ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
លេខ០៥៩សហវ/ទវ                    រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមករា ឆ្នាំ២០០៤

**គោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

កម្មវត្ថុ៖ ករណីសំណើសុំអនុញ្ញាតជាគោលការណ៍លើតម្លៃសេវាចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ សម្រាប់គម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី (LMAP) នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

យោង៖ លិខិតលេខ១២១៦ដសន/LMAP ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបឯកឧត្តមមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមឯកភាពជាគោលការណ៍តាមសំណើរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់លើតម្លៃសេវាចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធដូចខាងក្រោម៖

| | |
|---|---|
| ១-ដីកសិកម្មជនបទ | ១រៀល/ម$^{២}$ |
| | (១០០រៀលសម្រាប់ដីតូចជាង១០០ម$^{២}$) |
| ២-ដីលំនៅឋានជនបទ | ១០រៀល/ម$^{២}$ |
| ៣-ដីទីប្រជុំជនស្រុក ឬដីជាយទីប្រជុំជនខេត្ត | ២០រៀល/ម$^{២}$ |
| ៤-ដីទីប្រជុំជនខេត្ត ឬជាយទីប្រជុំជនក្រុងភ្នំពេញ | ៥០រៀល/ម$^{២}$ |
| ៥-ដីទីប្រជុំជនក្រុងភ្នំពេញ | ១០០រៀល/ម$^{២}$ |

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងទទួលអនុវត្តតាមការគួរ។

សូមឯកឧត្តមមេត្តាទទួលនូវគារវកិច្ចក៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ហត្ថលេខា និងត្រា**
**គាត ឈន់**

ចម្លងជូន
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**លេខ០១ជនស/សជ**

**សារាចរណែនាំអនុវត្ត**

**នីតិវិធីនៃការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ**

អនុលោមតាមអនុក្រឹត្យលេខ៤៨អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមធ្វើការណែនាំដូចតទៅ៖

**ដំណាក់កាលទី១ អំពីការដាក់ពាក្យស្នើសុំចុះបញ្ជីដី**

អ្នកកាន់កាប់ដីដែលមានបំណងស្នើសុំចុះបញ្ជីក្បាលដីរបស់ខ្លួន (ទោះមានទំហំប៉ុន្មានក្តី) ត្រូវបំពេញពាក្យសុំតាមគំរូដែលបានរៀបចំ ដាក់ជូនរដ្ឋបាលសុរិយោដីស្រុក-ខណ្ឌ តាមរយៈមេឃុំ ចៅសង្កាត់នៃឃុំ-សង្កាត់ដែលក្បាលដីនោះឋិតនៅ។

ពាក្យស្នើសុំត្រូវធ្វើជាពីរច្បាប់ និងអាចមានឯកសារណាផ្សេងៗភ្ជាប់មកជាមួយ ដូចជាឯកសារ និងភស្តុតាងទាក់ទងនឹងក្បាលដី ឬសិទ្ធិលើក្បាលដីដែលស្នើសុំចុះបញ្ជី។

មេឃុំ ចៅសង្កាត់ត្រូវពិនិត្យមើលពាក្យស្នើសុំ ណែនាំឱ្យសាមីអ្នកកាន់កាប់ដីបំពេញបានគ្រប់គ្រាន់ តាមខ្លឹមសារដែលបានរៀបចំ ថាតើសេចក្តីដែលសាមីអ្នកស្នើសុំបានបំពេញនោះស្របតាមហេតុការណ៍ដែលបានកើតឡើងជាក់ស្តែងដែរឬទេ?

ចំណុចដែលត្រូវយកចិត្តទុកដាក់ជាសំខាន់នោះគឺលក្ខណៈនៃការចូលកាន់កាប់ដី មានប្រើអំពើហិង្សា ឬគ្មាន? កាលបរិច្ឆេទនៃការចូលកាន់កាប់ដីពិតប្រាកដដែរឬទេ? ទីតាំងក្បាលដីមានលក្ខណៈប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់រដ្ឋដែរឬទេ? ក្បាលដីដែលកំពុងស្នើសុំចុះបញ្ជីមានទំនាស់ដែរឬទេ?

បន្ទាប់ពីពិនិត្យឃើញថា ពាក្យស្នើសុំមានលក្ខណៈគ្រប់គ្រាន់ហើយ មេឃុំ ឬចៅសង្កាត់ នោះត្រូវចារលើពាក្យស្នើសុំ រួចធ្វើបែបបទបញ្ជូលពាក្យស្នើសុំទាំងអស់នោះមករដ្ឋបាលសុរិយោដី ស្រុក-ខណ្ឌ។

រដ្ឋបាលសុរិយោដីស្រុក-ខណ្ឌត្រូវត្រួតពិនិត្យពាក្យស្នើសុំចុះបញ្ជី ដោយផ្អែកលើគោលការណ៍ជំនាញ និងច្បាប់៖

-ក្នុងករណីពិនិត្យឃើញថា ពាក្យស្នើសុំមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប រដ្ឋបាលសុរិយោដីស្រុក-ខណ្ឌត្រូវកត់ត្រាពាក្យស្នើសុំទាំងនោះចូលក្នុងសៀវភៅទទួលពាក្យ ចុះលេខ រួចចារលើពាក្យនោះ កំណត់កាលបរិច្ឆេទ និងទីកន្លែងដែលត្រូវចុះអនុវត្តកំណត់ព្រំដី វាស់វែង និងវិនិច្ឆ័យ ហើយប្រគល់ពាក្យមួយច្បាប់ជូនអ្នកដាក់ពាក្យវិញ។ ប្រសិនបើមានក្បាលដីច្រើន មានទីតាំងឋិតនៅជាប់ៗគ្នា ឬជិតៗគ្នាក្នុងឃុំ-សង្កាត់ជាមួយគ្នា ហើយទទួលបានការយល់ព្រមឱ្យអនុវត្តនីតិវិធីចុះបញ្ជី និងកំណត់កាលបរិច្ឆេទចុះអនុវត្តការងារវាលថ្ងៃជាមួយគ្នា ពាក្យស្នើសុំចុះបញ្ជីក្បាលដីទាំងនោះ អាចត្រូវបានប្រមូលផ្តុំទៅតាមលទ្ធភាពដែលក្រុមការងារវាលអាចអនុវត្តបានក្នុងមួយថ្ងៃ ដើម្បីបង្កើតបញ្ជីឈ្មោះអ្នកស្នើសុំចុះបញ្ជីដី និងធ្វើសេចក្តីជូនដំណឹងតែមួយដាក់ជូនអភិបាលស្រុក-ខណ្ឌចុះហត្ថលេខាក្នុងរយៈពេលមិនលើសពីពាថ្ងៃ បន្ទាប់ពីរដ្ឋបាលសុរិយោដីស្រុក-ខណ្ឌលើកសំណើដើម្បីកំណត់ជាផ្លូវការនូវកាលបរិច្ឆេទ និងទីកន្លែងដែលត្រូវអនុវត្ត។ សេចក្តីជូនដំណឹងនេះត្រូវប្រគល់ជូនអ្នកដាក់ពាក្យស្នើសុំ និងបិទផ្សាយឱ្យបានយ៉ាងតិច១៤ (ដប់បួន) ថ្ងៃ មុនកាលបរិ-ច្ឆេទនៃការចុះកំណត់ព្រំដី នៅសាលាស្រុក-ខណ្ឌ សាលាឃុំ-សង្កាត់ និងនៅកន្លែងដែលងាយមើលឃើញ ក្នុងភូមិដែលក្បាលដីស្នើសុំចុះបញ្ជីនោះឋិតនៅ។

-ក្នុងករណីពិនិត្យឃើញថា កាលបរិច្ឆេទនៃការចូលកាន់កាប់ដីរដ្ឋ កើតឡើងក្រោយថ្ងៃ ៣០ សីហា ២០០១ រដ្ឋបាលសុរិយោដីស្រុក-ខណ្ឌត្រូវចារលើពាក្យស្នើសុំឱ្យបានច្បាស់អំពីភាពខុសច្បាប់នៃការចូលកាន់កាប់ដី ហើយប្រគល់ពាក្យនោះទៅសាមីអ្នកស្នើសុំវិញ។

-ក្នុងករណីពិនិត្យឃើញថា ការកាន់កាប់ដីមានលក្ខណៈមិនសមស្រប ពិសេសការចូលកាន់កាប់ដោយទុច្ចរិត (ប្រើហិង្សា ឬលួងលោមបោកបញ្ឆោត) ដោយលួចលាក់ ឬមិនចេញមុខ រដ្ឋបាលសុរិយោដីស្រុក-ខណ្ឌត្រូវចារលើពាក្យ ដោយបញ្ជាក់ឱ្យបានច្បាស់អំពីមូលហេតុ និងភស្តុតាង

ដែលនាំឱ្យការអនុវត្តនីតិវិធីចុះបញ្ជីដីមិនអាចប្រព្រឹត្តទៅបាន រួចប្រគល់ពាក្យនោះទៅសាមីអ្នកស្នើសុំវិញ។

-ក្នុងករណីពិនិត្យឃើញថាដីដែលស្នើសុំចុះបញ្ជីជាដីសាធារណៈរបស់រដ្ឋ រដ្ឋបាលសុរិយោដីស្រុក-ខណ្ឌត្រូវចារលើពាក្យដោយបញ្ជាក់ឱ្យបានច្បាស់អំពីមូលហេតុ និងភស្តុតាងដែលនាំឱ្យការអនុវត្តនីតិវិធីចុះបញ្ជីដីមិនអាចប្រព្រឹត្តទៅបាន រួចប្រគល់ពាក្យនោះទៅសាមីអ្នកស្នើសុំវិញ លើកលែងតែអ្នកស្នើសុំនោះជានីតិបុគ្គលសាធារណៈ។

-ក្នុងករណីពិនិត្យឃើញថាមានវិវាទពាក់ព័ន្ធនឹងក្បាលដីដែលស្នើសុំចុះបញ្ជីនោះ រដ្ឋបាលសុរិយោដីស្រុក-ខណ្ឌត្រូវបញ្ជូនសំណុំរឿងវិវាទនោះ ទៅគណៈកម្មការសុរិយោដីដោះស្រាយតាមនីតិវិធី។

-គ្រប់ករណីដែលរដ្ឋបាលសុរិយោដីស្រុក-ខណ្ឌ បដិសេធមិនព្រមអនុវត្តនីតិវិធីនៃការចុះបញ្ជីដីតាមការស្នើសុំ សាមីអ្នកស្នើសុំ ឬតំណាងស្របច្បាប់របស់ជននេះមានសិទ្ធិប្ដឹងតវ៉ាទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង ឬក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីដីត្រូវបង់សោហ៊ុយសេវាសុរិយោដី ទៅតាមការកំណត់របស់រដ្ឋ។

**ដំណាក់កាលទី២ អំពីកិច្ចប្រតិបត្តិការបច្ចេកទេស**

**១_អំពីការងារវាល**

យោងតាមការណែនាំរបស់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ និងការណែនាំជាក់ស្ដែងរបស់ថ្នាក់ដឹកនាំរដ្ឋបាលសុរិយោដីស្រុក-ខណ្ឌ តាមលក្ខណៈភូមិសាស្ត្រដោយឡែក១ ការងារវាលត្រូវបានអនុវត្តដោយមន្ត្រីជំនាញ ដោយមានការសហការ និងការជួយជ្រោមជ្រែងពីមន្ត្រីនៅមូលដ្ឋាន (មេភូមិ មេឃុំ ឬចៅសង្កាត់)។ មន្ត្រីជំនាញដែលត្រូវបានចាត់តាំងឱ្យទទួលបន្ទុកការងារវាល មានភារកិច្ចទទួលខុសត្រូវលើការងារកំណត់ព្រំដី ការងារវាស់វែង ការងារបំពេញទម្រង់បែបបទនៃការប្រមូលទិន្នន័យដើម្បីធ្វើការវិនិច្ឆ័យឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស និងគោលការណ៍ច្បាប់។ ចំនួនមន្ត្រីចុះបំពេញការងារវាលអាចមានច្រើន ឬតិច អាស្រ័យលើតម្រូវការជាក់ស្ដែងនៃការងារក្នុងតំបន់ប្រតិបត្តិការនីមួយៗ។

ប្រសិនបើរដ្ឋបាលសុរិយោដីស្រុក-ខណ្ឌណាមួយមិនអាចបំពេញបានភារកិច្ច តាមល័ក្ខខ័ណ្ឌសម្រាប់អនុវត្តនីតិវិធីនៃការចុះបញ្ជីដី ក្នុងក្របខណ្ឌសមត្ថកិច្ចរបស់ខ្លួន ដោយខ្វះមន្ត្រី ឬដោយ

សមត្ថភាពបច្ចេកទេស រដ្ឋបាលសុរិយោដីនោះអាចស្នើសុំឱ្យរដ្ឋបាលសុរិយោដីខេត្ត-ក្រុង ជួយដល់ការអនុវត្តការងារទាំងនោះបាន ។

**១.១_តួនាទីរបស់មន្ត្រីជំនាញក្នុងការអនុវត្តការងារវាល**

**ក_អំពីការកំណត់ព្រំដី**

-មន្ត្រីទទួលបន្ទុកកំណត់ព្រំដីត្រូវចុះប្រតិបត្តិការតាមពេលវេលា និងទីកន្លែងដែលបានកំណត់ក្នុងសេចក្តីជូនដំណឹងរបស់អភិបាលស្រុក-ខណ្ឌ ។

-មន្ត្រីទទួលបន្ទុកកំណត់ព្រំដីមានសិទ្ធិចូលក្នុងបរិវេណដី ដើម្បីកំណត់ព្រំដី និងវាស់វែង ហើយអាចអញ្ជើញជនពាក់ព័ន្ធឱ្យផ្តល់ព័ត៌មានដោយផ្ទាល់មាត់ ឯកសារ ឬ/និងបង្ហាញភស្តុតាងផ្សេងៗទាក់ទងនឹងព្រំដីនោះ ។

-មន្ត្រីទទួលបន្ទុកកំណត់ព្រំដីត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

ក-ក្នុងករណីអ្នកដាក់ពាក្យ និងម្ចាស់ដីជាប់ព្រំមានវត្តមាន ហើយព្រមព្រៀងគ្នាអំពីព្រំប្រទល់ និងគ្មានភស្តុតាងផ្ទុយ ការកំណត់ព្រំដីត្រូវធ្វើដោយផ្អែកតាមការព្រមព្រៀង ។

ខ-ក្នុងករណីម្ចាស់ដីជាប់ព្រំមិនមានវត្តមាន ការកំណត់ព្រំដីត្រូវធ្វើដោយផ្អែកតាមឯកសារដែលមាន និងភស្តុតាងជាលក្ខណរូប ជាលាយលក្ខណ៍អក្សរ ឬផ្តល់ព័ត៌មានដោយផ្ទាល់មាត់ទាក់ទងទៅនឹងព្រំដីនោះ ។

គ-ក្នុងករណីក្បាលដីដែលស្នើសុំចុះបញ្ជីឋិតនៅជាប់នឹងដីសាធារណៈ ឬជាប់នឹងក្បាលដីដែលប្រើប្រាស់ជាសាធារណៈ ការកំណត់ព្រំដីត្រូវធ្វើដោយយោងតាមចំណុច (ក) ឬ (ខ) ខាងលើ ។

ឃ-វិវាទអំពីព្រំដីដែលមិនអាចដោះស្រាយបានក្នុងពេលកំណត់ព្រំដី ត្រូវបញ្ជូនទៅធ្វើការសម្រុះសម្រួលនៅថ្នាក់ស្រុក-ខណ្ឌ តាមនីតិវិធីដែលបានកំណត់ក្នុងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មការសុរិយោដី ។

**ខ_អំពីការវាស់វែង និងការកំណត់ទីតាំងក្បាលដី**

ក្រោយពីបានកំណត់ព្រំដីរួច មន្ត្រីទទួលបន្ទុកវាស់វែងត្រូវធ្វើការវាស់វែងទៅតាមតម្រូវការនៃការកសាងផែនទីក្បាលដី (parcel map) គំនូសបង្ហាញទីតាំងក្បាលដី និងផែនទីមានលក្ខណៈដាច់ដោយដុំ (sporadic index map) ក្នុងតំបន់នីមួយៗ ។

ក្នុងប្រព័ន្ធនេះ ការវាស់វែងអាចប្រព្រឹត្តទៅបានតាមវិធីពីរ អាស្រ័យទៅលើលក្ខណៈនៃភូមិសាស្ត្រ និងឧបករណ៍វាស់វែង៖

-លទ្ធផលនៃការវាស់វែងដែលធ្វើឡើងដោយប្រើឧបករណ៍ខ្សែម៉ែត្រ ឬខ្សែម៉ែត្រនិងព្រីស (prism) ក្នុងទីតាំងដែលមិនទាន់មានរូបថតពីអាកាស ឬមានរូបថតពីអាកាសតែមិនទាន់អាចភ្ជាប់ចំណុចប្រថពីវិភាគបាន អាចកសាងបានគំនូសបង្ហាញផែនទីក្បាលដី និងទីតាំងក្បាលដី ។

-ក្នុងការវាស់វែងដើម្បីកសាងគំនូសបង្ហាញទីតាំងក្បាលដី មន្ត្រីជំនាញត្រូវធ្វើការវាស់វែងដោយចងភ្ជាប់រាល់ចំណុចកាច់ជ្រុងដីទៅនឹងចំណុចគោល (point de repère) រឹងមាំ ស្ថិតស្ថេរ (ប្រសិនបើមាន) ឱ្យបានពីរចំណុចយ៉ាងតិច ។

-លទ្ធផលនៃការវាស់វែងដែលធ្វើឡើងដោយប្រើឧបករណ៍ទំនើប មាន Teodolite Total Station, EDM, GPS ឬ Orthophoto អាចកសាងផែនទីក្បាលដីដែលមាននិយាមកាបាន ។ ហើយនៅពេលដែលការចុះបញ្ជីដីមានលក្ខណៈដោយជាប្រព័ន្ធ ដំណើរការមកដល់តំបន់នេះ គេអាចបញ្ចូលប្រព័ន្ធចុះបញ្ជីដាច់ដោយដុំជាមួយប្រព័ន្ធចុះបញ្ជីថ្មីបាន ។

**គ-អំពីការវិនិច្ឆ័យ**

-មន្ត្រីទទួលបន្ទុកការងារវិនិច្ឆ័យមានសិទ្ធិសាកសួរយកព័ត៌មាន សម្រាប់អនុវត្តការងារវិនិច្ឆ័យ អាចអញ្ជើញជនពាក់ព័ន្ធឱ្យផ្តល់ព័ត៌មានដោយផ្ទាល់មាត់ ឯកសារ ឬ/និងវត្ថុតាងផ្សេងៗដែលទាក់ទងនឹងការវិនិច្ឆ័យ ។

-មន្ត្រីទទួលបន្ទុកការងារវិនិច្ឆ័យត្រូវកត់ត្រាព័ត៌មានអំពីម្ចាស់ដី ក្បាលដី ព្រមទាំងសិទ្ធិ និងបន្ទុកទាំងអស់ដែលមានលើក្បាលដី ចូលក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី រួចឱ្យអ្នកពាក់ព័ន្ធទាំងអស់ផ្តិតមេដៃ ហើយមន្ត្រីវិនិច្ឆ័យនោះក៏ត្រូវចុះហត្ថលេខា និងឈ្មោះទទួលខុសត្រូវលើឯកសារនោះផងដែរ ។

បន្ទាប់មក ទម្រង់បែបបទនេះក៏ត្រូវដាក់ជូនរដ្ឋបាលសុរិយោដីស្រុក-ខណ្ឌ ពិនិត្យ និងចុះហត្ថលេខាបញ្ជាក់ ។

-ក្នុងករណីមានវិវាទកើតឡើងទាក់ទងនឹងព្រំប្រទល់ក្បាលដី ទាក់ទងនឹងសិទ្ធិលើក្បាលដី មន្ត្រីទទួលបន្ទុកការងារវិនិច្ឆ័យត្រូវកត់ត្រាចូលក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យនោះថា ជាដីមានទំនាស់ និងបញ្ជាក់អំពីប្រភេទនៃទំនាស់នោះផង ។

**១.២-អំពីសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកកាន់កាប់ដី ឬអ្នកតំណាងស្របច្បាប់**

អ្នកកាន់កាប់ដី ឬអ្នកតំណាងស្របច្បាប់របស់ជននេះ មានកាតព្វកិច្ចចូលរួម និងសហការក្នុងការងារកំណត់ព្រំដី វាស់វែង និងវិនិច្ឆ័យ ដោយផ្តល់ព័ត៌មានពិតដោយផ្ទាល់មាត់ ជាលាយលក្ខណ៍អក្សរ ឬភស្តុតាងផ្សេងៗទាក់ទងនឹងក្បាលដីរបស់ខ្លួន ឬក្បាលដីដែលខ្លួនត្រូវបានចាត់ធ្វើជាតំណាង ឬក្បាលដីអ្នកជាប់ព្រំជូនមន្ត្រីជំនាញ។

ជនណាដែលបានផ្តល់ព័ត៌មានខុស ដោយចេតនា ឬបំភាន់មន្ត្រីសុរិយោដីក្នុងពេលបំពេញបេសកកម្ម ឬបំភាន់ក្នុងការចុះបញ្ជីដីត្រូវទទួលទោសតាមមាត្រា២៥២នៃច្បាប់ភូមិបាល។

ក្នុងរយៈពេលប្រតិបត្តិការរបស់មន្ត្រីជំនាញ អ្នកកាន់កាប់ដី ឬអ្នកតំណាងស្របច្បាប់របស់ជននេះ ឬជនមានផលប្រយោជន៍ពាក់ព័ន្ធ មានសិទ្ធិជំទាស់ ឬតវ៉ា ប្រសិនបើខ្លួនយល់ថា ទិន្នន័យដែលមន្ត្រីជំនាញបានកត់ត្រាចូលក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យ ឬឯកសារផ្សេងទៀតទាក់ទងនឹងការវិនិច្ឆ័យនោះមិនត្រឹមត្រូវ ឬខុសពីចម្លើយរបស់ខ្លួន។

**១.៣-អំពីសិទ្ធិភារកិច្ចរបស់អាជ្ញាធរដែនដី**

ក-អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវបង្កលក្ខណៈងាយស្រួល សហការឱ្យបានល្អ និងផ្តល់សុវត្ថិភាពដល់កិច្ចប្រតិបត្តិការរបស់មន្ត្រីជំនាញ ដើម្បីធ្វើឱ្យសម្រេចនូវការអនុវត្តនីតិវិធីនៃការវិនិច្ឆ័យដែលប្រព្រឹត្តទៅនៅក្នុងដែនដីដែលខ្លួនទទួលខុសត្រូវ។

ក្នុងករណីចាំបាច់ រដ្ឋបាលសុរិយោដីអាចស្នើសុំទៅអាជ្ញាធរដែនដី ឬកម្លាំងប្រដាប់អាវុធឱ្យជួយជ្រោមជ្រែងដល់ការអនុវត្តការងារវាល។

ខ-ក្នុងការផ្តល់យោបល់លើពាក្យស្នើសុំ ឬឯកសារព័ត៌មានពាក់ព័ន្ធនឹងការកំណត់សិទ្ធិលើដី ពិសេសការផ្តល់យោបល់ទាក់ទងនឹងល័ក្ខខ័ណ្ឌនៃការកាន់កាប់ដី ប្រភព និងកាលបរិច្ឆេទនៃការកាន់កាប់ដី ត្រូវតែជាព័ត៌មានពិត មិនបំភ្លៃ បំភាន់ ឬផ្អែកលើមនោសញ្ចេតនាបុគ្គលដែលជាហេតុនាំឱ្យការកំណត់សិទ្ធិលើអចលនវត្ថុមិនបានត្រឹមត្រូវ និងនាំឱ្យមានកើតទំនាស់។

ក្នុងរយៈពេលនៃការបិទផ្សាយនូវឯកសារនៃការវិនិច្ឆ័យក្នុងឃុំ ឬសង្កាត់ណា មេឃុំ ឬចៅសង្កាត់នោះត្រូវមានវត្តមានតាមតម្រូវការជាក់ស្តែងនៃការងារ។ ក្នុងករណីមានធុរៈ មេឃុំ ឬចៅសង្កាត់នោះត្រូវចាត់តាំងតំណាងរបស់ខ្លួនមកជំនួស។

**២-ការងារនៅការិយាល័យ**

ទិន្នន័យដែលប្រមូលបានពីការងារវាលមានគុណភាពពីរៈ

-អាចបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រដើម្បីកសាងផែនទីក្បាលដី ផែនទីបង្ហាញទីតាំងដីស្នើសុំ ផែនទីមានលក្ខណៈដាច់ដោយដុំ កសាងបញ្ជីឈ្មោះម្ចាស់ដី និងសៀវភៅចុះបញ្ជីអចលនវត្ថុ ចំពោះក្បាលដីទាំងឡាយដែលការវាស់វែង ត្រូវបានធ្វើឡើងដោយឧបករណ៍ទំនើប (រាល់ចំណុចជ្រុងនៃក្បាលដីនីមួយៗ ត្រូវបានកំណត់ដោយនិយាមកា)។

-អាចគូរផែនទីក្បាលដី គូរគំនូសបង្ហាញទីតាំងដីស្នើសុំ ផែនទីមានលក្ខណៈដាច់ដោយដុំ កសាងបញ្ជីឈ្មោះម្ចាស់ដី និងសៀវភៅចុះបញ្ជីអចលនវត្ថុ ចំពោះក្បាលដីដែលការវាស់វែងត្រូវបានធ្វើឡើងដោយឧបករណ៍សាមញ្ញ (មិនអាចបង្កើតនិយាមកាតាមចំណុចជ្រុងនៃក្បាលដីនីមួយៗបាន)។

របៀបរៀបចំខ្លឹមសារ និងការកាន់កាប់ឯកសារសុរិយោដីៈ សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីអចលនវត្ថុ ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី បញ្ជីឈ្មោះម្ចាស់ដី ផែនទីក្បាលដី ផែនទីមានលក្ខណៈដាច់ដោយដុំ និងឯកសារណាបផ្សេងៗទៀត ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ដំណាក់កាលទី៣ អំពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ**

ឯកសារនៃការវិនិច្ឆ័យដែលត្រូវបិទផ្សាយ រួមមានផែនទីក្បាលដី ឬគំនូសបង្ហាញទីតាំងក្បាលដី និងបញ្ជីឈ្មោះម្ចាស់ដី។

ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ត្រូវធ្វើឡើងក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃ នៅសាលាស្រុក-ខណ្ឌដែលក្បាលដីនោះឋិតនៅ។ សេចក្ដីចម្លងនៃឯកសារទាំងនេះ ក៏ត្រូវបិទផ្សាយផងដែរនៅសាលាឃុំ-សង្កាត់ដែលក្បាលដីស្នើសុំចុះបញ្ជីនោះឋិតនៅ។

អភិបាលស្រុក-ខណ្ឌត្រូវជូនដំណឹងអំពីការបិទផ្សាយជាសាធារណៈ នូវឯកសារនៃការវិនិច្ឆ័យនេះ ដល់អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីដី។ សេចក្ដីជូនដំណឹងត្រូវធ្វើឡើងយ៉ាងតិច៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃបើកការផ្សព្វផ្សាយជាសាធារណៈ ហើយត្រូវបិទផ្សាយនៅកន្លែងដែលងាយមើលឃើញនៅក្នុងភូមិ នៅសាលាឃុំ-សង្កាត់ និងសាលាស្រុក-ខណ្ឌ។

ក្នុងរយៈពេលនៃការបិទផ្សាយ សាមីអ្នកកាន់កាប់ដី ឬអ្នកតំណាងស្របច្បាប់របស់ខ្លួន និងជនដែលមានផលប្រយោជន៍ពាក់ព័ន្ធនឹងក្បាលដីស្នើចុះបញ្ជី អាចជូនដំណឹងពីការជំទាស់របស់

ខ្លួន ឬធ្វើបណ្ដឹងជំទាស់ ឬបណ្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ដល់អ្នកប្រចាំការកន្លែងបិទផ្សាយ។ រដ្ឋបាលសុរិយោដីស្រុក-ខណ្ឌត្រូវស៊ើបអង្កេតលើការជំទាស់នោះ ដោយផ្អែកតាមឯកសារ និងព័ត៌មានទាំងអស់ដែលប្រមូលបានក្នុងពេលអនុវត្តនីតិវិធី។

ក្នុងករណីដែលការស៊ើបអង្កេតនោះបង្ហាញថា ការជំទាស់ ឬការតវ៉ាមានលក្ខណៈសមហេតុសមផល រដ្ឋបាលសុរិយោដីស្រុក-ខណ្ឌអាចធ្វើការកែតម្រូវការខុសឆ្គង ឬការភ្លេចភ្លាំងដែលមិនប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់នៃជនណាមួយ។ ការកែតម្រូវផ្សេងទៀតក្នុងឯកសារនៃការវិនិច្ឆ័យ អាចធ្វើបានដរាបណាមានការយល់ព្រមពីជនពាក់ព័ន្ធដែលទទួលឥទ្ធិពលពីការកែតម្រូវនោះ។

ក្នុងករណីដែលការស៊ើបអង្កេតនោះបង្ហាញថា ការជំទាស់ ឬការតវ៉ាមានលក្ខណៈមិនសមហេតុសមផល ឬមិនអាចសម្រុះសម្រួលបាន ការជំទាស់ ឬការតវ៉ាទាំងនោះត្រូវដាក់ឱ្យធ្វើការសម្រុះសម្រួល និងដោះស្រាយតាមនីតិដែលមានកំណត់ក្នុងអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី។

បណ្ដឹងនីមួយៗត្រូវធ្វើកំណត់ត្រាដោយឡែក ហើយត្រូវបញ្ជាក់អំពីកម្មវត្ថុនៃបណ្ដឹង ឈ្មោះ និងស្នាមមេដៃម្ចាស់បណ្ដឹង ឈ្មោះ និងហត្ថលេខាមន្ត្រីកត់ត្រា និងមានការបញ្ជាក់ដឹងឮពីមេឃុំ-ចៅសង្កាត់ ឬតំណាង។

ក្នុងករណីមិនមានការជំទាស់ ឬតវ៉ា ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈ ទិន្នន័យដែលបានកត់ត្រាក្នុងឯកសារបិទផ្សាយនោះ ត្រូវបានចាត់ទុកជាទិន្នន័យសុក្រឹតដែលអាចកំណត់យកជាផ្លូវការតាមច្បាប់បាន។

**ដំណាក់កាលទី៤ អំពីការសម្រេចលើឯកសារ**

១-ក្រោយពីផុតរយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ មន្ត្រីជំនាញទទួលបន្ទុកការងារវិនិច្ឆ័យត្រូវធ្វើរបាយការណ៍ស្ដីពីលទ្ធផលនៃការវិនិច្ឆ័យ តាមខ្លឹមសារខាងក្រោម៖

ក-លទ្ធផលសម្រេចបាន៖

-ចំនួនក្បាលដីសរុបដែលបានធ្វើការវិនិច្ឆ័យ

-ចំនួនក្បាលដីដែលមានលក្ខណៈត្រឹមត្រូវ និងគ្មានវិវាទ ហើយគួរផ្តល់ប័ណ្ណ

-ចំនួនក្បាលដីដែលមិនគួរផ្តល់ប័ណ្ណជូន មានជាអាទិ៍៖

+ក្បាលដីស្នើសុំត្រូវបានកាន់កាប់ ក្រោយច្បាប់ភូមិបាលចូលជាធរមាន

+ក្បាលដីកំពុងមានវិវាទ

-បញ្ជូនទៅគណៈកម្មការសុរិយោដី

-កំពុងមានបណ្តឹង និងកំពុងដំណើរការនីតិវិធីនៅតុលាការ ។

ខ-មន្ត្រីជំនាញដែលទទួលបន្ទុកការងារវិនិច្ឆ័យត្រូវធ្វើការវាយតម្លៃ លើកសំណើផ្តល់សិទ្ធិលើដី ឬអចលនវត្ថុជូនអ្នកកាន់កាប់ដែលបានស្នើសុំ ឬអាជ្ញាធរដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងតាមប្រភេទ៖ កម្មសិទ្ធិ ភោគៈ សម្បទានមិនត្រូវផ្តល់ប័ណ្ណជាលក្ខណៈឯកជន ឬរក្សាទុកជាទ្រព្យរដ្ឋ ដោយយោងតាមច្បាប់បទដ្ឋានគតិយុត្តពាក់ព័ន្ធ និងឯកសារភស្តុតាងដែលប្រមូលបាន ។

គ-មន្ត្រីជំនាញដែលទទួលបានការងារវិនិច្ឆ័យ ត្រូវគូសក្បាលដីដែលមានលក្ខណៈត្រឹមត្រូវ និងគ្មានទំនាស់ចូលក្នុងផែនទីមានលក្ខណៈដាច់ដោយដុំ ។

២-ក្រោយពីផែនទីក្បាលដី និងបញ្ជីឈ្មោះអ្នកកាន់កាប់ដីត្រូវបានកែតម្រូវរួចហើយ មន្ត្រីជំនាញដែលទទួលបន្ទុកការងារវិនិច្ឆ័យក្បាលដីតាមពាក្យស្នើសុំ ត្រូវរៀបចំសំណុំឯកសារដូចខាងក្រោម ដើម្បីដាក់ជូនរដ្ឋបាលសុរិយោដីស្រុក-ខណ្ឌពិនិត្យ និងបញ្ជូនបន្តទៅរដ្ឋបាលសុរិយោដីខេត្ត-ក្រុង ។

-ពាក្យស្នើសុំចុះបញ្ជីដី

-ឯកសារនៃការវិនិច្ឆ័យ (ឯកសារទាក់ទងនឹងការកំណត់ព្រំដី ការវាស់វែងដី ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ផែនទីក្បាលដី)

-សេចក្តីជូនដំណឹងស្តីពីកាលបរិច្ឆេទនៃការកំណត់ព្រំដី

-ការដកស្រង់ផែនទីមានលក្ខណៈដាច់ដោយដុំ ឬគំនូសបង្ហាញទីតាំងក្បាលដី

-សេចក្តីជូនដំណឹងស្តីពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ

-កំណត់ហេតុបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ

-របាយការណ៍ស្តីពីលទ្ធផលនៃការវិនិច្ឆ័យ

-ពាក្យបណ្តឹងជំទាស់តវ៉ាដែលពុំអាចដោះស្រាយបាន ប្រសិនបើមាន

-លិខិតស្នើសុំកែតម្រូវ ប្រសិនបើមាន

-កំណត់ហេតុសម្រុះសម្រួលវិវាទដែលបានដោះស្រាយរួច ប្រសិនបើមាន។

**ដំណាក់កាលទី៥ អំពីការចេញប័ណ្ណដី**

បន្ទាប់ពីបានទទួលសំណុំរឿងពីរដ្ឋបានសុរិយោដីស្រុក-ខណ្ឌ រដ្ឋបាលសុរិយោដីខេត្ត-ក្រុង ត្រូវ៖

-ពិនិត្យ និងផ្តល់យោបល់ជូនអភិបាលខេត្ត-ក្រុង សម្រេចយល់ព្រមឱ្យចេញប័ណ្ណ ឬជំទាស់ត្រង់ចំណុចណា ឬច្រានចោលទាំងស្រុងតែម្តង។

ករណីអភិបាលខេត្ត-ក្រុងសម្រេចយល់ព្រមឱ្យចេញប័ណ្ណ រដ្ឋបាលសុរិយោដីខេត្ត-ក្រុង ដែលបានទទួលប្រតិភូកម្មហត្ថលេខាពីក្រសួងអាណាព្យាបាល អាចចេញប័ណ្ណជូនសាមីអ្នកស្នើសុំតែម្តង លើកលែងតែវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ (ប័ណ្ណកម្មសិទ្ធិ) ដែលត្រូវសុំការសម្រេចយល់ព្រមឱ្យចេញប័ណ្ណពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ជាមុនសិន។

ករណីអភិបាលខេត្ត-ក្រុងជំទាស់ត្រង់ចំណុចណាមួយ ឬច្រានចោល អភិបាលខេត្ត-ក្រុង នោះត្រូវបញ្ជាក់ឱ្យច្បាស់ពីមូលហេតុនៃការជំទាស់ ឬការច្រានចោលនោះ ដើម្បីរដ្ឋបាលសុរិយោដីជម្រាបទៅអ្នកស្នើសុំឱ្យបានជ្រាប។

-ពិនិត្យ និងផ្តល់យោបល់ជូនអភិបាលខេត្ត-ក្រុងសម្រេចយល់ព្រម ឬជំទាស់ចំណុចណាមួយ ឬច្រានចោលមិនផ្តល់ប័ណ្ណជូនអ្នកស្នើសុំ។

ករណីអភិបាលខេត្ត-ក្រុងសម្រេចយល់ព្រម រដ្ឋបាលសុរិយោដីខេត្ត-ក្រុងដែលមិនទាន់បានទទួលប្រតិភូកម្មហត្ថលេខាពីក្រសួងអាណាព្យាបាល ត្រូវបញ្ជូនសំណុំរឿងនេះបន្តមកអគ្គនាយកដ្ឋាន និងភូមិសាស្ត្រដើម្បីពិនិត្យ បន្ថែមគោលការណ៍ជំនាញ បើឃើញថាត្រឹមត្រូវ ត្រូវធ្វើការចុះបញ្ជី ហើយចេញប័ណ្ណជូនអ្នកស្នើសុំ។

តែបើមានចំណុចណាមិនទាន់ត្រឹមត្រូវ ឬមិនគ្រប់គ្រាន់ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រត្រូវណែនាំរដ្ឋបាលសុរិយោដីខេត្ត-ក្រុង កែតម្រូវ ឬបំពេញឡើងវិញដោយផ្អែកលើគោលការណ៍ជំនាញ និងច្បាប់ជាមូលដ្ឋាន។

ករណីអភិបាលខេត្ត-ក្រុងជំទាស់ចំណុចណាមួយ ឬច្រានចោលទាំងស្រុងតែម្តង រដ្ឋបាលសុរិយោដីខេត្ត-ក្រុងត្រូវពិនិត្យមើលចំណុចនោះឡើងវិញ ហើយរាយការណ៍សុំយោបល់អភិបាលខេត្ត-ក្រុងនោះជាលើកទី២ ប្រសិនពិនិត្យឃើញថាមូលហេតុនៃការជំទាស់ ឬច្រានចោលនោះមិនស្របនឹងសភាពការណ៍ពិតដូចដែលគាត់បានដឹង។

ករណីដែលអភិបាលខេត្ត-ក្រុងនៅតែរក្សារការសម្រេចលើកទីមួយ រដ្ឋបាលសុរិយោដីខេត្ត-ក្រុងត្រូវបញ្ជូនសំណុំរឿងនោះមកអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ដោយភ្ជាប់យោបល់ជំទាស់ ឬច្រានចោល និងរបាយការណ៍ពិនិត្យឡើងវិញមកជាមួយ ដើម្បីអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រពិនិត្យ និងសម្រេច ។

**គោលការណ៍នៃការចេញប័ណ្ណដី**

១-សមត្ថកិច្ចក្នុងការសម្រេចលើទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី និងការចេញប័ណ្ណដីត្រូវបានប្រគល់សិទ្ធិជូនរដ្ឋបាលសុរិយោដីខេត្ត-ក្រុង លើកលែងតែដីដែលមានទំហំលើសពី២០ហិកតាឡើងទៅដែលត្រូវសម្រេចដោយរដ្ឋបាលសុរិយោដីថ្នាក់កណ្តាល ។

ឯសមត្ថកិច្ចក្នុងការវាស់វែង គឺអាស្រ័យទៅលើសមត្ថភាពបច្ចេកទេសរបស់មន្ត្រីមូលដ្ឋាន និងឧបករណ៍ប្រើប្រាស់ដែលមាន។ ករណីមិនអាចធ្វើបាន ឬមានទំហំលើសពី២០ហិកតា រដ្ឋបាលសុរិយោដីខេត្ត-ក្រុងត្រូវលើកសំណើមករដ្ឋបាលសុរិយោដីថ្នាក់កណ្តាលដើម្បីឧបត្ថម្ភ ។

២-ចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ (ប័ណ្ណកម្មសិទ្ធិ) ជូន ចំពោះក្បាលដីណាដែលម្ចាស់សិទ្ធិបានចូលកាន់កាប់ដីមុនថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ឬបានកាន់កាប់បន្តពីភោគីដើម មានលក្ខណៈត្រឹមត្រូវតាមច្បាប់ មិនមានការជំទាស់ មានរយៈពេល៥ឆ្នាំយ៉ាងតិច គិតពីថ្ងៃចូលកាន់កាប់ដីមកដល់ថ្ងៃចេញប័ណ្ណ ហើយក្បាលដីនោះត្រូវបានកសាងផែនទីក្បាលដីដែលមាននិយាមកាច្បាស់លាស់រួច ។

៣-ចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ (ប័ណ្ណភោគៈ) ជូន ចំពោះក្បាលដីណាដែលម្ចាស់សិទ្ធិបានចូលកាន់កាប់ដីមុនថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ឬកាន់កាប់បន្តពីភោគីដើម មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ហើយមានរយៈពេលតិចជាង៥ឆ្នាំ ឬក្នុងករណីដែលបានកាន់កាប់លើសពី៥ឆ្នាំ តែមិនទាន់បានកសាងផែនទីក្បាលដីដែលមាននិយាមកាច្បាស់លាស់រួច ។

ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុដែលបានផ្តល់ឱ្យតាមនីតិវិធីចុះបញ្ជីថ្មីនេះ អាចដូរយកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុបាន នៅពេលដែលរយៈពេលនៃការកាន់កាប់ដីនោះ បានគ្រប់៥ឆ្នាំ ឬលើស ហើយប្លង់សុរិយោដីត្រូវបានកសាងរួច ។

៤-អាចចេញប័ណ្ណជូនបានចំពោះតែក្បាលដីណាដែលគ្មានទាក់ទិននឹងវិវាទ ឬមានវិវាទតែត្រូវបានដោះស្រាយចប់ជាស្ថាពរ ។

៥-មិនអាចចេញប័ណ្ណជូនបានទេចំពោះក្បាលដីដែលអ្នកស្នើសុំបានចូលកាន់កាប់ដី ក្រោយច្បាប់ភូមិបាលចូលជាធរមាន ។

៦-មិនអាចចេញប័ណ្ណជូនជាឯកជនបានទេ ចំពោះក្បាលដីណាដែលត្រូវបានកំណត់ទាំងស្រុងជាទ្រព្យសម្បត្តិសាធារណៈ ឬទុកបម្រើសេវាសាធារណៈ ។

ចំពោះក្បាលដីស្នើសុំចុះបញ្ជី ដែលមានចំណែកណាមួយត្រួតគ្នាលើដីដែលជាសម្បត្តិសាធារណៈ ឬទុកបម្រើសេវាសាធារណៈអាចចេញប័ណ្ណជូនបុគ្គលឯកជនបាន លុះត្រាតែចំណែកត្រួតគ្នានោះត្រូវបានដកចេញពីទំហំសរុបនៃក្បាលដី ។

៧-នៅពេលទទួលប័ណ្ណថ្មី ម្ចាស់ដីត្រូវប្រគល់ឯកសារទាំងអស់ទាក់ទងនឹងសិទ្ធិលើក្បាលដីនោះដែលខ្លួនមានពីមុនមក ជូនមន្ត្រីសុរិយោដី ។

រាល់ឯកសារទាក់ទងនឹងសិទ្ធិលើក្បាលដីដែលសាមីម្ចាស់ដីមិនបានប្រគល់ ឬមិនបានរាយការណ៍ពីការប្រើប្រាស់ជូនមន្ត្រីជំនាញមានសមត្ថកិច្ចត្រូវបានចាត់ទុកជាមោឃៈ និងមិនមានអានុភាពតាមផ្លូវច្បាប់ ។

៨-ការប្រគល់ប័ណ្ណដីត្រូវបានធ្វើឡើងដោយមានសៀវភៅសម្រាប់កត់ឈ្មោះ និងចុះហត្ថលេខាមន្ត្រីប្រគល់ និងកត់ឈ្មោះ រួចផ្ដិតមេដៃអ្នកទទួលទុកជាភស្តុតាងផង ។

ការប្រគល់ប័ណ្ណដីត្រូវប្រព្រឹត្តទៅនៅអង្គភាពសុរិយោដីដែលមានសមត្ថកិច្ច ។

មន្ត្រីសុរិយោដីមិនត្រូវបានអនុញ្ញាតឱ្យប្រគល់ប័ណ្ណដី ជូនបុគ្គលក្រៅពីម្ចាស់សិទ្ធិពិតប្រាកដឡើយ លើកលែង

-ករណីម្ចាស់សិទ្ធិទទួលមរណភាព ឬអវត្តមាន ឬត្រូវបាត់ខ្លួន ឬបាត់បង់សមត្ថភាព ហើយត្រូវបានច្បាប់ទទួលស្គាល់អ្នកតំណាងស្របច្បាប់

-ករណីពិសេស និងចាំបាច់ ម្ចាស់សិទ្ធិអាចប្រគល់សិទ្ធិឱ្យអ្នកតំណាងស្របច្បាប់របស់ខ្លួនមកទទួលយកប័ណ្ណជំនួស តែត្រូវបញ្ជាក់ច្បាស់ជាលាយលក្ខណ៍អក្សរអំពីហេតុដែលមិនអាចមកទទួលយកនៅរដ្ឋបាលសុរិយោដី ។

៩-ចំពោះនីតិបុគ្គល ប័ណ្ណត្រូវចុះឈ្មោះអង្គភាព ឬនាមករណ៍ (នីតិបុគ្គលសាធារណៈមានជាអាទិ៍ សាលារៀន សាលាឃុំ . . . នីតិបុគ្គលឯកជនមានជាអាទិ៍ សមាគម ក្រុមហ៊ុន . . .) គឺមិនត្រូវចុះឈ្មោះរូបវន្តបុគ្គលជាដាច់ខាត ចំពោះដី ឬអចលនវត្ថុរបស់សមូហភាព ដូចជាវត្ត ឬ

សហគមន៍ជនជាតិដើមភាគតិច . . . នៅក្នុងប័ណ្ណ ក៏ត្រូវចុះឈ្មោះវត្ត ឬសហគមន៍ . . . ដែរ គឺមិនត្រូវចុះឈ្មោះរូបវន្តបុគ្គល ជាតំណាងឡើយ ។

ទាក់ទងដល់ការប្រើសិទ្ធិ និងការបំពេញកាតព្វកិច្ចផ្សេងៗ ក្នុងការអនុវត្តនីតិវិធីនៃការវិនិច្ឆ័យ នីតិបុគ្គលនានាក៏ដូចជាសមូហភាពទាំងអស់នោះ ត្រូវជ្រើសរើសតំណាងស្របច្បាប់រៀងខ្លួនតាមវិធីផ្សេងៗគ្នា ដូចជានីតិបុគ្គលសាធារណៈ មានលិខិតតែងតាំង នីតិបុគ្គលឯកជន មានការជ្រើសតាំងបណ្ណាធិការក្រុមហ៊ុន ឬប្រធានសមាគម បើវត្ត មានប្រធានគណៈកម្មការវត្ត បើសហគមន៍ជនជាតិដើមភាគតិច មានមេសហគមន៍ . . .។ល។ តំណាងស្របច្បាប់ទាំងនេះមានសិទ្ធិ និងកាតព្វកិច្ចទាក់ទងនឹងដី ឬអចលនវត្ថុ ដូចម្ចាស់សិទ្ធិជារូបវន្តបុគ្គលដែរ ។

ឯប័ណ្ណដី ឬអចលនវត្ថុរបស់នីតិបុគ្គលសាធារណៈ និងឯកជនត្រូវប្រគល់ឱ្យតំណាងស្របច្បាប់នៃនីតិបុគ្គលនីមួយៗ ជាអ្នកទទួលយក និងរក្សាទុក ។

ចំពោះប័ណ្ណដី ឬអចលនវត្ថុរបស់សមូហភាពត្រូវប្រគល់ជូនតំណាងស្របច្បាប់ ឬមេសហគមន៍ទទួលយក និងរក្សាទុក ។

ក្នុងពេលដែលមិនទាន់មានលក្ខណសម្បត្តិបច្ចេកទេសគ្រប់គ្រាន់ ក្នុងការអនុវត្តពេញលេញសារាចរណែនាំខាងលើនេះ និងដើម្បីកុំឱ្យមានការរាំងស្ទះដំណើរការចេញប័ណ្ណ នីតិវិធីនៃការចេញប័ណ្ណត្រូវគួបផ្សំជាមួយនឹងនីតិវិធីដែលធ្លាប់អនុវត្តកន្លងមក ។

ភ្នំពេញ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៤

**រដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**អ៊ឹម ឈុនលឹម**

<u>កន្លែងទទួល</u>

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"
-គ្រប់ក្រសួង ស្ថាប័ន
-គ្រប់ខេត្ត-ក្រុង
"ដើម្បីសហការអនុវត្ត"
-គ្រប់អគ្គនាយកដ្ឋានក្រោមឱវាទក្រសួង
-គ្រប់មន្ទីរ ដ.ន.ស.ស ខេត្ត-ក្រុង
"ដើម្បីអនុវត្ត"
-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**លេខ០២ជនស/សជ** ភ្នំពេញ ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៤

## សេចក្តីណែនាំស្តីពីការចុះបញ្ជីដីបន្ត

រយៈកន្លងមកឯកសារសុរិយោដីត្រូវបានកសាង និងកាន់កាប់តាមពីររបៀបគឺរបៀបចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ និងរបៀបចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ។ ឯកសារមូលដ្ឋាននៃការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធមានទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី បញ្ជីឈ្មោះម្ចាស់ដី ប្លង់សុរិយោដី និងឯកសារណេបផ្សេងៗ។ រីឯ ឯកសារមូលដ្ឋាននៃការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ មានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ប្រកាសជូនដំណឹងពីការចុះធ្វើអង្កេតវាស់វែងកំណត់ហេតុអង្កេតដី និងឯកសារណេបផ្សេងៗ។

ឯកសារទាំងនោះ ទោះបីមានការណែនាំជាបន្តបន្ទាប់ក៏ដោយ ក្រសួងសង្កេតឃើញថាការកាន់កាប់ឯកសារសុរិយោដីនៅមិនទាន់ឯកភាពគ្នា និងមានភាពសុក្រឹតនៅឡើយ។

ដើម្បីឱ្យភាពរលូនក្នុងការងារ ពិសេសពាក់ព័ន្ធនឹងការងារចុះបញ្ជីដីបន្ត ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមធ្វើការណែនាំដល់គ្រប់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុងដូចតទៅ៖

+ត្រូវពង្រឹង ណែនាំដល់មន្ត្រីក្រោមឱវាទ ជាអាទិ៍ ថ្នាក់ដឹកនាំការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ មន្ត្រីទទួលបន្ទុកកាន់កាប់ឯកសារ (មន្ត្រីអភិរក្សសុរិយោដី) ឱ្យខិតខំយកចិត្តទុកដាក់បង្កើនស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការកសាងឯកសារមូលដ្ឋានដូចជាកិច្ចសន្យាលក់ លិខិតអំណោយផ្តាច់ ការបញ្ជាក់អំពីប្រភេទទ្រព្យ ការបញ្ជាក់អំពីអត្តសញ្ញាណម្ចាស់ទ្រព្យ និងកិច្ចសន្យាដាក់បន្ទុកលើអចលនវត្ថុជាដើម ធ្វើការផ្ទៀងផ្ទាត់ ត្រួតពិនិត្យសុពលភាពភាពត្រឹមត្រូវ និងគ្រប់គ្រាន់នៃឯកសារ។

+ត្រូវបន្តពង្រឹងការកាន់កាប់ឯកសារមូលដ្ឋាន ដោយត្រូវធ្វើចរន្តការក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ ឬសៀវភៅគោលបញ្ជីដី ផែនទីមានលក្ខណៈដាច់ដោយដុំ និងប្លង់សុរិយោដីនូវរាល់

ការប្រែប្រួលគតិយុត្ត ឬលក្ខណរូបនៃក្បាលដី កសាងតារាងវាយឈ្មោះម្ចាស់ដីតាមលំដាប់អក្សរ (T.A = Tableau Alphabétique des propriétaires) ពង្រឹងការងារប័ណ្ណសារដ្ឋាន . . .។

+ត្រូវយកចិត្តទុកដាក់សម្របសម្រួលគ្នារវាងការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ និង ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ ដោយ៖

-ចំពោះការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធត្រូវប្រមូលប័ណ្ណចាស់ (ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬប័ណ្ណស្នាបមាន់ ចេញដោយអតីតការិយាល័យសុរិយោដីខេត្ត-ក្រុង ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ចេញដោយអតីតនាយកដ្ឋានសុរិយោដី ឬអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ) ដែលបានចេញហើយក្នុងតំបន់ធ្វើការវិនិច្ឆ័យ នៅពេលចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ រួចធ្វើតារាង (គំរូលេខ១) ផ្ញើជូននាយកដ្ឋានអភិរក្សដើម្បីចាត់ការតាមនីតិវិធីអភិរក្សសុរិយោដី។

ម្យ៉ាងទៀត ចំពោះវិញ្ញាបនបត្រគំរូចាស់ដែលបានចេញរួចកន្លងមក នៅពេលមានការផ្លាស់ប្តូរ ប្រែប្រួលសិទ្ធិ ឬលក្ខណរូបនៃក្បាលដី ត្រូវប្រមូលមកវិញ ហើយចេញវិញ្ញាបនបត្រគំរូថ្មីជំនួសវិញ។ ឯវិញ្ញាបនបត្រចាស់ត្រូវគូសឆូត ឬបោះត្រាមោឃភាព ហើយរក្សាទុកជាឯកសារ រួចធ្វើតារាងសម្រង់អចលនវត្ថុផ្ញើជូននាយកដ្ឋានអភិរក្សសុរិយោដី ផ្នែកប្រព័ន្ធព័ត៌មានដី (LIS) នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌដើម្បីធ្វើចរន្តការក្នុងឯកសារសុរិយោដីឱ្យបានស្របគ្នា។

បន្ទាប់ពីសេចក្តីណែនាំនេះត្រូវបានសម្រេចហើយ ផ្នែកប្រព័ន្ធព័ត៌មានដី (LIS) និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង ត្រូវផ្ញើឯកសារសុរិយោដីនៃតំបន់ចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធទាំងអស់ មានប្លង់សុរិយោដី សៀវភៅគោលបញ្ជីដី បញ្ជីឈ្មោះម្ចាស់ដី ទៅនាយកដ្ឋានអភិរក្សសុរិយោដីដើម្បីតាមដានការវិវត្តនៃក្បាលដី ត្រួតពិនិត្យការធ្វើលេខាចារឹកលើឯកសារ និងជាមូលដ្ឋានក្នុងការផ្តល់ព័ត៌មានដល់ជនទាំងឡាយដែលបានមកទាក់ទងសាកសួរ។

-ចំពោះការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ បន្ទាប់ពីទទួលបានឯកសារ នាយកដ្ឋានអភិរក្សត្រូវចាត់ធ្វើលេខាចារឹកក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ និងតារាងវាយឈ្មោះម្ចាស់ដី តាមលំដាប់អក្សរ រួចធ្វើតារាងសម្រង់អចលនវត្ថុផ្ញើជូនផ្នែកប្រព័ន្ធព័ត៌មានដី(LIS)នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង

ដើម្បីធ្វើចរន្តការឱ្យបានស្របគ្នា ក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ និងតារាងវាយឈ្មោះម្ចាស់ដីតាមលំដាប់អក្សរ។

**អំពីការកសាងឯកសារ**

+ការចុះបញ្ជីដីបន្តទាក់ទងនឹងការផ្ទេរសិទ្ធិ៖ ក្នុងរឿងអចលនវត្ថុ ការផ្ទេរសិទ្ធិអាចប្រព្រឹត្តទៅបាន ហើយតតិយជនមិនអាចជំទាស់បាន លុះត្រាតែលិខិតផ្ទេរសិទ្ធិនោះធ្វើឡើងតាមរូបមន្តយថាភូត ដោយបុគ្គលដែលមាននីតិសម្បទា និងត្រូវបានចុះបញ្ជីនៅអង្គភាពសុរិយោដី។ កិច្ចសន្យាដែលនាំទៅដល់ការផ្ទេរសិទ្ធិមាន កិច្ចសន្យាលក់ កិច្ចសន្យាដូរ កិច្ចសន្យាឱ្យ និងកិច្ចសន្យាជម្រះមតិក។

ក្នុងការតាក់តែងលិខិតសញ្ញាខាងលើ មន្ត្រីទទួលបន្ទុក (ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ) ត្រូវយកចិត្តទុកដាក់ និងទទួលខុសត្រូវចំពោះមុខច្បាប់លើអត្តសញ្ញាណគូភាគី គឺភាគីអ្នកលក់ត្រូវតែជាម្ចាស់អចលនវត្ថុដែលត្រូវលក់ពិតប្រាកដ ហើយម្ចាស់បំណុលរបស់គេម្នាក់ៗអាចប្ដឹងរឹបអូសចំណែកឯកជននោះបាន។

ក្រៅពីកិច្ចសន្យា សេចក្ដីសម្រេចរបស់តុលាការក៏នាំឱ្យទៅដល់ការផ្ទេរសិទ្ធិដែរ។

+ការចុះបញ្ជីដីបន្តទាក់ទងនឹងការបង្កើតសិទ្ធិថ្មីលើក្បាលដី៖ កិច្ចសន្យាបង្កើតសិទ្ធិថ្មីលើក្បាលដី (ដាក់បន្ទុក ឬធានាសងបំណុល) មានកិច្ចសន្យាផលុបភោគ កិច្ចសន្យាបង្កើតសេវភាព កិច្ចសន្យាបង្កើតសិទ្ធិប្រើប្រាស់និងអាស្រ័យនៅ កិច្ចសន្យាហ៊ីប៉ូតែក កិច្ចសន្យានេះមិននាំឱ្យទៅដល់ការផ្ទេរសិទ្ធិឡើយ។

មន្ត្រីទទួលបន្ទុកបន្ទាប់ពីពិនិត្យឃើញថាឯកសារត្រឹមត្រូវ និងគ្រប់គ្រាន់ហើយ ត្រូវធ្វើលេខាចារឹកនៅក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ ឬសៀវភៅគោលបញ្ជីដី និងចុះចរន្តការក្នុងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ តាមរូបមន្តកំណត់។

+ការចុះបញ្ជីដីបន្តទាក់ទងនឹងការប្រែប្រួលលក្ខណរូបនៃក្បាលដី៖ ការប្រែប្រួលលក្ខណរូបនៃក្បាលដីអាចកើតឡើងដោយការព្រមព្រៀងខាងឆន្ទៈ ឬដោយសេចក្ដីសម្រេចរបស់តុលាការ ឬដោយធម្មជាតិ។

មន្ត្រីទទួលបន្ទុកអនុវត្តត្រូវយកចិត្តទុកដាក់ និងទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងការវាស់វែង និងការកសាងឯកសារ (សលាកប័ត្របំបែកក្បាលដី សលាកប័ត្របង្រួមក្បាលដី)។ លើ

ការងារវាស់វែង ត្រូវយកចិត្តទុកដាក់លើភាពទៀងទាត់ និងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដូចជាការកំណត់ចំណីផ្លូវ ការបម្រុងទុក ការហាមឃាត់ជាដើម។ លើការងារកសាងឯកសារ ត្រូវប្រុងប្រយ័ត្នអំពីអត្តសញ្ញាណម្ចាស់ក្បាលដីជាប់ព្រំដែលត្រូវផ្ទិតមេដៃឯកភាពអំពីព្រំដីលើឯកសារ។

បន្ទាប់ពីពិនិត្យឃើញថាឯកសារត្រឹមត្រូវ និងគ្រប់គ្រាន់ហើយ មន្ត្រីទទួលបន្ទុកត្រូវធ្វើលេខាចារឹកក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ ឬសៀវភៅគោលបញ្ជីដី និងក្នុងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ។ ដោយឡែក ចំពោះវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដែលបានចេញក្នុងតំបន់ធ្វើការវិនិច្ឆ័យ ត្រូវប្រមូលវិញ្ញាបនបត្រចាស់ រួចចេញវិញ្ញាបនបត្រថ្មីជូនម្ចាស់កម្មសិទ្ធិនៃក្បាលដីដែលត្រូវបានបំបែក ឬបង្រួមវិញ។

**II-អំពីការកាន់កាប់ឯកសារសុរិយោដី**

ឯកសារសុរិយោដីរួមមាន ប្លង់សុរិយោដី (Cadastral Index Map) ផែនទីមានលក្ខណៈដាច់ដោយដុំ (Sporadic Index Map) សៀវភៅគោលបញ្ជីដី សៀវភៅចុះបញ្ជីអចលនវត្ថុ និងឯកសាររណប។

១-ប្លង់សុរិយោដីគឺជាប្លង់រួមនៃក្បាលដីទាំងឡាយក្នុងតំបន់ធ្វើការវិនិច្ឆ័យដែលបង្ហាញអំពីស្ថានភាពឋានលេខា (Situation topographique) នៃក្បាលដី៖ រូបសណ្ឋានដី ទីតាំងដី ព្រំប្រទល់ដី ប្រភេទដី និងអ្វីៗដែលមាននៅលើដី ដូចជាសំណង់ ផ្លូវ អណ្តូងទឹក . . .។ ក្នុងប្រព័ន្ធសុរិយោដីទំនើប (Cadastre informatisé) ប្លង់សុរិយោដីបង្ហាញតាំងពីអ្វីនៅក្រោមដីទៀត ដូចជាប្រព័ន្ធលូ ប្រព័ន្ធខ្សែភ្លើង បណ្តាញឧស្ម័ន បណ្តាញទូរគមនាគមន៍ . . .។ ប្លង់សុរិយោដីគ្របដណ្តប់តំបន់ដែលបានធ្វើការវិនិច្ឆ័យដោយមានកំណត់ព្រំប្រទល់កម្មសិទ្ធិសាធារណៈ ឬ/និងកម្មសិទ្ធិឯកជនទាំងអស់ ហើយមានបញ្ជាក់អំពីប្រភេទដី ដូចជាដីដាំដុះ ដីព្រៃ ដីលិចទឹក ដីសម្រាប់សំណង់ឧស្សាហកម្មជាដើម។ ការកសាងប្លង់សុរិយោដីត្រូវអនុវត្តតាមនីតិវិធីដែលត្រូវចែងក្នុងអនុក្រឹត្យលេខ៤៦ អនក្រ/បក ចុះថ្ងៃទី៣១ ឧសភា ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដី។

ក-ការប្រែប្រួលដោយការបំបែកក្បាលដី៖ បន្ទាប់ពីឯកសារនៃការបំបែកក្បាលដីត្រូវបានសម្រេចហើយ លេខក្បាលដីដើមក្នុងប្លង់សុរិយោដីត្រូវឆូតលុប ហើយដាក់លេខថ្មី។ លេខថ្មីគឺជាលេខបន្តពីលេខចុងក្រោយបង្អស់នៃក្បាលដីក្នុងភូមិនីមួយៗ។

ខ-ការប្រែប្រួលដោយការបង្រួមក្បាលដី៖ ដូចគ្នានឹងចំណុច(ក) ដែរ បន្ទាប់ពីឯកសារនៃការបង្រួមក្បាលដីត្រូវបានសម្រេចហើយ លេខក្បាលដីទាំងឡាយដែលត្រូវបានបង្រួមត្រូវឆូតលុប ហើយជំនួសវិញដោយលេខថ្មីដែលជាលេខចុងក្រោយបង្អស់នៃក្បាលដីក្នុងភូមិ។

លេខក្បាលដីទាក់ទងគ្នានឹងទំហំដី មានន័យថា បើប្រែប្រួលទំហំគឺមិនមែនក្បាលដីលេខហ្នឹងទេ នោះគឺក្បាលដីថ្មី ដូច្នេះ ត្រូវឆូតលុបលេខក្បាលដីចាស់ ហើយដាក់លេខថ្មីជំនួសវិញដូចករណីបំបែក ឬបង្រួមក្បាលដី។

២-ផែនទីមានលក្ខណៈដាច់ដោយដុំ៖ គឺជាប្លង់សុរិយោដីដែលកសាងឡើងតាមនីតិវិធីនៃការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ អនុលោមតាមអនុក្រឹត្យលេខ៤៨អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២។ មន្ត្រីទទួលបន្ទុកត្រូវធ្វើចរន្តការនូវរាល់ក្បាលដីស្នើសុំចុះបញ្ជីដែលបានបិទផ្សាយរួច និងគ្មានការជំទាស់តវ៉ា ឬបន្ទាប់ពីបានសម្រុះសម្រួលដោះស្រាយរួច ឬបានដោះស្រាយរួចដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ។ ការកសាងផែនទីមានលក្ខណៈដាច់ដោយដុំ និងការធ្វើចរន្តការលើផែនទីនេះត្រូវបញ្ជាក់ឱ្យច្បាស់នូវសញ្ញាសម្គាល់ចំពោះក្បាលដី (គំរូលេខ៣)។

ក្នុងការធ្វើចរន្តការលើផែនទីមានលក្ខណៈដាច់ដោយដុំ មន្ត្រីទទួលបន្ទុកត្រូវគោរពតាមស្តង់ដារបច្ចេកទេស អំពីមាត្រដ្ឋាន និងភាពទៀងទាត់។

៣-សៀវភៅគោលបញ្ជីដី៖ សៀវភៅគោលបញ្ជីដីគឺជាសៀវភៅផ្លូវការមានតម្លៃពេញលេញតាមផ្លូវច្បាប់ ប្រើសម្រាប់កត់ត្រានូវសិទ្ធិកម្មសិទ្ធិ និងរាល់ព័ត៌មានទាក់ទងនឹងអត្តសញ្ញាណក្បាលដីនីមួយៗ (លេខក្បាលដី, ទីតាំងដី, រូបសណ្ឋាន និងលក្ខណៈប្រើប្រាស់ដី . . .) អត្តសញ្ញាណម្ចាស់ (ឈ្មោះ, ឆ្នាំ និងទីកន្លែងកំណើត, សាវតារ, អាសយដ្ឋាន . . . ) ប្រភេទទ្រព្យ ប្រភព និងបន្ទុកលើក្បាលដី។

អាស្រ័យដោយបច្ចុប្បន្ន នៅប្រទេសកម្ពុជាយើងមិនទាន់មានបណ្តាញកុំព្យូទ័រ (Computer Network) ភ្ជាប់ដល់មូលដ្ឋាន ការធ្វើលេខាចារឹក និងការចុះចរន្តការក្នុងសៀវភៅគោលបញ្ជីដី ក៏ដូចជាលើប្លង់សុរិយោដី ធ្វើឡើងតាមវិធីកត់ត្រាដោយដៃ។ ការធ្វើលេខាចារឹក និងការចុះចរន្តការនេះ ត្រូវធ្វើឡើងឱ្យស្របគ្នានៅគ្រប់ថ្នាក់ ក្រោមការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំនៃថ្នាក់នីមួយៗ។

មានតែមន្ត្រីទទួលបន្ទុកការងារអភិរក្សប៉ុណ្ណោះដែលមានសមត្ថកិច្ចកាន់កាប់ ធ្វើលេខាចារឹក និងចុះចរន្តការក្នុងសៀវភៅគោលបញ្ជីដី លើផែនទីមានលក្ខណៈដាច់ដោយដុំ និងលើប្លង់

សុរិយោដី។ ការសាកសួរព័ត៌មាន ការពិនិត្យមើលទិន្នន័យក្នុងសៀវភៅគោលបញ្ជីដី ត្រូវធ្វើឡើងក្រោមការទទួលខុសត្រូវរបស់មន្ត្រីទទួលបន្ទុក នៅក្នុងការិយាល័យមិនអនុញ្ញាតឱ្យយកសៀវភៅគោលបញ្ជីដីចេញពីការិយាល័យ ដោយគ្មានការយល់ព្រមពីថ្នាក់ដឹកនាំបានឡើយ។

ដោយឡែក ចំពោះប្រព័ន្ធព័ត៌មានដីធ្លី (LIS) នៅថ្នាក់កណ្តាល និងនៅថ្នាក់ខេត្ត-ក្រុង ដែលបានទទួលប្រតិភូកម្មពីក្រសួងដែលរួមមានប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីត្រូវធ្វើឱ្យទាន់សម័យ (Update) ក្នុងកុំព្យូទ័រនូវទិន្នន័យពីការប្រែប្រួល ផ្លាស់ប្តូរ បន្ទាប់ពីបានទទួលតារាងផ្លាស់ប្តូរ។ ការធ្វើឱ្យទាន់សម័យ (Update) ក្នុងកុំព្យូទ័រ ក៏ត្រូវឱ្យបានស្របគ្នាដែររវាងថ្នាក់កណ្តាល និងថ្នាក់ខេត្ត-ក្រុង ដោយត្រូវផ្តល់ព័ត៌មានពីការប្រែប្រួលទិន្នន័យទៅវិញទៅមកក្រោមការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំនៃថ្នាក់នីមួយៗ។

របៀបរបបនៃការធ្វើឱ្យទាន់សម័យ (Update) នៃទិន្នន័យក្នុងកុំព្យូទ័រត្រូវធ្វើឡើងនៅពេលដែលពិនិត្យឃើញថាឯកសាររណបត្រឹមត្រូវ និងគ្រប់គ្រាន់ហើយ រួចបោះពុម្ព (Print) សម្រង់ ទើបចុះចរន្តការដោយដៃក្នុងសៀវភៅគោលបញ្ជីដី និងប័ណ្ណ។

៤-សៀវភៅចុះបញ្ជីអចលនវត្ថុ៖ សៀវភៅចុះបញ្ជីអចលនវត្ថុគឺជាសៀវភៅផ្លូវការមានតម្លៃពេញលេញតាមផ្លូវច្បាប់ ប្រើសម្រាប់កត់ត្រានូវសិទ្ធិភោគៈ និងរាល់ព័ត៌មានទាក់ទងនឹងអត្តសញ្ញាណក្បាលដីនីមួយៗ (លេខក្បាលដី, ទីតាំងដី, រូបភាព និងលក្ខណៈប្រើប្រាស់ដី . . .) អត្តសញ្ញាណម្ចាស់ (ឈ្មោះ, ឆ្នាំ និងទីកន្លែងកំណើត, សាវតារ, អាសយដ្ឋាន . . .) ប្រភេទទ្រព្យប្រភព និងបន្ទុកលើក្បាលដីដូចសៀវភៅគោលបញ្ជីដីដែរ។

រាល់ការផ្លាស់ប្តូរសិទ្ធិពីភោគៈក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ មកកម្មសិទ្ធិដោយល័ក្ខខ័ណ្ឌរយៈពេលកាន់កាប់៥ឆ្នាំ ត្រូវបានធ្វើការវិនិច្ឆ័យ និងបិទផ្សាយជាសាធារណៈរួច អនុលោមតាមអនុក្រឹត្យលេខ៤៦អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ក្បាលដីភោគៈនោះនឹងត្រូវផ្ទេរមកកត់ត្រាចូលក្នុងសៀវភៅគោលបញ្ជីដីវិញ។

ម្យ៉ាងទៀត ប្រធាននាយកដ្ឋានអភិរក្សសុរិយោដី ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង ត្រូវសហការជម្រះបញ្ជីក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុក្នុងតំបន់ដែលបានចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធរួច ដោយត្រូវ៖

+បើការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធបានធ្វើរួចទាំងឃុំ មានន័យថាក្បាលដីទាំងអស់ក្នុងគ្រប់ភូមិនៃឃុំត្រូវបានចុះបញ្ជីហើយ ត្រូវធ្វើការផ្ទៀងផ្ទាត់ ធ្វើអត្តសញ្ញាណក្បាលដី ឈ្មោះ

ម្ចាស់ដី លេខប័ណ្ណ ក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ និងធ្វើការកត់ត្រាបញ្ជូនទៅលេខសៀវភៅគោលបញ្ជីដី និងលេខក្បាលដី។ ចំពោះសៀវភៅគោលបញ្ជីដី ក៏ត្រូវកត់ត្រាលេខក្បាលដី (លេខអាទិសង្កេត) ដែលក្បាលដីនោះត្រូវបានប្រើលេខថ្មីតាមប្រព័ន្ធ UPRN។ ករណីនេះ សៀវភៅចុះបញ្ជីអចលនវត្ថុត្រូវបានបញ្ឈប់ដោយទិន្នន័យទាំងអស់ក្នុងសៀវភៅនេះ ត្រូវបានផ្ទេរទៅសៀវភៅគោលបញ្ជីដីវិញ។

+បើការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ មិនទាន់បានធ្វើរួចទាំងឃុំ មានន័យថា ក្បាលដីមួយចំនួនក្នុងភូមិនៃឃុំមិនទាន់ត្រូវបានចុះបញ្ជី នោះសៀវភៅចុះបញ្ជីអចលនវត្ថុត្រូវបានបន្តប្រើចំពោះតែភូមិណាដែលក្បាលដីមិនទាន់បានចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ។

៥-ឯកសារវណប

ក-លិខិតសញ្ញាទាក់ទងនឹងការផ្ទេរសិទ្ធិដែលរួមមានកិច្ចសន្យាលក់ កិច្ចសន្យាដូរ កិច្ចសន្យាឱ្យ ត្រូវធ្វើឡើងតាមរូបមន្តនៃលិខិតយថាភូត និងត្រូវបង់ពន្ធប្រថាប់ត្រាពីការផ្ទេរ។ លិខិតសញ្ញាទាំងនេះជាលិខិតផ្លូវការ មានតម្លៃពេញលេញតាមផ្លូវច្បាប់ដែលត្រូវតម្កល់ទុកយ៉ាងប្រុងប្រយ័ត្ន មានរបៀប និងសុវត្ថិភាពជាទីបំផុត។

ខ-សេចក្តីសម្រេចរបស់តុលាការដែលរួមមានសាលក្រម និងសាលដីកា ត្រូវតែជាច្បាប់ដើម ឬជាច្បាប់ចម្លងដោយធ្វើនីត្យានុកូលកម្ម (Légaliser)។

គ-លិខិតបញ្ជាក់

+អំពីប្រភេទទ្រព្យ៖ លិខិតបញ្ជាក់អំពីប្រភេទទ្រព្យជាលិខិតដែលប្រកាសដោយម្ចាស់ទ្រព្យ មានសាក្សីដឹងឮ និងបញ្ជាក់ដោយមេឃុំ ចៅសង្កាត់។ ក្នុងករណីម្ចាស់ទ្រព្យមានប្តី ឬប្រពន្ធដើម្បីក្លាយជាទ្រព្យផ្ទាល់ខ្លួន (PM ឬ PF) ចាំបាច់ត្រូវមានការទទួលស្គាល់ ឬយល់ព្រមពីសហព័ទ្ធម្ខាងទៀត។ ទ្រព្យផ្ទាល់ខ្លួនគឺជាទ្រព្យដែលសហព័ទ្ធទទួលបាន ឬមានមុនរៀបអាពាហ៍ពិពាហ៍តាមរយៈអំណោយ មតិក ឬអច្ច័យទានជាដើម។

+អំពីស្ថានភាពស៊ីវិល៖ លិខិតបញ្ជាក់អំពីស្ថានភាពស៊ីវិលគឺជាលិខិតចេញដោយមេឃុំចៅសង្កាត់ បញ្ជាក់អំពីភាពលីវ មេម៉ាយ ពោះម៉ាយ ឬមរណភាពរបស់ម្ចាស់ទ្រព្យ។ ដោយបច្ចុប្បន្នយើងមិនទាន់កសាងសៀវភៅអត្រានុកូលដ្ឋានបានចប់សព្វគ្រប់ លិខិតបញ្ជាក់អំពីស្ថានភាពស៊ីវិលរបស់ម្ចាស់ទ្រព្យគឺជាឯកសារសំខាន់ក្នុងការងារចុះបញ្ជីដីធ្លី ពិសេសទាក់ទងនឹងការកំណត់ប្រភេទ

ទ្រព្យ ដូចជាទ្រព្យលីវ ទ្រព្យផ្ទាល់ខ្លួនខាងប្រពន្ធ ទ្រព្យផ្ទាល់ខ្លួនខាងប្ដី ទ្រព្យរួមប្ដីប្រពន្ធ សហកម្មសិទ្ធិ . . . និងទាក់ទងនឹងទំនាក់ទំនងញាតិក្នុងការជម្រះមតិក ។

+លិខិតផ្សេងៗទៀត៖ មានលិខិតរណបផ្សេងៗទៀតដែលជាប្រភេទលិខិតបញ្ជាក់ដែរ ដូចជាលិខិតបញ្ជាក់អំពីអាសយដ្ឋាន ឬទីលំនៅ លិខិតបញ្ជាក់អំពីកាលបរិច្ឆេទនៃការកាន់កាប់ដី លិខិតស្នើកែតម្រូវ លិខិតបញ្ជាក់អះអាងផ្សេងៗ . . . ។

ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីត្រូវទទួលខុសត្រូវក្នុងការកសាងឯកសារ ការត្រួតពិនិត្យសុពលភាព ភាពត្រឹមត្រូវ និងគ្រប់គ្រាន់នៃឯកសារ និងការកាន់កាប់ឯកសារសុរិយោដី ។ ឯកសារសុរិយោដីមិនត្រូវឱ្យមានការកោសលុប ឬសរសេរជ្រៀតបន្ថែម សរសេរត្រួត ឬគូសបន្ថែមបានឡើយ ។ ការកែតម្រូវក្នុងឯកសារសុរិយោដីដែលទាក់ទងនឹងកំហុសបច្ចេកទេសអាចប្រព្រឹត្តទៅបាន លុះត្រាតែមានឯកសារបញ្ជាក់ត្រឹមត្រូវ ។

ក្រសួងសង្ឃឹមយ៉ាងមុតមាំថា អស់លោក លោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុងទាំងអស់នឹងខិតខំអនុវត្តសារាចរណែនាំនេះមានប្រសិទ្ធភាព ។ នៅពេលដែលក្រសួងកំពុងរៀបចំពិនិត្យកែលំអឯកសារទាក់ទងនឹងវិធីដែលបានអនុវត្តកន្លងមកក្នុងប្រព័ន្ធចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ក្នុងការចុះបញ្ជីដីបន្តនេះ ។

សេចក្ដីណែនាំអនុវត្តនេះមានសុពលភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**អ៊ឹម ឈុនលឹម**

<u>កន្លែងទទួល</u>

-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី

-ទីស្ដីការគណៈរដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"

-គ្រប់អគ្គនាយកដ្ឋានក្រោមឱវាទក្រសួង

-គ្រប់មន្ទីរ ដ.ន.ស.ស ខេត្ត-ក្រុង

"ដើម្បីអនុវត្ត"

-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ០១ បប

បទបញ្ជា
ស្តីពីការទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការកាប់រាន ការដុត ការឈូសឆាយ
និងហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើ

ព្រៃឈើគឺជាសម្បត្តិធម្មជាតិ ដែលមានតម្លៃមិនអាចកាត់ថ្លៃបានចំពោះមនុស្សជាតិ និងសត្វនៅលើផែនដី។ ដោយមើលឃើញនូវសារៈសំខាន់របស់ព្រៃឈើ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការអភិរក្ស និងគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព សំដៅបម្រើឱ្យផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថានសម្រាប់មនុស្សជំនាន់បច្ចុប្បន្ន ក៏ដូចជាសម្រាប់អនាគតផងដែរ។

ផ្តើមចេញពីទស្សនៈវិស័យខាងលើ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវបទបញ្ជាលេខ០២ ចុះថ្ងៃទី៦ ខែមករា ឆ្នាំ១៩៩៩ សេចក្តីប្រកាសលេខ០១ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៩ និងសេចក្តីប្រកាសលេខ០៦ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៩៩ដើម្បីគ្រប់គ្រង និងលុបបំបាត់ភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើ និងការទន្ទ្រានកាន់កាប់ដីធ្លី និងបានអនុវត្តកំណែទម្រង់វិស័យព្រៃឈើដ៏ស៊ីជម្រៅមួយប្រកបដោយប្រសិទ្ធភាព និងទទួលបានជោគជ័យជាបន្តបន្ទាប់ ព្រមទាំងទទួលបាននូវការវាយតម្លៃខ្ពស់ និងការគាំទ្រយ៉ាងខ្លាំងក្លាពីសំណាក់មតិជាតិ និងអន្តរជាតិ។ ប៉ុន្តែទន្ទឹមនឹងនេះ សកម្មភាពកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើ ចម្ការព្រៃដាំ និងតំបន់ការពារធម្មជាតិធ្វើជាកម្មសិទ្ធិ ដែលធ្លាប់កើតមានឡើងកន្លងមកនេះ កាន់តែមានសភាពកើនឡើងជាបន្តបន្ទាប់ស្ទើរនៅគ្រប់ខេត្ត-ក្រុង។ ទង្វើនេះជាឧក្រិដ្ឋកម្មបានប្រព្រឹត្តផ្ទុយនឹងច្បាប់ស្តីពីព្រៃឈើ និងលិខិតបទដ្ឋានច្បាប់ផ្សេងៗទៀត ដែលជាសកម្មភាពអាចនាំទៅរកគ្រោះមហន្តរាយ វិនាសកម្មព្រៃឈើ និងបាត់បង់សម្បត្តិព្រៃឈើរបស់រដ្ឋ ព្រមទាំងអាចធ្វើឱ្យបរាជ័យនូវគោលដៅគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ប្រសិន

បើរិធានការទប់ស្កាត់ និងបង្ក្រាបពុំត្រូវបានអនុវត្តឱ្យបានម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពទាន់ពេលវេលានោះទេ។

ចំពោះមុខ ដើម្បីទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការកាប់រាន ការដុត ការឈូសឆាយ និងការហ៊ុមព័ទ្ធកាន់កាប់ដីព្រៃ រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវបទបញ្ជាបន្ទាន់ដូចខាងក្រោម៖

១-លុបចោលរាល់លិខិតកាន់កាប់ដីធ្លី និងប័ណ្ណសម្គាល់សិទ្ធិដីទាំងឡាយណាដែលបានមកពីការកាប់រានដីព្រៃឈើ ចម្ការព្រៃដាំកន្លងមក ក៏ដូចជាពេលបច្ចុប្បន្ន ស្របតាមច្បាប់ស្តីពីព្រៃឈើ និងច្បាប់ភូមិបាល។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវធ្វើការណែនាំដល់អង្គភាពក្រោមឱវាទ ឱ្យបញ្ឈប់ជាបន្ទាន់នូវរាល់ការចេញលិខិតកាន់កាប់ ឬប័ណ្ណសម្គាល់សិទ្ធិដីធ្លីដែលមានប្រភពពីការកាប់រានដីព្រៃឈើ និងព្រៃដាំរបស់រដ្ឋ។ រាល់ការចេញលិខិត ឬសម្គាល់សិទ្ធិដីធ្លីដែលពាក់ព័ន្ធនឹងដែនព្រៃឈើ ត្រូវមានមតិឯកភាពពីសមត្ថកិច្ចរដ្ឋបាលព្រៃឈើនៅមូលដ្ឋាននោះ។

២-ក្រសួងការពារជាតិ និងអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ ត្រូវរៀបចំគម្រោងផែនការបោះទីតាំងមូលដ្ឋានទ័ពឱ្យមានលក្ខណៈអចិន្ត្រៃយ៍ ដោយចៀសវាងការប៉ះពាល់តំបន់ព្រៃឈើ។ ក្នុងករណីមានការប៉ះពាល់ដល់ដែនព្រៃឈើ ត្រូវធ្វើការពិគ្រោះយោបល់ និងមានការយល់ព្រមពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាមុន។

៣-ហាមដាច់ខាតការបោះដាក់តាំងលំនៅឋានថ្មីតាមផ្លូវសាធារណៈ ឬផ្លូវព្រៃ ក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ មុនពេលមានការយល់ព្រមពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមានការអនុញ្ញាតពីរាជរដ្ឋាភិបាល។ អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ត្រូវគ្រប់គ្រងឱ្យបានល្អនូវស្ថិតិប្រជាជនមូលដ្ឋាន និងត្រូវសហការជាមួយរដ្ឋបាលព្រៃឈើ ដើម្បីមានវិធានការទប់ស្កាត់ និងបង្ក្រាបឱ្យបានទាន់ពេលវេលាចំពោះប្រជាជនត្រាចចរដែលដើរកាប់រាន ដុត ឈូសឆាយ ហ៊ុមព័ទ្ធកាន់កាប់ដីព្រៃ និងសង់លំនៅឋានក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ក្រោមរូបភាពធ្វើចម្ការពនេចរ ឬក្រោមគោលបំណងផ្សេងទៀត។

៤-ការឈូសឆាយដីព្រៃក្នុងគោលបំណងស្ថាបនាផ្លូវសាធារណៈ ក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវមានការសម្រេចពីរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន

ឬស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត ដោយត្រូវមានការពិគ្រោះយោបល់ និងមានការយល់ព្រមពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៥-ការអនុវត្តចម្ការពនេចរ ត្រូវហាមឃាត់ចំពោះព្រៃស្រោង និងពាក់កណ្តាលស្រោងក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍។ ចម្ការពនេចរអាចអនុវត្តបានចំពោះតែប្រជាជន សហគមន៍ជនជាតិដើមភាគតិចតែប៉ុណ្ណោះ ដោយត្រូវមានការពិនិត្យ និងយល់ព្រមពីសមត្ថកិច្ចជំនាញនៅមូលដ្ឋាន។

៦-ការជីកយកថ្ម ដី ខ្សាច់ រ៉ែ និងធនធានធម្មជាតិដទៃទៀតក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវមានការវាយតម្លៃជាមុនពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមានការអនុញ្ញាតពីរាជរដ្ឋាភិបាល។

៧-គ្មានរូបវន្តបុគ្គល នីតិបុគ្គល សមាគម អង្គការ ឬអាជ្ញាធរណាមួយមានសិទ្ធិផ្តល់ការអនុញ្ញាត ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តីឱ្យកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធ កាន់កាប់ដីព្រៃឈើក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងចម្ការព្រៃជំរបស់រដ្ឋជាដាច់ខាត។

៨-ដីព្រៃឈើទាំងអស់ដែលបានដកហូតយកមកវិញ ស្របតាមច្បាប់ស្តីពីព្រៃឈើ ត្រូវទុកជាសម្បត្តិរដ្ឋបាលព្រៃឈើត្រូវធ្វើការដាំដុះដើមឈើ ដើម្បីបង្កើតជាព្រៃឈើឡើងវិញជាចាំបាច់។

៩-ការនាំចូលរណារយន្តកាត់ឈើ (Chainsaw = Tronçoneuse) គ្រប់ប្រភេទ អាចប្រព្រឹត្តទៅបានតែតាមរយៈរដ្ឋបាលព្រៃឈើប៉ុណ្ណោះ។ រដ្ឋបាលព្រៃឈើត្រូវធ្វើការចាប់ឃាត់ និងប្រមូលទុកនូវរាល់រណារយន្តកាត់ឈើ (Chainsaw = Tronçoneuse) គ្រប់ប្រភេទដែលគ្មានលិខិតអនុញ្ញាតឱ្យប្រើប្រាស់នៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលាដែលបានជួបប្រទះឃើញ។ រណារយន្តទាំងអស់ដែលប្រមូលបានត្រូវរៀបចំធ្វើពិធីកម្ទេចចោលដូចករណីកម្ទេចឧបករណ៍នេសាទខុសច្បាប់ដែរ។

១០-រាល់ការចេញលិខិត ឬប័ណ្ណសម្គាល់សិទ្ធិដីធ្លី ការកាប់រាន ការដុត ការឈូសឆាយ និងការហ៊ុមព័ទ្ធកាន់កាប់ដីព្រៃ ការបោះទីតាំងមូលដ្ឋានទ័ព ការឈូសឆាយដីព្រៃ ក្នុងគោលបំណងស្ថាបនាផ្លូវសាធារណៈ ការតាំងលំនៅឋានថ្មីតាមផ្លូវសាធារណៈ ការធ្វើចម្ការពនេចរ ការជីកថ្ម ខ្សាច់ រ៉ែ និងធនធានធម្មជាតិដែលពាក់ព័ន្ធនឹងតំបន់ការពារធម្មជាតិត្រូវធ្វើការពិគ្រោះយោបល់ និងមានការយល់ព្រមពីក្រសួងបរិស្ថានជាមុន។

*វាយឡើងវិញ*

១១-អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ កងរាជអាវុធហត្ថ និងអាជ្ញាធរពាក់ព័ន្ធដទៃទៀតត្រូវបង្កភាពងាយស្រួល និងផ្តល់កម្លាំងចូលរួមសហការជាមួយសមត្ថកិច្ចរដ្ឋបាលព្រៃឈើមូលដ្ឋាន តាមការស្នើសុំដើម្បីចាត់វិធានការទប់ស្កាត់ និងបង្ក្រាបការកាប់រាន ការដុត ការឈូសឆាយ និងការហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើគ្រប់ប្រភេទ។

១២-ជនណាដែលមិនបានអនុវត្តតាមបទបញ្ជានេះ ត្រូវទទួលទោសទណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីព្រៃឈើ និងច្បាប់ជាធរមានផ្សេងៗទៀត។

ទទួលបានបទបញ្ជានេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលព្រៃឈើ អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ អគ្គស្នងការដ្ឋាននគរបាលជាតិ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងអនុវត្តបទបញ្ជាខាងលើនេះឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៤

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**លេខ៦២១ដនស/សជ**

ភ្នំពេញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៤

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជម្រាបមក**

**លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីគ្រប់ខេត្ត-ក្រុង**

កម្មវត្ថុ៖ ការបញ្ឈប់ចេញបង្កាន់ដៃទទួលពាក្យស្នើសុំកាន់កាប់ដីធ្លី

យោង៖ -ប្រកាសលេខ០៦ប្រក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាល

-សារាចរណែនាំលេខ០១ដនស/សជក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៤ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១បប ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៤

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ក្រសួងបានពិនិត្យឃើញថា កន្លងមកស្ទើរតែគ្រប់ខេត្ត-ក្រុងទាំងអស់មានជនល្មើសមួយចំនួនបានចូលទៅរំលោភបំពាន កាប់ រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធកាន់កាប់ដីព្រៃសាធារណៈ ដើម្បីបែងចែកគ្នាយកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។ ទង្វើទាំងអស់នេះ ទោះបីមានការហាមប្រាមច្បាស់លាស់ក្នុងច្បាប់ភូមិបាលក្តី និងលិខិតណែនាំជាបន្តបន្ទាប់ក្តី ក៏នៅតែមានបាតុភាពខុសឆ្គងកើតមានឡើងឥតឈប់ឈរ បង្កនូវភាពអនាធិបតេយ្យ និងបង្កើតនូវឧបសគ្គដ៏ធ្ងន់ធ្ងរ រាំងស្ទះដល់ផែនការអភិវឌ្ឍន៍ប្រទេសជាតិនាពេលបច្ចុប្បន្ន និងទៅអនាគត។

ដើម្បីចៀសវាងនូវរាលបាតុភាពខុសឆ្គងខាងលើនេះ មន្ត្រីជំនាញនៅគ្រប់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីត្រូវបញ្ឈប់ជាបន្ទាន់នូវការចេញបង្កាន់ដៃទទួលពាក្យស្នើសុំកាន់កាប់ដីតាមគ្រប់រូបភាព និងខិតខំផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់គ្រប់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល និងមន្ត្រីក្រោមឱវាទទាំងអស់ឱ្យអនុវត្តតាមខ្លឹមសារនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

<u>ចម្លងជូន</u>
-គ្រប់អភិបាលខេត្ត-ក្រុង
-គ្រប់អគ្គនាយកដ្ឋានក្រោមឱវាទក្រសួងដនស
-ឯកសារ-កាលប្បវត្តិ

**រដ្ឋមន្ត្រី**
**ហត្ថលេខា និងត្រា**
**អ៊ឹម ឈុនលឹម**

*វាយឡើងវិញ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**លេខ៦២៣ដនស/សជ**

ភ្នំពេញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៤

## សេចក្តីណែនាំអនុវត្តបទបញ្ជាស្តីពីការទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើ

ដោយអនុលោមតាមបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១បប ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៤ ស្តីពីការទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការកាប់រាន ការដុត ការឈូសឆាយ និងការហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមធ្វើការណែនាំដល់អស់លោក លោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីគ្រប់ខេត្ត-ក្រុងដូចតទៅ៖

១-បញ្ឈប់ជាបន្ទាន់នូវរាល់ការចេញលិខិតកាន់កាប់ដីធ្លី ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លីដែលមានប្រភពពីការកាប់រានដីព្រៃឈើ និងព្រៃដាំរបស់រដ្ឋ។ រាល់ការចេញលិខិត ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លីដែលពាក់ព័ន្ធនឹងដែនព្រៃឈើ ត្រូវមានមតិឯកភាពពីសមត្ថកិច្ចរដ្ឋបាលព្រៃឈើនៅមូលដ្ឋាននោះ។

២-រាល់ការចេញលិខិត ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លីដែលពាក់ព័ន្ធនឹងតំបន់ការពារធម្មជាតិ ត្រូវធ្វើការពិគ្រោះយោបល់ និងមានការយល់ព្រមពីក្រសួងបរិស្ថានជាមុន។

ក្រោយពេលទទួលបានសេចក្តីណែនាំនេះ គ្រប់ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីគ្រប់ខេត្ត-ក្រុង ត្រូវខិតខំអនុវត្ត ព្រមទាំងផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវវិធានការខាងលើនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

**រដ្ឋមន្ត្រី**
**ហត្ថលេខា និងត្រា**
**អ៊ឹម ឈុនលឹម**

<u>ចម្លងជូន</u>
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន
-គ្រប់សាលាខេត្ត-ក្រុង
-គ្រប់អគ្គនាយកដ្ឋានក្រោមឱវាទក្រសួងដនស
"ដើម្បីសហការអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**លេខ៣១៥សហវ/ប្រក** រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៤

## ប្រកាសស្តីពីវិធានការប្រមូលបំណុល
## ចំណូលថ្លៃឈ្នួលរោងចក្រ សហគ្រាស និងអចលនវត្ថុរបស់រដ្ឋ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ០១នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣
- យោងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ៣០បប ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- យោងសេចក្តីជូនដំណឹងស្តីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៩៩
- យោងកិច្ចសន្យាជួលរោងចក្រ សហគ្រាស និងអចលនវត្ថុ រវាងក្រសួង ស្ថាប័ន និងខេត្តក្រុងជាមួយនឹងរូបវន្តបុគ្គល ឬនីតិបុគ្គលឯកជន
- យោងតាមតម្រូវការចាំបាច់

**សម្រេច**

**ប្រការ១**

ក្រសួង ស្ថាប័ន និងខេត្ត-ក្រុង (ភាគី "ក" នៃកិច្ចសន្យាជួលរោងចក្រ សហគ្រាស និងអចលនវត្ថុ) ជាអ្នកជំរុញ និងប្រមូលបំណុល ចំណូលថ្លៃឈ្នួល រោងចក្រ សហគ្រាស និងអចលនវត្ថុដែលបានជួលឱ្យរូបវន្តបុគ្គល ឬនីតិបុគ្គលឯកជនដែលជាភាគី "ខ" នៃកិច្ចសន្យា។

**ប្រការ២**

ក្រសួង ស្ថាប័ន និងខេត្ត-ក្រុងទាំងអស់ត្រូវចាត់ចែងឱ្យអ្នកជួលរោងចក្រ សហគ្រាស និងអចលនវត្ថុអនុវត្តការបង់ប្រាក់ថ្លៃឈ្នួលជូនរដ្ឋដូចតទៅ៖

-ត្រូវបង់ត្រង់ទៅថវិការដ្ឋតែម្តងចូលគណនីលេខ ០២-៣៥.១២១១-T០២៣ នៅធនាគារជាតិនៃកម្ពុជាចំពោះរាល់រោងចក្រ សហគ្រាស និងអចលនវត្ថុដែលមានទីតាំងនៅរាជធានីភ្នំពេញ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាត្រូវផ្ញើប្រកាសឥណទាន ឬបង្កាន់ដៃបង់ប្រាក់ចំនួនបីច្បាប់ដែលក្នុងនោះមួយច្បាប់ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ) និងមួយច្បាប់ផ្ញើជូនសាមីក្រសួង ឬស្ថាប័នដែលជាភាគី "ក" នៃកិច្ចសន្យា (នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ) ហើយមួយច្បាប់ទៀតផ្តល់ជូនរូបវន្តបុគ្គលដែលបានបង់ប្រាក់ថ្លៃឈ្នួលរោងចក្រ សហគ្រាស ឬ អចលនវត្ថុ។

-ត្រូវបង់ចូលគណនីថវិការដ្ឋនៅរតនាគារខេត្ត-ក្រុងតែម្តង ចំពោះរោងចក្រ សហគ្រាស ឬអចលនវត្ថុដែលមានទីតាំងនៅតាមខេត្ត-ក្រុងដទៃទៀតក្រៅពីរាជធានីភ្នំពេញ។ រតនាគារខេត្តក្រុងត្រូវផ្ញើសលាកប័ត្របង់ប្រាក់ចូលថវិញការដ្ឋចំនួនបីច្បាប់ ក្នុងនោះមួយច្បាប់ផ្ញើជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មួយច្បាប់ផ្ញើជូនមន្ទីរ ឬអង្គភាពជំនាញរបស់ក្រសួង ឬស្ថាប័ន និងមួយច្បាប់ទៀតផ្តល់ជូនរូបវន្តបុគ្គល ឬនីតិបុគ្គលឯកជនដែលបានបង់ប្រាក់ថ្ងៃឈ្នួលរោងចក្រ ឬអចលនវត្ថុ។

**ប្រការ៣**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ" ជាអ្នកតាមដាន និងកត់ត្រានូវបំណុល ចំណូលថ្លៃឈ្នួល ព្រមទាំងមានវិធានការលើការជំរុញ និងប្រមូលបំណុលចំណូលថ្លៃឈ្នួលខាងលើនេះ រួមទាំងធ្វើការណែនាំទៅគ្រប់ក្រសួង ស្ថាប័ន និងខេត្ត-ក្រុងឱ្យអនុវត្តតាមកិច្ចសន្យាដែលនៅមានជាធរមាន។

-អនុលោមមាត្រា៩ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសឱ្យប្រើដោះព្រះរាជក្រមលេខ០១នស៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ មាត្រាទី១២នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៩ និងមាត្រាទី៧ និងទី១១ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០០០ ប្រសិនបើក្នុងរយៈពេល៣០ថ្ងៃ ចាប់ពីថ្ងៃដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុណែនាំដល់ក្រសួង ស្ថាប័ន

និងខេត្ត-ក្រុងដែលជាភាគី "ក" នៃកិច្ចសន្យាឱ្យមានវិធានការលុបកិច្ចសន្យា ប៉ុន្តែនៅតែមិនព្រមមានវិធានការនោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងបន្តលើកករណីនោះគោរពជូនសម្តេចនាយករដ្ឋមន្ត្រីដើម្បីចាត់វិធានការជាចុងក្រោយ ។

**ប្រការ៤**

រាល់ការស្នើសុំជួល សុំបញ្ចុះថ្លៃឈ្នួល ពន្យាររយៈពេលកិច្ចសន្យាជួល និងសុំរួចថ្លៃឈ្នួលក្នុងរយៈពេលរុះរើ ជួសជុល និងសាងសង់លើទីតាំងដែលបានជួលពីរដ្ឋ ត្រូវតែអនុវត្តតាមនីតិវិធីនៃបទបញ្ញត្តិស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងបទប្បញ្ញត្តិ និងនីតិវិធីជាធរមាន ។

**ប្រការ៥**

គ្រប់ក្រសួង ស្ថាប័ន និងខេត្ត-ក្រុងដែលមានជួលរោងចក្រ សហគ្រាស ឬអចលនវត្ថុ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវសហការអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ៦**

រាល់ប្រកាសរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនិងអន្តរក្រសួង ស្ថាប័នស្តីពីវិធានការប្រមូលចំណូលថ្លៃឈ្នួលអចលនវត្ថុដែលមានន័យផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៧**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តជាគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ហត្ថលេខា និងត្រា**

**គាត ឈន់**

ចម្លងជូន

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ធនាគារជាតិនៃកម្ពុជា
-ក្រសួង ស្ថាប័នពាក់ព័ន្ធ "ដូចប្រការ៥"
-សាលាខេត្ត-ក្រុង "ដូចប្រការ៥"
-មន្ទីរ អង្គភាពពាក់ព័ន្ធ
-រតនាគារខេត្ត-ក្រុងពាក់ព័ន្ធ
-រូបវន្តបុគ្គល ឬនីតិបុគ្គលឯកជននៃកិច្ចសន្យា
-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ៦៨អនក្រ/បក

## អនុក្រឹត្យ
## ស្តីពីការកែសម្រួលមាត្រា៤នៃអនុក្រឹត្យលេខ៨៨អនក្រ/បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១០០/២១៣ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០០ ស្តីពីការបញ្ចូលសមាសភាពឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ៨៨អនក្រ/បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- តាមសំណើរបស់ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ

**សម្រេច**

មាត្រា១

មាត្រា៤នៃអនុក្រឹត្យលេខ៨៨អនក្រ/បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លីត្រូវបានកែប្រែដូចខាងក្រោម៖

មាត្រា៤ថ្មី

ក្រុមប្រឹក្សាគោលនយោបាយដីធ្លីមានសមាសភាពដូចតទៅ៖

-ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធាន
-អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ អនុប្រធាន
-រដ្ឋមន្ត្រីនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុប្រធាន
-រដ្ឋលេខាធិការនៃក្រសួងអភិវឌ្ឍន៍ជនបទ អនុប្រធាន
-រដ្ឋលេខាធិការនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិកអចិន្ត្រៃយ៍ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាគោលនយោបាយដីធ្លី
-រដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
-រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ សមាជិក
-រដ្ឋលេខាធិការនៃក្រសួងការពារជាតិ សមាជិក
-រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
-រដ្ឋលេខាធិការនៃក្រសួងពាណិជ្ជកម្ម សមាជិក
-រដ្ឋលេខាធិការនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក
-រដ្ឋលេខាធិការនៃក្រសួងផែនការ សមាជិក
-រដ្ឋលេខាធិការនៃក្រសួងបរិស្ថាន សមាជិក
-រដ្ឋលេខាធិការនៃក្រសួងធនធានទឹក និងឧតុនិយម សមាជិក
-រដ្ឋលេខាធិការនៃក្រសួងព័ត៌មាន សមាជិក
-រដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌ សមាជិក
-រដ្ឋលេខាធិការនៃក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក
-រដ្ឋលេខាធិការនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
-រដ្ឋលេខាធិការនៃក្រសួងទេសចរណ៍ សមាជិក
-រដ្ឋលេខាធិការនៃក្រសួងកិច្ចការនារី សមាជិក
-ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា សមាជិក
-តំណាងក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សមាជិក

វាយឡើងវិញ

-អគ្គលេខាធិការនៃគណៈកម្មការជាតិវិនិយោគកម្ពុជានៃ
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

**មាត្រា២**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៣**

រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងសមាជិកទាំងអស់នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដូចមានសមាសភាពចែងក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៤

**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា និងត្រា**
**ហ៊ុន សែន**

**បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី**
**ជ.ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ**
**អនុប្រធានអចិន្ត្រៃយ៍**
**ហត្ថលេខា**
**សុខ អាន**

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-គ្រប់ក្រសួង ស្ថាប័ន
-ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
-ដូចមាត្រា៣
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
**លេខ៣៨៦សហវ/ទវ** រាជធានីភ្នំពេញ ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៤

## ប្រកាសស្តីពីបែបបទនៃការដោះដូរអចលនទ្រព្យ
## របស់រដ្ឋនៅតាមបណ្តាក្រសួង ស្ថាប័ន និងខេត្ត-ក្រុង

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ០១នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣
- យោងអនុក្រឹត្យលេខ៣៨អនក្រ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៥ ស្តីពីបែបបទនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- យោងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ៣០បប ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- យោងសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ០៧សរណន ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៤ ស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៥
- យោងចំណារសម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៤
- យោងតាមតម្រូវការចាំបាច់

### សម្រេច

### ប្រការ១

រាល់ការដោះដូរអចលនទ្រព្យរបស់រដ្ឋ "ដីទំនេរ ដី និងអគាររបស់រដ្ឋ" ត្រូវអនុវត្តតាមដំណើរការឯកជនភាវូបនីយកម្មរបស់គណៈកម្មាធិការឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ ។

### ប្រការ២

រាល់ការដោះដូរអចលនទ្រព្យរបស់រដ្ឋ "ដីទំនេរ ដី និងអគាររបស់រដ្ឋ" ត្រូវអនុវត្តតាមនីតិវិធីដេញថ្លៃជាសាធារណៈ ដោយត្រូវដេញថ្លៃទាំងអចលនទ្រព្យរបស់រដ្ឋ និងសំណង់ថ្មីដែលជាថ្នូររបស់ឯកជន ។

*វាយឡើងវិញ*

**ប្រការ៣**

ចំណុចដែលបានមកពីការដេញថ្លៃលក់អចលនទ្រព្យរបស់រដ្ឋ ត្រូវតម្កល់នៅគណនីឯកជនភាវូបនីយកម្មសម្រាប់យកទៅទូទាត់ថ្លៃដែលត្រូវសាងសង់ដោយឯកជន ឬរួមទាំងថ្លៃទីតាំងដីថ្មីរបស់ឯកជន។

**ប្រការ៤**

ចំណូលដែលបានមកពីការលក់អចលនទ្រព្យរដ្ឋនេះ និងចំណាយទូទាត់ថ្លៃសំណង់ថ្មីដែលត្រូវផ្តល់ដោយឯកជន ឬរួមទាំងថ្លៃទីតាំងថ្មីរបស់ឯកជន ត្រូវឆ្លុះបញ្ចាំងក្នុងប្រតិបត្តិការចំណូលចំណាយថវិការដ្ឋ ស្របតាមបទប្បញ្ញត្តិ និងនីតិវិធីជាធរមាន។

**ប្រការ៥**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង អាចផ្ទេរកម្មសិទ្ធិកាន់កាប់អចលនវត្ថុ និងបន្ទាប់ពីភាគីឯកជនបានបង់ប្រាក់ថ្លៃទិញអចលនទ្រព្យបានគ្រប់ចំនួនតាមកំណត់ហេតុដេញថ្លៃ ចូលថវិការដ្ឋតាមគណនីលេខ 02-35-1211-T020 នៅធនាគារជាតិនៃកម្ពុជាព្រមទាំងភាគីឯកជនបានបំពេញកាតព្វកិច្ចដោះស្រាយរាល់បញ្ហាពាក់ព័ន្ធនឹងទីតាំងដែលដេញថ្លៃបាននោះរួចរាល់ជាស្ថាពរ។

**ប្រការ៦**

គ្រប់ក្រសួង ស្ថាប័ន និងខេត្ត-ក្រុង ព្រមទាំងនាយកដ្ឋានជំនាញ និងមន្ទីរជំនាញពាក់ព័ន្ធទាំងអស់ត្រូវសហការអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធខ្ពស់។

**ប្រការ៧**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តជាគតិយុត្តចាប់ពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៤តទៅ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ហត្ថលេខា និងត្រា**

**គាត ឈន់**

ចម្លងជូន

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចប្រការ៦

-ឯកសារ

*វាយឡើងវិញ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
លេខ៣៩៦សហវ/ប្រក

ប្រកាសអន្តរក្រសួង
ស្តីពីការកែសម្រួលប្រកាសអន្តរក្រសួងលេខ៣៧៧សហវ ចុះថ្ងៃទី២៨.០៥.២០០២
ស្តីពីការកំណត់ចំណូលពីសោហ៊ុយសេវាសុរិយោដី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ០៤អនក្រ/បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ៦២អនក្រ/បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- អនុវត្តតាមអនុក្រឹត្យលេខ៨១អនក្រ/បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័តរាជធានីភ្នំពេញ និងអង្គការសាធារណរដ្ឋបាល
- អនុវត្តតាមអនុក្រឹត្យលេខ៨២អនក្រ/បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- អនុវត្តតាមប្រកាសលេខ០០៤សហវ/មប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសអន្តរក្រសួងស្តីពីការកំណត់ចំណូលពីសោហ៊ុយសេវាសុរិយោដី លេខ ៣៧៧សហវ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០២
- បានឃើញលិខិតលេខ០៥៩សហវ/ទរ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញលិខិតលេខ២៩៨៣សហវ/ទរ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុវត្តតាមសារាចរណែនាំលេខ០០២សហវ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩៦ ស្តីពីរដ្ឋទេយ្យចំណូល
- តាមការចាំបាច់ក្នុងការអនុវត្តច្បាប់ភូមិបាល។

**សម្រេច**

**ប្រការតែមួយ**

ប្រការ២នៃប្រកាសអន្តរក្រសួងលេខ៣៧៧សហវ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០២ ស្តីពីការកំណត់ចំណូលសោហ៊ុយសេវាសុរិយោដី ត្រូវបានកែសម្រួលដូចខាងក្រោម៖

**ប្រការ២ថ្មី**

សោហ៊ុយសេវាសុរិយោដី ត្រូវបានកំណត់ដូចតទៅ៖

ក-សម្រាប់ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំគឺ៖

| ល.រ | បរិយាយ | សោហ៊ុយសេវាសុរិយោដី | | | | |
|---|---|---|---|---|---|---|
| | | ដីផលិតកម្ម ឬដីភោគៈ គ្រប់ខេត្ត-ក្រុង | ដីលំនៅឋាន និងដីសម្រាប់សំណង់ទូទៅ | | | |
| | | | ក្រុងភ្នំពេញ ក្រុងព្រះសីហនុ ខេត្តកណ្តាល និង ខេត្តសៀមរាប | | ក្រៅពីទីក្រុងភ្នំពេញ ក្រុងព្រះសីហនុ ខេត្តកណ្តាល និងខេត្តសៀមរាប | |
| | | | ជនបទ ឬ ក្រៅក្រុង | ទីក្រុង ឬ ទីរួមខេត្ត | ជនបទ ឬ ក្រៅក្រុង | ទីក្រុង ឬ ទីរួមខេត្ត |
| 1 | 2 | 3 | 4 | 5 | 6 | 7 |
| ១ | ការចេញប័ណ្ណ ឬ ប័ណ្ណទុតិយតា ឬ ប័ណ្ណតតិយតា "ក្នុង១ក្បាលដី" | ១០.០០០៛០០ | ៥០.០០០៛០០ | ៣៥០.០០០៛០០ | ៥០.០០០៛០០ | ២០០.០០០៛០០ |
| ២ | ការផ្ទេរអចលនវត្ថុ (ផ្ទេរដោយបំបែក ឬផ្ទេរទាំងមូល) "ក្នុង១ប័ណ្ណ" | ៥០.០០០៛០០ | ១០០.០០០៛០០ | ២០០.០០០៛០០ | ១០០.០០០៛០០ | ១២០.០០០៛០០ |
| ៣ | ការបង្រួមក្បាលដី "ក្នុង១ក្បាលដីដើម" | ១០០.០០០៛០០ | ១២០.០០០៛០០ | ១៥០.០០០៛០០ | ១២០.០០០៛០០ | ១៥០.០០០៛០០ |
| ៤ | ការបំបែកក្បាលដី ដោយមិនផ្ទេរ (ក្នុង ១ក្បាលដីបំបែក) | ៥០.០០០៛០០ | ១០០.០០០៛០០ | ២០០.០០០៛០០ | ៨០.០០០៛០០ | ១០០.០០០៛០០ |
| ៥ | ការបោះគោលព្រំដីជាថ្មី | ៣០.០០០៛០០ | ៣៥.០០០៛០០ | ៤០.០០០៛០០ | ៣០.០០០៛០០ | ៣៥.០០០៛០០ |
| ៦ | ការចេញលិខិតបញ្ជាក់ (ហ៊ីប៉ូតែក ដាក់បញ្ចាំ ដាក់ធានា) "ក្នុង១ក្បាលដី" | ១៥.០០០៛០០ | ១៨.០០០៛០០ | ២០.០០០៛០០ | ១៥.០០០៛០០ | ១៨.០០០៛០០ |
| ៧ | ការចេញសលាកប័ត្រ ព័ត៌មាន "ក្នុង១ក្បាលដី" | ១៥.០០០៛០០ | ១៨.០០០៛០០ | ២០.០០០៛០០ | ១៥.០០០៛០០ | ១៨.០០០៛០០ |
| ៨ | ការចេញលិខិតបញ្ជាក់ សុរិយោដី "ក្នុង១ក្បាលដី" | ១៥.០០០៛០០ | ១៨.០០០៛០០ | ២០.០០០៛០០ | ១៥.០០០៛០០ | ១៨.០០០៛០០ |

ខ-សម្រាប់ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ និងការចេញប័ណ្ណ

១-ដីកសិកម្មជនបទ ១រៀល/ម$^{២}$

(១០០រៀលសម្រាប់ដីតូចជាង១០០ម$^{២}$)

២-ដីលំនៅឋានជនបទ ១០រៀល/ម$^{២}$

៣-ដីទីប្រជុំជនស្រុក ឬដីជាយទីប្រជុំជនខេត្ត ២០រៀល/ម$^{២}$

៤-ដីទីប្រជុំខេត្ត ឬដីជាយទីប្រជុំជនក្រុងភ្នំពេញ ៥០រៀល/ម$^{២}$

៥-ដីទីប្រជុំជនក្រុងភ្នំពេញ ១០០រៀល/ម$^{២}$

ក្នុងករណីមានប្រជាពលរដ្ឋក្នុងតំបន់ ដែលគ្របដណ្តប់ដោយសារគម្រោងចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ហើយសាមីជនមានសំណើពិសេសក្នុងការសុំចុះបញ្ជីដោយដុំនោះ ការកំណត់សោហ៊ុយសេវាត្រូវអនុវត្តតាមចំណុច (ក) នៃប្រកាសនេះ។

ចំពោះការផ្ទេរសិទ្ធិលើអចលនវត្ថុ សោហ៊ុយសេវាសុរិយោដីជាបន្ទុករបស់អ្នកទទួលសិទ្ធិ។ អ្នកទទួលសិទ្ធិអចលនវត្ថុ ក៏ត្រូវបង់ពន្ធផ្សេងៗទៀតតាមច្បាប់សារពើពន្ធជាធរមាន។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៤

| | |
|---|---|
| **ទេសរដ្ឋមន្ត្រី** | **ទេសរដ្ឋមន្ត្រី** |
| **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច** | **រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី** |
| **និងហិរញ្ញវត្ថុ** | **នគរូបនីយកម្ម និងសំណង់** |
| **ហត្ថលេខា និងត្រា** | **ហត្ថលេខា និងត្រា** |
| **គាត ឈន់** | **អ៊ឹម ឈុនលឹម** |

<u>កន្លែងទទួល</u>

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អាជ្ញាធរសវនកម្មជាតិ

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់សាលាខេត្ត-ក្រុង

"ដើម្បីជូនជ្រាប"

-ដូចប្រការ៣ "ដើម្បីអនុវត្ត"

-ឯកសារ និងកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ២២៥សជណ** រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**គោរពជូន**

**-ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**-ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

កម្មវត្ថុ៖ ករណីរបាយការណ៍ស្តីពីការប្រមូលពន្ធប្រថាប់ត្រាលើការផ្ទេរអចលនវត្ថុ។

យោង៖ -លិខិតលេខ៩៨ជនស ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ចំណាររបស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៥។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីមានកិត្តិយស សូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា រាជរដ្ឋាភិបាលបានសម្រេចយកនូវចំណុចមួយចំនួនដូចមានខាងក្រោម៖

-ដើម្បីដោះស្រាយបញ្ហាវាយតម្លៃអចលនវត្ថុទាបជាងតម្លៃទិញលក់ពិត គឺរកវិធានការដើម្បីយកតម្លៃនៃការទិញលក់អចលនវត្ថុធ្វើជាមូលដ្ឋានគិតពន្ធ។

-ចំពោះការផ្ទេរដីមិនទាន់ចុះបញ្ជីគឺឯកភាពយកពន្ធប្រថាប់ត្រាដូចដីចុះបញ្ជីដែរ បើពុំនោះសោតទេនឹងនាំឱ្យលើកទឹកចិត្តអ្នកមិនចុះបញ្ជី។ នេះជាប្រភពចំណូលមួយយ៉ាងសំខាន់ដោយដីភាគច្រើនជាដីមិនទាន់ចុះបញ្ជី។

-ចំពោះអត្រាពន្ធប្រថាប់ត្រាលើការផ្ទេរអចលនវត្ថុ គួរបន្ទាបពន្ធឱ្យនៅទាប ហើយយកពន្ធតិច តែយកឱ្យបានច្រើនតាមរយៈអ្នកបង់ពន្ធច្រើន។

*វាយឡើងវិញ*

-ចំពោះការសិក្សាអំពីយន្តការប្រមូលពន្ធ គួរយកជម្រើសទី១ដែលងាយស្រួល និងឆាប់រហ័ស ហើយប្រមូលពន្ធបាននោះ គឺសិក្សាអំពីលទ្ធភាពប្រគល់ឱ្យរដ្ឋបាលសុរិយោដីទទួលភារកិច្ចទាំងស្រុងលើការងារកាត់ឈ្មោះផ្ទេរអចលនវត្ថុ ពោលគឺធ្វើការផ្ទៀងផ្ទាត់បញ្ជី ត្រួតពិនិត្យភាពត្រឹមត្រូវនៃឯកសារ-ចុះពិនិត្យ វាស់វែងដី-គាក់តែងលិខិតសញ្ញា-ទទួលពន្ធប្រថាប់ត្រា-ធ្វើលេខាចារឹក-ប្រគល់ប័ណ្ណឱ្យម្ចាស់ថ្មី-បន្តគ្រប់គ្រងទិន្នន័យនៃក្បាលដី។ លទ្ធភាពនេះនឹងសម្រួលដល់ការផ្ទេរសិទ្ធិឱ្យបានឆាប់រហ័ស ហើយភាគីអាចបង់ពន្ធនៅរដ្ឋបាលសុរិយោដីតែម្តងជាការស្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបញ្ជូនមន្ត្រីជំនាញខាងពន្ធដារមកធ្វើប្រតិបត្តិការរួមគ្នា នៅរដ្ឋបាលសុរិយោដីតែម្តង។

-ចំពោះតួលេខសរុបនៃចំណូលពន្ធប្រថាប់ត្រា និងសោហ៊ុយសេវាសុរិយោដីគឺឯកភាពគិតរាប់បញ្ចូលជាចំណូលរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ព្រោះថាចំណូលនេះជាផលិតផលនៃការងារសុរិយោដីទាំងស្រុង (Fruit du Cadastre) ដែលត្រូវបង់ចូលរតនាគារជាតិតាមមាតិកាថវិកា។

-ឯកភាពឱ្យធ្វើការសិក្សាអំពីរង្វាន់ជាភាគរយនៃចំណូលពីពន្ធនៃការផ្ទេរអចលនវត្ថុដើម្បីលើកទឹកចិត្តដល់ផ្នែកសុរិយោដី ផ្នែកពន្ធដារ និងរដ្ឋអំណាចឃុំ-សង្កាត់។

អាស្រ័យហេតុនេះ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

**ជ.ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**ហត្ថលេខា និងត្រា**

**ប្រាក់ សុខុន**

<u>ចម្លងជូន</u>

-ក្រសួងមហាផ្ទៃ

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**លេខ១៧៩ដនស/សជ** រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៥

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជម្រាបមក**

**លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង**

កម្មវត្ថុ៖ ការទទួលខុសត្រូវលើលិខិតសញ្ញាផ្ទេរសិទ្ធិ។

កន្លងមក ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានកត់សម្គាល់ឃើញថា រាល់លិខិតសញ្ញាផ្ទេរកម្មសិទ្ធិអ្នកកាន់កាប់អចលនវត្ថុដែលការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌតាក់តែង និងបញ្ជូនឡើងតាមលំដាប់ថ្នាក់នោះ នៅមានការខ្វះចន្លោះក្នុងការទទួលខុសត្រូវឱ្យបានដាច់ខាតក្នុងការតាក់តែងលិខិតសញ្ញាទាំងនោះ។

ដើម្បីមានមូលដ្ឋានទទួលខុសត្រូវនៅពេលជួបប្រទះបាតុភាពផ្សេងៗដែលកើតឡើង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមជម្រាបជូនថា រាល់លិខិតសញ្ញាផ្ទេរសិទ្ធិអ្នកកាន់កាប់អចលនវត្ថុ ត្រូវសរសេរឈ្មោះ និងចុះហត្ថលេខាទទួលខុសត្រូវ។ នៅពេលតាក់តែងលិខិតចប់សព្វគ្រប់ហើយ អ្នកតែងលិខិតសញ្ញាត្រូវចុះហត្ថលេខា និងឈ្មោះនៅរឹមខាងលើទំព័រទី១នៃលិខិតសញ្ញាដែលបោះពុម្ព ដាក់ថា "អ្នកតែងលិខិត" ដោយប្រធាន ឬអនុប្រធាន ឬអនុប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌដែលមានជំនាញបច្ចេកទេសការងារសុរិយោដី។ ករណីដែលថ្នាក់ដឹកនាំការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលណាពុំមានជំនាញបច្ចេកទេសការងារសុរិយោដី ត្រូវឱ្យមន្ត្រីដែលមានជំនាញបច្ចេកទេសការងារសុរិយោដីជាអ្នកតាក់តែង និងចុះហត្ថលេខាលើលិខិតសញ្ញា។ លិខិតសញ្ញាត្រូវធ្វើជាពីរច្បាប់ សរសេរបំពេញដោយដៃ មិនឱ្យកោសលុប ឬសរសេរជ្រែត ឬត្រួតលើគ្នាតាមរូបមន្តឱ្យបានត្រឹមត្រូវ។

នៅពេលឯកសារនេះមកដល់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង ប្រធានការិយាល័យសុរិយោដីត្រូវពិនិត្យបន្ថែមទៀត។ បើពិនិត្យឃើញមានលក្ខណៈត្រឹមត្រូវ និងគ្រប់គ្រាន់ហើយ អនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុងទទួលបន្ទុកការងារសុរិយោដីត្រូវចុះហត្ថលេខាបំព្រួញ ចុះថ្ងៃ ខែ ឆ្នាំ និងបោះត្រាលេខាចារឹកនៅពីខាងមុខតួលេខតម្លៃអចលនវត្ថុ ត្រង់បន្ទាត់ "តម្លៃជាប្រាក់ . . ." រួចចាត់ការតាមមុខសញ្ញា៖

១-បើខេត្ត-ក្រុងណាដែលបានទទួលប្រតិភូកម្មហត្ថលេខាពីក្រសួងរួចហើយ ត្រូវចាត់ការចុះបញ្ជីបន្ត និងបញ្ជូនតារាងផ្លាស់ប្តូរ ព្រមទាំងឯកសារណបទាំងអស់ទៅអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ដើម្បីចាត់ការពិនិត្យ និងចុះបញ្ជី។

២-ចំពោះខេត្ត-ក្រុងដែលពុំទាន់បានទទួលប្រតិភូកម្មហត្ថលេខា ត្រូវបញ្ជូនទៅអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ដើម្បីចាត់ការពិនិត្យ និងចុះបញ្ជីបន្ត។

ដូចបានជម្រាបជូនខាងលើនេះ ខ្ញុំសង្ឃឹមថា អស់លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុងនឹងផ្សព្វផ្សាយជាទូលាយ ដល់មន្ត្រីរាជការទាំងអស់ក្រោមឱវាទ ជាពិសេសប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ ឱ្យអនុវត្តប្រកបដោយប្រសិទ្ធភាពចាប់ពីថ្ងៃចេញលិខិតនេះតទៅ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ហត្ថលេខា និងត្រា**

**អ៊ឹម ឈុនលឹម**

<u>ចម្លងជូន</u>

-អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ

-អគ្គនាយកដ្ឋានរដ្ឋបាល

"ដើម្បីមុខការ"

-ឯកសារ កាលប្បវត្តិ

*វាយឡើងវិញ*

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ០២បប

## បទបញ្ជា
## ស្តីពីការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

អនុលោមតាមមាត្រា៩នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ០១នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវបទបញ្ជាស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ លេខ៣០បប ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៧ តម្រូវឱ្យគ្រប់ក្រសួង ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន និងខេត្ត-ក្រុងអនុវត្ត និងធានានូវការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋឱ្យបានគត់មត់ គង់វង្ស និងប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ច និងតាមគោលការណ៍ហិរញ្ញវត្ថុជាធរមាន។ បទបញ្ជាស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ លេខ៣០បប នេះគ្របដណ្តប់លើសម្បទាន ការជួល លក់ ផ្ទេរ និងឯកជនភាវូបនីយកម្ម ព្រមទាំងការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ។

ដើម្បីពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅក្រោមក្រសួង ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន ខេត្ត-ក្រុង និងឃុំ-សង្កាត់ឱ្យមានប្រសិទ្ធភាព រាជរដ្ឋាភិបាលដាក់ចេញនូវបទបញ្ជាដូចតទៅ៖

**១.គោលការណ៍គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ**

ក-ចាប់ពីពេលនេះតទៅ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈទាំងឡាយដូចមានចែងក្នុងច្បាប់ភូមិបាល ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ មិនអាចត្រូវបានលក់ជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈស្របតាមបទប្បញ្ញត្តិច្បាប់។

ខ-ចាប់ពីពេលនេះតទៅ ត្រូវផ្អាកការលក់ ផ្ទេរ ជួល ឬឱ្យជាសម្បទានផ្សេងៗនូវទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈទាំងឡាយ លើកលែងតែមានច្បាប់ អនុក្រឹត្យ និងលិខិតបទដ្ឋានសម្រាប់អនុវត្តត្រឹមត្រូវ។

គ-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវសហការគ្នារៀបចំជាបន្ទាន់នូវច្បាប់ អនុក្រឹត្យ និងលិខិតបទដ្ឋានសម្រាប់អនុវត្តនីតិវិធីនៃការលក់ ផ្ទេរ ជួល ឬផ្តល់ឱ្យជាសម្បទានផ្សេងៗនូវទ្រព្យសម្បត្តិរដ្ឋ។ ក្នុងនោះ អាទិភាពបន្ទាន់បំផុតដែលត្រូវសម្រេចឱ្យបានមុនខែធ្នូ ឆ្នាំ២០០៥ គឺ៖

-ច្បាប់ស្តីពីសម្បទាន (សម្រាប់ឱ្យវិស័យឯកជនចូលរួមកសាងហេដ្ឋារចនាសម្ព័ន្ធ) និងលិខិតបទដ្ឋានសម្រាប់អនុវត្តច្បាប់នេះ

-អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច

-អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ

-អនុក្រឹត្យស្តីពីនីតិវិធីនៃការលក់ និងការគ្រប់គ្រងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ ស្របតាមមាត្រា១៧នៃច្បាប់ភូមិបាល។

**២-ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ ស្របតាមបទប្បញ្ញត្តិនៃច្បាប់ហិរញ្ញវត្ថុ**

ចំពោះឯកជនភាវូបនីយកម្មទ្រព្យសម្បត្តិរដ្ឋដែលត្រូវបានអនុញ្ញាតដោយមាត្រា៨១ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ គឺត្រូវអនុវត្តឱ្យបានត្រឹមត្រូវ ប្រកបដោយតម្លាភាព និងម៉ឺងម៉ាត់បំផុត តាមការកំណត់នៃបទប្បញ្ញត្តិច្បាប់ និងលិខិតបទដ្ឋានជាធរមាន រួមមានជាអាទិ៍ អនុក្រឹត្យលេខ៣៨អនក្រ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៥ និងអនុក្រឹត្យលេខ៤៩អនក្រ/បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ព្រមទាំងបទបញ្ជាស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ លេខ៣០បប ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៧។

**៣-ការគ្រប់គ្រងសម្បទាន**

ក្នុងរយៈពេលរង់ចាំច្បាប់ស្តីពីសម្បទាន ចាប់ពីពេលនេះតទៅ ការផ្តល់សម្បទាននានាត្រូវអនុវត្តនីតិវិធីនៃការដេញថ្លៃជាសាធារណៈ ប្រកបដោយតម្លាភាពលើមូលដ្ឋាននៃសៀវភៅបន្ទុកត្រឹមត្រូវ និងច្បាស់លាស់។ សម្បទានទាំងឡាយនេះគ្របដណ្តប់លើការវិនិយោគក្នុងវិស័យដូចតទៅ៖

ក-ការផលិត ការបញ្ជូន និងការចែកចាយថាមពលអគ្គិសនី

ខ-ហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធដឹកជញ្ជូន មានជាអាទិ៍ ផ្លូវថ្នល់ ស្ពាន ព្រលានយន្តហោះ កំពង់ផែ ផ្លូវដែក។

គ-ការផ្គត់ផ្គង់ទឹក និងអនាម័យ។

ឃ-ហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យទូរគមនាគមន៍ និងបច្ចេកវិទ្យាព័ត៌មាន។

ង-ហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យមូលដ្ឋានសម្ភារៈ បម្រើឱ្យគម្រោងផ្នែកទេសចរណ៍ មានជាអាទិ៍ រមណីយដ្ឋានទេសចរណ៍ សារមន្ទីរ។

ច-ហេដ្ឋារចនាសម្ព័ន្ធ បម្រើឱ្យវិស័យឧស្ម័ន និងប្រេងកាត មានជាអាទិ៍ បំពង់បង្ហូរប្រេងកាត និងឧស្ម័ន។

ឆ-ប្រព័ន្ធលូ ប្រព័ន្ធបង្ហូរទឹក និងប្រព័ន្ធបូមស្តារ។

ជ-ប្រព្រឹត្តិកម្ម និងការគ្រប់គ្រងកាកសំណល់។

ឈ-ហេដ្ឋារចនាសម្ព័ន្ធសាធារណៈពាក់ព័ន្ធនឹងវិស័យសុខាភិបាល វិស័យអប់រំ និងវិស័យកីឡា។

ញ-ហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យតំបន់សេដ្ឋកិច្ចពិសេស និងលំនៅឋានសង្គម។

ដ-ហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យប្រព័ន្ធធារាសាស្ត្រ និងការងារកសិកម្ម។

ឋ-វិស័យផ្សេងទៀតដែលច្បាប់ពិសេសណាមួយអនុញ្ញាតនូវសម្បទាន។

គ្រប់ក្រសួង ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន ខេត្ត-ក្រុង និងឃុំ-សង្កាត់ត្រូវអនុវត្តបទបញ្ជានេះឱ្យបានម៉ឺងម៉ាត់ និងឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៥

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

<u>កន្លែងទទួល</u>

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អាជ្ញធរសវនកម្មជាតិ

-កាលប្បវត្តិ-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ០៥សរណន

## សារាចរណែនាំស្តីពីការផ្តល់សម្បទានដីសេដ្ឋកិច្ចសម្រាប់គម្រោងវិនិយោគ នៅក្នុងក្របខ័ណ្ឌនៃការអនុវត្តបទបញ្ជាលេខ០២បប ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៥ស្តីពីការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

ក្នុងទិសដៅពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅក្រោមក្រសួង ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន ខេត្ត-ក្រុង និងឃុំ-សង្កាត់ឱ្យមានប្រសិទ្ធភាព រាជរដ្ឋាភិបាលដាក់ចេញនូវបទបញ្ជាលេខ០២បប ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៥។ ដោយពិនិត្យឃើញសេចក្តីត្រូវការចាំបាច់របស់រាជរដ្ឋាភិបាល ក្នុងការជំរុញលើកទឹកចិត្តការអនុវត្តគម្រោងវិនិយោគនានា ពិសេសក្នុងវិស័យកសិកម្មដែលត្រូវការ ដោយខ្វះមិនបាននូវសម្បទានដីសេដ្ឋកិច្ច រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់គ្រប់ក្រសួង ស្ថាប័នទាំងអស់ដែលមានការពាក់ព័ន្ធ ពិសេសគឺក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអាជ្ញាធរខេត្ត-ក្រុងដូចតទៅ៖

ទី១ ដោយអនុវត្តតាមបទបញ្ជាលេខ០២បប ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៅក្នុងរយៈពេលរង់ចាំអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យផ្តល់សម្បទានដីសេដ្ឋកិច្ច ក្នុងទំហំមិនលើស១០.០០០ហត ស្របតាមបទប្បញ្ញត្តិនៃច្បាប់ភូមិបាល ជូនដល់វិនិយោគិនដែលបានចំណាយទុនរបស់ខ្លួនរួចហើយ ក្នុងការស្វែងរកទីតាំងផ្ទៃដីវិនិយោគ និងក្នុងការរៀបចំសិក្សាអំពីសមិទ្ធិលទ្ធភាពនៃការអនុវត្តគម្រោង ហើយបានដាក់ពាក្យស៊ីវិនិយោគ និងការសិក្សាទាំងអស់នេះជូនក្រសួង ស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលពិនិត្យ និងសម្រេចតាមនីតិវិធីជាធរមាន។

ទី២ ក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ចជូនដល់វិនិយោគិនមានលក្ខណៈគ្រប់គ្រាន់ ដូចមានចែងក្នុងចំណុចទី១ខាងលើ ក្រសួង ស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល និងវិនិយោគិនដែលមានការពាក់ព័ន្ធ ត្រូវគោរពដាច់ខាតតាមល័ក្ខខ័ណ្ឌបួនយ៉ាងដូចខាងក្រោម៖

*វាយឡើងវិញ*

(១) ផ្ទៃដីសម្បទានដែលត្រូវប្រគល់ជូននោះ មិនត្រូវមានការប៉ះពាល់ដល់កម្មសិទ្ធិឯកជន ឬកម្មសិទ្ធិសមូហភាពរបស់ប្រជាជននៅក្នុងតំបន់គម្រោងវិនិយោគនោះឡើយ ។ ដើម្បីគោលដៅនេះ ផ្ទៃដីសម្បទានដែលត្រូវប្រគល់ជូននោះ ត្រូវតែបានធ្វើការចុះបញ្ជីត្រឹមត្រូវជាមុនសិន ស្របតាមអនុក្រឹត្យលេខ៤៦អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ឬអនុក្រឹត្យលេខ៤៨អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ។

(២) ត្រូវរៀបចំផ្ទៃដីត្រៀមបម្រុងសម្រាប់ដោះស្រាយកំណើនប្រជាជន នៅក្នុងរយៈពេលវែងខាងមុខ ។

(៣) ត្រូវមានការធានាឱ្យប្រជាជននៅក្នុងតំបន់នៃគម្រោងវិនិយោគ អាចទទួលបាននូវផលប្រយោជន៍សមរម្យពីគម្រោងវិនិយោគនេះ ដូចជាហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ សាលារៀន មណ្ឌលសុខភាព និងកាលានុវត្តភាពការងារដែលផ្សារភ្ជាប់នឹងគម្រោងវិនិយោគ រាប់ទាំងសមាហរណកម្មផលិតកម្មរបស់គ្រួសារកសិករជាមួយនឹងគម្រោងវិនិយោគនេះផងដែរ ។

(៤) នៅក្នុងកិច្ចសន្យាសម្បទាន ត្រូវមានប្រការចែងពីល័ក្ខខ័ណ្ឌនៃការបង្អាកការអនុវត្តគម្រោងវិនិយោគ នៅតាមទីតាំងផ្ទៃដីណាដែលមានទំនាស់អំពីកម្មសិទ្ធិជាមួយប្រជាជន រហូតដល់មានការដោះស្រាយរួចរាល់ត្រឹមត្រូវ ស្របតាមនីតិវិធីច្បាប់ជាធរមាន ។

គ្រប់ក្រសួង ស្ថាប័ន និងខេត្ត-ក្រុងដែលមានការពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់អនុវត្តតាមស្មារតី និងខ្លឹមសារនៃសារាចរណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៥

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

*<u>កន្លែងទទួល</u>*

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័ន

-គ្រប់សាលាខេត្ត-ក្រុង

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**លេខ១០២៩ដនស/សជ** ភ្នំពេញ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៥

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជម្រាបមក**

**លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង**

កម្មវត្ថុ៖ អំពីការផ្តល់ព័ត៌មាន និងឯកសារដីធ្លីដែលពាក់ព័ន្ធនឹងដីព្រៃ។

យោង៖ សេចក្តីជូនដំណឹងលេខ១០៧៤សជណ/កស ចុះថ្ងៃទី០៥/០៧/០៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សុំអស់លោក លោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុងធ្វើការណែនាំទៅគ្រប់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌក្រោមឱវាទឱ្យអនុវត្តនូវស្មារតីនៃសេចក្តីជូនដំណឹងនេះ ដោយសហការជាមួយរដ្ឋបាលព្រៃឈើ ដើម្បីកំណត់តំបន់ព្រៃឈើ។ ផ្អែកលើនេះ ត្រូវស្រង់ព័ត៌មាន និងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ និងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ (ប្រសិនបើមាន) ដែលឋិតនៅក្នុងតំបន់នេះ ដើម្បីចម្លងជូនអនុគណៈកម្មាធិការខេត្តក្រុងទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើ និងរដ្ឋបាលព្រៃឈើប្រចាំខេត្ត-ក្រុង។

ក្នុងការវិនិច្ឆ័យកំណត់តំបន់ព្រៃ ប្រសិនបើមានបញ្ហាមិនឯកភាពគ្នា ត្រូវរាយការណ៍សុំយោបល់ប្រធានគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីខេត្ត-ក្រុង ដើម្បីប្រធានគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីខេត្ត-ក្រុង ធ្វើការសម្របសម្រួលជាមួយគ្រប់ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីស្រុក-ខណ្ឌ ក្រុមប្រឹក្សាឃុំ-សង្កាត់ និងប្រជាពលរដ្ឋដែលពាក់ព័ន្ធនឹងតំបន់ផ្ទាល់ ដើម្បីរក

ការឯកភាពគ្នាដោះស្រាយ ក្នុងករណីរកការឯកភាពគ្នាមិនឃើញ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីត្រូវស្នើសុំប្រធានគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីខេត្ត-ក្រុង បញ្ជូនសំណុំរឿងនោះ ទៅសុំយោបល់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី។

អាស្រ័យហេតុនេះ សូមអស់លោក លោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីគ្រប់ខេត្ត-ក្រុងធ្វើការផ្សព្វផ្សាយដល់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ និងមន្ត្រីក្រោមឱវាទឱ្យអនុវត្តសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាព ក្នុងស្មារតីទទួលខុសត្រូវខ្ពស់។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ហត្ថលេខា និងត្រា**

**អ៊ឹម ឈុនលឹម**

<u>ចម្លងជូន</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ក្រសួងបរិស្ថាន

-គ្រប់សាលាខេត្ត-ក្រុង

-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ក្រសួងមហាផ្ទៃ ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ២១៥ប្រក/ដនស/មផ

ប្រកាសអន្តរក្រសួង

ស្តីពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ-សង្កាត់ក្នុងការចុះបញ្ជីដីធ្លី

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើដោយច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ៤៦អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី

- បានឃើញអនុក្រឹត្យលេខ៤៨អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ
- តាមការចាំបាច់របស់ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**ប្រការ១**

ត្រូវបានធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ឱ្យបំពេញភារកិច្ចចូលរួមក្នុងការចុះបញ្ជីដីធ្លី ក្នុងមូលដ្ឋានរបស់ខ្លួន សំដៅធានាការពារផលប្រយោជន៍របស់ប្រជាពលរដ្ឋ ធានាការពារសិទ្ធិនៃកម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុ។

**ប្រការ២**

ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវធ្វើប្រតិភូកម្មបន្តឱ្យដល់មេឃុំ ចៅសង្កាត់ ដើម្បីអនុវត្តភារកិច្ចដូចបានចែងក្នុងប្រការ១នៃប្រកាសនេះ។ មេឃុំ ចៅសង្កាត់ត្រូវធ្វើសេចក្តីរាយការណ៍អំពីការងារចុះបញ្ជីដីធ្លី ជូនក្រុមប្រឹក្សាឃុំ-សង្កាត់រៀងរាល់កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំសង្កាត់។

## ផ្នែកទី១ អំពីការចុះបញ្ជីដីលើកដំបូង

**ប្រការ៣**

មេឃុំ ចៅសង្កាត់ត្រូវចូលរួមនូវរាល់ប្រតិបត្តិការចុះបញ្ជីដីធ្លី តាមដំណាក់កាលនីមួយៗ ដោយទទួលខុសត្រូវលើភាពប្រាកដប្រជាក្នុងការបញ្ជាក់អំពីអត្តសញ្ញាណក្បាលដី និងម្ចាស់ដីនៅមូលដ្ឋានរបស់ខ្លួន។

ទាក់ទងនឹងអត្តសញ្ញាណកម្មក្បាលដី មេឃុំ ចៅសង្កាត់ត្រូវបញ្ជាក់ឱ្យច្បាស់ថា ក្បាលដីដែលត្រូវធ្វើការចុះបញ្ជីនោះពិតជាមានទីតាំងក្នុងឃុំ-សង្កាត់របស់ខ្លួន និងមានព្រំដីច្បាស់លាស់ដូចពាក្យស្នើសុំ ឬដូចការប្រកាសរបស់សាមីខ្លួនក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី។

ទាក់ទងនឹងអត្តសញ្ញាណម្ចាស់ដី មេឃុំ ចៅសង្កាត់ត្រូវបញ្ជាក់អំពីឈ្មោះសាវតារ ស្ថានភាពស៊ីវិល ឬអត្រានុកូលដ្ឋាន និងទីលំនៅបច្ចុប្បន្នរបស់ម្ចាស់ដី។ ក្នុងករណីម្ចាស់ដីមានទីលំនៅនៅឃុំ-សង្កាត់ផ្សេង មេឃុំ ចៅសង្កាត់នៃឃុំ-សង្កាត់នោះជាអ្នកបញ្ជាក់។

**ប្រការ៤**

មេឃុំ ចៅសង្កាត់ត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់ភាពត្រឹមត្រូវនៃឯកសារលោប រួមមានការបញ្ជាក់អំពីប្រភព និងកាលបរិច្ឆេទនៃការកាន់កាប់ដី អំពីស្ថានភាពដី អំពីប្រវត្តិដី។

**ប្រការ៥**

ការចូលកាន់កាប់ភោគៈបានបញ្ចប់ចាប់ពីច្បាប់ភូមិបាលចូលជាធរមាននៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១។ មេឃុំ ចៅសង្កាត់ត្រូវទប់ស្កាត់នូវរាល់ការរានដីតាមទំនើងចិត្ត និងការចូលកាន់កាប់ដីដោយគ្មានការអនុញ្ញាតនៅក្នុងមូលដ្ឋានរបស់ខ្លួន។ មេឃុំ ចៅសង្កាត់ត្រូវរាយការណ៍ជាបន្ទាន់ជូនអភិបាលស្រុក-ខណ្ឌ ដើម្បីមានវិធានការដោះស្រាយក្នុងករណីទប់ស្កាត់មិនបាន។

**ប្រការ៦**

ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវកសាងគំនូសព្រាងផែនទីប្រើប្រាស់ដីធ្លី ក្នុងឃុំ-សង្កាត់របស់ខ្លួន ដោយកំណត់ដីឯកជន ដីរដ្ឋ ដីសមស្របសម្រាប់កម្មវិធីសម្បទានដីសង្គមកិច្ច សម្បទានដីសេដ្ឋកិច្ចដើម្បីមានមូលដ្ឋានអភិវឌ្ឍក្នុងឃុំ-សង្កាត់របស់ខ្លួន ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងឃុំសង្កាត់។

## ផ្នែកទី២ អំពីការចុះបញ្ជីដីបន្ត

**ប្រការ៧**

ការចុះបញ្ជីដីបន្តទាមទារឱ្យមានឯកសារគតិយុត្តជាសំអាង ដូចជាកិច្ចសន្យាលក់ ឱ្យ ដូរ អច្ច័យទាន បញ្ចាំ ដាក់ធានា ហ៊ីប៉ូតែក ជួលរយៈពេលវែង បង្កើតសេវភាព ផលុបភោគ ឬសេចក្តីសម្រេចរបស់តុលាការ។

**ប្រការ៨**

ដើម្បីឱ្យការផ្ទេរសិទ្ធិ ការធានាប្រាក់បំណុល ការបង្កើតបន្ទុកផ្សេងៗមិនអាចជំទាស់ពីតតិយជនបាន កិច្ចសន្យាផ្ទេរ កិច្ចសន្យាធានាប្រាក់បំណុល និងកិច្ចសន្យាបង្កើតបន្ទុកត្រូវធ្វើជាលាយលក្ខណ៍អក្សរតាមទម្រង់លិខិតយថាភូត ដោយអាជ្ញាធរមានសមត្ថកិច្ច ហើយត្រូវបានចុះបញ្ជីនៅអង្គភាពសុរិយោដី។

**ប្រការ៩**

អភិបាលស្រុក-ខណ្ឌ ឬមេឃុំ ចៅសង្កាត់ជាអ្នកបញ្ជាក់លើលិខិតសញ្ញាផ្សេងៗ ដូចជាលិខិតលក់ផ្តាច់ អំណោយផ្តាច់ កិច្ចសន្យាបញ្ចាំ ដាក់ធានា ហ៊ីប៉ូតែក កិច្ចសន្យាជួលរយៈពេលវែង កិច្ចសន្យាបង្កើតសេវភាព ផលុបភោគ អាស្រ័យលើការព្រមព្រៀងរបស់គូភាគី។ ក្នុងការបញ្ជាក់ អភិបាលស្រុក-ខណ្ឌ ឬមេឃុំ-ចៅសង្កាត់ត្រូវយកចិត្តទុកដាក់ និងទទួលខុសត្រូវលើ៖

-អត្តសញ្ញាណអចលនវត្ថុដែលជាកម្មវត្ថុនៃលិខិតកិច្ចសន្យា និង

-អត្តសញ្ញាណគូភាគីនៃកិច្ចសន្យា។

**ប្រការ១០**

ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌធ្វើការចុះបញ្ជីបាន លុះត្រាតែកិច្ចសន្យាទាក់ទងនឹងអចលនវត្ថុនោះ ត្រូវបានធ្វើជាលាយលក្ខណ៍អក្សរតាមទម្រង់លិខិតយថាភូត ដោយអាជ្ញាធរមានសមត្ថកិច្ច និងមានភស្តុតាងបង្ហាញថា រាល់ពន្ធដារ ឬថ្លៃសេវាផ្សេងៗត្រូវបានបង់រួច។

ការចុះបញ្ជីនូវរាល់ការប្រែប្រួលសិទ្ធិ ការបង្កើតសិទ្ធិ និងការរំលត់សិទ្ធិលើក្បាលដី ក៏ដូចជាការប្រែប្រួលលក្ខណរូបនៃក្បាលដី និងនាំឱ្យតតិយជនមិនអាចជំទាស់បាន។

**ប្រការ១១**

មេឃុំ ចៅសង្កាត់ត្រូវផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋក្នុងរង្វង់ដែនដីរបស់ខ្លួន យល់ដឹងអំពីអានុភាពនៃការចុះបញ្ជីដីធ្លី អំពីភាពចាំបាច់ក្នុងការចូលរួមការចុះបញ្ជីដីធ្លី និងអំពីផលវិបាកដែលកើតឡើងអំពីការមិនបានចុះបញ្ជីនូវរាល់ការប្រែប្រួលសិទ្ធិតាមរយៈការលក់ ទិញ ការឱ្យ ឬប្រទានកម្ម ការផ្ទេរ ការជម្រះមតិក ការបង្កើតសិទ្ធិតាមរយៈការបញ្ចាំ ការដាក់ធានា ការដាក់ហ៊ីប៉ូតែក ការជួលរយៈពេលវែង ការបង្កើតសេវភាព និងការរលត់សិទ្ធិលើក្បាលដីតាមរយៈការលើកលែងបញ្ចាំ ការលើកលែងការដាក់ធានា ការលើកលែងហ៊ីប៉ូតែក ក៏ដូចជាការប្រែប្រួលលក្ខណរូបនៃក្បាលដីតាមរយៈការកែតម្រូវព្រំដី ការបំបែកក្បាលដី ឬការបង្រួមក្បាលដី។

**ផ្នែកទី៣ អំពីការផ្តល់ព័ត៌មាន**

**ប្រការ១២**

បន្ទាប់ពីបញ្ជាក់លើលិខិតសញ្ញារួចហើយ បើលិខិតនោះបញ្ជាក់នៅឃុំ-សង្កាត់ មេឃុំ ចៅសង្កាត់ត្រូវយកលិខិតនោះទៅចុះក្នុងបញ្ជីមួយហៅថា សៀវភៅចុះលិខិតបញ្ជាក់គឺត្រូវចុះលេខរៀង និងកាលបរិច្ឆេទនៃប្រតិបត្តិការ រួចស្រង់លេខរៀង និងថ្ងៃ ខែ ឆ្នាំ ដាក់លើលិខិតដើមគ្រប់លិខិតបញ្ជាក់ដែលត្រូវប្រគល់ទៅឱ្យភាគីម្នាក់ៗ។ បន្ទាប់មកត្រូវចុះថ្ងៃ ខែ ឆ្នាំនៃលិខិត ចុះឈ្មោះព្រមទាំងទីលំនៅនៃភាគី ចុះប្រភេទនៃលិខិត និងចុះកម្មវត្ថុនៃលិខិត។ បើលិខិតនោះទាក់ទងនឹងអចលនវត្ថុ សេចក្តីនៃលិខិតត្រូវចម្លងចូលដោយសង្ខេបដាក់ក្នុងបញ្ជិកាមួយទៀត ហៅថា បញ្ជិកានៃលិខិតបញ្ជាក់អចលនវត្ថុសម្រាប់ឃុំ-សង្កាត់នីមួយៗ។

**ប្រការ១៣**

លិខិតបញ្ជាក់អចលនវត្ថុដោយអភិបាលស្រុក-ខណ្ឌត្រូវបញ្ជូនទៅមេឃុំ ចៅសង្កាត់ដែលអចលនវត្ថុនោះឋិតនៅ ដើម្បីមេឃុំ ចៅសង្កាត់ចុះសេចក្តីបញ្ជាក់ក្នុងសៀវភៅចុះលិខិតបញ្ជាក់អចលនវត្ថុថែមទៀត។ បញ្ជិកានៃលិខិតបញ្ជាក់អចលនវត្ថុត្រូវមាននៅសាលាឃុំ-សង្កាត់ នៅសាលាស្រុក-ខណ្ឌ និងនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ។

**ប្រការ១៤**

បញ្ជិកានៃលិខិតបញ្ជាក់នៃលិខិតបញ្ជាក់អចលនវត្ថុ ត្រូវប្រើប្រាស់សម្រាប់ការផ្សាយលិខិតអចលនវត្ថុក្នុងឃុំ-សង្កាត់នីមួយៗ។ ចំពោះលិខិតបញ្ជាក់អចលនវត្ថុ មេឃុំ ចៅសង្កាត់ ឬអភិបាលស្រុក-ខណ្ឌជាអ្នកបញ្ជាក់ តែមិនបានចុះក្នុងបញ្ជិកានៃលិខិតបញ្ជាក់អចលនវត្ថុ មេឃុំ ចៅសង្កាត់ ឬអភិបាលស្រុក-ខណ្ឌនោះត្រូវទទួលខុសត្រូវចំពោះភាគី ឬតតិយជនដែលមានប្រយោជន៍ក្នុងរឿងនេះ។

**ប្រការ១៥**

ការិយាល័យរៀបចំដែនដី នគរូបនីយកម្មសំណង់ និងភូមិបាលស្រុក-ខណ្ឌ ត្រូវផ្ញើច្បាប់ចម្លងនៃសម្រង់ឯកសារសុរិយោដីដល់ឃុំ-សង្កាត់ដែលពាក់ព័ន្ធ។ សម្រង់ឯកសារសុរិយោដីទាំងនោះមាន៖

**១-ចំពោះតំបន់ដែលធ្វើការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ៖**

-ប្លង់សុរិយោដី

-បញ្ជីឈ្មោះកម្មសិទ្ធិករ

-ព័ត៌មានពីការទប់ស្កាត់ផ្សេងៗ ប្រសិនបើមាន។

**២-ចំពោះតំបន់ដែលធ្វើការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ៖**

-បញ្ជីឈ្មោះម្ចាស់ដី ប្រសិនបើមាន

-ផែនទីក្បាលដី ប្រសិនបើមាន

-ព័ត៌មានពីការទប់ស្កាត់ផ្សេងៗ ប្រសិនបើមាន

**ប្រការ១៦**

មេឃុំ ចៅសង្កាត់ត្រូវទទួលខុសត្រូវក្នុងការកាន់កាប់ច្បាប់ចម្លងនៃសម្រង់សុរិយោដីដែលបានទទួល ហើយអាចធ្វើចរន្តការលើឯកសារនូវរាល់ការផ្លាស់ប្តូរ ប្រែប្រួលសិទ្ធិ ឬបន្ទុកលើក្បាលដីនីមួយៗ ដើម្បីជាការកត់សម្គាល់ផ្ទាល់ខ្លួន និងជាមូលដ្ឋានបញ្ជាក់ទៅថ្ងៃក្រោយ។

លើមូលដ្ឋាននៃសម្រង់សុរិយោដី មេឃុំ ចៅសង្កាត់ត្រូវអនុញ្ញាតឱ្យជនគ្រប់រូបពិគ្រោះយោបល់ ហើយត្រូវរាយការណ៍ទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌនូវរាល់ការផ្លាស់ប្តូរដែលទាក់ទងទៅនឹងស្ថានភាពនៃកម្មសិទ្ធិ និងកម្មសិទ្ធិករក្នុងមូលដ្ឋានរបស់ខ្លួន។

**ប្រការ១៧**

ក្នុងការចុះបញ្ជីដីធ្លី រដ្ឋបាលឃុំ-សង្កាត់ត្រូវទទួលបាននូវកម្រៃ តាមការកំណត់រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ព្រមទាំងត្រូវទទួលបាននូវការបណ្តុះបណ្តាល ការកសាងសមត្ថភាព និងសម្ភារៈផ្សេងៗទៀតដែលចាំបាច់។

**ប្រការ១៨**

ក្នុងការអនុវត្តអំណាចប្រតិភូកម្មនេះ ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវទទួលខុសត្រូវចំពោះរដ្ឋបាលសុរិយោដីដែលមានសមត្ថកិច្ចទទួលខុសត្រូវទាំងស្រុង ចំពោះដំណើរការនៃការចុះបញ្ជីដីធ្លី។

ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវបំពេញភារកិច្ចខាងលើនេះ ឱ្យបានសមស្របតាមច្បាប់ភូមិបាល និងលិខិតបទដ្ឋានពាក់ព័ន្ធនានា។

*វាយឡើងវិញ*

**ប្រការ១៩**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ២០**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល គ្រប់ប្រធានអង្គភាពក្រោមឱវាទក្រសួងមហាផ្ទៃ នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន គ្រប់ប្រធានអង្គភាពក្រោមឱវាទក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អភិបាលគ្រប់ខេត្តក្រុង គ្រប់ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង អភិបាលគ្រប់ស្រុក-ខណ្ឌ គ្រប់ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុកខណ្ឌ ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀង១ខ្លួនចាប់ពីចុះហត្ថលេខាតទៅ។

ភ្នំពេញ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៥

| | | |
|---|---|---|
| | **ឧបនាយករដ្ឋមន្ត្រី** | **ទេសរដ្ឋមន្ត្រី** |
| <u>កន្លែងទទួល</u> | **សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** | **រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី** |
| -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា | | **នគរូបនីយកម្ម និងសំណង់** |
| -អគ្គលេខាធិការដ្ឋានរដ្ឋសភា | **ហត្ថលេខា និងត្រា** | **ហត្ថលេខា និងត្រា** |
| -ទីស្តីការគណៈរដ្ឋមន្ត្រី | **ស ខេង  នរោត្តម សិរីវុឌ្ឍ** | **អ៊ឹម ឈុនលឹម** |

-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន

-ដូចប្រការ២០

-កាលប្បវត្តិ-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**គណៈកម្មការសុរិយោដីថ្នាក់ជាតិ**

លេខ១៤៥៥ដនស/គសជ

# សេចក្តីណែនាំ

## ស្តីពីនីតិវិធីសវនាការនៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ

អនុលោមតាមអនុក្រឹត្យលេខ៤៧អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមធ្វើការកំណត់អំពីនីតិវិធីសវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិដូចតទៅ៖

**I-ការចាប់ផ្តើមនៃករណីវិវាទ**

១-គណៈកម្មការសុរិយោដីថ្នាក់ជាតិទទួលករណីវិវាទពីគណៈកម្មការសុរិយោដីខេត្ត-ក្រុង និងគណៈកម្មការរដ្ឋបាលដែលធ្វើការសម្រុះសម្រួលមិនបានជោគជ័យ។ លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវរៀបចំទម្រង់បែបបទបញ្ជាក់ពីការទទួលសំណុំរឿងវិវាទដែលបានបញ្ជូនមក ហើយទម្រង់បែបបទនេះត្រូវបានរក្សាទុកក្នុងសំណុំរឿងវិវាទ។ លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវចុះលេខសំណុំរឿងវិវាទ។

២-លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ពិនិត្យមើលឡើងវិញនូវសំណុំរឿងវិវាទផ្លូវការ ហើយធ្វើកំណត់បង្ហាញឱ្យបានឆាប់បំផុតជូនទៅប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ។ កំណត់បង្ហាញនេះធ្វើការសម្គាល់ថា តើសំណុំរឿងវិវាទមានលក្ខណៈពេញលេញ និងគ្រប់គ្រាន់ឬទេ ហើយថាតើតម្រូវឱ្យមានការស៊ើបអង្កេតបន្ថែមដែរឬទេ។

៣-ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចបង្គាប់ឱ្យមានស៊ើបអង្កេតបន្ថែមទៀត ប្រសិនបើយល់ថាជាការចាំបាច់។ នៅដំណាក់កាលណាមួយនៃដំណើរការវិនិច្ឆ័យមុននឹងធ្វើសេចក្តី

សម្រេច គណៈកម្មការសុរិយោដីថ្នាក់ជាតិអាចបង្គាប់ឱ្យមានការស៊ើបអង្កេតបន្ថែមទៀតបាន។ ការស៊ើបអង្កេតនេះគឺត្រូវធ្វើឡើងដោយលេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ។

៤-ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិអាចធ្វើការបង្គាប់ផ្សេងទៀតដែលចាំបាច់ ទៅលេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដើម្បីរៀបចំសំណុំរឿងវិវាទឱ្យមានលក្ខណៈពេញលេញ និងគ្រប់គ្រាន់។

## II-ការរៀបចំដំណើរការករណីវិវាទ

នៅពេលសំណុំរឿងវិវាទមានលក្ខណៈពេញលេញ និងគ្រប់គ្រាន់ហើយនោះ លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវបញ្ជូនសំណុំរឿងនេះទៅប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដើម្បីធ្វើការពិនិត្យ។ ក្រោយពីការពិនិត្យរួចហើយ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិអាចកំណត់៖

១-ចំពោះសំណុំរឿងវិវាទដែលចាំបាច់ត្រូវមានការពិភាក្សាផ្ទៃក្នុង ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចអញ្ជើញសមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ និងសមាជិកអាជហុក (សមាជិកចំពោះកិច្ច) ចូលរួម។ ការពិភាក្សាផ្ទៃក្នុងនេះជាការពិគ្រោះយោបល់ ដើម្បីសម្រេចបន្តករណីវិវាទ ឬត្រូវច្រានចោលករណីវិវាទតែប៉ុណ្ណោះ ដោយពុំចាំបាច់មានការជូនដំណឹងដល់សាធារណជន និងប្រព័ន្ធផ្សព្វផ្សាយឡើយ។

២-ចំពោះសំណុំរឿងវិវាទដែលមានពាក្យបណ្ដឹងមិនត្រឹមត្រូវ ឬគ្មានមូលដ្ឋានដែលធ្វើឡើងគ្រាន់តែដើម្បីយាយី ឬបំភិតបំភ័យភាគីវិវាទម្ខាង ឬមិនឋិតនៅក្នុងយុត្តាធិការរបស់គណៈកម្មការសុរិយោដី ទោះឋិតក្នុងដំណាក់កាលកំពុងដំណើរការក្នុងនីតិវិធីរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិក៏ដោយ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវសម្រេចច្រានចោលសំណុំរឿងវិវាទនោះ។

៣-ចំពោះសំណុំរឿងវិវាទដែលមានលក្ខណៈពេញលេញ និងគ្រប់គ្រាន់ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិអាចបង្គាប់ទៅលេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ឬគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង ដើម្បីកំណត់អំពីទីកន្លែង និងពេលវេលាដែលនឹងត្រូវរៀបចំសវនាការនៃសំណុំរឿងវិវាទនោះ។ បន្ទាប់ពីបានទទួលរបាយការណ៍អំពីពេលវេលា និងទីកន្លែងច្បាស់លាស់

ដែលត្រូវរៀបចំសវនាការ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវសម្រេចបើកសវនាការលើសំណុំរឿងវិវាទនោះ។

៤-ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិអាចបង្គាប់ឱ្យមានការសម្រុះសម្រួលវិវាទបន្ថែមទៀតតាមសំណើរបស់ភាគីវិវាទ ឬតាមការយល់ឃើញរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ។ នីតិវិធីរដ្ឋបាលនៃការសម្រុះសម្រួលនៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវអនុវត្តដូចនីតិវិធីទាំងឡាយសម្រាប់គណៈកម្មការសុរិយោដីស្រុក-ខណ្ឌដែរ។ នៅពេលដំណើរការនីតិវិធីសវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ភាគីវិវាទអាចបដិសេធការចូលរួមរបស់ប្រធាន ឬសមាជិករូបណាដែលពាក់ព័ន្ធនឹងវិវាទផលប្រយោជន៍ត្រូវដកខ្លួនចេញពីការដោះស្រាយករណីវិវាទនោះ ហើយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវតែងតាំងប្រធានអាដហុក (ប្រធានចំពោះកិច្ច) ឬសមាជិកថ្មីជំនួសវិញ។ ក្នុងកំលុងពេលនៃដំណើរការនីតិវិធីរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ រហូតដល់ពេលធ្វើសេចក្តីសម្រេចលើវិវាទ ភាគីវិវាទនីមួយៗ ឬតំណាងអាចផ្តល់ពីពេលមុន។

**III-ការជូនដំណឹង និងពេលវេលានៃសវនាការ**

**ក-ការជូនដំណឹង**

ការជូនដំណឹងអំពីសវនាការត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរដោយកំណត់ច្បាស់លាស់អំពីកាលបរិច្ឆេទ និងទីកន្លែងដែលត្រូវបើកសវនាការ។ លិខិតជូនដំណឹងត្រូវប្រគល់ឱ្យដល់ដៃដើមបណ្តឹង ឬតំណាង និងចុងបណ្តឹង ឬតំណាង យ៉ាងហោច១៥ថ្ងៃនៃថ្ងៃធ្វើការ មុនថ្ងៃបើកសវនាការដោយមានហត្ថលេខា ឬស្នាមមេដៃរបស់អ្នកទទួល និងអ្នកប្រគល់លិខិតជូនដំណឹងនោះ។ ក្នុងករណីភាគីវិវាទណាមួយបដិសេធមិនទទួល ឬអវត្តមានពីលំនៅឋានដោយគ្មានមូលហេតុសមស្រប អ្នកប្រគល់លិខិត្រូវចារលើខ្នងលិខិតបញ្ជាក់ពីមូលហេតុ។

**ខ-ពេលវេលាសវនាការ**

គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវបើកសវនាការចាប់ពីម៉ោង០៨:៣០នាទីព្រឹក ដល់ម៉ោង១១:៣០នាទីនៃថ្ងៃធ្វើការ។ ក្នុងករណីចាំបាច់ សវនាការអាចធ្វើនៅម៉ោងផ្សេងពីការកំណត់នេះ ឬអាចបន្តទៅទៀតបាន។ ការបើកសវនាការអាចដោះស្រាយបណ្តឹងច្រើនករណីបាន។

**គ-ការបង្ហាញខ្លួននៅពេលសវនាការ**

១-ប្រសិនបើភាគីដើមបណ្តឹង ឬតំណាងបានទទួលលិខិតជូនដំណឹងហើយ តែមិនបានមកបង្ហាញខ្លួននៅថ្ងៃសវនាការដោយគ្មានមូលហេតុ ឬមានមូលហេតុមិនសមស្រប ប្រធានសវនាការត្រូវសម្រេចបញ្ចាក់ពីការបញ្ឈប់ដំណើរការដោះស្រាយ។

២-ប្រសិនបើភាគីចុងបណ្តឹង ឬតំណាងបានទទួលលិខិតជូនដំណឹងហើយ តែមិនបានមកបង្ហាញខ្លួននៅថ្ងៃសវនាការដោយគ្មានមូលហេតុ ឬមានមូលហេតុមិនសមស្រប ប្រធានសវនាការត្រូវសម្រេចករណីវិវាទនេះ ដោយអវត្តមានចុងបណ្តឹង ឬតំណាង។

៣-បើភាគីដើមបណ្តឹង ឬ/និងចុងបណ្តឹងស្លាប់មុនពេលសវនាការ អ្នកតំណាងស្របច្បាប់របស់ភាគីនោះអាចចូលរួមក្នុងសវនាការបាន។

៤-សាក្សីគ្រប់រូបត្រូវមកបង្ហាញខ្លួនចំពោះមុខប្រធានសវនាការតាមការអញ្ជើញ។

IV-**អំពីសវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ**

សវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិគឺជាដំណើរការនៃការប្រជុំរវាងភាគីវិវាទ (ឬតំណាង) និងសាក្សីជាមួយនឹងក្រុមវិនិច្ឆ័យ ឬប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ឬសមាជិកតែម្នាក់ ឬមន្ត្រីចំពោះដីវិវាទដែលមិនទាន់ចុះបញ្ជីសុរិយោដី។ សវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវធ្វើឡើងជាសាធារណៈ។

សវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិអាចដឹកនាំដោយ៖

-ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ តែ១រូប ជាប្រធានសវនាការ ឬ

-សមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ០១រូប ដែលត្រូវបានតែងតាំងជាប្រធានសវនាការ ឬ

-មន្ត្រីសវនាការតែ០១រូប ដែលត្រូវបានតែងតាំងជាប្រធានសវនាការ ឬ

-ក្រុមវិនិច្ឆ័យមានសមាសភាពប្រធាន និងសមាជិកមួយរូប ឬសមាជិកទាំងអស់នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដែលដឹកនាំដោយប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ជាប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ជាប្រធានក្រុមវិនិច្ឆ័យ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិអាចរៀបចំឱ្យមានជាសវនាការចល័ត ឬអចល័ត៖

-*សវនាការចល័ត*

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិអាចសម្រេចឱ្យមានការធ្វើសវនាការចល័តតាមសំណូមពររបស់ភាគីវិវាទបាន។ សវនាការចល័តត្រូវធ្វើឡើងនៅលើ ឬជិតទីតាំងដីទំនាស់ ឬកន្លែងណាមួយដែលភាគីវិវាទសំណូមពរ សវនាការចល័តអាចដឹកនាំដោយក្រុមអ្នកវិនិច្ឆ័យ ឬសមាជិកគណៈកម្មការតែម្នាក់ ឬមន្ត្រីសវនាការតែមួយរូបដែលតែងតាំងជាប្រធានសវនាការ។

-*សវនាការអចល័ត*

សវនាការអចល័តធ្វើឡើងដោយការសម្រេចរបស់ប្រធានគណៈកម្មការថ្នាក់ជាតិ ឬ/និងតាមសំណូមពររបស់ភាគីវិវាទ។ សវនាការអចល័តត្រូវធ្វើនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ សវនាការអចល័តអាចដឹកនាំដោយក្រុមអ្នកវិនិច្ឆ័យ ឬសមាជិកគណៈកម្មការតែម្នាក់ ឬមន្ត្រីសវនាការតែមួយរូបដែលតែងតាំងជាប្រធានសវនាការ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវបើកសវនាការរបស់ខ្លួនតាមរបៀបដូចខាងក្រោម៖

១-គណៈកម្មការសុរិយោដីថ្នាក់ជាតិអាចធ្វើសវនាការជាក្រុមវិនិច្ឆ័យ ឬប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ឬសមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិតែម្នាក់ ឬមន្ត្រីសវនាការតែ១រូបដែលតែងតាំងជាប្រធានសវនាការ។

២-សវនាការត្រូវប្រព្រឹត្តទៅក្រោមការដឹកនាំរបស់ប្រធានសវនាការ។ ប្រធានសវនាការអាចជាប្រធាន ឬសមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ ឬមន្ត្រីសវនាការដែលចាត់តាំងដោយប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ។

៣-ក្នុងពេលសវនាការ ប្រធានសវនាការត្រូវមានលេខាធិការសវនាការជាជំនួយការដែលជាមន្ត្រីលេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ។

**V-ដំណើរការនៃការរៀបចំសវនាការ**

របៀបរៀបចំសវនាការត្រូវធ្វើតាមការណែនាំដូចខាងក្រោម៖

ក-លេខាធិការសវនាការ

លេខាធិការសវនាការមានភារកិច្ចដូចតទៅ៖

-ពិនិត្យ ឬស្រង់វត្តមាន អវត្តមានដើមបណ្តឹង ចុងបណ្តឹង ឬតំណាង និងសាក្សី

-អានបទបញ្ជាផ្ទៃក្នុងសវនាការ

-នាំភាគីវិវាទ និងសាក្សីទៅស្បថ

-ប្រាប់ទៅអ្នកចូលរួមទាំងអស់ឱ្យក្រោកឈរនៅពេលសវនាការស្រែកថា "ប្រធានសវនាការ"

-រាយការណ៍ពីវត្តមាន អវត្តមានអំពីភាគីវិវាទពាក់ព័ន្ធជូនប្រធានសវនាការ

-រាយការណ៍ដោយសង្ខេបនូវដំណើររឿងរបស់ករណីវិវាទ

-ត្រូវសរសេរ ឬកត់ត្រាកំណត់ហេតុសវនាការ។ កំណត់ហេតុសវនាការត្រូវមានហត្ថលេខាអ្នកកត់ត្រា ភាគីវិវាទ និងសាក្សី។

-អានឯកសារផ្សេងៗដែលពាក់ព័ន្ធតាមការស្នើសុំពីប្រធានសវនាការ។

ខ-ប្រធានសវនាការ

-ប្រធានសវនាការត្រូវអង្គុយតាមកន្លែងដែលបានរៀបចំទុក។

-ប្រធានសវនាការអង្គុយចំកណ្តាល

-សមាជិកអង្គុយអមសងខាង

-លេខាធិការសវនាការត្រូវអង្គុយនៅតុផ្សេងដែលឋិតនៅខាងស្តាំដៃប្រធានសវនាការ

ក្រោយពីបានអង្គុយតាមកន្លែងកំណត់រួចមក ប្រធានសវនាការត្រូវប្រកាសថា "យើងសូមបើកសវនាការ" រួចត្រូវបន្តសេចក្តីតាមលំដាប់ដូចតទៅៈ

១-សវនាការនេះត្រូវបានធ្វើឡើងដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិទាំងមូល ឬដោយប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ឬដោយសមាជិកតែម្នាក់ ឬដោយមន្ត្រីសវនាការតែមួយរូប ដោយបង្ហាញអំពីឈ្មោះ និងឋានៈរបស់ប្រធានសវនាការ ឬ/និងសមាជិកសវនាការ ព្រមទាំងលេខាធិការសវនាការ លេខសំណុំរឿងវិវាទ ឈ្មោះភាគីវិវាទ ទីតាំងដីវិវាទ និងកម្មវត្ថុនៃវិវាទ។

ឧទាហរណ៍ ថ្ងៃនេះគណៈកម្មការសុរិយោដីថ្នាក់ជាតិបើកសវនាការជំនុំជម្រះសំណុំរឿងលេខ............ ចុះថ្ងៃទី............ខែ................ឆ្នាំ.................ឋិតនៅភូមិ................ឃុំ............ស្រុក.............ខេត្ត.............រវាងដើមបណ្តឹងឈ្មោះ...................ឬតំណាងឈ្មោះ................និងចុងបណ្តឹងឈ្មោះ.............................ឬតំណាងឈ្មោះ........................។

២-មូលហេតុនៃការរៀបចំសវនាការ (ដោយហេតុថាករណីវិវាទនេះបានធ្វើការសម្រុះសម្រួល ប៉ុន្តែភាគីវិវាទមិនអាចឈានដល់ការព្រមព្រៀងនៅគណៈកម្មការសុរិយោដីខេត្ត-ក្រុង............... ឬគណៈកម្មការរដ្ឋបាលក្នុងតំបន់វិនិច្ឆ័យនៃខេត្ត-ក្រុងណាមួយ)។

៣-ប្រធានសួរទៅកាន់លេខាធិការសវនាការថា តើសេចក្តីជូនដំណឹងអំពីសវនាការត្រូវបានផ្តល់ឱ្យភាគីវិវាទទាំងអស់ត្រឹមត្រូវតាមនីតិវិធីដែរឬទេ? បើសិនជាភាគីវិវាទមិនបានធ្វើការស្នើសុំទេ ប្រធានសវនាការអាចធ្វើការសម្រេចថា តើត្រូវកំណត់ពេលសវនាការនៅលើកក្រោយ ឬធ្វើសវនាការនៅពេលនេះតែម្តង។ សវនាការមិនអាចដំណើរការដោយអវត្តមានភាគីវិវាទណាមួយឡើយ លើកលែងតែការអវត្តមាននោះគ្មានមូលហេតុ ឬមានមូលហេតុមិនសមស្រប។

៤-ប្រធានត្រូវឱ្យភាគីវិវាទក្រោកឈរម្នាក់ម្តងៗដើម្បីបង្ហាញអំពីអត្តសញ្ញាណ ហើយត្រូវសួរទៅដើមបណ្តឹងថា (តើលោក ឬលោកស្រីនៅតែបន្តប្តឹងដូចមានចែងក្នុងកម្មវត្ថុនៃពាក្យបណ្តឹងខាងលើ ឬមានការកែប្រែឬទេ?) ប្រសិនបើដើមបណ្តឹងនៅតែបន្តប្តឹង ប្រធានសវនាការត្រូវបន្តដំណើរការសវនាការ។

៥-ប្រធានសួរទៅកាន់ភាគីវិវាទថា តើពួកគេមានអ្នកការពារក្តីដែរឬទេ? បើមាន ប្រធានត្រូវឱ្យអ្នកការពារក្តីនោះក្រោកឈរឡើង ហើយបង្ហាញអំពីអត្តសញ្ញាណរបស់ខ្លួន។

៦-ប្រធានសួរទៅកាន់ភាគីវិវាទថា តើពួកគេមានសាក្សីដែរឬទេ? តើមានសាក្សីផ្សេងទៀតដែរឬទេ? បន្ទាប់មកប្រធានត្រូវឱ្យសាក្សីទាំងអស់ក្រោកឈរឡើងដើម្បីបង្ហាញអំពីអត្តសញ្ញាណ។

៧-ប្រធានសួរទៅលេខាធិការសវនាការថា តើសាក្សីទាំងអស់ដែលមានវត្តមាននេះបានធ្វើការស្បថស្បែរហើយឬនៅ? បើមិនទាន់បានស្បថទេ លេខាធិការសវនាការត្រូវនាំសាក្សីទាំងនោះទៅស្បថ?

៨-ប្រធានសួរទៅកាន់ភាគីវិវាទថាតើមានវត្ថុតាង ឬឯកសារ ដើម្បីផ្តល់ជាភស្តុតាងបន្ថែមផ្សេងទៀត ជូនសវនាការដែរឬទេ? ប្រធានត្រូវឱ្យភាគីវិវាទបង្ហាញឯកសារ និងវត្ថុតាងទាំងនោះភ្លាម ប្រសិនបើមាន។ បើភស្តុតាងទាំងនោះទាក់ទងទៅនឹងករណីវិវាទពិតប្រាកដ ប្រធានត្រូវឱ្យលេខាធិការសវនាការថតចម្លងជាបន្ទាន់ដើម្បីបញ្ចូលក្នុងសំណុំរឿងវិវាទ។

៩-ប្រធានត្រូវប្រកាសប្រាប់ឱ្យសាក្សីទាំងអស់ថយទៅបន្ទប់រង់ចាំ ឬនៅកន្លែងណាមួយជិតនោះ ប៉ុន្តែមិនអាចស្តាប់ ឮការជជែកដេញដោលក្នុងសវនាការបានឡើយ។

១០-ប្រធានបង្គាប់ឱ្យលេខាធិការសវនាការអានរបាយការណ៍សង្ខេបអំពីករណីវិវាទ។ ខ្លឹមសាររបាយការណ៍មានជាអាទិ៍ ប្រវត្តិករណីដីទំនាស់ ការរកឃើញរបស់អ្នកស៊ើបអង្កេត ជំហរ និងអាកប្បកិរិយារបស់ភាគីវិវាទនៅពេលសម្រុះសម្រួល និងសេចក្តីសន្និដ្ឋានរបស់អ្នកសម្រុះសម្រួល។

១១-ប្រធានបង្គាប់ជាបន្តបន្ទាប់ឱ្យភាគីដើមបណ្តឹង ឬតំណាង និងភាគីចុងបណ្តឹង ឬតំណាង ហើយភាគីវិវាទ ឬតំណាងអាចតាំងសំណួរទៅភាគីវិវាទម្ខាងទៀត ឬតំណាងតាមរយៈប្រធានសវនាការ។

១២-ប្រធាន និង/ឬសមាជិកអាចសួរសាក្សីរបស់ភាគីដើមបណ្តឹង និងសាក្សីរបស់ភាគីចុងបណ្តឹងឱ្យបំភ្លឺនូវចំណុចមួយចំនួនដែលពាក់ព័ន្ធ ហើយភាគីវិវាទ ឬតំណាងអាចតាំងសំណួរទៅសាក្សីរបស់ភាគីវិវាទម្ខាងទៀតតាមរយៈប្រធានសវនាការ។

១៣-សាក្សីដែលឆ្លើយរួចហើយអាចអង្គុយក្នុងបន្ទប់សវនាការ ឬអាចចាកចេញពីបន្ទប់សវនាការបាន។

១៤-ប្រធានត្រូវសួរបញ្ជាក់ថាតើនៅមានសាក្សីណាដែលមិនទាន់ត្រូវបានអញ្ជើញមកបំភ្លឺដែរឬទេ?

១៥-នៅពេលដែលភាគីវិវាទ ឬតំណាង និងសាក្សីបញ្ចប់សក្ខីកម្ម ប្រធានបង្គាប់ឱ្យភាគីវិវាទ ឬតំណាងបង្ហាញអំពីជំហររបស់ភាគីវិវាទចំពោះករណីវិវាទ។

១៦-ក្រោយពីបានដំណើរការតាមលំដាប់រួចហើយ ប្រធាន និងសមាជិក (ករណីសវនាការធ្វើជាក្រុម) ឬប្រធាន (ករណីសវនាការធ្វើឡើងដោយប្រធាន ឬសមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ ឬមន្ត្រីសវនាការតែម្នាក់) ត្រូវថយទៅពិចារណាករណីនោះនៅបន្ទប់ដែលបានរៀបចំដោយឡែក។

១៧-ក្រោយពេលពិចារណា ប្រធានត្រូវធ្វើការប្រកាសថា៖

-សវនាការនឹងធ្វើការសម្រេចលើករណីវិវាទនាពេលនេះតែម្តង ឬ

-សវនាការមិនអាចធ្វើការសម្រេចលើករណីវិវាទ នាពេលនេះបានឡើយដោយហេតុថា ប្រធានសវនាការត្រូវការពេលវេលាបន្ថែមទៀតដើម្បីពិចារណា។ សេចក្ដីសម្រេចនឹងត្រូវផ្ញើជូនភាគីវិវាទនៅពេលក្រោយ។ ភាគីវិវាទមានសិទ្ធិប្ដឹងទៅតុលាការក្នុងករណីដែលពុំសុខចិត្តនឹងការសម្រេច ឬអាចស្នើសុំធ្វើសវនាការសាជាថ្មីនៅពេលដែលភាគីវិវាទមានភស្តុតាងថ្មីធំដាក់ជូនមកគណៈកម្មការសុរិយោដីថ្នាក់ជាតិ ក្នុងរយៈពេល៣០ថ្ងៃ ចាប់ពីថ្ងៃដែលបានទទួលសេចក្ដីសម្រេចនេះ ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរទៅលេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ។

១៨-ការធ្វើសវនាការឡើងវិញត្រូវអនុវត្តនីតិវិធីសវនាការដូចពេលមុនដែរ។ ប្រសិនបើគណៈកម្មការសុរិយោដីថ្នាក់ជាតិបដិសេធចំពោះសំណើសុំឱ្យមានសវនាការឡើងវិញនោះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបដិសេធដល់ភាគីវិវាទ។ នៅក្នុងករណីនេះ សេចក្ដីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិនឹងក្លាយជាស្ថាពរក្រោយរយៈពេល៣០ថ្ងៃ បន្ទាប់ពីសេចក្ដីជូនដំណឹងពីការបដិសេធត្រូវបានបញ្ជូនដល់ភាគីវិវាទ លើកលែងតែភាគីម្ខាងនៃភាគីវិវាទជូនដំណឹងអំពីការប្ដឹងជំទាស់ទៅតុលាការ ក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីបានទទួលសេចក្ដីជូនដំណឹងពីការបដិសេធសំណើនោះ។

១៩-ប្រធានធ្វើការពន្យល់ទៀតថា នៅពេលដែលសេចក្ដីសម្រេចនោះចូលជាស្ថាពរហើយ គណៈកម្មការសុរិយោដីថ្នាក់ជាតិនឹងផ្ញើសេចក្ដីសម្រេចនោះទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង ដើម្បីចាត់ការតាមនីតិវិធីនៃការចុះបញ្ជីសុរិយោដី។

២០-នៅចុងបញ្ចប់នៃសវនាការប្រធានត្រូវប្រកាសថា "បិទសវនាការ"។

## VI-**របៀបនៃការធ្វើសេចក្ដីសម្រេច**

១-សេចក្ដីសម្រេចទៅលើករណីវិវាទណាមួយរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវសម្រេចដោយ៖

-ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិតែ១រូប

-ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ និងសមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ ១រូប ហើយសេចក្ដីសម្រេចត្រូវធ្វើឡើងដោយសំឡេងជាឯកច្ឆ័ន្ទ។ ក្នុងករណីមិនឯកភាពគ្នា ប្រធានមានឧត្តមភាព។

-ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ និងសមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ ២រូបហើយសេចក្ដីសម្រេចត្រូវធ្វើឡើងដោយសំឡេងភាគច្រើន។ ក្នុងករណីមិនអាចរកសំឡេងភាគច្រើនបាន ប្រធានមានឧត្ដមភាព។

២-សេចក្ដីសម្រេចទាំងអស់ត្រូវធ្វើតាមទម្រង់បែបបទរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ។

**VII-របៀបនៃការសម្រេចក្នុងការធ្វើសវនាការឡើងវិញ**

១-សំណើសុំឱ្យមានសវនាការឡើងវិញត្រូវធ្វើជាលាយលក្ខណ៍អក្សរក្នុងកំលុងពេល៣០ថ្ងៃ បន្ទាប់ពីភាគីវិវាទបានទទួលសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សររបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ។ សំណើសុំឱ្យមានសវនាការឡើងវិញត្រូវបញ្ជាក់ពីមូលហេតុច្បាស់លាស់នូវព័ត៌មាន ភស្ដុតាងថ្មីធំដុំ និងគំនូសតាងចាំបាច់នានា។

២-ការធ្វើសវនាការឡើងវិញពុំអាចធ្វើបានទេ លើកលែងតែមានសំឡេងយល់ព្រមពីសមាជិកទាំងអស់នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ នៅពេលដែលភស្ដុតាងថ្មីធំដុំត្រូវបានដាក់ជូនគណៈកម្មការសុរិយោដីថ្នាក់ជាតិ។

៣-ការធ្វើសវនាការឡើងវិញត្រូវអនុលោមទៅតាមសេចក្ដីជូនដំណឹង និងល័ក្ខខ័ណ្ឌតម្រូវផ្នែកនីតិវិធីដូចសវនាការដើមដែរ។

៤-ក្នុងករណីបណ្ដឹងសុំធ្វើសវនាការឡើងវិញត្រូវបានបដិសេធ នោះគណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវជូនដំណឹងដល់ភាគីវិវាទជាលាយលក្ខណ៍អក្សរពីមូលហេតុនៃការបដិសេធនេះ។ នៅក្នុងករណីនេះ សេចក្ដីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិនឹងក្លាយជាស្ថាពរក្រោយបញ្ចប់រយៈពេល៣០ថ្ងៃ បន្ទាប់ពីសេចក្ដីជូនដំណឹងពីការបដិសេធត្រូវបានបញ្ជូនដល់ភាគីវិវាទ លើកលែងតែភាគីម្ខាងនៃភាគីវិវាទជូនដំណឹងអំពីការប្ដឹងជំទាស់ទៅតុលាការក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីបានទទួលសេចក្ដីជូនដំណឹងពីការបដិសេធចំពោះសំណើនោះ។

**VIII-បណ្ដឹងជំទាស់ទៅតុលាការ**

១-ភាគីវិវាទណាក៏ដោយអាចប្ដឹងទៅតុលាការដោយរួមគ្នា ឬជាបុគ្គលអំពីសេចក្ដីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ។ បណ្ដឹងជំទាស់ត្រូវដាក់ជូនទៅតុលាការ ក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សររបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវបាន

បញ្ជូនដល់ភាគីវិវាទ។ ភាគីវិវាទណាមួយដែលធ្វើបណ្ដឹងទៅតុលាការត្រូវដាក់តម្កល់ឯកសារថតចម្លងមួយច្បាប់នៃបណ្ដឹងជំទាស់នៅលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីភាគីនោះបានទទួលសេចក្ដីសម្រេចពីគណៈកម្មការសុរិយោដីថ្នាក់ជាតិ។

២-លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវធ្វើសេចក្ដីបញ្ជាក់ជាបន្ទាន់នូវរបាយការណ៍ផ្លូវការ ដើម្បីបញ្ជូនទៅតុលាការ។

៣-ក្នុងករណីតុលាការបញ្ជូនករណីវិវាទមកគណៈកម្មការសុរិយោដីថ្នាក់ជាតិវិញ ដោយហេតុថាគណៈកម្មការសុរិយោដីមិនបានអនុវត្តតាមនីតិវិធីសមស្រប ឬដោយមានវិវាទផលប្រយោជន៍ ឬដោយមិនបានផ្ដល់ហេតុផលសមរម្យ ឬដោយអនុវត្តហួសពីសមត្ថកិច្ចរបស់ខ្លួន នោះគណៈកម្មការសុរិយោដីត្រូវចាត់វិធានការអនុវត្តតាមសំណូមពររបស់តុលាការ។

**IX-បទបញ្ជាផ្ទៃក្នុងពេលសវនាការ**

ដើម្បីរក្សាសណ្ដាប់ធ្នាប់ របៀបរៀបរយ សុវត្ថិភាព និងសន្តិសុខក្នុងបន្ទប់សវនាការ ជនគ្រប់រូបដែលមានវត្តមានក្នុងបន្ទប់សវនាការត្រូវគោរព និងអនុវត្តបទបញ្ជាដូចតទៅ៖

១-ហាមជក់បារីក្នុងបន្ទប់សវនាការ ឬកន្លែងប្រជុំសម្រេច

២-ហាមបង្កភាពអនាធិបតេយ្យក្នុងបន្ទប់សវនាការ ឬកន្លែងប្រជុំសម្រេចដូចជា

-ការដើរឆ្លងការត់ ឬដើរចេញ-ចូលរហេតុរហូត ដោយគ្មានការអនុញ្ញាត

-ការជជែកគ្នាខ្លាំងៗ ឬស្រែកឡូឡា ឬបង្កសំឡេងរំខានផ្សេងៗមានសំឡេងទូរស័ព្ទ ឬសំឡេងឧបករណ៍ផ្សេងៗជាដើម។

៣-ហាមយកក្មេងអាយុក្រោម១៨ឆ្នាំ ចូលក្នុងបន្ទប់សវនាការ លើងលែងមានការអនុញ្ញាតជាមុនពីប្រធានសវនាការ។

៤-ហាមថតរូប និងអាត់សំឡេង លើងលែងតែមានការអនុញ្ញាតពីប្រធានសវនាការ។

ជនណាមិនគោរពបទបញ្ជានេះ ឬបង្កភាពវឹកវរក្នុងពេលសវនាការត្រូវទទួលទោសតាមច្បាប់ជាធរមាន។

**X-នីតិវិធី និងខ្លឹមសារនៃសម្បថ**

ភាគី និងសាក្សីត្រូវធ្វើសម្បថ និងឆ្លើយបំភ្លឺជូនប្រធានសវនាការ។ ក្នុងករណីភាគី និងសាក្សីឆ្លើយកុហក ឬបំផ្លើសពីការពិតនឹងត្រូវផ្តន្ទាទោសតាមច្បាប់។

នីតិវិធីនៃការធ្វើសម្បថ និងខ្លឹមសារនៃសម្បថមានដូចខាងក្រោម៖

១-<u>នីតិវិធីនៃសម្បថ</u>

-សម្បថរបស់ភាគី និងសាក្សីត្រូវធ្វើមុនពេលសាកសួរ ឬការឆ្លើយបំភ្លឺ។

-មុនពេលធ្វើសម្បថ លេខាធិការសវនាការត្រូវពន្យល់អំពីគោលការណ៍នៃសម្បថ និងប្រាប់ឱ្យដឹងជាមុនអំពីទុក្ខទោសនៃការក្លែងបន្លំពាក្យសម្បថ។

-នៅពេលធ្វើសម្បថ ភាគី និងសាក្សីត្រូវក្រោកឈរឡើង ហើយត្រូវធ្វើការស្ងិងស្ងាធំ

-លេខាធិការសវនាការត្រូវឱ្យភាគី និងសាក្សីអានលិខិតសម្បថ ហើយត្រូវឱ្យចុះហត្ថលេខាលើលិខិតនោះផង។ នៅពេលដែលភាគី និងសាក្សីមិនអាចអានលិខិតសម្បថបានទេ លេខាធិការសវនាការត្រូវអានសម្បថនោះ រួចឱ្យភាគី និងសាក្សីថាតាម បន្ទាប់មកឱ្យភាគី និងសាក្សីផ្តិតមេដៃលើលិខិតសម្បថនេះ។

២-<u>ខ្លឹមសារនៃពាក្យសម្បថ</u>

ពាក្យសម្បថត្រូវមានខ្លឹមសារដូចខាងក្រោម៖

**សម្បថ**

យើងទាំងអស់គ្នាសូមស្បថចំពោះមុខព្រះអង្គដងកើ លោកយាយទេពដងកើ ទេព្តាថែរក្សាព្រះមហាស្វេតច្ឆ័ត្រ លោកមេទ័ពសេះសរក្សាក្នុងរាជវាំង ព្រះអង្គវិហារសួគ៌ ព្រះអង្គគោកធ្លក ព្រះនាងចេក ព្រះនាងចម សូមលោកអញ្ជើញលោកតាព្រះចៅ លោកតាដំបងក្រញូង លោកតាក្រហមក លោកតាក្បាលប្រាំបីរក្សាក្បាលជ្រោយ បើយើងខ្ញុំសច្ចានេះមិនស្មោះត្រង់ មានចិត្តវៀចវេរ សូមឱ្យព្រះអង្គដាក់ទោសតាមពាក្យសម្បថដូចខាងក្រោម

-បើយើងខ្ញុំនៅផ្ទះឱ្យធ្លាក់ពីលើផ្ទះ ឬរអិលដួលស្លាប់ប្រាំបីរយជាតិ បើយើងខ្ញុំជិះទូកកប៉ាល់ សូមឱ្យធ្លាក់ទឹកលង់ស្លាប់ប្រាំបីរយជាតិ បើយើងខ្ញុំស្លាប់ទៅជាខ្មោច សូមឱ្យស៊ីខ្ទុះឈាម ឬហែលនៅក្នុងខ្ទះភ្លើងប្រាំបីរយជាតិ បើកើតមកជាមនុស្ស សូមឱ្យជួបតែក្រខ្វះខាតគ្រប់ប្រាំបីរយជាតិ និងសូមឱ្យបារមីគ្រប់ព្រះអង្គបរាមុខ និងវាយបំបាក់កគ្រប់ប្រាំបីរយជាតិ។

*វាយឡើងវិញ*

-បើយើងខ្ញុំមានការទៀងត្រង់ សូមវត្ថុសក្តិសិទ្ធិគ្រប់ទិសទី និងទេព្តារក្សាទិសទាំងប្រាំបី ជួយឱ្យយើងខ្ញុំទាំងអស់ជួបតែសេចក្តីសុខគ្រប់ប្រការ បើខ្ញុំស្លាប់ពីជាតិនេះ អន្ទោលទៅកើតក្នុងភព ធំ ឬភពតូចណាក្តី សូមបានជួបព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ មានបញ្ញាស្មារតីឆ្លាតវៃ កុំឱ្យស្គាល់សេចក្តី ក្រលំបាក ជំងឺដង្កាត់ជារៀងរាល់ជាតិ រហូតដល់បានសម្រេចព្រះនិព្វានជាឋានបរមសុខនោះហោង ។

យើងខ្ញុំសូមស្បថថានឹងបរិយាយការពិត ដោយយោលទៅតាមមនសិការ មិនលាក់រឿង អ្វីទាំងអស់ និងមិនបន្ថែមបន្ថយរឿងអ្វីឡើយ ។

ដោយករណីនេះ ជានីតិវិធីថ្មីដំបូងពុំធ្លាប់បានអនុវត្តកន្លងមកនោះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់អាចធ្វើការកែសម្រួលក្នុងពេលអនុវត្ត ឬអាចអនុវត្តដោយពុំតម្រូវតាម នីតិវិធីមួយចំនួនជាបណ្តោះអាសន្ន និងជំនួសដោយនីតិវិធីដែលពុំមានចែង តែជាការចាំបាច់ដើម្បី ចៀសវាងការកកស្ទះការងារ ។ សេចក្តីណែនាំនេះអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៥

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ហត្ថលេខា និងត្រា**

**អ៊ឹម ឈុនលឹម**

កន្លែងទទួល

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័ន

-គ្រប់សាលាខេត្ត-ក្រុង

-គ្រប់គណៈកម្មការសុរិយោដីខេត្ត-ក្រុង

-អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ

-មន្ទីរដនសស. ខេត្ត-ក្រុង

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**លេខ០១ជនស/អកគដ/សរណន**

## សារាចរណែនាំ
## ស្តីពីការចុះបញ្ជីអគារ និងក្បាលដីសហកម្មសិទ្ធិ

អនុលោមតាមអនុក្រឹត្យលេខ៤៦អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី និងអនុក្រឹត្យលេខ៤៨អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់សូមធ្វើការណែនាំដូចតទៅ៖

**១.វិសាលភាពនៃការអនុវត្ត**

សារាចរណែនាំនេះ អនុវត្តសម្រាប់ការចុះបញ្ជីអគារ និងក្បាលដីសហកម្មសិទ្ធិ តាមនីតិវិធីនៃការចុះបញ្ជីដីធ្លីដែលមានចែងក្នុងអនុក្រឹត្យលេខ៤៦អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី និងអនុក្រឹត្យលេខ៤៨អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ។

សារាចរណែនាំនេះមានវិសាលភាពគ្រប់ដណ្តប់លើ៖

-ក្បាលដី និងអគារដែលមានតែជាន់ផ្ទាល់ដី ហើយមានកម្មសិទ្ធិករច្រើន បែងចែកជាចំណែកឯកជន

-ក្បាលដី និងអគារច្រើនជាន់ដែលមានជណ្តើររួម ទីធ្លារួម និងផ្លូវរួមនាំទៅដល់ចំណែកឯកជននានា

-ក្បាលដីដែលមានអគារច្រើនជាន់ដាច់ៗពីគ្នា និងមានកម្មសិទ្ធិករជាច្រើនបានរស់នៅទីនោះ។

-ក្បាលដី និងអគារដែលពីមុនមានម្ចាស់តែមួយ តែក្រោយមកមានការលក់ចំណែកមួយ ឬចំណែកច្រើនទៅឱ្យភាគីផ្សេងទៀត។

**២.និយមន័យពាក្យសំខាន់ៗទាក់ទងនឹងសហកម្មសិទ្ធិ**

ពាក្យទាំងឡាយខាងក្រោមនេះមានន័យដូចតទៅ៖

-"អគារសហកម្មសិទ្ធិ" សំដៅដល់អគារគ្រប់ប្រភេទដូចជាភូមិគ្រឹះ ពាក់កណ្តាលភូមិគ្រឹះ ផ្ទះល្វែង ឬផ្ទះប្រភេទផ្សេងទៀតដែលមានរចនាសម្ព័ន្ធជាប់គ្នា ដូចជាគ្រឹះក្រោមដីជាប់គ្នា ធ្នឹមជាប់គ្នា លូបង្ហូរទឹករួមគ្នា ជញ្ជាំងរួម ជណ្តើររួម រានហាល និងទែរ៉ាស់រួម ហើយមានកម្មសិទ្ធិករច្រើន។

-"ចំណែកឯកជន" សំដៅដល់ចំណែកនៃអគារ និងដីដែលឋិតក្រោមការកាន់កាប់ និងប្រើប្រាស់ជាឯកជន។

**៣.ចំណែកឯកជន**

សហកម្មសិទ្ធិករនីមួយៗមានសិទ្ធិជាកម្មសិទ្ធិឯកជនលើចំណែករបស់ខ្លួន លើកលែងតែមានការកម្រិតល័ក្ខខ័ណ្ឌដោយច្បាប់ ឬដោយបទប្បញ្ញត្តិផ្សេងទៀត។

ចំណែកឯកជនត្រូវបានកំណត់ទៅតាមការព្រមព្រៀងគ្នារវាងកម្មសិទ្ធិករពាក់ព័ន្ធ បើការព្រមព្រៀងមិនផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ។

**៤.ការកំណត់ព្រំខណ្ឌចំណែកឯកជន**

ការវាស់វែងដើម្បីកំណត់ព្រំខណ្ឌនៃចំណែកឯកជននានា ត្រូវគិតដល់ខ្សែបន្ទាត់កណ្តាលនៃជញ្ជាំងដែលខណ្ឌចែកចំណែកនីមួយៗ។

**៥.អំពីយ៉**

យ៉ដែលជាប់ជាមួយនឹងចំណែកឯកជន និងបានប្រើប្រាស់ជាឯកជនត្រូវចាត់ទុកជាចំណែកឯកជន ប្រសិនបើយ៉នោះមិនប៉ះពាល់ដល់ការប្រើប្រាស់នៃចំណែកឯកជនផ្សេងទៀតទេ។

**៦.ការរៀបចំឯកសារសម្រាប់ការចុះបញ្ជី**

ឯកសារដែលត្រូវរៀបចំសម្រាប់ការចុះបញ្ជីមានដូចតទៅ៖

-ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី

-ផែនទីក្បាលដីដែលមានបន្ថែមទិន្នន័យលើសពីផែនទីក្បាលដីធម្មតា រួមមាន៖

+គំនូសប្លង់អគារ និង

+ចំណែកឯកជនដែលមានលេខយោង

-បញ្ជីឈ្មោះកម្មសិទ្ធិករនៃចំណែកឯកជននីមួយៗ និង

-ទម្រង់បែបបទនៃការប្រមូលទិន្នន័យដោយឡែកសម្រាប់ចំណែកឯកជន

-ប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី។

ក្នុងការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី និងផែនទីក្បាលដីដែលមានគំនូសប្លង់អគារ ត្រូវបានរៀបចំសម្រាប់ការចុះបញ្ជីចំណែកឯកជនលើកដំបូង។ ឯកសារនេះនឹងត្រូវបានបំពេញគ្រប់សព្វនៅពេលដែលចំណែកឯកជនទាំងអស់ត្រូវបានចុះបញ្ជី។

**៧-ការចុះបញ្ជី**

ចំណែកឯកជននីមួយៗនឹងត្រូវបានចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លីមួយដោយឡែកអំពីសៀវភៅគោលបញ្ជីធម្មតា ដោយមានបញ្ជាក់ឈ្មោះកម្មសិទ្ធិករ ទំហំ ទីតាំង និងប្រភេទនៃចំណែកឯកជន។ ក្បាលដីដែលអគារសហកម្មសិទ្ធិតាំងនៅ ត្រូវចុះបញ្ជីជាក្បាលដីសហកម្មសិទ្ធិនៅក្នុងសៀវភៅគោលបញ្ជីធម្មតា។

**៨-ទិន្នន័យគោលសុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី**

ព័ត៌មានអំពីអគារ និងក្បាលដីសហកម្មសិទ្ធិត្រូវបានកត់ត្រាក្នុងទិន្នន័យគោលសុរិយោដី និងក្នុងសៀវភៅគោលបញ្ជីដីធ្លី។

ក-នៅក្នុងទិន្នន័យគោលសុរិយោដី ត្រូវកត់ត្រា៖

-ទិន្នន័យបានមកពីទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី និងទិន្នន័យចំណែកឯកជន

-ផែនទីក្បាលដី

-គំនូសប្លង់អគារមានភ្ជាប់លេខយោងទៅរកចំណែកឯកជន ទីតាំង និងទំហំ

ខ-នៅក្នុងសៀវភៅគោលបញ្ជីដីដែលនឹងត្រូវរៀបចំជាពីរសៀវភៅ ត្រូវកត់ត្រា៖

-ទិន្នន័យទូទៅទាក់ទងនឹងក្បាលដី នៅក្នុងសៀវភៅគោលបញ្ជីដីធម្មតា ដោយមានយោងទៅរកទំព័របន្ថែមនៃសៀវភៅគោលបញ្ជី សម្រាប់ចំណែកឯកជន និង

-ព័ត៌មានលំអិតអំពីចំណែកឯកជន និងម្ចាស់កម្មសិទ្ធិ នៅក្នុងសៀវភៅគោលបញ្ជីមួយដោយឡែកក្រៅពីសៀវភៅគោលបញ្ជីធម្មតា។

**៩-ការចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ**

-ក្នុងតំបន់ដែលអនុវត្តការចុះបញ្ជីតាមលក្ខណៈជាប្រព័ន្ធ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនទ្រព្យ នឹងត្រូវចេញឱ្យកម្មសិទ្ធិករនៃចំណែកឯកជននីមួយៗ ជំនួសឱ្យវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលើផ្ទះសំបែងដែលសាលាខេត្ត-ក្រុងបានចេញឱ្យ នៅមុនពេលដែលការចុះបញ្ជីតាមលក្ខណៈជាប្រព័ន្ធមិនទាន់បានអនុវត្ត។ វិញ្ញាបនបត្រទាំងនោះត្រូវអស់សុពលភាពប្រើប្រាស់ ហើយត្រូវបានប្រមូលរក្សាទុកនៅអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

-អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រត្រូវរៀបចំគំរូឯកសារមួយចំនួន ធ្វើជាឧបសម្ព័ន្ធនៃសារាចរណែនាំនេះ ដែលរួមមាន៖

+គំរូប័ណ្ណ (វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ) សម្រាប់ក្បាលដីសហកម្មសិទ្ធិ

+គំរូប័ណ្ណ (វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ) សម្រាប់ចំណែកឯកជន

+សៀវភៅគោលបញ្ជីដោយឡែកពីសៀវភៅគោលបញ្ជីធម្មតា សម្រាប់ចុះបញ្ជីតែចំណែកឯកជននៃសហកម្មសិទ្ធិ

+គំរូឯកសារដូចមានចែងក្នុងចំណុច៦។

សារាចរណែនាំនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៥

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ហត្ថលេខា និងត្រា**

**អ៊ឹម ឈុនលឹម**

<u>ចម្លងជូន</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-គ្រប់សាលាខេត្ត-ក្រុង
"ដើម្បីជូនជ្រាប"
-គ្រប់អង្គភាពក្រោមឱវាទក្រសួង ដនស
-គ្រប់មន្ទីរ ដនសស ខេត្ត-ក្រុង
"ដើម្បីជ្រាប និងអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ១១៨អនក្រ/បក

**អនុក្រឹត្យ**
**ស្តីពីការគ្រប់គ្រងដីរដ្ឋ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០១/នស/៩៣[8] ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/ករម/០២៩៨/០៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់

---

[8] ឯកសារផ្លូវការត្រូវបានសរសេរ "០១/នស/០៣"។

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤[9] ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ៨៨អនក្រ/បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ៤៦អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ៤៨អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ
- បានឃើញអនុក្រឹត្យលេខ១៩អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ៥៣អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីនីតិវិធីការបង្កើត ការចាត់ថ្នាក់ និងការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ២០០៥

## សម្រេច

## ជំពូកទី១ បទប្បញ្ញត្តិទូទៅ

**មាត្រា១**

អនុក្រឹត្យនេះមានគោលដៅកំណត់គោលការណ៍ នីតិវិធី យន្តការ និងការរៀបចំផ្នែកស្ថាបនាសម្រាប់ការគ្រប់គ្រងដីរដ្ឋ លើ៖

-ការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ

---

[9] ឯកសារផ្លូវការត្រូវបានសរសេរ "នស/រកម/០៨០១/០៥"។

-ការចុះបញ្ជី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ

-ការបង្កើត និងការថែរក្សាប្រព័ន្ធទិន្នន័យដីរដ្ឋ

-ការបែងចែក និងការគ្រប់គ្រងដីរដ្ឋ និង

-ការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ ។

**មាត្រា២**

ពាក្យបច្ចេកទេសទាំងឡាយខាងក្រោមនេះមានន័យដូចតទៅ៖

-"ដីរដ្ឋ" សំដៅដល់ដីទាំងអស់ដែលជារបស់រដ្ឋ ហើយដែលឋិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង ឬស្ថាប័នថ្នាក់ជាតិ និងដីដែលត្រូវបានប្រគល់ឱ្យនីតិបុគ្គលសាធារណៈ ឬគ្រឹះស្ថានសាធារណៈដែលបានទទួលស្គាល់ដោយច្បាប់ថាជានីតិបុគ្គលដើម្បីកាន់កាប់ ។

-"អាជ្ញាធរដែនដី" សំដៅដល់រដ្ឋបាលខេត្ត-ក្រុង ស្រុក-ខណ្ឌ និងឃុំ-សង្កាត់ ។

-"អាជ្ញាធរកាន់កាប់ដីរដ្ឋ" សំដៅដល់ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលរដ្ឋបានប្រគល់ដីរដ្ឋណាមួយជាក់លាក់សម្រាប់គ្រប់គ្រង ថែរក្សា ការពារ និងប្រើប្រាស់បម្រើឱ្យស្ថាប័ន ។

-"ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ" សំដៅដល់ក្រុមការងារធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋតាមស្រុក-ខណ្ឌ ។

**មាត្រា៣**

គោលការណ៍ទូទៅសម្រាប់អនុវត្តក្នុងការគ្រប់គ្រងដីរដ្ឋមានដូចខាងក្រោម៖

ក-ជាទូទៅ រដ្ឋគឺជាម្ចាស់នៃដីទាំងអស់ដែលមិនឋិតនៅក្រោមការកាន់កាប់ជាភោគៈស្របច្បាប់ ឬជាកម្មសិទ្ធិ ដោយបុគ្គលឯកជន ឬដោយសមូហភាពស្របតាមច្បាប់ភូមិបាលឆ្នាំ ២០០១ ។

ខ-ដីរដ្ឋរួមមានដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ ។

គ-ក្បាលដីរដ្ឋនីមួយៗត្រូវចុះបញ្ជីជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ។

ឃ-ដីរដ្ឋអាចផ្តល់ឱ្យជាសម្បទានដីសង្គមកិច្ច ជាសម្បទានដីសេដ្ឋកិច្ច ឬជាសម្បទានផ្សេងៗទៀតបានលុះត្រាតែដីនោះត្រូវបានចុះបញ្ជីថាជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ និងត្រូវអនុវត្តតាមនីតិវិធីច្បាប់ ។

មាត្រា៤

ដីសាធារណៈរបស់រដ្ឋជាដីដែលមានជាប់ផលប្រយោជន៍សាធារណៈ និងឋិតនៅក្នុងប្រភេទជាក់លាក់នៃទ្រព្យដែលមានផលប្រយោជន៍សាធារណៈដូចខាងក្រោម៖

ក-ទ្រព្យទាំងឡាយដែលបង្ហាញការកើតឡើងពីធម្មជាតិ ដូចជា៖

១-ព្រៃឈើ ។

២-ផ្លូវទឹកដែលនាវា ឬក្បូនអាចចេញចូលបាន បណ្តែតបាន ។

៣-បឹងធម្មជាតិ ។

៤-ច្រាំងទន្លេដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបាន ។

៥-ត្រើយសមុទ្រ ។

ខ-ទ្រព្យទាំងឡាយដែលជាកម្មវត្ថុនៃការរៀបចំពិសេសសម្រាប់ប្រយោជន៍សាធារណៈទូទៅ ដូចជា៖

១-តិរឋាន ។

២-កំពង់ផែ ។

៣-ផ្លូវដែក ។

៤-ស្ថានីយរថភ្លើង ។

៥-ព្រលានយន្តហោះ ។

គ-ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈ តាមស្ថានភាពពីកំណើត ឬក្រោយពីបានរៀបចំ ដូចជា៖

១-ផ្លូវថ្នល់ ។

២-ផ្លូវលំ ។

៣-ផ្លូវរទេះ ។

៤-ផ្លូវដើរ ។

៥-សួនច្បារ ឧទ្យានសាធារណៈ ។

៦-ដីចំណី ។

ឃ-ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យដំណើរការសម្រាប់សេវាសាធារណៈ ដូចជា៖

១-សាលារៀន ឬអគារសិក្សាសាធារណៈ ។

២-អគាររដ្ឋបាល ។

៣-មន្ទីរពេទ្យសាធារណៈ ។

ង-ដែនបម្រុងធម្មជាតិការពារដោយច្បាប់ ។

ច-បេតិកភណ្ឌបុរាណវិទ្យា វប្បធម៌ និងប្រវត្តិសាស្ត្រ ។

ឆ-អចលនវត្ថុជាព្រះរាជទ្រព្យដែលមិនមែនជាទ្រព្យសម្បត្តិឯកជនរបស់ព្រះរាជវង្សានុវង្ស ។

ជ-ដីផ្សេងៗទៀតដែលមានចរិតបម្រើផលប្រយោជន៍សាធារណៈ និងដីដែលមានមូលដ្ឋានគតិយុត្តកំណត់រួចហើយ ។

**មាត្រា៥**

ដីឯកជនរបស់រដ្ឋរួមមានដីទាំងអស់ដែលមិនមែនជាដីសាធារណៈរបស់រដ្ឋ និងមិនមែនជាដីដែលកាន់កាប់ជាភោគៈស្របច្បាប់ ឬជាកម្មសិទ្ធិដោយបុគ្គលឯកជន ឬដោយសមូហភាពស្របតាមច្បាប់ភូមិបាលឆ្នាំ២០០១ ។ ដីឯកជនរបស់រដ្ឋមានរួមបញ្ចូលដូចជាទ្រព្យនិទាយាទភាពទាំងអស់ ឬទ្រព្យដែលម្ចាស់ប្រគល់ឱ្យរដ្ឋដោយស្ម័គ្រចិត្ត ឬទ្រព្យដែលមិនអាចកំណត់បាននូវអត្តសញ្ញាណភោគី ឬកម្មសិទ្ធិករស្របច្បាប់ ។

**ជំពូកទី២ ការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ**

**មាត្រា៦**

ក-ការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋជាដំណើរការមួយដែលមានលក្ខណៈសម្របសម្រួល និងមានតម្លាភាព ធ្វើឡើងដោយក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ ក្រោមការដឹកនាំរបស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថាក់ខេត្ត-ក្រុង ដើម្បីប្រមូល និងចងក្រងឯកសារដូចខាងក្រោម៖

១-ទីតាំង និងព្រំប្រទល់ប្រហាក់ប្រហែលនឹងដីរដ្ឋ ។

២-ព័ត៌មាននានាដែលមានប្រយោជន៍សម្រាប់ការចុះបញ្ជីដីរដ្ឋថា ជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ ។

៣-ព័ត៌មានអំពីប្រភេទដី និងការប្រើប្រាស់បច្ចុប្បន្ន ប្រសិនបើមាន ។

ខ-ការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ ត្រូវធ្វើឡើងដោយកិច្ចសហការរួមគ្នាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ហើយត្រូវបង្ហាញរាល់ការអះអាងទាំងអស់របស់ក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីនោះទាក់ទងនឹងឋានៈនៃដី និងអាណត្តិកាន់កាប់ ។

គ-តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធមានភារកិច្ចផ្តល់ព័ត៌មាន និងឯកសារទាក់ទងនឹងដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋទាំងអស់ដែលឋិតនៅក្រោមអាណត្តិកាន់កាប់របស់ក្រសួង ស្ថាប័ននោះ ។ អាជ្ញាធរដែនដីមានភារកិច្ចផ្តល់ព័ត៌មានទាក់ទងនឹងដីសាធារណៈរបស់រដ្ឋ ឬដីឯកជនរបស់រដ្ឋទាំងអស់ដែលឋិតនៅក្នុងដែនដីរបស់ខ្លួន ទោះបីដីនោះឋិត ឬមិនឋិតនៅក្រោមអាណត្តិកាន់កាប់របស់ខ្លួនក៏ដោយ ។

ឃ-តំណាងរបស់ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីណាមួយដែលអះអាងអំពីអាណត្តិកាន់កាប់លើក្បាលដីណាមួយជាក់លាក់របស់រដ្ឋ ឬអះអាងថាជាដីសាធារណៈរបស់រដ្ឋ ត្រូវផ្តល់ព័ត៌មាន និងឯកសារគាំទ្រ ។

ង-រាល់ព័ត៌មានដែលប្រមូលបានពីការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋត្រូវចាត់ទុកជាព័ត៌មានបឋម និងមិនទាន់មានការបញ្ជាក់ច្បាស់លាស់ជាផ្លូវការ រហូតដល់ដីនោះត្រូវបានចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ។

**មាត្រា៧**

ក-ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌត្រូវបំពេញកិច្ចការនៃការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋដោយមានជំនួយបច្ចេកទេសពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ខ-ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌត្រូវប្រមូលព័ត៌មានទាក់ទងនឹងដីរដ្ឋនៅក្នុងឃុំ-សង្កាត់ពីសមាជិកក្រុមការងាររបស់ខ្លួន និងពីតំណាងរបស់រាល់ស្ថាប័នរដ្ឋ និងអាជ្ញាធរដែនដីនៃឃុំ-សង្កាត់នីមួយៗក្នុងស្រុក-ខណ្ឌ ។

គ-ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌត្រូវរៀបចំរបាយការណ៍ការងារ ដែលមានបញ្ចូលព័ត៌មានដូចបានរៀបរាប់ក្នុងមាត្រា៦ ក ផែនទីបង្ហាញពីការអះអាងរបស់តំណាងក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីទាំងអស់ព្រមទាំងសេចក្តីសង្ខេបអំពីមតិសាធារណៈ ។

ឃ-ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌត្រូវរកការឯកភាពគ្នាក្នុងចំណោមក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីទាំងអស់ដែលមានការពាក់ព័ន្ធ ។ ប៉ុន្តែ ប្រសិនបើមិនអាចសម្រេចបាននូវការឯកភាព

មតិគ្នាទេ នោះក្រុមការងារជីវរដ្ឋថ្នាក់ស្រុក-ខណ្ឌត្រូវបញ្ជាក់អំពីការអះអាងដែលមិនស្របគ្នាទាំងឡាយនៅក្នុងរបាយការណ៍ដែលត្រូវដាក់ជូនទៅគណៈកម្មាធិការគ្រប់គ្រងជីវរដ្ឋថ្នាក់ខេត្ត-ក្រុង។

ង-មុននឹងដាក់របាយការណ៍ការងារជូនគណៈកម្មាធិការគ្រប់គ្រងជីវរដ្ឋថ្នាក់ខេត្ត-ក្រុង ក្រុមការងារជីវរដ្ឋថ្នាក់ស្រុក-ខណ្ឌត្រូវធ្វើការបិទផ្សាយជាសាធារណៈរយៈពេល៣០ថ្ងៃ (សាមសិប) ថ្ងៃ នូវសេចក្ដីសង្ខេបអំពីការអះអាងអំពីផែនទីបង្ហាញពីការអះអាង និងសេចក្ដីពន្យល់ច្បាស់លាស់អំពីគោលបំណងនៃការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីជីវរដ្ឋសម្រាប់ឱ្យសាធារណជនចូលរួមផ្ដល់មតិយោបល់ និងត្រូវផ្ដល់ជូនតាមការស្នើសុំនូវសំណៅថតចម្លងនៃឯកសារដែលបានបិទផ្សាយដោយតម្រូវឱ្យបង់ថ្លៃសមស្រប។

ច-ក្រុមការងារជីវរដ្ឋថ្នាក់ស្រុក-ខណ្ឌត្រូវធ្វើការសង្ខេបមតិយោបល់សាធារណៈដែលទទួលបាន ហើយបញ្ចូលសេចក្ដីសង្ខេបនោះទៅក្នុងរបាយការណ៍ការងាររបស់ខ្លួន ដើម្បីដាក់ជូនទៅគណៈកម្មាធិការគ្រប់គ្រងជីវរដ្ឋថ្នាក់ខេត្ត-ក្រុង។

ឆ-ប្រសិនបើមានការអះអាងមិនស្របគ្នា គណៈកម្មាធិការគ្រប់គ្រងជីវរដ្ឋថ្នាក់ខេត្ត-ក្រុង ត្រូវធ្វើការស៊ើបអង្កេតការអះអាងរបស់ស្ថាប័ន ឬអាជ្ញាធរដែនដី តាមការបង្ហាញនៅក្នុងរបាយការណ៍របស់ក្រុមការងារជីវរដ្ឋថ្នាក់ស្រុក-ខណ្ឌ និងត្រូវពិចារណារាល់មតិយោបល់សាធារណៈដែលបានសង្ខេបបញ្ចូលនៅក្នុងរបាយការណ៍នោះ។

ជ-ប្រសិនបើគ្មានការអះអាងដែលមិនស្របគ្នា ឬប្រសិនបើគណៈកម្មាធិការគ្រប់គ្រងជីវរដ្ឋថ្នាក់ខេត្ត-ក្រុងអាចសម្រេចបានការឯកភាពមតិគ្នាលើការអះអាងដែលមិនស្របគ្នានោះ លទ្ធផលនៃការអត្តសញ្ញាណកម្ម និងការធ្វើផែនទីជីវរដ្ឋត្រូវបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យ និងផែនទីជីវរដ្ឋដែលត្រូវបង្កើតឡើងស្របតាមអនុក្រឹត្យនេះ។

ឈ-ប្រសិនបើគណៈកម្មាធិការគ្រប់គ្រងជីវរដ្ឋថ្នាក់ខេត្ត-ក្រុងមិនអាចសម្រេចបានការឯកភាពគ្នាលើការអះអាងដែលមិនស្របគ្នា លទ្ធផលនៃការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីជីវរដ្ឋរួមទាំងព័ត៌មានអំពីការអះអាងដែលមិនស្របគ្នានោះ ត្រូវបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យ និងផែនទីជីវរដ្ឋ។

ញ-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចេញប្រកាសណែនាំលំអិតស្ដីពីការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីជីវរដ្ឋ និងអំពីក្រុមការងារជីវរដ្ឋថ្នាក់ស្រុក-ខណ្ឌ។ ប្រកាស

ណែនាំនេះត្រូវមានបញ្ចូលល័ក្ខខ័ណ្ឌលំអិតសម្រាប់ឱ្យសាធារណជនទូទៅ និងអាជ្ញាធរប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិចបានដឹងឮអំពីការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួន និងផ្តល់ឱកាសគ្រប់គ្រាន់ដល់សាធារណជន និងសហគមន៍ជនជាតិដើមភាគតិចបានផ្តល់ឱកាសគ្រប់គ្រាន់ដល់សាធារណជន និងសហគមន៍ជនជាតិដើមភាគតិចបានចូលរួមផ្តល់មតិយោបល់លើរបាយការណ៍របស់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ។

## ជំពូកទី៣ ការចុះបញ្ជីដីរដ្ឋ

**មាត្រា៨**

ក-ការចុះបញ្ជីដីរដ្ឋត្រូវធ្វើឡើងផ្អែកលើការចុះបញ្ជីដែលមានលក្ខណៈជាប្រព័ន្ធ អនុលោមតាមអនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ឬផ្អែកលើការចុះបញ្ជីដែលមានលក្ខណៈដាច់ដោយដុំ អនុលោមតាមអនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីដាច់ដោយដុំ។

ខ-ដំណើរការចុះបញ្ជីដីរដ្ឋរួមមាន៖

១-ការបញ្ជាក់កម្មសិទ្ធិរបស់រដ្ឋលើដី។

២-ការកំណត់ព្រំប្រទល់ច្បាស់លាស់លើដី។

៣-ការដោះស្រាយទំនាស់ដោយអាជ្ញាធរមានសមត្ថកិច្ច។

៤-ការចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លី។

គ-ប្រសិនបើមានការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋមុនពេលធ្វើការចុះបញ្ជីដី លទ្ធផលនៃការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋនោះមិនមែនជាព័ត៌មានសម្រេចឡើយ តែជាព័ត៌មានបឋមសម្រាប់ប្រើប្រាស់ក្នុងដំណើរការចុះបញ្ជីដីរដ្ឋ។

ឃ-ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលអះអាងថាក្បាលដីរដ្ឋណាមួយជាដីសាធារណៈរបស់រដ្ឋត្រូវផ្តល់ឯកសារ និងភស្តុតាងផ្សេងៗទៀតដែលបង្ហាញថា ដីនោះត្រូវបានរាប់បញ្ចូលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ ដូចមានចែងក្នុងមាត្រា១៥នៃច្បាប់ភូមិបាលឆ្នាំ២០០១។

ង-ក្នុងការចុះបញ្ជីដីលើកដំបូង ដីរដ្ឋដែលមិនបានបង្ហាញឱ្យឃើញថា មានចរិតបម្រើប្រយោជន៍សាធារណៈ ដូចមានចែងក្នុងមាត្រា៤នៃអនុក្រឹត្យនេះ និងមាត្រា១៥នៃច្បាប់ភូមិបាល ត្រូវចុះបញ្ជីជាដីឯកជនរបស់រដ្ឋ។

*វាយឡើងវិញ*

មាត្រា៩

ក-នៅក្នុងការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធលើកដំបូង ដីរដ្ឋនៅក្នុងតំបន់វិនិច្ឆ័យត្រូវបានកំណត់ព្រំប្រទល់ ហើយដីនោះត្រូវបានចុះក្នុងសៀវភៅគោលបញ្ជីដីធ្លីថាជាដីរដ្ឋ។

ខ-ឋានៈជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋត្រូវបានចុះបញ្ជី ប្រសិនបើ

-ការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋត្រូវបានធ្វើចប់មុនការចុះបញ្ជី ដោយគ្មានការអះអាងណាមួយរបស់ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលមិនស្របគ្នា ឬ

-ទោះបីមិនទាន់មានការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋក្តី ប៉ុន្តែមានព័ត៌មានដែលអាចឱ្យធ្វើការសន្និដ្ឋានបានអំពីឋានៈ និងការប្រើប្រាស់បច្ចុប្បន្ននៃដីនោះ ហើយក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីទាំងឡាយក៏មានការឯកភាពមតិគ្នាលើឋានៈនៃដីនោះថា ជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ។

មាត្រា១០

ក-ក្នុងការចុះបញ្ជីដីធ្លីដែលមានលក្ខណៈដាច់ដោយដុំលើកដំបូង ដីរដ្ឋដែលមានព្រំប្រទល់ជាក់លាក់ត្រូវបានចុះបញ្ជីដោយមានឋានៈច្បាស់លាស់ ជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ។

ខ-ត្រូវអនុវត្តនីតិវិធីនៃការធ្វើចំណាត់ថ្នាក់ដីរដ្ឋដែលមានចែងក្នុងជំពូកទី៤ នៃអនុក្រឹត្យនេះ មុននឹងធ្វើការចុះបញ្ជីដីបាន ចំពោះស្ថានភាពដូចខាងក្រោម៖

-ការធ្វើអត្តសញ្ញាណកម្ម និងផែនទីដីរដ្ឋត្រូវបានធ្វើរួច ហើយមានការអះអាងមិនស្របគ្នាពីក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដី ឬ

-ដីដែលគ្មានព័ត៌មានច្បាស់លាស់អំពីឋានៈ និងអំពីការប្រើប្រាស់បច្ចុប្បន្ននៃដីនោះ។

## ជំពូកទី៤ ការធ្វើចំណាត់ថ្នាក់ដីរដ្ឋជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ

មាត្រា១១

នីតិវិធីនៃការធ្វើចំណាត់ថ្នាក់ដីរដ្ឋដែលចែងក្នុងជំពូកនេះ ត្រូវយកមកអនុវត្តលើករណីដូចខាងក្រោម៖

១-ដីនោះត្រូវបានចុះបញ្ជីថាជាដីរដ្ឋនៅក្នុងការអនុវត្តការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ប៉ុន្តែដីនោះមិនទាន់ត្រូវបានធ្វើចំណាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋនៅឡើយ។

២-ការចុះបញ្ជីដីរដ្ឋមានលក្ខណៈដាច់ដោយដុំលើកដំបូង ចំពោះដីដែលមិនទាន់អាចចុះបញ្ជីបាន ដោយសារហេតុផលដែលរៀបរាប់ក្នុងមាត្រា១០ ខ ខាងលើ។

**មាត្រា១២**

ក-ក្នុងករណីដែលតម្រូវឱ្យអនុវត្តនីតិវិធីនៃការធ្វើចំណាត់ថ្នាក់ដី អនុលោមតាមជំពូកនេះ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង មានភារកិច្ចផ្តល់អនុសាសន៍ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អំពីឋានៈនៃដីនោះ ដោយបញ្ជាក់ថា ការធ្វើចំណាត់ថ្នាក់ដីនោះ អនុលោមតាមច្បាប់ភូមិបាល និងច្បាប់ផ្សេងៗទៀត។

ខ-ប្រសិនបើបានធ្វើអត្តសញ្ញាណកម្ម និងផែនទីដីរដ្ឋរួចហើយ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងត្រូវពិចារណារបាយការណ៍របស់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ ដែលមានរួមបញ្ចូលទាំងមតិយោបល់សាធារណៈ មុនពេលធ្វើការផ្តល់អនុសាសន៍។

គ-ប្រសិនបើមិនទាន់បានធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋទេ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ត្រូវធ្វើការស៊ើបអង្កេតរាល់ការអះអាងដែលមិនស្របគ្នារបស់ស្ថាប័ន ឬអាជ្ញាធរដែនដី និងផ្តល់ឱកាសឱ្យសាធារណជនចូលរួមមតិលើការធ្វើចំណាត់ថ្នាក់នោះ។

ឃ-ប្រសិនបើគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង អាចសម្រេចបានការឯកភាពមតិគ្នាលើការធ្វើចំណាត់ថ្នាក់ដីនោះ ថាជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ អនុលោមតាមច្បាប់ភូមិបាល និងច្បាប់ពាក់ព័ន្ធផ្សេងទៀត គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ត្រូវលើកអនុសាសន៍ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់អំពីឋានៈនៃដីនោះ។

ង-ប្រសិនបើក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់យល់ព្រមតាមអនុសាសន៍របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ក្រសួងត្រូវចុះបញ្ជីចំណាត់ថ្នាក់នៃដីរដ្ឋនោះនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ស្របតាមអនុសាសន៍។ ប៉ុន្តែ ប្រសិនបើក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មិនយល់ព្រមតាមអនុសាសន៍របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងទេ ក្រសួងត្រូវបញ្ជូនករណីនោះទៅប្រឹក្សាគោលនយោបាយដីធ្លី។

ច-ប្រសិនបើគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងមិនអាចសម្រេចបានការឯកភាពមតិគ្នា អំពីឋានៈនៃដីនោះទេ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងត្រូវធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លីដើម្បីពិចារណាបន្តទៀត។

ឆ-ប្រសិនបើក្រុមប្រឹក្សាគោលនយោបាយដីធ្លីអាចសម្រេចបានការឯកភាពមតិគ្នាអំពីឋានៈនៃដីនោះថាជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ ផ្អែកលើមូលដ្ឋានច្បាប់ភូមិបាល និងច្បាប់ផ្សេងៗទៀតដែលពាក់ព័ន្ធ ក្រុមប្រឹក្សាគោលនយោបាយដីធ្លីត្រូវផ្តល់អនុសាសន៍ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់អំពីការចុះបញ្ជីដីនោះ ។

ជ-ប្រសិនបើក្រុមប្រឹក្សាគោលនយោបាយដីធ្លីមិនអាចសម្រេចបានការឯកភាពមតិគ្នាអំពីឋានៈនៃដីនោះទេ ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី ត្រូវបញ្ជូនករណីនោះទៅគណៈរដ្ឋមន្ត្រីដើម្បីសម្រេចលើការធ្វើចំណាត់ថ្នាក់ដីនោះ ។

ឈ-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចុះបញ្ជីចំណាត់ថ្នាក់នៃដីរដ្ឋនោះនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ស្របតាមសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រី ។

ញ-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចេញប្រកាសណែនាំអនុវត្តស្តីពីការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ។

## ជំពូកទី៥ ការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ

### មាត្រា១៣

ការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញគឺជាការប្តូរឋានៈដីរដ្ឋដែលត្រូវបានចុះបញ្ជីថា ជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋរួចហើយ៖

-ពីដីឯកជនរបស់រដ្ឋទៅជាដីសាធារណៈរបស់រដ្ឋ ឬ

-ពីដីសាធារណៈរបស់រដ្ឋទៅជាដីឯកជនរបស់រដ្ឋ ។

### មាត្រា១៤

ក-លើកលែងតែមានច្បាប់ចែងផ្សេងពីនេះ ការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញត្រូវអនុវត្តតាមនីតិវិធីដែលមានចែងក្នុងជំពូកនេះ ។

ខ-ការធ្វើចំណាត់ថ្នាក់ឡើងវិញពីដីឯកជនរបស់រដ្ឋទៅជាដីសាធារណៈរបស់រដ្ឋ ត្រូវធ្វើឡើងដោយអនុក្រឹត្យ ។

គ-ការធ្វើចំណាត់ថ្នាក់ឡើងវិញពីដីសាធារណៈរបស់រដ្ឋទៅជាដីឯកជនរបស់រដ្ឋ ត្រូវធ្វើឡើងដោយអនុលោមតាមមាត្រា១៦នៃច្បាប់ភូមិបាលឆ្នាំ២០០១ ។

**មាត្រា១៥**

ក-ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីក្នុងមូលដ្ឋានណាមួយអាចផ្តួចផ្តើមការធ្វើចំណាត់ថ្នាក់ដីរដ្ឋមួយឡើងវិញ ដោយដាក់សំណើជាលាយលក្ខណ៍អក្សរជូនទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងដែលពាក់ព័ន្ធ។ សំណើនោះត្រូវពណ៌នាអំពីដីដែលស្នើសុំឱ្យធ្វើចំណាត់ថ្នាក់ឡើងវិញ ដោយមានបង្ហាញលេខសម្គាល់ក្បាលដីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ហើយត្រូវបញ្ជាក់មូលហេតុជាក់លាក់សម្រាប់ការស្នើឱ្យធ្វើចំណាត់ថ្នាក់ឡើងវិញ។

ខ-ក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃបន្ទាប់ពីបានទទួលសំណើ ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ត្រូវចាត់តាំងក្រុមត្រួតពិនិត្យមួយដែលមានតំណាងរបស់មន្ទីរដែលមានជំនាញបច្ចេកទេសពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យសំណើ និងលើកអនុសាសន៍អំពីសំណើនោះ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង។

គ-ក្រុមត្រួតពិនិត្យនោះត្រូវបញ្ចប់ការត្រួតពិនិត្យក្នុងរយៈពេល៤៥ (សែសិបប្រាំ) ថ្ងៃ បន្ទាប់ពីត្រូវបានចាត់តាំងឡើង។ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងអាចអនុញ្ញាតឱ្យពន្យារពេលមួយដង ឬច្រើនដង ប៉ុន្តែទោះក្នុងករណីណាក៏ដោយ ក្រុមត្រួតពិនិត្យត្រូវតែបញ្ចប់ការត្រួតពិនិត្យ ព្រមទាំងរបាយការណ៍ស្តីពីការត្រួតពិនិត្យនោះ ក្នុងរយៈពេលមិនលើសពី៩០ (កៅសិប) ថ្ងៃ គិតចាប់ពីថ្ងៃចាត់តាំង។

ឃ-ក្រុមត្រួតពិនិត្យដែលត្រូវបានចាត់តាំងត្រូវបិទផ្សាយជាសាធារណៈ សម្រាប់រយៈពេល៣០ (សាមសិប) ថ្ងៃ អំពីការស្នើសុំឱ្យមានការធ្វើចំណាត់ថ្នាក់ឡើងវិញ។ ក្នុងពេលនោះ ក្រសួងស្ថាប័ននានា អាជ្ញាធរដែនដី និងអ្នកលើកសំណើ ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋាន ឬសង្គមស៊ីវិល និងប្រជាពលរដ្ឋនៃឃុំ-សង្កាត់ដែលពាក់ព័ន្ធអាចផ្តល់មតិយោបល់របស់ខ្លួន ចំពោះសំណើនោះដល់ក្រុមត្រួតពិនិត្យ ប្រសិនបើមាន។

ង-ក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីក្រុមត្រួតពិនិត្យបានដាក់ជូនរបាយការណ៍ត្រួតពិនិត្យ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ត្រូវលើកអនុសាសន៍របស់ខ្លួនជាលាយលក្ខណ៍អក្សរជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លីថា គួរទទួលយក ឬបដិសេធ ឬតម្រូវឱ្យធ្វើការកែសម្រួលលើសំណើនោះ។

ច-ក្រុមប្រឹក្សាគោលនយោបាយដីធ្លីត្រូវពិនិត្យអនុសាសន៍របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ហើយលើកអនុសាសន៍ជូនគណៈរដ្ឋមន្ត្រី។

ឆ-ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីក្នុងមូលដ្ឋានដែលលើកសំណើនោះត្រូវរៀបចំឯកសារដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីនូវសេចក្ដីព្រាងអនុក្រឹត្យ ឬច្បាប់ស្ដីពីការធ្វើចំណាត់ថ្នាក់ដីរដ្ឋជាក់លាក់ឡើងវិញ តាមករណីជាក់ស្ដែងដោយមានភ្ជាប់ជាមួយនូវអនុសាសន៍របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង និងរួមទាំងអនុសាសន៍របស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លីផង។

ជ-នៅពេលដែលអនុក្រឹត្យស្ដីពីការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញត្រូវបានសម្រេច ឬច្បាប់ស្ដីពីការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញត្រូវបានប្រកាសឱ្យប្រើ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវបញ្ចូលព័ត៌មាននៃការធ្វើចំណាត់ថ្នាក់ឡើងវិញ ទៅក្នុងប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋ និងត្រូវចុះក្នុងបញ្ជីសៀវភៅគោលបញ្ជីដីធ្លី។

## ជំពូកទី៦ ប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋ

### មាត្រា១៦

ប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋជាទិន្នន័យដែលមានផ្ទុកព័ត៌មានអំពីដីរដ្ឋដូចខាងក្រោម៖

១-ព័ត៌មានបឋមមិនទាន់បានបញ្ជាក់ច្បាស់លាស់ដែលបានមកពីការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ។

២-ព័ត៌មានដែលបង្ហាញថាដីនោះបានចុះបញ្ជីរួចហើយ ឬមិនទាន់ចុះបញ្ជី។

៣-អត្តសញ្ញាណនៃក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលមានអាណត្តិកាន់កាប់ដីនោះ។

៤-ឯកសារផ្ដល់ដោយក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលមានអាណត្តិកាន់កាប់ដីនោះដែលបង្ហាញអំពីការអះអាងពីឋានៈនៃដីនោះ។

៥-ព័ត៌មានអំពីប្រទានកម្ម សម្បទាន ការជួល ឬបន្ទុកផ្សេងៗទៀតលើដីនោះ។

### មាត្រា១៧

ក-គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង មានភារកិច្ចថែរក្សា និងធ្វើចរន្តការប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋប្រចាំខេត្ត-ក្រុង។

ខ-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវកំណត់លក្ខណៈបច្ចេកទេសនៃប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋ និងត្រូវផ្ដល់ការគាំទ្រផ្នែកបច្ចេកទេសសម្រាប់ការថែរក្សា និងការធ្វើចរន្តការប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋ។

គ-ប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋនេះបំពេញទិន្នន័យឱ្យបញ្ជីទ្រព្យសម្បត្តិរដ្ឋ ដែលគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបំពេញឱ្យសៀវភៅគោលបញ្ជីដីធ្លី ដែលគ្រប់គ្រងដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ឃ-សាធារណជនមានសិទ្ធិមើលប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋក្នុងថ្ងៃធ្វើការ និងទទួលបានឯកសារថតចម្លងដោយត្រូវបង់ថ្លៃចម្លង។

## ជំពូកទី៧ អាណត្តិកាន់កាប់ដីរដ្ឋ

**មាត្រា១៨**

ក-រដ្ឋអាចប្រគល់ឱ្យក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីនូវសិទ្ធិប្រើប្រាស់ជាផ្លូវការ និងភារកិច្ចរក្សាការពារដីសាធារណៈរបស់រដ្ឋ ឬដីឯកជនរបស់រដ្ឋ។ ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលទទួលសិទ្ធិនោះហៅថា អាជ្ញាធរកាន់កាប់ដីរដ្ឋ។

ខ-អាណត្តិកាន់កាប់ដីរដ្ឋត្រូវប្រគល់ឱ្យតាមរយៈលិខិតគតិយុត្តជាក់លាក់។ អាណត្តិកាន់កាប់ដីឯកជនរបស់រដ្ឋត្រូវប្រគល់ឱ្យតាមនីតិវិធីដែលមានចែងក្នុងជំពូកទី៨នៃអនុក្រឹត្យនេះ។ អាណត្តិនេះអាចត្រូវដកហូតវិញនៅពេលណាក៏បាន

គ-អាជ្ញាធរកាន់កាប់ដីរដ្ឋមានសិទ្ធិប្រើប្រាស់ដីនោះ ដើម្បីបម្រើបេសកកម្មរបស់ស្ថាប័នខ្លួន និងមានភារកិច្ចការពារដីនោះពីការបំពាន ឬការចូលទន្ទ្រានកាន់កាប់នានា។

ឃ-អាជ្ញាធរកាន់កាប់ដីរដ្ឋអាចធ្វើប្រតិភូកម្មសិទ្ធិប្រើប្រាស់ជាផ្លូវការ និងភារកិច្ចរក្សាការពារឱ្យទៅមន្ទីរ ឬការិយាល័យខ្សែបណ្តោយរបស់ខ្លួនបាន តាមរយៈការចេញលិខិតផ្លូវការដែលបញ្ជាក់ច្បាស់អំពីទីតាំង និងទំហំដីជាក់លាក់ ព្រមទាំងវិសាលភាពនៃការទទួលខុសត្រូវដែលត្រូវបានធ្វើប្រតិភូកម្ម។

ង-លើកលែងតែមានច្បាប់ចែងផ្ទុយពីនេះ ការប្តូរពីដីសាធារណៈរបស់រដ្ឋដែលបម្រើផលប្រយោជន៍សាធារណៈមួយជាក់លាក់ ទៅបម្រើសាធារណៈមួយទៀតត្រូវកំណត់ដោយអនុក្រឹត្យ។

ច-អាជ្ញាធរកាន់កាប់ដីរដ្ឋគ្មានសិទ្ធិជួល លក់ ផ្ទេរ ធ្វើអំណោយ ឬដោះដូរដីនោះបានឡើយ លើកលែងតែមានកំណត់ក្នុងអនុក្រឹត្យដោយឡែក។

ឆ-អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ត្រូវទទួលខុសត្រូវជាមួយអាជ្ញាធរកាន់កាប់ដីរដ្ឋ ក្នុងកិច្ចការពារដីសាធារណៈ និងដីឯកជនរបស់រដ្ឋ និងត្រូវមានវិធានការទប់ស្កាត់ការបំពាន ឬការចូលទន្ទ្រានកាន់កាប់ដីរដ្ឋ។

**ជំពូកទី៨ ការបែងចែក និងការធ្វើផែនការប្រើប្រាស់ដីឯកជនរបស់រដ្ឋ**

**មាត្រា១៩**

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង មានភារកិច្ចធ្វើផែនការបែងចែកសម្រាប់ការប្រើប្រាស់ផ្សេងៗនូវដីឯកជនរបស់រដ្ឋ ដែលបានចុះបញ្ជីរួចនៅក្នុងខេត្ត-ក្រុង ហើយដែលរដ្ឋមិនទាន់បានប្រគល់ទៅឱ្យស្ថាប័នសាធារណៈ ឬអាជ្ញាធរណាមួយកាន់កាប់នៅឡើយ។

**មាត្រា២០**

ដីឯកជនរបស់រដ្ឋអាចត្រូវបានបែងចែកសម្រាប់ការប្រើប្រាស់នៅថ្នាក់ខេត្ត-ក្រុង ថ្នាក់ស្រុក-ខណ្ឌ ឬថ្នាក់ឃុំ-សង្កាត់ដែលត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា២១**

ដីឯកជនរបស់រដ្ឋអាចត្រូវបានបែងចែកសម្រាប់ការប្រើប្រាស់ដោយបុគ្គល ឬអង្គការឯកជន ឬសមូហភាពតាមរយៈ៖

១-សម្បទានដីសង្គមកិច្ច អនុលោមតាមអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច។

២-សម្បទានដីសេដ្ឋកិច្ច អនុលោមតាមអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច។

៣-សម្បទានផ្សេងៗទៀត អនុលោមតាមអនុក្រឹត្យដែលពាក់ព័ន្ធ ព្រមទាំងនីតិវិធី និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា២២**

នីតិវិធីសម្រាប់ការធ្វើផែនការប្រើប្រាស់ដីឯកជនរបស់រដ្ឋនៅក្នុងខេត្ត-ក្រុងដែលមានលក្ខណៈចូលរួមនឹងត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងមហាផ្ទៃ។

**ជំពូកទី៩**

**មាត្រា២៣**

យន្តការនៃការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋមានដូចខាងក្រោម៖

១-គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងមានទីតាំងក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង និងមានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្ត-ក្រុង។

២-ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌមានទីតាំងក្នុងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ និងមានសិទ្ធិប្រើប្រាស់ត្រារបស់សាលាស្រុក-ខណ្ឌ។

**មាត្រា២៤**

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងមានសមាសភាពដូចតទៅ៖

| | |
|---|---|
| -អភិបាលខេត្ត-ក្រុង | ជាប្រធាន |
| -ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង | ជាសមាជិកអចិន្ត្រៃយ៍ |
| -មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្ត-ក្រុង | ជាសមាជិក |
| -ស្នងការនគរបាលខេត្ត-ក្រុង | ជាសមាជិក |
| -ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត-ក្រុង | ជាសមាជិក |
| -ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត-ក្រុង | ជាសមាជិក |
| -ប្រធានមន្ទីរបរិស្ថានខេត្ត-ក្រុង | ជាសមាជិក |
| -ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្ត-ក្រុង | ជាសមាជិក |
| -ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង | ជាសមាជិក |
| -ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង | ជាសមាជិក |
| -ប្រធានមន្ទីរទេសចរណ៍ខេត្ត-ក្រុង | ជាសមាជិក |
| -ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត-ក្រុង | ជាសមាជិក |
| -នាយខណ្ឌរដ្ឋបាលព្រៃឈើដែលជាប់ពាក់ព័ន្ធនឹងខេត្ត-ក្រុង | ជាសមាជិក |
| -អគ្គលេខាធិការសាលាខេត្ត-ក្រុង | ជាសមាជិក |

សមាសភាពដែលមានចែងខាងលើត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងអាចអញ្ជើញតំណាងមន្ទីរពាក់ព័ន្ធផ្សេងទៀតចូលរួមជាសមាជិកតាមតម្រូវការនៃករណីនីមួយៗ។

*វាយឡើងវិញ*

**មាត្រា២៥**

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងមានមុខងារ និងភារកិច្ចដូចតទៅ៖

-ដឹកនាំក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌក្នុងការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ

-សម្របសម្រួលជាមួយក្រសួង ស្ថាប័ន អាជ្ញាធរដែនដីអំពីអាណត្តិកាន់កាប់ និងឋានៈនៃដីរដ្ឋ

-ប្រមូល និងចងក្រងឯកសារព័ត៌មានអំពីទីតាំង ឋានៈ និងការប្រើប្រាស់បច្ចុប្បន្ននៃដីរដ្ឋ

-ផ្ដល់មតិយោបល់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬក្រុមប្រឹក្សាគោលនយោបាយដីធ្លីអំពីអាណត្តិកាន់កាប់ និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ព្រមទាំងការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ

-ថែរក្សា និងធ្វើចរន្តការប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋប្រចាំខេត្ត-ក្រុង

-សម្រេច និងត្រួតពិនិត្យលើការរៀបចំផែនការសកម្មភាពប្រើប្រាស់ដីថ្នាក់ឃុំ-សង្កាត់ដោយមានការចូលរួមផ្ដល់មតិយោបល់លើគម្រោងសម្បទានដីធ្លី និងសហការតាមដានការអនុវត្តគម្រោងទាំងនោះ

-សហការក្នុងការរៀបចំពិគ្រោះយោបល់ជាសាធារណៈលើគម្រោងសម្បទានដីធ្លី

-លើកគម្រោងថវិកាប្រចាំឆ្នាំ និង

-បំពេញភារកិច្ចផ្សេងៗទៀតដូចមានចែងក្នុងអនុក្រឹត្យនេះ។

**មាត្រា២៦**

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងមានលេខាធិការដ្ឋានមួយជាសេនាធិការដើម្បីជួយក្នុងកិច្ចការរដ្ឋបាល និងកិច្ចការបច្ចេកទេសមានជាអាទិ៍ ការបញ្ចូលទិន្នន័យ និងព័ត៌មានពីក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ ការថែរក្សា និងការធ្វើចរន្តការប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋ។

លេខធិការដ្ឋានគ្រប់គ្រងដីរដ្ឋនេះ ដឹកនាំដោយប្រធានមួយរូបដែលមានអនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុងទទួលបន្ទុកការងារសុរិយោដី និងសមាជិកមួយចំនួនតាមការចាំបាច់ដែលត្រូវតែងតាំងដោយអភិបាលខេត្ត-ក្រុង។

លេខាធិការដ្ឋាននេះមានទីតាំងនៅក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង។

**មាត្រា២៧**

ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌមានសមាសភាពដូចខាងក្រោម៖

-អភិបាលស្រុក-ខណ្ឌ ជាប្រធាន

-ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ ជាសមាជិកអចិន្ត្រៃយ៍

-ប្រធានការិយាល័យជំនាញថ្នាក់ស្រុក-ខណ្ឌពាក់ព័ន្ធ និងនាយផ្នែករដ្ឋបាលព្រៃឈើដែលពាក់ព័ន្ធ ជាសមាជិក

-មេឃុំ ចៅសង្កាត់ពាក់ព័ន្ធក្នុងស្រុក-ខណ្ឌ ជាសមាជិក

ប្រធាន និងសមាជិកនៃក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌត្រូវតែងតាំងដោយអភិបាលខេត្ត-ក្រុង។

**មាត្រា២៨**

ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌត្រូវឋិតនៅក្រោមការណែនាំផ្នែករដ្ឋបាលពីគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង និងក្រោមការណែនាំផ្នែកបច្ចេកទេសពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ចំពោះដីរដ្ឋនៅតាមបណ្តោយព្រំដែនជាមួយប្រទេសជិតខាងទាំងបី ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ និងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ត្រូវឋិតក្រោមការណែនាំផ្នែកបច្ចេកទេសបន្ថែមពីគណៈកម្មាធិការបច្ចេកទេសនៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន។

មុខងារ និងភារកិច្ចរបស់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌមានដូចតទៅ៖

-ប្រមូល និងចងក្រងឯកសារព័ត៌មានដើម្បីធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋ

-សម្របសម្រួលជាមួយស្ថាប័ន អាជ្ញាធរ ឬអ្នកកាន់កាប់ដីរដ្ឋអំពីអាណត្តិកាន់កាប់ដីរដ្ឋ

-ស្វែងរកការឯកភាពលើព្រំប្រទល់ប្រហាក់ប្រហែល ឋានៈ និងការប្រើប្រាស់បច្ចុប្បន្ននៃដីរដ្ឋ

-ធ្វើការបិទផ្សាយជាសាធារណៈនូវសំណៅព័ត៌មាន និងផែនទីដីរដ្ឋនៅតាមទីប្រជុំជន និងតាមឃុំ-សង្កាត់ពាក់ព័ន្ធ និងទទួលមតិយោបល់ពីសាធារណៈតាមកាលបរិច្ឆេទ និងទីកន្លែងដែលបានកំណត់

-សង្ខេបមតិយោបល់សាធារណៈដែលបានទទួល និងរៀបចំទិន្នន័យ និងឯកសារចាំបាច់ រួមទាំងផែនទីដីរដ្ឋដែលមានបញ្ជាក់ព័ត៌មានទាំងអស់ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង

-ចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី និងផ្តល់មតិយោបល់ក្នុងការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ

-រៀបចំការពិគ្រោះយោបល់ និងចូលរួមផ្តល់មតិយោបល់លើគម្រោងសម្បទានដីធ្លី ព្រមទាំងសហការតាមដានការអនុវត្តគម្រោងសម្បទានដីធ្លី និង

-បំពេញភារកិច្ចផ្សេងៗទៀត ដូចមានចែងក្នុងអនុក្រឹត្យនេះ ។

## ជំពូកទី១០ ប្រភពធនធាន

**មាត្រា២៩**

ថវិកាសម្រាប់ការគ្រប់គ្រងដីរដ្ឋដែលរួមមានការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទីដីរដ្ឋ ការធ្វើចំណាត់ថ្នាក់ ការចុះបញ្ជីដីរដ្ឋ ការថែរក្សា និងការធ្វើចរន្តការប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋ ឋិតនៅក្នុងកញ្ចប់ថវិការបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ស្របតាមប្រព័ន្ធថវិកាឯកភាព ធនធាន និងថវិកាសម្រាប់ការគ្រប់គ្រងដីរដ្ឋបានមកពី៖

-ថវិកាជាតិ

-ហិរញ្ញប្បទានបានមកពីក្នុង និងក្រៅប្រទេស ឬអង្គការផ្តល់ជំនួយអន្តរជាតិ ។

## ជំពូកទី១១ អវសានប្បញ្ញត្តិ

**មាត្រា៣០**

គោលការណ៍ណែនាំអនុវត្តអនុក្រឹត្យនេះត្រូវកំណត់ដោយប្រកាសរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**មាត្រា៣១**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា៣២**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*វាយឡើងវិញ*

**មាត្រា៣៣**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការពាក់ព័ន្ធ អភិបាលគ្រប់ខេត្ត-ក្រុង គ្រប់ប្រធានស្ថាប័ន អង្គភាពដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងមាត្រា២៤ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

<u>កន្លែងទទួល</u>

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-គ្រប់ក្រសួង ស្ថាប័នកណ្តាល

-គ្រប់សាលាខេត្ត-ក្រុង

-ដូចមាត្រា៣៣

-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ១៤៦អនក្រ/បក

# អនុក្រឹត្យ
# ស្តីពីសម្បទានដីសេដ្ឋកិច្ច

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/0៧0៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២00៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ0២/នស/៩៤ ចុះថ្ងៃទី២0 ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ0១/នស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ0៤/នស/៩៤ ចុះថ្ងៃទី១0 ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/0១៩៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/0២៩៨/0៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង
- បានឃើញព្រះរាជក្រមលេខ នស/រកម/0៣0១/0៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២00១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ៤៦អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្ដីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ៤៨អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្ដីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ
- បានឃើញអនុក្រឹត្យលេខ១៩អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្ដីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ៥៣អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្ដីពីនីតិវិធីការបង្កើត ការចាត់ថ្នាក់ និងការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍
- បានឃើញអនុក្រឹត្យលេខ៧២អនក្រ/បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្ដីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- បានឃើញអនុក្រឹត្យលេខ១១៨អនក្រ/បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្ដីពីការគ្រប់គ្រងដីរដ្ឋ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ២០០៥

**សម្រេច**

**ជំពូកទី១ បទប្បញ្ញត្តិទូទៅ**

មាត្រា១

អនុក្រឹត្យនេះមានគោលដៅកំណត់លក្ខណវិនិច្ឆ័យ នីតិវិធី យន្តការ និងការរៀបចំស្ថាប័នសម្រាប់ការផ្ដួចផ្ដើម និងការផ្ដល់សម្បទានដីសេដ្ឋកិច្ច សម្រាប់ការតាមដានត្រួតពិនិត្យការអនុវត្តកិច្ចសន្យា និងសម្រាប់ការត្រួតពិនិត្យឡើងវិញលើសម្បទានដីសេដ្ឋកិច្ចដែលបានចុះកិច្ចសន្យាមុនពេលដែលអនុក្រឹត្យនេះចូលជាធរមាន ស្របតាមការកំណត់នៃច្បាប់ភូមិបាលឆ្នាំ២០០១។

មាត្រា២

ពាក្យទាំងឡាយខាងក្រោមនេះមានន័យដូចតទៅ៖

-សម្បទានដីសេដ្ឋកិច្ច សំដៅដល់យន្តការសម្រាប់ផ្តល់ដីឯកជនរបស់រដ្ឋ តាមរយៈកិច្ចសន្យាសម្បទានមួយជាក់លាក់ទៅឱ្យសម្បទានិក ដើម្បីប្រើប្រាស់សម្រាប់ធ្វើអាជីវកម្មកសិកម្ម និងកសិ-ឧស្សាហកម្ម

-ការធ្វើអាជីវកម្មកសិ-ឧស្សាហកម្ម សំដៅដល់

+ការដាំដំណាំស្បៀង ឬដំណាំឧស្សាហកម្ម រាប់ទាំងការដាំដើមឈើជាចម្ការឈើ

+ការចិញ្ចឹមសត្វ និងវារីវប្បកម្ម

+ការងារសាងសង់ ដូចជារោងសិប្បកម្ម ឬរោងចក្រ និងការបំពាក់បរិក្ខារនានាសម្រាប់កែច្នៃវត្ថុធាតុដើមដែលជាកសិផលក្នុងស្រុក ឬ

+សកម្មភាពរួមគ្នានៃសកម្មភាពមួយចំនួន ឬទាំងអស់ដែលបានរៀបរាប់ខាងលើ

-អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា សំដៅដល់អាជ្ញាធរដែលមានសិទ្ធិអំណាចតាមផ្លូវច្បាប់ក្នុងការចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ដោយអនុវត្តសិទ្ធិនោះតាមការផ្តល់សិទ្ធិប្រទានពីនាយករដ្ឋមន្ត្រីដើម្បីបំពេញភារកិច្ចស្របតាមការចែងក្នុងអនុក្រឹត្យនេះ

-ស្ថាប័នដាក់បញ្ញត្តិ សំដៅដល់អាជ្ញាធរមានអំណាចតាមផ្លូវច្បាប់ក្នុងការចេញ និងដាក់ឱ្យអនុវត្តនូវវិធាន និងបទប្បញ្ញត្តិ ដើម្បីគ្រប់គ្រងលើសកម្មភាព ឬបរិក្ខារដែលជាកម្មវត្ថុនៃកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច

-លេខាធិការដ្ឋានបច្ចេកទេស សំដៅដល់លេខាធិការដ្ឋានបច្ចេកទេសសម្រាប់សម្បទានដីសេដ្ឋកិច្ច។

**មាត្រា៣**

សម្បទានដីសេដ្ឋកិច្ចអាចត្រូវបានផ្តល់ឱ្យ ដើម្បីសម្រេចគោលបំណងដូចខាងក្រោម៖

-អភិវឌ្ឍសកម្មភាពកសិកម្មប្រពលវប្បកម្ម និងកសិ-ឧស្សាហកម្មដែលតម្រូវឱ្យមានការវិនិយោគដើមទុនដំបូងក្នុងអត្រាខ្ពស់ និងកម្រិតសមស្រប។

-សម្រេចបាននូវការព្រមព្រៀងមួយចំនួនជាក់លាក់ពីអ្នកវិនិយោគ សម្រាប់ការអភិវឌ្ឍដីក្នុងលក្ខណៈសមស្រប និងប្រកបដោយចីរភាព ដោយផ្អែកលើផែនការប្រើប្រាស់ដីនៃតំបន់នោះ

-បង្កើនភាពមានការងារធ្វើនៅជនបទក្នុងក្របខ័ណ្ឌនៃការធ្វើប្រពលវប្បកម្ម និងការធ្វើឱ្យមានកាលានុវត្តភាពនៃការរកស៊ីចិញ្ចឹមជីវិតមានលក្ខណៈសម្បូរណ៍បែប និងក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងធនធានធម្មជាតិ តាមប្រព័ន្ធអេកូឡូស៊ីសមស្រប

-លើកទឹកចិត្តរាល់ការវិនិយោគក្នុងគម្រោងសម្បទានដីសេដ្ឋកិច្ច និង

-បង្កើនចំណូលរដ្ឋ ឬចំណូលខេត្ត-ក្រុង ឃុំ-សង្កាត់ តាមរយៈការប្រមូលថ្លៃប្រើប្រាស់ដី ពន្ធ និងកម្រៃលើសេវាពាក់ព័ន្ធ។

## ជំពូកទី២ លក្ខខ័ណ្ឌទូទៅសម្រាប់ការផ្តល់សម្បទានដីសេដ្ឋកិច្ច

### មាត្រា៤

សម្បទានដីសេដ្ឋកិច្ចអាចត្រូវបានផ្តល់ឱ្យចំពោះតែដីដែលមានលក្ខណវិនិច្ឆ័យទាំង៥ ដូចខាងក្រោម៖

១-ដីដែលត្រូវបានចុះបញ្ជី និងធ្វើចំណាត់ថ្នាក់ថាជាដីឯកជនរបស់រដ្ឋ ស្របតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ និងអនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ឬអនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ។

២-ដីដែលមានផែនការប្រើប្រាស់ដី អនុម័តដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុង ហើយការប្រើប្រាស់មានលក្ខណៈសមស្របទៅតាមផែនការនោះ។

៣-ដីដែលបានធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមចំពោះការប្រើប្រាស់ និងការអភិវឌ្ឍដីសម្រាប់គម្រោងសម្បទាន។

៤-ដីដែលមានដំណោះស្រាយចំពោះបញ្ហាតាំងទីលំនៅថ្មីស្របតាមក្របខ័ណ្ឌគតិយុត្ត និងនីតិវិធីជាធរមាន។ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាធានាថា មិនមានការបង្ខំឱ្យធ្វើការតាំងទីលំនៅថ្មីដោយគ្មានការស្ម័គ្រចិត្តពីអ្នកកាន់កាប់ដីស្របច្បាប់ និងត្រូវធានាចំពោះការគោរពសិទ្ធិមានច្រកចេញចូលទៅកាន់ដីឯកជន។

៥-ដីដែលមានការពិគ្រោះយោបល់ជាសាធារណៈ ឬសំណើសម្បទានដីសេដ្ឋកិច្ចជាមួយអាជ្ញាធរដែនដី និងប្រជាពលរដ្ឋដែលនៅក្នុងតំបន់។

### មាត្រា៥

ការវាយតម្លៃសំណើសម្បទានដីសេដ្ឋកិច្ចត្រូវផ្អែកលើលក្ខណវិនិច្ឆ័យដូចខាងក្រោម៖

-ការបង្កើនផលិតផលកសិកម្ម និងកសិ-ឧស្សាហកម្ម ដោយប្រើប្រាស់បច្ចេកទេសទំនើប

-ការបង្កើតឱ្យមានការងារធ្វើកាន់តែច្រើន

-ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ

-ការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព

-ការចៀសវាង ឬការកាត់បន្ថយឱ្យនៅតិចបំផុតនូវហេតុប៉ះពាល់អវិជ្ជមានសង្គម

-ការផ្សារភ្ជាប់ និងការគាំទ្រទៅវិញទៅមករវាងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច ប្រសិនបើមាន

-ការកែច្នៃវត្ថុធាតុដើមជាកសិផលដែលត្រូវកំណត់នៅក្នុងកិច្ចសន្យាសម្បទាន។

**ជំពូកទី៣ នីតិវិធីសម្រាប់ផ្តួចផ្តើម ការស្នើសុំ និងការផ្តល់សម្បទានដីសេដ្ឋកិច្ច**

**មាត្រា៦**

ការផ្តួចផ្តើមគម្រោងសម្បទានដីសេដ្ឋកិច្ចមានពីររូបភាពគឺ៖

១-សំណើមានការអំពាវនាវដែលអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាជាអ្នកលើកគម្រោងដើម្បីអំពាវនាវឱ្យអ្នកវិនិយោគដាក់សំណើ។

២-សំណើមិនមានការអំពាវនាវដែលអ្នកវិនិយោគជាអ្នកលើកគម្រោងស្នើទៅរដ្ឋ ដើម្បីសុំការអនុញ្ញាត។

**ផ្នែកទី១ ការផ្តួចផ្តើមសម្បទានដីសេដ្ឋកិច្ចតាមរយៈការអំពាវនាវឱ្យដាក់សំណើ**

**មាត្រា៧**

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាជាអ្នកផ្តួចផ្តើមលើកគម្រោងសម្បទានដីសេដ្ឋកិច្ចតាមជំហានដូចតទៅ៖

១-រៀបចំឯកសារដំបូងសម្រាប់ស្នើគម្រោងសម្បទានដីសេដ្ឋកិច្ច តាមទម្រង់ដែលត្រូវបង្កើតឡើងដោយលេខាធិការដ្ឋានបច្ចេកទេស ហើយដែលត្រូវមានបញ្ចូលព័ត៌មានដូចចែងក្នុងមាត្រា៨នៃអនុក្រឹត្យនេះ។

២-បញ្ជូនឯកសារដំបូងទៅលេខាធិការដ្ឋានបច្ចេកទេស ដើម្បីធ្វើការពិនិត្យសិក្សា និងផ្តល់អនុសាសន៍បឋមដោយផ្អែកលើមាត្រា៣ និងមាត្រា៥នៃអនុក្រឹត្យនេះ។

៣-ពិគ្រោះយោបល់ជាមួយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង និងជាមួយស្ថាប័នដាក់បញ្ញត្តិលើគម្រោងសម្បទានដីសេដ្ឋកិច្ច។

៤-រៀបចំឱ្យមានការវាយតម្លៃដំបូងអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គមសម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ច។

៥-ប្រសិនបើការវាយតម្លៃដំបូងអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គម បង្ហាញនូវហេតុប៉ះពាល់អវិជ្ជមានកម្រិតមធ្យម ឬខ្ពស់ ត្រូវរៀបចំឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ។

៦-រៀបចំឯកសារពេញលេញសម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ច ដែលមានបញ្ចូលអនុសាសន៍ទាំងអស់ និងរបាយការណ៍នានាដែលជាលទ្ធផលនៃជំហានរៀបរាប់ខាងលើ ជាមូលដ្ឋានក្នុងការរៀបចំឯកសារស្តីពីល័ក្ខខ័ណ្ឌសម្រាប់ការដាក់សំណើដែលមានការអំពាវនាវ។

**មាត្រា៨**

ឯកសារដំបូងសម្រាប់ស្នើគម្រោងសម្បទានដីសេដ្ឋកិច្ចត្រូវមានបញ្ចូលព័ត៌មានដូចខាងក្រោម៖

១-ការពណ៌នាអំពីដីដែលស្នើឡើងដូចជាទីតាំង ទំហំ ប្រភេទ លេខសម្គាល់ក្បាលដីដែលចុះក្នុងសៀវភៅគោលបញ្ជីដីធ្លី និងព័ត៌មានទូទៅអំពីតំបន់ដែលដីនោះឋិតនៅ។

២-ផែនការទូទៅអំពីការប្រើប្រាស់ និងការអភិវឌ្ឍដីសម្រាប់គម្រោងសម្បទាន។

៣-សកម្មភាពចាំបាច់ផ្សេងៗដែលតម្រូវឱ្យសម្បទានិកធ្វើ មុនពេលចាប់ផ្តើមសកម្មភាពលើសម្បទានដីសេដ្ឋកិច្ចនោះ ប្រសិនបើមាន។

៤-សកម្មភាពចាំបាច់ផ្សេងៗដែលតម្រូវឱ្យអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ឬក្រសួងស្ថាប័នណាមួយធ្វើ មុនពេលចាប់ផ្តើមអនុវត្តសកម្មភាពសម្បទានដីសេដ្ឋកិច្ច ប្រសិនបើមាន។

៥-ការធានារបស់រដ្ឋ ឬកាតព្វកិច្ចរបស់រដ្ឋ ប្រសិនបើតម្រូវឱ្យមានសម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ច។

**មាត្រា៩**

នៅពេលទទួលបានឯកសារពេញលេញសម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ចពីអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា លេខាធិការដ្ឋានបច្ចេកទេសត្រូវរៀបចំឯកសារដោយមានការអំពាវនាវឱ្យដាក់សំណើសុំសម្បទានដីសេដ្ឋកិច្ចរួមមាន៖

-សេចក្តីជូនដំណឹង

-ឯកសារស្តីពីល័ក្ខខ័ណ្ឌ និង

-ពាក្យស្នើសុំ។

**មាត្រា១០**

លេខាធិការដ្ឋានបច្ចេកទេសត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវសេចក្តីជូនដំណឹងឱ្យដាក់សំណើ និងបញ្ជូនសេចក្តីជូនដំណឹងនេះទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

សេចក្តីជូនដំណឹងត្រូវបញ្ជាក់ពីរបៀប ទីកន្លែង និងរយៈពេលសម្រាប់ការដាក់សំណើ ដោយកំណត់នូវកាលបរិច្ឆេទទទួល និងឈប់ទទួលពាក្យ។ ការដាក់សំណើត្រូវមានរយៈពេលយ៉ាងតិច៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹង។

**មាត្រា១១**

ឯកសារស្តីពីល័ក្ខខ័ណ្ឌសម្រាប់ការដាក់សំណើដែលមានការអំពាវនាវត្រូវបញ្ចូលខ្លឹមសារដូចខាងក្រោម៖

-សេចក្តីពណ៌នាអំពីគម្រោងសម្បទានដីសេដ្ឋកិច្ច និងឯកសារគាំទ្រដែលតម្រូវឱ្យដាក់ភ្ជាប់ជាមួយសំណើ

-លក្ខណវិនិច្ឆ័យសម្រាប់ការវាយតម្លៃផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និងពាណិជ្ជកម្មនៃសំណើ និង

-ល័ក្ខខ័ណ្ឌចាំបាច់មួយចំនួនដែលមិនអនុញ្ញាតឱ្យចរចា។

**មាត្រា១២**

ពាក្យស្នើសុំសម្រាប់សំណើមានការអំពាវនាវត្រូវមានភ្ជាប់ព័ត៌មានទាំងឡាយដូចខាងក្រោម៖

-ផែនការអាជីវកម្មដែលលំអិតអំពីផែនការប្រើប្រាស់ដី ផែនការវិនិយោគ ផែនការចំណូលចំណាយសម្រាប់ការអភិវឌ្ឍដី និងប្រភពដើមទុនសម្រាប់គាំទ្រដល់គម្រោងសម្បទាន

-ការពណ៌នាអំពីសេចក្តីត្រូវការកម្លាំងពលកម្ម និងប្រភពផ្គត់ផ្គង់កម្លាំងពលកម្មសម្រាប់គម្រោងសម្បទាន

-ព័ត៌មានអំពីបច្ចេកវិទ្យា ឧបករណ៍ គ្រឿងចក្រ ជី ថ្នាំសម្លាប់សត្វល្អិត ប្រភេទដំណាំ អាទិភាពដែលគ្រោងនឹងប្រើប្រាស់

-ការបង្ហាញពីហេតុប៉ះពាល់បរិស្ថាន និងសង្គមនៃសកម្មភាពគម្រោងវិនិយោគរបស់ខ្លួន ព្រមទាំងវិធានការទប់ស្កាត់ ឬកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមាន

-ការពណ៌នាអំពីការផ្សារភ្ជាប់ និងការគាំទ្រទៅវិញទៅមករវាងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច ប្រសិនបើមាន

-ការពណ៌នាអំពីការផ្សារភ្ជាប់ទៅនឹងការកែច្នៃវត្ថុធាតុដើម ដែលជាកសិផលក្នុងស្រុក ប្រសិនបើមាន

-ថ្លៃប្រើប្រាស់ដីដែលអ្នកដាក់សំណើស្នើជូនរដ្ឋ

-ការបង្ហាញព័ត៌មានអំពីការកាន់កាប់ដីសម្បទានសេដ្ឋកិច្ចដោយម្ចាស់សំណើ ប្រសិនបើមាន ស្របតាមការចែងក្នុងមាត្រា៥៩នៃច្បាប់ភូមិបាល និង

-កិច្ចធានាណាមួយដែលអ្នកដាក់សំណើចង់បានពីរដ្ឋ ប្រសិនបើមាន។

**មាត្រា១៣**

លេខាធិការដ្ឋានបច្ចេកទេសត្រូវរៀបចំការប្រជុំជាសាធារណៈ ដើម្បីបំភ្លឺអំពីចំណុចនានានៃឯកសារអំពាវនាវឱ្យដាក់សំណើ យ៉ាងតិច៣០ (សាមសិប) ថ្ងៃ មុនកាលបរិច្ឆេទបិទការទទួលសំណើ និងត្រូវកត់ត្រាទុកជាឯកសារសាធារណៈនូវការបំភ្លឺដែលបានធ្វើឡើង។

**មាត្រា១៤**

លក្ខណវិនិច្ឆ័យសម្រាប់វាយតម្លៃ និងចាត់ថ្នាក់សំណើមានការអំពាវនាវត្រូវបញ្ចូលចំណុចដូចខាងក្រោម៖

-កម្រិតបច្ចេកទេសនៃការប្រើប្រាស់ និងការអភិវឌ្ឍដី រួមទាំងភាពសមស្របរបស់ដី

-ការគោរពតាមស្តង់ដារបរិស្ថានជាតិ និងវិធានការសមស្របសម្រាប់ទប់ស្កាត់ ឬកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងសង្គម

-លទ្ធភាពដំណើរការប្រតិបត្តិការនៃសំណើ ដោយផ្អែកជាអាទិ៍លើផែនការផ្គត់ផ្គង់ និងតម្រូវការកម្លាំងពលកម្ម ប្រភពហិរញ្ញវត្ថុ និងយុទ្ធសាស្ត្រទីផ្សារនៃផែនការអាជីវកម្ម

-លទ្ធភាពបង្កើតការងារធ្វើ និងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ

-ការកែច្នៃវត្ថុធាតុដើម ឬកសិផលក្នុងស្រុកដែលត្រូវកំណត់ក្នុងកិច្ចសន្យា

-លទ្ធភាពផ្សារភ្ជាប់ និងគាំទ្រទៅវិញទៅមករវាងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច

-ចំនួនទឹកប្រាក់ និងរបៀបបង់ថ្លៃប្រើប្រាស់ដីដែលអ្នកដាក់សំណើស្នើឡើង ។

លក្ខណវិនិច្ឆ័យសម្រាប់ការវាយតម្លៃ និងការចាត់ថ្នាក់សំណើមិនអាចធ្វើការកែប្រែបានឡើយ ក្រោយពីចុះផ្សាយសេចក្តីជូនដំណឹងឱ្យដាក់សំណើដែលមានការអំពាវនាវ អនុលោមតាមមាត្រា១០នៃអនុក្រឹត្យនេះ ។

លេខាធិការដ្ឋានបច្ចេកទេសត្រូវរៀបចំ និងផ្សព្វផ្សាយអំពីការដាក់ពិន្ទុសម្រាប់ការចាត់ថ្នាក់សំណើនីមួយៗតាមលំដាប់ ដោយផ្អែកលើលក្ខណវិនិច្ឆ័យខាងលើ ។

**មាត្រា១៥**

សំណើត្រូវដាក់នៅលេខាធិការដ្ឋានបច្ចេកទេសក្នុងស្រោមសំបុត្របិទជិត និងមានចុះហត្ថលេខា ឬបោះត្រារបស់ម្ចាស់សំណើលើស្នាមបិទមុខសំបុត្រ ។

សំណើដែលបានទទួលក្រោយកាលបរិច្ឆេទការទទួលសំណើត្រូវបង្វិលឱ្យម្ចាស់សំណើវិញដោយមិនត្រូវបើកស្រោមសំបុត្រឡើយ ។

សំណើទាំងអស់ ឬសំណើតែមួយ (០១) ដែលបានទទួលត្រូវបើកជាសាធារណៈ តាមកាលបរិច្ឆេទដែលបានកំណត់ក្នុងសេចក្តីអញ្ជើញឱ្យដាក់សំណើមានការអំពាវនាវ ។ ម្ចាស់សំណើម្នាក់ៗមានសិទ្ធិចូលរួមមើលការបើកសំណើ ។

លេខាធិការដ្ឋានបច្ចេកទេសត្រូវកំណត់សំណើណាដែលមានលក្ខណៈឆ្លើយតប ហើយពិនិត្យ និងលើកអនុសាសន៍លើសំណើនោះ ជូនទៅអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ដោយផ្អែកលើលក្ខណវិនិច្ឆ័យដែលចែងក្នុងមាត្រា១៤នៃអនុក្រឹត្យនេះ និងតាមនីតិវិធីដែលមានក្នុងឯកសារស្តីពីល័ក្ខខ័ណ្ឌសម្រាប់ការដាក់សំណើ ។

**មាត្រា១៦**

បន្ទាប់ពីការពិចារណាលើអនុសាសន៍របស់លេខាធិការដ្ឋានបច្ចេកទេស អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវធ្វើការវាយតម្លៃ និងកំណត់បញ្ជីសង្ខេបតាមលំដាប់ថ្នាក់សំណើដែល

មានលក្ខណៈឆ្លើយតបទាំងអស់ និងរៀបចំរបាយការណ៍វាយតម្លៃសំណើដែលមានលក្ខណៈឆ្លើយតប ហើយផ្តល់របាយការណ៍វាយតម្លៃនោះមួយច្បាប់ឱ្យម្ចាស់សំណើនីមួយៗ។

**មាត្រា១៧**

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា មិនត្រូវបានអនុញ្ញាតឱ្យធ្វើការចរចាលើល័ក្ខខ័ណ្ឌចាំបាច់មួយចំនួនដែលបានកំណត់ជាមុនថា មិនអនុញ្ញាតឱ្យចរចានៅក្នុងឯកសារអំពាវនាវឱ្យដាក់សំណើនោះឡើយ។

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវអញ្ជើញម្ចាស់សំណើដែលជាប់លំដាប់ថ្នាក់ខ្ពស់ជាងគេ មកធ្វើការចរចាកិច្ចសន្យាសម្បទាន។ ប្រសិនបើការចរចាមិនអាចឈានដល់ការសម្រេចកិច្ចសន្យាសម្បទាន ដោយមកពីអាជ្ញាធរមិនអាចទទួលយកល័ក្ខខ័ណ្ឌដែលស្នើឡើងចុងក្រោយដោយម្ចាស់សំណើ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវបញ្ឈប់ការចរចាជាមួយម្ចាស់សំណើ ហើយត្រូវអញ្ជើញអ្នកដាក់សំណើដែលជាប់លំដាប់ថ្នាក់បន្ទាប់ មកធ្វើការចរចាកិច្ចសន្យាជាបន្តបន្ទាប់។

ប្រសិនបើការចរចាឈានដល់ការសម្រេចបាននូវសេចក្តីព្រាងកិច្ចសន្យាសម្បទាន អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវឱ្យម្ចាស់សំណើបំពេញល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា២៣នៃអនុក្រឹត្យនេះ។

ក្នុងករណីដែលមានសំណើតែមួយ (០១) ឬពីរ (០២) លេខាធិការដ្ឋានបច្ចេកទេសក៏ត្រូវតែអនុវត្តតាមនីតិវិធីដែលមានចែងក្នុងមាត្រាខាងលើដែរ។

**ផ្នែកទី២ ការផ្តួចផ្តើមគម្រោងសម្បទានដីសេដ្ឋកិច្ចតាមរយៈសំណើមិនមានការអំពាវនាវ**

**មាត្រា១៨**

វិធីសាស្ត្រអាទិភាពសម្រាប់ការផ្តល់សម្បទានដីសេដ្ឋកិច្ចគឺវិធីសាស្ត្រអំពាវនាវឱ្យដាក់សំណើក្នុងលក្ខណៈប្រកួតប្រជែង ប៉ុន្តែអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាសម្បទានអាចធ្វើការពិចារណាលើសំណើសម្បទានដីសេដ្ឋកិច្ច ដែលមិនមានការអំពាវនាវណាមួយបាន ក្នុងករណីម្ចាស់សំណើសន្យាផ្តល់អត្ថប្រយោជន៍ក្នុងលក្ខណៈពិសេស ដើម្បីសម្រេចនូវគោលបំណងនៃសម្បទានដីសេដ្ឋកិច្ច មានជាអាទិ៍៖

-ការនាំមកនូវបច្ចេកវិទ្យាថ្មី

-ការផ្សារភ្ជាប់ជាពិសេសរវាងសម្បទានដីសេដ្ឋកិច្ចទៅនឹងសម្បទានដីសង្គមកិច្ច

-លទ្ធភាពពិសេសក្នុងការរកទីផ្សារកែច្នៃ ឬទីផ្សារនាំចេញ។

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាមិនត្រូវទទួលយកមកពិចារណានូវសំណើសម្បទានដីសេដ្ឋកិច្ចមិនមានការអំពាវនាវទេ ប្រសិនបើសំណើនោះទាក់ទងទៅនឹងដីដែលជាកម្មវត្ថុនៃគម្រោងសម្បទានដីសេដ្ឋកិច្ចមានការអំពាវនាវដែលបានផ្សព្វផ្សាយសេចក្តីជូនដំណឹងឱ្យដាក់សំណើរួចហើយ។

**មាត្រា១៩**

លេខាធិការដ្ឋានបច្ចេកទេសត្រូវរៀបចំពាក្យសុំសម្រាប់លើកសំណើមិនមានការអំពាវនាវ ដោយបញ្ចូលសេចក្តីពណ៌នាសង្ខេបអំពីសាវតារផ្នែកអាជីវកម្ម និងហិរញ្ញវត្ថុរបស់ម្ចាស់សំណើ គោលគំនិតស្តីពីការវិនិយោគដែលស្នើឡើង ព្រមទាំងព័ត៌មានទាក់ទងទៅនឹងទំហំដី និងទីតាំងដី។

ម្ចាស់សំណើអាចដាក់ពាក្យសុំសម្រាប់សំណើមិនមានការអំពាវនាវនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬនៅអនុគណៈកម្មការវិនិយោគខេត្ត-ក្រុង ឬនៅអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា។ ប្រសិនបើពាក្យសុំសម្រាប់សំណើមិនមានការអំពាវនាវ ត្រូវបានដាក់នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬនៅអនុគណៈកម្មការវិនិយោគខេត្ត-ក្រុង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មការវិនិយោគខេត្ត-ក្រុង ត្រូវបញ្ជូនសំណើនោះទៅអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ក្នុងរយៈពេល០៧ (ប្រាំពីរ) ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលពាក្យសុំ។

ប្រសិនបើអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាសម្រេចធ្វើការពិចារណាសំណើមិនមានការអំពាវនាវ អាជ្ញាធរត្រូវធ្វើការពិគ្រោះយោបល់ដូចមានចែងក្នុងមាត្រា៧ នៃអនុក្រឹត្យនេះត្រង់ចំណុចទី៣។ បន្ទាប់មក អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវរៀបចំបំពេញលក្ខណវិនិច្ឆ័យសម្រាប់ការជ្រើសរើសដីធ្វើសម្បទាន ដូចមានចែងក្នុងមាត្រា៤នៃអនុក្រឹត្យនេះ ហើយស្នើឱ្យម្ចាស់សំណើផ្តល់នូវឯកសារលំអិតនៃសំណើ។

**មាត្រា២០**

ឯកសារលំអិតនៃសំណើមិនមានការអំពាវនាវត្រូវបញ្ចូលព័ត៌មានដូចខាងក្រោម៖

-ព័ត៌មានដូចមានចែងក្នុងមាត្រា១២នៃអនុក្រឹត្យនេះ និង

-របាយការណ៍នៃការសិក្សាវាយតម្លៃដំបូងអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គម។ ប្រសិនបើការសិក្សាវាយតម្លៃដំបូងបង្ហាញថា អាចមានហេតុប៉ះពាល់អវិជ្ជមានកម្រិតមធ្យម ឬខ្ពស់ សំណើនោះត្រូវបញ្ចូលរបាយការណ៍នៃការវាយតម្លៃពេញលេញអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គម។

**មាត្រា២១**

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាដែលបានទទួលសំណើមិនមានការអំពាវនាវ ត្រូវអនុវត្តតាមបែបបទដូចតទៅ៖

ក-អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវបញ្ជូនឯកសារលំអិតនៃសំណើមិនមានការអំពាវនាវទៅលេខាធិការដ្ឋានបច្ចេកទេស ឬទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ដើម្បីពិនិត្យ និងផ្តល់អនុសាសន៍។

ខ-លេខាធិការដ្ឋានបច្ចេកទេស ឬគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ត្រូវផ្តល់អនុសាសន៍ជូនអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ថាគួរ ឬមិនគួរធ្វើការចរចាកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច អនុលោមតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា៣ ដល់មាត្រា៥នៃអនុក្រឹត្យនេះ។

**មាត្រា២២**

ការចរចាចុះកិច្ចសន្យាសម្រាប់គម្រោងសម្បទានមិនមានការអំពាវនាវ ត្រូវធ្វើក្នុងរយៈពេលយ៉ាងច្រើន២៨ (ម្ភៃប្រាំបី) ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃផ្តើមការចរចា។ បើការចរចាមិនឈានដល់ការសម្រេចសេចក្តីព្រាងកិច្ចសន្យាសម្បទានក្នុងរយៈពេលកំណត់នេះទេ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាអាចបញ្ឈប់ការពិចារណាលើសំណើនោះ។

**មាត្រា២៣**

មុនចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច អ្នកដាក់សំណើត្រូវចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មស្របតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២៤**

លេខាធិការដ្ឋានបច្ចេកទេសត្រូវរៀបចំទម្រង់ស្តង់ដារនៃកិច្ចសន្យាសម្បទាន ដែលត្រូវប្រើសម្រាប់រាល់សម្បទានដីសេដ្ឋកិច្ចដោយត្រូវពិគ្រោះយោបល់ និងកំណត់ប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ជំពូកទី៤ ការគ្រប់គ្រង និងការកែប្រែកិច្ចសន្យាសម្បទាន

**មាត្រា២៥**

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវទទួលខុសត្រូវក្នុងការធានាឱ្យមានការអនុវត្តកិច្ចសន្យាសម្បទានដោយបង្កើតយន្តការ និងនីតិវិធីសម្រាប់ការត្រួតពិនិត្យតាមដានការអនុវត្តកិច្ចសន្យា

សម្បទាន និងរាយការណ៍ជាប្រចាំអំពីការគ្រប់គ្រងកិច្ចសន្យាសម្បទានទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយផ្ដល់ព័ត៌មានដល់លេខាធិការដ្ឋានបច្ចេកទេស ឬគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង។

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យលើការអនុវត្តកិច្ចសន្យាសម្បទានរបស់សម្បទានិក និងទទួលព័ត៌មានពីសម្បទានិក និងពីក្រសួង ស្ថាប័នពាក់ព័ន្ធទាក់ទងនឹងការអនុវត្តកិច្ចសន្យាសម្បទាន។

**មាត្រា២៦**

មុននឹងធ្វើការកែប្រែកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវធ្វើការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងភាគីចុះកិច្ចសន្យា ដោយអនុលោមតាមបទប្បញ្ញត្តិ និងច្បាប់ជាធរមាន។

**មាត្រា២៧**

ការពន្យារ ការព្យួរ ការបញ្ចប់កិច្ចសន្យាសម្បទានត្រូវកំណត់ក្នុងកិច្ចសន្យាសម្បទាន។

## ជំពូកទី៥ យន្តការរដ្ឋបាល និងការអនុវត្តកិច្ចសន្យាសម្បទាន

**មាត្រា២៨**

យន្តការសម្បទានដីសេដ្ឋកិច្ច មានដូចខាងក្រោមៈ

-អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា

-លេខាធិការដ្ឋានបច្ចេកទេស

-គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង

-ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ

-ក្រុមប្រឹក្សាឃុំ-សង្កាត់។

**មាត្រា២៩**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិ និងទទួលខុសត្រូវក្នុងការផ្ដល់សម្បទានដីសេដ្ឋកិច្ចដែលមានទុនវិនិយោគចាប់ពី១០.០០០.០០០.០០០ (ដប់ពាន់លាន) រៀលឡើង ឬមានទំហំដីសម្បទានចាប់ពី១.០០០ (មួយពាន់) ហិកតាឡើង។

*វាយឡើងវិញ*

អភិបាលខេត្ត-ក្រុងមានសិទ្ធិ និងទទួលខុសត្រូវក្នុងការផ្ដល់សម្បទានដីសេដ្ឋកិច្ច ដែលមានទុនវិនិយោគក្រោម១០.០០០.០០០.០០០ (ដប់ពាន់លាន) រៀល និងមានទំហំដីសម្បទានក្រោម១.០០០ (មួយពាន់) ហិកតា។[10]

**មាត្រា៣០**

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

-ផ្ដួចផ្ដើម និងរៀបចំឯកសារគម្រោងសម្បទានដីសេដ្ឋកិច្ចសម្រាប់អំពាវនាវឱ្យមានការដាក់សំណើ ឬអាចពិចារណាសំណើគម្រោងសម្បទានដីសេដ្ឋកិច្ចដែលមិនមានការអំពាវនាវ

-វាយតម្លៃ និងកំណត់បញ្ជីសង្ខេបតាមលំដាប់ថ្នាក់សំណើ

-ចរចាល័ក្ខខ័ណ្ឌសម្រាប់កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច

-ដាក់ឱ្យអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច

-តាមដានការអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច

-រាយការណ៍អំពីការគ្រប់គ្រងលើការអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ជូនគណៈរដ្ឋមន្ត្រីជារៀងរាល់០៦ (ប្រាំមួយ) ខែម្ដង និងតាមការចាំបាច់

-សម្របសម្រួល ប្រមូលព័ត៌មាន និងទិន្នន័យពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងការពារជាតិ ចំពោះដីក្នុងតំបន់អភិវឌ្ឍន៍យោធា លើល័ក្ខខ័ណ្ឌដែលត្រូវដាក់បញ្ចូលក្នុងកិច្ចសន្យាសម្បទាន

-ពិនិត្យយោបល់របស់លេខាធិការដ្ឋានបច្ចេកទេសអំពីសំណើកែប្រែកិច្ចសន្យាសម្បទានណាមួយ និង

-បំពេញភារកិច្ចផ្សេងៗទៀតស្របតាមការចែងក្នុងអនុក្រឹត្យនេះ។

**មាត្រា៣១**

សមាសភាពនៃលេខាធិការដ្ឋានបច្ចេកទេសមានដូចខាងក្រោម៖

---

[10] អាជ្ញាធរខេត្ត-ក្រុងត្រូវបានដកហូតសិទ្ធិចុះហត្ថលេខាចាប់ពីថ្ងៃ១៥ ខែកញ្ញា ឆ្នាំ២០០៨ តាមរយៈអនុក្រឹត្យស្ដីពីការកែសម្រួលអនុក្រឹត្យស្ដីពីសម្បទានដីសេដ្ឋកិច្ច, លេខ១៣១អនក្រ/បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨។ សូមមើលទំព័រ 960 ។

| | |
|---|---|
| -តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| -តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| -តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| -តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| -តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| -តំណាងក្រសួងបរិស្ថាន | សមាជិក |
| -តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| -សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |

ប្រធាន និងសមាជិកនៃលេខាធិការដ្ឋានបច្ចេកទេសត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

មន្ត្រីជំនួយការរបស់លេខាធិការដ្ឋានបច្ចេកទេសត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមសំណើរបស់លេខាធិការដ្ឋានបច្ចេកទេស។

លេខាធិការដ្ឋានបច្ចេកទេសមានទីតាំងនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៣២**

លេខាធិការដ្ឋានបច្ចេកទេសមានភារកិច្ច៖

-រៀបចំគម្រោងសម្បទានដីសេដ្ឋកិច្ច

-រៀបចំឯកសារអំពាវនាវឱ្យដាក់សំណើសម្បទានដីសេដ្ឋកិច្ច

-ផ្តល់អនុសាសន៍ចំពោះសំណើសម្បទានដីសេដ្ឋកិច្ចទាំងអស់

-តាមដានការអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច

-ផ្តល់អនុសាសន៍អំពីការត្រួតពិនិត្យឡើងវិញនូវសម្បទានដែលមានស្រាប់ និង

-បំពេញភារកិច្ចផ្សេងៗទៀតស្របតាមការចែងក្នុងអនុក្រឹត្យនេះ។

**មាត្រា៣៣**

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងមានតួនាទី និងភារកិច្ចដូចមានចែងក្នុងមាត្រា២៥នៃអនុក្រឹត្យលេខ១១៨អនក្រ/បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ។

**មាត្រា៣៤**

ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌមានតួនាទី និងភារកិច្ចដូចមានចែងក្នុងមាត្រា២៨នៃអនុក្រឹត្យលេខ១១៨អនក្រ/បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ។

**មាត្រា៣៥**

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវរៀបចំការពិគ្រោះយោបល់ជាមួយអាជ្ញាធរដែនដី និងតំណាងប្រជាពលរដ្ឋមូលដ្ឋាន ក្រោយពីទទួលបានឯកសារលំអិតនៃគម្រោងសម្បទានដីសេដ្ឋកិច្ចមានការអំពាវនាវ ឬឯកសារលំអិតនៃសំណើមិនមានការអំពាវនាវ ដោយបញ្ជូនឯកសារនោះមួយច្បាប់ទៅឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់ដែលដីសម្បទានតាំងនៅ ដើម្បីពិនិត្យ និងផ្តល់យោបល់ក្នុងរយៈពេលយ៉ាងច្រើន២៨ (ម្ភៃប្រាំបី) ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃដែលក្រុមប្រឹក្សាឃុំ-សង្កាត់បានទទួលសំណៅឯកសារលំអិតនៃគម្រោងសម្បទានមានការអំពាវនាវ ឬឯកសារលំអិតនៃសំណើមិនមានការអំពាវនាវ។ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវពិចារណាលើមតិយោបល់របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ពាក់ព័ន្ធ។ ក្នុងករណីបដិសេធយោបល់ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវផ្តល់ហេតុផលច្បាស់លាស់។

**ជំពូកទី៦ ការត្រួតពិនិត្យឡើងវិញនូវសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់**

**មាត្រា៣៦**

ចំពោះសម្បទានដីសេដ្ឋកិច្ចដែលបានផ្តល់ឱ្យមុនអនុក្រឹត្យនេះចូលជាធរមាន ហើយដែលកិច្ចសន្យាសម្បទាននោះនៅមានសុពលភាព៖

-លេខាធិការដ្ឋានបច្ចេកទេសត្រូវបង្កើតសៀវភៅកត់ត្រាសម្បទានដីសេដ្ឋកិច្ច ក្នុងរយៈពេល៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីមានសេចក្តីសម្រេចតែងតាំង និងត្រូវជូនដំណឹងក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃ ដល់ក្រសួង ស្ថាប័ន អាជ្ញាធរដែនដីទាំងឡាយដែលបានចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច និងក្រុមហ៊ុនសម្បទានទាំងអស់ឱ្យបានទូលំទូលាយ។

-ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីទាំងឡាយដែលបានចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ឬសម្បទានិកទាំងអស់ត្រូវទទួលខុសត្រូវផ្តល់ព័ត៌មាន និងឯកសារថតចម្លងដែលពាក់ព័ន្ធដល់លេខាធិការដ្ឋានបច្ចេកទេស ក្នុងរយៈពេល០៦ (ប្រាំមួយ) ខែ បន្ទាប់ពីការជូនដំណឹង ឬការផ្សព្វផ្សាយសេចក្តីជូនដំណឹង ដើម្បីចុះក្នុងសៀវភៅកត់ត្រាសម្បទានដីសេដ្ឋកិច្ច។

*វាយឡើងវិញ*

**មាត្រា៣៧**

ដោយមានជំនួយពីលេខាធិការដ្ឋានបច្ចេកទេស ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យាសម្បទានដែលមានស្រាប់ ត្រូវអនុវត្តនូវដំណាក់កាលត្រួតពិនិត្យឡើងវិញ តាមស្ថានភាពនៃករណីនីមួយៗដូចខាងក្រោម៖

-ការអនុវត្តរបស់សម្បទានិកផ្អែកលើល័ក្ខខ័ណ្ឌនៃកិច្ចសន្យាជាធរមាន ដោយពិចារណាលើកម្រិតនៃការវិនិយោគដែលបានធ្វើរួចហើយ និងដែលគ្រោងធ្វើបន្ត

-ប្រាក់ចំណូល និងថ្លៃប្រើប្រាស់ដីតាមកិច្ចសន្យាសម្បទាន

-ធ្វើការពិគ្រោះយោបល់ជាសាធារណៈ ដើម្បីប្រមូលមតិយោបល់អំពីសកម្មភាពសម្បទានដីសេដ្ឋកិច្ច នៅឃុំ-សង្កាត់ដែលដីសម្បទាននោះឋិតនៅ។

-ប្រសិនបើសម្បទានិកម្នាក់កាន់កាប់ដីសម្បទានសរុបលើសពី១០.០០០ (មួយម៉ឺន) ហិកតា ត្រូវស្នើឱ្យសម្បទានិកនោះស្ម័គ្រចិត្តកាត់ដីដែលលើសជូនរដ្ឋវិញ ឬប្រសិនបើសម្បទានិកមិនស្ម័គ្រចិត្តកាត់បន្ថយដីសម្បទាននោះទេ ត្រូវព្យាយាមចរចាលើការកាត់បន្ថយ

-ស្នើឱ្យមានការធ្វើនិយតកម្មដីនោះ ដូចមានចែងក្នុងមាត្រា៤២នៃអនុក្រឹត្យនេះ។

-យោបល់របស់លេខាធិការដ្ឋានបច្ចេកទេស លើសេចក្តីព្រាងរបាយការណ៍ត្រួតពិនិត្យឡើងវិញ

-ក្នុងរយៈពេល០៦ (ប្រាំមួយ) ខែ បន្ទាប់ពីការជូនដំណឹងស្តីពីការបង្កើតសៀវភៅកត់ត្រាសម្បទានដីសេដ្ឋកិច្ច ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យា ត្រូវដាក់របាយការណ៍ជូនគណៈរដ្ឋមន្ត្រី ដោយមានភ្ជាប់យោបល់របស់លេខាធិការដ្ឋានបច្ចេកទេស ទាក់ទងនឹងការត្រួតពិនិត្យឡើងវិញនូវសម្បទានដីសេដ្ឋកិច្ចដែលខ្លួនបានចុះកិច្ចសន្យា ហើយបន្ទាប់មកទៀតរបាយការណ៍នេះត្រូវធ្វើការទៀងទាត់រៀងរាល់០៦ (ប្រាំមួយ) ខែម្តង។

-នៅក្នុងអំឡុងពេល និងក្រោយពេលបញ្ចប់ការត្រួតពិនិត្យឡើងវិញ ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យា ត្រូវបន្តការតាមដានការអនុវត្តកិច្ចសន្យាដែលខ្លួនបានចុះហត្ថលេខា និងមិនត្រូវលុបចោល ឬមានបញ្ហាឱ្យផ្អាកដំណើរការ ហើយរាយការណ៍អំពីការអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច លើកលែងតែមានសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រីផ្ទុយពីនេះ។

**មាត្រា៣៨**

នីតិវិធីសម្រាប់ការកាត់បន្ថយទំហំដីសម្បទានសេដ្ឋកិច្ចដែលមានស្រាប់ ដោយស្ម័គ្រចិត្ត ឬដោយការចរចា ដូចមានចែងក្នុងមាត្រា៥៩នៃច្បាប់ភូមិបាល ត្រូវអនុវត្តដូចតទៅ៖

-ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ត្រូវស្នើឱ្យសម្បទានិកស្ម័គ្រចិត្តជ្រើសរើសចំណែកណាមួយនៃដីសម្បទានបង្វិលជូនរដ្ឋវិញ ស្របតាមមាត្រា៤០នៃអនុក្រឹត្យនេះ

-ប្រសិនបើសម្បទានិកមិនមានឆន្ទៈស្ម័គ្រចិត្តកាត់បន្ថយទំហំដីសម្បទាននោះទេ ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យាសម្បទានត្រូវអញ្ជើញសម្បទានិក មកចរចាអំពីផែនការប្រើប្រាស់ដីសម្បទានដោយមានជំនួយពីលេខាធិការដ្ឋានបច្ចេកទេស

-ប្រសិនបើការចរចាមិនសម្រេចបានជោគជ័យនៅក្នុងអំឡុងពេល០៦ (ប្រាំមួយ) ខែ គិតចាប់ពីថ្ងៃផ្តើមការចរចា ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យាសម្បទានត្រូវរាយការណ៍ជូនទៅគណៈរដ្ឋមន្ត្រី តាមរយៈលេខាធិការដ្ឋានបច្ចេកទេស

-ប្រសិនបើសម្បទានិកខកខានមិនបានចូលមកចរចាក្នុងរយៈពេល៤៥ (សែសិបប្រាំ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលលិខិតអញ្ជើញឱ្យមកចរចាត្រូវបានបញ្ជូលដល់អាសយដ្ឋាន ឬដល់ដៃសម្បទានិក ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យាសម្បទាន ត្រូវរាយការណ៍ជូនគណៈរដ្ឋមន្ត្រី ដើម្បីមាននីវិធានការ។

**មាត្រា៣៩**

គណៈរដ្ឋមន្ត្រីមានសិទ្ធិលើកលែងការកាត់បន្ថយការកាន់កាប់សម្បទានដីសេដ្ឋកិច្ច ដែលមានទំហំសរុបលើសពី១០.០០០ (មួយម៉ឺន) ហិកតា ក្នុងករណីដូចខាងក្រោម៖

-ដីសម្បទាននោះត្រូវបានផ្តល់ឱ្យមុនពេលដែលច្បាប់ភូមិបាលឆ្នាំ២០០១ចូលជាធរមាន

-ការកាត់បន្ថយដីសម្បទាននោះនាំឱ្យខូចប្រយោជន៍អាជីវកម្មដែលកំពុងមានដំណើរការនៅពេលដែលច្បាប់ភូមិបាលចូលជាធរមាន។ ការកាប់ឆ្ការដើមឈើ ឬការដុតព្រៃសំអាតដីមិនត្រូវបានចាត់ទុកជាអាជីវកម្មកំពុងដំណើរការ ឬជាការបំពេញតាមល័ក្ខខ័ណ្ឌនៃការអភិវឌ្ឍដីដែលចែងក្នុងកិច្ចសន្យាឡើយ។

មាត្រា៤០

យោបល់របស់លេខាធិការដ្ឋានបច្ចេកទេសលើសេចក្តីព្រាងរបាយការណ៍ត្រួតពិនិត្យឡើងវិញ លើសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់នីមួយៗដែលផ្តល់ជូនទៅក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យាសម្បទានត្រូវមានបញ្ជាក់សេចក្តីដូចខាងក្រោម៖

-កិច្ចសន្យានោះកំពុងដំណើរការដោយពេញលេញ

-កិច្ចសន្យានោះគួរមានការកែប្រែលើចំណុចជាក់លាក់ ដោយបញ្ជាក់អំពីកិច្ចការដែលត្រូវបំពេញដោយភាគីនៃកិច្ចសន្យា ដើម្បីទទួលយកបានទាំងសង្ខាង

-គួរលុបចោលកិច្ចសន្យានោះដោយមូលហេតុសម្បទានិកបានបំពានលើកិច្ចសន្យា

-ចំពោះដីសម្បទានលើសពី១០.០០០ (មួយម៉ឺន) ហិកតា ត្រូវបញ្ជាក់អំពីការស្ម័គ្រចិត្តកាត់បន្ថយទំហំដីដោយសម្បទានិក ឬត្រូវធ្វើការចរចាដើម្បីកាត់បន្ថយ ឬហេតុផលចាំបាច់សម្រាប់ការលើកលែងការកាត់បន្ថយដីសម្បទាន។ ការជ្រើសរើសដីសម្រាប់កាត់បន្ថយ ត្រូវបញ្ចូលផ្នែកដែលមានទំនាស់ ផ្នែកដែលមិនទាន់បានកាប់ឆ្ការ ផ្នែកដែលមិនទាន់បានអភិវឌ្ឍ និងផ្នែកដែលជាដីសាធារណៈរបស់រដ្ឋ។

មាត្រា៤១

របាយការណ៍ត្រួតពិនិត្យ អនុសាសន៍របស់លេខាធិការដ្ឋានបច្ចេកទេស និងលទ្ធផលចុងក្រោយនៃការត្រួតពិនិត្យឡើងវិញលើសម្បទាននីមួយៗ ត្រូវរក្សាទុកជាឯកសារសាធារណៈ នៅលេខាធិការដ្ឋានបច្ចេកទេស និងនៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង។

មាត្រា៤២

ក្នុងការត្រួតពិនិត្យឡើងវិញនូវសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវធ្វើនិយតកម្មដីក្នុងតំបន់ដីសម្បទានដែលជាកម្មវត្ថុនៃការត្រួតពិនិត្យឡើងវិញ។ ការធ្វើនិយតកម្មដីមានរាប់បញ្ចូលការកែតម្រូវក្បាលដី ការវិនិច្ឆ័យសិទ្ធិលើដីធ្លីរបស់អ្នកកាន់កាប់ក្បាលដីក្នុងតំបន់ត្រួតពិនិត្យឡើងវិញ និងការចុះបញ្ជីក្បាលដីតាមនីតិវិធីជាធរមាន។

**ជំពូកទី៧ ប្រភពធនធាន**

មាត្រា៤៣

ថវិកាសម្រាប់ប្រតិបត្តិការរបស់លេខាធិការដ្ឋានបច្ចេកទេសត្រូវបិតក្នុងកញ្ចប់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ស្របតាមប្រព័ន្ធថវិកាឯកភាព ធនធាន និងថវិការបស់លេខាធិការដ្ឋានបច្ចេកទេសបានមកពីថវិកាជាតិ និងហិរញ្ញប្បទានដែលបានមកពីប្រភពក្នុងស្រុក ឬក្រៅស្រុក ឬពីអ្នកផ្តល់ជំនួយអន្តរជាតិ។

## ជំពូកទី៨ អវសានប្បញ្ញត្តិ

មាត្រា៤៤

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា៤៥

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រធានស្ថាប័ន និងអភិបាលខេត្ត-ក្រុងទាំងអស់ដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

<u>កន្លែងទទួល</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-គ្រប់ក្រសួង ស្ថាប័នកណ្តាល
-គ្រប់សាលាខេត្ត-ក្រុង
-ដូចមាត្រា៤៥
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ០៣៣សហវ/ប្រក *រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមករា ឆ្នាំ២០០៦*

## ប្រកាសអន្តរក្រសួង
## ស្តីពីសោហ៊ុយលើសេវាសំណង់

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទីកដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ០៤អនក្រ/បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ៦២អនក្រ/បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៨៦អនក្រ/បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្ដីពីលិខិតសញ្ញាសាងសង់
- បានឃើញអនុក្រឹត្យលេខ៨១អនក្រ/បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័តរាជធានីភ្នំពេញ និងអង្គការសាធារណរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៨២អនក្រ/បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ៧៩ប្រក/ដនស ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៩ ស្ដីពីការគ្រប់គ្រងសហគ្រាសក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់
- បានឃើញប្រកាសលេខ០០៤សហវ/មប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្ដីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- អនុវត្តតាមសារាចរណែនាំលេខ០០២សហវ/ម ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩៦ ស្ដីពីរដ្ឋទេយ្យចំណូល
- យោងតាមការចាំបាច់លើការងារគ្រប់គ្រងវិស័យសំណង់

**សម្រេច**

**ប្រការ១**

ត្រូវបានបង្កើតសោហ៊ុយលើសេវាសំណង់ ក្នុងការពនិត្យ និងសម្រេចលើការសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋាន លិខិតបិទការដ្ឋាន ឬវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវលើការចុះបញ្ជីប្រកបអាជីវកម្មសាងសង់សិក្សាគម្រោងប្លង់។

**ប្រការ២**

សោហ៊ុយលើសេវាសំណង់មានចែងក្នុងប្រការ១ខាងលើ ត្រូវបានកំណត់ដូចតារាងខាងក្រោមនេះ៖

*វាយឡើងវិញ*

## I-លិខិតអនុញ្ញាតដែលជាសមត្ថកិច្ចរបស់សាលាខេត្ត-ក្រុង

| ល.រ | វាយមុខសេវាកម្ម | សោហ៊ុយសេវា (គិតជាប្រាក់រៀល) | | | | | | | | | | | ទឹកប្រាក់សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ក. ពាក្យសុំ | ខ. តែម | គ.បង្កាន់ដៃទទួលពាក្យ | ឃ.ផ្ទៃក្រឡាកម្រាលសំណង់ | | | | | | | | |
| | | | | | ≤១០០ម$^{២}$ | ≤២០០ម$^{២}$ | ≤៣០០ម$^{២}$ | ≤៤០០ម$^{២}$ | ≤៥០០ម$^{២}$ | ≤១០០០ម$^{២}$ | ≤២០០០ម$^{២}$ | ≤៣០០០ម$^{២}$ | |
| ក-លិខិតអនុញ្ញាតសាងសង់ | | | | | | | | | | | | | |
| ១ | សំណង់លំនៅឋាន | | | | | | | | | | | | |
| | ១.១.ភូមិគ្រឹះ | ២០០០ | ២០០០ | ៥០០ | ១២០០០០ | ១៤០០០០ | ១៦០០០០ | ១៨០០០០ | ២០០០០០ | ២៤០០០០ | ២៨០០០០ | ៣២០០០០ | ក+ខ+គ+ឃ |
| | ១.២.ផ្ទះល្វែង | ២០០០ | ២០០០ | ៥០០ | ៨០០០០ | ១០០០០០ | ១២០០០០ | ១៤០០០០ | ១៦០០០០ | ២០០០០០ | ២៤០០០០ | ២៨០០០០ | ដ |
| | ១.៣.ផ្ទះក្រោមឈើលើ | ២០០០ | ២០០០ | ៥០០ | ៤០០០០ | ៦០០០០ | ៨០០០០ | ១០០០០០ | ១២០០០០ | ១៦០០០០ | ២០០០០០ | ២៤០០០០ | ដ |
| ២ | សំណង់អគារផ្សេងៗក្រៅពីលំនៅឋាន | ២០០០ | ២០០០ | ៥០០ | ១៤០០០០ | ១៦០០០០ | ១៨០០០០ | ២០០០០០ | ២២០០០០ | ២៦០០០០ | ៣០០០០០ | ៣៤០០០០ | ដ |
| ខ-លិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែម រុះរើ ជួសជុល | | | | | | | | | | | | | |
| ១ | សំណង់លំនៅឋាន | | | | | | | | | | | | |
| | ១.១.ភូមិគ្រឹះ | ២០០០ | ២០០០ | ៥០០ | ៨០០០០ | ១០០០០០ | ១២០០០០ | ១៤០០០០ | ១៦០០០០ | ២០០០០០ | ២៤០០០០ | ២៨០០០០ | ក+ខ+គ+ឃ |
| | ១.២.ផ្ទះល្វែង | ២០០០ | ២០០០ | ៥០០ | ៤០០០០ | ៦០០០០ | ៨០០០០ | ១០០០០០ | ១២០០០០ | ១៦០០០០ | ២០០០០០ | ២៤០០០០ | ដ |
| | ១.៣.ផ្ទះក្រោមឈើលើ | ២០០០ | ២០០០ | ៥០០ | ២០០០០ | ៤០០០០ | ៦០០០០ | ៨០០០០ | ១០០០០០ | ១៤០០០០ | ១៨០០០០ | ២២០០០០ | ដ |
| ២ | សំណង់អគារផ្សេងៗក្រៅពីលំនៅឋាន | ២០០០ | ២០០០ | ៥០០ | ១០០០០០ | ១២០០០០ | ១៤០០០០ | ១៦០០០០ | ១៨០០០០ | ២២០០០០ | ២៦០០០០ | ៣០០០០០ | ដ |

*វាយឡើងវិញ*

| ល.រ | វាយមុខសេវាកម្ម | សោហ៊ុយសេវា (គិតជាប្រាក់រៀល) | | | | | | | | | | | ទឹកប្រាក់សុរប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ក. ពាក្យសុំ | ខ. តែម | គ.បង្កាន់ដៃទទួលពាក្យ | ឃ.ផ្ទៃក្រឡាកម្រាលសំណង់ | | | | | | | | |
| | | | | | ≤១០០ម$^{២}$ | ≤២០០ម$^{២}$ | ≤៣០០ម$^{២}$ | ≤៤០០ម$^{២}$ | ≤៥០០ម$^{២}$ | ≤១០០០ម$^{២}$ | ≤២០០០ម$^{២}$ | ≤៣០០០ម$^{២}$ | |
| គ-លិខិតអនុញ្ញាតបើកការដ្ឋាន | | | | | | | | | | | | | |
| ១ | សំណង់លំនៅឋាន | | | | | | | | | | | | |
| | ១.១.ភូមិគ្រឹះ | ២០០០ | ២០០០ | ៥០០ | ២០០០០ | ២៥០០០ | ៣០០០០ | ៣៥០០០ | ៤០០០០ | ៦០០០០ | ៨០០០០ | ១០០០០០ | ក+ខ+គ+ឃ |
| | ១.២.ផ្ទះល្វែង | ២០០០ | ២០០០ | ៥០០ | ១០០០០ | ១៥០០០ | ២០០០០ | ២៥០០០ | ៣០០០០ | ៥០០០០ | ៧០០០០ | ៩០០០០ | ដ |
| | ១.៣.ផ្ទះក្រោមឈើលើ | ២០០០ | ២០០០ | ៥០០ | ៥០០០ | ១០០០០ | ១៥០០០ | ២០០០០ | ២៥០០០ | ៤៥០០០ | ៦៥០០០ | ៨៥០០០ | ដ |
| ២ | សំណង់អគារផ្សេងៗ ក្រៅពីលំនៅឋាន | ២០០០ | ២០០០ | ៥០០ | ៣០០០០ | ២៥០០០ | ៤០០០០ | ៤៥០០០ | ៥០០០០ | ៧០០០០ | ៩០០០០ | ១១០០០០ | ដ |
| ឃ-លិខិតបិទការដ្ឋាន ឬវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ | | | | | | | | | | | | | |
| ១ | សំណង់លំនៅឋាន | | | | | | | | | | | | |
| | ១.១.ភូមិគ្រឹះ | ២០០០ | ២០០០ | ៥០០ | ២៥០០០ | ៣០០០០ | ៣៥០០០ | ៤០០០០ | ៤៥០០០ | ៦៥០០០ | ៨៥០០០ | ១០៥០០០ | ក+ខ+គ+ឃ |
| | ១.២.ផ្ទះល្វែង | ២០០០ | ២០០០ | ៥០០ | ១៥០០០ | ២០០០០ | ២៥០០០ | ៣០០០០ | ៣៥០០០ | ៥៥០០០ | ៧៥០០០ | ៩៥០០០ | ដ |
| | ១.៣.ផ្ទះក្រោមឈើលើ | ២០០០ | ២០០០ | ៥០០ | ១០០០០ | ១៥០០០ | ២០០០០ | ២៥០០០ | ៣០០០០ | ៥០០០០ | ៧០០០០ | ៩០០០០ | ដ |
| ២ | សំណង់អគារផ្សេងៗ ក្រៅពីលំនៅឋាន | ២០០០ | ២០០០ | ៥០០ | ៣៥០០០ | ៤០០០០ | ៤៥០០០ | ៥០០០០ | ៥៥០០០ | ៧៥០០០ | ៩៥០០០ | ១១៥០០០ | ដ |

*វាយឡើងវិញ*

## II-លិខិតអនុញ្ញាតដែលជាសមត្ថកិច្ចក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

| ល.រ | វាយមុខសេវាកម្ម | សោហ៊ុយសេវា (គិតជាប្រាក់រៀល) | | | | | | | | | | | ទឹកប្រាក់សុរប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ក. ពាក្យសុំ | ខ. តែម | គ.បង្កាន់ដៃ ទទួលពាក្យ | ឃ.ផ្ទៃក្រឡាកម្រាលសំណង់ | | | | | | | | |
| | | | | | ≤៤០០០ម$^{២}$ | ≤៦០០០ម$^{២}$ | ≤១០០០០ម$^{២}$ | ≤២០០០០ម$^{២}$ | ≤៤០០០០ម$^{២}$ | ≤៦០០០០ម$^{២}$ | ≤១០០០០០ម$^{២}$ | ≥១០០០០ម$^{២}$ | |
| ក-លិខិតអនុញ្ញាតបើកការដ្ឋាន | | | | | | | | | | | | | |
| ១ | សំណង់លំនៅឋាន | ២០០០ | ២០០០ | ៥០០ | ៣៦០០០០ | ៤៤០០០០ | ៦០០០០០ | ៦៨០០០០ | ៧៦០០០០ | ៨៤០០០០ | ១០០០០០០ | ១៥០០០០០ | ក+ខ+គ+ឃ |
| ២ | សំណង់អគារផ្សេងៗ ក្រៅពីលំនៅឋាន | ២០០០ | ២០០០ | ៥០០ | ៣៨០០០០ | ៤៦០០០០ | ៦២០០០០ | ៧០០០០០ | ៧៨០០០០ | ៨៦០០០០ | ១០២០០០០ | ១៥២០០០០ | ដ |
| ខ-លិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែម រុះរើ ជួសជុល | | | | | | | | | | | | | |
| ១ | សំណង់លំនៅឋាន | ២០០០ | ២០០០ | ៥០០ | ៣២០០០០ | ៤០០០០០ | ៥៦០០០០ | ៦៤០០០០ | ៧២០០០០ | ៨០០០០០ | ៩៦០០០០ | ១៤៦០០០០ | ក+ខ+គ+ឃ |
| ២ | សំណង់អគារផ្សេងៗ ក្រៅពីលំនៅឋាន | ២០០០ | ២០០០ | ៥០០ | ៣៤០០០០ | ៤២០០០០ | ៥៨០០០០ | ៦៦០០០០ | ៧៤០០០០ | ៨២០០០០ | ៩៨០០០០ | ១៤៨០០០០ | ដ |
| គ-លិខិតបើកការដ្ឋាន | | | | | | | | | | | | | |
| ១ | សំណង់លំនៅឋាន | ២០០០ | ២០០០ | ៥០០ | ១៤០០០០ | ២២០០០០ | ៣៨០០០០ | ៤៦០០០០ | ៥៤០០០០ | ៦២០០០០ | ៧៨០០០០ | ១២៨០០០០ | ក+ខ+គ+ឃ |
| ២ | សំណង់អគារផ្សេងៗ ក្រៅពីលំនៅឋាន | ២០០០ | ២០០០ | ៥០០ | ១៥០០០០ | ២៣០០០០ | ៣៩០០០០ | ៤៧០០០០ | ៥៥០០០០ | ៦៣០០០០ | ៧៩០០០០ | ១២៩០០០០ | ដ |
| ឃ-លិខិតបិទការដ្ឋាន ឬវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ | | | | | | | | | | | | | |
| ១ | សំណង់លំនៅឋាន | ២០០០ | ២០០០ | ៥០០ | ១៤៥០០០ | ២២៥០០០ | ៣៨៥០០០ | ៤៦៥០០០ | ៥៤៥០០០ | ៦២៥០០០ | ៧៨៥០០០ | ១២៨៥០០០ | ក+ខ+គ+ឃ |
| ២ | សំណង់អគារផ្សេងៗ ក្រៅពីលំនៅឋាន | ២០០០ | ២០០០ | ៥០០ | ១៥៥០០០ | ២៣៥០០០ | ៣៩៥០០០ | ៤៧៥០០០ | ៥៥៥០០០ | ៦៣៥០០០ | ៧៩៥០០០ | ១២៩៥០០០ | ដ |

*វាយឡើងវិញ*

ផ្ទៃក្រឡាកម្រាលសំណង់ដែលត្រូវយកសោហ៊ុយលើសេវា ចំពោះការសាងសង់ពង្រីកបន្ថែម រុះរើ ជួសជុល គឺត្រូវកំណត់យកតែផ្ទៃក្រឡាកម្រាលសំណង់សាងសង់ពង្រីកបន្ថែម រុះរើ ជួសជុល ដោយមិនបូកបញ្ចូលនូវផ្ទៃក្រឡាកម្រាលសំណង់មានស្រាប់។

III-ការចុះបញ្ជីប្រកបអាជីវកម្មដែលជាសមត្ថកិច្ចមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង

| ល.រ | សោហ៊ុយសេវា (គិតជាប្រាក់រៀល) | | | | | | |
|---|---|---|---|---|---|---|---|
| | ប្រភេទ | ក.ពាក្យសុំ | ខ.តែមប្រិ៍ | គ.បង្កាន់ដៃទទួលពាក្យ | ឃ.វិញ្ញាបនបត្រ | ង.សេវាប្រតិបត្តិ | ទឹកប្រាក់សរុប |
| ក-ចុះបញ្ជីលើកដំបូង | | | | | | | |
| ១ | *ក្រុមជាងសំណង់* | ២000 | ២000 | ៥00 | ២000 | ៦0000 | ក+ខ+គ+ឃ+ង |
| ខ-បន្តសុពលភាព | | | | | | | |
| ២ | *ក្រុមជាងសំណង់* | ២000 | ២000 | ៥00 | ២000 | ៤0000 | ដ |

IV-ការចុះបញ្ជីប្រកបអាជីវកម្មដែលជាសមត្ថកិច្ចក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

| ល.រ | សោហ៊ុយសេវា (គិតជាប្រាក់រៀល) | | | | | | |
|---|---|---|---|---|---|---|---|
| | ប្រភេទ | ក.ពាក្យសុំ | ខ.តែមប្រិ៍ | គ.បង្កាន់ដៃទទួលពាក្យ | ឃ.វិញ្ញាបនបត្រ | ង.សេវាប្រតិបត្តិ | ទឹកប្រាក់សរុប |
| ក-ចុះបញ្ជីលើកដំបូង | | | | | | | |
| ១ | *ប្រភេទ៣ (តូច)* | ២000 | ២000 | ៥00 | ២000 | ១00000 | ក+ខ+គ+ឃ+ង |
| ២ | *ប្រភេទ២ (មធ្យម)* | ២000 | ២000 | ៥00 | ២000 | ២00000 | ដ |
| ៣ | *ប្រភេទ១ (ធំ)* | ២000 | ២000 | ៥00 | ២000 | ៣00000 | ដ |
| ខ-បន្តសុពលភាព | | | | | | | |
| ១ | *ប្រភេទ៣ (តូច)* | ២000 | ២000 | ៥00 | ២000 | ៨0000 | ដ |
| ២ | *ប្រភេទ២ (មធ្យម)* | ២000 | ២000 | ៥00 | ២000 | ១៤0000 | ដ |
| ៣ | *ប្រភេទ១ (ធំ)* | ២000 | ២000 | ៥00 | ២000 | ២00000 | ដ |

*វាយឡើងវិញ*

| គ-ដំឡើងឋានៈប្រភេទ | | | | | | | |
|---|---|---|---|---|---|---|---|
| ល.រ | សោហ៊ុយសេវា (គិតជាប្រាក់រៀល) | | | | | | |
| | ប្រភេទ សុំដំឡើង | ក.ពាក្យសុំ | ខ.តែមប្រើ | គ.បង្កាន់ដៃ ទទួលពាក្យ | ឃ.វិញ្ញាបនបត្រ | ង.សេវា ប្រតិបត្តិតាម ប្រភេទចំណាត់ថ្នាក់នីមួយៗ | ទឹកប្រាក់ សរុប |
| ១ | *ប្រភេទ៣ (តូច)-ប្រភេទ២ (មធ្យម)* | ២០០០ | ២០០០ | ៥០០ | ២០០០ | ១៥០០០០ | ដ |
| ២ | *ប្រភេទ២ (មធ្យម)-ប្រភេទ១ (ធំ)* | ២០០០ | ២០០០ | ៥០០ | ២០០០ | ២៥០០០០ | ដ |

**ប្រការ៣**

ម្ចាស់សំណង់ត្រូវទទួលបន្ទុកបន្ថែមលើថ្លៃបង្គោល និងការដាំបង្គោល។

ចំពោះសំណង់ដែលមានទីតាំងឆ្ងាយលើសពី៥០គីឡូម៉ែត្រពីអង្គភាពជំនាញ ម្ចាស់សំណង់ត្រូវទទួលបន្ទុកបន្ថែមលើ៖

១-សោហ៊ុយធ្វើដំណើរស្នាក់នៅ ហូបចុករបស់មន្ត្រីជំនាញ

២-ចំពោះតំបន់ដាច់ស្រយាល សោហ៊ុយលើសេវាសំណង់ត្រូវគិតបន្ថែម២០% លើសោហ៊ុយសេវាសំណង់សរុប។

**ប្រការ៤**

រាល់ទម្រង់បែបបទ និងការទទួលប្រាក់ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តតាមនីតិវិធីនៃការសុំលិខិតអនុញ្ញាតជាធរមាន។

**ប្រការ៥**

ការបង់ប្រាក់ និងការទទួលប្រាក់ចំណូលពីសោហ៊ុយលើសេវាសំណង់ ត្រូវអនុវត្តតាមរយៈរដ្ឋទេយ្យករចំណូលនៅថ្នាក់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង ឬថ្នាក់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៦**

ការគ្រប់គ្រងចំណូលពីសោហ៊ុយលើសេវាសំណង់ត្រូវអនុវត្តតាមនីតិវិធីនៃកិច្ចប្រតិបត្តិការថវិកាទូទៅរបស់រដ្ឋ។

**ប្រការ៧**

ចំណូលពីសោហ៊ុយលើសេវាសំណង់ត្រូវបង់១០០% ចូលថវិការដ្ឋ ដោយកត់ត្រាក្នុងជំពូក២១ ប្រការ០៣ កថាខណ្ឌ៣០ ថវិកាខេត្ត-ក្រុង និងថវិកាឃុំ-សង្កាត់នៅរតនាគារជាតិ និងខេត្ត-ក្រុង។

**ប្រការ៨**

ចំណូលពីសោហ៊ុយលើសេវាសំណង់ត្រូវបានកំណត់បែងចែកដូចខាងក្រោម៖

ក-ចំណូលពីសោហ៊ុយលើសេវាផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋាន លិខិតបិទការដ្ឋាន ឬវិញ្ញាបនបត្របញ្ជាក់ពីភាពត្រឹមត្រូវសម្រាប់សមត្ថកិច្ចសាលាខេត្ត-ក្រុងត្រូវបាន បែងចែកដូចតទៅ៖

-៣០% សម្រាប់បង់ចូលថវិការដ្ឋ

-៣០% ជាជំណែករបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងសម្រាប់ចាត់ចែងផ្តល់អង្គភាពជំនាញក្រោមឱវាទ

-៣០% សម្រាប់បម្រើឱ្យគុណប្រយោជន៍ថវិកាខេត្ត-ក្រុង ក្នុងនោះមាន១០% ជាចំណែករបស់ស្រុក-ខណ្ឌ

-១០% សម្រាប់បម្រើឱ្យគុណប្រយោជន៍ថវិការបស់ឃុំ-សង្កាត់។

ខ-ចំណូលពីសោហ៊ុយលើសេវាផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋាន លិខិតបិទការដ្ឋាន ឬវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវសម្រាប់សមត្ថកិច្ចក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវបានបែងចែកដូចតទៅ៖

-៣០% សម្រាប់បង់ចូលថវិការដ្ឋ

-៣៥% ជាចំណែករបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងសម្រាប់ចាត់ចែងផ្តល់ដល់អង្គភាពជំនាញក្រោមឱវាទ

-២៥% សម្រាប់បម្រើឱ្យគុណប្រយោជន៍ថវិកាខេត្ត-ក្រុង ក្នុងនោះមាន៨% ជាចំណែករបស់ស្រុក-ខណ្ឌ

-១០% សម្រាប់បម្រើឱ្យគុណប្រយោជន៍ថវិការបស់ឃុំ-សង្កាត់។

គ-ចំណូលពីសោហ៊ុយលើសេវាចុះបញ្ជីប្រកបអាជីវកម្ម សម្រាប់សមត្ថកិច្ចមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុងត្រូវបានបែងចែកដូចតទៅ៖

-៤០% សម្រាប់បង់ចូលថវិការដ្ឋ

-៣៥% ជាចំណែករបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងសម្រាប់ចាត់ចែងផ្តល់ដល់អង្គភាពជំនាញក្រោមឱវាទ

-២៥% សម្រាប់បម្រើគុណប្រយោជន៍ថវិកាខេត្ត-ក្រុង

ឃ-ចំណូលពីសោហ៊ុយលើសេវាចុះបញ្ជីប្រកបអាជីវកម្ម សម្រាប់សមត្ថកិច្ចក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវបានបែងចែកដូចតទៅ៖

-៣០% សម្រាប់បង់ចូលថវិការដ្ឋ

-៧០% ជាចំណែករបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងសម្រាប់ចាត់ចែងផ្តល់ដល់អង្គភាពជំនាញក្រោមឱវាទ។

**ប្រការ៩**

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង និងអគ្គនាយកដ្ឋានជំនាញពាក់ព័ន្ធត្រូវបូកសរុបធ្វើរបាយការណ៍នៃចំណូលនេះជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុង១ត្រីមាសម្តង ដោយភ្ជាប់មកជាមួយនូវសលាកប័ត្របង់ប្រាក់។

ផ្អែកលើការបូកសរុបស្ថានភាពបង់ចំណូលប្រចាំត្រីមាស អង្គភាពដែលមានចំណែកត្រូវលើកសំណើសុំចំណាយក្នុងរង្វង់ភាគរយ (%) នៃចំណូលរបស់ខ្លួនទៅអង្គភាពហិរញ្ញវត្ថុ ដើម្បីពិនិត្យសម្រេចផ្តល់ជូនតាមចំណែកដែលត្រូវបានទទួល តែត្រូវភ្ជាប់មកជាមួយនូវ៖

-សលាកប័ត្របង់ប្រាក់ចំណូលពីសោហ៊ុយលើសេវាសំណង់

-របាយការណ៍ចំណាយនៃចំណែកភាគរយ (%) របស់ខ្លួន ដែលថវិការដ្ឋបានបើកផ្តល់លើកមុនដោយមានភ្ជាប់មកជាមួយនូវសក្ខីប័ត្រគ្រប់គ្រាន់ និងត្រឹមត្រូវ។

*វាយឡើងវិញ*

នីតិវិធីនៃការបើក ផ្តល់ ចំណាយត្រូវធ្វើឡើងតាមរយៈអាណត្តិបើកប្រាក់ ដោយកត់ត្រានៅក្នុងជំពូក១០ ប្រការ០២ កថាខណ្ឌ០៣ វាក្យខណ្ឌ០៧ ដែលមានអាទិភាពក្នុងការបើកផ្តល់សាច់ប្រាក់ ។

**ប្រការ១០**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ១១**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធានរតនាគារជាតិ ប្រធាននាយកដ្ឋានជំនាញ និងអង្គភាពពាក់ព័ន្ធដែលឋិតក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានជំនាញ និងអង្គភាពពាក់ព័ន្ធដែលឋិតនៅក្រោមឱវាទក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

| | | |
|---|---|---|
| <u>ចម្លងជូន</u> | **ទេសរដ្ឋមន្ត្រី** | **ទេសរដ្ឋមន្ត្រី** |
| -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា | **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច** | **រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី** |
| -អគ្គលេខាធិការដ្ឋានរដ្ឋសភា | **និងហិរញ្ញវត្ថុ** | **នគរូបនីយកម្ម និងសំណង់** |
| -អាជ្ញាធរសវនកម្មជាតិ | **ហត្ថលេខា និងត្រា** | **ហត្ថលេខា និងត្រា** |
| -ទីស្តីការគណៈរដ្ឋមន្ត្រី | **គាត់ ឈន់** | **អ៊ឹម ឈុនលឹម** |

-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន
-គ្រប់សាលាខេត្ត-ក្រុង
-ឯកសារ-កាលប្បវត្តិ

*វាយឡើងវិញ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ០៥សសរ

**សេចក្តីសម្រេច**

**ស្តីពីការកំណត់បរិបទនៃការពិនិត្យ និងសម្រេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៨៦អនក្រ/បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ/បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងប្រកាសលេខ៦៤ប្រក/ដនស ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង និងតួនាទីភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ
- យោងលិខិតលេខ៧៧៥ដនស/អដន/០៤ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីកំណែទម្រង់សេវាត្រួតពិនិត្យពាក្យសុំ និងផ្តល់លិខិតអនុញ្ញាតសាងសង់
- យោងលិខិតលេខ១០៨សជណ ចុះថ្ងៃទីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៦ របស់ក្រសួងមហាផ្ទៃ។

## សម្រេច

### ប្រការ១

កំណត់បរិបទនៃការពិនិត្យ និងសម្រេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ដូចខាងក្រោម៖

ក-បរិបទនៃការពិនិត្យ និងសម្រេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ដែលជាសមត្ថកិច្ចរបស់សាលាខេត្ត-ក្រុង

សំណុំឯកសារនៃពាក្យសុំលិខិតអនុញ្ញាតសាងសង់ត្រូវធ្វើតាមរយៈអាជ្ញាធរមូលដ្ឋានឃុំ-សង្កាត់ ស្រុក-ខណ្ឌ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង ឬអង្គការពាក់ព័ន្ធក្នុងករណីចាំបាច់ ហើយបញ្ចូលសំណុំឯកសារនៃពាក្យសុំលិខិតអនុញ្ញាតសាងសង់ដោយមានភ្ជាប់នូវយោបល់ និងមូលវិចាររបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីទៅសាលាខេត្ត-ក្រុង ដើម្បីពិនិត្យ និងសម្រេច ក្នុងរយៈពេលយ៉ាងយូរ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ ដោយកំណត់ដូចខាងក្រោម៖

-ម្ចាស់សំណើត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតសាងសង់ នៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ ដោយឡែកចំពោះក្រុងភ្នំពេញ ម្ចាស់សំណើត្រូវដាក់ពាក្យសុំនៅការិយាល័យរដ្ឋបាលនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី។ ការពិនិត្យ និងសម្រេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង រយៈពេលយ៉ាងយូរ២៥ (ម្ភៃប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតរួមទាំងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ និងនៅសាលាខេត្ត-ក្រុង រយៈពេលយ៉ាងយូរ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ សរុបទាំងអស់៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ (ដូចមានចែងក្នុងឧបសម្ព័ន្ធ I)

-ម្ចាស់សំណើត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតបើកការដ្ឋាន បិទការដ្ឋាន ឬវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង។ ការពិនិត្យ និងសម្រេចលើពាក្យសុំលិខិតអនុញ្ញាតបើកការដ្ឋាននៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង រយៈពេលយ៉ាងយូរ៦ (ប្រាំមួយ) ថ្ងៃនៃថ្ងៃធ្វើការ (ដូចមានចែងក្នុងឧបសម្ព័ន្ធ II សន្លឹក៣)

-ការពិនិត្យ និងសម្រេចលើពាក្យសុំលិខិតបិទការដ្ឋាន ឬវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង រយៈពេលពេលយ៉ាងយូរ៦ (ប្រាំមួយ) ថ្ងៃនៃថ្ងៃធ្វើការ (ដូចមានចែងក្នុងឧបសម្ព័ន្ធ II សន្លឹក៤)

ខ-បរិបទនៃការពិនិត្យ និងសម្រេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ដែលជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សាលាខេត្ត-ក្រុងត្រូវបញ្ជូនសំណុំឯកសារនៃពាក្យសុំលិខិតអនុញ្ញាតសាងសង ដោយភ្ជាប់ជាមួយនូវលិខិតដែលជាយោបល់របស់សាលាខេត្ត-ក្រុង មកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យ និងសម្រេចក្នុងរយៈពេលយ៉ាងយូរ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ ដោយមិនគិតពីរយៈពេល៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការរបស់សមត្ថកិច្ចសាលាខេត្ត-ក្រុង ដោយកំណត់ដូចខាងក្រោម៖

-ការពិនិត្យ និងសម្រេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់នៅអគ្គនាយកដ្ឋានរដ្ឋបាល រយៈពេលយ៉ាងយូរ១ (មួយ) ថ្ងៃនៃថ្ងៃធ្វើការ (ដូចមានចែងក្នុងឧបសម្ព័ន្ធ I សន្លឹក៦)

-ការពិនិត្យ និងសម្រេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់នៅអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម រយៈពេលយ៉ាងយូរ១២ (ដប់ពីរ) ថ្ងៃនៃថ្ងៃធ្វើការ (ដូចមានចែងក្នុបឧបសម្ព័ន្ធ I សន្លឹក៦)

-ការពិនិត្យ និងសម្រេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់នៅអគ្គនាយកដ្ឋានសំណង់ រយៈពេលយ៉ាងយូរ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការ ស្របពេលនៃការពិនិត្យរបស់អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម (ដូចមានចែងក្នុងឧបសម្ព័ន្ធ I សន្លឹក៧)

-ការពិនិត្យ និងសម្រេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់នៅខុទ្ទកាល័យទេសរដ្ឋមន្ត្រី រយៈពេលយ៉ាងយូរ២ (ពីរ) ថ្ងៃនៃថ្ងៃធ្វើការ (ដូចមានចែងក្នុងឧបសម្ព័ន្ធ I សន្លឹក១)

-ម្ចាស់សំណើត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតបើកការដ្ឋាន បិទការដ្ឋាន ឬវិញ្ញាបនបត្រពីភាពត្រឹមត្រូវ នៅនាយកដ្ឋានសំណង់នៃអគ្គនាយកដ្ឋានសំណង់។ ការពិនិត្យ និងសម្រេចលើពាក្យសុំលិខិតអនុញ្ញាតបើកការដ្ឋាននៅអគ្គនាយកដ្ឋានសំណង់ រយៈពេលយ៉ាងយូរ៨ (ប្រាំបី) ថ្ងៃនៃថ្ងៃធ្វើការ (ដូចមានចែងក្នុងឧបសម្ព័ន្ធ II សន្លឹក១)

-ការពិនិត្យ និងសម្រេចលើពាក្យសុំលិខិតបិទការដ្ឋាន ឬវិញ្ញាបនបត្របញ្ជាក់ពីភាពត្រឹមត្រូវ នៅអគ្គនាយកដ្ឋានសំណង់ រយៈពេលយ៉ាងយូរ៦ (ប្រាំមួយ) ថ្ងៃនៃថ្ងៃធ្វើការ (ដូចមានចែងក្នុងឧបសម្ព័ន្ធ II សន្លឹក២)។

គ-នីតិវិធីនៃការពិនិត្យ និងសម្រេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ត្រូវបានកំណត់ដូចខាងក្រោម

-រយៈពេលពិនិត្យ និងសម្រេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់គិតចាប់ពីថ្ងៃដែលរាល់លិខិតស្នាមភ្ជាប់មកជាមួយនឹងពាក្យសុំលិខិតអនុញ្ញាតសាងសង់បានបំពេញគ្រប់គ្រាន់ និងត្រឹមត្រូវ ហើយម្ចាស់សំណើទទួលបានបង្កាន់ដៃទទួលពាក្យសុំ

-ក្នុងករណីសំណុំឯកសារនៃពាក្យសុំមានលក្ខណៈខ្វះខាត ឬខុសឆ្គង មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង ឬអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម និងអគ្គនាយកដ្ឋានសំណង់ ត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកស្នើសុំឱ្យបំពេញបន្ថែម ឬកែតម្រូវ។ រយៈពេលពិនិត្យ និងសម្រេចដែលជាសមត្ថកិច្ចសាលាខេត្ត-ក្រុង ឬក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់លើការបំពេញបន្ថែម ឬកែតម្រូវលើសំណុំឯកសារនៃពាក្យសុំត្រូវគិតជាថ្មី ចាប់ពីថ្ងៃដាក់ពាក្យឡើងវិញនូវពាក្យសុំលិខិតអនុញ្ញាតសាងសង់

-ក្នុងករណីការពិនិត្យ និងសម្រេចលើសំណុំឯកសារនៃពាក្យសុំលិខិតអនុញ្ញាតសាងសង់មានការអូសបន្លាយពេលវេលាលើសពីការកំណត់ ដោយគ្មានមូលហេតុសមស្រប មន្ត្រីពាក់ព័ន្ធត្រូវទទួលខុសត្រូវចំពោះម្ចាស់សំណើ និងច្បាប់ជាធរមាន។

**ប្រការ២**

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន គ្រប់ប្រធាននាយកដ្ឋានពាក់ព័ន្ធ អស់លោក និងលោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីគ្រប់ខេត្ត-ក្រុង ត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ភ្នំពេញ ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ហត្ថលេខា និងត្រា**

**អ៊ឹម ឈុនលឹម**

<u>កន្លែងទទួល</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-គ្រប់សាលាខេត្ត-ក្រុង (ដើម្បីសហការអនុវត្ត)

-ដូចប្រការ២ (ដើម្បីអនុវត្ត)

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ០១សជណ ភ្នំពេញ ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៦

## សេចក្តីជូនដំណឹង
## ស្តីពីការបង់សេវានៃការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ

- យោងមាត្រា២៣០នៃច្បាប់ភូមិបាលឆ្នាំ២០០១ ស្តីពីសោហ៊ុយសេវាសុរិយោដី
- យោងអនុក្រឹត្យលេខ៤៦អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- យោងសារាចរណែនាំលេខ០០១ជនស/សជ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០២ ស្តីពីការអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- អនុលោមតាមលិខិតលេខ០៥៩សហវ/ទរ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមជូនដំណឹងដល់សាធារណជនដែលជាអ្នកកាន់កាប់ ឬអ្នកពាក់ព័ន្ធដីស្រែ ចម្ការ ឬដីសាងសង់ ព្រមទាំងគ្រប់មន្ទីរ អង្គភាព និងស្ថាប័ន ឬភ្នាក់ងារហិរញ្ញវត្ថុដែលមានជាប់ពាក់ព័ន្ធនឹងក្បាលដីទាំងអស់ដែលឋិតនៅក្នុងតំបន់វិនិច្ឆ័យជ្រាបថា នៅពេលទទួលយកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ (ប័ណ្ណកម្មសិទ្ធិ) ម្ចាស់ដីត្រូវបង់សេវានៃការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធតែម្តងគត់ដូចតទៅ៖

១-ដីកសិកម្មជនបទ ១រៀល/ម$^2$

(១០០រៀលសម្រាប់ដីតូចជាង១០០ម$^2$)

២-ដីលំនៅឋានជនបទ ១០រៀល/ម$^2$

៣-ដីទីប្រជុំជនស្រុក ឬដីជាយទីប្រជុំជនខេត្ត ២០រៀល/$ម^2$

៤-ដីទីប្រជុំជនខេត្ត ឬដីជាយទីប្រជុំជនក្រុងភ្នំពេញ ៥០រៀល/$ម^2$

៥-ដីទីប្រជុំជនក្រុងភ្នំពេញ ១០០រៀល/$ម^2$

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន និងសូមចូលរួមអនុវត្តស្មារតីខាងលើឱ្យទទួលបានប្រសិទ្ធភាពខ្ពស់។

ក្រសួងសង្ឃឹមលើការចូលរួមផ្តល់ព័ត៌មានពីសំណាក់សាធារណជន ចំពោះអំពើប្រព្រឹត្តណាដែលផ្ទុយនឹងសេចក្តីជូនដំណឹងនេះ។

**ត.ប ទេសរដ្ឋមន្ត្រី**
**អគ្គនាយករដ្ឋបាល**
**ហត្ថលេខា និងត្រា**
**ណាក សាខន**

ចម្លងជូន
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងមហាផ្ទៃ
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -គ្រប់សាលាខេត្ត-ក្រុង
- -គ្រប់មន្ទីរ ដ.ន.ស.ស ខេត្ត-ក្រុង

(ដើម្បីជូនជ្រាប និងផ្សព្វផ្សាយ)
- -ឯកសារ-កាលប្បវត្តិ

**នស/រកត/០២០៦/០៩៧**

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា**
**រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស**
**កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានការយល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១**

ត្រូវបានបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីដែលមានសមាសភាពដូចតទៅ៖

| | |
|---|---|
| ១-តំណាងនាយករដ្ឋមន្ត្រី | ប្រធាន |
| ២-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធានទី១ |
| ៣-រដ្ឋមន្ត្រីក្រសួងបរិស្ថាន | សមាជិក |
| ៤-រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៥-រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម ថាមពល និងរ៉ែ | សមាជិក |
| ៦-រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៧-រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |

| | |
|---|---|
| ៨-រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៩-រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១០-រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១១-រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១២-អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ១៣-អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ | សមាជិក |
| ១៤-មេបញ្ជាការកងទ័ពជើងគោក | សមាជិក |
| ១៥-មេបញ្ជាការកងទ័ពជើងទឹក | សមាជិក |
| ១៦-មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៧-អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៨-អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រីជាអគ្គលេខាធិការ | សមាជិក |
| ១៩-មេធាវីរាជរដ្ឋាភិបាល | សមាជិក |
| ២០-តំណាងគណបក្សសម រង្ស៊ី | សមាជិក |
| ២១-តំណាងគណបក្សហ៊្វុន ស៊ិន ប៉ិច | សមាជិក |
| ២២-តំណាងអង្គការក្រៅរដ្ឋាភិបាលសំខាន់៧ដែលពាក់ព័ន្ធ | សមាជិក |

សមាសភាពជាក់ស្តែងនឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា២**

អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីនេះអាចមានអនុប្រធានមួយចំនួនតាមការចាំបាច់ ។

តំណាងអង្គការក្រៅរដ្ឋាភិបាលសំខាន់៧ដែលពាក់ព័ន្ធជាសមាជិក នឹងត្រូវតែងតាំងដោយអនុក្រឹត្យ ។

**មាត្រា៣**

អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានបេសកកម្ម តួនាទី និងភារកិច្ចដូចខាងក្រោម៖

-ទប់ស្កាត់ និងកាត់បន្ថយទំនាស់ដីធ្លីតាមរយៈការអប់រំ ផ្សព្វផ្សាយឱ្យសាធារណៈយល់ដឹងអំពីផលវិបាកបណ្តាលមកពីទំនាស់ដីធ្លី និងមានវិធានការដាក់វិន័យចំពោះជនល្មើស ដែលបានរំលោភបំពានលើបញ្ហាដីធ្លីដោយខុសច្បាប់ជាធរមាន

-ទទួលសំណុំរឿងទំនាស់ដីធ្លីដែលហួសពីសមត្ថកិច្ចគណៈកម្មការសុរិយោដីថ្នាក់ជាតិ និងទទួលពាក្យបណ្តឹងពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធទំនាស់ដីធ្លី

-ស្វែងយល់ ស៊ើបអង្កេត និងដោះស្រាយទំនាស់ដីធ្លី

-ឃ្លាំមើលការដោះស្រាយទំនាស់ដីធ្លីរបស់គណៈកម្មការសុរិយោដី និងអាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់

-ធ្វើរបាយការណ៍អំពីលទ្ធផលការងារនៃការដោះស្រាយទំនាស់ដីធ្លី ជូនប្រមុខរាជរដ្ឋាភិបាល ។

**មាត្រា៤**

អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានអគ្គលេខាធិការដ្ឋានជាសេនាធិការ ។

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីដឹកនាំដោយអគ្គលេខាធិការមួយរូប និងអមដោយអគ្គលេខាធិការរងមួយចំនួន ជាជំនួយការ ។

រចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី នឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា៥**

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានតួនាទី និងភារកិច្ចដូចតទៅ៖

-ទទួល និងពិនិត្យសំណុំរឿង ពាក្យបណ្តឹង និងចុះស្វែងយល់ ស៊ើបអង្កេត ហើយធ្វើរបាយការណ៍អំពីលទ្ធផលនៃការស៊ើបអង្កេតពាក់ព័ន្ធនឹងបញ្ហាទំនាស់ដីធ្លី ដើម្បីដាក់ជូនប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ពិនិត្យសម្រេចតាមដំណាក់កាល និងករណីនីមួយៗ

-រៀបចំការប្រជុំ និងធ្វើកំណត់ហេតុអំពីអង្គប្រជុំរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

-ចុះស្វែងយល់ ស៊ើបអង្កេត និងឃ្លាំមើលសកម្មភាពរបស់អាជ្ញាធរមានសមត្ថកិច្ច ក្នុងការដោះស្រាយទំនាស់ដីធ្លីតាមការបញ្ជាណែនាំរបស់ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

-បញ្ជូនកំណត់ហេតុ និងភស្តុតាងទាំងអស់ទៅតុលាការ នៅពេលមានការប្តឹងតវ៉ាលើសេចក្តីសម្រេចរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីទៅតុលាការ

-រៀបចំ និងតម្កល់ទុកឯកសារពាក់ព័ន្ធទំនាស់ និងបណ្តឹងដីធ្លី

-រៀបចំសេចក្តីព្រាងរបាយការណ៍ធំពីសកម្មភាពការងាររបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីជូនប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី តាមកាលកំណត់ដើម្បីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល

-ផ្សព្វផ្សាយជូនសាធារណជនអំពីលទ្ធផលនៃដំណោះស្រាយទំនាស់ដីធ្លីដែលអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីបានដោះស្រាយចប់ជាស្ថាពរ ។

**មាត្រា៦**

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានទីតាំងនៅទីស្តីការគណៈរដ្ឋមន្ត្រី និងមានសិទ្ធិប្រើត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ហើយនិងការចំណាយក្នុងកិច្ចដំណើរការជាបន្ទុករបស់ថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា៧**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៨**

ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

លេខ១០០ច.ល **នរោត្តម សីហមុនី**

**ដើម្បីចម្លងចែក**

**រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៦**

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌
លេខ៣៣០/កយ/រប/០៦ ភ្នំពេញ ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៦

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**
**គោរពជូន**
**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម សំណង់**

កម្មវត្ថុ៖ ស្តីអំពីការអនុវត្តសាលក្រម ឬសាលដីកាស្ថាពរពាក់ព័ន្ធនឹងការផ្ទេរអចលនវត្ថុ។

យោង៖ -ច្បាប់ស្តីអំពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩២

-ច្បាប់ស្តីអំពីប្រាក់ប្រដាប់ក្តី ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៣

-សេចក្តីបង្គាប់លេខ១១៧សរ/រវ/៩៧ ចុះថ្ងៃទី៣១-០១-១៩៩៧របស់ក្រសួងយុត្តិធម៌ ស្តីពីការអនុវត្តសាលក្រម សាលដីកាស្ថាពរ និងសេចក្តីសម្រេចផ្សេងៗរបស់តុលាការ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមទេសរដ្ឋមន្ត្រី មេត្តាជ្រាបថា កន្លងមក ក្រសួងយុត្តិធម៌បានពិនិត្យឃើញថា ក្រោយពីតុលាការបានសម្រេចលើរឿងក្តីរដ្ឋប្បវេណីចប់សព្វគ្រប់ទៅតាមនីតិវិធី និងច្បាប់រួចហើយ ភាគីឈ្នះក្តីមួយចំនួនបានយកសាលក្រម ឬសាលដីកាស្ថាពរពីតុលាការទៅប្រគល់ជូនមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង ដើម្បីស្នើសុំផ្ទេរសិទ្ធិតាមអំណាចសាលក្រម ឬសាលដីកាស្ថាពរដោយខ្លួនឯង។ ជាក់ស្តែង មានករណីខ្លះបានផ្ទេររហូតដល់ជនទីបីដែលក្រោយពីការផ្ទេរសិទ្ធិស្របតាមនីតិវិធីសុរិយោដីរួចក៏មានបណ្តឹងតតិយជនប្តឹងជំទាស់សាលក្រម ឬសាលដីកាស្ថាពរនោះ។ ម្យ៉ាងទៀត ក៏មានភាគីឈ្នះក្តីខ្លះបានយកសាលក្រម ឬសាលដីកាស្ថាពរនោះទៅអនុវត្តដោយពុំទាន់បានបង់ពន្ធសមាមាត្រដែលសាលក្រម ឬសាលដីកាស្ថាពរនោះបានសម្រេចផងដែរ។ ជាហេតុបង្កឱ្យមានការលំបាក និងស្មុគស្មាញក្នុងការដោះស្រាយបញ្ហាទាំងនេះ និងខាតបង់ថវិកាជាតិ។

*វាយឡើងវិញ*

ដោយផ្អែកតាមច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ ១៩៩២ ច្បាប់ស្តីអំពីប្រាក់ប្រដាប់ក្តី ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៣ និងសេចក្តីបង្គាប់លេខ០១៧ សរ/រវ/៩៧ ចុះថ្ងៃទី៣១-០១-១៩៩៧ របស់ក្រសួងយុត្តិធម៌ស្តីពីការអនុវត្តសាលក្រម សាលដីកាស្ថាពរ និងសេចក្តីសម្រេចផ្សេងៗរបស់តុលាការ ខ្ញុំសូមឯកឧត្តមទេសរដ្ឋមន្ត្រីមេត្តាជូនដំណឹងដល់គ្រប់អង្គភាពសុរិយោដីដែលមានសមត្ថកិច្ចអនុវត្តភារកិច្ចអំណាចសាលក្រម ឬសាលដីកាស្ថាពររបស់តុលាការជ្រាបថា ក្នុងករណីមានភាគីឈ្នះក្តីបានយកសាលក្រម ឬសាលដីកាស្ថាពរទៅស្នើសុំផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុ នោះអាជ្ញាធរសុរិយោដីមានសមត្ថកិច្ចត្រូវតម្រូវឱ្យភាគីឈ្នះក្តីយកភ្ជាប់មកជាមួយនូវកំណត់ហេតុអនុវត្តសាលក្រម ឬសាលដីកាស្ថាពររបស់តុលាការ។ ក្នុងករណីភាគីឈ្នះក្តីពុំមានសំអាងណាមួយបញ្ជាក់ថា សាលក្រម ឬសាលដីកាស្ថាពរនោះត្រូវបានអនុវត្តដោយតុលាការទេ អាជ្ញាធរសុរិយោដីមិនអាចធ្វើការផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុតាមសំណើរបស់ភាគីឈ្នះក្តីនោះបានឡើយ ហើយជួយណែនាំឱ្យភាគីឈ្នះក្តីនោះ ទៅស្នើសុំការអនុវត្តសាលក្រម ឬសាលដីកាស្ថាពរនោះពីតុលាការសិន។

ខ្ញុំសង្ឃឹម និងជឿជាក់ថា កាលបើអាជ្ញាធរសុរិយោដីអនុវត្តតាមការណែនាំខាងលើបានត្រឹមត្រូវ អំណឹះតទៅនឹងកាត់បន្ថយបានរាល់បញ្ហាដែលកើតឡើងដូចបានជម្រាបជូនខាងលើជាក់ជាពុំខាន។

សូមឯកឧត្តមទេសរដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

**រដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**អង្គ វង្សវឌ្ឍនា**

<u>ចម្លងជូន</u>

-ក្រសួងមហាផ្ទៃ

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-តុលាការខេត្ត-ក្រុង

"ដើម្បីជូនជ្រាប"

-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ៤២ដនស/ប្រក

ប្រកាស

**ស្តីពីការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ/បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៤៦អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ៤៧អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី

- បានឃើញអនុក្រឹត្យលេខ៤៨អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្ដីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ
- បានឃើញអនុក្រឹត្យលេខ១១៨អនក្រ/បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្ដីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញប្រកាសលេខ៧៦ប្រក/ដនស ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៩ ស្ដីពីតួនាទី និងរចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង និងតួនាទី ភារកិច្ចរបស់បណ្ដាការិយាល័យក្រោមឱវាទ
- តាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**សម្រេច**

**១.បទប្បញ្ញត្តិទូទៅ**

### ប្រការ១ គោលបំណង

ប្រកាសនេះកំណត់ការណែនាំ និងនីតិវិធីលំអិតសម្រាប់ការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ ព្រមទាំងសម្រាប់ការធ្វើចំណាត់ថ្នាក់ដីរដ្ឋថាជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ ក្នុងគោលបំណងអនុវត្តអនុក្រឹត្យលេខ១១៨អនក្រ/បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្ដីពីការគ្រប់គ្រងដីរដ្ឋ។

### ប្រការ២ យន្តការអនុវត្ត

យន្តការសម្រាប់អនុវត្តប្រកាសនេះមានដូចខាងក្រោម៖

"គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង" សំដៅដល់គណៈកម្មាធិការដែលបង្កើតឡើងស្រាបតាមមាត្រា២៤នៃអនុក្រឹត្យ១១៨អនក្រ/បក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥ ស្ដីពីការគ្រប់គ្រងដីរដ្ឋ។

"ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ" សំដៅដល់ក្រុមការងារធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋថ្នាក់ខេត្ត-ក្រុង ដែលបង្កើតឡើងស្របតាមមាត្រា២៧នៃអនុក្រឹត្យលេខ១១៨អនក្រ/បក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥ ស្ដីពីការគ្រប់គ្រងដីរដ្ឋ។

"លេខាធិការដ្ឋាន" សំដៅដល់លេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ដែលបង្កើតឡើងស្របតាមមាត្រា២៦នៃអនុក្រឹត្យលេខ១១៧អនក្រ/បក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥ ស្ដីពីការគ្រប់គ្រងដីរដ្ឋ។

"មន្ត្រី ឬក្រុមមន្ត្រីស៊ើបអង្កេត" សំដៅដល់មន្ត្រី ឬក្រុមមន្ត្រីដែលចាត់តាំងដោយប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង អនុលោមតាមប្រការ២២ ប្រការ២៣ និងប្រការ៣១ នៃប្រកាសនេះ ។

"ក្រុមការងារវាល" សំដៅដល់ក្រុមការងារដែលចាត់តាំងដោយប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ អនុលោមតាមប្រការ១០នៃប្រកាសនេះ ។

## ២.ការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ

### ២.១.ការណែនាំទូទៅសម្រាប់ការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ

**ប្រការ៣ ដំណើរការ**

ការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋជាដំណើរការមួយដែលត្រូវមានលក្ខណៈសម្របសម្រួល និងតម្លាភាពធ្វើឡើងដោយកិច្ចសហការរួមគ្នារវាងក្រសួង ស្ថាប័ន អាជ្ញាធរដែនដី និងប្រជាពលរដ្ឋក្នុងមូលដ្ឋាន ។ ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌត្រូវដំណើរការធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋតាមឃុំ-សង្កាត់នីមួយៗ ដោយចាប់ផ្តើមពីភូមិមួយនៅក្នុងឃុំ-សង្កាត់នោះ ។

**ប្រការ៤ ព័ត៌មានបឋម**

រាល់ព័ត៌មានអំពីក្បាលដីដែលប្រមូលបានត្រូវចាត់ទុកជាព័ត៌មានបឋម និងមិនទាន់មានការបញ្ជាក់ច្បាស់លាស់ជាផ្លូវការរហូតដល់ដីនោះត្រូវបានចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ។

**ប្រការ៥ ផែនទី និងឧបករណ៍សម្រាប់ប្រមូលព័ត៌មាន**

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុងត្រូវផ្តល់ផែនទីអរតូហ្វូតូកម្រិតភូមិ ឃុំ-សង្កាត់ និងស្រុក-ខណ្ឌ (ឬផែនទីរូបថតពីលើអាកាសក្នុងករណីមិនទាន់បានផលិតផែនទីអរតូហ្វូតូ សម្រាប់តំបន់នោះ) ក្រដាសកាល់ប្លង់ផែនទី ឧបករណ៍ GPS និងឧបករណ៍ចាំបាច់ផ្សេងទៀត ជូនក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ និងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង សម្រាប់ប្រើប្រាស់ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ។

**ប្រការ៦ ថវិកា**

ប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌត្រូវរៀបចំផែនការសកម្មភាពលំអិត និងសំណើថវិកាសម្រាប់ចំណាយលើការអនុវត្តសកម្មភាពក្នុងផែនការ ព្រមទាំងលើការតាមដាន និងធ្វើរបាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ។

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងត្រូវពិនិត្យជ្រើសរើស និងបូកសរុបសំណើដើម្បីបញ្ជូនមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នឹងចេញសេចក្តីណែនាំអំពីការរៀបចំគម្រោងថវិកា និងសំណើថវិកាសម្រាប់ចំណាយលើសកម្មភាពក្នុងផែនការទាក់ទងនឹងការគ្រប់គ្រងដីរដ្ឋ ដល់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង និងក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ។

## ២.២.នីតិវិធីនៃការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ

### ២.២.១.ការប្រមូលព័ត៌មាន

**ប្រការ៧ ការត្រៀមរៀបចំ និងការជូនដំណឹង**

មុនចាប់ផ្តើមប្រមូលព័ត៌មាន ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ ត្រូវធ្វើកិច្ចការដូចខាងក្រោម៖

-រៀបចំបញ្ជីឈ្មោះក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងអាជ្ញាធរទាំងអស់ដែលមានក្នុងមូលដ្ឋានស្រុក-ខណ្ឌ

-ស្នើសុំសេចក្តីចម្លងនូវផ្នែកពាក់ព័ន្ធនៃបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ (ដីរដ្ឋក្នុងស្រុកខណ្ឌ ទោះមានអគារ ឬគ្មានអគារ ពីមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត-ក្រុង ដើម្បីពិនិត្យមើលឱ្យដឹងអំពីឈ្មោះក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងអាជ្ញាធរដែលកាន់កាប់គ្រប់គ្រងដីរដ្ឋ នៅក្នុងស្រុកខណ្ឌនោះ។

-រៀបចំ និងផ្តល់សេចក្តីជូនដំណឹងដោយប្រើទម្រង់ដូចក្នុងឧបសម្ព័ន្ធទី១ និងសេចក្តីពន្យល់អំពីគោលបំណងដំណើរការ និងភារកិច្ចទាក់ទងនឹងការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទីនិងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ដល់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងអាជ្ញាធរឃុំ-សង្កាត់នោះ។ ក្នុងសេចក្តីជូនដំណឹងត្រូវមានបញ្ជាក់ពីពេលវេលាដែលបានកំណត់សម្រាប់ចុះជួបប្រមូលព័ត៌មាន និងមានសេចក្តីស្នើឱ្យតំណាងប្រចាំមូលដ្ឋានរបស់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងអាជ្ញាធរពាក់ព័ន្ធរៀបចំប្រមូលឯកសារពាក់ព័ន្ធដីរដ្ឋទុកជាស្រេច មុនការចុះជួបប្រមូលព័ត៌មាន។

-រៀបចំ និងផ្តល់សេចក្តីជូនដំណឹងដល់ប្រជាពលរដ្ឋក្នុងឃុំ-សង្កាត់ ដើម្បីត្រៀមលក្ខណៈចូលរួមផ្តល់មតិ យោបល់លើផែនទី និងព័ត៌មានអំពីដីរដ្ឋដែលនឹងប្រមូលបានពីភូមិ និងឃុំ-សង្កាត់ដោយប្រើប្រាស់ទម្រង់ដូចមានក្នុងឧបសម្ព័ន្ធទី២។

**ប្រការ៨ ការជូនដំណឹងដល់ប្រជាពលរដ្ឋ**

ប្រធានក្រុមការងារជីវរដ្ឋថ្នាក់ស្រុក-ខណ្ឌត្រូវចាត់ចែងបញ្ជូនលិខិតជូនដំណឹងអំពី ការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ជីវរដ្ឋដល់ប្រជាពលរដ្ឋ ទៅគ្រប់មេភូមិ និងមេឃុំ ចៅសង្កាត់ពាក់ព័ន្ធ ដើម្បីបិទផ្សាយនៅសាលាឃុំ-សង្កាត់ នៅទីកន្លែងសាធារណៈ ដូចជា សាលារៀន វត្តអារាម ទីផ្សារ រោងជំនុំ សាលាឆទាន និងនៅមុខផ្ទះរបស់មេភូមិ។ ក្នុងមួយភូមិ ត្រូវផ្តល់លិខិតជូនដំណឹងយ៉ាងតិចចំនួន១០ច្បាប់ ដើម្បីយកទៅបិទផ្សាយជាសាធារណៈ និងរក្សាទុកមួយច្បាប់ដោយមេភូមិ និងមួយច្បាប់រក្សាទុកនៅសាលាឃុំ-សង្កាត់។

មេឃុំ-សង្កាត់ត្រូវចាត់ឱ្យមេភូមិធ្វើការអានប្រកាសសេចក្តីជូនដំណឹងតាមឧត្បោសនសព្ទផងដែរ។ ក្នុងករណីដែលក្នុងភូមិ ឃុំ-សង្កាត់មានជនជាតិដើមភាគតិចរស់នៅ ត្រូវបកប្រែលិខិតជូនដំណឹងជាភាសាជនជាតិនោះ និងពន្យល់ខ្លឹមសារនៃលិខិតជូនដំណឹង ដល់អាជ្ញាធរប្រពៃណីរបស់ក្រុមជនជាតិដើមភាគតិចនីមួយៗ។

**ប្រការ៩ ការប្រមូលព័ត៌មានពីសមាជិកក្រុមការងារជីវរដ្ឋថ្នាក់ស្រុក-ខណ្ឌ**

សមាជិកនីមួយៗនៃក្រុមការងារត្រូវបំពេញតារាងទិន្នន័យស្តីពីការប្រកាសអះអាងជីវរដ្ឋដោយប្រើទម្រង់ដូចក្នុងឧបសម្ព័ន្ធទី៣ និងរៀបចំឯកសារបង្ហាញមតិអះអាងដែលត្រូវបញ្ចប់ក្នុងរយៈពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃចែកតារាងទិន្នន័យ។

ប្រធានក្រុមការងារជីវរដ្ឋថ្នាក់ស្រុក-ខណ្ឌត្រូវរៀបចំការប្រជុំជាមួយសមាជិកក្រុម ដើម្បីធ្វើការគូសបង្ហាញជីវរដ្ឋដែលសមាជិកនីមួយៗបានប្រកាសអះអាងនៅលើក្រដាសកាល់ផែនទីកម្រិតភូមិ។

សមាជិកនីមួយៗនៃក្រុមការងារជីវរដ្ឋថ្នាក់ស្រុក-ខណ្ឌជាអ្នកគូសបង្ហាញដីដែលខ្លួនប្រកាសអះអាងថាជាជីវរដ្ឋ នៅលើក្រដាសកាល់ផែនទីនោះដោយផ្ទាល់ម្នាក់ម្តងៗ ដោយមិនគិតថាគងជាន់លើដីដែលប្រកាសអះអាងដោយតំណាងក្រសួង ស្ថាប័ន អង្គភាពរដ្ឋ ឬអាជ្ញាធរផ្សេងទៀតឡើយ។

នៅក្នុងពេលប្រជុំ សមាជិកណាម្នាក់នៃក្រុមការងារជីវរដ្ឋថ្នាក់ស្រុក-ខណ្ឌអាចបង្ហាញការប្រកាសអះអាង និងភស្តុតាងថ្មីៗទៀតដែលខ្លួនទើបតែរកឃើញ។

ប្រធានក្រុមការងារជីវរដ្ឋថ្នាក់ស្រុក-ខណ្ឌត្រូវចាត់ចែងឱ្យមានបញ្ជីវត្តមានដែលមានចុះហត្ថលេខារបស់អ្នកចូលរួមទាំងអស់ដោយប្រើទម្រង់ដូចក្នុងឧបសម្ព័ន្ធទី៨។

### ២.២.២.ក្រុមការងារវាល

**ប្រការ១០ ការចាត់តាំងក្រុមការងារវាល**

ប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌត្រូវចាត់តាំងក្រុមការងារវាលដែលត្រូវមានសមាជិកយ៉ាងតិចបីនាក់ ក្នុងចំណោមសមាជិកនៃក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ និងត្រូវមានបញ្ចូលមេឃុំ ចៅសង្កាត់ពាក់ព័ន្ធដើម្បីចុះទៅជួបតំណាងក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងអាជ្ញាធរផ្សេងៗទៀតដែលមិនមែនជាសមាជិកនៃក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ ដើម្បីប្រមូលយកព័ត៌មានប្រកាសអះអាងអំពីដីរដ្ឋ និងឯកសារភស្តុតាងនានាដែលគាំទ្រដល់ការប្រកាសអះអាងនោះ។

**ប្រការ១១ ការគូសបង្ហាញព្រំប្រទល់ដីនៅលើក្រដាសកាល់ផែនទីកម្រិតភូមិ**

ក្រុមការងារវាលត្រូវស្នើឱ្យតំណាងក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងអាជ្ញាធរដែលមិនមែនជាសមាជិកនៃក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ គូសបង្ហាញ ឬណែនាំការគូសបង្ហាញការប្រកាសអះអាងនោះនៅលើក្រដាសកាល់ផែនទីកម្រិតភូមិ ដោយផ្ទាល់ម្នាក់ម្តងៗ ដោយមិនគិតថាគងជាន់លើដីដែលប្រកាសអះអាងដោយតំណាងក្រសួង ស្ថាប័ន អង្គភាពរដ្ឋ ឬអាជ្ញាធរផ្សេងទៀតឡើយ។

**ប្រការ១២ ការចុះទៅអង្កេតទីតាំងក្បាលដីដោយក្រុមការងារវាល**

ក្រុមការងារវាលត្រូវចុះទៅវាលជាមួយតំណាងក្រសួង ស្ថាប័ន អង្គភាពរដ្ឋ ឬអាជ្ញាធរដែលបានប្រកាសអះអាងអំពីដីរដ្ឋនៅក្នុងឃុំ-សង្កាត់នោះ ដើម្បីទទួលបានការចង្អុលបង្ហាញទីតាំងជាក់ស្តែង និងព្រំប្រទល់ប្រហាក់ប្រហែលនៃដីនោះ សម្រាប់ធ្វើការផ្ទៀងផ្ទាត់ជាមួយគំនូសនៅលើក្រដាសកាល់ផែនទីកម្រិតភូមិ។ ក្នុងករណីដែលអាចធ្វើទៅបាន ក្រុមការងារវាលត្រូវដើរពិនិត្យមើលស្ថានភាពជុំវិញក្បាលដីនីមួយៗ និងធ្វើការកត់ត្រាទុកជាកំណត់ហេតុនូវរាល់ការសង្កេតឃើញនានាអំពីស្ថានភាពប្រើប្រាស់ដី។

ប្រសិនជាការគូសនៅលើប្លង់ផែនទីមុនពេលចុះវាល ខុសពីភាពជាក់ស្តែងដែលសង្កេតឃើញនៅវាល ក្រុមការងារវាលត្រូវស្នើការឯកភាពពីតំណាងក្រសួង ស្ថាប័ន អង្គភាពរដ្ឋ ឬអាជ្ញាធរដែលប្រកាសអះអាងដើម្បីធ្វើការកែតម្រូវនៅលើក្រដាសកាល់ផែនទីនោះ។ ប្រសិនបើតំណាងនោះមិនយល់ព្រមចំពោះសំណើកែតម្រូវទេ ក្រុមការងារវាលត្រូវរក្សាទុកតាមមតិរបស់តំណាង

នោះ ប៉ុន្តែត្រូវសរសេរកំណត់ហេតុអំពីភាពខុសគ្នារវាងការប្រកាសអះអាង និងភាពមើលឃើញជាក់ស្តែងសម្រាប់បញ្ចូលទៅក្នុងរបាយការណ៍របស់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ និងត្រូវធ្វើកំណត់សម្គាល់នៅលើក្រដាសកាល់ផែនទីត្រង់ចំណុចនៃទីតាំងមានបញ្ហានោះ។

សមាជិកក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌណាម្នាក់ដែលបានអះអាងថាក្រសួង ស្ថាប័ន អង្គភាពរដ្ឋ ឬអាជ្ញាធរដែលខ្លួនតំណាងមានដីរដ្ឋដែលឋិតនៅក្រោមអាណត្តិកាន់កាប់ និងគ្រប់គ្រងរបស់ខ្លួន ឬដឹង និងប្រកាសថាមានដីរដ្ឋនៅក្នុងភូមិ និងឃុំ-សង្កាត់គោលដៅ ចាំបាច់ត្រូវចុះទៅវាលដើម្បីចង្អុលបង្ហាញទីតាំងជាក់ស្តែង និងព្រំប្រទល់ប្រហាក់ប្រហែលនៃដីនោះ និងផ្ទៀងផ្ទាត់គំនូសលើក្រដាសកាល់ផែនទីកម្រិតភូមិ។

**ប្រការ១៣ ការបង្ហាញការប្រើប្រាស់ដីដោយបុគ្គលឯកជន**

ក្នុងករណីក្រុមការងារវាលសង្កេតឃើញមានការកាន់កាប់[11] ឬការប្រើប្រាស់ដោយបុគ្គលឯកជន ឬដោយប្រជាជនចំពោះក្បាលដីទាំងមូល ឬចំណែកណាមួយនៃក្បាលដីដែលតំណាងក្រសួង ស្ថាប័ន អង្គភាពរដ្ឋ ឬអាជ្ញាធរណាមួយបានប្រកាសអះអាងថាជាដីរដ្ឋ ក្រុមការងារវាលត្រូវធ្វើរបាយការណ៍សង្ខេបអំពីស្ថានភាពនៃការកាន់កាប់ ឬការប្រើប្រាស់ និងធ្វើសញ្ញាសម្គាល់នៅលើក្រដាសកាល់ផែនទីនោះ។

**ប្រការ១៤ ការប្រកាសដីរដ្ឋដោយក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងនាមរដ្ឋ**

ទោះក្នុងពេលកំពុងធ្វើការងារវាល ឬក្រោយពេលបញ្ចប់ការងារវាល ក្នុងករណីសង្កេតឃើញមានដីទំនេរដោយគ្មានបុគ្គលឯកជនកាន់កាប់ជាភោគៈស្របច្បាប់ ឬជាកម្មសិទ្ធិ ហើយគ្មានក្រសួង ស្ថាប័ន អង្គភាពរដ្ឋ ឬអាជ្ញាធរណាមួយបានប្រកាសអះអាងថាជាដីរដ្ឋទេនោះ ក្រុមប្រឹក្សាឃុំ-សង្កាត់ដែលពាក់ព័ន្ធមានភារកិច្ចរាយការណ៍ និងពណ៌នាអំពីស្ថានភាព និងលក្ខណៈដីនោះឱ្យច្បាស់ជូនដល់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ ឬក្រុមការងារវាល។ ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ ឬក្រុមការងារវាលត្រូវចាត់ទុកសេចក្តីរាយការណ៍ជូនដំណឹងនោះ ថាជាការប្រកាសដីរដ្ឋដោយក្រុមប្រឹក្សាឃុំ-សង្កាត់នោះក្នុងនាមរដ្ឋ។

---

[11] អត្ថបទផ្លូវការសរសេរ "ការកាន់កាន់" ដែលយើងគិតថាជាការវាយច្រឡំ។

**ប្រការ១៥ ការធ្វើសមាហរណកម្មផែនទីដីរដ្ឋ**

នៅពេលធ្វើការងារវាលចប់សម្រាប់ដីមួយភូមិៗ ក្រុមការងារវាលត្រូវសម្រេចបាននូវប្លង់ផែនទីដីរដ្ឋសម្រាប់ភូមិនោះ ដែលនឹងត្រូវធ្វើសមាហរណកម្មទៅក្នុងផែនទីដីរដ្ឋសរុបសម្រាប់ឃុំ-សង្កាត់នីមួយៗ និងបន្ទាប់មកទៀត ធ្វើសមាហរណកម្មទៅក្នុងផែនទីដីរដ្ឋសរុបសម្រាប់ស្រុកខណ្ឌទាំងមូល។ ផែនទីទាំងនេះ បង្ហាញឱ្យឃើញនូវរាល់ការអះអាង និងការប្រកាសដីរដ្ឋរបស់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងអាជ្ញាធរទាំងអស់ដែលមាននៅក្នុងស្រុក-ខណ្ឌនោះ។ ផែនទីដីរដ្ឋដែលបានធ្វើសមាហរណកម្មរួចហើយនោះ ត្រូវមានបញ្ចូលទាំងការអះអាងស្របគ្នា ការអះអាងមិនស្របគ្នា ការសង្កេតឃើញលើដីជាក់ស្តែងខុសពីការប្រកាសអះអាង និងការកាន់កាប់ ឬប្រើប្រាស់ដោយបុគ្គលឯកជន ឬប្រជាពលរដ្ឋដែលក្រុមការងារវាលបានសង្កេតឃើញ។

ក្រុមការងារវាលត្រូវដាក់ជូនប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌនូវផែនទីបង្ហាញការអះអាង ឬការប្រកាសដីរដ្ឋកម្រិតភូមិ ឃុំ-សង្កាត់ និងស្រុក-ខណ្ឌ ព្រមទាំងរបាយការណ៍ និងកំណត់ហេតុនានាទាក់ទងនឹងការងារវាល ដោយមានចុះហត្ថលេខារបស់សមាជិកទាំងអស់នៃក្រុមការងារវាល នៅពេលបញ្ចប់ការងារវាលសម្រាប់កម្រិតនីមួយៗ។

### ២.២.៣_ការឯកភាពមតិគ្នារបស់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក_ខណ្ឌ

**ប្រការ១៦ ការប្រជុំស្វែងរកការឯកភាពមតិគ្នាលើផែនទី**

ក្នុងរយៈពេល១៥ថ្ងៃបន្ទាប់ពីបានទទួលរបាយការណ៍ និងឯកសារពាក់ព័ន្ធពីក្រុមការងារវាល ប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ ត្រូវរៀបចំការប្រជុំដើម្បីព្យាយាមរកការងារឯកភាពមតិគ្នាចំពោះដីរដ្ឋ ទាក់ទងនឹងអាណត្តិកាន់កាប់ដីរដ្ឋ និងចំណាត់ថ្នាក់ដីរដ្ឋទាំងអស់ ដែលមានក្នុងឃុំ-សង្កាត់នោះ មុននឹងបិទផ្សាយលទ្ធផលជាសាធារណៈ។

ប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌត្រូវអញ្ជើញតំណាងក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងអាជ្ញាធរផ្សេងទៀតដែលមិនមែនជាសមាជិកក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ ប៉ុន្តែបានអះអាងថាក្រសួង ស្ថាប័ន អង្គភាព ឬអាជ្ញាធររបស់ខ្លួនមានអាណត្តិកាន់កាប់ក្បាលដីណាមួយ ឬប្រកាសក្បាលដីណាមួយក្នុងឃុំ-សង្កាត់ថាជាដីរដ្ឋឱ្យចូលរួមក្នុងកិច្ចប្រជុំសម្របសម្រួលនោះផងដែរ។

ប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌត្រូវជូនដំណឹង និងផ្តល់ឯកសារជូនសមាជិកខ្លួនយ៉ាងតិច៧ថ្ងៃ មុនកាលបរិច្ឆេទប្រជុំ។ រាល់សមាជិកនៃក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌត្រូវតែចូលរួមក្នុងកិច្ចប្រជុំនេះ។ សមាជិក ឬតំណាងក្រសួង ស្ថាប័ន អង្គភាពរដ្ឋ ឬអាជ្ញាធរណាមួយដែលមិនចូលរួមក្នុងការប្រជុំ ដោយគ្មានមូលហេតុអាចទទួលយកបាន ត្រូវចាត់ទុកថាឯកភាពតាមសេចក្តីសម្រេចរបស់អង្គប្រជុំនោះ។ ទោះជាយ៉ាងណាក៏ដោយ ការឯកភាពគ្នានោះ មិនអាចផ្ទុយនឹងច្បាប់ និងបទប្បញ្ញត្តិជាធរមានឡើយ។

ដីរដ្ឋដែលមិនទាន់បានប្រគល់ជូនទៅក្រសួង ស្ថាប័ន អង្គភាព ឬអាជ្ញាធរណាមួយជាក់លាក់កាន់កាប់ ត្រូវឋិតក្នុងអាណត្តិកាន់កាប់របស់ថ្នាក់ជាតិ ដែលជាកម្មវត្ថុនៃការធ្វើផែនការបែងចែក។

## ២.២.៤_ការចូលរួមជាសាធារណៈ

### ប្រការ១៧ ការបិទផ្សាយជាសាធារណៈ

បន្ទាប់ពីការប្រជុំសម្របសម្រួល និងបានកែសម្រួលផែនទីដីរដ្ឋតាមលទ្ធផលនៃការប្រជុំ ប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌត្រូវរៀបចំ និងបិទផ្សាយជាសាធារណៈរយៈពេល៣០ថ្ងៃនូវឯកសារដូចតទៅ៖

-សេចក្តីសង្ខេបអំពីការអះអាង ឬការប្រកាសដីរដ្ឋ

-ផែនទីកម្រិតភូមិ និងឃុំ-សង្កាត់ដែលបង្ហាញការអះអាង ឬការប្រកាសដីរដ្ឋ

មេឃុំ ចៅសង្កាត់ពាក់ព័ន្ធត្រូវចាត់ចែងឱ្យមេភូមិធ្វើការបិទផ្សាយសេចក្តីជូនដំណឹង និងប្រកាសជូនដំណឹងដល់ប្រជាពលរដ្ឋតាមឧគ្ឃោសនសព្ទឱ្យមកពិនិត្យមើលលទ្ធផល និងបញ្ចេញមតិ ដោយបញ្ជាក់ទីតាំង និងពេលវេលាបិទផ្សាយឯកសារលទ្ធផលនោះឱ្យបានច្បាស់លាស់ យ៉ាងហោចណាស់មួយកន្លែងក្នុងមួយភូមិ។

ប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌត្រូវចាត់ឱ្យមានអ្នកចាំទទួល ឬកត់ត្រា នៅសាលាឃុំ-សង្កាត់ និង/ឬនៅទីសាធារណៈណាមួយសមស្រប នូវមតិយោបល់របស់ប្រជាជនដោយបង្ហាញឈ្មោះ ឬមិនបាច់បង្ហាញឈ្មោះអ្នកផ្តល់មតិឡើយ (ប៉ុន្តែ ប្រសិនបើជាមតិបញ្ចេញក្នុងនាមជាអាជ្ញាធរ ត្រូវបញ្ជាក់ឈ្មោះ និងតួនាទីរបស់មន្ត្រីនោះ)។ អ្នកចាំទទួល ឬកត់ត្រាមតិយោបល់

សាធារណៈអាចជាមន្ត្រី ឬជាប្រជាពលរដ្ឋក្នុងឃុំ-សង្កាត់ដែលមានចំណេះដឹង រួសរាយរាក់ទាក់ និងចេះសរសេរអក្សរខ្មែរបានច្បាស់លាស់។

ក្នុងករណីដែលមានជនជាតិដើមភាគតិចរស់នៅក្នុងភូមិ ឃុំ-សង្កាត់នោះ ប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌត្រូវរកអ្នកចេះស្តាប់ និងនិយាយភាសាជនជាតិដើមភាគតិចនោះឱ្យជួយបកប្រែជូនអ្នកចាំកត់ត្រា។

ប្រសិនបើមានការផ្តល់មតិយោបល់ជាលាយលក្ខណ៍អក្សរដោយអង្គការសង្គមស៊ីវិល ឬអង្គការក្រៅរដ្ឋាភិបាលដែលមានភ្នាក់ងារប្រចាំមូលដ្ឋានភូមិ ឃុំ-សង្កាត់ អ្នកចាំទទួល ឬកត់ត្រាមតិសាធារណៈត្រូវទទួកយកមតិនោះទុកជូនក្រុមការងារថ្នាក់ស្រុក-ខណ្ឌ និងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងពិចារណា។

**ប្រការ១៨ ការប្រមូល និងសង្ខេបមតិសាធារណៈ**

ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈ៣០ថ្ងៃ ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌត្រូវប្រមូលមតិយោបល់សាធារណៈទាំងអស់ ទោះជាធ្វើដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ហើយត្រូវធ្វើសេចក្តីសង្ខេបមតិយោបល់សាធារណៈទាំងអស់ ទោះជាធ្វើដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ហើយត្រូវធ្វើសេចក្តីសង្ខេបមតិយោបល់សាធារណៈដែលបានទទួល ក្នុងរយៈពេលមិនលើសពី១៥ថ្ងៃ ក្រោយពីការបញ្ចប់ការបិទផ្សាយជាសាធារណៈ ដោយប្រើទម្រង់ដូចក្នុងឧបសម្ព័ន្ធទី៦។

**ប្រការ១៩ ការទាមទារសិទ្ធិឯកជនលើក្បាលដី**

ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌគ្មានសិទ្ធិ និងភារកិច្ចដោះស្រាយ ឬសម្រេចលើការតវ៉ាទាមទារសិទ្ធិឯកជនលើក្បាលដីដោយបុគ្គល ឬប្រជាជនណាមួយឡើយ តែត្រូវបញ្ជាក់ថាព័ត៌មានដែលប្រមូលបាននោះត្រូវបានចាត់ទុកជាព័ត៌មានបឋម និងមិនទាន់មានការបញ្ជាក់ច្បាស់លាស់ជាផ្លូវការ រហូតដល់ដីនោះត្រូវបានចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លី។

**ប្រការ២០ ការរាយការណ៍អំពីការទន្ទ្រានកាន់កាប់ដីរដ្ឋ**

ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌត្រូវយកចិត្តទុកដាក់ខ្ពស់ចំពោះមតិយោបល់ទាក់ទងទៅនឹងប្រយោជន៍សាធារណៈដែលមានចំពោះក្បាលដីណាមួយ ឬការទន្ទ្រានកាន់កាប់ដីរដ្ឋដោយ

ខុសច្បាប់តាមមធ្យោបាយផ្សេងៗ និងត្រូវចាត់វិធានការរក្សាអនាមិកភាព និងការពារសុវត្ថិភាពតាមករណីចាំបាច់ដល់អ្នកផ្តល់ព័ត៌មាន។

### ២.២.៥-របាយការណ៍របស់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ

**ប្រការ២១ ឯកសារដែលត្រូវបញ្ចូលក្នុងរបាយការណ៍**

ក្នុងរយៈពេលមិនលើសពី៣០ថ្ងៃបន្ទាប់ពីបញ្ចប់សេចក្តីសង្ខេបមតិសាធារណៈសម្រាប់ឃុំ-សង្កាត់នីមួយៗ ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌត្រូវបញ្ជូនរបាយការណ៍ (ឧបសម្ព័ន្ធទី៩) និងឯកសារពាក់ព័ន្ធទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង តាមរយៈលេខាធិការដ្ឋាន។ ឯកសារពាក់ព័ន្ធមានដូចតទៅ៖

-បញ្ជីរាយឈ្មោះឯកសារដែលបានបញ្ចូលក្នុងសំណុំរបាយការណ៍ស្តីពីការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ។

-តារាងទិន្នន័យស្តីពីការអះអាងចំពោះការកាន់កាប់[12]ដីរដ្ឋដោយសមាជិកនីមួយៗនៃក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ និងដោយតំណាងក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងអាជ្ញាធរផ្សេងៗទៀតក្នុងភូមិ ឃុំ-សង្កាត់ និងស្រុក-ខណ្ឌពាក់ព័ន្ធ (ឧបសម្ព័ន្ធទី៣)។

-តារាងសង្ខេបទិន្នន័យស្តីពីការអះអាង និងការប្រកាសដីរដ្ឋទាំងអស់ដែលមានក្នុងភូមិ ឃុំ-សង្កាត់ និងស្រុក-ខណ្ឌ (ឧបសម្ព័ន្ធទី៤)។

-គ្រប់ផែនទីទាំងអស់ដែលបានគូរនៅថ្នាក់ភូមិ ឃុំ-សង្កាត់ និងស្រុក-ខណ្ឌ។

-រាល់ឯកសារព័ត៌មាន និងភស្តុតាងទាំងឡាយដែលអាចកំណត់បានថាជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ។

-បញ្ជីវត្តមានដែលមានចុះហត្ថលេខារបស់អ្នកចូលរួមក្នុងរាល់កិច្ចប្រជុំទាំងអស់របស់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ (ឧបសម្ព័ន្ធទី៨)។

-ឯកសារបង្ហាញពីការមិនឯកភាពមតិគ្នា ដោយមានមូលហេតុជាក់លាក់ ហើយត្រូវចុះហត្ថលេខាដោយសមាជិកពាក់ព័ន្ធនៃក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ ឬដោយតំណាងក្រសួង ស្ថាប័ន អង្គភាពរដ្ឋ អាជ្ញាធរផ្សេងៗទៀតដែលបានអះអាង ឬប្រកាសដីរដ្ឋ (ឧបសម្ព័ន្ធទី៥)។

---

[12] អត្ថបទផ្លូវការត្រូវបានសរសេរ "ការកាប់កាប់"។

*វាយឡើងវិញ*

-សេចក្តីសង្ខេបមតិយោបល់សាធារណៈ (ឧបសម្ព័ន្ធទី៦) និងព័ត៌មានពាក់ព័ន្ធផ្សេងៗទៀតប្រសិនបើមាន។

របាយការណ៍របស់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌត្រូវមានសេចក្តីបញ្ជាក់ចំពោះក្បាលដីនីមួយៗ ថាមានតំណាងក្រសួង ស្ថាប័ន អង្គភាពរដ្ឋ ឬអាជ្ញាធរណាខ្លះដែលឯកភាពលើអាណត្តិកាន់កាប់ដីនោះ និង/ឬលើចំណាត់ថ្នាក់ដីនោះ និងតំណាងណាខ្លះដែលមិនឯកភាព ហើយត្រូវចុះហត្ថលេខាដោយប្រធានក្រុមការងារ និងត្រូវចម្លងចែកជូនដល់រាល់សមាជិក និងតំណាងក្រសួង ស្ថាប័ន អង្គភាពរដ្ឋ អាជ្ញាធរពាក់ព័ន្ធទាំងអស់ ដើម្បីពិនិត្យមើលក្នុងរយៈពេល៣ថ្ងៃធ្វើការ មុននឹងបញ្ជូនរបាយការណ៍ទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង។

ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌត្រូវធ្វើការបិទផ្សាយជាសាធារណៈនូវសេចក្តីសង្ខេបមតិយោបល់សាធារណៈ។

**២.២.៦_ការសម្របសម្រួលដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង**

**ប្រការ២២ ការប្រជុំសម្របសម្រួល**

ក្នុងរយៈពេលយ៉ាងយូរ៣០ថ្ងៃ បន្ទាប់ពីបានទទួលរបាយការណ៍ពីក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងត្រូវរៀបចំការប្រជុំ ដើម្បីត្រួតពិនិត្យមើលរបាយការណ៍នោះ។

ក្នុងករណីមានការប្រកាសអះអាងស្របគ្នា ឬមានការឯកភាពមតិគ្នានៅថ្នាក់ស្រុក-ខណ្ឌលើក្បាលដីណាមួយ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង អាចទទួលយកតាមមតិនោះ ឬអាចត្រួតពិនិត្យឡើងវិញមុននឹងបញ្ចូលព័ត៌មានអំពីក្បាលដីនោះទៅក្នុងប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋ។

ប្រសិនបើមានការប្រកាសអះអាងមិនស្របគ្នាលើក្បាលដីណាមួយ ជាពិសេសជាមួយមតិរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានភូមិ ឃុំ-សង្កាត់ ត្រូវព្យាយាមស្វែងរកការឯកភាពមតិគ្នាលើករណីមិនស្របគ្នានោះ។ ប្រសិនបើមិនមានការឯកភាពគ្នា ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងត្រូវចាត់ឱ្យមានមន្ត្រីម្នាក់ ឬច្រើននាក់ ដែលជាសមាជិកនៃគណៈកម្មាធិការ និង/ឬលេខាធិការដ្ឋានដើម្បីចុះទៅធ្វើការស៊ើបអង្កេតដល់ទីកន្លែង និងធ្វើសម្ភាសន៍ជាមួយបុគ្គលពាក់ព័ន្ធ។

មន្ត្រី ឬក្រុមមន្ត្រីស៊ើបអង្កេតត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីការរកឃើញរបស់ខ្លួន ដើម្បីដាក់ជូនដល់គណៈកម្មាធិការពិនិត្យពិចារណា។

**ប្រការ២៣ រយៈពេលស៊ើបអង្កេត**

ជាទូទៅ មន្ត្រី ឬក្រុមមន្ត្រីស៊ើបអង្កេតត្រូវបញ្ចប់ការស្រាវជ្រាវស៊ើបអង្កេត និងធ្វើរបាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ក្នុងរយៈពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃចាត់តាំង។ ក្នុងករណីស្មុគស្មាញ ប្រធានគណៈកម្មាធិការអាចអនុញ្ញាតឱ្យមន្ត្រី ឬក្រុមមន្ត្រីស៊ើបអង្កេតបន្តរយៈពេលស៊ើបអង្កេតរហូតដល់៣០ថ្ងៃបន្ថែមទៀត សម្រាប់ក្បាលដីដែលមានបញ្ហានីមួយៗ។

**ប្រការ២៤ ការបញ្ចប់ការគូរប្លង់ផែនទី**

ក្នុងរយៈពេលមិនលើសពី១៥ថ្ងៃបន្ទាប់ពីបានទទួលរបាយការណ៍ស៊ើបអង្កេត និងធ្វើរបាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ត្រូវកោះប្រជុំគណៈកម្មាធិការនេះ ដើម្បីស្វែងរកការឯកភាពមតិគ្នារវាងសមាជិកទាំងអស់នៃគណៈកម្មាធិការ។ ករណីមិនមានការឯកភាពមតិគ្នា ត្រូវធ្វើឯកសារដោយប្រើទម្រង់ដូចក្នុងឧបសម្ព័ន្ធទី៥។ នៅដំណាក់កាលនេះ ការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋក្នុងឃុំ-សង្កាត់នោះត្រូវបានបញ្ចប់។

**២.២.៧.ការបញ្ចូលលទ្ធផលទៅក្នុងប្រព័ន្ធទិន្នន័យ ការងារតាមដាន និងការរាយការណ៍**

**ប្រការ២៥ ការបញ្ចូលលទ្ធផលទៅក្នុងប្រព័ន្ធទិន្នន័យ**

លេខាធិការដ្ឋានត្រូវបញ្ចូលលទ្ធផលទៅក្នុងប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋថ្នាក់ខេត្ត-ក្រុង ដែលត្រូវបង្កើតឡើង ថែរក្សា និងធ្វើចរន្តការ ស្របតាមអនុក្រឹត្យលេខ១១៨អនក្រ/បក ស្តីពីការគ្រប់គ្រងដីរដ្ឋ។

លេខាធិការដ្ឋានត្រូវរៀបចំចម្លងព័ត៌មានទិន្នន័យដីរដ្ឋ និងផែនទីដីរដ្ឋ ដើម្បីផ្តល់ជូនក្រសួង ស្ថាប័ន អង្គភាពរដ្ឋ អាជ្ញាធរនៅថ្នាក់ខេត្ត-ក្រុង ស្រុក-ខណ្ឌ ឃុំ-សង្កាត់ និងសាធារណជនដូចមានចែងក្នុងប្រការ៣៦ និងប្រការ៣៨នៃប្រកាសនេះ និងបទប្បញ្ញត្តិទាក់ទងនឹងការបង្កើត ការថែរក្សា និងការធ្វើចរន្តការប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋ សម្រាប់សម្រួលដល់ការចូលរួមតាមដានការប្រើប្រាស់ ឬការគ្រប់គ្រងដីរដ្ឋនៅក្នុងមូលដ្ឋាន។

**ប្រការ២៦ ការងារតាមដាន និងការរាយការណ៍**

ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌមានភារកិច្ចតាមដាន និងរាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង រៀងរាល់៦ខែម្តង (ក្នុងករណីចាំបាច់ត្រូវរាយការណ៍ជាបន្ទាន់) អំពីការវិវត្តប្រែប្រួលលើលក្ខណៈស្ថានភាព និងការប្រើប្រាស់ដីរដ្ឋទាំងឡាយក្នុងស្រុក-ខណ្ឌដែលត្រូវបានធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទី ព្រមទាំងរាយការណ៍ និងផ្តល់ព័ត៌មានច្បាស់លាស់អំពីការរកឃើញដីរដ្ឋថ្មីៗទៀត ដែលមានក្នុងស្រុក-ខណ្ឌ ប្រសិនបើមាន។

ក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងអាជ្ញាធរមានភារកិច្ចសហការផ្តល់ព័ត៌មានអំពីការប្រើប្រាស់ដីរដ្ឋ ក្នុងស្រុក-ខណ្ឌដែលឋិតនៅក្រោមអាណត្តិកាន់កាប់របស់ខ្លួនដល់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌតាមការស្នើសុំរបស់ប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ ស្របតាមការចែងក្នុងមាត្រា៦នៃអនុក្រឹត្យលេខ១១៨អនក្រ/បក ស្តីពីការគ្រប់គ្រងដីរដ្ឋ។

## ៣.ការធ្វើចំណាត់ថ្នាក់ដីរដ្ឋ

### ៣.១.ការណែនាំទូទៅសម្រាប់ការធ្វើចំណាត់ថ្នាក់ដីរដ្ឋ

**ប្រការ២៧ ដំណើរការ**

ការធ្វើចំណាត់ថ្នាក់ដីរដ្ឋគឺជាដំណើរការធ្វើសេចក្តីសម្រេចផ្នែករដ្ឋបាលលើក្បាលដីរដ្ឋ។

ការធ្វើចំណាត់ថ្នាក់ដីរដ្ឋអាចធ្វើឡើងក្នុងដំណើរការនៃការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ ឬអាចធ្វើឡើងនៅពេលមានតម្រូវការដីឯកជនរបស់រដ្ឋ សម្រាប់បែងចែកតាមរយៈគម្រោងសម្បទានដីសេដ្ឋកិច្ច គម្រោងសម្បទានដីសង្គមកិច្ច លក់ ដោះដូរ ឬជួលដីរដ្ឋ។

ការធ្វើចំណាត់ថ្នាក់ដីរដ្ឋត្រូវចាត់ទុកថាបានសម្រេចតាមផ្លូវច្បាប់ ក្រោយពេលដែលក្បាលដីនោះត្រូវបានចុះក្នុងបញ្ជីថាជាដីសាធារណៈរបស់រដ្ឋ ឬដីឯកជនរបស់រដ្ឋ។

**ប្រការ២៨ ករណីដែលតម្រូវឱ្យអនុវត្តនីតិវិធីនៃការធ្វើចំណាត់ថ្នាក់ដីរដ្ឋ**

ក្បាលដីដែលតម្រូវឱ្យអនុវត្តនីតិវិធីនៃការធ្វើចំណាត់ថ្នាក់គឺ៖

១-ដីដែលត្រូវបានចុះបញ្ជីថាជាដីរដ្ឋនៅក្នុងការអនុវត្តការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ប៉ុន្តែមិនទាន់បានធ្វើចំណាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋនៅឡើយ។

វាយឡើងវិញ

២-ដីដែលជាកម្មវត្ថុនៃការចុះបញ្ជីដីរដ្ឋមានលក្ខណៈដាច់ដោយដុំលើកដំបូង តាមការស្នើសុំរបស់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋ ឬអាជ្ញាធរថ្នាក់ណាមួយ ហើយដែលដីនោះមិនទាន់អាចចុះបញ្ជីបានដោយសារមានការប្រកាសអះអាងមិនស្របគ្នា នៅពេលបញ្ចប់ការធ្វើអត្តសញ្ញាណកម្ម និងផែនទីដីរដ្ឋ ឬមិនទាន់មានការឯកភាពលើការធ្វើចំណាត់ថ្នាក់លើក្បាលដីនោះ។

៣-ដីដែលជាកម្មវត្ថុនៃការចុះបញ្ជីដីរដ្ឋមានលក្ខណៈដាច់ដោយដុំលើកដំបូង តាមការស្នើសុំដោយក្រសួង ស្ថាប័ន អង្គភាពរដ្ឋ ឬអាជ្ញាធរថ្នាក់ណាមួយ ហើយដែលដីនោះមិនទាន់អាចចុះបញ្ជីបាន ដោយសារគ្មានព័ត៌មានច្បាស់លាស់អំពីឋានៈ និងការប្រើប្រាស់បច្ចុប្បន្ននៃដីនោះ។

## ៣.២-នីតិវិធីនៃការធ្វើចំណាត់ថ្នាក់ដីរដ្ឋ

### ប្រការ២៩ ពេលទទួលបានសំណើឱ្យលើកអនុសាសន៍

នៅពេលទទួលបានសំណើជាលាយលក្ខណ៍អក្សរ ស្តីពីការស្នើសុំធ្វើចំណាត់ថ្នាក់ដីរដ្ឋណាមួយពីក្រុមការងារចុះបញ្ជីដីធ្លី ឬពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬពីរាជរដ្ឋាភិបាលសម្រាប់គោលបំណងនៃការចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លី ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងត្រូវកោះប្រជុំសមាជិកទាំងអស់នៃគណៈកម្មាធិការនេះ ដើម្បីពិភាក្សាសម្រេចលើកអនុសាសន៍អំពីចំណាត់ថ្នាក់នៃដីនោះ ដើម្បីជូនទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្របតាមប្រការ៣០ ប្រការ៣១ និងប្រការ៣២នៃប្រកាសនេះ។

### ប្រការ៣០ ករណីបានធ្វើអត្តសញ្ញាណកម្ម និងផែនទីដីរដ្ឋរួចហើយ

ក្នុងករណីដែលបានធ្វើអត្តសញ្ញាណកម្ម និងផែនទីដីរដ្ឋរួចហើយ ប៉ុន្តែមិនមានការឯកភាពមតិគ្នាអំពីចំណាត់ថ្នាក់ក្បាលដី គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងត្រូវ៖

-ពិនិត្យពិចារណាលើរបាយការណ៍របស់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ និងមតិយោបល់សាធារណៈទាំងឡាយដែលបានសង្ខេបបញ្ចូលជាផ្នែកមួយនៃរបាយការណ៍

-កំណត់បទប្បញ្ញត្តិជាក់លាក់នៃច្បាប់ភូមិបាល និង/ឬនៃច្បាប់ផ្សេងៗទៀតដែលត្រូវយកមកអនុវត្តក្នុងការធ្វើចំណាត់ថ្នាក់ដីរដ្ឋនោះ។

-បញ្ចប់ការពិនិត្យពិចារណាក្នុងរយៈពេល៤៥ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលសំណើ

-លើកអនុសាសន៍ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លី បើមានការឯកភាពមតិគ្នាលើចំណាត់ថ្នាក់ដីនោះ

-ធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដើម្បីពិនិត្យពិចារណាបន្ត បើមិនមានការឯកភាពមតិគ្នាលើចំណាត់ថ្នាក់ដីនោះ។

**ប្រការ៣១ ករណីមិនទាន់បានធ្វើអត្តសញ្ញាណកម្ម និងផែនទីដីរដ្ឋ**

ក្នុងករណីដែលមិនទាន់បានធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋៈ

ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងត្រូវចាត់តាំងឱ្យមានក្រុមស៊ើបអង្កេតលើការអះអាងដែលមិនស្របគ្នា (ប្រសិនបើមាន) របស់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋ ឬអាជ្ញាធរ និងរៀបចំដំណើរការផ្ដល់ឱកាសឱ្យសាធារណជនជាចូលរួមលើការធ្វើចំណាត់ថ្នាក់ដីនោះ។

ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងត្រូវផ្ដល់លិខិតជូនដំណឹងអំពីការធ្វើចំណាត់ថ្នាក់ដីរដ្ឋលើក្បាលដីជាក់លាក់ទៅឱ្យគ្រប់មេភូមិ និងមេឃុំ ចៅសង្កាត់ពាក់ព័ន្ធតាមរយៈប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌដើម្បីបិទផ្សាយរយៈពេល១៥ថ្ងៃ ជូនប្រជាពលរដ្ឋនៅទីតាំងក្បាលដីនោះ នៅសាលាឃុំ-សង្កាត់ និងនៅមុខផ្ទះរបស់មេភូមិ។ ក្នុងករណីដែលក្នុងភូមិ ឃុំ សង្កាត់មានជនជាតិភាគតិចរស់នៅ ត្រូវបកប្រែលិខិតជូនដំណឹងជាភាសាជនជាតិនោះ និងពន្យល់ខ្លឹមសារនៃលិខិតជូនដំណឹងដល់អាជ្ញាធរប្រពៃណីរបស់ក្រុមជនជាតិដើមភាគតិចនីមួយៗ។

ដោយអនុវត្តការចែងក្នុងវាក្យខណ្ឌទី៣ និងទី៤នៃប្រការ១៧ សម្រាប់រយៈពេលបិទផ្សាយជាសាធារណៈ ប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌត្រូវចាត់ឱ្យមានអ្នកចាំទទួល ឬកត់ត្រានូវមតិយោបល់សាធារណៈទាំងអស់ ទោះជាធ្វើដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ហើយត្រូវធ្វើសេចក្ដីសង្ខេបមតិយោបល់សាធារណៈដែលបានទទួលដោយប្រើទម្រង់ដូចក្នុងឧបសម្ព័ន្ធទី៦ ដើម្បីប្រគល់ឱ្យក្រុមស៊ើបអង្កេត។

ប្រសិនបើមានការផ្ដល់មតិយោបល់ជាលាយលក្ខណ៍អក្សរដោយអង្គការសង្គមស៊ីវិល ឬអង្គការក្រៅរដ្ឋាភិបាលដែលមានភ្នាក់ងារប្រចាំមូលដ្ឋានភូមិ ឃុំ-សង្កាត់ អ្នកចាំទទួល ឬកត់ត្រាមតិសាធារណៈត្រូវទទួលយកមតិនោះផ្ដល់ជូនក្រុមស៊ើបអង្កេត ដើម្បីដាក់ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងពិចារណា។

ក្រុមស៊ើបអង្កេតត្រូវអង្កេតលើស្ថានភាពប្រើប្រាស់ដីបច្ចុប្បន្ន និងពិនិត្យពិចារណាលើមតិយោបល់របស់ប្រជាពលរដ្ឋ និងមតិរបស់អាជ្ញាធរដែនដីក្នុងមូលដ្ឋាន។

ក្រុមស៊ើបអង្កេតត្រូវបញ្ចប់ការស៊ើបអង្កេតរបស់ខ្លួន និងធ្វើរបាយការណ៍ដែលមានបញ្ចូលទាំងសេចក្តីសង្ខេបមតិរបស់ប្រជាពលរដ្ឋ និងមតិរបស់អាជ្ញាធរដែនដីជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ក្នុងរយៈពេលមិនលើសពី៤៥ថ្ងៃគិតចាប់ពីថ្ងៃចាត់តាំង។

បន្ទាប់ពីបានទទួលរបាយការណ៍ស៊ើបអង្កេត គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុងត្រូវពិនិត្យ ពិចារណាលើរបាយការណ៍ និងមតិយោបល់ទាំងឡាយ ព្រមទាំងកំណត់បទប្បញ្ញត្តិជាក់លាក់ដែលមានចែងក្នុងច្បាប់ភូមិបាល និង/ឬច្បាប់ផ្សេងៗទៀតដែលត្រូវយកមកអនុវត្តក្នុងការធ្វើចំណាត់ថ្នាក់ដីរដ្ឋនោះ។

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងត្រូវបញ្ចប់ការពិនិត្យ ពិចារណាខាងលើនេះ ក្នុងរយៈពេលមិនលើសពី៤៥ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលរបាយការណ៍ស៊ើបអង្កេតនោះ។

មុននឹងបញ្ចូលអនុសាសន៍ទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងត្រូវបញ្ជូនខ្លឹមសារនៃអនុសាសន៍របស់ខ្លួនទៅឱ្យប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌដើម្បីបិទផ្សាយជាសាធារណៈ នៅទីតាំងក្បាលដី នៅសាលាឃុំសង្កាត់ និងនៅមុខផ្ទះមេភូមិ ដោយមានសេចក្តីបញ្ជាក់ថាខ្លឹមសារអនុសាសន៍នេះមិនមែនជាសេចក្តីសម្រេចផ្លូវការ និងមិនទាន់អាចយកទៅអនុវត្តបានឡើយ។

**ប្រការ៣២ ការពិចារណា និងរបាយការណ៍**

ក្នុងការពិនិត្យពិចារណាលើរបាយការណ៍របស់ក្រុមស៊ើបអង្កេត គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងត្រូវខិតខំស្វែងរកការឯកភាពមតិគ្នា ក្នុងចំណោមសមាជិកទាំងអស់លើចំណាត់ថ្នាក់ដីនោះ ដោយអនុលោមតាមច្បាប់ភូមិបាល ព្រមទាំងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតដែលពាក់ព័ន្ធ។

ក្រោយពីបានពិចារណាសម្រេច៖

-ប្រសិនបើគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងអាចសម្រេចបានការឯកភាពមតិគ្នាលើការធ្វើចំណាត់ថ្នាក់ដីនោះ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ត្រូវលើកអនុ-

សាសន៍ជាលាយលក្ខណ៍អក្សរជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងរយៈពេលកំណត់៤៥ថ្ងៃ

-ប្រសិនបើគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងមិនអាចសម្រេចបានការឯកភាពមតិគ្នាអំពីចំណាត់ថ្នាក់នៃដីនោះទេ ប្រធានគណៈកម្មាធិការនេះត្រូវធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដើម្បីពិចារណាបន្ត និងត្រូវជូនដំណឹងដល់អ្នកដែលស្នើសុំអនុសាសន៍ផងដែរ

របាយការណ៍របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងត្រូវមានបញ្ជាក់អំពីសមាជិកដែលឯកភាព ឬមិនឯកភាពលើចំណាត់ថ្នាក់ដីនោះ ហើយត្រូវចុះហត្ថលេខាដោយប្រធានគណៈកម្មាធិការ និងត្រូវចែកជូនដល់សមាជិកទាំងអស់យ៉ាងតិច៣ថ្ងៃធ្វើការ ដើម្បីពិនិត្យមុននឹងបញ្ជូនមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬក្រុមប្រឹក្សាគោលនយោបាយដីធ្លី។ សមាជិកនៃគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងដែលមិនឯកភាព ត្រូវផ្តល់ជូនប្រធានគណៈកម្មាធិការនូវមតិសង្ខេបរបស់ខ្លួនទាក់ទងនឹងក្បាលដីជាក់លាក់នោះ ដោយប្រើទម្រង់ដូចក្នុងឧបសម្ព័ន្ធទី៥ សម្រាប់ភ្ជាប់ជាមួយរបាយការណ៍។

**ប្រការ៣៣ ការពិនិត្យអនុសាសន៍ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

ប្រសិនបើក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់យល់ព្រមតាមអនុសាសន៍របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ក្រសួងត្រូវចុះបញ្ជីចំណាត់ថ្នាក់ដីក្នុងសៀវភៅគោលបញ្ជីដីធ្លី ស្របតាមអនុសាសន៍នោះ។ ប្រសិនបើក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មិនយល់ស្របតាមអនុសាសន៍នោះទេ ដោយឈរលើមូលដ្ឋានអង្គហេតុ ឬអង្គច្បាប់ច្បាស់លាស់ ក្រសួងត្រូវបញ្ជូនករណីនោះទៅក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដើម្បីបន្តស្វែងរកការឯកភាពមតិគ្នាមួយកម្រិតទៀត។

**ប្រការ៣៤ ការពិនិត្យដោយក្រុមប្រឹក្សាគោលនយោបាយដីធ្លី**

ក្នុងករណីទទួលបានឯកសារស្តីពីការធ្វើចំណាត់ថ្នាក់ដីរដ្ឋ៖

-ក្រុមប្រឹក្សាគោលនយោបាយដីធ្លីត្រូវធ្វើការប្រជុំដើម្បីពិនិត្យពិចារណា និងសម្រេចលើសំណើសុំធ្វើចំណាត់ថ្នាក់ដីរដ្ឋ និងរបាយការណ៍ពាក់ព័ន្ធក្នុងរយៈពេលមិនលើសពី៦០ថ្ងៃបន្ទាប់ពីបានទទួលរបាយការណ៍។

-ប្រសិនបើក្រុមប្រឹក្សាគោលនយោបាយដីធ្លីអាចសម្រេចបានការឯកភាពគ្នាក្នុងចំណោមសមាជិកក្រុមប្រឹក្សា អំពីចំណាត់ថ្នាក់នៃដីនោះថាជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋផ្អែកលើមូលដ្ឋានច្បាប់ភូមិបាល ព្រមទាំងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតដែលពាក់ព័ន្ធ ក្រុមប្រឹក្សាគោលនយោបាយដីធ្លីត្រូវផ្តល់អនុសាសន៍ជាលាយលក្ខណ៍អក្សរជូនទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីធ្វើការចុះបញ្ជីដីរដ្ឋនោះស្របតាមអនុសាសន៍

-ប្រសិនបើក្រុមប្រឹក្សាគោលនយោបាយដីធ្លីមិនអាចសម្រេចបានការឯកភាពមតិគ្នាអំពីឋានៈ និងចំណាត់ថ្នាក់នៃដីនោះទេ ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លីត្រូវបញ្ជូនសំណុំឯកសារនៃករណីនោះទៅគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យសម្រេចលើការធ្វើចំណាត់ថ្នាក់ដីនោះ និងជូនដំណឹងដល់អ្នកស្នើសុំអនុសាសន៍។

**ប្រការ៣៥ ក្រោយមានការសម្រេចដោយគណៈរដ្ឋមន្ត្រី**

ក្រោយពេលបានទទួលឯកសារនៃសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រីអំពីចំណាត់ថ្នាក់នៃដីនោះ ថាជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចុះបញ្ជីចំណាត់ថ្នាក់ដីរដ្ឋនោះក្នុងសៀវភៅគោលបញ្ជីដីធ្លីស្របតាមសេចក្តីសម្រេចនោះ។

**៤-ឯកសារសាធារណៈ**

**ប្រការ៣៦ ការរក្សាទុកឯកសារនៅលេខាធិការដ្ឋាន**

ឯកសារព័ត៌មាន ផែនទីដីរដ្ឋ របាយការណ៍របស់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ របាយការណ៍ស៊ើបអង្កេតរបស់មន្ត្រីស៊ើបអង្កេត និងអនុសាសន៍របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង និងរាល់ព័ត៌មានទាក់ទងនឹងដីរដ្ឋទាំងអស់ ត្រូវបានចាត់ទុកជាឯកសារសាធារណៈ និងត្រូវរក្សាទុកនៅលេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង។

**ប្រការ៣៧ ការផ្តល់ឯកសារថតចម្លងដោយឥតគិតថ្លៃ**

ក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងអាជ្ញាធរថ្នាក់ស្រុក-ខណ្ឌ ឃុំ-សង្កាត់ត្រូវទទួលបានយ៉ាងហោចទូវផែនទីដីរដ្ឋប្រចាំមូលដ្ឋានមួយច្បាប់ដោយឥតបង់ថ្លៃ (ប្រសិនបើមាន) ដែលជាលទ្ធផលសម្រេចនៃការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ឬដែលបានធ្វើបច្ចុប្បន្នភាពនៅថ្នាក់ខេត្ត-ក្រុងរៀងរាល់៦ខែម្តង និងសេចក្តីសង្ខេបព័ត៌មានអំពីក្បាលដីរដ្ឋនីមួយៗ

ដែលបង្ហាញឱ្យដឹងអំពីចំណោត់ថ្នាក់ដី បន្ទុកលើដី និងអាជ្ញាធរកាន់កាប់ដីនោះ ដើម្បីរក្សាទុកនៅការិយាល័យជាឯកសារសាធារណៈ ។

**ប្រការ៣៨ ការផ្តល់ឯកសារថតចម្លងតាមការស្នើសុំដោយគិតថ្លៃ**

សាធារណជន ឬស្ថាប័នរដ្ឋនានាដែលមានបំណងចង់បានឯកសារចម្លងនៃព័ត៌មានដីរដ្ឋ និង/ឬផែនទីដីរដ្ឋអាចចុះឈ្មោះស្នើសុំចម្លងឯកសារជាក់លាក់នៅសាលាស្រុក-ខណ្ឌ ឬនៅលេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ដោយត្រូវបង់ថ្លៃសេវាជាមុន ដែលជាថ្លៃថតចម្លង ឬថ្លៃបោះពុម្ពឯកសារ និងថ្លៃសេវាបញ្ជូនឯកសារតាមតម្លៃជាក់ស្តែង ។

**ប្រការ៣៩ ការកំណត់រយៈពេលទទួលបានឯកសារថតចម្លងដែលស្នើសុំ**

ដោយពិគ្រោះយោបល់ជាមួយនឹងអ្នកផលិតឯកសារ អភិបាលស្រុក-ខណ្ឌកំណត់ និងត្រួតពិនិត្យជាប្រចាំអំពីរយៈពេលដើម្បីទទួលបានឯកសារ ប៉ុន្តែទោះជាយ៉ាងណា រយៈពេលកំណត់នោះមិនអាចលើសពី២០ថ្ងៃឡើយ គិតចាប់ពីថ្ងៃបានទទួលប្រាក់ថ្លៃសេវា ។

## ៥_អវសានប្បញ្ញត្តិ

**ប្រការ៤០ ប្រសិទ្ធភាពអនុវត្ត**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់បីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ហត្ថលេខា និងត្រា**

**អ៊ឹម ឈុនលឹម**

កន្លែងទទួល
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -គ្រប់ក្រសួង ស្ថាប័នកណ្តាល
- -គ្រប់សាលាខេត្ត-ក្រុង
- -ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ៣៤អនក្រ/បក

**អនុក្រឹត្យ**

**ស្តីពីការកែប្រែមាត្រា៥ និងមាត្រា២៨នៃអនុក្រឹត្យលេខ៤៧អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/៩៤ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ/បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៤៧អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី

- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**សម្រេច**

**មាត្រា១**

មាត្រា៥ និងមាត្រា២៨នៃអនុក្រឹត្យលេខ៤៧អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដីត្រូវបានកែប្រែដូចខាងក្រោម៖

**មាត្រា៥ថ្មី**

គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌដឹកនាំដោយប្រធានមួយរូបដែលជាអភិបាលស្រុក-ខណ្ឌ និងអនុប្រធានមួយរូបដែលជាប្រធានការិយាល័យរៀបចំដែនដី នគរូនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌមានមន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌជាសមាជិក។

ប្រធានគណៈកម្មការសុរិយោដីនេះត្រូវអញ្ជើញតំណាងអាជ្ញាធរដែនដីឃុំ-សង្កាត់ ភូមិដែលពាក់ព័ន្ធ ឬ/និងចាស់ព្រឹទ្ធាចារ្យនៅក្នុងមូលដ្ឋានឱ្យចូលរួមជាសមាជិកអាដហុក។

**មាត្រា២៨ថ្មី**

គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌមានសិទ្ធិប្រើប្រាស់ត្រារបស់សាលាស្រុក-ខណ្ឌ។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុងមានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្ត-ក្រុង។

គណៈកម្មការសុរិយោដីថ្នាក់ជាតិមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៣**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្ត-ក្រុង

*វាយឡើងវិញ*

ទាំងអស់ និងមន្ត្រីដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យបានសម្រេច ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

<u>កន្លែងទទួល</u>

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័ន

-គ្រប់សាលាខេត្ត-ក្រុង

-ដូចមាត្រា៣

-ឯកសារ កាលប្បវត្តិ

*វាយឡើងវិញ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ**

**លេខ៦៦៨អសជភ** ភ្នំពេញ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៦

**អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ**

**ជម្រាបជូន**

**លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ**

កម្មវត្ថុ៖ អំពីបញ្ហាទាក់ទងនឹងការផ្ទេរដី-ផ្ទះ ក្នុងតំបន់ដែលបានធ្វើការវិនិច្ឆ័យរួចហើយ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបលោកប្រធានថា៖ កន្លងមក ក្រុមការងារអនុវត្តគម្រោង LMAP ក្រុងភ្នំពេញតែងជួបបញ្ហារាំងស្ទះក្នុងការផ្ទេរសិទ្ធិដី-ផ្ទះ។ ករណីបណ្តាលមកពីមិនទាន់មានដំណោះស្រាយ និងគោលការណ៍អំពីការចុះបញ្ជីដី-ផ្ទះ ដែលម្ចាស់ក្បាលដីមិនទាន់បានផ្ទេរសិទ្ធិពីម្ចាស់មុនតាមផ្លូវការ ហើយក្រុមការងារអនុវត្តនីតិវិធីចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ បានកត់ចូលក្នុងឯកសារនូវឈ្មោះម្ចាស់ថ្មី ប៉ុន្តែ មន្ទីរមិនទាន់បានចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុជូនម្ចាស់ដី-ផ្ទះតែប៉ុណ្ណោះ។

ពិនិត្យឯកសារសុរិយោដីកសាងឡើង ដោយក្រុមការងារអនុវត្តនីតិវិធីចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ មានតែទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីទេ ដែលបានបង្ហាញច្បាស់លាស់អំពីប្រភពនៃការកាន់កាប់តាមរយៈការទិញ ឬធ្វើអំណោយ។

ដូចនេះ មានតែទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី (ច្បាប់ដើម) ដែលអាចយកជាមូលដ្ឋានឯកសារសម្រាប់ការប្រថាប់ត្រាផ្ទេរ ជំនួសលិខិតលក់ផ្តាច់ ឬអំណោយបាន។

*វាយឡើងវិញ*

ស្នើលោកប្រធានមន្ទីរភ្ជាប់ឯកសារនេះ ជូនទៅអង្គភាពពន្ធ ដើម្បីចុះពិនិត្យបន្ថែមលើតម្លៃគិតពន្ធ រួចប្រថាប់ត្រានៅខាងស្តាំដៃនៃចំណុច គ-សិទ្ធិលើអចលនវត្ថុ ឬនៅបន្ទាត់ខាងក្រោមចំពាក្យថា "ទិញ" តែម្តង។

អាស្រ័យហេតុនេះ សូមលោកប្រធានចាត់ការអនុវត្តតាមខ្លឹមសារខាងលើនេះឱ្យបានសម្រេច និងទទួលបានលទ្ធផលល្អប្រសើរ។

<u>ចម្លងជូន</u>

-ក្រសួង ដ.ន.ស

-គ្រប់មន្ទីរ ដ.ន.ស.ស ខេត្ត-ក្រុង អនុវត្តគម្រោង LMAP

-ឯកសារ-កាលប្បវត្តិ

**អគ្គនាយក**

**ហត្ថលេខា និងត្រា**

**លឹម វ៉ាន់**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ០៥សណន

## សេចក្តីណែនាំរួម
## ស្តីពីការអនុវត្តអនុក្រឹត្យលេខ៣៤អនក្រ/បកចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៦

ក្នុងគោលបំណងរួមជំរុញការងាររបស់គណៈកម្មការសុរិយោដីគ្រប់ថ្នាក់សំដៅកាត់បន្ថយ និងដោះស្រាយបញ្ហាប់ទំនាស់ដីធ្លី ពិសេសនៅថ្នាក់ស្រុក-ខណ្ឌ ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំនគរូបនីយកម្ម និងសំណង់ធ្វើការណែនាំដល់អាជ្ញាធរដែនដីខេត្ត-ក្រុង ស្រុក-ខណ្ឌ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌក្នុងការអនុវត្តអនុក្រឹត្យលេខ៣៤អនក្រ/បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៦ ដូចខាងក្រោម៖

១-អភិបាលស្រុក-ខណ្ឌក្នុងមុខតំណែងត្រូវទទួលភារកិច្ចជាប្រធានគណៈកម្មការសុរិយោដីស្រុក-ខណ្ឌ ក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន។ ចំពោះស្រុក-ខណ្ឌដែលពុំទាន់តែងតាំងអភិបាល អភិបាលរងដែលទទួលបន្ទុកដឹកនាំការងាររួម មានភារកិច្ចដឹកនាំគណៈកម្មការសុរិយោដីស្រុក-ខណ្ឌនោះ។ អភិបាលស្រុក-ខណ្ឌដែលជាប់បេសកកម្មក្រៅប្រទេស ឬអវត្តមានរយៈពេលយូរត្រូវផ្ទេរសិទ្ធិជូនអភិបាលរង០១រូប ទទួលបន្ទុកដឹកនាំបន្តគណៈកម្មការសុរិយោដីស្រុក-ខណ្ឌនោះ។ អភិបាលរងស្រុក-ខណ្ឌដែលបានទទួលសិទ្ធិដឹកនាំការងារនេះ ត្រូវរាយការណ៍អំពីលទ្ធផលការងារជូនប្រធានគណៈកម្មការសុរិយោដីស្រុក-ខណ្ឌ ពេលមានវត្តមាននៅអង្គភាពវិញ។

២-ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌក្នុងមុខតំណែងត្រូវទទួលភារកិច្ចជាអនុប្រធានគណៈកម្មការសុរិយោដីស្រុក-ខណ្ឌ។ ចំពោះការិយាល័យ

រៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌដែលពុំទាន់មានប្រធានការិយាល័យ ប្រធានគណៈកម្មការសុរិយោដីស្រុក-ខណ្ឌត្រូវលើកសំណើជូនគណៈកម្មការសុរិយោដីថ្នាក់ជាតិក្នុងការតែងតាំងបណ្តោះអាសន្នអនុប្រធានគណៈកម្មការសុរិយោដីស្រុក-ខណ្ឌនោះ ។

៣-គណៈកម្មការសុរិយោដីស្រុក-ខណ្ឌត្រូវសិក្សាស្រាវជ្រាវស្វែងយល់ច្បាប់ និងបទដ្ឋានគតិយុត្តនានាក្នុងការអនុវត្តអនុក្រឹត្យលេខ៤៧អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ប្រកាសលេខ១១២ដនស/ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពីគោលការណ៍ណែនាំនីតិវិធីរបស់គណៈកម្មការសុរិយោដី និងប្រកាសរួមលេខ០២ប្រករ/០៣ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកំណត់ភារកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងរឿងវិវាទដីធ្លី ។

អាជ្ញាធរដែនដីខេត្ត-ក្រុង ស្រុក-ខណ្ឌ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៦

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃស្តីទី**
**ហត្ថលេខា និងត្រា**
**ព្រុំ សុខា**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ**
**ហត្ថលេខា និងត្រា**
**អ៊ឹម ឈុនលឹម**

<u>កន្លែងទទួល</u>

-ក្រសួងព្រះបរមរាជវាំង
-ទីស្តីការគណៈរដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន
-គ្រប់មន្ទីរ ដនសស ខេត្ត-ក្រុង
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**លេខ០៦សណន** ភ្នំពេញ ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦

## សារាចរណែនាំ
## ស្តីពីគោលការណ៍ និងនីតិវិធីចុះបញ្ជីដីបំពេញបន្ថែម

ដោយពិនិត្យឃើញថា ក្រោយពីបានបញ្ចប់នីតិវិធីចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធក្នុងតំបន់មួយចំនួនរួចមក នៅមានក្បាលដីខ្លះឋិតនៅក្នុងតំបន់វិនិច្ឆ័យ ប៉ុន្តែម្ចាស់នៃក្បាលដីទាំងនោះមិនបានមកចូលរួមបំពេញបែបបទ ដើម្បីទទួលបានសិទ្ធិពេញលេញតាមកាលកំណត់។ ក្បាលដីទាំងនេះមានស្ថានភាពខុសៗគ្នា មួយចំនួនត្រូវបានផ្តល់ប័ណ្ណសម្គាល់សិទ្ធិរួចហើយតាមនីតិវិធីចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ ឯមួយចំនួនទៀតត្រូវបានកាន់កាប់ត្រឹមត្រូវប៉ុន្តែមិនទាន់ត្រូវបានផ្តល់ប័ណ្ណសម្គាល់សិទ្ធិនៅឡើយ។ ទោះក្នុងករណីណា ក៏ការកាន់កាប់ស្របច្បាប់ និងមានលក្ខណសម្បត្តិគ្រប់គ្រាន់ទាំងនេះត្រូវបានសម្រួលឱ្យចុះចូលក្នុងសៀវភៅគោលបញ្ជីដីធ្លី ដើម្បីធានាសិទ្ធិពេញលេញតាមផ្លូវច្បាប់។

ក្នុងការសម្រួលដោះស្រាយបញ្ហាខាងលើ ក្រសួងបានកំណត់នូវគោលការណ៍ និងនីតិវិធីនៃការចុះបញ្ជីដីបំពេញបន្ថែមដូចតទៅ៖

-ម្ចាស់អចលនវត្ថុដែលមិនបានចូលរួមបំពេញបែបបទតាមកាលកំណត់ក្នុងពេលប្រកាសតំបន់វិនិច្ឆ័យ និងកិច្ចដំណើរការអនុវត្តនីតិវិធីចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធដោយមានមូលហេតុសមស្រប ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីដី មកការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល (ការិ.ដនសភ.) តាមរយៈមេឃុំ ចៅសង្កាត់នៃឃុំ-សង្កាត់ដែលជាទីតាំងនៃដីឋិតនៅ។

-មេឃុំ ចៅសង្កាត់ត្រូវពិនិត្យលក្ខណៈសមស្រប ផ្តល់យោបល់ និងបញ្ជូនសំណុំរឿងមកការិ.ដនសភ.ស្រុក-ខណ្ឌ។

-បើការិយាល័យជំនាញពិនិត្យឃើញសមស្រប រាយការណ៍ជូនអភិបាលស្រុក-ខណ្ឌដើម្បីផ្តល់យោបល់ និងសហការចុះពិនិត្យទិដ្ឋភាពបច្ចេកទេស និងរដ្ឋបាល-គតិយុត្ត ហើយកំណត់ព្រំវាស់វែង និងកសាងទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីដែលបានស្នើសុំ។

បើក្បាលដីស្នើចុះបញ្ជីឋិតនៅចន្លោះក្បាលដីដែលបានចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធរួច ហើយ ព្រំនៃក្បាលដីនោះមិនចាំបាច់ធ្វើការកំណត់ជាថ្មីទៀត។ ចំពោះក្បាលដីដែលមិនទាន់បាន កំណត់ព្រំជាផ្លូវការ ជាមួយក្បាលដីជាប់ព្រំគ្នាសោះ ឬបានកំណត់ព្រំខ្លះ ចាំបាច់ត្រូវធ្វើការកំណត់ព្រំ ដែលនៅសេសសល់តាមនីតិវិធី។ ត្រូវសង់យកចំណែកពាក់ព័ន្ធនឹងការចុះបញ្ជីបំពេញបន្ថែមនេះ ពី ប្លង់សុរិយោដីដែលជាលទ្ធផលនៃការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធលើកមុន មកគូសបំពេញព្រំ ប្រទល់ដែលទើបកំណត់ក្រោយ ហើយដាក់លេខក្បាលដីតពីលេខលើកមុន។

-ក្រោយពីរៀបចំសំណុំឯកសារគ្រប់គ្រាន់ត្រូវបិទផ្សាយជាសាធារណៈនូវទិន្នន័យដែល ប្រមូលបានក្នុងរយៈពេល៣០ថ្ងៃនៅសាលាសង្កាត់ និងនៅការិ.ដនសភ.ស្រុក-ខណ្ឌ។ រាល់ការ ជំទាស់ ឬតវ៉ាត្រូវធ្វើនៅការិ.ដនសភ.ស្រុក-ខណ្ឌ។ ការកែតម្រូវអាចធ្វើបានតាមសមត្ថកិច្ច និង គោលការណ៍ដែលដែលបានកំណត់ដោយអនុក្រឹត្យពាក់ព័ន្ធ។

-ការិ.ដនសភ.ត្រូវធ្វើរបាយការណ៍បូកសរុប ផ្តល់យោបល់ និងបញ្ជូនសំណុំរឿងមក អភិបាលស្រុក-ខណ្ឌដើម្បីសុំយោបល់ ហើយបញ្ជូនបន្តមកមន្ទីរដនសស.ខេត្ត-ក្រុងពិនិត្យបន្ថែម លើលក្ខណៈបច្ចេកទេស រួចទើបបញ្ជូនទៅសាលាខេត្ត-ក្រុងសុំយោបល់សម្រេច។

-នៅពេលដែលអភិបាលខេត្ត-ក្រុងយល់ព្រមហើយ សំណុំឯកសារនៃការវិនិច្ឆ័យត្រូវ បញ្ជូនមកមន្ទីរដនសស.វិញ ដើម្បីធ្វើការចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លី និងក្នុង Digital file ហើយបោះពុម្ពប័ណ្ណ ចុះហត្ថលេខា រួចប្រគល់ជូនអ្នកស្នើសុំ។ ករណីអភិបាលខេត្ត-ក្រុងមិនយល់ ព្រម ឬច្រានចោល ត្រូវបញ្ជាក់ឱ្យច្បាស់អំពីមូលហេតុដែលមិនយល់ព្រម ឬច្រានចោលនោះ ដើម្បី ឆ្លើយតបទៅនឹងអ្នកស្នើសុំវិញ និងទុកជាឯកសារ។

សារាចរណែនាំនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី**
**នគរូបនីយកម្ម និងសំណង់**
**ហត្ថលេខា និងត្រា**
**អ៊ឹម ឈុនលឹម**

<u>កន្លែងទទួល</u>

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-គ្រប់សាលាខេត្ត-ក្រុង "ដើម្បីជូនជ្រាបជាព័ត៌មាន"

-គ្រប់អង្គភាពក្រោមឱវាទក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ "ដើម្បីមុខការ"

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ០១បប** រាជធានីភ្នំពេញ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៦

**បទបញ្ជា**

**ស្តីពីការទប់ស្កាត់ការកាប់រានដីព្រៃឈើគ្រប់ប្រភេទរបស់រដ្ឋយកមកធ្វើជាកម្មសិទ្ធិ**

ក្នុងគោលបំណងថែរក្សាការពារ និងពង្រឹងយ៉ាងម៉ឺងម៉ាត់នូវការគ្រប់គ្រងដីព្រៃឈើគ្រប់ប្រភេទពីការកាប់បំផ្លាញ ទន្ទ្រាន និងហ៊ុំព័ទ្ធយកធ្វើជាកម្មសិទ្ធិ រាជរដ្ឋាភិបាលចាំបាច់ដាក់ចេញនូវបទបញ្ជាជាបន្ទាន់ឱ្យអភិបាលខេត្ត-ក្រុងអនុវត្តដូចខាងក្រោម៖

១-ត្រូវប្រើប្រាស់អំណាចរដ្ឋ ដោយចេញដីកាជាបន្ទាន់យ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៦ ដោយប្រកាសបដិសេធ និងដកហូតដីព្រៃឈើគ្រប់ប្រភេទដែលត្រូវបានរំលោភបំពានទាំងអស់មកទុកជាសម្បត្តិរដ្ឋវិញតាមការចាំបាច់។

២-ដីកានេះត្រូវកំណត់រយៈពេល៣០ថ្ងៃ ដើម្បីឱ្យគេធ្វើការប្តឹងតវ៉ា ហើយក្នុងករណីមិនមានអ្នកប្តឹងទាមទារនោះ អភិបាលខេត្ត-ក្រុងត្រូវរាយការណ៍ជូនអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងគណៈកម្មាធិការជាតិដើម្បីទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបការកាប់រានដុត ឈូសឆាយ និងហ៊ុំព័ទ្ធដីព្រៃឈើវាតយកដីធ្វើកម្មសិទ្ធិ ដើម្បីរាជរដ្ឋាភិបាលចេញអនុក្រឹត្យកំណត់ទុកដីទាំងនោះជាសម្បត្តិរដ្ឋ។

៣-ត្រូវពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងដីព្រៃឈើគ្រប់ប្រភេទដែលមានជាធរមានឱ្យបានត្រឹមត្រូវ និងម៉ឺងម៉ាត់បំផុត ជាពិសេសអំពីទោសប្បញ្ញត្តិចំពោះជនទាំងឡាយណា ដែលបានរំលោភបំពានលើដីព្រៃឈើគ្រប់ប្រភេទយកធ្វើជាកម្មសិទ្ធិនោះ។

៤-ក្រសួង ស្ថាប័នពាក់ព័ន្ធ អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គស្នងការដ្ឋាននគរបាលជាតិ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ត្រូវសហការអនុវត្តបទបញ្ជានេះក្នុងស្មារតីទទួលខុសត្រូវ និងឱ្យមានប្រសិទ្ធភាពខ្ពស់ ហើយរាយការណ៍អំពីលទ្ធផល

*វាយឡើងវិញ*

ជូនអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងគណៈកម្មាធិការជាតិដើម្បីទប់ស្កាត់ លុបបំបាត់ និងបង្ក្រាប ការកាប់រាន ដុត ឈូសឆាយ និងហ៊ុំព័ទ្ធដីព្រៃឈើ វាតយកដីធ្វើកម្មសិទ្ធិតាមករណីជាក់ស្តែងនីមួយៗ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

*<u>ចម្លងជូន</u>*

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ក្រសួងព្រះបរមរាជវាំង

-អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

-អគ្គលេខាធិការដ្ឋានប្រតិបត្តិ គជ

-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ដូចចំណុចទី៤

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ**
**លេខ៩៩៥អសដភ** ភ្នំពេញ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៦

## សេចក្តីណែនាំ
## ស្តីអំពី
## វិធានការសុវត្ថិភាពនៃឯកសារសុរិយោដី និងទិន្នន័យគោលនៃការចុះបញ្ជីដីធ្លី Digital

យោងអនុក្រឹត្យលេខ៤៦អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី អនុក្រឹត្យលេខ៤៨អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ ប្រកាសណែនាំចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៥ ស្តីពីការចុះបញ្ជីបន្ត និងស្មារតី សិក្ខាសាលាស្តីពីការគ្រប់គ្រងថែរក្សាទិន្នន័យនៃការចុះបញ្ជីដីធ្លីតាមប្រព័ន្ធកុំព្យូទ័រ នាថ្ងៃទី១៦-១៧ ខែកុម្ភៈ ឆ្នាំ២០០៦ នៅក្រុងព្រះសីហនុ និងដោយមានការឯកភាពពីឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រសូមធ្វើការណែនាំដូចតទៅ៖

**១-វិសាលភាពនៃសេចក្តីណែនាំ**

សេចក្តីណែនាំនេះអនុវត្តលើវិធានការធានាសុវត្ថិភាពជាមូលដ្ឋាន ដែលទាក់ទងនឹងការគ្រប់គ្រងឯកសារសុរិយោដី និងទិន្នន័យគោលនៃការចុះបញ្ជីដីធ្លីជា Digital របស់បណ្តាខេត្ត-ក្រុង ដោយយោងអនុក្រឹត្យលេខ៤៦អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី និងអនុក្រឹត្យលេខ៤៨អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ។

**២-ការថតចម្លងទិន្នន័យទុក** (BACKUP)

ទិន្នន័យគោលនៃការចុះបញ្ជីដីធ្លីជា Digital ដែលមានមូលដ្ឋានទិន្នន័យ និងទិន្នន័យប្លង់សុរិយោដី (Database and Map data) ត្រូវតែថតចម្លងទុកឱ្យបានរៀងរាល់ថ្ងៃ។ នៅលើ Network Server មាន Folder Backup ដែលមាន Sub Folder ចំនួន៥ គឺពីថ្ងៃចន្ទ ដល់សុក្រ (Monday, Tuesday, Wednesday, Thursday និង Friday)។ នៅថ្ងៃចន្ទត្រូវថតចម្លងទិន្នន័យទុកនៅក្នុង Folder Backup\Monday។ នៅថ្ងៃអង្គារត្រូវតែថតចម្លងទុកនៅក្នុង Folder Backup\Tuesday រហូតដល់ថ្ងៃសុក្រ Folder Backup\Friday។ ការថតចម្លងទិន្នន័យទុកនេះត្រូវធ្វើនៅល្ងាចចុងម៉ោងធ្វើការនៃថ្ងៃនីមួយៗ។

នៅសប្តាហ៍បន្តបន្ទាប់ត្រូវថតចម្លងទិន្នន័យថ្មីទុកភ្ជាន់ (Overwrite) លើទិន្នន័យចាស់ទៅតាមថ្ងៃនីមួយៗនៃសប្តាហ៍។ គ្រប់មន្ទីរខេត្ត-ក្រុងអនុវត្តគម្រោងមាន Tapes ចំនួនពីរនៅម៉ាស៊ីន Server សម្រាប់ថតចម្លងទិន្នន័យតាមបណ្តាញ Network។ ជារៀងរាល់ថ្ងៃ ការថតចម្លងទិន្នន័យពី Folder Backup ក្នុង Server ត្រូវបានគេរៀបចំដោយស្វ័យប្រវត្តិចូលទៅក្នុង Tape នៅលើម៉ាស៊ីន Server។ នៅថ្ងៃចន្ទ មន្ត្រីទទួលគ្រប់គ្រងទិន្នន័យត្រូវប្តូរ Tape ទី១ ជំនួសដោយ Tape ទី២ និងសប្តាហ៍បន្ទាប់ត្រូវប្តូរ Tape ទី២មក Tape ទី១វិញ អនុវត្តតាមរបៀបនេះ ចំពោះសប្តាហ៍បន្តបន្ទាប់ទៀត។ តាមវិធីនេះ រក្សាទិន្នន័យបានចំនួន២សប្តាហ៍ទៅតាមថ្ងៃនីមួយៗ។

**៣.ការរក្សាទិន្នន័យទុកជាឯកសារ** (ARCHIVING)

ទិន្នន័យគោលនៃការចុះបញ្ជីដីធ្លីជា Digital ដែលមានមូលដ្ឋានទិន្នន័យ និងទិន្នន័យប្លង់សុរិយោដីត្រូវតែរក្សាទុកមុន និងក្រោយការបិទផ្សាយជាសាធារណៈនូវឯកសារវិនិច្ឆ័យ។ ទិន្នន័យនេះត្រូវបានរក្សាទុកនៅម៉ាស៊ីន Server ហើយមិនអនុញ្ញាតឱ្យមានការកែប្រែទិន្នន័យក្បាលដីលើ File នេះទេ។

មន្ត្រីសុរិយោដីដែលទទួលបន្ទុកការងារគ្រប់គ្រងទិន្នន័យនេះ បានទទួលការណែនាំពីរបៀបរក្សាទុកទិន្នន័យទាំងនេះនៅក្នុងឯកសារបណ្តុះបណ្តាលឆ្នាំ២០០៦។

**៤.ការថតចម្លងទិន្នន័យផ្ញើទុកនៅអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ**

ក-រាល់២សប្តាហ៍ម្តង ការថតចម្លងទិន្នន័យគោលនៃការចុះបញ្ជីដីធ្លីជា Digital មានមូលដ្ឋានទិន្នន័យ ទិន្នន័យប្លង់សុរិយោដី និងទិន្នន័យប្លង់សុរិយោដីសម្រេចចុងក្រោយ ប្រើសម្រាប់

ចុះបញ្ជីបន្ត ទាក់ទងនឹងការប្រែប្រួលលក្ខណរូបនៃក្បាលដី (Database, Map data and Final GDB) ត្រូវផ្ញើមកអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ (អគ្គនាយកដ្ឋានអភិរក្សសុរិយោដី)។

ខ-នៅមុនពេលបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ Digital ដែលបានត្រៀមបិទផ្សាយនេះ (Archive Before Public Display) មកអគ្គនាយកដ្ឋានមួយច្បាប់។

គ-គ្រប់ឯកសារសុរិយោដីដែលបានសម្រេចជាផ្លូវការរួចហើយ ត្រូវផ្ញើទិន្នន័យគោលនៃការចុះបញ្ជីដីធ្លីជា Digital ដែលជាទិន្នន័យក្រោយប្រកាស (Archive after Public Display) មកជាមួយនឹងរបាយការណ៍គណៈកម្មការរដ្ឋបាល ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី បញ្ជីឈ្មោះម្ចាស់ដី សៀវភៅគោលបញ្ជីដីធ្លី ប្លង់សុរិយោដី សំណុំឯកសារចុះបញ្ជីបន្ត និងឯកសារ រណបពាក់ព័ន្ធមកអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ (នាយកដ្ឋានអភិរក្សសុរិយោដី) យ៉ាងយូរ៧ថ្ងៃ ក្រោយថ្ងៃកំណត់បញ្ចប់នៃការចែកប័ណ្ណ។

នៅលើខ្នងនៃ CD ដែលបានថតចម្លងនោះ ត្រូវចុះថ្ងៃ ខែ ឆ្នាំថតចម្លង និងឈ្មោះខេត្ត ក្រុងអនុវត្តគម្រោង។

## ៥-ការផ្ញើឯកសារសុរិយោដីទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល

គ្រប់ឯកសារសុរិយោដីដែលបានសម្រេចជាផ្លូវការរួចហើយ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង អនុវត្តគម្រោងត្រូវផ្ញើរបាយការណ៍គណៈកម្មការរដ្ឋបាល បញ្ជីឈ្មោះម្ចាស់ដី សៀវភៅគោលបញ្ជីដីធ្លី ប្លង់សុរិយោដី សំណុំឯកសារការចុះបញ្ជីបន្ត និងឯកសាររណបដែលពាក់ព័ន្ធទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ យ៉ាងយូរ៧ថ្ងៃ ក្រោយថ្ងៃកំណត់បញ្ចប់នៃការចែកប័ណ្ណ។

### ៦-លេខសម្ងាត់ (PASSWORD)

លេខសម្ងាត់ និងឈ្មោះអ្នកប្រើប្រាស់ត្រូវបានផ្តល់ជូនមន្ត្រីការិយាល័យក្នុងការប្រើប្រាស់កុំព្យូទ័រតាមបណ្តាញ Network និងប្រើប្រាស់លើមូលដ្ឋាន (Database)។ លេខសម្ងាត់ចែកចេញជាបីប្រភេទក្នុងការប្រើប្រាស់លើមូលដ្ឋានទិន្នន័យ លេខសម្ងាត់របស់មន្ត្រីនីមួយៗត្រូវមានការទទួលខុសត្រូវនូវអ្វីដែលខ្លួនបានបញ្ចូលទិន្នន័យ ឬកែប្រែដោយសំអាងលើឈ្មោះ និងលេខសម្ងាត់របស់

មន្ត្រីទាំងនោះ ដែលបានកត់ត្រាតាមប្រព័ន្ធកុំព្យូទ័រ។ នៅពេលលេខសម្ងាត់ត្រូវបានអ្នកផ្សេងៗដឹងក្រៅពីសាមីខ្លួន ត្រូវតែដូរជាបន្ទាន់តាមតែអាចធ្វើទៅបាន។ លេខសម្ងាត់ទាំងនេះត្រូវប្តូរដោយមន្ត្រី GIS នៃអគ្គនាយកដ្ឋាននៅពេលធ្វើការ Update លើមូលដ្ឋានទិន្នន័យនៅមន្ទីរខេត្ត-ក្រុងអនុវត្តគម្រោង។

**៧-ការការពារប្រឆាំងមេរោគកុំព្យូទ័រ** (PROTECTION AGAINST VIRUSES)

ពេលថ្មីៗនេះ ទិន្នន័យនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធរងនូវការគំរាមកំហែងដោយមេរោគកុំព្យូទ័រ។

ដើម្បីការពារទិន្នន័យនៃការចុះបញ្ជីដីធ្លីពីមេរោគកុំព្យូទ័រ និងការប៉ះពាល់ពីខាងក្រៅនោះបណ្តាញកុំព្យូទ័រនៅមន្ទីរខេត្ត-ក្រុងអនុវត្តគម្រោងមិនត្រូវអនុញ្ញាតឱ្យភ្ជាប់ជាមួយ Internet ទេ។ លើកលែងតែមានការអនុញ្ញាតឱ្យបញ្ចូល (Install) ក្នុងបណ្តាញកុំព្យូទ័រពីក្រសួង (អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ)។

កម្មវិធីកម្ចាត់មេរោគត្រូវបានបញ្ចូលនៅគ្រប់កុំព្យូទ័រទាំងអស់។ នៅមន្ទីរខេត្ត-ក្រុងអនុវត្តគម្រោងមានកុំព្យូទ័រមួយគ្រឿងពុំបានភ្ជាប់ទៅបណ្តាញ Network ទេ ប៉ុន្តែត្រូវបានភ្ជាប់ជាមួយ Internet សម្រាប់ប្រើប្រាស់ email ឬទាញយក (Download) កម្មវិធី Update Antivirus។

កម្មវិធីកម្ចាត់មេរោគកុំព្យូទ័រត្រូវតែ Update ឱ្យបានទៀងរាល់២សប្តាហ៍ម្តង។ ប្រសិនបើមន្ត្រីខេត្ត-ក្រុងពុំមានសមត្ថភាពក្នុងការ Download កម្មវិធី Update Antivirus ទេ ត្រូវតែស្នើមកអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រភ្លាម កុំទុកឱ្យមានបញ្ហាទាន់។

**កំណត់សម្គាល់** នៅពេលមានការតភ្ជាប់ ឬ Download email ឬ Update Antivirus កុំព្យូទ័រងាយទទួលរងនូវការឆ្លងមេរោគណាស់។ ដូច្នេះ នៅពេលមានការ Update file Antivirus ត្រូវតែ Scan ឧបករណ៍ថតចម្លងសម្លាប់មេរោគជាមុនសិន មុននឹងចម្លងទៅកុំព្យូទ័រផ្សេងទៀតតាមរយៈបណ្តាញ Network។

**៨-ការប្រើប្រាស់កុំព្យូទ័រ**

អ្នកប្រើប្រាស់កុំព្យូទ័រតាមបណ្តាញ Network ត្រូវបានកំណត់ឱ្យប្រើប្រាស់សម្រាប់មន្ត្រីចុះបញ្ជីដីធ្លី និងក្នុងគោលបំណងសម្រាប់ត្រួតពិនិត្យលើចំនួននៃអ្នកប្រើប្រាស់កុំព្យូទ័រតាមបណ្តាញ Network ។

នេះជាការងាររបស់មន្ត្រី IT នៅតាមខេត្ត-ក្រុងអនុវត្តគម្រោង ដើម្បីបង្កើតឈ្មោះ និងលេខសម្ងាត់នៃអ្នកប្រើប្រាស់ សម្រាប់ត្រួតពិនិត្យលើចំនួននៃអ្នកប្រើប្រាស់កុំព្យូទ័រតាមបណ្តាញ Network ។

ពេលបញ្ចប់ម៉ោងធ្វើការងារ កុំព្យូទ័របិទ ហើយទ្វារនៃការិយាល័យដែលមានកុំព្យូទ័រ ក៏ត្រូវចាក់សោផងដែរ ។ ម៉ាស៊ីន Server ត្រូវរក្សានៅបន្ទប់ស្អាតដាច់ដោយឡែក បំពាក់ដោយម៉ាស៊ីនត្រជាក់ ហើយដែលអាចចាក់សោបាន ។

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ សង្ឃឹមយ៉ាងមុតមាំថា អស់លោក លោកស្រី ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង អនុវត្តគម្រោងទាំងអស់នឹងខិតខំអនុវត្តសេចក្តីណែនាំឱ្យមានប្រសិទ្ធភាព ។

សេចក្តីណែនាំនេះមានអានុភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**អគ្គនាយក**

**ហត្ថលេខា និងត្រា**

**លឹម វ៉ាន់**

កន្លែងទទួល

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

"ដើម្បីជូនជ្រាប"

-គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួង ដនស

"ដើម្បីជ្រាប"

-គ្រប់មន្ទីរ ដ.ន.ស.ស ខេត្ត-ក្រុង

"ដើម្បីអនុវត្ត"

-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ**
**លេខ១១២៩សណន/សដភ** ភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦

# សេចក្តីណែនាំ
## ស្តីអំពីការប្រើប្រាស់ត្រាមោឃភាពប័ណ្ណចាស់ក្នុងតំបន់វិនិច្ឆ័យ

-ផ្អែកតាមស្មារតីអង្គប្រជុំកាលពីថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៦

-ចំណារឯកភាពរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៦

អគ្គនាយកនៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ សូមធ្វើការណែនាំដល់គ្រប់ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង ដែលអនុវត្តគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី “LMAP” ដូចតទៅ៖

១-ត្រាមោឃភាពសម្រាប់បោះលើប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬវិញ្ញាបនបត្រសម្គាល់សិទ្ធិម្ចាស់អចលនវត្ថុ និងសៀវភៅចុះបញ្ជីអចលនវត្ថុចាស់ និងឯកសារសុរិយោដីផ្សេងទៀត ដែលអស់សុពលភាពប្រើប្រាស់តាមផ្លូវច្បាប់ ។

២-ការប្រើប្រាស់គឺនៅពេលដែលប័ណ្ណ ឬឯកសារទាំងនោះអស់សុពលភាពតាមផ្លូវច្បាប់ចាប់ពីថ្ងៃចែកវិញ្ញាបនបត្រសម្គាល់សិទ្ធិម្ចាស់អចលនវត្ថុ (ប័ណ្ណកម្មសិទ្ធិ) ដោយបោះលើទំព័រទី១នៃប័ណ្ណ និងលើខណ្ឌក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុដែលត្រូវមោឃៈ ងាយស្រួលមើលឃើញដោយទឹកត្រាពណ៌ក្រហម ។

៣-មន្ត្រីដែលមានភារកិច្ចចែកវិញ្ញាបនបត្រ ឬផ្តល់ឯកសារថ្មីជំនួស និងមន្ត្រីអភិរក្សសុរិយោដីដែលត្រូវបានប្រគល់ភារកិច្ច មានសិទ្ធិប្រើប្រាស់ត្រានេះ ។

*វាយឡើងវិញ*

៤-រាល់ប័ណ្ណ និងឯកសារដែលបានបោះត្រាមោឃៈរួចត្រូវប្រមូលទុកនៅការិយាល័យអភិរក្ស នៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រង់ចាំការណែនាំបន្ត។

ទទួលបាននូវសេចក្ដីណែនាំនេះ សូមលោកប្រធានចាត់ចែងមកទទួលយកត្រានៅអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ (នាយកដ្ឋានអភិរក្សសុរិយោដី) ដើម្បីយកទៅប្រើប្រាស់ជាផ្លូវការ។

**អគ្គនាយក**

**ហត្ថលេខា និងត្រា**

**លឹម វ៉ាន់**

<u>ចម្លងជូន</u>

-ក្រសួង ដ.ន.ស

-គ្រប់នាយកដ្ឋានក្រោមឱវាទ

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**លេខ៤០៩សជណ/សជ** ភ្នំពេញ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០០៦

## សេចក្តីជូនដំណឹង

ដោយអនុលោមតាមលិខិតលេខ៧៦២សជណ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីសំណើសុំប្រកាសផ្អាកបណ្តោះអាសន្ននូវការចេញវិញ្ញាបនបត្រសម្គាល់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលើដីព្រៃឈើគ្រប់ប្រភេទដែលមានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមជូនដំណឹងដល់អស់លោក-លោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីគ្រប់ខេត្ត-ក្រុងដូចតទៅ៖

១-គ្រប់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង ត្រូវផ្អាកការចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុនៅលើដីព្រៃឈើគ្រប់ប្រភេទ ជាពិសេស ដីព្រៃឈើតាមបណ្តោយផ្លូវពីតំបន់កន្ទុយគោ ទៅព្រំប្រទល់ប្រទេសឡាវ ក្នុងខេត្តស្ទឹងត្រែង។

២-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នឹងចាត់វិធានការយ៉ាងតឹងរ៉ឹងបំផុតចំពោះមន្ត្រីណាដែលអនុវត្តផ្ទុយនឹងសេចក្តីជូនដំណឹងនេះ។

ទទួលបានសេចក្តីជូនដំណឹងនេះ អស់លោក-លោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីគ្រប់ខេត្ត-ក្រុងត្រូវខិតខំអនុវត្ត ព្រមទាំងផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់មន្ត្រីក្រោមឱវាទ ដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

**ជ.ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**រដ្ឋលេខាធិការ**
**ហត្ថលេខា និងត្រា**
**ឆាន់ សាផាន**

<u>ចម្លងជូន</u>
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-ក្រសួងបរិស្ថាន
-អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ
-គ្រប់សាលាខេត្ត-ក្រុង
-ឯកសារ-កាលប្បវត្តិ

*វាយឡើងវិញ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**លេខ៦៥៣ដនស/សជ**

ភ្នំពេញ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**សូមគោរពជូន**
**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កម្មវត្ថុ៖ ករណីសំណើសុំគោលការណ៍ពង្រឹងការងារគ្រប់គ្រងដីធ្លី ។

យោង៖ លិខិតលេខ៦៤៧សជណ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមអនុញ្ញាតជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា ដើម្បីបង្កើនចំណូលថវិកាជូនរដ្ឋដែលបានមកពីការយកពន្ធប្រថាប់ត្រានោះ គួរតែអនុវត្តតាមលិខិតលេខ២២៥សជណ ចុះថ្ងៃទី០៩-០២-០៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ត្រង់ចំណុចទី២ដែលមានខ្លឹមសារថា "ចំពោះការផ្ទេរដីមិនទាន់ចុះបញ្ជី គឺឯកភាពឱ្យកពន្ធប្រថាប់ត្រាដូចដីចុះបញ្ជីដែរ បើពុំនោះសោតទេ នឹងនាំឱ្យលើកទឹកចិត្តអ្នកមិនទាន់ចុះបញ្ជី។ នេះជាប្រភពចំណូលមួយយ៉ាងសំខាន់ ដោយដីភាគច្រើនជាដីមិនទាន់ចុះបញ្ជី" ។

ពាក់ព័ន្ធបញ្ហានេះ គួរមានការប្រជុំមួយ ដោយមានតំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ) តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ពន្ធដារ) និងតំណាងក្រសួងមហាផ្ទៃ ស្តីពីបែបបទ និងនីតិវិធីនៃការប្រមូលពន្ធប្រថាប់ត្រាលើការផ្ទេរដីមិនទាន់ចុះបញ្ជី។ ក្រោយពីបានឯកភាពគ្នា ត្រូវចេញប្រកាសអន្តរក្រសួង (ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ) ដើម្បីធ្វើការណែនាំអនុវត្តឱ្យបានទូលំទូលាយ ។

អាស្រ័យហេតុនេះ សូមឯកឧត្តមមេត្តាពិនិត្យ និងសម្រេចតាមការគួរ ។

**ជ.ទេសរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**
**ហត្ថលេខា និងត្រា**
**ឆាន់ សាផាន**

<u>ចម្លងជូន</u>
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ៦៥អនក្រ/បក

**អនុក្រឹត្យ**
**ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន**
**នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី**

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០២០៦/០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៩៤ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- យោងតាមសំណើប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

**សម្រេច**

**ជំពូកទី១ បទប្បញ្ញត្តិទូទៅ**

មាត្រា១

អនុក្រឹត្យនេះកំណត់អំពីបេសកកម្ម សិទ្ធិអំណាច មុខងារ ភារកិច្ច និងរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។

## ជំពូកទី២ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា២**

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានតួនាទីជាអង្គភាពប្រតិបត្តិ និងជាសេនាធិការផ្ទាល់នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ដែលត្រូវដឹកនាំ និងគ្រប់គ្រងដោយអគ្គលេខាធិការមួយរូប និងអមដោយអគ្គលេខាធិការរង ព្រមទាំងសមាជិកមួយចំនួនជាជំនួយការ។

**មាត្រា៣**

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានបេសកកម្មជួយអាជ្ញាធរក្នុងការដោះស្រាយ និងសម្របសម្រួលចំពោះរាល់វិវាទដីធ្លី និងមានភារកិច្ចដូចកំណត់ក្នុងមាត្រា៥នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។ ទន្ទឹមនឹងនេះ យោងតាមការសម្រេចរបស់ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានសិទ្ធិចេញលិខិតណែនាំឱ្យផ្អាកជាបណ្តោះអាសន្នទីតាំងទំនាស់ មិនឱ្យធ្វើសកម្មភាពផ្សេងៗ ក្រោយពីទទួលពាក្យបណ្តឹង ឬពាក្យសុំអន្តរាគមន៍ពីគូវិវាទ។

**មាត្រា៤**

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ត្រូវធ្វើការប្រជុំការងារយ៉ាងតិចមួយខែម្តង តាមការអញ្ជើញ និងការណែនាំរបស់អគ្គលេខាធិការ ហើយក្នុងករណីចាំបាច់អាចធ្វើការកោះប្រជុំភ្លាម។

**មាត្រា៥**

អគ្គលេខាធិការត្រូវលើកសំណើជូនប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ដើម្បីពិនិត្យ និងសម្រេចតែងតាំង ដំឡើងឋានៈ ផ្ទេរភារកិច្ច ឬដកចេញពីតំណែងនូវមន្ត្រីបុគ្គលិករបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។

**មាត្រា៦**

អគ្គលេខាធិការមានជំនួយការពីររូបដែលមានឋានៈស្មើប្រធាននាយកដ្ឋាន។

**មាត្រា៧**

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រីក្នុងពេលបំពេញភារកិច្ច និងបេសកកម្មរបស់ខ្លួន។

**មាត្រា៨**

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានរចនាសម្ព័ន្ធដូចតទៅ៖

១-នាយកដ្ឋានទប់ស្កាត់ បង្ការ និងអប់រំ

២-នាយកដ្ឋានស៊ើបអង្កេត និងអធិការកិច្ច

៣-នាយកដ្ឋានទទួល និងដោះស្រាយបណ្តឹង

៤-នាយកដ្ឋានបូកសរុប ព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ

៥-នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក

**មាត្រា៩**

នាយកដ្ឋាននីមួយៗត្រូវដឹកនាំ និងគ្រប់គ្រងដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ។ អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី អាចស្នើសុំបង្កើតនាយកដ្ឋានផ្សេងទៀតតាមតម្រូវការចាំបាច់។

**មាត្រា១០**

នាយកដ្ឋានទប់ស្កាត់ បង្ការ និងអប់រំមានតួនាទី និងភារកិច្ចដូចតទៅ៖

១-លើកផែនការបណ្តុះបណ្តាល និងផ្សព្វផ្សាយដល់ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋទូទៅឱ្យយល់ដឹងអំពីបញ្ហា និងផលវិបាកដែលកើតមានឡើងពីវិវាទដីធ្លី។

២-រៀបចំកិច្ចការប្រជុំ សិក្ខាសាលាថ្នាក់ភូមិភាគ ជាតិ និងអន្តរជាតិ និងបង្កើតកម្មវិធីផ្សេងៗ ដើម្បីផ្សព្វផ្សាយគោលនយោបាយរបស់រាជរដ្ឋាភិបាល និងគោលការណ៍របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីស្តីពីការអប់រំ ការបង្ការ ការទប់ស្កាត់ទំនាស់ដីធ្លី សំដៅឱ្យសាធារណជនយល់ដឹងពីផលវិបាកនៃទំនាស់ដីធ្លី និងឈានទៅកាត់បន្ថយបានជាអតិបរមានូវបញ្ហាទំនាស់ដីធ្លី។

៣-ជំរុញ និងលើកទឹកចិត្តដល់គ្រប់មជ្ឈដ្ឋានសាធារណៈទាំងអស់ រួមមានសង្គមស៊ីវិល និងអង្គការក្រៅរដ្ឋាភិបាលនានាឱ្យចូលរួមផ្តល់ព័ត៌មាន និងអនុសាសន៍នានាសំដៅបង្ការ ទប់ស្កាត់នូវរាល់បញ្ហាទំនាស់ដីធ្លីប្រកបដោយប្រសិទ្ធភាព។

៤-សហការជាមួយស្ថាប័នជាតិ និងអន្តរជាតិ ដើម្បីស្វែងរកការឧបត្ថម្ភពីដៃគូនានាក្នុងគោលដៅបង្កើនល្បឿននៃការដោះស្រាយទំនាស់ដីធ្លី ជាពិសេសការអប់រំ បង្ការ ទប់ស្កាត់នូវរាល់បញ្ហាទំនាស់ដីធ្លីតាមគ្រប់រូបភាព។

៥-ស្នើសុំ និងទទួលយកគោលការណ៍ពីអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ក្នុងការចាត់វិធានការ និងអនុវត្តភារកិច្ចនីមួយៗដើម្បីបង្ការ ទប់ស្កាត់ និងអប់រំអំពីបញ្ហាទំនាស់ដីធ្លីគ្រប់រូបភាព។

៦-រៀបចំផលិតឯកសារអប់រំ និងល្ខោនវិដេអូផ្សេងៗ ក្នុងគោលដៅអប់រំសាធារណជនតាមរយៈការចុះអប់រំផ្ទាល់ ឬតាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន អំពីផលវិបាកនៃបញ្ហាដែលកើតមានឡើងពីវិវាទដីធ្លី។

៧-សម្របសម្រួល និងសហការជាមួយស្ថាប័នជំនាញដទៃទៀតដើម្បីប្រមូល និងផ្លាស់ប្តូរព័ត៌មានគ្នាសំដៅបង្ការ និងទប់ស្កាត់ឱ្យបាននូវបញ្ហាទំនាស់ដីធ្លី និងសំដៅជំរុញការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាព និងតម្លាភាពខ្ពស់។

៨-រៀបចំជាកម្មវិធីទស្សនកិច្ចសិក្សា ដើម្បីដកស្រង់បទពិសោធន៍ទាំងក្នុង និងក្រៅប្រទេសដែលពាក់ព័ន្ធទៅនឹងការរៀបចំ និងការជំរុញអនុវត្តការងារដោះស្រាយទំនាស់ដីធ្លីប្រកបដោយប្រសិទ្ធភាព។

**មាត្រា១១**

នាយកដ្ឋានស៊ើបអង្កេត និងអធិការកិច្ចមានតួនាទី និងភារកិច្ចដូចតទៅ៖

ក-អំពីការងារស៊ើបអង្កេត

១-តាក់តែង និងរៀបចំនីតិវិធី និងបែបបទរាយការណ៍ស្តីពីការផ្តល់ព័ត៌មាននូវរាល់ទំនាស់ដីធ្លី និងបង្កើតឡើងនូវយន្តការស៊ើបអង្កេតមួយប្រកបដោយលក្ខណៈរលូន មានតម្លាភាព និងប្រសិទ្ធភាព។

២-ទទួលអនុវត្តបទបញ្ជាទាំងឡាយរបស់អគ្គលេខាធិការនៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីពាក់ព័ន្ធទៅនឹងដំណើរការស្រាវជ្រាវ និងស៊ើបអង្កេតករណីទំនាស់ដីធ្លីនីមួយៗ។

៣-ស្នើសុំគោលការណ៍ចុះស្រាវជ្រាវ និងស៊ើបអង្កេតដល់ទីកន្លែងកើតហេតុ ដើម្បីចងក្រងឯកសារ ស៊ើបអង្កេត និងប្រមូលភស្តុតាងពាក់ព័ន្ធទៅនឹងទំនាស់ដីធ្លី ដោយសហការជាមួយ

ស្ថាប័នជំនាញពាក់ព័ន្ធ ព្រមទាំងអាជ្ញាធរដែនដី និងធ្វើរបាយការណ៍ រួមទាំងធ្វើការសន្និដ្ឋានជូនថ្នាក់ដឹកនាំតាមឋានានុក្រម ពិនិត្យ និងសម្រេច។

៤-រៀបចំ និងបង្កើតឡើងនូវបណ្ណាញស្រាវជ្រាវដែលមានលក្ខណៈជាប្រព័ន្ធ គ្រប់ជ្រុងជ្រោយ និងមានសមត្ថភាពសម្រាប់បម្រើឱ្យការងារឃ្លាំមើល តាមដាន និងប្រមូលព័ត៌មាន។

៥-សិក្សាស្រាវជ្រាវ ប្រមូល និងស្វែងរកព័ត៌មានពីបណ្ណាញស្រាវជ្រាវរបស់ខ្លួនដែលពាក់ព័ន្ធទៅនឹងបញ្ហាទំនាស់ដីធ្លី ជាពិសេសព័ត៌មានអំពីការចោទប្រកាន់ ការឃុំខ្លួន និងអំពីពាក្យបណ្ដឹងនានាដែលពាក់ព័ន្ធនឹងទំនាស់ដីធ្លី។

៦-រៀបចំ និងបង្កើតឡើងនូវបែបបទ នីតិវិធី និងគោលការណ៍សម្រាប់ធ្វើការវិភាគ និងវាយតម្លៃព័ត៌មានដែលប្រមូលបានពីគ្រប់មជ្ឈដ្ឋានទាំងអស់ និងធានាឱ្យបាននូវសុក្រឹតភាព និងសុចរិតភាពលើរបាយការណ៍ផ្លូវការដែលបានមកពីការស៊ើបអង្កេត។

៧-ចងក្រង និងបង្កើតឡើងជាប្រព័ន្ធគ្រប់គ្រងទិន្នន័យស្រាវជ្រាវ ឬព័ត៌មានដែលពាក់ព័ន្ធដទៃទៀតសម្រាប់យកទៅប្រើប្រាស់ជាភស្តុតាងក្នុងការស៊ើបអង្កេត និងក្នុងការចោទប្រកាន់អំពីការរំលោភ និងទន្ទ្រានដីធ្លី។

៨-សិក្សាស្រាវជ្រាវចងក្រងច្បាប់ អនុក្រឹត្យ សារាចរណែនាំ ប្រកាស សេចក្ដីសម្រេច និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងបញ្ហាដីធ្លី។

ខ-អំពីការងារអធិការកិច្ច

១-ត្រួតពិនិត្យការអនុវត្តច្បាប់ បទបញ្ជា សេចក្ដីសម្រេច និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងបញ្ហាដីធ្លីរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងស្ថាប័នអនុវត្តច្បាប់ពាក់ព័ន្ធ។

២-ត្រួតពិនិត្យការដោះស្រាយទំនាស់ដីធ្លី និងស្ថាប័នអនុវត្តច្បាប់ពាក់ព័ន្ធ។

៣-ធ្វើរបាយការណ៍អំពីលទ្ធផលនៃការងារអធិការកិច្ច ជូនអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។

**មាត្រា១២**

នាយកដ្ឋានទទួល និងដោះស្រាយបណ្ដឹងមានតួនាទី និងភារកិច្ចដូចតទៅ៖

១-ទទួល និងចុះលេខពាក្យបណ្ដឹងចេញចូលតាមខេត្ត-ក្រុង និងរៀបចំកសាងសំណុំរឿង។

២-បញ្ចូលទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័រ។

៣-កោះអញ្ជើញដើមបណ្ដឹង និង/ឬចុងចម្លើយពាក់ព័ន្ធឱ្យមកបំពេញឯកសារបន្ថែម ប្រសិនយល់ថាឯកសារមិនគ្រប់គ្រាន់ និងធ្វើកំណត់ហេតុសួរយកចម្លើយជាបឋម។

៤-ធ្វើចំណាត់ថ្នាក់ កំណត់អាទិភាព និងប្រភេទវិវាទតាមវិស័យ។

៥-ប្រមូលទិន្នន័យ និងឯកសារបន្ថែម ដោយធ្វើទំនាក់ទំនងជាមួយភាគីជម្លោះ សាក្សី រដ្ឋអំណាចមូលដ្ឋាន ក្រសួង ស្ថាប័នពាក់ព័ន្ធជាតិ និងអន្តរជាតិសម្រាប់ធ្វើការវិភាគឱ្យបានសុក្រឹត។

៦-សហការជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ចុះពិនិត្យវាស់វែងប្លង់ និងព្រំដីវិវាទដល់ទីកន្លែង ដើម្បីផ្ទៀងផ្ទាត់ទៅតាមខ្លឹមសារនៃសំណុំរឿងវិវាទ។

៧-រៀបចំសំណុំឯកសារវាយតម្លៃលើលទ្ធផលចុះវាស់វែង និងបញ្ជូនលទ្ធផលដំបូងខាងផ្នែកបច្ចេកទេស ដើម្បីសុំគោលការណ៍ និងសេចក្ដីសម្រេចពីអគ្គលេខាធិការនៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។

៨-ធ្វើកំណត់បង្ហាញដោយសង្ខេបខ្លឹមសារបណ្ដឹង លើកអង្គហេតុ និងអង្គច្បាប់ពាក់ព័ន្ធ និងផ្ដល់យោបល់ជាបឋម ជូនថ្នាក់ដឹកនាំតាមឋានានុក្រម ពិនិត្យ និងសម្រេច។

៩-ធ្វើសេចក្ដីសម្រេចរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីដែលមានសុពលភាពអាចអនុវត្តបានទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីដើម្បីចាត់ចែងធ្វើការចុះបញ្ជីក្បាលដីតាមនីតិវិធី។

**មាត្រា១៣**

នាយកដ្ឋានបូកសរុប ព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ មានតួនាទី និងភារកិច្ចដូចតទៅ៖

១-សហការជាមួយនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ដើម្បីរៀបចំរបាយការណ៍បូកសរុបការងារគ្រប់នាយកដ្ឋាន និងរបាយការណ៍សកម្មភាពការងារផ្សេងៗទៀតរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ជូនអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ជាពិសេសកំណត់បង្ហាញ និងរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល។

២-កំណត់លក្ខណៈបច្ចេកទេសកុំព្យូទ័រ បង្កើត និងអនុវត្តនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា។

៣-គ្រប់គ្រង ការពារ និងថែទាំបណ្ណាញព័ត៌មានវិទ្យា ។

៤-បណ្តុះបណ្តាលរបៀបប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាដល់មន្ត្រី និងបុគ្គលិក ។

៥-ប្រមូលផ្តុំព័ត៌មានតាមប្រព័ន្ធឃោសនាជាតិ និងអន្តរជាតិដែលពាក់ព័ន្ធទៅនឹងទំនាស់ដីធ្លី ។

៦-សហការទំនាក់ទំនងជាមួយអង្គការជាតិ អន្តរជាតិ ដើម្បីផ្សព្វផ្សាយ រៀបចំ កៀងគរជំនួយក្នុងទិសដៅបម្រើគោលនយោបាយរបស់អាជ្ញាធរជាតិ ។

៧-ធ្វើរបាយការណ៍អំពីអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ

៨-ធ្វើការចងក្រងព័ត៌មាន និងធ្វើការផ្សព្វផ្សាយតាមប្រព័ន្ធឃោសនាជាតិ និងអន្តរជាតិរាល់ពេលប្រជុំសវនាការដោះស្រាយវិវាទ និងសកម្មភាពដោះស្រាយវិវាទទាំងឡាយរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ។

៩-សហការធ្វើស្បៀវភៅផ្ទត់បញ្ចាំងរូបភាពផ្សព្វផ្សាយអំពីការអប់រំ ទប់ស្កាត់កុំឱ្យមានទំនាស់ដីធ្លីតាមសហគមន៍ ។

**មាត្រា១៤**

នាយកដ្ឋានរដ្ឋបាល និងបុគ្គលិកមានតួនាទី និងភារកិច្ចដូចតទៅ៖

១-គ្រប់គ្រងការងាររដ្ឋបាលរបស់អគ្គលេខាធិការដ្ឋាន ។

២-កសាង និងរៀបចំលិខិតបទដ្ឋាននានារបស់អគ្គលេខាធិការដ្ឋាន និងចរាចរលិខិតទៅគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធ ។

៣-កសាង និងរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ។

៤-គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ ។

៥-រៀបចំ និងសម្រួលកិច្ចប្រជុំរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ។

៦-សហការជាមួយនាយកដ្ឋានបូកសរុប ព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ ដើម្បីធ្វើកំណត់ហេតុអង្គប្រជុំ របាយការណ៍បូកសរុបការងារគ្រប់នាយកដ្ឋាន និងរបាយការណ៍សកម្មភាព

ការងារផ្សេងៗទៀតរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ជូនអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ជាពិសេសកំណត់បង្ហាញ និងរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល ។

៧-រៀបចំផែនការគ្រប់គ្រងបុគ្គលិក និងធនធានមនុស្ស ជាពិសេសរៀបចំផែនការបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីធ្វើយ៉ាងណាឱ្យបុគ្គលិកដែលបម្រើការងារមានសមត្ថភាព និងជំនាញគ្រប់គ្រាន់ ដើម្បីអនុវត្តការងារឱ្យមានប្រសិទ្ធភាព ។

**មាត្រា១៥**

នាយកដ្ឋាននីមួយៗត្រូវសហការគ្នា ឱ្យដំណើរការងាររបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីប្រព្រឹត្តទៅដោយរលូន មានប្រសិទ្ធភាព និងទទួលបានជោគជ័យ ។ នាយកដ្ឋាននីមួយៗអាចស្នើសុំបង្កើតការិយាល័យមួយចំនួនតាមការចាំបាច់ដើម្បីជាសេនាធិការ ។

## ជំពូកទី៣ មន្ត្រី បុគ្គលិក

**មាត្រា១៦**

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដ្ឋី ប្រើប្រាស់បុគ្គលិកនៃមុខងារសាធារណៈ ឬអាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ។ ល័ក្ខខ័ណ្ឌនៃលាភការរបស់ភ្នាក់ងារជាប់កិច្ចសន្យា និងប្រាក់បំណាច់ពិសេសសម្រាប់បើកជូនភ្នាក់ងារមុខងារសាធារណៈ ត្រូវកំណត់ដោយប្រកាសរបស់ទីស្តីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់អគ្គលេខាធិការ ។

**មាត្រា១៧**

សមាជិក និងបុគ្គលិកទាំងអស់របស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានសិទ្ធិទទួលបានប្រាក់បំណាច់ផ្សេងៗដែលបានផ្តល់មកពីអង្គការផ្តល់ជំនួយក្នុងស្រុក ឬអង្គការផ្តល់ជំនួយអន្តរជាតិនានា ។

## ជំពូកទី៤ អវសានប្បញ្ញត្តិ

**មាត្រា១៨**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីចាប់ពីក្រោមថ្នាក់ប្រធាននាយកដ្ឋានចុះត្រូវកំណត់ដោយប្រកាសរបស់ទីស្តីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់អគ្គលេខាធិការនៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ។

*វាយឡើងវិញ*

**មាត្រា១៩**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ប្រធានស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្ត-ក្រុងត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

<u>កន្លែងទទួល</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ដូចមាត្រា១៩
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**លេខ១១សណន**

## សេចក្តីណែនាំ

## ស្តីពីការកសាងឯកសារចុះបញ្ជីដីធ្លី

មុននឹងដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ក្រសួងបានចេញឯកសារបណ្តុះបណ្តាលជំនាន់ទី១ នាខែមករា ឆ្នាំ២០០៣ និងជំនាន់ទី២ នាខែមីនា ឆ្នាំ២០០៤ និងបានដំណើរការបណ្តុះបណ្តាលមន្ត្រីជំនាញទាំងអស់អំពីនីតិវិធីនៃការបំពេញទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី តែក្នុងការអនុវត្តជាក់ស្តែង ក្រសួងពិនិត្យឃើញថាការកសាងឯកសារចុះបញ្ជីដីធ្លីនៅតាមខេត្ត-ក្រុងអនុវត្តគម្រោងមួយចំនួនមានការធ្វេសប្រហែស ខ្វះការទទួលខុសត្រូវ ទាំងនីតិវិធី និងទិដ្ឋភាពគតិយុត្ត ពិសេសទាក់ទងនឹងការកំណត់អត្តសញ្ញាណម្ចាស់អចលនវត្ថុ។

ដើម្បីចៀសវាងកំហុសឆ្គង និងបាតុភាពខាងលើ ក្រសួងធ្វើការណែនាំដូចខាងក្រោម៖

១-មន្ត្រីវិនិច្ឆ័យត្រូវផ្អែកលើច្បាប់ និងបទដ្ឋានគតិយុត្តដែលមានជាធរមានក្នុងការកំណត់អត្តសញ្ញាណម្ចាស់អចលនវត្ថុ ជាអាទិ៍ ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើត សញ្ជាតិ សាវតារ និងស្ថានភាពស៊ីវិលនៅពេលបំពេញទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី។

២-មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យត្រូវត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ និងទទួលខុសត្រូវរាល់ទិន្នន័យនៅក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី។

៣-មន្ត្រីបញ្ចូលទិន្នន័យ (GIS) ត្រូវយកចិត្តទុកដាក់ និងទទួលខុសត្រូវលើការបញ្ចូលទិន្នន័យក្នុងកុំព្យូទ័រ។ ទិន្នន័យដែលបញ្ចូលក្នុងកុំព្យូទ័រត្រូវតែធានាត្រឹមត្រូវ។ មន្ត្រីទទួលបន្ទុកមិនត្រូវកែប្រែ ឬបន្ថែមឱ្យខុសពីទិន្នន័យនៃទម្រង់បែបបទតាមទំនើងចិត្តឡើយ ពុំនោះនឹងត្រូវប្រឈមនឹងច្បាប់ និងបទបញ្ជាជាធរមាន។

*វាយឡើងវិញ*

៤-ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុងត្រូវចាត់តាំងមន្ត្រីទទួលបន្ទុកត្រួតពិនិត្យគុណភាព។ មន្ត្រីទទួលបន្ទុកនេះ ត្រូវផ្សេងពីមន្ត្រីបញ្ចូលទិន្នន័យ។

(ភ្ជាប់ជាមួយឯកសារឧបសម្ព័ន្ធណែនាំស្តីពីការកសាងឯកសារចុះបញ្ជីដីធ្លី)

ទទួលបានសេចក្តីណែនាំនេះ គ្រប់មន្ទីរអនុវត្តគម្រោងទាំងអស់ត្រូវចាត់ចែងអនុវត្តខ្លឹមសារខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

ភ្នំពេញ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៦

**ជ.ទេសរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**
**ហត្ថលេខា និងត្រា**
**ឆាន់ សាផាន**

<u>ចម្លងជូន</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
-គ្រប់ក្រសួង ស្ថាប័ន
-គ្រប់សាលាខេត្ត-ក្រុង
-ឯកសារ-កាលប្បវត្តិ

## ឯកសារឧបសម្ព័ន្ធ ឯកសារណែនាំស្តីពីការកសាងឯកសារចុះបញ្ជីដីធ្លី លេខ១១ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៦

### សញ្ជាតិ

១-ច្បាប់ភូមិបាល មាត្រា៨

មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីនៃព្រះរាជាណាចក្រកម្ពុជា។ អ្នកមានឧបនិស្ស័យជាកម្មសិទ្ធិករលើដីនៅកម្ពុជាគឺពលរដ្ឋខ្មែរទាំងអស់ សមូហភាពដែនដីសាធារណៈ គ្រឹះស្ថានសាធារណៈ សហគមន៍ ឬសមាគមកម្ពុជា សហគ្រាសសាធារណៈ និងក្រុមហ៊ុនស៊ីវិល ឬពាណិជ្ជកម្ម និងគ្រប់អង្គការកម្ពុជាដែលបានទទួលស្គាល់ដោយច្បាប់ថាជានីតិបុគ្គល។

ជនបរទេសដែលបានក្លែងបន្លំប័ណ្ណសញ្ជាតិ ដើម្បីឱ្យក្លាយជាកម្មសិទ្ធិករលើដីនៅកម្ពុជា នឹងត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា២៥១នៃច្បាប់នេះ។ ទ្រព្យដែលបានមកក្នុងល័ក្ខខ័ណ្ឌនេះត្រូវរឹបអូសយកទុកជាសម្បត្តិរដ្ឋ ដោយរដ្ឋមិនចេញសំណងឱ្យឡើយ។

២-ក្នុងឯកសារបណ្តុះបណ្តាលក្រុមចុះបញ្ជីដីធ្លីជំនាន់ទី១ ខែមករា ២០០៣ ត្រង់ចំណុចសញ្ជាតិក្នុងទំព័រទី១២៥បានបញ្ជាក់ថា៖

សម្រាប់រូបវន្តបុគ្គល ប្រសិនបើមានអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនដែលបង្ហាញពីសញ្ជាតិរបស់បុគ្គលនោះយ៉ាងច្បាស់លាស់។ ប្រសិនបើមិនមានឯកសារណាផ្តល់ឱ្យទេ មន្ត្រីវិនិច្ឆ័យត្រូវបំពេញទម្រង់បែបបទស្របទៅតាមអ្វីដែលម្ចាស់ដី ឬភោគី និងសាក្សីផ្សេងទៀតនិយាយប្រាប់។

> ត្រូវប្រុងប្រយ័ត្នមិនត្រូវច្រឡំរវាងពាក្យ "ជនជាតិខ្មែរ" និង "សញ្ជាតិខ្មែរ" នោះទេ។ សញ្ជាតិខ្មែរគឺមិនមែនទាក់ទងទៅនឹងភាពជាជនជាតិខ្មែរទេ។ ឧទាហរណ៍ ជនជាតិដើមភាគតិចមួយចំនួនធំជាជនជាតិចាម ចិន នៅប្រទេសកម្ពុជា ពួកគេមានសញ្ជាតិខ្មែរពីកំណើត ប៉ុន្តែមិនមែនជាជនជាតិខ្មែរទេ។ មនុស្សម្នាក់អាចទទួលសញ្ជាតិខ្មែរ ប្រសិនបើឪពុក ឬម្តាយរបស់ខ្លួនជាជនជាតិខ្មែរ ឬប្រសិនបើបើមនុស្សនេះបានកើតនៅប្រទេសកម្ពុជាស្របតាមល័ក្ខខ័ណ្ឌជាក់លាក់ (មាត្រា៤នៃច្បាប់ស្តីពីសញ្ជាតិ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៩៦) ឬបន្ទាប់ពីបានរៀបអាពាហ៍ពិពាហ៍ជាមួយសញ្ជាតិខ្មែរ ស្របតាម

លក័្ខខណ្ឌជាក់លាក់ (មាត្រា៥ និង៦នៃច្បាប់នេះ) ឬដោយការធ្វើសញ្ជាតូបនីយកម្ម (មាត្រា៧ ដល់១៧នៃច្បាប់នេះ)។

៣-ក្នុងឯកសារបណ្តុះបណ្តាលក្រុមចុះបញ្ជីដីធ្លី ជំនាន់ទី២ ខែមីនា ២០០៤ ត្រង់ចំណុចសញ្ជាតិ ទំព័រទី១២ បានបញ្ជាក់ថា៖

| | | |
|---|---|---|
| សញ្ជាតិ | ខ្មែរ | ខ្មែរ |

គឺសំអាងលើឯកសារដូចជាអត្តសញ្ញាណប័ណ្ណ ឬសំបុត្រអត្រានុកូលដ្ឋាន ឬសៀវភៅគ្រួសារ ឬលិខិតឆ្លងដែន។ តាមច្បាប់ មានតែបុគ្គលដែលមានសញ្ជាតិខ្មែរទេ ទើបមានសិទ្ធិជាកម្មសិទ្ធិលើដីនៃព្រះរាជាណាចក្រកម្ពុជា។

**ការទទួលខុសត្រូវ** ក្នុងឯកសារបណ្តុះបណ្តាលទាក់ទងនឹងការងារ GIS ក៏បានបញ្ជាក់នូវភារកិច្ចរបស់មន្ត្រី GIS ដូចខាងក្រោម៖

ទិន្នន័យនៃការចុះបញ្ជីដីធ្លីគឺជាទិន្នន័យមានសារៈសំខាន់ ព័ត៌មានរបស់វានិយាយអំពីម្ចាស់កម្មសិទ្ធិ និងសិទ្ធិជាកម្មសិទ្ធិ។

*វាយឡើងវិញ*

**នស/រកត/០៨០៦/៣៣៩**

# ព្រះរាជក្រឹត្យ

## ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរការនៃការធ្វើអនុបយោគទ្រព្យ សម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រ កាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ និងច្បាប់ទាំងឡាយដែលធ្វើវិសោធនកម្មច្បាប់នេះ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រការឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី ដែលបានការឯក ភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៦

## ត្រាស់បង្គាប់

**មាត្រា១**

ព្រះរាជក្រឹត្យនេះមានគោលដៅកំណត់គោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ ។

**មាត្រា២**

អនុបយោគគឺជាប្រតិបត្តិការនៃការធ្វើចំណាត់ថ្នាក់ឡើងវិញ លើទ្រព្យសម្បត្តិរបស់រដ្ឋដែលនាំឱ្យមានការផ្លាស់ប្តូរឋានៈ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។

**មាត្រា៣**

ការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈត្រូវគោរពតាមល័ក្ខខ័ណ្ឌដូចខាងក្រោម៖

-ទ្រព្យសម្បត្តិនោះលែងជាតម្រូវការនៃផលប្រយោជន៍សាធារណៈ ឬ

-ទ្រព្យសម្បត្តិនោះបាត់បង់លក្ខណៈសម្បត្តិពេញលេញរបស់ខ្លួនក្នុងការបម្រើប្រយោជន៍សាធារណៈ ឬ

-ទ្រព្យសម្បត្តិនោះលែងជាការប្រើប្រាស់ដោយផ្ទាល់ ដោយសាធារណជន។

**មាត្រា៤**

ការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈអាចធ្វើទៅបានតែចំពោះទ្រព្យសម្បត្តិទាំងឡាយណា ដែលបានចុះក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋរួចជាស្រេច។

**មាត្រា៥**

រាជរដ្ឋាភិបាលសម្រេចធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ ដោយអនុក្រឹត្យ ។

វិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ ត្រូវកំណត់ដោយអនុក្រឹត្យ ។

*វាយឡើងវិញ*

**មាត្រា៦**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៧**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

លេខ ៣២១ច.ល **នរោត្តម សីហមុនី**

**ដើម្បីចម្លងចែក**

**រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៦**

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន

លេខ២៥៨ប្រក/បស្ត/កអធ

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៦

# ប្រកាស

## ស្តីពីការគ្រប់គ្រង និងការទប់ស្កាត់បទល្មើសលើធនធានធម្មជាតិ នៅក្នុងតំបន់ការពារធម្មជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៤ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញា ស្តីពីតំបន់ពីដីសើមមានសារៈសំខាន់ជាអន្តរជាតិ ពិសេសជាទីជម្រកសត្វស្លាបទឹក
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៧០ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០១ ស្តីពីការបង្កើត និងគ្រប់គ្រងឋបនីយជីវមណ្ឌលបឹងទន្លេសាប

- បានឃើញអនុក្រឹត្យលេខ៥៧អនក្រ/បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមការងារចាំបាច់ក្នុងការគ្រប់គ្រងធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ ។

**សម្រេច**

**ប្រការ១**

គោលបំណងនៃប្រកាសនេះគឺអនុវត្តបទប្បញ្ញត្តិច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងវិធានការដែលពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ការពារធនធានធម្ម-ជាតិ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង ការអភិរក្សជីវៈចម្រុះ ធនធានធម្មជាតិ ការប្រើប្រាស់ធនធានធម្មជាតិ និងការចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយនិរន្តរភាពស្របតាមគោលនយោបាយរបស់រដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រប្រជាពលរដ្ឋ ។

**ប្រការ២**

ប្រកាសនេះអនុវត្តចំពោះតំបន់ការពារធម្មជាតិដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន ដូចបានកំណត់ដោយលិខិតបទដ្ឋានដែលមានជាអាទិ៍ ដូចខាងក្រោមនេះ៖

-ព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ

-ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៧០ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០១ ស្តីពីការបង្កើត និងការគ្រប់គ្រងបរិវេណជីវមណ្ឌលបឹងទន្លេសាប

-ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៤ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញា ស្តីពីតំបន់ដីសើមមានសារៈសំខាន់ជាអន្តរជាតិ ពិសេសជាទីជម្រកសត្វស្លាបទឹក ។

**ប្រការ៣**

ក្រសួងបរិស្ថានគ្រប់គ្រងតំបន់ការពារធម្មជាតិក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ហើយតំបន់ការពារធម្មជាតិនីមួយៗបែងចែកជាបួន (៤) តំបន់គ្រប់គ្រង រួមមានតំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍នៃតំបន់ការពារធម្មជាតិ ។

ប្រការ៤

តំបន់ស្នូល ជាតំបន់គ្រប់គ្រងដែលមានតម្លៃខ្ពស់ សម្រាប់ការអភិរក្សប្រភេទ សត្វ រុក្ខជាតិដែលកម្រ ជិតផុតពូជ ទទួលរងគ្រោះថ្នាក់ គំរាមកំហែង និងមានប្រព័ន្ធអេកូឡូស៊ីផុយស្រួយ ។

ការចេញចូលតំបន់នេះត្រូវហាមឃាត់ លើកលែងតែមន្ត្រីនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិដែលមានភារកិច្ច និងអ្នកស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រធម្មជាតិ ក្នុងគោលបំណងការពារ និងអភិរក្សធនធានធម្មជាតិ ជីវៈចម្រុះ និងបរិស្ថានដែលត្រូវមានការអនុញ្ញាតជាមុនពីក្រសួងបរិស្ថាន លែកលែងតែមានការចាំបាច់ក្នុងវិស័យសន្តិសុខ និងការពារជាតិ ។

ប្រការ៥

តំបន់អភិរក្សជាតំបន់គ្រប់គ្រងឋិតនៅជាប់នឹងតំបន់ស្នូល ដែលមានតម្លៃខាងការអភិរក្សធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី តំបន់ទីជម្រាល និងតំបន់ដែលមានលក្ខណៈទេសភាពធម្មជាតិ ។

ការចេញចូលក្នុងតំបន់នេះត្រូវមានការអនុញ្ញាតជាមុន ពីមន្ត្រីនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ នៅនឹងកន្លែងលើកលែងតែមានការចាំបាច់ក្នុងវិស័យសន្តិសុខ និងការពារជាតិ ។

ការប្រើប្រាស់អនុផលធនធានធម្មជាតិក្នុងតំបន់នេះ សម្រាប់ជីវភាពរបស់សហគមន៍មូលដ្ឋានជនជាតិភាគតិចដែលមិនប៉ះពាល់ពាល់ខ្លាំងដល់ជីវៈចម្រុះ ត្រូវឋិតនៅក្រោមការត្រួតពិនិត្យម៉ត់ចត់បំផុតរបស់មន្ត្រីនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ ។

ប្រការ៦

តំបន់ប្រើប្រាស់ដោយចីរភាពជាតំបន់គ្រប់គ្រងដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់ បម្រើដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ការគ្រប់គ្រង ការអភិរក្សតំបន់ការពារធម្មជាតិផ្ទាល់ និងចូលរួមលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ។ តំបន់ប្រើប្រាស់ដោយចីរភាពរួមមាន៖

-តំបន់អភិរក្សវប្បធម៌ធម្មជាតិ

-តំបន់ទេសចរណ៍ធម្មជាតិ

-តំបន់អភិរក្សសត្វព្រៃ និងសេវាកម្ម

-តំបន់ស្តារធនធានជីវៈចម្រុះ

-សហគមន៍តំបន់ការពារធម្មជាតិ

-តំបន់រុក្ខឧទ្យាន

-តំបន់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ រួមមានប្រព័ន្ធធារាសាស្ត្រ អាងស្តុកទឹក វារីអគ្គិសនី បង្គោលចរន្តអគ្គិសនី

-តំបន់ភូគព្ភសាស្ត្រ

-តំបន់អាជីវកម្មរុក្ខជាតិ អនុគ្រោះដល់បរិស្ថានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ និងតំបន់ជុំវិញ។

ការអភិវឌ្ឍ និងការវិនិយោគនៅក្នុងតំបន់នេះ អាចអនុវត្តទៅបានលុះណាតែមានការសម្រេច និងអនុញ្ញាតពីរាជរដ្ឋាភិបាល តាមការស្នើសុំរបស់ក្រសួងបរិស្ថាន និងស្របតាមបទប្បញ្ញត្តិនៃមាត្រា៦ និងមាត្រា៧ ក្នុងជំពូក៣នៃច្បាប់ស្តីពីបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

**ប្រការ៧**

តំបន់សហគមន៍នៃតំបន់ការពារធនធានធម្មជាតិ ជាតំបន់គ្រប់គ្រងបម្រើឱ្យការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចរបស់សហគមន៍ និងជនជាតិដើមភាគតិចដែលមានសកម្មភាពស្រាប់ រួមមានលំនៅឋាន ស្រែ និងចម្ការ។

ការចេញប័ណ្ណដីធ្លី ឬការអនុញ្ញាតឱ្យប្រើប្រាស់ និងកាន់កាប់ដីធ្លីនៅក្នុងតំបន់នេះ ត្រូវមានការបញ្ជាក់យល់ព្រមជាមុនពីក្រសួងបរិស្ថាន ដោយអនុលោមតាមច្បាប់ភូមិបាល។

**ប្រការ៨**

តំបន់ការពារធម្មជាតិនីមួយៗត្រូវកំណត់ព្រំប្រទល់ ទីតាំង ទីចាត់ការ ស្នាក់ការ ស្នាក់ការរង និងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រង។

**ប្រការ៩**

ហាមដាច់ខាតការបរបាញ់ ដាក់អន្ទាក់ អង្គប់ ប្រមូលពងកូនសត្វព្រៃ និងសត្វស្លាប និងវារីសត្វដើម្បីយកសាច់ ភ្លុក ឆ្អឹង ស្លាប ស្នែង ស្បែក រោម ឈាម ការបរបាញ់ជាលក្ខណៈកីឡា និងការស្តុក ការទិញ ការតាំងលក់សត្វព្រៃ សំណាកសត្វព្រៃគ្រប់ប្រភេទនៅក្នុងតំបន់ការពារធម្មជាតិ។

**ប្រការ១០**

ហាមដាច់ខាតការកាប់ព្រៃលិចទឹក ព្រៃកោងកាង ការប្រើប្រាស់ឧបករណ៍នេសាទ ដែលរដ្ឋហាមឃាត់ ការបំផ្លាញពូជមច្ឆាជាតិកម្រ ផ្កាថ្ម ស្មៅសមុទ្រ និងសកម្មភាពផ្សេងទៀតដែលបំផ្លិចបំផ្លាញធនធានធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិ ។

**ប្រការ១១**

ហាមដាច់ខាតការតាក់តែងព្រៃគុប ការសង់រោងចក្រអារឈើ ការធ្វើអាជីវកម្មព្រៃឈើគ្រប់ប្រភេទ ឡចម្រាញ់វល្លិរមៀត ខ្លឹមចន្ទន៍ធម្មជាតិ ឡចម្រាញ់ប្រេងព្រៅនៅក្នុងតំបន់ការពារធម្មជាតិ ។

**ប្រការ១២**

ហាមដាច់ខាតការសង់រោងសិប្បកម្មកែច្នៃឈើ អនុផលព្រៃឈើ ឡធ្យូង ឡឥដ្ឋ ឡក្បឿង ឡកំបោរ ឡចំហុយថ្នាំជក់នៅក្នុងតំបន់ស្នូល តំបន់អភិរក្ស និងតំបន់ប្រើប្រាស់ដោយចីរភាពនៃតំបន់ការពារធម្មជាតិ ។

**ប្រការ១៣**

ហាមដាច់ខាតការកាប់គាស់ រុករាន ឆ្ការព្រៃ ឈូសឆាយ និងហ៊ុំព័ទ្ធ កាន់កាប់ដីព្រៃ ដីតំបន់ឆ្នេរដើម្បីយកដីធ្វើដំណាំកសិឧស្សាហកម្ម ការយកដីសាងសង់លំនៅឋាន ធ្វើស្រែចម្ការពង្រីកដីកសិកម្មជាកម្មសិទ្ធិឯកជន ឬអង្គភាពរដ្ឋ ឬសមូហភាពនៅក្នុងតំបន់ការពារធម្មជាតិ ។

**ប្រការ១៤**

ការកាប់គាស់ ការឈូសឆាយដីព្រៃក្នុងតំបន់ការពារធម្មជាតិ ដើម្បីស្ថាបនា និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈគ្រប់ប្រភេទដែលកាត់តាមតំបន់ស្នូល និងតំបន់អភិរក្សនៃតំបន់ការពារធម្មជាតិត្រូវហាមឃាត់ ។

ករណីនេះអាចធ្វើទៅបានតែក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍នៃតំបន់ការពារធម្មជាតិ ដោយមានការសម្រេចពីរាជរដ្ឋាភិបាល តាមការស្នើសុំរបស់ក្រសួងបរិស្ថាន ។

**ប្រការ១៥**

ហាមដាច់ខាតការធ្វើអាជីវកម្មកូនរុក្ខជាតិគ្រប់ប្រភេទ ការផ្តួលរំលំ គាស់រំលើងគល់ ក្រៀវ ចងរឹតការកាប់បំផ្លាញដើមឈើតាមគ្រប់រូបភាព ដើម្បីប្រមូលអនុផលព្រៃឈើនៅក្នុងតំបន់ការពារធម្មជាតិ ។

**ប្រការ១៦**

ហាមបង្កឱ្យភ្លើងឆេះព្រៃក្នុងតំបន់ការពារធម្មជាតិ។ ការប្រើប្រាស់ភ្លើងអាចអនុគ្រោះបាន ចំពោះមន្ត្រីនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ ដើម្បីផលប្រយោជន៍រុក្ខវប្បកម្ម ផ្លូវភ្លើង ឬ អនាម័យព្រៃ។

ប្រជាពលរដ្ឋ កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ មានករណីកិច្ច ចូលរួមសហការក្នុងការថែរក្សាការពារព្រៃឈើ ក្នុងការប្រយុទ្ធទប់ស្កាត់ភ្លើងឆេះព្រៃនៅក្នុងតំបន់ ការពារធម្មជាតិ។

**ប្រការ១៧**

ហាមដាច់ខាត ការវាយបំផ្លាញ ដុត គាស់រំលើង ដកចេញ រំកិលបង្គោលព្រំសីមា ផ្លាកសញ្ញា អគារ ស្ពាន លូ ផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតនៅក្នុងតំបន់ការពារធម្មជាតិ។

**ប្រការ១៨**

ហាមដាច់ខាតការដាក់ថ្នាំបំពុល ការប្រើសារធាតុគីមី ការប្រើឧបករណ៍ ការចោល សំណល់រឹង រាវបំផ្លាញគុណភាពទឹក ឬដីនៅតំបន់ការពារធម្មជាតិ។

**ប្រការ១៩**

ការស្រាវជ្រាវសិក្សាពិសោធន៍ ការស្រាវជ្រាវភូគព្ភសាស្ត្រ ឬការសិក្សាផ្នែកវិទ្យាសាស្ត្រ ធម្មជាតិ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចជាតិក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍នៃតំបន់ ការពារធម្មជាតិ ត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថាន។

**ប្រការ២០**

ដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន និងសង្គមឱ្យបានជាអប្បបរមា និងសម្រេចបាន នូវគោលបំណងយុទ្ធសាស្ត្រនៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ រាល់គម្រោងអភិវឌ្ឍន៍ ឬវិនិយោគ ក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍នៃតំបន់ការពារធម្មជាតិ ត្រូវអនុលោមតាម នីតិវិធី និងបទប្បញ្ញត្តិនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។

**ប្រការ២១**

រាល់ការនាំចេញ ការនាំចូលគ្រាប់រុក្ខជាតិ ការបង្កាត់ពូជប្រភេទសត្វព្រៃ និងពូជមច្ឆជាតិ

គ្រប់ប្រភេទក្នុងតំបន់ការពារធម្មជាតិ ត្រូវធ្វើការសិក្សាស្រាវជ្រាវ វិភាគ វិនិច្ឆ័យ វាយតម្លៃឱ្យបានច្បាស់លាស់ពីនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ និងត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិន។

**ប្រការ២២**

រាល់ការនាំចេញ ការនាំចូល ឬការដោះដូរដែលពុំមានលក្ខណៈពាណិជ្ជកម្មនូវប្រភេទសត្វ រុក្ខជាតិ គ្រាប់ពូជរុក្ខជាតិ ការបង្កាត់ពូជ និងសំណាករបស់ប្រភេទទាំងនោះ ដែលមានដើមកំណើតនៅក្នុងតំបន់ការពារធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា ជាមួយប្រទេសដទៃត្រូវធ្វើការសិក្សាស្រាវជ្រាវ វិភាគ វិនិច្ឆ័យ វាយតម្លៃឱ្យបានច្បាស់លាស់ពីមន្ត្រីនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ និងត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថាន។

**ប្រការ២៣**

ការប្រើប្រាស់គ្រឿងចក្រធន់ធ្ងន់ គ្រឿងផ្ទុះអាចអនុញ្ញាតឱ្យប្រើប្រាស់បានតែក្នុងតំបន់អភិវឌ្ឍន៍ដោយចីរភាព និងតំបន់សហគមន៍នៃតំបន់ការពារធម្មជាតិ ដោយមានកិច្ចសន្យាការពារបរិស្ថានជាមួយក្រសួងបរិស្ថាន។ ម្ចាស់គ្រឿងចក្រ និងអ្នកប្រើប្រាស់គ្រឿងផ្ទុះត្រូវបំពាក់ឧបករណ៍កាត់បន្ថយការបំពងសំឡេងរំញ័រហួសកម្រិតស្តង់ដាកំណត់ និងត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថានជាមុន។

**ប្រការ២៤**

ហាមដាច់ខាតការនេសាទដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់ ការធ្វើឱ្យប៉ះពាល់ដល់ធនធានធម្មជាតិទាំងក្នុងដែនសមុទ្រ និងដែនទឹកសាប ព្រៃលិចទឹក ព្រៃកោងកាង ផ្កាថ្ម ស្មៅសមុទ្រនៅក្នុងតំបន់ការពារធម្មជាតិ។

**ប្រការ២៥**

ហាមដាច់ខាតការធ្វើវារីវប្បកម្មទឹកសាប ទឹកប្រៃដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់ និងបច្ចេកទេសដែលនាំដល់ការបំពុល ឬការបំផ្លាញមជ្ឈដ្ឋានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ការពារធម្មជាតិ។

ការធ្វើវារីវប្បកម្មលក្ខណៈធម្មជាតិ ដែលជួយទ្រទ្រង់ដល់ប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ការពារធម្មជាតិ ត្រូវមានការយល់ព្រមពីរាជរដ្ឋាភិបាលតាមការស្នើសុំរបស់ក្រសួងបរិស្ថាន។

**ប្រការ២៦**

រាល់ការថតខ្សែភាពយន្ត វីដេអូ និងថតរូបភាពផ្សេងៗនៅក្នុងតំបន់ការពារធម្មជាតិសម្រាប់ធ្វើអាជីវកម្ម ត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថានជាមុន។

**ប្រការ២៧**

មន្ត្រីនគរបាលយុត្តិធម៌នៃនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ ក្រសួងបរិស្ថាន និងមន្ត្រីឧទ្យាននុរក្សមានសមត្ថកិច្ចស៊ើបអង្កេត ស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសលើធនធានធម្មជាតិក្នុងរង្វង់ដែនសមត្ថកិច្ចរបស់ខ្លួន និងកសាងសំណុំរឿងបញ្ជូនទៅតុលាការ។

**ប្រការ២៨**

ជនណាដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ២៩**

ប្រកាសលេខ១០៣៣បដ្ឋ/នកធ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៩៨ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៣០**

អគ្គនាយកបច្ចេកទេស អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គាធិការ នាយកខុទ្ទកាល័យទេសរដ្ឋមន្ត្រី ប្រធាននាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ ប្រធានមន្ទីរបរិស្ថានខេត្ត-ក្រុង នាយកតំបន់ការពារធម្មជាតិ និងអង្គភាពពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ហត្ថលេខា និងត្រា**

**ម៉ុក ម៉ារ៉េត**

**បណ្ឌិត ជីវវិទ្យា**

*<u>ចម្លងជូន</u>*

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី

-គ្រប់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន

-គ្រប់អភិបាលខេត្ត-ក្រុង

-ដូចប្រការ៣០ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ**
**លេខ១៨៧អសជភ** ភ្នំពេញ ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៦

**អគ្គនាយកនៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ**
**ជម្រាបមក**
**លោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីគ្រប់ខេត្ត-ក្រុង**

កម្មវត្ថុ៖ អំពីការអនុវត្តសាលក្រម ឬសាលដីកាស្ថាពរពាក់ព័ន្ធនឹងការផ្ទេរអចលនវត្ថុ
យោង៖ -លិខិតលេខ៣៣០កយ/រប/០៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៦ របស់ក្រសួងយុត្តិធម៌
-ចំណារឯកភាពរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី ចុះថ្ងៃទី០៤-០៥-២០០៦

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក-លោកស្រីជាប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុងជ្រាបថា ការអនុវត្តសាលក្រម ឬសាលដីកាស្ថាពរដែលពាក់ព័ន្ធនឹងការផ្ទេរអចលនវត្ថុ និងសេចក្តីសម្រេចផ្សេងៗរបស់តុលាការ ដែលភាគីអ្នកឈ្នះក្តីបានយកសាលក្រម ឬសាលដីកាស្ថាពរទៅស្នើសុំផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុនោះ ចាំបាច់ត្រូវឱ្យភ្ជាប់មកជាមួយសាលក្រម ឬសាលដីកាស្ថាពរនូវកំណត់ហេតុអនុវត្តសាលក្រម ឬសាលដីកាស្ថាពរនេះ ទើបអនុវត្តបាន។ ក្នុងករណីភាគីឈ្នះក្តីពុំមានសំអាងណាមួយ បញ្ជាក់ថា សាលក្រម ឬសាលដីកាស្ថាពរនោះត្រូវបានអនុវត្តដោយតុលាការទេ ជំនាញសុរិយោដីមិនអាចធ្វើការផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុតាមសំណើរបស់ភាគីឈ្នះក្តីបានឡើយ។

ដើម្បីឱ្យការអនុវត្តប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព ខ្ញុំសូមអស់លោក-លោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី អនុវត្តតាមការណែនាំនេះឱ្យបាន

*វាយឡើងវិញ*

ត្រឹមត្រូវ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់គ្រប់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រោមឱវាទ។

សូមលោក-លោកស្រីទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ។

<u>ចម្លងជូន</u>

-ក្រសួងយុត្តិធម៌

-គ្រប់សាលាខេត្ត-ក្រុង

"ដើម្បីសូមជូនជ្រាប"

-ឯកសារ-កាលប្បវត្តិ

**អគ្គនាយក**

**ហត្ថលេខា និងត្រា**

**លឹម វ៉ាន់**

*វាយឡើងវិញ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ៤៣សសរ

## សេចក្តីសម្រេច

## ស្តីពីការកំណត់ក្រមសីលធម៌សម្រាប់មន្ត្រីអនុវត្តគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤/០៩ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ/បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

### សម្រេច

**ប្រការ១**

ត្រូវបានកំណត់ក្រមសីលធម៌សម្រាប់មន្ត្រីអនុវត្តគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី ដូចខាងក្រោម៖

១-មន្ត្រីអនុវត្តគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីទាំងអស់ជាអ្នកអនុវត្តការងារសំខាន់ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាលក្នុងការកែទម្រង់ដីធ្លី ត្រូវប្តេជ្ញាចិត្តខ្ពស់ប្រកបដោយមនសិការវិជ្ជាជីវៈ សេចក្តីថ្លៃថ្នូមានភាពស្មោះត្រង់ តម្លាភាព និងមានអភិបាលកិច្ចល្អក្នុងគ្រប់ការងារ ដោយត្រូវប្រកាន់ខ្ជាប់នូវការរីកចម្រើនប្រកបដោយចីរភាព និងយុត្តិធម៌ ។

២-មន្ត្រីអនុវត្តគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីត្រូវទទួលខុសត្រូវចំពោះការផ្តល់សេវាសាធារណៈ ដោយត្រូវធ្វើឱ្យមានការជឿជាក់ពីសំណាក់សាធារណជន និងលើការបម្រើសេវាសាធារណៈ។ មន្ត្រីទាំងអស់ត្រូវអនុវត្តការងារតាមច្បាប់ អនុក្រឹត្យ បទដ្ឋានគតិយុត្ត និងបទបញ្ជាពាក់ព័ន្ធនានាដោយកំណត់ច្បាស់លាស់ថា ការបម្រើប្រយោជន៍សាធារណៈជាភារកិច្ចចម្បង ។

មន្ត្រីទាំងអស់ត្រូវមានភក្តីភាពចំពោះគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយប្រកាន់ជាប់នូវសុចរិតភាព ភាពមិនលំអៀងដែលទិសដៅណែនាំច្បាស់លាស់ និងមានតម្លាភាពលើគ្រប់ទិដ្ឋភាពការងារ ។

៣-មន្ត្រីទាំងអស់ត្រូវបម្រើសេវាកម្មជូនសាធារណជនដោយមិនទារសគុណ កម្រៃជើងសាក្រៅពីតម្លៃសេវាជាផ្លូវការដែលរដ្ឋបានកំណត់ និងមិនត្រូវស្វែងរកប្រយោជន៍ផ្ទាល់ខ្លួនក្នុងពេលអនុវត្តការងារ ទោះបីតាមរូបភាពណាក៏ដោយ ។ មិនត្រូវប្រព្រឹត្តអំពើណាដែលនាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់គម្រោង និងកិត្យានុភាពរបស់ក្រសួងឡើយ ។

៤-ត្រូវគោរពសិទ្ធិ សេរីភាព សេចក្តីថ្លៃថ្នូរ និងសមភាពរបស់ប្រជាពលរដ្ឋជាអតិថិជនដោយ៖

-មិនត្រូវមានភាពលំអៀង មិនត្រូវបំភាន់ព័ត៌មានដែលនាំឱ្យមានការសម្រេចខុស មិនត្រូវនាំសហការីក្រោមឱវាទរបស់ខ្លួន ឬសាធារណជនឱ្យធ្វើខុសដោយបំពានច្បាប់ ឬបំភាន់ ក្លែងឯកសារឡើយ

-ត្រូវគោរពសេរីភាពក្នុងជំនឿ និងសាសនា និងគ្មានការរើសអើង

-មិនត្រូវឃុបឃិតលើអំពើខុសឆ្គងរបស់បុគ្គលណាម្នាក់ឡើយ ទោះបីជាអ្នកនោះបម្រើការ ឬតំណាងឱ្យគម្រោងក៏ដោយ

-ត្រូវមានសមានចិត្តទូលំទូលាយក្នុងការប្រាស្រ័យទាក់ទងជាមួយសាធារណជន

-ត្រូវមានអាកប្បកិរិយាប្រកបដោយការគោរព មានយុត្តិធម៌ សមធម៌ ព្រមទាំងការពារសិទ្ធិរបស់អ្នកនៅក្រោមឱវាទរបស់ខ្លួន រួមទាំងការគោរព និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ឬការបង្កើតសមាគម

-ត្រូវចាត់វិធានការម៉ឺងម៉ាត់ និងជាបន្ទាន់ក្នុងការកែលំអ នៅពេលដែលរកឃើញកំហុសឆ្គងរបស់មន្ត្រីក្រោមឱវាទ និងរាយការណ៍ជូនថ្នាក់លើ ដើម្បីមានវិធានការតាមច្បាប់

-ត្រូវលើកទឹកចិត្តមន្ត្រីក្រោមឱវាទដែលបានផ្តល់ព័ត៌មានអំពីការប្រព្រឹត្តអំពើខុសឆ្គងរបស់មន្ត្រីក្នុងការអនុវត្តគម្រោង

-មន្ត្រីអនុវត្តគម្រោងទាំងអស់ត្រូវពាក់ឯកសណ្ឋាន ផ្លាកសញ្ញាសម្គាល់ខ្លួនដែលមានឈ្មោះ មុខតំណែង និងអង្គភាពគ្រប់ពេលចុះបំពេញភារកិច្ច និងរាល់ពេលប្រាស្រ័យទាក់ទងជាមួយសាធារណជន។ ត្រូវបិទបញ្ជីឈ្មោះមន្ត្រីអនុវត្តគម្រោងនៅមុខការិយាល័យធ្វើការ ដែលអាចឱ្យសាធារណជនមើលឃើញបាន និងត្រូវធ្វើបច្ចុប្បន្នភាពរាល់ពេលដែលមានការផ្លាស់ប្តូរ។

៥-ត្រូវគោរពឋានានុក្រមក្នុងការអនុវត្តការងារគម្រោង៖

-ប្រសិនបើមានបញ្ជាឱ្យធ្វើការងារអ្វីមួយ ហើយអ្នកអនុវត្តផ្ទាល់ពិនិត្យដោយជឿជាក់ថាមិនត្រឹមត្រូវ អាចខុសច្បាប់ អសីលធម៌ រំលោភនឹងក្រមសីលធម៌ និងមិនស្របតាមគោលការណ៍អភិបាលកិច្ចល្អ ត្រូវរាយការណ៍ជាបន្ទាន់ទៅថ្នាក់លើ តាមគ្រប់រូបភាពដែលអាចធ្វើបាន ឬត្រូវរាយការណ៍ជូនថ្នាក់លើបន្ទាប់ ដើម្បីសុំគោលការណ៍ដឹកនាំ

-ក្នុងករណីមានទំនាស់ពីផលប្រយោជន៍ក្នុងការចុះបញ្ជីដីធ្លី ត្រូវរាយការណ៍សុំគោលការណ៍ដឹកនាំពីថ្នាក់លើ ដោយបង្ហាញពីលទ្ធភាពនៃការដោះស្រាយដោយសន្តិវិធី ដែលភាគីទំនាស់ទាំងសងខាងអាចទទួលយកបាន

-មិនត្រូវប្រកាន់គ្រួសារនិយម បក្សពួកនិយម ដោយចៀសវាងអូសទាញសាច់ញាតិ បក្សពួកដែលអសមត្ថភាពមកទទួលតំណែងក្នុងយន្តការណាមួយរបស់គម្រោងឡើយ

-មិនត្រូវប្រើប្រាស់មុខតំណែង សិទ្ធិទទួលខុសត្រូវក្នុងការងារណាមួយ ឬព័ត៌មានបច្ចេកទេសរបស់គម្រោងទៅប្រើប្រាស់សម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួន ឬផលប្រយោជន៍ផ្សេងទៀតឡើយ

-មិនត្រូវចូលរួមជាមួយអំពើកេងបន្លំ ពុករលួយ ស៊ីសំណូក ឬសកម្មភាពមិនប្រក្រតីលើផ្នែកហិរញ្ញវត្ថុផ្សេងទៀត។

៦-ត្រូវប្រើប្រាស់មូលនិធិរបស់គម្រោងឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អតាមគោលការណ៍កំណត់៖

-សម្ភារៈ បរិក្ខារ មធ្យោបាយ និងធនធានហិរញ្ញវត្ថុរបស់គម្រោង ត្រូវបានប្រើប្រាស់សម្រាប់តែគោលដៅអនុវត្តគម្រោងប៉ុណ្ណោះ

-មិនត្រូវរើអង្គាស ឬទទួលថវិកាក្រៅផ្លូវការ អំណោយ ប្រាក់សគុណដែលកើតចេញអំពីការងាររបស់ខ្លួន និងមិនត្រូវគំរាមកំហែង ឬបង្អាប់សាធារណជនឱ្យបង់សេវាក្រៅផ្លូវការឡើយ

-មិនត្រូវកាត់ប្រាក់ឧបត្ថម្ភប្រចាំខែរបស់មន្ត្រីអនុវត្តគម្រោងដែលត្រូវទទួលបានឡើយ ហើយមន្ត្រីអនុវត្តគម្រោងមិនត្រូវសូកប៉ាន់ថ្នាក់លើរបស់ខ្លួន ដើម្បីគោលបំណងណាមួយឡើយ។

៧-មន្ត្រីអនុវត្តគម្រោងត្រូវប្រកាន់ខ្ជាប់នូវសេចក្ដីថ្លៃថ្នូរនៅពេលអនុវត្តការងារ ដោយត្រូវផ្ដល់ព័ត៌មានពេញលេញ អំពីដំណើរការនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធគ្រប់ដំណាក់កាល និងតម្រូវការឯកសារចាំបាច់ដែលត្រូវមាន ដូចជាតម្លៃសេវាផ្លូវការដែលម្ចាស់ដីត្រូវបង់ ហើយត្រូវឆ្លើយសំណួរទាំងឡាយឱ្យបានទាន់ពេលវេលា ពិតប្រាកដ និងពេញលេញ។ មិនត្រូវរារាំង ឬបន្ទុចបង្អាក់សាធារណជនដែលមានសិទ្ធិតាមផ្លូវច្បាប់ទទួលបានព័ត៌មានឡើយ។

៨-ក្នុងរយៈពេលបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ប្រសិនបើមានបណ្ដឹងតវ៉ា ដោយបញ្ជាក់ពីឈ្មោះមុខតំណែងមានការឃុបឃិត បង្ខំទារសគុណ ប្រជាពលរដ្ឋម្ចាស់ដីមានសិទ្ធិប្ដឹងតវ៉ា ដោយបញ្ជាក់ពីឈ្មោះមុខតំណែងរបស់មន្ត្រីនោះ។ រាល់បណ្ដឹងតវ៉ាត្រូវបានចុះក្នុងបញ្ជី និងធ្វើការស៊ើបអង្កេតដោយម៉ត់ចត់តាមប្រព័ន្ធទទួល និងដោះស្រាយបណ្ដឹង។

**ប្រការ២**

ក្រមសីលធមិនេះអនុវត្តចំពោះតែមន្ត្រីរាជការក្នុងក្របខ័ណ្ឌក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដែលកំពុងអនុវត្តគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី ទាំងនៅថ្នាក់កណ្ដាល និងនៅថ្នាក់ខេត្ត-ក្រុង។

**ប្រការ៣**

*វាយឡើងវិញ*

មន្ត្រីអនុវត្តគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីទាំងនៅថ្នាក់កណ្តាល និងថ្នាក់ខេត្ត ក្រុងដែលអនុវត្តផ្ទុយពីខ្លឹមសារក្នុងប្រការ១នៃសេចក្តីសម្រេចនេះ នឹងឈានដល់ការអនុវត្តតាមមាត្រាទាំងឡាយ ដូចមានចែងក្នុងជំពូកទី៥ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤**

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន គ្រប់ប្រធាននាយកដ្ឋានពាក់ព័ន្ធ នាយកគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី នាយកប្រតិបត្តិគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីខេត្ត-ក្រុង និងមន្ត្រីអនុវត្តគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីទាំងអស់មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦

**ទេសរដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**អ៊ឹម ឈុនលឹម**

កន្លែងទទួល

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-គ្រប់សាលាខេត្ត-ក្រុងអនុវត្តគម្រោង
 រៀបចំដែនដី និងរដ្ឋបាលដីធ្លី
-ដូចប្រការ៤
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ៤២សសរ

## សេចក្តីសម្រេច
## ស្តីពីការបង្កើតប្រព័ន្ធទទួល និងដោះស្រាយបណ្តឹង
## សម្រាប់គម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ/បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

### សម្រេច

**ប្រការ១**

ត្រូវបានបង្កើតប្រព័ន្ធ និងដោះស្រាយបណ្តឹងសម្រាប់គម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី ដោយកំណត់ពីរបៀបប្តឹង របៀបទទួលបណ្តឹង និងនីតិវិធីដោះស្រាយបណ្តឹងពាក់ព័ន្ធនឹងការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ការងារលទ្ធកម្ម និងការងារហិរញ្ញវត្ថុ។

**ប្រការ២**

គម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីត្រូវបង្កើត៖

-ប្រអប់សំបុត្រសម្រាប់ទទួលពាក្យប្តឹងដាក់នៅគ្រប់ការិយាល័យអនុវត្តគម្រោងខេត្ត-ក្រុង និងនៅទីស្តីការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ខ្សែទូរស័ព្ទពិសេស[១] ដាក់នៅទីចាត់ការកណ្តាលនៃគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីដោយមានអ្នកប្រចាំការចំនួន០២រូប នៅរៀងរាល់ម៉ោងធ្វើការ ដើម្បីទទួល កត់ត្រា ថតសំឡេងបណ្តឹង អនុសាសន៍ផ្សេងៗរបស់អតិថិជនទុកជាមូលដ្ឋានសម្រាប់ការបកស្រាយបំភ្លឺ។

**ប្រការ៣**

អំពីបណ្តឹង និងការដាក់ពាក្យប្តឹង៖

សាធារណជនអាចប្តឹងផ្ទាល់មាត់ តាមទូរស័ព្ទ ឬដាក់ពាក្យប្តឹងជាលាយលក្ខណ៍អក្សរក្នុងការតវ៉ា ឬការផ្តល់អនុសាសន៍ផ្សេងៗទៅគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី ឬទៅក្រសួងផ្ទាល់។ ករណីមានសំណូមពរ អ្នកទទួលពាក្យបណ្តឹងត្រូវតែរក្សានូវអនាមិកភាពរបស់អ្នកប្តឹង ប៉ុន្តែអ្នកប្តឹងត្រូវផ្តល់ព័ត៌មានដោយមានភស្តុតាងគ្រប់គ្រាន់ ដើម្បីជាមូលដ្ឋានក្នុងការពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយ។

**ប្រការ៤**

អំពីយន្តការទទួល និងដោះស្រាយបណ្តឹង

យន្តការទទួល និងដោះស្រាយបណ្តឹងមាន០២ថ្នាក់៖

១-គណៈកម្មការទទួល និងដោះស្រាយបណ្តឹងថ្នាក់កណ្តាលដឹកនាំដោយនាយកគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី។ សមាជិកគណៈកម្មការនេះមួយចំនួនជ្រើសរើសពីក្នុងជួរថ្នាក់ដឹកនាំគម្រោង និងមួយចំនួនទៀតពីក្នុងជួរមន្ត្រីពាក់ព័ន្ធនឹងការងារចុះបញ្ជីដីធ្លី ការងារលទ្ធកម្ម ការងារហិរញ្ញវត្ថុ ការងារសេវាកម្ម ការងារបុគ្គលិក។ ចំពោះសវនករផ្ទៃក្នុងរបស់គម្រោងមានតួនាទីជាសមាជិកសង្កេតការណ៍។ ក្នុងករណីដែលភាគីបណ្តឹងមិនពេញចិត្តនឹងលទ្ធផលដែលគណៈកម្មការបានសម្រេច ភាគីបណ្តឹងអាចប្តឹងទៅថ្នាក់ដឹកនាំក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

២-អនុគណៈកម្មការទទួល និងដោះស្រាយបណ្តឹងថ្នាក់ខេត្ត-ក្រុងអនុវត្តគម្រោងដឹកនាំដោយនាយកចាត់ការគម្រោងខេត្ត-ក្រុង អនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង

(១) ខ្សែទូរស័ព្ទពិសេសគឺជាខ្សែទូរស័ព្ទដែលអ្នកហៅចូលមិនអស់ប្រាក់។

ស៊ុរិយោដីខេត្ត-ក្រុងទទួលបន្ទុកការងារពិនិត្យគុណភាពបច្ចេកទេសជាអនុប្រធាន និងប្រធានវាល ជាសមាជិក។ ក្នុងករណីដែលភាគីបណ្តឹងមិនពេញចិត្តនឹងលទ្ធផលដែលអនុគណៈកម្មការបានសម្រេច ភាគីបណ្តឹងអាចប្តឹងទៅប្រធានគណៈកម្មការរដ្ឋបាល។

**ប្រការ៥**

អំពីនីតិវិធីនៃការដោះស្រាយបណ្តឹងសម្រាប់គណៈកម្មការថ្នាក់កណ្តាល៖

១-គណៈកម្មការទទួល និងដោះស្រាយបណ្តឹងថ្នាក់កណ្តាលត្រូវធ្វើការពិចារណារាល់បណ្តឹង ក្នុងរយៈពេល០៥ថ្ងៃនៃថ្ងៃធ្វើការ និងត្រូវធ្វើការសន្និដ្ឋានបណ្តឹងនីមួយៗ ក្នុងរយៈពេល១៤ថ្ងៃនៃ ថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបានទទួលបណ្តឹង។ ក្នុងករណីបណ្តឹងតម្រូវឱ្យដោះស្រាយបន្ទាន់ គណៈកម្មការត្រូវរៀបចំកិច្ចប្រជុំពិសេសដើម្បីពិចារណា។ ប្រសិនបើចាំបាច់ត្រូវស៊ើបអង្កេត ឬត្រួតពិនិត្យបន្ថែម ត្រូវសុំគោលការណ៍ដឹកនាំពីក្រសួង។ ក្នុងករណីការស៊ើបអង្កេតមានភាពស្មុគស្មាញ និងត្រូវប្រើពេលវេលាយូរ គណៈកម្មការត្រូវជូនដំណឹងទៅដើមបណ្តឹងពីលទ្ធផលបណ្តោះអាសន្ននៃការស៊ើបអង្កេតក្នុងចន្លោះ១៤ថ្ងៃនៃការពិចារណា និងសន្និដ្ឋាន។ គណៈកម្មការត្រូវផ្តល់ឱកាសគ្រប់គ្រាន់ និងសច្ចធម៌ដល់បុគ្គល ក្រុមហ៊ុន ឬអង្គភាពដែលជាចុងបណ្តឹង ដើម្បីបង្ហាញភស្តុតាងគ្រប់គ្រាន់ឆ្លើយតបនឹងបណ្តឹងនោះ។

២-ចំពោះបណ្តឹងដែលពាក់ព័ន្ធនឹងការងារលទ្ធកម្មដែលបានធ្វើឡើងក្នុងអំឡុងពេលវាយតម្លៃការដេញថ្លៃ ការស៊ើបអង្កេត និងការវិនិច្ឆ័យត្រូវធ្វើឡើងបន្ទាប់ពីការវាយតម្លៃត្រូវបានបញ្ចប់មុននឹងផ្ញើរបាយការណ៍វាយតម្លៃសុំការមិនជំទាស់ពីសមាគមអភិវឌ្ឍន៍អន្តរជាតិ៖

-ត្រូវរក្សាការសម្ងាត់ក្នុងពេលស៊ើបអង្កេត ហើយលទ្ធផលនៃការស៊ើបអង្កេតមិនត្រូវផ្សព្វផ្សាយក្រៅពីសមាជិកគណៈកម្មការឡើយ។

-ក្រោយពីបានធ្វើការសន្និដ្ឋានលើបណ្តឹងហើយ គណៈកម្មការត្រូវធ្វើរបាយការណ៍ជូនក្រសួងសុំការសម្រេច និងកំណត់វិធានការកែតម្រូវនានា។ ការសម្រេច និងវិធានការកែតម្រូវត្រូវបានផ្សព្វផ្សាយជាសាធារណៈ។

-គណៈកម្មការត្រូវទទួលយកមកពិចារណាឡើងវិញនូវរាល់ការប្តឹងជំទាស់ ប្រសិនបើដើមបណ្តឹង ឬចុងបណ្តឹងមិនទាន់ពេញចិត្តនឹងសេចក្តីសម្រេច ឬវិធានការកែតម្រូវណាមួយ។ ដើម

បណ្តឹង ឬចុងបណ្តឹងអាចប្តឹងជំទាស់ទៅអាជ្ញាធរថ្នាក់លើបន្តទៀត ក្នុងករណីមិនអាចទទួលយកបាននូវលទ្ធផលនៃការពិចារណាឡើងវិញនេះ។

-សៀវភៅទទួលបណ្តឹង របាយការណ៍នៃការអង្កេត សេចក្តីសម្រេច និងវិធានការកែតម្រូវនានា ឯកសារក្នុងកុំព្យូទ័រ ឯកសារកំណត់ត្រា ឯកសារជំនួយស្មារតី និងឯកសារផ្សេងៗទៀតពាក់ព័ន្ធទៅនឹងបណ្តឹង ត្រូវរក្សាទុកក្នុងរយៈពេលយ៉ាងតិច២ឆ្នាំ។

-ប្រសិនបើនៅក្នុងករណីដែលបណ្តឹងតវ៉ាអាចមានភស្តុតាងពាក់ព័ន្ធទៅនឹងការរំលោភទៅលើប្រការណាមួយនៃកិច្ចព្រមព្រៀងរបស់សមាគមអភិវឌ្ឍន៍អន្តរជាតិ និងជំនួយឥតសំណងត្រូវជូនដំណឹងជាបន្ទាន់ទៅប្រធានក្រុមការងាររបស់ធនាគារពិភពលោក និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត ដោយភ្ជាប់ជាមួយនូវលទ្ធផលនៃការស៊ើបអង្កេត។

**ប្រការ៦**

អនុគណៈកម្មការទទួល និងដោះស្រាយបណ្តឹងខេត្ត-ក្រុងមានភារកិច្ចបូកសរុបបណ្តឹងប្រចាំថ្ងៃរបស់អតិថិជន ហើយដោះស្រាយបំភ្លឺបណ្តឹងណាដែលអាចដោះស្រាយ ឬសម្របសម្រួលបាន។ ចំពោះបណ្តឹងដែលមិនអាចដោះស្រាយ ឬសម្របសម្រួលបានត្រូវបញ្ជូនទៅគណៈកម្មការទទួល និងដោះស្រាយបណ្តឹងថ្នាក់កណ្តាលដើម្បីពិនិត្យ និងដោះស្រាយតាមនីតិវិធី។

**ប្រការ៧**

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន គ្រប់ប្រធាននាយកដ្ឋានពាក់ព័ន្ធនាយកគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី នាយកប្រតិបត្តិគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីខេត្ត-ក្រុង និងមន្ត្រីអនុវត្តគម្រោងទាំងអស់មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦

**ទេសរដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**អ៊ឹម ឈុនលឹម**

កន្លែងទទួល

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-គ្រប់សាលាខេត្ត-ក្រុងអនុវត្តគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី

-ដូចប្រការ៧

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ១២៩អនក្រ/បក

## អនុក្រឹត្យ

## ស្ដីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ និងច្បាប់ទាំងឡាយដែលធ្វើវិសោធនកម្មច្បាប់នេះ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ ២០០៦ ស្ដីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ០៤អនក្រ/បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៨អនក្រ/បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៦

## សម្រេច

## ជំពូកទី១ បទប្បញ្ញត្តិទូទៅ

### មាត្រា១

អនុក្រឹត្យនេះមានគោលដៅកំណត់គោលការណ៍ យន្តការ និងនីតិវិធីសម្រាប់គ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិរបស់រដ្ឋទាក់ទងនឹង៖

-ការរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ

-ការជួលទ្រព្យសម្បត្តិរបស់រដ្ឋ

-ការលក់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

-ការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។

### មាត្រា២

គោលការណ៍ទូទៅសម្រាប់អនុវត្តក្នុងការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិរបស់រដ្ឋ មានដូចខាងក្រោម៖

១-រាជរដ្ឋាភិបាលគឺជាអ្នកគ្រប់គ្រងរាល់ទ្រព្យសម្បត្តិរបស់រដ្ឋ ដែលឋិតនៅក្រោមការកាន់កាប់ ការប្រើប្រាស់ ការថែរក្សា ការធ្វើអាជីវកម្មរបស់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង ស្រុក-ខណ្ឌ ឃុំសង្កាត់ និងរបស់នីតិបុគ្គលសាធារណៈ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគឺជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ។ អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋជាសេនាធិការឱ្យរាជរដ្ឋាភិបាលលើការលក់ ការដូរ និងការជួលនូវទ្រព្យសម្បត្តិរបស់រដ្ឋ។

អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋត្រូវរាយការណ៍អំពីលទ្ធផលនៃការជួល ការលក់ និងការដូរចលនទ្រព្យ និងអចលនទ្រព្យដែលជាទ្រព្យសម្បត្តិរបស់រដ្ឋជូនរាជរដ្ឋាភិបាល។

២-ក្រសួង ស្ថាប័ន ខេត្ត-ក្រុង ស្រុក-ខណ្ឌ ឃុំ-សង្កាត់ និងនីតិបុគ្គលសាធារណៈដទៃទៀត ដែលកំពុងកាន់កាប់ ប្រើប្រាស់ ថែរក្សា និងធ្វើអាជីវកម្មទ្រព្យសម្បត្តិរបស់រដ្ឋ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋនៅក្នុងន័យអនុក្រឹត្យនេះ។ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋមានសមត្ថកិច្ចត្រឹមតែប្រើប្រាស់ ថែរក្សា និងស្នើសុំលក់ ដូរ ឬជួល។

៣-ទ្រព្យសម្បត្តិរបស់រដ្ឋទាំងអស់ដែលរួមមានទាំងទ្រព្យសម្បត្តិ ដែលកំពុងឋិតនៅក្រោមការកាន់កាប់របស់នីតិបុគ្គលសាធារណៈត្រូវចុះបញ្ជីនៅក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋតាមបែបបទ និងនីតិវិធីដែលត្រូវកំណត់ក្នុងប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៤-ទ្រព្យសម្បត្តិរបស់រដ្ឋទាំងអស់ដែលរួមមានទាំងទ្រព្យសម្បត្តិ ដែលកំពុងឋិតនៅក្រោមការកាន់កាប់របស់នីតិបុគ្គលសាធារណៈអាចត្រូវបានលក់ ដូរ ជួល ឬផ្តល់ឱ្យជាសម្បទានផ្សេងទៀតបាន លុះត្រាតែទ្រព្យសម្បត្តិទាំងនោះត្រូវបានចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ។ ល័ក្ខខ័ណ្ឌ និងនីតិវិធីនៃការលក់ ការដូរ និងការជួលទ្រព្យសម្បត្តិរបស់រដ្ឋត្រូវអនុវត្តតាមបទប្បញ្ញត្តិដោយឡែក។

**មាត្រា៣**

ទ្រព្យសម្បត្តិរបស់រដ្ឋរួមមានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ ទ្រព្យសម្បត្តិទាំងនេះអាចជាចលនទ្រព្យ និងអចលនទ្រព្យ។ ទ្រព្យសម្បត្តិរបស់រដ្ឋ សំដៅលើទ្រព្យសម្បត្តិទាំងឡាយដែលកំពុងឋិតនៅក្រោមការកាន់កាប់ ការប្រើប្រាស់ ការថែរក្សា ការធ្វើអាជីវកម្មរបស់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង ស្រុក-ខណ្ឌ ឃុំ-សង្កាត់ ព្រមទាំងទ្រព្យសម្បត្តិទាំងឡាយដែលរដ្ឋប្រគល់ទៅឱ្យនីតិបុគ្គលសាធារណៈដទៃទៀតកាន់កាប់ ប្រើប្រាស់ ថែរក្សា និងធ្វើអាជីវកម្ម។

ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋគឺមានទ្រព្យសម្បត្តិទាំងអស់របស់រដ្ឋ ក្រៅពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដូចបានកំណត់ក្នុងមាត្រា៥៨នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ព្រមទាំងមាត្រា១២ និងមាត្រា១៥នៃច្បាប់ភូមិបាលដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១។

**មាត្រា៤**

ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋទាំងអស់រួមទាំងទ្រព្យសម្បត្តិ ដែលកំពុងឋិតនៅក្រោមការកាន់កាប់របស់រដ្ឋ របស់នីតិបុគ្គលសាធារណៈដទៃទៀត អាចជាកម្មវត្ថុនៃការជួល ការលក់ និងការដូរបាន ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ក៏ដូចជាទ្រព្យសម្បត្តិសាធារណៈរបស់នីតិបុគ្គលសាធារណៈដទៃទៀតមិនអាចជាកម្មវត្ថុនៃការលក់ ការដូរ ឬការផ្ទេរកម្មសិទ្ធិណាមួយបានឡើយ។ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋទាំងនេះអាចជាកម្មវត្ថុនៃការជួលបានតែក្នុងល័ក្ខខ័ណ្ឌ និងនីតិវិធីដែលមានបញ្ញត្តនៅក្នុងអនុក្រឹត្យនេះ។

## ជំពូកទី២ ការរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ

### មាត្រា៥

ទ្រព្យសម្បត្តិរបស់រដ្ឋដែលត្រូវចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ រួមមានចលនទ្រព្យ និងអចលនទ្រព្យទាំងអស់ដែលឋិតនៅក្រោមអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ដូចជា ក្រសួង ស្ថាប័ន ខេត្ត-ក្រុង ស្រុក-ខណ្ឌ ឃុំ-សង្កាត់ និងនីតិបុគ្គលសាធារណៈដទៃទៀត។

### មាត្រា៦

ការធ្វើបញ្ជីសារពើភ័ណ្ឌចែកចេញជាបួនថ្នាក់ រួមមាន៖

១-ថ្នាក់កណ្តាល ឬថ្នាក់ក្រសួង ស្ថាប័ន

គណៈកម្មការបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋដែលកាន់កាប់ដោយក្រសួង ស្ថាប័ន ត្រូវបង្កើតឡើងដើម្បីធ្វើបញ្ជីសារពើភ័ណ្ឌ រួមមានសមាជិកដូចខាងក្រោម៖

| | |
|---|---|
| -ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន | ជាប្រធាន |
| -ប្រធាននាយកដ្ឋានជំនាញពាក់ព័ន្ធ | ជាសមាជិក។ |

ប្រធាន និងសមាជិកនៃគណៈកម្មការនេះ ត្រូវចុះហត្ថលេខាទទួលខុសត្រូវលើបញ្ជីសារពើភ័ណ្ឌដែលបានរៀបចំរួច។

២-ថ្នាក់មន្ទីរជំនាញតាមខេត្ត-ក្រុង

គណៈកម្មការបញ្ជីសារពើភ័ណ្ឌត្រូវបង្កើតឡើង ដើម្បីធ្វើបញ្ជីសារពើភ័ណ្ឌ រួមមានសមាជិកដូចខាងក្រោម៖

-ប្រធានមន្ទីរជំនាញសាមីដែលទទួលខុសត្រូវអង្គភាពប្រើប្រាស់ ជាប្រធាន

-ប្រធានការិយាល័យប្រើប្រាស់នៃមន្ទីរជំនាញ ជាសមាជិក

-ប្រធានការិយាល័យប្រើប្រាស់តាមស្រុក-ខណ្ឌ ជាសមាជិក។

ប្រធាន និងសមាជិកនៃគណៈកម្មការនេះត្រូវចុះហត្ថលេខាទទួលខុសត្រូវលើបញ្ជីសារពើភ័ណ្ឌ និងត្រូវមានហត្ថលេខាពីប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត-ក្រុង ព្រមទាំងមានការឯកភាពពីអភិបាលខេត្ត-ក្រុង។

៣-ថ្នាក់ខេត្ត-ក្រុង

គណៈកម្មការបញ្ជីសារពើភ័ណ្ឌត្រូវបង្កើតឡើង រួមមានសមាជិកដូចខាងក្រោម៖

ក-សាលាខេត្ត-ក្រុង

-នាយខុទ្ទកាល័យ ឬប្រធានក្រុមហិរញ្ញវត្ថុ ជាប្រធាន

-គ្រប់ប្រធានការិយាល័យផ្ទៃក្នុងរបស់សាលាខេត្ត-ក្រុង ជាសមាជិក

ខ-សាលាស្រុក-ខណ្ឌ

-អភិបាលស្រុក-ខណ្ឌ ជាប្រធាន

-ប្រធានការិយាល័យផ្ទៃក្នុង ជាសមាជិក

-មេឃុំ-ចៅសង្កាត់ ជាសមាជិក។

ប្រធាន និងសមាជិកនៃគណៈកម្មការនេះត្រូវចុះហត្ថលេខាទទួលខុសត្រូវលើបញ្ជីសារពើភ័ណ្ឌ និងត្រូវមានហត្ថលេខាពីប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត-ក្រុង ព្រមទាំងមានការឯកភាពពីអភិបាលខេត្ត-ក្រុង

៤-ថ្នាក់និតិបុគ្គលសាធារណៈដទៃទៀត

គណៈកម្មការបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវបង្កើតឡើងដើម្បីធ្វើបញ្ជីសារពើភ័ណ្ឌ រួមមានសមាជិកដូចខាងក្រោម៖

-ប្រធានអង្គភាព ជាប្រធាន

-ប្រធានផ្នែកជំនាញពាក់ព័ន្ធ ជាសមាជិក

ប្រធាន និងសមាជិកនៃគណៈកម្មការនេះត្រូវចុះហត្ថលេខាទទួលខុសត្រូវលើបញ្ជីសារពើភ័ណ្ឌដែលបានរៀបចំរួច។

វាយឡើងវិញ

មាត្រា៧

អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋជាអ្នកជំរុញ និងណែនាំដល់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋឱ្យរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ តាមបែបបទ និងនីតិវិធីដែលមានកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌប្រចាំឆ្នាំនីមួយៗឱ្យបានត្រឹមត្រូវរួចរាល់ និងផ្ញើមកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ យ៉ាងយូរនៅចុងត្រីមាសទី១នៃឆ្នាំបន្ទាប់។

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះមុខរាជរដ្ឋាភិបាល ក្នុងករណីមិនអាចសម្រេចបាននូវការធ្វើបញ្ជីសារពើភ័ណ្ឌតាមពេលវេលាកំណត់ និងពុំបានចុះបញ្ជីអស់គ្រប់ចំនួននូវទ្រព្យសម្បត្តិរបស់រដ្ឋចូលក្នុងបញ្ជីសារពើភ័ណ្ឌ។

រាល់បញ្ជីសារពើភ័ណ្ឌដែលបានរៀបចំរួចរាល់ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋត្រូវផ្តល់ចំនួនពីរច្បាប់ ជូនអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ដើម្បីតម្កល់ទុក និងតាមដាន។

អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋត្រូវរាយការណ៍ជារៀងរាល់ឆ្នាំនូវលទ្ធផលស្តីពីការរៀបចំបញ្ជីសារពើភ័ណ្ឌ ជូនប្រមុខរាជរដ្ឋាភិបាលតាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី។

## ជំពូកទី៣ ការជួលទ្រព្យសម្បត្តិរបស់រដ្ឋ

## ផ្នែកទី១ ការជួលទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

មាត្រា៨

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋត្រូវរៀបចំឱ្យបានត្រឹមត្រូវនូវរាល់ឯកសារពាក់ព័ន្ធនឹងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាកម្មវត្ថុនៃការជួល រួចលើកសំណើសុំជួលទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនោះ មកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋដើម្បីពិនិត្យ និងលើកយោបល់សុំការសម្រេចពីរាជរដ្ឋាភិបាល។

មាត្រា៩

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋត្រូវបង្កើតគណៈកម្មការវាយតម្លៃមួយលើទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដែលជាកម្មវត្ថុនៃការជួល ដោយផ្អែកលើមូលដ្ឋានបច្ចេកទេស និងតម្លៃទី

ផ្សារ ហើយលើកសំណើនៃការវាយតម្លៃរបស់ខ្លួន ជូនអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ។ គណៈកម្មការវាយតម្លៃនេះត្រូវមានតំណាងរបស់អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ តំណាងរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងស្ថាប័នពាក់ព័ន្ធ ដើម្បីសិក្សាវាយតម្លៃទ្រព្យសម្បត្តិរបស់រដ្ឋដែលជាកម្មវត្ថុនៃការជួលនោះ។

**មាត្រា១០**

ការជួលទ្រព្យសម្បត្តិឯកជនរបស់រដ្ឋត្រូវរៀបចំធ្វើឡើង ក្រោមរូបភាពនៃការដេញថ្លៃ ឬចរចាពិគ្រោះថ្លៃ។

ផ្អែកលើសំណើរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងលទ្ធផលនៃការវាយតម្លៃលើទ្រព្យសម្បត្តិដែលជាការជួល អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋត្រូវពិនិត្យ ផ្តល់យោបល់ និងសម្រេចជាគោលការណ៍ឱ្យដេញថ្លៃ ឬចរចាពិគ្រោះថ្លៃ។ ក្នុងករណីចាំបាច់ ត្រូវមានការសម្រេចជាមុនពីប្រមុខរាជរដ្ឋាភិបាល។

នីតិវិធីលំអិតនៃការដេញថ្លៃ និងការចរចា ពិគ្រោះថ្លៃ ត្រូវកំណត់ដោយប្រកាសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា១១**

ការជួលទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាចលនទ្រព្យជាសមត្ថកិច្ចរបស់អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ លើកលែងតែចលនទ្រព្យដែលមានតម្លៃខ្ពស់។

ការជួលទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាអចលនទ្រព្យជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល។

**មាត្រា១២**

ការដេញថ្លៃអាចប្រព្រឹត្តទៅបាន បើមានការចូលរួមពីរូបវន្តបុគ្គល ឬនីតិបុគ្គល កម្រិតជាតិ ឬអន្តរជាតិចាប់ពី២ឡើងទៅ និងអាស្រ័យលើវិសាលភាពនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលត្រូវជួល។

ការដេញថ្លៃអាចប្រព្រឹត្តទៅតាមរូបភាព៖

១-ប្រកួតប្រជែងដោយចំហ ជាលក្ខណៈជាតិ ឬអន្តរជាតិ

២-ប្រកួតប្រជែងដោយផ្ទាល់មាត់ជាលក្ខណៈជាតិ ឬអន្តរជាតិ។

**មាត្រា១៣**

ការចរចាពិគ្រោះថ្លៃអាចប្រព្រឹត្តទៅបានក្នុងករណីណាមួយដូចខាងក្រោម៖

១-ការដេញថ្លៃមិនទទួលបានលទ្ធផល

២-លក្ខណៈពិសេសនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដែលតម្រូវឱ្យអ្នកជួលត្រូវបំពេញបន្ថែមនូវល័ក្ខខ័ណ្ឌចាំបាច់ផ្សេងៗទៀត។

៣-មានរូបវន្តបុគ្គល ឬនីតិបុគ្គលស្នើសុំជួលតែមួយ។

**មាត្រា១៤**

ផ្អែកតាមលទ្ធផលនៃការដេញថ្លៃ ឬការចរចាពិគ្រោះថ្លៃដែលត្រូវបានទទួលស្គាល់ជាផ្លូវការជាស្ថាពរ ដោយអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ឬរាជរដ្ឋាភិបាល អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ មានរយៈពេលយ៉ាងយូរ៣ (បី) ខែ ដើម្បីពិភាក្សាជាមួយភាគីដែលត្រូវចុះកិច្ចសន្យាជួល ដើម្បីរៀបចំនូវសេចក្តីព្រាងកិច្ចសន្យានោះ។ រយៈពេលនេះអាចបន្តសាជាថ្មីបានមួយលើកទៀតដែលមានរយៈពេលយ៉ាងយូរ៣ (បី) ខែ ប្រសិនបើពិនិត្យឃើញមានមូលហេតុសមស្រប និងចាំបាច់។ ក្នុងករណីអ្នកដេញថ្លៃបាន មិនព្រមចរចា ពិភាក្សា រៀបចំកិច្ចសន្យាជួល តាមរយៈពេលកំណត់នោះ គោលការណ៍ ឬលទ្ធផលនៃការដេញថ្លៃនឹងត្រូវទុកជាមោឃៈ ហើយប្រាក់កក់នឹងត្រូវរឹបអូសបង់ចូលថវិការដ្ឋ។

ភាគីនៃកិច្ចសន្យាមានសិទ្ធិចុះហត្ថលេខា លុះត្រាតែល័ក្ខខ័ណ្ឌទាំងអស់នៃសេចក្តីព្រាងកិច្ចសន្យាត្រូវបានព្រមព្រៀងរវាងភាគីនៃកិច្ចសន្យា ហើយត្រូវបានពិនិត្យ កែសម្រួល និងយល់ព្រមដោយអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋជាមុនសិន ក្នុងរយៈពេល៤៥ (សែសិបប្រាំ) ថ្ងៃយ៉ាងយូរ ក្រោយពីទទួលបានពីអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ។

កិច្ចសន្យាត្រូវចែងអំពីល័ក្ខខ័ណ្ឌចាំបាច់ដែលមានជាអាទិ៍៖

១-ការកំណត់ថ្លៃឈ្នួល និងការបង់ថ្លៃឈ្នួល ដោយគិតតាមខែ ត្រីមាស ឬឆ្នាំ តាមការព្រមព្រៀងរវាងភាគីនៃកិច្ចសន្យា។

២-ក្នុងករណីបង់ថ្លៃឈ្នួលយឺតយ៉ាវ អ្នកទទួលជួលត្រូវទទួលការពិន័យ២ (ពីរ) ភាគរយក្នុងមួយខែលើថ្លៃឈ្នួល ដែលត្រូវបង់តាមខែ ត្រីមាស ឬឆ្នាំ ចាប់ពីរយៈពេល៦០ (ហុកសិប) ថ្ងៃក្រោយការកំណត់តទៅ។ ប្រាក់ពិន័យនេះត្រូវគណនាតាមរូបមន្តការប្រាក់សមាស។

៣-ក្នុងករណីខកខានបង់ថ្លៃឈ្នួលក្នុងរយៈពេលសរុប៦ (ប្រាំមួយ) ខែ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋត្រូវលុបកិច្ចសន្យា និងត្រូវអនុវត្តតាមផ្លូវច្បាប់ជាធរមាន បន្ទាប់ពីមានការយល់ព្រមពីអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ។ ក្នុងករណីនេះ ប្រសិនបបើអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋមិនអាចអនុវត្តបានទេ អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋនឹងចាត់វិធានការ ក្នុងសមត្ថកិច្ចរបស់ខ្លួន ដើម្បីលុបកិច្ចសន្យា និងចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន។

កិច្ចសន្យាជួលទ្រព្យសម្បត្តិឯកជនរបស់រដ្ឋទាំងឡាយណា ដែលមិនគោរពតាមនីតិវិធី និងមិនចែងនូវល័ក្ខខ័ណ្ឌចាំបាច់ខាងលើនេះត្រូវចាត់ទុកជាមោឃៈ។

## ផ្នែកទី២ ការជួលទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ

### មាត្រា១៥

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវរៀបចំឱ្យបានត្រឹមត្រូវនូវរាល់ឯកសារពាក់ព័ន្ធនឹងទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋដែលជាកម្មវត្ថុនៃការជួល រួចលើកសំណើសុំជួលទ្រព្យសម្បត្តិសាធារណៈនោះមកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ដើម្បីពិនិត្យ និងលើកយោបល់សុំការសម្រេចពីរាជរដ្ឋាភិបាល។

### មាត្រា១៦

ការជួលទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋត្រូវគោរពទៅតាមល័ក្ខខ័ណ្ឌដូចខាងក្រោម៖

១-ការជួលទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមិនត្រូវធ្វើឱ្យមានការកែប្រែទិសដៅនៃការប្រើប្រាស់ ឬធ្វើឱ្យមានការខូចខាតដល់ទ្រព្យសម្បត្តិទាំងនោះឡើយ។

២-ការជួលទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមិនត្រូវមានការប៉ះពាល់ ឬធ្វើឱ្យផ្លាស់ប្តូរដល់មុខងារបម្រើសេវាសាធារណៈរបស់ទ្រព្យសម្បត្តិទាំងនោះឡើយ។

### មាត្រា១៧

ក្រោយពីទទួលបានការអនុញ្ញាតពីអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ អាចរៀបចំដំណើរការនៃការជួលទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនេះ ទៅតាមនីតិវិធីដូចដែលកំណត់នៅក្នុងផ្នែកទី២នៃជំពូកនេះ។

### មាត្រា១៨

កិច្ចសន្យាជួលទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមិនអាចមានរយៈពេលលើសពី១៥ (ដប់ប្រាំ) ឆ្នាំឡើយ។ កិច្ចសន្យានេះធ្វើឡើងក្រោមរូបភាពជាលិខិតអនុញ្ញាតកាន់កាប់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋដែលមានលក្ខណៈជាបណ្ដោះអាសន្ន មិនទៀង ហើយអាចដកហូតវិញបានគ្រប់ពេលវេលា ក្នុងបំណងការពារទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងបម្រើប្រយោជន៍សាធារណៈ។

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ មានភារកិច្ចរៀបចំសៀវភៅបន្ទុកដែលកំណត់អំពីល័ក្ខខ័ណ្ឌផ្សេងៗនៃការប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនោះ។

## ផ្នែកទី៣ ការកែសម្រួលបំពេញបន្ថែមលើកិច្ចសន្យាជួល និងការបង់ចំណូល

### មាត្រា១៩

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋដែលជាភាគីនៃកិច្ចសន្យាជួលមានរយៈពេល៩ (ប្រាំបួន) ខែ ដើម្បីពិនិត្យ និងធ្វើការកែសម្រួលលើកិច្ចសន្យាជួលទ្រព្យសម្បត្តិរបស់រដ្ឋទាំងឡាយដែលបានធ្វើឡើងមុនអនុក្រឹត្យនេះចូលជាធរមាន ដោយរៀបចំបន្ថែមនូវល័ក្ខខ័ណ្ឌចាំបាច់ដូចដែលមានចែងក្នុងមាត្រា១៤នៃអនុក្រឹត្យនេះ។

### មាត្រា២០

ចំណូលដែលបានមកពីការជួលទ្រព្យសម្បត្តិរបស់រដ្ឋ អ្នកទទួលជួលត្រូវបង់ចូលថវិការដ្ឋក្នុងខ្ទង់ចំណូលផលទុននៃទ្រព្យសម្បត្តិរបស់រដ្ឋ ឬក្នុងខ្ទង់ថវិកាផ្សេងទៀត តាមការកំណត់របស់រាជរដ្ឋាភិបាល។

## ជំពូកទី៤ ការលក់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

### មាត្រា២១

បទប្បញ្ញត្តិទាំងឡាយនៃជំពូកនេះត្រូវអនុវត្តចំពោះការលក់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដែលកំពុងឋិតក្រោមការកាន់កាប់ ការប្រើប្រាស់ ការថែរក្សា ការធ្វើអាជីវកម្មរបស់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង ស្រុក-ខណ្ឌ ឃុំ-សង្កាត់ និងនីតិបុគ្គលសាធារណៈដទៃទៀត ទាំងអចលនទ្រព្យ និងចលនទ្រព្យ។

### មាត្រា២២

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋជាអ្នកលើកសំណើសុំលក់ទ្រព្យសម្បត្តិឯកជន ហើយត្រូវបានរៀបចំឱ្យបានត្រឹមត្រូវនូវរាល់ឯកសារពាក់ព័ន្ធនឹងទ្រព្យសម្បត្តិរដ្ឋនេះ ដែលជាកម្ម

វត្ថុនៃការលក់ទៅឱ្យភាគីម្ខាងទៀត ដោយភ្ជាប់ឯកសារពាក់ព័ន្ធទាំងអស់នេះមកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋដើម្បីពិនិត្យ និងលើកយោបល់សុំការសម្រេចពីរាជរដ្ឋាភិបាល។

**មាត្រា២៣**

ការលក់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាចលនទ្រព្យជាសមត្ថកិច្ចរបស់អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ លើកលែងតែចលនទ្រព្យដែលមានតម្លៃខ្ពស់។

ការលក់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាអចលនទ្រព្យជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល។

**មាត្រា២៤**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋត្រូវបង្កើតគណៈកម្មការវាយតម្លៃមួយលើទ្រព្យឯកជនរបស់រដ្ឋដែលជាកម្មវត្ថុនៃការលក់នោះ ដោយផ្អែកលើមូលដ្ឋានបច្ចេកទេស និងតម្លៃទីផ្សារ ហើយលើកសំណើនៃការវាយតម្លៃរបស់ខ្លួនជូនអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ។ គណៈកម្មការវាយតម្លៃនេះ ត្រូវមានតំណាងរបស់អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ តំណាងរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងរបស់ស្ថាប័នជំនាញពាក់ព័ន្ធ ដើម្បីសិក្សាវាយតម្លៃទ្រព្យសម្បត្តិរបស់រដ្ឋដែលជាកម្មវត្ថុនៃការលក់នោះ។

**មាត្រា២៥**

ការលក់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋត្រូវរៀបចំធ្វើឡើងក្រោមរូបភាពនៃការដេញថ្លៃ ឬចរចាពិគ្រោះថ្លៃដូចករណីនៃការជួលដែរ។

ផ្អែកលើសំណើរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងលទ្ធផលនៃការវាយតម្លៃលើទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាកម្មវត្ថុនៃការលក់ អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋត្រូវពិនិត្យ ផ្តល់យោបល់ និងសម្រេចជាគោលការណ៍ឱ្យដេញថ្លៃ ឬចរចាពិគ្រោះថ្លៃ។ ក្នុងករណីចាំបាច់ត្រូវមានការសម្រេចជាមុនពីរាជរដ្ឋាភិបាល។

នីតិវិធីលំអិតនៃការដេញថ្លៃ និងការចរចាពិគ្រោះថ្លៃត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា២៦**

ការដេញថ្លៃអាចប្រព្រឹត្តទៅបាន បើមានការចូលរួមពីរូបវន្តបុគ្គល ឬនីតិបុគ្គលកម្រិតជាតិ ឬអន្តរជាតិចាប់ពី២ (ពីរ) ឡើងទៅ និងអាស្រ័យលើវិសាលភាពនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលត្រូវលក់។

ការដេញថ្លៃអាចប្រព្រឹត្តទៅតាមរូបភាព៖

១-ប្រកួតប្រជែងដោយចំហជាលក្ខណៈជាតិ ឬអន្តរជាតិ។

២-ប្រកួតប្រជែងដោយផ្ទាល់មាត់ជាលក្ខណៈជាតិ ឬអន្តរជាតិ។

**មាត្រា២៧**

ការចរចាពិគ្រោះថ្លៃអាចប្រព្រឹត្តទៅបានក្នុងករណីណាមួយដូចខាងក្រោម៖

១-បើការដេញថ្លៃមិនទទួលបានលទ្ធផល។

២-មានរូបវន្តបុគ្គល ឬនីតិបុគ្គលស្នើសុំទិញតែមួយ។

៣-អ្នកជួលទ្រព្យសម្បត្តិរបស់រដ្ឋនោះស្នើសុំទិញពីរដ្ឋ ក្នុងករណីអ្នកជួលទ្រព្យសម្បត្តិរបស់រដ្ឋនោះបានចំណាយទុនវិនិយោគបានយ៉ាងតិចចំនួន៣០ (សាមសិប) ភាគរយនៃគម្រោងវិនិយោគ ឬក្នុងករណីដែលរដ្ឋបានផ្តល់មធ្យោបាយ និងហេដ្ឋារចនាសម្ព័ន្ធដែលមានរួចស្រេច ហើយគម្រោងនោះបានដំណើរការរយៈពេល១ (មួយ) ឆ្នាំ យ៉ាងតិច។

**មាត្រា២៨**

ផ្អែកតាមលទ្ធផលនៃការដេញថ្លៃ ឬការចរចាពិគ្រោះថ្លៃដែលទទួលស្គាល់ជាផ្លូវការជាស្ថាពរពីអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ឬរាជរដ្ឋាភិបាលហើយនោះ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋមានរយៈពេលយ៉ាងយូរ៣ (បី) ខែ សម្រាប់ពិភាក្សាជាមួយភាគីដែលត្រូវចុះកិច្ចសន្យាលក់-ទិញ ដើម្បីរៀបចំសេចក្តីព្រាងកិច្ចសន្យានោះ។ រយៈពេលនេះអាចពន្យារជូនបានមួយលើកទៀត ដែលរយៈពេលយ៉ាងយូរ៣ (បី) ខែ ប្រសិនបើពិនិត្យឃើញមានមូលហេតុសមស្រប និងជាការចាំបាច់។ ក្នុងករណីអ្នកដេញថ្លៃមិនព្រមចរចាពិភាក្សារៀបចំកិច្ចសន្យាទិញ-លក់តាមរយៈពេលកំណត់នោះ គោលការណ៍ ឬលទ្ធផលនៃការដេញថ្លៃត្រូវទុកជាមោឃៈ ហើយប្រាក់កក់នឹងត្រូវរឹបអូសចូលថវិការដ្ឋ។

បន្ទាប់ពីមានការព្រមព្រៀងលើរាល់ល័ក្ខខ័ណ្ឌនៃសេចក្តីព្រាងកិច្ចសន្យា រវាងភាគីកិច្ចសន្យា និងក្រោយពីបានទទួលការពិនិត្យ និងកែសម្រួលពីអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋរួចរាល់ ភាគីនៃកិច្ចសន្យាមានសិទ្ធិចុះហត្ថលេខា។

**មាត្រា២៩**

ចំណូលដែលបានមកពីការលក់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋត្រូវបង់ចូលថវិការដ្ឋក្នុងខ្ទង់ចំណូលផលទុននៃទ្រព្យសម្បត្តិរបស់រដ្ឋ ឬក្នុងខ្ទង់ថវិកាផ្សេងទៀតតាមការកំណត់របស់រាជរដ្ឋា-

ភិបាល ។

**មាត្រា៣០**

ការផ្ទេរកម្មសិទ្ធិពីរដ្ឋជូនភាគីឯកជនបាន អាចធ្វើទៅបានលុះត្រាតែមានការបញ្ជាក់ពីអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋអំពីការបង់ប្រាក់គ្រប់ចូលថវិការដ្ឋ ការបំពេញកាតព្វកិច្ចស្របតាមសៀវភៅបន្ទុកដេញថ្លៃ ឬកិច្ចសន្យាចប់សព្វគ្រប់ ការបង់ថ្លៃពន្ធប្រថាប់ត្រាគ្រប់ចំនួនជូនរដ្ឋ និងពន្ធអាករផ្សេងទៀត តាមកំណត់ច្បាប់ ។

**ជំពូកទី៥ ការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ**

**មាត្រា៣១**

ការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋគឺជាការផ្ទេរកម្មសិទ្ធិទៅវិញទៅមករវាងភាគីឯកជននិងភាគីរដ្ឋ ។

ការដូរធ្វើឡើងក្នុងគោលបំណងដោះស្រាយទីកន្លែងបំពេញការងារ រៀបចំតំបន់រដ្ឋបាលឱ្យបានសមស្របតាមតម្រូវការជាក់ស្តែង និងតាមទិន្នាការអភិវឌ្ឍន៍ ។

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ អាចស្នើដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋទាំងឡាយដែលរួមមានចលនទ្រព្យ និងអចលនទ្រព្យ ដើម្បីបានមកវិញនូវទ្រព្យសម្បត្តិថ្មីសមស្របដែលផ្តល់ដោយភាគីឯកជន ។

**មាត្រា៣២**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋត្រូវរៀបចំឱ្យបានត្រឹមត្រូវនូវរាល់ឯកសារពាក់ព័ន្ធនឹងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដែលជាកម្មវត្ថុនៃការដូរជាមួយនឹងទ្រព្យសម្បត្តិដែលផ្តល់ដោយឯកជន មកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ដើម្បីពិនិត្យ និងលើកយោបល់សុំការសម្រេចពីរាជរដ្ឋាភិបាល ។

**មាត្រា៣៣**

ការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាចលនទ្រព្យជាសមត្ថកិច្ចរបស់អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ លើកលែងតែចលនទ្រព្យដែលមានតម្លៃខ្ពស់ ។

ការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាអចលនទ្រព្យជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។

**មាត្រា៣៤**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋត្រូវបង្កើតគណៈកម្មការវាយតម្លៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដោយមានការចូលរួមពីតំណាងរបស់អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ តំណាងរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី និងតំណាងរបស់ស្ថាប័នពាក់ព័ន្ធ ដើម្បីសិក្សាវាយតម្លៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាកម្មវត្ថុនៃការដូរនោះស្របតាមគោលការណ៍បច្ចេកទេស និងតម្លៃទីផ្សារ។

**មាត្រា៣៥**

ការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋជាមួយនឹងទ្រព្យសម្បត្តិរបស់ភាគីឯកជន ត្រូវប្រព្រឹត្តតាមរូបភាពដេញថ្លៃជាសាធារណៈ ឬចរចាពិគ្រោះថ្លៃទៅតាមនីតិវិធីដូចដែលមានចែងក្នុងមាត្រា២៦ និងមាត្រា២៧នៃអនុក្រឹត្យនេះ។

ភាគីឯកជនដែលចូលរួមដេញថ្លៃ ឬចរចាពិគ្រោះថ្លៃត្រូវមានទ្រព្យសម្បត្តិសមស្របដើម្បីជាថ្នូរនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។

ល័ក្ខខ័ណ្ឌ និងការទូទាត់តម្លៃនៃការដូរត្រូវកំណត់ឡើងដោយសៀវភៅបន្ទុកមួយ ដែលត្រូវរៀបចំដោយអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ហើយអាជ្ញាធរនេះត្រូវផ្ញើសៀវភៅបន្ទុកនោះមកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ដើម្បីពិនិត្យ និងលើកយោបល់សុំការសម្រេចពីរាជរដ្ឋាភិបាល។

**មាត្រា៣៦**

ផ្អែកលើសំណើរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងលទ្ធផលនៃការវាយតម្លៃលើទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាកម្មវត្ថុនៃការដូរ អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋត្រូវពិនិត្យផ្ដល់យោបល់ និងសម្រេចជាគោលការណ៍ឱ្យដេញថ្លៃ ឬចរចាពិគ្រោះថ្លៃ។ ក្នុងករណីចាំបាច់ អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋត្រូវស្នើសុំការសម្រេចជាមុនពីរាជរដ្ឋាភិបាល។

នីតិវិធីលំអិតនៃការដេញថ្លៃ និងការចរចាពិគ្រោះថ្លៃត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា៣៧**

ផ្អែកតាមលទ្ធផលនៃការដេញថ្លៃ និងការចរចាពិគ្រោះថ្លៃដែលត្រូវបានទទួលស្គាល់ជាផ្លូវការស្ថាពរដោយអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ឬរាជរដ្ឋាភិបាល អាជ្ញាធរកាន់កាប់

ទ្រព្យសម្បត្តិរបស់រដ្ឋមានរយៈពេលយ៉ាងយូរ៣ (បី) ខែ ដើម្បីពិភាក្សាជាមួយភាគីដែលត្រូវចុះកិច្ចសន្យាដូរ ដើម្បីរៀបចំសេចក្ដីព្រាងកិច្ចសន្យានោះ។ រយៈពេលនេះអាចពន្យារជូនបានមួយលើកទៀតដែលមានរយៈពេលយ៉ាងយូរ៣ (បី) ខែ ប្រសិនបើពិនិត្យឃើញមានមូលហេតុសមស្រប និងចាំបាច់។ ក្នុងករណីអ្នកដេញថ្លៃបានមិនព្រមចរចាពិភាក្សា រៀបចំកិច្ចសន្យាដូរតាមរយៈពេលកំណត់នោះ គោលការណ៍ ឬលទ្ធផលនៃការដេញថ្លៃនឹងត្រូវទុកជាមោឃៈ ហើយប្រាក់កក់នឹងត្រូវរឹបអូសបង់ចូលថវិការដ្ឋ។

ភាគីនៃកិច្ចសន្យាមានសិទ្ធិចុះហត្ថលេខាលុះត្រាតែល័ក្ខខ័ណ្ឌទាំងអស់នៃសេចក្ដីព្រាងកិច្ចសន្យា ត្រូវបានព្រមព្រៀងរវាងភាគីនៃកិច្ចសន្យា ហើយត្រូវបានពិនិត្យ កែសម្រួល និងយល់ព្រមដោយអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋជាមុនសិន។

**មាត្រា៣៨**

ការផ្ទេរកម្មសិទ្ធិពីរដ្ឋជូនឯកជនអាចធ្វើទៅបាន លុះត្រាតែមានការបញ្ជាក់ពីអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ អំពីការបង់ប្រាក់គ្រប់ចូលថវិការដ្ឋ ការបំពេញកាតព្វកិច្ចស្របតាមសៀវភៅបន្ទុកដេញថ្លៃ ឬកិច្ចសន្យាចប់សព្វគ្រប់ ការបង់ថ្លៃពន្ធប្រថាប់ត្រាគ្រប់ចំនួនជូនរដ្ឋ និងពន្ធអាករផ្សេងទៀត។

**មាត្រា៣៩**

ចំណូលដែលបានមកពីការជួលទ្រព្យសម្បត្តិរបស់រដ្ឋ អ្នកទទួលជួលត្រូវបង់ចូលថវិការដ្ឋក្នុងខ្ទង់ចំណូលផលទុននៃទ្រព្យសម្បត្តិរបស់រដ្ឋ ឬខ្ទង់ថវិកាផ្សេងទៀតតាមការកំណត់របស់រាជរដ្ឋាភិបាល។

## ជំពូកទី៦ អន្តរប្បញ្ញត្តិស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគ

**មាត្រា៤០**

ការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈត្រូវធ្វើឡើងតាមគោលការណ៍ និងបទប្បញ្ញត្តិដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ។

*វាយឡើងវិញ*

វិធាន និងនីតិវិធីនៃការធ្វើអនុបយោគត្រូវបានកំណត់នៅក្នុងអនុក្រឹត្យនេះ ។

**មាត្រា៤១**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋមានតួនាទីធ្វើការអង្កេតជាសាធារណៈ ត្រូវធ្វើឡើងតាមគោលការណ៍ និងបទប្បញ្ញត្តិដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ ហើយស្នើសុំធ្វើអនុបយោគ ដោយមានភ្ជាប់សំណុំឯកសារទាំងអស់មកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ដើម្បីពិនិត្យ និងលើកយោបល់ជូនរាជរដ្ឋាភិបាលសម្រេច តាមរយៈអនុក្រឹត្យ ។

## ជំពូកទី៧ អវសានប្បញ្ញត្តិ

**មាត្រា៤២**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា៤៣**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

<u>កន្លែងទទួល</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ដូចមាត្រា៤៣
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ**

**លេខ២៦៥អសដក** ភ្នំពេញ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦

**អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ**

**ជម្រាបមក**

**លោក លោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត-ក្រុងដែលបានទទួលប្រតិភូកម្មហត្ថលេខា**

កម្មវត្ថុ៖ អំពីការយឺតយូរក្នុងការបញ្ជូនតារាងសម្រង់អចលនវត្ថុ និងតារាងផ្លាស់ប្តូរអចលនវត្ថុ

យោង៖ អនុក្រឹត្យលេខ៤៨អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបអស់លោកប្រធានថា កន្លងមកនេះ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្របានសង្កេតឃើញថា ទោះបីមានការណែនាំជាច្រើនលើកច្រើនសា តាមរូបភាពជាលិខិតក្តី ឬដោយផ្ទាល់ក្តី ក៏នៅមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុងមួយចំនួនមិនបានយកចិត្តទុកដាក់ក្នុងការបញ្ជូនតារាងសម្រង់អចលនវត្ថុ និងតារាងផ្លាស់ប្តូរអចលនវត្ថុមកអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ដើម្បីចុះក្នុងសៀវភៅចុះបញ្ជីដីឱ្យបានស្របគ្នាទាំង៣ថ្នាក់ តាមកាលកំណត់នោះឡើយ។ ទង្វើបែបនេះបណ្តាលឱ្យឃ្លាតចាកពីភាពសុក្រឹត និងគតិយុត្ត និងបង្កើតបាននូវភាពកកស្ទះឯកសារ ហើយអាចបង្កើតកំហុសរបស់មន្ត្រីអភិរក្ស ក្នុងការផ្តល់ព័ត៌មានពាក់ព័ន្ធនឹងក្បាលដីទៅអ្នកស្នើសុំ។

ដើម្បីចៀសវាងរាល់ការខុសឆ្គង អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ធ្វើការណែនាំដូចតទៅ៖

*វាយឡើងវិញ*

១-ចាប់ពីពេលនេះតទៅ គ្រប់ឯកសារសំណុំរឿងសុរិយោដីដែលបានចេញជាផ្លូវការរួចហើយ ត្រូវធ្វើតារាងសម្រង់អចលនវត្ថុ និងតារាងផ្លាស់ប្តូរអចលនវត្ថុ និងលិខិតរណបទាំងឡាយដែលពាក់ព័ន្ធមកអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រឱ្យបានទៀងទាត់តាមការកំណត់យ៉ាងយូរ១៥ ថ្ងៃ (គិតពីថ្ងៃចេញឯកសារ + មកដល់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ)។

២-ដីកាអមបញ្ជូនឯកសារនេះត្រូវញែកឱ្យដាច់ដោយឡែកពីគ្នា គឺ០១សម្រាប់ឯកសារសុរិយោដីអនុវត្តនីតិវិធីចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ និង០១ទៀតសម្រាប់ឯកសារសុរិយោដីអនុវត្តនីតិវិធីចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ។

ករណីមានការយឺតយ៉ាវ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រនឹងរាយការណ៍ជូនក្រសួង ដើម្បីណែនាំបន្ថែម។

ទទួលបានលិខិតនេះ សូមលោកប្រធានចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរ។

**អគ្គនាយក**

**ហត្ថលេខា និងត្រា**

**លឹម វ៉ាន់**

ចម្លងជូន

-ក្រសួង ដ.ន.ស

-គ្រប់សាលាខេត្ត-ក្រុងពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

-នាយកដ្ឋានអភិរក្សសុរិយោដី

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ**

**លេខ២៧៣អសដភ** ភ្នំពេញ ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៦

**អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ**

**ជម្រាបមក**

**លោក លោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី**

**ខេត្ត-ក្រុងអនុវត្តគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី** (LMAP)

កម្មវត្ថុ៖ ការអនុវត្តនីតិវិធីចុះបញ្ជីដី-ការផ្ទេរសិទ្ធិ និងការចុះបន្ទុកលើដី-ផ្ទះ ក្នុងតំបន់ដែលកំពុងធ្វើការវិនិច្ឆ័យ និងតំបន់ដែលបានធ្វើការវិនិច្ឆ័យរួចហើយ

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបអស់លោក លោកស្រីជាប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងសុរិយោដីខេត្ត-ក្រុងឱ្យបានជ្រាបថា កន្លងមកការស្នើសុំចុះបញ្ជីតាមនីតិវិធីដាច់ដោយដុំ ការផ្ទេរសិទ្ធិ និងការដាក់បន្ទុកលើដី-ផ្ទះ ក្នុងតំបន់វិនិច្ឆ័យតែងជួបការលំបាកដោយនៅខ្វះគោលការណ៍ណែនាំ និងនីតិវិធីអនុវត្តច្បាស់លាស់។ ដើម្បីដោះស្រាយករណីនេះ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ សូមធ្វើការណែនាំដូចតទៅ៖

១-ការស្នើសុំចុះបញ្ជីដីតាមនីតិវិធីដាច់ដោយដុំ ក្នុងតំបន់ដែលបានប្រកាសតំបន់វិនិច្ឆ័យរួចហើយ ត្រូវបានអនុញ្ញាតឱ្យអនុវត្ត ដោយត្រូវគិតពីរយៈពេលដែលនឹងត្រូវចេញប័ណ្ណ ចៀសវាងការទទួលប័ណ្ណតាមនីតិវិធីដាច់ដោយដុំ និងការទទួលប័ណ្ណតាមនីតិវិធីមានលក្ខណៈជាប្រព័ន្ធនៅពេលជាមួយគ្នា ឬការទទួលប័ណ្ណតាមនីតិវិធីដាច់ដោយដុំ ក្រោយពេលទទួលប័ណ្ណតាមនីតិវិធីមានលក្ខណៈជាប្រព័ន្ធ។

*វាយឡើងវិញ*

២-ការផ្ទេរសិទ្ធិក្នុងប័ណ្ណដីចាស់ (ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ) អាចអនុញ្ញាតគ្រប់ពេលរហូតវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុត្រូវបានផ្តល់ជូនតាមនីតិវិធីចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ។ ក្រោយពេលចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុថ្មី ប័ណ្ណដីចាស់នឹងត្រូវបានចាត់ទុកជាមោឃៈលែងមានសុពលភាពប្រើប្រាស់តាមផ្លូវច្បាប់ទៀតហើយ។ រាល់ការលួចប្រើប្រាស់ដោយបំពាននឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន។

៣-នៅពេលអនុវត្តនីតិវិធីចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ក្រុមការងារតែងតែកត់ចូលក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី នូវព័ត៌មានជាក់ស្តែងដែលទទួលបានពេលចុះប្រតិបត្តិការ ដោយមិនគិតពីការផ្ទេរសិទ្ធិតាមច្បាប់ឡើយ។ ករណីនេះនាំមកនូវភាពស្មុគស្មាញដល់ការធ្វើនិយតកម្មឯកសារនៃការផ្ទេរសិទ្ធិតាមច្បាប់ និងការបង់ពន្ធប្រថាប់ត្រា។ ក្នុងឯកសារគោលទាក់ទងនឹងសិទ្ធិលើក្បាលដី មានតែទម្រង់បែបបទនៃការប្រមូលទិន្នន័យតែមួយគត់ដែលអាចយកមកធ្វើជាមូលដ្ឋានក្នុងការប្រថាប់ត្រាបង់ពន្ធបាន។ ចំណុចដែលត្រូវបោះត្រាគឺផ្នែកខាងស្តាំដៃនៃចំណុច គ-សិទ្ធិលើអចលនវត្ថុ ឬនៅបន្ទាត់ខាងក្រោមចំពាក្យថា "ទិញ"។

អាស្រ័យហេតុនេះ សូមលោក លោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង អនុវត្តតាមការណែនាំឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

<u>ចម្លងជូន</u>

-ក្រសួង ដ.ន.ស

-គ្រប់សាលាខេត្ត-ក្រុងអនុវត្តគម្រោង LMAP

"<u>ដើម្បីជូនជ្រាប</u>"

-នាយកដ្ឋានអភិរក្សសុរិយោដី

-ឯកសារ-កាលប្បវត្តិ

**អគ្គនាយក**

**ហត្ថលេខា និងត្រា**

**លឹម វ៉ាន់**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ**
**លេខ២៧៤អសជក** ភ្នំពេញ ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៦

## សេចក្ដីណែនាំ
## ស្ដីពីគោលការណ៍ នីតិវិធី និងរូបមន្ត លេខាចារឹកទាក់ទងនឹងទ្រព្យសហភោគី ឬកម្មសិទ្ធិករអវិភាគ

ការងារកាន់កាប់ឯកសារសុរិយោដីតម្រូវឱ្យមានគោលការណ៍ រូបមន្ត និងនីតិវិធីច្បាស់លាស់ដើម្បីធានាសិទ្ធិរបស់បុគ្គលម្ចាស់សិទ្ធិផង និងឱ្យមានការឯកភាពគ្នាក្នុងការអនុវត្តផង។ ក្នុងគោលដៅនេះ ការវិវត្តប្រែប្រួលខាងសតិអារម្មណ៍របស់មនុស្ស និងសង្គម ចេះតែប្រព្រឹត្តទៅឥតឈប់ឈរដែលធ្វើរូបមន្ត គោលការណ៍ និងនីតិវិធីដែលមានពីមុន មិនអាចឆ្លើយតបបានគ្រប់គ្រាន់ ហើយទាមទារឱ្យមានការដោះស្រាយបន្ថែម ទៅតាមអ្វីដែលជាសេចក្ដីត្រូវការថ្មីៗ។ ករណីជាក់ស្ដែងកើតឡើងពេលនេះ គឺទាក់ទងនឹងទ្រព្យសហភោគី ឬទ្រព្យកម្មសិទ្ធិករអវិភាគ។

**ករណីទី១** -បុគ្គលម្នាក់មានអចលនទ្រព្យជាដីផ្ទាល់ខ្លួនមួយក្បាល មានប័ណ្ណសម្គាល់សិទ្ធិត្រឹមត្រូវ ក្រោយមកបុគ្គលនេះចង់ដាក់ទ្រព្យនេះទៅជាទ្រព្យសហភោគី ឬកម្មសិទ្ធិអវិភាគវិញ តើខាងជំនាញត្រូវអនុវត្តគោលការណ៍អ្វី រូបមន្តណា ហើយតាមនីតិវិធីណាមួយ? ។

ឧទាហរណ៍ ឈ្មោះ ក មានទ្រព្យផ្ទាល់ខ្លួនជាដីមួយក្បាល ឬច្រើនក្បាល ហើយមានបំណងដាក់ទ្រព្យ ឬដីទាំងនេះ ទៅជាទ្រព្យរួមគ្នាជាមួយបុគ្គលផ្សេងៗ ម្នាក់ទៀត ឬច្រើននាក់អាចឈ្មោះ ខ ឬ គ . . . ដែលមានចំណែកស្មើៗគ្នា ឬមិនស្មើគ្នាគិតជាភាគរយ ។

១-គោលការណ៍៖ ផ្អែកលើគោលការណ៍នៃប្រភេទទ្រព្យដែលក្នុងករណីនេះ មានទំនាក់ទំនងរវាងប្រភេទទ្រព្យពីរខុសគ្នាគឺទីមួយ ជាទ្រព្យផ្ទាល់ខ្លួនរបស់បុគ្គល ឬរបស់គ្រួសារមួយ ហើយ

ទីពីរជាទ្រព្យរួមគ្នារវាងបុគ្គលពីរ ឬគ្រួសារពីរ ដែលគេឱ្យឈ្មោះថាជាទ្រព្យសហភោគី ឬជាទ្រព្យកម្មសិទ្ធិករអវិភាគ។

២-នីតិវិធី៖ ដូចគ្នានឹងការដាក់ទ្រព្យចូលក្នុងក្រុមហ៊ុន គ្រាន់តែករណីនេះវាគ្មានលក្ខន្តិកៈដែលក្នុងនោះគេបានប្រកាសភាគហ៊ុនទេ វាជាការយល់ព្រមរបស់ភាគីម្ចាស់ទ្រព្យ ឱ្យភាគីដែលចង់ចូលហ៊ុនដាក់ប្រាក់ឱ្យខ្លួនតាមតម្លៃពាក់កណ្ដាល ឬសមាមាត្រ ធៀបទៅនឹងតម្លៃដីទាំងមូល។ ពិនិត្យលើឯកសារផ្លូវការដែលមានពុំឃើញឯកសារណាមួយ ដែលអាចឱ្យភាគីចូលជាទ្រព្យសហភោគី ឬទ្រព្យកម្មសិទ្ធិករអវិភាគបំពេញ ហើយអាចយកទៅប្រថាប់ត្រាបង់ពន្ធបាននោះឡើយ។ ដូច្នេះ វិធីមានតែមួយគឺធ្វើលិខិតលក់ផ្ដាច់ ដោយអ្នកលក់ គឺម្ចាស់ទ្រព្យផ្ទាល់ ឬគ្រួសារ ឯអ្នកទិញគឺម្ចាស់ទ្រព្យជាសហភោគី ឬកម្មសិទ្ធិករអវិភាគ រួចបង់ពន្ធប្រថាប់ត្រា ហើយយកមកចុះបញ្ជីតែម្ដងទើបបាន។

៣-រូបមន្ត $\dfrac{\text{ក}}{\text{ក និង ខ}}$

(ទ្រព្យសហភោគី ឬទ្រព្យកម្មសិទ្ធិករអវិភាគ)

ចរន្តការ ឈ្មោះ ក (ទ្រព្យផ្ទាល់) លក់ផ្ដាច់ឱ្យ ក + ខ (ទ្រព្យសហភោគី ឬទ្រព្យកម្មសិទ្ធិករអវិភាគ) តាមសំបុត្រចុះថ្ងៃទី . . .

**ករណីទី២**-បុគ្គលពីរនាក់ ឬពីរគ្រួសារបានសម្រេចចូលដើមទុនគ្នាទិញដី ឬអចលនវត្ថុមួយ ទុកប្រើប្រាស់ ឬទុកលក់យកចំណេញចែកគ្នា។

ក-ប្រសិនបើ បុគ្គលដែលទាំងពីរជាបុគ្គលទោល (លីវ ឬមេម៉ាយ ពោះម៉ាយ) ដូចគ្នា រូបមន្តនៃការសរសេរក្នុងកំណត់ហេតុអង្កេតដី ឬទម្រង់បែបបទនៃការប្រមូលទិន្នន័យក្នុងបញ្ជីដី និងក្នុងប័ណ្ណដី រូបមន្តដែលមានអាចអនុវត្តបាន។

ខ-តែប្រសិនបើ បុគ្គលម្ខាង ឬទាំងពីរមានចំណងអាពាហ៍ពិពាហ៍ រូបមន្តនៃការសរសេរក្នុងឯកសារពិតជាត្រូវកំណត់ផ្សេងៗពីចំណុច (ក) ទើបអាចអនុវត្តបាន។

រូបមន្ត

១-បុគ្គលម្នាក់លីវ ឯបុគ្គលម្នាក់ទៀតមានចំណងអាពាហ៍ពិពាហ៍

ឧទាហរណ៍ $\dfrac{\text{ច}}{\text{ក (លីវ ឬមេម៉ាយ)}}$

និង

ខ (BC ល)

ចរន្តការ៖ ច លក់ផ្តាច់ឱ្យ ក (លីវ ឬមេម៉ាយ) និងខ (BC ល) តាមសំបុត្រចុះថ្ងៃទី...

នៅពេលទ្រព្យសហភោគី ឬទ្រព្យកម្មសិទ្ធិករអវិភាគលក់បន្ត អ្នកលក់ត្រូវផ្តិតមេដៃបីនាក់គឺ ក, ខ និង ល។

២-បុគ្គលទាំងពីរឋិតក្នុងចំណងអាពាហ៍ពិពាហ៍

ឧទាហរណ៍ ដ
ក (BC ត)
និង

ជ (BC ធ)

ចរន្តការ ដ លក់ផ្តាច់ឱ្យ ក (BC ត) និង ជ (BC ធ) តាមសំបុត្រចុះថ្ងៃ . . .

នៅពេលសហភោគីលក់បន្ត ក្នុងលិខិតលក់ត្រូវផ្តិតដៃ អ្នកលក់ពីរនាក់ប្តីប្រពន្ធទាំងពីរគូគឺ ក និង ត - ជ និង ធ។

**អគ្គនាយកសុរិយោដី និងភូមិសាស្ត្រ**

**ហត្ថលេខា និងត្រា**

**លឹម វ៉ាន់**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ៩១សសរ

## សេចក្តីសម្រេចស្តីពីសេវាសុរិយោដី

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ/បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញប្រកាសអន្តរក្រសួងលេខ៣៧៧សហវ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៩ ស្តីពីការកំណត់ចំណូលពីសោហ៊ុយសេវាសុរិយោដី
- បានឃើញប្រកាសអន្តរក្រសួងលេខ៣៩៦សហវ/ប្រក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៤ ស្តីពីការកែសម្រួលប្រកាសអន្តរក្រសួងលេខ៣៧៧សហវ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០២ ស្តីពីការកំណត់សោហ៊ុយសេវាសុរិយោដី
- យោងតាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

### សម្រេច

### ប្រការ១

ផ្អែកតាមប្រការ២ថ្មីនៃប្រកាសអន្តរក្រសួងលេខ៣៩៦សហវ/ប្រក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៤ ស្តីពីការកែសម្រួលប្រកាសអន្តរក្រសួងលេខ៣៧៧សហវ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០២ ស្តីពីការកំណត់ចំណូលសោហ៊ុយសេវាសុរិយោដី សោហ៊ុយសេវាសុរិយោដីនៅតែជាធរមានគឺ៖

**ក_សម្រាប់ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ**

| ល.រ | បរិយាយ | សោហ៊ុយសេវាសុរិយោដី | | | | |
|---|---|---|---|---|---|---|
| | | ដីផលិតកម្ម ឬដីភោគៈ គ្រប់ខេត្ត-ក្រុង | ដីលំនៅឋាន និងដីសម្រាប់សំណង់ទូទៅ | | | |
| | | | ក្រុងភ្នំពេញ ក្រុងព្រះសីហនុ ខេត្តកណ្តាល និង ខេត្តសៀមរាប | | ក្រៅពីទីក្រុងភ្នំពេញ ក្រុងព្រះសីហនុ ខេត្តកណ្តាល និងខេត្តសៀមរាប | |
| | | | ជនបទ ឬ ក្រៅក្រុង | ទីក្រុង ឬ ទីរួមខេត្ត | ជនបទ ឬ ក្រៅក្រុង | ទីក្រុង ឬ ទីរួមខេត្ត |
| 1 | 2 | 3 | 4 | 5 | 6 | 7 |
| ១ | ការចេញប័ណ្ណ ឬ ប័ណ្ណទុតិយតា ឬ ប័ណ្ណតតិយតា "ក្នុង១ក្បាលដី" | ១០.០០០៛០០ | ៥០.០០០៛០០ | ៣៥០.០០០៛០០ | ៥០.០០០៛០០ | ២០០.០០០៛០០ |
| ២ | ការផ្ទេរអចលនវត្ថុ (ផ្ទេរដោយបំបែក ឬផ្ទេរទាំងមូល) "ក្នុង១ប័ណ្ណ" | ៥០.០០០៛០០ | ១០០.០០០៛០០ | ២០០.០០០៛០០ | ១០០.០០០៛០០ | ១២០.០០០៛០០ |
| ៣ | ការបង្រួមក្បាលដី "ក្នុង១ក្បាលដីដើម" | ១០០.០០០៛០០ | ១២០.០០០៛០០ | ១៥០.០០០៛០០ | ១២០.០០០៛០០ | ១៥០.០០០៛០០ |
| ៤ | ការបំបែកក្បាលដី ដោយមិនផ្ទេរ (ក្នុង ១ក្បាលដីបំបែក) | ៥០.០០០៛០០ | ១០០.០០០៛០០ | ២០០.០០០៛០០ | ៨០.០០០៛០០ | ១០០.០០០៛០០ |
| ៥ | ការបោះគោលព្រំដីជាថ្មី | ៣០.០០០៛០០ | ៣៥.០០០៛០០ | ៤០.០០០៛០០ | ៣០.០០០៛០០ | ៣៥.០០០៛០០ |
| ៦ | ការចេញលិខិតបញ្ជាក់ (ហ៊ីប៉ូតែក ដាក់បញ្ចាំ ដាក់ធានា) "ក្នុង១ក្បាលដី" | ១៥.០០០៛០០ | ១៨.០០០៛០០ | ២០.០០០៛០០ | ១៥.០០០៛០០ | ១៨.០០០៛០០ |
| ៧ | ការចេញសលាកប័ត្រព័ត៌មាន "ក្នុង១ក្បាលដី" | ១៥.០០០៛០០ | ១៨.០០០៛០០ | ២០.០០០៛០០ | ១៥.០០០៛០០ | ១៨.០០០៛០០ |
| ៨ | ការចេញលិខិតបញ្ជាក់សុរិយោដី "ក្នុង១ក្បាលដី" | ១៥.០០០៛០០ | ១៨.០០០៛០០ | ២០.០០០៛០០ | ១៥.០០០៛០០ | ១៨.០០០៛០០ |

**ខ.សម្រាប់ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ និងការចេញប័ណ្ណ**

១-ដីកសិកម្មជនបទ ១រៀល/ម$^{២}$

(១០០រៀលសម្រាប់ដីតូចជាង១០០ម$^{២}$)

២-ដីលំនៅឋានជនបទ ១០រៀល/ម$^{២}$

៣-ដីទីប្រជុំជនស្រុក ឬដីជាយទីប្រជុំជនខេត្ត ២០រៀល/ម$^{២}$

៤-ដីទីប្រជុំខេត្ត ឬដីជាយទីប្រជុំជនក្រុងភ្នំពេញ ៥០រៀល/ម$^{២}$

៥-ដីទីប្រជុំជនក្រុងភ្នំពេញ ១០០រៀល/ម$^{២}$

*ប្រការ២*

ផ្អែកតាមប្រការ៣នៃប្រកាសអន្តរក្រសួងលេខ៣៧៧សហវ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០២ ស្តីពីការកំណត់ចំណូលពីសោហ៊ុយសេវាសុរិយោដី សោហ៊ុយសេវាសុរិយោដីលើការវាស់វែងដោយប្រើឧបករណ៍វាស់ស្ទង់ទំនើប ត្រូវបានកំណត់ដូចខាងក្រោម៖

| ល.រ | បរិយាយ | សោហ៊ុយក្នុង១ហិកតា |
|---|---|---|
| ១ | ទំហំដីតិចជាង១០ហិកតា | ៣០.០០០៛០០ |
| ២ | ទំហំដីចាប់ពី១០ហិកតា ដល់៥០ហិកតា | ១៥.០០០៛០០ |
| ៣ | ទំហំដីចាប់ពី៥១ហិកតា ដល់៣០០ហិកតា | ១០.០០០៛០០ |
| ៤ | ទំហំដីចាប់ពី៣០១ហិកតា ដល់១.០០០ហិកតា | ៨.០០០៛០០ |
| ៥ | ទំហំដីចាប់ពី១.០០០ហិកតាឡើងទៅ | ៦.០០០៛០០ |

ចំពោះដីដែលមានទីតាំងឆ្ងាយលើសពី៥០គីឡូម៉ែត្រពីអង្គភាពសុរិយោដី ម្ចាស់ដីត្រូវទទួលបន្ទុកបន្ថែមលើ៖

១-សោហ៊ុយធ្វើដំណើរ ស្នាក់នៅ ហូបចុករបស់មន្ត្រីជំនាញ។

២-ថ្លៃបង្គោល និងការដាំបង្គោលព្រំ។

៣-ចំពោះតំបន់ព្រៃភ្នំ សោហ៊ុយសេវាសុរិយោដីត្រូវគិតបន្ថែម២០% លើសោហ៊ុយសេវាវាស់វែងសរុប។

*ប្រការ៣*

ត្រូវបានសម្រេចកំណត់យករយៈពេលសម្រាប់ដំណើរអនុវត្តលើការចុះបញ្ជីដីធ្លី ដូចមានចែងក្នុងតារាងខាងក្រោម៖

| ល.រ | សកម្មភាពនៃដំណើរការចុះបញ្ជី | រយៈពេល | ពីចាប់ផ្តើម ដល់ពេលចេញប័ណ្ណ |
|---|---|---|---|
| ១ | ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ | ពី៥ខែទៅ៧ខែ ឬ១០០ថ្ងៃទៅ ១៤០ថ្ងៃធ្វើការ | ចាប់គិតពីថ្ងៃចុះប្រមូលទិន្នន័យ រហូតដល់ថ្ងៃប្រកាសចែកប័ណ្ណ |
| ២ | ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ | ពេលពី២ខែទៅ៣ខែ ឬ៤០ថ្ងៃទៅ ៦០ថ្ងៃធ្វើការ | ចាប់គិតពីថ្ងៃចុះប្រមូលទិន្នន័យ រហូតដល់ថ្ងៃប្រគល់ប័ណ្ណ |

| | | | |
|---|---|---|---|
| ៣ | ការផ្ទេរអចលនវត្ថុទាំងមូល | -សម្រាប់ខេត្ត-ក្រុងដែលបានទទួលប្រតិភូកម្ម ពី១០ទៅ១៥ថ្ងៃធ្វើការ ។<br>-ចំពោះខេត្ត-ក្រុងដែលពុំទាន់បានទទួលប្រតិភូកម្ម ពី១៥ថ្ងៃទៅ២០ថ្ងៃធ្វើការ ។ | គិតចាប់ពីថ្ងៃដែលអង្គភាពសុរិយោដីស្រុក-ខណ្ឌបានទទួលសំណុំឯកសារផ្ទេរសិទ្ធិដែលបានបញ្ជាក់ត្រឹមត្រូវ និងគ្រប់គ្រាន់រួចហើយ រហូតដល់ថ្ងៃប្រគល់ប័ណ្ណ |
| ៤ | ការផ្ទេរអចលនវត្ថុដោយបំបែកក្បាលដី | រយៈពេល១៥ថ្ងៃធ្វើការ ប្រែប្រួលទៅតាមទំហំបរិមាណក្បាលដីបំបែក និងទីតាំងដីឋិតនៅ | គិតចាប់ពីថ្ងៃចុះកំណត់ព្រំ និងវាស់វែងបំបែកក្បាលដី ដល់ថ្ងៃប្រគល់ប័ណ្ណ |
| ៥ | ការបង្រួមក្បាលដី | រយៈពេល២០ថ្ងៃទៅ៣០ថ្ងៃធ្វើការ ប្រែប្រួលទៅតាមទំហំបរិមាណក្បាលដីបង្រួម និងទីតាំងដីឋិតនៅ | គិតចាប់ពីថ្ងៃចុះកំណត់ព្រំ និងវាស់វែងបង្រួមក្បាលដី ដល់ថ្ងៃប្រគល់ប័ណ្ណ |
| ៦ | ចេញទុតិយតា | រយៈពេល៩០ថ្ងៃធ្វើការ | គិតពីទទួលពាក្យ ដល់ពេលប្រគល់ប័ណ្ណ |
| ៧ | ការចុះបន្ទុក និងលើកលែងបន្ទុក | មានរយៈពេល២ថ្ងៃធ្វើការ | ក្រោយពីបានទទួលសំណុំឯកសារត្រឹមត្រូវ និងគ្រប់គ្រាន់ ដល់ថ្ងៃប្រគល់ប័ណ្ណ |
| ៨ | ការចេញលិខិតបញ្ជាក់ផ្សេងៗ | មានរយៈពេល២ថ្ងៃធ្វើការ | ក្រោយពីបានទទួលពាក្យស្នើសុំដល់ថ្ងៃចេញលិខិតបញ្ជាក់ |
| ៩ | ការថតចម្លងឯកសារ | មានរយៈពេល២ថ្ងៃធ្វើការ | ក្រោយពីបានទទួលពាក្យស្នើសុំដល់ថ្ងៃប្រគល់ឯកសារថតចម្លង |

*ប្រការ៤*

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍ ។

*ប្រការ៥*

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន គ្រប់នាយកដ្ឋានពាក់ព័ន្ធ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីគ្រប់ខេត្ត-ក្រុង និងរដ្ឋបាលដីធ្លីទាំងអស់មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៦

**ជ.ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**រដ្ឋលេខាធិការ**

**ហត្ថលេខា និងត្រា**

**ឆាន់ សាផាន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ៥៤២សសរ

សេចក្តីសម្រេច
ស្តីពីការបញ្ចូលឯកសារលក្ខណវិនិច្ឆ័យក្នុងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ជាឧបសម្ព័ន្ធរបស់ប្រកាសលេខ៤២ដនស/បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៦ ស្តីពីការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
និងជាប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៨១/២៦ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៥ ស្តីពីការប្រកាសបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីជលផល
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ/បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៤៦អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្ដីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ៤៧អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី
- បានឃើញអនុក្រឹត្យលេខ៤៨អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្ដីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ
- បានឃើញអនុក្រឹត្យលេខ៩៨អនក្រ/បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ស្ដីពីការអនុវត្តច្បាប់ស្ដីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញអនុក្រឹត្យលេខ៥៣អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្ដីពីនីតិវិធីស្ដីពីការបង្កើត ការចាត់ថ្នាក់ និងចុះបញ្ជិការសម្បត្តិព្រៃឈើអចិន្ត្រៃយ៍
- បានឃើញអនុក្រឹត្យ១១៨អនក្រ/បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្ដីពីការគ្រប់គ្រងដីរដ្ឋ

- បានឃើញប្រកាសលេខ៤២ដនស/បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៦ ស្តីពីការធ្វើអត្តសញ្ញាណកម្ម ធ្វើផែនទី និងធ្វើចំណាត់ថ្នាក់ដីរដ្ឋ
- បានទទួលមតិឯកភាពក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៦
- តាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**សម្រេច**

ប្រការ១

បញ្ចូលឯកសារលក្ខណវិនិច្ឆ័យក្នុងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ជាឧបសម្ព័ន្ធរបស់ប្រកាសលេខ៤២ដនស/បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៦ ស្តីពីការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ។

ប្រការ២

ឯកសារស្តីពីលក្ខណវិនិច្ឆ័យក្នុងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ មានខ្លឹមសារដូចតទៅ៖

I-**និយមន័យ**

ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា១៥ និងអនុក្រឹត្យលេខ១១៨អនក្រ/បក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ មាត្រា៤ និងមាត្រា៥ បានចែងពីនិយមន័យនៃដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ ដូចតទៅ៖

**១-ដីសាធារណៈរបស់រដ្ឋ**

ដីសាធារណៈរបស់រដ្ឋជាដីដែលមានជាប់ផលប្រយោជន៍សាធារណៈ និងឋិតនៅក្នុងប្រភេទជាក់លាក់នៃទ្រព្យដែលមានផលប្រយោជន៍សាធារណៈដូចខាងក្រោម៖

ក-ទ្រព្យទាំងឡាយដែលបង្ហាញនូវការកើតឡើងពីធម្មជាតិ ដូចជា៖

១-ព្រៃឈើ។

២-ផ្លូវទឹកដែលមាននាវា ឬក្បូនចេញចូលបាន បណ្តែតបាន។

៣-បឹងធម្មជាតិ។

៤-ច្រាំងទន្លេដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបាន។

៥-ត្រើយសមុទ្រ ។

ខ-ទ្រព្យទាំងឡាយដែលជាកម្មវត្ថុនៃការរៀបចំពិសេសសម្រាប់ប្រយោជន៍ទូទៅ ដូចជា៖

១-តំបន់ ។

២-កំពង់ផែ ។

៣-ស្ថានីយរថភ្លើង ។

៤-ផ្លូវដែក ។

៥-ព្រលានយន្តហោះ ។

គ-ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈតាមស្ថានភាពពីកំណើត ឬក្រោយពីបានរៀបចំ ដូចជា៖

១-ផ្លូវថ្នល់ ។

២-ផ្លូវលំ ។

៣-ផ្លូវរទេះ ។

៤-ផ្លូវដើរ ។

៥-សួនច្បារ ឧទ្យានសាធារណៈ ។

៦-ដីចំណី ។

ឃ-ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យដំណើរការសម្រាប់សេវាសាធារណៈ ដូចជា៖

១-សាលារៀន ឬអគារសិក្សាសាធារណៈ ។

២-អគាររដ្ឋបាល ។

៣-មន្ទីរពេទ្យសាធារណៈ ។

ង-ដែនបម្រុងធម្មជាតិការពារដោយច្បាប់ ។

ច-បេតិកភណ្ឌបុរាណវិទ្យា វប្បធម៌ និងប្រវត្តិសាស្ត្រ ។

ឆ-អចលនទ្រព្យជាព្រះរាជទ្រព្យ ដែលមិនមែនជាទ្រព្យសម្បត្តិឯកជនរបស់ព្រះរាជវង្សានុវង្ស ។

ជ-ដីផ្សេងៗទៀតដែលមានចរិតបម្រើផលប្រយោជន៍សាធារណៈ និងដីដែលមានមូលដ្ឋានគតិយុត្តកំណត់រួចហើយ ។

**២-ដីឯកជនរបស់រដ្ឋ**

ដីឯកជនរបស់រដ្ឋរួមមានដីទាំងអស់ដែលមិនមែនជាដីសាធារណៈរបស់រដ្ឋ និងមិនមែនជាដីដែលកាន់កាប់ជាភោគៈស្របច្បាប់ ឬជាកម្មសិទ្ធិដោយបុគ្គលឯកជន ឬដោយសមូហភាពស្របតាមច្បាប់ភូមិបាលឆ្នាំ២០០១ ។ ដីឯកជនរបស់រដ្ឋមានរួមបញ្ចូលដូចជាទ្រព្យនិទាយាទភាពទាំងអស់ ឬទ្រព្យដែលម្ចាស់ប្រគល់ឱ្យរដ្ឋដោយស្ម័គ្រចិត្ត ឬទ្រព្យដែលមិនអាចកំណត់បាននូវអត្តសញ្ញាណភោគី ឬកម្មសិទ្ធិស្របច្បាប់ ។

**II-លក្ខណវិនិច្ឆ័យ ឬស្តង់ដារសម្រាប់ការធ្វើចំណាត់ថ្នាក់ដីរដ្ឋ**

| ប្រភេទដីរដ្ឋ | បទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធ | លក្ខណវិនិច្ឆ័យ | យន្តការ |
|---|---|---|---|
| -ព្រៃឈើ | -រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មាត្រា៥៨ ចែងថាព្រៃឈើជា សម្បត្តិរបស់រដ្ឋ ។<br><br>-ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា១៥ចែងថាព្រៃឈើជាសម្បត្តិសាធារណៈរបស់រដ្ឋ ។<br><br>-អនុក្រឹត្យលេខ១១៨អនក្រ/បក ស្តីពីការគ្រប់គ្រងដីរដ្ឋ មាត្រា៤ ក៏បានចែងថាព្រៃឈើជាសម្បត្តិសាធារណៈរបស់រដ្ឋ ។<br><br>-ច្បាប់ស្តីពីព្រៃឈើឆ្នាំ២០០២ ដែលមានវិសាលភាពអនុវត្តលើរាល់ព្រៃឈើទាំងអស់ទោះជាប្រភេទព្រៃនោះ កើតឡើងដោយធម្មជាតិក្តី ឬដោយដាំក្តី ។ | -ដីក្រោមទម្រង់ជាដីសើម ដីលិចទឹក ឬដីស្ងួតដែលគ្របដណ្តប់ដោយរុក្ខចម្រុះទោះ បីជាដុះដោយធម្មជាតិក្តី ឬដោយដាំក្តី រួមទាំងធនធានសត្វព្រៃ និងធនធាន ធម្មជាតិដទៃទៀតដែលឋិតនៅក្នុងនោះដែលមានគោលបំណងប្រើប្រាស់សំខាន់ គឺផល អនុផលព្រៃឈើ ឬសេវាកម្មដែលផ្តល់ដោយព្រៃឈើក្រៅពីព្រៃឯកជន ។<br>-ឬដើមឈើតូចៗដែលដុះដោយធម្មជាតិ ជាផ្នែកមួយនៃតំបន់ព្រៃឈើ ត្រូវបានកាប់បំផ្លាញព្រៃឈើដោយមនុស្ស | -ផ្ទៃដីព្រៃទាំងអស់នឹងត្រូវកំណត់ព្រំប្រទល់ឱ្យបានច្បាស់លាស់ដោយយន្តការដែលមានកំណត់ក្នុងអនុក្រឹត្យលេខ១១៨ស្តីពីការគ្រប់គ្រងដីរដ្ឋ ត្រូវចុះពិនិត្យ និងកំណត់ឱ្យបានច្បាស់លាស់នូវព្រំប្រទល់ដីព្រៃឈើដោយប្រើប្រាស់រូបថតពីលើអាកាស អំពីគម្របព្រៃឈើដែលថតនៅឆ្នាំ២០០២ គួបផ្សំនឹងព័ត៌មានទាំងឡាយដែលទទួលបាននៅលើដីជាក់ |

| | | | |
|---|---|---|---|
| | -អនុក្រឹត្យលេខ៥៣អនក្រ/បក ស្តីពីនីតិវិធី ការបង្កើត ការចាត់តាំង និងការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍។<br><br>-សេចក្តីប្រកាសលេខ០១ប្រក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៩ ស្តីពីវិធានការគ្រប់គ្រង និងលុបបំបាត់ភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើ។<br><br>-សេចក្តីប្រកាសលេខ០៦ប្រក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីវិធានការលុបបំបាត់ភាពអនាធិបតេយ្យក្នុងបញ្ហាទន្ទ្រានកាន់កាប់ដី រដ្ឋ។<br><br>-បទបញ្ជាលេខ០១បប ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៤ ស្តីពីការទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការកាប់រាន ការដុត ការឈូសឆាយ និងហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើ។<br><br>-បទបញ្ជាលេខ០១បប ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាលស្តីពីការទប់ស្កាត់ការកាប់រានព្រៃឈើគ្រប់ប្រភេទរបស់រដ្ឋ យកមកធ្វើជាកម្មសិទ្ធិ។ | ឬដោយគ្រោះធម្មជាតិដែលនឹងក្លាយទៅជាព្រៃឈើ។<br>-ឬអតីតដីព្រៃឈើដែល កន្លងមកទទួលការកាប់បំផ្លាញព្រៃឈើដោយកត្តាមនុស្ស កត្តាធម្មជាតិដែលនឹងអាចស្តារគម្របព្រៃឈើឡើងវិញបាន។<br>-ព្រៃឈើរដ្ឋគ្រប់ដណ្តប់លើដីដែលមិនមែនជាកម្មសិទ្ធិឯកជន និងត្រូវបានចាត់ថ្នាក់ជាព្រៃផ្តល់ផលព្រៃការពារ និងផ្ទៃដីព្រៃសម្រាប់ផ្ទេរដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត។<br><br>-ចំពោះដីស្ថានីយ៍ស្រាវជ្រាវ និងមណ្ឌលអភិវឌ្ឍន៍ផ្សេងៗ ព្រមទាំងដីត្រៀមបម្រុងផ្សេងៗទៀត ដែលគ្រប់គ្រងដោយអង្គភាពនានា ក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវចាត់ថ្នាក់ជាដីឯកជនរបស់រដ្ឋ។ ចំពោះលក្ខណវិនិច្ឆ័យត្រូវចាត់ថ្នាក់ជាដីឯកជនរបស់រដ្ឋ។ ចំពោះលក្ខណវិនិច្ឆ័យត្រូវផ្អែក លើឯកសារ និងការកាន់កាប់ ជាក់ស្តែង នៃយន្តការគ្រប់គ្រងបច្ចុប្បន្នរបស់ក្រសួង | ស្តែង។<br>-ការសិក្សាកំណត់ត្រូវផ្អែកលើផែនការប្រើប្រាស់ដី ប្រសិនបើមាន។<br>-យន្តការដែលមនាចែងក្នុងអនុក្រឹត្យលេខ៥៣ អនក្រ/បក ស្តីពីនីតិវិធី ការបង្កើត ការចាត់ថ្នាក់ និងការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ មានសមត្ថកិច្ច និងភារកិច្ចក្នុងរង្វង់ព្រំប្រទល់ដីដែលត្រូវបានកំណត់ដោយយន្តការគ្រប់គ្រងដីរដ្ឋថាពិតជាដីព្រៃ ព្រមទាំងការកំណត់ដោយយន្តការគ្រប់គ្រងដីរដ្ឋថាពិតជាដីដែលត្រូវបានកំណត់ដោយ យន្តការគ្រប់គ្រងដីរដ្ឋ ថាពិតជាដីព្រៃ ព្រមទាំងការធ្វើចំណាត់ថ្នាក់ដីព្រៃ និងការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ (ដែលអាចចុះសេចក្តីនោះបន្ថែមនៅក្នុងសៀវភៅគោលបញ្ជីដីធ្លីផងដែរ)។ |

| | | | |
|---|---|---|---|
| | -លិខិតលេខ៥៨៤សជណ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៦ ស្ដីពីការសម្រេចកំណត់យកផែនទីគម្របព្រៃឈើឆ្នាំ ២០០២ ជាផែនទីគោលសម្រាប់ជាមូលដ្ឋាននៃការកំណត់ព្រំប្រទល់ដែនព្រៃឈើ។ | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ | |
| -ដែននេសាទព្រៃលិចទឹក និងព្រៃកោងកាង | -ច្បាប់ស្ដីពីជលផលឆ្នាំ២០០៦ ដែលមានវិសាលភាពគ្រប់គ្រងព្រៃលិចទឹក និងព្រៃកោងកាងដែលទាក់ទងនឹងវដ្ដជីវិតនៃធនធានជលផល។ ច្បាប់នេះចែងថា ដែននេសាទរួមមានដែនដីលិចទឹកអចិន្ត្រៃយ៍ ដែនដីដែលទទួលរបបទឹកទន្លេមេគង្គ និងដែនដីដែលទទួលរបប ទឹកជោរនាចនៃសមុទ្រដែលមានតួនាទីសំខាន់បម្រើឱ្យការនេសាទគ្រប់ប្រភេទ និងការការពារប្រព័ន្ធអេកូឡូស៊ីជលផល។ ដែនដីលិចទឹកអចិន្ត្រៃយ៍មានជាអាទិ៍ សមុទ្រ ទន្លេ ដៃទន្លេ បឹង ព្រែក អូរ អាងទឹក និងប្រឡាយ។ ដែនដីដែលទទួលរបបទឹកទន្លេមេគង្គមានជាអាទិ៍ ត្រពាំង រណ្ដៅ វាលភក់ ល្បាប់ វាលទំនាបដែលលិចទឹកក្នុងរដូវទឹកឡើង និងនាទីព្រៃលិចទឹក។ ដែនដីដែលទទួលរបបទឹកជោរ នាចនៃសមុទ្រមានជាអាទិ៍ នាទីព្រៃកោកាង។ | -នាទីព្រៃលិចទឹក និងនាទីព្រៃកោងកាងត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ។<br><br>-ដីបឹងនានាក្រៅពីបឹងធម្មជាតិដែលត្រូវបានកំណត់ជាផ្នែកមួយនៃឡូត៍នេសាទ ឬកន្លែងនេសាទដទៃទៀតដែលត្រូវបានកំណត់ថាជាទ្រព្យសម្បត្តិរបស់រដ្ឋ អនុលោមតាមក្រឹត្យ-ច្បាប់លេខ៣៣ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៨៧ និងប្រកាសរបស់ក្រសួងកសិកម្ម ស្ដីពីការកំណត់ព្រំប្រទល់នាទីឡូត៍នេសាទ និងកន្លែងនេសាទបម្រុង (មុនមានការកាន់កាប់ជាភោគៈស្រប ច្បាប់) ត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ។<br><br>-ដីក្នុងតំបន់ដែលត្រូវបានកំណត់ដោយអនុក្រឹត្យ ស្របតាមច្បាប់ | -ដែននេសាទទាំងអស់នឹងត្រូវកំណត់ព្រំប្រទល់ឱ្យបានច្បាស់លាស់ដោយយន្តការដែលមានកំណត់ក្នុងអនុក្រឹត្យលេខ១១៨ ស្ដីពីការគ្រប់គ្រងដីរដ្ឋ។<br><br>-យន្តការដែលបង្កើតឡើងដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសមត្ថកិច្ចធ្វើចំណាត់ថ្នាក់ដែននេសាទទាំងឡាយក្នុងរង្វង់ព្រំប្រទល់ដែននេសាទដែលត្រូវបានកំណត់ថាពិតជាដែននេសាទតាមមូលដ្ឋានគតិយុត្តជាធរមាន។ |

| | | | |
|---|---|---|---|
| | ដែននេសាទជាទ្រព្យសម្បត្តិរបស់រដ្ឋ។ ព្រំប្រទល់នៃដែននេសាទត្រូវកំណត់ដោយអនុក្រឹត្យ។ ការបង្កើត ការរំសាយតំបន់គ្រប់គ្រងជលផលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ នីតិវិធីនៃការបង្កើត ឬរំសាយតំបន់ជលផលត្រូវកំណត់ដោយអនុក្រឹត្យ។<br><br>ដែននេសាទអាចគ្របដណ្តប់លើដីសាធារណៈ ឬដីកម្មសិទ្ធិឯកជននារដូវទឹកឡើង ប៉ុន្តែការគ្រប់គ្រងជលផលមិនប៉ះពាល់ដល់ដីកម្មសិទ្ធិទាំងនោះឡើយ។ រាល់ការប្រើប្រាស់ដែននេសាទដើម្បីគោលបំណងក្រៅវិស័យជលផលត្រូវមានការសម្រេចពីរាជរដ្ឋាភិបាលតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ការផ្តល់កម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ដីធ្លីនៅក្នុងតំបន់គ្រប់គ្រងជលផលអាចប្រព្រឹត្តទៅបានលុះត្រាតែមានការសិក្សាវាយតម្លៃពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។<br><br>-ប្រកាសលេខ๐๐៦៧ប្រក/កសក ស្តីពីការកំណត់ នាទីព្រៃដែលជាដែននេសាទទឹកសាប និងសមុទ្រ។ | ស្តីពីជលផល ឆ្នាំ២០០៦ ដោយកាត់ចេញដី ដែលត្រូវបានកាន់កាប់ជាភោគៈស្របច្បាប់ ឬជាកម្មសិទ្ធិស្របច្បាប់ត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ។ | |

| | | | |
|---|---|---|---|
| -ភ្នំ | -រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មាត្រា៥៨ ចែងថាភ្នំជាសម្បត្តិរបស់រដ្ឋ។ ប៉ុន្តែមិនបានធ្វើចំណាត់ថ្នាក់ថាជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋឡើយ។ | -ភ្នំ ឬចំណែកណាមួយនៃភ្នំដែលមានជាប់ប្រយោជន៍សាធារណៈ ឬមានការប្រើប្រាស់ជាសាធារណៈត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ។<br>-ភ្នំ ឬចំណែកណាមួយនៃភ្នំដែលមិនមានជាប់ប្រយោជន៍សាធារណៈ ឬមិនមានការប្រើប្រាស់ជាសាធារណៈ ហើយមិនមានការកាន់កាប់ជាឯកជនស្របច្បាប់ ត្រូវចាត់ថ្នាក់ជាដីឯកជនរបស់រដ្ឋ។ | -យន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ១១៨ អនក្រ/បក ស្តីពីការគ្រប់គ្រងដីរដ្ឋត្រូវសិក្សា និងកំណត់ច្បាស់លាស់អំពីភ្នំ ឬចំណែកណាមួយនៃភ្នំដែលជាប់ប្រយោជន៍សាធារណៈ ឬមានការប្រើប្រាស់ជាសាធារណៈ ឬដែលមិនទាន់មានការកាន់កាប់ជាឯកជនស្របច្បាប់។<br>-ការសិក្សាកំណត់ខាងលើនេះក៏ត្រូវផ្អែកលើផែនការប្រើប្រាស់ដីប្រសិនបើមាន។ |
| -ត្រើយសមុទ្រ (Seashore)<br>-ឆ្នេរសមុទ្រ (Seaside) | -រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មាត្រា៥៨ ចែងថាសមុទ្រ បាតសមុទ្រ ក្រោមបាទសមុទ្រ ឆ្នេរសមុទ្រជាសម្បត្តិរបស់រដ្ឋ។ ប៉ុន្តែមិនមានបញ្ចូលពាក្យត្រើយសមុទ្រទេ។<br>-ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា១៥ចែងថាត្រើយសមុទ្រជាសម្បត្តិសាធារណៈរបស់រដ្ឋ។ ប៉ុន្តែមិនមានបញ្ចូលពាក្យថាឆ្នេរសមុទ្រទេ។ | -ត្រើយសមុទ្រក្នុងន័យនៃឯកសារលក្ខណវិនិច្ឆ័យនេះគឺជាផ្ទៃដីដែលឋិតនៅចន្លោះខ្សែបន្ទាត់ទឹកជោរ និងទឹកនាច។ ត្រើយសមុទ្រត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ។<br>-ឆ្នេរសមុទ្រដែលនៅជាប់ត្រើយសមុទ្រឡើងមកលើរហូតដល់ខ្សែបន្ទាត់ហាមឃាត់ការកាន់ | -ព្រំប្រទល់ត្រើយសមុទ្រ និងឆ្នេរសមុទ្រ គួរកំណត់ឱ្យបានច្បាស់លាស់ ដោយយន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ១១៨ អនក្រ/បក ស្តីពីការគ្រប់គ្រងដីរដ្ឋត្រូវចុះពិនិត្យ និងកំណត់ឱ្យបានច្បាស់លាស់នូវព្រំប្រទល់ត្រើយសមុទ្រដែលត្រូវកំណត់ |

| | | | |
|---|---|---|---|
| | -ច្បាប់ស្ដីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ឆ្នាំ១៩៩៤ មាត្រា១២ចែងថា ឆ្នេរ និងច្រាំងទន្លេ សមុទ្រ ព្រែក ស្ទឹង ជាទីធ្លាដែលមានលក្ខណៈជាសាធារណៈ ហើយត្រូវហាមឃាត់មិនឱ្យសាងសង់។ ប៉ុន្តែមិនមានការកំណត់ទំហំឆ្នេរទេ។ | កាប់ ឬសាងសង់នានា (Setback line) ហើយមានថ្ម ឬខ្សាច់ដែលគួរកំណត់ទុកជាតំបន់សម្រាប់ប្រើប្រាស់ជាសាធារណៈ ហើយចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ។<br>ចំពោះផ្នែកណាមួយនៃឆ្នេរសមុទ្រដែលគ្មានការកាន់កាប់ជាកម្មសិទ្ធិឯកជនស្របច្បាប់ ឬមានការចូលកាន់កាប់មិនស្របច្បាប់ក្រោយច្បាប់ភូមិបាលឆ្នាំ២០០១ចូលជាធរមាន គួរកំណត់តំបន់ឆ្នេរសមុទ្រដោយវាស់តាមខ្សែស្របនឹងផ្ទៃទឹកសមុទ្រ។<br>-ចំពោះឆ្នេរជម្រាល គួរកំណត់៣០ទៅ៥០ម៉ែត្រ ចាប់ពីខ្សែបន្ទាត់ទឹកជោរ (ដែលអាចមានស្មៅដុះ)។<br>-ចំពោះច្រាំចោទគួរកំណត់យកពី២០ទៅ៣០ម៉ែត្រ ចាប់រាប់ពីចំណុចកំពូលនៃផ្ទៃចោទ។ | ទុកជាដីសាធារណៈរបស់រដ្ឋ។<br>-ការសិក្សារកំណត់ខាងលើនេះក៏ត្រូវផ្អែកលើផែនការប្រើប្រាស់ដី ប្រសិនបើមាន។ |
| -កោះធំ កោះតូច និងដីដុះ | -រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មាត្រា៥៨ចែងថាកោះជាសម្បត្តិរបស់រដ្ឋ។ ប៉ុន្តែ មិនបានធ្វើចំណាត់ថ្នាក់ថាជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋឡើយ។<br>-ច្បាប់ភូមិបាលឆ្នាំ១៩៩២ មាត្រា | -កោះណាមួយ ឬផ្នែកខ្លះនៃកោះដែលបង្ហាញឱ្យឃើញថា មានប្រយោជន៍សាធារណៈ ឬមានការប្រើប្រាស់ជាសាធារណៈ ត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ ក្រៅពីនេះត្រូវចាត់ទុក | -យន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ១១៨ អនក្រ/បក ស្ដីពីការគ្រប់គ្រងដីរដ្ឋ ត្រូវសិក្សា និងកំណត់ច្បាស់លាស់ថា កោះណា ឬចំណែកនៃ |

| | | | |
|---|---|---|---|
| | ៣២ចែងថា កោះធំ កោះតូចទាំងឡាយ ដីដែលដុះក្នុងផ្ទៃទន្លេ ឬស្ទឹង ព្រែកដែលជាទីអាចដើរបាន អាចបណ្តែតនាវា ក្បូនបានត្រូវបានមករដ្ឋតាមបទបញ្ជាដែលមានជាធរមាន។<br>-មាត្រា៣៣ចែងថា កោះធំ កោះតូចទាំងឡាយ និងដីដុះក្នុងស្ទឹង ព្រែកមិនជាទីដើរ បណ្តែតនូវក្បូនទេត្រូវ បានទៅកម្មសិទ្ធិករដែលមានដីនៅនឹងមាត់ស្ទឹង មាត់ព្រែក ខាងកោះដុះនោះ បើកោះនោះមិនដុះជ្រុលទៅម្ខាងទេនោះត្រូវបានទៅកម្មសិទ្ធិករដែលមានដីនៅត្រើយទាំងពីរខាងយកតាមបន្ទាត់ដែលគេសន្មតថាពុះពាក់កណ្តាលស្ទឹងជាប្រមាណ។<br>-អនុក្រឹត្យលេខ៥៣អនក្រ/បក ឆ្នាំ១៩៩៥ មាត្រា២ចែងថា "ក្នុងន័យនេះដីដែលដុះចាស់ ឬថ្មីជាកោះនៅសមុទ្រ ទន្លេ ព្រែក ស្ទឹង បឹងបួទទាំងព្រះរាជាណាចក្រកម្ពុជាត្រូវប្រកាសជាទ្រព្យសម្បត្តិរបស់រដ្ឋ ហើយមិនអនុញ្ញាតឱ្យឯកជន ឬសមូហភាពប្រកាសជាកម្មសិទ្ធិផ្ទាល់ខ្លួនឡើយ។<br>-ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា១០២ចែងថាកោះធំ កោះតូចនិងដីដុះទាំងឡាយដែលនឹងកកើតថ្មីក្នុងផ្ទៃទន្លេ ឬស្ទឹង ព្រែកដែលនាវា ឬ | ដីឯកជនរបស់រដ្ឋ។<br>-កោះធំតូច ឬចំណែកនៃកោះដែលមានការចូលកាន់កាប់ជាភោគៈស្របច្បាប់មុនច្បាប់ភូមិបាលឆ្នាំ២០០១ ចូលជាធរមានអាចផ្តល់ជាកម្មសិទ្ធិឯកជន។<br>-ព្រំប្រទល់ដីកោះក្នុងសមុទ្រត្រូវកំណត់ត្រឹមខ្សែទឹកជោរឡើងលើ។<br>-ចំណែកឯកោះក្នុង ទន្លេ ស្ទឹង ព្រែកត្រូវកំណត់ត្រឹមកម្រិតទឹកនៅរដូវវស្សានៃឆ្នាំដែលធ្វើការកំណត់នោះ លើកលែងតែមានទឹកជំនន់ខុសធម្មតា។<br>-ដីចន្លោះខ្សែបន្ទាត់ទឹកនៅរដូវប្រាំង និងខ្សែបន្ទាត់ទឹកនៅរដូវវស្សានៃកោះអាចផ្តល់ការអនុញ្ញាតឱ្យប្រើប្រាសបណ្តោះអាសន្ន និងមិនទៀតតាមរយៈកិច្ចសន្យាច្បាស់លាស់។ | កោះណាមួយជារបស់រដ្ឋដែលមិនទាន់បានកាន់កាប់ដោយឯកជនស្របច្បាប់មុនច្បាប់ភូមិបាលឆ្នាំ២០០១ចូលជាធរមាន។<br>-ការសិក្សា កំណត់ខាងលើនេះក៏ត្រូវផ្អែកលើផែនការប្រើប្រាស់ដីប្រសិនបើមាន។ |

| | | | |
|---|---|---|---|
| | ក្បូនចេញចូលបានបណ្តែតបានជារបស់រដ្ឋ។ មាត្រា១០៣ ចែងថា កោះធំ កោះតូច និងដីដុះទាំងឡាយដែលនឹងកកើតថ្មីក្នុងស្ទឹង ព្រែកដែលនាវា ឬក្បូនចេញចូលមិនបាន បណ្តែតមិនបាន ត្រូវបានមកកម្មសិទ្ធិករនៃដីជាប់ច្រាំងដែលមានកោះ ឬដីដុះនោះ។ ប្រសិនបើការដុះនោះមិនបានដុះជ្រុលទៅច្រាំងម្ខាងទេនោះ ត្រូវបានទៅកម្មសិទ្ធិករដែលមានដីជាប់ច្រាំងទាំងសងខាងគិតពីបន្ទាត់ពុះពាក់កណ្តាលស្ទឹង។ | | |
| -ទន្លេ | -រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មាត្រា៥៨ បានចែងថាទន្លេជាសម្បត្តិរបស់រដ្ឋ។<br><br>-ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា១៥ចែងថាផ្លូវទឹកដែលនាវា ក្បូនចេញចូលបាន បណ្តែតបានជាសម្បត្តិសាធារណៈរបស់រដ្ឋ។ | -ទន្លេគឺជាផ្លូវទឹក ដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបានហើយដែលត្រូវបានកំណត់ថាជាទន្លេ។ នៅព្រះរាជាណាចក្រកម្ពុជាមានទន្លេទាំងអស់៧គឺ ទន្លេមេគង្គ ទន្លេសាប ទន្លេបាសាក់ ទន្លេសេកុង ទន្លេសេសាន ទន្លេស្រែពក និងទន្លេតូច។<br><br>-ដីទន្លេគឺជាដីដែលឋិតនៅចន្លោះច្រាំងទាំងសងខាងដែលមានទឹកជាប្រចាំនៅរដូវប្រាំង។ ដីទន្លេជាដីសាធារណៈរបស់រដ្ឋ។ តាមច្បាប់ភូមិបាលឆ្នាំ២០០១ ច្រាំងទន្លេត្រូវបានចាត់ទុកជា | -យន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ១១៨ អនក្រ/បក ស្តីពីការគ្រប់គ្រងដីរដ្ឋត្រូវសិក្សា និងកំណត់ច្បាស់លាស់អំពីព្រំប្រទល់ច្រាំងទន្លេ។<br><br>-ការសិក្សា កំណត់ខាងលើនេះក៏ត្រូវផ្អែកលើផែនការប្រើប្រាស់ដីប្រសិនបើមាន។ |

| | | | |
|---|---|---|---|
| | | សម្បត្តិសាធារណៈរបស់រដ្ឋ ដូចទន្លេដែរ ដូច្នេះមិនចាំបាច់ធ្វើការកំណត់ឱ្យច្បាស់នូវខ្សែបន្ទាត់ផ្នែកខាងលើនៃច្រាំងទន្លេ។ | |
| -ច្រាំងទន្លេ | -ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា១៥ ចាត់ទុកច្រាំងទន្លេ ជាសម្បត្តិសាធារណៈរបស់រដ្ឋ។<br><br>-ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ឆ្នាំ១៩៩៤ មាត្រា១២ ចែងថាឆ្នេរ និងច្រាំងទន្លេ សមុទ្រ ព្រែក ស្ទឹង ជាទីធ្លាដែលមានលក្ខណៈជាសាធារណៈ ហើយត្រូវហាមឃាត់មិនឱ្យសាងសង់ ប៉ុន្តែមិនមានការកំណត់ទំហំឆ្នេរទេ។<br><br>-គ្មានច្បាប់ ឬលិខិតបទដ្ឋានណាមួយបានកំណត់ថាត្រូវមានដីចំណីទន្លេ ចំណីព្រែក ឬចំណីស្ទឹងទេ។ | -ច្រាំងទន្លេជាដីសាធារណៈរបស់រដ្ឋ។<br><br>-ច្រាំងទន្លេជាផ្នែកនៃដីដែលនៅចន្លោះខ្សែបន្ទាត់នៃកម្រិតទឹកទាបបំផុតនៅរដូវប្រាំង និងខ្សែបន្ទាត់កម្រិតទឹកខ្ពស់បំផុតនៅរដូវវស្សានៃឆ្នាំកំណត់ព្រំប្រទល់នោះ លើកលែងករណីឆ្នាំដែលមានទឹកជំនន់ខុសធម្មតា។ | -យន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ១១៨ អនក្រ/បក ស្តីពីការគ្រប់គ្រងដីរដ្ឋត្រូវសិក្សា និងកំណត់ ច្បាស់លាស់អំពីព្រំប្រទល់ច្រាំងទន្លេ។<br><br>-ការសិក្សា កំណត់ខាងលើនេះក៏ត្រូវផ្អែកលើផែនការប្រើប្រាស់ដីប្រសិនបើមាន។ |
| -ផ្លូវទឹកដែលនាវា ឬក្បូនចេញចូលបានបណ្តែតបាន (ក្រៅពីទន្លេ) | -ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា១៥ ចែងថាផ្លូវទឹកដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបានត្រូវចាត់ទុកជាសម្បត្តិសាធារណៈរបស់រដ្ឋ។ មាត្រា២២៧ចែងថា "ក្បាលដី ឬឯកតាសុរិយោដីគឺជាផ្ទៃដីមួយជាកំណត់ជាក់លាក់ឋិតនៅក្នុងឃុំ ឬសង្កាត់តែមួយមិនពុះបំបែកដោយព្រំជាប់មិនដាច់ជារបស់ជនម្នាក់ ឬច្រើននាក់ក្នុង | -ដីផ្លូវទឹកដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបាន (ក្រៅពីទន្លេ) ត្រូវចាត់ទុកជាដីសាធារណៈរបស់រដ្ឋ។<br><br>-ទទឹងផ្លូវទឹកដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបានត្រូវកំណត់យកត្រឹមខ្សែបន្ទាត់កម្រិតទឹកខ្ពស់បំផុតទាំងសងខាងនៅ | -យន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ១១៨ អនក្រ/បក ស្តីពីការគ្រប់គ្រងដីរដ្ឋត្រូវសិក្សា និងកំណត់ច្បាស់លាស់អំពីផ្លូវទឹកទាំងឡាយ និងព្រំប្រទល់ដី ផ្លូវទឹកដែលត្រូវចាត់ថ្នាក់ថាជាដីសាធារណៈរបស់រដ្ឋ។ |

| | | | |
|---|---|---|---|
| | ករណើអវិភាគកម្ម ហើយប្រើប្រាស់ក្នុងរូបភាពតែមួយ។ ចាត់ទុកជាព្រំជាប់មិនដាច់ដែលនាំឱ្យបំបែកក្បាលដីជាច្រើនក្បាលគឺរបងផ្លូវសាធារណៈ ប្រឡាយ និងផ្លូវទឹកដែលមានទទឹងយ៉ាងតិចពីរម៉ែត្រ។<br>-ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ឆ្នាំ១៩៩៤ មាត្រា១២ និងច្បាប់ភូមិបាលឆ្នាំ១៩៩២ មាត្រា២១៧ចែងថាទន្លេ ដៃទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយដែលបណ្តែតក្បូនបាន ឬមិនបាន ប្រឡាយបង្ហូរទឹកចេញចូលត្រូវចាត់ ចូលជាសម្បត្តិសាធារណៈទាំងអស់។ | រដូវវស្សា លើកលែងតែមានទឹកជំនន់ខុសធម្មតា។<br><br>-ដីផ្លូវទឹកដែលនាវា ឬក្បូនចេញចូលមិនបាន បណ្តែតមិនបាន ត្រូវចាត់ទុកជាដីឯកជនរបស់រដ្ឋ។<br><br>-ប្រសិនបើទទឹងផ្លូវទឹកនោះមានទំហំតិចជាង២ម៉ែត្រ អាចចុះបញ្ជីដីផ្លូវទឹកនោះជាចំណែកនៃក្បាលដីឯកជនបាន។ ប៉ុន្តែអាចមានបន្ទុកសេវភាពចំពោះផ្លូវទឹកនោះប្រសិនបើក្បាលដីនោះជាកម្មសិទ្ធិឯកជន។ | -ការសិក្សាកំណត់ខាងលើនេះត្រូវផ្អែកលើផែនការប្រើប្រាស់ដីប្រសិនបើមាន។ |
| -បឹងធម្មជាតិ | -រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មាត្រា៥៨ចែងថាបឹងជាសម្បត្តិរបស់រដ្ឋ។<br><br>-ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា១៥ចែងថាបឹងធម្មជាតិ ជាសម្បត្តិសាធារណៈរបស់រដ្ឋ។ ប៉ុន្តែ គ្មានច្បាប់ ឬលិខិតបទដ្ឋានណាមួយដែលកំណត់អំពីចំណើបឹងទេ។ | -តួបឹងធម្មជាតិជាដីសាធារណៈរបស់រដ្ឋ ហើយត្រូវកំណត់យកត្រឹមខ្សែបន្ទាត់កម្រិតទឹកនៅរដូវប្រាំងនៃឆ្នាំកំណត់ព្រំប្រទល់បឹង លើកលែងឆ្នាំមានភាពរាំងស្ងួត។<br><br>-ដីដែលឋិតនៅចន្លោះខ្សែបន្ទាត់កម្រិតទឹកទាបបំផុតនៅរដូវប្រាំង និងខ្សែបន្ទាត់កម្រិតទឹកខ្ពស់បំផុតនៅរដូវវស្សា ចាត់ទុកជាដីឯកជនរបស់រដ្ឋ លើកលែងតែចំណែកណានៃផ្ទៃដីនោះ | -យន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ១១៨ អនក្រ/បក ស្តីពីការគ្រប់គ្រងដីរដ្ឋត្រូវសិក្សា និងកំណត់ច្បាស់លាស់អំពីបឹងធម្មជាតិ និងព្រំប្រទល់បឹង។<br><br>-ការសិក្សា កំណត់ខាងលើនេះត្រូវផ្អែកលើផែនការប្រើប្រាស់ដីប្រសិនបើមាន។ |

| | | | |
|---|---|---|---|
| | | ដែលបង្ហាញថាមានប្រយោជន៍សាធារណៈ ឬការប្រើប្រាស់ជាសាធារណៈដែលត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ។ | |
| -តំរហ៊ាន<br>-កំពង់ផែ | -ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា១៥ចែងថា តំរហ៊ាន និងកំពង់ផែដែលរៀបចំពិសេសសម្រាប់ប្រយោជន៍សាធារណៈរបស់រដ្ឋ។ | -ដីតំរហ៊ាន ឬកំពង់ផែដែលរៀបចំពិសេសសម្រាប់ប្រយោជន៍ទូទៅត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ ហើយទំហំដីត្រូវកំណត់តាមប្លង់តំរហ៊ាន ឬប្លង់កំពង់ផែដែលបានអនុម័តជាផ្លូវការ។<br><br>-ដីតំរហ៊ាន ឬដីកំពង់ផែដែលមិនបានរៀបចំពិសេសសម្រាប់ប្រយោជន៍ទូទៅអាចឋិតនៅលើដីឯកជនរបស់រដ្ឋ លើដីសម្បទាន ឬនៅលើដីកម្មសិទ្ធិរបស់បុគ្គលឯកជនដែលត្រូវកំណត់តាមករណីជាក់ស្តែងនីមួយៗ។ | -យន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ១១៨ ស្តីពីការគ្រប់គ្រងដីរដ្ឋ និងដោយមានការចូលរួមផងដែរពីតំណាងអាជ្ញាធរកំពង់ផែ ត្រូវសិក្សា និងកំណត់ច្បាស់លាស់អំពីព្រំប្រទល់តំរហ៊ាន និងកំពង់ផែដែលត្រូវចាត់ថ្នាក់ថាជាដីសាធារណៈរបស់រដ្ឋ។<br><br>-ការសិក្សា កំណត់ខាងលើនេះត្រូវផ្អែកលើផែនការប្រើប្រាស់ដីប្រសិនបើមាន។ |
| -ផ្លូវដែក ស្ថានីយរថភ្លើង និងដីចំណើផ្លូវដែក | -ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា១៥ ចែងថាផ្លូវដែក ស្ថានីយរថភ្លើងដែលរៀបចំពិសេសសម្រាប់ប្រយោជន៍ទូទៅ និងដីចំណើជាសម្បត្តិសាធារណៈរបស់រដ្ឋ។ មាត្រា១៤៨ចែងថា ការកំណត់ព្រំដី និងកម្មសិទ្ធិដែលឋិតនៅតាមបណ្តោយផ្លូវសាធា | -ដីផ្លូវដែក ដីស្ថានីយរថភ្លើងនិងដីចំណើផ្លូវដែកជាដីសាធារណៈ របស់រដ្ឋ។<br>-ដីចំណើផ្លូវដែកត្រូវបានកំណត់ដូចតទៅ៖<br>+ទំហំ២០ម៉ែត្រពីសងខាងអ័ក្សផ្លូវចំពោះទីក្រុង ទីរួមខេត្ត | -យន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ១១៨ អនក្រ/បក ស្តីពីការគ្រប់គ្រងដីរដ្ឋ ត្រូវសិក្សា និងកំណត់ច្បាស់លាស់អំពីដីផ្លូវដែក ឬដីចំណើផ្លូវដែក និងស្ថានីយរថភ្លើង |

| | | | |
|---|---|---|---|
| | រណៈត្រូវកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច យោងតាមសេចក្តីត្រូវការជាក់ស្តែងនៃផលប្រយោជន៍រួម ពិសេសតាមសេចក្តីត្រូវការនៃការធ្វើចរាចរ...។ នៅពេលដែលអាជ្ញាធរធ្វើការសម្រេចពង្រីកទំហំផ្លូវ សំណង់ទាំងឡាយដែលឋិតនៅលើបន្ទាត់តម្រង់ជួរ ត្រូវបន្ថយទៅក្រោយ។ បើជារបងធម្មតា ឬជាសំណង់ស្រាល អាជ្ញាធរតម្រូវឱ្យធ្វើការរំកិលចេញ។ ប្រសិនបើជាអចលនវត្ថុដែលមិនអាចជាកម្មវត្ថុនៃការផ្លាស់ប្តូរ កែសម្រួលរុះរើបាន អចលនវត្ថុនោះត្រូវឋិតក្នុងសភាពដដែលសិន រហូតដល់ពេលអាជ្ញាធរមានសមត្ថកិច្ចសម្រេចអំពីការពង្រីកដែលបានគ្រោងទុក។ ការដកហូតកម្មសិទ្ធិមួយចំណែក ឬទាំងស្រុងអាចប្រព្រឹត្តទៅបានដោយអនុវត្តត្រឹមត្រូវតាមនីតិវិធីនៃច្បាប់។ ចំពោះដីដែលបានកាន់កាប់ស្របច្បាប់ ព្រមទាំងរបង និងសំណង់ទាំងឡាយដែលបានធ្វើឡើងត្រឹមត្រូវតាមបញ្ញត្តិច្បាប់ម្ចាស់កម្មសិទ្ធិមានសិទ្ធិទាមទារឱ្យសងការខូចខាតរបស់ខ្លួន។<br><br>-ច្បាប់ស្តីពីការរៀចំទឹកដី នគរូបនីយកម្ម និងសំណង់ឆ្នាំ១៩៩៤ មាត្រា | និងទីប្រជុំជន<br>+ទំហំ៣០ម៉ែត្រពីសងខាងអ័ក្សផ្លូវចំពោះផ្លូវដែកដែលឋិតនៅក្រៅក្រុង។<br>+ទំហំ១០០ម៉ែត្រពីសងខាងអ័ក្សផ្លូវចំពោះផ្លូវដែកដែលនៅតំបន់ព្រៃភ្នំដែលមានថ្មរមាលធ្លាក់ ឬតំបន់ព្រៃខ្ពស់។<br><br>-ទំហំដីនៃស្ថានីយរថភ្លើងត្រូវកំណត់តាមប្លង់នៃស្ថានីយដែលបានអនុម័តផ្លូវការ។<br>-ដីបម្រុងខុសពីដីចំណីផ្លូវ។ ចំពោះដីបម្រុងទុកធ្វើផ្លូវរថភ្លើង ឬស្ថានីយរថភ្លើងត្រូវអនុវត្តតាមមាត្រា១៤៨នៃច្បាប់ភូមិបាលឆ្នាំ២០០១។<br><br>-គួរកំណត់លក្ខណវិនិច្ឆ័យសម្រាប់កំណត់តំបន់ទីប្រជុំជន ទីរួមខេត្ត និងទីក្រុងឱ្យបានច្បាស់លាស់។ | ទាំងឡាយ ដែលត្រូវចាត់ថ្នាក់ថាជាដីសាធារណៈរបស់រដ្ឋ។<br><br>-ក្រុមប្រឹក្សាគោលនយោបាយដីធ្លី គួរស្វែងរកការ ឯកភាពគ្នាក្នុងការកំណត់ វិសាលភាពទីប្រជុំជន ទីរួមខេត្ត និងទីក្រុងឱ្យបានច្បាស់លាស់ សម្រាប់គោល បំណងនៃការចុះបញ្ជីដី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ។<br><br>-យន្តការដីរដ្ឋត្រូវរៀបចំការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋក្នុងមូលដ្ឋានដើម្បីកំណត់ព្រំប្រទល់ជាក់ស្តែងនៅលើដីនៃទីប្រជុំជន ទីរួមខេត្ត ទីក្រុង និងតំបន់ព្រៃភ្នំដែលមានថ្មរមាលធ្លាក់ ឬតំបន់ព្រៃខ្ពស់។<br><br>-ការសិក្សា កំណត់ខាងលើនេះត្រូវផ្អែកលើផែនការប្រើប្រាស់ដី ប្រសិនបើមាន។ |

| | | | |
|---|---|---|---|
| | ១២ និងច្បាប់ភូមិបាលឆ្នាំ១៩៩២ មាត្រា៥ចែងថា ដីបម្រុង និងដីចំណីសម្រាប់ផ្លូវដែក ឬផ្លូវរថភ្លើងត្រូវចាត់ទុកជាសម្បត្តិសាធារណៈ ។<br><br>-សេចក្តីប្រកាសលេខ០៦ប្រក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៩៤ ស្តីពីវិធានការលុបបំបាត់ភាពអនាធិបតេយ្យក្នុងបញ្ហាទន្ទ្រានកាន់កាប់ដីរដ្ឋ ។ | | |
| -ព្រលានយន្តហោះ | -ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា១៥ចែងថាព្រលានយន្តហោះដែលរៀបចំពិសេសសម្រាប់ប្រយោជន៍ទូទៅចាត់ទុកជាសម្បត្តិសាធារណៈរបស់រដ្ឋ ។<br><br>-ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ឆ្នាំ១៩៩៤ មាត្រា១២ ចែងថាដីបម្រុងទុកសម្រាប់អាកាសយានដ្ឋានជាទីធ្លាដែលមានលក្ខណៈជាសាធារណៈ ។ | -ដីព្រលានយន្តហោះដែលរៀបចំពិសេសសម្រាប់ប្រយោជន៍ទូទៅចាត់ទុកជាដីសាធារណៈរបស់រដ្ឋ ។ ប៉ុន្តែបើមិនបានរៀបចំពិសេសទុកសម្រាប់ប្រយោជន៍ទូទៅទេនោះ អាចជាដីឯកជនរបស់រដ្ឋ ។ | -យន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ១១៨ អនក្រ/បកស្តីពីការគ្រប់គ្រងដីរដ្ឋដោយមានការចូលរួមផងដែរពីតំណាងអាកាសចរស៊ីវិលត្រូវសិក្សា និងកំណត់ច្បាស់លាស់អំពីដីព្រលានយន្តហោះ និងដីបម្រុងទុកសម្រាប់ធ្វើអាកាសយានដ្ឋានដែលត្រូវចាត់ថ្នាក់ថាជាដីសាធារណៈរបស់រដ្ឋ ។<br>-ការសិក្សា កំណត់ខាងលើត្រូវផ្អែកលើផែនការប្រើប្រាស់ដីប្រសិនបើមាន ។ |
| -ផ្លូវថ្នល់ (ផ្លូវជាតិ ផ្លូវខេត្ត និងផ្លូវឃុំ) និង | -ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា១៥ចែងថា ផ្លូវថ្នល់ដែលត្រូវបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈ និង | -ផ្លូវថ្នល់មានបីប្រភេទគឺ ផ្លូវជាតិ ផ្លូវខេត្ត និងផ្លូវឃុំ។ ផ្លូវថ្នល់ និងដីចំណីផ្លូវថ្នល់ ជាដីសា | -ចំពោះតំបន់ទីប្រជុំជនទីរួមខេត្ត-ក្រុង ទីក្រុង និងដីចំណីផ្លូវថ្នល់ទាំងឡាយ |

| | | | |
|---|---|---|---|
| ដីចំណីផ្លូវ | ដីចំណីផ្លូវត្រូវចាត់ទុកជាសម្បត្តិសាធារណៈរបស់រដ្ឋ។ មាត្រា១៤៨ ចែងថាការកំណត់ព្រំដី និងកម្មសិទ្ធិដែលឋិតនៅតាមបណ្តោយផ្លូវសាធារណៈត្រូវកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច យោងតាមសេចក្តីត្រូវការជាក់ស្តែងនៃផលប្រយោជន៍រួម ពិសេសតាមសេចក្តីត្រូវការនៃការធ្វើចរាចរ...។ នៅពេលដែលអាជ្ញាធរធ្វើការសម្រេចពង្រីកទំហំផ្លូវ សំណង់ទាំងឡាយដែលឋិតនៅលើបន្ទាត់តម្រង់ជួរត្រូវទៅក្រោយ។ បើជារបងធម្មតា ឬជាសំណង់ស្រាលអាជ្ញាធរតម្រូវឱ្យធ្វើការរំកិលចេញ។ ប្រសិនបើជាអចលនវត្ថុដែលមិនអាចជាកម្មវត្ថុនៃការផ្លាស់ប្តូរកែសម្រួលរុះរើបាន អចលនវត្ថុនោះត្រូវក្នុងសភាពដដែលសិន រហូតដល់ពេលអាជ្ញាធរមានសមត្ថកិច្ចសម្រេចអំពីការពង្រីកដែលបានគ្រោងទុក។ ការដកហូតកម្មសិទ្ធិមួយចំណែក ឬទាំងស្រុងអាចប្រព្រឹត្តទៅបានដោយអនុវត្តត្រឹមត្រូវតាមនីតិវិធីនៃច្បាប់។ ចំពោះដីដែលបានកាន់កាប់ស្របច្បាប់ព្រមទាំងរបង និងសំណង់ទាំងឡាយដែលបានធ្វើឡើងត្រឹមត្រូវតាមបញ្ញត្តិនៃច្បាប់ ម្ចាស់កម្មសិទ្ធិ | ធារណៈរបស់រដ្ឋ។<br>-ផ្លូវក្នុងទីក្រុង ទីរួមខេត្ត ទីរួមស្រុក មិនចាំបាច់មានដីចំណីទេ ប៉ុន្តែត្រូវមានចិញ្ចើមផ្លូវ។ ដីផ្លូវនិងចិញ្ចើមផ្លូវទាំងនេះក៏ជាដីសាធារណៈរបស់រដ្ឋដែរ។<br><br>-សម្រាប់គោលបំណងនៃការចុះបញ្ជីដីធ្លី ផ្លូវថ្នល់ត្រូវបានកំណត់និយមន័យដូចតទៅ៖<br>-ផ្លូវជាតិគឺសំដៅដល់ផ្លូវថ្នល់ទាំងឡាយដែលអាជ្ញាធរមានសមត្ថកិច្ចបានប្រកាស ឬកំណត់ថាជាផ្លូវជាតិ។ ជាទូទៅផ្លូវជាតិគឺជា៖<br>១-ផ្លូវដែលតភ្ជាប់ពីរាជធានីទៅទីរួមខេត្ត និងព្រំដែនអន្តរជាតិ<br>២-ផ្លូវដែលតភ្ជាប់ពីទីរួមខេត្តមួយទៅទីរួមខេត្តមួយទៀត និងទៅព្រំដែនអន្តរជាតិ។<br>-ផ្លូវខេត្តគឺជា៖<br>១-ផ្លូវដែលតភ្ជាប់ពីទីរួមស្រុកមួយទៅទីរួមស្រុកមួយទៀត<br>២-ផ្លូវដែលតភ្ជាប់ពីទីរួមស្រុកមួយទៅទីរួមខេត្ត ឬរាជធានី<br>៣-ផ្លូវដែលតភ្ជាប់ពីផ្លូវជាតិមួយទៅផ្លូវជាតិមួយទៀត<br>៤-ផ្លូវដែលតភ្ជាប់ពីផ្លូវជាតិ | ដែលត្រូវចាត់ថ្នាក់ថាជាដីសាធារណៈរបស់រដ្ឋ។ ទន្ទឹមនេះយន្តការខាងលើអាចលើកអនុសាសន៍ផងដែរក្នុងករណីដែលពិនិត្យឃើញថាអាចមានផលប៉ះពាល់សង្គមតិចតួច ឬក្នុងកម្រិតដែលរដ្ឋអាចមានលទ្ធភាពសងសំណងចំពោះការដកហូតសិទ្ធលើទ្រព្យ និងតាមលទ្ធភាពរៀបចំការផ្លាស់ប្តូរទីតាំង ឬតាំងទីលំនៅថ្មី សមស្របសម្រាប់អ្នកដែលត្រូវបង្ខំឱ្យចាកចេញពីដីផ្លូវ ឬដីចំណីផ្លូវនោះ។<br><br>-ក្នុងតំបន់ដែលមិនមែនជាទីប្រជុំជន ទីរួមខេត្តទីក្រុងគឺអាចអនុវត្តតាមប្រកាសលេខ០៦ប្រក ឆ្នាំ១៩៩៩ តែត្រូវមានសំណងចំពោះការដកហូតសិទ្ធិនានាលើដីដល់ប្រជាពលរដ្ឋដែលបានកាន់កាប់ដីដោយស្របច្បាប់ភូមិបាលឆ្នាំ១៩៩២ មុន |

| | | | |
|---|---|---|---|
| | មានសិទ្ធិទាមទារឱ្យសងការខូចខាតរបស់ខ្លួន។<br><br>-ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ឆ្នាំ១៩៩៤ មាត្រា ១២ ចែងថាដីបម្រុងទុកសម្រាប់ផ្លូវជាទីធ្លាដែលមានលក្ខណៈជាសាធារណៈ។<br><br>-សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលលេខ០៦ប្រក ឆ្នាំ១៩៩៩ស្តីពីវិធានការលុបបំបាត់ភាពអនាធិបតេយ្យក្នុងបញ្ហាទន្ទ្រានកាន់កាប់ដីធ្លី។ | មួយទៅទីរួមខេត្ត។<br><br>-ផ្លូវឃុំគឺជា៖<br>១-ផ្លូវដែលតភ្ជាប់ពីស្រុកមួយទៅស្រុកមួយទៀត<br>២-ផ្លូវដែលតភ្ជាប់ពីស្រុកមួយទៅឃុំមួយ<br>៣-ផ្លូវដែលតភ្ជាប់ពីស្រុកមួយទៅឃុំមួយទៀត។<br><br>ដីចំណីផ្លូវថ្នល់ត្រូវបានកំណត់ដូចតទៅ៖<br>-ផ្លូវជាតិលេខ១, ៤, ៥ កំណត់ទំហំ៣០ម៉ែត្រពីសងខាងអ័ក្សផ្លូវ។<br>-ផ្លូវជាតិលេខ១ខ្ទង់ដូចជាលេខ ២, ៣, ៦, ៧ កំណត់ទំហំ២៥ម៉ែត្រពីសងខាងអ័ក្សផ្លូវ។<br>-ផ្លូវជាតិលេខ២ខ្ទង់មានជាអាទិ៍លេខ១១, ២២, ៦៤, ៧៨ កំកំណត់ទំហំ២៥ម៉ែត្រពីសងខាងអ័ក្សផ្លូវ។<br>-ផ្លូវខេត្តកំណត់ទំហំ២០ម៉ែត្រពីសងខាងអ័ក្សផ្លូវ។<br>-ផ្លូវឃុំកំណត់ទំហំ១៥ម៉ែត្រពីសងខាងអ័ក្សផ្លូវ។<br>-ចំពោះតំបន់ទីប្រជុំជន ទីរួមខេត្ត ទីក្រុង ការកំណត់ដីចំណី | ការចេញសេចក្តីប្រកាសខាងលើ ហើយក៏ត្រូវយកចិត្តទុកដាក់ដល់សំណងចំពោះការដកហូតសិទ្ធិលើទ្រព្យ និងលទ្ធភាពរៀបចំការផ្លាស់ប្តូរទីតាំង ឬការតាំងទីលំនៅថ្មីសមស្របសម្រាប់អ្នកដែលត្រូវបង្ខំឱ្យចាកចេញពីដីផ្លូវ ឬចំណីផ្លូវនោះ។<br><br>-ក្រុមប្រឹក្សាគោលនយោបាយដីធ្លីគួរស្វែងរកការឯកភាពគ្នាក្នុងការកំណត់វិសាលភាពទីប្រជុំជន ទីរួមខេត្ត និងទីក្រុងឱ្យបានច្បាស់លាស់សម្រាប់គោលបំណងនៃការចុះបញ្ជីដី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ។<br><br>-យន្តការដីរដ្ឋត្រូវរៀបចំធ្វើការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋក្នុងមូលដ្ឋាន ដើម្បីកំណត់ព្រំប្រទល់ជាក់ស្តែងនៅលើដីនៃទីប្រជុំជន ទីរួមខេត្តទីក្រុង និងលើកសំណើជូន |

| | | | |
|---|---|---|---|
| | | ផ្លូវខាងលើនេះមិនយកមកអនុវត្តទេ។<br>-គួរកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់កំណត់តំបន់ទីប្រជុំជនទីរួមខេត្ត ទីក្រុងឱ្យបានច្បាស់លាស់។<br>-ការផ្លាស់ប្តូរទំហំផ្លូវត្រូវអនុវត្តតាមមាត្រា១៤៨នៃច្បាប់ភូមិបាល។ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់អំពីទំហំសមស្របជាក់លាក់សម្រាប់កំណត់ដីចំណើផ្លូវថ្នល់ក្នុងតំបន់ទីប្រជុំជន ទីរួមខេត្ត ទីក្រុងនីមួយៗតាមស្ថានភាពជាក់ស្តែង និងសេចក្តីត្រូវការក្នុងមូលដ្ឋាន។<br>-ការសិក្សា កំណត់ខាងលើត្រូវផ្អែកលើផែនការប្រើប្រាស់ដីប្រសិនបើមាន។ |
| -ផ្លូវលំ<br>ផ្លូវរទេះ<br>ផ្លូវដើរ | -ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា១៥ ចែងថាផ្លូវលំ ផ្លូវរទេះ ផ្លូវដើរដែលត្រូវបានដាក់ឱ្យប្រើជាសាធារណៈ ត្រូវចាត់ទុកជាសម្បត្តិសាធារណៈរបស់រដ្ឋ។<br>-គ្មាននិយមន័យ និងគ្មានលិខិតបទដ្ឋានណាមួយកំណត់អំពីទំហំផ្លូវលំ ផ្លូវទោះ និងផ្លូវដើរទេ។ | -ដីផ្លូវលំ ផ្លូវរទេះ និងផ្លូវដើរជាដីសាធារណៈរបស់រដ្ឋ។<br>-ផ្លូវលំគឺជាផ្លូវដែលតភ្ជាប់ពីភូមិមួយទៅភូមិមួយ ឬច្រើនក្នុងឃុំតែមួយដែលអាចបើករថយន្តបាន។<br>-ផ្លូវរទេះគឺកំណត់យកផ្លូវដែលអ្នកស្រុកជាច្រើនក្នុងភូមិ ឬឃុំបាននិងកំពុងប្រើប្រាស់សម្រាប់បររទេះធ្វើដំណើរទៅមកជាញឹកញាប់។<br>-ផ្លូវដើរគឺជាផ្លូវដែលតភ្ជាប់ពីប្លុកផ្ទះមួយទៅប្លុកផ្ទះមួយក្នុងភូមិតែមួយ ឬផ្លូវភ្លឺព្រែក ឬទំនប់ | -យន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ១១៨ អនក្រ/បក ស្តីពីការគ្រប់គ្រងដីរដ្ឋដែលមានការចូលរួមផងដែរពីក្រុមប្រឹក្សាឃុំ-សង្កាត់គួរពិនិត្យ និងកំណត់តាមករណីជាក់ស្តែងនីមួយៗដោយថ្លឹងថ្លែងការប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍភូមិ-ឃុំ។<br>-ការសិក្សា កំណត់ខាងលើនេះក៏ត្រូវផ្អែកលើ |

| | | | |
|---|---|---|---|
| | | ប្រឡាយដែលយ៉ាងច្រើនបំផុតអាចជិះបានត្រឹមម៉ូតូ ឬកង់។<br>-ផ្លូវលំ ផ្លូវរទេះ និងផ្លូវដើរមិនចាំបាច់មានដីចំណីផ្លូវទេ។ ប៉ុន្តែគួរកំណត់ទំហំផ្លូវទៅនោះតាមការព្រមព្រៀងទូទៅរបស់អ្នកភូមិភាគច្រើន ដូចខាងក្រោម៖<br>+ផ្លូវលំ៖ ៤-៦ម៉ែត្រ<br>+ផ្លូវរទេះ៖ ៣-៤ម៉ែត្រ<br>+ផ្លូវដើរ៖ ១-២ម៉ែត្រ | ផែនការប្រើប្រាស់ដីប្រសិនបើមាន។ |
| -សួនច្បារ និងឧទ្យានសាធារណៈ | -ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា១៥រាប់បញ្ចូលទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈ តាមស្ថានភាពពីកំណើត ឬក្រោយពីបានរៀបចំ ដូចជាសួនច្បារ និងឧទ្យានសាធារណៈជាសម្បត្តិសាធារណៈរបស់រដ្ឋ។<br>-ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ឆ្នាំ១៩៩៤ មាត្រា១២ចែងថាសួនច្បារ ឧទ្យានសាធារណៈ និងតំបន់អភិវឌ្ឍន៍ជាទីធ្លាមានលក្ខណៈសាធារណៈ។ | -សួនច្បារ និងឧទ្យានសាធារណៈជាដីសាធារណៈរបស់រដ្ឋ។<br>-សួនច្បារ និងឧទ្យានសាធារណៈមិនមានន័យដូចគ្នានឹងឧទ្យាជាតិ ដែលកំណត់ដោយព្រះរាជក្រឹត្យស្តីពីការកំណត់ និងការបង្កើតតំបន់ការពារធម្មជាតិនោះទេ។ | -យន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ១១៨ អនក្រ/បក ស្តីពីការគ្រប់គ្រងដីរដ្ឋ ត្រូវសិក្សា និងកំណត់សួនច្បារ និងឧទ្យានសាធារណៈទាំងឡាយដែលជាសម្បត្តិសាធារណៈរបស់រដ្ឋ។ |
| -សាលារៀន អគារសិក្សាសាធារណៈ អគាររដ្ឋបាល | -ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា១៥ចាត់ទុកសាលារៀន ឬអគារសិក្សាសាធារណៈ អគាររដ្ឋបាល និងមន្ទីរពេទ្យដែលត្រូវបានដាក់ | -ដីសាលារៀន ឬអគារសិក្សាសាធារណៈ ដីអគាររដ្ឋបាល និងដីមន្ទីរពេទ្យ ឬមណ្ឌលសុខភាពសាធារណៈ ព្រមទាំងបរិវេណ | -យន្តការដែលមានចែងក្នុងអនុក្រឹត្យ១១៨អនក្រ/បក ស្តីពីការគ្រប់គ្រងដីរដ្ឋត្រូវសិក្សា និងកំណត់ |

| | | | |
|---|---|---|---|
| និងមន្ទីរពេទ្យសាធារណៈ | ឱ្យដំណើរការសម្រាប់សេវាសាធារណៈជាសម្បត្តិសាធារណៈរបស់រដ្ឋ។ | ទីធ្លានៃគ្រឹះស្ថានទាំងនេះដែលឋិតនៅលើដីរដ្ឋគឺជាដីសាធារណៈរបស់រដ្ឋ។ | ដី ឬចំណែកដីសាលារៀន អគារសិក្សា អគាររដ្ឋបាល មន្ទីរទេព្យ និងមណ្ឌលសុខភាពរដ្ឋទាំងឡាយដែលជាដីសាធារណៈរបស់រដ្ឋ។<br>-ការសិក្សា កំណត់ខាងលើក៏ត្រូវផ្អែកលើផែនការប្រើប្រាស់ដី ប្រសិនបើមាន។ |
| ដែនបម្រុងធម្មជាតិការពារដោយច្បាប់ (តំបន់ការពារធម្ម-ជាតិ) | -ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា១៥ចែងថា ទ្រព្យទាំងឡាយដែលបង្កើតជាដែនបម្រុងធម្មជាតិការពារដោយច្បាប់ (តំបន់ការពារធម្មជាតិ) រាប់ចូលជាសម្បត្តិសាធារណៈរបស់រដ្ឋ។<br>-ព្រះរាជក្រឹត្យស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិឆ្នាំ១៩៩៣ ហើយដែលត្រូវចែងយោងក្នុងច្បាប់ស្តីពីព្រៃឈើឆ្នាំ២០០២។ ព្រះរាជក្រឹត្យនេះចែងថាប្រព័ន្ធការពារធម្មជាតិ រួមបញ្ចូលរាល់ប្រភេទដែលបម្រុងទុកសម្រាប់ឧទ្យានជាតិ ដែលជម្រកសត្វព្រៃ តំបន់ការពារធម្មជាតិចំនួន២៣កន្លែង នៅទូទាំងប្រទេសកម្ពុជាដែលក្នុងនោះមានឧទ្យានជាតិ៧កន្លែងដែនជម្រកសត្វព្រៃ១០កន្លែង តំបន់ការពារទេស | -ជាទូទៅដីក្នុងដែនបម្រុងធម្ម-ជាតិការពារដោយច្បាប់ (ដីក្នុងតំបន់ការពារធម្មជាតិ) ជាដីសាធារណៈរបស់រដ្ឋ។<br>-ការកំណត់ព្រំប្រទល់ជាក់លាក់នៃក្បាលដីក្នុងតំបន់ការពារធម្មជាតិទាំងនេះដែលត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋត្រូវកាត់ចេញក្បាលដី ឬចំណែកនៃដីទាំងឡាយណាដែលប្រជាពលរដ្ឋបានកាន់កាប់ស្របច្បាប់រហូតមក ទោះជាបានទទួលការផ្ទេរសិទ្ធិពីអ្នកកាន់កាប់មុនក៏ដោយ ហើយត្រូវកំណត់ក្បាលដី ឬចំណែកដីនោះជាកម្មសិទ្ធិឯកជនស្របច្បាប់។<br>រដ្ឋអាចរំកិលសិទ្ធិប្រើប្រាស់លើ | -យន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ១១៨ អនក្រ/បក ស្តីពីការគ្រប់គ្រងដីរដ្ឋ និងត្រូវមានការចូលរួមរបស់មន្ត្រី ឬអតីតមន្ត្រីអាជ្ញាធរដែនដីក្នុងតំបន់នីមួយៗត្រូវធ្វើការសិក្សា និងកំណត់ព្រំប្រទល់លើដីជាក់ស្តែងធ្វើផែនទីផ្លូវការ និងបោះបង្គោលព្រំប្រទល់លើដីជាក់ស្តែងឱ្យបានគ្រប់គ្រាន់ និងកំណត់អំពីការកាន់កាប់មុនព្រះរាជក្រឹត្យ និងក្រោយព្រះរាជក្រឹត្យ។<br>-ការសិក្សា កំណត់ខាង |

| | | | |
|---|---|---|---|
| | ភាពពាកន្លែង និងតំបន់ប្រើប្រាស់ច្រើនយ៉ាងពាកន្លែង។ ប៉ុន្តែព្រះរាជក្រឹត្យមិនបានកំណត់ថាដី ក្នុងតំបន់ការពារធម្មជាតិទាំងនោះជាដីសាធារណៈរបស់រដ្ឋទេ។<br>-ផែនទីដែលត្រូវបានចាត់ទុកជាផ្នែកមួយនៃព្រះរាជក្រឹត្យបានគូសបញ្ជាក់អំពីទីតាំងតំបន់ការពារធម្មជាតិទាំង២៣កន្លែង ហើយមានការកំណត់ទំហំជាក់លាក់នៃតំបន់ការពារធម្មជាតិនីមួយៗ ប៉ុន្តែពុំមានការកំណត់ព្រំប្រទល់ច្បាស់លាស់គ្រប់គ្រាន់ទេ។ ក្រសួងបរិស្ថានបានធ្វើផែនទីកំណត់ព្រំប្រទល់លើតំបន់ការពារធម្មជាតិបាន១៧កន្លែងរួចហើយ។<br>-នៅលើដីជាក់ស្តែងក៏មិនទាន់បានបោះបង្គោលព្រំប្រទល់គ្រប់គ្រាន់នៅឡើយដែរទេ។<br>-ច្បាប់ភូមិបាលឆ្នាំ១៩៩២ មាត្រា៥ចែងថាមិនឱ្យមានសិទ្ធិជាឯកជនក្នុងដែនបម្រុងរុក្ខា នេសាទ អាងតម្កល់ទឹកស្រោចស្រពបរិវេណមណ្ឌលរ៉ែ មណ្ឌលបេតិកភណ្ឌ ប្រវត្តិសាស្ត្រជាតិ...អតីតសំណង់រដ្ឋ...។ ប៉ុន្តែច្បាប់នេះមិនបានហាមឃាត់ការប្រើប្រាស់ដោយឯកជនទេ។<br>-សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាល | ដីឯកជននោះបានតាមរយៈច្បាប់ បទបញ្ជា ឬលិខិតបទដ្ឋានគតិយុត្តនានានៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ។ ដីឯកជនស្របច្បាប់ដែលត្រូវកាត់ចេញ និងមិនចុះបញ្ជីជាដីសាធារណៈរបស់រដ្ឋ ក៏នៅតែឋិតនៅក្រោមសមត្ថកិច្ចទូទៅរបស់ក្រសួងបរិស្ថានដដែល។<br><br>-គួរកំណត់ក្បាលដី ឬចំណែកដីដែលមានការចូលកាន់កាប់ប្រើប្រាស់ក្រោយពេលចេញព្រះរាជក្រឹត្យ និងមុនច្បាប់ភូមិបាលឆ្នាំ២០០១ ចូលជាធរមានផងដែរ ព្រោះអ្នកទាំងនោះអាចមានសិទ្ធិប្រើប្រាស់ដីនោះដោយត្រូវអនុវត្តស្របតាមច្បាប់ បទបញ្ជា និងលិខិតបទដ្ឋានគតិយុត្តនានានៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ។<br><br>-បន្តធ្វើផែនទីកំណត់ព្រំប្រទល់តំបន់ការពារធម្មជាតិ និងបោះបង្គោលព្រំប្រទល់នៅលើដីជាក់ស្តែងឱ្យបានច្បាស់លាស់ និងគ្រប់គ្រាន់សម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិទាំងអស់។ | លើនេះក៏ត្រូវផ្អែកលើផែនការប្រើប្រាស់ដីប្រសិនបើមាន។ |

| | | | |
|---|---|---|---|
| | លេខ០៦ប្រក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីវិធានការលុបបំបាត់ភាពអនាធិបតេយ្យក្នុងបញ្ហាទន្ទ្រានកាន់កាប់ដីធ្លី ក៏បានបញ្ជាក់ការហាមឃាត់មិនឱ្យមានសិទ្ធិឯកជនលើដីតំបន់ការពារធម្មជាតិ ឧទ្យានជាតិ ដែនជម្រកសត្វព្រៃ...។<br>-បទបញ្ជាលេខ០១បប ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៤ របស់រាជរដ្ឋាភិបាលស្តីពីការទប់ស្កាត់ បង្ក្រាប លុបបំបាត់ការកាន់កាប់ ការឈូសឆាយ និងការហ៊ុមព័ទ្ធដីព្រៃឈើត្រង់ចំណុច ១០ បានចែងថា រាល់ការចេញលិខិតឬប័ណ្ណសម្គាល់កម្មសិទ្ធិ និងការហ៊ុមព័ទ្ធកាន់កាប់ដីព្រៃ ការបោះទីតាំងមូលដ្ឋានទ័ព ការស្ថាបនាផ្លូវសាធារណៈ ការតាំងទីលំនៅថ្មី...ដែលពាក់ព័ន្ធតំបន់ការពារធម្មជាតិ ត្រូវធ្វើការពិគ្រោះ និងមានការយល់ព្រមពីក្រសួងបរិស្ថានជាមុន។<br>-បទបញ្ជាលេខ០១បប ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាលស្តីពីការទប់ស្កាត់ ការកាប់រានដីព្រៃឈើគ្រប់ប្រភេទរបស់រដ្ឋយកធ្វើជាកម្មសិទ្ធិបានកំណត់ឱ្យគ្រប់ក្រសួង ស្ថាប័នត្រូវពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធ | -ដីតំបន់ដីសើមពាកន្លែងដែលមានសារៈសំខាន់ជាអន្តរជាតិពិសេសជាទីជម្រកសម្រាប់សត្វស្លាបទឹក ត្រូវកំណត់ជាដីសាធារណៈរបស់រដ្ឋ។ តំបន់ដីសើម៣កន្លែង រួមមានតំបន់កោះកាពិ នៅខេត្តកោះកុង តំបន់បឹងទន្លេឆ្មារ នៅខេត្តកំពង់ធំ និងតំបន់រាមសារ នៅខេត្តស្ទឹងត្រែង។ | |

| | | | |
|---|---|---|---|
| | ដីព្រៃឈើគ្រប់ប្រភេទដែលមានជាធរមាន ដើម្បីដាក់ទោសចំពោះជនណាដែលបានរំលោភបំពានលើដីព្រៃឈើគ្រប់ប្រភេទយកធ្វើជាកម្មសិទ្ធិ។<br>-ច្បាប់ស្តីពីការអនុម័តយល់ព្រមអនុសញ្ញាស្តីពីតំបន់ដីសើមមានសារៈសំខាន់ជាអន្តរជាតិ ពិសេសជាទីជម្រកសត្វស្លាបទឹកឆ្នាំ១៩៨៦ ចែងថា រាជរដ្ឋាភិបាលកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ និងលិខិតលេខ៤០១០អជ/កបទ/សអ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៩ ចែងថាពិធីសារស្នើសុំដាក់តំបន់ដីសើម៣កន្លែងនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានទទួលចុះក្នុងបញ្ជីដីសើមអន្តរជាតិ តាមអនុសញ្ញារ៉ាមសារ។ | | |
| បេតិកភណ្ឌបុរាណវិទ្យា វប្បធម៌ និងប្រវត្តិសាស្ត្រ | -ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា១៥ចែងថាបេតិកភណ្ឌបុរាណវិទ្យា វប្បធម៌ និងប្រវត្តិសាស្ត្ររាប់ចូលជាសម្បត្តិសាធារណៈរបស់រដ្ឋ។<br><br>-ច្បាប់ភូមិបាលឆ្នាំ១៩៩២ មាត្រា៩បានចែងហាមឃាត់មិនឱ្យមានកម្មសិទ្ធិឯកជនក្នុងមណ្ឌលបេតិកភណ្ឌវប្បធម៌ ប្រវត្តិសាស្ត្រជាតិ...។ | -បេតិកភណ្ឌបុរាណវិទ្យា វប្បធម៌ និងប្រវត្តិសាស្ត្រជាសម្បត្តិសាធារណៈរបស់រដ្ឋ។<br>-បេតិកភណ្ឌអាចត្រូវបានគេរកឃើញនៅក្នុងដី ឬលើដីដែលជាកម្មសិទ្ធិឯកជនផងដែរ។<br><br>-ប្រសិនបើ បេតិកភណ្ឌនោះឋិតនៅក្នុង ឬនៅលើដីរដ្ឋ ហើយការដកយកបេតិកភណ្ឌចេញពីដីនោះ | -យន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ១១៨ អនក្រ/បក ស្តីពីការគ្រប់គ្រងដីរដ្ឋ (និងត្រូវមានការចូលរួមរបស់អាជ្ញាធរអប្សរា ក្នុងករណីតំបន់សៀមរាបអង្គរ) ត្រូវសិក្សា និងកំណត់ព្រំប្រទល់បរិវេណទីតាំងបុរាណវិទ្យាវប្បធម៌ និង |

| | | | |
|---|---|---|---|
| | -ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ឆ្នាំ១៩៩៤កំណត់ថា រមណីយដ្ឋានបុរាណវិទ្យា និងប្រវត្តិសាស្ត្រជាទីធ្លាមានលក្ខណៈសាធារណៈ។<br><br>-សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលលេខ០០៦ប្រក ឆ្នាំ១៩៩៩ ស្តីពីវិធានការលុបបំបាត់ភាពអនាធិបតេយ្យក្នុងបញ្ហាទន្ទ្រានកាន់កាប់ដីធ្លី បានចែងហាមឃាត់មិនឱ្យមានសិទ្ធិឯកជននៅក្នុងមណ្ឌលបេតិកភណ្ឌវប្បធម៌។ | មិននាំឱ្យធ្លាក់តម្លៃ ឬអស់តម្លៃនៃបេតិកភណ្ឌនោះទេ ដីនោះត្រូវចាត់ទុកជាដីឯកជនរបស់រដ្ឋ។ ប៉ុន្តែ បើការដកយកបេតិកភណ្ឌធ្លាក់តម្លៃ ឬអស់តម្លៃចាំបាច់ត្រូវតែរក្សាបេតិកភណ្ឌទុកលើទីតាំងដដែល ហើយដីរដ្ឋនោះត្រូវចាត់ទុកជាដីសាធារណៈរបស់រដ្ឋ។<br>-ប្រសិនបើរកឃើញបេតិកភណ្ឌនៅក្នុង ឬនៅលើដីជាកម្មសិទ្ធិរបស់បុគ្គលឯកជន ហើយការដកយកបេតិកភណ្ឌចេញពីដីនោះ មិននាំឱ្យធ្លាក់តម្លៃ ឬអស់តម្លៃនៃបេតិកភណ្ឌនោះទេ ត្រូវដកយកបេតិកភណ្ឌចេញពីដីកម្មសិទ្ធិឯកជននោះ។ ប៉ុន្តែ បើការដកយកបេតិកភណ្ឌចេញពីដីនោះ នឹងនាំឱ្យធ្លាក់ចុះតម្លៃ ឬអស់តម្លៃនៃបេតិកភណ្ឌ ជាចាំបាច់ត្រូវតែរក្សាបេតិកភណ្ឌទុកលើទីតាំងដដែល ហើយត្រូវចេញបទបញ្ជា ឬលិខិតបទដ្ឋានគតិយុត្ត ដើម្បីកម្រិតសិទ្ធិប្រើប្រាស់ដីនោះត្រឹមកម្រិតជាក់លាក់ដែលមិននាំឱ្យប៉ះពាល់ខូចខាតបេតិកភណ្ឌនោះ ឬ | ប្រវត្តិសាស្ត្រដែលត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ។<br><br>-ការសិក្សា កំណត់ខាងលើនេះក៏ត្រូវផ្អែកលើផែនការប្រើប្រាស់ដីប្រសិនបើមាន។ |

| | | | |
|---|---|---|---|
| | | ប្រកាសដឹងកជននោះជាកម្មវត្ថុនៃការដកហូតតាមផ្លូវច្បាប់ដើម្បីប្រយោជន៍សាធារណៈ ដោយមានផ្តល់សំណងសមរម្យ និងយុត្តិធម៌ជាមុន។ ដីដែលបានដកហូតនោះត្រូវចាត់ទុកជាដីសាធារណៈរបស់រដ្ឋ។<br>-គួរមានការកំណត់តំបន់ដែលប្រជាពលរដ្ឋកាន់កាប់មុនឆ្នាំ ១៩៩២ ឬមុនការរកឃើញដោយរដ្ឋនូវបេតិកភណ្ឌនោះ និងបន្តកាន់កាប់ដោយស្របច្បាប់រហូតមក ទោះតាមរយៈការផ្ទេរក៏ដោយ ព្រោះពួកគេគួរទទួលបានកម្មសិទ្ធិ ឬសិទ្ធិប្រើប្រាស់លើដីនោះ។ | |
| -អចលនវត្ថុព្រះរាជទ្រព្យដែលមិនមែនជាទ្រព្យសម្បត្តិឯកជនរបស់ព្រះរាជវង្សា-នុវង្ស | -ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា ១៥រាប់អចលនវត្ថុជាព្រះរាជទ្រព្យដែលមិនមែនជាទ្រព្យសម្បត្តិឯកជនរបស់ព្រះរាជវង្សានុវង្សចូលជាសាធារណៈរបស់រដ្ឋ។ | -ដីព្រះរាជវាំង ឬព្រះរាជដំណាក់ទាំងឡាយដែលឋិតនៅក្រោមការថែរក្សាការពារដោយក្រសួងព្រះបរមរាជវាំង គឺជាដីសាធារណៈរបស់រដ្ឋ។<br><br>-ដីដែលបានទិញ ឬកាន់កាប់ជាភោគៈ ឬទទួលបានជាកម្មសិទ្ធិតាមរយៈលទ្ធកម្មស្របច្បាប់ផ្សេងៗដោយសមាជិកនៃព្រះរាជវង្សានុវង្សគឺជាដីឯកជន | -យន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ១១៨ អនក្រ/បក ស្តីពីការគ្រប់គ្រងដីរដ្ឋ ត្រូវសិក្សា និងកំណត់ថាដីណាខ្លះជាព្រះរាជទ្រព្យដែលត្រូវចាត់ថ្នាក់ថាជាដីសាធារណៈរបស់រដ្ឋ។<br>-ការសិក្សា កំណត់ខាងលើនេះក៏ត្រូវផ្អែកលើផែនការប្រើប្រាស់ដី |

| | | | |
|---|---|---|---|
| | | របស់ព្រះរាជវង្សានុវង្ស។ | ប្រសិនបើមាន។ |
| -ដីផ្សេងៗទៀតដែលមានចរិតបម្រើផលប្រ-យោជន៍សាធារណៈ និងដីដែលមានមូលដ្ឋានគតិយុត្ត កំណត់រួចហើយ | -មាត្រា៤នៃអនុក្រឹត្យលេខ១១៨ អនក្រ/បក ស្តីពីការគ្រប់គ្រងដីរដ្ឋ ចែងថា "...ដីផ្សេងៗទៀតដែលមានចរិតបម្រើផលប្រយោជន៍សាធារណៈ និងដីដែលមានមូលដ្ឋានគតិយុត្ត កំណត់រួចហើយ"។<br>-ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ឆ្នាំ១៩៩៤ មាត្រា១២ចែងថា "រាល់បុគ្គល ឬស្ថាប័នឯកជន ក៏ដូចជាអាជ្ញាធរសាធារណៈ ត្រូវហាមឃាត់មិនឱ្យសាងសង់លើទីធ្លាដែលមានលក្ខណៈជាសាធារណៈ ដូចតទៅ៖<br>-ទីបម្រុងទុកទឹក និងទំនប់ទឹក<br>-ទីបម្រុងជីករ៉ែ និងតំបន់ព្រៃឈើ<br>-រមណីយដ្ឋានបុរាណវិទ្យា និងប្រវត្តិសាស្ត្រ<br>-សួនច្បារ ឧទ្យានសាធារណៈ និងតំបន់អភិរក្ស<br>-ដីបម្រុងទុកសម្រាប់ផ្លូវ បម្រុងសម្រាប់ចំណីផ្លូវ និងដីបម្រុងទុកសម្រាប់ផ្លូវរថភ្លើង និងអាកាសយានដ្ឋាន<br>-ទន្លេ សមុទ្រ ព្រែក ព្រមទាំងឆ្នេរច្រាំង..."។ | -ប្រឡាយ ឬអូរបង្ហូរទឹកស្អុយនៅតាមដងផ្លូវដែលមិនទាន់បានរៀបចំ ត្រូវចាត់ទុកជាដីសាធារណៈរបស់រដ្ឋ។<br><br>-ដីស្ថានីយវារីអគ្គិសនី ដីស្ថានីយចែកចាយភ្លើងរបស់រដ្ឋ ដីស្ថានីយចែកចាយទឹកស្អាតរបស់រដ្ឋ និងដីអាងស្តុកទឹករបស់ត្រូវចាត់ទុកជាដីសាធារណៈរបស់រដ្ឋ។ | -យន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ១១៨ អនក្រ/បក ស្តីពីការគ្រប់គ្រងដីរដ្ឋ ត្រូវសិក្សា និងកំណត់ដីដែលត្រូវចាត់ចូលក្នុងជំពូកដីសាធារណៈរបស់រដ្ឋនេះ។<br><br>-ការសិក្សា កំណត់ខាងលើនេះក៏ត្រូវផ្អែកលើផែនការប្រើប្រាស់ដីប្រសិនបើមាន។ |

*វាយឡើងវិញ*

III-**ការគ្រប់គ្រង ថែរក្សា និងការពារដីរដ្ឋ**

ដើម្បីអាចគ្រប់គ្រង ថែរក្សា និងការពារដីរដ្ឋឱ្យមានប្រសិទ្ធភាព រាល់ដីរដ្ឋទាំងអស់ក្រោយពីបានកំណត់ទីតាំងព្រំប្រទល់ច្បាស់លាស់ ចុះបញ្ជី និងធ្វើចំណាត់ថ្នាក់រួចមក អាជ្ញាធរកាន់កាប់ដីរដ្ឋត្រូវរៀបចំបោះបង្គោលរបង សម្រាប់ចំណាំឱ្យសាធារណជនដឹង និងការពារដីនោះ។ អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ត្រូវទទួលខុសត្រូវជាមួយអាជ្ញាធរកាន់កាប់ដីរដ្ឋ ក្នុងកិច្ចការពារដីសាធារណៈ និងដីឯកជនរបស់រដ្ឋ និងត្រូវមានវិធានការទប់ស្កាត់ការបំពាន ឬការចូលទន្ទ្រានកាន់កាប់ដីរដ្ឋ។

**ប្រការ៣**

សេចក្តីសម្រេចនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**និងជាប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី**

**ហត្ថលេខា និងត្រា**

**អ៊ឹម ឈុនលឹម**

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័នកណ្តាល

-គ្រប់សាលាខេត្ត-ក្រុង

-គ្រប់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
លេខ៥០៧ប្រក/កសក

## ប្រកាសរួម
## ស្តីពីយន្តការផ្តល់សេវាផ្សព្វផ្សាយកសិកម្មដល់កសិករសម្បទានដីសង្គមកិច្ច

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

- បានឃើញអនុក្រឹត្យលេខ១៧អនក្រ/បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ/បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៩អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ១១៨អនក្រ/បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦អនក្រ/បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- យោងការចាំបាច់ក្នុងការអនុវត្តអនុក្រឹត្យសម្បទានដីសង្គមកិច្ច

**សម្រេច**

**ប្រការ១**

បង្កើតយន្តការផ្តល់សេវាផ្សព្វផ្សាយកសិកម្មដល់កសិករ ដែលទទួលបានដីសម្បទានសង្គមកិច្ច និងអ្នកទទួលផលក្នុងតំបន់សម្បទានសង្គមកិច្ច សំដៅធានាដល់ការប្រើប្រាស់ដីទាំងនោះបម្រើឱ្យការអភិវឌ្ឍវិស័យកសិកម្មឱ្យមានប្រសិទ្ធភាព។

**ប្រការ២**

យន្តការផ្តល់សេវាផ្សព្វផ្សាយកសិកម្មដល់កសិករ ដែលទទួលបានដីសម្បទានសង្គមកិច្ច និងអ្នកទទួលផលក្នុងតំបន់សម្បទានសង្គមកិច្ច ត្រូវកំណត់ដូចខាងក្រោម៖

ក-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានភារកិច្ច៖

-ផ្តល់ព័ត៌មាន និងទិន្នន័យដីសម្បទានសេដ្ឋកិច្ចដែលបានលុបចោលកិច្ចសន្យា និងកាត់ចេញជូនដល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដើម្បីរៀបចំចុះបញ្ជីជាដីឯកជនរបស់រដ្ឋសម្រាប់ប្រើប្រាស់ក្នុងគោលដៅដីសម្បទានសង្គមកិច្ច ស្របតាមខ្លឹមសារនៃអនុក្រឹត្យ១៩អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច។

-សហការរៀបចំកំណត់តំបន់សម្បទានដីសង្គមកិច្ច ដោយត្រូវចូលរួមក្នុងការធ្វើអត្តសញ្ញាណ ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ និងចុះអង្កេតវាយតម្លៃធនធានដី។

-ផ្ដល់សេវាផ្សព្វផ្សាយកសិកម្មដល់កសិករដែលទទួលបានដីសម្បទានសង្គមកិច្ច និងអ្នកទទួលផលក្នុងតំបន់សម្បទានសង្គមកិច្ច។

ខ-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានភារកិច្ច៖

-ផ្ដល់ព័ត៌មាន និងទិន្នន័យស្ដីពីដីឯកជនរបស់រដ្ឋ និងទីតាំងដីសម្បទានសង្គមកិច្ចដែលបានអនុម័តរួចដោយក្រុមប្រឹក្សាគោលនយោបាយដីធ្លី និងដែលបានចុះបញ្ជីជាដីឯកជនរបស់រដ្ឋ ជូនដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

-សហការប្រើប្រាស់យន្តការដែលមានស្រាប់ដើម្បីអនុវត្តអនុក្រឹត្យលេខ១៩អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្ដីពីសម្បទានដីសង្គមកិច្ចឱ្យបានជោគជ័យ និងមានប្រសិទ្ធភាព។

**ប្រការ៣**

អគ្គលេខាធិការ អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យរដ្ឋមន្ត្រី ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធទាំងអស់ដែលឋិតនៅក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៦

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី**
**នគរូបនីយកម្ម និងសំណង់**
**ហត្ថលេខា និងត្រា**
**អ៊ឹម ឈុនលឹម**

**រដ្ឋមន្ត្រីក្រសួងកសិកម្ម**
**រុក្ខាប្រមាញ់ និងនេសាទ**
**ហត្ថលេខា និងត្រា**
**ច័ន្ទ សារុន**

កន្លែងទទួល

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី

-ដូចប្រការ៣

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ**
**លេខ០៤អសដភ** ភ្នំពេញ ថ្ងៃទី០៣ ខែមករា ឆ្នាំ២០០៧

**អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ**
**ជម្រាបមក**
**លោក លោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី**
**ខេត្ត-ក្រុងដែលអនុវត្តគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី “LMAP”**

កម្មវត្ថុ៖ អំពីករណីលក់ផ្ទះ (ដី ឬអចលនវត្ថុ) ក្នុងតំបន់ដែលបានធ្វើការចុះបញ្ជីជាលក្ខណៈប្រព័ន្ធរួច តែម្ចាស់ផ្ទះអាក់ខានពុំបានចូលរួមផ្តល់ព័ត៌មាន

ដើម្បីដោះស្រាយករណីខាងលើ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ សូមធ្វើការណែនាំដូចតទៅ

១-តម្រូវឱ្យម្ចាស់ផ្ទះ (ដី ឬអចលនវត្ថុ) ធ្វើសំណើសុំចុះបញ្ជីដីបន្ថែមតាមនីតិវិធី

២-ក្នុងពេលជាមួយគ្នានេះ ឬក្រោយពេលនេះ បើត្រូវការបន្ទាន់ ម្ចាស់ផ្ទះអាចស្នើមកអង្គភាពជំនាញតាក់តែងលិខិតលក់ផ្តាច់តាមទម្រង់ដែលច្បាប់តម្រូវ រួចបង់ពន្ធប្រថាប់ត្រា ហើយតម្កល់ទុកសំណុំឯកសារ (ប័ណ្ណផ្ទះ ឬដី លិខិតលក់ផ្តាច់ដែលបានប្រថាប់ត្រារួច) នៅអង្គភាពជំនាញជាបណ្តោះអាសន្នសិន

៣-ក្រោយពេលចុះបញ្ជីបំពេញបន្ថែមតាមនីតិវិធីរួច អង្គភាពជំនាញត្រូវយកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ (ថ្មី) មកធ្វើបន្តការកាត់ឈ្មោះពីអ្នកលក់ទៅអ្នកទិញ រួចប្រគល់ប័ណ្ណនេះឱ្យអ្នកទិញតែម្តង ឯប័ណ្ណចាស់ត្រូវមោឃភាពចោល។

អាស្រ័យហេតុនេះ សូមលោកប្រធានចាត់ចែងអនុវត្តតាមខ្លឹមសារខាងលើនេះឱ្យបានសម្រេចលទ្ធផលល្អ និងមានប្រសិទ្ធភាព។

**អគ្គនាយក**
**ហត្ថលេខា និងត្រា**
**លឹម វ៉ាន់**

ចម្លងជូន
-ក្រសួង ដ.ន.ស
-គ្រប់សាលាខេត្ត-ក្រុងពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
-នាយកដ្ឋានអភិរក្សសុរិយោដី "ដើម្បីមុខការ"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ០០១សណន ភ្នំពេញ ថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៧

## សេចក្តីណែនាំ
## ស្តីពីវិធានការទប់ស្កាត់ការកាប់រានដីព្រៃឈើ និងការចេញលិខិតបញ្ជាក់ការទិញលក់ដីក្នុងតំបន់ការពារធម្មជាតិ

ព្រះរាជាណាចក្រកម្ពុជាយើង ជាប្រទេសមួយដែលមានសក្តានុពលធម្មជាតិយ៉ាងសម្បូរបែប ពិសេសធនធានធម្មជាតិដែលគ្របដណ្តប់ជាង៧០%លើផ្ទៃប្រទេស។ នៅក្នុងពេលដែលប្រទេសជួបប្រទះសង្គ្រាមស៊ីវិញរ៉ាំរ៉ៃជាងពីរទសវត្សរកន្លងមក ព្រៃឈើមួយភាគធំបានរងការបំផ្លាញគួរឱ្យសោកស្តាយបំផុត។ ជាមួយគ្នានេះ ទោះបីប្រទេសជាតិទទួលបាននូវសុខសន្តិភាព និងស្ថិរភាពបរិបូរណ៍នៅគ្រប់ច្រកល្ហកនៃផ្ទៃប្រទេស ដូចសព្វថ្ងៃនេះក៏ដោយ ព្រៃឈើធម្មជាតិក៏នៅតែបន្តទទួលរងនូវការបំផ្លិចបំផ្លាញឥតឈប់ឈរដែរ។

ដោយពិនិត្យឃើញពីសារៈសំខាន់ដ៏ធំធេងនៃព្រៃឈើធម្មជាតិ និងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដែលបណ្តាលមកពីការបាត់បង់ព្រៃឈើនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវបទបញ្ជាយ៉ាងម៉ឺងម៉ាត់ជាបន្តបន្ទាប់ ក្នុងគោលដៅទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើរានយកដីគ្រប់រូបភាពរួមមាន បទបញ្ជាលេខ០១បប ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៤របស់រាជរដ្ឋាភិបាល ស្តីពីការទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការកាប់រាន ការដុត ការឈូសឆាយ និងហ៊ុមព័ទ្ធកាន់កាប់ព្រៃឈើ និងបទបញ្ជាលេខ០១បប ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៦របស់រាជរដ្ឋាភិបាលស្តីពីការទប់ស្កាត់ការកាប់រានដីព្រៃឈើគ្រប់ប្រភេទរបស់រដ្ឋយកធ្វើជាកម្មសិទ្ធិ។

ទន្ទឹមនឹងនេះ ក្រសួងមហាផ្ទៃបានពិនិត្យឃើញថាទោះបីជារដ្ឋាភិបាលបានចេញបទបញ្ជាយ៉ាងតឹងរ៉ឹងយ៉ាងដូច្នេះក៏ដោយ ក៏ការកាប់បំផ្លាញទន្ទ្រានយកដីព្រៃឈើរបស់រដ្ឋ ពិសេសដីព្រៃក្នុងតំបន់ការពារធម្មជាតិ មកធ្វើជាកម្មសិទ្ធិឯកជនពីសំណាក់ជនឱកាសនិយម កាន់តែមានសន្ទុះកើនឡើងជាលំដាប់ តាមរយៈការបំផុសប្រជាពលរដ្ឋក្រីក្រឱ្យរុករានទន្ទ្រានកាន់កាប់ រួចប្រមូលទិញពីពួកគេជាក្រោយ។ លើសពីនេះទៀត ប្រការដែលកាន់តែធ្ងន់ធ្ងរបំផុតនោះគឺការចូលរួមឃុបឃិតរបស់អាជ្ញាធរមូលដ្ឋានឃុំ-សង្កាត់ និងមេភូមិមួយចំនួន តាមរយៈការចេញលិខិតបញ្ជាក់ការទិញដីដែលបានមកពីការទន្ទ្រានដោយខុសច្បាប់ក្នុងតំបន់ការពារធនធានធម្មជាតិ។

ជាក់ស្តែង តាមរយៈលិខិតលេខ១៥៤៨សណ/បស្ថ/កអភ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ក្រសួងបរិស្ថានបានរាយការណ៍មកថា នៅក្នុងឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" ដែលឋិតក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ និងខេត្តកោះកុង ឧទ្យានជាតិព្រះសីហនុ "គិរីរម្យ" ដែលឋិតក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ និងខេត្តកោះកុង ឧទ្យានជាតិព្រះសីហនុ "រាម" ដែលឋិតក្នុងភូមិសាស្ត្រក្រុងព្រះសីហនុ និងតំបន់ប្រើប្រាស់យ៉ាងដងពែង ដែលឋិតក្នុងភូមិសាស្ត្រខេត្តកោះកុង។

ដើម្បីទប់ស្កាត់ និងបង្ក្រាបឈានទៅលុបបំបាត់ទាំងស្រុងនូវការកាប់រានដុតឈូសឆាយដីព្រៃយ៉ាងអនាធិបតេយ្យនៅក្នុងតំបន់ការពារធម្មជាតិនានា ក្រសួងមហាផ្ទៃសូមធ្វើការណែនាំដល់គ្រប់ខេត្ត-ក្រុង ពិសេសខេត្ត-ក្រុងពាក់ព័ន្ធដូចតទៅ៖

១-ណែនាំ និងផ្សព្វផ្សាយផ្សាយដល់គ្រប់មជ្ឈដ្ឋានអំពីបទបញ្ជារបស់រដ្ឋាភិបាល លេខ០១ បប ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៤របស់រាជរដ្ឋាភិបាល ស្តីពីការទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការកាប់រាន ការដុត ការឈូសឆាយ និងហ៊ុមព័ទ្ធ កាន់កាប់ព្រៃឈើ និងបទបញ្ជាលេខ០១បប ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាលស្តីពី ការទប់ស្កាត់ការកាប់រានដីព្រៃឈើគ្រប់ប្រភេទរបស់រដ្ឋយកធ្វើជាកម្មសិទ្ធិ

២-ណែនាំ និងផ្សព្វផ្សាយដល់គ្រប់មជ្ឈដ្ឋានអំពីផលប៉ះពាល់នៃការកាប់បំផ្លាញព្រៃឈើ

៣-ណែនាំដល់អាជ្ញាធរមានសមត្ថកិច្ចថ្នាក់មូលដ្ឋាន និងមេភូមិឱ្យបញ្ឈប់ជាបន្ទាន់ រាល់ការគាំទ្រការកាប់ និងការទន្ទ្រានដីព្រៃក្នុងតំបន់ការពារធនធានធម្មជាតិ ការចេញលិខិតបញ្ជាក់ការទិញលក់ដីក្នុងតំបន់ហាមឃាត់

*វាយឡើងវិញ*

៤-ចាត់តាំងកម្លាំងសរុបតាមគ្រប់រូបភាពចុះស្រាវជ្រាវ និងបង្ក្រាបមេក្លោងដែលបំផុសឱ្យមានការកាប់រានដីព្រៃមកផ្តន្ទាទោសតាមច្បាប់

៥-ចាត់តាំងកម្លាំងសរុប និងមធ្យោបាយសរុបចុះបង្ក្រាបការកាប់រាន ដុត និងឈូសឆាយព្រៃក្នុងតំបន់ការពារធម្មជាតិ

៦-រាយការណ៍អំពីលទ្ធផលនៃយុទ្ធនាការចុះបង្ក្រាប មកក្រសួងមហាផ្ទៃរៀងរាល់ខែ។

ទទួលបានសេចក្តីណែនាំនេះ ក្រសួងមហាផ្ទៃមានជំនឿយ៉ាងមុតមាំថា ឯកឧត្តមអភិបាលគ្រប់ខេត្ត-ក្រុងនឹងយកចិត្តទុកដាក់អនុវត្ត ដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ហត្ថលេខា និងត្រា**

**ស ខេង**

<u>ចម្លងជូន</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងបរិស្ថាន

-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

"ដើម្បីជូនជ្រាបជាព័ត៌មាន"

-គ្រប់សាលាខេត្ត-ក្រុង

"ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

*វាយឡើងវិញ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ០២សរ**

## សារាចរ
## ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់

កន្លងមក ដីរដ្ឋ ទាំងដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋភាគច្រើនមិនទាន់បានធ្វើអត្តសញ្ញាណកម្មធ្វើផែនទីកំណត់ទីតាំង និងព្រំប្រទល់ច្បាស់លាស់ ធ្វើចំណាត់ថ្នាក់ និងចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លីនៅឡើយ ដែលធ្វើឱ្យអាជ្ញាធរគ្រប់ជាន់ថ្នាក់ប្រឈមនឹងការលំបាកក្នុងការគ្រប់គ្រង ដូចជាការទប់ស្កាត់ ការទន្ទ្រានកាន់កាប់ដីរដ្ឋដោយខុសច្បាប់ជាដើម ។

ការចូលកាន់កាប់ដីតាមរូបភាពភោគៈ ត្រូវបានបញ្ចប់បន្ទាប់ពីច្បាប់ភូមិបាលឆ្នាំ២០០១ចូលជាធរមាន ក្នុងពេលដែលរដ្ឋមិនទាន់បានអនុវត្តទូលំទូលាយនៅឡើយនូវកម្មវិធីសម្បទានដីសង្គមកិច្ចសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ដើម្បីដោះស្រាយសេចក្តីត្រូវការដីរបស់ប្រជាពលរដ្ឋ ដែលចេះតែកើនឡើងជារៀងរាល់ថ្ងៃ ដោយសារកំណើនប្រជាជន ការរំសាយកងទ័ព ការបាត់បង់ដីដោយសារគ្រោះធម្មជាតិជាដើម ដែលជាហេតុនាំឱ្យមានការចូលកាន់កាប់ដីរដ្ឋ ដោយអនាធិបតេយ្យ ។ ទន្ទឹមនេះ ក៏មានជនឆ្លៀតឱកាស ពួកឈ្មួញដី និងអ្នកមានអំណាចមួយចំនួនបានចូលកាន់កាប់ដីរដ្ឋដោយខុសច្បាប់តាមរូបភាពផ្សេងៗ ។

ចំពោះមុខស្ថានការណ៍នេះ និងអនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តជាធរមានដែលទាក់ទងនឹងដីធ្លី ដូចជាច្បាប់ភូមិបាល ច្បាប់ស្តីពីព្រៃឈើ ច្បាប់ជលផល ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ និងព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៧០ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០១ ស្តីពីការបង្កើត និងការគ្រប់គ្រងបំរីនីយជីវមណ្ឌលបឹងទន្លេសាបជាដើម រាជរដ្ឋាភិបាលបានយល់ថា ដើម្បីដោះស្រាយបញ្ហាទន្ទ្រានកាន់កាប់ដីរបស់រដ្ឋដោយខុសច្បាប់កន្លងមកពីសំណាក់បុគ្គលឯកជន ទន្ទឹម

នឹងការអនុវត្តច្បាប់ក៏ទាមទារនូវការពិនិត្យករណីរំលោភជាក់ស្តែងនីមួយៗ និងដោះស្រាយដោយមានការអនុគ្រោះមួយចំនួន ពិសេសចំពោះគ្រួសារជនក្រីក្រ និងចំពោះដីធ្លីដែលបានធ្វើអាជីវកម្មពិតប្រាកដ ស្របតាមគោលនយោបាយដែលមានចែងក្នុងសារាចរនេះ។ ដោយឡែក ចំពោះសម្បទានដីសេដ្ឋកិច្ច ករណីដែលសម្បទានិកមិនបានធ្វើការអភិវឌ្ឍតាមកិច្ចសន្យា ឬកាន់កាប់ដីសរុបលើសពីទំហំកំណត់នៃច្បាប់ភូមិបាល ការដកហូត ឬការកាត់បន្ថយត្រូវអនុវត្តតាមនីតិវិធីដែលមានចែងក្នុងអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច។

ដើម្បីរួមចំណែកដល់គោលនយោបាយកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់រាជរដ្ឋាភិបាលតាមរយៈការផ្តល់សុវត្ថិភាពនៃការកាន់កាប់ដីធ្លី ការផ្តល់សម្បទានដីសង្គមកិច្ច ការបង្កើនចំណូលពីការប្រើប្រាស់ដីរដ្ឋ ការទប់ស្កាត់ និងកាត់បន្ថយចលនាទន្ទ្រានកាន់កាប់ដីរដ្ឋ ពិសេសដីព្រៃ និងដើម្បីធានាការពារធនធានធម្មជាតិ និងបរិស្ថានប្រកបដោយនិរន្តរភាព រាជរដ្ឋាភិបាលធ្វើការណែនាំនូវវិធានការ និងនីតិវិធីក្នុងការទាមទារ ដកយកដីរដ្ឋដែលកាន់កាប់ដោយខុសច្បាប់មកវិញ ដូចតទៅ៖

**១-ត្រូវចាត់ទុកការកាន់កាប់ដីរដ្ឋដោយខុសច្បាប់នូវ**

-រាល់ការចូលកាន់កាប់ដីរដ្ឋ (ដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ) ជាភោគៈក្រោយច្បាប់ភូមិបាលឆ្នាំ២០០១ ចូលជាធរមាន

-រាល់ការកាន់កាប់ដីរដ្ឋជាភោគៈនៅលើដីដែលត្រូវបានកំណត់រួចហើយ ជាដីសាធារណៈរបស់រដ្ឋ ទោះជាមុន ឬក្រោយច្បាប់ភូមិបាលចូលជាធរមានក៏ដោយ

-រាល់ការបន្តកាន់កាប់ដីរដ្ឋក្រោយពេលលិខិតអនុញ្ញាត ឬកិច្ចសន្យាឱ្យប្រើប្រាស់ដីរដ្ឋអស់សុពលភាព ហើយអ្នកកាន់កាប់មិនបានសុំបន្តសុពលភាពត្រឹមត្រូវតាមនីតិវិធីជាធរមាន

-រាល់ការកាន់កាប់ដីរដ្ឋលើសពីទំហំ ឬខុសទីតាំងដែលកំណត់ក្នុងលិខិតអនុញ្ញាត ឬកិច្ចសន្យាឱ្យប្រើប្រាស់

-រាល់ការផ្ទេរសិទ្ធិប្រើប្រាស់ដីរដ្ឋដោយបំពានល័ក្ខខ័ណ្ឌក្នុងលិខិតអនុញ្ញាត ឬកិច្ចសន្យា

-រាល់ការផ្ទេរបំប្លែងការកាន់កាប់ដីរដ្ឋទៅជាកម្មសិទ្ធិឯកជនដោយខុសច្បាប់ មានជាអាទិ៍ការបន្លំធ្វើប័ណ្ណកម្មសិទ្ធិលើដីសម្បទានសេដ្ឋកិច្ច ឬលើដីដែលទទួលបានត្រឹមតែការអនុញ្ញាតឱ្យប្រើប្រាស់ ឬធ្វើអាជីវកម្ម ឬការបំប្លែងដីដែលត្រូវបានកំណត់ជាដីសាធារណៈរបស់រដ្ឋ។

**២.នីតិវិធីអនុវត្តចំពោះដីដែលបានចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លីជាដីរដ្ឋរួចហើយ**

២.១-អាជ្ញាធរកាន់កាប់ដីរដ្ឋត្រូវចេញលិខិតទាមទារយកដីរដ្ឋមកវិញ ដោយបញ្ជាក់ពីលេខក្បាលដី ទីតាំងក្បាលដី និងប្លង់បង្ហាញទីតាំងក្បាលដី ឈ្មោះអ្នកកាន់កាប់ដីរដ្ឋបច្ចុប្បន្ន រយៈពេលឆ្លើយតប ឬប្ដឹងតវ៉ារបស់អ្នកមានផលប្រយោជន៍ផ្សេងៗលើក្បាលដីនោះ (ប្រើទម្រង់លេខ១)។

២.២-លិខិតទាមទារយកដីរដ្ឋមកវិញត្រូវបិទប្រកាសជាសាធារណៈនៅសាលាឃុំ-សង្កាត់ និងនៅលើដីដែលជាកម្មវត្ថុនៃការទាមទារយកមកវិញ និងបញ្ជូនមួយច្បាប់ទៅឱ្យអ្នកកាន់កាប់ដី ប្រសិនបើគេរស់នៅក្នុងឃុំ-សង្កាត់នៃទីតាំងដីនោះ។ អាជ្ញាធរកាន់កាប់ដីរដ្ឋត្រូវប្រើប្រាស់គ្រប់មធ្យោបាយដើម្បីផ្ដល់ដំណឹងដល់អ្នកកាន់កាប់ដីរដ្ឋ ប្រសិនបើគេរស់នៅក្រៅឃុំ-សង្កាត់នៃទីតាំងដីនោះ។

២.៣-ក្នុងករណីដែលអាជ្ញាធរកាន់កាប់ដីរដ្ឋមិនអាចរកឃើញថា បុគ្គលណាមួយជាក់លាក់ជាអ្នកកាន់កាប់ដីនោះទេ អាជ្ញាធរកាន់កាប់ដីរដ្ឋអាចចេញលិខិតទាមទារយកដីរដ្ឋមកវិញ ដោយគ្មានបញ្ជាក់ឈ្មោះអ្នកកាន់កាប់ដី ហើយបិទប្រកាសជាសាធារណៈនៅសាលាឃុំ-សង្កាត់នៃទីតាំងដីនៅលើដីដែលជាកម្មវត្ថុនៃការទាមទារយកមកវិញ និងផ្សព្វផ្សាយតាមសារព័ត៌មានថែមទៀត។

២.៤-អាជ្ញាធរកាន់កាប់ដីរដ្ឋត្រូវទុករយៈពេល៣០ថ្ងៃគិតចាប់ពីថ្ងៃបិទប្រកាស ឬអ្នកកាន់កាប់ដីរដ្ឋបានទទួលលិខិតទាមទារយកដីរដ្ឋមកវិញ ដើម្បីឱ្យអ្នកកាន់កាប់ដីធ្វើការឆ្លើយតប ឬអ្នកមានផលប្រយោជន៍លើក្បាលដីនោះ ប្ដឹងតវ៉ាមកអាជ្ញាធរដែលចេញលិខិត។ ចំពោះករណីដែលអាជ្ញាធរកាន់កាប់ដីរដ្ឋមិនអាចរកឃើញបុគ្គលណាមួយជាក់លាក់ជាអ្នកកាន់កាប់ដីរដ្ឋនោះទេ រយៈពេល៣០ថ្ងៃ ត្រូវគិតចាប់ពីថ្ងៃដែលបានបិទប្រកាសជាសាធារណៈ និងដែលបានផ្សព្វផ្សាយតាមសារព័ត៌មាន។

២.៥-ក្នុងរយៈពេលនោះ អ្នកកាន់កាប់ដីរដ្ឋត្រូវឆ្លើយតបដោយបង្ហាញពីការយល់ព្រមប្រគល់ដីនោះមកឱ្យរដ្ឋវិញដោយគ្មានល័ក្ខខ័ណ្ឌ ឬការយល់ព្រមប្រគល់ដោយមានសំណើ ល័ក្ខខ័ណ្ឌច្បាស់លាស់ ឬការមិនយល់ព្រមប្រគល់ហើយទាមទារសិទ្ធិលើដីនោះ (ប្រើទម្រង់លេខ២) និងភ្ជាប់នូវរាល់ឯកសារភស្តុតាងពាក់ព័ន្ធដែលខ្លួនមានមកជាមួយ។

២.៦-ក្រោយរយៈពេលកំណត់៣០ថ្ងៃខាងលើ ប្រសិនបើមានការឆ្លើយតបមិនយល់ព្រមប្រគល់ដីឱ្យរដ្ឋវិញដោយគ្មានល័ក្ខខ័ណ្ឌ ឬមានការប្ដឹងតវ៉ាណាមួយ អាជ្ញាធរកាន់កាប់ដីរដ្ឋត្រូវធ្វើ

លិខិតជូនទៅមេឃុំ ចៅសង្កាត់ និងអភិបាលស្រុក-ខណ្ឌ ដើម្បីស្នើសុំកិច្ចសហការចូលរួមរបស់អាជ្ញាធរដែនដី ក្នុងការពិភាក្សាសម្របសម្រួល ដោយផ្អែកលើគោលនយោបាយដែលបានកំណត់ក្នុងចំណុច៦ និង៧នៃសារាចរនេះ ជាមួយអ្នកកាន់កាប់ដីរដ្ឋ ឬអ្នកប្តឹងតវ៉ា ហើយក្នុងលិខិតនោះត្រូវមានកំណត់កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃការជួបពិភាក្សាសម្របសម្រួល ព្រមទាំងភ្ជាប់នូវច្បាប់ចម្លងនៃលិខិតឆ្លើយតប ឬពាក្យប្តឹងតវ៉ានោះ។

២.៧-បើការពិភាក្សាសម្របសម្រួលជាមួយអ្នកកាន់កាប់ដីរដ្ឋខុសច្បាប់ ឬអ្នកប្តឹងតវ៉ាមិនអាចសម្រេចបាននូវដំណោះស្រាយដែលអាចទទួលយកបានទាំងសងខាងទេ អាជ្ញាធរកាន់កាប់ដីរដ្ឋដែលជាអាជ្ញាធរមានសមត្ថកិច្ចត្រូវចេញលិខិតបញ្ជាឱ្យអ្នកកាន់កាប់ដីរដ្ឋខុសច្បាប់នោះរុះរើ ជួសជុលការខូចខាត និងចាកចេញពីដីរដ្ឋក្នុងរយៈពេល៤៥ថ្ងៃ (ប្រើទម្រង់លេខ៣)។

២.៨-បើអ្នកកាន់កាប់ដីរដ្ឋខុសច្បាប់នោះមិនយល់ព្រមចាកចេញតាមកាលកំណត់ អាជ្ញាធរកាន់កាប់ដីរដ្ឋត្រូវរៀបចំពាក្យប្តឹងទៅតុលាការ ដើម្បីចាត់វិធានការតាមនីតិវិធីច្បាប់ជាធរមាន។

២.៩-បើអ្នកកាន់កាប់ដីរដ្ឋខុសច្បាប់បានចាកចេញ ប៉ុន្តែខកខានមិនបានជួសជុលការខូចខាតចំពោះដីនោះ អាជ្ញាធរកាន់កាប់ដីរដ្ឋអាចរៀបចំសំណុំរឿងប្តឹងទៅតុលាការ ដើម្បីស្នើសុំការជួសជុល ឬសំណងការខូចខាតដីរដ្ឋនោះ។

២.១០-នៅពេលដែលអ្នកកាន់កាប់ដីចាកចេញដោយស្ម័គ្រចិត្ត ឬក្រោយការអនុវត្តវិធានការបណ្តេញចេញបានសម្រេច អាជ្ញាធរកាន់កាប់ដីរដ្ឋត្រូវអនុវត្តផែនការប្រើប្រាស់ ឬរៀបចំដំណើរការធ្វើចំណាច់ថ្នាក់ដី និង/ឬធ្វើផែនការប្រើប្រាស់ដីនោះ ប្រសិនបើមិនទាន់បានធ្វើ។

២.១១-ចំពោះក្បាលដីរដ្ឋណាដែលរកអ្នកកាន់កាប់មិនឃើញ ផុតរយៈពេលកំណត់៣០ថ្ងៃ គិតចាប់ពីថ្ងៃបិទប្រកាសជាសាធារណៈ អាជ្ញាធរកាន់កាប់ដីរដ្ឋមានសិទ្ធិរឹបអូសយកក្បាលដីនៃដីរដ្ឋនោះមកវិញដោយស្វ័យប្រវត្តិ។

ចំពោះករណីដែលអ្នកកាន់កាប់ក្បាលដីរដ្ឋណា បានទទួលលិខិតទាមទារយកដីរដ្ឋមកវិញហើយ តែមិនបានឆ្លើយតប ឬមិនបានតវ៉ា ផុតរយៈពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃទទួលលិខិតទាមទារនេះ អាជ្ញាធរកាន់កាប់ដីរដ្ឋមានសិទ្ធិរឹបអូសយកក្បាលដីនៃដីរដ្ឋនោះមកវិញដោយស្វ័យប្រវត្តិ។

**៣-នីតិវិធីអនុវត្តចំពោះដីដែលមានក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យរដ្ឋ ឬដីដែលបានធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋហើយមានការឯកភាពគ្នាលើអាណត្តិកាន់កាប់ដី**

៣.១-អាជ្ញាធរកាន់កាប់ដីរដ្ឋត្រូវចេញលិខិតទាមទារយកដីរដ្ឋមកវិញ ដោយបញ្ជាក់ទីតាំងក្បាលដី ប្លង់បង្ហាញទីតាំងក្បាលដី ទំហំប្រហាក់ប្រហែលនៃក្បាលដី ព័ត៌មានអំពីព្រំប្រទល់ប្រហាក់ប្រហែលនៃក្បាលដី ឈ្មោះអ្នកកាន់កាប់ដីបច្ចុប្បន្ន រយៈពេលឆ្លើយតប ឬប្តឹងតវ៉ាដោយអ្នកមានផលប្រយោជន៍ផ្សេងៗលើក្បាលដីនោះ (ប្រើទម្រង់លេខ១)។ អាជ្ញាធរកាន់កាប់ដីរដ្ឋត្រូវអនុវត្តដូចមានចែងក្នុងចំណុច២.២, ២.៣, ២.៤, ២.៥, ២.៦ និងចំណុច២.១១នៃសារាចរនេះ។

៣.២-ក្រោយពីបានធ្វើការពិភាក្សាសម្របសម្រួលជាមួយអ្នកកាន់កាប់ដី ឬអ្នកប្តឹងតវ៉ាដើម្បីរកដំណោះស្រាយ (ដោយធ្វើកំណត់ហេតុអំពីការពិភាក្សាសម្របសម្រួលនោះផង) អាជ្ញាធរកាន់កាប់ដីរដ្ឋត្រូវធ្វើរបាយការណ៍ និងលើកយោបល់ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ដោយចម្លងជូនក្រុមប្រឹក្សាឃុំ-សង្កាត់ និងអភិបាលស្រុក-ខណ្ឌដែលជាប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ។

៣.៣-ក្នុងករណីមិនឯកភាពលើខ្លឹមសាររបាយការណ៍របស់អាជ្ញាធរកាន់កាប់ដីរដ្ឋ ក្រុមប្រឹក្សាឃុំ-សង្កាត់ ឬអភិបាលស្រុក-ខណ្ឌមានសិទ្ធិសរសេរលិខិតបង្ហាញហេតុផល អំពីការមិនឯកភាពរបស់ខ្លួន ភ្ជាប់នឹងរបាយការណ៍របស់អាជ្ញាធរកាន់កាប់ដីរដ្ឋ ទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង។

៣.៤-ក្រោយពីទទួលបានរបាយការណ៍ ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង អាចចាត់តាំងមន្ត្រីចុះទៅពិនិត្យ ឬពិភាក្សាបន្ថែមទៀតជាមួយអ្នកកាន់កាប់ដី ឬអ្នកប្តឹងតវ៉ាដល់ទីកន្លែងតាមការចាំបាច់ និងត្រូវកោះប្រជុំគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ដើម្បីពិនិត្យពិចារណាលើរបាយការណ៍ និងមតិយោបល់នានាដែលទទួលបាន ដើម្បីស្វែងរកការឯកភាពគ្នា ផ្អែកលើគោលនយោបាយដែលបានកំណត់ក្នុងចំណុច៦ និង៧នៃសារាចរនេះ និងរកដំណោះស្រាយសម្រាប់ករណីអ្នកកាន់កាប់ដី ឬអ្នកប្តឹងតវ៉ានីមួយៗ។

៣.៥-ក្រោយពីបញ្ចប់ការប្រជុំពិនិត្យពិចារណាលើករណីនោះ (ដោយធ្វើកំណត់ហេតុប្រជុំផង) ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ត្រូវធ្វើរបាយការណ៍អំពីករណី

អ្នកកាន់កាប់ និងអ្នកប្តឹងតវ៉ានីមួយៗ ដោយមានភ្ជាប់នូវបញ្ជីឈ្មោះរបស់ពួកគេ គំនូសប្លង់បង្ហាញទីតាំង និងទំហំដីប្រហាក់ប្រហែលដែលពួកគេកាន់កាប់ ឬតវ៉ា ព្រមទាំងយោបល់របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ចំពោះករណីអ្នកកាន់កាប់ដីរដ្ឋ ឬអ្នកប្តឹងតវ៉ានីមួយៗ ដើម្បីសុំយោបល់សម្រេចពីអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។

៣.៦-ក្រោយពីបានទទួលសេចក្តីសម្រេចពីអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី អភិបាលខេត្ត-ក្រុងត្រូវចេញដីកាសម្រេចដោយមានការបញ្ជាក់ឈ្មោះអ្នកកាន់កាប់ដី ឬអ្នកប្តឹងតវ៉ា ទីតាំង និងទំហំដីពាក់ព័ន្ធនីមួយៗ និងទុករយៈពេល៦០ថ្ងៃ គិតចាប់ពីថ្ងៃចេញដីកាសម្រាប់ការប្តឹងតវ៉ា។

៣.៧-ក្នុងករណីអ្នកកាន់កាប់ដីរដ្ឋយល់ព្រមតាមដីការបស់អភិបាលខេត្ត-ក្រុង ដោយពុំមានការតវ៉ា អាជ្ញាធរកាន់កាប់ដីរដ្ឋត្រូវដាក់ពាក្យស្នើសុំទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ ដើម្បីចុះបញ្ជីដីនោះក្នុងសៀវភៅគោលបញ្ជីដីធ្លី។

៣.៨-ក្នុងដំណើរការចុះបញ្ជី ប្រសិនបើមានវិវាទអំពីសិទ្ធិលើដីនោះជាមួយបុគ្គលឯកជន ឬសមូហភាពណាមួយ ក្រៅពីអ្នកមានឈ្មោះក្នុងបញ្ជី ដែលកំណត់នៅចំណុច៣.៥ វិវាទនោះត្រូវដាក់ជូនគណៈកម្មការសុរិយោដីថ្នាក់ជាតិដើម្បីសម្រេច។

៣.៩-ក្រោយពីបានចុះបញ្ជីជាដីរដ្ឋរួចហើយ ប្រសិនបើនៅមានអ្នកបន្តកាន់កាប់ដីនោះដោយខុសច្បាប់ អាជ្ញាធរកាន់កាប់ដីរដ្ឋដែលជាអាជ្ញាធរមានសមត្ថកិច្ច ត្រូវចេញលិខិតបញ្ជាឱ្យអ្នកកាន់កាប់ដីរដ្ឋខុសច្បាប់នោះ រុះរើ ជួសជុលការខូចខាត និងចាកចេញពីដីនោះ ក្នុងរយៈពេល៤៥ថ្ងៃ (ប្រើទម្រង់លេខ៣)។

៣.១០-ប្រសិនបើអ្នកកាន់កាប់ដីរដ្ឋខុសច្បាប់នោះ មិនយល់ព្រមចាកចេញតាមកាលកំណត់ អាជ្ញាធរកាន់កាប់ដីរដ្ឋត្រូវរៀបចំពាក្យប្តឹងទៅតុលាការ ដើម្បីចាត់វិធានការតាមនីតិវិធីច្បាប់ជាធរមាន។

៣.១១-ប្រសិនបើអ្នកកាន់កាប់ដីរដ្ឋខុសច្បាប់បានចាកចេញតាមកាលកំណត់ ប៉ុន្តែខកខានមិនបានជួសជុលការខូចខាតចំពោះដីនោះ ត្រូវអនុវត្តនីតិវិធីដូចមានចែងក្នុងចំណុច២.៩។ នៅពេលដែលអ្នកកាន់កាប់ដីបានចាកចេញដោយស្ម័គ្រចិត្ត ឬក្រោយការអនុវត្តវិធានការបណ្តេញចេញបានសម្រេច អាជ្ញាធរកាន់កាប់ដីរដ្ឋត្រូវអនុវត្តតាមខ្លឹមសារដូចមានចែងក្នុងចំណុច២.១០។

**៤-នីតិវិធីអនុវត្តចំពោះដីរដ្ឋដែលមិនទាន់បញ្ចូលក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យរដ្ឋ និងមិនទាន់បានធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋ ឬបានធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋចប់ហើយ ប៉ុន្តែមិនទាន់មានការឯកភាព ឬមិនទាន់ដឹងអំពីអាណត្តិកាន់កាប់ដីរដ្ឋ**

៤.១-ចំពោះក្បាលដីរដ្ឋណា ដែលមិនទាន់បានធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទី និងមិនទាន់បានបញ្ចូលក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យរដ្ឋ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងត្រូវប្រមូលព័ត៌មានអំពីទីតាំង និងអ្នកកាន់កាប់ក្បាលដីរដ្ឋ ទំហំ និងព្រំប្រទល់ប្រហាក់ប្រហែលនៃក្បាលដី។ បន្ទាប់មក អភិបាលខេត្ត-ក្រុងត្រូវទទួលភារៈជាអាជ្ញាធរមានសមត្ថកិច្ចចេញលិខិតទាមទារដីរដ្ឋមកវិញ។ នីតិវិធីនៃការទាមទារដីរដ្ឋមកវិញត្រូវអនុវត្តតាមខ្លឹមសារ ដូចមានចែងក្នុងចំណុច៣.១ ដល់៣.៧នៃសារាចរនេះ ទើបអាជ្ញាធរដែលមានអាណត្តិកាន់កាប់ដីរដ្ឋនោះ ក្លាយជាអាជ្ញាធរមានសមត្ថកិច្ចទទួលអនុវត្តជំហាន និងនីតិវិធីបន្តបន្ទាប់ទៀតនៃចំណុច៣។

៤.២-ចំពោះក្បាលដីរដ្ឋណាដែលបានធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋរួចហើយ ប៉ុន្តែមិនមានការឯកភាពគ្នាអំពីអាណត្តិកាន់កាប់ ឬមិនទាន់ដឹងអំពីអាណត្តិកាន់កាប់ដីរដ្ឋ និងមិនទាន់បានបញ្ចូលក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យរដ្ឋ អភិបាលខេត្ត-ក្រុងត្រូវទទួលភារៈជាអាជ្ញាធរមានសមត្ថកិច្ចចេញលិខិតទាមទារដីរដ្ឋមកវិញ។ នីតិវិធីនៃការទាមទារដីរដ្ឋមកវិញត្រូវអនុវត្តតាមខ្លឹមសារដូចមានចែងក្នុងចំណុច៣.១ ដល់៣.៧នៃសារាចរនេះ ទើបអាជ្ញាធរដែលមានអាណត្តិកាន់កាប់ដីរដ្ឋនោះ ក្លាយជាអាជ្ញាធរមានសមត្ថកិច្ចដែលមានភារកិច្ចទទួលអនុវត្តជំហាន និងនីតិវិធីបន្តបន្ទាប់ទៀតនៃចំណុច៣នៃសារាចរនេះ។

**៥-នីតិវិធីអនុវត្តចំពោះដីព្រៃឈើគ្រប់ប្រភេទដែលបានចេញដីកាប្រកាសបដិសេធ និងដកហូតតាម បទបញ្ជាលេខ០១បប របស់រដ្ឋាភិបាល ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៦ ស្តីពីការទប់ស្កាត់ការកាប់រានដីព្រៃឈើគ្រប់ប្រភេទរបស់រដ្ឋយកធ្វើជាកម្មសិទ្ធិ៖**

៥.១-បន្ទាប់ពីបានទទួលពាក្យប្តឹងតវ៉ា ចំពោះដីកាប្រកាសបដិសេធ និងដកហូតតាមបទបញ្ជាលេខ០១បប របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៦ ស្តីពីការទប់ស្កាត់ការកាប់រានដីព្រៃឈើគ្រប់ប្រភេទរបស់រដ្ឋយកធ្វើជាកម្មសិទ្ធិ អាជ្ញាធរខេត្ត-ក្រុងត្រូវធ្វើការសម្របសម្រួលដោយត្រូវធ្វើកំណត់ហេតុ ជាមួយអ្នកប្តឹងតវ៉ា ដើម្បីរកដំណោះស្រាយជាបឋម។ ការសម្របសម្រួល

ត្រូវយកផែនទីគម្របព្រៃឆ្នាំ២០០២ជាគោល និងផ្អែកលើគោលនយោបាយដែលបានកំណត់ក្នុងចំណុច៦ និង៧នៃសារាចរនេះ ជាពិសេសតាមស្ថានភាពជាក់ស្តែងនៅលើដី។

៥.២-បន្ទាប់ពីបានទទួលពាក្យប្តឹងតវ៉ាមិនយល់ព្រមតាមការសម្របសម្រួលនោះទេ អភិបាលខេត្ត-ក្រុងត្រូវចេញសេចក្តីសម្រេចបដិសេធពាក្យប្តឹងតវ៉ា បន្ទាប់ពីថ្ងៃសម្របសម្រួល។

៥.៣-ករណីអ្នកប្តឹងតវ៉ាមិនឯកភាព តាមសេចក្តីសម្រេចបដិសេធរបស់អភិបាលខេត្ត-ក្រុងលើពាក្យប្តឹងតវ៉ា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង/ឬក្រសួងបរិស្ថាន ត្រូវសហការជាមួយមេធាវីរាជរដ្ឋាភិបាលប្តឹងអ្នកប្តឹងតវ៉ានោះ ទៅតុលាការដើម្បីចាត់វិធានការតាមនីតិវិធីច្បាប់ជាធរមាន។

៥.៤-ចំពោះដីព្រៃឈើគ្រប់ប្រភេទដែលអ្នកប្តឹងតវ៉ាឯកភាពតាមសេចក្តីសម្រេចបដិសេធរបស់អភិបាលខេត្ត-ក្រុង លើពាក្យប្តឹងតវ៉ានោះ ឬដែលពុំមានអ្នកប្តឹងតវ៉ា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង/ឬក្រសួងបរិស្ថាន ត្រូវរឹបអូសយកដីព្រៃទាំងនោះមកទុកជាសម្បត្តិរដ្ឋវិញដោយស្វ័យប្រវត្តិ។

៥.៥-អភិបាលខេត្ត-ក្រុងត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីសកម្មភាពដោះស្រាយពាក្យប្តឹងតវ៉ាខាងលើនេះ ជូនអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ដើម្បីអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានមូលដ្ឋានធ្វើសេចក្តីរាយការណ៍ ជូនប្រមុខរាជរដ្ឋាភិបាល។ ក្នុងករណីចាំបាច់ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី នឹងចុះធ្វើអធិការកិច្ចលើដំណោះស្រាយទាំងឡាយណាដែលមានភាពមិនប្រក្រតី។

៥.៦-ដីព្រៃឈើគ្រប់ប្រភេទដែលប្រមូលបានដូចមានចែងក្នុងចំណុច៥.៣ និងចំណុច៥.៤ខាងលើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង/ឬក្រសួងបរិស្ថានត្រូវស្នើទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីធ្វើការចុះបញ្ជីដីនោះក្នុងសៀវភៅគោលបញ្ជីដីធ្លី ថាជាដីរដ្ឋតាមនីតិវិធីច្បាប់ជាធរមាន។

៥.៧-អភិបាលខេត្ត-ក្រុងត្រូវបន្តចេញដីកាប្រកាសបដិសេធ និងដកហូតដីព្រៃឈើគ្រប់ប្រភេទដែលត្រូវបានរំលោភកាន់កាប់ដោយខុសច្បាប់ ជាការចាំបាច់ និងបន្ទាន់។

**៦.គោលនយោបាយចំពោះអ្នកកាន់កាប់ដីរដ្ឋដោយខុសច្បាប់**

*វាយឡើងវិញ*

៦.១-អ្នកដែលកាន់កាប់ដីរដ្ឋដោយខុសច្បាប់ គ្មានសិទ្ធិទាមទារសំណង និងអាចត្រូវទទួលទោសដូចមានចែងក្នុងច្បាប់ភូមិបាលឆ្នាំ២០០១។

៦.២-គ្រួសារក្រីក្រគ្មានដី ឬខ្វះដី ជនងាយរងគ្រោះដែលកាន់កាប់ដីរដ្ឋដោយខុសច្បាប់ គ្មានសិទ្ធិទាមទារសំណង ប៉ុន្តែរាជរដ្ឋាភិបាលអាចផ្ដល់ការអនុគ្រោះក្នុងការទទួលបានដី ដែលមានទំហំសមស្របដើម្បីប្រកបរបរចិញ្ចឹមជីវិត និង/ឬស្នាក់នៅ តាមករណីជាក់ស្តែង ដូចមានចែងក្នុងចំណុច ៧នៃសារាចរនេះ។

៦.៣-ករណីពាក់ព័ន្ធនឹងជនជាតិដើមភាគតិចដែលអាជ្ញាធរប្រពៃណីរបស់គេបានអះអាងថាក្បាលដី ឬចំណែកនៃក្បាលដីដែលជាកម្មវត្ថុនៃការទាមទាររបស់រដ្ឋមកវិញនោះ ឋិតក្រោមការប្រើប្រាស់ជាសមូហភាពតាមទំនៀមទម្លាប់ប្រពៃណីរបស់ពួកគេ នោះការទាមទារយកដីមកវិញត្រូវផ្អាកសិន រហូតដល់ដីនោះត្រូវបានចុះបញ្ជីថាជាដីរដ្ឋ។ ប៉ុន្តែចំពោះការកាន់កាប់ និងការទាមទារសិទ្ធិលើដីដោយបុគ្គលឯកជនណាម្នាក់ជាជនជាតិដើមភាគតិច ដំណើរការទាមទារដកដីរដ្ឋមកវិញត្រូវអនុវត្តជាធម្មតា ដូចករណីអ្នកកាន់កាប់ដីរដ្ឋដោយខុសច្បាប់ជាទូទៅដែរ។

**៧.គោលនយោបាយចំពោះដីរដ្ឋដែលបានកាន់កាប់ដោយខុសច្បាប់**

៧.១-ដីដែលជាកម្មវត្ថុនៃការដកយកមកវិញ ឬដីដែលបានដកយកមកវិញពីការកាន់កាប់ដោយខុសច្បាប់ ហើយដែលជាផ្នែកនៃដីឯកជនរបស់រដ្ឋ អាចជាកម្មវត្ថុនៃការលក់ ការជួល ការធ្វើប្រទានកម្ម ការផ្ដល់សិទ្ធិផលុបភោគ ការផ្ដល់សម្បទានដីសង្គមកិច្ច ការផ្ដល់សម្បទានដីសេដ្ឋកិច្ច ឬការអនុញ្ញាតឱ្យប្រើប្រាស់ដី។

៧.២-ដីដែលជាកម្មវត្ថុនៃការទាមទារយកមកវិញ ឬដីដែលបានទាមទារយកមកវិញពីការកាន់កាប់ដោយខុសច្បាប់ ហើយជាផ្នែកនៃដីសាធារណៈរបស់រដ្ឋ មិនអាចជាកម្មវត្ថុនៃការលក់ ការជួលរយៈពេលវែង ការផ្ដល់ជាសម្បទាន ឬការផ្ដល់ជាកម្មសិទ្ធិបានឡើយ។ ប៉ុន្តែ ដីសាធារណៈរបស់រដ្ឋនេះអាចជាកម្មវត្ថុនៃ៖

-ការជួលរយៈពេលខ្លី ហើយអាចបន្តជាថ្មីបានតាមនីតិវិធីជាធរមាន

-ការផ្ដល់សិទ្ធិផលុបភោគ

-ការអនុញ្ញាតឱ្យកាន់កាប់ ឬប្រើប្រាស់ជាបណ្ដោះអាសន្ន មិនទៀង ហើយអាចដកហូតវិញបាន

*វាយឡើងវិញ*

-ការចុះកិច្ចសន្យាព្រមព្រៀងសហគមន៍ កិច្ចព្រមព្រៀងផ្សេងៗទៀត

-ឬការស្នើសុំធ្វើចំណាត់ថ្នាក់ដីឡើងវិញ ដោយអនុវត្តតាមនីតិវិធីជាធរមាន។

**៨-ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចមិនអាចរកភស្តុតាងបញ្ជាក់ អំពីពេលវេលានៃការចូលកាន់កាប់ដីរដ្ឋ ក្រោយច្បាប់ភូមិបាលឆ្នាំ២០០១ចូលជាធរមាន ឬមិនអាចរកភស្តុតាងបញ្ជាក់ពីការបោះបង់ចោលភោគៈ ហើយមានការទាមទារពីអ្នកកាន់កាប់ដីនោះ អាចផ្តល់ជូនអ្នកកាន់កាប់ ឬអ្នកទាមទារ ក្នុងករណីដែលដីនោះ៖**

-មិនជាប់ផលប្រយោជន៍សាធារណៈ ឬមិនមានចរិតបម្រើផលប្រយោជន៍សាធារណៈ

-មិនទាន់បានចុះបញ្ជីជាដីរដ្ឋ និង

-បានធ្វើអាជីវកម្មពិតប្រាកដ និងបានបំពេញល័ក្ខខ័ណ្ឌតម្រូវផ្សេងៗទៀតនៃភោគៈស្របច្បាប់។

ទទួលបានសារាចរនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

<u>កន្លែងទទួល</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-គ្រប់ក្រសួង ស្ថាប័ន
-គ្រប់សាលាខេត្ត-ក្រុង
-គ្រប់សាលាស្រុក-ខណ្ឌ
-គ្រប់សាលាឃុំ-សង្កាត់
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
លេខ២៩៤៣កសក

## សេចក្តីណែនាំ
## អនុវត្តសារាចរាជរដ្ឋាភិបាលលេខ០២សរ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់ ក្រោមដែនសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

កន្លងមកទោះបីជាច្បាប់ភូមិបាលឆ្នាំ២០០១ បានកំណត់បញ្ចប់នូវការចូលកាន់កាប់ដីតាមរូបភាពភោគៈហើយក៏ដោយ ក៏មានជនឆ្លៀតឱកាសមួយចំនួនដែលជាឈ្មួញដី ឬអ្នកមានអំណាចបានចូលកាន់កាប់ដីរដ្ឋដោយអនាធិបតេយ្យតាមរូបភាពផ្សេងៗល្មើសចំពោះនីតិវិធីនៃច្បាប់។ ម្យ៉ាងទៀតដោយដីរដ្ឋភាគច្រើនមិនទាន់បានធ្វើអត្តសញ្ញាណកម្ម ធ្វើផែនទីកំណត់ទីតាំង និងព្រំប្រទល់ច្បាស់លាស់ ធ្វើចំណាត់ថ្នាក់ និងចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លីជាដីរដ្ឋនៅឡើយ ជាហេតុធ្វើឱ្យស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធមានសមត្ថកិច្ចមានការលំបាកក្នុងការគ្រប់គ្រង ទប់ស្កាត់នូវរាល់ការទន្ទ្រានកាន់កាប់ដីរដ្ឋដោយខុសច្បាប់។

ដើម្បីដោះស្រាយបញ្ហាទន្ទ្រានកាន់កាប់ដីរដ្ឋដោយខុសច្បាប់ អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមានដែលទាក់ទងនឹងដីធ្លីជាអាទិ៍ ច្បាប់ភូមិបាល ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល បទបញ្ជាលេខ០១បប របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៦ ស្តីពីការទប់ស្កាត់ការកាប់រានដីព្រៃឈើគ្រប់ប្រភេទរបស់រដ្ឋយកធ្វើជាកម្មសិទ្ធិចំពោះមុខនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវសារាចរ០២សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់ក្នុងគោលបំណងធ្វើការណែនាំនូវនីតិវិធីលំអិតចំពោះស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធមានសមត្ថកិច្ចក្នុងការទាមទារ ដកហូតយកដីរដ្ឋដែលកាន់កាប់ដោយខុសច្បាប់មកវិញ។

កន្លងមក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានពិនិត្យឃើញថា ការអនុវត្តនូវបណ្តានីតិវិធីទាំងឡាយដើម្បីដោះស្រាយបញ្ហារំលោភកាន់កាប់ដីរដ្ឋនៅមូលដ្ឋានពុំទាន់ធានាបាននូវប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសូមណែនាំ និងប្រគល់ភារកិច្ចជូនដល់បណ្តាអង្គភាពជំនាញពាក់ព័ន្ធ ដូចខាងក្រោម៖

១-គ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទក្រសួង និងមន្ទីរកសិកម្មខេត្ត-ក្រុង ត្រូវក្តាប់ឱ្យជាប់នូវបណ្តាដីរដ្ឋដែលអង្គភាពនីមួយៗមានសមត្ថកិច្ចកាន់កាប់ និងគ្រប់គ្រងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន មានជាអាទិ៍៖

-ដីព្រៃបម្រុងទុកអចិន្ត្រៃយ៍ក្រោមការគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើ

-ដីដែននេសាទទឹកសាប និងសមុទ្រគ្រប់ប្រភេទ ជាពិសេស ដីព្រៃលិចទឹក ដីព្រៃកោងកាងក្រោមការគ្រប់គ្រងរបស់រដ្ឋបាលជលផល

-ដីជាកម្មសិទ្ធិឯកជនរបស់រដ្ឋផ្សេងទៀតឋិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋាន អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្មខេត្ត-ក្រុងដែលបាន ឬមិនទាន់បានចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ឬបានចុះបញ្ជីដីរដ្ឋក្នុងសៀវភៅគោលបញ្ជីដីធ្លី។

២-ចំពោះការកាន់កាប់ដីរដ្ឋដោយខុសច្បាប់លើដីព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដីព្រៃលិចទឹក ដីព្រៃកោងកាង និងដីដែននេសាទដែលបានធ្វើអត្តសញ្ញាណកម្មមានផែនទីសម្គាល់ផ្លូវការ និងមានអាណត្តិកាន់កាប់ដីច្បាស់លាស់ដែលច្បាប់បានប្រគល់សិទ្ធិ និងសមត្ថកិច្ចឱ្យធ្វើការគ្រប់គ្រងជាសម្បត្តិសាធារណៈរបស់រដ្ឋ អង្គភាពរដ្ឋបាលព្រៃឈើ អង្គភាពរដ្ឋបាលជលផលមានសមត្ថកិច្ចដែលមានតួនាទីជាអាជ្ញាធរមានសមត្ថកិច្ចកាន់កាប់ដីរដ្ឋនៅមូលដ្ឋាន ត្រូវអនុវត្តនីតិវិធីដូចមានចែងក្នុងចំណុចទី៥នៃសារាចរលេខ០២សរ ដែលមានអភិបាលខេត្ត-ក្រុងអនុវត្តការចេញដីកាប្រកាសបដិសេធ និងដកហូតដីរដ្ឋនោះមកវិញ ឬធ្វើការសម្របសម្រួលជាមួយអ្នកប្តឹងតវ៉ា និងចាត់ការតាមនីតិវិធី។ ក្នុងករណីអ្នកប្តឹងតវ៉ា មិនឯកភាពតាមសេចក្តីសម្រេចបដិសេធរបស់អភិបាលខេត្ត-ក្រុងលើពាក្យប្តឹងតវ៉ា រដ្ឋបាលព្រៃឈើ ឬរដ្ឋបាលជលផលត្រូវស្នើមកក្រសួងដើម្បីសុំមេធាវីរាជរដ្ឋាភិបាលប្តឹងអ្នកតវ៉ានោះទៅតុលាការដើម្បីចាត់ការតាមនីតិវិធីច្បាប់ជាធរមាន។

៣-ចំពោះការកាន់កាប់ដោយខុសច្បាប់លើដីដែននេសាទគ្រប់ប្រភេទ ទោះជាបាន ឬមិនទាន់បានធ្វើអត្តសញ្ញាណកម្ម និងមានផែនទីជាផ្លូវការក៏ដោយ ប៉ុន្តែមិនទាន់មានអាណត្តិកាន់កាប់ច្បាស់លាស់ រដ្ឋបាលជលផលត្រូវសហការជាមួយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ដើម្បីចុះស្រាវជ្រាវប្រមូលព័ត៌មាននីតិវិធី ដូចមានចែងក្នុងចំណុចទី៤ នៃសារាចរលេខ០២សរដែលមានអភិបាលខេត្ត-ក្រុង ទទួលភារៈជាអាជ្ញាធរមានសមត្ថកិច្ចចេញលិខិតទាមទារដីរដ្ឋមកវិញរហូតដល់ដំណោះស្រាយត្រូវបានបញ្ចប់ អនុលោមតាមចំណុចទី៣.១ ដល់ចំណុចទី៣.៧ នៃសារាចរនេះទើបរដ្ឋបាលជលផលចាត់ការអនុវត្តនីតិវិធីបន្តទៀតស្របតាមចំណុចទី៣នៃសារាចរនេះ។

៤-ចំពោះការកាន់កាប់ដីរដ្ឋផ្សេងទៀតដោយខុសច្បាប់ ជាអាទិ៍ ដីកសិដ្ឋាន ដីស្ថានីយ៍ពិសោធន៍ស្រាវជ្រាវ ដីមណ្ឌលអភិវឌ្ឍន៍កសិកម្មដែលឋិតក្រោមការគ្រប់គ្រងរបស់បណ្ដានាយកដ្ឋានអង្គភាពក្រោមឱវាទក្រសួង និងមន្ទីរកសិកម្មខេត្ត-ក្រុង ដែលមានតួនាទីជាអាជ្ញាធរកាន់កាប់ដីរដ្ឋនៅមូលដ្ឋានត្រូវ៖

-អនុវត្តតាមនីតិវិធីដូចមានចែងក្នុងចំណុចទី៣ នៃសារាចរ០២សរ ក្នុងករណីដីដែលត្រូវរំលោភនោះមានក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យរដ្ឋ

-អនុវត្តតាមនីតិវិធីដូចមានចែងក្នុងចំណុចទី៤នៃសារាចរលេខ០២សរ ក្នុងករណីដីរដ្ឋដែលត្រូវរំលោភនោះមិនទាន់បានចុះក្នុងបញ្ជីទ្រព្យរដ្ឋ

-អនុវត្តតាមនីតិវិធីដូចមានចែងក្នុងចំណុចទី២នៃសារាចរលេខ០២សរ ក្នុងករណីដីរដ្ឋដែលត្រូវរំលោភនោះបានចុះក្នុងសៀវភៅគោលបញ្ជីដីធ្លីរួចហើយ។

៥-អាជ្ញាធរកាន់កាប់ដីរដ្ឋនៅមូលដ្ឋានក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវធ្វើសម្រង់ករណីចូលកាន់កាប់ដីរដ្ឋដោយខុសច្បាប់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងប្រមូលផ្ដុំឯកសារគ្រប់គ្រាន់តាមករណីនីមួយៗ ហើយត្រូវចូលរួមតាមដានមុខការគ្រប់ករណីនៃការដោះស្រាយបណ្ដឹងតវ៉ា។

៦-អាជ្ញាធរកាន់កាប់ដីរដ្ឋនៅមូលដ្ឋានក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវធ្វើរបាយការណ៍តាមករណីនីមួយៗ និងជាប្រចាំស្ដីពីលទ្ធផលនៃដំណោះស្រាយបណ្ដឹងតវ៉ាលើការកាន់កាប់ដីរដ្ឋដោយខុសច្បាប់មកក្រសួងតាមឋានានុក្រម។ ក្នុងករណីអ្នកកាន់កាប់ដីរដ្ឋដោយ

ខុសច្បាប់សុខចិត្តប្រគល់ដីរដ្ឋនោះមកវិញតាមនីតិវិធី អាជ្ញាធរកាន់កាប់ដីរដ្ឋនោះត្រូវចាត់វិធានការបន្ទាន់ថែរក្សាការពារឱ្យបានគង់វង្ស និងស្នើសុំការសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើម្បីចាត់វិធានការអនុវត្តបន្ត។

៧-ក្នុងករណីដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានទទួលសំណុំឯកសារពាក់ព័ន្ធនឹងការប្រគល់ដីជូនរដ្ឋវិញ នាយកដ្ឋានផែនការ ស្ថិតិ មានភារកិច្ចធ្វើជាចំណុចកណ្តាលទទួល-ផ្តល់ព័ត៌មាន និងរាល់ឯកសារស្តីពីការប្រគល់ដីរដ្ឋ និងការទាមទារដីរដ្ឋនានាមកវិញ។ ក្នុងករណីពិនិត្យឃើញថា ប្រភេទដីដែលបានប្រគល់ ឬទាមទារនោះឋិតនៅក្រោមសមត្ថកិច្ចអង្គភាពជំនាញជាក់លាក់ណាមួយក្រោមឱវាទក្រសួង នាយកដ្ឋានផែនការ ស្ថិតិ ត្រូវចាត់វិធានការដើម្បីក្រសួងបញ្ជូនសំណុំឯកសារនោះជាបន្ទាន់ទៅអង្គភាពជំនាញដើម្បីមុខការបន្ត។

ក្នុងករណីដីដែលបានប្រគល់ ឬត្រូវទាមទារមកវិញនោះមិនទាន់មានភាពច្បាស់លាស់ឋិតក្រោមសមត្ថកិច្ចនៃអង្គភាពណានោះ នាយកដ្ឋានផែនការ ស្ថិតិ ត្រូវសហការសម្របសម្រួលជាមួយបណ្តាអង្គភាពជំនាញពាក់ព័ន្ធក្រោមឱវាទក្រសួង ដើម្បីពិនិត្យ និងសិក្សាលើរាល់សំណុំឯកសារទាំងអស់ ព្រមទាំងកំណត់អំពីទីតាំង អត្តសញ្ញាណនៃដីរដ្ឋដែលបានប្រគល់ ឬត្រូវទាមទារមកវិញនោះ។ អង្គភាពពាក់ព័ន្ធត្រូវចាត់តាំងមន្ត្រីជំនាញដើម្បីចូលរួមពិនិត្យ និងសិក្សាតាមការស្នើសុំរបស់នាយកដ្ឋានផែនការ ស្ថិតិ។ ក្រោយពីពិនិត្យឃើញប្រភេទដីរដ្ឋដែលត្រូវទទួល ឬទាមទារមកវិញនោះឋិតនៅក្រោមសមត្ថកិច្ចអង្គភាពណាហើយ នាយកដ្ឋានផែនការ ស្ថិតិត្រូវចាត់វិធានការដើម្បីក្រសួងបញ្ជូនសំណុំឯកសារទៅអង្គភាពពាក់ព័ន្ធនោះដើម្បីមុខការបន្ត។

ក្រោយពេលទទួលបានព័ត៌មាន ឬឯកសារស្តីការប្រគល់ដីរដ្ឋមកវិញនោះ អង្គភាពជំនាញមានសមត្ថកិច្ចត្រូវចាត់វិធានការគ្រប់គ្រង ថែរក្សាដីរដ្ឋនោះឱ្យបានគង់វង្ស។

៨-បន្ទាប់ពីទទួលបានសំណុំឯកសារគ្រប់គ្រាន់ហើយ អង្គភាពពាក់ព័ន្ធដែលជាអាជ្ញាធរមានសមត្ថកិច្ចកាន់កាប់ដីរដ្ឋក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចាត់ការដោយពិនិត្យកំណត់ឱ្យបានច្បាស់លាស់នូវប្រភេទដីរដ្ឋដែលបានទទួលមកវិញ ដើម្បីអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

*វាយឡើងវិញ*

ក-ក្នុងករណីដីរដ្ឋដែលបានទទួលមកតាមនីតិវិធីណាមួយនោះ អាជ្ញាធរមានសមត្ថកិច្ចកាន់កាប់ដីរដ្ឋត្រូវទំនាក់ទំនងធ្វើការចុះបញ្ជីតាមប្រភេទដីរដ្ឋនីមួយៗនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌសាមី ក្នុងសៀវភៅគោលបញ្ជីដីធ្លីអនុលោមតាមនីតិវិធីនៃច្បាប់ និងសារាចរលេខ០២សរ ជាធរមាន។

ខ-ក្នុងករណីដីរដ្ឋដែលបានប្រគល់មកអាជ្ញាធរមានសមត្ថកិច្ចកាន់កាប់ដីរដ្ឋតាមរូបភាពណាមួយនោះគឺជាដីព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដីព្រៃលិចទឹក ដីព្រៃកោងកាង ឬដីដែននេសាទគ្រប់ប្រភេទដែលមានអាណត្តិកាន់កាប់ច្បាស់លាស់ អាជ្ញាធរមានសមត្ថកិច្ចកាន់កាប់ដីរដ្ឋត្រូវធ្វើសំណើតាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្នើទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីធ្វើការចុះបញ្ជីដីនោះក្នុងសៀវភៅគោលបញ្ជីដីធ្លី ជាដីរដ្ឋតាមនីតិវិធីនៃច្បាប់ជាធរមាន។

ទទួលបានសេចក្តីណែនាំនេះ អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រធានមន្ទីរកសិកម្មខេត្ត-ក្រុង ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៧

**រដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ច័ន្ទ សារុន**

កន្លែងទទួល

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-គ្រប់សាលាខេត្ត-ក្រុង

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**លេខ០១០សហវ/ប្រក/ពជ**

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៧

## សេចក្តីជូនដំណឹង
## ស្តីពីការគ្រប់គ្រងប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់

យោងតាមមាត្រា៣០ថ្មី ក្នុងមាត្រា៣នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ និងប្រកាសលេខ៤៥២សហវ/ប្រក/ពជ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៧ ស្តីពីការកែប្រែប្រកាសស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានកិត្តិយស សូមជម្រាបកម្មសិទ្ធិករនៃដីធ្លីមិនបានប្រើប្រាស់នៅតាមខេត្ត-ក្រុង និងរាជធានីភ្នំពេញឱ្យបានជ្រាបថា៖

ដីធ្លីមិនបានប្រើប្រាស់ឋិតនៅក្នុងខេត្ត-ក្រុងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់។ ដូចមានចែងក្នុងមាត្រា៣០ថ្មី ក្នុងមាត្រា៣នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ក្នុងការគិតពន្ធមិនត្រូវបានអនុញ្ញាតឱ្យកាត់ចេញពីមូលដ្ឋានកំណត់ពន្ធចំនួន១.២០០ម៉ែត្រក្រឡាសម្រាប់ដីមួយកន្លែងទៀតទេ។

-ពន្ធនេះត្រូវបង់តាមអត្រា២ភាគរយលើមូលដ្ឋានកំណត់ពន្ធ ដែលកំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ផ្អែកលើតម្លៃទីផ្សារតាមទីក្រុង និងតាមតំបន់នីមួយៗដែលវាយតម្លៃទៅតាមតម្លៃគិតក្នុងមួយម៉ែត្រក្រឡាសម្រាប់ឆ្នាំនីមួយៗ។

-កម្មសិទ្ធិករនៃដីធ្លីមិនបានប្រើប្រាស់នីមួយៗត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសបង់ពន្ធចំនួនពីរច្បាប់ និងគណនាប្រាក់ពន្ធដោយខ្លួនឯង ទៅតាមគំរូលិខិតប្រកាសដែលនាយកដ្ឋានពន្ធដារ

ផ្តល់ជូន ហើយត្រូវបង់ពន្ធឱ្យបានចប់សព្វគ្រប់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣០ ខែកញ្ញានៃឆ្នាំសារពើពន្ធនីមួយៗ ជូនទៅសាខាពន្ធដារខេត្ត-ក្រុងដែលដីធ្លីនោះឋិតនៅ។ ក្នុងករណីដែលកម្មសិទ្ធិករមិនបានដាក់លិខិតប្រកាសបង់ពន្ធ ឬមិនបានបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ត្រូវរងការដាក់ទណ្ឌកម្មតាមមាត្រា១១៦ និង១១៧នៃច្បាប់ស្តីពីសារពើពន្ធ។ ទន្ទឹមនឹងនេះ ផ្អែកតាមមាត្រា១៣១ និងមាត្រា១៣២នៃច្បាប់ដដែលខាងលើ កម្មសិទ្ធិករត្រូវទទួលរងពិន័យបង់ប្រាក់ពន្ធបន្ថែមស្មើនឹង១០ភាគរយ ២៥ភាគរយ និង៤០ភាគរយនៃចំនួនប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់២ភាគរយនៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលចំនួនប្រាក់ពន្ធខ្វះមិនទាន់បានបង់។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសង្ឃឹម និងជឿជាក់ថា កម្មសិទ្ធិករនៃដីធ្លីមិនបានប្រើប្រាស់ទាំងអស់ ប្រាកដជាយកចិត្តទុកដាក់បំពេញកាតព្វកិច្ចសារពើពន្ធបានល្អប្រសើរជាពុំខាន។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ហត្ថលេខា និងត្រា**

**គាត ឈន់**

ចម្លងជូន

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន
- គ្រប់សាលាខេត្ត-ក្រុង "ដើម្បីជូនជ្រាប"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "ដើម្បីមុខការ"
- គ្រប់អង្គភាពពន្ធដារ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងយុត្តិធម៌**
**លេខ០១កយ/សរណន/០៧** រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៧

**សារាចរណែនាំ**
**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**
**សូមជម្រាបមក**
**លោក លោកស្រីប្រធាន អនុប្រធាន និងចៅក្រមគ្រប់តុលាការខេត្ត-ក្រុង**
**លោក លោកស្រីព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមតុលាការខេត្ត-ក្រុង**

កម្មវត្ថុ៖ សារាចរណែនាំស្តីពីចំណាត់ការ និងនីតិវិធីនៃការដោះស្រាយរឿងក្តីដែលមានពាក់ព័ន្ធនឹងដីរដ្ឋ

យោង៖ -អនុក្រឹត្យលេខ១១៨អនក្រ/បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥[13] ស្តីពីការគ្រប់គ្រងដីរដ្ឋ
-អនុសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាដែលបានលើកឡើងក្នុងឱកាសប្រារព្ធពិធី "ទិវាមច្ឆាជាតិ" នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៧

កន្លងមកក្រសួងយុត្តិធម៌បានពិនិត្យឃើញថា តុលាការ និងអយ្យការអមតុលាការខេត្តក្រុងមិនទាន់យកចិត្តទុកដាក់ខ្ពស់ក្នុងការអនុវត្តភារកិច្ចលើចំណាត់ការ និងដោះស្រាយរឿងក្តីដែលមានកម្មវត្ថុពាក់ព័ន្ធនឹងភោគៈ ឬកម្មសិទ្ធិលើដីដែលចាត់ថាជាដីរដ្ឋឱ្យបានត្រឹមត្រូវតាមស្មារតីនៃរដ្ឋធម្មនុញ្ញ និងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាឡើយ។ ការសម្រេចដល់អង្គសេចក្តីលើវិវាទដីធ្លី ឬសំណុំរឿងដែលពាក់ព័ន្ធនឹងការផ្ទេរកម្មសិទ្ធិលើដីធ្លី ដោយមិនបានពិនិត្យ និងពិចារណាលើនីត្យានុកូលភាពនៃលិខិតបញ្ជាក់សិទ្ធិ កិច្ចសន្យា ឬឯកសារគតិយុត្តពាក់ព័ន្ធនឹងសិទ្ធិលើដីវិវាទ បានបង្កឱ្យមានភាពអវិជ្ជមានកើតឡើង ហើយធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ការគ្រប់គ្រង និងសុវត្ថិភាពគតិយុត្តនៃដីធ្លីជាពិសេសដីរដ្ឋដែលត្រូវបានការពារដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ភូមិបាលឆ្នាំ២០០១ និងអនុក្រឹត្យលេខ១១៨អនក្រ/បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥[14] ស្តីពី

---

[13] ឯកសារផ្លូវការត្រូវបានសរសេរ "ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៥"។

[14] ឯកសារផ្លូវការត្រូវបានសរសេរ "ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៥"។

ការគ្រប់គ្រងដីរដ្ឋ។ ទង្វើនេះ ក៏បានធ្វើឱ្យប៉ះពាល់ដល់កិត្យានុភាពរបស់ប្រព័ន្ធតុលាការ ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជា លើវិស័យគ្រប់គ្រងដីធ្លីផងដែរ។

ដើម្បីធានាសុវត្ថិភាពគតិយុត្តនៃដីរដ្ឋ និងបង្កើនការជឿទុកចិត្តសាធារណៈ ក៏ដូចជាការលើកកម្ពស់កិត្យានុភាពរបស់ប្រព័ន្ធតុលាការ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងយុត្តិធម៌សូមធ្វើការណែនាំដល់តុលាការ និងអយ្យការអមតុលាការខេត្ត-ក្រុងដូចខាងក្រោម៖

**១.វិវាទនៃសិទ្ធិលើដីធ្លី**

នៅពេលទទួលបានបណ្ដឹងពាក់ព័ន្ធនឹងវិវាទនៃសិទ្ធិលើដី តុលាការត្រូវពិនិត្យជាបឋមអំពីឯកសារគតិយុត្តដែលបញ្ជាក់សិទ្ធិលើដីវិវាទនោះ ជាអាទិ៍ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុដែលត្រូវបានផ្ដល់ឱ្យតាមមាត្រា២៤២នៃច្បាប់ភូមិបាលឆ្នាំ២០០១ ហើយត្រូវចាត់ការដូចតទៅ៖

ក-ក្នុងករណីដីវិវាទនេះមានឯកសារគតិយុត្តដូចបានកំណត់ខាងលើនេះ តុលាការអាចបន្តនីតិវិធីនៃបណ្ដឹងរហូតដល់ចេញសេចក្ដីសម្រេចដល់អង្គសេចក្ដីបាន។

ខ-ក្នុងករណីដីវិវាទនេះគ្មានឯកសារគតិយុត្តដូចបានកំណត់ក្នុងមាត្រា២៤២នៃច្បាប់ភូមិបាលទេ តុលាការត្រូវពិនិត្យជាបឋមអំពីនីត្យានុកូលភាពនៃភោគៈលើដីវិវាទ ដែលតម្រូវឱ្យអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធធ្វើការបញ្ជាក់អំពីស្ថានភាពគតិយុត្តនៃដីដែលជាកម្មវត្ថុនៃវិវាទ ដើម្បីផ្ទៀងផ្ទាត់ថាតើជាដីរដ្ឋតាមស្មារតីនៃអនុក្រឹត្យលេខ១១៨អនក្រ/បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥[15] ស្ដីពីការគ្រប់គ្រងដីរដ្ឋដែរឬទេ។ ក្នុងករណីចាំបាច់ ដើម្បីធានាប្រសិទ្ធភាព និងសម្រួលដល់ការទទួលព័ត៌មានពាក់ព័ន្ធនឹងដីវិវាទពីអាជ្ញាធរមានសមត្ថកិច្ចថ្នាក់ជាតិពាក់ព័ន្ធ តុលាការត្រូវស្នើសុំមកក្រសួងយុត្តិធម៌ ដើម្បីឱ្យក្រសួងធ្វើការសម្របសម្រួល និងចាត់វិធានការតាមផ្លូវច្បាប់។

កាលបើអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធបានធ្វើការបញ្ជាក់ជាផ្លូវការថា ដីវិវាទជាដីដែលត្រូវចាត់ជាដីរដ្ឋ តុលាការត្រូវបដិសេធពាក្យបណ្ដឹងនោះចោល។

**២.រឿងក្ដីដែលមានកម្មវត្ថុពាក់ព័ន្ធនឹងការផ្ទេរ-ប្រគល់សិទ្ធិលើដី**

---

[15] ឯកសារផ្លូវការត្រូវបានសរសេរ "ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៥"។

នៅពេលទទួលពាក្យបណ្ដឹងទាមទារឱ្យអនុវត្តកាតព្វកិច្ច តាមអានុភាពនៃលិខិតលក់ឱ្យ ដូរ ឬជម្រះមតិក ដូចមានចែងក្នុងមាត្រា២៨៤នៃច្បាប់ភូមិបាលឆ្នាំ២០០១ ឬលិខិតគតិយុត្តផ្សេងៗទៀតនោះ មុននឹងសម្រេចដល់អង្គសេចក្ដី តុលាការត្រូវពិនិត្យជាបឋមអំពីសុពលភាព ឬនីត្យានុកូលភាពនៃលិខិតទាំងនេះ ដោយផ្អែកតាមស្មារតីនៃច្បាប់ភូមិបាល ជាអាទិ៍ ជំពូកទី៦ និងជំពូកទី១៨ និងក្រឹត្យ-ច្បាប់លេខ៣៨ក្រច ស្ដីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា (ជាអាទិ៍ជំពូកទី១ និងជំពូកទី២)។ តាមផ្លូវច្បាប់ កាលបើលិខិតដែលបញ្ជាក់អំពីទំនាក់ទំនងសិទ្ធិ ឬបង្កើតសិទ្ធិមិនស្របច្បាប់ ការសម្រេចដល់អង្គសេចក្ដីអំពីសិទ្ធិ ឬទំនាក់ទំនងសិទ្ធិដែលមានមូលដ្ឋានលើលិខិតទាំងនោះមិនអាចមានអានុភាពគតិយុត្តបានឡើយ។

**៣.ភារកិច្ចរបស់ព្រះរាជអាជ្ញា**

ក្នុងគ្រប់រឿងក្ដីទាំងអស់ដែលមានកម្មវត្ថុពាក់ព័ន្ធនឹងដីដែលអាចចាត់ថាជាដីរដ្ឋ តាមស្មារតីនៃអនុក្រឹត្យលេខ១១៨អនក្រ/បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥[16] ស្ដីពីការគ្រប់គ្រងដីរដ្ឋ ព្រះរាជអាជ្ញាត្រូវតាំងខ្លួនជាភាគីក្នុងរឿងក្ដីដើម្បីការពារដីរដ្ឋដែលជាប្រយោជន៍សាធារណៈ និងសង្គម។

ក្រសួងយុត្តិធម៌នឹងចាត់វិធានការយ៉ាងតឹងរ៉ឹងតាមផ្លូវច្បាប់ ចំពោះការមិនអនុវត្តឱ្យបានត្រឹមត្រូវតាមបញ្ញត្តិច្បាប់ និងសារាចរណែនាំនេះ។

ទទួលបានសារាចរណែនាំនេះ តុលាការ និងអយ្យការគ្រប់ខេត្ត-ក្រុងត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព។

**រដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**អង្គ វង្សវឌ្ឍានា**

<u>ចម្លងជូន</u>

-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងកសិកម្ម
-ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម
-តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល
-សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
-គ្រប់សាលាក្រសួង និងស្ថាប័នពាក់ព័ន្ធ
-ឯកសារ-កាលប្បវត្តិ

[16] ឯកសារផ្លូវការត្រូវបានសរសេរ "ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៥"។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន**
**និងយុវនីតិសម្បទា**
**លេខ២៦៣សអយ** រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៧

ប្រកាស
ស្តីពីលក្ខណវិនិច្ឆ័យខាងហិរញ្ញវត្ថុរបស់អ្នកសុំដីសម្បទានសង្គមកិច្ច

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ៥៥អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ១៩អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញលិខិតលេខ៧០៤ដនស/LASED ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៧ របស់ប្រធានរបស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ

**សម្រេច**

**ប្រការ១**

ប្រកាសនេះកំណត់អំពីលក្ខណវិនិច្ឆ័យខាងហិរញ្ញវត្ថុរបស់មុខសញ្ញាសុំដីសម្បទានសង្គមកិច្ច ដូចមានចែងក្នុងមាត្រា១០ ចំណុច (គ) នៃអនុក្រឹត្យលេខ១៩អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច ។

**ប្រការ២**

មុខសញ្ញាដែលអាចសុំដីសម្បទានសង្គមកិច្ចបានដូចមានចែងក្នុងមាត្រា៣នៃអនុក្រឹត្យលេខ១៩អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច នឹងត្រូវយកចិត្តទុកដាក់ដល់មុខសញ្ញាគ្រួសារក្រីក្រ គ្រួសារជនពិការ គ្រួសារដែលមានស្ត្រីមេម៉ាយជាមេគ្រួសារដែលគ្មានដី គ្រួសារក្រីក្រគ្មានដីសម្រាប់ធ្វើកសិកម្ម គ្រួសារអតីតយុទ្ធជន និងគ្រួសារយោធិនរំសាយដែលគ្មានដី និងជនអនាថា ជនរងគ្រោះដោយប្រការផ្សេងៗ នៅតាមមជ្ឈមណ្ឌលសង្គមកិច្ចនានាដែលត្រូវបានធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ហើយបានរស់នៅមូលដ្ឋាននោះរយៈពេល១ឆ្នាំ ។

**ប្រការ៣**

អ្នកសុំដីសម្បទានសង្គមកិច្ចត្រូវមានលក្ខណវិនិច្ឆ័យខាងហិរញ្ញវត្ថុដូចខាងក្រោម៖

១-អ្នកសុំដីសម្បទានសង្គមកិច្ចសម្រាប់សង់លំនៅឋាន គឺជាមេគ្រួសារដែលគ្មានដីសម្រាប់សង់លំនៅឋាន និងគ្មានលទ្ធភាពរកដីដោយខ្លួនឯង ។

២-អ្នកសុំដីសម្បទានសង្គមកិច្ចសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ គឺជាគ្រួសារដែលគ្មានដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ឬមានដីដែរតែមានទំហំតូចជាងការកំណត់ទំហំដីសម្បទានសង្គមកិច្ច និងគ្មានលទ្ធភាពរកដីដោយខ្លួនឯង ហើយគ្មានមុខរបរក្រៅពីធ្វើកសិកម្ម ។

៣-អ្នកសុំដីសម្បទានសង្គមកិច្ចដែលមានទ្រព្យសម្បត្តិផ្សេងៗ ជាមធ្យោបាយសម្រាប់រកប្រាក់ចំណូល ។ អ្នកសុំដីសម្បទានសង្គមកិច្ចដូចមានចែងនៅក្នុង១ ចំណុច២ និងចំណុច៣នៃប្រការ៣ គឺជាអ្នកដែលមានប្រាក់ចំណូលប្រចាំថ្ងៃគិតជាមធ្យមក្នុងសមាជិកគ្រួសារម្នាក់ៗឋិតក្នុងស្ថានភាពក្រីក្រត្រូវបានត្រួតពិនិត្យផ្ទាល់ និងវាយតម្លៃពីអាជ្ញាធរភូមិ ឃុំ-សង្កាត់ ដោយមានការចូលរួមពីសហគមន៍ចំពោះបណ្តាប្រភេទមុខរបរដែលមានចែងក្នុងប្រការ៤នៃប្រកាសនេះ ។

**ប្រការ៤**

បណ្តាប្រភេទមុខរបរមានដូចខាងក្រោម

| ល.រ | បរិយាយមុខរបរ | ចំណូលប្រចាំថ្ងៃ គិតជាមធ្យម (គិតជារៀល) | ចំនួនថ្ងៃប្រកបរបរក្នុង១ខែ (គិតជាថ្ងៃ) | ចំនួនថ្ងៃ × ប្រាក់ចំណូលប្រចាំថ្ងៃ | សរុបប្រាក់ចំណូលតាមមុខរបរ១ខែ |
|---|---|---|---|---|---|
| ១ | រត់ម៉ូតូឌុប | | | | |
| ២ | បររទេះសេះ | | | | |
| ៣ | កម្មករសំណង់ | | | | |
| ៤ | កម្មករចម្ការកៅស៊ូ | | | | |
| ៥ | ស៊ីឈ្នួលធ្វើចម្ការ | | | | |
| ៦ | ប្រមូលអនុផលព្រៃឈើដើម្បីចិញ្ចឹមគ្រួសារ | | | | |
| ៧ | នេសាទជាលក្ខណៈគ្រួសារ | | | | |
| ៨ | ចាំចម្ការឱ្យគេ | | | | |
| ៩ | កាត់សក់ | | | | |
| ១០ | ប៉ះកង់-ម៉ូតូ | | | | |
| ១១ | មុខរបរផ្សេងទៀតដែលមានប្រភេទប្រហាក់ប្រហែលនឹងមុខរបរទាំង១០ខាងលើ | | | | |

**ប្រការ៥**

លក្ខណវិនិច្ឆ័យដូចមានចែងក្នុងប្រការ២ ប្រការ៣ និងប្រការ៤ខាងលើ សម្រាប់ប្រើប្រាស់ក្នុងការរៀបចំកសាងនូវបញ្ជីឈ្មោះគ្រួសារដែលបានដាក់ពាក្យសុំដីសម្បទានសង្គមកិច្ច និងសម្រាប់ប្រើប្រាស់ក្នុងការត្រួតពិនិត្យនូវបញ្ជីឈ្មោះ ដោយត្រូវកាត់ចេញនូវឈ្មោះគ្រួសារដែលបានទទួលដីសម្បទានសង្គមកិច្ចរួចហើយ ព្រមទាំងធ្វើបច្ចុប្បន្នភាពនូវស្ថានភាពខាងហិរញ្ញវត្ថុនៃឈ្មោះ

គ្រួសារ ដែលមានក្នុងបញ្ជីឈ្មោះគ្រួសារ សុំដីសម្បទានសង្គមកិច្ចកន្លងមកដើម្បីឱ្យស្របទៅតាមលក្ខណវិនិច្ឆ័យខាងហិរញ្ញវត្ថុ។

**ប្រការ៦**

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត-ក្រុង និងការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្រុក-ខណ្ឌ ត្រូវចូលរួមសហការជាមួយគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត-ក្រុង និងក្រុមការងារថ្នាក់ស្រុក-ខណ្ឌ ក្នុងការពិនិត្យលក្ខណវិនិច្ឆ័យខាងហិរញ្ញវត្ថុរបស់អ្នកសុំដីសម្បទានសង្គមកិច្ច ដោយផ្អែកតាមសំណើរបស់អាជ្ញាភូមិ ឃុំ-សង្កាត់។

រៀងរាល់ឆមាស និងបំណាច់ឆ្នាំ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត-ក្រុង និងការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្រុក-ខណ្ឌត្រូវចូលរួមសហការជាមួយអាជ្ញាធរភូមិឃុំ-សង្កាត់ ក្នុងការរៀបចំបញ្ជីអ្នកសុំសម្បទានសង្គមកិច្ច។

**ប្រការ៧**

នាយកខុទ្ទកាល័យអគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស ប្រធាននាយកដ្ឋានសុខុមាលភាពសង្គម និងប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត-ក្រុង និងផ្នែកពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**
**ហត្ថលេខា និងត្រា**
**អ៊ិត សំហេង**

ចម្លងជូន
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីគ្រប់ខេត្ត-ក្រុង
- គ្រប់សាលាខេត្ត-ក្រុង
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងយុត្តិធម៌**
**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**លេខ៩៥ប្រក/ដនស/មផ**

ប្រកាសអន្តរក្រសួង
ស្តីពីនីតិវិធីនៃការប្រើប្រាស់ដីឯកជនរបស់រដ្ឋ

**ឧបនាយករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់
- បានឃើញអនុក្រឹត្យលេខ១៦អនក្រ/បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ

- បានឃើញអនុក្រឹត្យលេខ៦២អនក្រ/បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៤៦អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ៤៨អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ
- បានឃើញអនុក្រឹត្យលេខ១១៨អនក្រ/បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញប្រកាសលេខ៤២ដនស/បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៦ ស្តីពីការធ្វើអត្តសញ្ញាណកម្ម ធ្វើផែនទី និងធ្វើចំណាត់ថ្នាក់ដីរដ្ឋ
- យោងយោបល់ឯកភាពរបស់ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

### *ប្រការ១*

ប្រកាសនេះមានគោលការណ៍ នីតិវិធី និងយន្តការសម្រាប់ធ្វើផែនការប្រើប្រាស់ផ្សេងៗនូវដីឯកជនរបស់រដ្ឋដែលបានចុះបញ្ជីរួចនៅក្នុងខេត្ត-ក្រុង ហើយដែលរដ្ឋមិនទាន់បានប្រគល់ទៅឱ្យស្ថាប័នសាធារណៈ ឬអាជ្ញាធរណាមួយកាន់កាប់នៅឡើយ ។

### *ប្រការ២*

ដីឯកជនរបស់រដ្ឋជាកម្មវត្ថុនៃការធ្វើផែនការនេះ មានជាអាទិ៍ ដីនិទាយាទភាព ដីដែលឯកជនបានប្រគល់ជូនរដ្ឋដោយស្ម័គ្រចិត្ត ដីដែលម្ចាស់បោះបង់ចោល ដីដែលក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌបានរកឃើញក្នុងដំណើរការធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋ ដីដែលមិនអាចកំណត់បាននូវអត្តសញ្ញាណភោគី ឬកម្មសិទ្ធិករស្របច្បាប់ ហើយដែលឋិតក្រោមការគ្រប់គ្រងរបស់ខេត្ត-ក្រុង ។

ការធ្វើផែនការប្រើប្រាស់ដីឯកជនរបស់រដ្ឋមិនអនុវត្តទៅលើដីរបស់កម្មសិទ្ធិករឯកជន ដីជាកម្មសិទ្ធិសមូហភាព ដីវត្ត ឬដីរបស់សហគមន៍ជនជាតិដើមភាគតិច ឬដីសាធារណៈរបស់រដ្ឋឡើយ ។

ការធ្វើផែនការប្រើប្រាស់ដីឯកជនរបស់រដ្ឋ មិនមែនជាការផ្ដល់ ឬការបែងចែកដីឱ្យប្រើប្រាស់ជាក់ស្ដែងនោះទេ។

**ប្រការ៣**

ការធ្វើផែនការប្រើប្រាស់ដីឯកជនរបស់រដ្ឋដែលត្រូវធ្វើឡើងតាមវិធីសាស្ត្រមានលក្ខណៈចូលរួម មានគោលបំណងដើម្បីសម្រេចបាននូវផលិតភាពខ្ពស់នៃការប្រើប្រាស់ដីស្របតាមស្ថានភាពសក្ដានុពលដី និងឆ្លើយតបចំពោះសេចក្ដីត្រូវការដីរបស់អាជ្ញាធរនានា និងរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ជាពិសេសក្នុងភូមិ ឃុំ-សង្កាត់នៃទីតាំងដីនោះ។

ការធ្វើផែនការប្រើប្រាស់ដីឯកជនរបស់រដ្ឋត្រូវមានការវាយតម្លៃអំពីតម្រូវការដី ស្ថានភាព និងសក្ដានុពលនៃដី។

ការវាយតម្លៃខាងលើនេះ មិនមែនជាការវាយតម្លៃគុណភាពដី ដើម្បីដឹងពីប្រភេទដំណាំរុក្ខជាតិដែលគួរដាំនៅលើដីនៅឡើយ។ ការវាយតម្លៃបែបនេះអាចនឹងធ្វើក្រោយពេលធ្វើផែនការប្រើប្រាស់ដីរួច។ ការធ្វើផែនការប្រើប្រាស់ដីឯកជនរបស់រដ្ឋ ចាំបាច់ត្រូវមានការបង្ហាញ និងពិចារណាអំពីការប្រើប្រាស់ដី សេចក្ដីត្រូវការដីរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានភូមិ ឃុំ ឬសេចក្ដីត្រូវការដីរបស់ថ្នាក់ឃុំ-សង្កាត់ ស្រុក-ខណ្ឌ ខេត្ត-ក្រុងសម្រាប់សេវាសាធារណៈ គម្រោងអភិវឌ្ឍន៍របស់រដ្ឋ ឬគម្រោងអភិវឌ្ឍន៍របស់មូលដ្ឋាន។ លទ្ធផលនៃការវាយតម្លៃដី និងសេចក្ដីត្រូវការដីត្រូវបិទផ្សាយជាសាធារណៈ ដើម្បីប្រមូលមតិយោបល់របស់ប្រជាពលរដ្ឋ ព្រមទាំងពិចារណាលើមតិយោបល់ទាំងនោះ មុនមានការសម្រេចជាផ្លូវការអំពីផែនការប្រើប្រាស់ដីនោះ។

ការធ្វើផែនការប្រើប្រាស់ដីឯកជនរបស់រដ្ឋត្រូវពិចារណាលើផែនការមេ ឬផែនការអភិវឌ្ឍន៍ ផ្សេងៗទៀតដែលបានទទួលការឯកភាពនៅថ្នាក់រដ្ឋបាលមូលដ្ឋាន ឬដែលបានសម្រេចជាផ្លូវការរួចហើយ ប្រសិនបើមាន។

រាល់ការធ្វើផែនការមេ ឬផែនការអភិវឌ្ឍន៍ផ្សេងៗ ក៏គួរពិចារណាអំពីផែនការប្រើប្រាស់ដីឯកជនរបស់រដ្ឋ មុននឹងសម្រេចធ្វើអ្វីមួយលើក្បាលដីនោះ ដែលផ្ទុយពីខ្លឹមសារនៃផែនការប្រើប្រាស់ដីឯកជនរបស់រដ្ឋនោះ ប្រសិនបើមាន។

ផែនការប្រើប្រាស់ដីឯកជនរបស់រដ្ឋត្រូវផ្ដល់អាទិភាពខ្ពស់ដល់តម្រូវការដីធ្លីក្នុងមូលដ្ឋាន នាពេលបច្ចុប្បន្ន និងអនាគត ប្រាំ ឬដប់ឆ្នាំខាងមុខ សម្រាប់សេវា និងការប្រើប្រាស់ជាសាធារណៈ និងសម្រាប់ដោះស្រាយការតាំងទីលំនៅថ្មី ដែលបណ្ដាលមកពីគម្រោងអភិវឌ្ឍន៍របស់រដ្ឋ ឬគម្រោងអភិវឌ្ឍន៍របស់មូលដ្ឋាន ឬដោយសារគ្រោះធម្មជាតិផ្សេងៗ ឬកំណើនប្រជាពលរដ្ឋ តាមរយៈការបម្រុងទុកដីសម្រាប់គោលបំណងជាក់លាក់។ ដីដែលបម្រុងទុកនេះត្រូវតែរក្សាជាដីឯកជនរបស់រដ្ឋ រហូតដល់មានការបែងចែកជាក់ស្ដែង។

**ប្រការ៤**

បន្ទាប់ពីបានធ្វើផែនការប្រើប្រាស់ដីណាមួយរួចហើយ ដីនោះអាចត្រូវបានផ្ដល់ ឬបែងចែកឱ្យអង្គភាពរដ្ឋ ឬរដ្ឋបាលថ្នាក់ខេត្ត-ក្រុង ស្រុក-ខណ្ឌ ឃុំ-សង្កាត់ ស្របតាមផែនការប្រើប្រាស់ដីនោះតាមរយៈប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃដែលមានការបញ្ជាក់ច្បាស់លាស់ពីល័ក្ខខ័ណ្ឌនៃការផ្ដល់សិទ្ធិគ្រប់គ្រង ប្រើប្រាស់ និងអាស្រ័យផល។

**ប្រការ៥**

ប្រសិនបើក្បាលដីណាមួយមិនត្រូវបានកំណត់ថា ទុកបែងចែក ឬទុកផ្ដល់ឱ្យអង្គភាពរដ្ឋ ឬរដ្ឋបាលថ្នាក់ខេត្ត-ក្រុង ស្រុក-ខណ្ឌ ឃុំ-សង្កាត់ណាមួយទេ ដីនោះត្រូវកំណត់ក្នុងផែនការប្រើប្រាស់ដីថាទុកសម្រាប់ផ្ដល់ ឬប្រើប្រាស់តាមរូបភាពណាមួយដែលសមស្រប ដូចជាសម្បទានដីសង្គមកិច្ច ការលក់ ការដូរ ការជួល ឬការអនុញ្ញាតឱ្យប្រើប្រាស់រយៈពេលខ្លី។ ក្បាលដីណាដែលមិនទាន់បានបែងចែកជាក់ស្ដែងទេ ត្រូវរក្សាទុករហូតដល់មានការបែងចែកជាផ្លូវការស្របតាមនីតិវិធី ដូចមានចែងក្នុងប្រកាសអន្តរក្រសួងនេះ។

**ប្រការ៦**

ការអនុញ្ញាតឱ្យប្រើប្រាស់ដីរយៈពេលខ្លីគឺមិនលើសពីមួយឆ្នាំ និងអាចបន្តសាជាថ្មីបានតែម្ដងគត់ ហើយអាចដកហូតវិញបានគ្រប់ពេលវេលា។ ការអនុញ្ញាតនេះសម្រាប់ផ្ដល់ជូនប្រជាពលរដ្ឋក្រីក្រក្នុងមូលដ្ឋានភូមិ ឃុំ-សង្កាត់ ដែលត្រូវការដី ឬខ្វះដីត្រូវដាក់សំណើសុំការអនុញ្ញាតប្រើប្រាស់ដីរយៈពេលខ្លីជាបណ្ដោះអាសន្ន តាមរយៈមេភូមិ ដោយមានបញ្ជាក់ពីទីតាំងដី និងគោលបំណងប្រើប្រាស់ជាក់លាក់។

កិច្ចសន្យាដែលមានកំណត់ល័ក្ខខ័ណ្ឌនៃការអនុញ្ញាតឱ្យប្រើប្រាស់ដីនោះ ត្រូវទុកជាឯក-សារសាធារណៈនៅសាលាឃុំ-សង្កាត់នៃទីតាំងដីនោះ និងចម្លងជូនប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌមួយច្បាប់ និងជូនមេភូមិនៃទីតាំងនោះមួយច្បាប់។

ការអនុញ្ញាតឱ្យប្រើប្រាស់ដីឯកជនរបស់រដ្ឋ ឬការពារជនដែលប្រើប្រាស់ដីឯកជនរបស់រដ្ឋ ដោយគ្មានកិច្ចសន្យាជាលាយលក្ខណ៍អក្សរត្រឹមត្រូវ ឬដោយបំពានសិទ្ធិអំណាចរបស់អាជ្ញាធរត្រូវបានហាមឃាត់។

**ប្រការ៧**

យន្តការសម្រាប់ការធ្វើផែនការប្រើប្រាស់ដីឯកជនរបស់រដ្ឋមានដូចតទៅ៖

-គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងដែលមានសមាសភាព មុខងារ និងភារកិច្ចតាមការកំណត់នៃអនុក្រឹត្យលេខ១១៨អនក្រ/បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ។

-ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌដែលពាក់ព័ន្ធនឹងដីជាកម្មវត្ថុនៃការធ្វើផែនការប្រើប្រាស់ដី និងដែលត្រូវបានតែងតាំងដោយអភិបាលខេត្ត-ក្រុង តាមស្មារតីនៃអនុក្រឹត្យលេខ១១៨អនក្រ/បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋមានភារកិច្ចធ្វើការវាយតម្លៃអំពីតម្រូវការដី ស្ថានភាព និងសក្តានុពលដី។

-ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវធ្វើការសិក្សា និងបង្ហាញអំពីសេចក្តីត្រូវការដីរបស់ប្រជា-ពលរដ្ឋក្នុងមូលដ្ឋានភូមិ ឃុំ-សង្កាត់ខ្លួន ព្រមទាំងកិច្ចសហការចាំបាច់ផ្សេងៗទៀត។

**ប្រការ៨**

ក្នុងដំណើរការធ្វើផែនការប្រើប្រាស់ដីឯកជនរបស់រដ្ឋ ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌត្រូវ៖

-ធ្វើការវាយតម្លៃសេចក្តីត្រូវការដី ស្ថានភាព និងសក្តានុពលដី ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ

-ពិចារណាអំពីការប្រើប្រាស់ដី និងសេចក្តីត្រូវការដីរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានភូមិ ឃុំ-សង្កាត់នីមួយៗនៃស្រុក-ខណ្ឌ និងរបស់អង្គភាពរដ្ឋ និងដឹកនាំការធ្វើផែនការប្រើប្រាស់ដីឯកជនរបស់រដ្ឋ។

-លើកសំណើផែនការប្រើប្រាស់ដីឯកជនរបស់រដ្ឋ ទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ដោយមានសេចក្តីអធិប្បាយអំពីសេចក្តីត្រូវការដីរបស់មូលដ្ឋាន ស្ថានភាព និងសក្តានុពលដី ព្រមទាំងផែនការអភិវឌ្ឍន៍ផ្សេងៗទៀត ប្រសិនបើមាន

-ជូនដំណឹង និងបិទផ្សាយជាសាធារណៈនូវលទ្ធផលនៃការធ្វើផែនការប្រើប្រាស់ដីឯក-ជនរបស់រដ្ឋដែលគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងបានផ្តល់យោបល់កែលំអ

-ប្រមូល និងសង្ខេបមតិយោបល់សាធារណៈជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុង ក្រោយការបិទផ្សាយ

-កែតម្រូវផែនការប្រើប្រាស់ដីឯកជនរបស់រដ្ឋ តាមការសម្រេចរបស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង

-ជំរុញការអនុវត្តផែនការប្រើប្រាស់ដីដែលបានសម្រេចជាផ្លូវការ និងធ្វើរបាយការណ៍បូកសរុបប្រចាំឆ្នាំ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង អំពីដីដែលត្រូវបានផ្តល់ ឬចែកឱ្យឯកជន ឬសមូហភាព ឬអង្គភាពរដ្ឋនានានៅថ្នាក់ស្រុក-ខណ្ឌ និងដីដែលនៅសល់ក្នុងផែនការមិនទាន់ត្រូវបានបែងចែក។

**ប្រការ៩**

ការធ្វើផែនការប្រើប្រាស់ដីឯកជនរបស់រដ្ឋត្រូវអនុវត្តតាមនីតិវិធីដូចតទៅ៖

១-នៅពេលដែលក្បាលដីឯកជនរបស់រដ្ឋណាមួយត្រូវបានចុះបញ្ជីនៅក្នុងខេត្ត-ក្រុងរួចហើយរដ្ឋបាលឃុំ-សង្កាត់ ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ ប្រសិនបើបានតែងតាំងហើយ អាចលើកសំ-ណើទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ឱ្យធ្វើផែនការប្រើប្រាស់ដី ឬកែប្រែផែនការប្រើប្រាស់ដីដែលមានស្រាប់ ដោយបញ្ជាក់អំពីទីតាំង និងទំហំក្បាលដី ព្រមទាំងគោលបំណងនៃការប្រើប្រាស់ ឬមូលហេតុនានា ប្រសិនបើមាន។

២-បន្ទាប់ពីបានទទួលសំណើឱ្យធ្វើផែនការប្រើប្រាស់ដី ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ត្រូវប្រជុំពិភាក្សាលើសំណើដែលបានស្នើឡើងក្នុងរយៈពេល១៥ថ្ងៃយ៉ាងយូរ។

៣-នៅពេលដែលគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង សម្រេចលើសំណើសុំធ្វើផែនការប្រើប្រាស់ដីនោះ លេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ត្រូវរៀបចំសំណើថវិកាទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

៤-ក្រោយពីបានទទួលការងកភាពលើសំណើថវិកា អភិបាលខេត្ត-ក្រុងត្រូវតែងតាំងក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌតាមស្មារតីនៃអនុក្រឹត្យលេខ១១៨អនក្រ/បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ ប្រសិនបើមិនទាន់បានតែងតាំង និងត្រូវធ្វើការបណ្តុះបណ្តាលអំពីដំណើរការ និងនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដី ដល់គ្រប់សមាជិកនៃក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ។

៥-ប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌត្រូវកំណត់ពេលវេលា និងជូនដំណឹងដល់គ្រប់សមាជិកក្នុងអំឡុងពេលយ៉ាងតិច១៥ថ្ងៃជាមុន ដើម្បីចុះពិនិត្យមើលស្ថានភាព និងសក្តានុពលដីដល់ទីកន្លែង។

៦-មុនពេលចុះទៅពិនិត្យវាយតម្លៃអំពីតម្រូវការដី ស្ថានភាព និងសក្តានុពលដីដល់ទីកន្លែងជាក់ស្តែង មេឃុំ-ចៅសង្កាត់ ត្រូវអញ្ជើញមេភូមិពាក់ព័ន្ធមកប្រជុំ ដើម្បីជម្រាបជូនអំពីគម្រោងការ និងដំណើរការធ្វើផែនការប្រើប្រាស់ដី និងការជូនដំណឹងអំពីគម្រោងការនៃការធ្វើផែនការប្រើប្រាស់ដីដល់ប្រជាពលរដ្ឋក្នុងភូមិ។

៧-មេឃុំ ចៅសង្កាត់ ក្រោយពីបានពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវដឹកនាំការសិក្សាអំពីសេចក្តីត្រូវការដីរបស់ឃុំ-សង្កាត់ និងរបស់ប្រជាពលរដ្ឋក្នុងឃុំ-សង្កាត់ ដើម្បីត្រៀមលក្ខណៈលើកយោបល់ ឬសំណើ ក្នុងដំណើរការធ្វើផែនការប្រើប្រាស់ដី។ មេឃុំ ចៅសង្កាត់ត្រូវបង្ហាញដល់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ អំពីផ្នែកពាក់ព័ន្ធនៃការផែនការអភិវឌ្ឍន៍ និងគម្រោងវិនិយោគរបស់ឃុំ-សង្កាត់ដែលបានសម្រេចរួចហើយអំពីតម្រូវការដី សម្រាប់ផែនការអភិវឌ្ឍន៍អំពីចំនួនគ្រួសារដែលខ្វះដី ឬគ្មានដីសម្រាប់សាងសង់លំនៅឋាន និង/សម្រាប់ប្រកបរបរកសិកម្មចិញ្ចឹមជីវិត។

៨-បន្ទាប់ពីចុះទៅពិនិត្យស្ថានភាព និងសក្តានុពលដីដល់ទីកន្លែង ប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌត្រូវធ្វើការប្រជុំស្តាប់ការបង្ហាញអំពីសេចក្តីត្រូវការដីក្នុងឃុំ-សង្កាត់ពាក់ព័ន្ធ និងពិចារណាលើលទ្ធផលនៃការវាយតម្លៃស្ថានភាព និងសក្តានុពលដីលើផែនការមេ ឬផែនការអភិវឌ្ឍន៍ផ្សេងទៀតដែលពាក់ព័ន្ធ ដើម្បីសម្រេច និងលើកយោបល់ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង។

៩-ក្រោយពីបានទទួលសំណើផែនការប្រើប្រាស់ដីពីក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ត្រូវរៀបចំប្រជុំដើម្បីផ្តល់យោបល់លើសំណើផែនការប្រើប្រាស់ដី ក្នុងរយៈ៣០ថ្ងៃយ៉ាងយូរ។

១០-ក្រោយពីបានទទួលការឯកភាព ឬការកែសម្រួលសំណើផែនការប្រើប្រាស់ពីគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌត្រូវបិទផ្សាយជាសាធារណៈរយៈពេល៣០ថ្ងៃ ក្នុងភូមិ និងនៅសាលាឃុំ-សង្កាត់ពាក់ព័ន្ធ ដើម្បីទទួលមតិយោបល់សាធារណៈ និងសង្ខេបមតិនោះជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង។

១១-ក្នុងករណីចាំបាច់ ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង អាចចាត់តាំងមន្ត្រីម្នាក់ ឬច្រើននាក់ដែលជាសមាជិកនៃគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ និង/ឬលេខាធិការដ្ឋានដើម្បីចុះត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែង និងធ្វើរបាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្ត-ក្រុង មុនការប្រជុំសម្រេចលើផែនការប្រើប្រាស់ដីនោះ។

១២-លេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ត្រូវចម្លងឯកសារអំពីផែនការប្រើប្រាស់ដីដែលបានសម្រេចរួចហើយ និងគូសប្លង់បង្ហាញទីតាំងក្បាលដីនីមួយៗ នៅក្នុងផែនទីរួមនៃដីរដ្ឋដែលបានធ្វើការនេះ ជូនគ្រប់ស្ថាប័នពាក់ព័ន្ធ។ ផែនទីរួមនេះ ត្រូវដៅបញ្ចោក់នៅក្នុងផែនទីឃុំ-សង្កាត់ពាក់ព័ន្ធ។

១៣-ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុងត្រូវរៀបចំការប្រជុំត្រួតពិនិត្យការអនុវត្តផែនការ និងផែនទីរួមដែលមាននៅគ្រប់ថ្នាក់រដ្ឋបាលរៀងរាល់ឆ្នាំ។

**ប្រការ១០**

រាល់ការបែងចែកដីឱ្យទៅបុគ្គល ស្ថាប័ន ឬអង្គភាពរដ្ឋណាមួយ ចាំបាច់ត្រូវគោរពតាមផែនការប្រើប្រាស់ដីដែលបានសម្រេចជាផ្លូវការរួចហើយ លើកលែងតែផែនការនោះត្រូវបានកែសម្រួលជាមុនសិន។

ការកែប្រែផែនការប្រើប្រាស់ដីត្រូវអនុវត្តតាមនីតិវិធីដែលមានលក្ខណៈចូលរួម ដូចដំណើរការធ្វើផែនការប្រើប្រាស់ដីពីដំបូងដែរ។

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង តាមសំឡេងភាគច្រើនដាច់ខាតនៃសមាជិកចូលរួមប្រជុំដែលត្រូវមានយ៉ាងតិច២ភាគ៣ នៃសមាជិកទាំងអស់ អាចផ្តួចផ្តើម និងសម្រេចធ្វើការកែប្រែផែនការប្រើប្រាស់ក្បាលដីឯកជនរបស់រដ្ឋថ្នាក់ណាមួយ ដែលបានធ្វើផែនការប្រើប្រាស់រួចហើយ ដោយមិនចាំបាច់គោរពតាមនីតិវិធីទូទៅ ប៉ុន្តែត្រូវធ្វើការពន្យល់ហេតុច្បាស់លាស់អំពីការសម្រេចកែប្រែផែនការនោះ និងជូនដំណឹងដល់មេឃុំ ចៅសង្កាត់ និងភាគីពាក់ព័ន្ធយ៉ាងតិច ៣០ថ្ងៃជាមុន។

**ប្រការ១១**

ដើម្បីធានាប្រសិទ្ធភាពនៃការផែនការប្រើប្រាស់ រដ្ឋបាលខេត្ត-ក្រុង ស្រុក-ខណ្ឌ ឃុំ សង្កាត់ត្រូវគោរពតាមផែនការ ដែលបានសម្រេចជាផ្លូវការ។ រាល់ការប្រើប្រាស់ដីមិនស្របតាមផែនការត្រូវដកហូតយកមកវិញ ឬត្រូវបញ្ឈប់ការប្រើប្រាស់នោះក្នុងរយៈពីរ (០២) ខែយ៉ាងយូរ។

**ប្រការ១២**

ផែនការប្រើប្រាស់ដីត្រូវកត់ត្រាអំពីការកំណត់ និងការសម្រេចលើរបៀបប្រើប្រាស់ ឬការបែងចែកដីដែលបានធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចតាមនីតិវិធីជាធរមាន ចំពោះក្បាលដីឯកជនរបស់រដ្ឋជាក់លាក់នីមួយៗ។

ដីដែលបានធ្វើផែនការប្រើប្រាស់រួចត្រូវមានប្លង់បង្ហាញអំពីផែនការបែងចែក និងការគូសប្លង់បង្ហាញទីតាំងដីនៅលើផែនទីរួមមួយ ហើយត្រូវរក្សាទុកមួយច្បាប់ៗនៅសាលាឃុំ-សង្កាត់ ស្រុក-ខណ្ឌ និងខេត្ត-ក្រុងជាឯកសារសាធារណៈ។

ក្បាលដីណាមួយដែលបានប្រគល់ជូនស្ថាប័ន ឬអង្គភាពណាមួយឱ្យគ្រប់គ្រងជាផ្លូវការ ឬត្រូវបានធ្វើលទ្ធកម្មកម្មសិទ្ធិដល់បុគ្គលឯកជន ត្រូវធ្វើចរន្តការក្នុងរយៈពេល៣០ថ្ងៃ ដោយធ្វើសញ្ញាសម្គាល់ ឬលុបចេញពីផែនទីរួម បង្ហាញទីតាំងក្បាលដីរបស់រដ្ឋ។

ដីឯកជនរបស់រដ្ឋណាមួយដែលបានចុះបញ្ជី ហើយត្រូវបានធ្វើផែនការប្រើប្រាស់ដីរួចត្រូវគូសប្លង់បង្ហាញទីតាំងក្បាលដីនីមួយៗនៅក្នុងផែនទីរួម និងដៅបញ្ជាក់នៅក្នុងផែនទីឃុំ-សង្កាត់ពាក់ព័ន្ធ ក្នុងរយៈពេល៣០ថ្ងៃ ក្រោយពីទទួលបានការសម្រេចលើផែនការប្រើប្រាស់ដីជាផ្លូវការ។

**ប្រការ១៣**

ការចំណាយលើការរៀបចំធ្វើផែនការប្រើប្រាស់ដីឯកជនរបស់រដ្ឋ ឋិតក្នុងកញ្ចប់ថវិការបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ត្រូវលើកសំណើសុំថវិកាដោយមានភ្ជាប់ឯកសារផែនការជាក់លាក់ ដែលបង្ហាញឈ្មោះស្រុក-ខណ្ឌ ឃុំ-សង្កាត់នៃទីតាំងក្បាលដី ចំនួនក្បាលដី និងទំហំដីសរុបដែលត្រូវធ្វើផែនការប្រើប្រាស់ដី និងគំនូសប្លង់បង្ហាញទីតាំងក្បាលដី។

សំណើថវិកាត្រូវមានបញ្ចូលខ្ទង់ចំណាយសម្រាប់ការផ្សព្វផ្សាយ និងការបណ្តុះបណ្តាលអំពីដំណើរការ និងនីតិវិធីផែនការប្រើប្រាស់ដីដល់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក-ខណ្ឌ ការឧបត្ថម្ភលើការធ្វើដំណើររបស់សមាជិកក្រុមការងារដីរដ្ឋ ឬរបស់ក្រុមចុះត្រួតពិនិត្យតាមករណីចាំបាច់ ការចំណាយសម្រាប់រៀបចំការប្រជុំ និងការរៀបចំឯកសារ ការចំណាយលើសម្ភារៈ ឧបករណ៍បច្ចេក-ទេស និងការចំណាយចាំបាច់ផ្សេងៗទៀត។

**ប្រការ១៤**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៧

| | | |
|---|---|---|
| <u>កន្លែងទទួល</u> | **ឧបនាយករដ្ឋមន្ត្រី** | **ទេសរដ្ឋមន្ត្រី** |
| -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា | **រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** | **រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី** |
| -អគ្គលេខាធិការដ្ឋានរដ្ឋសភា | | **នគរូបនីយកម្ម និងសំណង់** |
| -ទីស្តីការគណៈរដ្ឋមន្ត្រី | **ហត្ថលេខា និងត្រា** | **ហត្ថលេខា និងត្រា** |
| -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី | **ស ខេង** | **អ៊ឹម ឈុនលឹម** |
| -គ្រប់ក្រសួង-ស្ថាប័ន | | |
| -គ្រប់សាលាខេត្ត-ក្រុង | | |
| -ឯកសារ-កាលប្បវត្តិ | | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ១០១អនក្រ/បក

## អនុក្រឹត្យ
## ស្តីពីការបង្កើតគណៈកម្មាធិការកំណត់ផ្ទៃបឹងទីតាំងបឹងបួក្នុងព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រមក/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ៥៨អនក្រ/បក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

### មាត្រា១

ត្រូវបានបង្កើតគណៈកម្មាធិការកំណត់ផ្ទៃទីតាំងបឹងបួ ក្នុងព្រះរាជាណាចក្រកម្ពុជា រួមមានសមាសភាពដូចខាងក្រោម៖

១-ឯកឧត្តម លឹម គានហោ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ប្រធាន
២-ឯកឧត្តម អ៊ឹម ឈុនលឹម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អនុប្រធាន
៣-ឯកឧត្តម ច័ន្ទ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

៤-ឯកឧត្តម ប៊ុន ហ៊ាន អគ្គនាយកកិច្ចការបច្ចេកទេសក្រសួងធនធានទឹក
និងឧតុនិយម សមាជិក

៥-ឯកឧត្តម ណៅ ធួក ប្រធានរដ្ឋបាលជលផលក្រសួងកសិកម្ម រុក្ខាប្រមាញ់
និងនេសាទ សមាជិក

៦-អភិបាលខេត្ត-ក្រុង សមាជិក

មាត្រា២

គណៈកម្មាធិការកំណត់ផ្ទៃទីតាំងបឹងបួក្នុងព្រះរាជាណាចក្រកម្ពុជាមានភារកិច្ចដូចតទៅ៖

-ជាសេនាធិការផ្ទាល់របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល ដើម្បីត្រួតពិនិត្យ និងតាមដានលើសកម្មភាពប្រើប្រាស់បឹងបួក្នុងព្រះរាជាណាចក្រកម្ពុជា

-ចុះសិក្សា និងកំណត់ផ្ទៃទីតាំងបឹងបួ ដើម្បីលើកយោបល់ជូនសម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាពិនិត្យ និងសម្រេច

-ពិនិត្យ និងលើកយោបល់សុំការសម្រេចពីប្រមុខរាជរដ្ឋាភិបាល ដើម្បីលុបចោលនូវរាល់ឯកសារទាំងឡាយណាដែលទាក់ទងនឹងករណីទន្រ្ទានកាន់កាប់បឹងបួ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស

-ធ្វើរបាយការណ៍ពីលទ្ធផលការងារដែលអនុវត្តបានជូនប្រមុខរាជរដ្ឋាភិបាល ។

មាត្រា៣

គណៈកម្មាធិការកំណត់ផ្ទៃទីតាំងបឹងបួក្នុងព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងធនធានទឹក និងឧតុនិយមលើរាល់លិខិតស្នាម និងមានថវិកាដោយឡែករបស់ខ្លួនដែលភ្ជាប់ទៅនឹងគណនីយរបស់ក្រសួងធនធានទឹក និងឧតុនិយម ។

គណៈកម្មាធិការកំណត់ផ្ទៃទីតាំងបឹងបួក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

មាត្រា៤

គណៈកម្មាធិការកំណត់ផ្ទៃបឹងបួក្នុងព្រះរាជាណាចក្រកម្ពុជា មានលេខាធិការដ្ឋានមួយជាជំនួយការការងារ នៅទីស្តីការក្រសួងធនធានទឹក និងឧតុនិយម ។ លេខាធិការដ្ឋាននេះត្រូវដឹកនាំដោយប្រធានមួយរូប និងជំនួយការមួយចំនួនតាមការចាំបាច់ ។ មន្ត្រីជំនួយការក្នុងលេខាធិការដ្ឋាននេះ ជាមន្ត្រីរបស់ក្រសួងធនធានទឹក និងឧតុនិយម ឬជាមន្ត្រីក្របខ័ណ្ឌមកពីក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលដែលទទួលការតែងតាំងពីប្រធានគណៈកម្មាធិការ ។

មាត្រា៥

លេខាធិការដ្ឋាននៃគណៈកម្មាធិការកំណត់ផ្ទៃទីតាំងបឹងបួក្នុងព្រះរាជាណាចក្រកម្ពុជា មានភារកិច្ចដូចតទៅ៖

-ជាសេនាធិការទទួលបន្ទុកបច្ចេកទេស និងច្បាប់ឱ្យគណៈកម្មាធិការកំណត់ផ្ទៃទីតាំងបឹងបួក្នុងព្រះរាជាណាចក្រកម្ពុជា

-ទទួលរៀបចំផែនការការងារ និងកិច្ចប្រជុំរបស់គណៈកម្មាធិការ

-សម្របសម្រួល និងទំនាក់ទំនងជាមួយក្រសួង ស្ថាប័នដែលជាសមាជិក គណៈកម្មាធិការកំណត់ផ្ទៃទីតាំងបឹងបួក្នុងព្រះរាជាណាចក្រកម្ពុជា

-បំពេញការងារផ្សេងៗទៀត តាមណែនាំរបស់របស់គណៈកម្មាធិការកំណត់ផ្ទៃទីតាំងបឹងបួក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៦**

រាល់បទប្បញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៧**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៧

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

<u>កន្លែងទទួល</u>

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ដូចមាត្រា៧

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ១១៤អនក្រ/បក

**អនុក្រឹត្យ**

**ស្តីពីការដាក់បញ្ចាំ ការផ្ទេរ**

**នូវសិទ្ធិលើការជួលរយៈពេលវែង ឬសិទ្ធិលើសម្បទានដីសេដ្ឋកិច្ច**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៤/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ/បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៤៦អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ៤៨អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ
- បានឃើញអនុក្រឹត្យលេខ៤៨អនក្រ/បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦អនក្រ/បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញអនុក្រឹត្យលេខ១១១អនក្រ/បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា១**

អនុក្រឹត្យនេះមានគោលដៅកំណត់គោលការណ៍ និងល័ក្ខខ័ណ្ឌតម្រូវទាំងឡាយក្នុងការផ្តល់សិទ្ធិដល់អ្នកវិនិយោគក្នុងការដាក់បញ្ចាំសម្រាប់ធានា និងការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬសិទ្ធិលើសម្បទានដីក្នុងរយៈពេលមិនលើសពីរយៈពេលដែលមានកំណត់ក្នុងកិច្ចសន្យាជួលរយៈពេលវែង ឬកិច្ចសន្យាសម្បទានដី។

**មាត្រា២**

ក្នុងន័យនៃអនុក្រឹត្យនេះ វាក្យសព្ទ៖

-ការផ្ទេរសិទ្ធិ សំដៅដល់ការផ្ទេរសិទ្ធិទាំងឡាយដែលមានចែកក្នុងកិច្ចសន្យាសម្បទានដី ឬកិច្ចសន្យាជួលដីរយៈពេលវែង។

-ការដាក់បញ្ចាំ សំដៅដល់ការយកសិទ្ធិលើការជួលរយៈពេលវែង ឬសិទ្ធិលើសម្បទានដី ទៅដាក់ធានាការសងបំណុល ។

-ការជួលរយៈពេលវែង សំដៅដល់ការជួលអចលនវត្ថុដោយរូបវន្តបុគ្គល នីតិបុគ្គល ឬ រាជរដ្ឋាភិបាលអនុលោមទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។ ការជួលរយៈពេលវែងនេះ មានរយៈពេល១៥ (ដប់ប្រាំ) ឆ្នាំ ឬលើស ។

-សម្បទានដី សំដៅដល់សម្បទានដីសេដ្ឋកិច្ចដែលផ្តល់ដោយរដ្ឋដល់វិនិយោគិនដែលបាន បំពេញល័ក្ខខ័ណ្ឌស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

-ភតិសន្យា សំដៅដល់កិច្ចសន្យាជួលអចលនវត្ថុដែលធ្វើឡើងរវាងម្ចាស់ទ្រព្យ និងអ្នក ជួលទ្រព្យនោះ ។

-ភតិបតី សំដៅដល់ម្ចាស់ទ្រព្យ ឬកម្មសិទ្ធិករដែលបានជួលទ្រព្យទៅឱ្យអ្នកដទៃ ។

-ភតិកៈ សំដៅដល់អ្នកទទួលជួលទ្រព្យពីម្ចាស់ទ្រព្យ ឬពីកម្មសិទ្ធិករ ។

-លេខាចារឹក សំដៅដល់ការកត់ត្រារឿងហេតុអ្វីមួយចូលក្នុងសៀវភៅ ឬបញ្ជីតាមរូប- មន្តដែលបានកំណត់ ដើម្បីគ្រប់គ្រងអចលនវត្ថុឱ្យបានត្រឹមត្រូវតាមច្បាប់ ។

-បុព្វសិទ្ធិ សំដៅដល់សិទ្ធិជាពិសេសដែលឱ្យដាច់ទៅលើមុខងារ ឬទៅលើក្រុមនីមួយៗ លើសពីអ្នកដទៃ ។

-បុរិមា សំដៅដល់សិទ្ធិដែលបើកឱ្យជនណាម្នាក់បានអ្វីមួយមុនជនឯទៀត ។

-មតកជន សំដៅដល់ជនដែលបានស្លាប់ហើយ ។

មាត្រា៣

រាល់ការដាក់បញ្ចាំ ឬការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬសិទ្ធិលើសម្បទានដី មិនមែនជាការដាក់បញ្ចាំដី ឬការផ្ទេរដីដែលអ្នកវិនិយោគបានទទួលសម្បទានពីរដ្ឋ ឬបានជួលរយៈ ពេលវែងឡើយ ។

ចំពោះដីសម្បទានណាដែលពុំទាន់បានដំណើរការស្របតាមល័ក្ខខ័ណ្ឌនៃកិច្ចសន្យា អ្នក វិនិយោគមិនអាចផ្ទេរ ឬបញ្ចាំបន្តទៀតជាដាច់ខាត ។

មាត្រា៤

សម្បទានដីជាសិទ្ធិស្របច្បាប់ដែលបានចែងក្នុងឯកសារគតិយុត្ត ចេញដោយអាជ្ញាធរមានសមត្ថកិច្ចតាមអំណាចឆន្ទានុសិទ្ធិឱ្យរូបវន្តបុគ្គល ឬនីតិបុគ្គល ឬក្រុមមនុស្សដើម្បីកាន់កាប់ដី និងសិទ្ធិប្រើប្រាស់ដីតាមល័ក្ខខ័ណ្ឌកំណត់ជាក់លាក់។

សម្បទានដីអាចបង្កើតបានតែសិទ្ធិក្នុងរយៈពេលមួយជាកំណត់តាមកិច្ចសន្យា ដែលបានបង្កើតសម្បទាននោះ។ សិទ្ធិសម្បទានដីមិនអាចឈានដល់ការបង្កើតនូវសិទ្ធិកម្មសិទ្ធិលើដីដែលបានផ្តល់ជាសម្បទាន ជាប្រយោជន៍ដល់សាមីជននោះទេ។

**មាត្រា៥**

មានតែអចលនវត្ថុដែលបានចុះបញ្ជីក្នុងសៀវភៅគោលដីធ្លីទេ ទើបអាចជាកម្មវត្ថុនៃការធ្វើសម្បទាន ឬការជួលរយៈពេលវែងបាន។

ក្នុងករណីនៃការជួលដែលផ្តល់ដោយរាជរដ្ឋាភិបាល ហើយដីជាកម្មវត្ថុនៃការជួល នៅមិនទាន់មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុនៅឡើយនោះ កិច្ចសន្យាជួលត្រូវចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រី ឬប្រធានស្ថាប័ន ឬអភិបាលខេត្ត-ក្រុងពាក់ព័ន្ធ។

**មាត្រា៦**

សម្បទានដី ឬការជួលរយៈពេលវែងត្រូវធ្វើលេខាចារឹកនៅលើប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬលើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចេញវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលរយៈពេលវែង ឬវិញ្ញាបនបត្រសម្គាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ច។

រាល់ការដាក់បញ្ចាំ ឬការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬសិទ្ធិលើសម្បទានដីត្រូវធ្វើលេខាចារឹកលើវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលរយៈពេលវែង ឬលើវិញ្ញាបនបត្រសម្គាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ច។

**មាត្រា៧**

ភតិកៈ ឬសម្បទានិកមានសិទ្ធិក្នុងការដាក់បញ្ចាំ ឬការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬសិទ្ធិលើសម្បទានដី រួមជាមួយនឹងអគារ ឬ/និងអចលនវត្ថុដទៃទៀតដែលខ្លួនបានវិនិយោគ

លើដី លើកលែងតែមានការចែងផ្សេងពីនេះ ក្នុងកិច្ចសន្យាជួល ឬកិច្ចសន្យាសម្បទាន ឬការកំណត់នៃច្បាប់ ។

**មាត្រា៨**

នៅពេលដែលភតិកៈ ឬសម្បទានិកស្លាប់ ទាយាទរបស់មតកជនអាចបន្តសិទ្ធិក្នុងកិច្ចសន្យាជួល ឬសម្បទានដីបានត្រឹមតែក្នុងរយៈពេលនៃកិច្ចសន្យាជួលរយៈពេលវែង ឬកិច្ចសន្យាសម្បទានដីតែប៉ុណ្ណោះ ។

រូបវន្តបុគ្គល ឬនីតិបុគ្គល ឬក្រុមមនុស្សដែលបានទទួលការអនុញ្ញាតឱ្យជួលដីពីរដ្ឋអាចជួលបន្តទៅឱ្យតតិយជនបាន បើមានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ចជាមុន ។

**មាត្រា៩**

ក្នុងករណីណាក៏ដោយ ម្ចាស់បំណុលមិនអាចក្លាយជាកម្មសិទ្ធិករ និងគ្មានសិទ្ធិទាមទារសិទ្ធិកម្មសិទ្ធិលើអចលនវត្ថុដែលកូនបំណុលរបស់ខ្លួនបានជួល ឬបានទទួលសម្បទាន ហើយបានវិនិយោគ និងយកសិទ្ធិជួល ឬសិទ្ធិសម្បទាននេះទៅដាក់បញ្ចាំបានឡើយ ។ កិច្ចសន្យាទាំងឡាយដែលចែងផ្ទុយពីនេះត្រូវទុកជាមោឃៈ ។

ម្ចាស់បំណុលមានសិទ្ធិប្ដឹងកូនបំណុលដែលបានដាក់បញ្ចាំសិទ្ធិទៅតុលាការ ដើម្បីដោះស្រាយស្របតាមច្បាប់ និងនីតិវិធីជាធរមាន យកមកសងបំណុលតាមបុព្វសិទ្ធិ និងបុរិមាដែលខ្លួនមានជាងម្ចាស់បំណុលដទៃទៀត ត្រឹមតែក្នុងអំឡុងពេលដែលមានចែងក្នុងកិច្ចសន្យាជួល ឬកិច្ចសន្យាសម្បទានប៉ុណ្ណោះ ។

ម្ចាស់បំណុលគ្មានសិទ្ធិទាមទារនូវសិទ្ធិចាត់ចែងលើអចលនទ្រព្យដែលកូនបំណុលរបស់ខ្លួនបានទទួលជួល ឬសម្បទានពីភាគីទីពបានឡើយ ។

**មាត្រា១០**

វិញ្ញាបនបត្រសម្គាល់សិទ្ធិជួលរយៈពេលវែង និងវិញ្ញាបនបត្រសម្គាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ចមានកំណត់អំពីប្រភេទអចលនវត្ថុ ទំហំ ទីតាំង អត្តសញ្ញាណនៃកម្មសិទ្ធិករ អត្តសញ្ញាណភតិកៈ ឬសម្បទានិក និងរយៈពេលនៃការជួល ឬសម្បទាន ។ គំរូនៃវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលរយៈពេលវែង និងវិញ្ញាបនបត្រសម្គាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ចជាឧបសម្ព័ន្ធទី១ និងទី២នៃអនុក្រឹត្យ ។

*វាយឡើងវិញ*

សោហ៊ុយសេវាចេញវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលរយៈពេលវែង វិញ្ញាបនបត្រសម្គាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ច និងការធ្វើលេខាចារឹកត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា១១**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១២**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អភិបាលគ្រប់ខេត្ត ក្រុង គ្រប់ប្រធានស្ថាប័ន អង្គភាពដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៧

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី

-ដូចមាត្រា១២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

*វាយឡើងវិញ*

*ឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យលេខ១១៤ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៧*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## វិញ្ញាបនបត្រសម្គាល់សិទ្ធិជួលរយៈពេលវែង

**លេខ.............................**

| | | | |
|---|---|---|---|
| ខេត្ត | .......................... | សន្លឹកផែនទីលេខ | 5930-II 65 |
| ស្រុក | .......................... | លេខក្បាលដី | 21040202-0245 |
| ឃុំ | .......................... | ទំហំ | 1660 ម$^{២}$ |
| ភូមិ | .......................... | ប្រភេទដី........................................... | |




រូបភាពប្រើប្រាស់ដី...............................

កម្មសិទ្ធិករនៃដី..................................

រយៈពេល......ឆ្នាំ ចាប់ពី.......ដល់............

ភ្នំពេញ, ថ្ងៃទី......ខែ..........ឆ្នាំ២០០៧

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី**

**នគរូបនីយកម្ម និងសំណង់**

មាត្រដ្ឋាន1/2000

*វាយឡើងវិញ*

## តារាងផ្លាស់ប្តូរ

| អត្រានុកូលដ្ឋានគតិកៈ | | | ការផ្លាស់ប្តូរ | | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| នាមត្រកូល និងនាមខ្លួន / ប្រភេទទ្រព្យ | ថ្ងៃ ខែ ឆ្នាំ ទីកន្លែងកំណើត | សាវតារ | លេខាចារឹកដោយសង្ខេបនៃលិខិតសញ្ញា ឬសាលក្រមតុលាការ | បន្ទុកលើអចលនវត្ថុ | |
| ១ | ២ | ៣ | ៤ | ៥ | ៦ |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

*វាយឡើងវិញ*

*ឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យលេខ១១៤ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៧*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# វិញ្ញាបនបត្រសម្គាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ច

**លេខ..............................**

| | | | |
|---|---|---|---|
| ខេត្ត | ......................... | សន្លឹកផែនទីលេខ | 5930-II 65 |
| ស្រុក | ......................... | លេខក្បាលដី | 21040202-0245 |
| ឃុំ | ......................... | ទំហំ | 1660 ម$^{២}$ |
| ភូមិ | .......................... | ប្រភេទដី........................................... | |

រូបភាពប្រើប្រាស់ដី...............................

កម្មសិទ្ធិករនៃដី...................................

រយៈពេល......ឆ្នាំ ចាប់ពី.......ដល់............




ភ្នំពេញ, ថ្ងៃទី......ខែ..........ឆ្នាំ២០០៧

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី**

**នគរូបនីយកម្ម និងសំណង់**

មាត្រដ្ឋាន1/2000

*វាយឡើងវិញ*

## តារាងផ្លាស់ប្តូរ

| អត្រានុកូលដ្ឋានសម្បទានិក | | | ការផ្លាស់ប្តូរ | | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| នាមត្រកូល និងនាមខ្លួន / ប្រភេទទ្រព្យ | ថ្ងៃ ខែ ឆ្នាំ ទីកន្លែងកំណើត | សាវតារ | លេខាចារឹកដោយសង្ខេបនៃលិខិតសញ្ញា ឬសាលក្រមតុលាការ | បន្ទុកលើអចលនវត្ថុ | |
| ១ | ២ | ៣ | ៤ | ៥ | ៦ |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ**

**លេខ២៧៣អសដភ** ភ្នំពេញ ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៧

**សេចក្តីណែនាំ**

**ស្តីពីវិធីកែតម្រូវឯកសារផ្លូវការ និង Digital**

**(សម្រាប់នីតិវិធីចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ)**

ឯកសារទាក់ទងនឹងសិទ្ធិលើដីធ្លី (អចលនវត្ថុ) ជាឯកសារប្រវត្តិសាស្ត្រ និងគតិយុត្តដែលទាមទារត្រូវមានគុណភាពខ្ពស់ ទាំងរូបភាព និងខ្លឹមសារ ហើយដែលត្រូវធានាដោយស្ថាប័នជំនាញរបស់រដ្ឋដែលទទួលបន្ទុកកិច្ចការនេះ។

ដោយសង្កេតឃើញ រយៈកាលកន្លងមក ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធនៅមានកំហុសផ្នែកបច្ចេកទេសក្នុងការកំណត់អត្តសញ្ញាណក្បាលដី ដោយព្រំប្រទល់រដ្ឋបាលមិនទាន់បានកំណត់ច្បាស់លាស់ ព្រំដីសាធារណៈមិនទាន់ត្រូវបានកំណត់ ម្ចាស់ដីខ្លះមិនបានចូលរួមពិនិត្យទិន្នន័យពេលបិទផ្សាយជាសាធារណៈ និងកង្វះការត្រួតពិនិត្យម៉ត់ចត់ពេលបញ្ចូលទិន្នន័យក្នុងកុំព្យូទ័រ និងពេលបោះពុម្ពប័ណ្ណចេញ បណ្តាលឱ្យក្បាលដីខ្លះខុសទីតាំងពិតប្រាកដ ក្បាលដីខ្លះត្រួតលើគ្នាទាំងមូល ឬចំណែកខ្លះ ក្បាលដីខ្លះខុសទំហំ ក្បាលដីខ្លះត្រូវបានកត់ត្រាទំហំខុសគ្នាក្នុងសៀវភៅគោលបញ្ជីដីធ្លី និងក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ករណីខ្លះទៀត វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុត្រូវបាត់មុនពេលចែកជូនម្ចាស់ដី។ ជារឿយៗ ក្រោយពេលចែកប័ណ្ណរួច តែងតែមានការតវ៉ាពីសាមីម្ចាស់នៃក្បាលដីទាំងអស់នោះ ធ្វើឱ្យមន្ត្រីជំនាញស្មុគស្មាញក្នុងការដោះស្រាយ។

ដើម្បីដោះស្រាយកង្វះខាតដូចបានពោលខាងលើ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រសូមធ្វើការណែនាំដូចតទៅ៖

**១-កំហុសទាក់ទងនឹងអត្តសញ្ញាណនៃក្បាលដី**

មានន័យថា ការកំណត់ក្បាលដីមួយខុសពីទីតាំងពិតប្រាកដនៃក្បាលដីនោះ ដូច្នេះក្បាលដីមួយត្រូវបិតនៅលើទីតាំងនៃក្បាលដីមួយទៀត ឬក្បាលដីមួយត្រួតលើក្បាលដីមួយទៀត ឬក្បាល

ដីពីរមានមួយចំណែកត្រួតលើគ្នា។ ក្បាលដីទាំងនោះអាចមានទំហំស្មើគ្នា សណ្ឋានទ្រង់ទ្រាយដូចគ្នា ហើយក៏អាចមានទំហំខុសគ្នា ឬសណ្ឋានទ្រង់ទ្រាយមិនដូចគ្នា ដូច្នេះ ប្រសិនបើចង់កែតម្រូវក្បាលដីណាមួយ គឺត្រូវកែតម្រូវក្បាលដីដែលមានការពាក់ព័ន្ធគ្នាទាំងអស់ជាចាំបាច់។

ចំណុចដែលត្រូវកែមាន៖

ក-ក្នុងឯកសារជាក្រដាស

១-ត្រូវពិនិត្យដល់ទីកន្លែង និងធ្វើអត្តសញ្ញាណកម្មក្បាលដីទាំងអស់នោះឱ្យបានត្រឹមត្រូវឡើងវិញរួច

-ក្នុងប្លង់សុរិយោដី ត្រូវដាក់លេខសាជាថ្មីសម្រាប់ក្បាលដីដែលត្រូវកែ ដោយយកលេខបន្តពីលេខចុងក្រោយក្នុងប្លង់សុរិយោដីនៃភូមិនោះ (ប្រើទឹកពណ៌ក្រហម) ឯលេខក្បាលដីចាស់ត្រូវឆូតចោលដោយប្រើទឹកពណ៌ក្រហម

-ក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ត្រូវកែលេខក្បាលដី និងទំហំនៃក្បាលដីឱ្យត្រឹមត្រូវតាមជាក់ស្តែង កែលេខក្បាលដីជាប់ព្រំ ដោយឆូតទឹកពណ៌ក្រហម ហើយសរសេរលេខថ្មីជំនួសដោយទឹកពណ៌ក្រហមនៅក្នុងបញ្ជីឈ្មោះម្ចាស់ដី ក៏ត្រូវកែតម្រូវលេខក្បាលដីដូចគ្នាដែរ។

-ក្នុងសៀវភៅគោលបញ្ជីដីធ្លី ត្រូវសរសេរក្នុងទំព័របម្រុងទុក ឯទំព័រដែលសរសេរខុសត្រូវបោះត្រាមោឃភាពចោល។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុចាស់ដែលផ្ទុកដោយទិន្នន័យខុស ត្រូវបោះត្រាមោឃភាពចោល ហើយបោះពុម្ពវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុថ្មីតាមទិន្នន័យថ្មី។

២-ករណីក្បាលដីដែលត្រូវកែទិន្នន័យនេះ មានព្រំណាមួយមិនទាន់បានកំណត់ ឬបានកំណត់ម្តងហើយ តែត្រូវកែប្រែទៅតាមទិន្នន័យដែលបានធ្វើអត្តសញ្ញាណកម្មឡើងវិញត្រឹមត្រូវហើយនោះត្រូវយកឯកសារដែលបានបញ្ចូលទិន្នន័យថ្មី ឬឯកសារដែលមានទិន្នន័យកែប្រែនេះទៅបិទផ្សាយជាសាធារណៈរយៈពេល៣០ថ្ងៃ រួចធ្វើរបាយការណ៍ស្នើសុំការសម្រេចពីអភិបាលខេត្ត-ក្រុងឡើងវិញ ចំពោះក្បាលដីនោះ ទើបអាចចេញប័ណ្ណជូនអ្នកស្នើសុំបាន។ ការបិទផ្សាយជាសាធារណៈត្រូវបានលើកលែងចំពោះករណីក្បាលដីដែលមានសល់ជ្រុងខ្លះមិនទាន់បានកំណត់ព្រំច្បាស់លាស់ ឬជ្រុងខ្លះត្រូវបានកែប្រែ ហើយម្ចាស់នៃក្បាលដីដែលមានព្រំជាប់គ្នានោះ បានទទួលស្គាល់ព្រំថ្មីនេះ និងក្នុងករណីព្រំត្រូវបានកំណត់ដោយតុលាការ ឬដោយគណៈកម្មការសុរិយោដី (ពេលអនុវត្តសេចក្តីសម្រេចរបស់តុលាការ ឬសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដី)។

ក្នុងករណីដែលក្បាលដីក្នុងប្លង់សុរិយោដីមានព្រំត្រឹមត្រូវ ហើយមិនបានធ្វើអ្វីឱ្យប៉ះពាល់ ឬត្រូវកែប្រែអ្វីទេ ប៉ុន្តែទំហំក្នុងឯកសារ និងប័ណ្ណសរសេរខុស នោះមន្ត្រីជំនាញត្រូវពិនិត្យ និងកែតម្រូវឱ្យបានត្រឹមត្រូវ ក្នុងឯកសារពាក់ព័ន្ធ ហើយបោះពុម្ពប័ណ្ណជូនតែម្តងដោយមិនចាំបាច់បិទផ្សាយទិន្នន័យជាសាធារណៈទៀតឡើយ ។

<u>**ចំណាំ**</u> នៅគ្រប់ចំណុច និងខ្លឹមសារកែប្រែលើឯកសារផ្លូវការ ត្រូវមានដាក់លេខយោង ដើម្បីសរសេរបញ្ជាក់អំពីឯកសារបទាល់ដែលនាំឱ្យកែ រួចចុះហត្ថលេខា និងបោះត្រា សមត្ថកិច្ចដែលបានកែតម្រូវ (ប្រធានមន្ទីរដនសស) នៅកន្លែងណាមួយនៃប្លង់សុរិយោដី ឬឯកសារពាក់ព័ន្ធ។ អក្សរ និងលេខដែលសរសេរអំពីចំណុច និងខ្លឹមសារដែលត្រូវកែ ត្រូវប្រើទឹកពណ៌ក្រហម ហើយហត្ថលេខា និងត្រារបស់សមត្ថកិច្ច ត្រូវប្រើទឹកបោះពណ៌ខៀវ ឬខ្មៅ ។

ខ-ទិន្នន័យក្នុងឌីជីថល (Digital)

ទិន្នន័យមូលដ្ឋាន/សៀវភៅគោលបញ្ជីដីធ្លី និងប្លង់សុរិយោដី ។

មន្ត្រីគ្រប់គ្រងទិន្នន័យត្រូវពិនិត្យឱ្យបានត្រឹមត្រូវ ហើយកែឱ្យដូចគ្នា និងទិន្នន័យក្នុងឯកសារជាក្រដាស ។

**២-ករណីបាត់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុមុនពេលប្រគល់**

នៅខេត្ត-ក្រុងអនុវត្តគម្រោងមួយចំនួនបានបោះពុម្ពវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុរួចហើយ ថែមទាំងបានថតចម្លងទុកជាឯកសារទៀតផង ប៉ុន្តែវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុមួយចំនួនត្រូវបាត់ រកពុំឃើញ ហើយត្រូវបានម្ចាស់ដីស្នើសុំ។ ករណីនេះ តម្រូវឱ្យមន្ទីរដនសស. អនុវត្តនីតិវិធីនៃការផ្តល់ប័ណ្ណទុតិយតាដែលមានដំណាក់កាលបន្តបន្ទាប់ គឺការបិទប្រកាសរកប័ណ្ណដែលបាត់ ការធ្វើប្រកាសមោឃភាពប័ណ្ណដែលបាត់ ហើយរកមិនឃើញ និងការចេញប័ណ្ណទុតិយតាជូនម្ចាស់ដី ។

គួរកត់សម្គាល់ថា ប័ណ្ណដែលបោះពុម្ពលើកក្រោយមានទិន្នន័យដូចគ្នានឹងប័ណ្ណដែលបាត់ ប៉ុន្តែលេខទំព័រនៃប័ណ្ណមិនដូចគ្នាទេ ។

សេចក្តីណែនាំនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**អគ្គនាយក**

**ហត្ថលេខា និងត្រា**

**លឹម វ៉ាន់**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ០៦សរណន** រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៧

## សារាចរណែនាំ
## ស្តីពីការអនុវត្តផែនការបែងចែកសម្បទានដីសង្គមកិច្ច

រាជរដ្ឋាភិបាលបានពិនិត្យឃើញថា ចាប់ពីប្រទេសជាតិបានទទួលសន្តិភាពពេញលេញដោយសារនយោបាយឈ្នះឈ្នះ បានធ្វើឱ្យសភាពការណ៍កម្ពុជាមានការរីកចម្រើនយ៉ាងឆាប់រហ័ស។ សភាពការណ៍សេដ្ឋកិច្ច សង្គម ក្នុងនេះទីផ្សារដីមានការវិវត្តប្រែប្រួលយ៉ាងលឿន ធ្វើឱ្យដីធ្លីមិនគ្រាន់ដែលជាមធ្យោបាយផលិតកម្មប៉ុណ្ណោះទេ តែជាប្រភពធនធានហិរញ្ញវត្ថុយ៉ាងសំខាន់របស់ប្រជាពលរដ្ឋ ក្នុងការកែលំអជីវភាពរស់នៅ ក៏ដូចជាការវិនិយោគលើគ្រប់ផ្នែក។ ទន្ទឹមនេះ អត្រាកំណើនខ្ពស់នៃប្រជាពលរដ្ឋ និងការវិវត្តដ៏លឿននៃទីផ្សារដី បានធ្វើឱ្យមានតម្រូវការដីធ្លីសម្រាប់សាងសង់លំនៅឋាន និងប្រកបរបរកសិកម្ម ពិសេសចំពោះគ្រួសារក្រីក្រ និងយោធិនរំសាយ ក៏បានកើនឡើងដែរ។ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច សម្រាប់គាំទ្រដល់ការអនុវត្តគោលនយោបាយបែងចែកដីធ្លីប្រកបដោយសមធម៌ ដូចដែលមានចែងក្នុងឯកសារបឋមស្តីពីក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី។ អនុវត្តនូវស្មារតីនៃអនុក្រឹត្យនេះ រាជរដ្ឋាភិបាលបានធ្វើការបែងចែកដី និងធ្វើនិយតកម្មការកាន់កាប់ដីធ្លីដោយប្រជាពលរដ្ឋក្រីក្រសម្រាប់ប្រជាពលរដ្ឋរាប់ម៉ឺនគ្រួសារជាបន្តបន្ទាប់។

ដើម្បីជំរុញការអនុវត្តឱ្យបានជោគជ័យនូវកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០០៦-២០១០ ដែលបានកំណត់ឱ្យជំរុញការបែងចែកដីសម្បទានសង្គមកិច្ច

ដល់គ្រួសារក្រីក្រដែលខ្វះដី និង/ឬគ្មានដីឱ្យបានយ៉ាងតិច១០.០០០គ្រួសារដល់ឆ្នាំ២០០៨ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចខាងក្រោម៖

១-អភិបាលគ្រប់ខេត្ត-ក្រុងដែលជាប្រធានគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីខេត្តក្រុង ត្រូវរៀបចំផែនការបែងចែកដីសម្បទានសង្គមកិច្ចទាំងការជ្រើសរើសដី ការធ្វើផែនការប្រើប្រាស់ដី និងការជ្រើសរើសមុខសញ្ញាអ្នកទទួលដីចាប់ពីពេលនេះ រហូតដល់ពាក់កណ្តាលឆ្នាំ២០០៨ ក្នុង០១ខេត្ត-ក្រុង ឱ្យបានយ៉ាងតិចជាមធ្យមសម្រាប់៤១៦គ្រួសារ។ ចំពោះខេត្ត-ក្រុងណាដែលមានលទ្ធភាពដីច្រើន ត្រូវធ្វើការជ្រើសរើសដីឱ្យបានលើសមធ្យមភាគខាងលើ ដើម្បីរួមចំណែកជួយដោះស្រាយដល់ខេត្ត-ក្រុងដែលខ្វះដី។ ទន្ទឹមនឹងនេះ ត្រូវកសាងផែនការអភិវឌ្ឍន៍ទីតាំងបែងចែកដីសម្បទានសង្គមកិច្ច ដើម្បីរៀបចំផែនការថវិកាចំណាយបញ្ចូលក្នុងគម្រោងថវិកាជាតិឆ្នាំ២០០៩។ ផែនការអភិវឌ្ឍន៍នេះត្រូវយកចិត្តទុកដាក់ជាសំខាន់ ធ្វើឱ្យមានការប្រែប្រួលខាងជីវភាព និងសុខុមាលភាពរបស់អ្នកទទួលដីសម្បទានសង្គមកិច្ចមានជាអាទិ៍ ប្រភពផ្គត់ផ្គង់ទឹក ផ្លូវថ្នល់ មណ្ឌលសុខភាព សាលារៀន ។ល។

២-គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ សហការជាមួយគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីណែនាំតម្រង់ទិសឱ្យគ្រប់ខេត្ត-ក្រុង ស្រុក-ខណ្ឌ ឃុំ-សង្កាត់ អនុវត្តឱ្យបានត្រឹមត្រូវតាមស្មារតីនៃអនុក្រឹត្យលេខ១៩អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច។

៣-គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិត្រូវរាយការណ៍តាមដំណាក់កាលការងារ ជូនរាជរដ្ឋាភិបាលស្តីពីលទ្ធផលនៃការអនុវត្តសារាចរនេះ។

ទទួលបានសារាចរណែនាំនេះ រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័ន អភិបាលគ្រប់ខេត្ត-ក្រុង ស្រុក-ខណ្ឌ ក្រុមប្រឹក្សាគ្រប់ឃុំ-សង្កាត់ត្រូវចាត់តាំងអនុវត្តតាមការណែនាំខាងលើ ដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាព។

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ២៦អនក្រ/បក

## អនុក្រឹត្យ

## ស្តីពីវិធាននៃការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ការដាំឈើ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ០១/នស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ/បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ៦៤អនក្រ/បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការ ប្តូរឈ្មោះនាយកដ្ឋានរុក្ខាប្រមាញ់ ទៅជារដ្ឋបាលព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ៥៣អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីនីតិវិធីការបង្កើត ការចាត់ថ្នាក់ និងការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍
- បានឃើញអនុក្រឹត្យ១១៨អនក្រ/បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី០៧ ខែមីនា ឆ្នាំ ២០០៨

## សម្រេច

## ជំពូកទី១ បទប្បញ្ញត្តិទូទៅ

**មាត្រា១**

អនុក្រឹត្យនេះមានគោលដៅកំណត់នូវវិធានផ្តល់សិទ្ធិប្រើប្រាស់របស់រដ្ឋសម្រាប់ដាំឈើនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២**

អនុក្រឹត្យនេះមានគោលបំណងបង្កើនផលិតភាព និងសេវាកម្មព្រៃឈើធានាដល់ការរក្សាការពារគម្របព្រៃឈើ និងផ្គត់ផ្គង់ឈើសម្រាប់តម្រូវការប្រើប្រាស់ទូទៅ ស្របតាមគោលនយោបាយ និងផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិ។

## ជំពូកទី២ ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចទទួលខុសត្រូវ

**មាត្រា៣**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសមត្ថកិច្ចលើការគ្រប់គ្រងដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើដូចខាងក្រោម៖

-ចេញប្រកាសកំណត់ ឬបដិសេធ ឬរំសាយតំបន់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ តាមសំណើរបស់រដ្ឋបាលព្រៃឈើ

-ផ្តល់ការអនុញ្ញាតជូនរដ្ឋបាលព្រៃឈើ ក្នុងការចុះកិច្ចព្រមព្រៀងជាមួយនឹងសហគមន៍មូលដ្ឋាន សហគមន៍ព្រៃឈើ ឬបុគ្គលជាលក្ខណៈគ្រួសារ ក្នុងការប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ

-សហការ ឬសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ ដើម្បីជំរុញការគ្រប់គ្រង និងប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើឱ្យមានប្រសិទ្ធភាព។

**មាត្រា៤**

រដ្ឋបាលព្រៃឈើមានតួនាទីពង្រឹងការអនុវត្តច្បាប់ បច្ចេកទេស វាយតម្លៃនូវរាល់សកម្មភាពដាំឈើ និងវាយតម្លៃការប្រមូលផលឈើដែលត្រូវដាំគ្រប់ប្រភេទ ដើម្បីធានាដល់ការប្រើប្រាស់ធនធានព្រៃឈើ និងផលិតផលព្រៃដែលត្រូវដាំឱ្យមានប្រសិទ្ធភាពខ្ពស់ និងមានភារកិច្ចដូចខាងក្រោម៖

-ផ្តល់លិខិតអនុញ្ញាតឱ្យដាំឈើលើដីព្រៃរបស់រដ្ឋ

-សិក្សាវាយតម្លៃ និងកំណត់តំបន់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ

-លើកសំណើជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីចេញប្រកាសកំណត់ ឬបដិសេធ ឬរំសាយតំបន់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ

-ចុះហត្ថលេខាជាមួយសហគមន៍មូលដ្ឋាន សហគមន៍ព្រៃឈើ ឬបុគ្គលជាលក្ខណៈគ្រួសារ លើកិច្ចព្រមព្រៀងផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ

-ពិនិត្យ និងសម្រេចលើផែនការគ្រប់គ្រងព្រៃដាំ

-ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តកិច្ចព្រមព្រៀងលើដំណើរការដាំឈើ

-សម្របសម្រួលជាមួយស្ថាប័ន អង្គភាព និងភាគីពាក់ព័ន្ធ ក្នុងការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ

-សម្របសម្រួល និងដោះស្រាយទំនាស់ដែលអាចកើតមាន ក្នុងអំឡុងពេលដំណើរការអនុវត្តកិច្ចព្រមព្រៀង

-ផ្តល់សេវាកម្មបច្ចេកទេសលើការងារដាំឈើ

## ជំពូកទី៣ លក្ខខណ្ឌ និងនីតិវិធីនៃការស្នើសុំ និងការសម្រេចផ្ដល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ

**មាត្រា៥**

ផ្ទៃដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងចំណោតថ្នាក់ណាមួយជាព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងបានចុះបញ្ជិកានៅរដ្ឋបាលព្រៃឈើតាមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីព្រៃឈើ ។

**មាត្រា៦**

ការដាំដើមឈើនៅលើដីព្រៃរបស់រដ្ឋអាចធ្វើឡើងដោយៈ

-រដ្ឋបាលព្រៃឈើ

-សហគមន៍ព្រៃឈើ

-រដ្ឋបាលព្រៃឈើដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន ឬផ្នែកឯកជន

-ប្រជាពលរដ្ឋ ឬបុគ្គលជាលក្ខណៈគ្រួសារ ។

**មាត្រា៧**

រាល់សំណើសុំដាំឈើលើព្រៃរបស់រដ្ឋនីមួយៗ រដ្ឋបាលព្រៃឈើត្រូវពិនិត្យវាយតម្លៃ និងលើកយោបល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីពិនិត្យ និងសម្រេចដោយផ្អែកលើលទ្ធភាពដីព្រៃរបស់រដ្ឋ ស្របទៅតាមលក្ខណវិនិច្ឆ័យដូចតទៅៈ

-តំបន់ដីព្រៃដែលងាយរងគ្រោះដោយសារគ្រោះធម្មជាតិ ទឹកជំនន់ រាំងស្ងួត និងខ្យល់ព្យុះ

-តំបន់ដីព្រៃរេចរិល ភ្នំរេចរិល ព្រៃត្រូវភ្លើងឆេះ ឬទីវាលរហោស្ថានដែលមិនទាន់មានការអភិវឌ្ឍ

-តំបន់ដីព្រៃដែលត្រូវស្ដារព្រៃឈើឡើងវិញ

-តំបន់ដីព្រៃបម្រុងទុកសម្រាប់ដាំឈើឡើងវិញ

-តំបន់ដីព្រៃការពារប្រភពទឹក និងរក្សានិយតកម្មប្រភពទឹក

-តំបន់ដីព្រៃអតីតព្រៃសម្បទាន ឬតំបន់ដីសម្បទានដែលត្រូវបានដកហូតជាសម្បត្តិរដ្ឋវិញ

-ស្ថានីយដាំឈើរបស់រដ្ឋ

-តំបន់ដីព្រៃផ្សេងៗទៀតដែលមានសក្តានុពលសមប្រកប សម្រាប់តែការដាំដុះដើមឈើឡើងវិញ។

ដំណើរការពិនិត្យ និងវាយតម្លៃលើសំណើនីមួយៗត្រូវមានការពិគ្រោះយោបល់ ជាមួយអាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋាន។

**មាត្រា៨**

ការស្នើសុំសិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើអាចនឹងប្រព្រឹត្តទៅក្រោមរូបភាពខាងក្រោម៖

-តាមការអំពាវនាវរកដៃគូ អភិវឌ្ឍដាំឈើលើដីព្រៃរបស់រដ្ឋ ស្របតាមទីតាំង ទំហំ ស្ថានភាពភូមិសាស្ត្រដែលនឹងត្រូវកំណត់ក្នុងប្រកាសស្តីពីការបង្កើតផ្ទៃដីព្រៃរបស់រដ្ឋ សម្រាប់ដាំឈើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

-តាមការធ្វើសំណើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ស្នើសុំសិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ តាមរយៈរដ្ឋបាលព្រៃឈើ មកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធផ្សេងទៀតតាមការកំណត់របស់រដ្ឋបាលព្រៃឈើ។

**មាត្រា៩**

ការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើធ្វើឡើងដោយរដ្ឋបាលព្រៃឈើដោយមានការចូលរួមពីផ្នែកឯកជន ត្រូវមានការអនុញ្ញាតពីរាជរដ្ឋាភិបាល។

ការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ ធ្វើឡើងរដ្ឋបាលព្រៃឈើ ដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន សហគមន៍ព្រៃឈើ ប្រជាពលរដ្ឋ ឬបុគ្គលជាលក្ខណៈគ្រួសារ ត្រូវមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយត្រូវចុះកិច្ចព្រមព្រៀងដាំឈើលើដីព្រៃរបស់រដ្ឋជាមួយរដ្ឋបាលព្រៃឈើ។

រាល់ការដាំដើមឈើលើដីព្រៃរបស់រដ្ឋ តម្រូវឱ្យមានលិខិតអនុញ្ញាតដាំឈើ ចេញដោយរដ្ឋបាលព្រៃឈើ។

សម្រាប់គោលដៅនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវផ្តល់ព័ត៌មានអំពីការអនុញ្ញាតនេះ ដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាល់មុនដំណាច់ឆ្នាំនីមួយៗ។

**មាត្រា១០**

សហគមន៍មូលដ្ឋានដែលស្នើសុំសិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ ចាំបាច់ត្រូវមានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់។ សហគមន៍នីមួយៗត្រូវមានការទទួលស្គាល់ពីអាជ្ញាធរដែនដី។

ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើត្រូវបានផ្តល់អាទិភាពចំពោះសហគមន៍ ប្រជាពលរដ្ឋ ឬបុគ្គលជាលក្ខណៈគ្រួសារកំពុងរស់នៅក្នុង ឬក្បែរតំបន់ព្រៃដែលបានស្នើសុំ និងមានការទទួលស្គាល់ពីអាជ្ញាធរដែនដី។

តំណាងសហគមន៍មូលដ្ឋាន ប្រជាពលរដ្ឋ ឬបុគ្គលជាលក្ខណៈគ្រួសារដែលស្នើសុំដាំឈើលើដីព្រៃរបស់រដ្ឋត្រូវមានសញ្ជាតិខ្មែរ មានសមត្ថភាព និងមាននីតិភាពតាមច្បាប់ ដើម្បីទទួលបានសិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ។

ផ្នែកឯកជនដែលមានបំណងស្នើសុំសិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ ត្រូវមានទីស្នាក់ការរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានសមត្ថភាពហិរញ្ញវត្ថុ បច្ចេកទេស ហើយបានចុះបញ្ជិកា និងទទួលស្គាល់ដោយក្រសួង ឬស្ថាប័នមានសមត្ថកិច្ចនៃរាជរដ្ឋាភិបាលកម្ពុជា។

**មាត្រា១១**

ផលប្រយោជន៍ដែលទទួលបានពីការដាំឈើលើដីព្រៃរបស់រដ្ឋ ត្រូវធ្វើការបែងចែករវាងរដ្ឋ និងអ្នកទទួលបានសិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ ដូចមានចែងនៅក្នុងមាត្រា១២ នៃអនុក្រឹត្យនេះ។

**ជំពូកទី៤ កិច្ចព្រមព្រៀងផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ**

**មាត្រា១២**

ខ្លឹមសារ និងល័ក្ខខ័ណ្ឌអប្បបរមានៃកិច្ចព្រមព្រៀងផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ អនុវត្តចំពោះរដ្ឋបាលព្រៃឈើដោយមានការចូលរួមពីផ្នែកឯកជន និងរដ្ឋបាលព្រៃឈើដោយមានការចូលរួមពីសហគមន៍មូលដ្ឋានយ៉ាងហោចណាស់ត្រូវមានចែងពី៖

-កាលបរិច្ឆេទនៃការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋ និងសុពលភាពនៃកិច្ចព្រមព្រៀង

-ការកំណត់ទីតាំង និងទំហំផ្ទៃដីដែលត្រូវផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ ដោយមានផែនទីបញ្ជាក់និយាមកាច្បាស់លាស់

-ប្រភេទដើមឈើដែលត្រូវដាំ និងវិធីសាស្រ្តរុក្ខវប្បកម្មដែលត្រូវអនុវត្ត

-ការប្រមូលផល និងការដាំឈើឡើងវិញ នៅខួបលើកក្រោយៗទៀត

-ការអធិប្បាយពីសិទ្ធិ និងការទទួលខុសត្រូវរបស់រដ្ឋបាលព្រៃឈើ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ល័ក្ខខ័ណ្ឌនៃការបែងចែកផលប្រយោជន៏

-ការអធិប្បាបាយពីកាតព្វកិច្ចរបស់អ្នកទទួលសិទ្ធិ ក្នុងការកសាង និងអនុវត្តគម្រោងផែនការគ្រប់គ្រងព្រៃដាំ

-ការត្រួតពិនិត្យ និងរាយការណ៍

-ការកំណត់ល័ក្ខខ័ណ្ឌផ្សេងទៀតដែលចាំបាច់ ដើម្បីធានាដល់ដំណើរការគ្រប់គ្រងដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើឱ្យមានចីរភាព និងប្រសិទ្ធភាព។

គំរូកិច្ចព្រមព្រៀងផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា១៣**

អ្នកទទួលសិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើអាចស្នើសុំបន្តកិច្ចព្រមព្រៀងបានដោយស្នើសុំជាលាយលក្ខណ៍អក្សរជូនរដ្ឋបាលព្រៃឈើ មុនពេលកិច្ចព្រមព្រៀងផុតសុពលភាពដើម្បីលើកសំណើជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទពិនិត្យ សម្រេច។

**មាត្រា១៤**

ការព្យួរ ការបញ្ឈប់ ការបញ្ចប់មុនកាលកំណត់ ការលុបចោលកិច្ចព្រមព្រៀង និងការដកហូតសិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើរវាងរដ្ឋបាលព្រៃឈើ ដោយមានការចូលរួមពីផ្នែកឯកជន ដោយសាររំលោភល័ក្ខខ័ណ្ឌកំណត់ក្នុងកិច្ចព្រមព្រៀង ឬដើម្បីបម្រើផលប្រយោជន៏សាធារណៈ សេដ្ឋកិច្ច សង្គម និងបរិស្ថានត្រូវសម្រេចដោយរាជរដ្ឋាភិបាល។

ការព្យួរ ការបញ្ឈប់ ការលុបចោលកិច្ចព្រមព្រៀង និងការដកហូតសិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន ដោយសារការអនុវត្តពុំបានត្រឹមត្រូវតាមកិច្ចព្រមព្រៀងត្រូវសម្រេចដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

មុនដំណាច់ឆ្នាំនីមួយៗ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវផ្តល់ព័ត៌មានអំពីការសម្រេចនេះ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ជំពូកទី៥ សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកទទួលសិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ**

**មាត្រា១៥**

អ្នកទទួលបានសិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើមានសិទ្ធិអភិវឌ្ឍ ប្រើប្រាស់ លក់ និងចែកចាយផលិតផលរបស់ខ្លួនបាន ស្របតាមកិច្ចព្រមព្រៀងជាមួយរដ្ឋបាលព្រៃឈើ ឬមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា១៦**

អ្នកទទួលបានសិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើមិនមានសិទ្ធិ៖

-លក់ ដោះដូរ ជួល ធ្វើអំណោយ ប្រវាស់ បែងចែក ឱ្យខ្ចី បញ្ចាំ ឬផ្ទេរដីព្រៃរបស់រដ្ឋទោះតាមរូបភាពណាក៏ដោយ។

-រុករករ៉ែគ្រប់ប្រភេទក្នុងដែនដីព្រៃរបស់រដ្ឋ

-ប្រើប្រាស់សម្រាប់ធ្វើស្រែចម្ការកសិកម្ម ឬសាងសង់លំនៅឋានក្រៅពីការដាំឈើបង្កើតជាព្រៃឡើយ។

**មាត្រា១៧**

អ្នកទទួលបានសិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើមានកាតព្វកិច្ចដូចតទៅ៖

-រៀបចំផែនការគ្រប់គ្រងព្រៃដាំដោយចីរភាព ស្របតាមការណែនាំរបស់រដ្ឋបាលព្រៃឈើ

-អនុវត្តដំណើរការដាំដុះ និងគ្រប់គ្រងព្រៃដាំដោយចីរភាព ស្របតាមច្បាប់ លិខិតបទដ្ឋាន និងកិច្ចព្រមព្រៀង

-គោរព និងអនុវត្តតាមច្បាប់ លិខិតបទដ្ឋានបច្ចេកទេស និងតាមការណែនាំរដ្ឋបាលព្រៃឈើ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា១៨**

អ្នកទទួលបានសិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ ដែលបានជួបប្រទះនូវការរំលោភ ឬបទល្មើសព្រៃឈើជាក់ស្តែងក្នុងតំបន់ដីព្រៃរបស់រដ្ឋ ត្រូវរាយការណ៍ជាបន្ទាន់ដល់មន្ត្រីរដ្ឋបាលព្រៃឈើ ឬអាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតបំផុត ។ ក្នុងករណីនេះ អ្នកទទួលសិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ អាចឃាត់ខ្លួនជនប្រព្រឹត្តល្មើស និងបញ្ជូនទៅមន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចជាបន្ទាន់ ដើម្បីចាត់តាមនីតិវិធី ។

## ជំពូកទី៦ ផែនការគ្រប់គ្រងព្រៃដាំ

**មាត្រា១៩**

ការគ្រប់គ្រងព្រៃដាំប្រកបដោយចីរភាព និងប្រសិទ្ធភាពទាមទារឱ្យមានការធ្វើផែនការគ្រប់គ្រងចាំបាច់ទៅតាមកម្រិត ទំហំ និងពេលវេលា ។ ផែនការគ្រប់គ្រងព្រៃដាំត្រូវមានពីរកម្រិតគឺ៖

-ផែនការមេសម្រាប់គ្រប់គ្រងតំបន់ដែលបានទទួលសិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋ សម្រាប់ដាំឈើ

-ផែនការសកម្មភាពប្រចាំឆ្នាំ ។

អ្នកដែលទទួលបានសិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ ត្រូវរៀបចំផែនការគ្រប់គ្រងព្រៃដាំទាំងពីរកម្រិតខាងលើឱ្យស្របទៅតាមគោលការណ៍បច្ចេកទេស បទប្បញ្ញត្តិនានាសម្រាប់គ្រប់គ្រងព្រៃឈើដោយចីរភាព ហើយអាចជួលសេវាកម្មបច្ចេកទេស ឬស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលព្រៃឈើ និងត្រូវដាក់ជូនផែនការគ្រប់គ្រងព្រៃដាំទៅរដ្ឋបាលព្រៃឈើ ដើម្បីពិនិត្យសម្រេច ។

**មាត្រា២០**

ផែនការគ្រប់គ្រងព្រៃដាំត្រូវមានសុពលភាពស្មើនឹងកិច្ចព្រមព្រៀងផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ ។ ផែនការគ្រប់គ្រងព្រៃដាំត្រូវបានពិនិត្យឡើងវិញដោយរដ្ឋបាលព្រៃ

ឈើរៀងរាល់០៥ (ប្រាំ) ឆ្នាំម្តង ឬមុនរយៈពេលនេះ ប្រសិនបើចាំបាច់។ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការគ្រប់គ្រងព្រៃជាំត្រូវមានការចូលរួមពីភាគីនៃកិច្ចព្រមព្រៀង។

**ជំពូកទី៧ អវសានប្បញ្ញត្តិ**

**មាត្រា២១**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា២២**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្ត-ក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៨

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u>

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី

-ដូចមាត្រា២២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ០១ដនស/សណន/អសដភ ភ្នំពេញ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៨

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជម្រាបមក**

**លោក លោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់**
**និងសុរិយោដីគ្រប់ខេត្ត-ក្រុង**

**កម្មវត្ថុ៖** គោលការណ៍ណែនាំស្តីពីការចុះបញ្ជីដីសម្បទានសេដ្ឋកិច្ច

**យោង៖** អនុក្រឹត្យលេខ១៤៦អនក្រ/បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច

ន័យដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក លោកស្រីជ្រាបថា អនុលោមតាមអនុក្រឹត្យលេខ១៤៦អនក្រ/បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច ដីដែលនឹងត្រូវផ្តល់ជាសម្បទានដីសេដ្ឋកិច្ចត្រូវតែជាដីដែលត្រូវបានចុះបញ្ជីជាដីឯកជនរបស់រដ្ឋ។ ក្នុងន័យនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បាននិងកំពុងខិតខំជំរុញដំណើរការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ តាមរយៈការចុះបញ្ជីដីរដ្ឋ សំដៅបម្រើឱ្យការផ្តល់សម្បទានដី ទាំងសម្បទានដីសង្គមកិច្ច ទាំងសម្បទានដីសេដ្ឋកិច្ច និងសម្បទានផ្សេងៗទៀត។

ដើម្បីកុំឱ្យរាំងស្ទះដល់ការវិនិយោគតាមរយៈសម្បទានដីសេដ្ឋកិច្ច ក្រសួងសូមធ្វើការណែនាំដល់លោក លោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីយកចិត្តទុកដាក់ជំរុញការចុះបញ្ជីដីសម្បទាន ដោយត្រូវអនុវត្តតាមវិធីសាស្ត្រដូចខាងក្រោម៖

**១-ការចុះបញ្ជីដីសម្បទានដែលបានចុះកិច្ចសន្យារួចហើយ**

អនុលោមតាមស្មារតីលិខិតលេខ១១៩៦ដនស/អសដ ចុះថ្ងៃទី០៣-១០-០៧ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ការចុះបញ្ជីដីសម្បទានសេដ្ឋកិច្ចត្រូវធ្វើឱ្យបានសម្រេចក្នុង

រយៈពេល៣ខែ ចាប់ពីថ្ងៃទទួលសំណើ។ ដូចនេះ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត-ក្រុងដែលមានការវិនិយោគតាមរយៈសម្បទានដីសេដ្ឋកិច្ចត្រូវ៖

-ជូនដំណឹងទៅក្រុមហ៊ុនម្ចាស់សំណើឱ្យបោះបង្គោលរឹងមាំតាមព្រំដី

-លើកសំណើសុំមន្ត្រីបច្ចេកទេសចុះវាស់វែង និងកសាងប្លង់ដីសម្បទាន បន្ទាប់ពីបានបោះបង្គោលព្រំដីរួច។ ទន្ទឹមនេះ ត្រូវត្រៀមមន្ត្រីជំនាញនៅមន្ទីរ១រូប និងនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុកពាក់ព័ន្ធ១រូប ដើម្បីចូលរួមអនុវត្តការងារវាស់វែង។ មុនថ្ងៃកំណត់ចុះវាស់វែង មន្ទីរត្រូវជូនដំណឹងទៅអាជ្ញាធរមូលដ្ឋានជ្រាប និងសហការចូលរួម។

-ជូនប្លង់ដីកសាងបានទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ដើម្បីធ្វើចំណាត់ថ្នាក់ដី (បើមិនទាន់ជ្រះស្រឡះដោយជាប់ពាក់ព័ន្ធនឹងដីសាធារណៈរបស់រដ្ឋ ត្រូវលើកសំណើធ្វើអនុបយោគទីតាំងនេះ)

-បិទផ្សាយជាសាធារណៈនូវប្លង់ដីសម្បទានរយៈពេល៣០ថ្ងៃ

-ចុះបញ្ជីដីសម្បទាននូវចំណែកដែលមិនពាក់ព័ន្ធនឹងដីសាធារណៈរបស់រដ្ឋ និងដីប្រជាជន...។

២-<u>**ការចុះបញ្ជីដីសម្បទានដែលមិនទាន់បានចុះកិច្ចសន្យា**</u>

អ្នកវិនិយោគ ឬក្រុមហ៊ុនត្រូវដាក់ពាក្យស្នើសុំវិនិយោគលើដី ដោយត្រូវភ្ជាប់ជាមួយនូវប្លង់បង្ហាញទីតាំងដី (ផែនទី) ការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម (ESIA)។

មានជម្រើសពីរ៖

+បើទីតាំងវិនិយោគមានភាពស្មុគស្មាញត្រូវ៖

-បិទផ្សាយជាសាធារណៈនូវប្លង់បង្ហាញទីតាំងដីសម្បទាន ដែលជាកម្មវត្ថុនៃសំណើវិនិ-យោគ នៅឃុំ ស្រុក ខេត្ត រយៈពេល៣០ថ្ងៃ។

-ធ្វើអនុបយោគទីតាំងដីនេះ ចំពោះដីជាប់ពាក់ព័ន្ធនឹងដីសាធារណៈ

-ចុះកិច្ចសន្យាបណ្តោះអាសន្នរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអ្នកវិនិយោគ ឬក្រុមហ៊ុន។ ក្នុងដំណាក់កាលនៃកិច្ចសន្យាបណ្តោះអាសន្ននេះ អ្នកវិនិយោគ ឬក្រុមហ៊ុន រួមជាមួយស្ថាប័នមានសមត្ថកិច្ច ត្រូវខិតខំដោះស្រាយ សម្រុះសម្រួលជាមួយអ្នកពាក់ព័ន្ធឱ្យជ្រះស្រឡះ។

-លើកសំណើសុំមន្ត្រីបច្ចេកទេសពីអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ចុះវាស់វែង និងកសាងប្លង់ដីសម្បទានដែលមិនជាប់ពាក់ព័ន្ធនឹងដីសាធារណៈ និងដីប្រជាជន...។

-ចុះបញ្ជីដីជាដីឯកជនរបស់រដ្ឋ (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬសាលាខេត្ត)

-និងចុះកិច្ចសន្យាស្ថាពរ។

+បើទីតាំងវិនិយោគមិនមានភាពស្មុគស្មាញទេ ត្រូវ៖

-បិទផ្សាយជាសាធារណៈនូវប្លង់បង្ហាញទីតាំងដីសម្បទានដែលជាកម្មវត្ថុនៃសំណើវិនិយោគ នៅឃុំ ស្រុក ខេត្ត រយៈពេល៣០ថ្ងៃ។ ក្នុងរយៈពេលនេះ បើអាចធ្វើទៅបាន ត្រូវផ្សព្វផ្សាយទូលំទូលាយតាមកាសែត វិទ្យុ ទូរទស្សន៍

-ការសម្រេចលើអនុក្រឹត្យស្តីពីការធ្វើអនុបយោគទីតាំងនេះ ចំពោះដីជាប់ពាក់ព័ន្ធនឹងដីសាធារណៈ

-កសាងប្លង់ដីសម្បទាន ដោយកាត់ចេញនូវផ្ទៃដីពាក់ព័ន្ធនឹងប្រជាពលរដ្ឋ (ករណីមិនអាចដោះស្រាយសម្រុះសម្រួលបានជាមួយប្រជាពលរដ្ឋម្ចាស់ដី) ដីព្រៃឈើ ទីវត្តអារាម ទីកប់ខ្មោច សំណង់វប្បធម៌ ដីរបស់សហគមន៍ជនជាតិដើមភាគតិច ផ្លូវថ្នល់ ផ្លូវរថភ្លើង និងដីចំណី ស្ទឹង ព្រែក ទន្លេ បឹងធម្មជាតិ... (លទ្ធផលនៃការបិទផ្សាយជាសាធារណៈ)

-ចុះបញ្ជីដីជាដីឯកជនរបស់រដ្ឋ (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬសាលាខេត្ត-ក្រុង)

-និងចុះកិច្ចសន្យាស្ថាពរ។

ដើម្បីឱ្យចំណេញពេលវេលា មុននឹងបិទផ្សាយជាសាធារណៈនូវប្លង់ដីសម្បទាន គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ត្រូវធ្វើចំណាត់ថ្នាក់ដីរដ្ឋឱ្យហើយ រួចបញ្ចូលទិន្នន័យចំណាត់ថ្នាក់នេះក្នុងប្លង់ដីសម្បទានដែលត្រូវបិទផ្សាយ។

សូមលោក លោកស្រីប្រធានមន្ទីរទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ។

**ទេសរដ្ឋមន្ត្រី**

**ហត្ថលេខា**

**[អ៊ឹម ឈុនលឹម]**

<u>ចម្លងជូន</u>

-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-សាលាខេត្ត-ក្រុង គ្រប់ខេត្ត-ក្រុង

-អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ១៣១អនក្រ/បក

## អនុក្រឹត្យ
## ស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ៤៦អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី

- បានឃើញអនុក្រឹត្យលេខ៤៨អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីដែលមានលក្ខណៈដាច់ដោយដុំ
- បានឃើញអនុក្រឹត្យលេខ១៤៦អនក្រ/បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញអនុក្រឹត្យលេខ៥៣អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីនីតិវិធីការបង្កើត ការចាត់ថ្នាក់ និងការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍
- បានឃើញអនុក្រឹត្យលេខ១១៨អនក្រ/បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- យោងតាមសំណូមពរចាំបាច់ចំពោះមុខ

## សម្រេច

### មាត្រា១

ត្រូវបានដកចេញនូវរាល់ខ្លឹមសារទាំងឡាយដែលពាក់ព័ន្ធនឹងការផ្តល់សិទ្ធិជូនខេត្ត-ក្រុងមានសិទ្ធិសម្រេចផ្តល់ដីសម្បទានសេដ្ឋកិច្ច ដែលមានចែងក្នុងអនុក្រឹត្យលេខ១៤៦អនក្រ/បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥។

### មាត្រា២

រាល់ខ្លឹមសារផ្សេងទៀតនៃអនុក្រឹត្យលេខ១៤៦អនក្រ/បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ នៅមានសុពលភាពដដែល។

### មាត្រា៣

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវបានចាត់ទុកជាមោឃៈ។

### មាត្រា៤

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង

*វាយឡើងវិញ*

សំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រធានស្ថាប័ន និងអភិបាលខេត្ត-ក្រុងទាំងអស់ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានជម្រាបជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**ចម ប្រសិទ្ធ**

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

-ដូចមាត្រា៤ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

*វាយឡើងវិញ*

**នស/រកត/១០០៨/១១០៦**

# ព្រះរាជក្រឹត្យ

## ស្តីពីវិសោធនកម្មមាត្រា១នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

**មាត្រាមួយ**

ត្រូវបានធ្វើវិសោធនកម្មមាត្រា១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីដូចតទៅ៖

មាត្រា១ថ្មី អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានសមាសភាពដូចតទៅ៖

| | |
|---|---|
| ១-តំណាងនាយករដ្ឋមន្ត្រី | ប្រធាន |
| ២-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធានទី១ |
| ៣-ឥស្សរជនមួយរូប | អនុប្រធានប្រចាំការ |
| ៤-ឥស្សរជនមួយចំនួន | អនុប្រធាន |
| ៥-រដ្ឋមន្ត្រីក្រសួងបរិស្ថាន | សមាជិក |
| ៦-រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៧-រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម ថាមពល និងរ៉ែ | សមាជិក |
| ៨-រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៩-រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ១០-រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១១-រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១២-រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១៣-រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៤-អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ១៥-អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ | សមាជិក |
| ១៦-មេបញ្ជាការកងទ័ពជើងគោក | សមាជិក |
| ១៧-មេបញ្ជាការកងទ័ពជើងទឹក | សមាជិក |
| ១៨-មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៩-អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ២០-មេធាវីរាជរដ្ឋាភិបាល | សមាជិក |
| ២១-តំណាងអង្គការក្រៅរដ្ឋាភិបាលសំខាន់ៗដែលពាក់ព័ន្ធ | សមាជិក |

សមាសភាពជាក់ស្តែងនឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រាពីរ**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រាបី**

*វាយឡើងវិញ*

ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៨*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នស/រកត/១០០៨/១១៦៦ **នរោត្តម សីហមុនី**

**បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ**

**សូមឡាយព្រះហស្តលេខា**

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ១០៣៦ចល

**ដើម្បីចម្លងចែក**

**រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨**

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

*វាយឡើងវិញ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ៣៥អនក្រ/បក

# អនុក្រឹត្យ
## ស្តីពីការកែសម្រួលមាត្រា៤ថ្មីនៃអនុក្រឹត្យលេខ៦៨អនក្រ/បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៤ ស្តីពីការកែប្រែមាត្រា៤នៃអនុក្រឹត្យលេខ៨៨អនក្រ/បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១០០/២១៣ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០០ ស្តីពីការបញ្ចូលសមាសភាពឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ៨៨អនក្រ/បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ៦៨អនក្រ/បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៤ ស្តីពីការកែប្រែមាត្រា៤នៃអនុក្រឹត្យលេខ៨៨អនក្រ/បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី

## សម្រេច

**មាត្រាមួយ**

មាត្រា៤ថ្មីនៃអនុក្រឹត្យលេខ៦៨អនក្រ/បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៤ ស្តីពីការកែប្រែមាត្រា៤នៃអនុក្រឹត្យលេខ៨៨អនក្រ/បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លីត្រូវបានកែសម្រួលដូចតទៅ៖

**មាត្រា៤ថ្មី (ពីរ)**

ក្រុមប្រឹក្សាគោលនយោបាយដីធ្លីមានសមាសភាពដូចតទៅ៖

| | |
|---|---|
| -ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| -ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | អនុប្រធាន |
| -រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| -អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ | អនុប្រធាន |
| -រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | អនុប្រធាន |
| -រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាគោលនយោបាយដីធ្លី | សមាជិកអចិន្ត្រៃយ៍ |
| -រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| -រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| -រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| -រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| -រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| -រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| -រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| -រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| -រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| -រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| -រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| -រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| -រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |

*វាយឡើងវិញ*

-រដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក

-រដ្ឋលេខាធិការក្រសួងកិច្ចការនារី សមាជិក

-តំណាងក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សមាជិក

-អគ្គលេខាធិការគណៈកម្មការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

**មាត្រាពីរ**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រាបី**

រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងសមាជិកទាំងអស់នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដូចមានសមាសភាពចែងក្នុងមាត្រាមួយខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-អគ្គលេខាធិការរាជរដ្ឋាភិបាល*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*

*-ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ*

*-ដូចមាត្រាបី*

*-រាជកិច្ច*

*-ឯកសារ កាលប្បវត្តិ*

*វាយឡើងវិញ*

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ៧២អនក្រ/បក

## អនុក្រឹត្យ

## ស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៤/នស/៩៤ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីនគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៦ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១៦អនក្រ/បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ/បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៩អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ១១៨អនក្រ/បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦អនក្រ/បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច

- បានឃើញអនុក្រឹត្យលេខ១២៩អនក្រ/បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គថ្ងៃទី០៣ ខែមេសា ឆ្នាំ ២០០៩

## សម្រេច

## ជំពូកទី១ បទប្បញ្ញត្តិទូទៅ

### មាត្រា១

អនុក្រឹត្យនេះមានគោលដៅកំណត់គោលការណ៍ យន្តការ និងនីតិវិធីសម្រាប់ការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់។

### មាត្រា២

អនុក្រឹត្យនេះមានគោលបំណង៖

-ផ្តល់សមត្ថកិច្ចឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់ រៀបចំផែនការគ្រប់គ្រង និងប្រើប្រាស់ធនធានដី ធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព

-គាំទ្រកិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គមប្រកបដោយនិរន្តរភាព និងសមធម៌

-រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ

-ជួយឱ្យសម្រេចបាននូវផលិតភាពខ្ពស់នៃការប្រើប្រាស់ដីក្នុងមូលដ្ឋានឃុំ-សង្កាត់ ស្របតាមស្ថានភាពដីជាក់ស្តែង និងសក្តានុពលធម្មជាតិនៃដី

-ឆ្លើយតបចំពោះសេចក្តីត្រូវការដីរបស់អាជ្ញាធរនានា និងរបស់ប្រជាពលរដ្ឋក្នុងឃុំ-សង្កាត់

-ជួយការពារធនធានដី និងធនធានធម្មជាតិផ្សេងៗទៀតមិនឱ្យបាត់បង់គុណភាព និងមិនឱ្យប្រើប្រាស់ខុសទិសដៅ

-រួចចំណែកក្នុងការកំណត់ និងគ្រប់គ្រងដីរដ្ឋដែលមាននៅក្នុងឃុំ-សង្កាត់ឱ្យបានល្អប្រសើរតាមតួនាទីជាភ្នាក់ងារតំណាងរដ្ឋរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់

-ស្វែងរកការគាំទ្រផ្នែកបច្ចេកទេសពីស្ថាប័ន អង្គភាពនានា និងពីផ្នែកឯកជន ដើម្បីបំពេញបន្ថែមចំពោះការរៀបចំកសាងផែនការអភិវឌ្ឍឃុំ-សង្កាត់ និងកម្មវិធីវិនិយោគឃុំ-សង្កាត់។

**មាត្រា៣**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះដីសាធារណៈរបស់រដ្ឋ ដីឯកជនរបស់រដ្ឋ ព្រមទាំងដីឯកជនរបស់បុគ្គលឯកជនដែលឋិតនៅក្នុងឃុំ-សង្កាត់នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤**

វាក្យសព្ទខាងក្រោមប្រើក្នុងអនុក្រឹត្យនេះមានន័យដូចតទៅ៖

-ផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់ សំដៅដល់ផែនការប្រើប្រាស់ដីក្នុងឃុំ-សង្កាត់ទាំងមូលទាំងដីរដ្ឋទាំងដីឯកជនរបស់បុគ្គលឯកជន។

-ផែនការអភិវឌ្ឍឃុំ-សង្កាត់ សំដៅដល់ផែនការអភិវឌ្ឍនានាដែលបានអនុម័តជាផ្លូវការរួចហើយសម្រាប់ឃុំ-សង្កាត់ទាំងមូល ដើម្បីឱ្យឃុំ-សង្កាត់នោះមានការរីកចម្រើនជាទូទៅ ជាពិសេសផ្នែកសេដ្ឋកិច្ចសង្គមកិច្ច និងធ្វើឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ-សង្កាត់នោះបានល្អប្រសើរជាលំដាប់។

-កម្មវិធីវិនិយោគនៅឃុំ-សង្កាត់ សំដៅដល់កម្មវិធីវិនិយោគសម្រាប់រយៈពេល០១ (មួយ) ឆ្នាំដែលជាឧបករណ៍ចាំបាច់សម្រាប់អនុវត្តឱ្យសម្រេចបាននូវចក្ខុវិស័យ ទិសដៅ និងយុទ្ធសាស្ត្រនានាដែលបានកំណត់នៅក្នុងផែនការអភិវឌ្ឍឃុំ-សង្កាត់

-ផែនទីរដ្ឋបាលឃុំ-សង្កាត់ សំដៅដល់ផែនទីរដ្ឋបាលដែលចេញផ្សាយដោយនាយកដ្ឋានភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

-ផែនទីប្រើប្រាស់ដីឃុំ-សង្កាត់ សំដៅដល់ផែនទីដែលមានព័ត៌មានស្តីពីប្រភេទនៃការប្រើប្រាស់ដី គម្របដី ព្រំប្រទល់ និងទីតាំងរដ្ឋបាលឃុំ-សង្កាត់ដែលមានកន្លងមក។

## ជំពូកទី២ គោលការណ៍សម្រាប់រៀបចំផែនការ

**មាត្រា៥**

ការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់ ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

១-ត្រូវធ្វើតាមវិធីសាស្ត្រដែលមានលក្ខណៈចូលរួម ដោយឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធនឹងការងារដីធ្លី។

២-ត្រូវស្របតាមគម្រោងផែនការអភិវឌ្ឍដែលមានជាផ្លូវការនៅថ្នាក់ឃុំ-សង្កាត់ ដែលអាចជាប្រភេទនៃការអភិវឌ្ឍចម្រុះ ឬជាប្រភេទនៃការអភិវឌ្ឍផ្អែកតាមប្រភពធនធានជាក់លាក់នីមួយៗ តាមទស្សនៈភូមិមួយផលិតផលមួយ ឬតាមលក្ខណៈពិសេសជាក់លាក់របស់តំបន់នីមួយៗ។

៣-ត្រូវយកផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់ ធ្វើជាមូលដ្ឋានបង្អែកសម្រាប់រៀបចំផែនការអភិវឌ្ឍឃុំ-សង្កាត់។

៤-ត្រូវតែបើកចំហរាល់ព័ត៌មានទាំងអស់ចំពោះគ្រប់ភាគីពាក់ព័ន្ធទាំងអស់។

៥-ត្រូវផ្តល់អាទិភាពខ្ពស់ដល់តម្រូវការដីនៅមូលដ្ឋានឃុំ-សង្កាត់សាមី នាពេលបច្ចុប្បន្ន និងទៅអនាគតសម្រាប់រយៈពេលពី១០ (ដប់) ទៅ១៥ (ដប់ប្រាំ) ឆ្នាំខាងមុខ សម្រាប់សេវា និងការប្រើប្រាស់ជាសាធារណៈ សម្រាប់ការដោះស្រាយការតាំងទីលំនៅថ្មីដែលបណ្តាលមកពីគម្រោងអភិវឌ្ឍរបស់រដ្ឋ គម្រោងអភិវឌ្ឍមូលដ្ឋាន គ្រោះធម្មជាតិផ្សេងៗ ឬកំណើនប្រជាពលរដ្ឋតាមរយៈការបម្រុងដីទុកសម្រាប់គោលដៅជាក់លាក់នីមួយៗស្របតាមបញ្ញត្តិច្បាប់ទាំងឡាយ ដូចជាការផ្តល់ដីតាមរយៈសម្បទានដីសង្គមកិច្ចជាដើម។

៦-ធ្វើផែនការប្រើប្រាស់ដីមិនមែនជាការផ្តល់ដី ឬបែងចែកដីជាក់ស្តែងនោះទេ។

## ជំពូកទី៣ យន្តការ និងភារកិច្ច

### មាត្រា៦

យន្តការសម្រាប់ការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់មានដូចតទៅ៖

១-ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវធ្វើការសិក្សា និងបង្ហាញអំពីសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានឃុំ-សង្កាត់របស់ខ្លួន ផ្តល់ព័ត៌មានជាក់លាក់នានា រៀបចំកិច្ចពិភាក្សា ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ជាមួយប្រជាជនក្នុងភូមិ ដើម្បីរៀបចំធ្វើផែនការប្រើប្រាស់ដីជាលក្ខណៈផែនការលំអិត និងជាម្ចាស់នៃផែនការប្រើប្រាស់ដីឃុំ-សង្កាត់។ ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវចាត់តាំងជនបង្គោលមួយ ឬច្រើនរូបឱ្យទទួលខុសត្រូវក្នុងការសម្របសម្រួល និងធ្វើទំនាក់ទំនងជាប្រចាំជាមួយក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង-ស្រុក-ខណ្ឌ លើការងាររៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់។

២-ក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុក-ខណ្ឌដែលមានសមាសភាពតាមការកំណត់ ដោយមាត្រា២៧នៃអនុក្រឹត្យលេខ១១៨អនក្រ/បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ មានភារកិច្ចសំខាន់ក្នុងការសម្របសម្រួលផ្តល់ការគាំទ្រផ្នែកបច្ចេកទេសចំពោះក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់ និងជួយកៀរគរការគាំទ្រពីភាគីពាក់ព័ន្ធនានា។ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុក-ខណ្ឌត្រូវបង្កើតក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង-ស្រុក-ខណ្ឌ ដើម្បីធ្វើការជាប្រចាំជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ និងមន្ត្រីបច្ចេកទេសនៃលេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្ត។

៣-គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្តដែលមានសមាសភាពតាមការកំណត់ដោយមាត្រា២៤នៃអនុក្រឹត្យលេខ១១៨អនក្រ/បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ មានភារកិច្ចពិនិត្យឡើងវិញ ផ្តល់យោបល់កែសម្រួល សម្រេច និងត្រួតពិនិត្យការអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់។

**មាត្រា៧**

ក្រុមប្រឹក្សាឃុំ-សង្កាត់មានភារកិច្ចដូចតទៅ៖

-ស្រង់ និងផ្តល់ទិន្នន័យនៃការប្រើប្រាស់ដីជាក់ស្តែងកន្លងមក

-ធ្វើការសិក្សា និងបង្ហាញអំពីសេចក្តីត្រូវការដីរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានឃុំ-សង្កាត់របស់ខ្លួន និងពិចារណាអំពីការរៀបចំគម្រោងផែនការអភិវឌ្ឍឃុំ-សង្កាត់ ព្រមទាំងកិច្ចសហការចាំបាច់ផ្សេងទៀតក្នុងដំណើរការរៀបចំធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់

-ជូនដំណឹង និងបិទផ្សាយជាសាធារណៈនូវលទ្ធផលនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់ដែលគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្តបានផ្តល់យោបល់កែសម្រួលរួច

-ប្រមូល និងសង្ខេបមតិយោបល់សាធារណៈជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានីខេត្ត តាមរយៈក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុក-ខណ្ឌ ដូចមានចែងក្នុងមាត្រា១៨នៃអនុក្រឹត្យនេះ

-តាមដាន និងវាយតម្លៃការអនុវត្តផែនការ និងធ្វើរបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្ត។ មេឃុំ ចៅសង្កាត់ មានភារកិច្ចដឹកនាំកិច្ចប្រជុំ

នានាពាក់ព័ន្ធដល់ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់ និងទទួលខុសត្រូវលើការអនុវត្ត ផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់ដែលបានអនុម័តរួចហើយ ។

**មាត្រា៨**

ក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុក-ខណ្ឌមានភារកិច្ចដូចតទៅ៖

-ដឹកនាំការប្រជុំដើម្បីរៀបចំធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់

-រួមជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ ធ្វើការវាយតម្លៃសេចក្ដីត្រូវការដី ស្ថានភាពជាក់ស្ដែង នៃដី និងសក្ដានុពលដី ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ

-រួមសហការជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ លើកសំណើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្ត ដោយមានសេចក្ដីអធិប្បាយអំពី សេចក្ដីត្រូវការដីរបស់មូលដ្ឋាន ស្ថានភាពជាក់ស្ដែងនៃដី និងសក្ដានុពលដី និងគម្រោងរៀបចំផែន ការអភិវឌ្ឍផ្សេងៗទៅអនាគតរបស់ឃុំ-សង្កាត់

-ជួយធ្វើការកែតម្រូវគម្រោងផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់ តាមការសម្រេចរបស់ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្ត

-ជំរុញការអនុវត្តផែនការប្រើប្រាស់ដីដែលបានសម្រេចជាផ្លូវការ និងជួយរៀបចំរបាយការណ៍ បូកសរុបប្រចាំឆមាស និងឆ្នាំ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ រាជធានីខេត្តអំពីការអនុវត្ត ផែនការប្រើប្រាស់ដី ជាពិសេសដីដែលបានផ្ដល់ ឬចែកឱ្យបុគ្គលឯកជន សមូហភាព ឬអង្គភាពរដ្ឋ នានា នៅថ្នាក់ក្រុង-ស្រុក-ខណ្ឌ និងដីដែលនៅសល់ក្នុងផែនការមិនទាន់បានបែងចែក ព្រមទាំងដី ដែលឋិតនៅក្រោមការគ្រប់គ្រងកាន់កាប់របស់អាជ្ញាធរកាន់កាប់ដីរដ្ឋ ដែលមាននៅក្នុងឃុំ-សង្កាត់

-ចាត់តាំងបង្កើតក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង-ស្រុក-ខណ្ឌ។ សមាសភាពក្រុមនេះអាចមានពី៣ (បី) ទៅ៥ (ប្រាំ) នាក់ ដែលជាមន្ត្រីបច្ចេកទេសពីការិយាល័យ ជំនាញជុំវិញក្រុង-ស្រុក-ខណ្ឌ។

**មាត្រា៩**

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្តមានភារកិច្ចដូចតទៅ៖

-ដឹកនាំពិគ្រោះយោបល់សម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្នុងការងាររៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់

-ផ្ដល់យោបល់ដល់ក្រុមការងារដឹកនាំថ្នាក់ក្រុង-ស្រុក-ខណ្ឌ និងក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងការកែសម្រួលផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់ ដោយពិចារណាជាមួយប្លង់មេ ផែនការអភិវឌ្ឍផ្សេងៗ និងការកំណត់តំបន់ប្រើប្រាស់ដីទាំងឡាយដែលបានសម្រេចជាផ្លូវការហើយ

-សម្រេច និងត្រួតពិនិត្យលើការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់

-ចាត់តាំងបង្កើតក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី-ខេត្ត ដែលសមាសភាពក្រុមនេះអាចមានពីបី (៣) ទៅប្រាំ (៥) នាក់ ជាមន្ត្រីបច្ចេកទេសពីមន្ទីរជំនាញជុំវិញរាជធានី-ខេត្ត ហើយមានភារកិច្ចសំខាន់ ជួយសម្របសម្រួលការងារអង្គភាពពាក់ព័ន្ធនៅជុំវិញរាជធានី-ខេត្ត និងធ្វើជាគ្រូបណ្តុះបណ្តាលការងាររៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់

-បូកសរុប និងលើកផែនការសកម្មភាពនិងគម្រោងថវិកាប្រចាំឆ្នាំសម្រាប់គាំទ្រការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់

-បំពេញភារកិច្ចផ្សេងទៀតដែលពាក់ព័ន្ធនឹងការងាររៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំសង្កាត់ តាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៤ នីតិវិធីនៃការរៀបចំផែនការ

**មាត្រា១០**

ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់ ត្រូវអនុវត្តដូចខាងក្រោម៖

១-ក្រុមប្រឹក្សាឃុំ-សង្កាត់ លើកសំណើសុំគោលការណ៍រៀបចំផែនការប្រើប្រាស់ដីទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្ត តាមរយៈក្រុមការងារដឹកនាំថ្នាក់ក្រុង-ស្រុក-ខណ្ឌ។ ក្រុមការងារដឹកនាំថ្នាក់ក្រុង-ស្រុក-ខណ្ឌ ត្រូវបញ្ជូនសំណើសុំរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំសង្កាត់ទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្ត ក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ។ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្ត ត្រូវធ្វើការសម្រេច និងឆ្លើយតបក្នុងរយៈពេលមិនលើសពី២១ (ម្ភៃមួយ) ថ្ងៃ។

២-បន្ទាប់ពីមានការយល់ព្រមពីគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្ត ក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុក-ខណ្ឌ និងក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវរៀបចំសំណើថវិកាសម្រាប់ធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់ ទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្ត រៀបចំថវិកាស្របតាមបញ្ញត្តិដែលមានចែងក្នុងមាត្រា១៩នៃអនុក្រឹត្យនេះ។

៣-ក្រោយពីទទួលបានការឯកភាពថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬមានការគាំទ្រពីដៃគូអភិវឌ្ឍ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុក-ខណ្ឌ និងក្រុមប្រឹក្សាឃុំ-សង្កាត់ តំណាងដោយមេឃុំ ចៅសង្កាត់ និងសមាជិកម្នាក់របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលទទួលបន្ទុកការងារដី ត្រូវប្រជុំដើម្បីរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់។ អង្គប្រជុំត្រូវចាត់តាំងក្រុមការងារសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង-ស្រុក-ខណ្ឌ និងមានមេឃុំ ឬចៅសង្កាត់សាមី ចុះស្រង់ព័ត៌មានពីស្ថានភាពជាក់ស្តែងនៃការប្រើប្រាស់ដីកន្លងមក ហើយគូសលើផែនទីរដ្ឋបាល និង/ឬផែនទីប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់ ប្រសិនបើមាន។

៤-ក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃយ៉ាងយូរ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុក-ខណ្ឌ និងក្រុមប្រឹក្សាឃុំ-សង្កាត់ប្រជុំលើកទី២ ដើម្បីពិចារណាអំពីៈ

-ការរៀបចំផែនការប្រើប្រាស់ដី ដោយប្រើប្រាស់ផែនទីដែលមានទិន្នន័យ ឬព័ត៌មានពីស្ថានភាពប្រើប្រាស់ដីជាក់ស្តែងដែលមានកន្លងមក

-ផែនការមេ ឬផែនការអភិវឌ្ឍឃុំ-សង្កាត់ ឬផែនការអភិវឌ្ឍរបស់រដ្ឋផ្សេងទៀតដែលបានអនុម័តជាផ្លូវការរួចហើយ ឬមិនទាន់អនុម័ត ប្រសិនបើមាន

-ការគ្រប់គ្រងដីរដ្ឋដែលមាននៅក្នុងឃុំ-សង្កាត់នោះ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព

-សេចក្តីត្រូវការដីរបស់ស្ថាប័ន អាជ្ញាធរផ្សេងៗ និងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានឃុំ-សង្កាត់។

៥-ពេលបានសម្រេចធ្វើផែនការនេះរួចហើយ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុក-ខណ្ឌ ត្រូវបញ្ជូនសេចក្តីព្រាងផែនការនេះទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្ត ដើម្បីពិនិត្យ និងកែសម្រួល។

៦-ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវបិទផ្សាយជាសាធារណៈក្នុងរយៈពេល៤៥ (សែសិបប្រាំ) ថ្ងៃ តាមទីកន្លែងជាក់ស្តែងនូវផែនការដែលបានពិនិត្យ និងកែសម្រួលរួចហើយ ដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្ត។ រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមិនឯកភាពនឹងទិន្នន័យដែលបានបិទផ្សាយជាសាធារណៈមានសិទ្ធិតវ៉ាទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្ត។

៧-ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវបូកសរុបមតិសាធារណៈ ពិនិត្យ និងលើកអនុសាសន៍ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្ត តាមរយៈក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុក-ខណ្ឌ ដើម្បីពិនិត្យសម្រេចចុងក្រោយក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃ។

៨-គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្ត ប្រជុំលើកទីពីរដើម្បីពិនិត្យមតិយោបល់សាធារណៈ និងអនុសាសន៍របស់ក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុក-ខណ្ឌ និងក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃ។ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្ត អាចចាត់បញ្ជូនក្រុមស៊ើបអង្កេតមួយទៅពិនិត្យ និងស្រង់យកព័ត៌មានបន្ថែមទៀត ប្រសិនបើយល់ឃើញថាជាការចាំបាច់។ ក្រុមស៊ើបអង្កេតអាចប្រើពេលវេលាមិនឱ្យហួសពី៣០ (សាមសិប) ថ្ងៃទេ។

៩-ការសម្រេចលើផែនការប្រើប្រាស់ដី ត្រូវអនុវត្តតាមសំឡេងភាគច្រើនដាច់ខាតនៃអង្គប្រជុំគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្ត ដែលមានសមាជិកចូលរួមប្រជុំយ៉ាងតិច២/៣ (ពីរភាគបី) នៃសមាជិកទាំងអស់។ ក្រោយពីគម្រោងផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់ត្រូវបានសម្រេចរួចហើយ លេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្ត ត្រូវចម្លងឯកសារអំពីផែនការប្រើប្រាស់ដីនេះ ជូនគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងឃុំ-សង្កាត់សាមី។

១០-ប្រធានក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុក-ខណ្ឌ ត្រូវរៀបចំការប្រជុំជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យការអនុវត្តផែនការប្រើប្រាស់ដី និងធ្វើរបាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្ត ជារៀងរាល់ឆមាស និងប្រចាំឆ្នាំ។

**មាត្រា១១**

ការរៀបចំ និងការអនុវត្តផែនការប្រើប្រាស់ដីលំអិតនៅក្នុងឃុំ-សង្កាត់ ត្រូវកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងផែនការ។

មាត្រា១២

ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវធ្វើការផ្សព្វផ្សាយខ្លឹមសារនៃអនុក្រឹត្យនេះឱ្យបានទូលំទូលាយដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងបណ្តារាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ និងឃុំ-សង្កាត់ដែលជាអ្នកអនុវត្តផ្ទាល់។

**ជំពូកទី៥ ការអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់**

មាត្រា១៣

ដើម្បីធានាប្រសិទ្ធភាពនៃផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់ រដ្ឋបាលរាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ និងឃុំ-សង្កាត់ត្រូវអនុវត្តតាមផែនការដែលបានសម្រេចជាផ្លូវការរួចហើយតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ក្រុមប្រឹក្សាឃុំ-សង្កាត់ ដោយមានជំនួយពីក្រុមការងារជីវរដ្ឋថ្នាក់ក្រុង-ស្រុក-ខណ្ឌ ត្រូវដំណើរការអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់ដែលបានសម្រេចរួចហើយ ឱ្យមានប្រសិទ្ធភាព និងប្រកបដោយតម្លាភាព។

មាត្រា១៤

ដីដែលមានចំណាត់ថ្នាក់ជាដីឯកជនរបស់រដ្ឋ មួយចំណែកអាចត្រូវបានផ្តល់ ឬបែងចែកឱ្យអង្គភាពរដ្ឋ ឬរដ្ឋបាលថ្នាក់រាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ ឃុំ-សង្កាត់ ស្របតាមផែនការប្រើ-ប្រាស់ដីនេះ និងមួយចំណែកទៀតអាចផ្តល់ជាសម្បទានដីសង្គមកិច្ច ដោះស្រាយការតាំងទីលំនៅថ្មី ជាសម្បទានដីសេដ្ឋកិច្ច អាចលក់ ដូរ ជួល ឬអាចអនុញ្ញាតឱ្យប្រើប្រាស់រយៈពេលខ្លី ឬក៏សម្រាប់គម្រោងវិនិយោគផ្សេងៗរបស់រដ្ឋ និងរបស់មូលដ្ឋានដោយត្រូវគោរពតាមនីតិវិធីច្បាប់ជាធរមាន។

ចំណែកដីដែលមានចំណាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ ដីនោះត្រូវរក្សាទុកសម្រាប់បម្រើសេវាសាធារណៈ ឬសម្រាប់គ្រប់គ្រង និងប្រើប្រាស់ប្រកបដោយសមធម៌ និងនិរន្តរភាព។

មាត្រា១៥

ការអនុញ្ញាតឱ្យប្រើប្រាស់ដីរយៈពេលខ្លីគឺមិនលើសពី០១ (មួយ) ឆ្នាំ អាចបន្តជាថ្មីបានតែម្តងគត់ ហើយអាចដកហូតវិញបានគ្រប់ពេលវេលា។ ការអនុញ្ញាតនេះសម្រាប់ជូនប្រជាពលរដ្ឋក្រីក្រមូលដ្ឋានឃុំ-សង្កាត់ដែលត្រូវការដីចាំបាច់ ឬខ្វះដីសម្រាប់ធ្វើជម្រកស្នាក់នៅបណ្តោះអាសន្ន

ឬធ្វើកសិកម្មចិញ្ចឹមជីវិតជាបណ្តោះអាសន្ន ក្នុងពេលរង់ចាំការបែងចែកដីក្នុងក្របខ័ណ្ឌសម្បទានដីសង្គមកិច្ច ឬការតាំងទីលំនៅថ្មី។

ការអនុញ្ញាតនេះ ត្រូវមានការចុះកិច្ចសន្យាជាលាយលក្ខណ៍អក្សរច្បាស់លាស់ជាមួយមេឃុំ ចៅសង្កាត់។ ប្រជាពលរដ្ឋក្រីក្រដែលត្រូវការដី ឬខ្វះដី ត្រូវដាក់សំណើសុំការអនុញ្ញាតប្រើប្រាស់ដីរយៈពេលខ្លីជាបណ្តោះអាសន្ន តាមរយៈមេភូមិទៅមេឃុំ ចៅសង្កាត់ ដោយមានបញ្ជាក់ទីតាំងដី និងគោលបំណងប្រើប្រាស់ដីជាក់លាក់។ កិច្ចសន្យាដែលមានកំណត់ល័ក្ខខ័ណ្ឌនៃការអនុញ្ញាតឱ្យប្រើប្រាស់ដីនោះ ត្រូវទុកជាឯកសារសាធារណៈនៅសាលាឃុំ-សង្កាត់ និងត្រូវចម្លងជូនក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុក-ខណ្ឌ។

ការអនុញ្ញាតឱ្យប្រើប្រាស់ដីរបស់រដ្ឋ ឬការការពារជនប្រើប្រាស់ដីរបស់រដ្ឋដោយគ្មានកិច្ចសន្យាជាលាយលក្ខណ៍អក្សរត្រឹមត្រូវ ឬដោយបំពានសិទ្ធិអំណាចរបស់អាជ្ញាធរត្រូវបានហាមឃាត់។

**មាត្រា១៦**

ការប្រើប្រាស់ដីដែលមិនស្របតាមផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់ ត្រូវដកហូតយកមកវិញ ឬត្រូវបញ្ឈប់ការប្រើប្រាស់ចំពោះដីរដ្ឋ ឬត្រូវបញ្ឈប់ការប្រើប្រាស់ដីជាបណ្តោះអាសន្នចំពោះដីឯកជនរបស់បុគ្គលឯកជន ក្នុងរយៈពេលពីរខែយ៉ាងយូរ។ ការដកហូត ឬការបញ្ឈប់ការប្រើប្រាស់ដី ត្រូវសម្រេចដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្ត តាមសំណើរបស់ក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុក-ខណ្ឌ លើកលែងតែគម្រោងថ្នាក់ជាតិដែលត្រូវសម្រេចដកហូតឬបញ្ឈប់ការប្រើប្រាស់ដីដោយថ្នាក់ជាតិ។ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្ត ត្រូវតាមដាន និងត្រួតពិនិត្យការអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់ឱ្យបានជាប់ជាប្រចាំ។

រូបវន្តបុគ្គល ឬនីតិបុគ្គលមានសិទ្ធិប្តឹងតវ៉ាអំពីការសម្រេចបញ្ឈប់ការប្រើប្រាស់ដីឯកជនដែលសម្រេចដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្ត ទៅស្ថាប័នមានសមត្ថកិច្ច ឬទៅតុលាការ។

**មាត្រា១៧**

ផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់ ត្រូវកត់ត្រាអំពីការកំណត់ និងការសម្រេចលើរបៀបប្រើប្រាស់ ឬការបែងចែកដីដែលបានធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ច តាមនីតិវិធីជាធរមានចំពោះក្បាលដីនីមួយៗរបស់រដ្ឋ។

## ជំពូកទី៦ ការកែប្រែផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់

### មាត្រា១៨

ក្រោយពីទទួលបានការឯកភាពពីក្រុមប្រឹក្សាឃុំ-សង្កាត់ និង/ឬក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុក-ខណ្ឌ មេឃុំ ចៅសង្កាត់អាចស្នើទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្ត ដើម្បីកែប្រែផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់ ដោយភ្ជាប់ជាមួយនូវសេចក្តីពន្យល់ពីមូលហេតុផ្សេងៗក្នុងការកែប្រែផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់។

ការកែប្រែផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់ ត្រូវអនុវត្តតាមនីតិវិធីដែលមានលក្ខណៈចូលរួម ដូចដំណើរការធ្វើផែនការប្រើប្រាស់ដីពីដំបូងដែរ។

ក្នុងករណីចាំបាច់ដែលមានការតម្រូវពីរាជរដ្ឋាភិបាល ការកែប្រែផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់មិនចាំបាច់គោរពតាមនីតិវិធីទូទៅឡើយ។ ការសម្រេចលើការកែប្រែផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់នេះ ត្រូវជូនដំណឹងដល់ក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុក-ខណ្ឌ ក្រុមប្រឹក្សាឃុំ-សង្កាត់ និងភាគីពាក់ព័ន្ធយ៉ាងតិច៣០ (សាមសិប) ថ្ងៃជាមុន។

ក្រោយពីផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់ ត្រូវបានកែប្រែរួចហើយ លេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្ត ត្រូវចម្លងឯកសារកែសម្រួលនេះជូនគ្រប់ស្ថាប័នពាក់ព័ន្ធ និងឃុំ-សង្កាត់សាមីដើម្បីអនុវត្ត។

## ជំពូកទី៧ ថវិកាចំណាយសម្រាប់ធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់

### មាត្រា១៩

ថវិកាសម្រាប់ការងាររៀបចំធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់បានមកពី៖

-ថវិកាជាតិ។

-ហិរញ្ញប្បទានបានមកពីក្នុង និងក្រៅប្រទេស ឬពីដៃគូអភិវឌ្ឍ។

នីតិវិធីនៃការស្នើសុំ និងប្រើប្រាស់ថវិកាសម្រាប់ធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់ ត្រូវកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

*វាយឡើងវិញ*

## ជំពូកទី៨ អវសានប្បញ្ញត្តិ

**មាត្រា២០**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា២១**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលរាជធានី និងអភិបាលខេត្តត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន**

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័នកណ្តាល

-គ្រប់សាលារាជធានី-ខេត្ត

-ដូចមាត្រា២១

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

*វាយឡើងវិញ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ០៦ដនស/អសជ/សណន ភ្នំពេញ ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៩

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
ជម្រាបមក
លោកស្រី អស់លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់
និងសុរិយោដីគ្រប់រាជធានី-ខេត្ត

**កម្មវត្ថុ៖** ការណែនាំស្តីពីការចុះបញ្ជីដីរដ្ឋដែលជាកម្មវត្ថុនៃសម្បទានដីសេដ្ឋកិច្ច ឬជួលរយៈពេលវែង និងការចុះបញ្ជីសិទ្ធិលើសម្បទានដីសេដ្ឋកិច្ច ឬសិទ្ធិលើការជួលរយៈពេលវែង។

**យោង៖** -អនុក្រឹត្យលេខ១៨៨អនក្រ/បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ

-អនុក្រឹត្យលេខ១៤៦អនក្រ/បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច

-អនុក្រឹត្យលេខ១១៤អនក្រ/បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៧ ស្តីពីការដាក់បញ្ចាំ-ការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬសិទ្ធិលើសម្បទានដីសេដ្ឋកិច្ច។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកស្រី អស់លោកប្រធានមន្ទីរឱ្យបានជ្រាបថា៖ ដើម្បីចុះបញ្ជីសិទ្ធិសម្បទានដីសេដ្ឋកិច្ច ឬសិទ្ធិជួលរយៈពេលវែងជូនម្ចាស់សិទ្ធិតាមការស្នើសុំបាន លុះត្រាតែដីរដ្ឋដែលជាកម្មវត្ថុនៃសម្បទានដីសេដ្ឋកិច្ច ឬជួលរយៈពេលវែងនោះ ត្រូវបានចុះបញ្ជីជាដីឯកជនរបស់រដ្ឋជាមុនសិន។ ការចុះបញ្ជីដីរដ្ឋអាចអនុវត្តតាមអនុក្រឹត្យលេខ៤៦អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ។ ចំពោះការអនុវត្ត ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមធ្វើការណែនាំដូចខាងក្រោម សម្រាប់គ្រប់ក្បាលដីរដ្ឋដែលជាកម្មវត្ថុនៃសម្បទានដីសេដ្ឋកិច្ច ឬជួលរយៈពេលវែង៖

១-មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្ត ត្រូវស្នើឱ្យបុគ្គលដែលទទួលបានសិទ្ធិសម្បទានដីសេដ្ឋកិច្ច ឬជួលរយៈពេលវែង សហការជាមួយអាជ្ញាធរមូលដ្ឋាន

និងអាជ្ញាធរកាន់កាប់ដីរដ្ឋ បោះបង្គោលរឹងមាំតាមព្រំដីដែលជាកម្មវត្ថុនៃសម្បទានដីសេដ្ឋកិច្ច ឬជួលរយៈពេលវែង។ មន្ទីរត្រូវរៀបចំប្រកាសស្ដីពីការចុះដាំបង្គោលព្រំដី ចុះហត្ថលេខាដោយអភិបាលស្រុក-ខណ្ឌ ឬក្រុងដែលជាសមត្ថកិច្ចដែនដី (គំរូភ្ជាប់) ដើម្បីជូនសាធារណជនជ្រាបមុន និងចូលរួមតាមកាលបរិច្ឆេទកំណត់។

២-មន្ទីរត្រូវចាត់មន្ត្រីចុះពិនិត្យព្រំដី ធ្វើការវាស់វែង រួចគូរប្លង់ដីរដ្ឋ និងកសាងកំណត់ហេតុអង្កេតដី ឬទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី និងឯកសារផ្សេងៗទៀតដែលចាំបាច់។ ក្រសួងប្រគល់សិទ្ធិវាស់វែងដីរដ្ឋ ជូនមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្ត ដោយត្រូវប្រើប្រាស់ឧបករណ៍វាស់វែងតាមក្បួនខ្នាតបច្ចេកទេសតម្រូវ។ មន្ទីរអាចប្រើឧបករណ៍ GPS កាន់ដៃដែលមានកម្រិតលំអៀងក្រោម០៨ម៉ែត្រ ដើម្បីធ្វើការវាស់វែងជ្រុងដីរដ្ឋដែលមានព្រំជាប់នឹងដីរដ្ឋ។ ចំពោះជ្រុងដែលមានការពាក់ព័ន្ធនឹងដីឯកជន តម្រូវឱ្យធ្វើការវាស់វែងដោយឧបករណ៍ដែលមានកម្រិតជាក់លាក់ខ្ពស់ ដើម្បីចៀសផុតពីភាពជាន់លើចំណែកដីរបស់បុគ្គលឯកជន ដែលអាចនាំដល់វិវាទ។ ក្នុងករណីពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការវាស់វែង មន្ទីរអាចលើកសំណើមកអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ សុំមន្ត្រីជំនាញទៅបំពេញភារកិច្ចវាស់វែង និងកសាងប្លង់ដីរដ្ឋជូនបាន។

៣-មន្ទីរត្រូវបញ្ជូនប្លង់ដីរដ្ឋដែលបានកសាងរួច ទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្ត ដើម្បីធ្វើការប្រជុំពិភាក្សា ធ្វើចំណាត់ថ្នាក់ដីថាជាដីឯកជនរបស់រដ្ឋ និងធ្វើការវាយតម្លៃផលប៉ះពាល់ផ្សេងៗ។ ក្នុងករណីដីរដ្ឋ ជាប្រភេទទ្រព្យសាធារណៈ មន្ទីរត្រូវលើកសំណើទៅអភិបាលខេត្ត ជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ដើម្បីរៀបចំអនុក្រឹត្យសុំធ្វើអនុបយោគទីតាំងឱ្យទៅជាទ្រព្យឯកជននៃរដ្ឋ។

៤-មន្ទីរត្រូវធ្វើការបិទផ្សាយជាសាធារណៈនូវប្លង់ដីរដ្ឋដែលជាកម្មវត្ថុនៃសម្បទានដីសេដ្ឋកិច្ច ឬជួលរយៈពេលវែង ក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃ នៅសាលាឃុំ-សង្កាត់ និងសាលាស្រុក-ខណ្ឌ-ក្រុង ដើម្បីផ្ដល់ឱកាសឱ្យអ្នកពាក់ព័ន្ធធ្វើការជំទាស់ ឬតវ៉ា។

៥-ផុតរយៈពេលបិទផ្សាយជាសាធារណៈ មន្ទីរត្រូវធ្វើរបាយការណ៍បូកសរុប និងស្នើសុំការសម្រេចលើឯកសារ (ប្លង់សុរិយោដី កំណត់ហេតុ អង្កេតដី ឬទម្រង់បែបបទនៃការប្រមូលទិន្នន័យ

ក្បាលដី) ពីអភិបាលរាជធានី-ខេត្ត រួចចុះបញ្ជីដីរដ្ឋដែលជាកម្មវត្ថុនៃសម្បទានសេដ្ឋកិច្ច ឬជួលរយៈពេលវែងនោះ (ចំណែកដីដែលមិនពាក់ព័ន្ធនឹងដីសាធារណៈ ឬ/និងដីប្រជាពលរដ្ឋកំពុងកាន់កាប់) ចូលក្នុងសៀវភៅគោលបញ្ជីដីធ្លី ឬសៀវភៅចុះបញ្ជីអចលនវត្ថុ។

៦-នៅត្រង់ខ្ទង់សេចក្ដីផ្សេងៗនៃសៀវភៅចុះបញ្ជីអចលនវត្ថុ ឬសៀវភៅគោលបញ្ជីដីធ្លី និងនៅលើប័ណ្ណ ត្រូវសរសេរបញ្ជាក់ថា "ដីឯកជនរបស់រដ្ឋ តាមកំណត់ហេតុចំណាត់ថ្នាក់ដី/អនុក្រឹត្យអនុបយោគលេខ......ចុះថ្ងៃ....." ។

៧-ក្រោយពីក្បាលដីរដ្ឋដែលជាកម្មវត្ថុនៃសម្បទានដីសេដ្ឋកិច្ច ឬជួលរយៈពេលវែង ត្រូវបានចុះបញ្ជីរួច មន្ទីរត្រូវធ្វើការចុះបញ្ជីសិទ្ធិសម្បទានដីសេដ្ឋកិច្ច ឬសិទ្ធិជួលរយៈពេលវែង ចូលក្នុងសៀវភៅចុះបញ្ជីសិទ្ធិសម្បទានដីសេដ្ឋកិច្ច ឬសៀវភៅចុះបញ្ជីសិទ្ធិជួលរយៈពេលវែង ដែលបានបង្កើតឡើងសម្រាប់ចុះបញ្ជីសិទ្ធិទាំងនោះដាច់ដោយឡែក តាមរូបមន្តដូចខាងក្រោម៖

-នៅលើសៀវភៅចុះបញ្ជីសិទ្ធិសម្បទានដីសេដ្ឋកិច្ច ឬសៀវភៅចុះបញ្ជីសិទ្ធិជួលរយៈពេលវែង និងនៅលើវិញ្ញាបនបត្រសម្គាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ច ឬជួលរយៈពេលវែង ត្រង់ខ្ទង់លេខាចារឹកដោយសង្ខេប ត្រូវសរសេរថា "ទទួលបានសិទ្ធិសម្បទានដីសេដ្ឋកិច្ចពីរដ្ឋ រយៈពេល......(.......) ចាប់ពី.......ដល់.......តាមកិច្ចសន្យាចុះថ្ងៃ......" ឬ "ជួលពី.......រយៈពេល.........(.......) ឆ្នាំ ចាប់ពី.....ដល់......តាមកិច្ចសន្យាចុះថ្ងៃ...." ជាទឹកពណ៌ខ្មៅ រួចបោះត្រាលេខាចារឹកពណ៌ក្រហម។

-ក្នុងពេលជាមួយគ្នានេះ ត្រូវចុះបន្ទុកលើសៀវភៅគោលបញ្ជីដីធ្លី ឬសៀវភៅចុះបញ្ជីអចលនវត្ថុ និងប័ណ្ណដីរដ្ឋត្រង់ខ្ទង់បន្ទុកលើអចលនវត្ថុ សរសេរថា "ផ្ដល់សិទ្ធិសម្បទានដីសេដ្ឋកិច្ចរយៈពេល....(....) ឆ្នាំ ជូន......តាមកិច្ចសន្យាចុះថ្ងៃ......." ឬ "ជួលរយៈពេល.....ឆ្នាំឱ្យ....តាមកិច្ចសន្យាចុះថ្ងៃ...." ជាទឹកពណ៌ខ្មៅ រួចបោះត្រាលេខាចារឹកពណ៌ក្រហម។

អាស្រ័យហេតុនេះ សូមលោកស្រី អស់លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្តជ្រាប និងចាត់ចែងអនុវត្តតាមការណែនាំនេះឱ្យមានប្រសិទ្ធភាព។

សូមលោកស្រី អស់លោកទទួលនូវសេចក្ដីរាប់អានដ៏ស្មោះអំពីខ្ញុំ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ហត្ថលេខា**

**[អ៊ឹម ឈុនលឹម]**

<u>ចម្លងជូន</u>

-អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ

-សាលារាជធានី-ខេត្ត

"ដើម្បីជូនជ្រាប"

-ឯកសារ-កាលប្បវត្តិ

*វាយឡើងវិញ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ៨៣អនក្រ/បក

**អនុក្រឹត្យ**

**ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៤៦អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ៤៧អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការបង្កើតគណៈកម្មការសុរិយោដី
- បានឃើញអនុក្រឹត្យលេខ៤៨អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ
- បានឃើញអនុក្រឹត្យលេខ៧៩អនក្រ/បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ១១៨អនក្រ/បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គថ្ងៃទី២៥ ខែមេសា ឆ្នាំ ២០០៩

## សម្រេច

## ជំពូកទី១ បទប្បញ្ញត្តិទូទៅ

**មាត្រា១**

អនុក្រឹត្យនេះមានគោលដៅកំណត់គោលការណ៍ នីតិវិធី និងយន្តការសម្រាប់ចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចជាកម្មសិទ្ធិសមូហភាព។

**មាត្រា២**

អនុក្រឹត្យនេះមានគោលបំណងផ្តល់សិទ្ធិស្របច្បាប់ក្នុងការកាន់កាប់ដីធ្លីដល់សហគមន៍ជនជាតិដើមភាគតិច ធានាសុវត្ថិភាពនៃការកាន់កាប់ដីធ្លី និងការពារកម្មសិទ្ធិសមូហភាព ដោយរក្សានូវអត្តសញ្ញាណ វប្បធម៌ ទំនៀមទម្លាប់ និងប្រពៃណីល្អរបស់សហគមន៍ជនជាតិដើមភាគតិច។

**មាត្រា៣**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះសហគមន៍ជនជាតិដើមភាគតិច ដែលបានបង្កើតជានីតិបុគ្គលស្របច្បាប់លើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤**

វាក្យសព្ទដែលមានប្រើមាននៅក្នុងអនុក្រឹត្យនេះមាននិយមន័យដូចតទៅ៖

កម្មសិទ្ធិសមូហភាព សំដៅដល់ដីធ្លីដែលជាកម្មសិទ្ធិរួមរបស់សហគមន៍ជនជាតិដើមភាគតិចមួយក្រុម ហើយកម្មសិទ្ធិនេះមិនមែនជាកម្មសិទ្ធិឯកជនដោយឡែកៗរបស់សមាជិកសហគមន៍នោះឡើយ។ សមាជិកសហគមន៍ម្នាក់ៗ ឬគ្រួសារនីមួយៗនៃសហគមន៍គ្មានសិទ្ធិចាត់ចែងដីជាកម្មសិទ្ធិសមូហភាពនេះទេ។

ដីលំនៅឋាន សំដៅដល់ដីដែលសមាជិកសហគមន៍ជនជាតិដើមភាគតិចប្រើប្រាស់ ដើម្បីសាងសង់លំនៅឋានសម្រាប់ស្នាក់នៅ ឬរស់នៅជាអចិន្ត្រៃយ៍ (និវេសនដ្ឋាន)។

ដីបម្រុងចាំបាច់ក្នុងការដូរវេនដំណាំ ឬដីរៀបចំបម្រុងសម្រាប់ចម្ការពនេចរ ឬដីចម្ការវិលជុំ សំដៅដល់ដីដែលសហគមន៍ជនជាតិដើមភាគតិចធ្លាប់បានប្រើប្រាស់កន្លងមកជាស្រែ ឬជាចម្ការក្នុងការដូរវេនដំណាំតាមប្រពៃណី។

ដីព្រៃអារក្ស សំដៅដល់ទីកន្លែងដែលសហគមន៍ទុកសម្រាប់គោរពបូជា ឬសែនព្រេនតាមទំនៀមទម្លាប់ប្រពៃណី

ដីកប់ខ្មោច សំដៅដល់ទីកន្លែងដែលសហគមន៍ប្រើប្រាស់សម្រាប់បញ្ចុះសពទៅតាមប្រពៃណីរបស់ខ្លួន។

អាជ្ញាធររដ្ឋបាល សំដៅដល់អាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរដែលមានអាណត្តិកាន់កាប់ដីរដ្ឋ ឬធនធានធម្មជាតិរបស់រដ្ឋក្នុងតំបន់នោះ។

គណៈកម្មាធិការសហគមន៍ ឬអាជ្ញាធរប្រពៃណី សំដៅដល់ថ្នាក់ដឹកនាំសហគមន៍ដែលត្រូវបានជ្រើសរើសដោយសមាជិកសហគមន៍ទាំងមូល។

អ្នកជិតខាង សំដៅដល់ប្រជាពលរដ្ឋ ឬសហគមន៍ទាំងឡាយ ឬអាជ្ញាធរកាន់កាប់ដីរដ្ឋដែលមានព្រំប្រទល់ដីជាប់នឹងដីរបស់សហគមន៍ដែលបានស្នើសុំចុះបញ្ជីដី។

ក្រុមការងារវាល សំដៅដល់សមាជិកក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុកមួយក្រុមដែលប្រធានក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុក បានចាត់តាំងឱ្យចុះធ្វើអត្តសញ្ញាណកម្ម ធ្វើផែនទីដីរដ្ឋ និងដីសហគមន៍នៅក្នុងឃុំ-សង្កាត់នីមួយៗ។

ក្រដាសកាល់ សំដៅដល់ក្រដាសម្យ៉ាងសថ្លា ហើយស្តើង ប្រើសម្រាប់ដាន ឬគូសប្លង់ផែនទី។

ចរន្តការ សំដៅដល់ការកត់ត្រាទុកជាប្រចាំក្នុងឯកសារសុរិយោដីនូវរាល់ការប្រើប្រាស់ ឬការផ្លាស់ប្តូរ ដោយយោងតាមឯកសារគតិយុត្ត។

សហគមន៍ដែលបានបង្កើតជានីតិបុគ្គល សំដៅដល់សហគមន៍ជនជាតិដើមភាគតិចដែលបានចងក្រង និងចុះបញ្ជីទទួលស្គាល់ជាផ្លូវការនៅក្រសួងមហាផ្ទៃ។

**ជំពូកទី២ គោលការណ៍នៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច**

**មាត្រា៥**

គោលការណ៍ទូទៅដែលត្រូវអនុវត្តក្នុងការចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចមានដូចតទៅ៖

-ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចគឺជាការចុះបញ្ជីទាំងអស់របស់សហគមន៍មួយ ជាកម្មសិទ្ធិសមូហភាពនៅក្នុងប្លង់រួមតែមួយ

-វិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិសមូហភាពដែលត្រូវចេញជូនសហគមន៍ត្រូវបញ្ជាក់ឈ្មោះសហគមន៍ ទីតាំងសហគមន៍ លេខយោងទៅរកប្លង់រួមដែលចង្អុលបង្ហាញនូវទីតាំង ទំហំ ព្រំប្រទល់ និយាមកានៃចំណែកដី ដែលជាកម្មសិទ្ធិសមូហភាព និងមានបញ្ជាក់ប្រភេទនៃការប្រើប្រាស់ដី និងកំណត់សម្គាល់ផ្សេងៗ

-សហគមន៍ដែលបានបង្កើតជានីតិបុគ្គលស្របច្បាប់មានលក្ខន្តិកៈដែលបានចុះបញ្ជី និង មានការទទួលស្គាល់ជាផ្លូវការអាចដាក់ពាក្យសុំចុះបញ្ជីដីកម្មសិទ្ធិសមូហភាពបាន

-សហគមន៍ជានីតិបុគ្គលស្របច្បាប់ដែលមានបទបញ្ញាផ្ទៃក្នុង សហគមន៍ចែងអំពីការគ្រប់គ្រង និងការប្រើប្រាស់ដីសមូហភាព ព្រមទាំងកំណត់នូវល័ក្ខខ័ណ្ឌមួយចំនួនមានជាអាទិ៍ ការចាត់ចែងដីជាសមូហភាព ការប្រើប្រាស់ដីទៅតាមប្រភេទដី និងការសម្រុះសម្រួលកម្រិតសហគមន៍ក្នុងករណីវិវាទលើការប្រើប្រាស់ដីតាមបែបប្រពៃណី ។

**ជំពូកទី៣ ដីដែលត្រូវចុះបញ្ជីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច**

**មាត្រា៦**

ដីដែលត្រូវចុះបញ្ជីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចមាន៖

១-ដីឯកជនរបស់រដ្ឋ ដូចជា៖

-ដីលំនៅឋាន ឬដីដែលសហគមន៍បានរៀបចំនិវេសនដ្ឋាន

-ដីដែលសហគមន៍ប្រកបរបរកសិកម្មប្រពៃណី មានដីដាំដុះជាក់ស្តែង ដីស្រែចម្ការ និង

២-ដីសាធារណៈរបស់រដ្ឋដែលបានចុះបញ្ជីរួចហើយជាមួយរដ្ឋ ដូចជា៖

-ដីបម្រុងចាំបាច់ក្នុងការដូរវេនដំណាំដែលបានទទួលស្គាល់ដោយអាជ្ញាធររដ្ឋបាល និង មានការព្រមព្រៀងពីអ្នកជិតខាង

-ដីព្រៃអារក្សដែលអាចមានមួយកន្លែង ឬច្រើនកន្លែងសម្រាប់សហគមន៍នីមួយៗ ដោយមានទំហំសរុបមិនលើសពី០៧ ( ប្រាំពីរ ) ហិកតា

-ដីកប់ខ្មោចដែលអាចមានមួយកន្លែង ឬច្រើនកន្លែងសម្រាប់សហគមន៍នីមួយៗ ដោយមានទំហំសរុបមិនលើសពី០៧ ( ប្រាំពីរ ) ហិកតា ។

**មាត្រា៧**

ចំពោះដីរដ្ឋផ្សេងៗទៀតដែលសហគមន៍ជនជាតិដើមភាគតិចធ្លាប់ប្រើប្រាស់តាមបែបប្រពៃណីកន្លងមក ដូចជា ដីព្រៃឈើសម្រាប់ការប្រមូលផល អនុផលព្រៃឈើ កន្លែងប្រើប្រាស់ទឹក សហគមន៍អាចបន្តប្រើប្រាស់ និងអាស្រ័យផលតាមប្រពៃណីរបស់ខ្លួន ប៉ុន្តែត្រូវចុះកិច្ចព្រមព្រៀងជាមួយស្ថាប័នសាមីដែលមានអាណត្តិកាន់កាប់ដីរដ្ឋនោះ ។

**ជំពូកទី៤ នីតិវិធី និងយន្តការនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច**

**មាត្រា៨**

ប្រធានគណៈកម្មាធិការសហគមន៍ ឬអាជ្ញាធរប្រពៃណីជនជាតិដើមភាគតិចនីមួយៗត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីដីសហគមន៍ ជាកម្មសិទ្ធិសមូហភាពនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុកដែលដីតាំងនៅ ដោយប្រើប្រាស់គំរូពាក្យសុំដូចមានក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។ នៅលើពាក្យសុំចុះបញ្ជីដីត្រូវមានការបញ្ជាក់ពីចៅសង្កាត់ មេឃុំថាសហគមន៍ ដែលស្នើសុំចុះបញ្ជីដីពិតជាសហគមន៍ដែលឋិតនៅក្នុងសង្កាត់-ឃុំរបស់ខ្លួនពិតប្រាកដមែន។

សំណុំលិខិតស្នើសុំចុះបញ្ជីដីសហគមន៍របស់ជនជាតិដើមភាគតិចមានដូចតទៅ៖

-ពាក្យស្នើសំចុះបញ្ជីដីសហគមន៍មានផ្តិតមេដៃប្រធានគណៈកម្មាធិការសហគមន៍ ឬអាជ្ញាធរប្រពៃណី

-លិខិតប្រគល់សិទ្ធិជូនសមាជិកគណៈកម្មាធិការសហគមន៍ណាម្នាក់ជាតំណាងសហគមន៍ក្នុងដំណើរការផ្តល់ព័ត៌មាន ការបញ្ចេញទម្រង់បែបបទក្នុងការចុះបញ្ជីដីសហគមន៍តាមនីតិវិធីជាធរមាន ប្រសិនបើប្រធានគណៈកម្មាធិការសហគមន៍ ឬអាជ្ញាធរប្រពៃណីមិនអាចចូលរួមបាន

-លក្ខន្តិកៈរបស់សហគមន៍ និងបញ្ជីរាយនាមសមាជិកសហគមន៍មានសេចក្តីបញ្ជាក់ពីចៅសង្កាត់ មេឃុំ

-បទបញ្ជាផ្ទៃក្នុងសហគមន៍ទាក់ទងនឹងរបៀបគ្រប់គ្រង
និងការប្រើប្រាស់ដីជាសមូហភាព

-លិខិតជូនដំណឹងស្តីពីការយល់ព្រមឱ្យចុះបញ្ជីសហគមន៍ដោយក្រសួងមហាផ្ទៃ

-សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសង្កាត់-ឃុំ ស្តីពីការតែងតាំងគណៈកម្មាធិការសហគមន៍ និង

-រាល់ឯកសារពាក់ព័ន្ធនឹងដីដែលស្នើសុំចុះបញ្ជី ប្រសិនបើមាន។

**មាត្រា៩**

ក្រោយពីបានទទួលពាក្យសុំចុះបញ្ជីដី ប្រសិនបើទីតាំង ទំហំ និងព្រំប្រទល់ដីរបស់សហគមន៍ជនជាតិដើមភាគតិចនោះមានការឯកភាពពីអ្នកជិតខាង ពីអាជ្ញាធររដ្ឋបាល និងមិនមានទំនាស់ ឬមានទំនាស់តែត្រូវបានដោះស្រាយរួចហើយ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក ត្រូវលើកសំណើជូនអភិបាលក្រុង-ស្រុកដើម្បីចេញសេចក្តីជូនដំណឹងជាសាធារណៈក្នុងរយៈពេល២០ (ម្ភៃ) ថ្ងៃយ៉ាងតិច មុនកាលបរិច្ឆេទនៃការចុះកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ ។ សេចក្តីជូនដំណឹងត្រូវបិទផ្សាយជាសាធារណៈនៅកន្លែងដែលងាយមើលឃើញ ដូចជានៅទីស្នាក់ការភូមិ នៅសាលាសង្កាត់-ឃុំ ទីប្រជុំជន និងទីតាំងដីរបស់សហគមន៍សាមី ។

ក្រោយពីមានការកំណត់ព្រំប្រទល់ និងការវាស់វែងជាក់ស្តែង ទិន្នន័យដែលប្រមូលបាន ត្រូវបិទផ្សាយជាសាធារណៈរយៈពេល៣០ (សាមសិប) ថ្ងៃ នៅក្នុងសហគមន៍សាមី និងនៅសាលាសង្កាត់-ឃុំដែលសហគមន៍នោះឋិតនៅ ។

ក្រោយរយៈពេលបិទផ្សាយ និងក្រោយពីការតវ៉ាផ្សេងៗ ប្រសិនបើមាន ត្រូវបានដោះស្រាយរួចហើយ រដ្ឋបាលសុរិយោដីត្រូវដំណើរការចុះបញ្ជីដី និងចេញវិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិសមូហភាពជូនសហគមន៍តាមនីតិវិធីដូចមានមាត្រា១០នៃអនុក្រឹត្យនេះ ។

**មាត្រា១០**

ក្នុងករណីដែលទីតាំង ទំហំ និងព្រំប្រទល់ដីរបស់សហគមន៍ជនជាតិដើមភាគតិចដែលស្នើសុំចុះបញ្ជីនៅមិនទាន់មានការឯកភាពពីអ្នកជិតខាង ឬពីអាជ្ញាធររដ្ឋបាល ត្រូវរៀបចំកិច្ចដំណើរតាមរយៈយន្តការ និងនីតិវិធីដូចខាងក្រោម៖

១-ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក ត្រូវលើកសំណើទៅអភិបាលក្រុង-ស្រុកដែលជាប្រធានក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុក ដើម្បីដំណើរការធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋនៅតំបន់ដែលសហគមន៍ស្នើសុំចុះបញ្ជីដី ។

២-បន្ទាប់ពីបានទទួលសំណើ អភិបាលក្រុង-ស្រុកត្រូវពិនិត្យ និងលើកយោបល់ជូនអភិបាលខេត្តជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្នុងរយៈពេលមិនលើសពី១៥ (ដប់ប្រាំ) ថ្ងៃ សុំឱ្យក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុក ចុះធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋ និងដីរបស់សហគមន៍នៅតំបន់ដែលសហគមន៍ស្នើសុំចុះបញ្ជី ។

៣-អភិបាលខេត្តត្រូវចាត់តាំងការងារដីរដ្ឋថ្នាក់ក្រុង-ស្រុក ប្រសិនបើមិនទាន់បានចាត់តាំង ដើម្បីអនុវត្តដំណើរការធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋ និងដីរបស់សហគមន៍ជនជាតិដើមភាគតិច ដែលសុំចុះបញ្ជីស្របតាមនីតិវិធី ដូចមានចែងក្នុងមាត្រា៦ និងមាត្រា៧នៃអនុក្រឹត្យ១១៨ ស្តីពីការគ្រប់គ្រងដីរដ្ឋ។

៤-ក្រោយពីទទួលបានយោបល់ឯកភាពពីអភិបាលខេត្ត ក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុក ត្រូវជូនដំណឹងដល់ប្រជាពលរដ្ឋក្នុងសហគមន៍សាមី អ្នកជិតខាង និងអ្នកពាក់ព័ន្ធ យ៉ាងតិច២០ (ម្ភៃ) ថ្ងៃ មុនពេលធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋ និងដីសហគមន៍។

៥-ក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុកត្រូវរៀបចំកិច្ចប្រជុំកសាងបញ្ជីដីរដ្ឋ និងដីរបស់សហគមន៍ ដោយមានការចូលរួមពីអាជ្ញាធរប្រពៃណីរបស់សហគមន៍ ឬតំណាងរបស់សហគមន៍សាមី ដើម្បីធ្វើការគូសបង្ហាញទីតាំង ព្រំប្រទល់ និងទំហំដីរបស់ខ្លួន នៅលើក្រដាសកាល់ដែលដាក់នៅលើផែនទីមាននិយាមកាច្បាស់លាស់។ អាជ្ញាធរកាន់កាប់ដីរដ្ឋ ក៏ត្រូវគូសបង្ហាញដីរដ្ឋនៅលើក្រដាសកាល់ផ្សេងទៀត ដែលដាក់នៅលើផែនទីនេះដែរ។

៦-បន្ទាប់ពីធ្វើការផ្ទៀងផ្ទាត់លទ្ធផលនៃការគូសបង្ហាញលើក្រដាសកាល់នានា ក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុកត្រូវដៅនូវចំណុចដែលគងជាន់គ្នា ឬមានភាពមិនច្បាស់លាស់មកពិភាក្សាគ្នា និងកំណត់ថ្ងៃចុះពិនិត្យរួមគ្នា រវាងការងារវាលដែលក្នុងនោះត្រូវមានវត្តមានមន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក អាជ្ញាធរប្រពៃណីរបស់សហគមន៍ ប្រជាពលរដ្ឋក្នុងសហគមន៍ និង/ឬតំណាងរបស់សហគមន៍សាមី និងសហគមន៍ ឬប្រជាពលរដ្ឋនៅជិតខាង ក្នុងការកំណត់ទីតាំង ព្រំប្រទល់ និងទំហំដែលសហគមន៍បាន និងកំពុងកាន់កាប់ ឬប្រើប្រាស់ផ្សេងៗ។

៧-ក្នុងការចុះពិនិត្យជាក់ស្តែង ក្រុមការងារវាលអាចស្នើធ្វើការកែតម្រូវ ប្រសិនបើពិនិត្យឃើញថាទីតាំង ព្រំប្រទល់ និងទំហំដីដែលសហគមន៍បាន និងកំពុងកាន់កាប់ ប្រើប្រាស់ជាប្រពៃណីកន្លងមកខុសពីការអះអាងដែលបានគូសលើផែនទី និងដោយមានការយល់ព្រមពីតំណាងសាមីសហគមន៍ និងសមាជិកសហគមន៍។ រាល់សំណើកែតម្រូវ ទោះបីមានការព្រមព្រៀងគ្នា ឬមិនមាន

ការព្រមព្រៀង ក៏ត្រូវធ្វើកំណត់ហេតុ និងចុះហត្ថលេខា ឬផ្តិតមេដៃរបស់ភាគីពាក់ព័ន្ធទាំងអស់ និងមន្ត្រីការងារវាល។

៨-លទ្ធផលនៃការធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដែលត្រូវភ្ជាប់ជាមួយរបាយការណ៍ និងកំណត់ហេតុផ្សេងៗត្រូវដាក់ជូនក្រុមការងារជីវជ្ជថ្នាក់ក្រុង-ស្រុក ដើម្បីធ្វើការប្រជុំសម្របសម្រួលរកការឯកភាពគ្នា។

៩-លទ្ធផលសង្ខេបនៃការប្រជុំ និងផែនទីទីតាំង ព្រំប្រទល់ និងទំហំដីសហគមន៍ និងជីវជ្ជ ត្រូវបិទផ្សាយជាសាធារណៈរយៈពេល៣០ (សាមសិប) ថ្ងៃ នៅទីស្នាក់ការសហគមន៍ ទីស្នាក់ការភូមិ និងសាលាសង្កាត់-ឃុំ ដើម្បីរង់ចាំទទួលមតិសាធារណៈ។ ការផ្តល់មតិពីសាធារណជននឹងត្រូវទទួលនៅសាលាសង្កាត់-ឃុំនៃសហគមន៍សាមី។

១០-បន្ទាប់ពីការបិទផ្សាយជាសាធារណៈ លទ្ធផលនៃការធ្វើអត្តសញ្ញាណកម្ម ធ្វើផែនទីដីសហគមន៍ និងជីវជ្ជ ព្រមទាំងរបាយការណ៍សង្ខេបមតិសាធារណៈត្រូវបញ្ជូនទៅសុំយោបល់សម្រេចពីគណៈកម្មាធិការគ្រប់គ្រងជីវជ្ជថ្នាក់ខេត្ត ក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ។

១១-គណៈកម្មាធិការគ្រប់គ្រងជីវជ្ជថ្នាក់ខេត្តអាចចាត់តាំងក្រុមមន្ត្រីចុះស៊ើបអង្កេត និងសាកសួរព័ត៌មានបន្ថែម ក្នុងករណីដែលមានការអះអាងមិនស្របគ្នា ឬមានភាពមិនច្បាស់លាស់ដោយប្រការណាមួយ។

១២-ក្រោយពីការឯកភាពគ្នាលើទីតាំងព្រំប្រទល់ និងទំហំដីដែលសហគមន៍បានចុះបញ្ជី គណៈកម្មាធិការគ្រប់គ្រងជីវជ្ជថ្នាក់ខេត្តត្រូវបញ្ជូនសេចក្តីសម្រេចនោះ ទៅក្រុមការងារជីវជ្ជថ្នាក់ក្រុង-ស្រុក ដើម្បីពិនិត្យ និងសម្រុះសម្រួលវិវាទផ្សេងៗ ប្រសិនបើមាន។ ក្នុងករណី ដែលការសម្រុះសម្រួលមិនអាចស្វែងការឯកភាពគ្នាបាន ក្រុមការងារជីវជ្ជថ្នាក់ក្រុង-ស្រុក ត្រូវបញ្ជូនសំណុំរឿងវិវាទនោះ ទៅគណៈកម្មាធិការសុរិយោដី។

១៣-បន្ទាប់ពីការសម្រេចឯកភាពលើទីតាំង ព្រំប្រទល់ ទំហំដី និងដោះស្រាយវិវាទនានារួចហើយ ក្រុមការងារជីវជ្ជថ្នាក់ក្រុង-ស្រុកត្រូវប្រគល់ឯកសារពាក់ព័ន្ធនឹងដីសហគមន៍បានស្នើ ទៅរដ្ឋបាលសុរិយោដីថ្នាក់ក្រុង-ស្រុក ដើម្បីវាស់វែង និងចុះបញ្ជីចំណែកផ្សេងៗនៃដីសហគមន៍ តាមនីតិវិធីដូចមានចែងក្នុងមាត្រា៩នៃអនុក្រឹត្យនេះ និងបញ្ចូលទិន្នន័យជីវជ្ជទៅក្នុងប្រព័ន្ធទិន្នន័យជីវជ្ជ។

**មាត្រា១១**

រដ្ឋបាលសុរិយោដីត្រូវបង្កើតសៀវភៅគោលបញ្ជីដោយឡែក សម្រាប់ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។

រដ្ឋបាលសុរិយោដីថ្នាក់ក្រុង-ស្រុកត្រូវចុះបញ្ជីដីសហគមន៍ដែលបានដាក់ពាក្យសុំជាកម្ម-សិទ្ធិសមូហភាព ក្នុងសៀវភៅគោលបញ្ជី ដោយផ្អែកលើទិន្នន័យដែលប្រមូលបានដូចមានចែងក្នុងមាត្រា៩នៃអនុក្រឹត្យនេះ ឬដោយផ្អែកលើលទ្ធផលនៃការធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដែលបានសម្រេចជាផ្លូវការ ដូចមានចែងក្នុងមាត្រា១០នៃអនុក្រឹត្យនេះ។

ការចុះបញ្ជីដីរបស់សហគមន៍ត្រូវចុះគ្រប់ចំណែកនៃក្បាលដីទាំងអស់របស់សហគមន៍មួយ នៅលើប្លង់រួមតែមួយ ទោះបីក្បាលដីនោះឋិតនៅក្នុងភូមិ ឃុំខុសគ្នាក៏ដោយ។ ផ្អែកលើប្លង់រួមនេះ រដ្ឋបាលសុរិយោដីត្រូវចេញវិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិសមូហភាពជូនសហគមន៍ ទៅតាមស្ថានភាពជាក់ស្តែងនៃក្បាលដីនីមួយៗ ដោយបញ្ជាក់ឈ្មោះសហគមន៍ ទីតាំងសហគមន៍ លេខយោងទៅរកប្លង់រួមដែលចង្អុលបង្ហាញទីតាំង ទំហំ ព្រំប្រទល់ និយាមកានៃចំណែកដីដែលជាកម្មសិទ្ធិសមូហភាព និងមានបញ្ជាក់នូវប្រភេទនៃការប្រើប្រាស់ដី និងកំណត់សម្គាល់ផ្សេងៗ។ គំរូវិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិសមូហភាពរបស់សហគមន៍មានទម្រង់ ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**មាត្រា១២**

ក្នុងករណីក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុកចុះអនុវត្តការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ នៅកន្លែងដែលមានសហគមន៍ជនជាតិដើមភាគតិចរស់នៅ ហើយជាសហគមន៍បានចុះបញ្ជី និងបានទទួលស្គាល់ជាផ្លូវការដោយក្រសួងមហាផ្ទៃរួចហើយ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុកត្រូវផ្សព្វផ្សាយឱ្យសហគមន៍នោះដាក់ពាក្យស្នើសុំចុះបញ្ជីដីកម្មសិទ្ធិសហគមន៍។ សហគមន៍ត្រូវចូលរួមបង្ហាញនូវទីតាំង ព្រំប្រទល់ និងទំហំនៃចំណែកដីផ្សេងៗដែលសហគមន៍បានកាន់កាប់ និងកំពុងប្រើប្រាស់ដល់ក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុក ស្របតាមនីតិវិធីដែលមានចែងក្នុងមាត្រា៩ និងមាត្រា១០នៃអនុក្រឹត្យនេះ។

## ជំពូកទី៥ ល័ក្ខខ័ណ្ឌក្នុងការទទួលបានដីនៅពេលសមាជិកសហគមន៍សុំចូល ឬសុំចេញពីសហគមន៍ និងការរំសាយសហគមន៍

**មាត្រា១៣**

ជនជាតិដើមភាគតិចដែលបានកាន់កាប់ចំណែកដីជាឯកជនស្របច្បាប់ ឬមានដីជាកម្មសិទ្ធិឯកជន ហើយស្នើសុំចូលជាសមាជិកសហគមន៍ជនជាតិដើមភាគតិចណាមួយ នោះសាមីខ្លួនត្រូវលះបង់ចំណែកដីឯកជនរបស់ខ្លួនទាំងអស់ មកដាក់បញ្ចូលជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ ហើយសមាជិកថ្មីនេះត្រូវទទួលបាននូវអត្ថប្រយោជន៍ផ្សេងៗពីសហគមន៍ដូចសមាជិកដទៃទៀត។

**មាត្រា១៤**

នៅពេលដែលសមាជិកណាម្នាក់សម្រេចចាកចេញពីសហគមន៍ សាមីជននោះអាចនឹងត្រូវទទួលបាននូវចំណែកដីសមស្របដែលនឹងត្រូវកាត់ចេញពីដីកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ឬអាចទទួលបានជាសំណងទូទាត់សមស្រប ទៅតាមការសម្រេចរបស់សមូហភាពសហគមន៍ ក្នុងករណីដែលអ្នកចាកចេញយល់ព្រម។

ចំណែកដីដែលត្រូវកាត់ជូនសមាជិកចាកចេញពីសហគមន៍ អាចជាដីដែលសហគមន៍បានរៀបចំជំនិវេសនដ្ឋាន និង/ឬដីដែលសហគមន៍ប្រកបរបរកសិកម្មប្រពៃណី ដូចជាដីដាំដុះជាក់ស្តែង និងដីស្រែចម្ការ។

ក្នុងការកាត់ចេញចំណែកដី ឬបញ្ចូលចំណែកដីរបស់សហគមន៍ជនជាតិដើមភាគតិចណាមួយដែលបណ្តាលមកពីសមាជិកសុំចាកចេញ ឬសុំចូលថ្មី តំណាងសហគមន៍ត្រូវស្នើសុំទៅរដ្ឋបាលសុរិយោដី ដើម្បីធ្វើការចុះបញ្ជីបន្តនូវរាល់ការផ្លាស់ប្តូរទាំងនោះ។

**មាត្រា១៥**

ក្នុងករណីដែលសហគមន៍ត្រូវរំសាយ ការចាត់ចែងទ្រព្យសម្បត្តិរបស់សហគមន៍ត្រូវអនុលោមតាមខ្លឹមសារនៃលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍។

## ជំពូកទី៦ អវសានប្បញ្ញត្តិ

**មាត្រា១៦**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

*វាយឡើងវិញ*

**មាត្រា១៧**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលរាជធានី និងអភិបាលខេត្តត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*

*-ដូចមាត្រា១៧*

*-រាជកិច្ច*

*-ឯកសារ-កាលប្បវត្តិ*

*វាយឡើងវិញ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ៨៩អនក្រ/បក

**អនុក្រឹត្យ**
**ស្តីពីការបន្ថែមសមាជិកគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ៨៨អនក្រ/បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១៩អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីសម្បទានដីសង្គមកិច្ច
- តាមសំណើរបស់ប្រធានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ

*វាយឡើងវិញ*

## សម្រេច

**មាត្រា១**

ត្រូវបានបន្ថែមសមាជិកគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដែលមានចែងក្នុងមាត្រា២១នៃអនុក្រឹត្យលេខ១៩អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច ដូចខាងក្រោម៖

១- រដ្ឋលេខាធិការនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
ដែលទទួលការងារសម្បទានដីសង្គមកិច្ច ជាសមាជិក
២-អនុប្រធានរដ្ឋបាលព្រៃឈើ០១រូប ជាសមាជិក
៣-អគ្គនាយករងអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម
នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាអគ្គលេខាធិការរងអចិន្ត្រៃយ៍។

**មាត្រា២**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រុមប្រឹក្សាគោលនយោបាយដីធ្លី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ប្រធានគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីធ្លីរាជធានី-ខេត្ត សមាជិកទាំងអស់នៃគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ និងសមាសភាពដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា និងត្រា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u>
*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយរដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ*
*-ដូចមាត្រា២*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

*វាយឡើងវិញ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ២២៧សជណ/អគ

**សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាល**
**ស្តីពីគោលនយោបាយដីធ្លី**

ដោយយល់ឃើញពីភាពចាំបាច់ក្នុងការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិឱ្យមានប្រសិទ្ធភាព ផលិតភាព និរន្តរភាពបរិស្ថាន និងដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចដាក់ចេញនូវចក្ខុវិស័យ គោលបំណង និងសកម្មភាពទាំងឡាយក្នុងវិស័យដីធ្លីដូចខាងក្រោម៖

ចក្ខុវិស័យនៃគោលនយោបាយដីធ្លីនៅកម្ពុជាគឺ "គ្រប់គ្រង រៀបចំ ប្រើប្រាស់ និងបែងចែកដីប្រកបដោយសមធម៌ តម្លាភាព ប្រសិទ្ធភាព និងចីរភាព ដើម្បីរួមចំណែកធ្វើឱ្យសម្រេចគោលដៅជាតិនៃការកាត់បន្ថយភាពក្រីក្រ ការធានាសន្តិសុខស្បៀង ការការពារបរិស្ថាន និងធនធានធម្មជាតិ កិច្ចការពារជាតិ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ក្នុងបរិបទសេដ្ឋកិច្ចទីផ្សារ"។

ក្រុមប្រឹក្សាគោលនយោបាយដីធ្លីមានភារកិច្ចជំរុញ និងត្រួតពិនិត្យការអនុវត្តគោលនយោបាយដីធ្លី ស្របតាមទិសដៅរបស់ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ព្រមទាំងសម្របសម្រួលរវាងអនុវិស័យដីធ្លីទាំងបី (រដ្ឋបាលដីធ្លី ការរៀបចំដែនដី និងការបែងចែកដីធ្លី) ក្នុងការអនុវត្តច្បាប់ភូមិបាល និងច្បាប់ដទៃទៀតដែលពាក់ព័ន្ធនឹងបរិស្ថាន ព្រៃឈើ ជលផល ធនធានទឹក ក្រមរដ្ឋប្បវេណី វិមជ្ឈការ និងវិសហមជ្ឈការ ។ល។

គោលបំណង និងសកម្មភាពពាក់ព័ន្ធនឹងអនុវិស័យដីធ្លីទាំងបីរួមមាន៖

**ក-អនុវិស័យរដ្ឋបាលដីធ្លី** (Land Administration)

គោលបំណងនៃរដ្ឋបាលដីធ្លីគឺធ្វើការចុះបញ្ជីកម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុទាំងអស់ (រដ្ឋ និងឯកជន) ឱ្យបានច្បាស់លាស់ ធ្វើការផ្ទេរសិទ្ធិលើទ្រព្យទាំងនោះជាផ្លូវការ ទប់ស្កាត់ និងដោះស្រាយវិវាទដីធ្លី សំដៅពង្រឹងសុវត្ថិភាពនៃការកាន់កាប់ដីធ្លី ធានាបាននូវទំនុកចិត្ត និងប្រសិទ្ធភាពនៃទីផ្សារដីធ្លី។

ការចុះបញ្ជីដីធ្លីត្រូវគោរពតាមគោលការណ៍អភិបាលកិច្ចល្អ តម្លាភាព វិមជ្ឈការ និងវិសហមជ្ឈការ និងសមធម៌យេនឌ័រ ដើម្បីបង្កើតបានជាវប្បធម៌នៃការចុះបញ្ជីដីធ្លី និងបង្កើនភាពជឿជាក់លើប្រព័ន្ធចុះបញ្ជីដីធ្លី។ ការងារនេះ ត្រូវមានលក្ខណៈសាមញ្ញ ច្បាស់លាស់ ឆាប់រហ័ស ងាយទទួលបាន មានតម្លៃទាប។ ត្រូវរៀបចំឱ្យមានប្រព័ន្ធព័ត៌មានដីធ្លី (Land Information System) ដើម្បីផ្តល់ព័ត៌មានជាក់លាក់ពីអចលនវត្ថុក្នុងតម្លៃសមស្រប។

<u>សកម្មភាពនៃអនុវិស័យរដ្ឋបាលដីធ្លី</u>

១-បង្កើត និងពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យពាក់ព័ន្ធដូចជាច្បាប់អស្សាមិករណ៍ (ការដកហូតកម្មសិទ្ធិ - Expropriation Law) ច្បាប់ស្តីពីសិទ្ធិបុព្វក្រៃ (រដ្ឋមានសិទ្ធិទិញមុនអ្នកដទៃ - Pre-emption Law) ច្បាប់ស្តីពីដីកសិកម្ម ការផ្ទេរដី (Land Transfer) ការបង្រួមក្បាលដី (Land Consolidation) ការបំបែកក្បាលដី (Land Sub-division) ពន្ធលើដីធ្លី (Land Taxation) ការវាយតម្លៃថ្លៃដី (Land Valuation) ទីផ្សារដី (Land Market) ធនាគារដី (Land Banking) និងការវាស់វែងដី (Land Survey)... ។ល។ ព្រមទាំងធ្វើវិសោធនកម្មមាត្រាច្បាប់ និងបទដ្ឋានគតិយុត្តមួយចំនួន ដែលពាក់ព័ន្ធនឹងច្បាប់ភូមិបាល ច្បាប់សារពើពន្ធ . . . ស្របតាមការវិវត្តនៃសភាពការណ៍ប្រទេសជាតិ។

២-បង្កើតបញ្ជីសារពើភ័ណ្ឌអចលនវត្ថុ (ដី និងអគារ) របស់រដ្ឋជាជំហានៗឱ្យបានច្បាស់លាស់ និងពេញលេញនៅក្នុងប្រព័ន្ធទិន្នន័យឯកភាពតែមួយ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងអចលនវត្ថុរបស់រដ្ឋ។

៣-ដំណើរការចុះបញ្ជីដីធ្លីទូទាំងប្រទេសប្រកបដោយតម្លាភាព និងប្រសិទ្ធភាពសម្រាប់អចលនវត្ថុទាំងអស់ ទាំងដីរដ្ឋ (ដីសាធារណៈ និងដីឯកជនរបស់រដ្ឋ) និងដីឯកជនរបស់បុគ្គលឯកជន៖

៣.១-បន្តអនុវត្តនីតិវិធីចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ និងមានលក្ខណៈដាច់ដោយដុំ។

៣.២-ចុះបញ្ជីបន្ត និងធ្វើចរន្តការលើព័ត៌មានសុរិយោដីឱ្យបានឆាប់រហ័សដើម្បីបង្កើនចំណូលរបស់រដ្ឋ។

៣.៣-ធ្វើលេខាចារីកនូវរាល់ហ៊ីប៉ូតែក ការបញ្ចាំ ការដាក់ធានា ការជួលរយៈពេលវែង សម្បទានដីសេដ្ឋកិច្ច ឬសេវភាព ដែលបានបង្កើតឡើងលើទ្រព្យជាអចលនវត្ថុ។

៣.៤-ជំរុញការចុះបញ្ជីសហកម្មសិទ្ធិ។

៣.៥-យកចិត្តទុកដាក់លើការចុះបញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិច។

៣.៦-ជំរុញការចុះបញ្ជីដីរដ្ឋ (ដីសាធារណៈ និងដីឯកជនរបស់រដ្ឋ)។

៣.៧-បង្កើតប្រព័ន្ធព័ត៌មានដីធ្លី (LIS) ដែលអាចផ្តល់ព័ត៌មានជាក់លាក់ជូនអតិថិជន។ ប្រព័ន្ធព័ត៌មានដីធ្លីជាមូលដ្ឋានសម្រាប់ហេដ្ឋារចនាសម្ព័ន្ធទិន្នន័យភូមិសាស្ត្រជាតិ (National Spatial Data Infrastructure) និងសម្រាប់បម្រើដល់ពហុគោលបំណង។

៤-បង្កើតប្រព័ន្ធព័ត៌មានធរណីសាស្ត្រ និងធ្វើចំណាត់ថ្នាក់ប្រភេទដី តាមលក្ខណៈពីធម្មជាតិនៃដី (Soil Classification)។

៥-ការបង្កើតប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) ឱ្យមានការឯកភាពនៅទូទាំងប្រទេស៖

៥.១-បង្កើតប្រព័ន្ធព័ត៌មានភូមិសាស្ត្រឯកភាពមួយ (GIS) ក្រោមការសម្របសម្រួលរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ បង្កើតផ្នែកទទួលខុសត្រូវបោះពុម្ព និងចែកចាយផែនទីគោល។

៥.២-បន្តរៀបចំបណ្តាញប្រថពីវិភាគ (Geodetic Network) នៅទូទាំងប្រទេស និងរៀបចំបង្កើតបណ្តាញរយៈកម្ពស់ (Leveling Network)។

៥.៣-រៀបចំបង្កើតស្ថានីយវាស់វែងជីភីអេសអចិន្ត្រៃយ៍ (Permanent GPS Base Station)។

៦-រៀបចំប្រព័ន្ធវាយតម្លៃថ្លៃដីដែលមានលក្ខណៈចូលរួម តម្លាភាព និងទទួលស្គាល់ជាផ្លូវការ។ ការវាយតម្លៃថ្លៃដី ត្រូវផ្អែកលើគុណភាពអំណោយផលពីធម្មជាតិនៃដី និងរាប់បញ្ចូលអចលនវត្ថុទាំងអស់នៅលើដីផងដែរ (Land and Improvements) ដើម្បីបង្កើតជាមូលដ្ឋាន

មួយសម្រាប់ការលក់-ទិញ ការជួល ការវិនិយោគ ការឱ្យខ្ចីប្រាក់ ការយកពន្ធ (ពន្ធប្រចាំឆ្នាំ ពន្ធលើការផ្ទេរ លើការជួល លើប្រាក់ចំណេញ លើដីធ្លីមិនប្រើប្រាស់) ការកំណត់សេវាសុរិយោដី និងការទូទាត់សំណង... ។ល។

៦.១-ផ្តល់អាជ្ញាប័ណ្ណដល់អ្នកវាយតម្លៃថ្លៃអចលនវត្ថុ។

៦.២-កសាង និងពង្រឹងសមត្ថភាពដល់អ្នកវាយតម្លៃថ្លៃអចលនវត្ថុ។

៦.៣-បន្តអនុវត្តគោលនយោបាយមិនយកពន្ធលើដីធ្លីកសិកម្មរបស់កសិករ ដែលធ្វើការបង្កបង្កើនផលជាលក្ខណៈគ្រួសារ។ ទន្ទឹមនេះ ត្រូវផ្តួចផ្តើមសិក្សាការយកពន្ធប្រចាំឆ្នាំលើអចលនវត្ថុក្រៅពីដីកសិកម្មជាលក្ខណៈគ្រួសារ។

៦.៤-រៀបចំផែនទីតម្លៃថ្លៃដី។

៦.៥-ដំណើរការវាយតម្លៃថ្លៃអចលនវត្ថុនៅតំបន់ទីប្រជុំជន និងជនបទ និងតាមដានត្រួតពិនិត្យការវាយតម្លៃ។

៧-លើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជនលើការងារវាស់វែងដីធ្លី ក្រោមការត្រួតពិនិត្យរបស់រដ្ឋបាលសុរិយោដី។

៨-បន្តដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការតាមរយៈគណៈកម្មការរដ្ឋបាល គណៈកម្មការសុរិយោដីគ្រប់លំដាប់ថ្នាក់ (ថ្នាក់ជាតិ ថ្នាក់រាជធានី-ខេត្ត ថ្នាក់ក្រុង-ស្រុក-ខណ្ឌ និងក្រុមចល័ត) និងអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី ជាពិសេសចំពោះករណីវិវាទពហុភាគី។

៩-បង្កើតប្រព័ន្ធស្វ័យគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ផ្នែករដ្ឋបាលដីធ្លី ដោយផ្តើមពីចំណូលបានមកពីការចុះបញ្ជី និងពីសេវាសុរិយោដីដើម្បីគាំទ្រ និងពន្លឿនដំណើរការចុះបញ្ជីដីនៅទូទាំងប្រទេស។

**ខ.អនុវិស័យរៀបចំដែនដី** (Land Management)

**គោលបំណងនៃការរៀបចំដែនដី** គឺធានាការគ្រប់គ្រង ការការពារ និងការប្រើប្រាស់ដី និងធនធានធម្មជាតិប្រកបដោយតម្លាភាព និងប្រសិទ្ធភាព ដើម្បីរក្សានិរន្តរភាពបរិស្ថាន និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយសមធម៌នៅទីប្រជុំជន និងជនបទ ព្រមទាំងទប់ស្កាត់វិវាទលើការប្រើប្រាស់ដី ដោយដាក់បញ្ញត្តិលើការអភិវឌ្ឍដី (Land Development) ការប្តូរប្រភេទ

នៃការប្រើប្រាស់ដី (Land Conversion) លើការកែសម្រួលក្បាលដី (Land Readjustment) លើការសាងសង់ លើការតាំងទីលំនៅជាថ្មី អនុលោមតាមច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ក្របខ័ណ្ឌយុទ្ធសាស្ត្រគោលនយោបាយដីធ្លី គោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ និងអភិបាលកិច្ចល្អ។

ទន្ទឹមនេះ ការងាររៀបចំដែនដីត្រូវធ្វើឱ្យស្របតាមគោលការណ៍សមធម៌ តម្លាភាព ការចូលរួម ការព្រមព្រៀងគ្នា និងគោរពតាមឋានានុក្រមនៃការរៀបចំផែនការ បទបញ្ញា និងនីតិវិធីពាក់ព័ន្ធ។

**សកម្មភាពនៃអនុវិស័យរៀបចំដែនដី**

១-អភិវឌ្ឍគោលនយោបាយជាតិ និងក្របខ័ណ្ឌគតិយុត្ត ព្រមទាំងនីតិវិធីសមស្របសម្រាប់ការគ្រប់គ្រង អភិវឌ្ឍដីនៅទីប្រជុំជន និងជនបទ រួមទាំងដីបម្រើឱ្យផលិតកម្មកសិកម្ម ការសាងសង់ និងការតាំងទីលំនៅជាថ្មី។

២-បង្កើតប្រព័ន្ធផែនការរៀបចំដែនដី (spatial planning system) ដែលចង្អុលបង្ហាញអំពីការរៀបចំតំបន់ ឬទីតាំងនីមួយៗ ដោយផ្អែកលើលក្ខណៈពិធម្មជាតិនៃដី និងតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយសមធម៌។ ប្រព័ន្ធផែនការរៀបចំដែនដី (spatial planning system) ត្រូវបង្កើតតាមរយៈ៖

២.១-ការកំណត់ខ្លឹមសារ និងឋានានុក្រមនៃផែនការ (រួមមានយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ទីក្រុង)។

២.២-ការកំណត់សមត្ថកិច្ចកសាង និងអនុម័តផែនការ។

២.៣-ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីគាំទ្រការអនុវត្ត។

៣-រាល់ផែនការប្រើប្រាស់ដីសម្រាប់តំបន់អាទិភាពដូចជា ផែនការអភិវឌ្ឍតំបន់ឆ្នេរ តំបន់ទេសចរណ៍ តំបន់វិនិយោគ តំបន់ដែលមានសក្តានុពលសេដ្ឋកិច្ច តំបន់ទីប្រជុំជន និងច្រករបៀងសំខាន់ៗ ត្រូវគោរពតាមគោលការណ៍ តម្លាភាព ការចូលរួម ការព្រមព្រៀងគ្នា សមធម៌ និងធានានិរន្តរភាព។

៤-គ្រប់គ្រង និងត្រួតពិនិត្យការប្រើប្រាស់ដី និងធនធានធម្មជាតិដោយប្រើប្រាស់ឧបករណ៍៖

៤.១-ផែនការរៀបចំដែនដី (Spatial Planning) ។

៤.២-ផែនការប្រើប្រាស់ដី (Land Use Planning) ។

៤.៣-ផែនការអភិវឌ្ឍន៍សម្រាប់ទីប្រជុំជន និងជនបទ (Urban and Rural Development Plan)

៤.៤-ការកំណត់តំបន់ប្រើប្រាស់ដី (Zoning) ។

៤.៥-ការត្រួតពិនិត្យប្លង់ទីតាំងសំណង់ ដោយរួមបញ្ចូលទាំងនីតិវិធីរៀបចំដីមិនទាន់អភិវឌ្ឍន៍ (Sub-division Control) ។

៤.៦-ក្រមនគរូបនីយកម្ម (Urban Code) ។

៤.៧-ក្រមសំណង់ (Construction Code) ស្តង់ដារសំណង់ និងលិខិតបទដ្ឋានបច្ចេកទេសសំណង់ ។

៤.៨-ការត្រួតពិនិត្យការអភិវឌ្ឍ (Development Control) ។

៥-ជំរុញការធ្វើផែនការរៀបចំដែនដីថ្នាក់ជាតិ ថ្នាក់ខេត្ត និងផែនការប្រើប្រាស់ដីថ្នាក់ក្រោមជាតិ ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ ហើយដែលក្នុងនោះ ត្រូវរៀបចំ (i)-ផែនការរៀបចំដែនដីថ្នាក់ជាតិ (ii)-ផែនការរៀបចំដែនដីថ្នាក់ខេត្ត (iii)-ប្លង់គោលប្រើប្រាស់ដីធ្លី និងផែនការប្រើប្រាស់ដីថ្នាក់រាជធានី (iv)-ប្លង់គោលប្រើប្រាស់ដីធ្លី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង (v)-ប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក (vi)-ប្លង់គោលប្រើប្រាស់ដីថ្នាក់ខណ្ឌ និង (vii)-ផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់ ។

៦-ពន្លឿនការរៀបចំគោលការណ៍ណែនាំលើការប្រើប្រាស់ដីនៅមូលដ្ឋាន ដើម្បីគាំទ្រដល់វិមជ្ឈការ និងវិសហមជ្ឈការនៃការរៀបចំដែនដីក្រោមការគាំទ្របច្ចេកទេសពីថ្នាក់ជាតិដល់អាជ្ញាធរមូលដ្ឋាន ។

៧-ជំរុញវិមជ្ឈការនៃការរៀបចំដែនដី ។ ស្ថាប័នដែលមានអាណត្តិកាន់កាប់ដីរដ្ឋ ត្រូវផ្តល់បញ្ជីសារពើភ័ណ្ឌប្រចាំឆ្នាំដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីឱ្យក្រសួងនេះធ្វើរបាយការណ៍សរុបជូនរាជរដ្ឋាភិបាល អំពីស្ថានភាពនៃការប្រើប្រាស់ដី ។ សាធារណជនអាចទទួលបានព័ត៌មាននេះពីស្ថាប័នពាក់ព័ន្ធ ។ ស្ថាប័នដែលទទួលបានអាណត្តិកាន់កាប់ដីរដ្ឋ រួមជាមួយអាជ្ញាធរដែនដី

គ្រប់លំដាប់ថ្នាក់ត្រូវទទួលខុសត្រូវក្នុងកិច្ចការពារ និងធានានូវគណនេយ្យភាពចំពោះការគ្រប់គ្រងដីសាធារណៈ និងដីឯកជនរបស់រដ្ឋ។

៨-ផ្តួចផ្តើមការកែសម្រួលក្បាលដី ដើម្បីបង្កើនផលិតភាពសេដ្ឋកិច្ច និងការអភិវឌ្ឍមូលដ្ឋានរួមទាំងការអភិវឌ្ឍភូមិ (Village Development) ។

**គ. អនុវិស័យបែងចែកដីធ្លី** (Land Distribution)

គោលបំណងនៃការបែងចែកដីធ្លី គឺផ្តល់ទិសដៅច្បាស់លាស់ដើម្បីធ្វើការបែងចែក និងការប្រើប្រាស់ដីរដ្ឋសម្រាប់គោលបំណងឯកជន និងសាធារណៈ ប្រកបដោយតម្លាភាព និងសមធម៌ ដោយឆ្លើយតបទៅនឹងតម្រូវការជីវភាពរបស់ប្រជាពលរដ្ឋទូទៅ ជាពិសេសប្រជាពលរដ្ឋក្រីក្រ យុទ្ធជនពិការ និងគ្រួសារយុទ្ធជនពលី ដែលគ្មានដី និងខ្វះដីតាមរយៈកម្មវិធីសម្បទានដីសង្គមកិច្ច។

ការបែងចែកដីធ្លី ត្រូវធានាឱ្យបាននូវសមធម៌ ស្ថិរភាពសង្គម សន្តិសុខស្បៀង និងការសម្រួលដល់ការវិនិយោគ ដោយផ្អែកលើប្រភេទ និងគុណភាពអំណោយផលពីធម្មជាតិនៃដី ដើម្បីការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ប្រកបដោយចីរភាព ទប់ស្កាត់ការប្រមូលដីទុក និងជំរុញការប្រើប្រាស់ដីប្រកបដោយប្រសិទ្ធភាព និងផលិតភាព។

**សកម្មភាពនៃការបែងចែកដីធ្លី៖**

១. ជំរុញការប្រមូល និងចងក្រងបញ្ជីសារពើភ័ណ្ឌដីរដ្ឋ សម្រាប់បម្រុងទុកក្នុងគោលដៅបែងចែក និងប្រើប្រាស់ដីពេលបច្ចុប្បន្ន និងទៅអនាគតប្រកបដោយសមធម៌ តម្លាភាព និងគណនេយ្យភាព។

២-បង្កើត និងអនុវត្តយុទ្ធសាស្ត្រ និងក្របខ័ណ្ឌនៃផែនការបែងចែកដីធ្លីរយៈពេលមធ្យម និងវែង ដើម្បីបែងចែក និងប្រើប្រាស់ដីសម្រាប់គោលដៅសង្គមកិច្ច និងសេដ្ឋកិច្ច ស្របតាមផែនការថ្នាក់ជាតិ ថ្នាក់រាជធានី-ខេត្ត ថ្នាក់ក្រុង-ស្រុក-ខណ្ឌ និងថ្នាក់ឃុំ-សង្កាត់ ដោយធានាតម្លាភាព និងប្រសិទ្ធភាព ចៀសវាងការជះឥទ្ធិពលអវិជ្ជមានដល់សង្គម និងបរិស្ថាន។

៣-ជំរុញការបែងចែកដីធ្លីសម្រាប់គោលដៅសង្គមកិច្ចឱ្យបានទាន់ពេលវេលា ដើម្បីរួមចំណែកដោះស្រាយបញ្ហាសង្គម និងទប់ស្កាត់ការទន្ទ្រានកាន់កាប់ដីរដ្ឋដោយខុសច្បាប់។

*វាយឡើងវិញ*

៤-អនុវត្តភាពជាដៃគូរវាងម្ចាស់ចម្ការខ្នាតតូច ខ្នាតធំ និងសាជីវកម្មនៅក្នុងការងារកសិផលិតកម្ម និងរវាងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច សំដៅបង្កើតការងារធ្វើ និងបង្កើតទីផ្សារ សម្រាប់អ្នករស់នៅក្នុងមូលដ្ឋាន។

រាជរដ្ឋាភិបាលមានជំនឿយ៉ាងមុតមាំថា គ្រប់ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធទាំងអស់ នឹងចូលរួមអនុវត្តគោលនយោបាយនេះឱ្យមានប្រសិទ្ធភាព ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ តាមរយៈការបំពេញតួនាទី និងភារកិច្ចតាមវិស័យជំនាញរៀងៗខ្លួន។ គោលនយោបាយរបស់រាជរដ្ឋាភិបាល ដូចបានសង្ខេបខាងលើនេះនឹងត្រូវបន្តរៀបចំ "គោលនយោបាយដីធ្លីទូលំទូលាយ" (Comprehensive Land Policy) នៅពេលខាងមុខនេះ។

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*វាយឡើងវិញ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ១២៦អនក្រ/បក

**អនុក្រឹត្យ**

**ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញអនុក្រឹត្យលេខ៨៦អនក្រ/បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់

- បានឃើញអនុក្រឹត្យលេខ៦២អនក្រ/បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩

**សម្រេច**

**ជំពូកទី១ បទប្បញ្ញត្តិទូទៅ**

**មាត្រា១**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ ព្រមទាំងយន្តការ និងនីតិវិធីសម្រាប់ធ្វើការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ។

**មាត្រា២**

អនុក្រឹត្យមានគោលបំណងដូចតទៅ៖

-ធានាការពារសិទ្ធិកម្មសិទ្ធិស្របច្បាប់របស់អ្នកកាន់កាប់ចំណែកឯកជន នៃអគារសហកម្មសិទ្ធិ

-សម្រួលដល់ការងារគ្រប់គ្រងអគារសហកម្មសិទ្ធិ និងសហកម្មសិទ្ធិករដែលរស់នៅក្នុងអគារសហកម្មសិទ្ធិ

-សម្រួលដល់សហកម្មសិទ្ធិករក្នុងការលក់ ការដូរ ការធ្វើអំណោយ ការបន្តមតិក ការជួលអចិន្ត្រៃយ៍ ការដាក់ហ៊ីប៉ូតែក និងការដាក់បញ្ចាំនូវចំណែកឯកជនដែលជាកម្មសិទ្ធិរបស់ខ្លួន។

**មាត្រា៣**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះអគារសហកម្មសិទ្ធិគ្រប់ប្រភេទ នៅទូទាំងព្រះរាជាណាចក្រកម្ពុជាដែលបានសាងសង់ដោយស្របច្បាប់។

មានតែរូបវន្តបុគ្គលដែលមានសញ្ជាតិខ្មែរប៉ុណ្ណោះ ទើបអាចមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ លើកលែងតែមានបទប្បញ្ញត្តិផ្សេងពីនេះ។

**មាត្រា៤**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចតទៅ៖

-<u>អគារសហកម្មសិទ្ធិ</u> សំដៅដល់អគារ ឬសំណង់ដែលមានកម្មសិទ្ធិករច្រើននាក់រស់នៅ។ អគារសហកម្មសិទ្ធិមានចំណែកខ្លះជាកម្មសិទ្ធិផ្តាច់មុខរបស់កម្មសិទ្ធិករនីមួយៗហៅថា "ចំណែកឯកជន" និងមានចំណែកខ្លះជាលំហរួមសម្រាប់ការប្រើប្រាស់រួមរបស់សហកម្មសិទ្ធិករទាំងអស់ហៅថា "ចំណែករួម"។

ប្រភេទនៃអគារសហកម្មសិទ្ធិទាំងនោះមានជាអាទិ៍ភូមិគ្រឹះ ពាក់កណ្តាលភូមិគ្រឹះ ផ្ទះល្វែងដែលមានច្រើនល្វែង និងច្រើនជាន់ជាប់គ្នា ខុនដូ ប្រភេទផ្ទះផ្សេងទៀតដែលមានរចនាសម្ព័ន្ធជាប់គ្នា។

-<u>ចំណែកឯកជន</u> សំដៅដល់រាល់ចំណែកនៃអគារសហកម្មសិទ្ធិដែលឋិតក្រោមការកាន់កាប់ និងប្រើប្រាស់ជាឯកជនផ្តាច់មុខ។

-<u>ចំណែករួម</u> សំដៅដល់រាល់ចំណែកនៃអគារសហកម្មសិទ្ធិដែលត្រូវចាត់ជាកម្មវត្ថុសម្រាប់ការប្រើប្រាស់ ឬជាប្រយោជន៍នៃសហកម្មសិទ្ធិករទាំងអស់មានជាអាទិ៍ ដី ទីធ្លា ជណ្តើរ ឧទ្យាន និងសួនច្បារ ផ្លូវ ច្រកចេញ-ចូល ជញ្ជាំងអឡសិទ្ធិ ទីកន្លែងនៃសេវាកម្មរួម។

-<u>អ្នកអភិវឌ្ឍអចលនវត្ថុ</u> សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលដាក់ទុនវិនិយោគលើការសាងសង់ អគារសហកម្មសិទ្ធិក្នុងគោលបំណងសម្រាប់លក់ ឬជួល។

-<u>អ្នកអាណាព្យាបាល</u> សំដៅដល់បុគ្គលដែលមានភារកិច្ចតំណាងអនីតិជន ឬអសមត្ថជន។

-<u>ហិតូបត្ថម្ភកៈ</u> សំដៅដល់ជនដែលតុលាការចាត់តាំងឱ្យគ្រប់គ្រងលើជនដែលមានសមត្ថភាពតិចតួចពេក ក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយមានវិបត្តិផ្នែកបញ្ញាស្មារតី។

-<u>ក្បាលដីសហកម្មសិទ្ធិ</u> សំដៅដល់ចំណែកដីនៃអគារសហកម្មសិទ្ធិដែលមានទីតាំង និងទំហំជាក់លាក់សម្រាប់ការសាងសង់អគារសហកម្មសិទ្ធិ ឬដែលមានអគារសហកម្មសិទ្ធិតាំងនៅហើយឋិតនៅក្នុងគម្រោងប្លង់សាងសង់អគារសហកម្មសិទ្ធិ។ ក្បាលដី ឬចំណែកនៃអគារសហកម្មសិទ្ធិនេះ ត្រូវឋិតនៅក្រោមការគ្រប់គ្រង និងប្រើប្រាស់រួមរបស់សហកម្មសិទ្ធិករទាំងអស់។

-<u>ឡូតិ៍</u> សំដៅដល់ចំណែកឯកជនដែលភ្ជាប់ទៅនឹងចំណែករួមនៃអគារសហកម្មសិទ្ធិ។ ឡូតិ៍នីមួយៗមានតម្លៃខុសៗគ្នាទៅតាមទំហំនៃចំណែកឯកជនតូច ឬធំ ហើយការគណនាត្រូវគិតទៅតាមផ្ទៃក្រឡានៃចំណែកឯកជនរបស់សហកម្មសិទ្ធិករនីមួយៗ។

-<u>សិទ្ធិជួលអចិន្ត្រៃយ៍</u> សំដៅទៅលើសិទ្ធិជួលអចលនវត្ថុរយៈពេលវែងចាប់ពី១៥ (ដប់ប្រាំ) ឆ្នាំឡើងទៅ។

## ជំពូកទី២ ការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ

**មាត្រា៥**

រូបវន្តបុគ្គល ឬនីតិបុគ្គលមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិនៅព្រះរាជាណាចក្រកម្ពុជាដោយគោរពតាមល័ក្ខខ័ណ្ឌ និងបញ្ញត្តិទាំងឡាយនៃអនុក្រឹត្យនេះ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតជាធរមាន។

រូបវន្តបុគ្គលជានីតិជន និងមានសមត្ថភាពតាមផ្លូវច្បាប់ អាចជាកម្មសិទ្ធិករលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ។ ប៉ុន្តែករណីនេះត្រូវបានលើកលែងចំពោះការបន្តមតិករបស់ទាយាទដែលជាអនីតិជន ឬអសមត្ថជនដោយអនុញ្ញាតឱ្យមានសិទ្ធិកម្មសិទ្ធិបាន តែតម្រូវឱ្យមានអ្នកអាណាព្យាបាល ឬហិតូបត្ថម្ភកៈជាអ្នកកាន់កាប់ជំនួសរហូតដល់អនីតិជន ឬអសមត្ថជននោះមានសមត្ថភាពពេញលេញតាមផ្លូវច្បាប់។ ចំពោះករណីនេះ អ្នកអាណាព្យាបាល ឬហិតូបត្ថម្ភកៈគ្មានសិទ្ធិចាត់ចែងនូវចំណែកឯកជននោះបានឡើយ លើងលែងតែមានការអនុញ្ញាតពីតុលាការ។

**មាត្រា៦**

ការផ្តល់កម្មសិទ្ធិជូនសហកម្មសិទ្ធិករ គឺផ្តល់តែលើចំណែកឯកជននៃអគារសហកម្មសិទ្ធិប៉ុណ្ណោះ។ ចំពោះចំណែករួមត្រូវរក្សាទុកសម្រាប់សហកម្មសិទ្ធិករទាំងអស់នៃអគារសហកម្មសិទ្ធិប្រើប្រាស់ជារួម។

នីតិវិធីនៃការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិត្រូវមានលក្ខណៈងាយស្រួល សាមញ្ញ តម្លាភាព និងស្របតាមគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ និងអភិបាលកិច្ចល្អ។

**មាត្រា៧**

ក្បាលដីសម្រាប់សាងសង់អគារសហកម្មសិទ្ធិត្រូវតែជាក្បាលដីតែមួយដែលត្រូវបានចុះបញ្ជីរួចហើយ នៅក្នុងសៀវភៅគោលបញ្ជីដីធ្លី។

ក្នុងករណីដែលសំណង់អគារសហកម្មសិទ្ធិមានច្រើនប្រភេទឋិតនៅក្បាលដីតែមួយ អ្នកអភិវឌ្ឍអចលនវត្ថុត្រូវស្នើសុំបំបែកក្បាលដីនៅរដ្ឋបាលសុរិយោដី ទៅតាមប្រភេទ និងចំនួននៃអគារសហកម្មសិទ្ធិនីមួយៗ។ ការបំបែកក្បាលដីធ្វើឱ្យស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

អ្នកអភិវឌ្ឍអចលនវត្ថុ ឬបុគ្គលដែលបានកំពុងសាងសង់អគារសហកម្មសិទ្ធិត្រូវផ្លាស់ប្តូរប្រភេទក្បាលដីឱ្យទៅជាក្បាលដីសហកម្មសិទ្ធិនៅរដ្ឋបាលសុរិយោដី នៅពេលផ្ទេរលើកដំបូងនៃចំណែកឯកជនណាមួយ លើកលែងតែអគារសហកម្មសិទ្ធិដែលបានសង់នៅលើដីជួលអចិន្ត្រៃយ៍។

នៅពេលផ្លាស់ប្តូរប្រភេទក្បាលដីឱ្យទៅជាក្បាលដីសហកម្មសិទ្ធិ អ្នកអភិវឌ្ឍនអចលនវត្ថុ ឬបុគ្គលដែលបាន ឬកំពុងសាងសង់អគារសហកម្មសិទ្ធិលើក្បាលដីនោះត្រូវប្រគល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុនៃក្បាលដីឱ្យរដ្ឋបាលសុរិយោដីដើម្បីធ្វើលេខាចារឹក និងរក្សាទុក ហើយរដ្ឋបាលសុរិយោដីត្រូវចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជនជំនួសវិញ។

ការផ្លាស់ប្តូរប្រភេទក្បាលដីឱ្យទៅជាក្បាលដីសហកម្មសិទ្ធិ និងទម្រង់បែបបទផ្សេងទៀតអាចត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ក្បាលដីសហកម្មសិទ្ធិដែលអគារសហកម្មសិទ្ធិឋិតនៅ ជាទ្រព្យរួមរបស់សហកម្មសិទ្ធិករទាំងអស់។

**មាត្រា៨**

អ្នកអភិវឌ្ឍអចលនវត្ថុដែលសាងសង់អគារសហកម្មសិទ្ធិត្រូវរៀបចំបទបញ្ជាផ្ទៃក្នុង មុននឹងប្រកាសលក់ ឬជួលចំណែកឯកជននៃអគារសហកម្មសិទ្ធិ។

បទបញ្ជាផ្ទៃក្នុងខាងលើនេះដែលជាការព្រមព្រៀងរវាងសហកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិមិនត្រូវផ្ទុយពីសណ្តាប់ធ្នាប់សាធារណៈ និងច្បាប់ជាធរមាន។

ដើម្បីគ្រប់គ្រងអគារសហកម្មសិទ្ធិ សហកម្មសិទ្ធិករអាចបង្កើតក្រុមប្រឹក្សាភិបាល ឬគណៈកម្មការគ្រប់គ្រងអគារសហកម្មសិទ្ធិ តាមការព្រមព្រៀងរវាងសហកម្មសិទ្ធិករ ដូចមានចែងក្នុងបទបញ្ជាផ្ទៃក្នុង។

ការរៀបចំបទបញ្ជាផ្ទៃក្នុងត្រូវស្របតាមគោលការណ៍ និងល័ក្ខខ័ណ្ឌអប្បបរមានៃបទបញ្ជាផ្ទៃក្នុងគំរូ ដែលមានភ្ជាប់ជាឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ ហើយដែលត្រូវចែងជាអាទិ៍អំពី៖

-សិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់សហកម្មសិទ្ធិករលើចំណែកឯកជន និងលើចំណែករួមដោយមិនផ្ទុយពីគោលការណ៍កម្មសិទ្ធិ។

-ការកំណត់ពីសមាមាត្រនៃចំណាយរួមនានារបស់សហកម្មសិទ្ធិករ សម្រាប់ការថែទាំ ការជួសជុលចំណែករួម ការបង់ថ្លៃលើការប្រើប្រាស់សេវាសាធារណៈនានា . . .។ល។

-នីតិវិធីនៃការធ្វើសេចក្តីសម្រេចចិត្តក្នុងករណីដែលសហកម្មសិទ្ធិករបង្កើតអង្គការគ្រប់គ្រងអគារសហកម្មសិទ្ធិ៖

ក-តម្រូវឱ្យមានសំឡេងគាំទ្រភាគច្រើនដាច់ខាតនៃសហកម្មសិទ្ធិករទាំងអស់ សម្រាប់ការសម្រេចចិត្តពាក់ព័ន្ធនឹងការកែសម្រួលបទបញ្ជាផ្ទៃក្នុង ការជួសជុល ឬការថែទាំអគារសហកម្មសិទ្ធិ ឬការបង់ថ្លៃសេវាសាធារណៈនានា។

ខ-តម្រូវឱ្យមានសំឡេងគាំទ្រយ៉ាងតិច៧៥ (ចិតសិបប្រាំ) ភាគរយនៃសហកម្មសិទ្ធិករទាំងអស់ សម្រាប់សម្រេចចិត្តក្នុងករណីដែលអគារចាស់ទ្រុឌទ្រោម មិនអាចប្រើប្រាស់បាន ហើយតម្រូវឱ្យរុះរើអគារ ឬសាងសង់អគារជាថ្មី។ ក្នុងករណីមិនអាចរកការគាំទ្រយ៉ាងតិច៧៥ (ចិតសិបប្រាំ) ភាគរយបាននោះ ការវាយតម្លៃជាផ្លូវការដោយសមត្ថកិច្ចជំនាញ ត្រូវយកមូលដ្ឋានសម្រាប់ការសម្រេចរបស់តុលាការ។

**មាត្រា៩**

ការកំណត់ព្រំខណ្ឌនៃចំណែកឯកជនដែលមានជញ្ជាំងអឌ្ឍសិទ្ធិត្រូវកំណត់ត្រឹមពាក់កណ្តាលនៃកម្រាស់ជញ្ជាំងដែលខណ្ឌចំណែកឯកជននីមួយៗ។

យ៉ ឬរានហាលជាប់ជាមួយចំណែកឯកជន និងប្រើប្រាស់ជាឯកជន ហើយត្រូវមិនប៉ះពាល់ដល់ការប្រើប្រាស់ជារួមរបស់សហកម្មសិទ្ធិករផ្សេងទៀត ត្រូវចាត់ទុកជាផ្នែកនៃចំណែកឯកជន។

**ជំពូកទី៣ សិទ្ធិ និងកាតព្វកិច្ចរបស់សហកម្មសិទ្ធិករ**

**មាត្រា១០**

សហកម្មសិទ្ធិករនីមួយៗមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជនរបស់ខ្លួន លើកលែងតែមានការកម្រិតល័ក្ខខ័ណ្ឌដោយច្បាប់ ឬបញ្ញត្តិផ្សេងទៀត។

**មាត្រា១១**

សហកម្មសិទ្ធិករនៃចំណែកឯកជននៃអគារសហកម្មសិទ្ធិ មានសិទ្ធិចាត់ចែងលើចំណែកឯកជនរបស់ខ្លួនដោយមិនបំពានទៅលើចំណែករួម និងមិនរំខាន ឬរាំងស្ទះដល់ការប្រើប្រាស់ចំណែក

រួមដោយសហកម្មសិទ្ធិករដទៃទៀត និងមិនធ្វើឱ្យប៉ះពាល់ដល់ភាពរឹងមាំនៃសំណង់ និងសោភ័ណភាពនៃអគារ ។

សិទ្ធិចាត់ចែងចំណែកឯកជនរបស់សហកម្មសិទ្ធិករ ដូចជាការលក់ ការដូរ ការជួលប្រទានកម្ម ការបន្ថមតិក ការជួលអចិន្ត្រៃយ៍ ការបង្កើតផលុបភោគ ការប្រើប្រាស់និងអាស្រ័យនៅ ការដាក់ហ៊ីប៉ូតែក និងការដាក់បញ្ចាំត្រូវអនុវត្តតាមនីតិវិធីច្បាប់ជាធរមាន ។

សហកម្មសិទ្ធិករមិនអាចបង្កើតសេវភាពលើចំណែកឯកជនរបស់ខ្លួនបានទេ ។

**មាត្រា១២**

រាល់ចំណែកនៃអគារ ឬដីសម្រាប់ការប្រើប្រាស់រួម ឬសម្រាប់ជាប្រយោជន៍នៃសហកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិបង្កើតបានជាចំណែករួម ។ ចំណែករួមមានជាអាទិ៍៖

-ដី ទីធ្លា ឧទ្យាន និងសួនច្បារ ផ្លូវ ច្រកចេញចូល

-ជញ្ជាំង សសរទ្រទ្រង់សំខាន់ៗនៃអគារ ឧបករណ៍រួមរាប់បញ្ចូលចំណែកនៃបណ្តាញទឹកភ្លើង បណ្តាញឧស្ម័ន ប្រព័ន្ធលូទឹកស្អុយដែលអាចឆ្លងកាត់ចំណែកឯកជន

-ទូរួម បំពង់ និងក្បាលបំពង់ផ្សេង និងដំបូល

-ទីកន្លែងសេវារួមផ្សេងៗដែលបានកំណត់ដោយឡែក ឬមានចែងក្នុងបទបញ្ជាផ្ទៃក្នុង

-សិទ្ធិបន្ទាប់បន្សំទាំងឡាយ ដូចមានចែងក្នុងមាត្រា១៧៩ នៃច្បាប់ភូមិបាល ។

សហកម្មសិទ្ធិករនីមួយៗមានត្រឹមតែសិទ្ធិប្រើប្រាស់ប៉ុណ្ណោះលើចំណែករួម ។ គ្មានករណីណាមួយដែលកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិជាន់លើបំផុតអាចលើកបន្តសម្រាប់តែខ្លួនឯងផ្ទាល់ ឬលក់សិទ្ធិនៃការលើកបន្តនេះបានឡើយ ។

**មាត្រា១៣**

សហកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុង ដែលកំណត់របៀបគ្រប់គ្រង និងវិធាននៃការថែទាំ ព្រមទាំងការបំពេញកាតព្វកិច្ចផ្សេងៗទៀត ។

**មាត្រា១៤**

ចំណែករួមគឺជាកម្មសិទ្ធិអវិភាគរបស់សហកម្មសិទ្ធិករ ។ សហកម្មសិទ្ធិករទាំងអស់ត្រូវធានាការថែទាំចំណែករួម ។ បន្ទុកនៃការថែទាំនេះត្រូវចែកគ្នាទៅតាមសមាមាត្រទៅនឹងតម្លៃឡូតិ៍

នីមួយៗ លើកលែងតែមានការព្រមព្រៀងគ្នាផ្សេងពីនេះ ឬមានចែងដោយឡែកក្នុងបទបញ្ជាផ្ទៃក្នុង។

**មាត្រា១៥**

សិទ្ធិលើក្បាលដីដែលអាគាសហកម្មសិទ្ធិតាំងនៅជាសិទ្ធិដែលមិនត្រូវបានបាត់បង់ឡើយ ទោះបីអគារ ឬចំណែកឯកជននោះបានខូចខាតក៏ដោយ។

ក្នុងករណីដែលអគារសហកម្មសិទ្ធិចុះទ្រុឌទ្រោម មិនអាចស្នាក់នៅបាន ឬទទួលរងមហន្តរាយដោយប្រការណាមួយ សហកម្មសិទ្ធិករទាំងអស់អាចឯកភាពគ្នាជួសជុល ឬសាងសង់ឡើងវិញ ដោយទទួលបន្ទុកក្នុងការចំណាយតាមសមាមាត្រទៅនឹងតម្លៃនៃឡូត៍នីមួយៗ ឬតាមការព្រមព្រៀងគ្នាកន្លងមកដូចជា កិច្ចសន្យាដោយឡែក ឬបទបញ្ជាផ្ទៃក្នុងរបស់អគារសហកម្មសិទ្ធិ។ កិច្ចសន្យាដោយឡែកត្រូវស្របតាមស្មារតីនៃបទបញ្ជាផ្ទៃក្នុង។ ការជួសជុល ឬសាងសង់ឡើងវិញ ត្រូវអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ប្រសិនបើសហកម្មសិទ្ធិករឯកភាពគ្នាក្នុងការបែងចែកដី ឬលក់ដីដែលអគារសហកម្មសិទ្ធិនោះឋិតនៅ ការបែងចែកត្រូវអនុវត្តតាមគោលការណ៍សមាមាត្រទៅនឹងតម្លៃនៃឡូត៍នីមួយៗ ឬតាមការព្រមព្រៀងគ្នាពីមុនមក ប្រសិនបើមានចែងនៅក្នុងកិច្ចសន្យាដោយឡែក ឬបទបញ្ជាផ្ទៃក្នុងរបស់អគារសហកម្មសិទ្ធិ។

ប្រសិនបើអ្នកអភិវឌ្ឍអចលនវត្ថុបានសាងសង់អគារសហកម្មសិទ្ធិលើដីជួលពីបុគ្គលទីបី នោះអាជ្ញាយុកាលនៃសិទ្ធិជួលអចិន្ត្រៃយ៍លើចំណែកឯកជន និងសិទ្ធិប្រើប្រាស់លើចំណែករួមមានត្រឹមតែរយៈពេលដូចបានកំណត់ក្នុងកិច្ចសន្យាជួលដីអចិន្ត្រៃយ៍រវាងអ្នកអភិវឌ្ឍអចលនវត្ថុ និងម្ចាស់ដីប៉ុណ្ណោះ។ វិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍មានភ្ជាប់ជាឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យនេះ។

**ជំពូកទី៤ យន្តការ និងនីតិវិធីនៃការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ**

**មាត្រា១៦**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានសមត្ថកិច្ចធ្វើការចុះបញ្ជី និងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជននៃអគារសហកម្មសិទ្ធិ ជូនសហកម្មសិទ្ធិករទាំងអស់តាមនីតិវិធីដូចមានចែងក្នុងអនុក្រឹត្យនេះ។

មានតែអគារសហកម្មសិទ្ធិដែលបានសាងសង់រួចចប់សព្វគ្រប់តាមច្បាប់ និងបទប្បញ្ញត្តិជាធរមានប៉ុណ្ណោះ ទើបអាចជាកម្មវត្ថុនៃការចុះបញ្ជីចំណែកឯកជនបាន។

**មាត្រា១៧**

ការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិត្រូវដំណើរការដូចតទៅ៖

១-សហកម្មសិទ្ធិករចំណែកឯកជននៃអគារសហកម្មសិទ្ធិត្រូវស្នើសុំចុះបញ្ជីចំណែកឯកជនរបស់ខ្លួននៅរដ្ឋបាលសុរិយោដីថ្នាក់ក្រុង-ស្រុក-ខណ្ឌ។

សហកម្មសិទ្ធិករត្រូវបំពេញពាក្យស្នើសុំចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ដោយបញ្ជាក់ច្បាស់អំពីអត្តសញ្ញាណ និងព័ត៌មានទាំងឡាយនៃចំណែកឯកជនរបស់ខ្លួនឱ្យបានត្រឹមត្រូវ និងត្រូវភ្ជាប់មកជាមួយនូវ៖

-វិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវនៃសំណង់ ឬលិខិតបិទការដ្ឋានសំណង់

-ឯកសារប្លង់ស្ថាបត្យកម្មលំអិតនៃអគារសហកម្មសិទ្ធិ ដោយបញ្ជាក់ពីចំនួនជាន់ ចំនួនចំណែកឯកជន ដោយមានលេខយោង និងព័ត៌មានអំពីចំណែករួមនៃអគារ

-បទបញ្ជាផ្ទៃក្នុង

-ឯកសារបញ្ជាក់អត្តសញ្ញាសហកម្មសិទ្ធិករ

-ឯកសារពាក់ព័ន្ធផ្សេងទៀត ប្រសិនបើមាន។

២-ពាក្យស្នើសុំត្រូវយកទៅដាក់នៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក-ខណ្ឌ ដែលអគារសហកម្មសិទ្ធិនោះឋិតនៅ។ មន្ត្រីទទួលពាក្យត្រូវចេញបង្កាន់ដៃទទួលពាក្យជូនអ្នកស្នើសុំ។

៣-ក្រោយពេលទទួលពាក្យស្នើសុំចុះបញ្ជី ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក-ខណ្ឌត្រូវពិនិត្យទម្រង់ និងឯកសារភ្ជាប់ឱ្យបានត្រឹមត្រូវ ហើយបញ្ជូនពាក្យស្នើសុំចុះបញ្ជីនេះទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្ត ក្នុងរយៈពេល៣ (បី) ថ្ងៃនៃថ្ងៃធ្វើការយ៉ាងយូរ ដើម្បីពិនិត្យ និងសម្រេចឱ្យអនុវត្តដំណើរការចុះបញ្ជី។

៤-មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្តត្រូវពិនិត្យសម្រេចក្នុងរយៈពេល៣ (បី) ថ្ងៃនៃថ្ងៃធ្វើការ លើពាក្យស្នើសុំចុះបញ្ជីនេះ។

៥-ក្រោយពីមន្ទីរសម្រេចឱ្យអនុវត្តដំណើរការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក-ខណ្ឌ ត្រូវធ្វើការជូនដំណឹងរយៈពេល១ (មួយ) សប្តាហ៍ មុនកាលបរិច្ឆេទនៃការចុះប្រមូលទិន្នន័យ។

៦-មន្ត្រីជំនាញនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក-ខណ្ឌក្នុងរយៈពេល១ (មួយ) សប្តាហ៍យ៉ាងយូរ ត្រូវចុះសហការណ៍ជាមួយមន្ត្រីឃុំ-សង្កាត់ អ្នកអភិវឌ្ឍអចលនវត្ថុ ឬតំណាង និងសហកម្មសិទ្ធិករ ដើម្បីប្រមូល និងផ្ទៀងផ្ទាត់ទិន្នន័យនៅទីតាំងជាក់ស្តែង ដើម្បីបំពេញទម្រង់បែបបទប្រមូលទិន្នន័យ។

៧-ក្រោយប្រមូលទិន្នន័យជាក់ស្តែងអំពីចំណែកឯកជននៃអគារសហកម្មសិទ្ធិរួច មន្ត្រីជំនាញនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក-ខណ្ឌ ត្រូវបញ្ជូនសំណុំឯកសារទាំងអស់ និងលើកយោបល់ក្នុងរយៈពេល១ (មួយ) សប្តាហ៍ មកមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្ត ដើម្បីពិនិត្យ និងសម្រេចឱ្យបិទផ្សាយទិន្នន័យជាសាធារណៈ។

ប្រសិនបើមានភាពមិនច្បាស់លាស់ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្តអាចស្វែងរកព័ត៌មានបន្ថែម ឬចាត់តាំងមន្ត្រីជំនាញដើម្បីចុះស៊ើបអង្កេត ឬបញ្ជាក់បន្ថែមក្នុងរយៈពេល១ (មួយ) សប្តាហ៍យ៉ាងយូរ។

៨-ក្រោយពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្តបានសម្រេចបិទផ្សាយជាសាធារណៈនូវទិន្នន័យដែលប្រមូលបានរួចហើយ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក-ខណ្ឌត្រូវបិទផ្សាយជាសាធារណៈ នូវលទ្ធផលនៃការប្រមូលទិន្នន័យរយៈពេល១ (មួយ) សប្តាហ៍ ដើម្បីឱ្យសហកម្មសិទ្ធិករទាំងអស់ និងអ្នកមានប្រយោជន៍អាចតវ៉ា ឬស្នើធ្វើការកែតម្រូវ។ ការបិទផ្សាយជាសាធារណៈត្រូវអនុវត្តនៅទីតាំងអចលនវត្ថុផ្ទាល់ និងនៅសាលាឃុំ-សង្កាត់ដែលអចលនវត្ថុនោះតាំងនៅ។

ក្នុងករណីមានការតវ៉ា ឬវិវាទ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក-ខណ្ឌត្រូវព្យាយាមសម្រុះសម្រួលស្វែងរកការឯកភាពគ្នា។

ក្នុងករណីមិនអាចរកការស្រុះស្រួលគ្នាបាន ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក-ខណ្ឌត្រូវបញ្ជូនករណីវិវាទនេះទៅតុលាការ ដើម្បីដោះស្រាយតាមនីតិវិធីច្បាប់ជាធរមាន។

៩-ផុតរយៈពេលនៃការបិទផ្សាយ ប្រសិនបើគ្មានបណ្តឹងតវ៉ា ឬប្រសិនបើរាល់វិវាទត្រូវបានដោះស្រាយរួចរាល់ ហើយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្ត ត្រូវធ្វើការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ តាមការស្នើសុំរបស់សហកម្មសិទ្ធិករក្នុងរយៈពេល១ (មួយ) សប្តាហ៍យ៉ាងយូរ។

**មាត្រា១៨**

ចំណែកឯកជននីមួយៗត្រូវចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ។ ក្នុងសៀវភៅគោលបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិត្រូវកត់ត្រាទិន្នន័យលំអិតអំពីចំណែកឯកជន និងម្ចាស់កម្មសិទ្ធិនៃចំណែកឯកជន ដោយមានបញ្ជាក់ជាអាទិ៍ ឈ្មោះសហកម្មសិទ្ធិករ ទំហំ ទីតាំង ប្រភេទទ្រព្យនៃចំណែកឯកជន។

សៀវភៅគោលបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ និងទម្រង់បែបបទផ្សេងទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា១៩**

វិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជនដែលត្រូវបានចេញជូនសហកម្មសិទ្ធិករ តាមការស្នើសុំត្រូវកត់ត្រាទិន្នន័យដែលមានជាអាទិ៍លេខយោងសម្គាល់ចំណែកឯកជន ទំហំ ទីតាំង ប្រភេទទ្រព្យនៃចំណែកឯកជន។

គំរូវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជននៃអគារសហកម្មសិទ្ធិ មានភ្ជាប់ជាឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

រដ្ឋបាលសុរិយោដីត្រូវរៀបចំកម្មវិធីកុំព្យូទ័រសម្រាប់បញ្ចូលទិន្នន័យចំណែកឯកជននៃអគារសហកម្មសិទ្ធិ នៅក្នុងប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីរក្សាទុកជាឯកសារ។

**មាត្រា២០**

រាល់ការផ្ទេរសិទ្ធិតាមរយៈការលក់ ការដូរ ប្រទានកម្ម និងការបន្តមតិក សហកម្មសិទ្ធិករ ឬអ្នកទទួលសិទ្ធិត្រូវស្នើធ្វើចរន្តការនូវរាល់ការប្រែប្រួលនោះ នៅរដ្ឋបាលសុរិយោដី។ កិច្ចប្រតិបត្តិការក្នុងការផ្ទេរសិទ្ធិនេះ ត្រូវប្រើរយៈពេល២០ (ម្ភៃ) ថ្ងៃនៃថ្ងៃធ្វើការយ៉ាងយូរ។ អ្នកទទួលសិទ្ធិបន្តមានសិទ្ធិ និងកាតព្វកិច្ចដូចសហកម្មសិទ្ធិករមុនដែរ។

រាល់ការដាក់ហ៊ីប៉ូតែក ការដាក់បញ្ចាំ និងការជួលអចិន្ត្រៃយ៍នូវចំណែកឯកជនរបស់ខ្លួនសហកម្មសិទ្ធិករ និងអ្នកពាក់ព័ន្ធត្រូវទៅធ្វើលេខាចារឹកលើវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជននោះនៅរដ្ឋបាលសុរិយោដី។

**មាត្រា២១**

រាល់ការផ្លាស់ប្តូរប្រភេទក្បាលដីដើម មកជាក្បាលដីសហកម្មសិទ្ធិដូចមានចែងក្នុងមាត្រា៧ នៃអនុក្រឹត្យនេះត្រូវបង់ថ្លៃសេវាសុរិយោដី។

រាល់ការបំបែកក្បាលដីទៅតាមប្រភេទ និង/ឬចំនួនអគារសហកម្មសិទ្ធិដូចមានចែងក្នុងមាត្រា៧ នៃអនុក្រឹត្យនេះត្រូវបង់ថ្លៃសុរិយោដី។

រាល់ការផ្ទេរសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិត្រូវបង់ថ្លៃសេវាសុរិយោដី និងបង់ពន្ធប្រថាប់ត្រាជូនរដ្ឋតាមច្បាប់កំណត់។

## ជំពូកទី៥ អន្តរប្បញ្ញត្តិ

**មាត្រា២២**

ចំពោះប្រភេទអគារសហកម្មសិទ្ធិដែលបានសាងសង់មុនថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ហើយដែលមានសហកម្មសិទ្ធិករច្រើននាក់រស់នៅ ការស្នើសុំចុះបញ្ជីចំណែកឯកជនពុំតម្រូវឱ្យមានវិញ្ញាបនបត្របញ្ជាក់ពីភាពត្រឹមត្រូវនៃសំណង់ ឬលិខិតបិទការដ្ឋានសំណង់ និងឯកសារប្លង់ស្ថាបត្យកម្មលំអិតនៃអគារសហកម្មសិទ្ធិ ដូចមានចែងក្នុងមាត្រា១៧ ចំណុចទី១ឡើយ។

ចំពោះប្រភេទអគារសហកម្មសិទ្ធិដែលបានសាងសង់ក្រោយថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ រហូតដល់អនុក្រឹត្យនេះចូលជាធរមាន ហើយដែលអគារសហកម្មសិទ្ធិនោះពុំមានលិខិតអនុញ្ញាតសាងសង់ ការស្នើសុំបញ្ជីចំណែកឯកជនតម្រូវឱ្យធ្វើនិយតកម្មលើប្លង់ស្ថាបត្យកម្មនៃអគារសហកម្មសិទ្ធិជាមុនសិន។

*វាយឡើងវិញ*

មាត្រា២៣

ចំពោះប្រភេទអគារសហកម្មសិទ្ធិ ដែលបានសាងសង់មុនអនុក្រឹត្យនេះចូលជាធរមាន ការស្នើសុំចុះបញ្ជីចំណែកឯកជនតម្រូវឱ្យសហកម្មសិទ្ធិករទាំងអស់រៀបចំបទបញ្ជាផ្ទៃក្នុងជាមុនសិន ស្របតាមខ្លឹមសារអប្បបរមាដូចមានចែងក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។ ក្នុងករណីដែល សហកម្មសិទ្ធិករមិនអាចស្រុះស្រួលគ្នាក្នុងការរៀបចំបទបញ្ជាផ្ទៃក្នុងទេ ការស្នើសុំចុះបញ្ជីចំណែក ឯកជននឹងត្រូវកំណត់ដោយបទដ្ឋានដោយឡែក។

មាត្រា២៤

ចំពោះអគារជាភូមិគ្រឹះ ពាក់កណ្ដាលភូមិគ្រឹះ ឬជាផ្ទះល្វែងដែលមានច្រើនល្វែង និង ច្រើនជាន់ជាប់គ្នា ហើយមានម្ចាស់ជាកម្មសិទ្ធិករតែម្នាក់ ហើយដែលមានបំណងផ្ទេរចំណែកឯកជន ណាមួយនៃអគារទៅឱ្យបុគ្គលដទៃ ការចុះបញ្ជីចំណែកឯកជនត្រូវអនុលោមតាមស្មារតីនៃអនុក្រឹត្យ នេះ លើកលែងតែករណីដែលការផ្ទេរនេះអនុវត្តទៅលើផ្ទះល្វែងមួយជង់ពីលើដល់ក្រោមទៅឱ្យបុគ្គល តែមួយ។ ការផ្ទេរចុងក្រោយនេះត្រូវអនុវត្តតាមនីតិវិធីដែលមានកន្លងមក។

## ជំពូកទី៦ ទោសប្បញ្ញត្តិ

មាត្រា២៥

សហកម្មសិទ្ធិករដែលធ្វើឱ្យប៉ះពាល់ចំណែករួមនៃអគារ ឬដីដោយបានកែប្រែដើម្បីការ ប្រើប្រាស់ជាឯកជន ឬសម្រាប់លក់នឹងត្រូវបង្ខំឱ្យរៀបចំដូចសភាពដើមវិញ។ សហកម្មសិទ្ធិករនោះ នឹងត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងមាត្រា២៥៧នៃច្បាប់ភូមិបាល។

សហកម្មសិទ្ធិករដែលមិនព្រមទទួលបន្ទុកថែទាំចំណែករួម ឬមិនបានគោរពតាមល័ក្ខខ័ណ្ឌ នៃសណ្ដាប់ធ្នាប់សាធារណៈត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងមាត្រា២៥៨នៃច្បាប់ភូមិបាល។

## ជំពូកទី៧ អវសានប្បញ្ញត្តិ

មាត្រា២៦

បទប្បញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា២៧

*វាយឡើងវិញ*

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន អភិបាលរាជធានី គ្រប់អភិបាលខេត្តត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី

-ដូចមាត្រា២៧

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យលេខ១២៦អនក្រ/បក
ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គំរូបទបញ្ជាផ្ទៃក្នុង**

**សម្រាប់ការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ**

**នៃអគារសហកម្មសិទ្ធិឈ្មោះ...........................**

អាសយដ្ឋាន៖ ..........................................................................................
..........................................................................................

សង់លើក្បាលដីសហកម្មសិទ្ធិ

លេខយោង ..........................................................................................

អនុលោមតាមច្បាប់ភូមិបាលដែលចែងអំពីសហកម្មសិទ្ធិ សហកម្មសិទ្ធិករទាំងអស់បានព្រមព្រៀងគ្នាលើការគ្រប់គ្រង និងប្រើប្រាស់អគាសហកម្មសិទ្ធិ ឈ្មោះ....................................
តាមល័ក្ខខ័ណ្ឌទាំងឡាយដូចតទៅ៖

**ជំពូកទី១ គោលការណ៍ទូទៅ**

*ប្រការ១*

១.១-បទបញ្ជាផ្ទៃក្នុងសម្រាប់អគារសហកម្មសិទ្ធិឈ្មោះ.............................. មានគោលដៅកំណត់បន្ថែមអំពីសិទ្ធិ និងកាតព្វកិច្ចរបស់សហកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិដោយអនុលោមតាមសិទ្ធិ និងកាតព្វិច្ចដូចមានចែងក្នុងជំពូកទី១០នៃច្បាប់ភូមិបាល ។

១.២-បទបញ្ជាផ្ទៃក្នុងនេះអនុវត្តដូចគ្នាចំពោះសហកម្មសិទ្ធិករទាំងអស់ និងចំពោះអ្នកជួលចំណែកឯកជនផងដែរ ដោយគ្មានករណីលែកលែងឡើយ ។

១.៣-បទបញ្ជាផ្ទៃក្នុងនេះជាផ្នែកមួយនៃកិច្ចសន្យាផ្ទេររវាងសហកម្មសិទ្ធិករ ដែលតម្រូវឱ្យអ្នកទទួលបានសិទ្ធិជាសហកម្មសិទ្ធិករថ្មី ចុះហត្ថលេខា និងគោរពតាម ។

១.៤-អ្នកលក់ចំណែកឯកជនត្រូវបង្ហាញបទបញ្ជាផ្ទៃក្នុងនេះដល់អ្នកទិញ ដោយកំណត់បទបញ្ជាផ្ទៃក្នុងនេះជាល័ក្ខខ័ណ្ឌមួយនៃការលក់ មិនអាចតវ៉ាបាន។ អ្នកទិញត្រូវយល់ព្រម និងចុះហត្ថលេខាលើបទបញ្ជាផ្ទៃក្នុងនេះ ដែលជាផ្នែកមួយនៃកិច្ចសន្យាលក់។

១.៥-សហកម្មសិទ្ធិករ និងអ្នកដែលមានផលប្រយោជន៍លើអគារសហកម្មសិទ្ធិទាំងអស់ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងនេះ ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗជាធរមាន និងរក្សាសណ្តាប់ធ្នាប់សាធារណៈ សេចក្តីថ្លៃថ្នូរ ការគោរពសិទ្ធិអ្នកដទៃ និងការបំពេញកាតព្វកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ ដើម្បីធានាភាពសុខដុមរវាងសហកម្មសិទ្ធិករទាំងអស់។

## ជំពូកទី២ សិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់សហកម្មសិទ្ធិករ

### ប្រការ២ ចំណែកឯកជន

២.១-ចំណែកឯកជន សំដៅដល់ចំណែកនៃអគារសហកម្មសិទ្ធិដែលឋិតក្រោមការកាន់កាប់ និងប្រើប្រាស់ជាឯកជនផ្តាច់មុខ តាមគំនូសប្លង់ និងបញ្ជីសារពើភ័ណ្ឌដូចមានភ្ជាប់មកជាមួយបទ-បញ្ជាផ្ទៃក្នុងនេះ។

២.២-សហកម្មសិទ្ធិករនីមួយៗមានសិទ្ធិគ្រប់គ្រាន់ក្នុងការកាន់កាប់ និងប្រើប្រាស់ផ្តាច់មុខលើចំណែកឯកជនរបស់ខ្លួន រួមបញ្ចូលទាំងអចលនវត្ថុទាំងអស់ដែលមាននៅក្នុងចំណែកឯកជនដូចជាជញ្ជាំងខាងក្នុង ទ្វារទាំងអស់ រួមទាំងទ្វារចូលទៅក្នុងផ្ទះផង ផ្ទៃបង្អួចខាងក្នុង ផ្ទៃការ៉ូ ផ្ទៃជញ្ជាំង ពិដាន គ្រឿងបំពាក់បច្ចេកទេសទាំងអស់សម្រាប់ការប្រើប្រាស់ផ្តាច់មុខនៅក្នុងចំណែកឯកជន ផ្ទះបាយ និងទូខោអាវ។

២.៣-យ៉ដែលជាប់ជាមួយនឹងចំណែកឯកជននឹងបានប្រើប្រាស់ជាឯកជន ត្រូវគណនាបញ្ចូលជាចំណែកឯកជន ប្រសិនបើមិនប៉ះពាល់ដល់ការប្រើប្រាស់ចំណែកឯកជនរបស់សហកម្មសិទ្ធិករផ្សេងទៀត ឬចំណែករួម។

២.៤-សហកម្មសិទ្ធិករនៃចំណែកឯកជន មានសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ចំណែកឯកជនរបស់ខ្លួនតាមកម្រិតល័ក្ខខ័ណ្ឌដោយច្បាប់ បទប្បញ្ញត្តិ និងបទបញ្ជាផ្ទៃក្នុងនេះ។ ឧទាហរណ៍ កម្ម-សិទ្ធិករអាចលក់ ឬជួលចំណែកឯជនរបស់ខ្លួន ប្រើប្រាស់ជាប្រាតិភោគអចលនវត្ថុ ដាក់បញ្ចាំ ឬដាក់ហ៊ីប៉ូតែក ឬមានសិទ្ធិប្រើប្រាស់និងអាស្រ័យនៅ។

២.៥-សហកម្មសិទ្ធិករនីមួយៗ ត្រូវគោរពសិទ្ធិនៃកម្មសិទ្ធិករដទៃក្នុងការប្រើប្រាស់ចំណែកឯកជនរបស់ខ្លួន។ ការប្រើប្រាស់ចំណែកឯកជននេះ ត្រូវហាមឃាត់ប្រសិនបើការប្រើប្រាស់នោះបង្កការប៉ះពាល់ ឬខូចខាតដល់ចំណែករួម ឬចំណែកឯកជនផ្សេងទៀត។

២.៦-សហកម្មសិទ្ធិករត្រូវបង្កលក្ខណៈងាយស្រួលដល់បុគ្គលដែលត្រូវមកធ្វើការថែទាំ ជួសជុលផ្សេងៗ សហកម្មសិទ្ធិករមិនអាចទាមទារសំណង ឬតម្លៃតបស្នងណាមួយអំពីការបង្កលក្ខណៈងាយស្រួលក្នុងការជួសជុល ថែទាំនេះទេ។

**ប្រការ៣ ចំណែករួម**

៣.១-ចំណែកដែលនៅសល់ពីចំណែកឯកជន ត្រូវបានចាត់ទុកជាចំណែករួម។ ចំណែករួមសំដៅដល់ដី និងរាល់ចំណែកនៃអគារសហកម្មសិទ្ធិដែលជាកម្មវត្ថុសម្រាប់ការប្រើប្រាស់រួម ឬជាប្រយោជន៍នៃសហកម្មសិទ្ធិករទាំងអស់ មានជាអាទិ៍ ដី ទីធ្លា ជណ្តើរ ឧទ្យាន និងសួនច្បារ ផ្លូវ ច្រកចេញចូល ជញ្ជាំង ទីកន្លែងនៃសេវាកម្មរួម

៣.២-សហកម្មសិទ្ធិករទាំងអស់ គឺជាម្ចាស់នៃចំណែករួម។ ចំណែករួមនេះ មិនអាចយកមកប្រើប្រាស់ផ្តាច់មុខដោយបុគ្គលណាមួយឡើយ។ ចំណែករួមជាកម្មសិទ្ធិអវិភាគរបស់សហកម្មសិទ្ធិ-ករ។

៣.៣-ចំណែកទាំងឡាយដូចខាងក្រោមត្រូវបានចាត់ទុកជាចំណែករួម

ក-ដី ទីធ្លាក្នុងរបងសួនច្បារ ផ្លូវ ច្រកចេញចូល ចំណតរថយន្ត សួនច្បារ កន្លែងកីឡា

ខ-ជញ្ជាំង និងជញ្ជាំងទ្រទ្រង់អគារ ឧបករណ៍ប្រើប្រាស់រួមគ្នា ដូចជាបណ្តាញទឹក ភ្លើង បណ្តាញឧស្ម័ន ទោះបីជាបណ្តាញនោះរត់កាត់តាមចំណែកឯកជនក៏ដោយ

គ-ទូរួម បំពង់ និងក្បាលបំពង់ផ្សេង និងដំបូល

ឃ-ទីកន្លែងនៃសេវារួមផ្សេងទៀត

ង-សិទ្ធិបន្ទាប់បន្សំទាំងឡាយដូចមានចែងក្នុងមាត្រា១៧៩នៃច្បាប់ភូមិបាល។

៣.៤-សិទ្ធិលើក្បាលដីដែលអគារសហកម្មសិទ្ធិតាំងនេះ ជាសិទ្ធិដែលមិនបាត់បង់ឡើយ ទោះជាអគារសហកម្មសិទ្ធិនេះត្រូវខូចខាត ឬទទួលរងមហន្តរាយទាំងស្រុងក៏ដោយ។

**ប្រការ៤ ការចាត់ចែងចំណែកឯកជន**

៤.១-សិទ្ធិចាត់ចែងលើចំណែកឯកជនរបស់សហកម្មសិទ្ធិករត្រូវអនុវត្តតាមច្បាប់ និងបទ-ប្បញ្ញត្តិជាធរមាន។

៤.២-នៅពេលផ្ទេរសិទ្ធិលើចំណែកឯកជន តាមរយៈការលក់ ការដូរ ប្រទានកម្ម និងការបន្តមតិក សិទ្ធិចាត់ចែងលើចំណែកឯកជនរបស់សហកម្មសិទ្ធិករ រួមទាំងកាតព្វកិច្ចទាំងអស់ ត្រូវផ្ទេរទៅឱ្យអ្នកទទួលសិទ្ធិបន្ត ឬសហកម្មសិទ្ធិករថ្មី។

៤.៣-អ្នកផ្ទេរសិទ្ធិឬអ្នកលក់ និង/ឬអ្នកទទួលសិទ្ធិបន្ត ឬអ្នកទិញត្រូវសុំធ្វើចរន្តការនូវការផ្ទេរសិទ្ធិនេះ នៅរដ្ឋបាលសុរិយោដី។

៤.៤-អ្នកផ្ទេរសិទ្ធិឬអ្នកទិញ និង/ឬអ្នកទទួលសិទ្ធិបន្ត ឬអ្នកទិញត្រូវទទួលខុសត្រូវលើការចំណាយថ្លៃសេវា និងការបង់ពន្ធផ្សេងៗជូនរដ្ឋតាមច្បាប់កំណត់។

៤.៥-ផ្ទៃខាងក្នុងនៃចំណែកឯកជនដែលមើលពុំឃើញពីខាងក្រៅ សហកម្មសិទ្ធិករអាចរៀបចំ និងជួសជុលបាន តែមិនអាចប៉ះពាល់រចនាសម្ព័ន្ធដើម និងមិនអាចផ្ទុកទម្ងន់លើសពីការកំណត់ ឬធ្វើអ្វីបណ្ដាលឱ្យប៉ះពាល់ដល់អ្នកជិតខាង ឬដែលបង្កគ្រោះថ្នាក់ដល់ភាពរឹងមាំ និងសុវត្ថិ-ភាពនៃសំណង់ ឬធ្វើឱ្យខូចដល់សោភ័ណភាពនៃអគារសហកម្មសិទ្ធិទាំងមូលទេ។

៤.៦-សហកម្មសិទ្ធិករ ឬអ្នកជួលចំណែកឯកជនដែលបានលក់ ឬជួលបន្តចំណែកឯកជននៃអគាសហកម្មសិទ្ធិ មិនត្រូវដោះយកទៅជាមួយខ្លួននូវអចលនវត្ថុពីភ័ព្វវាសទាំងឡាយ ដែលនៅភ្ជាប់ជាមួយអគារសហកម្មសិទ្ធិនោះឡើយ។

## ជំពូកទី៣ ការគ្រប់គ្រងអគារសហកម្មសិទ្ធិ

### ប្រការ៥

៥.១-សហកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិដែលមានកម្មសិទ្ធិករចាប់ពី៥ឡើងទៅ ត្រូវរៀបចំអង្គការគ្រប់គ្រងអគារសហកម្មសិទ្ធិ ដោយការបង្កើតជាក្រុមប្រឹក្សាភិបាល ឬគណៈកម្មការគ្រប់គ្រង ដើម្បីទទួលបន្ទុកកិច្ចការសហកម្មសិទ្ធិ ដោយអនុលោមតាមមាត្រា១៧៤នៃច្បាប់ភូមិបាល។ ករណីមានការផ្ទេរកម្មសិទ្ធិលើចំណែកឯកជន អ្នកទទួលសិទ្ធិបន្ត ឬសហកម្មសិទ្ធិករថ្មីត្រូវក្លាយជាសមាជិកនៃអគារសហកម្មសិទ្ធិជាស្វ័យប្រវត្តិ។

៥.២-សហកម្មសិទ្ធិករទាំងអស់ ត្រូវរៀបចំមហាសន្និបាតដើម្បីតែងតាំងក្រុមប្រឹក្សាភិបាល ឬគណៈកម្មការគ្រប់គ្រងអគារសហកម្មសិទ្ធិ និងដើម្បីកំណត់ពីការផ្តល់សិទ្ធិសម្រេចចិត្ត ក្នុងករណីអវត្តមានសមាជិកខ្លះ។ ការសម្រេចចិត្តទាំងឡាយត្រូវផ្អែកលើភាគរយនៃសហកម្មសិទ្ធិករ។

៥.១[17] -នីតិវិធីនៃការធ្វើសេចក្តីសម្រេចចិត្តត្រូវអនុវត្តដូចតទៅៈ

ក-តម្រូវឱ្យមានសំឡេងគាំទ្រភាគច្រើនដាច់ខាតនៃសហកម្មសិទ្ធិករទាំងអស់ សម្រាប់ការសម្រេចចិត្តពាក់ព័ន្ធនឹងការកែសម្រួលបទបញ្ជាផ្ទៃក្នុង ការជួសជុល ឬការថែទាំអគារសហកម្មសិទ្ធិ ឬការបង់ថ្លៃសេវាសាធារណៈនានា។

ខ-តម្រូវឱ្យមានសំឡេងគាំទ្រយ៉ាងតិច៧៥ភាគរយនៃសហកម្មសិទ្ធិករទាំងអស់ សម្រាប់ការសម្រេចចិត្តក្នុងករណីដែលអគារទ្រុឌទ្រោមមិនអាចប្រើប្រាស់បាន ហើយតម្រូវឱ្យធ្វើការរុះរើអគារ ឬសាងសង់អគារជាថ្មី។ ក្នុងករណីមិនអាចរកការគាំទ្រ៧៥ភាគរយបាន នោះការវាយតម្លៃជាផ្លូវការលើស្ថានភាពអគាររបស់សមត្ថកិច្ចជំនាញ ត្រូវយកជាមូលដ្ឋានសម្រាប់ការសម្រេចរបស់តុលាការ។

## ជំពូកទី៤ សមាមាត្រនៃការចំណាយលើការជួសជុល ការថែទាំ និងការចំណាយផ្សេងៗ

### ប្រការ៦

៦.១-សហកម្មសិទ្ធិករនីមួយៗទទួលខុសត្រូវក្នុងការជួសជុល ថែទាំ និង/ឬបន្ទុកផ្សេងៗទៀតលើចំណែកឯកជនរបស់ខ្លួន។

៦.២-សហកម្មសិទ្ធិករទាំងអស់ត្រូវទទួលខុសត្រូវក្នុងការជួសជុល ថែទាំ និងបន្ទុកផ្សេងៗទៀតលើចំណែករួមឱ្យបានសមស្រប។ ការចំណាយទាក់ទងនឹងការប្រើប្រាស់ ការផ្លាស់ប្តូរ ការថែទាំ និង/ឬបន្ទុកផ្សេងៗទៀតលើចំណែករួម ត្រូវគិតជាភាគរយទៅតាមសមាមាត្រនៃទំហំផ្ទៃក្រឡានៃចំណែកឯកជនរបស់កម្មសិទ្ធិករនីមួយៗ។

៦.៣-ក្នុងករណីដែលអគារសហកម្មសិទ្ធិចុះទ្រុឌទ្រោម មិនអាចស្នាក់នៅបាន ឬទទួលរងមហន្តរាយ ដោយប្រការណាមួយ សហកម្មសិទ្ធិករទាំងអស់អាចឯកភាពគ្នាសាងសង់ឡើងវិញ

---

[17] គួរតែជាលេខរៀង "៥.៣"។

ដោយទទួលបន្ទុកក្នុងការចំណាយតាមសមាមាត្រនៃទំហំផ្ទៃក្រឡានៃចំណែកឯកជនរបស់សហកម្មសិទ្ធិករនីមួយៗ។ ការសាងសង់ឡើងវិញ ត្រូវអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន និងត្រូវធ្វើឡើងដោយយកតាមរចនាសម្ព័ន្ធដើម លើកលែងតែមានការព្រមព្រៀងគ្នាផ្សេងពីនេះ។ ក្នុងករណីដែលសហកម្មសិទ្ធិករឯកភាពគ្នាក្នុងការបែងចែកដី ឬលក់ដីដែលអគារសហកម្មសិទ្ធិនោះឋិតនៅ ការបែងចែកផលប្រយោជន៍ ត្រូវសមាមាត្រនឹងទំហំផ្ទៃក្រឡានៃចំណែកឯកជននីមួយៗ ឬតាមការព្រមព្រៀងគ្នាពីមុនមក ប្រសិនបើមានចែងនៅក្នុងកិច្ចសន្យាដោយឡែក។

## ជំពូកទី៥ អវសានប្បញ្ញត្តិ

### ប្រការ៧

វិវាទទាំងឡាយដែលកើតឡើងរវាងសហកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិ ត្រូវដោះស្រាយជាជំហានដំបូង ដោយការសម្រុះសម្រួលក្នុងក្របខ័ណ្ឌនៃក្រុមប្រឹក្សាភិបាល ឬគណៈកម្មាធិការគ្រប់គ្រងអគារសហកម្មសិទ្ធិ។ ក្នុងករណីដែលមិនអាចដោះស្រាយបាន វិវាទនេះនឹងត្រូវដោះស្រាយដោយតុលាការ។

### ប្រការ៨

បទបញ្ជាផ្ទៃក្នុងនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃដែលអ្នកទទួលសិទ្ធិក្លាយជាសហកម្មសិទ្ធិករពេញលក្ខណៈច្បាប់លើចំណែកឯកជននៃអគារសហកម្មសិទ្ធិ។

*ថ្ងៃទី................ខែ................ឆ្នាំ..................*

| | |
|---|---|
| អ្នកផ្ទេរសិទ្ធិ | អ្នកទទួលសិទ្ធិ |
| ឈ្មោះ......................... | ឈ្មោះ......................... |

*វាយឡើងវិញ*

*ឧបសម្ព័ន្ធទី២* នៃអនុក្រឹត្យលេខ១២៦ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# វិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជន

**លេខ.............................**

ក្បាលដីសហកម្មសិទ្ធិលេខ......................
រាជធានី/ខេត្ត....................................
ក្រុង/ស្រុក/ខណ្ឌ.................................
ឃុំ/សង្កាត់.......................................
ភូមិ.................................................
ផ្លូវ..................................................

អគារសហកម្មសិទ្ធិឈ្មោះ......................
ប្លង់ស្ថាបត្យកម្មនៃលិខិតអនុញ្ញាតសាងសង់ចុះថ្ងៃទី...ខែ....ឆ្នាំ...
ទំហំចំណែកឯកជនសរុប..................................ម២
ជាន់ទី...........................................................
ភាគរយនៃចំណែកឯកជនធៀបនឹងទំហំសរុបអគារសហកម្មសិទ្ធិ.....

យោង៖
-បទបញ្ជាផ្ទៃក្នុងលេខ....................
 ចុះថ្ងៃទី.......ខែ...........ឆ្នាំ............

ជើង
✧
*មាត្រដ្ឋាន.....................*

ធ្វើនៅ................ ថ្ងៃទី........ខែ..........ឆ្នាំ២០០៧

**តប.រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ប្រកាស៖** បើលោកអ្នកបានទទួលវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជននៃអគារសហកម្មសិទ្ធិនេះ ដោយបានចំណែកជាកេរ្តិ៍ក្តី ទទួលទិញ-ដូរក្តី ទទួលបញ្ចាំក្តី ឬហ៊ីប៉ូតែកក្តី ឬជួលរយៈពេលវែង ចូរលោកអ្នកកុំភ្លេចនាំម្ចាស់ចំណែកឯកជនទៅធ្វើលិខិតជាលាយលក្ខណ៍អក្សរនៅចំពោះមុខមន្ត្រីសុរិយោដី ដើម្បីផ្លាស់ឈ្មោះ ឬធ្វើលេខាចារឹកនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក-ខណ្ឌ ដែលអចលនវត្ថុនេះតាំងនៅ ព្រោះកាលបើមិនបានបំពេញកិច្ចទាំងនេះទេ អចលនវត្ថុនោះនឹងទុកជាការធានាប្រាក់របស់លោកក៏មិនកើត ឬក៏ទុកជាម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ក៏ពុំបាន។

ចុះបញ្ជីលេខ........................ អត្តសញ្ញាខ្លួន........................

ចំណែកឯកជនលេខ..................ជង់ (BLOCK) លេខ..................ជាន់ទី..........ប្លង់ស្ថាបត្យកម្មនៃលិខិតអនុញ្ញាតសាងសង់ចុះថ្ងៃទី........ខែ.......ឆ្នាំ..............

ប្រភេទសំណង់..................រូបភាពប្រើប្រាស់..................លក្ខណៈនៃការប្រើប្រាស់..................

## តារាងផ្លាស់ប្តូរ

| អត្រានុកូលដ្ឋានម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍នៃចំណែកឯកជន | | | | ការផ្លាស់ប្តូរ | | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|
| ទំហំនៃចំណែកឯកជន (ម²) | នាមត្រកូល នាមខ្លួន / ប្រភេទទ្រព្យ | ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត | សាវតារ | លេខាចារឹកដោយសង្ខេបនៃលិខិតសញ្ញា ឬសាលក្រមតុលាការ | បន្ទុកលើចំណែកឯកជន | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

*វាយឡើងវិញ*

*ឧបសម្ព័ន្ធទី៣* នៃអនុក្រឹត្យលេខ១២៦ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# វិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍នៃចំណែកឯកជន
**លេខ...........................**

| | |
|---|---|
| ក្បាលដីសហកម្មសិទ្ធិលេខ..................... | អគារសហកម្មសិទ្ធិឈ្មោះ..................... |
| រាជធានី/ខេត្ត.................................... | ប្លង់ស្ថាបត្យកម្មនៃលិខិតអនុញ្ញាតសាងសង់ចុះថ្ងៃទី...ខែ....ឆ្នាំ... |
| ស្រុក/ខណ្ឌ/ក្រុង................................ | ទំហំចំណែកឯកជនសរុប................................ម² |
| ឃុំ/សង្កាត់....................................... | ជាន់ទី.......................................................... |
| ភូមិ................................................ | ភាគរយនៃចំណែកឯកជនធៀបនឹងទំហំសរុបអគារសហកម្មសិទ្ធិ..... |
| ផ្លូវ................................................ | រយៈពេលជួលចំណែកឯកជន......ឆ្នាំ ចាប់ពី....ដល់.... |

យោង៖
-វិញ្ញាបនបត្រសម្គាល់សិទ្ធិជួលដីលេខ....
ចុះថ្ងៃទី........ខែ..........ឆ្នាំ..............
រយៈពេល......ឆ្នាំ ចាប់ពី.......ដល់......
-បទបញ្ជាផ្ទៃក្នុងលេខ......................
ចុះថ្ងៃទី.......ខែ............ឆ្នាំ............

ជើង
✧
*មាត្រដ្ឋាន..................*

ធ្វើនៅ............... ថ្ងៃទី........ខែ..........ឆ្នាំ២០០៧

**តប.រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

ប្រកាស៖ បើលោកអ្នកបានទទួលវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍នៃចំណែកឯកជននៃអគារសហកម្មសិទ្ធិនេះ ដោយបានចំណែកជាកេរ្តិ៍ក្តី ទទួលទិញ-ដូរក្តី ទទួលបញ្ចាំក្តី ឬហ៊ីប៉ូតែកក្តី ឬជួលរយៈពេលវែង ចូរលោកអ្នកកុំភ្លេចនាំម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍នៃចំណែកឯកជន ទៅធ្វើលិខិតជាលាយលក្ខណ៍អក្សរនៅចំពោះមុខមន្ត្រីសុរិយោដី ដើម្បីផ្លាស់ឈ្មោះ ឬធ្វើលេខាចារឹកនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក-ខណ្ឌ ដែលអចលនវត្ថុនេះតាំងនៅ ព្រោះកាលបើមិនបានបំពេញកិច្ចទាំងនេះទេ អចលនវត្ថុនោះនឹងទុកជាការធានាប្រាក់របស់លោកក៏មិនកើត ឬក៏ទុកជាម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ក៏ពុំបាន។

ចុះបញ្ជីលេខ................................................................ អត្តសញ្ញាខ្លួន................................................................

ចំណែកឯកជនលេខ..............................ដង់ (BLOCK) លេខ..................ជាន់ទី..........ប្លង់ស្ថាបត្យកម្មនៃលិខិតអនុញ្ញាតសាងសង់ចុះថ្ងៃទី........ខែ.......ឆ្នាំ...............

ប្រភេទសំណង់..................................រូបភាពប្រើប្រាស់......................លក្ខណៈនៃការប្រើប្រាស់..................................................

## តារាងផ្លាស់ប្តូរ

| អត្រានុកូលដ្ឋានម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍នៃចំណែកឯកជន | | | | ការផ្លាស់ប្តូរ | | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|
| ទំហំនៃចំណែកឯកជន (ម$^2$) | នាមត្រកូល នាមខ្លួន / ប្រភេទទ្រព្យ | ថ្ងៃ ខែ ឆ្នាំ និង ទីកន្លែងកំណើត | សាវតារ | លេខាចារីកដោយសង្ខេបនៃលិខិតសញ្ញា ឬសាលក្រមតុលាការ | បន្ទុកលើចំណែកឯកជន | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
លេខ១២ដនស/សជ ភ្នំពេញ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជម្រាបមក**

**លោកស្រី អស់លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់**
**និងសុរិយោដីរាជធានី-ខេត្ត**

**កម្មវត្ថុ៖** គោលការណ៍ណែនាំស្តីពីការចុះបញ្ជីដីដែលតុលាការបដិសេធវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ។

**យោង៖** លិខិតលេខ១៥៧ដនសស/សជ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកស្រី អស់លោកប្រធានមន្ទីរឱ្យបានជ្រាបថា នាពេលកន្លងមក ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានកត់សម្គាល់ឃើញថា មានក្បាលដីមួយចំនួនដែលរដ្ឋបាលសុរិយោដីបានចុះបញ្ជី និងចេញប័ណ្ណរួចហើយ ត្រូវបានតុលាការសម្រេចបដិសេធសិទ្ធិរបស់ម្ចាស់ដីដែលមានចារឹកក្នុងឯកសារសុរិយោដី តែអត្តសញ្ញាណក្បាលដីមិនផ្លាស់ប្តូរ និងមានករណីខ្លះទៀតត្រូវបានតុលាការសម្រេចបដិសេធសិទ្ធិ ដោយមូលហេតុការផ្តល់ប័ណ្ណខុសនីតិវិធី ឬកំណត់អត្តសញ្ញាណក្បាលដីមិនត្រឹមត្រូវ។ ប៉ុន្តែប័ណ្ណដីដើមទាំងនោះពុំត្រូវបានតុលាការធ្វើការដកហូតពីអ្នកចាញ់ក្តី ឬអ្នកដែលកំពុងកាន់កាប់ឡើយ។

ដូចនេះ ដើម្បីអនុវត្តសេចក្តីសម្រេចរបស់តុលាការឱ្យមានប្រសិទ្ធភាព ក្រសួងសូមធ្វើការណែនាំដូចខាងក្រោម៖

១-ករណីតុលាការសម្រេចបដិសេធសិទ្ធិរបស់បុគ្គលដែលចារឹកក្នុងឯកសារ តែអត្តសញ្ញាណក្បាលដីមិនផ្លាស់ប្តូរ៖

ករណីនេះកើតឡើងច្រើន ដោយអ្នកមានឈ្មោះក្នុងប័ណ្ណមិនព្រមប្រគល់ប័ណ្ណដីដើមឱ្យតុលាការ នៅពេលខ្លួនចាញ់ក្ដី ធ្វើឱ្យរដ្ឋបាលសុរិយោដីដែលមានសមត្ថកិច្ចផ្ទេរសិទ្ធិ/កាត់ឈ្មោះពីម្ចាស់ដើមទៅអ្នកឈ្នះក្ដីពុំអាចធ្វើបាន។ ដើម្បីដោះស្រាយករណីនេះ រដ្ឋបាលសុរិយោដីត្រូវអនុវត្តនីតិវិធីចេញប័ណ្ណទុតិយតា/តតិយតា រួចយកប័ណ្ណនេះមកធ្វើចរន្តការផ្ទេរសិទ្ធិ/កាត់ឈ្មោះ តាមអំណាចសាលក្រម/សាលដីការបស់តុលាការ ជូនអ្នកឈ្នះក្ដីតែម្ដង។

២-ករណីផ្ដល់ប័ណ្ណខុសនីតិវិធី ឬកំណត់អត្តសញ្ញាណក្បាលដីមិនបានត្រឹមត្រូវ៖

(១)-មន្ទីរត្រូវធ្វើសេចក្ដីជូនដំណឹងដល់សាធារណជនអំពីការបដិសេធប័ណ្ណដោយតុលាការ ដើម្បីឱ្យអ្នកកាន់កាប់ប័ណ្ណទាំងនោះបានជ្រាប និងប្រគល់ប័ណ្ណឱ្យរដ្ឋបាលសុរិយោដីយកមកបោះត្រារក្សាទុក (ដូចមានគំរូភ្ជាប់)។

(២)-នៅលើកំណត់ហេតុអង្កេតដី ឬទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី និងនៅត្រង់ខ្ទង់សេចក្ដីផ្សេងៗលើប័ណ្ណ និងលើសន្លឹកសៀវភៅគោលបញ្ជីដីធ្លី ឬខណ្ឌនៃសៀវភៅចុះបញ្ជីអចលនវត្ថុ ដែលត្រូវបានតុលាការបដិសេធចោល មន្ទីរត្រូវសរសេរបញ្ជាក់ថា "ត្រូវបានបដិសេធចោលតាមសាលក្រម/សាលដីកាលេខ......ចុះថ្ងៃ......របស់តុលាការ....." រួចត្រូវឆូតខ្វែងដោយទឹកក្រហមនៅលើសន្លឹកសៀវភៅគោលបញ្ជីដីធ្លី ឬខណ្ឌនៃសៀវភៅចុះបញ្ជីអចលនវត្ថុនោះ។

(៣)-មន្ទីរត្រូវកសាងឯកសារចេញប័ណ្ណថ្មីជូនអ្នកទទួលបានសិទ្ធិតាមការសម្រេចរបស់តុលាការ។

អាស្រ័យហេតុនេះ សូមលោកស្រី អស់លោកប្រធានមន្ទីរជ្រាប និងចាត់ចែងអនុវត្តតាមខ្លឹមសារណែនាំខាងលើឱ្យមានប្រសិទ្ធភាព។

សូមលោកស្រី អស់លោកប្រធានមន្ទីរទទួលនូវការរាប់អានអំពីខ្ញុំ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ហត្ថលេខា**

**[អ៊ឹម ឈុនលឹម]**

<u>ចម្លងជូន</u>

-អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ

-គ្រប់សាលារាជធានី-ខេត្ត

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ១៨ដនស/ណន

ភ្នំពេញ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៩

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជម្រាបមក**

**លោកស្រី អស់លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់**
**និងសុរិយោដីរាជធានី-ខេត្ត អនុវត្តគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី (LMAP)**

**កម្មវត្ថុ**៖ គោលការណ៍ណែនាំស្តីពីការចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ចំពោះក្បាលដីឋិតក្នុងតំបន់វិនិច្ឆ័យសម្រាប់ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ដែលម្ចាស់មិនបានផ្តល់ព័ត៌មានអំពីការផ្លាស់ប្តូរ មុនពេលបិទផ្សាយទិន្នន័យជាសាធារណៈ

**យោង**៖ លិខិតលេខ១៥៨ជនសស/សជ ចុះថ្ងៃទី៣0 ខែមីនា ឆ្នាំ២០០៩ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកស្រី អស់លោកប្រធានមន្ទីរឱ្យបានជ្រាបថា កន្លងមក ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានកត់សម្គាល់ឃើញថា មានតំបន់វិនិច្ឆ័យសម្រាប់ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធមួយចំនួនត្រូវបានបញ្ចប់ដំណើរការនីតិវិធីរួចរាល់ហើយ ប៉ុន្តែមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីមិនទាន់បានផ្តល់វិញ្ញា-បនបត្រសម្គាល់ម្ចាស់អចលនវត្ថុជូនម្ចាស់ក្បាលដីមួយចំនួន ដោយមូលហេតុ៖

ទី១-ទិន្នន័យនៅក្នុងកុំព្យូទ័រមានឈ្មោះម្ចាស់ដីដើម ក្រោយមកម្ចាស់ដើមនេះបានលក់ដីនោះឱ្យទៅអ្នកផ្សេង និងបានចុះបញ្ជីផ្ទេរសិទ្ធិ/កាត់ឈ្មោះ ក្នុងឯកសារតាមលក្ខណៈដាច់ដោយដុំរួចថែមទៀត ប៉ុន្តែនៅមុនពេលបិទផ្សាយទិន្នន័យជាសាធារណៈ អ្នកលក់ និងអ្នកទិញពុំបានយកឯកសារទាំងនេះមកបង្ហាញមន្ត្រីគ្រប់គ្រងតំបន់វិនិច្ឆ័យធ្វើការផ្លាស់ប្តូរ និងកែតម្រូវទិន្នន័យពីម្ចាស់ដើម មក

អ្នកទិញទេ។ ដូចនេះ នៅក្នុងឯកសារទិន្នន័យនៃការវិនិច្ឆ័យដែលមានទម្រង់បែបបទនៃការប្រមូលទិន្នន័យបញ្ជីឈ្មោះម្ចាស់ដី និងសៀវភៅគោលបញ្ជីដីធ្លី មានតែឈ្មោះម្ចាស់ដើម ឯអ្នកទទួលសិទ្ធិបន្ត (អ្នកទិញ) ដែលបានបង់ពន្ធប្រថាប់ត្រា និងទទួលបានប័ណ្ណផ្ទេរឈ្មោះតាមឯកសារមានលក្ខណៈដាច់ដោយដុំរួចហើយ ពុំមានឈ្មោះទេវិញ។

ទី២-នៅពេលប្រមូលទិន្នន័យ ម្ចាស់ដីបានផ្តល់ព័ត៌មានថាជាទ្រព្យរួមគ្នាប្តីប្រពន្ធ លុះដល់ពេលបិទផ្សាយទិន្នន័យជាសាធារណៈ ម្ចាស់ដីដដែលនេះបានដាក់ពាក្យស្នើសុំប្តូរមកជាប្រភេទទ្រព្យផ្ទាល់ខ្លួនខាងប្រពន្ធវិញ។ នៅក្នុង Form បានកែតម្រូវតាមបច្ចេកទេសរួចហើយ ប៉ុន្តែនៅក្នុងកុំព្យូទ័របញ្ជីឈ្មោះម្ចាស់ដី និងសៀវភៅគោលបញ្ជីដីធ្លីមិនទាន់បានកែតម្រូវ ពោលគឺនៅជាទ្រព្យរួមគ្នាប្តីប្រពន្ធដដែល។

ចំពោះករណីទាំងពីរខាងលើនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់សូមធ្វើការណែនាំដូចខាងក្រោម៖

**ករណីទី១**-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុមិនទាន់ចែក ដោយខុសឈ្មោះ ឬឈ្មោះដើមបានលក់បន្តតាមឯកសារ មន្ទីរត្រូវអនុវត្តដូចខាងក្រោម៖

១-មន្ទីរត្រូវប្រមូលឯកសារពាក់ព័ន្ធ រួមមានប័ណ្ណចាស់ លិខិតលក់ផ្តាច់ បង្កាន់ដៃពន្ធមករក្សាទុក

២-បោះពុម្ពវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុឈ្មោះម្ចាស់ដើម រួចធ្វើចរន្តការផ្ទេរ/កាត់ឈ្មោះឱ្យទៅអ្នកទិញ យោងសំបុត្រចុះថ្ងៃ...........ហើយសរសេរបញ្ជាក់នៅត្រង់ខ្ទង់សេចក្តីផ្សេងៗថា "យោងប័ណ្ណសម្គាល់សិទ្ធិលេខ......."។

៣-ក្រោយពីបំពេញកិច្ចការចប់សព្វគ្រប់ មន្ត្រីកាន់កាប់ឯកសារត្រូវប្រគល់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុឱ្យទៅអ្នកទិញ និងបោះត្រាមោឃភាពប័ណ្ណចាស់ រួចរក្សាទុក។

**ករណីទី២**-ពេលប្រមូលទិន្នន័យជាទ្រព្យរួមប្តីប្រពន្ធ (BC) ក្រោយមកសុំប្តូរមកជាទ្រព្យខាងប្រពន្ធ (PF) ហើយមន្ត្រីជំនាញបានកែលើ Form រួចហើយ តែមិនបានកែលើឯកសារផ្សេងទៀត។ នេះជាកំហុសរបស់មន្ត្រីជំនាញដែលបានកែតែ Form រួចមិនប្រាប់មន្ត្រី GIS ឱ្យកែទិន្នន័យក្នុង Computer ។

*វាយឡើងវិញ*

ករណីនេះ មន្ទីរត្រូវណែនាំបន្ថែមដល់មន្ត្រីក្រោមឱវាទ រាល់ការកែទិន្នន័យក្នុងឯកសារណាមួយ ឯកសារពាក់ព័ន្ធផ្សេងទៀតត្រូវតែបានកែតម្រូវឱ្យស្របគ្នាទាំងអស់ បើមិនដូច្នោះទេ ទិន្នន័យនេះនឹងបាត់បង់សុពលភាពផ្លូវច្បាប់។

ចំពោះវិធីកែតម្រូវ៖ មន្ទីរត្រូវអនុវត្តតាមខ្លឹមសារនៃលិខិតលេខ៥៨៨អ/សជភ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៨ របស់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ស្តីពីការកែតម្រូវឯកសារនៃការអនុវត្តនីតិវិធីចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ។

អាស្រ័យហេតុនេះ សូមលោកស្រី អស់លោកប្រធានមន្ទីរជ្រាប និងចាត់ចែងអនុវត្តតាមខ្លឹមសារណែនាំខាងលើឱ្យមានប្រសិទ្ធភាព។

សូមលោកស្រី អស់លោកប្រធានមន្ទីរទទួលនូវការរាប់អានអំពីខ្ញុំ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ហត្ថលេខា**

**[អ៊ឹម ឈុនលឹម]**

<u>ចម្លងជូន</u>

-អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ

-គ្រប់សាលារាជធានី-ខេត្តអនុវត្តគម្រោង LMAP

-ឯកសារ-កាលប្បវត្តិ

*វាយឡើងវិញ*

# ព្រះរាជក្រម

**នស/រកម/០២១០/០០៣**

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា**
**រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស**
**កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីអស្សាមិករណ៍ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៦ នីតិកាលទី២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាព

និងបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ១០៨/00១/២០១០/កបធ/ច ចុះថ្ងៃទី0៤ ខែកុម្ភៈ ឆ្នាំ២០១០ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ៖

# ច្បាប់
# ស្តីពីអស្សាមិករណ៍

## ជំពូកទី១ បទប្បញ្ញត្តិទូទៅ

**មាត្រា១**

ច្បាប់នេះមានគោលដៅកំណត់ពីអស្សាមិករណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយកំណត់ពីគោលការណ៍ យន្តការ នីតិវិធីនៃអស្សាមិករណ៍ និងសំណងឱ្យបានសមរម្យ និងយុត្តិធម៌ សម្រាប់គម្រោងស្ថាបនា ស្តារ និងគម្រោងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ បម្រើឱ្យផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ជាតិ និងការអភិវឌ្ឍរបស់ព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២**

ច្បាប់នេះមានគោលបំណងជាអាទិ៍៖

-ធានាការដកសិទ្ធិស្របច្បាប់លើកម្មសិទ្ធិឯកជនដោយសមរម្យ និងយុត្តិធម៌

-ធានាការទូទាត់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌

-បម្រើផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ

-ធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ។

**មាត្រា៣**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះការធ្វើអស្សាមិករណ៍ ដែលមានពាក់ព័ន្ធទៅនឹងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ច្បាប់នេះមិនគ្របដណ្តប់លើកិច្ចព្រមព្រៀង ឬអនុស្សារណៈស្តីពីការគាំពារវិនិយោគរវាងរដ្ឋាភិបាល និងប្រទេសជាដៃគូដែលមានចែងពីអស្សាមិករណ៍ទេ។ ក្នុងករណីដែលពុំមានកិច្ចព្រមព្រៀងនេះទេ ឬក្នុងករណីដែលកិច្ចព្រមព្រៀង ឬអនុស្សារណៈពុំមានចែងពីអស្សាមិករណ៍ គឺត្រូវឋិតនៅក្រោមអនុភាពនៃច្បាប់នេះ។

## មាត្រា៤

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះមានដូចតទៅ៖

អស្សាមិករណ៍ សំដៅដល់ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ ឬសិទ្ធិប្រត្យក្សលើអចលនវត្ថុរបស់រូបវន្តបុគ្គល នីតិបុគ្គលឯកជន និងនីតិបុគ្គលសាធារណៈ រួមមានដី សំណង់ និងដំណាំដាំដុះ សម្រាប់បម្រើការស្ថាបនា ស្តារ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈដែលបម្រើប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ ព្រមទាំងផ្តល់នូវសំណងជាមុនដោយសមរម្យ និងយុត្តិធម៌។

ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិ សំដៅដល់រូបវន្តបុគ្គល នីតិបុគ្គលឯកជន និងនីតិបុគ្គលសាធារណៈ រួមមានកម្មសិទ្ធិករ ភោគី និងអ្នកមានសិទ្ធិទាំងឡាយនៅលើទីតាំងដីដែលជាអ្នកទទួលរងនូវផលប៉ះពាល់ដោយសារគម្រោងអស្សាមិករណ៍។

ផលប្រយោជន៍សាធារណៈ ឬទូទៅ សំដៅដល់ការប្រើប្រាស់ដី ឬទ្រព្យសម្បត្តិដោយសាធារណជនទូទៅ ឬដោយទីភ្នាក់ងារ ឬស្ថាប័នរដ្ឋ ឬសាធារណៈ។

តម្រូវការនៃផលប្រយោជន៍ជាតិ សំដៅដល់សកម្មភាព ឬគម្រោងមានជាអាទិ៍៖

-ការសាងសង់ ស្តារ ថែទាំ ឬពង្រីកសំណង់ចាំបាច់ដល់កិច្ចការពារជាតិ ឬការងារសន្តិសុខ

-ការកាន់កាប់ដី ឬទ្រព្យសម្បត្តិដើម្បីអនុវត្តជាក់ស្តែងនយោបាយការពារបូរណភាពទឹកដី។

អ្នកអនុវត្តគម្រោង សំដៅដល់រដ្ឋ សហគ្រាស និងគ្រឹះស្ថានសាធារណៈ អ្នកម៉ៅការ ឬវិនិយោគិន។

ភតិក: សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលទទួលសិទ្ធិកាន់កាប់ និងប្រើប្រាស់លើអចលនវត្ថុពីម្ចាស់អចលនវត្ថុ។

បុគ្គលដែលធ្វើការរារាំង សំដៅដល់រូបវន្ត ឬនីតិបុគ្គលឯកជនទាំងឡាយណាដែលជាមេក្លោង អ្នកសមគំនិត អ្នកញុះញង់ ដែលធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោល ដោយគំនិតទុច្ចរិតក្នុងគោលដៅធ្វើឱ្យរាំងស្ទះដល់ដំណើរការនៃការអនុវត្តសេចក្តីសម្រេចអស្សាមិករណ៍។

## មាត្រា៥

គម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈមានជាអាទិ៍៖

ក-ការសាងសង់ ឬពង្រីកផ្លូវអាកាសយានដ្ឋាន ផ្លូវថ្នល់ ស្ពាន អាកាសយានដ្ឋាន កំពង់ផែ ដោយរួមទាំងរចនាសម្ព័ន្ធ និងឧបករណ៍។

ខ-ការសាងសង់ ឬពង្រីកស្ថានីយថាមពល រចនាសម្ព័ន្ធ ឧបករណ៍ និងខ្សែសម្រាប់ការបញ្ជូន និងចែកចាយថាមពលអគ្គិសនី។

គ-ការសាងសង់ ឬពង្រីកអគារ និងឧបករណ៍សម្រាប់ប្រៃសណីយ៍ និងទូរគមនាគមន៍ និង ប្រព័ន្ធព័ត៌មានវិទ្យា។

ឃ-ការសាងសង់ ឬពង្រីកផ្លូវ ផ្លាក្រុង ចំណតយានយន្ត ទីផ្សារ សួនច្បារ និងទីលានសាធារ-ណៈ។

ង-ការសាងសង់ ឬពង្រីកប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធលូទឹកកខ្វក់ និង កន្លែងបម្រើសេវាសាធារណៈផ្សេងទៀត។

ច-ការសាងសង់ ឬពង្រីកអគារ សម្រាប់អប់រំបណ្តុះបណ្តាលវិទ្យាសាស្ត្រ វប្បធម៌ ថែរក្សា សុខភាព សន្តិសុខសង្គម និងកីឡាដ្ឋានសម្រាប់សម្តែងជូនជាសាធារណៈ។

ឆ-ការសាងសង់ ឬពង្រីកកន្លែងចម្រាញ់ និងកន្លែងប្រព្រឹត្តកម្ម សំណល់ឧបករណ៍ សម្រាប់ ការការពារធម្មជាតិ និងបរិស្ថាន។

ជ-ការសាងសង់ ឬពង្រីកអគារ និងឧបករណ៍សម្រាប់ស្រាវជ្រាវ និងសម្រាប់ការធ្វើអាជីវ-កម្មរ៉ែ និងធនធានធម្មជាតិផ្សេងទៀត។

ឈ-ការសាងសង់ ឬពង្រីកបណ្តាញឧស្ម័ន បណ្តាញបំពង់ប្រេងឥន្ធនៈ រោងចក្រចម្រាញ់ ប្រេង រោងចក្របូមប្រេង និងបណ្តាញដទៃទៀត។

ញ-ការសាងសង់ ឬពង្រីកអគារតាំងទីលំនៅដែលបណ្តាលមកពីការបំផ្លាញយ៉ាងធ្ងន់ធ្ងរពី ធម្មជាតិ រញ្ជួយផែនដី ទឹកជំនន់ អគ្គីភ័យ និងគ្រោះបាក់ដីជាដើម និងការរៀបចំសម្រាប់ការតាំងទី លំនៅឡើងវិញ។

ដ-ការសាងសង់ ឬពង្រីកអគារសម្រាប់ការការពារ និងការគាំពារប្រជាជន។

ឋ-ការសាងសង់ ឬពង្រីកទីកន្លែងឆ្លងកាត់ព្រំដែន។

ឌ-ការកសាង ពង្រីក ឬការរៀបចំសំណង់ចាំបាច់ដល់កិច្ចការពារជាតិ ឬការពារសន្តិសុខ។

ឈ-ការបង្កើតឡើងថ្មីនូវតំបន់ការពារធនធានធម្មជាតិ ព្រៃឈើ បេតិកភណ្ឌ វប្បធម៌បុរាណវិទ្យា ឬការពារបរិស្ថាន។

ញ-ការអនុវត្តតាមតម្រូវការរបស់ជាតិ តាមការកំណត់របស់រាជរដ្ឋាភិបាល។

## ជំពូកទី២ គោលការណ៍ទូទៅ

**មាត្រា៦**

អស្សាមិករណ៍អាចធ្វើលើអចលនវត្ថុមួយផ្នែក ឬទាំងស្រុង ឬលើសិទ្ធិប្រត្យក្សនៃអចលនវត្ថុ។

**មាត្រា៧**

មានតែរដ្ឋទេដែលជាអ្នកធ្វើអស្សាមិករណ៍ ដើម្បីប្រើប្រាស់ក្នុងគោលដៅជាផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ។

អស្សាមិករណ៍អាចអនុវត្តទៅបាន លុះត្រាតែយកទៅអនុវត្តគម្រោង ដូចមានចែងក្នុងមាត្រា៥នៃច្បាប់នេះ។

**មាត្រា៨**

រដ្ឋត្រូវតែទទួលទិញយកនូវចំណែកនៃអចលនវត្ថុ ដែលនៅសេសសល់ពីអស្សាមិករណ៍ ដោយថ្លៃសមរម្យ និងយុត្តិធម៌តាមសំណើរបស់ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិដែលពុំអាចរស់នៅក្បែរគម្រោងបាន ឬពុំអាចសាងសង់លំនៅឋានបាន ឬពុំអាចប្រកបអាជីវកម្មផ្សេងទៀតបាន។

**មាត្រា៩**

អចលនវត្ថុដែលត្រូវបានដកហូតនេះ ត្រូវប្រើប្រាស់សម្រាប់តែក្នុងគោលដៅដែលបានគ្រោងទុកនៅក្នុងប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ដើម្បីប្រយោជន៍សាធារណៈ ឬតម្រូវការនៃផលប្រយោជន៍ជាតិប៉ុណ្ណោះ និងមិនអាចឱ្យទុកនៅចោលទំនេរ ដោយគ្មានហេតុផលសមស្រប ឬផ្ទេរឱ្យតតិយជនណាម្នាក់ក្នុងគោលដៅបម្រើផលប្រយោជន៍ឯកជនបានឡើយ។

អចលនវត្ថុដែលនៅសល់ពីតម្រូវការប្រើប្រាស់ ត្រូវផ្តល់អាទិភាពលក់ជូនម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិតាមអត្រាតម្លៃនៃការទូទាត់សំណង។ ក្នុងករណីដែលម្ចាស់អចលនវត្ថុ និង/ឬម្ចាស់

សិទ្ធិមិនព្រមទទួលយកអចលនវត្ថុដែលសល់ពីតម្រូវការប្រើប្រាស់វិញទេ ត្រូវរក្សាទុកអចលនវត្ថុនោះជាទ្រព្យសម្បត្តិរបស់រដ្ឋ។

**មាត្រា១០**

ក្នុងករណីពិសេស និងបន្ទាន់ដែលសុវត្ថិភាពសាធារណៈតម្រូវដូចជាប្រយុទ្ធប្រឆាំងគ្រោះអគ្គិភ័យ ទឹកជំនន់ ភ្លើងឆេះព្រៃ រញ្ជួយដី សង្គ្រាមដែលប្រុងនឹងកើតឡើង ឬការវាយប្រហារដោយភេរវកម្ម និងស្ថានភាពផ្សេងៗទៀតដែលកំណត់ដោយរាជរដ្ឋាភិបាល រាជរដ្ឋាភិបាលអាចធ្វើការដកហូតអចលនវត្ថុ ឬសិទ្ធិប្រត្យក្សលើអចលនវត្ថុជាបណ្តោះអាសន្ន ដោយមិនចាំបាច់ធ្វើការពិគ្រោះយោបល់ឡើយ ហើយត្រូវប្រគល់ជូនម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិវិញនៅពេលចប់ការដកហូតនេះ។

ក្នុងករណីបន្ទាន់ និងចាំបាច់ដែលផលប្រយោជន៍ជាតិតម្រូវ រាជរដ្ឋាភិបាលមានអំណាចឆន្ទានុសិទ្ធិក្នុងការធ្វើអស្សាមិករណ៍ ដោយមិនចាំបាច់រៀបចំធ្វើការពិគ្រោះយោបល់តាមនីតិវិធីដូចមានចែងក្នុងជំពូកទី៤នៃច្បាប់នេះទេ។

**មាត្រា១១**

មុននឹងដំណើរការការងារអស្សាមិករណ៍ រាជរដ្ឋាភិបាលត្រូវគ្រោងថវិកាប្រចាំឆ្នាំឱ្យបានគ្រប់គ្រាន់ ហើយត្រូវផ្តល់ឥណទានឱ្យគ្រប់ចំនួន និងទាន់ពេលវេលាជូនគណៈកម្មាធិការអស្សាមិករណ៍តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់យកទៅទូទាត់សំណងជូនម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិដែលរងនូវផលប៉ះពាល់ដោយសារអស្សាមិករណ៍។

## ជំពូកទី៣ យន្តការអស្សាមិករណ៍

**មាត្រា១២**

គណៈកម្មាធិការអស្សាមិករណ៍មួយត្រូវបានបង្កើតឡើង និងដឹកនាំដោយតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមានតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធចូលរួម។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការអស្សាមិករណ៍ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១៣**

អនុគណៈកម្មាធិការអស្សាមិករណ៍ជាសេនាធិការនៃគណៈកម្មាធិការអស្សាមិករណ៍ត្រូវបានបង្កើតឡើង និងដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត និងមានតំណាងមន្ទីរជំនាញអាជ្ញាធរពាក់ព័ន្ធចូលរួម ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អនុគណៈកម្មាធិការអស្សាមិករណ៍ត្រូវកំណត់ដោយអនុក្រឹត្យ ដូចមានចែងក្នុងមាត្រា១២នៃច្បាប់នេះ ។

**មាត្រា១៤**

គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ត្រូវបានបង្កើតឡើង និងដឹកនាំដោយតំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមានតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធចូលរួម ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក ។

## ជំពូកទី៤ នីតិវិធីនៃអស្សាមិករណ៍

## ផ្នែកទី១ នីតិវិធីមុនអស្សាមិករណ៍

**មាត្រា១៥**

អស្សាមិករណ៍ត្រូវធ្វើឡើងដោយផ្អែកលើគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ និងមានការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួង ស្ថាប័នសាមី ។

គណៈកម្មាធិការអស្សាមិករណ៍ ត្រូវរៀបចំសំណើស្តីពីគម្រោងអស្សាមិករណ៍ដាក់ជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យ និងសម្រេច ។

**មាត្រា១៦**

មុននឹងធ្វើសំណើស្តីពីគម្រោងអស្សាមិករណ៍ គណៈកម្មាធិការអស្សាមិករណ៍ត្រូវធ្វើការអង្កេតជាសាធារណៈ ដោយត្រូវកត់ត្រាភិនភាគឱ្យបានលំអិត ចំពោះរាល់សិទ្ធិរបស់ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិ លើអចលនវត្ថុ និងទ្រព្យសម្បត្តិផ្សេងៗទៀតដែលមានជាប់ពាក់ព័ន្ធនឹងការផ្តល់សំណង ព្រមទាំងត្រូវកត់ត្រានូវបញ្ហាពាក់ព័ន្ធ ។

ក្នុងការធ្វើការអង្កេតនេះ គណៈកម្មាធិការអស្សាមិករណ៍ត្រូវរៀបចំចាត់ចែងធ្វើការពិគ្រោះយោបល់ជាសាធារណៈ នៅក្នុងកម្រិតអាជ្ញាធររាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ ជាមួយក្រុម

ប្រឹក្សាឃុំ-សង្កាត់ និងតំណាងភូមិ ឬសហគមន៍ដែលរងនូវអស្សាមិករណ៍ ដើម្បីផ្តល់ព័ត៌មានជាក់លាក់ ច្បាស់លាស់ និងទទួលបាននូវមតិយោបល់ពីគ្រប់ភាគីពាក់ព័ន្ធអំពីសំណើនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ។

ដើម្បីកំណត់ពេលវេលាដកហូត ឬទីកន្លែងដែលផ្តល់ថ្មី ឬសំណង គណៈកម្មាធិការអស្សាមិករណ៍ត្រូវសាកសួរគ្រប់ភាគីពាក់ព័ន្ធទាំងអស់ឱ្យបានគ្រប់ជ្រុងជ្រោយ អំពីបញ្ហាអចលនវត្ថុ ដែលពាក់ព័ន្ធនឹងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ។

បន្ទាប់ពីបានធ្វើការអង្កេតចប់ជាស្ថាពរក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ គណៈកម្មាធិការអស្សាមិករណ៍ត្រូវធ្វើរបាយការណ៍ដែលក្នុងនេះត្រូវលើកឡើងនូវអនុសាសន៍នានាដាក់ជូន និងសុំការសម្រេចពីរាជរដ្ឋាភិបាល ។

**មាត្រា១៧**

ផ្អែកលើការសម្រេចរបស់រាជរដ្ឋាភិបាល គណៈកម្មាធិការអស្សាមិករណ៍ត្រូវចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ដែលក្នុងនោះត្រូវជម្រាបដល់ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិឱ្យបានដឹងអំពីអចលនវត្ថុនៃការដកនោះ និងត្រូវថែងអំពីគោលបំណងនៃការដកហូតកម្មសិទ្ធិ និង/ឬសិទ្ធិលើអចលនវត្ថុឱ្យបានច្បាស់លាស់ដោយអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

ក-កំណត់អំពីកម្មវត្ថុនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ទីតាំងគម្រោង និងរយៈពេលសម្រាប់អនុវត្តគម្រោង និងអាជ្ញាធរមានសមត្ថកិច្ច ដែលមានសិទ្ធិរៀបចំធ្វើការដកហូតកម្មសិទ្ធិ និង/ឬទ្រព្យសម្បត្តិឯកជន។

ខ-កំណត់អំពីសំណងសមរម្យ និងយុត្តិធម៌

គ-កំណត់រយៈពេលនៃបណ្តឹងតវ៉ា

ឃ-ធ្វើសេចក្តីប្រកាសទៅដល់គ្រប់ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិដោយភ្ជាប់នូវលិខិតថតចម្លងនៃច្បាប់នេះ

ង-ដាក់ស្លាកសម្គាល់ថា អចលនវត្ថុនេះជាកម្មវត្ថុដកហូតសម្រាប់បម្រើគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ។

ច-ផ្សព្វផ្សាយសេចក្តីប្រកាសតាមប្រព័ន្ធផ្សព្វផ្សាយ

ឆ-បិទផ្សាយសេចក្ដីប្រកាសនៅសាលាឃុំ-សង្កាត់ពាក់ព័ន្ធនឹងទីតាំងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ហើយសេចក្ដីប្រកាសនេះត្រូវផ្សព្វផ្សាយជូនដល់ប្រជាជនដែលមានអចលនវត្ថុពាក់ព័ន្ធដោយមេភូមិ។

**មាត្រា១៨**

បន្ទាប់ពីទទួលបាននូវសេចក្ដីប្រកាសស្ដីពីគម្រោងអស្សាមិករណ៍ ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិអាចធ្វើបណ្ដឹងសុំឱ្យមានការអង្កេត ដើម្បីឱ្យដឹងថាជាតម្រូវការមួយចាំបាច់ ដើម្បីបម្រើផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិពិតប្រាកដមែន ឬក៏អាចបង្វែរទីតាំងគម្រោងទៅកន្លែងណាផ្សេងវិញបាន។ បណ្ដឹងនេះអាចធ្វើឡើងតាមរយៈមេធាវី ឬតំណាងរបស់ខ្លួន។

បណ្ដឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការក្រោយពីបានទទួលសេចក្ដីប្រកាសស្ដីពីគម្រោងអស្សាមិករណ៍ ជូនចំពោះគណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ា ដូចមានចែងក្នុងមាត្រា១៤នៃច្បាប់នេះ។ ខ្លឹមសារសំខាន់ៗនៃបណ្ដឹងមានជាអាទិ៍៖

-ឈ្មោះម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិ អាសយដ្ឋាន និងលេខទូរស័ព្ទ

-មូលហេតុនៃការធ្វើបណ្ដឹង

-ការរៀបរាប់អំពីលក្ខណៈស្របច្បាប់នៃដីនោះ

-ផលប្រយោជន៍របស់ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិនៅលើដីដែលត្រូវដកហូតនោះ។

ប៉ុន្តែម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិមិនអាចធ្វើពាក្យបណ្ដឹងតវ៉ាសុំឱ្យមានធ្វើការអង្កេតបានទេ ចំពោះតម្រូវការសម្រាប់កិច្ចអភិវឌ្ឍផ្លូវជាតិធំៗ ស្ពាន ផ្លូវរទេះភ្លើង ការតភ្ជាប់ ការចែក-ចាយបណ្ដាញទឹក ភ្លើង បំពង់បង្ហូរប្រេងកាត បំពង់បង្ហូរទឹកកខ្វក់ ខ្សែបណ្ដាញ ឬលូមេបង្ហូរទឹកប្រព័ន្ធធារាសាស្ត្រ។

បន្ទាប់ពីបានធ្វើការអង្កេតចប់ជាស្ថាពរក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការគណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ាត្រូវធ្វើរបាយការណ៍ដែលក្នុងនោះ ត្រូវលើកឡើងនូវអនុ-សាសន៍នានា និងសុំការសម្រេចពីរាជរដ្ឋាភិបាល។

## ផ្នែកទី២ កិច្ចដំណើរការអស្សាមិករណ៍

វាយឡើងវិញ

មាត្រា១៩

ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ និងសិទ្ធិប្រត្យក្សលើអចលនវត្ថុ អាចធ្វើទៅបានលុះត្រាតែគណៈកម្មាធិការអស្សាមិករណ៍ បានផ្តល់សំណងឱ្យម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិជាមុនដោយសមរម្យ និងយុត្តិធម៌ តាមគោលការណ៍ និងនីតិវិធីនៃការទូទាត់សំណង ដូចមានចែងក្នុងផ្នែកទី៣ ជំពូកទី៤នៃច្បាប់នេះ។

ការដកហូតនៅតែអាចប្រព្រឹត្តទៅបាន ទោះបីទំនាស់នៅមិនទាន់បានដោះស្រាយរួចរាល់ហើយក្តី។ ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិដែលបានទទួលប្រាក់សំណងតាមការកំណត់របស់គណៈកម្មាធិការអស្សាមិករណ៍ នៅតែមានសិទ្ធិបន្តការប្តឹងរបស់ខ្លួនទៅតាមនីតិវិធីនៃការជំទាស់ និងការដោះស្រាយទំនាស់ដូចបានកំណត់ក្នុងមាត្រា៣៤ ជំពូកទី៦នៃច្បាប់នេះ។

មាត្រា២០

ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ និងសិទ្ធិប្រត្យក្សលើអចលនវត្ថុដទៃទៀត ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការអស្សាមិករណ៍។ សេចក្តីសម្រេចអស្សាមិករណ៍ត្រូវកំណត់ជាអាទិ៍៖

-កម្មសិទ្ធិលើអចលនវត្ថុ និងសិទ្ធិប្រត្យក្សលើអចលនវត្ថុដែលត្រូវដកហូត

-សំណងដែលត្រូវទូទាត់

-កាលបរិច្ឆេទដែលតម្រូវឱ្យម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិធ្វើការរើចាកចេញពីទីតាំង និងធ្វើការប្រគល់អចលនវត្ថុ ជូនគណៈកម្មាធិការអស្សាមិករណ៍។

មាត្រា២១

គណៈកម្មាធិការអស្សាមិករណ៍ ត្រូវជូនដំណឹងអំពីសេចក្តីសម្រេចអស្សាមិករណ៍ និងត្រូវផ្តល់សំណងគ្រប់ចំនួនដល់ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិ មុននឹងធ្វើអស្សាមិករណ៍។

## ផ្នែកទី៣ ការទូទាត់សំណងនៃអស្សាមិករណ៍

មាត្រា២២

ប្រាក់សំណងដែលត្រូវផ្តល់ឱ្យទៅម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិត្រូវគិតតាមថ្លៃទីផ្សារ ឬថ្លៃជំនួសនៅកាលបរិច្ឆេទនៃការចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍។

ថ្លៃទីផ្សារ ឬថ្លៃជំនួសត្រូវកំណត់ដោយគណៈកម្មការ ឬភ្នាក់ងារឯករាជ្យមួយ តាមការជ្រើសរើសរបស់គណៈកម្មាធិការអស្សាមិករណ៍។

**មាត្រា២៣**

ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិ មានសិទ្ធិទទួលបាននូវសំណងលើការខូចខាតអចលនវត្ថុជាក់ស្តែងដែលមានចាប់ពីថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ដែលជាកាលបរិច្ឆេទចុងក្រោយសម្រាប់មានសិទ្ធិទទួលបានសំណងសមរម្យ និងយុត្តិធម៌។

**មាត្រា២៤**

សំណងត្រូវទូទាត់ជាសាច់ប្រាក់ ជាទ្រព្យ ឬជាសិទ្ធិជំនួសទៅតាមភាពជាក់ស្តែងដោយមានការយល់ព្រមពីម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិ និងពីគណៈកម្មាធិការអស្សាមិករណ៍។

បែបបទ និងនីតិវិធីនៃការទូទាត់សំណង ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា២៥**

ប្រាក់សំណងត្រូវគិតតាមតម្លៃសំណងសរុប ដកចំនួនទឹកប្រាក់បន្ទុកពន្ធប្រថាប់ត្រា និង/ឬពន្ធលើដីមិនប្រើប្រាស់ដែលកន្លងមកមិនទាន់បានបង់ជូនរដ្ឋ ហើយគណៈកម្មាធិការអស្សាមិករណ៍ត្រូវបង់ប្រាក់ពន្ធកាត់ទុកទាំងនោះ ចូលថវិកាជាតិ តាមនីតិវិធីជាធរមាន។

**មាត្រា២៦**

ប្រាក់សំណងចំពោះកម្មសិទ្ធិលើអចលនវត្ថុ និងសិទ្ធិប្រត្យក្សលើអចលនវត្ថុ មិនត្រូវបានគិតដល់ការប្រែប្រួលនៃតម្លៃដែលកើតមានឡើង ចាប់ពីថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សា-មិករណ៍នោះឡើយ ដោយការប្រែប្រួលទាំងនោះ អាចពាក់ព័ន្ធដល់ការផ្លាស់ប្តូរវិធានការបម្រុងផ្ទៃដីទុកដែលមានក្នុងផែនការនគរូបនីយកម្ម ដែលកំណត់តំបន់ប្រើប្រាស់ដីធ្លី ឬផែនការប្រើប្រាស់ដីធ្លីដែលបានអនុម័តត្រឹមត្រូវ ឬដោយការប្រែប្រួលនោះ បណ្តាលមកពីសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍។

**មាត្រា២៧**

បន្ទាប់ពីទទួលបានប្រាក់សំណងគ្រប់ចំនួនរួចហើយ ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិត្រូវទទួលខុសត្រូវក្នុងការថែរក្សា ស្នាក់អាស្រ័យ កាន់កាប់ និងទទួលផលដដែលលើសិទ្ធិ និងអចលនវត្ថុរហូតដល់មានការទទួលយកអចលនវត្ថុទាំងនោះ ដោយគណៈកម្មាធិការអស្សាមិករណ៍។

**មាត្រា២៨**

គណៈកម្មាធិការអស្សាមិករណ៍អាចទទួលយកអចលនវត្ថុ ឬសិទ្ធិលើអចលនវត្ថុនោះក្រោយពី៖

-បានអនុវត្តតាមនីតិវិធី និងល័ក្ខខ័ណ្ឌដូចមានចែងក្នុងផ្នែកទី១ និងផ្នែកទី២ ជំពូកទី៤នៃច្បាប់នេះ។

-ការផ្តល់ប្រាក់សំណងត្រូវបានអនុវត្តតាមគោលការណ៍ និងនីតិវិធីដូចមានចែងក្នុងផ្នែកទី៣ ជំពូកទី៤នៃច្បាប់នេះ។

**មាត្រា២៩**

ភតិកៈអចលនវត្ថុដែលមានកិច្ចសន្យាត្រឹមត្រូវ ត្រូវទទួលបាននូវសំណងសម្រាប់ការរំខាននានាពាក់ព័ន្ធនឹងការដកហូតជាអាទិ៍ ការរុះរើសំណង់ សម្ភារៈ ការដឹកជញ្ជូនទៅកាន់ទីតាំងថ្មី។

ចំពោះភតិកៈអចលនវត្ថុដែលកំពុងប្រកបអាជីវកម្ម ត្រូវមានសិទ្ធិទទួលបាននូវសំណងលើផលប៉ះពាល់ដល់អាជីវកម្ម និងការឧបត្ថម្ភបន្ថែមដោយអត្រាសមរម្យ និងយុត្តិធម៌ លើតម្លៃដើមទុនដែលបានចំណាយជាក់ស្តែង សម្រាប់សកម្មភាពនៃការប្រកបរបរអាជីវកម្មនោះ ដោយគិតត្រឹមថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍។

ចំពោះការដកហូតយកទីតាំងដែលកំពុងមានសកម្មភាពអាជីវកម្ម ម្ចាស់អចលនវត្ថុ ត្រូវមានសិទ្ធិទទួលបានសំណងឧបត្ថម្ភបន្ថែមដោយអាត្រាសមរម្យ និងយុត្តិធម៌ លើតម្លៃនៃទ្រព្យសម្បត្តិដែលរងផលប៉ះពាល់ជាក់ស្តែង ដោយគិតត្រឹមថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សា-មិករណ៍។

## ជំពូកទី៥ អន្តរកាលនៃការកាន់កាប់ និងគ្រប់គ្រងអចលនវត្ថុ

**មាត្រា៣០**

ចាប់ពីថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិពុំអាចលក់ ឬផ្ទេរអចលនវត្ថុនោះឱ្យអ្នកដទៃបានឡើយ។ លិខិតឯកសារនានា និងនីតិវិធីទាំងអស់ដែលផ្ទុយនឹងបទប្បញ្ញត្តិនេះ ត្រូវចាត់ទុកជាមោឃៈ។

ចំពោះការប្រើប្រាស់ដី ឬអចលនវត្ថុពាក់ព័ន្ធត្រូវរក្សាលក្ខណៈ និងទំហំប្រើប្រាស់ដូចមាននៅពេលចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ហើយមិនត្រូវសាងសង់សំណង់នៅលើដីនោះថែមទៀតឡើយ។ សកម្មភាពណាដែលផ្ទុយនឹងបញ្ញត្តិខាងលើនេះ ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិ មិនត្រូវមានសិទ្ធិទទួលបានសំណងលើការសាងសង់ថ្មីបន្ថែមនោះឡើយ។

**មាត្រា៣១**

ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិអាចកាន់កាប់អចលនវត្ថុទាំងនោះបានត្រឹមរយៈពេល១ (មួយ) ខែ បន្ទាប់ពីគណៈកម្មាធិការអស្សាមិករណ៍បានទូទាត់សំណងគ្រប់ចំនួន ស្របតាមនីតិវិធីដូចមានចែងនៅក្នុងជំពូកទី៤នៃច្បាប់នេះ លើកលែងតែមានការព្រមព្រៀង ឬមានការអនុញ្ញាតផ្ទុយពីនេះ។

ក្នុងករណីម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិពុំព្រមចាកចេញពីទីកន្លែងនោះ គណៈកម្មាធិការអស្សាមិករណ៍អាចស្នើសុំទៅស្ថាប័នមានសមត្ថកិច្ច ឬអាជ្ញាធរសាធារណៈ ដើម្បីចាត់វិធានការតម្រូវឱ្យជននោះចាកចេញពីទីកន្លែងដែលបានធ្វើអស្សាមិករណ៍រួចហើយ។

## ជំពូកទី៦ ការដោះស្រាយទំនាស់

**មាត្រា៣២**

គណៈកម្មាធិការអស្សាមិករណ៍ និងគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាមានសមត្ថកិច្ចទទួលពិនិត្យ និងដោះស្រាយបណ្តឹងតវ៉ា។

**មាត្រា៣៣**

ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិដែលមិនយល់ស្របនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិ-ការអស្សាមិករណ៍ អាចប្តឹងទៅគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា។

**មាត្រា៣៤**

*វាយឡើងវិញ*

ក្នុងករណីដែលមិនមានការយល់ព្រមចំពោះសេចក្ដីសម្រេចរបស់គណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ា ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិអាចប្ដឹងទៅតុលាការមានសមត្ថកិច្ច ចំពោះនីតិវិធីអស្សាមិករណ៍ដែលធ្វើឡើងមិនបានត្រឹមត្រូវ ការដកហូតដែលមិនយកទៅបម្រើផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ជាតិ និងការទូទាត់សំណងដែលធ្វើឡើងមិនបានគ្រប់ចំនួនសមរម្យ និងយុត្តិធម៌។

បែបបទ និងនីតិវិធីប្ដឹងត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

## ជំពូកទី៧ ទោសប្បញ្ញត្តិ

**មាត្រា៣៥**

មន្ត្រីមានសមត្ថកិច្ចដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មខាងរដ្ឋបាល ដោយមិនទាន់គិតពីទណ្ឌកម្មផ្សេងទៀត ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា៣៦**

បុគ្គលណាដែលធ្វើការរារាំងដល់ការអនុវត្តសេចក្ដីសម្រេចអស្សាមិករណ៍ ដោយគំនិតទុច្ចរិតធ្វើឱ្យរាំងស្ទះដល់ដំណើរការនៃការអនុវត្តគម្រោងដែលបម្រើឱ្យផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១ (មួយ) ខែដល់១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី១០០.០០០ (មួយសែន) រៀល ដល់ពី២.០០០.០០០ (ពីរលាន) រៀល។

**មាត្រា៣៧**

បុគ្គលណាដែលបានកាន់កាប់ ប្រើប្រាស់ដោយរំលោភបំពានលើទីកន្លែងដែលបានធ្វើអស្សាមិករណ៍រួចហើយ ត្រូវផ្ដន្ទាទោសតាមបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន។

## ជំពូកទី៨ អវសានប្បញ្ញត្តិ

**មាត្រា៣៨**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងច្បាប់នេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៣៩**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់។

*វាយឡើងវិញ*

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

*ពរល.១០០២.១៨៩* **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ហត្ថលេខា**

**គាត ឈន់**

លេខ១៨៥ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១០

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រម

**នស/រកម/០៥១០/០០៦**

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ ដល់ជនបរទេសដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី៧ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

# ច្បាប់
# ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិ
# លើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស

## ជំពូកទី១ បទប្បញ្ញត្តិទូទៅ

**មាត្រា១**

ច្បាប់នេះមានគោលដៅផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ និងសិទ្ធិប្រើប្រាស់និងអាស្រ័យផល លើចំណែករួមនៃអគារសហកម្មសិទ្ធិដល់ជនបរទេស។

**មាត្រា២**

ច្បាប់នេះមានគោលបំណងដូចតទៅ៖

-កំណត់អំពីគោលការណ៍ទូទៅ សិទ្ធិ និងកាតព្វកិច្ចទាំងឡាយសម្រាប់ជនបរទេសដែលមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ និងសិទ្ធិផ្សេងទៀតដែលមានទំនាក់ទំនងនឹងចំណែករួម និងកំណត់អំពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិទាំងនោះ

-បង្កលក្ខណៈងាយស្រួលដល់ជនបរទេស ក្នុងការយកទុនមកវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ជួយសម្រួលដល់ធុរកិច្ចរបស់វិនិយោគិនលើវិស័យសំណង់ ព្រមទាំងឆ្លើយតបទៅនឹងការកើនឡើងនៃទីផ្សារអចលនវត្ថុនៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះជនបរទេស និងពលរដ្ឋខ្មែរដែលមានកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិនៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤**

វាក្យសព្ទដែលប្រើក្នុងច្បាប់នេះមានន័យដូចតទៅ៖

-ជនបរទេស សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលបរទេស ដែលមិនមានសញ្ជាតិខ្មែរ ទោះបីជាបុគ្គលនោះមានសញ្ជាតិ ជំនឿសាសនា ឬមានដើមកំណើតពូជសាសន៍ណាមួយក៏ដោយ ដោយគ្មានការរើសអើង។

-ជនបរទេសដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមផ្លូវច្បាប់ សំដៅដល់ជនបរទេសដែលមានសមត្ថភាពតាមផ្លូវច្បាប់ និងបានចូលមកព្រះរាជាណាចក្រកម្ពុជាដោយស្របច្បាប់។

-អគាសហកម្មសិទ្ធិ សំដៅដល់អគារ ឬសំណង់ដែលមានកម្មសិទ្ធិករច្រើននាក់រស់នៅ។ អគារសហកម្មសិទ្ធិមានចំណែកខ្លះជាកម្មសិទ្ធិផ្ដាច់មុខរបស់សហកម្មសិទ្ធិករនីមួយៗ ហៅថា "ចំណែកឯកជន" និងមានចំណែកខ្លះជាលំហរួមសម្រាប់ការប្រើប្រាស់រួមរបស់សហកម្មសិទ្ធិករទាំងអស់ ហៅថា "ចំណែករួម"។

-ចំណែកឯកជន សំដៅដល់ចំណែកនៃអគារសហកម្មសិទ្ធិដែលឋិតក្រោមការកាន់កាប់ និងប្រើប្រាស់ជាឯកជនផ្ដាច់មុខ។

-សហកម្មសិទ្ធិករលើចំណែកឯកជន សំដៅដល់បុគ្គលដែលមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជន។

-ចំណែករួម សំដៅដល់រាល់ចំណែកនៃអគារសហកម្មសិទ្ធិដែលត្រូវចាត់ជាកម្មវត្ថុសម្រាប់ការប្រើប្រាស់ ឬជាប្រយោជន៍នៃសហកម្មសិទ្ធិករទាំងអស់ មានជាអាទិ៍ ដី ទីធ្លា ជណ្ដើរ ដំបូល ឧទ្យាននិងសួន ច្បារ ផ្លូវ ច្រកចេញចូល ជញ្ជាំងអឡសិទ្ធិ ទីកន្លែងនៃសេវាកម្មរួម។

-សហកម្មសិទ្ធិពិសេស សំដៅដល់សិទ្ធិរបស់បុគ្គលច្រើនរូបជាជនបរទេស និងជាពលរដ្ឋខ្មែរលើអគារសហកម្មសិទ្ធិតែមួយ ដែលក្នុងនោះជនបរទេស និងពលរដ្ឋខ្មែរមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជន និងមានសិទ្ធិកម្មសិទ្ធិអវិភាគពិសេស លើចំណែករួមនៃអគារសហកម្មសិទ្ធិ។

-សហកម្មសិទ្ធិរួមពិសេស សំដៅដល់ជនបរទេសដែលមានសិទ្ធិសហកម្មសិទ្ធិពិសេស។

-កម្មសិទ្ធិអវិភាគពិសេស សំដៅដល់សិទ្ធិរបស់បុគ្គលច្រើនរូបលើចំណែករួមនៃអគាសហកម្មសិទ្ធិ ដែលក្នុងនោះជនបរទេសមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើចំណែករួម ហើយពលរដ្ឋខ្មែរមានសិទ្ធិកម្មសិទ្ធិអវិភាគលើចំណែករួមដោយសារមានកម្មសិទ្ធិលើចំណែកឯកជន។

-ឡូត៍ សំដៅដល់ចំណែកឯកជនដែលភ្ជាប់ទៅនឹងចំណែករួមនៃអគារសហកម្មសិទ្ធិ។ ឡូត៍នីមួយៗមានតម្លៃខុសៗគ្នាទៅតាមទំហំតូច ឬធំនៃចំណែកឯកជន ហើយការគណនាត្រូវកើតទៅតាមផ្ទៃក្រឡានៃចំណែកឯកជនរបស់សហកម្មសិទ្ធិករនីមួយៗ។

**ជំពូកទី២ គោលការណ៍ទូទៅ**

**មាត្រា៥**

ជនបរទេសដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមផ្លូវច្បាប់ មានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ និងសិទ្ធិប្រើប្រាស់និងអាស្រ័យផលលើចំណែករួម និងមានកាតព្វកិច្ចគោរពតាមបញ្ញត្តិទាំងឡាយនៃច្បាប់នេះ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតជាធរមាន ។

**មាត្រា៦**

ជនបរទេសមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិចាប់ពីជាន់ទី១ (មួយ) ឡើងទៅ។ ជាន់ផ្ទាល់ដី និងជាន់ក្រោមដីមិនត្រូវបានអនុញ្ញាតឱ្យជនបរទេសមានសិទ្ធិកម្មសិទ្ធិឡើយ ។

ចំពោះអគារសហកម្មសិទ្ធិមួយកន្លែង សមាមាត្រនឹងរបៀបគិតគូរនៃចំណែកឯកជនដែលអាចជាកម្មសិទ្ធិរបស់ជនបរទេសត្រូវកំណត់ដោយអនុក្រឹត្យ ។

ការផ្តល់កម្មសិទ្ធិនេះគឺផ្តល់តែលើចំណែកឯកជននៃអគារសហកម្មសិទ្ធិតែមួយប៉ុណ្ណោះ ។ ចំពោះចំណែករួមនៃអគារសហកម្មសិទ្ធិត្រូវរក្សាទុកសម្រាប់សហកម្មសិទ្ធិករទាំងអស់ នៅក្នុងអគារសហកម្មសិទ្ធិប្រើប្រាស់រួម ។

ក្នុងករណីណាក៏ដោយ ក៏ក្បាលដីដែលអគារសហកម្មសិទ្ធិតាំងនេះមិនអាចជាកម្មវត្ថុនៃកម្មសិទ្ធិរបស់សហកម្មសិទ្ធិករពិសេសបានឡើយ ។

ជនបរទេស និងត្រូវបានអនុញ្ញាតឱ្យមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលឋិតនៅក្នុងចម្ងាយ៣០ (សាមសិប) គីឡូម៉ែត្រពីព្រំដែនគោកឡើយ និងតំបន់មួយចំនួនទៀតដែលកំណត់ដោយរាជរដ្ឋាភិបាល លើកលែងតែអគាសហកម្មសិទ្ធិឋិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ទីប្រជុំជនសំខាន់ៗ និងតំបន់ផ្សេងទៀតដែលកំណត់ដោយរាជរដ្ឋាភិបាល ។

ក្នុងករណីដែលអគារសហកម្មសិទ្ធិសាងសង់នៅលើដីជួលពីបុគ្គលទី៣ ជនបរទេសអាចមានសិទ្ធិជួលអចិន្ត្រៃយ៍លើចំណែកឯកជនដូចពលរដ្ឋខ្មែរដែរ ។

**ជំពូកទី៣ លទ្ធកម្មនៃសហកម្មសិទ្ធិពិសេស**

**មាត្រា៧**

សហកម្មសិទ្ធិពិសេសត្រូវបានបង្កើត ផ្ទេរ កែប្រែដោយ៖

-ការព្រមព្រៀងរវាងភាគី ដោយអនុលោមតាមបទប្បញ្ញត្តិ ឬបទដ្ឋានគតិយុត្តផ្សេងទៀត ។

-សន្តតិកម្ម ។

**មាត្រា៨**

ការផ្ទេរសហកម្មសិទ្ធិពិសេសដោយការព្រមព្រៀងមិនមានអានុភាពទេ ប្រសិនបើមិនបានចុះបញ្ជីដោយយោងតាមបញ្ញត្តិនៃច្បាប់ ឬបទដ្ឋានគតិយុត្តផ្សេងទៀត ស្តីពីការចុះបញ្ជី ។

**មាត្រា៩**

នៅពេលដែលសហកម្មសិទ្ធិករលើចំណែកឯកជនដែលជាពលរដ្ឋខ្មែរបានផ្ទេរកម្មសិទ្ធិ លើចំណែកឯកជនរបស់ខ្លួនទៅជនបរទេស សហកម្មសិទ្ធិករពិសេសទទួលបានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជន និងទទួលបានត្រឹមតែសិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើចំណែករួមតែប៉ុណ្ណោះ។ ក្នុងករណីនេះ អតីតសហកម្មសិទ្ធិករលើចំណែកឯកជនជាពលរដ្ឋខ្មែរ ត្រូវបាត់បង់នូវកម្មសិទ្ធិអវិភាគរបស់ខ្លួនលើចំណែករួម ។

ក្នុងករណីដែលសហកម្មសិទ្ធិករលើចំណែកឯកជនជាជនបរទេស បានផ្ទេរចំណែកឯកជនរបស់ខ្លួនមកឱ្យពលរដ្ឋខ្មែរ សហកម្មសិទ្ធិករជាពលរដ្ឋខ្មែរត្រូវទទួលបាននូវសិទ្ធិកម្មសិទ្ធិលើចំណែកឯកជន និងកម្មសិទ្ធិអវិភាគលើចំណែករួម ។

**មាត្រា១០**

សន្តតិជននៃសហកម្មសិទ្ធិករពិសេសត្រូវទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជនដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

ក្នុងករណីដែលមតិកនៅទំនេរ ដោយគ្មានសន្តតិជនទទួលបន្ត ឬសន្តតិជនបោះបង់ចោល ឬមតិកមិនត្រូវបានចាត់ចែងឱ្យទៅជនណាមួយតាមបញ្ញត្តិច្បាប់មតិក នៅទំនេរនោះត្រូវធ្លាក់ទៅជាទ្រព្យសម្បត្តិរបស់រដ្ឋ ។

**មាត្រា១១**

ក្នុងករណីដែលជនបរទេសណាដែលបានទទួលការផ្ទេរ ឬទិញចំណែកឯកជននៃអាគារសហ-កម្មសិទ្ធិណាមួយដោយរំលោភបំពានលើមាត្រា៦នៃច្បាប់នេះ បន្ទាប់ពីច្បាប់នេះចូលជាធរមាន

ត្រូវទុកប្រតិបត្តិការនោះជាមោឃៈ ហើយភាគីដែលធ្វើប្រតិបត្តិការជាមួយគ្នាត្រូវធ្វើបដិទានត្រលប់វិញ។

## ជំពូកទី៤ សិទ្ធិ និងកាតព្វកិច្ចរបស់សហកម្មសិទ្ធិករពិសេស

### ផ្នែកទី១ សិទ្ធិ និងកាតព្វកិច្ចរបស់សហកម្មសិទ្ធិករពិសេសលើចំណែកឯកជន

**មាត្រា១២**

សហកម្មសិទ្ធិករពិសេសលើចំណែកឯកជនមានសិទ្ធិប្រើប្រាស់ អាស្រ័យផល និងចាត់ចែងលើចំណែកឯកជនដែលជាកម្មសិទ្ធិរបស់ខ្លួនបានដោយសេរីក្នុងទំហំដែលច្បាប់បានកម្រិត។

**មាត្រា១៣**

សហកម្មសិទ្ធិករពិសេសនៃចំណែកឯកជន មិនអាចប្រើប្រាស់ចំណែកឯកជនរបស់ខ្លួនក្នុងគោលបំណងព្យាបាទ បំពាន ឬរាំងស្ទះដល់ការប្រើប្រាស់ ឬរំខានដល់ជីវភាពរស់នៅរបស់សហកម្មសិទ្ធិករលើចំណែកឯកជនផ្សេងទៀតឡើយ។

សហកម្មសិទ្ធិករពិសេសនៃចំណែកឯកជន មិនត្រូវប្រព្រឹត្តអំពើណាដែលនាំឱ្យប៉ះពាល់ដល់ការថែរក្សាអគារសហកម្មសិទ្ធិ ឬអំពើផ្សេងទៀតដែលផ្ទុយនឹងប្រយោជន៍រួមរបស់សហកម្មសិទ្ធិករលើចំណែកឯកជនទាក់ទងនឹងការគ្រប់គ្រង ឬប្រើប្រាស់អគារសហកម្មសិទ្ធិឡើយ។

**មាត្រា១៤**

សហកម្មសិទ្ធិករពិសេសលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ មានកាតព្វកិច្ចនឹងបន្ទុកផ្សេងៗដូចសហកម្មសិទ្ធិករខ្មែរដែរ។ សហកម្មសិទ្ធិករពិសេសត្រូវគោរពរាល់កាតព្វកិច្ច និង/ឬបន្ទុកដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុងនៃអគារសហកម្មសិទ្ធិ និង/ឬច្បាប់ជាធរមាន។

### ផ្នែកទី២ សិទ្ធិ និងកាតព្វកិច្ចរបស់សហកម្មសិទ្ធិករពិសេសលើចំណែករួម

**មាត្រា១៥**

ចំណែករួមត្រូវឋិតនៅក្នុងរបបកម្មសិទ្ធិអវិភាគពិសេសរបស់សហកម្មសិទ្ធិករលើចំណែកឯកជនទាំងអស់។

សហកម្មសិទ្ធិករពិសេសមានត្រឹមសិទ្ធិប្រើប្រាស់និងអាស្រ័យផលប៉ុណ្ណោះ លើចំណែករួម។

**មាត្រា១៦**

កម្មសិទ្ធិអវិភាគពិសេស និងសិទ្ធិបន្ទាប់បន្សំផ្សេងទៀតដែលទទួលស្គាល់ដោយច្បាប់មិនអាចជាកម្មវត្ថុនៃការបែងចែក ចាត់ចែង និងបង្ខំឱ្យលក់ដាច់ដោយឡែកពីចំណែកឯកជនបានឡើយ ។

**មាត្រា១៧**

សហកម្មសិទ្ធិករពិសេសត្រូវចូលរួមការថែទាំចំណែករួម ។ បន្ទុកនៃការថែទាំនេះត្រូវចែកគ្នាទៅតាមសមាមាត្រទៅនឹងតម្លៃនៃឡូត៍នីមួយៗ លើកលែងតែមានការព្រមព្រៀងគ្នាផ្សេងពីនេះ ឬមានចែងដោយឡែកក្នុងបទបញ្ជាផ្ទៃក្នុង ។

**មាត្រា១៨**

សិទ្ធិប្រើប្រាស់និងអាស្រ័យផលលើចំណែករួម រាប់បញ្ចូលទាំងដីដែលអគារសហកម្មសិទ្ធិតាំងនៅ ឬដីដែលរៀបចំដើម្បីជាទីធ្លាអគារដែលត្រូវបានកំណត់ថាជាចំណែករួមគឺជាសិទ្ធិដែលមិនត្រូវបានបាត់បង់ឡើយ ទោះបីជាអគារ ឬចំណែកឯកជននោះត្រូវបានបាត់បង់ក៏ដោយ ។

ក្នុងករណីដែលអគារសហកម្មសិទ្ធិទ្រុឌទ្រោមមិនអាចស្នាក់នៅបាន ឬទទួលរងមហន្តរាយដោយប្រការណាមួយ ឬដោយវិធានការបង្ខំឱ្យរុះរើដោយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីសុវត្ថិភាពរបស់អ្នកស្នាក់នៅ សហកម្មសិទ្ធិករទាំងអស់អាចឯកភាពគ្នា ជួសជុល ឬសាងសង់ជាថ្មីឡើងវិញដោយទទួលបន្ទុកក្នុងការចំណាយតាមសមាមាត្រទៅនឹងតម្លៃនៃឡូត៍នីមួយៗ ឬតាមការព្រមព្រៀងគ្នាកន្លងមក ឬតាមបទបញ្ជាផ្ទៃក្នុង ។ ការជួសជុល ឬសាងសង់ឡើងវិញ ត្រូវអនុវត្តតាមនីតិវិធីច្បាប់ជាធរមាន ស្តីពីលិខិតអនុញ្ញាតសាងសង់ និងត្រូវរក្សារចនាសម្ព័ន្ធដើមនៃអគារដដែល លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ ឬមានចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់អគារសហកម្មសិទ្ធិ ។

ក្នុងករណីដែលអគារសហកម្មសិទ្ធិទទួលរងនូវមហន្តរាយទាំងស្រុង ដោយអំពើរបស់មនុស្ស ឬដោយប្រធានសក្តិ ហើយសហកម្មសិទ្ធិករសញ្ជាតិខ្មែរ ឯកភាពគ្នាលក់ដីដែលអគារសហកម្មសិទ្ធិតាំងនៅ សហកម្មសិទ្ធិករពិសេសមានសិទ្ធិទទួលបាននូវផលប្រយោជន៍ពីសិទ្ធិប្រើប្រាស់និងអាស្រ័យផលលើចំណែករួម ស្របតាមសមាមាត្រទៅនឹងផ្ទៃក្រឡានៃទំហំចំណែកឯកជនរបស់ខ្លួន ឬតាមការព្រមព្រៀងគ្នាពីមុនមក ឬបទបញ្ជាផ្ទៃក្នុង ។

**ជំពូកទី៥ នីតិវិធីនៃការចុះបញ្ជី និងការចេញវិញ្ញាបនបត្រ**

**មាត្រា១៩**

បទប្បញ្ញត្តិនៃច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀតដែលទាក់ទងនឹងយន្តការនីតិវិធីនៃការចុះបញ្ជី និងការចេញវិញ្ញាបនបត្រសម្រាប់សហកម្មសិទ្ធិពិសេសនៃអគារសហកម្មសិទ្ធិ។

គំរូវិញ្ញាបនបត្រសម្គាល់ចំណែកឯកជនជាសហកម្មសិទ្ធិករពិសេស និងកំណត់ត្រាបញ្ជាក់ផ្សេងៗអំពីសិទ្ធិត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី៦ ទោសប្បញ្ញត្តិ

**មាត្រា២០**

សហកម្មសិទ្ធិករពិសេសដែលធ្វើឱ្យប៉ះពាល់ចំណែករួមនៃអគារ ឬដីដោយបានកែប្រែដើម្បីការប្រើប្រាស់ជាឯកជន ឬសម្រាប់លក់នឹងត្រូវបង្ខំឱ្យរៀបចំដូចសភាពដើមវិញ។ សហកម្មសិទ្ធិករនោះត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងមាត្រា២៥៧នៃច្បាប់ភូមិបាល។

សហកម្មសិទ្ធិករពិសេសដែលមិនព្រមចូលរួមទទួលបន្ទុកថែទាំចំណែករួម ឬមិនបានគោរពតាមល័ក្ខខ័ណ្ឌនៃសណ្តាប់ធ្នាប់សាធារណៈ ត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងមាត្រា២៥៨នៃច្បាប់ភូមិបាល។

**មាត្រា២១**

ការរំលោភធ្វើឡើងដោយមន្ត្រីសុរិយោដីពាក់ព័ន្ធនឹងការចុះបញ្ជី ឬការចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់សហកម្មសិទ្ធិករពិសេស ដោយបំពានលើបញ្ញត្តិទាំងឡាយនៃច្បាប់នេះ ត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា២៦៤នៃច្បាប់ភូមិបាល។

## ជំពូកទី៧ អន្តរប្បញ្ញត្តិ

**មាត្រា២២**

ជនបរទេសណាដែលបានទទួលទិញ ឬទទួលការផ្ទេរចំណែកឯកជននៃអគារសហកម្មសិទ្ធិមុនច្បាប់នេះចូលជាធរមាន ហើយមិនស្របនឹងបញ្ញត្តិទាំងឡាយដូចមានចែងក្នុងមាត្រា៦នៃច្បាប់នេះ ត្រូវបានអនុញ្ញាតឱ្យធ្វើការដោះស្រាយដើម្បីឱ្យស្របតាមច្បាប់នេះឡើងវិញ ក្នុងរយៈពេល ០២ (ពីរ) ឆ្នាំ។

*វាយឡើងវិញ*

ក្នុងករណីដែលមិនគោរពតាមកថាខណ្ឌទី១នោះ អាជ្ញាធរមានសមត្ថកិច្ចត្រូវប្តឹងទៅតុលាការមានសមត្ថកិច្ចដើម្បីឱ្យលក់ចំណែកឯកជននៃអគារសហកម្មសិទ្ធិនោះដោយបង្ខំ ។

**ជំពូកទី៨ អវសានប្បញ្ញត្តិ**

**មាត្រា២៣**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា២៤**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១០

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

*ពរល.១០០៥.៤១៥* **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ហត្ថលេខា**

**អ៊ឹម ឈុនលឹម**

លេខ៣៧៧ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១០

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ០៣សរ

## សារាចរ

## ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ ដោយខុសច្បាប់តាមរាជធានី ទីក្រុង និងទីប្រជុំជន

សារាចរនេះមានគោលដៅដោះស្រាយចំពោះតែសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋ ដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់។

គោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងឯកសារបឋមស្តីពីក្របខ័ណ្ឌយុទ្ធសាស្ត្រគោលនយោបាយដីធ្លីនាខែកញ្ញា ឆ្នាំ២០០២ បានលើកឡើងអំពីសិទ្ធិកាន់កាប់ដីធ្លីបណ្តោះអាសន្ន និងមានរយៈពេលកំណត់ចំពោះអ្នកតាំងទីលំនៅខុសច្បាប់ និងសំណង់អានាធិបតេយ្យដែលបានកើតជាបន្តនៅរាជធានី ទីរួមខេត្ត និងទីប្រជុំជនមួយចំនួន។ តាមការសិក្សា សំណង់បណ្តោះអាសន្នដែលបានសាងសង់ដោយខុសច្បាប់នៅទីក្រុង ទីប្រជុំជន ដែលបានកើតមានកន្លងមក បណ្តាលមកពីកត្តាជាច្រើន មានជាអាទិ៍កំណើនប្រជាជន ការធ្វើមាតុភូមិនិវត្តន៍នៃគ្រួសារភៀសខ្លួន និងភៀសសឹកក្នុងដំណាក់កាលមុនឆ្នាំ១៩៩៨ នៅពេលដែលប្រទេសជាតិពុំទាន់មានសុខសន្តិភាពពេញលេញ ការបាត់បង់ដីធ្លីដោយគ្រោះធម្មជាតិ និងកត្តាផ្សេងៗទៀត ជាពិសេស កត្តាចំណាកស្រុកពីតំបន់ជនបទទៅតំបន់ទីក្រុងដើម្បីស្វែងរកការងារនៅតំបន់ថ្មី ដែលមានការរីកចម្រើនឆាប់រហ័សនៃវិស័យឧស្សាហកម្ម សេវាកម្ម និងនគរូបនីយកម្ម។

ជាបទពិសោធន៍មួយដ៏ល្អ ក្រោមការឧបត្ថម្ភគាំទ្រហិរញ្ញវត្ថុផ្ទាល់របស់រាជរដ្ឋាភិបាល អាជ្ញាធររាជធានីបានបំផុសដឹកនាំចលនាសហគមន៍អ្នកក្រីក្រ និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនកសាងបាននូវមូលនិធិមួយហៅថា "មូលនិធិអភិវឌ្ឍកាត់បន្ថយភាពក្រីក្រក្នុងទីក្រុង" ដែលមកដល់ខែឧសភា ឆ្នាំ២០១០ មានទឹកប្រាក់១.៣២០ (មួយពាន់បីរយម្ភៃ) លានរៀលសម្រាប់ផ្តល់ជាប្រាក់

កម្ចីមីក្រូហិរញ្ញវត្ថុដល់គ្រួសារក្រីក្រ យកទៅប្រើប្រាស់ដើម្បីស្តារ និងបង្កើនចំណូលគ្រួសារ និងកែលំអជីវភាព ។

ក្នុងគោលដៅដោះស្រាយបញ្ហាខាងលើ រាជរដ្ឋាភិបាលដាក់ចេញនូវសារាចរនេះដើម្បីណែនាំដល់អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងស្ថាប័នពាក់ព័ន្ធអំពីនីតិវិធីដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់ ដែលបានកើតនៅតាមទីក្រុង និងនៅតាមទីប្រជុំជនដោយត្រូវអនុវត្តវិធានការដូចខាងក្រោម៖

**១-ការស្រង់ទិន្នន័យជាក់លាក់អំពីចំនួនទីតាំងសំណង់បណ្តោះអាសន្ន**

ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្ត ត្រូវជំរុញឱ្យក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុក-ខណ្ឌឱ្យចាត់តាំងក្រុមការងារវាលតាមឃុំ-សង្កាត់ ដោយមានការចូលរួមជាសមាជិកចំពោះកិច្ច ពីតំណាងសហគមន៍ប្រជាជនក្នុងមូលដ្ឋាន និងសង្គមស៊ីវិល ដើម្បីធ្វើការស្រង់ទិន្នន័យចំនួនទីតាំងសំណង់បណ្តោះអាសន្នទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ទីតាំងនៃសំណង់បណ្តោះអាសន្ននីមួយៗ ត្រូវមានស្នាមមេដៃពីក្រុមសមាជិកនៃក្រុមការងារដែលបានចុះស្រង់ទិន្នន័យ ហើយចងក្រងស្ថិតិរួមមួយសម្រាប់ជាមូលដ្ឋានក្នុងការស្វែងរកដំណោះស្រាយទៅតាមករណី និងតាមដំណាក់កាល ។

**២-ការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ទីតាំងដីដែលសំណង់បណ្តោះអាសន្នតាំងនៅ**

ក្រោយពីការស្រង់ស្ថិតិគ្រប់ទីតាំងសំណង់បណ្តោះអាសន្ន ក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុក-ខណ្ឌ ដោយមានការចូលរួមជាសមាជិកចំពោះកិច្ច ពីតំណាងសហគមន៍ប្រជាជនក្នុងមូលដ្ឋាន និងសង្គមស៊ីវិល ត្រូវជួបប្រជុំពិនិត្យ និងពិភាក្សាលើភាពត្រឹមត្រូវនៃស្ថិតិទីតាំងនីមួយៗ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុក-ខណ្ឌ និងតំណាងសហគមន៍ប្រជាជនក្នុងមូលដ្ឋាន សង្គមស៊ីវិល ជាសមាជិកចំពោះកិច្ច ត្រូវធ្វើការកំណត់ទីតាំងនីមួយៗដោយផ្អែកលើលក្ខណៈរូបវន្តនៃដីជា៖

-ដីដែលបានប្រើជាសួនសាធារណៈ លំហសាធារណៈ ដីឯកជនរបស់រដ្ឋ ដីរបស់បុគ្គលឯកជន ឬរបស់ក្រុមហ៊ុន ដីវត្តអារាម ។ល ។

-ដីដែលមានផែនការប្រើប្រាស់រួចហើយសម្រាប់៖ ធ្វើសួនសាធារណៈ ធ្វើប្រព័ន្ធ ឬប្រឡាយបង្ហូរទឹក បណ្តាញផ្លូវថ្នល់ តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម តំបន់លំនៅឋាន តំបន់ទេសចរណ៍ ។ល។

-ទីតាំងដែលអាចបង្កគ្រោះថ្នាក់ដល់អ្នកស្នាក់នៅ៖ ជិតទីវាលចាក់សំរាម លើចិញ្ចើមផ្លូវ ជិតប្រឡាយបង្ហូរទឹក លើដីចំណីផ្លូវថ្នល់ ផ្លូវរថភ្លើង លើទំនប់ការពារទឹកជំនន់ ច្រាំងទន្លេ ស្ទឹង ព្រែក លើដីបូល ទៅរ៉ាស ។ល។

ចំពោះផែនទីនៃទីតាំងបណ្តោះអាសន្ន ត្រូវសម្គាល់ដោយប្រើពណ៌ផ្សេងៗ ឬប្រើនិមិត្តសញ្ញាបច្ចេកទេស ដើម្បីបញ្ជាក់លក្ខណៈរូបវន្តនៃដីតាមប្រភេទដែលសំណង់បណ្តោះអាសន្នតាំងនៅ ដូចបានរៀបរាប់ខាងលើ ហើយត្រូវមានស្នាមមេដៃទទួលស្គាល់ដោយក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុក-ខណ្ឌ តំណាងសហគមន៍ប្រជាជនក្នុងមូលដ្ឋាន សង្គមស៊ីវិលជាសមាជិកចំពោះកិច្ចសម្រាប់ប្រើប្រាស់ជាឧបករណ៍ក្នុងការពិភាក្សាស្វែងរកដំណោះស្រាយ និងត្រូវផ្សព្វផ្សាយជាសាធារណៈ ដើម្បីទប់ស្កាត់ការចូលទន្ទ្រានកាន់កាប់ដីរដ្ឋដោយខុសច្បាប់តទៅទៀត ។

បន្ទាប់មក ក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុក-ខណ្ឌត្រូវប្រជុំស្វែងរកការឯកភាពគ្នាលើការកាន់កាប់ និងលើចំណាត់ថ្នាក់ដីជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ ឬជាដីរបស់បុគ្គលឯកជន និងធ្វើរបាយការណ៍ដោយភ្ជាប់ផែនទី ឯកសារវណប មតិឯកភាពគ្នា ឬមិនឯកភាពគ្នា និងយោបល់របស់អង្គប្រជុំ ដើម្បីសុំការសម្រេចពីគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្ត ។ ចំពោះដីរដ្ឋដែលបានធ្វើអត្តសញ្ញាណកម្ម ធ្វើផែនទី និងធ្វើចំណាត់ថ្នាក់ដីដោយមានការឯកភាពគ្នា ឬមានការសម្រេចពីគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្ត រួចហើយអាជ្ញាធរត្រូវធ្វើការចុះបញ្ជីដីនោះក្នុងសៀវភៅគោលបញ្ជីដីធ្លី ។ ដូច្នេះ ទន្ទឹមនឹងការដោះស្រាយករណីជាក់ស្តែងនីមួយៗ អាជ្ញាធររាជធានី-ខេត្តត្រូវយកចិត្តទុកដាក់កសាងជាជំហានៗ នូវផែនទីដីរបស់រដ្ឋ ដោយធ្វើការចុះបញ្ជីដីរដ្ឋទុកជាឯកសារមូលដ្ឋានសម្រាប់ការអនុវត្តដំណោះស្រាយ និងធ្វើការផ្សាយជាសាធារណៈ ដើម្បីទប់ស្កាត់ការចូលទន្ទ្រានកាន់កាប់ដីរបស់រដ្ឋដោយខុសច្បាប់ទៅថ្ងៃមុខ ។

**៣-ការធ្វើជំរឿនចំនួនគ្រួសារ និងចំនួនប្រជាជនដែលរស់នៅទីតាំងសំណង់បណ្តោះអាសន្ន**

ផ្អែកលើផែនទីដែលមាននៅទីតាំងសំណង់បណ្តោះអាសន្ន ប្រធានក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុក-ខណ្ឌ ដោយមានតំណាងសហគមន៍ប្រជាជនក្នុងមូលដ្ឋាន និងសង្គមស៊ីវិលជាសមាជិកចំពោះ

កិច្ចចូលរួមផង ត្រូវចាត់តាំងឱ្យក្រុមការងារវាលតាមឃុំ-សង្កាត់គោលដៅ ស្រង់ស្ថិតិសមាជិកគ្រួសារទាំងអស់សម្រាប់ភ្ជាប់ជាមួយស្ថិតិគ្រួសារ។ ក្នុងស្ថិតិគ្រួសារនីមួយៗត្រូវមានបញ្ជាក់ថាជាម្ចាស់សំណង់បណ្ដោះអាសន្ន ឬជាអ្នកជួល និងមានស្នាមមេដៃពីគ្រប់សមាជិកក្រុមការងារដែលបានចុះផ្ទាល់ ព្រមទាំងមានស្នាមមេដៃ មេគ្រួសារ ឬតំណាងគ្រួសារនីមួយៗទុកជាភស្តុតាង។

តារាងស្ថិតិគ្រួសារដែលបានស្រង់រួច ត្រូវបិទផ្សាយជាសាធារណៈក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃ នៅក្នុងទីតាំងសំណង់បណ្ដោះអាសន្នសាមី និងនៅសាលាឃុំ-សង្កាត់ ដើម្បីទទួលយកសំណូមពរប្រជាពលរដ្ឋក្នុងមូលដ្ឋាន។

**៤-ការស្វែងរកដំណោះស្រាយ**

ផ្អែកលើមូលដ្ឋានព័ត៌មានដែលប្រមូលបានខាងលើ ក្រុមការងារជីវរដ្ឋថ្នាក់ក្រុង-ស្រុក-ខណ្ឌ តំណាងសហគមន៍ប្រជាជនក្នុងមូលដ្ឋាន សង្គមស៊ីវិលជាសមាជិកចំពោះកិច្ចចូលរួមផង ត្រូវប្រជុំពិនិត្យពិភាក្សាសម្រេចជ្រើសរើសដំណោះស្រាយ ចំពោះករណីជាក់ស្ដែងរបស់ទីតាំងសំណង់បណ្ដោះអាសន្ននីមួយៗ ដោយត្រូវចាត់ទុកជាអាទិភាពផលប្រយោជន៍សាធារណៈ និងដោយផ្អែកលើលក្ខណៈរូបវន្តនៃទីតាំង និងលើផលប្រយោជន៍របស់ប្រជាពលរដ្ឋភាគច្រើនក្នុងសហគមន៍ ព្រមទាំងភាពចាំបាច់នៃការអភិវឌ្ឍរបស់មូលដ្ឋាន។ ក្រោយការឯកភាពសម្រេចជ្រើសរើសយកដំណោះស្រាយណាមួយ ដូចជាការប្ដូរទៅកាន់ទីតាំងថ្មី ឬអភិវឌ្ឍនៅនឹងកន្លែង ជាគោលនយោបាយដទៃទៀត រួចហើយក្រុមការងារនេះ ត្រូវរៀបចំផែនការអនុវត្ត និងកំណត់ពេលវេលាសម្រាប់អនុវត្តជាក់ស្ដែង ហើយត្រូវស្នើសុំសេចក្ដីសម្រេចពីគណៈកម្មាធិការគ្រប់គ្រងជីវរដ្ឋថ្នាក់រាជធានី-ខេត្ត។

៤.១-ចំពោះអ្នកស្នាក់នៅជាម្ចាស់សំណង់បណ្ដោះអាសន្នលើដីរបស់រដ្ឋដែលទន្ទ្រានកាន់កាប់ដោយខុសច្បាប់ លទ្ធភាពដោះស្រាយមាន៖

-ការប្ដូរទៅទីតាំងថ្មី ក្នុងករណីដែលមិនអាចធ្វើការអភិវឌ្ឍនៅនឹងកន្លែងបាន ឬ

-ការអភិវឌ្ឍនៅនឹងកន្លែង ចំពោះទីតាំងសំណង់បណ្ដោះអាសន្នលើដីរបស់រដ្ឋដែលទន្ទ្រានកាន់កាប់ដោយខុសច្បាប់ដែលអាចមានលក្ខណៈសមស្របសម្រាប់ការអភិវឌ្ឍនេះ ឬ

-ការដោះស្រាយគោលនយោបាយដទៃទៀតតាមការជាក់ស្ដែង។

៤.២-ចំពោះអ្នកស្នាក់នៅដែលជាអ្នកជួលពីម្ចាស់សំណង់បណ្ដោះអាសន្នមិនស្របច្បាប់ អ្នកជួលត្រូវដោះស្រាយជាមួយម្ចាស់សំណង់ខុសច្បាប់ ហើយគ្មានសិទ្ធិទាមទារសំណងអ្វីមួយពីក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុក-ខណ្ឌ ឬពីគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្ត ឬពីអាជ្ញាធរដែនដីឡើយ។

ប្រសិនបើការពិភាក្សារិះរកដំណោះស្រាយពុំមានការឯកភាពគ្នា ក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុក-ខណ្ឌ និងតំណាងសហគមន៍ប្រជាជនក្នុងមូលដ្ឋាន សង្គមស៊ីវិលដែលជាសមាជិកចំពោះកិច្ចត្រូវរាយការណ៍ស្នើសុំយោបល់ពីគណៈអភិបាលរាជធានី-ខេត្ត ដោយភ្ជាប់នូវរបាយការណ៍បញ្ជាក់អំពីលទ្ធផលនៃការប្រជុំដោះស្រាយមានជាអាទិ៍ មតិភាគច្រើននៃអង្គប្រជុំ មតិរបស់សហគមន៍មូលដ្ឋានផ្ទាល់ សំណើផ្សេងៗរបស់សង្គមស៊ីវិល និងមតិសាធារណៈចំពោះសំណើដំណោះស្រាយណាមួយប្រសិនបើមាន។

ចំពោះដំណោះស្រាយណាមួយដែលទទួលបានការឯកភាពគ្នា ត្រូវបិទផ្សាយជាសាធារណៈក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃ នៅក្នុងទីតាំងសំណង់បណ្ដោះអាសន្នសាមី និងនៅសាលាឃុំសង្កាត់ ដើម្បីជាព័ត៌មានជូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន។

**៥_ការពិភាក្សាសម្របសម្រួលដើម្បីកំណត់គោលនយោបាយ**

ចំពោះទីតាំងដែលអភិវឌ្ឍនៅនឹងកន្លែង អភិបាលរាជធានី ខេត្ត ក្រុងត្រូវពិភាក្សាជាមួយភាគីពាក់ព័ន្ធដើម្បីរៀបចំផែនការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ កំណត់វិធីដែលត្រូវរៀបចំទីតាំងជាដីឡូតិ៍ ឬជាផ្ទះ និង/ឬគោលនយោបាយផ្សេងៗដែលជួយសម្រួលដល់ការអភិវឌ្ឍជីវភាពរស់នៅ។

ចំពោះទីតាំងដែលមិនអាចអភិវឌ្ឍនៅនឹងកន្លែងបាន ហើយត្រូវរុះរើទីតាំងថ្មីត្រូវរៀបចំផែនការច្បាស់លាស់ មុននឹងអនុវត្តដំណោះស្រាយ និង/ឬជួយជាគោលនយោបាយ ដើម្បីសម្រួលដល់ការតាំងទីលំនៅថ្មីរបស់ប្រជាពលរដ្ឋ។

ក្នុងដំណោះស្រាយអភិវឌ្ឍនៅនឹងកន្លែង ឬការប្ដូរទៅទីតាំងថ្មី អ្នកដែលទទួលផលពីដំណោះស្រាយអាចទទួលបាន៖

១-សិទ្ធិផលុបភោគតាមការព្រមព្រៀង ឬ

២-សិទ្ធិកម្មសិទ្ធិបន្ទាប់ពីបានកាន់កាប់ផ្ទាល់ និងរស់នៅលើទីតាំងនោះមានរយៈពេលយ៉ាងតិច១០ (ដប់) ឆ្នាំជាប់គ្នា គិតពីថ្ងៃទទួលយកដំណោះស្រាយ ឬ

៣-សិទ្ធិជួលមានរយៈពេលកំណត់ និងមានប្រាក់ឈ្នួលអនុគ្រោះ ។

**៦_ហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈមូលដ្ឋានចាំបាច់សម្រាប់គាំទ្រដល់ការរស់នៅ**

ក-រាល់ដំណោះស្រាយត្រូវគិតគូរដល់ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈចាំបាច់ជាមូលដ្ឋានសម្រាប់អ្នកមានប្រាក់ចំណូលទាបដូចជា កំណត់ទំហំដី និង/ឬទំហំផ្ទះតូចល្មម ចៀសវាងការដោះស្រាយដែលអាចជាការលើកទឹកចិត្ត និងទាក់ទាញឱ្យមានសំណង់បណ្ដោះអាសន្នថ្មី លើដីកាន់កាប់ដោយខុសច្បាប់ថែមទៀត ។

ខ-ត្រូវរៀបចំជាមុននូវហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈចាំបាច់ៗ ទាំងសម្រាប់ទីតាំងអភិវឌ្ឍន៍នៅនឹងកន្លែង ទាំងទីតាំងថ្មី មានជាអាទិ៍ផ្លូវថ្នល់ ទឹកប្រើប្រាស់ លូបង្ហូរទឹក និងសេវាចាំបាច់ឯទៀតៗដូចជាសេវាអប់រំ និងសុខភាព និងត្រូវជួយគិតគូរដល់ប្រភពផ្ដល់ការងារធ្វើផងដែរ ។

**៧_ការចូលរួមរបស់ភាគីពាក់ព័ន្ធក្នុងការអភិវឌ្ឍ**

ដើម្បីអនុវត្តដំណោះស្រាយណាមួយដែលបានទទួលការព្រមព្រៀងពីភាគីពាក់ព័ន្ធ ក្រុមការងារជីវជ្ជថ្នាក់ក្រុង-ស្រុក-ខណ្ឌត្រូវពិនិត្យការរៀបចំទីតាំង មុននឹងឈានដល់ដំណាក់កាលអនុវត្តផែនការសកម្មភាពជាក់ស្ដែង ។ គ្រប់ភាគីពាក់ព័ន្ធត្រូវបន្តជួយប្រជាពលរដ្ឋ ទាំងករណីរើលំនៅឋានទៅទីកន្លែងថ្មី ទាំងករណីអភិវឌ្ឍនៅទីកន្លែងឱ្យបង្កើតជាសហគមន៍ ឬបន្តដំណើរការសហគមន៍ដែលបានរៀបចំរួចហើយ ដោយជួយរៀបចំឱ្យមានបទបញ្ជាផ្ទៃក្នុង និងការងារសន្សំប្រាក់របស់សហគមន៍ ដោយផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត ។ ក្នុងបទបញ្ជាផ្ទៃក្នុងនោះ គប្បីកំណត់អំពីរចនាសម្ព័ន្ធនៃការគ្រប់គ្រងសិទ្ធិ និងកាតព្វកិច្ចរបស់សមាជិក និងនីតិវិធីក្នុងការសម្រេចបញ្ហាសំខាន់ៗ ។

អាជ្ញាធរមូលដ្ឋានរួមជាមួយភាគីពាក់ព័ន្ធ ដូចជាដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិលអាចរួមចំណែកបំពេញការងារក្នុងដំណោះស្រាយ ទាំងស្មារតី ទាំងសម្ភារៈ ទាំងហិរញ្ញវត្ថុ ចាប់តាំងពីពេលផ្ដួចផ្ដើមស្វែងរកលទ្ធភាពកសាងកែលំអហេដ្ឋារចនាសម្ព័ន្ធ ផ្ដល់សេវាសាធារណៈចាំបាច់ៗជាមូលដ្ឋាន និងបង្កលក្ខណសម្បត្តិបង្កើតការងារធ្វើជូនប្រជាពលរដ្ឋទាំងនោះ ។

*វាយឡើងវិញ*

បន្ថែមលើវិធានការទាំង៧ដែលបានកំណត់ខាងលើ រាជរដ្ឋាភិបាលដាក់បញ្ជាយ៉ាងម៉ឺងម៉ាត់តាមរយៈសារាចរនេះដល់អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធទទួលខុសត្រូវទាំងស្រុង ក្នុងការទប់ស្កាត់កុំឱ្យមានសំណង់បណ្តោះអាសន្នថ្មីលើដីដែលកាន់កាប់ដោយខុសច្បាប់កើតឡើងជាថ្មីទៀត នៅក្នុងរាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ ឃុំ-សង្កាត់។

ទទួលបានសារាចរនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្ត ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន**

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័ន

-គ្រប់សាលារាជធានី-ខេត្ត

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

*វាយឡើងវិញ*

ព្រះរាជាណាចក្រកម្ពុជា

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាតិ សាសនា ព្រះមហាក្សត្រ

លេខ៤៩៣សហវ/ប្រក

*រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០*

# ប្រកាស
# ស្តីពីការប្រមូលពន្ធលើអចលនទ្រព្យ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៣០/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ

- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើអចលនទ្រព្យ

**សម្រេច**

**ប្រការ១ គោលបំណង**

ផ្អែកតាមផ្នែកទី២ ស្តីពីពន្ធលើអចលនទ្រព្យនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ អចលនទ្រព្យដែលឋិតនៅក្នុងភូមិសាស្ត្ររដ្ឋបាលរាជធានី និងខេត្តនៃព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់ពន្ធលើអចលនទ្រព្យ។ ពន្ធនេះត្រូវប្រមូលចំពោះអចលនទ្រព្យដែលមានតម្លៃលើសពី១០០.០០០.០០០រៀល (មួយរយលានរៀល)។

**ប្រការ២ គោលដៅ**

ពន្ធលើអចលនទ្រព្យនេះត្រូវប្រមូលដោយរដ្ឋបាលសារពើពន្ធ និងបង់ចូលក្នុងគណនីទោលនៃរតនាគារជាតិ ដើម្បីជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ (រាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ ឃុំ-សង្កាត់) សម្រាប់ការអភិវឌ្ឍមូលដ្ឋាន។

**ប្រការ៣ និយមន័យ**

១-ពាក្យ "អចលនទ្រព្យ" សំដៅដល់ដី ផ្ទះ អគារ និងសំណង់ផ្សេងៗដែលសង់ភ្ជាប់នឹងដីនោះ។

ក-ដី សំដៅដល់ដីគ្មានសំណង់ និង/ឬដីមានសំណង់។

ខ-ផ្ទះ សំដៅដល់ទីកន្លែងសម្រាប់ស្នាក់នៅ។

គ-អគារ និងសំណង់ផ្សេងៗ សំដៅដល់អគារ និងសំណង់ផ្សេងៗដែលសង់ភ្ជាប់ទៅនឹងដី ទោះមាន ឬគ្មានជញ្ជាំងឬដំបូលក៏ដោយ មានជាអាទិ៍ សណ្ឋាគារ អផាតមែន ខុនដូ ការិយាល័យ រោងចក្រ ឃ្លាំង ផ្សារទំនើប សំណង់អគារឧស្សាហកម្ម ផ្លូវ ស្ពាន ប្រព័ន្ធផលិតទឹកស្អាតឬផលិតអគ្គិសនី ព្រលានយន្តហោះ កំពង់ផែ ចំណតរថយន្ត។

២-ពាក្យ "<u>អ្នកជាប់ពន្ធ</u>" សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលជាកម្មសិទ្ធិករ ឬអ្នកកាន់កាប់ ឬអ្នកទទួលប្រយោជន៍ចុងក្រោយ លើអចលនទ្រព្យទាំងមូល ឬប្រភេទអចលនទ្រព្យណាមួយ ដូចមានចែងក្នុងកថាខណ្ឌ១នៃប្រការនេះ។

ក-<u>កម្មសិទ្ធិករ</u> សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលគ្មានប័ណ្ណសម្គាល់សិទ្ធិ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដែលចេញដោយរដ្ឋបាលសុរិយោដី។

ខ-<u>អ្នកកាន់កាប់</u> សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលគ្មានប័ណ្ណសម្គាល់សិទ្ធិ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដែលចេញដោយរដ្ឋបាលសុរិយោដី។

គ-<u>អ្នកទទួលប្រយោជន៍ចុងក្រោយ</u> សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលទទួលនូវសិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យផល សិទ្ធិចាត់ចែង និងសិទ្ធិអាស្រ័យផលនៅចុងក្រោយ លើអចលនទ្រព្យ។

៣-ពាក្យ "<u>ដីធ្លីកសិកម្ម</u>" សំដៅដល់ដីធ្លីកសិកម្មដែលកំពុងបង្កបង្កើនផលកសិកម្មមានជាអាទិ៍ ដីស្រែ ដីចម្ការ ដីដំណាំកសិ-ឧស្សាហកម្ម ដីកសិដ្ឋានចិញ្ចឹមសត្វ វារីវប្បកម្ម ដីស្រែអំបិល។

**ប្រការ៤ ការលើកលែងពន្ធលើអចលនទ្រព្យ**

អចលនទ្រព្យដែលត្រូវបានលើកលែងពន្ធ មានដូចខាងក្រោម៖

១-អចលនទ្រព្យដែលជាដីធ្លីកសិកម្ម។ ក្នុងករណីចំណែកណាមួយនៃដីធ្លីកសិកម្មត្រូវបានយកមកសាងសង់ផ្ទះ អគារ ឬសំណង់ផ្សេងៗ ដែលមិនបម្រើផ្ទាល់និងជាអចិន្ត្រៃយ៍ដល់សកម្មភាពកសិកម្ម ចំណែកដីនោះមិនត្រូវបានលើកលែងពន្ធនេះទេ។

២-អចលនទ្រព្យដែលជាកម្មសិទ្ធិរបស់រាជរដ្ឋាភិបាល ឬស្ថាប័នរាជរដ្ឋាភិបាល។ ក្នុងករណីអចលនទ្រព្យដែលបានកត់ត្រាជាទ្រព្យសកម្មរបស់សហគ្រាសសាធារណៈ ឬក្រុមហ៊ុនចម្រុះរដ្ឋ អចលនទ្រព្យនោះមិនត្រូវបានលើកលែងពន្ធនេះទេ។

៣-អចលនទ្រព្យដែលជាកម្មសិទ្ធិរបស់សហគមន៍ ឬបុគ្គលណាមួយដែល៖

-ត្រូវបានរៀបចំឡើង និងដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា និងសប្បុរសធម៌

-គ្មានចំណែកណាមួយនៃអចលនទ្រព្យ ឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាប្រយោជន៍ឯកជន។

ការលើកលែងពន្ធមិនរាប់បញ្ចូលទេ ចំពោះ៖

-អចលនទ្រព្យដែលត្រូវបានជូល ឬផ្តល់ឱ្យបណ្តោះអាសន្ន សម្រាប់គោលដៅសុទ្ធសាធខាងសាសនា និងសប្បុរសធម៌។

-អចលនទ្រព្យជាកម្មសិទ្ធិរបស់អង្គការសាសនា ឬអង្គការសប្បុរសធម៌ដែលបានជួល ឬផ្តល់ជាបណ្តោះអាសន្នឱ្យទៅសហគមន៍ ឬបុគ្គលណាមួយដែលប្រើប្រាស់អចលនទ្រព្យនោះក្រៅពីគោលដៅសាសនា និងសប្បុរសធម៌។

៤-អចលនទ្រព្យជាកម្មសិទ្ធិរបស់៖

ក-បេសកកម្មការទូត ឬកុងស៊ុលបរទេស

ខ-អង្គកាអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានាដែលទទួលស្គាល់ដោយរាជរដ្ឋាភិបាល។

៥-អចលនទ្រព្យដែលជាហេដ្ឋារចនាសម្ព័ន្ធ រួមមានផ្លូវ ស្ពាន ប្រព័ន្ធផលិតទឹកស្អាត ឬផលិតអគ្គិសនី ព្រលានយន្តហោះ កំពង់ផែ ស្ថានីយអយស្ម័យយាន រួមបញ្ចូលទាំងអគារ និងការិយាល័យដែលបម្រើផ្ទាល់ដល់សកម្មភាពនៃហេដ្ឋារចនាសម្ព័ន្ធទាំងនេះ។

៦-ផ្ទះ អគារ និងសំណង់ផ្សេងៗដែលសាងសង់លើដីធ្លីកសិកម្ម ដែលបម្រើផ្ទាល់និងជាអចិន្ត្រៃយ៍ដល់សកម្មភាពកសិកម្ម។

៧-អចលនទ្រព្យដែលទទួលរងនូវការខូចខាតធ្ងន់ធ្ងរដោយករណីប្រធានសក្តិដែលជាបាតុភូត ឬជាព្រឹត្តិការណ៍កើតឡើងដោយមិនដឹងជាមុន មិនអាចប៉ាន់ស្មានជាមុនបាន និងមិនអាចជំនះបានដូចជាគ្រោះធម្មជាតិ (ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយដី) សង្គ្រាម កុប្បកម្ម អគ្គីភ័យ ឬគ្រោះមហន្តរាយជាយថាហេតុ។

៨-ផ្ទះ អគារ និងសំណង់ដែលកំពុងត្រូវបានសាងសង់តិចជាង៨០% (ប៉ែតសិបភាគរយ) និងមិនទាន់បានប្រើប្រាស់។

៩-អចលនទ្រព្យដែលឋិតក្នុងតំបន់សេដ្ឋកិច្ចពិសេស ដែលបម្រើផ្ទាល់ដល់សកម្មភាពផលិតកម្ម។

**ប្រការ៥ អត្រាពន្ធ**

ពន្ធលើអចលនទ្រព្យត្រូវប្រមូលប្រចាំឆ្នាំតាមអត្រា០,១% (សូន្យក្បៀសមួយភាគរយ) លើមូលដ្ឋានគិតពន្ធ។

**ប្រការ៦ មូលដ្ឋានគិតពន្ធ**

មូលដ្ឋានគិតពន្ធលើអចលនទ្រព្យ គឺជាតម្លៃអចលនទ្រព្យដែលត្រូវអនុញ្ញាតឱ្យកាត់បន្ថយទឹកប្រាក់ចំនួន១០០.០០០.០០០រៀល (មួយរយលានរៀល)។

**ប្រការ៧ តម្លៃអចលនទ្រព្យ**

តម្លៃអចលនទ្រព្យត្រូវកំណត់ដោយគណៈកម្មការវាយតម្លៃអចលនទ្រព្យ ដោយយោងតាមតម្លៃទីផ្សារ។

**ប្រការ៨ ការគណនាប្រាក់ពន្ធ**

ប្រាក់ពន្ធត្រូវគណនាតាមរូបមន្ត ដូចខាងក្រោម៖

មូលដ្ឋានគិតពន្ធ = តម្លៃអចលនទ្រព្យ - ១០០.០០០.០០០រៀល

ប្រាក់ពន្ធ = មូលដ្ឋានគិតពន្ធ × ០,១%

ឧទាហរណ៍៖ អចលនទ្រព្យមួយដែលមានដីទំហំ ៧ម × ២៥ម និងមានផ្ទះល្វែងចំនួន៣ជាន់ (E0, E1, E2) ដែលមានទំហំ ៤ម × ២០ម និងមានតម្លៃទីផ្សារកំណត់ដោយគណៈកម្មការវាយតម្លៃអចលនទ្រព្យ ក្នុងមួយម៉ែត្រក្រឡា ដូចខាងក្រោម៖

| | |
|---|---|
| តម្លៃដី | = ១.០០០.០០០រៀល/ម៉ែត្រក្រឡា |
| តម្លៃផ្ទះជាន់ផ្ទាល់ដី (E0) | = ៤០០.០០០រៀល/ម៉ែត្រក្រឡា |
| តម្លៃផ្ទះជាន់ទី១ (E1) | = ៣០០.០០០រៀល/ម៉ែត្រក្រឡា |
| តម្លៃផ្ទះជាន់ទី២ (E2) | = ២០០.០០០រៀល/ម៉ែត្រក្រឡា |

ការគណនាតម្លៃអចលនទ្រព្យ៖

| | | |
|---|---|---|
| តម្លៃដី | = ៧ម × ២៥ម × ១.000.000រៀល = | ១៧៥.000.000រៀល |
| តម្លៃផ្ទះជាន់ផ្ទាល់ដី (E0) | = ៤ម × ២០ម × ៤00.000រៀល = | ៣២.000.000រៀល |
| តម្លៃផ្ទះជាន់ទី១ (E1) | = ៤ម × ២០ម × ៣00.000រៀល = | ២៤.000.000រៀល |
| តម្លៃផ្ទះជាន់ទី២ (E2) | = ៤ម × ២០ម × ២00.000រៀល = | ១៦.000.000រៀល |
| តម្លៃអចលនទ្រព្យសរុប | = | ២៤៧.000.000រៀល |
| ការគណនាប្រាក់ពន្ធ | = ( តម្លៃអចលនទ្រព្យ - ១00.000.000រៀល) × 0,១% | |
| | (២៤៧.000.000រៀល - ១00.000.000រៀល) × 0,១% | |
| ដូចនេះប្រាក់ពន្ធត្រូវបង់ | = ១៤៧.000រៀល | |

**ប្រការ៩ ការចុះបញ្ជី**

អ្នកជាប់ពន្ធដែលមានអចលនទ្រព្យមានតម្លៃ១00.000.000រៀល ឬតិចជាងមិនត្រូវមានកាតព្វកិច្ចចុះបញ្ជីឡើយ ។

អ្នកជាប់ពន្ធដែលមានអចលនទ្រព្យមានតម្លៃលើសពី១00.000.000រៀល ត្រូវមានកាតព្វកិច្ចចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ក្នុងភូមិសាស្ត្រដែលអចលនទ្រព្យនោះឋិតនៅ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣0 ខែកញ្ញា នៃឆ្នាំជាប់ពន្ធ ។

ការចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ អ្នកជាប់ពន្ធត្រូវបំពេញទម្រង់ចុះបញ្ជីអចលនទ្រព្យដែលបានផ្ដល់ដោយឥតគិតថ្លៃ និងភ្ជាប់មកជាមួយនូវឯកសារថតចម្លងដូចខាងក្រោម៖

១-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្រកំណើត ឬលិខិតឆ្លងដែនសម្រាប់ជនបរទេស

២-សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅ

៣-ប័ណ្ណសម្គាល់សិទ្ធិ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលចេញដោយរដ្ឋបាលសុរិយោដី ឬឯកសារពាក់ព័ន្ធនឹងការកាន់កាប់អចលនទ្រព្យដែលបញ្ជាក់ដោយអាជ្ញាធរឃុំ-សង្កាត់ឡើងទៅ ។

នៅពេលបានចុះបញ្ជី អ្នកជាប់ពន្ធត្រូវបានទទួលលិខិតបញ្ជាក់ការចុះបញ្ជីពន្ធលើអចលនទ្រព្យដែលមានចុះលេខអត្តសញ្ញាណកម្មពន្ធលើអចលនទ្រព្យសម្រាប់អចលនទ្រព្យនីមួយៗ ដែលចេញ

ដោយរដ្ឋបាលសារពើពន្ធ។ អ្នកជាប់ពន្ធត្រូវប្រើប្រាស់លេខអត្តសញ្ញាណកម្មនេះ លើឯកសារទាក់ទិនទៅនឹងពន្ធលើអចលនទ្រព្យ។ អចលនទ្រព្យដែលបានចុះបញ្ជីរួចហើយ មិនត្រូវបានចុះបញ្ជីឡើងវិញនៅឆ្នាំបន្តបន្ទាប់ទេ។

ក្នុងករណីអចលនទ្រព្យត្រូវបំបែកដើម្បីលក់ ឬផ្ទេរ ឬផ្តល់ជាអំណោយ អ្នកជាប់ពន្ធត្រូវផ្តល់ព័ត៌មានជូនរដ្ឋបាលសារពើពន្ធ ដើម្បីរៀបចំលេខអត្តសញ្ញាណកម្មពន្ធលើអចលនទ្រព្យជាថ្មី (ឧទាហរណ៍ អ្នកជាប់ពន្ធមានដីមួយកន្លែង ហើយត្រូវបានពុះជាឡូតិ៍ ដើម្បីលក់ ផ្ទេរ ឬផ្តល់ជាអំណោយ)។

អ្នកជាប់ពន្ធត្រូវផ្តល់ព័ត៌មានជូនរដ្ឋបាលសារពើពន្ធទៅតាមទម្រង់ដែលបានកំណត់ដោយរដ្ឋ-បាលសារពើពន្ធ ក្នុងករណីដូចខាងក្រោម៖

ក-មូលដ្ឋានគិតពន្ធត្រូវបានប្រែប្រួលដូចជា៖

-ដីត្រូវបានយកទៅសាងសង់ផ្ទះ អគារ និង/ឬសំណង់ផ្សេងៗ

-ផ្ទះ អគារ និងសំណង់ផ្សេងៗត្រូវបានសង់បន្ថែម ឬបន្ថយ ឬរំលាយចោល

ខ-អចលនទ្រព្យត្រូវបានផ្លាស់ប្តូរកម្មសិទ្ធិករ អ្នកកាន់កាប់ ឬអ្នកទទួលប្រយោជន៍ចុងក្រោយ។

**ប្រការ១០ ការដាក់លិខិតប្រកាស និងការបង់ប្រាក់ពន្ធ**

១-អ្នកជាប់ពន្ធដែលមានអចលនទ្រព្យមានតម្លៃ១០០.០០០.០០០រៀល ឬតិចជាងមិនមានកាតព្វកិច្ចដាក់លិខិតប្រកាសពន្ធឡើយ។

២-អ្នកជាប់ពន្ធដែលមានអចលនទ្រព្យមានតម្លៃលើសពី១០០.០០០.០០០រៀល ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធលើអចលនទ្រព្យ ជារៀងរាល់ឆ្នាំ ជូនរដ្ឋបាលសារពើពន្ធក្នុងភូមិសាស្ត្រដែលអចលនទ្រព្យនោះឋិតនៅ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣០ ខែកញ្ញា នៃឆ្នាំជាប់ពន្ធនីមួយៗ។ ចំពោះអ្នកជាប់ពន្ធដែលមានអចលនទ្រព្យច្រើន អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធលើអចលនទ្រព្យដាច់ដោយឡែកៗពីគ្នា។

៣-លិខិតប្រកាសពន្ធលើអចលនទ្រព្យ ត្រូវធ្វើតាមទម្រង់កំណត់ដោយរដ្ឋបាលសារពើពន្ធ ចំនួន២ច្បាប់ ដែលមួយច្បាប់សម្រាប់រក្សាទុកនៅរដ្ឋបាលសារពើពន្ធ និងមួយច្បាប់ទៀតសម្រាប់

អ្នកជាប់ពន្ធ ។ អ្នកជាប់ពន្ធត្រូវធ្វើការគណនាប្រាក់ពន្ធដោយខ្លួនឯង ដោយផ្អែកលើតម្លៃអចលនទ្រព្យដែលបានកំណត់ដោយគណៈកម្មការវាយតម្លៃអចលនទ្រព្យ ។

៤-ប្រសិនបើអចលនទ្រព្យណាមួយត្រូវបានលក់ ឬផ្ទេរ ឬផ្តល់ជាអំណោយ ដោយកម្មសិទ្ធិករ ឬអ្នកកាន់កាប់ខាងដើមមិនបានបង់ពន្ធលើអចលនទ្រព្យនោះ រាល់បំណុលពន្ធ និងកាតព្វកិច្ចចំពោះពន្ធលើអចលនទ្រព្យ ជាបន្ទុករបស់បុគ្គលដែលជាកម្មសិទ្ធិករ ឬអ្នកកាន់កាប់ ឬអ្នកទទួលប្រយោជន៍ចុងក្រោយ ។

៥-អ្នកជាប់ពន្ធ អាចបង់ប្រាក់ពន្ធដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធក្នុងភូមិសាស្រ្តដែលអចលនទ្រព្យនោះឋិតនៅ ឬបង់តាមប្រព័ន្ធធនាគារ ។

**ប្រការ១១ តំណាងអ្នកជាប់ពន្ធ**

អ្នកជាប់ពន្ធអាចធ្វើការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរទៅឱ្យបុគ្គលម្នាក់ទៀត ឱ្យធ្វើសកម្ម-ភាពជំនួសមុខខ្លួនក្នុងបញ្ហាពន្ធលើអចលនទ្រព្យ ដោយរួមមានសិទ្ធិ និងកាតព្វកិច្ចដូចមានចែងក្នុងប្រការ៩ និងប្រការ១០នៃប្រកាសនេះ ។

អ្នកជាប់ពន្ធត្រូវមានកាតព្វកិច្ចទទួលខុសត្រូវដោយផ្ទាល់ចំពោះសកម្មភាពរបស់បុគ្គល ដែលជាតំណាងតាមផ្លូវច្បាប់របស់ខ្លួន ឬបុគ្គលដែលបានទទួលការផ្ទេរសិទ្ធិពីខ្លួន រហូតដល់ពេលណាដែលរដ្ឋបាលសារពើពន្ធបានទទួលសេចក្តីបញ្ជាក់ជាលាយលក្ខណ៍អក្សរពីអ្នកជាប់ពន្ធ ស្តីពីការលុបចោលនូវការផ្ទេរសិទ្ធិនោះ ។

**ប្រការ១២ សិទ្ធិស្របច្បាប់នៃអចលនទ្រព្យ**

ការចុះបញ្ជីដូចមានចែងក្នុងប្រការ៩ និងការដាក់លិខិតប្រកាសនិងការបង់ប្រាក់ពន្ធដូចមានចែងក្នុងប្រការ១០នៃប្រកាសនេះ មិនមែនជាល័ក្ខខ័ណ្ឌបញ្ជាក់កម្មសិទ្ធិស្របច្បាប់របស់អចលនទ្រព្យទេ ។

**ប្រការ១៣ សិទ្ធិនៃការត្រួតពិនិត្យ**

ជារៀងរាល់ឆ្នាំ ចាប់ពីថ្ងៃទី០១ ខែតុលា នៃឆ្នាំជាប់ពន្ធ រដ្ឋបាលសារពើពន្ធមានសិទ្ធិត្រួតពិនិត្យលើមូលដ្ឋានគិតពន្ធ និងការបង់ពន្ធរបស់អ្នកជាប់ពន្ធ ។

ការត្រួតពិនិត្យនេះផ្តោតសំខាន់ទៅលើអ្នកជាប់ពន្ធដែល៖

-មានអចលនទ្រព្យមានតម្លៃលើសពី១០០.០០០.០០០រៀល មិនបានមកចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ

-មិនបានបំពេញកាតព្វកិច្ចដាក់លិខិតប្រកាសពន្ធ និងបង់ពន្ធ

-បង់ពន្ធខ្វះដោយប្រកាសមិនអស់នូវអចលនទ្រព្យដែលខ្លួនមាន ឬប្រកាសប្រាក់ទាបជាងប្រាក់ពន្ធត្រូវបង់

-បង់ពន្ធយឺតយ៉ាវមិនតាមកាលកំណត់។

**ប្រការ១៤ ទោសទណ្ឌ**

ការមិនចុះបញ្ជី ការបង់ពន្ធខ្វះ ការបង់ពន្ធយឺត ឬការមិនបានដាក់លិខិតប្រកាសពន្ធ ត្រូវរងទោសទណ្ឌតាមបទប្បញ្ញត្តិស្តីពីសារពើពន្ធ។

**ប្រការ១៥ ទោសប្បញ្ញត្តិ**

សម្រាប់ការចាប់ផ្តើមអនុវត្តពន្ធលើអចលនទ្រព្យ ចាប់ពីប្រកាសនេះចូលជាធរមានភ្លាម គណៈកម្មការវាយតម្លៃអចលនទ្រព្យ អនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ រដ្ឋបាលសារពើពន្ធ និងអង្គភាពដែលមានការពាក់ព័ន្ធត្រូវអនុវត្តគោលការណ៍ និងការងារចម្បងៗមួយចំនួន ដូចខាងក្រោមនេះ៖

១-ពន្ធលើអចលនទ្រព្យនេះមានវិសាលភាពអនុវត្តទូទាំងប្រទេស។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងកំណត់ការអនុវត្តពន្ធនេះ ជាដំណាក់ៗតាមរាជធានី-ខេត្ត។

២-ពន្ធលើអចលនទ្រព្យត្រូវបានអនុវត្តក្នុងដំណាក់កាលដំបូង ចំពោះតែអចលនទ្រព្យដែលឋិតក្នុងភូមិសាស្ត្ររដ្ឋបាលរាជធានី-ខេត្ត។

៣-គណៈកម្មការវាយតម្លៃអចលនទ្រព្យត្រូវរៀបចំកំណត់តម្លៃអចលនទ្រព្យតាមប្រភេទ និងតំបន់ក្នុងភូមិសាស្ត្ររដ្ឋបាលរាជធានី-ខេត្តឱ្យបានចប់សព្វគ្រប់ នៅមុនថ្ងៃទី៣១ ខែតុលា ឆ្នាំ ២០១០។

៤-អនុគណៈកម្មការវាយតម្លៃអចលនទ្រព្យរាជធានី-ខេត្តត្រូវ៖

ក-បង្កើតក្រុមការងារអចលនទ្រព្យឃុំ-សង្កាត់ជាជំនួយការក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យបានមុនថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១០។

ខ-រៀបចំបញ្ជីសរុបអចលនទ្រព្យ និងរៀបចំតម្លៃអចលនទ្រព្យតាមប្រភេទ និងតាមតំបន់ និងបញ្ជូនមកគណៈកម្មការវាយតម្លៃអចលនទ្រព្យឱ្យបានមុនថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១០។

គ-ផ្សព្វផ្សាយជាសាធារណៈ ណែនាំ អប់រំដល់អ្នកជាប់ពន្ធអំពីតម្លៃអចលនទ្រព្យ និងបទប្បញ្ញត្តិនានាស្តីពីការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យ។

៥-ក្រុមការងារអចលនទ្រព្យឃុំ-សង្កាត់ត្រូវ៖

ក-សហការជាមួយរដ្ឋបាលសារពើពន្ធ ដើម្បីរៀបចំបញ្ជីលំអិតអចលនទ្រព្យក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ហើយបញ្ជូនមកអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យរាជធានី-ខេត្ត។

ខ-ចូលរួមកំណត់អចលនទ្រព្យតាមតំបន់ ប្រភេទ និងទីតាំងក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតាមសេចក្តីណែនាំរបស់គណៈកម្មការវាយតម្លៃអចលនទ្រព្យ។

គ-ចូលរួមផ្សព្វផ្សាយ និងបិទប្រកាសផ្សាយតម្លៃអចលនទ្រព្យនៅតាមមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ឃ-ជួយសហការផ្តល់ស្ថិតិ និងទិន្នន័យសម្រាប់ការចុះបញ្ជីអចលនទ្រព្យដល់រដ្ឋបាលសារពើពន្ធ។

៦-រដ្ឋបាលសារពើពន្ធត្រូវ៖

ក-ប្រមូលទិន្នន័យអំពីអចលនទ្រព្យពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរឃុំ-សង្កាត់ និងចុះជំរឿនអចលនទ្រព្យនៅតាមមូលដ្ឋានឱ្យបានចប់សព្វគ្រប់ នៅមុនថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១០។

ខ-រៀបចំនីតិវិធី បែបបទ និងទម្រង់សម្រាប់ការចុះបញ្ជី ការដាក់លិខិតប្រកាសពន្ធ និងការបង់ពន្ធនៅតាមភូមិសាស្ត្ររដ្ឋបាលដូចមានចែងក្នុងកថាខណ្ឌ២នៃប្រការនេះ ឱ្យបានចប់សព្វគ្រប់នៅមុនថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០។

៧-គណៈកម្មការវាយតម្លៃអចលនទ្រព្យ រដ្ឋបាលសារពើពន្ធ និងស្ថាប័នពាក់ព័ន្ធត្រូវរៀបចំ និងធ្វើការផ្សព្វផ្សាយតម្លៃអចលនទ្រព្យ និងបទប្បញ្ញត្តិនានាស្តីពីការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យឱ្យបានចប់សព្វគ្រប់នៅមុនថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១១ ដើម្បីឱ្យអ្នកជាប់ពន្ធមកចុះបញ្ជី ដាក់លិខិតប្រកាសពន្ធ និងបង់ពន្ធ ស្របតាមការកំណត់ក្នុងប្រការ១០នៃប្រកាសនេះ។

*វាយឡើងវិញ*

**ប្រការ១៦ ការអនុវត្តប្រកាស**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ហត្ថលេខា និងត្រា**
**គាត ឈន់**

ចម្លងជូន
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ
ហ៊ុន សែន នាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន
-គ្រប់សាលារាជធានី-ខេត្ត
"ដើម្បីជូនជ្រាបជាព័ត៌មាន"
-គ្រប់អង្គភាពក្រោមឱវាទក្រសហវ "ដើម្បីមុខការ"
-ឯកសារ-កាលប្បវត្តិ